# ព្រះត្រៃបិដក

## ប្រែរួមនឹងព្រះអដ្ឋកថា

## ភាគ៤១

បាលីប្រែ ៥៦

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

និង

# បរមត្ថទីបនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

## ខុទ្ទកនិកាយ ថេរគាថា

## បញ្ចមភាគ

## ៤១

## បាលីប្រែ ៥៦



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៤១

# សុត្តន្តបិដក

# ខុទ្ទកនិកាយ ថេរគាថា

## និទានកថា

*សូមនមស្ការ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ ។*

*[ ១ ] អ្នកទាំងឡាយ ចូរស្តាប់នូវគាថាទាំងឡាយ ប្រកបដោយប្រយោជន៍ របស់ព្រះថេរៈទាំងឡាយ អ្នកមានចិត្តចម្រើនហើយ កាលបន្លឺឡើងដូចជាសីហៈ ជាសត្វមានចង្កូមដែលបន្លឺទៀបច្រកនៃភ្នំ ព្រះថេរៈទាំងឡាយ តាមនាម តាមគោត្ត តាមវិហារធម៌ តាមអធ្យាស្រ័យ ប្រកបដោយប្រាជ្ញា ជាបុគ្គលមិនខ្ជិលច្រអូស ចម្រើនវិបស្សនាក្នុងទីនោះៗ បានពាល់ត្រូវអច្ចុតបទ គឺ ព្រះនិព្វាន ពិចារណានូវគុណសម្បត្តិដែលលោកបានធ្វើស្រេចហើយ បានសម្តែងហើយនូវសេចក្តីដូចតទៅនេះ ។*

# បរមត្ថទីបនី អដ្ឋកថា

# ថេរគាថា

# គន្ថារម្ភកថា

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

## កថាផ្តើមបករណ៍

ខ្ញុំសូមថ្វាយបង្គំព្រះលោកនាថ ទ្រង់មានព្រះទ័យ ពេញដោយមហាករុណាទិគុណ ទ្រង់ដល់នូវត្រើយនៃសាគរ គឺញេយ្យធម៌ហើយ ទ្រង់សម្តែងធម៌ដ៏ល្អិតជ្រាលជ្រៅ មានន័យដ៏វិចិត្រ ។

ខ្ញុំសូមថ្វាយបង្គំព្រះធម៌ដ៏ឧត្តម ដែលសម្តេចព្រះសម្មាសម្ពុទ្ធ ទ្រង់បូជាហើយ ដែលជាគ្រឿងនាំបុគ្គលសម្បូរដោយវិជ្ជានិងចរណៈចេញចាកលោក ។

ខ្ញុំសូមថ្វាយបង្គំព្រះអរិយសង្ឃ ដែលសម្បូរដោយគុណ មានសីលជាដើម តាំងមាំក្នុងមគ្គ និងផល ជាស្រែបុណ្យដ៏ប្រសើរ ។

ដោយតេជានុភាពនៃបុណ្យ ដែលកើតអំពីការថ្វាយបង្គំព្រះរតនត្រ័យដូចពណ៌នាមកនេះ ខ្ញុំសូមរួចចាកអន្តរាយក្នុងទីគ្រប់ស្ថានសព្វកាល ។ គាថាឯណាដែលប្រាសចាកអាមិស ដែលព្រះថេរៈទាំងឡាយ ជាអ្នកមានកិច្ចធ្វើស្រេចហើយ ជាតាទិបុគ្គល មានព្រះសុភូតិត្ថេរជាដើមនិងព្រះថេរីទាំងឡាយភាសិតហើយ គាថាទាំងឡាយឯណាដែលជ្រាលជ្រៅ ល្អិត ស្តាប់ហើយដោយវិធី មានឧទានជាដើម បដិសំយុត្តដោយសុញ្ញតធម៌ ប្រកាសធម៌របស់

ព្រះអរិយៈ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ដែលជាតាទិបុគ្គល ជាអ្នកស្វែងរកគុណធំ រួបរួមគាថាទាំងនោះទុកក្នុងគម្ពីរខុទ្ទកនិកាយ ដោយឈ្មោះឈ្មោះថា **ថេរគាថា** និង **ថេរីគាថា** ។ សេចក្តីពិត ការរចនាអដ្ឋកថា ពណ៌នាសេចក្តីតាមលំដាប់បទ មានអត្ថជ្រាលជ្រៅ ដែលខ្ញុំធ្វើ មិនមែនជារបស់ដែលធ្វើបានងាយ ព្រោះជាអត្ថដែលគប្បីឈមចុះបានដោយបញ្ញាដ៏ជ្រាលជ្រៅ ។

តែព្រោះអដ្ឋកថា ជួយទ្រទ្រង់សាសនារបស់ព្រះសាស្តាទុកបាន ទាំងវិនិច្ឆ័យរបស់បណ្តាបុព្វាចារ្យ ដែលប្រៀបដូចរាជសីហ៍ ក៏នឹងតាំងនៅផងដូច្នោះ ទើបខ្ញុំសូមចងអដ្ឋកថាថេរគាថា និងថេរីគាថា ពេញកម្លាំងសមត្ថភាពដោយទាញយកវិនិច្ឆ័យរបស់បណ្តាបុព្វាចារ្យនោះជាគោល កាន់យកនិកាយ ៥ ជាទីតាំង អាស្រ័យន័យបោរាណដ្ឋកថា ត្រឹមតែជាពាក្យប្រាប់ ដែលបានអាស្រ័យគ្នាមក តែក៏បរិសុទ្ធត្រឹមត្រូវ មិនឃ្លៀងឃ្លាត ជាការវិនិច្ឆ័យដ៏ល្អិតជាលទ្ធិដែលមិនជំទាស់ក្នុងលទ្ធិរបស់បុព្វាចារ្យ គណៈមហាវិហារ ។

អត្ថរបស់គាថាទាំងឡាយឯណា វៀរអនុបុព្វីកថាចេញហើយ ក៏ដឹងបានលំបាក ខ្ញុំនឹងនាំអនុបុព្វីកថានោះ របស់គាថាទាំងនោះ មកសម្តែងឲ្យជាក់ច្បាស់ផង និងសម្តែងគោលវិនិច្ឆ័យផង ។

ហៃសាធុជនទាំងឡាយ សូមអ្នកទាំងឡាយតាំងចិត្តស្តាប់នូវការពណ៌នានៃអដ្ឋកថាថេរគាថា និងថេរីគាថានោះ ដែលនឹងបែកតទៅ ខ្ញុំបំណងឲ្យព្រះសទ្ធម្មតាំងនៅអស់កាលយូរទៅហោង ។

# អដ្ឋកថា គន្ថារម្ភកថា

ថេរគាថានិងថេរីគាថា គាថានីមួយៗ ដូចម្តេច និងមានប្រវត្តិដូចម្តេច សេចក្តីនេះលោកពោលទុកក្នុងគាថាទាំងឡាយហើយក៏ពិត តែថេរគាថាដែលព្រះសុភូតិត្ថេរជាដើម ពោលហើយក្នុងគាថានោះ ខ្ញុំនឹងពោលដដែលទៀត ដើម្បីធ្វើអត្ថឲ្យប្រាកដ ។ ព្រះថេរៈទាំងនោះពិចារណាឃើញសុខដែលកើតអំពីមគ្គផល តាមដែលខ្លួនសម្រេចហើយ បានពោលគាថាបទខ្លះទុក ដោយអំណាចនៃឧទាន បានពោលគាថាបទខ្លះទុក ដោយអំណាចនៃការពិចារណាធម៌ដែលជាគ្រឿងនៅ គឺសមាបត្តិរបស់ខ្លួន បានពោលគាថាបទខ្លះទុកដោយអំណាចនៃពាក្យសួរ បានពោលគាថាបទខ្លះទុកដោយអំណាចចង្អុលឲ្យឃើញនូវពាក្យប្រៀនប្រដៅដែលជានិយ្យានិកធម៌ ។ ក្នុងកាលធ្វើសង្គាយនាព្រះធម្មសង្គាហកាចារ្យទាំងឡាយ ចងគាថាទាំងអស់នោះទុកជាពួកតែមួយ ដោយឈ្មោះ ឈ្មោះថា **ថេរគាថា** ។ ឯថេរីគាថាលោកសម្តែងទុកចំពោះព្រះថេរីទាំងឡាយ ។

ក្នុងបណ្តាបិដកទាំង ៣ គឺ វិនយបិដក សុត្តន្តបិដក អភិធម្មបិដក ថេរ-ថេរីគាថានេះ ទាក់ទងនឹងសុត្តន្តបិដក ។ ក្នុងបណ្តានិកាយទាំង ៥ គឺទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរនិកាយ ខុទ្ទកនិកាយ គាថាទាំងនោះ ទាក់ទងក្នុងខុទ្ទកនិកាយ ។ ក្នុងបណ្តាសត្ថុសាសនៈ ៩ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម៌ វេទល្លៈ គាថាទាំងនោះសង្គ្រោះចូលក្នុងគាថា ។ បណ្តាធម្មក្ខន្ធ ៨៤០០០ ដែលព្រះអានន្ទត្ថេរ ជាធម្មភណ្ឌាគារិកប្តេជ្ញាទុក ( ក្នុងខុទ្ទកនិកាយថេរគាថា ) យ៉ាង

នេះថា

សាសនធម៌ ទាំងឡាយណា ដែលប្រព្រឹត្តទៅ (ក្នុងហឫទ័យ)
របស់ខ្ញុំ សាសនធម៌ទាំងឡាយនោះ មាន ៨ ហ្មឺន ៤ ពាន់
ធម្មក្ខន្ធ ខ្ញុំបានរៀនអំពីព្រះពុទ្ធ ៨ ហ្មឺន ២ ពាន់ធម្មក្ខន្ធ អំពី
ពួកភិក្ខុ ២ ពាន់ធម្មក្ខន្ធ ដូច្នេះ ។

ថេរគាថាសង្គ្រោះចូលក្នុងធម្មក្ខន្ធបន្តិចបន្តួច ។

ក្នុងបណ្ដាថេរគាថានិងថេរីគាថាទាំងនោះ នឹងពោលដោយថេរគាថាមុន ដោយនិបាត មាន ១៤ និបាត គឺផ្ដើមតាំងអំពីឯកនិបាត រហូតដល់ ចុទ្ទសនិបាត ដោយបន្ថែមឡើងមួយនិបាតមួយគាថា រួមជាមួយនឹងនិបាត ៧ ទៀត គឺសោឡសនិបាត វីសតិនិបាត តឹសនិបាត ចត្តាឡីសនិបាត បញ្ញាសនិបាត សដ្ឋិនិបាតនិងសត្តតិនិបាត រួមនិងនិបាត ១៤ ខាងដើម ត្រូវជា ២១ និបាត ដូច្នេះ ។

ឈ្មោះថា **និបាត** ព្រោះអត្ថថា តាំងទុក តម្រៀបទុក ។ ឈ្មោះថា **ឯកនិបាត** ព្រោះជាទីតាំង គឺតម្កល់ទុកនូវគាថាដែលជានិបាតមានគាថាមួយ សូម្បីនិបាតដ៏សេស ក៏គប្បីជ្រាបដោយន័យនេះ ។

បណ្ដានិបាតទាំងនោះ ឯកនិបាតមាន ១២ វគ្គ ក្នុងវគ្គនីមួយៗចែកចេញជា មួយវគ្គ ១០ អង្គ ទើបមានព្រះថេរៈ ១២០ អង្គ គាថាក៏មាន ១២០ គាថា ដូចគ្នា សមដូចលោកពោលទុកថា

ព្រះថេរៈ ១២០ អង្គ ជាអ្នកសម្រេចកិច្ចហើយ ជាអ្នកមិនមាន

អាសវៈ ដែលព្រះធម្មសង្គាហកាចារ្យ អ្នកស្វែងរកគុណដ៏ធំទាំងឡាយ ចងក្រងទុកល្អហើយ ក្នុងឯកនិបាត ដូច្នេះ ។

ក្នុងទុកនិបាត មានព្រះថេរៈ ៤៩ រូប មាន ៩៨ គាថា
ក្នុងតិកនិបាត មានព្រះថេរៈ ១៦ រូប មាន ៤៨ គាថា
ក្នុងចតុក្កនិបាត មានព្រះថេរៈ ១៣ រូប មាន ៥២ គាថា
ក្នុងបញ្ចកនិបាត មានព្រះថេរៈ ១២ រូប មាន ៦០ គាថា
ក្នុងឆក្កនិបាត មានព្រះថេរៈ ១៤ រូប មាន ៨៤ គាថា
ក្នុងសត្តកនិបាត មានព្រះថេរៈ ៥ រូប មាន ៣៥ គាថា
ក្នុងអដ្ឋកនិបាត មាន ព្រះថេរៈ ៣ រូប មាន ២៤ គាថា
ក្នុងនវកនិបាត មានព្រះថេរៈ ១ រូប មាន ៩ គាថា
ក្នុងទសកនិបាត មានព្រះថេរៈ ៧ រូប មាន ៧០ គាថា
ក្នុងឯកាទសកនិបាត មានព្រះថេរៈ ១ រូប មាន ១១ គាថា
ក្នុងទ្វាទសកនិបាត មានព្រះថេរៈ ២ រូប មាន ២៤ គាថា
ក្នុងតេរសកនិបាត មាន ព្រះថេរៈ ១ រូប មាន ១៣ គាថា
ក្នុងចុទ្ទសកនិបាត មានព្រះថេរៈ ២ រូប មាន ២៨ គាថា
ក្នុងបណ្ណរសកនិបាត មិនមាន
ក្នុងសោឡសកនិបាត មានព្រះថេរៈ ២ រូប មាន ៣២ គាថា
ក្នុងវីសតិនិបាត មានព្រះថេរៈ ១០ រូប មាន ២៤៥ គាថា
ក្នុងតឹសនិបាត មានព្រះថេរៈ ៣ រូប មាន ១០៥ គាថា

ក្នុងចត្តាឡីសនិបាត មានព្រះថេរៈ ១ រូប មាន ៤២ គាថា

ក្នុងបញ្ញាសនិបាត មានព្រះថេរៈ ១ រូប មាន ៥៥ គាថា

ក្នុងសដ្ឋិនិបាត មានព្រះថេរៈ ១ រូប មាន ៦៨ គាថា

ក្នុងសត្តតិនិបាតឬមហានិបាត មានព្រះថេរៈ ១ រូប មាន ៧១ គាថា

កាលបើសរុប ព្រះថេរៈមាន ២៦៤ រូប មាន ១៣៦០ គាថា ដូច្នេះឯង សូម្បីសេចក្តីនេះ ក៏មានវចនៈប្រព័ន្ធគាថាដែលលោកអះអាងទុកថា

ព្រះធម្មសង្គាហកាចារ្យប្រកាសទុកថា មាន ១៣៦០ គាថា

មានព្រះថេរៈ ២៦៤ រូប ដូច្នេះ ។

ឯថេរីគាថា មាន ៩ និបាត តាំងអំពីឯកនិបាត ដល់នវកនិបាត ដោយបន្ថែម ១ និបាត ១ គាថា រួមជាមួយនិបាត ៧ ទៀត គឺ ឯកាទសកនិបាត ទ្វាទសកនិបាត សោឡសកនិបាត វីសតិនិបាត តឹសនិបាត ចត្តាឡីសនិបាត មហានិបាត រួមជា ១៦ និបាត ។

ក្នុងថេរីគាថានោះ

ក្នុងឯកនិបាត មានព្រះថេរី ១៨ រូប មាន ១៨ គាថា

ក្នុងទុកនិបាត មានព្រះថេរី ១០ រូប មាន ២០ គាថា

ក្នុងតិកនិបាត មានព្រះថេរី ៨ រូប មាន ២៤ គាថា

ក្នុងចតុក្កនិបាត មានព្រះថេរី ១ រូប មាន ៤ គាថា

ក្នុងបញ្ចកនិបាត មានព្រះថេរី ១២ រូប មាន ៦០ គាថា

ក្នុងឆក្កនិបាត មានព្រះថេរី ៨ រូប មាន ៤៨ គាថា

ក្នុងសត្តកនិបាត មានព្រះថេរី ៣ រូប មាន ២១ គាថា

តែចាប់ពីអដ្ឋកនិបាតទៅ រហូតដល់សោឡសកនិបាត ក្នុង ១ និបាត មានព្រះថេរី ១ រូប ឯគាថាក៏មានស្មើនឹងនិបាតនោះៗ ។

ក្នុងវីសតិនិបាត មានព្រះថេរី ៥ រូប មាន ១១៨ គាថា

ក្នុងតឹសនិបាត មានព្រះថេរី ១ រូប មាន ៣៤ គាថា

ក្នុងចត្តាឡីសនិបាត មានព្រះថេរី ១ រូប មាន ៤៨ គាថា

ក្នុងមហានិបាត មានព្រះថេរី ១ រូប មាន ៧៥ គាថា

ក្នុងថេរៈ ថេរីគាថានេះ គប្បីជ្រាបចំនួននៃនិបាត ចំនួនអ្នកពោលគាថា និងចំនួនគាថាដូចពណ៌នាមកនេះ ។

## គន្ថារម្ភកថា ចប់

# អដ្ឋកថា និទានកថា

[ ១ ] ក្នុងថេរគាថានិងថេរីគាថាទាំងនេះដែលមានចំនួនតាមដែលកំណត់ហើយយ៉ាងនេះ ថេរគាថាជាគាថាដើម ។ ក្នុងបណ្តាថេរគាថាទាំងនោះគាថាដែលព្រះអានន្ទពោលទុក ដើម្បីសរសើរព្រះថេរៈទាំងនោះ ក្នុងគ្រាធ្វើបឋមសង្គាយនាថា

អ្នកទាំងឡាយ ចូរស្តាប់នូវគាថាទាំងឡាយ ប្រកបដោយ
ប្រយោជន៍ របស់ព្រះថេរៈទាំងឡាយ អ្នកមានចិត្តចម្រើន
ហើយ កាលបន្លឺឡើងដូចជាសីហៈ ជាសត្វមានចង្កូម ដែល
បន្លឺទៀបច្រកនៃភ្នំ ដូច្នេះ ជាគាថាដំបូង ។

សព្ទថា **សីហា** ក្នុងបទថា **សីហានំ** ក្នុងគាថានោះ មកហើយក្នុងអត្ថថា ស្តេចម្រឹគ ដូចក្នុងប្រយោគជាដើមថា **សីហោ ភិក្ខវេ មិគរាជា** ម្នាលភិក្ខុទាំងឡាយ សត្វសីហៈជាស្តេចម្រឹគ ដូច្នេះ ។

មកក្នុងអត្ថថា បញ្ញត្តិ ដូចក្នុងប្រយោគជាដើមថា **អថ ខោ សីហោ សេនាបតិ យេន ភគវា តេនុបសង្កមិ** គ្រានោះ សីហសេនាបតីចូលទៅគាល់ព្រះដ៏មានព្រះភាគ ដូច្នេះ ។

មកក្នុងអត្ថថា ព្រះតថាគត ដូចក្នុងប្រយោគជាដើមថា **សីហោតិ ខោ ភិក្ខវេ តថាគតស្សេតំ អធិវចនំ អរហតោ សម្មាសម្ពុទ្ធស្ស** ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថាសត្វសីហៈនេះ ជាឈ្មោះរបស់ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ដូច្នេះ ។

ក្នុងគាថានេះ **សីហា** សព្ទ គប្បីជ្រាបថា មានអត្ថប្រៀបធៀប ( ដូច

សីហៈ ) ដូច **សីហា** សត្វ ប្រើក្នុងអត្ថប្រៀបធៀបជាមួយពាក្យថា តថាគត ក្នុងទីនោះ ។

ព្រោះដូច្នោះ ទើបពាក្យថា **សីហានំវ** កាត់បទជា **សីហានំ ឥវ** ប្រែថា ដូចរាជសីហ៍ លុបស្រះចេញដោយអំណាចសន្ធិ ដូចក្នុងប្រយោគជាដើមថា **ឃរំ ស គេ** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **ឥវ** ត្រឹមតែជានិបាត ។

បទថា **សុណាថ** ជាបទអាខ្យាត ក្រៅអំពីនេះជាបទនាម ។ បទថា **សីហានំវ** ជាឆដ្ឋីវិភត្តិ ប្រើក្នុងការយោងសេចក្ដី ។ ឯការយោងសេចក្ដី ក្នុងគាថានេះ ទោះបីលោកមិនបានពោលទុកដោយសរុបក៏ពិត តែដោយ អត្ថរមែងឈ្មោះថា លោកពោលទុកហើយនោះឯង ព្រោះដូចកាលពោលថា **ឱដ្ឋស្សេវ មុខំ ឯតស្ស** ក៏ស្មើគ្នានឹងពោលថា **ឱដ្ឋស្ស មុខំ វិយ មុខំ ឯតស្ស** មុខរបស់បុគ្គលនោះដូចមុខឱដ្ឋ យ៉ាងណា ក្នុងសេចក្ដីនេះក៏ដូច្នោះ កាលពោលថា **សីហានំវ** ក៏ស្មើគ្នានឹងពោលថា **សីហានំ នាទោ វិយ** ដូចការបន្លឺនៃសីហៈ ដូច្នេះ ។ បើបន្ថែមសព្ទថា **មុខ** ចូលក្នុងបទថា **ឱដ្ឋ-ស្សេវ** បានសោត សូម្បីក្នុងបទថា **សីហានំវ** នេះ ក៏គួរបន្ថែមបទថា **ន-ទន្តានំ** ចូលបានដូចគ្នា ព្រោះដូច្នោះ ទើបបទថា **នទន្តានំ** ជាបទពង្រីករបស់បទថា **សីហានំវ** ។

បទថា **នទន្តានំ** ជាពាក្យសម្ដែងដល់ការទាក់ទងគ្នានៃបទថា **សីហានំវ** នោះ ដោយជាពាក្យពង្រីករបស់ពាក្យថា **សីហានំ** ។

បទថា **ទាឋីនំ** ជាវិសេសនៈនៃបទថា **សីហានំ** ។ បទថា **គិរិគព្ភរេ**

*សម្តែងដល់រាជសីហ៍នោះត្រាច់ទៅ ។ បទថា* **សុណាថ** *ជាពាក្យបបួលឲ្យស្តាប់ ។ បទថា* **ភាវិតត្តានំ** *សម្តែងដល់ប្រកពរបស់វត្ថុដែលគួរស្តាប់ ។ បទថា* **គាថា** *បានដល់ ពាក្យសម្តែងដល់រឿងដែលគួរស្តាប់ ។ បទថា* **អត្ត-បនាយិកា** *ជាវិសេសនៈនៃបទថា* **គាថា** *ពិតហើយ ពាក្យថា* **សីហានំ នទន្តានំ ទាឋីនំ** *ក្នុងគាថានេះ មកហើយដោយជានបុំសកលិង្គ ដោយពិតតែផ្លាស់លិង្គហើយ ប្រើជាឥត្ថីលិង្គក៏បាន ដូចពាក្យថា* **សីហីនំ** *ជាដើម ។ម្យ៉ាងទៀត ដោយរូបឯកសេសសមាស ទាំងរាជសីហ៍និងរាជសីហ៍ញី ហៅថា* **សីហា** *។ បណ្តាសីហៈទាំងនោះ និទានគាថាទាំង ៣ គាថានេះ មានពាក្យផ្តើមថា* **សីហានំ** *ទើបប្រើបានទូទៅ ទាំងថេរគាថានិងទាំងថេរីគាថា ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា* **សីហានំវ** *នោះតទៅ ឈ្មោះថា* **សីហា** *ព្រោះអត់ធន់ និងព្រោះសម្លាប់ អធិប្បាយថា ប្រៀបដូចរាជសីហ៍ដែលជាស្តេចម្រឹគ រមែងមិនមានអន្តរាយអំពីសរភម្រឹគនិងដំរីដែលចុះប្រេងជាដើម ព្រោះប្រកបដោយកម្លាំងពិសេស សូម្បីអំពីអន្តរាយ មានខ្យល់និងកម្តៅថ្ងៃ ជាដើម រាជសីហ៍ក៏អត់ធន់បានទាំងអស់ ។ កាលចេញរកស៊ី ជួបនឹងដំរីចុះប្រេងត្រកូលគន្ធៈនិងក្របីព្រៃជាដើម ក៏មិនតក់ស្លុត មិនភ្ញាក់ផ្អើល អាចផ្ចាញ់បាន ព្រោះសម្បូរដោយតេជះ កាលបើប្រយុទ្ធគ្នា ក៏នឹងសម្លាប់សត្វទាំងនោះបានគ្រប់អន្ទើ ហើយខាំស៊ីសាច់ដែលផុយក្នុងទីនោះៗ ដោយសប្បាយនោះឯង យ៉ាងណា ព្រះថេរៈទាំងឡាយក៏យ៉ាងនោះ មិនតក់ស្លុ[illegible] មិនភ្ញាក់ផ្អើលក្នុងទីណាមួយឡើយ ព្រោះសម្បូរដោយតេជះ លះអន្តរាយទាំងពួងចេញបាន*

ព្រោះប្រកបទៅដោយគុណវិសេស ដែលជាកម្លាំងរបស់ព្រះអរិយៈ ព្រោះគ្របសង្កត់នូវកម្លាំងនៃសង្កិលេស មានរាគៈជាដើម ហើយសម្លាប់ គឺលះបាន រមែងនៅដោយសុខមានសុខក្នុងឈានជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា **សីហា** ព្រោះដូចរាជសីហ៍ ដោយអត់ធន់និងដោយការសម្លាប់ ។ តែដោយអត្ថនៃសព្ទ គប្បីជ្រាបថា ឈ្មោះថា **សីហា** ដោយអត្ថថា បៀតបៀន ដូចសត្វលោកសន្មតថា **តក្ក** ព្រោះអត្ថថា កាត់ ដោយផ្លាស់អក្ខរៈខាងដើមមកទុកខាងចុង ។ ដែលឈ្មោះថា **រាជសីហ៍** ដោយអត្ថថា អត់ធន់ ក៏គប្បីជ្រាបយ៉ាងនោះ ( គឺសីហៈស្មើគ្នានឹងហឹសៈ ) ។

ម្យ៉ាងទៀត កេសរសីហៈស្តេចម្រឹគត្រាច់ទៅតែម្នាក់ឯង ព្រោះអាងក្នុងតេជៈរបស់ខ្លួន មិនប្រាថ្នាសត្វណាមួយជាសម្លាញ់ យ៉ាងណា សូម្បីព្រះថេរៈទាំងនេះ ក៏យ៉ាងនោះ ឈ្មោះថា **សីហា** ព្រោះដូចសីហៈ ព្រោះភាពជាអ្នកត្រេកអរក្រៃលែងក្នុងវិវេក និងព្រោះអត្ថថា ជាអ្នកត្រាច់ទៅតែឯង ព្រោះទៅតែម្នាក់ឯង ដោយភាពជាបុគ្គលខ្ពស់ដោយតេជៈ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **សីហំ វេកចរំ នាគំ** ប្រែថា ត្រាច់ទៅតែឯងដូចជាសត្វសីហៈឬដំរីដ៏ប្រសើរ ដូច្នេះ ។

ម្យ៉ាងទៀត ព្រះមហាថេរៈទាំងនេះ ឈ្មោះថា **សីហា** ព្រោះអត្ថថា ដូចសីហៈ ព្រោះប្រកបដោយគុណវិសេស មានការមិនតក់ស្លុត រាងវៃនិងការព្យាយាមជាដើម សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ ( ក្នុងអង្គុត្តរនិកាយទុកនិបាត ) ថា

ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ រមែងមិនតក់ស្លុត ក្នុងវេលាដែលរន្ទះបាញ់ ។ បុគ្គលពីរពួកតើដូចម្តេច ។ គឺភិក្ខុជាខីណាស្រព ១ សីហមិគរាជ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះឯង រមែងមិនតក់ស្លុត ក្នុងវេលាដែលរន្ទះបាញ់ ដូច្នេះ ។

សូម្បីការវាងវៃរបស់រាជសីហ៍ ក៏មិនទូទៅដល់សត្វដទៃ សូម្បីការអង់អាចក៏ដូចគ្នា ពិតយ៉ាងនោះ រាជសីហ៍លោតទៅបានឆ្ងាយរហូត ១០០ ឧសភ ធ្លាក់ក្នុងហ្វូងក្របីព្រៃជាដើម សូម្បីកូនរាជសីហ៍ ក៏នៅតែហ៊ានប្រយុទ្ធជាមួយដំរីចុះប្រេង ស៊ីសាច់ខ្ចីដែលជាប់ត្រង់គល់ភ្លុកបាន ។ ឯកម្លាំងនៃអរិយមគ្គ និងកម្លាំងនៃឫទ្ធិរបស់ព្រះមហាថេរៈទាំងនោះ ក៏មិនសាធារណៈដល់ភិក្ខុដទៃ ទាំងសេចក្តីព្យាយាមក្នុងសម្មប្បធាន ៤ ទាំងបុណ្យដ៏ប្រសើរក្រៃលែង ព្រោះហេតុនោះ បទថា **សីហានំវ** ទើបបានសេចក្តីថា ដូចរាជសីហ៍ ។ ក្នុងសេចក្តីនេះគប្បីជ្រាបថា លោកឧបមារាជសីហ៍ គង់នៅទាបសម្រាប់ពាក្យថា ថេរៈដែលមានអត្ថថា អត់ធន់ជាដើម ដែលជាគុណវិសេសលើសលុប ។

បទថា **នទន្តានំ** ប្រែថា គ្រហឹម ( បន្លឺ ) អធិប្បាយថា ក្នុងពេលស្វែងរកអាហារនិងពេលត្រូវការ ( កាមគុណ ) ជាដើម រាជសីហ៍ទាំងឡាយចេញអំពីគុហារបស់ខ្លួនហើយពត់កាយ បន្លឺសីហនាទ គួរស្ញែង យ៉ាងណា សូម្បីព្រះមហាថេរៈទាំងនេះ ក៏យ៉ាងនោះ បន្លឺសីហនាទគួរស្ញែង ក្នុងពេលពិចារណាអារម្មណ៍ដែលប្រព្រឹត្តទៅខាងក្នុង និងវេលាឧទានជាដើម ។

ដោយហេតុនោះ ទើបលោកពោលថា **សីហាធំវ ឆនច្ឆាធំ** ដូច្នេះ ។ បទថា **ធាឋីធំ** ប្រែថា មានចង្កូម អធិប្បាយថា មានចង្កូមប្រសើរ មានចង្កូមល្អ ក្រៃលែង អធិប្បាយថា រាជសីហ៍ទាំងឡាយ រមែងគ្របសង្កត់បរបក្ខដោយ កម្លាំងនៃចង្កូមទាំង ៤ ដ៏មាំនិងរឹងប៉ឹងក្រៃលែង ហើយញ៉ាំងមនោរថរបស់ ខ្លួនឲ្យដល់ទីបំផុតបាន យ៉ាងណា ព្រះមហាថេរៈទាំងនេះក៏យ៉ាងនោះ សង្កត់ កិលេសដែលជាបរបក្ខ ដែលខ្លួនមិនទាន់គ្របសង្កត់បានក្នុងសង្សារដែលមិន មានទីបំផុតខាងដើម ដោយកម្លាំងនៃចង្កូម គឺអរិយមគ្គទាំង ៤ ញ៉ាំងមនោ- រថរបស់ខ្លួនឲ្យដល់ទីបំផុតបាន ។ ក្នុងអធិការនេះ **អរិយមគ្គ** ឈ្មោះថា ចង្កូម ព្រោះដូចចង្កូម ព្រោះហេតុនោះ គប្បីជ្រាបថា មានន័យប្រៀបធៀប គ្នាបាន ។

បទថា **គិរិគព្ភរេ** ប្រែថា ក្បែរគុហាភ្នំ ។ បទថា **គិរិគព្ភរេ** នេះ ជា សត្តមីវិភត្តិ ចុះក្នុងអត្ថថា ជិត ។ អាចារ្យពួកខ្លះសូធ្យថា **គិរិគវ្ហរេ** ប្រែថា ត្រង់ដងព្រៃក្បែរភ្នំ ដូច្នេះក៏មាន ។ ពាក្យថា **គិរិគព្ភរេ** នេះ ជាពាក្យសម្តែង ដល់ទីដែលរុងរឿង និងសម្តែងដល់ទឹកដីដែលគួរបន្លឺសីហនាទរបស់រាជសីហ៍ ទាំងនោះ ប្រកបសេចក្តីថា ដូចរាជសីហ៍ទាំងឡាយដែលកំពុងបន្លឺក្បែរគុហា ភ្នំ ដូច្នេះ ។

ពិតណាស់ រាជសីហ៍ទាំងឡាយ តែងតែនៅក្បែរគុហាភ្នំ គឺក្នុងទីដែល ស្ងាត់ចាកមនុស្ស ព្រោះរាជសីហ៍ជាសត្វដែលមនុស្ស និងតិរច្ឆានដទៃចូល ជិតបានដោយលំបាក កាលបន្លឺសីហនាទក្នុងកាលទៅរកស៊ី ដើម្បីការពារនូវ

*ការភ័យខ្លាចរបស់ពួកម្រឹគតូចៗដែលកើតឡើង ព្រោះឃើញខ្លួន[១]យ៉ាងណា សូម្បីព្រះមហាថេរៈទាំងនេះ កាលនៅក្នុងសុញ្ញាគារ ដែលដូចគ្នានឹងគុហាភ្នំ ដែលមនុស្សដទៃចូលជិតបានដោយលំបាក ក៏បន្លឺសីហនាទដ៏អង់អាច ពោល គឺគាថាដែលនឹងពោលតទៅ ដើម្បីឲ្យមហាជនដែលរង់ចាំនូវគុណធម៌ ពួន សម្ងំចាកកិលេសដែលធ្វើឲ្យតក់ស្លុត មានតណ្ហានិងទិដ្ឋិ ( ជាដើម ) ដោយ ហេតុនោះ ទើបលោកពោលថា* **សីហានំវ ននទ្ទានំ ទាឋីនំ គិរិគព្ភរេ** *ដូច្នេះ ។*

*បទថា* **សុណាថ** *ជាពាក្យពោលប្រាប់ឲ្យស្តាប់ ។ ដោយពាក្យនេះ ព្រះ អានន្ទត្ថេរបំណងនឹងឲ្យកើតភាពជាអ្នកប្រាថ្នានឹងស្តាប់ ទើបដាស់តឿនឲ្យដាក់ ចិត្តស្តាប់ កាលឲ្យកើតនូវឧស្សាហៈ ទើបពញ្ញាក់នូវការគោរពនូវការរាប់អាន យ៉ាងច្រើនដល់បរិស័ទដែលមកប្រជុំគ្នាដើម្បីស្តាប់គាថាទាំងឡាយ ដែលនឹង ពោលតទៅ ។ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីនៃបទថា* **សីហានំ** *ជាដើម ដោយកាន់យកជាគោលនោះឯង មិនចាំបាច់ប្រៀបធៀបក៏បាន អធិប្បាយថា ព្រោះហេតុនោះ អ្នកទាំងឡាយចូរស្តាប់គាថាដែលដូចគ្នានឹង ការបន្លឺសីហ នាទដោយមិនតក់ស្លុតរបស់ព្រះថេរៈទាំងនោះ ដូចស្តាប់ការបន្លឺនូវសីហនាទ របស់រាជសីហ៍ដែលជាស្តេចនៃម្រឹគ ។ ឈ្មោះថា សត្វមានចង្កូម ព្រោះមាន ចង្កូមប្រសើរក្រៃលែង ដោយការៈជាចង្កូមដែលមាំទាំនិងមុតស្រួច កំពុងបន្លឺ*

---

*១-រាជសីហ៍កាលបន្លឺសីហនាទ តែងក្រឡេកមើលជុំវិញ ដោយគិតថា សត្វតូចៗកុំបីភ្ញាក់ផ្អើល មានរត់ធ្លាក់ជ្រោះជាដើម ។*

គឺគ្រហឹមបែបរាជសីហ៍ ដែលនៅក្បែរ គំរាមក្បែរគុហាភ្នំ ។ លោកពោលអធិប្បាយទុកថា អ្នកទាំងឡាយចូរស្តាប់គាថាដែលធ្វើនូវការតក់ស្លុតឲ្យដល់ពួកជនដែលប្រមាទ ដែលជាការបន្លឺរបស់បុគ្គលមិនតក់ស្លុត ព្រោះហេតុនៃភ័យទាំងឡាយលោកលះបានហើយដោយល្អដោយប្រការទាំងពួង ដូចគ្នានឹងការបន្លឺសីហនាទរបស់ព្រះថេរៈទាំងឡាយ ដែលមានខ្លួនអប់រំហើយ ជាអ្នកមិនប្រមាទហើយ ដូចការបន្លឺដ៏អង់អាច ព្រោះមិនចាំបាច់ខ្លាចក្រែងដល់បុគ្គលណាមួយ របស់រាជសីហ៍ ដែលជាស្តេចម្រឹគ បន្លឺសីហនាទ ធ្វើនូវការតក់សុ□ដល់សត្វដទៃក្រៅអំពីខ្លួនឯង ដូច្នោះ ។

បទថា **ភាវិតត្តានំ** បានដល់ ជាអ្នកមានចិត្តអប់រំហើយ អធិប្បាយថា ចិត្ត លោកហៅថា ខ្លួន ដូចក្នុងប្រយោគជាដើមថា ព្រោះថា ខ្លួន កម្រទូន្មានបានពេកណាស់ បុគ្គលណាមាន ខ្លួន ឋិតនៅត្រង់ដូចជាខ្នារ ដូច្នោះ និងដូចក្នុងប្រយោគជាដើមថា ការតម្កល់ ខ្លួន ប្រពៃ ដូច្នេះ ។ ព្រោះហេតុនោះ ទើបមានអធិប្បាយថា ព្រះអរិយបុគ្គលញុំាងចិត្ត ឲ្យចម្រើនក្រៃលែងដោយសមថៈ ញុំាងវិបស្សនាដោយការប្រកបរឿយៗនូវអធិចិត្ត គឺបុគ្គលញុំាងចិត្តឲ្យដល់ទីបំផុតនៃសមថភាវនានិងវិបស្សនាភាវនា ហើយតាំងនៅ ។ ម្យ៉ាងទៀត បទថា **ភាវិតត្តានំ** សេចក្តីថា មានខ្លួនអប់រំហើយជាសភាវៈ ។ អធិប្បាយថា មានខ្លួនអប់រំហើយដោយគុណ មានសីលគុណជាដើម ដែលមានតាមសភាវៈ ។ ឈ្មោះថា **គាថា** ព្រោះជាពាក្យដែលលោកចងក្រងទុក បានដល់ ពាក្យ ៤ បទ ឬ ៦ បទដែលឥសីទាំងឡាយចងទុកជា ឆន្ទ មាន

អនុដ្ឋុភឆន្ទ ជាដើម ព្រោះឆន្ទដទៃមានលក្ខណៈស្រដៀងគ្នានឹងអនុដ្ឋុភឆន្ទនោះ ទើបលោកហៅថា **គាថា** ។ គាថា ឈ្មោះថា **អត្ថុបនាយិកា** ព្រោះអត្ថថា បង្អោនចូលទៅកាន់ប្រយោជន៍ទាំងឡាយ មានប្រយោជន៍ខ្លួនជាដើម ឬព្រោះបង្អោនខ្លួនទៅក្នុងប្រយោគទាំងនោះ ។

ម្យ៉ាងទៀត បទថា **ភាវិតត្តានំ** ប្រែថា មានអត្តភាពដែលអប់រំហើយ អធិប្បាយថា អត្តភាពលោកហៅថា **អត្តា** ព្រោះជាទីតាំងនៃមានះថាជាអញ អត្តភាពនោះ ដែលព្រះថេរៈទាំងនោះអប់រំហើយ ដោយអប្បមាទភាវនានិង អនវជ្ជភាវនា គឺឲ្យកាន់យកក្លិននៃគុណធម៌ដោយប្រពៃនោះឯង ។ ព្រះអានន្ទត្ថេរសម្តែងសេចក្តីបរិបូណ៌នៃភាវនារបស់លោកទាំងនោះថា មាន ៤ គឺ កាយភាវនា ១ សីលភាវនា ១ ចិត្តភាវនា ១ បញ្ញាភាវនា ១ ទាំងនោះ ទុកដោយបទថា **ភាវិតត្តានំ** នោះ ឯភាវនាក្នុងទីនេះ លោកសំដៅដល់ផល ដែលប្រព្រឹត្តទៅកាន់សម្ពោធិញ្ញាណ ។ ឯការត្រាស់ដឹងសច្ចៈនេះ មាន ២ យ៉ាងគឺ ដោយការត្រាស់ដឹង ១ ដោយហេតុដើម្បីការត្រាស់ដឹងនោះ ១ ។ ឯសម្ពោធិនោះមាន ៣ យ៉ាង គឺសម្មាសម្ពោធិញ្ញាណ ១ បច្ចេកសម្ពោធិញ្ញាណ ១ សាវកសម្ពោធិញ្ញាណ ១ ។

ក្នុងបណ្តាសម្ពោធិ ៣ យ៉ាងនោះ ឈ្មោះថា **សម្មាសម្ពោធិ** ព្រោះដឹង គឺត្រាស់ដឹងធម៌ទាំងពួង ដោយប្រពៃដោយខ្លួនឯង ។ មគ្គញ្ញាណ ដែលជាបទដ្ឋានរបស់សព្វញ្ញុតញ្ញាណ និងសព្វញ្ញុតញ្ញាណដែលជាបទដ្ឋានរបស់មគ្គញ្ញាណ លោកហៅថា **សម្មាសម្ពោធិញ្ញាណ** ដោយហេតុនោះ ទើបព្រះ

សារីបុត្តត្ថេរពោល ( ទុកក្នុងខុទ្ទកនិកាយមហានិទ្ទេស ) ថា ត្រង់ពាក្យថា ព្រះពុទ្ធ បានដល់ ព្រះមានព្រះភាគ ជាសយម្ភូ ឥតមានគ្រូអាចារ្យ បាន ត្រាស់ដឹងសច្ចៈដោយព្រះអង្គឯងក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាល មុនផង ទ្រង់ដល់នូវសព្វញ្ញុតញ្ញាណក្នុងសច្ចៈនោះផង ទ្រង់ដល់នូវភាវៈស្ទាត់ ក្នុងពលទាំងឡាយផង ដូច្នេះ ។

ពិតហើយ ភាពជាអ្នកជំនាញក្នុងពលធម៌ទាំងឡាយ មានអត្ថថា ត្រាស់ ដឹងធម៌ដែលគួរត្រាស់ដឹង ។ ឈ្មោះថា **បច្ចេកសម្ពោធិ** ព្រោះត្រាស់ដឹងដោយ ខ្លួនឯងពិតជាការចំពោះខ្លួន ។ អធិប្បាយថា មិនបានត្រាស់ដឹងតាមបុគ្គល ណាមួយ បានដល់ ត្រាស់ដឹងសច្ចធម៌ដោយសយម្ភូញាណ ។

ពិតហើយ ការត្រាស់ដឹងសច្ចធម៌របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយដែល ប្រព្រឹត្តទៅដោយព្រះអង្គឯងនោះឯងដោយជាសយម្ភូញាណ ឈ្មោះថា មាន បុគ្គលត្រាស់ដឹងតាម ព្រោះជាហេតុនៃការត្រាស់ដឹងសច្ចធម៌របស់សត្វទាំង ឡាយ ប្រមាណមិនបាន ។ ការសម្រេចសច្ចៈរបស់ពួកសត្វដែលមិនមាន ប្រមាណទាំងនេះរមែងមិនជាហេតុនៃការត្រាស់ដឹងសច្ចធម៌របស់សត្វ សូម្បី តែមួយ ។ ឈ្មោះថា **សាវក** ព្រោះកើតក្នុងទីបំផុតនៃការស្តាប់ព្រះធម្មទេសនា របស់ព្រះសាស្តា ។ ការត្រាស់ដឹងសច្ចធម៌របស់សាវកទាំងឡាយ ឈ្មោះថា **សាវកសម្ពោធិ** ។

ការត្រាស់ដឹង ៣ យ៉ាងនេះ របស់ព្រះពោធិសត្វ ៣ ពួក គប្បីជ្រាបថា ជាការចម្រើន ពោធិបក្ខិយធម៌ ៣៧ ប្រការ មានសតិប្បដ្ឋានជាដើម ឲ្យ

បរិបូណ៌ ដើម្បីដល់ទីបំផុតនៃបដិបទាដែលនឹងមកដល់តាមលំដាប់របស់ខ្លួន ( រង់ចាំកាលបរិបូណ៌នៃបារមីរបស់ខ្លួន ) ព្រោះវៀរចាកពោធិបក្ខិយធម៌ ៣៧ ប្រការនោះ ការត្រាស់ដឹងក្រៅអំពីនេះមិនមាន អធិប្បាយថា វៀរការត្រាស់ដឹងដោយសច្ឆិកិរិយាកិច្ច ការត្រាស់ដឹងដោយភាវនាកិច្ចមិនមាន ។ កាលការត្រាស់ដឹងភាវនាកិច្ចមាន ការត្រាស់ដឹងបហានកិច្ច និងការត្រាស់ដឹងដោយបរិញ្ញាកិច្ច រមែងឈ្មោះថា ជាការសម្រេចហើយនោះឯង ។

ក្នុងពេលដែលព្រះពោធិសត្វបំពេញពោធិសម្ភារៈ ស្រេចបរិបូណ៌ហើយ ក្នុងភពចុងក្រោយ បំពេញបុព្វកិច្ចស្រេចហើយ ឡើងកាន់ពោធិមណ្ឌល ទ្រង់តាំងបដិជ្ញាថា អាត្មាអញមិនទម្លាយភ្នែននេះ ដរាបណាចិត្តរបស់អញរួចផុតចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ដូច្នេះហើយ គង់លើអបរាជិតបល្ល័ង្ក មិនទាន់ដល់ពេលល្ងាច ក៏ទ្រង់កម្ចាត់មារនិងពលនៃមារចេញបាន រឭកដល់ខន្ធដែលទ្រង់ធ្លាប់អាស្រ័យមកហើយក្នុងកាលមុន ក្នុងវេលាការកត ដែលមានអាការៈមិនមែនតិច ដោយបុព្វេនិវាសានុស្សតិញ្ញាណ ក្នុងបុរិមយាម ទ្រង់សម្រេចចុតូបបាតិញ្ញាណ និងអនាគតំសញ្ញាណ ដោយការជម្រះទិព្វចក្ខុឲ្យបរិសុទ្ធ ក្នុងមជ្ឈិមយាមទ្រង់តាំងមាំនូវវិបស្សនាដោយមុខ គឺបដិច្ចសមុប្បាទចាប់តាំងពីជរានិងមរណៈដោយន័យជាដើមថា សត្វលោកនេះដល់នូវសេចក្តីលំបាកហ្ន៎ រមែងកើត ចាស់ ស្លាប់ ចុតិ និងបដិសន្ធិ ដល់នូវសភាពយ៉ាងនេះ ព្រោះមិនដឹងព្រះនិព្វានដែលជាគ្រឿងរលាស់ទុក្ខនេះ គឺជរានិងមរណៈដែលព្រះលោកនាថ សំលៀងនូវពូថៅ គឺព្រះញាណ កាប់នូវព្រៃស្តុក គឺ

កិលេស ដូចសំលៀនពូថៅត្រង់ថ្មសំលៀង ដើម្បីកាប់ព្រៃធំ ដូច្នោះ ទ្រង់ញ៉ាំងវិបស្សនាឲ្យតាំងគភ៌ ដោយការសម្រេចសព្វញ្ញុតញ្ញាណ ព្រោះហេតុសម្បត្តិ គឺភាពជាព្រះពុទ្ធ ដល់នូវភាពចាស់ក្លា ទ្រង់ចូលសមាបត្តិផ្សេងៗក្នុងចន្លោះៗ ទ្រង់លើកនាមរូបតាមដែលទ្រង់កំណត់ហើយ ឡើងកាន់ត្រៃលក្ខណ៍ពិចារណាសង្ខារក្នុងវេាការកេព មានអាការៈមិនមែនតិច ដោយអំណាចនៃការពិចារណាតាមលំដាប់បទញ៉ាំងសម្មសនវារៈ ( ការពិចារណាបដិច្ចសមុប្បាទ) ឲ្យពិស្តារហើយដោយមុខនៃធម៌ ៣៦ សែនកោដិ ។ កាលវិបស្សនាញាណពោលគឺមហាវជិរញ្ញាណក្នុងសម្មសនញ្ញាណនោះចាស់ក្លា ផូរផង់ ប្រព្រឹត្តទៅដោយភាពជាវុដ្ឋានគាមិនី ទ្រង់បន្តសម្មសនញ្ញាណនោះដោយមគ្គ បានក្នុងពេលណា ក្នុងពេលនោះទ្រង់ញ៉ាំងកិលេស ១៥០០ ឲ្យអស់ទៅដោយលំដាប់នៃមគ្គ ឈ្មោះថា រមែងត្រាស់ដឹងព្រះសម្មាសម្ពោធិញ្ញាណ ក្នុងខណៈនៃមគ្គដ៏ប្រសើរ គឺអរហត្តមគ្គ ចាប់តាំងអំពីខណៈនៃអគ្គផល ឈ្មោះថា ទ្រង់សម្រេច ហើយក្នុងបច្ឆិមយាម ។

សូម្បីទសពលញ្ញាណនិងវេសារជ្ជញ្ញាណជាដើមឈ្មោះថា រមែងនៅក្នុងកណ្តាប់ព្រះហស្តរបស់ព្រះអង្គ ក្នុងពេលនោះ ព្រោះភាពជាព្រះសម្មាសម្ពុទ្ធ ដូច្នោះសេចក្តីនេះទើបចាត់ជាបដិបទានៃព្រះសម្មាសម្ពោធិញ្ញាណ ដោយការត្រាស់ដឹងមុន ។ ចំណែកដោយអត្ថ សម្មាសម្ពោធិបដិបទានោះ បានដល់ការចម្រើននូវពោធិសម្ភារៈ ដែលប្រព្រឹត្តទៅហើយក្នុងរវាងដែលទ្រង់កើតក្នុងតុសិតភពរហូតដល់ទ្រង់សម្តែងមហាភិនីហារ ។ ពាក្យដែលគួរពោលដល់

ក្នុងការបម្រើនពោធិសម្ភារៈនោះ ខ្ញុំពោលទុកហើយសម្បូរដោយអាការទាំងពួងក្នុងអដ្ឋកថាចរិយាបិដក ព្រោះហេតុនោះ អ្នកសិក្សាគប្បីកាន់យកដោយន័យដែលបានពោលហើយក្នុងអដ្ឋកថានៃចរិយាបិដកឯនោះហោង ។

ព្រះបច្ចេកពោធិសត្វទាំងឡាយ បំពេញអភិនីហារដើម្បីបច្ចេកពោធិ មានបច្ចេកពោធិសម្ភារ ដែលសន្សំមកហើយដោយលំដាប់ តាំងនៅក្នុងអត្តភាពចុងក្រោយក្នុងពេលបែបនោះ កាន់យកសំវេគនិមិត្តដែលប្រាកដហើយដោយភាពដែលញាណដល់នូវភាពចាស់ក្លា ឃើញទោសក្នុងភពជាដើមដោយមិនប្លែកគ្នា កំណត់បវត្តិ ( ទុក្ខ ) និងហេតុនៃបវត្តិ ( សមុទយ ) និវត្តិ ( និរោធ ) និងហេតុនៃនិវត្តិ ( មគ្គ ) ដោយសយម្ភូញាណ ចម្រើននូវចតុសច្ចកម្មដ្ឋាន មានសច្ចៈ ៤ ជាអារម្មណ៍ ដោយន័យដែលមកហើយថា លោកមនសិការដោយឧបាយថា នេះទុក្ខ ដូច្នេះជាដើម ពិចារណាអនុលោមបដិលោមនូវសង្ខារទាំងឡាយ តាមសមគួរដល់អភិនីហាររបស់ខ្លួន ខ្វល់ខ្វាយក្នុងវិបស្សនាដោយលំដាប់ សម្រេចអគ្គមគ្គតាមលំដាប់មគ្គ ឈ្មោះថា រមែងត្រាស់ដឹងបច្ចេកសម្ពោធិញ្ញាណចាប់តាំងអំពីខណៈនៃអគ្គផលទៅ ឈ្មោះថាជាព្រះបច្ចេកសម្ពុទ្ធរមែងជាអគ្គទក្ខិណេយ្យបុគ្គលរបស់សត្វលោក ព្រមទាំងទេវលោក ។ ឯសាវកឬសព្រហ្មចារីរបស់ព្រះសាស្តា ស្តាប់កម្មដ្ឋានដែលមានសច្ចៈធម៌ទាំង ៤ ជាអារម្មណ៍ ប្រព្រឹត្តតាម គឺព្យាយាមបដិបត្តិបដិបទាកើតអំពីកម្មដ្ឋាននោះ ខ្វល់ខ្វាយក្នុងវិបស្សនា ឬកាលបដិបទាចម្រើនឡើងចាក់ធ្លុះនូវសច្ចៈទាំងឡាយ ឈ្មោះថា រមែងសម្រេចសាវកសម្ពោធិញ្ញាណ

ក្នុងភូមិនៃអគ្គសាវកដែលសម្រេចតាមសមគួរដល់អភិនីហាររបស់ខ្លួន ឬក្នុងខណៈនៃមគ្គដ៏ប្រសើរតែម្យ៉ាង ។ បន្ទាប់អំពីនោះ រមែងឈ្មោះថា ជាសាវកពុទ្ធ ជាអគ្គទក្ខិណេយ្យបុគ្គលក្នុងលោកព្រមទាំងទេវលោក ។ បច្ចេកសម្ពោធិនិងសាវកសម្ពោធិ ដោយការត្រាស់ដឹងគប្បីជ្រាបដូចពណ៌នាមកនេះ ។

តែដោយហេតុដើម្បីការត្រាស់ដឹង គប្បីជ្រាបថា សម្រាប់ព្រះពោធិសត្វទាំងឡាយ កំណត់យ៉ាងទាប ត្រូវសន្សំពោធិសម្ភារៈអស់ ៤ អសង្ខេយ្យនិង ១ សែនកប្ប កំណត់យ៉ាងកណ្ដាលត្រូវចម្រើនសម្ពោធិសម្ភារៈអស់ ៨ អសង្ខេយ្យនិង ១ សែនកប្ប កំណត់យ៉ាងខ្ពស់ ត្រូវអប់រំពោធិសម្ភារៈអស់ ១៦ អសង្ខេយ្យនិង ១ សែនកប្ប ។ ការបែកផ្សេងគ្នាទាំងនេះ គប្បីជ្រាបតាមប្រភេទរបស់ព្រះពោធិសត្វដែលជា បញ្ញាធិក សទ្ធាធិកនិងវិរិយាធិក ។

ពិតហើយ ព្រះពោធិសត្វដែលជាបញ្ញាធិក រមែងមានសទ្ធាទន់ខ្សោយ តែបញ្ញាខ្លាំង ដោយហេតុនោះ ទើបបារមីក៏ដល់នូវភាពបរិបូរក្នុងកាលមិនយូរ ព្រោះការចាស់ក្លា និងភាពល្អិតសុខុមនៃភាពជាអ្នកឈ្លាសក្នុងឧបាយ ។

បុគ្គលដែលជាសទ្ធាធិក រមែងមានបញ្ញាជាកណ្ដាល ព្រោះហេតុនោះ បារមីរបស់ព្រះពោធិសត្វដែលជាសទ្ធាធិកទាំងនោះ ទើបដល់នូវសេចក្ដីបរិបូណ៌ មិនរហ័សពេក និងមិនយូរពេក ។

ឯបុគ្គលដែលជាវិរិយាធិក រមែងមានបញ្ញាតិច ព្រោះហេតុនោះបារមីនៃព្រះពោធិសត្វដែលជាវិរិយាធិកទាំងនោះ ដល់នូវសេចក្ដីបរិបូណ៌ ក្នុងកាលយូរនោះឯង ។

សម្រាប់ព្រះបច្ចេកពោធិសត្វមិនដូច្នោះឡើយ លោកទាំងនោះ ទោះបីជាបញ្ញាធិក ក៏ត្រូវអប់រំពោធិសម្ភារអស់ ២ អសង្ខេយ្យ និង ១ សែនកប្បមិនទាបជាងនោះឡើយ សូម្បីបច្ចេកពោធិសត្វដែលជាសទ្ធាធិករមែងសម្រេចបច្ចេកសម្ពោធិញ្ញាណរំលងកាលវេលាកំណត់ទៅបន្តិចបន្តួច តែមិនដល់ ៣ អសង្ខេយ្យ ។

សម្រាប់សាវកពោធិសត្វ បំពេញអភិនីហារដើម្បីភាពជាអគ្គសាវក ត្រូវអប់រំពោធិសម្ភារអស់កាលមួយអសេង្ខយ្យ និងមួយសែនកប្ប ។

សម្រាប់សាវកពោធិសត្វដែលបំពេញអភិនីហារដើម្បីភាពជាមហាសាវក ត្រូវសន្សំពោធិសម្ភារអស់កាលមួយសែនកប្បប៉ុណ្ណោះ សូម្បីពុទ្ធមាតា ពុទ្ធបិតា ពុទ្ធុបដ្ឋាក និងពុទ្ធជិនោរស ក៏ដូចគ្នា ។ ក្នុងអធិការនោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ។

កាលព្រះមហាសត្វទាំងឡាយ តាំងបណិធាន ដោយសមោធានធម៌ ៨ ដែលពោលទុកយ៉ាងនេះថា

> ព្រោះប្រជុំនៃធម៌ ៨ គឺភាពជាមនុស្ស ១ ភាពសម្បូរដោយភេទ ១ ហេតុ ១ ជួបព្រះសាស្តា ១ បព្វជ្ជា ១ គុណសម្បត្តិ ១ អធិការ ១ ភាពជាអ្នកមានឆន្ទៈ ១ ទើបអភិនីហារសម្រេចបាន ។

ចាប់តាំងពីបំពេញមហាភិនីហារខ្វល់ខ្វាយរឿយៗ ក្នុងទានជាដើម ជាពិសេស ថ្វាយមហាទានដូចគ្នានឹងទានរបស់ព្រះវេស្សន្តររាល់ៗ ថ្ងៃ សូម្បី

សន្សំបារមីធម៌សព្វយ៉ាង មានសីលដែលសមគួរដល់មហាទាននោះ ជាដើម ឈ្មោះថា ការកើតឡើងនៃព្រះពុទ្ធរមែងមិនមានក្នុងចន្លោះបានឡើយ ព្រោះមិនទាន់ដល់កំណត់កាលតាមដែលពោលហើយ ។ ព្រោះហេតុអ្វី ព្រោះព្រះញាណមិនទាន់ចាស់ក្លា អធិប្បាយថា ព្រះញាណរបស់ព្រះពុទ្ធដល់នូវសេចក្តីចម្រើន ដុះដាល បរិបូណ៌ តាំងគភ៌ រមែងដល់នូវការចាស់ក្លា ដូចសន្ទូងដែលឲ្យផលហើយក្នុងពេលដែលកំណត់ ដូច្នោះ យ៉ាងណា កាលព្រះបច្ចេកពោធិសត្វធ្វើអភិនីហារសមោធានធម៌ ៥ ប្រការនេះ គឺ

> ភាពជាមនុស្ស ១ បរិបូណ៌ដោយភេទ ១ ការជួបបុគ្គលដែលប្រាសចាកអាសវៈ ១ អធិការ ១ ជាអ្នកមានឆន្ទៈ ១ នេះជាហេតុនៃអភិនីហារ ។

ចំណែកសាវកពោធិសត្វដែលតាំងបណិធាន ដោយអំណាចនៃសេចក្តីប្រាថ្នាដែលប្រកបដោយអង្គ ២ គឺអធិការ ១ ជាអ្នកមានឆន្ទៈ ១ ការសម្រេចបច្ចេកសម្ពោធិញ្ញាណ និងសាវកសម្ពោធិញ្ញាណក្នុងចន្លោះនោះ មិនទាន់ដល់កំណត់កាលតាមដែលពោលហើយក្នុងទីនោះៗរមែងមិនមាន ក៏យ៉ាងនោះ ។ ព្រោះហេតុអ្វី ព្រោះញាណមិនទាន់ចាស់ក្លា អធិប្បាយថា បញ្ញាបារមីដែលបន្ថែមដោយបារមីទាំងឡាយ មានទានបារមីជាដើមរបស់មហាពោធិសត្វទាំងឡាយនេះ រមែងតាំងគភ៌ គឺដល់នូវការចាស់ក្លា ញុំាងពុទ្ធញ្ញាណឲ្យបរិបូណ៌ដោយលំដាប់ យ៉ាងណា បញ្ញាបារមីដែលបន្ថែមឡើងដោយបារមីទាំងឡាយមានទានបារមីជាដើមរបស់ព្រះបច្ចេកពុទ្ធ និងសាវកពុទ្ធទាំងឡាយ ក៏ដូច្នោះ

ដូចគ្នា រមែងតាំងគភ៌ដល់នូវភាពចាស់ក្លាញុំាងបច្ចេកពោធិញ្ញាណ និងសាវកពោធិញ្ញាណឲ្យបរិបូណ៌តាមសមគួរដោយលំដាប់ ។

ពិតហើយ ដោយការសន្សំទាន បុគ្គលទាំងនេះទើបជាអ្នកមានចិត្តមិនជាប់ជំពាក់ក្នុងកិលេសទាំងពួង ជាអ្នកមានចិត្តមិនសម្ងំរំពៃ ព្រោះមានអធ្យាស្រ័យមិនលោភលន់ក្នុងភពនោះៗ ដោយការសន្សំសីល ទើបជាអ្នកមានកាយ វាចា និងការងារបរិសុទ្ធដោយល្អ ព្រោះមានកាយវាចាសង្រួមល្អហើយ មានអាជីវៈបរិសុទ្ធ មានទ្វារគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយ ជាអ្នកដឹងប្រមាណក្នុងភោជន រមែងតាំងចិត្តមាំដោយជាគរិយានុយោគ ការប្រកបព្យាយាមរបស់លោកទាំងនោះ គប្បីជ្រាបដោយអំណាចនៃ បច្ចាគតិកវត្ត(១)ដែលធ្វើទុកហើយ ។

ឯសមាបត្តិ ៨ អភិញ្ញា ៥ អភិញ្ញា ៦ និងបុព្វភាគវិបស្សនាដែលជាអធិដ្ឋានធម៌ រមែងនៅក្នុងកណ្តាប់ដៃរបស់បុគ្គលដែលបដិបត្តិបែបនេះ ដោយមិនលំបាក ឯគុណធម៌ មានសេចក្តីព្យាយាមជាដើម ក៏ឈមចុះខាងក្នុងនៃបុព្វភាគវិបស្សនានោះឯង ។

ឯការអត់ធន់យ៉ាងក្រៃលែង ក្នុងការបំពេញកុសល មានទានជាដើម ដើម្បីបច្ចេកពោធិញ្ញាណ ឬសាវកពោធិញ្ញាណនេះ ឈ្មោះថា វីរិយៈ ការអត់ធន់ចំពោះសេចក្តីក្រោធ ឈ្មោះថា ខន្តិ ការឲ្យទាន ការសមាទានសីលជាដើម និងការមិនពោលឲ្យឃ្លៀងឃ្លាត ឈ្មោះថា សច្ចៈ ការអធិដ្ឋានចិត្ត

---

១-ក្នុងទីខ្លះជា គតបច្ចាគតវត្ត ។

មិនឲ្យញាប់ញ័រដែលឲ្យសម្រេចប្រយោជន៍ក្នុងទីទូទៅនោះឯង ឈ្មោះថា អ-ធិដ្ឋាន ។ ការប្រាថ្នាប្រយោជន៍ក្នុងពួកសត្វដែលជាបាទនៃការប្រព្រឹត្តទៅនៃទាននិងសីលជាដើម ឈ្មោះថា មេត្តា ។ ការដាក់ខ្លួនជាកណ្តាលក្នុងអាការៈផ្សេងៗដែលសត្វទាំងឡាយធ្វើ ឈ្មោះថា ឧបេក្ខា ។ ដូច្នោះ កាលបើ ទាន សីល ភាវនា ឬសីល សមាធិ បញ្ញាមាន បារមីទាំងឡាយ មានវីរិយបារមីជាដើមរមែងឈ្មោះថា សម្រេចហើយនោះឯង ។

បដិបទា មានទានជាដើម ដើម្បីជាប្រយោជន៍ដល់បច្ចេកពោធិញាណក្តី ដើម្បីជាប្រយោជន៍ដល់សាវកពោធិញាណក្តី នុ៎ះឯងឈ្មោះថា ភាវនា ព្រោះអប់រំ គឺ បន្ទំសន្តានរបស់ព្រះពោធិសត្វទាំងនោះ ។

ពោលដោយក្រៃលែងទៅទៀត បដិបទាដែលទាក់ទងដោយសមថៈ និងវិបស្សនាដែលប្រព្រឹត្តទៅហើយក្នុងសន្តាន ដែលទាននិងសីល តាក់តែងល្អហើយជាហេតុឲ្យព្រះពោធិសត្វទាំងនោះ សម្បូរដោយធម៌ជាទីកើតឡើង នៃការបំពេញព្យាយាមក្នុងខាងដើម ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ម្នាលអានន្ទ អានិសង្ស ៥ រមែងមានក្នុងការបំពេញព្យាយាមខាងដើម ៥ ប្រការដូចម្តេចខ្លះ ម្នាលអានន្ទ បុគ្គលបំពេញព្យាយាមខាងដើមក្នុងធម្មវិន័យនេះ រមែងសម្រេចអរហត្តផលក្នុងបច្ចុប្បន្ននេះឯងដោយរួសរាន់ ១ បើមិនទាន់សម្រេចអរហត្តផល ក្នុងបច្ចុប្បន្នដោយរួសរាន់ទេ ក្នុងមរណសម័យនឹងបានពាល់ត្រូវអរហត្តផល ១ បើពុំដូច្នោះទេ កើតជាទេវបុត្តនឹងបានពាល់

ត្រូវអរហត្តផល ១ បើពុំដូច្នោះទេ នឹងបានជាវិប្បាកិញ្ញាចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធទាំងឡាយ ១ បើពុំដូច្នោះទេ ក្នុងកាលជាខាងក្រោយ នឹងបានជាព្រះបច្ចេកពុទ្ធ ១ ។

ដោយប្រការដូចពណ៌នាមកនេះ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវកនៃព្រះពុទ្ធទាំងឡាយដែលមានអត្តភាពអប់រំហើយ ដោយការអប់រំធម៌ជាគ្រឿងឲ្យដល់នូវត្រៃយដែលជាបដិបទាខាងដើម ដោយសមថភាវនា និងវិបស្សនាភាវនា និងដោយមគ្គភាវនា ពោលគឺ ការត្រាស់ដឹងដែលជានិរោធគាមិនីបដិបទា រមែងបានឈ្មោះថា **ភាវិតត្តានំ** អ្នកមានចិត្តចម្រើនហើយ ។ ក្នុងបុគ្គលវិសេសទាំងនោះ សាវករបស់ព្រះពុទ្ធទាំងឡាយ លោកបំណងយកក្នុងទីនេះ ។

ដោយបទថា **សីហានំវ** នេះ ក្នុងគាថានេះ ព្រះធម្មសង្គាហកាចារ្យសម្ដែងដល់ភាពដែលព្រះថេរៈទាំងឡាយ ដែលបរបក្ខរបស់ខ្លួន គ្របសង្កត់មិនបាន លោកជាអ្នកប្រព្រឹត្តគ្របសង្កត់សត្រូវទាំងនោះ ដោយសម្ដែងការប្រព្រឹត្តទៅដែលប្រៀបបាននឹងសីហៈ ។

ដោយបាទគាថាថា **សីហានំវ នទន្តានំ ។បេ។ គាថា** នេះ លោកសម្ដែងដល់ភាពដែលព្រះថេរៈទាំងឡាយនោះ ដែលសត្រូវទាំងឡាយញាំញីមិនបាន ដោយបរវាទនិងព្រឹត្តិកម្មដែលសង្កត់សង្កិនសត្រូវទាំងនោះ ដោយការសម្ដែងថេរគាថាទាំងឡាយ ដូចគ្នានឹងសីហនាទ ។ ដោយបទថា **ភាវិតត្តានំ** នេះ លោកសម្ដែងដល់ហេតុនៃការបន្លឺសីហនាទរបស់ព្រះថេរៈទាំងឡាយនោះ ។

ក្នុងគាថានេះ ព្រះថេរៈទាំងឡាយ លោកហៅថា ដូចគ្នានឹងសីហៈ ព្រោះមានអត្តភាពអប់រំហើយ ហើយគាថារបស់ព្រះថេរៈទាំងនោះ លោកហៅថា ដូចគ្នានឹងសីហនាទ ។

ដោយបទថា **អត្តូបនាយិកា** នេះ លោកសម្តែងដល់ប្រយោជន៍ក្នុងការសង្កត់សង្កិន ។ បណ្តាអកុសលធម៌ទាំងនោះ សង្កិលេសធម៌ ឈ្មោះថាជាបរបក្ខរបស់ព្រះថេរៈទាំងឡាយ ។ សមុច្ឆេទប្បហាន តទង្គប្បហាន វិក្ខម្ភនប្បហាន ឈ្មោះថា ការសង្កត់សង្កិននូវសង្កិលេសធម៌នោះ ។

កាលសមុច្ឆេទប្បហាន តទង្គប្បហាន និងវិក្ខម្ភនប្បហានមាន ឈ្មោះថាសម្រេចជាបដិបស្សទ្ធិប្បហាន និងនិស្សរណប្បហាន តាមដែលលោកហៅថា ព្រះថេរៈទាំងនោះជាអ្នកមានចិត្តចម្រើន ( អប់រំ ) ហើយ លោកពោលអធិប្បាយទុកដូច្នេះក្នុងមគ្គខណៈ ព្រះអរិយៈទាំងឡាយ ឈ្មោះថារមែងចម្រើនអប្បមាទភាវនា ចាប់តាំងពីខណៈអគ្គផលទៅ ឈ្មោះថា អ្នកមានចិត្តចម្រើនហើយ ។

បណ្តាបហានទាំងនោះ លោកសម្តែងកិរិយាបរិបូណ៌ដោយ សីលរបស់ព្រះថេរៈទាំងនោះ ដោយតទង្គប្បហាន សម្តែងកិរិយាបរិបូណ៌ដោយសមាធិដោយ វិក្ខម្ភនប្បហាន សម្តែងការសម្បូរដោយបញ្ញា ដោយសមុច្ឆេទប្បហាន សម្តែងផលរបស់សម្បទាទាំងនោះ ដោយបទក្រៅអំពីនេះ ។

លោកសម្តែងបដិបទារបស់ព្រះថេរៈទាំងនោះ ល្អខាងដើមដោយសីល ។ សម្តែងថាសីលជាលម្អខាងដើម ដោយបដិបទា ដោយបាលីថា **កោ ចាទិ**

**កុសលានំ ធម្មានំ សីលញ្ច សុវិសុទ្ធំ** ចុះអ្វីជាខាងដើមនៃកុសលធម៌ទាំងឡាយ ។ គឺសីលដ៏បរិសុទ្ធ ១ ... ដូច្នេះ ។

ម្យ៉ាងទៀត លោកសម្តែងថា **សីលេ បតិដ្ឋាយ** ប្រែថា នរៈបានតាំងមាំក្នុងសីល និងគាថាថា **សព្វបាបស្ស អករណំ** ប្រែថា ការមិនធ្វើបាបទាំងពួង ព្រោះនាំមកនូវគុណមានការមិនក្តៅក្រហាយជាដើម ។

លោកសម្តែងលម្អត្រង់កណ្តាលដោយសមាធិ ។ សមាធិ ជាលម្អត្រង់កណ្តាលនៃបដិបទា ដោយព្រះបាលីថា **ចិត្តំ ភាវយំ** ប្រែថា ចម្រើននូវសមាធិចិត្ត[១]និងបាលីថា **កុសលស្សូបសម្បទា** ប្រែថា ញ៉ាំងកុសលធម៌ឲ្យដល់ព្រម ព្រោះហេតុនាំមកនូវគុណមានឥទ្ធិវិធជាដើម ។

លោកសម្តែងលម្អខាងចុងដោយបញ្ញា ។ បញ្ញា ឈ្មោះថា ជាទីបំផុតនៃបដិបទា ដោយព្រះបាលីថា **សចិត្តបរិយោទបនំ** ប្រែថា ធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ និងបាលីថា **បញ្ញំ ភាវយំ** ប្រែថា ចម្រើនវិបស្សនាបញ្ញា បញ្ញានោះឯងឈ្មោះថា ស្អាត ដោយហេតុដែលបញ្ញា ប្រសើរជាងកុសលធម៌ទាំងឡាយព្រោះនាំមកនូវភាពជាអ្នកមិនញាប់ញ័រ ក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ទាំងឡាយ សមដូចព្រះតម្រាស់ត្រាស់ ( ក្នុងធម្មបទ ) ថា

ភ្នំថ្មតាន់មិនរំភើបព្រោះខ្យល់ ដូចម្តេចមិញ បណ្ឌិតទាំងឡាយ
ក៏មិនរំភើប ព្រោះពាក្យតិះដៀល និងពាក្យសរសើរ ( ជាដើម )

---

១-បិដកខ្មែរ ( ជដាសូត្រ ) ជា ចិត្តំ បញ្ញញ្ច ភាវយំ តែក្នុងទីនេះ លោកពោលអំពីលម្អត្រង់កណ្តាល ទើបមិនមានពាក្យថា បញ្ញញ្ច ព្រោះបញ្ញាជាលម្អបទចុង ។

ដូច្នោះឯង ។

ម្យ៉ាងទៀត លោកសម្ដែងភាពជាបុគ្គលមានវិជ្ជា ៣ ដោយសីលសម្បទា ព្រោះសម្រេចវិជ្ជា ៣ បាន ត្រូវអាស្រ័យសីលសម្បត្តិ ។

សម្ដែងភាពជាអ្នកមានអភិញ្ញា ៦ ដោយសមាធិសម្បទា ព្រោះសម្រេចអភិញ្ញា ៦ បាន ត្រូវអាស្រ័យសមាធិសម្បត្តិ ។

សម្ដែងភាពជាអ្នកមានបដិសម្ភិទា ដោយបញ្ញាសម្បទា ព្រោះសម្រេចបដិសម្ភិទា ៤ បាន ត្រូវអាស្រ័យបញ្ញាសម្បត្តិ ។

ដោយបទថា **អត្ថុបនាយិកា** នេះ គប្បីជ្រាបថា លោកសម្ដែងសេចក្ដីនេះថា បណ្ដាព្រះថេរៈទាំងនោះ អង្គខ្លះបានវិជ្ជា ៣ អង្គខ្លះបានអភិញ្ញា ៦ អង្គខ្លះដល់នូវបដិសម្ភិទាទាំងឡាយ ។

ម្យ៉ាងទៀត លោកសម្ដែងការវៀរនូវអន្តធម៌ គឺកាមសុខល្លិកានុយោគរបស់ព្រះថេរៈទាំងនោះ ដោយសីលសម្បទា ។ សម្ដែងការវៀរអន្តធម៌ គឺអត្តកិលមថានុយោគ ដោយសមាធិសម្បទា សម្ដែងការសេពមជ្ឈិមប្បដិបទា ដោយបញ្ញាសម្បទា ។

ម្យ៉ាងទៀត គប្បីជ្រាបថា លោកសម្ដែងការលះ ដោយការឈានកន្លងកិលេសទាំងឡាយរបស់ព្រះថេរៈទាំងនោះ ដោយសីលសម្បទា ។ សម្ដែងការលះនូវការចោមរោមរបស់កិលេសទាំងឡាយ ដោយសមាធិសម្បទា ។ សម្ដែងការលះអនុស័យរបស់កិលេសទាំងឡាយ ដោយបញ្ញាសម្បទា ។

ម្យ៉ាងទៀត សម្ដែងការជម្រះសង្កិលេស គឺទុច្ចរិត ដោយសីលសម្បទា

សម្តែងការជម្រះសង្កិលេស គឺតណ្ហា ដោយសមាធិសម្បទា ។ សម្តែងការជម្រះសង្កិលេស គឺទិដ្ឋិ ដោយបញ្ញាសម្បទា ។

ម្យ៉ាងទៀត សម្តែងការឈានកន្លងអបាយរបស់ព្រះថេរៈទាំងនោះ ដោយតទង្គប្បហាន ។ សម្តែងការឈានកន្លងកាមធាតុ ដោយវិក្ខម្ភនប្បហាន ។ សម្តែងការឈានកន្លងភពទាំងពួង ដោយសមុច្ឆេទប្បហាន ។

ម្យ៉ាងទៀត ក្នុងបទថា **ភាវិតត្តានំ** នេះ គប្បីជ្រាបថា បានដល់ ភាវនា ៣ គឺសីលភាវនា ចិត្តភាវនា បញ្ញាភាវនា ព្រោះកាយភាវនាឈមចុះខាងក្នុងនៃភាវនាទាំង ៣ នោះ ។

ពាក្យថា សីល ( ជាលម្អខាងដើម ) នៃការបដិបត្តិ ជាដើម ដូចគ្នានឹងពាក្យដែលពោលហើយក្នុងកាលមុន ។ ពួកម្រឹគដទៃ រមែងអត់ធន់នឹងការបន្លឺរបស់សីហៈមិនបាន តើអត់ធន់ក្នុងការគំរាមបានដូចម្តេច ត្រឹមតែការបន្លឺរបស់សីហៈនោះឯងរមែងគំរាមពួកម្រឹគទាំងនោះ យ៉ាងណា វាទៈរបស់តិរ្ថិយទាំងឡាយ ក៏យ៉ាងនោះ ទប់ទល់នឹងវាទៈរបស់ព្រះថេរៈមិនបាន តើគ្របសង្កត់បានអំពីណា ដែលពិតវាទៈរបស់ព្រះថេរៈនោះឯង តែងគ្របសង្កត់វាទៈរបស់តិរ្ថិយទាំងនោះ ។ សេចក្តីនោះ ព្រោះហេតុអ្វី ព្រោះថេរវាទប្រព្រឹត្តទៅតាមត្រៃលក្ខណ៍និងគោលធម៌ថា សង្ខារទាំងពួងមិនទៀង សង្ខារទាំងពួងជាទុក្ខ ធម៌ទាំងពួងជាអនត្តាខ្លះ ថា និព្វានជាតុខ្លះ ។ ព្រោះដោយធម្មតាបុគ្គលណាមួយ មិនអាចជំទាស់ឲ្យប្រព្រឹត្តទៅដទៃបានឡើយ ។ ពាក្យណាដែលគប្បីពោលក្នុងសេចក្តីនេះ ពាក្យនោះជាក់ច្បាស់ទៅខាងមុខ ។ ក្នុងទី

*នេះ គប្បីជ្រាបការពង្រីកសេចក្តីនៃគាថាដំបូងដោយសង្ខេបប៉ុណ្ណេះសិន ។*

*ឯក្នុងគាថាទី ២ គប្បីជ្រាបការពង្រីកសេចក្តីដោយបំណងសម្តែងពាក្យដែលសម្ពន្ធគ្នាដូចតទៅនេះថា*

*បុគ្គលបំណងនឹងសូធ្យគាថារបស់ព្រះថេរៈណា បណ្តាព្រះថេរៈទាំងនោះ ដើម្បីប្រារព្ធព្រះថេរៈទាំងនោះ ដោយឈ្មោះ ដោយគោត្រនិងដោយគុណ ដោយអំណាចនៃសាធារណនាម ទើបពោលពាក្យជាដើមថា* **យថានាមា** *ដូច្នេះ ។ តែពោលដោយអសាធារណនាមហើយនិងអធិប្បាយក្នុងគាថានោះៗ ដោយចំពោះ ។*

*បណ្តាបទទាំងនោះ បទថា* **យថានាមា** *សេចក្តីថា មានឈ្មោះដូចម្តេច អធិប្បាយថា ប្រាកដដោយឈ្មោះ ដោយន័យជាដើមថា* **សុភូតិ មហាកោដ្ឋិក** *ដូច្នេះជាដើម ។*

*បទថា* **យថាគោត្តា** *សេចក្តីថា មានគោត្តយ៉ាងណា អធិប្បាយថា ដែលគេស្គាល់ដោយកំណើតដោយប្រារព្ធត្រកូល ដោយន័យថា គោតមគោត្ត កស្សបគោត្ត ជាដើម ។*

*បទថា* **យថាធម្មវិហារិនោ** *សេចក្តីថា មានប្រក្រតីនៅដោយធម៌ណា អធិប្បាយថា មិនតាំងនៅក្នុងភាពជាអ្នកក្រៃលែងដោយបរិយត្តិ គឺមិនដាក់ចិត្តក្នុងគន្ថធុរៈ តែមានប្រក្រតីនៅដោយសមាបត្តិតាមសមគួរ ។*

*ម្យ៉ាងទៀត បទថា* **យថាធម្មវិហារិនោ** *សេចក្តីថា ជាអ្នកមានប្រក្រតីនៅតាមធម្មតា បណ្តាទិព្វវិហារធម៌ជាដើមរឿយៗតាមធម៌ មានសីល ជាដើម*

ណាមួយ គឺទៅជាមួយធម៌ប្រភេទណាមួយ ។

បទថា **យថាធិមុត្តា** សេចក្តីថា មានអធិមុត្តិយ៉ាងណា គឺក្នុងបណ្តា សទ្ធាធិមុត្តិនិងបញ្ញាធិមុត្តិទាំងពីរ មានអធិមុត្តិយ៉ាងណា ម្យ៉ាងទៀត ឈ្មោះថា **យថាធិមុត្តា** ព្រោះបង្អោនទៅកាន់ព្រះនិព្វាន ដោយប្រការណាមួយក្នុងមុខទាំងឡាយ មានសុញ្ញតមុខជាដើម ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ ( ក្នុងធម្មបទ ) ថា **និព្វានំ អធិមុត្តានំ អត្ថំ គច្ឆន្តិ អាសវា** អាសវៈទាំងឡាយរបស់បុគ្គល ( អ្នកភ្ញាក់រឭកសព្វកាល ជាអ្នកសិក្សាត្រៃសិក្ខាទាំងថ្ងៃទាំងយប់ ) មានចិត្តចុះស៊ប់កាន់ព្រះនិព្វាន តែងដល់នូវការតាំងនៅមិនបានឡើយ ដូច្នេះ ។ ពាក្យទាំង ២ នេះ គប្បីជ្រាបដោយអំណាចនៃធម៌ដែលជាបុព្វភាគ ព្រោះថា ការបង្អោនទៅ តាមដែលពោលហើយ នឹងមានក្នុងខណៈមុនបានសម្រេចអរហត្តប៉ុណ្ណោះ បន្ទាប់អំពីនោះទៅក៏មិនមាន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា នរជនណា មិនជឿអ្នកដទៃផង ស្គាល់ព្រះនិព្វានផង កាត់នូវគ្រឿងត គឺ វដ្តៈផង ។ បាឋៈថា **យថាវិមុត្តា** ដូច្នេះក៏មាន សេចក្តីថា ផុតហើយដោយប្រការណាមួយ បណ្តាបញ្ញាវិមុត្តិ និងឧភតោភាគវិមុត្តិ ។

បទថា **សប្បញ្ញា** សេចក្តីថា មានបញ្ញាដោយបញ្ញា ៣ យ៉ាង គឺ តិហេតុកបដិសន្ធិបញ្ញា គឺ បញ្ញាដែលប្រកបដោយហេតុ ៣ ក្នុងបដិសន្ធិកាល ១ បារិហារិកប្បញ្ញា គឺបញ្ញាសម្រាប់រក្សាខ្លួន ១ ភាវនាបញ្ញា គឺបញ្ញាសម្រេចដោយភាវនា ១ ។ បទថា **វិហរឹសុ** សេចក្តីថា នៅហើយដោយផា-

សុវិហារធម៌ តាមដែលពោលហើយនោះឯង ព្រោះភាពជាអ្នកមានបញ្ញា ។

បទថា **អតន្ទិតា** ប្រែថា មិនខ្ជិលច្រអូស អធិប្បាយថា មានការខ្មីឃ្មាត ក្នុងបដិបទាដែលជាប្រយោជន៍ខ្លួន និងក្នុងបដិបទាដែលជាប្រយោជន៍អ្នកដទៃតាមកម្លាំង ។ ក្នុងព្រះគាថានេះ លោកសម្ដែងភាពដែលព្រះថេរៈទាំងនោះប្រាកដដោយការប្រកាសដោយសព្ទថា **ឆាមគោត្ត** ។ សម្ដែងដល់សីលសម្បទា និងសមាធិសម្បទា ដោយសព្ទថា **ព្រហ្មវិហារ** ។ សម្ដែងបញ្ញាសម្បទា ដោយបទថា **យថាធិមុត្តា សបញ្ញា** នេះ ។ សម្ដែងវីរិយសម្បទាដែលជាហេតុនៃសីលសម្បទាជាដើម ដោយបទថា **អតន្ទិតា** នេះ ។ សម្ដែងភាពដែលព្រះថេរៈទាំងនោះមានឈ្មោះដោយការប្រកាស ដោយបទថា **យថានាមា** នេះ ។ សម្ដែងដល់ការប្រជុំនៃសម្បត្តិ គឺពូជពង្សអរិយបុគ្គល មានសទ្ធានុសារីនិងធម្មានុសារី ដោយបទថា **យថាគោត្តា** នេះ ។ សម្ដែងការប្រកបដោយសម្បត្តិ គឺសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញាណទស្សនៈ ដោយបទជាដើមថា **យថាធម្មវិហារិនោ** នេះ ។ សម្ដែងការបំពេញនូវប្រយោជន៍ចំពោះអ្នកដទៃ របស់បុគ្គលដែលតាំងនៅក្នុងអត្តហិតសម្បត្តិហើយ ដោយបទថា **អតន្ទិតា** នេះ ។

ម្យ៉ាងទៀត បទថា **យថានាមា** នេះ សម្ដែងដល់ឈ្មោះ ដែលមាតាបិតាទាំងឡាយដាក់ឲ្យដល់ព្រះថេរៈទាំងនោះ ព្រោះប្រារព្ធត្រឹមតែឈ្មោះ ។ បទថា **យថាគោត្តា** នេះ សម្ដែងដល់ភាពជាកុលបុត្តមានត្រកូល ព្រោះប្រារព្ធចំពោះត្រកូល ។ ដោយបទថា **យថាគោត្តា** នោះ សម្ដែងដល់ភាព

ដែលព្រះថេរៈទាំងនោះបួសដោយសទ្ធា ។ បទថា **យថាធម្មវិហារិនោ** នេះ សម្តែងដល់ចរណសម្បត្តិ ព្រោះសម្តែងដល់ការដល់ព្រមដោយគុណ មានសីលសំវរៈជាដើម ។ បទថា **យថាធិមុត្តា សប្បញ្ញា** នេះ សម្តែងដល់វិជ្ជាសម្បត្តិ របស់ព្រះថេរៈទាំងនោះ ព្រោះសម្តែងដល់ការសម្រេចដោយញាណសម្បត្តិដែលជាទីបំផុតនៃការអស់ទៅនៃអាសវៈ ។ បទថា **អតន្ទិតា** នេះ សម្តែងដល់ឧបាយជាគ្រឿងសម្រេចវិជ្ជាសម្បត្តិនិងចរណសម្បត្តិ ។

ម្យ៉ាងទៀត ដោយបទថា **យថានាមា** នេះ លោកសម្តែងហេតុត្រឹមតែការប្រកាសឈ្មោះនៃព្រះថេរៈទាំងនោះ ។ ឯបទថា **យថាគោត្តា** នេះ លោកសម្តែងដល់សម្បត្តិ គឺចក្ក ២ ខាងចុង ។ ព្រោះការប្រជុំនៃ គោត្តសម្បត្តិរបស់ព្រះអរិយបុគ្គលដែលជាសទ្ធានុសារី និងធម្មានុសារី ដែលមិនបានតម្កល់ខ្លួនទុកប្រពៃ និងមិនបានធ្វើបុណ្យទុកក្នុងកាលមុន មានមិនបានឡើយ ។

ដោយបទថា **យថាធម្មវិហារិនោ** នេះ សម្តែងដល់សម្បត្តិ គឺចក្ក ២ ខាងដើម របស់ព្រះថេរៈទាំងនោះ ព្រោះកាលនៅក្នុងប្រទេសដែលមិនសមគួរក្តី វៀរចាកការគប់រកសប្បុរសក្តី គុណវិសេសទាំងនោះ មានមិនបានឡើយ ។ ដោយបទថា **យថាធិមុត្តា** នេះ សម្តែងដល់ការប្រកបដោយសម្បត្តិគឺការស្តាប់ព្រះសទ្ធម្ម ព្រោះវៀរចាកការប្រកាសរបស់អ្នកដទៃហើយ ការចាក់ធ្លុះនូវសច្ចធម៌របស់សាវកទាំងឡាយមិនមានឡើយ ។ ដោយបទថា **សប្បញ្ញា អតន្ទិតា** នេះ សម្តែងដល់ហេតុនៃការប្រព្រឹត្តខ្ពឺឃ្នាតដើម្បីគុណ

វិសេសតាមដែលពោលហើយ ព្រោះសម្តែងដល់ការផ្តើមរបស់ញាយធម៌ ។

ម្យ៉ាងទៀត បទថា **យថាគោត្តា** នេះ លោកសម្តែងដល់ការដល់ព្រម ដោយយោនិសោមនសិការ របស់ព្រះថេរៈទាំងនោះ ដោយការប្រារព្ធដល់គោត្ត ព្រោះបុគ្គលដែលសម្បូរដោយគោត្តតាមដែលពោលហើយ ទើបកើតយោនិសោមនសិការ ។

ដោយសព្ទថា **ធម្មវិហារ** ក្នុងបទថា **យថាធម្មវិហារិនោ** នេះ លោកសម្តែងដល់ការដល់ព្រមដោយការស្តាប់ព្រះសទ្ធម្ម ព្រោះវៀរចាកការស្តាប់ធម៌ហើយនឹងមិនមានវិហារធម៌នោះបានឡើយ ។ ដោយបទថា **យថាធិមុត្តា** នេះ សម្តែងដល់ការបដិបត្តិធម៌ សមគួរដល់ធម៌ដល់ទីបំផុត ។ ដោយបទថា **សប្បញ្ញា** នេះ សម្តែងដល់ភាពជាអ្នកមានសម្បជញ្ញៈក្នុងទីទាំងពួង ។ ដោយបទថា **អតន្ទិតា** នេះ សម្តែងដល់បុគ្គល ដែលបំពេញអត្តហិតសម្បត្តិឲ្យបរិបូណ៌ តាមន័យដែលពោលហើយ តាំងនៅ ជាអ្នកមិនលំបាកក្នុងការបដិ-បត្តិ ដើម្បីជាប្រយោជន៍និងសេចក្តីសុខដល់អ្នកដទៃ ។

ម្យ៉ាងទៀត ដោយបទថា **យថាគោត្តា** នេះ សម្តែងដល់ការបរិបូណ៌ដោយសរណគមន៍របស់ព្រះថេរៈទាំងនោះ ព្រោះប្រារព្ធដល់ព្រះអរិយៈទាំងឡាយដែលជាសទ្ធានុសារី ។ ដោយបទថា **យថាធម្មវិហារិនោ** នេះ សម្តែងដល់សមាធិក្ខន្ធដែលជាប្រធាននៃសីលក្ខន្ធ ។

គុណរបស់ភិក្ខុសាវកទាំងឡាយ មានសរណគមន៍ជាខាងដើម មានសមាធិជាកណ្តាល មានបញ្ញាជាបរិយោសាន ព្រោះហេតុនោះ គុណរបស់

សាវ័កទាំងអស់ ឈ្មោះថាលោកសម្តែងហើយ ដោយការសម្តែងគុណខាងដើម កណ្តាល និងបរិយោសាន ។

សម្បត្តិនៃគុណនេះ ដែលព្រះថេរៈទាំងឡាយសម្រេចហើយដោយសម្មាបដិបត្តិណា ដើម្បីសម្តែងសម្មាបដិបត្តិនោះ ទើបលោកពោលពាក្យថា **តត្ថ តត្ថ វិបស្សិត្វា** ដូច្នេះជាដើម ។

បទថា **តត្ថ តត្ថ** បានដល់ ក្នុងសេនាសនៈស្ងាត់ មានព្រៃ គល់ឈើនិងភ្នំជាដើមនោះៗ ។ ម្យ៉ាងទៀត បទថា **តត្ថ តត្ថ** បានដល់ ក្នុងពេលដែលលោកឧទានជាដើមនោះៗ ។

បទថា **វិបស្សិត្វា** ប្រែថា ឃើញច្បាស់ហើយ គឺញ៉ាំងទិដ្ឋិវិសុទ្ធិនិងកង្ខាវិតរណវិសុទ្ធិ ដែលកំណត់នាមរូបនិងកំណត់បច្ច័យឲ្យដល់ព្រម សម្រេចវិសុទ្ធិទី ៥ តាមលំដាប់នៃការពិចារណាកលាបៈជាដើម ញ៉ាំងវិបស្សនាឲ្យហើបខ្ពស់ឡើង ដោយអំណាចនៃការសម្រេចដល់កំពូលនៃបដិបទាញាណទស្សនវិសុទ្ធិ ។

បទថា **ផុសិត្វា** ប្រែថា ដល់ហើយ គឺធ្វើឲ្យជាក់ច្បាស់ហើយ ។ បទថា **អច្ចុតំ បទំ** បានដល់ ព្រះនិព្វាន អធិប្បាយថា ព្រះនិព្វាននោះ លោកហៅថា **អច្ចុតំ** ព្រោះជាទីដែលមិនមានចុតិ ដោយព្រះនិព្វាននោះ មានការមិនចុតិជាធម្មតា និងដោយបុគ្គលសម្រេចនិព្វានហើយ មិនមានហេតុដែលឲ្យចុតិ និងហៅថា **បទំ** ព្រោះនិព្វាននោះ មិនលាយដោយសង្ខតធម៌ទាំងឡាយ និងព្រោះជាដែនដែលបុគ្គលប្រាថ្នាព្រះនិព្វាននោះ គប្បីទៅ ។

បទថា **កតកិច្ចំ** បានដល់ ទីបំផុតនៃកិច្ចដែលខ្លួនធ្វើស្រេចហើយ អធិប្បាយថា អរិយមគ្គដែលព្រះយោគាវចរទាំងនោះបានសម្រេចហើយ ឈ្មោះថា ព្រះយោគាវចរធ្វើហើយ ព្រោះមគ្គដែលបច្ច័យរបស់ខ្លួនឲ្យកើតហើយ ឯផលជាទីបំផុតនៃអរិយមគ្គនោះ លោកបំណងយកថាជា **កតកិច្ចំ** គឺទីបំផុតកិច្ចដែលខ្លួនធ្វើហើយ ។ ម្យ៉ាងទៀត សង្ខតធម៌ទាំងឡាយ ឈ្មោះថា ធ្វើហើយ ព្រោះដែលបច្ច័យទាំងឡាយធ្វើហើយគឺឲ្យសម្រេចហើយ ។ ក្នុងទីបំផុតនៃសង្ខតធម៌ដែលបច្ច័យធ្វើហើយ ឈ្មោះថា ព្រះនិព្វាន ព្រោះជាដែនរលាស់ចេញនូវសង្ខតធម៌នោះ ។ នូវទីបំផុតនៃកិច្ចដែលខ្លួនធ្វើសម្រេចហើយនោះ ។

បទថា **បច្ចវេក្ខន្តា** សេចក្តីថា ពិចារណាឃើញអរិយផល និងនិព្វាន គឺបដិបទា ដោយវិមុត្តិញ្ញាណទស្សនៈថា អរិយផលនេះ ដែលអាត្មាអញសម្រេចហើយហ្ន៎ ដោយការសម្រេចអរិយមគ្គ អសង្ខតធាតុ ក៏អាត្មាអញសម្រេចហើយ ។ ម្យ៉ាងទៀត កិច្ច ១៦ យ៉ាង មានបរិញ្ញាកិច្ចជាដើមឯណាដែលព្រះអរិយៈគួរធ្វើ ឈ្មោះថា លោកធ្វើហើយ ព្រោះព្រះអរិយបុគ្គលតាំងនៅក្នុងអគ្គផល ឲ្យសម្រេចហើយ គឺឲ្យសម្រេចអស់ហើយ ដោយអំណាចនៃការចាក់ធ្លុះសច្ចធម៌ ពិចារណានូវសោឡសកិច្ចដែលលោកធ្វើហើយយ៉ាងនេះ ។ ដោយបទថា **បច្ចវេក្ខន្តា** នេះ លោកសម្តែងដល់ការពិចារណាកិលេសដែលលះបានហើយ ។ ចំណែកការពិចារណា ១៩ យ៉ាង មានឥតរបច្ចវេក្ខណៈជាដើម រមែងឈ្មោះថា លោកសម្តែងហើយដោយន័យមុន ។

ពាក្យថា **ឥមំ** ក្នុងបទថា **ឥមមត្ថំ** នេះ លោកពោលដោយបំណងថា

*អត្ថនៃថេរគាថានិងថេរីគាថាទាំងអស់នៅជិតនិងប្រចក្សច្បាស់ ព្រោះខ្លួន ( ព្រះអានន្ទ ) ក្តី ព្រះមហាថេរពួកដទៃដែលជាធម្មសង្គាហកាចារ្យដែលមកប្រជុំគ្នាក្នុងទីនោះក្តី បានដឹងបានឃើញហើយ ។ បទថា* **អត្ថំ** *បានដល់ អត្ថដែលបដិសំយុត្តដោយលោកិយនិងលោកុត្តរ ទាំងដែលបង្អោនទៅកាន់ខ្លួនផងបង្អោនទៅកាន់អ្នកដទៃផង ខ្ញុំនឹងពោលដោយគាថាទាំងឡាយ មានជាដើមថា* **ឆន្នា មេ កុដិកា** *ដូច្នេះជាដើម ។*

*បទថា* **អភាសឹសុ** *សេចក្តីថា ពោលហើយដោយចងជាគាថា ប្រកបសេចក្តីថា អ្នកទាំងឡាយចូរស្តាប់គាថាទាំងឡាយដែលបង្អោនចូលទៅក្នុងខ្លួនរបស់ព្រះថេរៈទាំងនោះ ដែលមានខ្លួនអប់រំហើយដែលខ្ញុំនឹងពោលតទៅ ក្នុងឥឡូវនេះ ។ ព្រះអានន្ទដែលជាធម្មកណ្ឌាគារិកសម្តែងសេចក្តីនេះទុកថា ព្រះមហាថេរៈទាំងនោះ កាលពោលយ៉ាងនេះ ឈ្មោះថា បង្អោនចូលទៅដោយចំណែកមួយនូវសាសនធម៌ ដោយគាថាទាំងឡាយដែលប្រកាសការបដិបត្តិប្រពៃរបស់ខ្លួន និងទូន្មានអ្នកដទៃក្នុងការបដិបត្តិប្រពៃនោះ ដោយការធ្វើឲ្យជាក់ច្បាស់ ហើយគប្បីជ្រាបថា ព្រះអានន្ទ កាលសម្តែងយ៉ាងនោះ រមែងសម្តែងដល់ការលើកតម្កើងព្រះថេរៈទាំងនោះដោយគាថាទាំងនេះ និងសម្តែងនិក្ខេបបទនៃគាថាទាំងនោះទុក ដោយមានពាក្យរបស់ព្រះថេរទាំងនោះ ជាទីមកថា មានគោលពិតប្រាកដ ។*

**អដ្ឋកថា និទានកថា ចប់**

# ឯកនិបាត

## ថេរគាថា ឯកនិបាត បឋមវគ្គ

[ ២ ] នែក្មេង ខ្ទមរបស់អាត្មា បានបិទបាំងហើយ ជាសុខមិនមានខ្យល់ អ្នកចូរបង្អុរតាមសប្បាយចុះ ចិត្តរបស់អាត្មាតម្កល់ទុកល្អហើយ ជាចិត្តរួចស្រឡះ ( ចាកអាសវៈ ) អាត្មាមានព្យាយាមដុតកម្ដៅកិលេសជាប្រក្រតី ម្នាលភ្លៀង អ្នកចូរបង្អុរមកចុះ ។

ឮថា ព្រះសុភូតិត្ថេរមានអាយុ បានពោលគាថា ដោយប្រការដូច្នេះ ។

ព្រះសុភូតិត្ថេរ ។

## ថេរគាថា ឯកនិបាត

## វគ្គទី ១

### អដ្ឋកថា សុភូតិត្ថេរគាថា

[ ២ ] ឥឡូវនេះ នឹងពណ៌នាអត្ថនៃគាថាទាំងឡាយដែលប្រព្រឹត្តទៅហើយ ដោយន័យជាដើមថា **ឆន្នា មេ កុដិកា** ដូច្នេះ ព្រោះហេតុដែលខ្ញុំពោលប្រកាសការប្រព្រឹត្តទៅនៃរឿងរ៉ាវរបស់គាថានោះៗ ការពណ៌នាសេចក្ដីនេះ ទើបប្រាកដ និងដឹងបានងាយ ដូច្នោះ ខ្ញុំនឹងប្រកាសអត្ថុប្បត្តិហេតុទុកក្នុងគាថានោះ ហើយពណ៌នាសេចក្ដី ។

បណ្ដាគាថាទាំងនោះ បទថា **ឆន្នា មេ កុដិកា** ជាដើម មានអត្ថុប្បត្តិហេតុដូចម្ដេច ខ្ញុំនឹងពោលដូចតទៅនេះថា

បានឮមកថា ក្នុងទីបំផុតនៃមួយសែនកប្ប រាប់អំពីភទ្ទកប្បនេះ កាលព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ ដែលជានាថរបស់សត្វលោក មិនទាន់កើតឡើង ទារកម្នាក់កើតហើយដល់ព្រាហ្មណមហាសាល ក្នុងនគរឈ្មោះហង្សវតី ព្រាហ្មណ៍បានដាក់ឈ្មោះទារកនោះថា នន្ទមាណព ។ នន្ទមាណពនោះ ចម្រើនវ័យហើយ រៀននូវត្រៃវេទ កាលមិនឃើញវត្ថុដែលជាសារៈក្នុងត្រៃវេទទើបបួសជាឥសីនៅត្រង់ជើងភ្នំ មួយអន្លើដោយមាណព ៤៤០០០ ដែលជាបរិវាររបស់ខ្លួន ញុំាងសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតហើយបានប្រាប់កម្មដ្ឋានដល់អន្តេវាសិកទាំងឡាយទៀតផង ។ សូម្បីអន្តេវាសិកទាំងនោះក៏បានឈានក្នុងកាលមិនយូរឡើយ ។

សម័យនោះ ព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កើតឡើងហើយក្នុងលោក អាស្រ័យហង្សវតីនគរគង់នៅ ។ ថ្ងៃមួយ ទ្រង់ប្រមើលមើលពួកសត្វក្នុងវេលាទៀបភ្លឺ ឃើញឧបនិស្ស័យនៃអរហត្តរបស់ជដិលដែលជាអន្តេវាសិករបស់នន្ទតាបសនិងការប្រាថ្នានូវតំណែងសាវ័ក ដែលប្រកបទៅដោយអង្គ ២ របស់នន្ទតាបស ទើបទ្រង់ធ្វើការបដិបត្តិសរីរៈអំពីព្រលឹម ទ្រង់កាន់យកបាត្រនិងចីវរ ទ្រង់មិនហៅភិក្ខុណាមួយ យាងទៅឯកអង្គ ដូចសីហៈកាលអន្តេវាសិក របស់នន្ទតាបសបានទៅរកផ្លែឈើហើយ ព្រះសាស្ដាទ្រង់ព្រះតម្រិះថា សូមនន្ទតាបសដឹងភាពជាព្រះពុទ្ធរបស់តថាគត កាលនន្ទតា-

បសកំពុងឃើញនោះឯង ទ្រង់ក៏ចុះអំពីអាកាស ប្រថាប់ឈរត្រង់ផែនដី ។

នន្ទតាបសឃើញពុទ្ធានុភាពនិងភាពបរិបូណ៌នៃព្រះលក្ខណៈ បានពិចារណាមើលតាមមន្តទាយលក្ខណៈ ដឹងថាបុគ្គលប្រកបដោយលក្ខណៈទាំងនេះ បើនៅគ្រប់គ្រងផ្ទះនឹងបានជាស្តេចចក្រពត្តិ បើបួសនឹងបានជាសព្វញ្ញុពុទ្ធកាត់វដ្តៈក្នុងលោកបានជាសមុច្ឆេទ ។ បុរសអាជានេយ្យនេះ ជាព្រះពុទ្ធដោយឥតសង្ស័យ ទើបធ្វើការទទួល ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ក្រាលអាសនៈថ្វាយ ។

ព្រះមានព្រះភាគ ទ្រង់គង់លើអាសនៈដែលតាបសក្រាលថ្វាយហើយ ឯនន្ទតាបស ជ្រើសរើសយកអាសនៈដែលសមគួរដល់ខ្លួន ហើយអង្គុយក្នុងចំណែកម្ខាង ។

សម័យនោះ ជដិល ៤៤០០០ កាន់យកផ្លែឈើ ដែលសម្បូរដោយរសនិងឱជៈ ជាផ្លែឈើប្រណីតមកដល់សម្នាក់អាចារ្យ សម្លឹងមើលអាសនៈដែលព្រះពុទ្ធនិងអាចារ្យអង្គុយហើយ ពោលថា បពិត្រលោកអាចារ្យ ពួកខ្ញុំទាំងឡាយគិតគ្នាថា ក្នុងលោកនេះ មិនមានអ្នកណាធំជាងលោកឡើយ តែបុរសនេះប្រហែលជាធំជាងលោក ។

នន្ទតាបសពោលថា នែបា ពួកអ្នកនិយាយអ្វី ពួកអ្នកបំណងយកគ្រាប់ស្ពៃទៅប្រៀបធៀបនឹងស្តេចភ្នំសិនេរុ ដែលមានកម្ពស់ ១៦៨០០០ យោជន៍ ឬ ពួកអ្នកកុំយកខ្ញុំទៅប្រៀបនឹងព្រះសព្វញ្ញុពុទ្ធឡើយ ។

លំដាប់នោះ តាបសទាំងនោះគិតថា បុរសនេះ បើជាបុគ្គលថោកថយ

អាចារ្យរបស់ពួកយើង គង់មិនឧបមាយ៉ាងនេះ បុរសអាជានេយ្យនេះធំប៉ុនណាហ្ន៎ ដូច្នេះហើយ នាំគ្នាក្រាបចុះទៀបបាទានមស្ការដោយសិរសាគឺត្បូង ។

លំដាប់នោះ អាចារ្យពោលនឹងតាបសទាំងនោះថា នែបាទាំងឡាយ ទេយ្យធម៌ដែលសមគួរ ដល់ព្រះពុទ្ធទាំងឡាយ របស់យើងមិនមាន ព្រះមានព្រះភាគយាងមកក្នុងពេលភិក្ខាចារ ព្រោះហេតុនោះ ពួកយើងនឹងថ្វាយទេយ្យធម៌តាមកម្លាំងសមត្ថភាព ពួកអ្នកចូរនាំយកផ្លែឈើដែលប្រណីត ដែលអ្នកទាំងឡាយបេះមកហើយចុះ ដូច្នេះហើយ ឲ្យនាំយកផ្លែឈើមក លាងដៃរួចដាក់ក្នុងបាត្ររបស់ព្រះតថាគតដោយខ្លួនឯង ។

គ្រាន់តែព្រះសាស្តាទទួលផ្លែឈើប៉ុណ្ណោះ ទេវតាទាំងឡាយក៏ដាក់ឱជះទិព្វចូលទៅ ។ តាបសត្រងទឹកថ្វាយដោយខ្លួនឯង ។

សម័យនោះ កាលព្រះសាស្តាសោយស្រេចហើយ តាបសដែលជាអាចារ្យ ក៏ហៅអន្តេវាសិកទាំងឡាយមក អង្គុយពោលសារាណីយកថា ក្នុងសម្នាក់របស់ព្រះសាស្តា ។

ព្រះសាស្តាត្រិះរិះថា ភិក្ខុទាំងឡាយចូរមក ។ ភិក្ខុទាំងឡាយដែលជាព្រះខីណាស្រពប្រមាណមួយសែនរូប ដឹងនូវការត្រិះរិះរបស់ព្រះសាស្តាហើយ ក៏នាំគ្នាមកថ្វាយបង្គំព្រះសាស្តា ហើយឈរក្នុងចំណែកម្ខាង ។

នន្ទតាបសហៅអន្តេវាសិកទាំងឡាយមកហើយ ពោលថា នែបាទាំងឡាយ អាសនៈដែលព្រះពុទ្ធគង់នៅទាបនៅឡើយ អាសនៈនោះទៀតសោត មិនគ្រប់គ្រាន់ដល់ព្រះសមណៈមួយសែនរូប ថ្ងៃនេះ អ្នកទាំងឡាយ គួរធ្វើ

សក្ការៈដល់ព្រះមានព្រះភាគ និងភិក្ខុសង្ឃឲ្យឧឡារ អ្នកទាំងឡាយចូរនាំផ្កាដែលសម្បូរដោយពណ៌និងក្លិនមកអំពីជើងភ្នំ ។ ព្រោះវិស័យនៃអ្នកមានឫទ្ធិជាអចិន្តេយ្យ តាបសទាំងឡាយនាំផ្កាដែលសម្បូរដោយពណ៌និងក្លិនមកក្នុងកាលមួយរំពេចប៉ុណ្ណោះ ក្រាលនូវអាសនៈផ្កាប្រមាណមួយយោជន៍ថ្វាយព្រះពុទ្ធហើយ ។ សម្រាប់ព្រះអគ្គសាវ័ក មានកម្រាស់ប្រមាណ ៣ គាវុត សម្រាប់ភិក្ខុទាំងឡាយដ៏សេស មានកម្រាស់ប្រមាណកន្លះយោជន៍ ឯសង្ឃនវកមានកម្រាស់ប្រមាណមួយឧសភ[១]កាលតាបសទាំងឡាយ ក្រាលអាសនៈស្រេចហើយយ៉ាងនេះ នន្ទតាបសឈរផ្គងអញ្ជលីខាងមុខព្រះទសពល ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់យាងឡើងកាន់អាសនៈផ្កានេះ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដើម្បីសេចក្តីចម្រើន ដល់ខ្ញុំអស់កាលយូរ ។ ព្រះមានព្រះភាគគង់លើអាសនៈផ្កាហើយ ។ កាលព្រះសាស្តាគង់ហើយយ៉ាងនេះ ភិក្ខុទាំងឡាយដឹងអាការរបស់ព្រះសាស្តាហើយ ទើបអង្គុយលើអាសនៈដែលដល់ហើយដល់ខ្លួន ។

នន្ទតាបសកាន់ឆត្រផ្កាធំ ឈរបាំងថ្វាយលើព្រះសិរសារបស់ព្រះមានព្រះភាគ ។ ព្រះសាស្តាទ្រង់ព្រះតម្រិះថា សក្ការៈរបស់តាបសទាំងឡាយនេះ ចូរមានផលច្រើន ទើបចូលនិរោធសមាបត្តិ ។ ភិក្ខុទាំងឡាយដឹងថាព្រះមុនីចូលសមាបត្តិហើយ ទើបនាំគ្នាចូលសមាបត្តិផងដែរ ។ កាលព្រះតថាគតគង់ចូលនិរោធសមាបត្តិ ៧ ថ្ងៃ កាលដល់ពេលភិក្ខាចារ អន្តេវាសិកទាំងឡាយនាំគ្នាបរិភោគមូលផលាផលក្នុងព្រៃ ក្នុងពេលដ៏សេសក៏ឈរផ្គងអញ្ជ-

លី ចំពោះព្រះសម្មាសម្ពុទ្ធ ។

ឯនន្ទតាបសមិនព្រមទៅបរិភោគ កាន់ឆត្រផ្កាបាំងថ្វាយព្រះសាស្តាញ៉ាំងកាលឲ្យកន្លងទៅដោយ បីតិ សុខ តែម្យ៉ាងអស់ ៧ ថ្ងៃ ។ ព្រះសាស្តាចេញអំពីនិរោធហើយ ត្រាស់ប្រាប់សាវកមួយរូបដែលប្រកបដោយអង្គ ២ គឺអង្គនៃភិក្ខុដែលនៅប្រាសចាកកិលេស និងអង្គនៃភិក្ខុដែលជាទក្ខិណេយ្យថា អ្នកចូរធ្វើអនុមោទនាដល់អាសនៈដែលសម្រេចដោយផ្កា ដល់ពួកឥសី ។ ភិក្ខុរូបនោះមានចិត្តត្រេកអរហើយ ដូចទាហានធំបានទទួលព្រះរាជទានលាភធំអំពីសម្នាក់របស់ស្តេចចក្រពត្តិ តាំងនៅក្នុងវិស័យរបស់ខ្លួនហើយ ពិចារណាពុទ្ធវចនៈ គឺព្រះត្រៃបិដក ធ្វើអនុមោទនា ។ ក្នុងទីបំផុតនៃទេសនារបស់ភិក្ខុនោះ ព្រះសាស្តាក៏ទ្រង់សម្តែងធម៌ដោយព្រះអង្គឯង ។

ក្នុងកាលចប់ទេសនា តាបស ៤៤០០០ សម្រេចអរហត្តហើយ ព្រះសាស្តាទ្រង់លាព្រះហស្តចេញ ត្រាស់ថា អ្នកទាំងឡាយចូរជាភិក្ខុចុះ សក់និងពុកមាត់របស់តាបសទាំងនោះក៏អន្តរធានទៅក្នុងពេលនោះឯង ។ បរិក្ខារ ៨ ស្រោបហើយក្នុងកាយរបស់តាបសទាំងនោះ គ្រប់គ្រាន់ ។ តាបសទាំងនោះ ដូចព្រះថេរៈមានវស្សា ៦០ ចោមរោមព្រះសាស្តាហើយ ឯនន្ទតាបសមិនបានសម្រេចគុណវិសេស ព្រោះមានចិត្តរាយមាយ ។ បានឮថា តាបសនោះ ចាប់តាំងពីផ្តើមស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះថេរៈដែលជាអ្នកនៅប្រាសចាកកិលេស បានកើតចិត្តប្បាទឡើងថា ឱហ្ន៎ ! អញគប្បីបានធុរៈ ដែលសាវកនេះបានហើយ ក្នុងសាសនារបស់ព្រះពុទ្ធដែលកើតឡើង ក្នុងអនាគត

កាល ។

ដោយបរិវិតក្កនោះ នន្ទតាបស មិនអាចធ្វើការបាក់ចុះមគ្គផលបាន ។ តាបសបានថ្វាយបង្គំព្រះសុគត ហើយឈរចំពោះព្រះភក្ត្រ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុដែលធ្វើអនុមោទនានូវអាសនៈដែលធ្វើអំពីផ្កា ចំពោះឥសីនេះ មានឈ្មោះដូចម្តេច ក្នុងសាសនារបស់ព្រះអង្គ ព្រះសាស្តាត្រាស់ថា ភិក្ខុនោះ ឈ្មោះថា ជាអ្នកដល់នូវឯតទគ្គៈ ក្នុងអង្គនៃភិក្ខុដែលនៅដោយមិនមានកិលេស និងក្នុងអង្គនៃភិក្ខុដែលជាទក្ខិណេយ្យបុគ្គល ។ ឥសីបានធ្វើសេចក្តីប្រាថ្នាទុកថា បពិត្រព្រះអង្គដ៏ចម្រើន សក្ការៈនេះដែលខ្ញុំចូលទៅទ្រទ្រង់ទុកនូវឆត្រផ្កាអស់ ៧ ថ្ងៃ ធ្វើហើយ ដោយអធិការនោះ ខ្ញុំព្រះអង្គមិនប្រាថ្នាសម្បត្តិដទៃក្នុងអនាគតកាល ខ្ញុំព្រះអង្គគប្បីជាសាវ័កដែលប្រកបដោយអង្គ ២ ដូចព្រះថេរៈនេះ ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយចុះ ។ ព្រះសាស្តាទ្រង់បញ្ជូនអនាគតំសញ្ញាណ ពិចារណាមើលថា សេចក្តីប្រាថ្នារបស់តាបសនេះនឹងសម្រេចឬហ្ន៎ ទ្រង់ប្រមើលមើល ទ្រង់ឃើញសេចក្តីប្រាថ្នារបស់តាបស សម្រេចដោយកន្លងទៅមួយសែនកប្ប ទើបត្រាស់នឹងនន្ទតាបសថា សេចក្តីប្រាថ្នារបស់អ្នកមិនឥតអំពើឡើយ ក្នុងអនាគតកាលកន្លងទៅមួយសែនកប្ប ព្រះពុទ្ធព្រះនាមថាគោតមកើតឡើងក្នុងលោក សេចក្តីប្រាថ្នារបស់អ្នក នឹងសម្រេចក្នុងសម្នាក់របស់ព្រះពុទ្ធព្រះនាមថាគោតមនោះ ហើយត្រាស់ធម្មកថា ទ្រង់ចោមរោមដោយភិក្ខុសង្ឃ ហើយយាងទៅតាមអាកាស ។

នន្ទតាបស ក៏ឈរផ្គងអញ្ជលីឧទ្ទិសចំពោះព្រះសាស្តានិងភិក្ខុសង្ឃរហូតដល់ដាច់កន្ទុយភ្នែក ។ ក្នុងកាលតមក តាបសចូលទៅគាល់ព្រះសាស្តា ស្តាប់ធម៌តាមកាល មានឈានមិនវិនាសធ្វើកាលកិរិយាកើតក្នុងព្រហ្មលោក កាលចុតិអំពីព្រហ្មលោកនោះបួស ៥០០ ជាតិ ជាអ្នកមានការនៅព្រៃជាវត្ត ។ ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធព្រះនាមថាកស្សបៈក៏បានបួស ជាអ្នកមានការនៅព្រៃជាវត្ត បំពេញគតបច្ចាគតវត្តឲ្យបរិបូណ៌ហើយ ។ បានឮថា បុគ្គលដែលមិនបានបំពេញវត្តនេះ ឈ្មោះថា សម្រេចដល់ភាពជាមហាសាវ័កបានមិនមានឡើយ ។ ឯគតបច្ចាគតវត្ត គប្បីជ្រាបតាមន័យដែលពោលក្នុងអដ្ឋកថា នៃសូត្រទាំងឡាយចុះ ។ លោកបំពេញគតបច្ចាគតវត្តអស់ ២០០០០ ឆ្នាំ ធ្វើកាលកិរិយាហើយ កើតក្នុងស្ថានតាវត្តិង្សនាទេវលោកជាន់កាមាវចរសមដូចពាក្យដែលលោកពោលក្នុងអបទានថា

មានភ្នំមួយឈ្មោះនិសភៈ នៅជិតព្រៃហិមពាន្ត អាស្រមរបស់ខ្ញុំ ទាំងបណ្ណសាលារបស់ខ្ញុំគេសង់ល្អហើយក្បែរភ្នំនោះ ។ ក្នុងកាលនោះ ខ្ញុំជាជដិលឈ្មោះ កោសិយៈ មានតបៈដ៏ឧក្រិដ្ឋប្រព្រឹត្តតែម្នាក់ឯង ឥតមានបុគ្គលជាទីពីរ អាស្រ័យនៅនាភ្នំនិសភៈ ។ ខ្ញុំមិនបរិភោគផ្លែឈើ មើមឈើនិងស្លឹកឈើទេ ខ្ញុំចិញ្ចឹមជីវិតដោយផ្លែឈើជ្រុះឯង ក្នុងវេលាព្រឹក ។ ខ្ញុំស៊ូលះបង់ជីវិត មិនញ៉ាំងអាជីវៈឲ្យកម្រើក ខ្ញុំញ៉ាំងចិត្តរបស់ខ្លួនឲ្យរីករាយ ចៀសវាងនូវអនេសនៈ ។ ចិត្តរបស់ខ្ញុំប្រកបដោយរាគៈ

កើតឡើងក្នុងកាលណា ខ្ញុំពិចារណាដោយខ្លួនឯង ខ្ញុំតែម្នាក់ឯង ទូន្មាននូវចិត្តនោះក្នុងកាលនោះថា អ្នកឯងនៅតែត្រេកអរក្នុងអារម្មណ៍ដែលគប្បីត្រេកអរផង ប្រទូស្តក្នុងអារម្មណ៍ដែលគប្បីប្រទូស្តផង វង្វេងក្នុងអារម្មណ៍ដែលគប្បីវង្វេងផង អ្នកចូរចៀសចេញចាកព្រៃទៅ ។ ប្រទេសនេះ ជាលំនៅរបស់ពួកបុគ្គលជាអ្នកស្អាត ដែលមិនមានមន្ទិល មានតបធម៌ អ្នកកុំប្រទូស្តទីស្អាតនេះឡើយ អ្នកចូរចៀសចេញចាកព្រៃទៅ ។ បើអ្នកជាគ្រហស្ថនឹងបាននូវគូប្រកបក្នុងកាលណា អ្នកកុំធ្វើជនទាំងពីរនាក់ឲ្យអាក់អន់ឡើយ ( ក្នុងកាលនោះ ) អ្នកចូរចៀសចេញចាកព្រៃទៅ ។ ឧសដែលគេដុតសាកសពហើយ ជារបស់ធ្វើកិច្ចមិនបានក្នុងទីណាមួយ គឺមិនបានការក្នុងស្រុក ឬក្នុងព្រៃ ព្រោះថាឧសនោះ គេមិនសន្មតថាជាឧសឡើយ យ៉ាងណាមិញ ។ អ្នកឯងទុកដូចជាឧសដែលគេដុតសាកសព គឺមិនមែនជាគ្រហស្ថ មិនមែនជាបព្វជិតសង្រួមទេ ជាមនុស្សផុតចាកភេទទាំងពីរក្នុងថ្ងៃនេះអ្នកចូរចៀសចេញចាកព្រៃទៅ ។ ក្រែងអ្នកគប្បីមានអំពើនុ៎ះឬ ព្រោះអ្នកណានឹងដឹងនូវអំពើរបស់អ្នកនេះ អ្នកនឹងនាំទៅនូវធុរៈចាកភាពនៃយើង ដែលជាអ្នកច្រើនដោយសេចក្តីខ្ជិលច្រអូសយ៉ាងដាច់ ។ អ្នកប្រាជ្ញទាំងឡាយនឹងខ្ពើមរអើមអ្នក ដូចអ្នកក្រុងខ្ពើមរអើមវត្ថុមិនស្អាត ឥសី

ទាំងឡាយនឹងកោះហៅអ្នកមកចោទសព្វៗកាល ។ អ្នកប្រាជ្ញទាំងឡាយនឹងតិះដៀលអ្នកថា ជាមនុស្សប្រព្រឹត្តកន្លងសាសនា អ្នកកាលមិនបានទៅរួមជាមួយ ( នឹងអ្នកប្រាជ្ញទាំងឡាយ ) តើនឹងរស់នៅដូចម្តេច ។ ដំរីមានកម្លាំងចូលទៅជិតដំរីដ៏ប្រសើរ មានអាយុ ៦០ ទើបថយកម្លាំង ចុះប្រេងដោយចំណែក ៣ ហើយ បណ្តេញដំរី ( ទុំះ ) ចាកហ្វូង ។ ដំរីទុំះ កាលត្រូវដំរីមានកម្លាំងបណ្តេញចេញចាកហ្វូងហើយ រមែងស្ងប់ស្ងៀម មិនបានសុខស្រួលទេជាសត្វដល់នូវសេចក្តីទុក្ខចិត្តសញ្ជប់សញ្ជឹង ញាប់ញ័រយ៉ាងណា ។ ពួកជដិលនឹងបណ្តេញអ្នកឯងដែលមានគំនិតអាក្រក់ចេញ អ្នកឯង ត្រូវពួកជដិលទាំងនោះបណ្តេញចេញហើយ រមែងស្ងប់ស្ងៀម មិនបានសុខស្រួលទេក៏យ៉ាងនោះឯង ។ អ្នកឯងកំពុងពោរពេញដោយសរ គឺសេចក្តីសោក ឆេះរោលរាល ព្រោះសេចក្តីក្តៅក្រហាយ ទាំងថ្ងៃទាំងយប់ ដូចជាដំរីចុះប្រេងដែលត្រូវ ដំរីមានកម្លាំងបណ្តេញចាកហ្វូង ។ ជាតរូបក្លែងក្លាយ ចាយមិនដាច់ក្នុងទីណាមួយយ៉ាងណា អ្នកឯងជាបុគ្គលសាបសូន្យចាកសីល នឹងចាយមិនដាច់ក្នុងទីណាមួយ យ៉ាងនោះដែរ ។ អ្នកឯងកាលបើនៅគ្រប់គ្រងផ្ទះនឹងរស់នៅដូចម្តេចបាន ព្រោះទ្រព្យជារបស់នៃមាតាក្តី ជារបស់នៃបិតាក្តីដែលអ្នកបម្រុងទុកមិនមានទេ ។ អ្នកឯងលុះ

តែធ្វើការងាររបស់ខ្លួនហើយញ៉ាំងញើសក្នុងខ្លួនឲ្យហូរចេញ ទើបនឹងរស់នៅក្នុងផ្ទះបាន ហេតុនោះ ខ្ញុំសូមអង្វរ អ្នកកុំគាប់ចិត្តនឹងការងារនោះឡើយ ។ ខ្ញុំឃាត់នូវចិត្តដែលដល់នូវសេចក្តីសៅហ្មង ក្នុងទីនោះយ៉ាងនេះហើយ ខ្ញុំធ្វើនូវធម្មកថាផ្សេងៗ ហើយឃាត់ចិត្តចាកអំពើអាក្រក់ ។ កាលបើខ្ញុំនៅដោយសេចក្តីមិនប្រហែសយ៉ាងនេះ ៣០ ពាន់ឆ្នាំរបស់ខ្ញុំ កន្លងហើយក្នុងព្រៃ ។ ព្រះបទុមុត្តរសម្ពុទ្ធ ទ្រង់ឃើញខ្ញុំ ជាអ្នកស្វែងរកនូវប្រយោជន៍ដ៏ឧត្តម ដោយសេចក្តីមិនប្រហែស ហើយស្តេចមកកាន់សំណាក់នៃខ្ញុំ ។ កាលនោះ ព្រះពុទ្ធមានពន្លឺដូចជាសម្បុរនៃផ្លែទន្លាប់ នឹងប្រមាណមិនបាន មិនមានគ្រឿងប្រៀបមិនមានរូបដទៃប្រាកដស្មើ ដោយព្រះរូប ( របស់ព្រះអង្គ ) ទ្រង់ចង្ក្រម ឰដ៏អាកាស ។ កាលនោះ ព្រះពុទ្ធមិនមានអ្វីប្រាកដស្មើដោយញាណ ទ្រង់ចង្ក្រមឰដ៏អាកាសដូចជាសាលព្រឹក្ស ដែលមានផ្ការីកល្អ ពុំនោះសោត ដូចផ្លេកបន្ទោរក្នុងចន្លោះនៃដុំពពក ។ កាលនោះ ព្រះពុទ្ធទ្រង់ចង្ក្រមឰដ៏អាកាសដូចជាស្តេចសីហៈ មិនមានសេចក្តីព្រឺព្រួច ឬដូចស្តេចដំរីដែលគេហាត់បានហើយ ពុំនោះសោតដូចស្តេចខ្លាដែលមិនមានសេចក្តីខ្លាច ។ គ្រានោះ ព្រះសម្ពុទ្ធមានរស្មីដូចមាសត្តោរឈ្មោះសិង្គិឬដូចរងើកភ្លើងឧសគគីរ ពុំនោះសោត ដូចកែវមណីមាន

រស្មីដ៏រុងរឿង ទ្រង់ចង្រ្កមឰដ៏អាកាស ។ គ្រានោះព្រះសម្ពុទ្ធ ដូចភ្នំកៃលាសដ៏បរិសុទ្ធ ឬដូចព្រះចន្ទក្នុងថ្ងៃពេញបូណ៌មី ពុំនោះសោត ដូចព្រះអាទិត្យតាំងនៅក្នុងទីពាក់កណ្ដាល ( ថ្ងៃត្រង់ ) ទ្រង់ចង្រ្កមឰដ៏អាកាស ។ គ្រានោះ ខ្ញុំឃើញព្រះសម្ពុទ្ធ ដែលកំពុងចង្រ្កមឰដ៏អាកាស ក៏គិតយ៉ាងនេះថា សត្វនេះជាទេវតាឬ ឬថាសត្វនេះជាមនុស្ស ។ នរៈបែបនេះលើផែនដីខ្ញុំមិនដែលឮ មិនដែលឃើញ ទំនងជាមានចំណែកនៃមន្ត្រ សត្វនេះប្រហែលជាសាស្ដា ។ ខ្ញុំលុះគិតយ៉ាងនេះហើយ ក៏ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា គ្រានោះខ្ញុំប្រមូលផ្កាផ្សេងៗ និងគ្រឿងក្រអូប ។ ខ្ញុំក្រាលបុប្ផាសនៈដ៏វិចិត្រល្អ ដែលជាទីរីករាយនៃចិត្ត ហើយពោលពាក្យនេះទៅរកព្រះមានព្រះភាគ ជាសារថីនៃនរជនដ៏ប្រសើរថា បពិត្រព្រះអង្គមានព្យាយាម អាសនៈដែលខ្ញុំព្រះអង្គក្រាលហើយនេះ សមគួរដល់ព្រះអង្គ សូមព្រះអង្គញុំាងចិត្តខ្ញុំព្រះអង្គឲ្យរីករាយ ហើយគង់លើអាសនៈ ជាវិការៈនៃផ្កា ។ ព្រះមានព្រះភាគ ទ្រង់គង់លើអាសនៈជាវិការៈនៃផ្កាដ៏ប្រសើរនោះអស់ ៧ យប់ ៧ ថ្ងៃ ដូចជាកេសររាជសីហ៍ ឥតតក់ស្លុតឡើយ ខ្ញុំបានឈរនមស្ការអស់ ៧ យប់ ៧ ថ្ងៃ ។

ព្រះសាស្ដា ព្រះអង្គប្រសើរក្នុងលោក ទ្រង់ចេញចាកស-

មាធិ កាលនឹងទ្រង់សំដែងនូវអំពើរបស់ខ្ញុំ ទ្រង់ត្រាស់ដូច្នេះថា អ្នកបូរបម្រើននូវពុទ្ធានុស្សតិ ដែលជាគុណជាតិដ៏ប្រសើរជាងការបម្រើននូវអនុស្សតិទាំងឡាយដទៃ ។ លុះអ្នកបម្រើននូវពុទ្ធានុស្សតិនេះហើយនឹងបានញុំាងចិត្តឲ្យពេញ នឹងរីករាយក្នុងទេវលោកអស់ ៣០ ពាន់កប្ប ។ អ្នកនឹងបានសោយទេវរាជ្យជាធំជាងទេវតាអស់ ៨០ ដង នឹងបានជាស្តេចចក្រពត្តិក្នុងដែនអស់មួយពាន់ដង ។ នឹងបានជាស្តេចក្នុងប្រទេសដ៏ធំទូលាយ សោយនូវសម្បត្តិទាំងអស់នោះ រាប់បានមួយអ-សង្ខេយ្យកប្ប នេះជាផលនៃពុទ្ធានុស្សតិ ។ អ្នកកាលបើអន្ទោលទៅក្នុងភពតូច និងភពធំ នឹងបាននូវភោគៈដ៏ច្រើន ការខ្វះខាតដោយភោគៈទាំងឡាយរបស់អ្នកមិនមានឡើយ នេះជាផលនៃពុទ្ធានុស្សតិ ។ លុះកន្លងទៅមួយសែនកប្ប ព្រះសាស្តាព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងឡើងក្នុងលោក ។ អ្នកនឹងលះបោលនូវទ្រព្យ ៨០ កោដិនិងពួកទាសកម្មករជាច្រើន ហើយទៅបួសក្នុងសាសនា របស់ព្រះមានព្រះភាគព្រះនាមគោតមនោះ ។ អ្នកមានឈ្មោះថា សុភូតិ នឹងញុំាងព្រះសម្ពុទ្ធ ព្រះនាមគោតម ទ្រង់ប្រសើរជាងពួកសក្យៈ ឲ្យប្រោសប្រាណ ហើយនឹងបានជាសាវកនៃព្រះសាស្តា ។ ព្រះគោតមសម្ពុទ្ធ ទ្រង់គង់ក្នុងកណ្តាលនៃភិក្ខុសង្ឃ ហើយទ្រង់

តាំងអ្នកថាជាភិក្ខុប្រសើរ ក្នុងឋានៈទាំងពីរ គឺក្នុងពួកនៃទក្ខិ-ណេយ្យបុគ្គល ១ ក្នុងការនៅមិនមានកិលេស ( ដោយធម្មទេសនា ) ១ ។

ព្រះសម្ពុទ្ធជាអ្នកប្រាជ្ញ ជានាយក ព្រះនាមបទុមុត្តរៈ លុះត្រាស់នូវពាក្យនេះហើយ ទ្រង់ហោះឡើងកាន់អាកាស ដូចស្តេចហង្សហើរទៅឰដ៏អាកាស ។ ខ្ញុំដែលព្រះលោកនាថទ្រង់ប្រៀនប្រដៅហើយ ក៏មានចិត្តរីករាយ នមស្ការព្រះតថាគតហើយចម្រើនពុទ្ធានុស្សតិដ៏ឧត្តមសព្វៗកាល ។ ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងតាវត្តិង្សទេវលោកដោយសារកុសលកម្មដែលខ្ញុំធ្វើល្អហើយនោះផង ដោយការតម្កល់ចេតនានោះផង ។ ខ្ញុំបានសោយទេវរាជ្យ ជាធំជាងទេវតាអស់ ៨០ ដង បានជាស្តេចចក្រពត្តិអស់មួយពាន់ដង ។ ខ្ញុំសោយរាជ្យក្នុងប្រទេសដ៏ធំទូលាយ ជាសម្បត្តិដ៏ប្រពៃ រាប់បានមួយអសង្ខេយ្យជាតិ នេះជាផលនៃពុទ្ធានុស្សតិ ។ ខ្ញុំកាលអន្ទោលទៅក្នុងភពតូច និងភពធំ តែងបាននូវភោគៈដ៏ច្រើន ការខ្វះខាតដោយភោគៈរបស់ខ្ញុំមិនមានឡើយ នេះជាផលនៃពុទ្ធានុស្សតិ ។ ក្នុងកប្បទីមួយសែនអំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធានុស្សតិ ។ បដិសម្ភិទា ៤

វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ
ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុក្ខតិត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

បានឮថា ព្រះសុក្ខតិបានពោលគាថាទាំងនេះ ដោយប្រការដូច្នេះឯង ។

នន្ទតាបសនោះ សោយទិព្វសម្បត្តិដោយការកើតស្លាប់អន្ទោលទៅមកក្នុងភពតាវត្តិង្សច្យុតិអំពីភពតាវត្តិង្សហើយ មកកើតជាស្ដេចចក្រពត្តិនិងស្ដេចបទេសរាជក្នុងមនុស្សលោករាប់បាន ១០០០ ដង សោយមនុស្សសម្បត្តិដ៏ឧឡារ ។ តមក ក្នុងសាសនាព្រះមានព្រះភាគនៃយើង មកកើតជាប្អូនប្រុសរបស់អនាថបិណ្ឌិកសេដ្ឋី ក្នុងផ្ទះរបស់សុមនសេដ្ឋី ក្នុងក្រុងសាវត្ថីមានឈ្មោះថា សុក្ខតិ ។

សម័យនោះ ព្រះមានព្រះភាគនៃយើង ទ្រង់កើតឡើងក្នុងលោក ទ្រង់ប្រកាសធម្មចក្រ យាងទៅកាន់ក្រុងរាជគ្រឹះតាមលំដាប់ ទ្រង់ធ្វើនូវការអនុគ្រោះដល់សត្វលោក ដោយការទទួលព្រះវិហារវេឡុវ័នជាដើម ក្នុងក្រុងរាជគ្រឹះនោះ អាស្រ័យនគររាជគ្រឹះគង់នៅក្នុងព្រៃសីតវ័ន ។ គ្រានោះ អនាថបិណ្ឌិកសេដ្ឋី នាំវត្ថុដែលផលិតក្នុងនគរសាវត្ថីទៅកាន់ផ្ទះរបស់រាជគហសេដ្ឋីដែលជាសម្លាញ់របស់ខ្លួន បានដំណឹងការកើតឡើងនៃព្រះពុទ្ធ ក៏ចូលទៅគាល់ព្រះសាស្ដាដល់ទីគង់ក្នុងព្រៃសីតវ័ន តាំងនៅក្នុងសោតាបត្តិផលដោយការចូលទៅគាល់លើកទី ១ ហើយទូលឲ្យព្រះសាស្ដា យាងមកក្រុងសាវត្ថី

ទៀត ឲ្យសាងវិហារមួយយោជន៍មួយកន្លែងក្នុងចម្ងាយផ្លូវ ៤៥ យោជន៍ អំពីនគរសាវត្ថីនោះ ដោយបរិច្ចាគទ្រព្យមួយកន្លែងមួយសែន ហើយទិញឧទ្យានរបស់ព្រះរាជកុមារព្រះនាមថា ជេតៈ ប្រមាណ ៨ ករីស ដោយមាត្រាព្រះរាជា ដោយការយកប្រាក់ក្រាលក្នុងផ្ទៃដីរាប់កោដិ ។ ក្នុងថ្ងៃដែលព្រះសាស្តាទទួលព្រះវិហារ សុភូតិកុដុម្ពិកៈនោះ បានទៅមួយអន្លើដោយអនាថបិណ្ឌិក ស្តាប់ធម្មទេសនាហើយ មានសទ្ធាជ្រះថ្លាបព្វជ្ជាហើយ ។

លោកបួសហើយ ធ្វើមាតិកា ២ ឲ្យស្ទាត់ ឲ្យអាចារ្យប្រាប់កម្មដ្ឋាន បំពេញសមណធម៌ក្នុងព្រៃ ចម្រើនវិបស្សនា មានមេត្តាឈានជាបាទ សម្រេចអរហត្តហើយ ។ ព្រោះកាលលោកសម្តែងធម៌ រមែងសម្តែងធម៌ មិនឧទ្ទិសចំពោះ ( មិនបៀតបៀនបុគ្គល ) តាមទំនងដែលព្រះសាស្តាទ្រង់សម្តែងហើយ ដូច្នោះ ទើបលោកបាននាមថា ជាអ្នកកំពូលជាងភិក្ខុដែលនៅដោយមិនមានកិលេស ។ កាលត្រាច់បិណ្ឌបាត ក៏ចូលមេត្តាឈានគ្រប់ៗផ្ទះ ចេញអំពីឈានហើយទើបទទួលភិក្ខាដោយគិតថា ដោយវិធីនេះទាយកទាំងឡាយនឹងមានផលច្រើន ។ ព្រោះហេតុនោះ ទើបលោកឈ្មោះថា ជាកំពូលលើសភិក្ខុទាំងឡាយខាងទក្ខិណេយ្យបុគ្គល ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកនៅដោយឥតកិលេសដែលជាសាវករបស់តថាគតស្រេចនឹងសុភូតិ ។ ពួកភិក្ខុអ្នកគួរដល់ទក្ខិណាទានស្រេចនឹងសុភូតិ ដូច្នេះ ។

ព្រះមហាថេរៈ តាំងនៅក្នុងអរហត្តផលហើយ ដល់នូវទីបំផុតនៃផលនៃ

បារមីដែលលោកបានបំពេញមក ជាអ្នកឈ្លាសប្រតិពលក្នុងលោក ត្រាច់ចារិកទៅតាមជនបទ ដើម្បីបំពេញប្រយោជន៍ដល់មហាជន ដល់ក្រុងរាជគ្រឹះ ហើយដោយលំដាប់ ដោយប្រការដូច្នេះ ។

ព្រះបាទពិម្ពិសារ ទ្រង់ស្តាប់ការមករបស់ព្រះថេរៈហើយ យាងទៅរកថ្វាយបង្គំហើយត្រាស់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់គង់នៅក្នុងទីនេះចុះ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អញនឹងសាងទីលំនៅប្រគេនព្រះថេរៈ លុះទ្រង់យាងទៅហើយក៏ភ្លេច ។ ព្រះថេរៈកាលមិនបានសេនាសនៈ ក៏ញុំាងកាលវេលាឲ្យកន្លងទៅដោយអព្ភោកាស ( គង់ក្នុងទីវាល ) ដោយអានុភាពរបស់ព្រះថេរៈ ភ្លៀងមិនធ្លាក់ឡើយ ។

មនុស្សទាំងឡាយ ត្រូវភាពរីងរាំងបៀតបៀនគំរាម ទើបនាំគ្នាទៅយំរៀបរាប់ត្រង់ទ្វារព្រះរាជវាំង របស់ព្រះរាជា ។ ព្រះរាជាទ្រង់ពិចារណាមើលថា ដោយហេតុអ្វីហ្ន៎ ទើបភ្លៀងមិនធ្លាក់ ហើយទ្រង់ព្រះតម្រិះថា ប្រហែលជាព្រះថេរៈនៅកណ្តាលវាល ទើបភ្លៀងមិនធ្លាក់ ទើបត្រាស់ឲ្យគេធ្វើកុដិប្រក់ដោយស្បូវ ប្រគេនព្រះថេរៈ ហើយត្រាស់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់គង់ក្នុងបណ្ណកុដិនេះឯង ថ្វាយបង្គំហើយចៀសចេញទៅ ។

ព្រះថេរៈចូលទៅកាន់កុដិ ហើយអង្គុយពត់ភ្នែនលើអាសនៈដែលក្រាលដោយស្មៅ ក្នុងកាលនោះ ភ្លៀងក៏ធ្លាក់ចុះមកតិចៗ ធ្លារទឹកមិនសើមទូទៅលំដាប់នោះ ព្រះថេរៈបំណងនឹងកម្ចាត់នូវភ័យ ដែលកើតអំពីគ្រោះរាំងស្ងួតដល់សត្វលោក ទើបប្រកាសការមិនមានអន្តរាយដែលជាវត្ថុខាងក្នុងនិងខាង

ក្រៅ ទើបពោលគាថាថា

នៃក្មៀង ខ្ទមរបស់អាត្មាបានបិទបាំងហើយ ជាសុខមិនមានខ្យល់ អ្នកចូរបង្អុរតាមសប្បាយចុះ ចិត្តរបស់អាត្មាតម្កល់ទុកល្អហើយ ជាចិត្តរួចស្រឡះ ( ចាកអាសវៈ ) អាត្មាមានព្យាយាមដុតកម្តៅកិលេសជាប្រក្រតី ម្នាលភ្លៀងអ្នកចូរបង្អុរមកចុះ ដូច្នេះ ។

**ឆន្ន** សព្ទ ក្នុងគាថានោះ មកហើយក្នុងអត្ថថា សម ដូចក្នុងប្រយោគជាដើមថា **ឆន្នា សា កុមារិកា ឥមស្ស កុមារកស្ស** ប្រែថា នាងកុមារីនោះ សមគ្នានឹងកុមារនេះណាស់ ដូច្នេះ ។ និងដូចក្នុងប្រយោគ ជាដើមថា **នច្ឆន្នំ នប្បដិរូបំ** ប្រែថា មិនសមគួរ មិនត្រូវបែប ដូច្នេះ ។

ប្រើក្នុងអត្ថថា ការរាប់បែបពិសេស គឺធ្វើពាក្យឲ្យពីរោះ ដូចក្នុងប្រយោគ ជាដើមថា **ឆន្នំ តេវ ផគ្គុន ឆស្សាយតនានំ** ម្នាលផគ្គុន ឯការរលត់នៃផស្សៈ ( ព្រោះការរលត់ឥតមានសេសសល់ ) នៃ ផស្សាយតនៈទាំង ៦ ដូច្នេះ ។

ប្រើក្នុងអត្ថថា បិទបាំង ដូចក្នុងប្រយោគជាដើមថា **ឆន្នមតិវស្សតិ វិវដំ នាតិវស្សតិ** ប្រែថា ភិក្ខុត្រូវអាបត្តិហើយ បើកអាបត្តិ មិនត្រូវអាបត្តិដទៃទៀត ដូច្នេះ ។

មកក្នុងអត្ថថា ស្លៀកដណ្តប់ ដូចក្នុងប្រយោគជាដើមថា **ក្យាហំ តេន អច្ឆន្នោបិ ករិស្សាមិ** ប្រែថា អាត្មានឹងធ្វើខ្លួនឲ្យជាអ្នកស្លៀកដណ្តប់នូវចីវរ

នោះ ដូចម្ដេចបាន ដូច្នេះ ។

ប្រើក្នុងអត្ថថា បញ្ញត្ត ( ឈ្មោះ ) ដូចក្នុងប្រយោគជាដើមថា **អាយស្មា ចន្ទោ អនាចារំ អាចរតិ** ប្រែថា ចន្ទដ៏មានអាយុ តែងតែប្រព្រឹត្ត អនាចារ ដូច្នេះ ។

ប្រើក្នុងអត្ថថា ប្រក់បាំង ដោយស្មៅជាដើម ដូចក្នុងប្រយោគជាដើមថា **សព្វច្ឆន្នា សព្វបរិច្ឆន្នា** ប្រែថា ទីដែលគេប្រក់ទាំងអស់ដែលគេបិទបាំងទាំងអស់ និងដូចប្រយោគថា **ឆន្នា កុដិ អាហិតោ គិនិ** ប្រែថា ខ្ទមយើងបានប្រក់ហើយ ភ្លើងក៏បង្កាត់ហើយ ដូច្នេះ ។ ក្នុងគាថានេះគប្បីជ្រាបថា មកក្នុងអត្ថថា ប្រក់បាំងដោយស្មៅជាដើម តែម្យ៉ាង ព្រោះហេតុនោះ ទើបមានអធិប្បាយថា កុដិដែលប្រក់ហើយដោយស្មៅឬស្លឹកឈើ ឈ្មោះថា ប្រក់បាំងល្អហើយនោះឯង ដោយប្រការដែលភ្លៀងមិនលិច គឺភ្លៀងមិនស្រក់មក បានដល់ លិចមិនបានឡើយ ។

**មេ** សព្ទ ប្រើក្នុងអត្ថ ករណៈ គឺតតិយាវិភត្តិ ដូចក្នុងប្រយោគជាដើមថា **កិច្ឆេន មេ អធិគតំ ហលន្ទានិ បកាសិតុំ** ប្រែថា ឥឡូវនេះ តថាគតគួរនឹងសម្ដែងធម៌ដែលតថាគតបានត្រាស់ដឹងដោយកម្រ ដូច្នេះ អធិប្បាយថា មានអត្ថស្មើគ្នានឹង **មយា** ប្រែថា ដែលតថាគត ។

ប្រើក្នុងអត្ថ សម្បទាន ( ចតុត្ថីវិភត្តិ ) ដូចក្នុងប្រយោគជាដើមថា **សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ** ប្រែថា សូមព្រះមានព្រះភាគសម្ដែងធម៌នោះដោយសង្ខេប ដល់ខ្ញុំព្រះអង្គឲ្យទាន ដូច្នេះ អធិប្បាយថា

មានអត្ថស្មើគ្នានឹង **មយ្ហំ** ប្រែថា ដល់ខ្ញុំ ។

ប្រើក្នុងអត្ថ ឆដ្ឋីវិភត្តិ ដូចក្នុងប្រយោគជាដើមថា **បុព្វេវ មេ ភិក្ខវេ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ** ប្រែថា ម្នាលភិក្ខុទាំងឡាយក្នុងកាលមុន តថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹង សម្ពោធិញ្ញាណនៅឡើយ ដូច្នេះ ។ ក្នុងគាថានេះ គប្បីជ្រាបថា ប្រើក្នុងអត្ថនៃឆដ្ឋីវិភត្តិនោះឯង អធិប្បាយថា មានអត្ថស្មើគ្នានឹង **មម** ។ ឈ្មោះថា វត្ថុណាមួយដែលគប្បីប្រកាន់ថា ជារបស់អញ មិនមានដល់ ព្រះខីណាស្រពទាំងឡាយ ព្រោះព្រះខីណាស្រពទាំងនោះ លោកធម៌ទាំងឡាយ ចូលទៅប្រឡាក់មិនបានក៏ពិត តែដោយលោកសម្មតិ ព្រះខីណាស្រពទាំងនោះ ក៏នៅមានការនិយាយគ្នាថា ខ្ញុំ ជារបស់ខ្ញុំ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា អ្នកទាំងឡាយចូរយកធម៌របស់តថាគតជាមត៌ក កុំយកអាមិសជាមត៌កឡើយ ដូច្នេះ ។ ផ្ទៃមាតាក្តី ករជកាយក្តី ទីប្រក់ទីបាំងដោយស្មៅជាដើមក្តី លោកហៅថា កុដិ ( ខ្ទម ) ពិតហើយ ផ្ទៃមាតា លោកហៅថា ខ្ទម ដូចក្នុងប្រយោគ ( ក្នុងសំយុត្តនិកាយសគាថវគ្គ ) ថា

> អ្នកពោលសំដៅមាតា ទុកជាខ្ទម អ្នកពោលសំដៅភរិយាទុកជាសម្បុក អ្នកពោលសំដៅពួកបុត្តទុកជាតំណវង្ស អ្នកពោលសំដៅតណ្ហាទុកជាចំណងរបស់តថាគត ដូច្នេះ ជាដើម ។

ករជកាយដែលជាទីប្រជុំនៃអាការ ៣២ មានសក់ជាដើម លោកហៅថា ខ្ទម ដូចក្នុងប្រយោគ ( ក្នុងថេរគាថា ) ថា

( នៃស្រីផ្កាមាស ) ប្តីយ នាងរាប់អានខ្ទមអ្នកដទៃ ដែលជាខ្ទមគឺរានផ្ទឹងបែបចម្អឹងៗ មានសាច់និងសរសៃ រួបរឹតហើយពេញ ( ដោយគ្រឿងមិនស្អាត ) មានក្លិនស្អុយ ដូច្នេះជាដើម ។

ទីអាស្រ័យ គឺទីប្រក់បាំងដោយស្មៅ លោកហៅថា ខ្ទម ដូចក្នុង ប្រយោគ ( ក្នុងឃដិការសូត្រ ) ថា ម្នាលនាង កុដិរបស់ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ លេចភ្លៀង ដូច្នេះជាដើម ។ និងដូចប្រយោគមួយទៀតថា ដែលឈ្មោះថា កុដិនោះ គឺកុដិដែលលាបខាងក្នុងឬកុដិដែលលាបខាងក្រៅ ដូច្នេះជាដើម ។ ក្នុងគាថានេះ គប្បីជ្រាបថា បានដល់ទីអាស្រ័យប្រក់បាំងដោយស្មៅនោះឯង ព្រោះសំដៅដល់បណ្ណសាលា គឺសាលាស្លឹក ព្រោះថា ខ្ទម គឺកុដិនោះឯង ។ អធិប្បាយថា កុដិដែលមិនប្រាកដ ( មិនធំដុំ ) លោកហៅថា ខ្ទម ។

ឯ **សុខ** សព្ទ ប្រើក្នុងអត្ថ សុខវេទនា ដូចប្រយោគជាដើមថា បុគ្គលបានធ្វើនូវសុខទុក្ខនិងសោមនស្ស ទោមនស្សក្នុងកាលមុន ឲ្យនៅពីក្រោយខ្នងហើយ ដូច្នេះ ។

ប្រើក្នុងអត្ថថា ជាមូលរបស់សេចក្តីសុខ ដូចក្នុងប្រយោគជាដើមថា ការកើតឡើងនៃព្រះពុទ្ធជាសុខ ការសម្តែងព្រះសទ្ធម្មជាសុខ ដូច្នេះ ។

ប្រើក្នុងអត្ថថា ហេតុនៃសេចក្តីសុខ ដូចក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងឡាយ ពាក្យថាបុណ្យនេះ ជាឈ្មោះនៃសេចក្តីសុខ ដូច្នេះ ។

ប្រើក្នុងអត្ថថា អារម្មណ៍ដែលជាសុខ ដូចក្នុងប្រយោគជាដើមថា ម្នាលមហាលិ តែរូបនេះជាសុខ មានសុខជាប់តាម មានសុខគ្របសង្កត់ ដូច្នេះ ។

ប្រើក្នុងអត្ថថា មិនសម្ងំ ដូចក្នុងប្រយោគជាដើមថា ( **ទិដ្ឋធម្មសុខ-វិហារា ឯតេ អរិយស្ស វិនយេ** ) ម្នាលចុន្ទ តែជាតថាគតគ្រាន់តែឲ្យឈ្មោះធម៌ទាំងនុ៎ះថា ជាការនៅសប្បាយក្នុងបច្ចុប្បន្ន ក្នុងវិន័យរបស់ព្រះអ-រិយៈ ( ប៉ុណ្ណោះ ) ដូច្នេះ ។

ប្រើក្នុងអត្ថថា ព្រះនិព្វាន ដូចក្នុងប្រយោគជាដើមថា ព្រះនិព្វានជាសុខយ៉ាងក្រៃលែង ដូច្នេះ ។

ប្រើក្នុងអត្ថថា ឋានៈ ដែលជាបច្ច័យនៃសេចក្ដីសុខ ដូចក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីនេះមិនងាយនឹងធ្វើឧបមា ឲ្យដល់កម្រិតឋានសួគ៌ដែលមានសេចក្ដីសុខបានឡើយ ដូច្នេះ ។

ប្រើក្នុងអត្ថថា អារម្មណ៍ដែលគួរប្រាថ្នា ដូចក្នុងប្រយោគជាដើមថា ជាទានគួរដល់នូវកិរិយាកើតក្នុងស្ថានសួគ៌ ជាទានមានផលនាំមកនូវសេចក្ដីសុខ ជាទានញុំាងធម៌ទាំង ១០ ដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅដោយល្អ ដូច្នេះ ។ ក្នុងគាថានេះ គប្បីជ្រាបថា ប្រើក្នុងអត្ថថា អារម្មណ៍ដែលគួរប្រាថ្នា ឬក្នុងអា-រម្មណ៍ដែលជាហេតុនៃសេចក្ដីសុខ ។

កុដិនោះ ញុំាងសេចក្ដីពេញចិត្តឲ្យដល់ព្រម ទាំងខាងក្នុង និងខាងក្រៅទើបលោកហៅថា សុខ ព្រោះនៅអាស្រ័យសប្បាយ ។ ម្យ៉ាងទៀត លោកហៅថាសុខ ព្រោះជាបច្ច័យនៃសេចក្ដីសុខផ្លូវកាយ និងសុខផ្លូវចិត្ត ព្រោះ

សេចក្តីសប្បាយគ្រប់រដូវ មិនត្រជាក់ពេក មិនក្តៅពេក ។ បទថា **និវាតា** បានដល់ មិនមានខ្យល់ អធិប្បាយថា វៀរចាកអន្តរាយដែលកើតអំពីខ្យល់ ព្រោះមានបង្អួចបិទជិតល្អ ។ បទថា **និវាតា** នេះ ជាបទសម្តែងដល់ភាព ដែលកុដិនោះឲ្យនូវសេចក្តីសុខ ។ ព្រោះថា ឧតុសប្បាយ រមែងរកមិនបាន ក្នុងសេនាសនៈដែលមានខ្យល់ ( ខ្លាំង ) តែរកបានក្នុងសេនាសនៈដែល ស្ងាត់ចាកខ្យល់ ។

បទថា **វស្ស** បានដល់ ញុំាងភ្លៀងឲ្យធ្លាក់ គឺញុំាងធារទឹកឲ្យហូរចុះ មកដោយប្រពៃ ។

**ទេវ** សព្ទ ក្នុងបទថា **ទេវ** នេះ មកក្នុងអត្ថថា ក្សត្រ ដែលជាសម្មតិ-ទេព ដូចក្នុងប្រយោគជាដើមថា **ឥមានិ តេ ទេវ ចតុរាសីតិនគរសហស្សានិ កុសាវតីរាជធានិប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ** ប្រែថា បពិត្រព្រះសម្មតិទេព នគរទាំង ៨៤០០០ របស់ព្រះអង្គនេះ មាននគរកុសាវតីរាជធានីជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គ បង្កើតនូវសេចក្តីស្រឡាញ់ ចំពោះនគរទាំងនុ៎ះ សូមព្រះអង្គធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិត ដូច្នេះ ។

មកក្នុងអត្ថថា ឧបបត្តិទេព ដូចក្នុងប្រយោគជាដើមថា **ចាតុមហារា-ជិកា ទេវា ទីឃាយុកា វណ្ណវន្តោ សុខពហុលា** ប្រែថា ពួកទេវតាក្នុង ឋានចាតុម្មហារាជិកៈ មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ដូច្នេះ ។

មកក្នុងអត្ថថា វិសុទ្ធិទេព ដូចក្នុងប្រយោគជាដើមថា **តស្ស ទេវាតិទេវស្ស សាសនំ សព្វទស្សិនោ** ប្រែថា ពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគអង្គនោះ ដែលជាទេវតាក្រៃលែងជាងទេវតា ជាអ្នកឃើញនូវធម៌ទាំងពួង ដូច្នេះ ។ ក្នុងកាលពោលដល់ភាពដែលព្រះមានព្រះភាគក្រៃលែងជាងវិសុទ្ធិទេពទាំងឡាយ ទេវតាក្រៅអំពីនេះ ឈ្មោះថា លោកពោលដល់ហើយនោះឯង ។

មកក្នុងអត្ថថា អាកាស ដូចក្នុងប្រយោគជាដើមថា **វិទ្ធេ វិគតវលាហកេ ទេវេ** ប្រែថា កាលអាកាសរាំងភ្លៀងឃ្លាតទៅចាកពពកហើយ ដូច្នេះ ។

មកក្នុងអត្ថថា ពពក ឬភ្លៀង ដូចក្នុងប្រយោគជាដើមថា **ន សម្មា ធារំ អនុប្បវេច្ឆតិ** ប្រែថា ភ្លៀងក៏មិនបង្អុរទឹកភ្លៀងចុះមកដោយប្រពៃ ដូច្នេះ ។ ក្នុងគាថានេះ លោកសំដៅយក ពពក ឬភ្លៀង ។ ព្រះថេរៈពោលប្រាប់ភ្លៀងទាំងនោះថា **វស្ស** ដូច្នេះ ។

បទថា **យថា សុខំ** បានដល់ តាមគាប់ចិត្ត ។ ព្រះថេរៈកាលអនុគ្រោះពួកសត្វដែលអាស្រ័យភ្លៀងរស់នៅ ទើបពោលថា អន្តរាយខាងក្រៅ មិនមានដល់យើងឡើយ ព្រោះការបង្អុររបស់អ្នក ព្រោះហេតុនោះ ចូរអ្នកបង្អុរតាមសប្បាយចុះ ដូច្នេះ ។

ឥឡូវនេះ ព្រះថេរៈកាលសម្តែងដល់ការមិនមានអន្តរាយខាងក្នុង ទើបពោលពាក្យជាដើមថា **ចិត្តំ មេ សុសមាហិតំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ចិត្តំ មេ សុសមាហិតំ** សេចក្តីថា ចិត្ត

*របស់អាត្មាតាំងនៅហើយ ក្នុងអារម្មណ៍ដោយល្អ គឺល្អក្រៃលែងដោយប្រពៃ គឺដោយភាពជាឯកគ្គតារម្មណ៍ដែលពាល់ត្រូវពិតប្រាកដនោះឯង ។*

*ចិត្តនោះ មិនបានតាំងមាំដោយហេតុគ្រាន់តែសង្កត់នូវនីវរណៈ ជាដើម បានប៉ុណ្ណោះ ដោយពិត ចិត្តនោះរួចផុតហើយ គឺផុតហើយដោយពិសេស ចាកសំយោជនៈទាំងពួងដែលសង្គ្រោះដោយឱរម្ភាគិយសំយោជនៈ និងឧទ្ធម្ភាគិយសំយោជនៈនិងចាកកិលេសធម៌ទាំងពួង អធិប្បាយថា លះនូវកិលេសទាំងនោះបាន ដោយអំណាចសមុច្ឆេទប្បហាន ហើយតាំងនៅ ។*

*បទថា* **អាតាបី** *បានដល់ មានសេចក្ដីព្យាយាម អធិប្បាយថា យើងជាបុគ្គលមានសេចក្ដីព្យាយាម ដែលប្រារព្ធហើយ ដើម្បីផលសមាបត្តិ និងដើម្បីនៅជាសុខក្នុងទិដ្ឋធម៌ ដោយផ្ដើមបំពេញវិបស្សនា ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយធម៌មានទិព្វវិហារ ជាដើម តែមិនមែនដើម្បីលះនូវកិលេសព្រោះមិនមានកិលេសដែលត្រូវលះនោះឯង ។ ព្រះថេរៈកាលសម្ដែងថា នែភ្ញៀវ អ្នកដែលយើងអញ្ជើញឲ្យធ្លាក់ ព្រោះមិនមានអន្តរាយខាងក្រៅ យ៉ាងណា សូម្បីអន្តរាយខាងក្នុង ក៏មិនមានយ៉ាងនោះ ទើបពោលពាក្យថា* **វស្ស ទេវ** *ដូច្នេះទៀត ។*

*ន័យម្យ៉ាងទៀត បទថា* **ឆន្នា** *បានដល់ បិទហើយ គឺប្រក់ហើយ ។ បទថា* **កុដិកា** *បានដល់ អត្តភាព ។ អត្តភាព ប្រើក្នុងអត្ថថា កាយ ដូចក្នុងប្រយោគជាដើមថា* **អវិជ្ជានីវរណស្ស ភិក្ខវេ បុគ្គលស្ស តណ្ហាយ សំយុត្តស្ស ឯវមយំ កាយោ សមុទាគតោ ឥតិ អយញ្ចេវ កាយោ**

**ពហិទ្ធា ច នាមរូបំ** ប្រែថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលមានអវិជ្ជាជាគ្រឿងរារាំង ដែលប្រកបដោយតណ្ហា រមែងមានកាយគឺបដិសន្ធិនេះកើតឡើងយ៉ាងនេះឯង ( ផ្សិតផស្សៈរមែងកើតឡើងព្រោះអាស្រ័យនូវធម៌ជាគូៗនឹងគ្នាទ៊ុះយ៉ាងនេះ ) គឺកាយនេះផង នាមរូបខាងក្រៅផង ដូច្នេះ ។

ប្រើក្នុងអត្ថថា ទូក ដូចក្នុងប្រយោគជាដើមថា **សិញ្ច ភិក្ខុ ឥមំ នាវំ សិត្តា តេ លហុមេស្សតិ** ប្រែថា ម្នាលភិក្ខុ ចូរអ្នកស្តារទូកគឺអត្តភាពនេះ ទូកដែលអ្នកស្តារហើយនឹងដល់ត្រើយឆាប់ ដូច្នេះ ។

ប្រើក្នុងអត្ថថា ផ្ទះ ដូចក្នុងប្រយោគជាដើមថា **គហការក ទិដ្ឋោសិ គហកូដំ វិសង្ខតំ** ប្រែថា នែជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ ( របស់តថាគត ) ទៀត មិនបានឡើយ ឆ្អឹងជំនីរគឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ ដូច្នេះ ។

ប្រើក្នុងអត្ថថា គុហា ដូចក្នុងប្រយោគជាដើមថា **សត្តោ គុហាយំ ពហុ-នាភិឆន្នោ តិដ្ឋំ នរោ មោហនស្មឹ បគាឡ្ហោ** ប្រែថា ជនជាប់ជំពាក់ក្នុងគុហាគឺរាងកាយស្រោបដោយកិលេសច្រើនប្រការធ្លាក់ចុះក្នុងមោហៈ គឺកាមគុណ ហើយឋិតនៅ ដូច្នេះ ។

ប្រើក្នុងអត្ថថា រថ ដូចក្នុងប្រយោគជាដើមថា **នេលង្គោ សេតបច្ឆាទោ ឯការោ វត្តតី រថោ** ប្រែថា រថគឺអត្តភាព មានអវយវៈឥតទោស មានដំបូលស មានកាំតែមួយ រមែងប្រព្រឹត្តទៅបាន ដូច្នេះ ។

ប្រើក្នុងអត្ថថា ទីលំនៅ ដូចក្នុងប្រយោគជាដើមថា **បុន គេហំ ន**

**កាហាសិ** ប្រែថា អ្នកនឹងធ្វើផ្ទះ ( របស់តថាគត ) ទៀត មិនបានឡើយ ដូច្នេះ ។

ប្រើក្នុងអត្ថថា កុដិ ដូចក្នុងប្រយោគជាដើមថា **វិវដា កុដិ ឆិន្នា គិនិ** ប្រែថា ខ្ទមគឺអត្តភាព មានដំបូល បើកចេញហើយ ភ្លើងរលត់ហើយ ដូច្នេះ ។ ព្រោះហេតុនោះ ក្នុងគាថានេះ ទើបលោកហៅអត្តភាពនេះថា **កុដិ** គឺខ្ទម អធិប្បាយថា អត្តភាពមាន ព្រោះអាស្រ័យបឋវីធាតុ និងផស្សៈជាដើម ដែលសន្មតថា ឆ្អឹង ជាដើម ដូចខ្ទមដែលបានឈ្មោះថាផ្ទះ មាន ព្រោះអា-ស្រ័យ ទព្វសម្ភារៈ មានឈើជាដើម ទើបលោកហៅថា ខ្ទម ព្រោះជាទីនៅអាស្រ័យរបស់ស្វា គឺចិត្ត សមដូចលោកពោលថា

> ខ្ទម គឺរាងឆ្អឹងនេះ ជាទីនៅអាស្រ័យនៃស្វា គឺចិត្ត ព្រោះហេតុ
> នោះ ទើបស្វា គឺចិត្ត ខ្វល់ខ្វាយនឹងចេញអំពីខ្ទម ដែលមាន
> ទ្វារ ៥ ព្យាយាមចេញចូលទៅមកតាមទ្វាររឿយៗ ដូច្នេះ ។

ឯខ្ទម គឺអត្តភាពនេះ លោកពោលថា ព្រះថេរៈប្រក់ហើយ ព្រោះភ្លៀង គឺកិលេសមានរាគៈជាដើមលិចស្រោចចូលមក តាមទ្វារដែលមិនសង្រួមនិង ប្រហោង៣ ប្រហោង៦ ប្រហោង៨ ដែលព្រះថេរៈសង្រួមហើយដោយ បញ្ញា គឺប្រក់ហើយដោយប្រពៃនោះឯង ដោយហេតុនោះ ទើបព្រះមានព្រះ ភាគត្រាស់ថា តថាគតពោលថា សតិជាគ្រឿងរាំងខ្សែតណ្ហាទាំងឡាយ បុគ្គល គប្បីបិទខ្សែតណ្ហាទាំងនោះដោយបញ្ញា ដូច្នេះ ។ ឈ្មោះថា មានសេចក្តីសុខ គឺដល់ហើយនូវសេចក្តីសុខ ព្រោះបិទបាំងបាន តាមន័យដូចពោលហើយ

នោះឯង និងព្រោះភាពជាបុគ្គលព្រមព្រៀងដោយសេចក្តីសុខ ដែលប្រាស ចាកអាមិសដោយមិនមានទុក្ខ គឺកិលេស ។ ព្រោះហេតុដែលដល់នូវសេចក្តីសុខហើយនោះឯង ទើបឈ្មោះថា ស្ងាត់ចាកខ្យល់ បានដល់ មានការប្រព្រឹត្តឱនលំទោន ព្រោះមានសេចក្តីស្រេវឹង គឺមានះ ការរឹងត្អឹង និងប្រណាំងប្រជែងដែលកម្ចាត់បានហើយ ។ ព្រះថេរៈកាលសម្តែងថា ផ្លូវនេះ សម្រេចដល់ខ្ញុំដោយហេតុត្រឹមតែ សង្រួមក្នុងសន្និលេសធម៌តែម្យ៉ាង ក៏មិនមែន ដោយពិត សម្រេចព្រោះភាពជាអ្នកមានចិត្តតាំងមាំដោយល្អ ដោយសមាធិដែលសម្បយុត្តហើយ ដោយអគ្គមគ្គ និងព្រោះភាពជាអ្នកមានចិត្តរួចផុតហើយចាកសំយោជនៈទាំងពួង ដោយបញ្ញាដែលសម្បយុត្តដោយអគ្គមគ្គ ទើបពោលពាក្យជាដើមថា **ចិត្តំ មេ សុសមាហិតំ វិមុត្តំ** ដូច្នេះ ។ គប្បីឃើញអត្ថក្នុងគាថានេះ យ៉ាងនេះថា ខ្ញុំជាបុគ្គលយ៉ាងនេះ ហើយជាអ្នកមានការខ្វល់ខ្វាយតិច ដោយគិតថា ឥឡូវនេះខ្ញុំធ្វើកិច្ចដែលគួរធ្វើសម្រេចហើយ ដូច្នេះ ក៏មិនមែន ដោយពិតនោះ ខ្ញុំជាបុគ្គលមានព្យាយាម គឺជាអ្នកមានឧស្សាហៈកើតហើយ ក្នុងការបំពេញប្រយោជន៍ និងសេចក្តីសុខដល់សត្វលោកមួយអន្លើដោយទេវតាក្នុងពេលដែលត្រាច់បិណ្ឌបាត ក៏ទៅតាមលំដាប់ផ្ទះ នៅដោយព្រហ្មវិហារធម៌តែម្យ៉ាង ។ ព្រោះហេតុនោះ នៃភ្លៀង ចូរអ្នកញុំាងធារទឹកឲ្យស្រក់ចុះមក ពេញទំហឹងចុះ ដើម្បីធ្វើឲ្យខ្ញុំពេញចិត្ត និងដើម្បីអនុគ្រោះពួកសត្វដែលអាស្រ័យទឹកភ្លៀងចិញ្ចឹមជីវិត ។

ដោយបទថា **ឆន្នា មេ កុដិកា សុខា និវាតា** ក្នុងគាថានេះ ព្រះ

*ថេរៈសម្ដែងដល់អធិសីលសិក្ខារបស់ខ្លួន ដោយប្រភេទដែលជាលោកិយ និង លោកុត្តរ ។ ដោយបទថា* **ចិត្តំ មេ សុសមាហិតំ** *នេះ សម្ដែងដល់អធិចិត្តសិក្ខា ដោយបទថា* **វិមុត្តំ** *នេះ សម្ដែងដល់អធិប្បញ្ញាសិក្ខា ។ ដោយបទថា* **អាតាបី វិហរាមិ** *នេះ សម្ដែងដល់ការនៅជាសុខក្នុងបច្ចុប្បន្ន ។ ម្យ៉ាងទៀត ដោយបទថា* **ឆន្នា មេ កុដិកា សុខា និវាតា** *នេះ សម្ដែងដល់អនិមិត្តវិហារ ព្រោះសម្ដែងការបើកនិមិត្ត មាននិមិត្តថាទៀងជាដើម ដោយមាតិកា គឺការបិទបាំងនូវភ្លៀង គឺកិលេស ។ បទថា* **ចិត្តំ មេ សុសមាហិតំ** *នេះ សម្ដែងដល់អប្បណិហិតវិហារ ។ បទថា* **វិមុត្តំ** *នេះ សម្ដែងដល់សុញ្ញតវិហារ ។ បទថា* **អាតាបី វិហរាមិ** *នេះ សម្ដែងដល់ឧបាយជាគ្រឿងសម្រេចវិហារធម៌ ៣ យ៉ាងនោះ ។ ម្យ៉ាងទៀត ដោយវិហារធម៌ដំបូង សម្ដែងដល់ការលះទោសៈ ដោយវិហារធម៌ទី ២ សម្ដែងដល់ការលះរាគៈ ដោយវិហារធម៌ទី ៣ សម្ដែងដល់ការលះមោហៈ ។ ម្យ៉ាងទៀត ដោយវិហារធម៌ទី ២ ឬទី ១ និងទី ២ សម្ដែងដល់ចេតោវិមុត្តិសម្បត្តិ ។ ដោយវិហារធម៌ទី ៣ សម្ដែងដល់វិមុត្តិសម្បត្តិ ។ គប្បីជ្រាបថា ដោយបទថា* **អាតាបី វិហរាមិ** *នេះ សម្ដែងដល់ភាពជាបុគ្គលមិនខ្ជិល ប្រឹងប្រែងក្នុងការបដិបត្តិ ដើម្បីជាប្រយោជន៍ដល់អ្នកដទៃ ។*

*កាលបើដូច្នេះ តាមនិទានគាថាថា មានឈ្មោះ មានគោត្ត មានវិហារធម៌ ព្រោះបានសម្ដែងធម៌ជាគ្រឿងនៅ ជាដើម ក្នុងគាថានេះហើយ ដើម្បីសម្ដែងឈ្មោះក្នុងឈ្មោះ និងគោត្តដែលមិនបានសម្ដែងទុកក្នុងគាថានេះ ទើប*

ពោលពាក្យជាដើមថា **ឥត្ថំ សុទំ** ដូច្នេះ ។ ព្រះថេរៈទាំងឡាយណាប្រាកដត្រឹមតែឈ្មោះ លោកសម្ដែងព្រះថេរៈទាំងនោះដោយឈ្មោះ ព្រះថេរៈទាំងឡាយណាប្រាកដហើយដោយគោត្ត លោកសម្ដែងព្រះថេរៈនោះដោយគោត្ត ព្រះថេរៈពួកណាប្រាកដទាំង ២ យ៉ាង ក៏សម្ដែងព្រះថេរៈទាំងនោះទាំង ២ យ៉ាងគឺទាំងឈ្មោះទាំងគោត្ត ឯព្រះសុភូតិលោកកំណត់ទុកហើយដោយឈ្មោះ តែមិនប្រាកដដោយគោត្តយ៉ាងនោះ ព្រោះហេតុនោះ ទើបលោកពោលពាក្យជាដើមថា **ឥត្ថំ សុទំ អាយស្មា សុភូតិ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥត្ថំ** ស្មើគ្នានឹង **ឥទំ បការំ** សេចក្ដីថាដោយអាការនេះ ។ បទថា **សុទំ** កាត់បទជា **សុ ឥទំ** លុប **ឥ** ចេញដោយអំណាចសន្ធិ ។ បទថា **សុ** ត្រឹមតែជានិបាត ។ ប្រកបសេចក្ដីថា នូវគាថានេះ ។ បទថា **អាយស្មា** នេះ ជាពាក្យហៅដែលគួរស្រឡាញ់ គឺពាក្យនេះជាពាក្យពោលរបស់បុគ្គល ដែលមានសេចក្ដីគោរពកោតក្រែង ក្នុងឋានៈជាគ្រូ ។ បទថា **សុភូតិ** ជាពាក្យប្រារព្ធដល់ឈ្មោះ ។ ព្រះសុភូតិនោះដោយសរីរសម្បត្តិ ក៏គួរសរសើរ ដោយគុណសម្បត្តិ ក៏គួរជ្រះថ្លាដោយប្រការដូច្នេះ ទើបលោកប្រាកដឈ្មោះថា សុភូតិ ព្រោះប្រកបទៅដោយសរីរៈល្អគួរពិចពិលរមិលមើល និងគុណសម្បត្តិ មានសីល ជាដើម គួរជាទីត្រេកអរនៃចិត្ត ។ បានឈ្មោះថា **ថេរ** ព្រោះប្រកបដោយគុណធម៌ដ៏មាំ មានសីលសារៈ ជាដើម ។ បទថា **អភាសិត្ថ** បានដល់ ពោលហើយ ។ សួរថា ព្រោះហេតុអ្វីទើបព្រះថេរៈទាំងនេះប្រកាសគុណទាំងឡាយរបស់ខ្លួន ឆ្លើយថា

ព្រះអរិយៈទាំងឡាយ មានការប្រាថ្នាតិចក្រៃលែង ប្រកាសគុណរបស់ខ្លួន ដោយអំណាចនៃការពិចារណាដល់លោកុត្តរធម៌ដែលខ្លួនមិនធ្លាប់បានសម្រេច ដោយកាលដ៏វែងឆ្ងាយនេះដែលជ្រាលជ្រៅក្រៃលែង ស្ងប់ ប្រណីត លើសប្រមាណដែលខ□សម្រេចហើយ បន្លឺឧទានដោយកម្លាំងបីតិជាស់តឿនហើយ និងដោយអំណាចនៃការលើកតម្កើងពាក្យប្រៀនប្រដៅថាជានិយ្យានិកធម៌ ។ ព្រះលោកនាថប្រកាសគុណរបស់ព្រះអង្គ ដោយពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតជាអ្នកប្រកបដោយទសពលញ្ញាណ ជាអ្នកក្លៀវក្លាដោយចតុវេសារជញ្ញាណ ដូច្នេះ ដោយអំណាចនៃព្រះអធ្យាស្រ័យដែលប្រព្រឹត្តទៅដើម្បីឲ្យសត្វបានសម្រេចមគ្គផល យ៉ាងណា គាថាព្យាករអរហត្តផលរបស់ព្រះថេរៈនេះ ក៏ដូចគ្នា យ៉ាងនោះឯង ។

## អដ្ឋកថា សុភូតិត្ថេរគាថា ចប់

## មហាកោដ្ឋិកត្ថេរគាថា

[ ៣ ] បុគ្គលអ្នកស្ងប់រម្ងាប់ វៀរចាកបាប ពោលពាក្យដោយឧបាយប្រាជ្ញា ជាអ្នកមិនរវើរវាយ តែងកម្ចាត់បង់នូវបាបធម៌ ( ចាកខន្ធសន្តាន ) ដូចខ្យល់បក់ផ្តាច់ស្លឹកឈើ ។

ឮថា មហាកោដ្ឋិកត្ថេរមានអាយុបានពោលគាថាដោយប្រការដូច្នេះ ។

**មហាកោដ្ឋិកត្ថេរ ។**

## អដ្ឋកថា

## មហាកោដ្ឋិកត្ថេរគាថា

[ ៣ ] គាថារបស់ព្រះមហាកោដ្ឋិកត្ថេរ មានពាក្យផ្តើមថា **ឧបសន្តោ** ដូច្នេះជាដើម ។ អត្ថុប្បត្តិហេតុរបស់ព្រះថេរៈមានដូចម្តេច ។

ក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈ ព្រះថេរៈនេះកើតក្នុងត្រកូលមានភោគៈច្រើន ក្នុងនគរឈ្មោះថា ហង្សវតី ចម្រើនវ័យហើយកាលមាតាបិតាអនិច្ចកម្មទៅ ទទួលទ្រព្យសម្បត្តិគ្រប់គ្រងផ្ទះ ។ ថ្ងៃមួយឃើញអ្នកក្រុងហង្សវតីកាន់គ្រឿងក្រអូបនិងផ្កាកម្រងជាដើម មានចិត្តទោរទន់បង្អោនទៅរកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទៅគាល់ព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈក្នុងវេលាសម្តែងធម៌ ដើរទៅមួយអន្លើដោយមហាជន ឃើញព្រះសាស្តាស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងឯតទគ្គៈ ខាងសម្រេចបដិសម្ភិទាទាំងឡាយ គិតថា បានឮថា ភិក្ខុនេះប្រសើរជាងភិក្ខុទាំងឡាយខាងបដិសម្ភិទា

ក្នុងសាសនានេះ បើដូច្នោះ អញគប្បីដល់នូវភាពដ៏ក្រៃលែងដោយបដិសម្ភិទាញាណដូចភិក្ខុនេះ ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយ ដូច្នេះ ។ ក្នុងកាលដែលព្រះសាស្ដាបញ្ចប់ធម្មទេសនា ក៏ចូលទៅរកព្រះមានព្រះភាគ ទូលអារាធនាថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែក ព្រះសាស្ដាទ្រង់ទទួលនិមន្តន៍ហើយ ។

កុលបុត្រនោះ អភិវាទព្រះសាស្ដាហើយ ធ្វើប្រទក្សិណ ត្រឡប់ទៅកាន់ផ្ទះរបស់ខ្លួនរៀបចំតាក់តែងអាសនៈរបស់ព្រះពុទ្ធនិងភិក្ខុសង្ឃដោយផ្កាកម្រងនិងគ្រឿងក្រអូបជាដើម ចាត់ចែងខាទនីយ និងភោជនីយាហារដ៏ប្រណីតមួយយប់ទល់ភ្លឺ កាលរាត្រីអស់ទៅហើយ ក៏អង្គាសព្រះមានព្រះភាគ មានភិក្ខុមួយសែនរូបជាបរិវារ ឲ្យសោយភោជននៃស្រូវសាលីដ៏ក្រអូប មានស្ដបព្យញ្ជនៈប្រកបដោយរសជាច្រើន មានបបរនិងរបស់ទំពាច្រើនយ៉ាងជាបរិវារ ក្នុងកាលស្រេចភត្តកិច្ចហើយ គិតថា អញប្រាថ្នាតំណែងធំក្រៃលែងហ្នឹ៎កាលថ្វាយទានត្រឹមមួយថ្ងៃ ហើយប្រាថ្នាតំណែងនោះ មិនសមគួរដល់អញឡើយ អញនឹងថ្វាយទាន ៧ ថ្ងៃដោយលំដាប់ហើយសឹមតាំងសេចក្ដីប្រាថ្នាដូច្នេះ ។

កុលបុត្តនោះថ្វាយមហាទាន ៧ ថ្ងៃ ដោយទំនងនេះឯង ក្នុងគ្រាស្រេចភត្តកិច្ចហើយ ក៏ប្រើឲ្យមនុស្សបើកឃ្លាំងសំពត់ ដាក់សំពត់សាច់ម៉ដ្ឋ ល្មមធ្វើចីវរបាន ដែលមានតម្លៃខ្ពស់ ទៀបបាទមូលព្រះមានព្រះភាគនិងប្រគេនត្រៃចីវរដល់ភិក្ខុមួយសែនរូប ចូលទៅគាល់ព្រះមានព្រះភាគហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន រាប់ថយក្រោយអំពីនេះទៅ ៧ ថ្ងៃ ទ្រង់តាំងភិក្ខុ

រូបណាក្នុងតំណែងឯតទគ្គៈ ឯខ្ញុំព្រះអង្គគប្បីបួសក្នុងសាសនារបស់ព្រះសម្ពុទ្ធ ដែលកើតឡើងក្នុងអនាគតកាល ហើយគប្បីជាអ្នកក្រៃលែង ជាងភិក្ខុទាំងឡាយខាងបដិសម្ភិទាញាណចុះ ដូច្នេះ ហើយក្រាបចុះទៀបបាទមូលរបស់ព្រះមុនីធ្វើសេចក្ដីប្រាថ្នាហើយ ។

ព្រះសាស្ដា ទ្រង់ឃើញការសម្រេចនៃសេចក្ដីប្រាថ្នារបស់កុលបុត្តនោះ ហើយទ្រង់ព្យាករថា ក្នុងអនាគតកាល ក្នុងទីបំផុតនៃសែនកប្បរាប់អំពីនេះទៅ ព្រះពុទ្ធទ្រង់ព្រះនាមថាគោតម នឹងកើតឡើងក្នុងលោក សេចក្ដីប្រាថ្នារបស់អ្នកនឹងសម្រេចក្នុងសាសនារបស់ព្រះសម្ពុទ្ធព្រះនាមថាគោតមនោះ ។ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះជិនស្រីព្រះនាមបទុមុត្តរៈជាអ្នកប្រាជ្ញ ទ្រង់ជ្រាបច្បាស់នូវលោកទាំងអស់ មានចក្ខុកើតឡើងក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ ព្រះពុទ្ធទ្រង់ឈ្លាសក្នុងទេសនា ទ្រង់ប្រទានឱវាទ ញុំាងសត្វឲ្យដឹង ចម្លងសព្វសត្វ ញុំាងពួកជនច្រើនឲ្យឆ្លង ទ្រង់អនុគ្រោះ មានសេចក្ដីករុណា ស្វែងរកប្រយោជន៍ដល់សត្វទាំងពួង បានញុំាងពួកតិរ្ថិយទាំងអស់ដែលមកប្រជុំគ្នាឲ្យតាំងនៅស៊ប់ក្នុងសីល ៥ ។ សាសនានេះឯង មិនរីករវល់ស្ងប់ស្ងាត់ចាកពួកតិរ្ថិយ វិចិត្រដោយព្រះអរហន្តទាំងឡាយ ជាបុគ្គលស្ទាត់ជំនាញ ប្រកបដោយតាទិគុណ ។ ព្រះមហាមុនីនោះ មានកម្ពស់ ៥៨ ហត្ថ ប្រាកដស្មើដោយគ្រឿងបូជា ជាវិការៈ

នៃមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ មានព្រះជន្មមួយសែនឆ្នាំ កាលព្រះអង្គគង់ព្រះជន្មនៅ បានញ៉ាំងពួកជនច្រើនឲ្យឆ្លង ( ចាកលោក ) ។ កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ក្នុងក្រុងហង្សវតី ជាអ្នកដល់នូវត្រើយនៃវេទ បានចូលទៅជិតព្រះពុទ្ធជាកំពូលនៃសត្វលោកទាំងពួង ហើយស្តាប់ធម្មទេសនា ។ គ្រានោះ ព្រះពុទ្ធជាអ្នកប្រាជ្ញទ្រង់តាំងសាវក ( មួយអង្គ ) ដែលបែកធ្លាយបដិសម្ភិទា ជាអ្នកឈ្លាសវៃក្នុង អត្ថ ធម៌ និរុត្តិ និងបដិភាណ ក្នុងទីជាឯតទគ្គៈ កាលនោះខ្ញុំបានឮនូវតំណែងនោះហើយ ក៏មានចិត្តរីករាយ បានញ៉ាំងព្រះជិនស្រីដ៏ប្រសើរព្រមទាំងសាវកឲ្យឆាន់អស់ ៧ ថ្ងៃ ។ ខ្ញុំញ៉ាំងព្រះពុទ្ធដូចជាសាគរ ព្រមទាំងសិស្សឲ្យស្លៀកសំពត់រួចខ្ញុំក្រាបទៀបបាទមូលប្រាថ្នាតំណែងនោះ ។

លំដាប់នោះ ព្រះពុទ្ធជាកំពូលលោក ទ្រង់ត្រាស់ថា អ្នកទាំងឡាយចូរមើលព្រាហ្មណ៍ដ៏ខ្ពង់ខ្ពស់នុ៎ះ ក្រាបទៀបបាទមូលមានរស្មីពន្លឺដ៏ពោះដូចផ្កាឈូក ព្រាហ្មណ៍នេះ ( បរិបូណ៌ ) ដោយសទ្ធា ចាគៈ និងសទ្ធម្មស្សវនៈនោះ ប្រាថ្នានូវតំណែងនៃភិក្ខុរបស់ព្រះពុទ្ធដ៏ប្រសើរ ។ ព្រាហ្មណ៍នេះ ជាអ្នកដល់នូវសេចក្តីសុខក្នុងទីទាំងពួង អន្ទោលទៅក្នុងភពតូចភពធំ រមែងបាននូវតំណែងនុ៎ះដូចបំណងក្នុងកាលជាអនាគត ។ ក្នុងកប្បទី

មួយសែនអំពីកប្បនេះ មានមហាបុរស សម្ភពក្នុងត្រកូលស្តេចឱក្កាកៈ នឹងបានជាព្រះសាស្តាក្នុងលោក ព្រះនាម គោតម ។ ព្រាហ្មណ៍នេះ នឹងបានជាធម្មទាយាទជាឱរសជាធម្មនិម្មិតរបស់ព្រះគោតមនោះ នឹងបានជាសាវកនៃព្រះសាស្តា មានទាមថា កោដ្ឋិកៈ ។

កាលនោះ ខ្ញុំឮពុទ្ធព្យាករណ៍នោះហើយ ក៏មានចិត្តរីករាយ មានចិត្តប្រកបដោយមេត្តា មានប្រាជ្ញាខ្ជាប់ខ្ជួន បានបម្រើព្រះជិនស្រីដរាបដល់អស់ជីវិត ។ ដោយផលនៃកុសលកម្មនោះផង ដោយការតម្កល់ទុកនូវសេចក្តីប្រាថ្នានោះផង ខ្ញុំលុះលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ខ្ញុំបានសោយរាជ្យជាស្តេចទេវតាអស់ ៣០០ ដង បានជាស្តេចចក្រពត្តិអស់ ៥០០ ដង ។ បានសោយប្រទេសរាជ្យដ៏ទូលាយរាប់ជាតិមិនអស់ ខ្ញុំបានសេចក្តីសុខក្នុងទីទាំងពួង ដោយអានិសង្សនៃកុសលកម្មនោះ ។ ខ្ញុំតែងអន្ទោលទៅក្នុងភព ២ គឺទេវតាឬមនុស្ស ខ្ញុំមិនដែលស្គាល់គតិដទៃ នេះជាផលនៃកុសលកម្មដែលខ្ញុំសន្សំល្អហើយ ខ្ញុំតែងកើតក្នុងត្រកូល ២ គឺក្សត្រឬព្រាហ្មណ៍ មិនដែលកើតក្នុងត្រកូលទាបថោកទេ នេះជាផលនៃកុសលកម្មដែលខ្ញុំសន្សំល្អហើយ ។ លុះដល់បច្ឆិមភព ខ្ញុំជាអ្នកមានផៅពង្សប្រសើរ ខាងក្រោយមក ខ្ញុំកើតក្នុងត្រកូល

ព្រាហ្មណ៍មានធនធានច្រើនក្នុងក្រុងសាវត្ថី មាតារបស់ខ្ញុំឈ្មោះ ចន្ទវតី បិតារបស់ខ្ញុំឈ្មោះ អស្សលាយនៈ ព្រះពុទ្ធទ្រង់ទូន្មាន បិតារបស់ខ្ញុំដើម្បីសេចក្តីស្អាតគ្រប់យ៉ាងក្នុងកាលណា ។ កាល នោះ ខ្ញុំជ្រះថ្លាចំពោះព្រះសុគត ហើយចូលទៅកាន់ផ្នួស ព្រះ មោគ្គល្លានជាអាចារ្យ ព្រះសារីបុត្តជាឧបជ្ឈាយ៍ ( របស់ខ្ញុំ ) កាលសក់ទាំងឡាយជាច់ចុះ ទិដ្ឋិព្រមទាំងឫស ក៏ដាច់ចុះដែរ ខ្ញុំកំពុងតែស្លៀកសំពត់កាសាវៈ ក៏បានសម្រេចអរហត្ត ។ ប្រាជ្ញា របស់ខ្ញុំបែកធ្លាយក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ ហេតុនេះ បានជាព្រះពុទ្ធជាកំពូលនៃលោក ទ្រង់តាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ ខ្ញុំត្រូវឧបតិស្សៈសាកសួរក្នុងបដិសម្ភិទា ក៏បានដោះស្រាយនូវ ធម៌ដែលខ្លួនមិនដែលបានឃើញ ហេតុនោះហើយ បានជាខ្ញុំជា អ្នកប្រសើរក្នុងសាសនានៃព្រះសម្ពុទ្ធ ។ កិលេសទាំងឡាយខ្ញុំ ដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិន មានអាសវៈ ព្រោះបានកាត់ចំណងដូចជាដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធដ៏ប្រសើររបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យ ជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិ ហើយ ។

កុលបុត្តនោះ សន្សំបុណ្យនិងញាណសម្ភារក្នុងភពនោះៗយ៉ាងនេះហើយ អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងក្រុងសាវត្ថី មាតាបិតា ដាក់ឈ្មោះថាកោដ្ឋិកៈ ។

កោដ្ឋិកមាណពនោះ ចម្រើនវ័យហើយ រៀនត្រៃវេទ សម្រេចសិប្បសាស្ត្ររបស់ព្រាហ្មណ៍ ថ្ងៃមួយទៅកាន់សម្នាក់ព្រះសាស្តា ស្តាប់ធម៌ហើយមានសទ្ធាហើយក៏បួស ។ ចាប់តាំងពីបំពេញឧបសម្បទាហើយ ចម្រើនវិបស្សនាសម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ ជាអ្នកជំនាញក្នុងបដិសម្ភិទាញាណ ចូលទៅរកព្រះមហាថេរៈដែលជំនាញទាំងឡាយហើយសួរបញ្ហាក្តី ចូលគាល់ព្រះទសពលហើយសួរបញ្ហាក្តី ក៏សួរក្នុងបដិសម្ភិទាប៉ុណ្ណោះ ។

ព្រះថេរៈរូបនេះក្រៃលែងជាងភិក្ខុដែលបានបដិសម្ភិទាទាំងឡាយ ព្រោះជាអ្នកមានអធិការដែលធ្វើទុកហើយក្នុងភពនោះៗ និងព្រោះជាអ្នកមានជំនាញដែលសន្សំទុកហើយដោយប្រការដូចពណ៌នាមកនេះ ។

សម័យនោះ ព្រះសាស្តាទ្រង់ធ្វើមហាវេទល្លសូត្រឲ្យជាអត្ថុប្បត្តិហេតុទ្រង់តាំងព្រះថេរៈទុកក្នុងតំណែងនៃភិក្ខុដែលក្រៃលែងជាងភិក្ខុទាំងឡាយ ខាងបដិសម្ភិទាញាណ ដោយព្រះពុទ្ធតម្រាស់ថា ម្នាលភិក្ខុទាំងឡាយបណ្តាពួកភិក្ខុអ្នកបានបដិសម្ភិទា ដែលជាសាវ័ករបស់តថាគត ស្រេចនឹងមហាកោដ្ឋិកប្រសើរជាងគេ ដូច្នេះ ។ សម័យតមក កាលលោកសោយវិមុត្តិសុខបានពោល

គាថាជាឧទានយ៉ាងនេះថា

បុគ្គលអ្នកស្ងប់រម្ងាប់ វៀរចាកបាប ពោលពាក្យដោយឧបាយប្រាជ្ញា ជាអ្នកមិនរវើរវាយ តែងកម្ចាត់បង់នូវបាបធម៌ ( ចាកខន្ធសន្តាន ) ដូចខ្យល់បក់ផ្តាច់ស្លឹកឈើ ។

ឮថា មហាកោដ្ឋិកត្ថេរមានអាយុបានពោលគាថាដោយប្រការដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧបសន្តោ** សេចក្តីថា បុគ្គលឈ្មោះថាស្ងប់ហើយ ព្រោះធ្វើនូវការស្ងប់រម្ងាប់នូវឥន្ទ្រិយទាំងឡាយ មានចិត្តជាគម្រប់ ៦ ដោយធ្វើឲ្យអស់ព្យសន៍ ។

បទថា **ឧបរតោ** សេចក្តីថា វៀរគឺវៀរចាកនូវការធ្វើអាក្រក់គ្រប់យ៉ាង ។ បទថា **មន្តភាណី** សេចក្តីថា បញ្ញា លោកហៅថា **មន្តា** បុគ្គលឈ្មោះថា **មន្តាភាណី** ព្រោះពិចារណាដោយបញ្ញានោះហើយ ទើបពោលអធិប្បាយថា ពោលដោយមិនលះនូវភាពជាអ្នកពោលតាមកាលជាដើម ។ ម្យ៉ាងទៀត បុគ្គលឈ្មោះថា **មន្តភាណី** ព្រោះពោលដោយអំណាចនៃការពោលមន្ត អធិប្បាយថា វៀរពាក្យដែលជាទុព្ភាសិត ពោលតែពាក្យដែលជាសុភាសិតដែលប្រកបដោយអង្គ ៤ ប៉ុណ្ណោះ ដោយភាសារបស់ខ្លួន ។ បុគ្គលឈ្មោះថា **អនុទ្ធតោ** ព្រោះមិនរាយមាយដោយការលើកខ្លួនដោយអំណាចនៃជាតិជាដើម ។

ម្យ៉ាងទៀត ឈ្មោះថា **ឧបសន្តោ** ព្រោះស្ងប់កាយទុច្ចរិត ៣ ដោយវៀរចាកកាយទុច្ចរិតនោះ ឈ្មោះថា **ឧបរតោ** ព្រោះវៀរបង់ គឺលះមនោ

ទុច្ចរិតទាំង ៣ បាន ឈ្មោះថា **មន្តភាណី** ព្រោះពោលល្អិតល្អន់ មិនកន្ទង់នូវវចីទុច្ចរិត ៤ ។ ឈ្មោះថា **អនុទ្ធតោ** ព្រោះមិនមានការរាយមាយដែលកើតអំពីនិមិត្ត គឺទុច្ចរិត ៣ យ៉ាង ។ បុគ្គលដែលតាំងនៅក្នុងសីលដ៏បរិសុទ្ធដោយលះទុច្ចរិត ៣ យ៉ាងបាន ដូច្នេះ ជាអ្នកមានចិត្តតាំងមាំ ព្រោះលះឧទ្ធច្ចៈបាន ធ្វើសមាធិនោះឯងឲ្យជាបទដ្ឋាន ចម្រើនវិបស្សនាហើយ រមែងឈ្មោះថា តែងកម្ចាត់បង់នូវបាបធម៌ ( ចាកខន្ធសន្តាន ) គឺកម្ចាត់សង្កិលេសធម៌ ដែលឈ្មោះថា បាប ព្រោះជាទីតាំងនៃបាបបានគ្រប់យ៉ាង តាមលំដាប់នៃមគ្គ បានដល់ លះបានដោយអំណាចនៃសមុច្ឆេទប្បហាន ។ សួរថា ដូចអ្វី ឆ្លើយថា ដូចខ្យល់បក់ផ្ដាច់ស្លឹកឈើ ដូច្នោះ ។ ឧបមាដូចខ្យល់រមែងកម្ចាត់ស្លឹកឈើ គឺស្លឹកឈើទុំ ឲ្យជ្រុះចាកទង យ៉ាងណា បុគ្គលដែលតាំងនៅក្នុងបដិបទា តាមដែលពោលហើយក៏ដូច្នោះ រមែងនាំបាបធម៌ទាំងពួងចេញចាកសន្តានរបស់ខ្លួនបាន ។ គប្បីជ្រាបថា គាថារបស់ព្រះថេរៈនេះ ចាត់ថាជាគាថាព្យាករអរហត្តផល ដោយការអាងដល់ព្រះអរហត្តផល របស់ព្រះថេរៈ ។

ក្នុងគាថានេះ លោកសម្ដែងដល់សេចក្ដីបរិសុទ្ធនៃប្រយោគ ដោយការពោលដល់ការលះកាយទុច្ចរិត និងវចីទុច្ចរិត សម្ដែងដល់សេចក្ដីបរិសុទ្ធនៃអាសយ ( អធ្យាស្រ័យ ) ដោយការពោលដល់ការលះមនោទុច្ចរិត សម្ដែងដល់ការលះនីវរណៈ របស់បុគ្គលដែលមានប្រយោគ និងអាសយបរិសុទ្ធយ៉ាងនេះ ព្រោះតាំងនៅក្នុងការមិនរាយមាយនោះ ដោយការពោលដល់ការ

មិនមានឧទ្ទេសដោយបទថា **អនុទ្ធតោ** នេះ ។ បណ្ដាប្រយោគ និងអាសយទាំងនោះ សីលសម្បត្តិ រមែងជាក់ច្បាស់ដោយសេចក្ដីបរិសុទ្ធិនៃប្រយោគ ។ ការកំណត់ធម៌ ដែលជាឧបការៈចំពោះសមថភាវនា រមែងជាក់ច្បាស់ដោយសេចក្ដីបរិសុទ្ធិនៃអាសយសមាធិភាវនា រមែងជាក់ច្បាស់ ដោយការលះនីវរណៈ ។ បញ្ញាភាវនា រមែងជាក់ច្បាស់ដោយបាទគាថានេះថា **ធុនាតិ បាបកេ ធម្មេ** ប្រែថា តែងកម្ចាត់បង់នូវបាបធម៌ ( ចាកខន្ធសន្ដាន ) ។

ដោយប្រការដូចពណ៌នាមកនេះ សិក្ខា ៣ មានអធិសីលសិក្ខាជាដើម ពាក្យប្រៀនប្រដៅដែលមានលម្អ ៣ យ៉ាង បហាន ៣ មានតទង្គប្បហានជាដើម បដិបទាដោយមជ្ឈិមប្បដិបទា មួយអន្លើដោយការវៀរអន្តធម៌ ២ យ៉ាង និងឧបាយជាគ្រឿងឈានកន្លងកព ក្នុងអបាយជាដើម បណ្ឌិតគប្បីនាំមកបរិយាយប្រកបសេចក្ដីតាមសមគួរ ។ សូម្បីក្នុងគាថាដ៏សេស ក៏គប្បីជ្រាបនូវការប្រកបតាមសមគួរដោយន័យនេះ ។ ខ្ញុំពណ៌នាត្រឹមតែអត្ថដែលមិនធ្លាប់ពោលទុកក្នុងទីដទៃៗប៉ុណ្ណោះ ។ បទថា **ឥត្ថំ សុទំ អាយស្មា មហាកោដ្ឋិតោ** នេះជាពាក្យពោលសរសើរ ដូចគ្នានឹងពោលសរសើរព្រះមហាមោគ្គល្លាន ដូច្នោះ ។

## អដ្ឋកថា មហាកោដ្ឋិកត្ថេរគាថា ចប់

## កង្ខារេវតត្ថេរគាថា

[ ៤ ] អ្នកចូរមើលបញ្ញានេះ របស់ព្រះតថាគតទាំងឡាយដូចជាភ្លើង ដែលរុងរឿងក្នុងរាត្រី ព្រះតថាគតទាំងឡាយ ជាអ្នកប្រទានពន្លឺចក្ខុ តែង កម្ចាត់បង់សេចក្តីសង្ស័យ របស់វេនេយ្យជន ដែលមកហើយ ។

ឮថា កង្ខារេវតត្ថេរមានអាយុ បានពោលគាថា ដោយប្រការដូច្នេះ ។

**កង្ខារេវតត្ថេរ ។**

## អដ្ឋកថា

## កង្ខារេវតត្ថេរគាថា

[ ៤ ] គាថារបស់ព្រះកង្ខារេវតៈ មានពាក្យផ្តើមថា **បញ្ញំ ឥមំ បស្ស** ដូច្នេះជាដើម ។ អត្ថុប្បត្តិហេតុរបស់ព្រះថេរៈកើតឡើងដូចម្តេច ។

ក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈ ព្រះថេរៈនេះ ក៏កើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងនគរហង្សវតី ។ ថ្ងៃមួយ ក្នុង ពេលសម្តែងព្រះធម្មទេសនារបស់ព្រះសម្ពុទ្ធ កុលបុត្តនោះទៅកាន់វិហារមួយ អន្លើដោយមហាជន ដោយន័យដូចពោលហើយខាងដើម ឈរស្តាប់ធម៌ខាង ចុងបរិស័ទ ឃើញព្រះសាស្តាទ្រង់តាំងភិក្ខុមួយរូបក្នុងតំណែងក្រៃលែងជាង ភិក្ខុទាំងឡាយ ខាងត្រេកអរក្នុងឈាន គិតថា ក្នុងអនាគត អាត្មាអញក៏គួរ ដូចភិក្ខុនេះ ដូច្នេះ ។ ក្នុងកាលចប់ទេសនា និមន្តព្រះសាស្តា ធ្វើមហា សក្ការៈ ដោយន័យដូចពោលហើយខាងដើមនោះឯង ក្រាបទូលព្រះមានព្រះ

ភាគថា បពិត្រព្រះអង្គដ៏ចម្រើន ដោយការធ្វើអធិការនេះ ខ្ញុំព្រះអង្គមិនប្រាថ្នាសម្បត្តិដទៃ រាប់អំពីថ្ងៃនេះទៅក្រោយ ៧ ថ្ងៃ ទ្រង់បានតាំងភិក្ខុរូបនោះក្នុងតំណែងនៃភិក្ខុដែលក្រៃលែងជាងភិក្ខុទាំងឡាយ ខាងសម្រឹងឈាន យ៉ាងណាក្នុងអនាគតកាល ខ្ញុំព្រះអង្គក៏គប្បីជាកំពូលជាងភិក្ខុទាំងឡាយ ខាងសម្រឹងឈាន ក្នុងសាសនារបស់ព្រះពុទ្ធអង្គណានីមួយ ដូច្នេះហើយ តាំងសេចក្តីប្រាថ្នាទុក ។

ព្រះបរមសាស្តា ទ្រង់ប្រមើលមើលអនាគតកាល ទ្រង់ឃើញនូវការសម្រេច ក៏ទ្រង់ព្យាករថា ព្រះពុទ្ធព្រះនាមថាគោតមនឹងកើតឡើងក្នុងទីបំផុតនៃមួយសែនកប្ប ក្នុងអនាគតកាល អ្នកនឹងជាបុគ្គលក្រៃលែងជាងភិក្ខុទាំង-ឡាយដែលសម្រឹងឈាន ក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមថា គោតមនោះ ហើយទ្រង់ចៀសចេញទៅ ។

កុលបុត្តនោះ ធ្វើតែសុចរិតកម្មដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយអស់សែនកប្ប ក្នុងសាសនារបស់ព្រះមានព្រះភាគនៃយើងទាំងឡាយ កើតក្នុងត្រកូលដែលមានសម្បត្តិច្រើនក្នុងក្រុងសាវត្ថី ទៅកាន់វិហារមួយអន្លើដោយមហាជន ដែលទៅដើម្បីស្តាប់ធម៌ ខាងក្រោយភត្តឈរខាងចុងបរិស័ទ ស្តាប់ធម្មកថារបស់ព្រះទសពលហើយ បានចំពោះនូវសទ្ធា បួសហើយ បានឧបសម្បទាហើយ ឲ្យអាចារ្យប្រាប់កម្មដ្ឋាន ធ្វើឈានបរិកម្ម ជាអ្នកបានឈាន ធ្វើឈានឲ្យជាបាទហើយសម្រេចអរហត្ត ។

ដោយច្រើន ព្រះថេរៈចូលសមាបត្តិដែលព្រះទសពលទ្រង់ចូល បានជា

អ្នកជំនាញ ដែលសន្សំហើយក្នុងឈានទាំងឡាយ ទាំងពេលថ្ងៃ និងពេលយប់ ។

ក្នុងកាលនោះ ព្រះសាស្តាទ្រង់តាំងព្រះថេរៈក្នុងតំណែងនៃភិក្ខុដែលត្រេកអរក្នុងឈានតែភិក្ខុទាំងឡាយខាងសម្ដីងឈាន ដោយព្រះពុទ្ធតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកបានឈានដែលជាសាវ័ករបស់តថាគតស្រេចនឹងកង្ខារេវតៈប្រសើរជាងគេ ដូច្នេះ ។ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់មានបញ្ញាចក្ខុ ក្នុងធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងកប្បទីមួយសែនអំពីកប្បនេះ ។ ព្រះសម្ពុទ្ធទ្រង់មានចង្កាដូចចង្កាសីហៈ មានព្រះសូរសេងដូចសំឡេងព្រហ្ម មានសូរសព្ទដូចហង្សនិងស្គរមានពុទ្ធដំណើរដូចដំរីដែលភ្លៀវក្លា មានរស្មីដូចព្រះចន្ទ និងព្រះអាទិត្យជាដើម ។ មានប្រាជ្ញាច្រើន មានព្យាយាមធំ មានឈានធំ មានគតិធំ ប្រកបដោយមហាករុណា ជាទីពឹងនៃសត្វលោក ទ្រង់កម្ចាត់បង់នូវងងឹតធំ គឺមោហៈ ។ ព្រះអង្គជាកំពូលនៃត្រៃលោក ទ្រង់ជ្រាបច្បាស់នូវចិត្តសត្វ ជាអ្នកប្រាជ្ញកាលទូន្មាននូវវេនេយ្យសត្វហើយទ្រង់សម្ដែងធម៌ច្រើន ។ ព្រះជិនស្រីទ្រង់សរសើរ នូវបុគ្គលអ្នកមានឈាន ត្រេកអរក្នុងឈាន មានព្យាយាម មានចិត្តស្ងប់រម្ងាប់ មិនល្អក់ ទ្រង់ញុំាង

ពួកជនឲ្យត្រេកអរក្នុងកណ្តាលបរិស័ទ ។ កាលនោះ ខ្ញុំជាព្រាហ្មណ៍ដល់នូវត្រើយនៃវេទនៅក្នុងក្រុងហង្សវតី លុះស្តាប់ធម៌ហើយ មានចិត្តរីករាយ ទើបប្រាថ្នានូវតំណែងនោះ ។

គ្រានោះ ព្រះជិនស្រីជានាយក ទ្រង់ព្យាករក្នុងកណ្តាលនៃជំនុំសង្ឃថា ម្នាលព្រាហ្មណ៍ អ្នកចូរត្រេកអរចុះ អ្នកនឹងបាននូវតំណែងនុ៎ះ ដូចចិត្តប៉ុនប៉ងពុំខាន ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះមានមហាបុរសសម្ភពក្នុងត្រកូលស្តេចឱក្កាកៈនឹងបានជាសាស្តាក្នុងលោក ព្រះនាមគោតម ។ ព្រាហ្មណ៍នេះនឹងបានជាឱរសដែលព្រះធម៌និម្មិត ជាអ្នកទទួលមត៌កក្នុងធម៌របស់ព្រះគោតមនោះ ជាសាវ័ករបស់ព្រះសាស្តា មាននាមថារេវតៈ ។

ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកចេតនានោះផង លុះខ្ញុំលះបង់រាងកាយរបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ក្នុងបច្ឆិមភព ឥឡូវនេះខ្ញុំកើតក្នុងត្រកូលក្សត្រ ជាត្រកូលសម្បូរ ស្តុកស្តម្ភទូលាយ មានទ្រព្យច្រើន នៅក្នុងក្រុងកោលយៈ ។ កាលណាព្រះពុទ្ធទ្រង់សម្តែងធម៌ក្នុងក្រុងកបិលវត្ថុ កាលនោះខ្ញុំជ្រះថ្លា ចំពោះព្រះសុគតហើយចូលទៅកាន់ផ្នួស ។ ខ្ញុំមានសេចក្តីសង្ស័យច្រើន ក្នុងវត្ថុគួរនិងមិនគួរនោះៗ ព្រះពុទ្ធទ្រង់សម្តែងធម៌ដ៏ឧត្តម កម្ចាត់

បង់នូវសេចក្តីសង្ស័យទាំងអស់នោះបាន ។ ហេតុនោះខ្ញុំឈ្មោះថា ជាអ្នកមានសង្ឃារច្ឆន្ទផុតហើយ ត្រេកអរចំពោះសេចក្តីសុខក្នុងឈាន ។ គ្រានោះ ព្រះពុទ្ធទ្រង់ឃើញខ្ញុំ ហើយទ្រង់ប្រកាសពាក្យនេះថា

សេចក្តីសង្ស័យណាមួយក្នុងលោកនេះ ឬក្នុងលោកខាងមុខ ពួកបុគ្គលមានឈាន មានព្យាយាម ជាអ្នកប្រព្រឹត្តព្រហ្មចរិយៈ តែងលះបង់នូវសេចក្តីសង្ស័យនោះបានដោយប្រាជ្ញានៃខ្លួន ឬដោយប្រាជ្ញានៃអ្នកដទៃ ។

អំពើដែលខ្ញុំបានធ្វើក្នុងកប្បទីមួយសែន ក៏បង្ហាញផលដល់ខ្ញុំក្នុងជាតិនេះ ខ្ញុំបានដុតបំផ្លាញកិលេសទាំងឡាយហើយ ដូចសន្ទុះសរដែលរបូតផុតចេញ ( ចាកធ្នូ ) ។ ព្រះមុនីទ្រង់ដល់នូវទីបំផុតនៃលោក មានប្រាជ្ញាច្រើនទ្រង់ឃើញខ្ញុំជាអ្នកត្រេកអរក្នុងឈាន ដូច្នោះ ក៏តាំងខ្ញុំជាអ្នកប្រសើរជាងពួកភិក្ខុអ្នកមានឈាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយទាំងសាសនា

របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

ព្រះមហាថេរៈនេះ ជាអ្នកធ្វើកិច្ចស្រេចហើយយ៉ាងនោះ ពិចារណាមើលនូវភាពដែលខ្លួនមានសេចក្ដីសង្ស័យជាប្រក្រតី អស់កាលយូរ ក្នុងកាលមុន និងប្រការដែលខ្លួនប្រាសចាកសេចក្ដីសង្ស័យបានដោយប្រការទាំងពួង ក្នុងឥឡូវនោះ កើតនូវការពេញចិត្តជាច្រើនថា អានុភាពនៃទេសនា របស់ព្រះសាស្ដាយើងគួរត្រេកអរពន់ពេកដោយអានុភាពរបស់ទ្រង់ ធ្វើឲ្យអញប្រាសចាកសេចក្ដីសង្ស័យ មានចិត្តស្ងប់រម្ងាប់ហើយខាងក្នុងយ៉ាងនេះ ដូច្នេះ កាលនឹងសរសើរបញ្ញារបស់ព្រះមានព្រះភាគ ទើបពោលគាថានេះថា

អ្នកចូរមើលបញ្ញានេះ របស់ព្រះតថាគតទាំងឡាយដូចជាភ្លើង
ដែលរុងរឿងក្នុងរាត្រី ព្រះតថាគតទាំងឡាយ ជាអ្នកប្រទាន
ពន្លឺចក្ខុ តែងកម្ចាត់បង់សេចក្ដីសង្ស័យរបស់វេនេយ្យជនដែល
មកហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បញ្ញំ** សេចក្ដីថា ធម្មជាតឈ្មោះថា បញ្ញា ព្រោះអត្ថថា ដឹងនូវប្រការទាំងឡាយ និងព្រោះញុំាងបុគ្គលដទៃឲ្យដឹងដោយប្រការទាំងឡាយ អធិប្បាយថា ដឹងអាការៈមានអាសយ អនុសយ ចរិយា និងអធិមុត្តិរបស់វេនេយ្យសត្វទាំងឡាយ និងដឹងប្រការដែលគប្បីសម្ដែងក្នុងបណ្ដាធម៌ទាំងឡាយ មានកុសលជាដើម និងខន្ធជាដើម គឺចាក់ធ្លុះតាមសេចក្ដីពិត និងញុំាងអ្នកដទៃឲ្យដឹងដោយប្រការនោះ ។

ក្នុងគាថានេះលោកបំណងយកញាណគឺព្រះធម្មទេសនារបស់ព្រះសាស្ដា

ដោយហេតុនោះទើបលោកពោលថា **ឥមំ** ដូច្នេះ អធិប្បាយថា ទេសនា-ញាណនោះ លោកពោលថា **ឥមំ** ដោយកាន់យកបញ្ញាដែលប្រាកដហើយដូចឃើញបានចំពោះមុខ ដោយការកាន់យកនូវន័យ ដោយកម្លាំងនៃទេសនាដែលសម្រេចហើយក្នុងខ្លួន ម្យ៉ាងទៀត ទេសនាញាណរបស់ព្រះសាស្តាដែលសាវកទាំងឡាយរមែងកាន់យក ដោយន័យ ដោយមគ្គផលដ៏ប្រសើរណា សូម្បីបដិវេធញ្ញាណ ក្នុងវិស័យរបស់ខ្លួន សាវកទាំងឡាយកាន់យកបានដោយន័យ ដោយមគ្គផល ដ៏ប្រសើរនោះដូចគ្នា ។ ដោយហេតុនោះទើបព្រះធម្មសេនាបតីពោលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គដឹងច្បាស់តាមទំនងធម៌ ក៏យ៉ាងនោះឯង ដូច្នេះ ។ បទថា **បស្ស** សេចក្តីថា បុគ្គលដែលអស់សេចក្តីសង្ស័យហើយរមែងហៅមកមើល ដោយមិនកំណត់ចំពោះឬហៅតាមចិត្តរបស់ខ្លួនដូចព្រះមានព្រះភាគកាលទ្រង់បន្លឺឧទាន ក៏ត្រាស់ ( ទុកក្នុងឧទាន ) ថា អ្នកចូរមើលលោកនេះចុះ ពួកសត្វក្តី អ្នកត្រេកអរក្នុងពួកសត្វក្តីដែលអវិជ្ជាដ៏ក្រាស់គ្របសង្កត់ហើយមិនរួចស្រឡះ ( ចាកទុក្ខ ) បានឡើយដូច្នេះ ។ បទថា **តថាគតានំ** សេចក្តីថា ឈ្មោះថា តថាគត ដោយអត្ថថាយាងមកហើយយ៉ាងនោះ ជាដើម អធិប្បាយថា ព្រះមានព្រះភាគទ្រង់ព្រះនាមថា តថាគត ដោយហេតុ ៨ ប្រការ គឺឈ្មោះថា តថាគត ព្រោះយាងមកហើយយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះយាងទៅហើយយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះយាងមកកាន់លក្ខណៈដែលពិត ១ ឈ្មោះថា តថាគត ព្រោះត្រាស់ដឹងធម៌ដែលពិតតាមសេចក្តីពិត ១ ឈ្មោះថា

តថាគត ព្រោះជាអ្នកមានប្រក្រតីឃើញយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះភាពជាអ្នកមានប្រក្រតីត្រាស់យ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះជាអ្នកមានប្រក្រតីធ្វើយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះអត្ថថា គ្របសង្កត់ ១ ។ ក្នុងអធិការនេះ មានសេចក្តីសង្ខេបដូច្នេះថា ព្រះមានព្រះភាគព្រះនាមថា តថាគត ដោយហេតុ ៨ ប្រការយ៉ាងនេះ គឺឈ្មោះថា តថាគត ព្រោះយាងមកហើយដោយអាការយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះយាងទៅហើយដោយអាការយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះយាងទៅហើយកាន់លក្ខណៈយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះយាងមកហើយកាន់ភាពយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះទ្រង់ប្រព្រឹត្តទៅហើយយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះយាងមកហើយដោយអាការយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះភាពជាបុគ្គលយាងទៅហើយដោយអាការយ៉ាងនោះ ១ ឯសេចក្តីពិស្តារគប្បីជ្រាបដោយន័យដូចពោលមកហើយក្នុងអដ្ឋកថាឧទាន និងក្នុងអដ្ឋកថាឥតិវុត្តកៈ ឈ្មោះថា បរមត្ថទីបនី ឯណោះចុះ ។

ឥឡូវនេះ ដើម្បីសម្តែងគុណវិសេស ដែលមិនទូទៅនៃបញ្ញានោះ ទើបលោកពោលពាក្យជាដើមថា **អគ្គិ យថា** ដូច្នេះ ។ បទថា **យថា អគ្គិ** ជាពាក្យឧបមា ។ បទថា **យថា** ជាពាក្យសម្តែងសេចក្តីឧបមារបស់ពាក្យថា **អគ្គិ** នោះ ។ បទថា **បជ្ជលិតោ** សម្តែងដល់អត្ថដែលទាក់ទងគ្នាដោយឧបមេយ្យ ។ បទថា **និសីថេ** ជាពាក្យសម្តែងដល់ពេលដែលធ្វើកិច្ច ។ ក្នុង

បទថា **និសីថេ** នេះ មានពាក្យអធិប្បាយដូច្នេះថា កាលភាពងងឹតដែលប្រ-កបដោយអង្គ ៤ ក្នុងរាត្រី គឺក្នុងរាត្រីប្រព្រឹត្តទៅ ភ្លើងដែលឆេះហើយក្នុងទីទួល រមែងតាំងឡើងកម្ចាត់ងងឹតក្នុងប្រទេសនោះ យ៉ាងណា អ្នកចូរមើលបញ្ញាដែលកម្ចាត់ងងឹត គឺសេចក្តីសង្ស័យរបស់វេនេយ្យសត្វទាំងឡាយដោយប្រការទាំងពួងពោលគឺទេសនាញាណនេះរបស់ព្រះតថាគតទាំងឡាយ ដូច្នោះដូចគ្នាដូច្នេះឯង ។ បញ្ញា ឈ្មោះថា **អាលោកទា** ព្រោះជាហេតុឲ្យនូវពន្លឺដែលសម្រេចដោយញាណដល់សត្វទាំងឡាយ ដោយលីលានៃព្រះធម្មទេ-សនា ឈ្មោះថា **ចក្ខុទទា** ព្រោះឲ្យនូវចក្ខុដែលសម្រេចដោយបញ្ញាដូចគ្នា ។ ព្រះថេរៈ កាលសម្តែងដល់បញ្ញាទាំង ២ ធ្វើឲ្យជាបទដ្ឋាននៃការកម្ចាត់ការសង្ស័យដូចគ្នា ទើបពោលថា **យេ អាគតានំ វិនយន្តិ កង្ខំ** ដូច្នេះ ។

ព្រះតថាគតអង្គណារមែងលះបង់ គឺកម្ចាត់ បំបាត់នូវកង្ខារ គឺសេចក្តីសង្ស័យដែលមានវត្ថុ ១៦ ប្រព្រឹត្តទៅហើយ ដោយន័យជាដើមថា ក្នុងអតីតដ៏យូរលង់អញធ្លាប់មានមកហើយឬហ្ន៎ និងមានវត្ថុ ៨ ប្រការដែលប្រព្រឹត្តទៅហើយដោយន័យជាដើមថា រមែងសង្ស័យក្នុងព្រះពុទ្ធ រមែងសង្ស័យក្នុងព្រះធម៌ ដូច្នេះ ដល់ពួកវេនេយ្យសត្វដែលចូលដល់ គឺចូលទៅកាន់សម្នាក់របស់ព្រះអង្គដោយមិនមានចំណែកសេសសល់ដោយអានុភាពនៃទេសនា ។

ម្យ៉ាងទៀត ភ្លើងដែលឆេះរុងរឿង គឺមានពន្លឺរុងរឿង ក្នុងពេលយប់ គឺក្នុងពេលរាត្រីរមែងកម្ចាត់ងងឹតឲ្យភ្លឺស្វាង មើលឃើញទីរាបស្មើ និងមិនរាបស្មើបានច្បាស់ដល់បុគ្គលដែលឈរក្នុងទីខ្ពស់ តែសម្រាប់បុគ្គលដែល

នៅក្នុងទីទាប កាលធ្វើនូវពន្លឺនោះឲ្យប្រាកដល្អហើយ ឈ្មោះថា រមែងឲ្យនូវកែវភ្នែក ព្រោះធ្វើកិច្ច គឺការឃើញ យ៉ាងណា ព្រះតថាគតទាំងឡាយ ក៏យ៉ាងនោះ ដូចគ្នា កាលកម្ចាត់ងងឹត គឺមោហៈដល់បុគ្គលដែលតាំងនៅក្នុងទីឆ្ងាយអំពីធម្មកាយរបស់ព្រះអង្គ គឺបុគ្គលដែលមានអធិការ មិនបានធ្វើទុកដោយពន្លឺ គឺបញ្ញា ហើយទ្រង់ញុំាងនូវការស្មើនិងមិនស្មើ មានការស្មើដោយកាយនិងមិនស្មើដោយកាយជាដើមឲ្យជាក់ច្បាស់ ឈ្មោះថា ជាអ្នកប្រទានពន្លឺ ។ តែសម្រាប់បុគ្គលដែលនៅក្នុងទីជិត កាលប្រគល់នូវធម្មចក្ខុឲ្យដល់បុគ្គលដែលមានអធិការធ្វើហើយ ឈ្មោះថា ជាអ្នកប្រទានចក្ខុ ។

ប្រកបសេចក្តីថា ព្រះសាស្តាទាំងឡាយណា ជាបុគ្គលយ៉ាងនេះ តែងកម្ចាត់សេចក្តីសង្ស័យរបស់បុគ្គលដែលច្រើនទៅដោយសេចក្តីសង្ស័យ ដូចខ្ញុំដែលមកស្តាប់ឱវាទរបស់ព្រះអង្គ គឺកម្ចាត់បាន ដោយការញុំាងអរិយមគ្គឲ្យកើតឡើង ចូរអ្នកមើលព្រះបញ្ញា ដែលមានព្រះញាណ ដែលល្អក្រៃលែងនៃព្រះតថាគតទាំងនោះ ។ គាថានេះក៏ចាត់ជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈដោយប្រកាសដល់ការឈានកន្លងនូវសេចក្តីសង្ស័យរបស់ខ្លួន ។

ព្រះថេរៈក្នុងកាលជាបុថុជ្ជន ជាអ្នកមានសេចក្តីរង្កៀសក្នុងរបស់ដែលជាកប្បិយទើបប្រាកដនាមថា កង្ខារេវតៈ ព្រោះភាពជាអ្នកច្រើនទៅដោយសេចក្តីសង្ស័យ ក្រោយមក សូម្បីបានជាព្រះខីណាស្រព មនុស្សទាំងឡាយ ក៏នៅតែហៅលោកយ៉ាងនោះដូចគ្នា ។

ដោយហេតុនោះ ព្រះធម្មសង្គាហកាចារ្យក៏ពោលថា ឮថា កង្ខារេវតត្ថេរ

មានអាយុ បានពោលគាថា ដោយប្រការដូច្នេះ ។ ពាក្យនោះមានអត្ថដូច ខ្ញុំបានពោលហើយនោះឯង ។

## អដ្ឋកថា កង្ខារេវតត្ថេរគាថា ចប់

## បុណ្ណមន្តានីបុត្តត្ថេរគាថា

[ ៥ ] បុគ្គលគប្បីនៅរួមជាមួយនឹងពួកសប្បុរស ជាបណ្ឌិតអ្នកឃើញប្រយោជន៍ ព្រោះអ្នកប្រាជ្ញទាំងឡាយ អ្នកមានប្រាជ្ញាឈ្លាសវៃ មិនប្រមាទ តែងបានប្រយោជន៍ច្រើន ជ្រៅ ល្អិត ម៉ត់ចត់ ដែលឃើញបានដោយក្រ ។

ឮថា បុណ្ណត្ថេរមានអាយុ ជាបុត្តនាងមន្តានី បានពោលគាថា ដោយប្រការដូច្នេះ ។

បុណ្ណត្ថេរ ។

## អដ្ឋកថា
## បុណ្ណមន្តានីបុត្តត្ថេរគាថា

[ ៥ ] គាថារបស់ព្រះបុណ្ណត្ថេរ មានពាក្យផ្ដើមថា **សព្ភិរេវ សមាសេថ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះថេរៈនេះ កើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងក្រុងហង្សវតី មុនការកើតឡើងរបស់ព្រះទសពលព្រះនាមថា បទុមុត្តរៈ នោះឯង ដល់នូវការដឹងក្តីដោយលំដាប់ កាលព្រះសាស្តាកើតឡើងក្នុងលោក ទៅកាន់វិហារមួយអន្លើដោយមហាជន ដោយន័យដូចពោលហើយខាងដើមនោះឯង ក្នុងពេលសម្ដែងធម៌របស់ព្រះសម្ពុទ្ធ អង្គុយខាងចុងបរិស័ទ ស្ដាប់ធម៌ ឃើញព្រះសាស្តាស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងនៃភិក្ខុដែលក្រៃលែង ជាងធម្មកថិកទាំងឡាយ គិតថា ក្នុងអនាគតកាលអាត្មាអញ ក៏គួរដូចភិក្ខុរូបនេះ ក្នុង

កាលចប់ទេសនា កាលបរិស័ទរំសាយហើយ ចូលទៅគាល់ព្រះសាស្តាទូល អារាធនាហើយធ្វើមហាសក្ការៈដោយន័យដូចពោលហើយខាងដើម នោះឯង ហើយក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ដោយការសាងបុញ្ញាធិការនេះ ខ្ញុំព្រះអង្គមិនប្រាថ្នាសម្បត្តិដទៃ តែក្នុងអនាគតកាល សូមឲ្យខ្ញុំព្រះអង្គជាអ្នកក្រៃលែងជាងភិក្ខុទាំងឡាយ ខាងធម្មកថិក ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយ ដូចភិក្ខុរូបនោះដែលទ្រង់តាំងទុកក្នុងតំណែងនៃភិក្ខុដែលក្រៃលែងជាងភិក្ខុទាំងឡាយដែលជាធម្មកថិក ក្នុងថ្ងៃទី ៧ មុននោះចុះ ដូច្នេះហើយ តម្កល់សេចក្តីប្រាថ្នាទុក ។

ព្រះបរមសាស្តា ទ្រង់ប្រមើលមើលអនាគតកាល ទ្រង់ឃើញសេចក្តីសម្រេចនៃការប្រាថ្នា របស់កុលបុត្តនោះ ទើបទ្រង់ព្យាករថា ក្នុងទីបំផុតនៃមួយសែនកប្ប ក្នុងអនាគតកាល ព្រះពុទ្ធព្រះនាមថា គោតមនឹងកើតឡើងក្នុងលោក អ្នកបួសក្នុងសាសនារបស់ទ្រង់ហើយនឹងបានជាភិក្ខុកំពូលជាងភិក្ខុទាំងឡាយ ខាងធម្មកថិក ដូច្នេះ ។

កុលបុត្តនោះ សាងកល្យាណកម្មក្នុងមនុស្សលោក ដរាបដល់អស់ជីវិត ចុតិអំពីមនុស្សលោកហើយសន្សំបុណ្យ និងញាណសម្ភារអស់មួយសែនកប្ប អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ កាលដល់សាសនានៃព្រះមានព្រះភាគរបស់យើងទាំងឡាយ កើតជាក្មួយរបស់ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ ក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងស្រុកព្រាហ្មណ៍ ឈ្មោះថា ទោណវត្ថុ មិនឆ្ងាយអំពីនគរកបិលពស្តុ ក្នុងថ្ងៃដាក់ឈ្មោះរបស់កុលបុត្តនោះ ជនទាំងឡាយ

ក៏បានដាក់ឈ្មោះថា បុណ្ណៈ ។

កាលព្រះបរមសាស្តាត្រាស់ដឹងអភិសម្ពោធិញ្ញាណ ទ្រង់ប្រកាសធម្មចក្កដ៏ប្រសើរ យាងទៅកាន់ក្រុងរាជគ្រឹះដោយលំដាប់ ចូលទៅអាស្រ័យក្រុងរាជគ្រឹះនោះគង់នៅ ។ បុណ្ណមាណពបួសក្នុងសម្នាក់នៃព្រះអញ្ញាកោណ្ឌញ្ញត្ថេរ បានឧបសម្បទាហើយ ធ្វើបុព្វកិច្ចសព្វយ៉ាងហើយ ខ្វល់ខ្វាយក្នុងសេចក្តីព្យាយាម គិតថា អញញុំាងកិច្ចនៃបព្វជិតឲ្យដល់នូវទីបំផុតហើយ នឹងទៅកាន់សម្នាក់ របស់ព្រះទសពល ហើយមិនទៅកាន់សម្នាក់របស់ព្រះសាស្តាមួយអន្លើដោយព្រះថេរៈដែលជាអ៊ំ សម្រាកក្នុងនគរកបិលពស្តុ ហើយធ្វើកម្មក្នុងយោនិសោមនសិការ ខ្វល់ខ្វាយវិបស្សនាហើយសម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

> ខ្ញុំជាអ្នកបង្រៀនមន្ត ចេះចាំមន្ត សម្រេចត្រៃវេទ មានពួកសិស្សចោមរោមហើយ បានចូលទៅគាល់ព្រះសម្មាសម្ពុទ្ធដ៏ប្រសើរជាងនរជន ។ ព្រះមហាមុនីព្រះនាម បទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវសត្វលោក ព្រះអង្គជាអ្នកគួរទទួលគ្រឿងបូជា បានសម្តែងនូវកម្មរបស់ខ្ញុំ ដោយសង្ខេប ។ ខ្ញុំបានស្តាប់ធម៌នោះហើយ ក៏ផ្គងអញ្ជលីថ្វាយបង្គំព្រះសាស្តា ហើយបែរមុខឆ្ពោះទៅកាន់ទិសទក្សិណដើរចេញទៅ ។ ខ្ញុំបានស្តាប់ដោយសង្ខេបទេ តែអាចសម្តែងដោយពិស្តារបាន ពួកសិស្សទាំងអស់បានស្តាប់ភាសិតដែលខ្ញុំសម្តែង ក៏មានចិត្តរីករាយគ្រប់ៗគ្នា ។

ពួកសិស្សទាំងនោះ លះបោលនូវទិដ្ឋិរបស់ខ្លួនហើយ ធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធ ខ្ញុំសំម្ដែងដោយសង្ខេបក៏បាន ដោយពិស្ដារយ៉ាងនោះក៏បាន ។ ខ្ញុំឈ្លាសវៃក្នុងន័យព្រះអភិធម្ម ឈ្លាសវៃក្នុងវិសុទ្ធិក្នុងកថាវត្ថុ ញុំាងជនជាបណ្ឌិតទាំងពួង ឲ្យត្រាស់ដឹង ទាំងជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ៥០០ អំពីកប្បនេះទៅ ខ្ញុំកើតជាស្ដេចចក្រពត្តិ ៤ ជង មានកេរ្តិ៍ឈ្មោះល្បីល្បាញទូទៅ បរិបូណ៌ដោយកែវទាំង ៧ ប្រការ ជាឥស្សរៈក្នុងទ្វីប ៤ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

កុលបុត្តអ្នកបួសក្នុងសម្នាក់ព្រះបុណ្ណត្ថេរនោះ មានប្រមាណ ៥០០ ។ ព្រះថេរៈបង្រៀនភិក្ខុទាំង ៥០០ រូបនោះ ដោយកថាវត្ថុ ១០ ព្រោះខ្លួនលោកជាអ្នកបាននូវកថាវត្ថុ ១០ ភិក្ខុទាំង ៥០០ រូបនោះតាំងនៅក្នុងឱវាទរបស់ព្រះថេរៈ សម្រេចអរហត្ត ។ ភិក្ខុទាំងនោះ ដឹងថា កិច្ចនៃបព្វជិតរបស់ខ្លួនដល់ទីបំផុតហើយ ទើបនាំគ្នាទៅរកព្រះឧបជ្ឈាយ៍ ពោលថា បពិត្រលោកម្ចាស់ កិច្ចរបស់យើងខ្ញុំដល់ទីបំផុតហើយ ទាំងបាននូវកថាវត្ថុទាំង ១០ ទៀតផង ឥឡូវនេះ ជាឱកាសដែលពួកខ្ញុំចូលគាល់ព្រះទសពល ។

ព្រះថេរៈស្ដាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ គិតថា ព្រះសាស្ដាទ្រង់ជ្រាបភាពដែលអញជាអ្នកបានកថាវត្ថុ ១០ កាលអញសំម្ដែងធម៌ ក៏មិនលះ

កថាវត្ថុ ១០ កាលអញទៅ ភិក្ខុទាំងអស់នេះនឹងចោមរោមអញទៅ ការចូលគាល់ព្រះទសពលដោយការប្រឡូកប្រឡំដោយពួកគណៈយ៉ាងនេះ មិនគួរដល់អញឡើយ ភិក្ខុទាំងនេះចូរទៅគាល់មុនចុះ ដូច្នេះ ទើបពោលនឹងភិក្ខុទាំងនោះថា អាវុសោទាំងឡាយ លោកទាំងឡាយចូរទៅមុនគាល់ព្រះមានព្រះភាគ និងចូរថ្វាយបង្គំបាទារបស់ទ្រង់ តាមពាក្យខ្ញុំ ឯខ្ញុំនឹងទៅតាមក្រោយតាមផ្លូវដែលលោកទាំងឡាយទៅហើយនោះឯង ។

ព្រះថេរៈទាំងនោះគ្រប់ៗរូប សុទ្ធតែជាអ្នកកើតក្នុងជាតិភូមិរបស់ព្រះទសពល មួយរូបៗសុទ្ធតែជាព្រះខីណាស្រព មួយរូបៗសុទ្ធតែមានប្រក្រតីបាននូវកថាវត្ថុ ១០ ទទួលឱវាទឧបជ្ឈាយ៍របស់ខ្លួនហើយ ថ្វាយបង្គំព្រះថេរៈត្រាច់ទៅតាមលំដាប់ រំលងផ្លូវប្រមាណ ៦០ យោជន៍ ដល់វេឡុវនមហាវិហារនាក្រុងរាជគ្រឹះ ថ្វាយបង្គំបាទាព្រះទសពល ហើយអង្គុយក្នុងចំណែកម្ខាង ។

ការចរចាប្រាស្រ័យជាមួយអាគន្តុកភិក្ខុទាំងឡាយ ជាទំនៀមដែលព្រះមានព្រះភាគសម្មាសម្ពុទ្ធទាំងឡាយទ្រង់ប្រតិបត្តិជាប្រចាំ ព្រោះហេតុនោះទើបព្រះមានព្រះភាគ ធ្វើបដិសណ្ឋារៈជាមួយភិក្ខុទាំងនោះ ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយល្មមអត់ធន់បានឬ ដូច្នេះហើយត្រាស់សួរទៀតថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមកអំពីណា កាលភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបដល់ជាតិភូមិហើយ ទើបត្រាស់សួរភិក្ខុដែលបាននូវកថាវត្ថុ ១០ ថា ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុដែលជាសព្រហ្មចារី

ដែលមានជាតិភូមិក្នុងទឹកដីកំណើតទាំងឡាយ អ្នកណាហ្ន៎ ដែលត្រូវលើកតម្កើងថា ខ្លួនឯងក៏មានសេចក្តីប្រាថ្នាតិច និងធ្វើការប្រៀនប្រដៅឲ្យភិក្ខុទាំងឡាយមានសេចក្តីប្រាថ្នាតិចផងដែរ ។

ភិក្ខុក៏នាំគ្នាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មានភិក្ខុឈ្មោះ បុណ្ណមន្តានីបុត្ត ។ ព្រះសារីបុត្តស្តាប់ពាក្យនោះហើយមានបំណងចង់ជួបព្រះថេរៈ ។

ក្នុងកាលតមក ព្រះសាស្តាចេញអំពីក្រុងរាជគ្រឹះ ទៅកាន់នគរសាវត្ថី ។ ព្រះបុណ្ណត្ថេរដឹងថា ព្រះសាស្តាយាងមកទីនោះ ទើបទៅដោយគិតថា អាត្មាអញនឹងគាល់ព្រះសាស្តា បានចូលគាល់ព្រះមានព្រះភាគ ខាងក្នុងព្រះគន្ធកុដិនោះឯង ។

ព្រះសាស្តាទ្រង់សម្តែងធម៌ដល់ព្រះថេរៈ ព្រះថេរៈស្តាប់ធម៌ហើយ ថ្វាយបង្គំព្រះទសពល ចូលទៅកាន់ព្រៃអន្ធវ័នដើម្បីពួនសម្ងំ អង្គុយសម្រាកពេលថ្ងៃ ត្រង់គល់ឈើមួយដើម ។

ព្រះសារីបុត្តត្ថេរ ដឹងការមករបស់ព្រះបុណ្ណៈ ទើបដើរតាមទៅ ដោយចម្ងាយល្មមមើលឃើញក្បាល កំណត់ឱកាសហើយ ទើបចូលទៅរកព្រះបុណ្ណត្ថេរ អង្គុយត្រង់គល់ឈើ សន្ទនាជាមួយព្រះថេរៈហើយ ទើបសាកសួរដល់លំដាប់នៃវិសុទ្ធិ ៧ ជាមួយព្រះថេរៈ ។

ព្រះថេរៈ ព្យាករបញ្ហាដែលព្រះសារីបុត្តនោះសួរហើយ ញុំាងចិត្តព្រះសារីបុត្តឲ្យត្រេកអរដោយឧបមាអំពីទីដែលនាំទៅដល់បានដោយរថ ។ លោកទាំង ២ នោះ ត្រេកអរនូវភាសិតនៃគ្នានឹងគ្នា ។

*ក្នុងកាលតមក ព្រះសាស្តាគង់កណ្តាលជំនុំសង្ឃ ទ្រង់តាំងព្រះថេរៈក្នុងឯតទគ្គៈក្រៃលែងជាងភិក្ខុដែលជាធម្មកថិកទាំងឡាយ ដោយព្រះពុទ្ធតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុជាធម្មកថិកដែលជាសាវករបស់តថាគត ស្រេចនឹងបុណ្ណមន្តានីបុត្តប្រសើរជាងគេ ដូច្នេះ ។*

*ថ្ងៃមួយ លោកពិចារណាដល់វិមុត្តិសម្បត្តិរបស់ខ្លួន កើតនូវបីតិនិងសោមនស្សថា អាត្មាអញ និងពួកសត្វដទៃជាច្រើនអាស្រ័យព្រះបរមសាស្តារួចផុតចាកសង្សារទុក្ខហើយ ការគប់រកបុគ្គលជាសប្បុរសមានឧបការៈច្រើនហ្ន៎ ដូច្នេះ ទើបពោលគាថាដោយកម្លាំងបីតិ ដោយអំណាចនៃឧទានថា*

> *បុគ្គលគប្បីនៅរួមជាមួយនឹងពួកសប្បុរសជាបណ្ឌិតអ្នកឃើញប្រយោជន៍ ព្រោះអ្នកប្រាជ្ញទាំងឡាយ អ្នកមានប្រាជ្ញាឈ្លាសវៃ មិនប្រមាទ តែងបានប្រយោជន៍ច្រើន ជ្រៅ ល្អិត ម៉ត់ចត់ ដែលឃើញបានដោយក្រ ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **សព្ភិរេវ** *បានដល់ ដោយសប្បុរសទាំងឡាយប៉ុណ្ណោះ ។ ក្នុងគាថានេះ ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើមលោកបំណងយកថា ជាសប្បុរស ។ ព្រះពុទ្ធជាដើមទាំងនោះ លះនូវធម៌របស់អសប្បុរសទាំងឡាយបានហើយ ដោយមិនសេសសល់ និងសរសើរគុណធម៌ដ៏ល្អក្រៃលែង ព្រោះសម្រេចដល់ព្រះសទ្ធម្មយ៉ាងឧក្រិដ្ឋ ទើបលោកហៅថា ជាសប្បុរសដែលស្ងប់រម្ងាប់ហើយ ។*

*បទថា* **សមាសេថ** *សេចក្តីថា គប្បីនៅស្មើ គឺនៅរួម អធិប្បាយថា កាល*

ចូលទៅជិតលោកទាំងនោះ ត្រងត្រាប់ស្តាប់នឹងដល់នូវទិដ្ឋានុគតិរបស់លោកទាំងនោះ ឈ្មោះថា ជាអ្នកនៅរួម ។

បាទព្រះគាថាថា **បណ្ឌិតេហត្ថទស្សិភិ** ជាពាក្យពោលលើកតម្កើងព្រះអរិយៈទាំងនោះ ។ បញ្ញាលោកហៅថា **បណ្ឌា** ឈ្មោះថា ជាបណ្ឌិត ព្រោះមានបញ្ញាដែលជា **បណ្ឌា** នោះ ។ បន្ទាប់អំពីនោះទៅ ក៏ឈ្មោះថា **អត្ថទស្សិនោ** ព្រោះឃើញប្រយោជន៍ មានប្រយោជន៍ខ្លួនជាដើម ដោយមិនវិបរិត ។ គប្បីគប់រកបណ្ឌិតដែលឃើញប្រយោជន៍ទាំងនោះ ។

បើមានពាក្យសួរថា ព្រោះហេតុអ្វី ក៏ឆ្លើយថា ព្រោះលោកទាំងនោះ ជាសប្បុរស ជាបណ្ឌិត ម្យ៉ាងទៀត ព្រោះកាលសេពគប់លោកទាំងនោះដោយប្រពៃរមែងឈ្មោះថា សម្រេចប្រយោជន៍ ព្រោះមានតែប្រយោជន៍ ដោយចំណែកមួយ និងព្រោះមិនមានកិលេសដែលជាហេតុឲ្យយំ ដោយមគ្គញាណជាដើម ដែលឈ្មោះថា **មហន្តំ** ព្រោះមានគុណច្រើន និងព្រោះល្អិត ដែលឈ្មោះថា **គម្ភីរំ** ព្រោះស្ទង់មិនដល់ និងព្រោះមានអារម្មណ៍ គឺញាណដ៏ជ្រាលជ្រៅ ដែលឈ្មោះថា **ទុទ្ទសំ** ព្រោះជាអ្នកមានធនូៈជាដើម គ្រោតគ្រាត មិនអាចឃើញបាន និងព្រោះបុគ្គលក្រៅអំពីនេះឃើញបានដោយក្រ ដែលឈ្មោះថា **និបុណំ** ព្រោះឃើញ បានដោយក្រ ព្រោះជាសភាវៈដ៏ល្អិត និងព្រោះជាអារម្មណ៍របស់ញាណដែលល្អិត ដែលឈ្មោះថា **អណុំ** ព្រោះជាសភាវៈសុខុម ព្រោះជាធម៌ដែលល្អិតនោះឯង ( ប្រយោជន៍ដែលពោលមកទាំងអស់នេះ ) ក៏គឺព្រះនិព្វាន ម្យ៉ាងទៀត ឈ្មោះថា **អត្ថំ** ព្រោះជាសភាវៈ

បរមត្ថ ដោយអត្ថថា មិនប្រែប្រួល ឈ្មោះថា **មហាន្តំ** ព្រោះធ្វើនូវភាពជាព្រះអរិយៈ និងព្រោះជានិមិត្តនៃភាពជាធំក្រៃលែង ដែលឈ្មោះថា **គម្ភីរំ** ព្រោះមានការមិនរាក់ជាសភាវៈ ឈ្មោះថា **ទុទ្ទសំ** ព្រោះឃើញបានដោយក្រ គឺមិនអាចឃើញបានដោយងាយ ឈ្មោះថា ឃើញបានដោយក្រនេះ ព្រោះជ្រៅ ឈ្មោះថា ជ្រៅនេះ ព្រោះឃើញបានដោយក្រ ( ប្រយោជន៍ដែលពោលមកទាំងអស់នេះ ) ក៏គឺសច្ចៈ ៤ ។ ដោយពិសេសជាងនេះទៅទៀត ប្រយោជន៍ដែលល្អិតសុខុម ក៏គឺនិរោធសច្ចៈ ព្រោះហេតុនោះ ធីរជនរមែងសម្រេចសច្ចៈ ៤ នេះ យ៉ាងនេះ គឺបុគ្គលទាំងឡាយ ឈ្មោះថា **ធីរា** ព្រោះសម្បូរដោយបញ្ញាជាគ្រឿងទ្រទ្រង់ចាំ ខ្វល់ខ្វាយកម្មដ្ឋានការនាដែលមានសច្ចៈ ៤ ជាអារម្មណ៍ រមែងត្រាស់ដឹងដោយប្រពៃនោះឯង ។

បទថា **អប្បមត្តា** សេចក្តីថា ញុំាំងបដិបទា គឺការមិនប្រមាទឲ្យបរិបូណ៌ ដោយការមិនទៅប្រាសចាកសតិ ក្នុងទីទាំងពួង ។

បទថា **វិចក្ខណា** បានដល់ មុតស្រួច ឈ្លាសក្នុងវិបស្សនាការនា ។ ភ្ជាប់សេចក្តីថា ព្រោះហេតុនោះ គប្បីសេពគប់ជាមួយសប្បុរសទាំងឡាយនោះឯង ។ ម្យ៉ាងទៀត បទថា **បណ្ឌិតេហាត្ថទស្សិភិ** នេះ ជាបញ្ចមីវិភត្តិ ភ្ជាប់សេចក្តីថា ព្រោះហេតុដែលធីរជនទាំងឡាយជាបុគ្គលមិនប្រមាទ ឃើញប្រចក្សដោយបញ្ញា រមែងសម្រេចប្រយោជន៍ពិសេស មានភាពជាអ្នកធំក្រៃលែងជាដើមអំពីបណ្ឌិតទាំងឡាយដែលឃើញប្រយោជន៍ ជាទីកើតនៃសេចក្តីល្អ ព្រោះហេតុនោះ គប្បីសេពគប់សប្បុរស ដែលមានសភាពបែបនោះតែ

ម្យ៉ាង ។

គាថានេះចាត់ជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈដោយការសម្តែងដល់បដិវេធធម៌ ដូច្នេះឯង ។

## អដ្ឋកថា បុណ្ណមន្តានីបុត្តត្ថេរគាថា ចប់

## ធព្វមល្លបុត្តត្ថេរគាថា

[ ៦ ] ភិក្ខុណាឈ្មោះទព្វៈដែលគេទូន្មានបានដោយក្រ បានទូន្មានដោយការទូន្មាន ( ឥន្ទ្រិយ ) ជាព្រះថេរៈមានចិត្តសន្តោស ឆ្លងសេចក្តីសង្ស័យ មានជ័យជំនះ ប្រាសចាកសេចក្តីតក់ស្លុត ភិក្ខុទព្វមល្លបុត្តនោះមានចិត្តខ្ជាប់ខ្ជួន បរិនិព្វានហើយ ។

ឮថា ទព្វត្ថេរមានអាយុ បានពោលគាថា ដោយប្រការដូច្នេះ ។

**ទព្វត្ថេរ ។**

## អដ្ឋកថា

## ធព្វមល្លបុត្តត្ថេរគាថា

[ ៦ ] គាថាព្រះទព្វត្ថេរ មានពាក្យផ្តើមថា **យោ ទុទ្ទមយោ** ដូច្នេះជាដើម ។ រឿងរបស់លោកមានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះថេរៈនេះ កើតក្នុងផ្ទះមានត្រកូលមួយក្នុងក្រុងហង្សវតី ក្នុងសាសនារបស់ព្រះពុទ្ធ ព្រះនាមថាបទុមុត្តរៈ ចម្រើនវ័យហើយ ស្តាប់ព្រះធម្មទេសនាដោយន័យដូចពោលហើយខាងដើមនោះឯង ឃើញព្រះបរមសាស្តា ទ្រង់តាំងភិក្ខុមួយរូបទុកក្នុងតំណែងនៃភិក្ខុដ៏ប្រសើរជាងភិក្ខុទាំងឡាយ ខាងក្រាលសេនាសនៈ ទើបផ្តើមសាងអធិការ ប្រាថ្នាតំណែងនោះ ជាបុគ្គលដែលព្រះបរមសាស្តា ទ្រង់ព្យាករហើយ បំពេញកុសលជរាបដល់អស់ជីវិត ហើយអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ បួសក្នុងវេលាដែលសាសនា

របស់ព្រះទសពលព្រះនាមថាកស្សបៈសាបសូន្យទៅ ។

ក្នុងគ្រានោះ មានភិក្ខុ ៦ រូប មួយអន្ទើជាមួយលោក រួមជា ៧ រូប មានការគិតដូចគ្នា ឃើញភិក្ខុដទៃមិនធ្វើនូវការគោរពក្នុងព្រះសាសនា ទើបគិតគ្នាថា ក្នុងទីនេះ ពួកយើងនឹងធ្វើអ្វីបាន ពួកយើងនឹងបំពេញសមណធម៌ក្នុងទីគួរមួយកន្លែង ហើយនឹងធ្វើទីបំផុតទុក្ខ ដូច្នេះហើយ ទើបចងជណ្តើរឡើងកាន់កំពូលភ្នំខ្ពស់ និយាយគ្នាថា បុគ្គលដែលដឹងកម្លាំងចិត្តរបស់ខ្លួនចូរប្រានជណ្តើរទម្លាក់ អ្នកណាអាឡោះអាល័យជីវិត សូមចុះវិញចុះ កុំក្តៅក្រហាយក្នុងកាលជាខាងក្រោយឡើយ ដូច្នេះហើយ ភិក្ខុទាំងនោះមានចិត្តតែមួយ ក៏ទម្លាក់ជណ្តើរចោល ទូន្មានគ្នានឹងគ្នាថា អាវុសោទាំងឡាយ អ្នកទាំងឡាយ ចូរជាអ្នកមិនប្រមាទចុះ ហើយអង្គុយក្នុងទីដែលខ្លួនពេញចិត្តផ្តើមបំពេញសមណធម៌ ។

ក្នុងភិក្ខុទាំងនោះ ព្រះថេរៈសម្រេចអរហត្តផលក្នុងថ្ងៃទី ៥ ក្នុងទីនោះឯង គិតថា កិច្ចរបស់អញស្រេចហើយ អញនឹងធ្វើអ្វីក្នុងទីនេះ ដូច្នេះហើយទៅបិណ្ឌបាតក្នុងឧត្តរកុរុទ្វីបដោយឫទ្ធិមកហើយពោលថា អាវុសោទាំងឡាយពួកលោកចូរឆាន់បិណ្ឌបាតនេះ កិច្ចដោយភិក្ខាជានាទីរបស់ខ្ញុំ ពួកលោកចូរធ្វើកិច្ចរៀងៗខ្លួនចុះ ។ ភិក្ខុទាំងឡាយសួរថា អាវុសោ ពួកយើងទម្លាក់ជណ្តើរចោល មិនបាននិយាយគ្នាយ៉ាងនេះថា អ្នកណាសម្រេចធម៌មុន អ្នកនោះត្រូវនាំអាហារមក ភិក្ខុដ៏សេសនឹងបរិភោគអាហារ ដែលនាំមកហើយ ហើយបំពេញសមណធម៌ដូច្នេះទេពិតមែនឬ ព្រះថេរៈពោលថា អើ អាវុសោ មិន

មានកតិកាដូច្នេះទេ ។ ភិក្ខុទាំងឡាយ ក៏ពោលថា លោកសម្រេចធម៌ដោយបុញ្ញហេតុរបស់ខ្លួនពួកខ្ញុំអាចធ្វើទីបំផុតនៃទុក្ខបាន សូមលោកទៅចុះ ដូច្នេះ ។ ព្រះថេរៈ កាលមិនអាចឲ្យភិក្ខុទាំងនោះយល់ព្រមបាន ក៏ធាន់បិណ្ឌបាតក្នុងទីដែលជាផាសុក ហើយក៏ចៀសចេញទៅ ។ ព្រះថេរៈមួយរូបទៀត សម្រេចអនាគាមិផលក្នុងថ្ងៃទី ៧ ចុតិអំពីភពនោះហើយ កើតក្នុងព្រហ្មលោកជាន់សុទ្ធាវាស ព្រះថេរៈក្រៅអំពីនេះ ចុតិអំពីភពនោះហើយ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយអស់មួយពុទ្ធន្តរ ហើយកើតក្នុងត្រកូលនោះៗ ក្នុងពុទ្ធុប្បាទយើងនេះ មួយរូបកើតក្នុងរាជត្រកូល ក្នុងតក្កសិលានគរដែនគន្ធារៈ មួយរូបកើតក្នុងផ្ទៃបរិញ្វជិកាក្នុងមជ្ឈន្តិករដ្ឋ មួយរូបកើតក្នុងផ្ទះកុដុម្ពិកៈ ដែនពាហិយៈ មួយរូបកើតក្នុងសម្នាក់របស់ភិក្ខុនី ។

ចំណែកព្រះទព្វត្ថេរនេះ បដិសន្ធិក្នុងវង្សរបស់ស្តេចមល្លៈ ក្នុងអនុបិយនគរដែនមល្លៈ ។ មាតារបស់លោកស្លាប់ក្នុងថ្ងៃប្រសូត មនុស្សទាំងឡាយក៏នាំយកសរីរៈទៅកាន់ឈាបនដ្ឋាន លើកឡើងកាន់ជើងថ្ករ ហើយដុតភ្លើងៗព្រោះកម្លាំងនៃភ្លើង ធ្វើឲ្យពោះរបស់នាងបែកចេញជា ២ ចំណែក ទារកអណ្តែតឡើងដោយកម្លាំងបុណ្យរបស់ខ្លួន ហើយធ្លាក់ត្រង់គំនរឧស មនុស្សទាំងឡាយក៏នាំទារកនោះមកប្រគល់ឲ្យជីដូន ។ ជីដូនកាលនឹងដាក់ឈ្មោះទារកនោះបានដាក់ឈ្មោះថា ទព្វៈ ព្រោះរួចចាកជីវិតមកធ្លាក់ត្រង់សសរឈើ ។

ក្នុងកាលដែលទារកនោះអាយុ ៧ ឆ្នាំ ព្រះបរមសាស្តា មានភិក្ខុសង្ឃជាបរិវារ ចារិកទៅកាន់ដែនមល្លៈ គង់នៅក្នុងអនុបិយម្ពវ័ន ។ ទព្វកុមារឃើញ

ព្រះសាស្ដាហើយជ្រះថ្លាដោយត្រឹមតែការឃើញប៉ុណ្ណោះ បំណងនឹងបួសទើបលាជីដូនថា ខ្ញុំនឹងបួសក្នុងសម្នាក់ព្រះទសពល ជីដូនពោលថា សាធុ ហើយនាំទព្វកុមារទៅកាន់សម្នាក់របស់ព្រះសាស្ដា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ឲ្យកុមារនេះបព្វជ្ជាចុះ ព្រះសាស្ដា ទ្រង់ឲ្យសញ្ញាដល់ភិក្ខុមួយរូបថា ម្នាលភិក្ខុ ចូរអ្នកឲ្យទារកនេះបព្វជ្ជា ព្រះថេរៈស្ដាប់ពាក្យរបស់ព្រះសាស្ដាហើយកាលនឹងឲ្យទព្វកុមារបព្វជ្ជា ក៏ប្រាប់តចបញ្ចកកម្មដ្ឋាន ។

សត្វដែលសម្បូរដោយបុព្វហេតុ មានអភិនីហារដែលធ្វើហើយ តាំងនៅក្នុងសោតាបត្តិផលក្នុងខណៈកោរសក់មួយកាំបិតដំបូង ក្នុងកាំបិតទី ២ តាំងនៅក្នុងសកទាគាមិផល ក្នុងកាំបិតទី ៣ តាំងនៅក្នុងអនាគាមិផល ក្នុងពេលកោរសក់ស្រេច ក៏ធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល មិនមុនមិនក្រោយ ។

ព្រះបរមសាស្ដា ទ្រង់សម្រាកសម្រាន្តឥរិយាបថ ក្នុងដែនមល្លៈហើយយាងទៅកាន់ក្រុងរាជគ្រឹះ គង់នៅក្នុងវេឡុវនមហាវិហារ ។

ឯព្រះទព្វមល្លបុត្តនេះ សម្ងំក្នុងទីស្ងាត់ ពិចារណាមើលការសម្រេចកិច្ចរបស់ខ្លួន បំណងនឹងឧទ្ទិសកាយ ជួយខ្វល់ខ្វាយកិច្ចរបស់សង្ឃ ទើបគិតថា ធ្វើម្ដេចហ្ន៎ អញគប្បីក្រាលសេនាសនៈ និងរៀបចំភត្តាហារដើម្បីភិក្ខុសង្ឃ ។ លោកចូលទៅកាន់សម្នាក់ របស់ព្រះសាស្ដាហើយ ក្រាបទូលដល់បរិវិតក្ករបស់ខ្លួន ។ ព្រះបរមសាស្ដាប្រទានសាធុការហើយ ទ្រង់ប្រទានតំណែងក្រាលអាសនៈនិងតំណែងភត្តុទ្ទេសក៍ដល់លោក ។

លំដាប់នោះព្រះបរមសាស្ដាទ្រង់ព្រះត្រិះរិះថា ទព្វសាមណេរនេះនៅក្មេង

ពិត តែតាំងនៅក្នុងមហាតំណែង ដូច្នេះហើយទើបទ្រង់ឲ្យឧបសម្បទា ក្នុងកាលដែលមានអាយុ ៧ ឆ្នាំប៉ុណ្ណោះ ។ តាំងពីឧបសម្បទាហើយ ព្រះថេរៈចាត់ចែងសេនាសនៈនិងចែកកត្តដល់ភិក្ខុសង្ឃទាំងអស់ ដែលអាស្រ័យក្រុងរាជគ្រឹះ ភាពដែលលោករៀបចំសេនាសនៈ បានប្រាកដ ល្បីទៅគ្រប់ទិសថា បានឮថា ព្រះទព្វមល្លបុត្តចាត់ចែងសេនាសនៈ ដល់ភិក្ខុដែលត្រូវអធ្យាស្រ័យគ្នាក្នុងទីតែមួយ ចាត់ចែងសេនាសនៈក្នុងទីជិតស្រុកខ្លះ ក្នុងទីឆ្ងាយស្រុកខ្លះ កាលមិនអាចទៅបានលោកក៏នាំទៅដោយឫទ្ធិ ។

កាលនោះ ភិក្ខុទាំងឡាយសូមឲ្យព្រះទព្វមល្លបុត្ត ចាត់ចែងសេនាសនៈទាំងក្នុងពេល ទាំងក្រៅពេល យ៉ាងនេះថា អាវុសោ សូមលោកចាត់ចែងសេនាសនៈក្នុងជីវកម្ពវនវិហារឲ្យពួកខ្ញុំ សូមលោកចាត់ចែងសេនាសនៈក្នុងមទ្ទកុច្ឆិមិគទាយវនឲ្យពួកខ្ញុំ បានឃើញឫទ្ធិ របស់ព្រះទព្វមល្លបុត្តនោះហើយទើបទៅ ។ ព្រះទព្វមល្លបុត្តក៏និម្មិតកាយដែលសម្រេចដោយមនោមយិទ្ធិ ឲ្យភិក្ខុដែលដូចខ្លួនមួយរូបមួយអង្គៗដើរខាងមុខ ប្រើម្រាមដៃជាគ្រឿងបំភ្លឺប្រាប់ថា នេះគ្រែ នេះតាំង រៀបចំសេនាសនៈហើយ ទើបត្រឡប់មកកាន់សម្នាក់របស់ខ្លួន នេះជាសេចក្តីសង្ខេបក្នុងរឿងនេះ ។ តែដោយពិស្តារ រឿងនេះមានមកក្នុងព្រះបាលីហើយនោះឯង ព្រះបរមសាស្តាទ្រង់ធ្វើហេតុនេះឯង ឲ្យជាអត្ថុប្បត្តិហេតុក្នុងកាលតមក ទ្រង់គង់កណ្តាលពួកព្រះអរិយសង្ឃ បានតែងតាំងព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈជាងបណ្តាភិក្ខុ ខាងចាត់ចែងសេនាសនៈដោយព្រះពុទ្ធតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកក្រាលសេនា

សនៈ ដែលជាសាវករបស់តថាគត ស្រេចនឹងទទួលមួយបុត្ត ប្រសើរជាងគេ ដូច្នេះ ។ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រះជិនស្រីព្រះនាម បទុ-មុត្តរៈ ជាអ្នកប្រាជ្ញ ទ្រង់ជ្រាបនូវលោកទាំងពួង ព្រះអង្គមានចក្ខុ ទ្រង់កើតឡើងហើយ ។ ព្រះពុទ្ធទ្រង់ប្រទានឱវាទ ទ្រង់បំភ្លឺ ទ្រង់ចម្លងពួកសត្វទាំងពួង ទ្រង់ឈ្លាសក្នុងទេសនា ចម្លងប្រជុំជនដ៏ច្រើន ។ ព្រះអង្គមានសេចក្តីអនុគ្រោះ មានសេចក្តីករុណា ទ្រង់ស្វែងរកប្រយោជន៍ដល់សត្វទាំងពួង តែងញុំាងតិរ្ថិយទាំងពួងដែលជួបប្រទះ ឲ្យតាំងនៅក្នុងសីល ៥ ។ កាលយ៉ាងនេះ សាសនារបស់ព្រះអង្គមិនរីករវរ ជាសាសនាសូន្យចាកពួកតិរ្ថិយ ជាសាសនាវិចិត្រដោយពួកព្រះអរហន្ត ដែលស្ទាត់ជំនាញ ជាតាទិបុគ្គល ។ ព្រះមហាមុនីអង្គនោះ មានកម្ពស់ ៥៨ ហត្ថ ប្រាកដស្មើដោយគ្រឿងបូជា ជាវិការៈនៃមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ មានព្រះជន្មាយុមួយសែនឆ្នាំ ព្រះបទុមុត្តរៈអង្គនោះ កាលប្រតិស្ឋាននៅ ទ្រង់ចម្លងប្រជុំជនច្រើន កំណត់ត្រឹមនោះ ។ កាលនោះ ខ្ញុំកើតជាសេដ្ឋីបុត្ត មានយសធំក្នុងក្រុងហង្សវតី បានចូលទៅជិតព្រះសម្ពុទ្ធ ជាប្រទីបក្នុងលោក បានស្តាប់ធម្មទេសនា ។ ខ្ញុំបានស្តាប់ព្រះពុទ្ធដីការបស់ព្រះមុនី ទ្រង់សម្តែងនូវគុណនៃ

សាវ័ករបស់ព្រះអង្គ ជាអ្នកក្រាលសេនាសនៈដល់ពួកភិក្ខុ ក៏មានចិត្តរីករាយ ។ ខ្ញុំធ្វើការកសាងចំពោះសង្ឃ ហើយក្រាបចុះទៀបព្រះបាទារបស់ព្រះមហេសីអង្គនោះដោយសិរប្រាថ្នានូវតំណែងនោះ ។ កាលនោះ ព្រះមហាវីរៈអង្គនោះទ្រង់សម្ដែងសរសើរនូវកម្មរបស់ខ្ញុំថា

កុលបុត្តណា ញុំាងតថាគតជាលោកនាយក ព្រមទាំងភិក្ខុសង្ឃឲ្យឆាន់អស់ ៧ ថ្ងៃ កុលបុត្តនោះមានភ្នែកដូចត្របកឈូក មានស្មាដូចសត្វសីហៈ មានស្បែកដូចមាសក្រាបចុះទៀបបាទមូលនៃតថាគត ហើយប្រាថ្នានូវទីដ៏ប្រសើរ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះព្រះសាស្ដា ព្រះនាមគោតម ទ្រង់កើតក្នុងត្រកូលក្សត្រឱក្កាកៈ នឹងបានត្រាស់ក្នុងលោក ។ កុលបុត្តនេះនឹងបានជាសាវ័ករបស់ព្រះពុទ្ធអង្គនោះ ប្រាកដនាមថាទព្វៈ ជាអ្នកក្រាលអាសនៈ ជាកំពូល ( នៃសាវ័កទាំងពួង ) ។

ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតឯឋានតាវត្តិង្សដោយកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតាំងសេចក្ដីប្រាថ្នានោះផង ។ ខ្ញុំបានទទួលទេវរាជសម្បត្តិអស់ ៣០០ ដង បានជាស្ដេចចក្រពត្តិអស់ ៥០០ ដង ។ ខ្ញុំបានគ្រប់គ្រងប្រទេសរាជ្យដ៏ធំទូលាយរាប់ជាតិមិនអស់ ខ្ញុំដល់នូវសេចក្ដីសុខ

ក្នុងភពទាំងពួងដោយអំណាចនៃកុសលកម្មនោះ ។ ក្នុងកប្ប ទី ៩១ អំពីកប្បនេះ ព្រះនាយកព្រះនាមវិបស្សី ទ្រង់មានព្រះនេត្រុងរឿង ទ្រង់ឃើញច្បាស់នូវធម៌ទាំងពួង ទ្រង់ត្រាស់ឡើង ។ ខ្ញុំមានចិត្តប្រទូស្ត តិះដៀលសាវកអ្នកមិនមានអាសវៈទាំងពួងរបស់ព្រះអង្គ ជាតាទិបុគ្គល ហើយបេ្តជ្ញាខ្លួនថាអាត្មាអញស្អាត ។ ( លុះមកខាងក្រោយ ) ខ្ញុំកាន់យកស្លាកហើយ ប្រគេនបាយលាយដោយទឹកដោះស្រស់ដល់ពួកសាវកអ្នកស្វែងរកសីលគុណរបស់ព្រះវិបស្សីអង្គនោះ ទ្រង់មានព្យាយាមជាងពួកនរៈ ។ ក្នុងកប្បនេះ ព្រះសម្ពុទ្ធព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ ទ្រង់មានយសធំ ប្រសើរជាងពួកអ្នកប្រាជ្ញទ្រង់ត្រាស់ឡើង ។ ព្រះសម្ពុទ្ធអង្គនោះ ព្រមទាំងសាវក ទ្រង់ញុំាងសាសនាឲ្យរុងរឿង ទ្រង់គ្របសង្កត់ពួកតិរ្ថិយអាក្រក់ ទ្រង់ណែនាំវេនេយ្យសត្វ ហើយបរិនិព្វាន ។ កាលព្រះលោកនាថ ព្រមទាំងសិស្សបរិនិព្វានហើយ កាលសាសនាសាបសូន្យហើយ ពួកទេវតាមានសេចក្តីតក់ស្លុត រំសាយសក់ មានមុខទទឹកដោយទឹកភ្នែក កន្ទក់កន្ទេញថា ព្រះសម្ពុទ្ធទ្រង់ប្រាប់ធម៌នឹងបរិនិព្វាន ពួកយើងនឹងមិនឃើញព្រះអង្គដែលមានវត្តល្អ នឹងមិនបានស្តាប់ព្រះសទ្ធម្ម ឱហ្ន៎ ពួកយើងចំជាអ្នកឥតបុណ្យមែន ។ កាលនោះឯង ផែនដីទាំង

មូលនេះដែលជារបស់មិនញាប់ញ័រ ផែនដីនោះធំទូលាយផង សាគរព្រមទាំងលោកផង ក៏បែរជាបន្ទឺសម្រែកករុណា ។ ស្គរទាំងឡាយក្នុងទិសទាំង ៤ ដែលមិនមែនជារបស់មនុស្ស ក៏បន្លឺឡើង រន្ទះទាំងឡាយជារបស់នាំមកនូវភ័យ ក៏ធ្លាក់ចុះជុំទិស ។ ភ្លើងគប់ទាំងឡាយ ក៏ធ្លាក់មកអំពីអាកាស ផ្សាយជុះកន្ទុយ អណ្តាតភ្លើងព្រមទាំងផ្សែង ក៏ប្រាកដឡើង ពួកម្រឹគស្រែកនូវសម្រែកករុណា ។ កាលនោះ យើងជាភិក្ខុ ៧ រូប ឃើញហេតុកាចអាក្រក់ជាចម្រូងឲ្យវិនាសសាសនាកើតឡើង ក៏មានសេចក្តីសង្វេគគិតគ្នាថា ពួកយើងបើវៀរចាកសាសនាហើយមិនគួររស់នៅឡើយ យើងទាំងឡាយ គួរចូលទៅក្នុងព្រៃធំ ហើយប្រកបនូវសាសនារបស់ព្រះជិនស្រី ។ កាលនោះពួកខ្ញុំបានឃើញភ្នំខ្ពស់ក្នុងព្រៃទើបឡើងភ្នំនោះតាមបង្អោង ហើយច្រានបង្អោងចោល ។ គ្រានោះ ព្រះថេរៈទូន្មាននូវពួកយើងថា ការកើតឡើងនៃព្រះពុទ្ធ ជាការកម្រណាស់ សទ្ធាសោតក៏រកបានដោយកម្រដែរឯសាសនាដែលសេសសល់នៅក៏ស្តួចស្តើង ។ សត្វទាំងឡាយ តែមានខណៈកន្លងហើយរមែងធ្លាក់ចុះក្នុងសាគរ គឺសេចក្តីទុក្ខ មិនមានទីបំផុត ព្រោះហេតុនោះ សាសនាប្រតិស្ឋាននៅដរាបណា ពួកយើងគប្បីធ្វើព្យាយាមដរាបនោះ ។ ព្រះថេរៈនោះជាព្រះអរហន្ត អនុត្តរ

ជាលំដាប់ និងមហាថេរៈនោះជាអនាគាមី ភិក្ខុទាំងឡាយក្រៅអំពីនេះ មានសីលល្អប្រកបព្យាយាម បានទៅកើតក្នុងទេវលោក ។ ( ព្រះថេរៈ ១ រូប ) មានសង្សារវដ្តធ្ងន់ហើយបរិនិព្វាន ព្រះថេរៈមួយរូបទៀត ទៅកើតក្នុងសុទ្ធាវាសព្រហ្មលោក ( ឯពួកយើង ) គឺខ្ញុំ ១ បុក្កុសាតិ ១ សភិយៈ ១ ពាហិយៈ ១ និងព្រះកុមារកស្សបៈ ១ ( នៅជាបុថុជ្ជន ) ដូចគ្នា ពួកយើងក៏ចូលទៅកើតហើយក្នុងភពនោះៗ បានព្រះសម្ពុទ្ធព្រះនាម គោតម អនុគ្រោះ ក៏រួចស្រឡះចាកចំណងសង្សារ ។ ខ្ញុំកើតក្នុងត្រកូលមល្លៈ ក្នុងក្រុងកុសិនារា កាលខ្ញុំនៅក្នុងគភ៌ មាតារបស់ខ្ញុំស្លាប់ លុះគេលើកឡើងកាន់ជើងថ្ករខ្ញុំក៏របូតចាកគភ៌នោះ ធ្លាក់ទៅលើគំនរស្មៅជំណោកទន្សាយ ព្រោះហេតុនោះទើបខ្ញុំមានឈ្មោះប្រាកដថា ទព្វៈ ខ្ញុំមានអាយុ ៧ ឆ្នាំ មានចិត្តផុតស្រឡះ ចាកកិលេសដោយផលនៃព្រហ្មចរិយៈ ។ ខ្ញុំប្រកបដោយអវយវៈ ៥ ដោយផលនៃបាយដែលលាយទឹកដោះស្រស់ ត្រូវបាបជាស់តឿនហើយដោយច្រើនដោយការតិះដៀលព្រះខីណាស្រព ។ ឥឡូវនេះ ខ្ញុំកន្លងបុណ្យនិងបាបទាំងពីរ បានដល់នូវសេចក្តី ស្ងប់យ៉ាងក្រៃលែង ជាអ្នកមិនមានអាសវៈ ។ ខ្ញុំក្រាលសេនាសនៈញុំាងពួកលោកអ្នកមានវត្តល្អឲ្យរីករាយព្រះជិនស្រីទ្រង់ត្រេក

អរនឹងគុណនោះ ទើបតាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំវិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

ទោះជាដូច្នេះ ដោយបាបកម្មដែលលោកធ្វើ ដោយអំណាចការពោលបន្ទាប់ព្រះថេរៈ ដែលជាខីណាស្រពមួយរូបក្នុងកាលមុន ទើបលោកឆេះក្នុងនរកច្រើនសែនឆ្នាំ ដោយសេសសល់កម្មនោះ ទើបលោកត្រូវភិក្ខុ ឈ្មោះមេត្តិយនិងភុម្មជក យល់ខុសថា ពួកយើងត្រូវព្រះថេរៈនេះ ធ្វើឲ្យបែកជាមួយគហបតីដែលពេញចិត្តក្នុងការឲ្យរបស់ល្អ ទើបពោលចោទដោយបារាជិកធម៌មិនមានមូល ។ កាលអធិករណ៍នោះដែលសង្ឃរម្ងាប់ហើយ ដោយសតិវិន័យព្រះថេរៈនេះកាលប្រកាសគុណរបស់ខ្លួនដើម្បីអនុគ្រោះសត្វលោក ទើបពោលគាថានេះថា

ភិក្ខុណាឈ្មោះទព្វៈ ដែលគេទូន្មានបានដោយក្រ បានទូន្មានដោយការទូន្មាន ( ឥន្ទ្រិយ ) ជាព្រះថេរៈមានចិត្តសន្ដោសឆ្លងសេចក្ដីសង្ស័យ មានជ័យជម្នះ ប្រាសចាកសេចក្ដីតក់ស្លុត

ភិក្ខុទព្វមល្លបុត្តនោះមានចិត្តខ្ជាប់ខ្ជួនបរិនិព្វានហើយ ដូច្នេះ ។

សព្ទថា **យោ** ក្នុងគាថានោះ ជាពាក្យប្រាប់សេចក្តីមិនចំពោះ ។ ដោយពាក្យថា **សោ** នេះ គប្បីជ្រាបថា លោកឧទ្ទិសចំពោះបុគ្គលទុក ។ ដោយពាក្យទាំង ២ ព្រះថេរៈពោលសំដៅដល់ខ្លួនឯងដោយធ្វើឲ្យដូចជាអ្នកដទៃ ។

បទថា **ទុទ្ទមយោ** សេចក្តីថា ទូន្មានបានដោយកម្រ គឺមិនអាចទូន្មានបាន ។ ព្រះថេរៈពោលដល់បទនេះ ព្រោះសំដៅដល់ការញាប់ញ័រនៃចិត្តដែលកម្រើកដោយសេចក្តីស្រវឹងរបស់ពួកកិលេសដែលជាសត្រូវ គឺទិដ្ឋិនិងការមិនស្ងប់នៃឥន្ទ្រិយទាំងឡាយ ។ បទថា **ទមេន** បានដល់ ទូន្មានដោយមគ្គដ៏ប្រសើរឧត្តម អធិប្បាយថា សមគួរពោលបានថា មានខ្លួនទូន្មានហើយ ព្រោះមិនចាំបាច់ទូន្មានទៀត មិនមែនទូន្មានបែបដទៃ ។

ម្យ៉ាងទៀត បទថា **ទមេន** សេចក្តីថា ដែលព្រះមានព្រះភាគជាសារថីទូន្មានបុរសដែលគួរទូន្មាន ទូន្មានហើយ ។ បទថា **តញ្ញោ** ស្មើគ្នានឹង **ឧត្តញ្ញោ** សេចក្តីថា សមគួរ ។ ដោយហេតុនោះ ព្រះមានព្រះភាគទ្រង់សំដៅដល់ព្រះថេរៈនោះឯង ទើបត្រាស់ថា ម្នាលទព្វៈ អ្នកប្រាជ្ញទាំងឡាយមិនពោលបណ្តោះបណ្តោយ៉ាងនោះទេ ដូច្នេះ ។ បទថា **សន្តុសិតោ** សេចក្តីថា សន្តោសហើយ ដោយសន្តោសក្នុងបច្ច័យតាមមានតាមបាន ដោយសន្តោសក្នុងឈានសមាបត្តិនិងដោយសន្តោសក្នុងមគ្គផល ។ បទថា **វិតិណ្ណកង្ខោ** សេចក្តីថា ឈ្មោះថា មានសេចក្តីសង្ស័យប្រាសទៅហើយ ដោយសេចក្តីសង្ស័យក្នុងវត្ថុ ១៦ និងក្នុងវត្ថុ ៨ ព្រោះដកវិចិកិច្ឆាបានហើយ ដោយបឋម

មគ្គនោះឯង ។ បទថា **វិជិតាវី** សេចក្តីថា ឈ្មោះថា ឈ្នះហើយ ព្រោះមានជ័យជម្នះ គឺកម្ចាត់បានហើយនូវធម៌ដែលជាចំណែកនៃសង្កិលេសទាំងអស់ដែលបុរសជាតិអាជានេយ្យគប្បីឈ្នះ ។

បទថា **អបេតភេរវោ** សេចក្តីថា ឈ្មោះថា ប្រាសចាកការខ្លាច គឺឈ្មោះថា ប្រាសចាកភ័យ ព្រោះភ័យ ២៥ យ៉ាងប្រាសទៅហើយ ដោយប្រការទាំងពួង ។ បទថា **ធញ្ញោ** ជាពាក្យប្រារព្ធដល់ឈ្មោះដដែលទៀត ។ ក្នុងបទថា **បរិនិព្វុតោ** នេះ បរិនិព្វានមាន ២ គឺកិលេសបរិនិព្វានដែលបានដល់សឧបាទិសេសនិព្វានធាតុ ១ ខន្ធបរិនិព្វានដែលបានដល់ អនុបាទិសេសនិព្វានធាតុ ១ ។ ក្នុង ២ យ៉ាងនោះ ក្នុងគាថានេះ លោកសំដៅយកកិលេសបរិនិព្វាន ព្រោះហេតុនោះ ទើបបានសេចក្តីថា ឈ្មោះថា បរិ-និព្វានហើយ ដោយកិលេសបរិនិព្វាន ព្រោះបហាតព្វធម៌ គឺធម៌ដែលគួរលះដែលមគ្គលះបានហើយដោយប្រការទាំងពួង ។ បទថា **ឋិតត្តោ** សេចក្តីថា ជាអ្នកមានចិត្តមាំទាំ គឺមិនញាប់ញ័រ បានដល់ មិនកម្រើកដោយលោកធម៌ទាំងឡាយព្រោះដល់នូវភាពជាតាទិបុគ្គលក្នុងឥដ្ឋារម្មណ៍ជាដើម ។ សព្ទថា **ហិ** ជានិបាត ចុះក្នុងអត្ថនៃហេតុ ។ ដោយ **ហិ** និបាតនោះ សបញ្ជាក់នូវអត្ថថា ព្រោះកាលមុន ទព្វមល្លបុត្តដែលបុគ្គលដទៃទូន្មានបានលំបាក តែលោកកាលព្រះសាស្តាទ្រង់ទូន្មានដោយមគ្គដ៏ខ្ពស់ជាអ្នកសន្តោសច្ចងសង្ស័យបានហើយ ជាអ្នកឈ្នះកិលេស ប្រាសចាកនូវការខ្លាច ព្រោះហេតុនោះ ទើបព្រះទព្វមល្លបុត្តនោះ រំលត់កិលេសបានហើយ បន្ទាប់អំពីនោះ ក៏ជាអ្នក

មានចិត្តតាំងមាំ ធ្វើចិត្តឲ្យជ្រះថ្លាក្នុងបរិនិព្វាននោះ មិនមែនធ្វើចិត្តឲ្យជ្រះថ្លាដទៃឡើយព្រោះហេតុនោះ កាលព្រះថេរៈអនុគ្រោះពួកសត្វដទៃ ដែលអាចត្រាស់ដឹងបាន ទើបព្យាករអរហត្តផល ។

## អដ្ឋកថា ទព្វមល្លបុត្តត្ថេរគាថា ចប់

## សីតវនិយត្ថេរគាថា

[ ៧ ] ភិក្ខុណាជាបុគ្គលម្នាក់ឯង ចូលទៅកាន់ព្រៃត្រជាក់ ជាអ្នកសន្តោស មានចិត្តខ្ជាប់ខ្ជួន មានជ័យជម្នះ ប្រាសចាកសេចក្តីព្រឺរោម ( ភិក្ខុនោះឈ្មោះថា ) មានប្រាជ្ញា រក្សាកាយគតាសតិ ។

ឮថា សីតវនិយត្ថេរមានអាយុ ( បានពោល ) ដោយប្រការដូច្នេះ ។

**សីតវនិយត្ថេរ ។**

## អដ្ឋកថា
## សីតវនិយត្ថេរគាថា

[ ៧ ] គាថារបស់ព្រះសម្ភូតត្ថេរ មានពាក្យផ្តើមថា **យោ សីតវនំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា រាប់ថយក្រោយអំពីនេះទៅ ១៨០០ កប្ប ព្រះសម្មាសម្ពុទ្ធព្រះនាមថា អត្ថទស្សីកើតឡើងក្នុងលោក ញ៉ាំងពួកសត្វលោក មួយអន្លើដោយទេវលោកឲ្យឆ្លងឱឃៈធំ គឺសង្សារ ។ ថ្ងៃមួយ ទ្រង់ក៏ដល់ឆ្នេរស្ទឹងគង្គាមួយអន្លើដោយភិក្ខុសង្ឃ ។ ក្នុងគ្រានោះ ព្រះថេរៈកើតក្នុងគហបតីត្រកូល ជួបព្រះមានព្រះភាគត្រង់ឆ្នេរស្ទឹងគង្គានោះ មានចិត្តជ្រះថ្លា ចូលទៅគាល់ហើយ ថ្វាយបង្គំ ក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់មានពុទ្ធបំណងឆ្លងទៅត្រើយនាយឬ ព្រះសាស្តាត្រាស់ថា តថាគតនឹងទៅ ។ គហបតីនោះក៏រៀបចំទូកថ្វាយក្នុងទីនោះឯង ។ ព្រះបរមសាស្តា កាលទ្រង់

អនុគ្រោះ មួយអន្លើដោយភិក្ខុសង្ឃ យាងចុះកាន់ទូកហើយ កុលបុត្តនោះជូនព្រះសាស្តាចូងដោយខ្លួនឯង ញ៉ាំងព្រះមានព្រះភាគ និងភិក្ខុសង្ឃឲ្យដល់ត្រើយនាយដោយសប្បាយ ហើយថ្វាយមហាទានក្នុងថ្ងៃទី ២ ជូនដំណើរព្រះសាស្តា មានចិត្តជ្រះថ្លា ថ្វាយបង្គំហើយត្រឡប់ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ រាប់អំពីកប្បនេះទៅក្រោយ ១៣០០ កប្ប កើតក្នុងត្រកូលក្សត្របានជាស្តេចចក្រពត្តិ ជាធម្មិករាជ ទ្រង់ញ៉ាំងពលនិករឲ្យតាំងនៅក្នុងផ្លូវនៃសុគតិ ចុតិអំពីមនុស្សលោកនេះហើយ បួសក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមវិបស្សី ក្នុងកប្បទី ៩១ សមាទានធុតង្គធម៌ នៅក្នុងព្រៃ បំពេញសមណធម៌ហើយ ។ ក្នុងពុទ្ធកាលព្រះសម្មាសម្ពុទ្ធកស្សបៈ កុលបុត្តនេះចេញបួសមួយអន្លើដោយសម្លាញ់ទាំង ៣ ក្នុងសាសនាព្រះអង្គ ហើយបំពេញសមណធម៌ពីរម៉ឺនឆ្នាំ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តរបស់ព្រាហ្មណមហាសាលក្នុងនគររាជគ្រឹះ ។ ជនទាំងឡាយ ដាក់ឈ្មោះឲ្យកុលបុត្តនោះថា សម្ភូត លោកចម្រើនវ័យហើយ សិក្សាសម្រេចនូវសិល្បសាស្ត្ររបស់ព្រាហ្មណ៍ កុលបុត្តនោះបានទៅកាន់សម្នាក់របស់ព្រះភគវា មួយអន្លើដោយសម្លាញ់ទាំង ៣ គឺភូមិជៈ ១ ជេយ្យសេន ១ អភិរាធនៈ ១ ស្តាប់ធម្មទេសនាហើយ បាននូវសទ្ធា ចេញបួស ព្រះសង្គាហកាចារ្យទាំងឡាយសំដៅយកហេតុនេះ ទើបពោលថា

មាណពទាំង ៤ គឺភូមិជៈ ១ ជេយ្យសេន ១ សម្មត ១ អភិរាជនៈ ១ បានត្រាស់ដឹងធម៌ក្នុងសាសនារបស់ព្រះមានព្រះភាគ ជាតាទិបុគ្គលដ៏ប្រសើរ ដូច្នេះ ។

កាលនោះ ព្រះសម្មតត្ថេររៀនកាយគតាសតិកម្មដ្ឋានក្នុងសម្នាក់របស់ព្រះមានព្រះភាគ នៅក្នុងព្រៃសីតវនជាប្រចាំ ។ ដោយហេតុនោះឯង ទើបលោកមាននាមប្រាកដថា សីតវនិយៈ ។ ក្នុងសម័យនោះ ស្ដេចវេស្សវណ្ណមហារាជ ទៅតាមអាកាស បែរមុខទៅទិសខាងត្បូង ក្នុងជម្ពូទ្វីប ឃើញព្រះថេរៈអង្គុយត្រង់អព្ភោកាស គឺទីវាល មនសិការកម្មដ្ឋាន ក៏ចុះអំពីវិមាន នមស្ការព្រះថេរៈ ប្រាប់យក្ខ ២ រូបថា បើព្រះថេរៈចេញអំពីសមាធិក្នុងកាលណា ចូរអ្នកប្រាប់ឲ្យលោកជ្រាបថា ខ្ញុំមក ក្នុងកាលនោះ ហើយចូរធ្វើការរក្សាព្រះថេរៈផង ដូច្នេះហើយ ក៏ចៀសចេញទៅ ។ យក្ខទាំង ២ នោះ ឈរក្បែរព្រះថេរៈហើយ ប្រាប់សេចក្ដីនោះ ក្នុងពេលដែលព្រះថេរៈឈប់មនសិការហើយអង្គុយ ។ ព្រះថេរៈស្ដាប់ពាក្យនោះហើយពោលថា ចូរក្រាបទូលស្ដេចវេស្សវណ្ណមហារាជតាមពាក្យរបស់អាត្មា ធម្មតាការរក្សា គឺសតិ ដែលព្រះមានព្រះភាគទ្រង់ទូន្មាន សម្រាប់បុគ្គល ដែលតាំងនៅក្នុងសាសនារបស់ព្រះអង្គនោះឯងដែលរក្សាបុគ្គលដូចអាត្មា ចូរអ្នកកុំដាក់ចិត្តក្នុងការរក្សានោះ កិច្ចដែលគប្បីធ្វើដោយការរក្សាបែបនេះ មិនមានដល់បុគ្គលដែលតាំងនៅក្នុងឱវាទរបស់ព្រះសាស្ដាឡើយ ដូច្នេះហើយ បញ្ជូនយក្ខទាំង ២ ត្រឡប់ទៅ ចម្រើនវិបស្សនាហើយធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា ៣ ក្នុងខណៈនោះឯង ។ លំ

ដាប់នោះ ស្តេចវេស្សវ័ណត្រឡប់មក ចូលទៅរកព្រះថេរៈ ដឹងថាព្រះថេរៈសម្រេចអរហត្តហើយ ដោយការសង្កេតទឹកមុខ ទើបយាងទៅក្រុងសាវត្ថី ក្រាបទូលព្រះមានព្រះភាគ កាលលើកតម្កើងព្រះថេរៈ ចំពោះព្រះភក្ត្ររបស់ព្រះបរមសាស្តា ទើបពណ៌នាគុណទាំងឡាយរបស់ព្រះថេរៈ ដោយគាថានេះថា

ព្រះសម្ពុតត្ថេរ សម្បូរដោយសតិ ជាគ្រឿងរក្សា មានបញ្ញា ប្រកបដោយសេចក្តីព្យាយាម ជាពុទ្ធជិនោរស មានវិជ្ជា ៣ ធូងត្រើយនៃ មច្ចុបានហើយ ដូច្នេះ ។

ដោយហេតុនោះ ទើបលោកពោលគាថាព័ន្ធទុកក្នុងអបទានថា

ព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ជាធំជាងសត្វជើង ២ ជានរាសភៈ មានពួកសាវ័កហែហម ស្តេចចូលទៅកាន់ឆ្នេរទន្លេគង្គា ។ ឯទន្លេគង្គា មានទឹកពេញប្រៀប ល្មមក្អែកឱនផឹកបាន ជាស្ទឹងដែលគេឆ្លងបានដោយកម្រ ខ្ញុំបានចម្លងភិក្ខុសង្ឃផង ព្រះពុទ្ធដ៏ឧត្តមជាងសត្វជើងពីរផង ។ ក្នុងកប្បទី ១៨០០ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្មខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃការចម្លង ។ ក្នុងកប្បទី ១៣០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៥ ជាតិ ព្រះនាមសព្វោភវៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង

អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា
របស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ(១) ។

គ្រានោះ ព្រះសម្ពុតឃើញភិក្ខុទាំងឡាយធ្វើដំណើរទៅគាល់ព្រះមានព្រះភាគទើបពោលថា អាវុសោ លោកទាំងឡាយ ចូរថ្វាយបង្គំព្រះបាទា របស់ព្រះមានព្រះភាគតាមពាក្យរបស់ខ្ញុំ ហើយក្រាបទូលយ៉ាងនេះ ដូច្នេះ ហើយកាលប្រកាសភាព ដែលខ្លួនមិនធ្វើព្រះសាស្តាឲ្យលំបាក ព្រោះហេតុនៃធម៌ទើបពោលគាថាថា **យោ សីតវនំ** ដូច្នេះជាដើម ។ ភិក្ខុទាំងនោះ ចូលទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំ កាលទូលឲ្យទ្រង់ជ្រាបដល់សាសន៍របស់ព្រះសម្ពុតត្ថេរ ក៏ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះសម្ពុតសូមថ្វាយបង្គំព្រះបាទារបស់ព្រះអង្គ ក្រាបទូលយ៉ាងនេះហើយ ទើបទូលសេចក្តីនោះ ។ ព្រះភគវាស្តាប់ពាក្យនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សម្ពុតជាបណ្ឌិត បដិបត្តិធម៌សមគួរដល់ធម៌ និងមិនបៀតបៀនតថាគតព្រោះហេតុនៃធម៌ រឿងរបស់សម្ពុតនោះ ស្តេចវេស្សវ័ណប្រាប់តថាគតហើយ ។ ភិក្ខុទាំងនោះក្រាបទូលគាថាដែលព្រះសម្ពុតត្ថេរពោលដល់ព្រះបរមសាស្តា ដូច្នេះថា

ភិក្ខុណាជាបុគ្គលម្នាក់ឯង ចូលទៅកាន់ព្រៃត្រជាក់ ជាអ្នក
សន្តោស មានចិត្តខ្ជាប់ខ្ជួន មានជ័យជម្នះ ប្រាសចាកសេចក្តី
ព្រឺរោម ( ភិក្ខុនោះឈ្មោះថា ) មានប្រាជ្ញា រក្សាកាយគតា-

---

១-ក្នុងអបទានជាព្រះ តរណិយត្ថេរ ។

សតិ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សីតវនំ** បានដល់ ព្រៃស្មសាន ដែលបានឈ្មោះយ៉ាងនេះ ជាព្រៃគួរខ្លាចផង ជាព្រៃធំផង ក្បែរនគររាជគ្រឹះ ។

បទថា **ឧបគា** បានដល់ ចូលដល់ហើយ ដោយកាន់យកជាទីលំនៅ ។

បទថា **ឧបគា** នេះ លោកសំដៅយកទីនៅអាស្រ័យដែលសមគួរដល់បព្វជិតដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ។

បទថា **ភិក្ខុ** សេចក្តីថា ឈ្មោះថា ភិក្ខុ ព្រោះជាអ្នកឃើញភ័យក្នុងសង្សារ និងព្រោះទម្លាយកិលេសបានហើយ ។ បទថា **ឯកកោ** សេចក្តីថា មិនមានសម្លាញ់ជាគម្រប់ ២ ដោយបទថា **ឯកកោ** នេះ លោកសំដៅដល់កាយវិវេក ។

បទថា **សន្តុសិតោ** បានដល់ ជាអ្នកសន្តោស ។ ដោយបទថា **សន្តុ-សិតោ** នេះ លោកសម្តែងដល់អរិយវង្សដែលមានការសន្តោសក្នុងបច្ច័យ ៤ ជាលក្ខណៈ ។

បទថា **សមាហិតត្តោ** សេចក្តីថា មានចិត្តតាំងមាំហើយ ដោយសមាធិមានឧបចារសមាធិ និងអប្បនាសមាធិជាដើម ។ ដោយបទថា **សមាហិត-ត្តោ** នេះ លោកសម្តែងដល់អរិយវង្ស ដែលមានភាវនាជាទីមកត្រេកអរ ដោយមានវិវេកភាវនាជាប្រធាន ។

បទថា **វិជិតាវី** សេចក្តីថា ឈ្នះនូវពួកកិលេសដែលព្រះយោគាវចរគប្បីឈ្នះ ដោយការបដិបត្តិប្រពៃក្នុងសាសនា ។ បទថា **វិជិតាវី** នេះ

លោកសម្តែងដល់ឧបធិវិវេក ។ ភិក្ខុឈ្មោះថា **អបេតលោមហំសោ** ប្រែថា ប្រាសចាកការព្រឺរោមព្រឺស្បែក ព្រោះមានកិលេសជាហេតុនៃភ័យប្រាសទៅហើយ ។ ដោយបទថា **អបេតលោមហំសោ** នេះ លោកសម្តែងដល់ផលនៃសម្មាបដិបត្តិ ។ បទថា **រក្ខំ** ប្រែថា រក្សា ។

បទថា **កាយគតាសតី** បានដល់ សតិមានកាយជាអារម្មណ៍ គឺមិនលះកាយគតាសតិកម្មដ្ឋានដោយអំណាចនៃការចម្រើន ។

បទថា **ធីតិមា** បានដល់ ជាអ្នកមានបញ្ញា ។ បទថា **ធីតិមា** នេះ សម្តែងដល់បដិបទាអាស្រ័យភាពដែលខ្លួនមានចិត្តតាំងមាំឬមានជ័យជម្នះជាក់ច្បាស់ហើយ ។

ក្នុងគាថានេះ មានសេចក្តីសង្ខេបដូចតទៅនេះថា

ភិក្ខុនោះ ជាបុគ្គលម្នាក់ឯង មកកាន់ព្រៃសីតវ័ន ដោយប្រាថ្នាសេចក្តីសុខដែលកើតអំពីវិវេក ចូលទៅហើយ ក៏ជាអ្នកសន្តោស ព្រោះមិនមានការទ្បេះទ្បោះ មានបញ្ញា មានកាយគតាសតិចម្រើនកម្មដ្ឋាន ធ្វើឈានដែលខ្លួនសម្រេចហើយយ៉ាងនោះឲ្យជាបាទ ខ្វល់ខ្វាយក្នុងវិបស្សនាដែលខ្លួនប្រារព្ធហើយ មានចិត្តតាំងមាំដោយមគ្គដ៏ប្រសើរ ដែលខ្លួនបានសម្រេចហើយ និងឈ្នះកិលេសបានហើយ ឈ្មោះថា ជាបុគ្គលប្រាសចាកការព្រឺរោមព្រឺស្បែក ព្រោះមានហេតុនៃភ័យទៅប្រាសហើយ ដោយប្រការទាំងពួង ព្រោះធ្វើកិច្ចស្រេចហើយ ដូច្នេះ ។

អដ្ឋកថា សីតវនិយត្ថេរគាថា ចប់

## កលិយត្ថេរគាថា

[ ៨ ] បុគ្គលណា កម្ចាត់បង់នូវសេនានៃមច្ចុរាជ ដូចជាដំរីដ៏ធំ កម្ចាត់បង់នូវស្ពានបបុសដែលមានកម្លាំងថយ ជាអ្នកមានជ័យជម្នះ ប្រាស ចាកសេចក្តីតក់ស្លុត បុគ្គលនោះឈ្មោះថា មានឥន្រ្ទិយទូន្មានហើយ មានចិត្ត ខ្ជាប់ខ្ជួន រំលត់ទុក្ខហើយ ។

ឮថា កលិយត្ថេរមានអាយុ ( បានពោល ) ដោយប្រការដូច្នេះ ។

**កលិយត្ថេរ**

## អដ្ឋកថា

## កលិយត្ថេរគាថា

[ ៨ ] គាថារបស់ព្រះកលិយត្ថេរ មានពាក្យផ្តើមថា **យោ ទានុទិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះថេរៈនេះ ក្នុងកប្បទី ៣១ អំពីកប្បនេះ កាលព្រះពុទ្ធ មិនទាន់កើតឡើង មានចិត្តជ្រះថ្លា បានថ្វាយផ្លែឈើទាំងឡាយ ដល់ព្រះ-បច្ចេកសម្ពុទ្ធព្រះនាមថា សុមនៈ អន្ទោលទៅកាន់សុគតិភពទាំងឡាយប៉ុណ្ណោះ កើតក្នុងត្រកូលសត្ថវាហៈ ក្នុងនគរអរុណាវតី ក្នុងពុទ្ធុប្បាទរបស់ព្រះសម្មា សម្ពុទ្ធ ព្រះនាមថា សិខី បានឮថា បុត្តឈ្មួញ ២ នាក់ គឺឧបជិតៈ ១ ឧជិតៈ ១ បានថ្វាយអាហារគ្រាដំបូង ដល់ព្រះមានព្រះភាគ ព្រះនាមថាសិខី ទ្រង់បានត្រាស់ដឹងថ្មីៗ ទើបចូលទៅគាល់ព្រះមានព្រះភាគ មួយអន្លើដោយ

សម្លាញ់របស់ខ្លួន ថ្វាយបង្គំហើយ ទូលអារាធនាដើម្បីសោយព្រះក្រយាហារក្នុងថ្ងៃស្អែក ថ្វាយមហាទានហើយ តាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ទាំង ២ គប្បីជាអ្នកបានថ្វាយអាហារជំបូងដល់ព្រះពុទ្ធដូចព្រះអង្គក្នុងអនាគតកាលផងចុះ ។

ដូច្នេះ ជនទាំង ២ ធ្វើបុញ្ញកម្មក្នុងភពនោះៗ ហើយអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទរបស់ព្រះកស្សបសម្មាសម្ពុទ្ធ កើតជាកូនសេដ្ឋីអ្នកចិញ្ចឹមគោ ជាបងប្អូននឹងគ្នា បានថ្វាយគោជនដែលផ្សំដោយទឹកដោះដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ឆ្នាំទាំងឡាយដ៏ច្រើន ។ លុះដល់ពុទ្ធុប្បាទរបស់ព្រះមានព្រះភាគនៃយើង មកកើតក្នុង បោក្ខរវតីនគរ ជាកូនឈ្មួញរទេះ ។ ក្នុងជនទាំង ២ នោះ កុលបុត្តដែលជាបង ឈ្មោះតបុស្សៈ កុលបុត្តជាប្អូន ឈ្មោះភល្លិយៈ ។ កុលបុត្តទាំង ២ ដាក់ទំនិញពេញរទេះ ៥០០ ធ្វើដំណើរទៅជួញដូរ កាលព្រះមានព្រះភាគត្រាស់ដឹងសម្មាសម្ពោធិញ្ញាណជំបូង ទ្រង់សម្ងំអស់ ៧ សប្តាហ៍ ដោយការពិចារណាធម៌ គឺសុខដែលកើតអំពីវិមុត្តិ ក្នុងសប្តាហ៍ទី ៨ ទ្រង់គង់ត្រង់ដើមកែស ពួកជនទាំងនោះធ្វើដំណើរឆ្លងផ្លូវធំទៅក្បែរដើមកែស សម័យនោះ រទេះរបស់ជនទាំង ២ មិនព្រមទៅមុខ ក្នុងទីដែលរាបស្មើមិនមានជង្ហុកមិនមានភក់ កាលឈ្មួញ ២ នាក់បងប្អូនគិតថា ព្រោះហេតុអ្វីហ្ន៎ ដូច្នេះ ទេវតាដែលធ្លាប់ជាញាតិសាលោហិត ក៏បង្ហាញខ្លួនត្រង់ប្រគាបឈើ ប្រាប់ថា អ្នកនិទ្ទុក្ខ ព្រះមានព្រះភាគអង្គនោះ ត្រាស់ដឹងសម្មាសម្ពោធិញ្ញាណថ្មីៗ ខានសោយព្រះក្រយាហារអស់

៧ សប្តាហ៍ សោយវិមុត្តិសុខ ហើយឥឡូវនេះ គង់នៅត្រង់ដើមកែស ការដែលអ្នកទាំង ២ បង្អោនអាហារថ្វាយព្រះអង្គនោះ គប្បីប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍និងសេចក្តីសុខដល់អ្នកទាំងឡាយអស់កាលយូរ ។

ឈ្មួញ ២ នាក់បងប្អូនស្តាប់ពាក្យនោះហើយ សោយបីតិសោមនស្សក្រៃលែង សម្គាល់ថា ការរៀបចំអាហារជាការយឺតយូរ ទើបថ្វាយសដូវផង់និងសដូវដុំដល់ព្រះមានព្រះភាគ ដល់នូវទ្វេវាចិកសរណគមន៍ គឺដល់ព្រះពុទ្ធនិងព្រះធម៌ជាសរណៈ បានព្រះកេសធាតុ ចៀសចេញទៅហើយ ។ ឈ្មួញទាំង ២ នោះ បានជាឧបាសកមុនអ្នកដទៃ ។

កាលព្រះមានព្រះភាគយាងដល់ក្រុងពារាណសីប្រកាសធម្មចក្រ ហើយគង់ក្នុងនគររាជគ្រឹះដោយលំដាប់ តបុស្សៈនិងភល្លិយៈ ក៏ចូលទៅកាន់នគររាជគ្រឹះគាល់ព្រះមានព្រះភាគ ហើយថ្វាយបង្គំ អង្គុយក្នុងចំណែកម្ខាង ព្រះមានព្រះភាគទ្រង់សម្តែងធម៌ដល់ជនទាំង ២ នោះ តបុស្សៈ តាំងនៅក្នុងសោតាបត្តិផល បានជាឧបាសកតែម្យ៉ាង ឯភល្លិយៈ បួសហើយ ជាអ្នកបានអភិញ្ញា ៦ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

គ្រានោះ ព្រះសម្ពុទ្ធព្រះនាម សុមនៈ គង់នៅក្នុងក្រុងឈ្មោះភគ្គរា ខ្ញុំបានយកផ្លែគុយ ទៅថ្វាយព្រះសយម្ភូ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំង

អស់ ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ថ្ងៃមួយ មារបង្ហាញរូបគួរខ្លាចដើម្បីបំភ័យព្រះកល្យិយត្ថេរឲ្យភ័យខ្លាចព្រះថេរៈកាលប្រកាសភាព ដែលខ្លួនកន្លងសេចក្តីខ្លាចបានទាំងអស់ ហើយទើបបានភាសិតគាថានេះថា

បុគ្គលណា កម្ចាត់បង់នូវសេនានៃមច្ចុរាជ ដូចជាជំនន់ដ៏ធំកម្ចាត់បង់នូវស្ពានបបុស ដែលមានកម្លាំងថយ ជាអ្នកមានជ័យជម្នះ ប្រាសចាកសេចក្តីតក់ស្លុត បុគ្គលនោះឈ្មោះថាមានឥន្ទ្រិយទូន្មានហើយ មានចិត្តខ្ជាប់ខ្ជួន រំលត់ទុក្ខហើយដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យោ ទាលេតិ** សេចក្តីថា បុគ្គលណាកម្ចាត់គឺបន្សាត់ទៅ គឺលះបានហើយ បានដល់ កម្ចាត់ហើយ ។ បទថា **មច្ចុរាជស្ស** សេចក្តីថា ការស្លាប់ ឈ្មោះថា **មច្ចុ** បានដល់ ការបែកធ្លាយនៃខន្ធទាំងឡាយ ។ មច្ចុនោះឯង ឈ្មោះថា **រាជា** ព្រោះអត្ថថា ជាធំ ព្រោះញុំាង

១-ក្នុងអបទានជាព្រះ វល្លិការផលទាយកត្ថេរ ។

សត្វទាំងឡាយ ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ព្រោះហេតុនោះ ទើបឈ្មោះថា **មច្ចុរាជ ។** នៃមច្ចុរាជនោះ ។ បទថា **សេនំ** បានដល់ សេនាមានការចាស់និងរោគជាដើមនៅក្នុងអំណាចរបស់មច្ចុនោះ ដោយហេតុនោះ ទើបមច្ចុរាជនោះលោកហៅថា មានសេនាធំ ព្រោះមានសេនាច្រើន សមដូចព្រះតម្រាស់ថា **ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា** ព្រោះជាការតទល់របស់យើង ចំពោះមច្ចុដែលមានសេនាដ៏ច្រើននោះ មិនមានសោះឡើយ ដូច្នេះ ។ ម្យ៉ាងទៀត ទេវបុត្តមារ លោកបំណងយកថាជា មច្ចុ ក្នុងព្រះគាថានេះ ព្រោះអត្ថថា សម្លាប់នូវគុណ ។ កាមជាដើម លោកបំណងយកថាជាសេនា ព្រោះចូលដល់ភាពជាសម្លាញ់នឹងមច្ចុរាជនោះ សមដូចព្រះតម្រាស់ ( ខុទ្ទកនិកាយសុត្តនិបាត ) ថា

កាមទាំងឡាយជាសេនាទី ១ របស់អ្នក សេចក្តីអផ្សុកជា
សេនាទី ២ សេចក្តីឃ្លាននិងស្រេកជាសេនាទី ៣ របស់អ្នក
តណ្ហាជាសេនាទី ៤ ថីនមិទ្ធៈជាសេនាទី ៥ សេចក្តីតក់ស្លុត
ជាសេនាទី ៦ សេចក្តីសង្ស័យជាសេនាទី ៧ របស់អ្នក ការ
រមិលគុណនិងសេចក្តីរឹងត្អឹងជាសេនាទី ៨ របស់អ្នក ដូច្នេះ ។

បាទគាថាថា **នឡសេតុំវ សុទុព្វលំ មហោឃោ** នេះ ប្រកបសេចក្តីថា បុគ្គលណាកម្ចាត់ហើយ គឺឈ្នះហើយនូវសេនា គឺសង្កិលេស ដែលឈ្មោះថា មានកម្លាំងថយ ព្រោះមិនមានកម្លាំងច្រើន ដូចជំនន់ទឹកធំ កួចនូវស្ពានដើមបបុស ព្រោះប្រាសចាកខ្លឹម ដោយមគ្គដ៏ប្រសើរ ដូចគ្នានឹងជំនន់ទឹកធំ

ព្រោះ លោកុត្តរធម៌ទាំង ៩ មានកម្លាំងច្រើន បុគ្គលនោះ ចាត់ថាជាអ្នកមានជ័យជម្នះ ប្រាសចាកសេចក្តីតក់ស្លុត មានឥន្ទ្រិយទូន្មានហើយ មានចិត្តខ្ជាប់ខ្ជួន រំលត់ទុក្ខហើយ ដូច្នេះ ។ មារស្តាប់ពាក្យនោះហើយ គិតថា សមណៈនេះស្គាល់អញ ដូច្នេះហើយ ក៏អន្តរធានទៅក្នុងទីនោះឯង ។

## អដ្ឋកថា ភល្លិយត្ថេរគាថា ចប់

## វីរត្ថេរគាថា

[ ៩ ] ភិក្ខុណាដែលគេទូន្មានបានដោយក្រ តែបានទូន្មានខ្លួនឯងដោយការទូន្មាន ( ឥន្ទ្រិយ ) ជាអ្នកប្រាជ្ញ មានចិត្តសន្តោស ឆ្លងផុតសេចក្តីសង្ស័យ មានជ័យជំនះ ប្រាសចាកសេចក្តីព្រឺរោម ភិក្ខុនោះ ប្រាសចាករាគៈ មានចិត្តខ្ជាប់ខ្ជួន រំលត់ទុក្ខហើយ ។

វីរត្ថេរ ។

## អដ្ឋកថា

## វីរត្ថេរគាថា

[ ៩ ] គាថារបស់ព្រះវីរត្ថេរ មានពាក្យផ្តើមថា **យោ ទុទ្ទមយោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងកប្បទី ៩១ រាប់ថយក្រោយអំពីភទ្ទកប្បនេះ លោកជាអ្នករក្សាទីគង់របស់ព្រះមានព្រះភាគព្រះនាមថា វិបស្សី ។ ថ្ងៃមួយ កុលបុត្តនោះបេះផ្កាកន្ទឹស[១]មានលក្ខណៈស្រដៀងនឹងផ្កាសិន្ទុវារៈ មកបូជាព្រះមានព្រះភាគ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ កើតក្នុងត្រកូលក្សត្រ ក្នុងកប្បទី ៣៥ រាប់ទៅក្រោយអំពីភទ្ទកប្បនេះ បានជាស្តេចចក្រពត្តិ ព្រះនាមថា មហាបតាបៈ ។ ព្រះរាជាគ្រងរាជ្យដោយធម៌ ញុំាងសត្វឲ្យតាំងនៅផ្លូវនៃស្ថានសួគ៌ អន្ទោលទៅ

---

១-ផ្កានេះបាលីថា និគ្គុណ្ឌិបុប្ផំ ក្នុងអបទាន លោកប្រែថា ផ្កាឈើក្ទឹង ។

មក កើតជាសេដ្ឋីមានសម្បត្តិច្រើន ក្នុងកាលរបស់ព្រះមានព្រះភាគព្រះនាមថា កស្សបៈ ក្នុងកប្បនេះ ។ បំពេញទានដល់មនុស្សកំព្រានិងអ្នកដំណើរជាដើម បានប្រគេនបាយផ្សំដោយទឹកដោះដល់សង្ឃ កុលបុត្តនោះបំពេញកុសលដែលសម្រេចដោយទាន និងសន្សំបុណ្យដទៃទៀតដើម្បីព្រះនិព្វានក្នុងភពនោះៗ ដូចពណ៌នាមកនេះហើយ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំង-ឡាយក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលអាមាត្យ របស់ព្រះបាទបសេនទិកោ-សលក្នុងក្រុងសាវត្ថី ។ មនុស្សទាំងឡាយឲ្យឈ្មោះថា វីរៈ ។

កុលបុត្តនោះចម្រើនវ័យហើយ ប្រកបដោយគុណទាំងឡាយ មានការបរិបូរដោយកម្លាំងនិងការវាងវៃជាដើម សក្តិសមនឹងឈ្មោះ ជាអ្នកអង់អាចក្នុងសង្គ្រាម កាលមាតាបិតារកកិរិយាឲ្យ ដោយការសម្ពន្ធមេត្រី ក៏បានកូនប្រុសម្នាក់ប៉ុណ្ណោះ ដែលហេតុនៃបុព្វកម្មជាស់តឿន ឃើញទោសក្នុងកាមទាំងឡាយក្នុងសង្សារ កើតសេចក្តីសង្វេគ បួសហើយ ព្យាយាមបានអ-ភិញ្ញា ៦ ក្នុងគ្រាមិនយូរឡើយ សមដូចគាថាព័ន្ធដែលពោលទុកក្នុងអបទានថា

> *ខ្ញុំជាអារាមិកជនរបស់ព្រះមានព្រះភាគព្រះនាម វិបស្សី បានយកផ្កាឈើភ្លើងទៅបូជាដល់ព្រះពុទ្ធ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៣៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១ អង្គ ជាធំជាងជន ព្រះនាម មហា-*

បតាប ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨
នឹងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសា-
សនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

កិរិយាចាស់របស់ព្រះថេរៈ បំណងឲ្យព្រះថេរៈដែលសម្រេចអរហត្តសម្ដំ ដោយសេចក្ដីសុខ ដែលកើតអំពីផលសមាបត្តិយ៉ាងនេះសឹក ព្យាយាមលួងលោមដោយន័យផ្សេងៗ ក្នុងចន្លោះៗ ថ្ងៃមួយទៅដល់ទីសម្រាកពេលថ្ងៃរបស់ព្រះថេរៈ ក៏សម្ដែងមាយាស្ត្រី មានកលមាយាជាដើម ។ លំដាប់នោះព្រះវីរត្ថេរគិតថា ស្រីនេះជាមនុស្សល្ងង់ខ្លៅហ្ន៎ បំណងមកលួងលោមអញ ដូចបំណាងអង្រួនភ្នំសិនេរុ ឲ្យញាប់ញ័រដោយខ្យល់ស្លាបរបស់សត្វមូសដូច្នោះ ដូច្នេះហើយកាលនឹងសម្ដែងភាពដែលកិរិយារបស់ស្រីនោះមិនមានប្រយោជន៍ ក៏បានភាសិតគាថាថា

ភិក្ខុណាដែលគេទូន្មានបានដោយក្រ តែបានទូន្មានខ្លួនឯង ដោយ
ការទូន្មាន ( ឥន្ទ្រិយ ) ជាអ្នកប្រាជ្ញ មានចិត្តសន្ដោស ឆ្លងផុត
សេចក្ដីសង្ស័យ មានជ័យជម្នះ ប្រាសចាកសេចក្ដីព្រឺរោម ភិក្ខុ
នោះ ប្រាសចាកភគៈ មានចិត្តខ្ជាប់ខ្ជួន រំលត់ទុក្ខហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យោ ទុទ្ទមយោ** ដូច្នេះជាដើម ខ្ញុំបានពោលខាងដើមហើយនោះឯង ។ ឯពាក្យដែលគួរពោលតទៅនេះ ត្រឹមតែជាយោ-ជនា គឺពាក្យប្រកបសេចក្ដីក្នុងគាថានេះ ។ កាលមុន បុគ្គលណា ឈ្មោះថា

---

១-ក្នុងអបទានជាព្រះ និគ្គុណ្ឌិបុប្ផិយត្ថេរ ។

ភិក្ខុណាដែលគេទូន្មានបានដោយក្រ ព្រោះនៅមានកិលេសដែលមិនទាន់បាន បង្ក្រាប ឬព្រោះសត្រូវទាំងឡាយ មិនអាចនឹងបង្ក្រាប គឺដើម្បីនឹងឈ្នះក្នុង សមរភូមិបាន តែឥឡូវនេះ បុគ្គលនោះដែលព្រះមានព្រះភាគទ្រង់ទូន្មានខ្លួន ហើយ ទ្រង់ទូន្មានហើយដោយធម៌ជាគ្រឿងទូន្មានដ៏ឧត្តម ឈ្មោះថា ជាអ្នក ក្លៀវក្លា ព្រោះដល់ព្រមដោយសេចក្តីព្យាយាម គឺសម្មប្បធាន ៤ យ៉ាង ទើប ជាអ្នកមានចិត្តសន្តោស ធ្លងផុតសេចក្តីសង្ស័យ មានជ័យជម្នះ ប្រាសចាក សេចក្តីព្រឺរោម ជាអ្នកប្រាជ្ញឈ្មោះថាវីរៈ ឈ្មោះថា រលត់ទុក្ខហើយ ព្រោះ រំលត់កិលេសបានដោយមិនមានចំណែកសេសសល់ បន្ទាប់អំពីនោះក៏ជាអ្នក មានចិត្តខ្ជាប់ខ្ជួន បុគ្គលដូចនាង ១០០ ឬ ១០០០ ក៏ធ្វើឲ្យញាប់ញ័រមិន បាន ។

ស្រីនោះស្តាប់ពាក្យនោះហើយ គិតថា កាលព្រះថេរៈជាប្តីរបស់អញបដិ បត្តិបានបែបនេះ ការនៅគ្រប់គ្រងផ្ទះរបស់អញ នឹងមានប្រយោជន៍អ្វី ដូច្នេះ ហើយកើតនូវសេចក្តីសង្វេគបួសក្នុងសម្នាក់ភិក្ខុនីទាំងឡាយ បាននូវវិជ្ជា ៣ ក្នុងកាលមិនយូរឡើយ ។

## អដ្ឋកថា វីរត្ថេរគាថា ចប់

## បិលិន្ទវច្ឆត្ថេរគាថា

[ ១០ ] ដំណើរនៃអាត្មាអញមកល្អហើយ មិនមែនប្រាសចាក ( បញ្ញា ) ទេ សេចក្តីគិតរបស់អាត្មាអញនោះ មិនមែនជាការគិតខុសទេ ព្រោះអាត្មាអញបានសម្រេចគុណដ៏ប្រសើរនោះ ក្នុងធម៌ទាំងឡាយ ដែលព្រះមានព្រះភាគទ្រង់ចែកទុកហើយ ។

**បិលិន្ទវច្ឆត្ថេរ ។**

## អដ្ឋកថា
## បិលិន្ទវច្ឆត្ថេរគាថា

[ ១០ ] គាថារបស់ព្រះបិលិន្ទវច្ឆត្ថេរ មានពាក្យផ្តើមថា **ស្វាគតំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះថេរៈនេះ ក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមថាបទុមុត្តរៈ កើតក្នុងត្រកូលមានភោគៈច្រើន ក្នុងនគរហង្សវតី ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា ដោយន័យដូចពោលហើយខាងដើមនោះឯង ឃើញព្រះបរមសាស្តាទ្រង់តាំងភិក្ខុមួយរូប ក្នុងតំណែងឯតទគ្គៈ ក្នុងភាពដែលជាទីពេញចិត្តរបស់ទេវតាទាំងឡាយ ប្រាថ្នាតំណែងដ៏កំពូលនោះ បំពេញកុសលជរាបដល់អស់ជីវិត ចុតិចាកអត្តភាពនោះហើយ អន្ទោលទៅក្នុងទេវតា និងមនុស្សប៉ុណ្ណោះ ហើយកើតក្នុងមនុស្សលោក ក្នុងពុទ្ធុប្បាទរបស់ព្រះសាស្តាព្រះនាមថា សុមេធ ។ កាលព្រះមានព្រះភាគទ្រង់រំលត់ខន្ធបរិនិព្វានហើយ ធ្វើការបូ-

ជាព្រះស្តូបរបស់ព្រះបរមសាស្តា និងញុំាងមហាទានឲ្យប្រព្រឹត្តទៅ ក្នុងពួកសង្ឃ ចុតិអំពីមនុស្សលោកនោះហើយ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយនោះឯង ។ កាលព្រះពុទ្ធមិនទាន់កើតឡើង បានជាស្តេចចក្រពត្តិញុំាងមហាជនឲ្យប្រព្រឹត្តទៅក្នុងសីល ៥ បានធ្វើឲ្យជាបុគ្គលមានស្ថានសួគ៌ជាទីទៅខាងមុខ ។ កុលបុត្តនោះ កាលព្រះមានព្រះភាគនៃយើងទាំងឡាយមិនទាន់កើតឡើងនោះឯង កើតក្នុងត្រកូលព្រាហ្មណ៍ក្នុងនគរសាវត្ថី ។ មនុស្សទាំងឡាយ ដាក់ឈ្មោះកុលបុត្តនោះថា បិលិន្ទ ឯពាក្យថា វច្ឆ គឺជាគោត្តដោយហេតុនោះក្នុងកាលតមក ទើបកុលបុត្តនោះ មាននាមប្រាកដថា បិលិន្ទ-វច្ឆៈ ។ ព្រោះសង្វេគក្នុងសង្សារ កុលបុត្តនោះ បួសជាបរិព្វាជក សម្រេចវិជ្ជាឈ្មោះ ចូឡគន្ធារៈ ដើរក្នុងអាកាសបានដោយវិជ្ជានោះនិងដឹងចិត្តរបស់អ្នកដទៃ ដល់នូវភាពជាបុគ្គលប្រសើរ ដោយលាភនិងយសអាស្រ័យនគររាជគ្រឹះ ។

គ្រានោះ ចាប់តាំងពីកាលដែលព្រះមានព្រះភាគនៃយើងត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ យាងចូលទៅកាន់ក្រុងរាជគ្រឹះដោយលំដាប់ ដោយពុទ្ធានុភាព ធ្វើឲ្យវិជ្ជារបស់កុលបុត្តនោះវិនាសទៅ មិនអាចញុំាងកិច្ចរបស់ខ្លួនឲ្យសម្រេចបាន កុលបុត្តនោះគិតថា បានឮថា កាលអាចារ្យនិងបរមាចារ្យទាំងឡាយពោលនូវមន្តនេះថា មហាគន្ធារវិជ្ជានៅក្នុងទីណា ចូឡគន្ធារវិជ្ជារមែងសាបសូន្យក្នុងទីនោះ ដូច្នេះ ។ តាំងពីព្រះសមណគោតមយាងមកហើយវិជ្ជានេះរបស់អញមិនបរិបូរសោះ ព្រះសមណគោតមមុខជាចេះ មហាគន្ធារ

វិជ្ជា ដោយឥតសង្ស័យ បើដូច្នោះ អញនឹងចូលទៅរកព្រះសមណគោតមនោះ ហើយរៀនវិជ្ជានោះក្នុងសម្នាក់របស់ព្រះអង្គ ។ កុលបុត្តនោះ ចូលទៅគាល់ព្រះមានព្រះភាគ ហើយក្រាបទូលថា បពិត្រមហាសមណៈ ខ្ញុំបំណងនឹងរៀនវិជ្ជាណាមួយក្នុងសម្នាក់របស់ព្រះអង្គ សូមទ្រង់ឲ្យឱកាសដល់ខ្ញុំផងចុះ ។ ព្រះមានព្រះភាគត្រាស់ថា បើដូច្នោះ ចូរអ្នកបួសចុះ ។ បិលិន្ទវច្ឆៈសម្គាល់ថា ការបួសជាការបរិកម្មវិជ្ជា ទើបព្រមបួស ។ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់ព្រះថេរៈ ហើយប្រទានកម្មដ្ឋាន ដែលសមគួរដល់ចរិត ។ លោកចម្រើនវិបស្សនាសម្រេចនូវអរហត្តក្នុងកាលមិនយូរឡើយ ព្រោះជាអ្នកបរិបូរដោយឧបនិស្ស័យ ។ ទេវតាទាំងឡាយណាដែលតាំងនៅក្នុងឱវាទរបស់លោកក្នុងជាតិមុនហើយកើតក្នុងស្ថានសួគ៌ ទេវតាទាំងនោះ អាស្រ័យភាពជាអ្នកដឹងគុណនោះកើតនូវការរាប់អានយ៉ាងច្រើន ចូលទៅរកព្រះថេរៈរាល់ល្ងាចព្រឹកហើយក៏ទៅ ។ ព្រោះហេតុនោះទើបព្រះថេរៈដល់នូវភាពជាកំពូល ព្រោះជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ទេវតាទាំងឡាយ ។ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលព្រះលោកនាថព្រះនាម សុមេធៈ ទ្រង់ជាអគ្គបុគ្គលទ្រង់បរិនិព្វានហើយ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានធ្វើនូវការបូជាព្រះស្តូប ។ ព្រះខីណាស្រពទាំងឡាយណាដែលបានអភិញ្ញា ៦ មានឫទ្ធិច្រើននៅក្នុងទីនោះ ខ្ញុំក៏បានប្រជុំព្រះខី-ណាស្រពទាំងនោះក្នុងទីនោះហើយ បានធ្វើសង្ឃភត្ត ។ កាល

នោះព្រះថេរៈឈ្មោះ សុមេធៈ ជាឧបដ្ឋាករបស់ព្រះមានព្រះភាគព្រះនាម សុមេធៈ ព្រះថេរៈនោះបានធ្វើអនុមោទនាក្នុងកាលនោះ ។ ដោយចិត្តជ្រះថ្លានោះ ខ្ញុំបានចូលទៅក្នុងវិមានដែលមានស្រីអប្សរ ៨៦ ពាន់ កើតឡើងសម្រាប់ខ្ញុំ ។ ពួកស្រីអប្សរនោះ ប្រព្រឹត្តតម្រូវចិត្តខ្ញុំ ដោយកាមទាំងពួង សព្វៗកាល ខ្ញុំគ្របសង្កត់នូវពួកទេវតាដទៃ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ២៥ កាលនោះ ខ្ញុំបានជាស្តេចចក្រពត្តិ ឈ្មោះវរុណៈមានភោជនដ៏បរិសុទ្ធ ។ មនុស្សទាំងឡាយនោះ មិនបាច់សាបព្រោះពូជ មិនបាច់ភ្ជួរដោយនង្គ័ល តែងបរិភោគស្រូវសាលីដែលដុះក្នុងទីមិនបាច់ភ្ជួរ ។ ខ្ញុំសោយរាជ្យក្នុងអត្តភាពជាមនុស្សនោះហើយ ក៏បានទៅកាន់អត្តភាពជាទេវតាម្តងទៀត ការបរិបូរណ៍ដោយភោគៈបែបនេះ ក៏កើតឡើងសម្រាប់ខ្ញុំ ក្នុងកាលនោះ ។ សត្វទាំងអស់ ទោះបីជាមិត្តក្តី មិនមែនជាមិត្តក្តី មិនដែលបៀតបៀនខ្ញុំ ខ្ញុំរមែងជាទីស្រឡាញ់នៃសត្វទាំងពួង នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ៣០ ពាន់ ព្រោះហេតុដែលខ្ញុំបានឲ្យទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃគ្រឿងក្រអូប និងគ្រឿងលាប ។ ក្នុងភទ្ទកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិមួយអង្គ ជាធំជាងជន មានអានុភាពច្រើន ជារាជឥសី មានកម្លាំងច្រើន ។ ខ្ញុំនោះ តាំង

នៅក្នុងសីល ៥ ហើយញុំាងពួកជនច្រើននាក់ ឲ្យដល់នូវសុគតិ ខ្ញុំជាទីស្រឡាញ់នៃទេវតាទាំងឡាយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

ម្យ៉ាងទៀត ព្រោះហេតុដែលព្រះថេរៈ ជាបុគ្គលដែលទេវតាទាំងឡាយស្រឡាញ់ពេញចិត្តក្រៃលែង ព្រះមានព្រះភាគ ក៏ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងនៃភិក្ខុដ៏ប្រសើរ ដោយភាពជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ទេវតាទាំងឡាយ ដោយព្រះពុទ្ធតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ទេវតាទាំងឡាយ ដែលជាសាវករបស់តថាគត ស្រេចនឹងបិលិន្ទវច្ឆៈប្រសើរជាងគេ ដូច្នេះ ។

ថ្ងៃមួយ លោកអង្គុយត្រង់កណ្តាលជំនុំសង្ឃ ពិចារណាមើលគុណទាំងឡាយរបស់ខ្លួនហើយ កាលនឹងសរសើរការមកក្នុងសម្នាក់នៃព្រះមានព្រះភាគថា ជានិមិត្តរបស់វិជ្ជា ជាហេតុនៃការសម្រេចគុណទាំងនោះ ទើបពោលថា

ដំណើរនៃអាត្មាអញមកល្អហើយ មិនមែនប្រាសចាក ( បញ្ញា ) ទេ សេចក្តីគិតរបស់អាត្មាអញនោះ មិនមែនជាការគិតខុសទេ ព្រោះអាត្មាអញបានសម្រេចគុណដ៏ប្រសើរនោះ ក្នុងធម៌ទាំងឡាយ ដែលព្រះមានព្រះភាគ ទ្រង់ចែកទុកហើយ

ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ស្វាគតំ** សេចក្ដីថា ជាការមកល្អ ។ ពាក្យនេះភ្ជាប់ជាមួយពាក្យថា **មម** ( របស់ខ្ញុំ ) ។ ម្យ៉ាងទៀត បទថា **ស្វាគតំ** សេចក្ដីថា ដែលអាត្មាអញមកល្អហើយ ( ពាក្យថា **មម** ) ត្រូវផ្លាស់វិភត្តិជា **មយា** ។ បទថា **នាបគតំ** កាត់បទជា **ន អបគតំ** សេចក្ដីថា មិនទៅប្រាសចាកការដល់នូវសេចក្ដីចម្រើន គឺប្រយោជន៍ ។ បទថា **នយិទំ ទុម្មន្តិតំ មម** សេចក្ដីថា ព្រះតម្រាស់នេះ ព្រះមានព្រះភាគ ត្រាស់ដល់អញមិនត្រឹមត្រូវឬអញពិចារណាមិនល្អក៏មិនមែន ។ លោកអធិប្បាយដូច្នេះថា ការគិត គឺការត្រិះរិះ បានដល់ ពាក្យដែលខ្ញុំ ពោលថា ខ្ញុំស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះមានព្រះភាគ ហើយនឹងបួស ដូច្នេះ ឬវត្ថុដែលខ្ញុំពិចារណាដោយចិត្តនេះ ជាការគិតដែលមិនឥតប្រយោជន៍ ។ ឥឡូវនេះ កាលនឹងសម្ដែងហេតុក្នុងសេចក្ដីនោះ ក្នុងបទនោះ ទើបលោកពោលពាក្យជាដើមថា **បវិភត្តេសុ** ដូច្នេះ ។ បទថា **បវិភត្តេសុ** សេចក្ដីថា ចែកហើយដោយប្រការផ្សេងៗ ។ បទថា **ធម្មេសុ** បានដល់ ក្នុងញេយ្យធម៌ ឬសមថធម៌ទាំងឡាយ ឬធម៌ដែលតិរ្ថិយពោលផ្សេងៗ ដោយអំណាចនៃបកតិ ( បរមាត្មន ) ជាដើម ឬក្នុងធម៌ដែលព្រះសម្មាសម្ពុទ្ធទាំងឡាយត្រាស់ចែកទុកដោយអំណាចរបស់អរិយសច្ច មានទុក្ខសច្ចជាដើម ។ បទថា **យំ សេដ្ឋំ តទុបាគមឹ** សេចក្ដីថា បណ្ដាធម៌ទាំងនោះ ធម៌ណាប្រសើរបំផុត ខ្ញុំពោលដល់ធម៌នោះដែលជាចតុរារិយសច្ចធម៌ ។

ម្យ៉ាងទៀត ខ្ញុំចូលដល់សាសនធម៌ ដែលជាហេតុនាំសត្វឲ្យត្រាស់ដឹង គឺចូលដល់ថា នេះធម៌ នេះវិន័យ ។ ម្យ៉ាងទៀត ក្នុងបណ្តាសភាវធម៌ទាំងឡាយ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ចែកទុកហើយដោយអំណាចនៃកុសលជាដើមនិងដោយអំណាចនៃខន្ធជាដើម តាមសេចក្តីពិត ធម៌ណាប្រសើរ គឺឧត្តម បានដល់ប្រសើរក្នុងសាសនានោះ ខ្ញុំចូលដល់ហើយ គឺចូលដល់ដោយប្រចក្សក្នុងខ្លួន បានដល់ ធ្វើឲ្យជាក់ច្បាស់ហើយនូវធម៌ដ៏ប្រសើរ សំដៅដល់ធម៌ គឺមគ្គ ផល និងនិព្វាន ព្រោះហេតុនោះ ទើបប្រកបសេចក្តីថា ការដែលខ្ញុំមកកាន់សម្នាក់របស់ព្រះសាស្តានេះ ជាការមកល្អហើយ មិនឥតប្រយោជន៍ ការដែលខ្ញុំគិតថានឹងស្តាប់ធម៌ ក្នុងសម្នាក់របស់ព្រះមានព្រះភាគហើយបួស ជាការគិតដែលមិនឥតប្រយោជន៍ ដូច្នេះ ។

## អដ្ឋកថា បិលិន្ទវច្ឆត្ថេរគាថា ចប់

# បុណ្ណមាសត្ថេរគាថា

[ ១១ ] បុគ្គលដែលបានដល់នូវវេទ ជាអ្នកសន្តោស មានខ្លួនសង្រួមហើយ មិនជាប់ជំពាក់ក្នុងធម៌ទាំងពួង គឺតណ្ហាទិដ្ឋិទេ រមែងកម្ចាត់ចេញនូវសេចក្តីអាល័យក្នុងលោកនេះនិងលោកខាងមុខបាន ព្រោះដឹងច្បាស់នូវទីកើតនិងទីរលត់នៃលោក ។

## បុណ្ណមាសត្ថេរ ។

## ឧទ្ទាន

និយាយអំពី សុភូតិត្ថេរ ១ មហាកោដ្ឋិកត្ថេរ ១ កង្ខារេវតត្ថេរ ១ បុណ្ណមន្តានីបុត្ត ១ ទព្វមល្លបុត្ត ១ សីតវនិយត្ថេរ ១ ភល្លិយត្ថេរ ១ វីរត្ថេរ ១ បិលិន្ទវច្ឆត្ថេរ ១ បុណ្ណមាសត្ថេរ អ្នកកម្ចាត់បង់ងងឹត ១ ។

## ចប់ បឋមវគ្គ ។

# អដ្ឋកថា

## បុណ្ណមាសត្ថេរគាថា

[ ១១ ] គាថារបស់ព្រះបុណ្ណមាសត្ថេរ មានពាក្យផ្ដើមថា **វិហរិ អបេក្ខំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមថាវិបស្សី ព្រះថេរៈអង្គនេះ យោនយកកំណើតជាសត្វចាក្រពាក ឃើញព្រះមានព្រះភាគយាងទៅ មានចិត្តជ្រះថ្លាហើយ យកចំពុះរបស់ខ្លួនពាំផ្កាសាវាយ ទៅធ្វើការបូជា ដោយបុញ្ញកម្មនោះកុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងកប្បទី ១៧ អំពីកប្បនេះបានជាស្ដេចចក្រពត្តិ ៨ ដង ។ ចំណែកក្នុងភទ្ទកប្បនេះ គឺក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមថាកស្សបៈ សាបសូន្យទៅ កុលបុត្តនោះកើតក្នុងត្រកូលកុដុម្ពិកៈ បួសហើយបំពេញសមណធម៌ ចុតិអំពីនោះហើយ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តរបស់ព្រាហ្មណ៍ ឈ្មោះថា សមិទ្ធៈ ក្នុងនគរសាវត្ថី ក្នុងថ្ងៃដែលកុលបុត្តនោះកើត ក្អមទទេទាំងអស់ក្នុងផ្ទះនោះពេញទៅដោយសណ្ដែកមាស ដោយហេតុនោះ ទើបជនទាំងឡាយដាក់ឈ្មោះកុមារនោះថា បុណ្ណមាស ។ កុមារចម្រើនវ័យហើយសម្រេចវិជ្ជាទាំងឡាយរបស់ព្រាហ្មណ៍ រៀបការបានកូនប្រុសម្នាក់ កើតសេចក្ដីនឿយណាយក្នុងការនៅគ្រប់គ្រងផ្ទះ ព្រោះជាអ្នកបរិបូណ៌ដោយឧបនិស្ស័យ ចូលទៅគាល់ព្រះមានព្រះភាគ ស្ដាប់ធម៌ បានចំពោះនូវសទ្ធា បព្វជ្ជាហើយ ខ្វល់ខ្វាយក្នុងកិច្ចគ្រប់យ៉ាង ប្រកបព្យាយាមរឿយៗក្នុងកម្មដ្ឋាន ៤ ប្រកបព្យា-

យាមក្នុងវិបស្សនា សម្រេចអរហត្ត ។ ដោយហេតុនោះ ទើបលោកពោលគាថាព័ន្ធទុកក្នុងអបទានថា

កាលនោះ ខ្ញុំជាបក្សីចាក្រពាក នៅនាច្នេរស្ទឹងសិន្ធុ ខ្ញុំមានសារាយសុទ្ធជាអាហារផង ខ្ញុំសង្រួមល្អ ក្នុងសត្វទាំងឡាយផង ។ ខ្ញុំបានឃើញព្រះពុទ្ធជាបុគ្គលប្រាសចាកធូលីគឺកិលេស កំពុងនិមន្តទៅព្ធដ៏អាកាស ខ្ញុំពាំនូវផ្កាពាំងដោយចំពុះ បង្អោនមកថ្វាយព្រះពុទ្ធព្រះនាមវិបស្សី ។ សទ្ធាមិនញាប់ញ័រ ដែលបុគ្គលណា តម្កល់ល្អហើយចំពោះព្រះតថាគត បុគ្គលនោះរមែងមិនទៅកាន់ទុគ្គតិដោយសេចក្ដីជ្រះថ្លានៃចិត្តនោះ ។

ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធ ព្រះអង្គជាបុគ្គលប្រសើរ ឱ ! ពូជដ៏ល្អគឺបុណ្យ ខ្ញុំជាបក្សីបណ្ដុះទុកល្អហើយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១៧ អំពីកប្បនេះ ខ្ញុំបានជាក្សត្រ ៨ ជង មានព្រះនាមដូចគ្នា គឺព្រះនាមថាសុចារុទស្សនៈ ជាស្ដេចចក្រពត្តិ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

លំដាប់នោះ បុរាណទុតិយិការបស់ព្រះថេរៈ បំណងនឹងលួងលោម ក៏

ប្រដាប់តាក់តែង ចូលទៅមួយអន្លើដោយបុត្តប្រារព្ធដើម្បីដោះនូវសំពត់ដោយការពាក្យលួងលោមដែលគួរស្រឡាញ់ ។ ព្រះថេរៈឃើញអាការរបស់នាងកាលនឹងប្រកាសឲ្យដឹងថា លោកមិនជាប់ជំពាក់ក្នុងអារម្មណ៍ណាមួយ ទើបភាសិតគាថាថា

បុគ្គលដែលបានដល់នូវវេទ ជាអ្នកសន្តោស មានខ្លួនសង្រួម ហើយ មិនជាប់ជំពាក់ក្នុងធម៌ទាំងពួង គឺតណ្ហាទិដ្ឋិទេ រមែងកម្ចាត់ចេញនូវសេចក្តីអាល័យ ក្នុងលោកនេះ និងលោកខាងមុខបានព្រោះដឹងច្បាស់នូវទីកើតនឹងទីរលត់នៃលោកដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិហរិ** សេចក្តីថា នាំទៅ គឺនាំចេញទៅបានដល់ កម្ចាត់បង់នូវទុក្ខដោយពិសេស ។ បទថា **អបេក្ខំ** បានដល់តណ្ហា ។ បទថា **ឥធ** បានដល់ ក្នុងលោក ឬអត្តភាពនេះ ។ បទថា **ហុរំ** បានដល់ ក្នុងអនាគត ឬអត្តភាពដទៃ ។ ម្យ៉ាងទៀត បទថា **ឥធ** បានដល់អាយតនៈដែលប្រព្រឹត្តទៅក្នុងខាងក្នុង ។ បទថា **ហុរំ** បានដល់ អាយតនៈដែលប្រព្រឹត្តទៅខាងក្រៅ ។ **វា** សព្ទ ត្រឹមតែសមុច្ចយត្ថៈ ( មានអត្ថរួមជាមួយ ) ដូចក្នុងប្រយោគជាដើមថា **អបទា វា ទ្វិបទា វា** ប្រែថា មិនមានជើងក្តី មានជើង ២ ក្តី ។ ដោយបទថា **យោ** ព្រះថេរៈសម្តែងដល់ខ្លួននោះឯងធ្វើឲ្យដូចជាអ្នកដទៃ ។ បទថា **វេទគូ** សេចក្តីថា ដល់ហើយដោយវេទ គឺបានដល់ សម្រេចព្រះនិព្វានដោយមគ្គញ្ញាណ ឬចប់សច្ចៈទាំង ៤ ដោយអំណាចនៃបរិញ្ញាកិច្ច បហានកិច្ច សច្ឆិកិរិយាកិច្ច និងភាវនាកិច្ច

តាំងនៅ ។ បទថា **យតត្តោ** សេចក្តីថា មានការសង្រួមដោយមគ្គសំវរៈ ជាសភាវៈ ឬមានការសង្រួមដោយសម្មាវាយាមៈ ជាសភាវៈ ។

បទថា **សព្វេសុ ធម្មេសុ អនូបលិត្តោ** សេចក្តីថា មិនជាប់ក្នុងធម៌ គឺក្នុងអារម្មណ៍ទាំងពួង ដោយអំណាចនៃការជាប់ដោយតណ្ហានិងទិដ្ឋិ ។ លោកសម្តែងដល់ការឈានកន្លងលោកធម៌ទាំងឡាយ មានលាភជាដើម ដោយពាក្យនោះ ។ បទថា **លោកស្ស** បានដល់ ពួក ៥ នៃឧបាទានក្ខន្ធ ។ ពួក ៥ នៃឧបាទានក្ខន្ធនោះ ឈ្មោះថា លោក ដោយអត្ថថា ទ្រុឌទ្រោមនិងបែកធ្លាយទៅ ។ បទថា **ឥញ្ញា** ស្មើគ្នានឹង **ជានិត្វា** ប្រែថា ដឹងច្បាស់ ។ បទថា **ឧទយព្វយញ្ច** បានដល់ ការកើតឡើងនិងការសូន្យទៅ ។ លោកសម្តែងដល់បដិបទាដែលជាចំណែកខាងដើមនៃគុណ តាមដែលពោលហើយដោយបទនេះ ។ ក្នុងគាថានេះ មានអធិប្បាយដូច្នេះថា បុគ្គលណាដឹងការកើតឡើងនិងការសូន្យទៅនៃលោក មានខន្ធលោកជាដើមដោយអាការ ៥០ ជាអ្នកចប់ត្រៃវេទ ជាអ្នកសង្រួម មិនជាប់ក្នុងធម៌ណាមួយ បុគ្គលនោះមិនសម្ងំក្នុងទីទាំងពួង ជាអ្នកសន្តោស មិនឲ្យការសម្គាល់ណាមួយ ចំពោះការធ្វើខុសប្រក្រតី ( របស់កិរិយាចាស់ ) មានសភាពបែបនោះ ព្រោះហេតុនោះ នៃស្រីអន្ធពាល នាងចូរទៅតាមផ្លូវដែលនាងមកហើយនោះឯងដូច្នេះ ។ គ្រានោះ ស្រីនោះដឹងថាសមណៈរូបនេះ អស់សេចក្តីត្រូវការក្នុងអញនិងបុត្តអញមិនអាចលួងលោមសមណៈនេះបានទេ ក៏ចៀសចេញទៅ ។

**អដ្ឋកថា បុណ្ណមាសត្ថេរគាថា ចប់**

**វគ្គទី ១ ចប់**

# ថេរគាថា ឯកនិបាត ទុតិយវគ្គ

## ចូឡវច្ឆត្ថេរគាថា

[ ១២ ] ភិក្ខុអ្នកច្រើនដោយសេចក្ដីរីករាយក្នុងធម៌ ដែលព្រះពុទ្ធទ្រង់ប្រកាសហើយ រមែងបាននូវសន្តិបទ គឺព្រះនិព្វាន ជាទីរម្ងាប់នូវសង្ខារ ជាគុណជាតនាំមកនូវសេចក្ដីសុខ ។

ចូឡវច្ឆត្ថេរ ។

# វគ្គទី២

## អដ្ឋកថា

## ចូឡវច្ឆត្ថេរគាថា

[ ១២ ] គាថារបស់ព្រះចូឡវច្ឆត្ថេរ មានពាក្យផ្ដើមថា **ចាមុជ្ជពហុលោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងកាលរបស់ព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ ព្រះថេរៈកើតក្នុងត្រកូលទុគ៌ត ចិញ្ចឹមជីវិតដោយការស៊ីឈ្នួលអ្នកដទៃ ឃើញព្រះថេរៈឈ្មោះថា សុជាត ជាសាវករបស់ព្រះមានព្រះភាគ ស្វែងរកសំពត់បង្សុកូល មានចិត្តជ្រះថ្លាចូលទៅរក ប្រគេនសំពត់ ហើយថ្វាយបង្គំ ដោយបញ្ចង្គប្រតិស្ឋាន ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ សោយរាជសម្បត្តិ ក្នុងពួកទេវតាអស់ ៣៣ ដង បានជាស្ដេចចក្រពត្តិ ៧៧ ដង បានជាស្ដេចបទេស

រាជរាប់មិនអស់ ។ កាលកុលបុត្តនោះ អន្ទោលទៅមកក្នុងទេវតានិងមនុស្ស យ៉ាងនេះ ក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមថាកស្សបៈសាបសូន្យទៅ បួសហើយបានបំពេញសមណធម៌ អន្ទោលទៅមកក្នុងគតិនៃទេវតានិងមនុស្សទាំងឡាយ អស់មួយពុទ្ធន្តរ ហើយកើតក្នុងត្រកូលព្រាហ្មណ៍ក្រុងកោសម្ពីក្នុងកាលរបស់ព្រះមានព្រះភាគនៃយើង មានឈ្មោះថា ចូឡវច្ឆៈ ។ ចូឡវច្ឆកុមារចម្រើនវ័យហើយ ដល់នូវការសម្រេចក្នុងសិប្បៈវិជ្ជារបស់ព្រាហ្មណ៍ទាំងឡាយ ស្តាប់ពុទ្ធគុណហើយ មានចិត្តជ្រះថ្លា ចូលទៅគាល់ព្រះមានព្រះភាគ ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដល់កុលបុត្តនោះ ។ កុលបុត្តនោះបាននូវសទ្ធា បព្វជ្ជាហើយ ធ្វើនូវកិច្ចនៃបព្វជិតស្រេចហើយ រៀនកម្មដ្ឋានដែលសមគួរដល់ចរិត ហើយបំពេញភាវនា ។ ដោយសម័យនោះ ភិក្ខុអ្នកកោសម្ពី កើតការប្រេះឆាដល់គ្នានឹងគ្នា ។ គ្រានោះ ព្រះចូឡវច្ឆត្ថេរមិនកាន់យកលទ្ធិរបស់ភិក្ខុទាំង ២ តាំងនៅក្នុងឱវាទដែល ព្រះមានព្រះភាគទ្រង់ប្រទានហើយ ផ្តើមចម្រើនវិបស្សនា សម្រេចអរហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

> ក្នុងកាលនោះ សាវកនាមសុជាតៈរបស់ព្រះមានព្រះភាគព្រះនាម បទុមុត្តរៈ លោកកំពុងស្វែងរកសំពត់បំសុកូលលើគំនរសំរាមក្បែរច្រក ។ ខ្ញុំជាអ្នកស៊ីឈ្នួលនៃបុគ្គលដទៃ ក្នុងនគរហង្សវតី បានប្រគេនសំពត់ពាក់កណ្តាល ហើយថ្វាយបង្គំដោយសិរ្សៈ ។ ដោយអំពើដែលខ្ញុំបានធ្វើល្អនោះផង ដោយ

ចេតនាដែលខ្ញុំបានតម្កល់ទុកហើយនោះផង ខ្ញុំលះរាងកាយជារបស់មនុស្សទៅ ក៏បានទៅកើតឯឋានតាវត្តិង្ស ។ ខ្ញុំបានកើតជាព្រះឥន្ទ្រសោយរាជ្យជាស្តេចនៃទេវតាអស់ ៣៣ ដង ខ្ញុំបានកើតជាស្តេចចក្រពត្តិអស់ ៧៧ ដង ។ ខ្ញុំបានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់ជាតិមិនអស់ ខ្ញុំឥតមានភ័យអំពីទីណា តែងត្រេកអរព្រោះកិរិយាឲ្យនូវសំពត់ពាក់កណ្តាល ។ ក្នុងថ្ងៃនេះ បើខ្ញុំប្រាថ្នាយកសំពត់ ដែលកើតអំពីសម្បកឈើមកប្រក់ព្រៃនិងភ្នំក៏សឹងបាន នេះជាផលនៃការថ្វាយនូវសំពត់ពាក់កណ្តាល ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសំពត់ពាក់កណ្តាល ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

គ្រានោះ ព្រះចូឡវច្ឆត្ថេរកាលសម្រេចអរហត្តហើយ ឃើញការវិនាសចាកប្រយោជន៍ខ្លួន របស់បុគ្គលដែលពេញចិត្តក្នុងការទាស់ទែងរបស់ភិក្ខុទាំងនោះ កើតធម្មសង្វេគ ពិចារណាដល់គុណវិសេសដែលខ្លួនបានសម្រេចហើយដោយអំណាចបីតិនិងសោមនស្ស ទើបភាសិតគាថាថា

ភិក្ខុអ្នកច្រើនដោយសេចក្តីរីករាយក្នុងធម៌ ដែលព្រះពុទ្ធទ្រង់

---

១-ក្នុងអបទានជាព្រះ ឧបឌ្ឍទុស្សទាយកត្ថេរ ។

ប្រកាសហើយ រមែងបានសន្តិបទ គឺព្រះនិព្វាន ជាទីរម្ងាប់នូវសង្ខារ ជាគុណធម៌នាំមកនូវសេចក្ដីសុខ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បាមោជ្ជពហុលោ** សេចក្ដីថា ឈ្មោះថាជាអ្នកច្រើនដោយបាមោជ្ជៈ ដោយអំណាចនៃការត្រេកអរក្រៃលែង ក្នុងធម៌ទាំងឡាយដែលជាអធិកុសល ដោយភាពជាអ្នកមិនមានកង្វល់ ព្រោះភាពជាអ្នកមានសីលបរិសុទ្ធល្អហើយ ។

ដោយហេតុនោះទើបលោកពោលថា **ធម្មេ ពុទ្ធប្បវេទិតេ** ក្នុងធម៌ដែលព្រះពុទ្ធទ្រង់ប្រកាសហើយ ។ បណ្ដាបទទាំងនោះ បទថា **ធម្មេ** បានដល់ពោធិបក្ខិយធម៌ ៣៧ ប្រការ ឬលោកុត្តរធម៌ ៩ យ៉ាង ។ ព្រះធម៌នោះឈ្មោះថា ព្រះពុទ្ធទ្រង់ប្រកាសហើយដ៏ល្អក្រៃលែង ព្រោះជាព្រះធម៌ដែលលោកអ្នកត្រាស់ដឹងសព្វញ្ញុតញ្ញាណទ្រង់ប្រកាសហើយ ដោយទេសនាដែលទ្រង់លើកឡើង មកសម្ដែងឯង ។ ឯទេសនាធម៌ ក៏សង្គ្រោះចូលក្នុងបទថា **ធម្មេ** នេះដូចគ្នា ព្រោះភាពដែលទេសនាធម៌នោះ ជាឧបាយឲ្យសត្វចូលដល់ធម៌ ។

ព្រះថេរៈពោលបទថា **បទំ សន្តំ** សំដៅដល់ ព្រះនិព្វាន ។ ភិក្ខុបែបនេះរមែងសម្រេច គឺជួបនូវសន្តិបទដែលជាចំណែកស្ងប់រម្ងាប់ ហើយបានដល់ព្រះនិព្វានដែលជាទីចូលទៅស្ងប់សង្ខារ ព្រោះចូលទៅស្ងប់រម្ងាប់សង្ខារទាំងពួងបាន ឈ្មោះថា ជាសុខ ព្រោះសុខក្រៃលែង ។

ពិតហើយ ភិក្ខុអ្នកមានសីលបរិសុទ្ធ ជាអ្នកច្រើនទៅដោយបាមោជ្ជៈ

ព្រោះមិនមានវិប្បដិសារៈ ជាអ្នកខ្វល់ខ្វាយក្នុងព្រះសទ្ធម្មរមែងជួបនូវសម្បត្តិគ្រប់យ៉ាង មានវិមុត្តិជាបរិយោសាន ។ សមដូចពាក្យដែលព្រះមានព្រះ-ភាគត្រាស់ ( ទុកក្នុងអង្គុត្តរនិកាយទសកនិបាត ) ថា ម្នាលអានន្ទ ពួកសីលជាកុសល មានអវិប្បដិសារៈ ( សេចក្តីមិនក្តៅក្រហាយ ) ជាប្រ-យោជន៍ មានអវិប្បដិសារៈជាអានិសង្ស ដូច្នេះ ។

ម្យ៉ាងទៀត បទថា **បាមុជ្ជពហុលោ** សេចក្តីថា ជាអ្នកច្រើនទៅដោយសេចក្តីត្រេកអរដោយបំណាងដល់ព្រះរតនត្រ័យថា ព្រះមានព្រះភាគជាអ្នកត្រាស់ដឹងឯងដោយប្រពៃ ព្រះធម៌ដែលព្រះមានព្រះភាគត្រាស់ល្អហើយ ព្រះសង្ឃបដិបត្តិល្អហើយ ។ ដើម្បីចៀសវាងពាក្យសួរដែលអាចមានឡើងថា បុគ្គលនោះច្រើនទៅដោយបាមោជ្ជៈក្នុងអ្វី ឬធ្វើអ្វី ទើបព្រះថេរៈពោលបាទគាថាជាដើមថា **ធម្មេ ពុទ្ធប្បវេទិតេ** ក្នុងធម៌ដែលព្រះពុទ្ធទ្រង់ប្រកាសល្អហើយ ដូច្នេះ អធិប្បាយថា សម្បត្តិទាំងឡាយរមែងនៅក្នុងកណ្តាប់ដៃរបស់បុគ្គលដែលសម្បូរដោយសទ្ធា ព្រោះឲ្យកើតនូវចក្កធម៌ ៤ ដោយងាយ ដោយការកើតឡើងគឺ សប្បុរិសូបសំសេវនៈ ១ សទ្ធម្មស្សវនៈ ១ យោនិសោមនសិការ ១ ធម្មានុធម្មប្បដិបត្តិ ១ សមដូចព្រះតម្រាស់ ( ក្នុងកីដាគិរិ-សូត្រ ) ថា ម្នាលភិក្ខុទាំងឡាយ កុលបុត្តក្នុងសាសនានេះ មានសទ្ធាទើបចូលទៅរក កាលបើចូលទៅរកហើយទើបចូលទៅអង្គុយជិត ដូច្នេះជាដើម ។

## អដ្ឋកថា ចូឡវច្ឆត្ថេរគាថា ចប់

## មហាវច្ឆត្ថេរគាថា

[ ១៣ ] ភិក្ខុមានប្រាជ្ញាជាកម្លាំង បរិបូណ៌ដោយសីលនឹងវត្ត មានចិត្តខ្ជាប់ខ្ជួន ត្រេកអរក្នុងឈាន មានស្មារតី បរិភោគភោជនតាមមាន ជាអ្នកប្រាសចាករាគៈ ក្នុងលោកនេះ តែងរង់ចាំកាលកិរិយាប៉ុណ្ណោះ ។

មហាវច្ឆត្ថេរ ។

## អដ្ឋកថា

## មហាវច្ឆត្ថេរគាថា

[ ១៣ ] គាថារបស់ព្រះមហាវច្ឆត្ថេរ មានពាក្យផ្ដើមថា **បញ្ញាពលី** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា លោកបានថ្វាយទឹកធាន់ជាទាន ដល់ព្រះមានព្រះភាគព្រះនាមថា បទុមុត្តរៈ និងដល់ភិក្ខុសង្ឃ ។ ក្នុងកាលរបស់ព្រះមានព្រះភាគព្រះនាមថា សិខី បានជាឧបាសក បានធ្វើបុញ្ញកម្មជាច្រើនដែលជាឧបនិស្ស័យនៃព្រះនិព្វាន ដោយបុញ្ញកម្មទាំងនោះ លោកអន្ទោលទៅក្នុងសុគតិភពនោះៗហើយ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនព្រាហ្មណ៍ ឈ្មោះថា សមិទ្ធិ ក្នុងនាលគាម[១] ដែនមគធៈ ។ កុលបុត្តនោះមានឈ្មោះថា មហាវច្ឆៈ ។ ចម្រើនវ័យហើយដឹងថាព្រះសារីបុត្តជាសាវ័ករបស់ព្រះមានព្រះភាគ ទើបគិតថា អម្បាលព្រះសារីបុត្តជាអ្នកមានបញ្ញាច្រើន គង់ចូលដល់ភាពជាសាវ័ករបស់ព្រះមានព្រះ

១-ក្នុងទីខ្លះជា នាលកគាម ឬនាឡកគាម ។

ភាគអង្គណា ប្រហែលព្រះមានព្រះភាគអង្គនោះឯង គង់ជាបុគ្គលប្រសើរបំផុតក្នុងលោកនេះ កើតនូវសទ្ធាក្នុងព្រះមានព្រះភាគ បួសក្នុងសម្នាក់របស់ព្រះសាស្តា ប្រកបរឿយៗនូវកម្មដ្ឋាន សម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តត្រេកអរ បានថ្វាយទឹកមួយក្អមចំពោះភិក្ខុសង្ឃដ៏ប្រសើរនៃព្រះបទុមុត្តរសម្ពុទ្ធ ។ ( ដោយកុសលកម្មនេះ ) បើខ្ញុំចង់បានទឹកសម្រាប់ផឹកលើកំពូលភ្នំ លើចុងឈើ ក្នុងអាកាស ឬក្នុងផែនដីក្នុងកាលណា ទឹកក៏កើតឡើងយ៉ាងឆាប់ ដល់ខ្ញុំក្នុងកាលនោះ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃឧទកទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

លុះសម្រេចអរហត្តយ៉ាងនេះហើយ សោយវិមុត្តិសុខ ដើម្បីឲ្យកើតនូវឧស្សាហៈ ដល់សព្រហ្មចារីទាំងឡាយ ដោយការសម្តែងឲ្យឃើញច្បាស់នូវការដែលព្រះសាសនាជានិយ្យានិកធម៌ ទើបបានភាសិតគាថាថា

ភិក្ខុមានប្រាជ្ញាជាកម្លាំង បរិបូណ៌ដោយសីលនិងវត្ត មានចិត្តខ្ជាប់ខ្ជួន ត្រេកអរក្នុងឈាន មានស្មារតី បរិភោគភោជនតាម

---

១-ក្នុងអបទានជាព្រះ ឧទកទាយកត្ថេរ ។

មានជាអ្នកប្រាសចាកភាគៈក្នុងលោកនេះតែងវង់ចាំកាលកិរិយា ប៉ុណ្ណោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បញ្ញាពលី** សេចក្ដីថា ជាអ្នកប្រកបដោយបញ្ញាដែលល្អក្រៃលែង ដោយអំណាចនៃបារិហារិយបញ្ញា និងវិបស្សនាបញ្ញា ។

បទថា **សីលវត្តូបបន្នោ** សេចក្ដីថា ចូលដល់ហើយ គឺប្រកបហើយ ដោយចតុប្បារិសុទ្ធិសីលដ៏ឧក្រិដ្ឋ និងដោយវត្ត ពោលគឺធុតង្គធម៌ ។

បទថា **សមាហិតោ** សេចក្ដីថា ប្រកបដោយសមាធិ មានឧបចារសមាធិ និងអប្បនាសមាធិ ។

បទថា **ឈានរតោ** សេចក្ដីថា តអំពីនោះទៅ ទើបត្រេកអរ គឺខ្មីឃ្មាតជាប់តគ្នាក្នុងអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ។ ឈ្មោះថា **សតិមា** ព្រោះមិននៅប្រាសចាកសតិក្នុងកាលទាំងពួង ។

បទថា **យទត្ថិយំ** សេចក្ដីថា ការមិនប្រាសចាកវត្ថុដែលមាន ឈ្មោះថាការមាន ការមានតាមវត្ថុណា ឈ្មោះថា តាមមាន ។ បុគ្គលបរិភោគបច្ច័យមានការបរិភោគយ៉ាងណា ក៏បរិភោគភោជនយ៉ាងនោះ ។ ព្រោះការបរិភោគភោជនតាមមាននោះ ( មាន ២ យ៉ាងគឺ ) ដោយសាមីបរិភោគឬទាយជ្ជបរិភោគ មិនមានដោយប្រការដទៃ ។ មួយវិញទៀតពាក្យថា ភោជន ត្រឹមតែជាគំរូប៉ុណ្ណោះ ។ មួយវិញទៀត ភោជនក្នុងពាក្យថា **ភុញ្ជិស្សតិ បរិភុញ្ជិស្សតិ** បានដល់ បច្ច័យ ៤ នោះឯង ។ បាឋៈថា **យទត្ថិកំ** ដូច្នេះក៏មាន ។ បច្ច័យ

៤ ដែលព្រះសាស្ដាទ្រង់អនុញ្ញាតហើយឯណា គឺដើម្បីប្រយោជន៍ឯណាដើម្បីប្រយោជន៍នោះ គឺដើម្បីប្រយោជន៍ឲ្យរាងកាយតាំងនៅបានជាដើម ឯការតាំងនៅបាននោះ ក៏ដើម្បីអនុបាទិសេសនិព្វាន ព្រោះហេតុនោះ កិក្ខុធាន់បច្ច័យ គឺភោជនដើម្បីប្រយោជន៍ដល់អនុបាទាបរិនិព្វាន បន្ទាប់អំពីនោះ រមែងរង់ចាំកាលគឺរង់ចាំវេលាអនុបាទាបរិនិព្វានរបស់ខ្លួន ឈ្មោះថា ប្រាសចាករាគៈនេះ គឺក្នុងសាសនានេះ អធិប្បាយថា អនុបាទាបរិនិព្វាននេះ រមែងមិនមានដល់បុគ្គលខាងក្រៅ ( សាសនា ) សូម្បីបុគ្គលប្រាសចាករាគៈក្នុងកាមទាំងឡាយហើយក៏ដោយ ។

## អដ្ឋកថា មហាវច្ឆត្ថេរគាថា ចប់

## វនវច្ឆត្ថេរគាថា

[ ១៤ ] ភ្នំជាវិការៈនៃថ្មទាំងឡាយនោះ មានពណ៌ខៀវ ដូចពពកជាភ្នំដ៏រុងរឿង មានទឹកត្រជាក់ ទ្រទ្រង់នូវវត្ថុដ៏បរិសុទ្ធ ដ៏ដេរដាសដោយសត្វអណ្តើកមាស តែងញុំាងយើងឲ្យរីករាយ ។

**វនវច្ឆត្ថេរ ។**

## អដ្ឋកថា

## វនវច្ឆត្ថេរគាថា

[ ១៤ ] គាថារបស់ព្រះវនវច្ឆត្ថេរ មានពាក្យផ្តើមថា **នីលព្ភវណ្ណា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងកាលរបស់ព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី កុលបុត្តនេះកើត ក្នុងកំណើតអណ្តើក អាស្រ័យនៅក្នុងស្ទឹងឈ្មោះវិនតា អត្តភាពរបស់អណ្តើកនោះទំហំប្រមាណប៉ុនទូកតូច ។ បានឮថា ក្នុងថ្ងៃមួយអណ្តើកនោះឃើញព្រះមានព្រះភាគទ្រង់ឈរត្រង់មាត់ស្ទឹង គិតថា ព្រះសាស្តា ប្រ-ហែលជាទ្រង់មានបំណងយាងទៅកាន់ត្រើយនាយ បំណងនឹងនិមន្តព្រះសាស្តាឲ្យគង់លើខ្នងរបស់ខ្លួន ក៏ក្រាបទៀបបាទមូល ។ ព្រះមានព្រះភាគយល់អធ្យាស្រ័យរបស់អណ្តើកនោះ កាលទ្រង់អនុគ្រោះ ក៏ឡើងគង់លើខ្នង ។ អណ្តើកកើតបីតិសោមនស្ស ហែលកាត់រលក នាំព្រះសាស្តាដល់ត្រើយក្នុងមួយរំពេចនោះឯង ដូចព្រួញដែលបាញ់ចេញអំពីប្រឡោះធ្នូ ដូច្នោះ ។

ព្រះមានព្រះភាគ ទ្រង់ព្យាករផលនៃបុណ្យនោះ និងសម្បត្តិដែលកើតក្នុងបច្ចុប្បន្ន ហើយយាងចៀសចេញទៅ ។ ដោយកម្មនោះ អណ្តើកអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ បួសជាតាបសច្រើនរយដង មានប្រក្រតីនៅព្រៃតែម្យ៉ាង ។ ក្នុងកាលព្រះសម្មាសម្ពុទ្ធព្រះនាមថា កស្សបៈ កើតក្នុងកំណើតនៃសត្វព្រាបឃើញភិក្ខុនៅក្នុងព្រៃមួយរូបដែលមានប្រក្រតីនៅដោយមេត្តា ញុំាងចិត្តឲ្យជ្រះថ្លាហើយ កាលចុតិអំពីកំណើតព្រាបនោះហើយ កើតក្នុងផ្ទះមានត្រកូលក្នុងនគរពារាណសី ចម្រើនវ័យហើយកើតក្តីសង្វេគ បួសហើយ សម្រេចនូវបុញ្ញកម្មដ៏ច្រើន ជាចំណែកឧបនិស្ស័យ នៃព្រះនិព្វានអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងភពនោះៗ យ៉ាងនេះហើយក្នុងពុទ្ធុប្បាទនេះ បដិសន្ធិក្នុងផ្ទះរបស់ព្រាហ្មណ៍ឈ្មោះថា វច្ឆគោត្ត ក្នុងព្រះនគរកបិលពស្តុ មាតារបស់កុលបុត្តនោះ មានគភ៌ចាស់ជុំវិញហើយ កើតនូវការចាញ់គភ៌ចង់ដើរលេងព្រៃ ទើបចូលព្រៃត្រាច់ទៅ ។ វេលានោះឯងខ្យល់កម្មជវាតរបស់នាង បានបក់ឡើងហើយ មនុស្សទាំងឡាយក៏រៀបចំរាំងននឲ្យ ។ នាងប្រសូតបុត្តសម្បូរដោយលក្ខណៈរបស់អ្នកបុណ្យ ។ កុមារនោះបានជាសម្លាញ់លេងដីជាមួយព្រះពោធិសត្វ កុមារនោះ មានគោត្ត ឈ្មោះថាវច្ឆៈ ក្រោយមក ប្រាកដនាមថាវនវច្ឆៈ ព្រោះជាអ្នកត្រេកអរក្នុងព្រៃ ក្នុងកាលតមក កាលព្រះមហាសត្វចេញមហាភិនេស្រ្កមណ៍ បំពេញមហាបធានក៏ចេញបួសដោយគិតថា ខ្ញុំក៏នឹងនៅព្រៃរួមជាមួយសិទ្ធត្ថកុមារដូច្នេះ ហើយចេញបួសជាតាបសក្នុងព្រៃហិមពាន្ត បានឮថា ព្រះសិទ្ធត្ថត្រាស់ដឹងសម្មា

សម្មាធិញ្ញាណហើយ ទើបទៅកាន់សម្នាក់របស់ព្រះមានព្រះភាគ បួសហើយ រៀនកម្មដ្ឋានក្នុងព្រៃ ខំះខ្នែងក្នុងវិបស្សនា មិនយូរប៉ុន្មានក៏បានធ្វើឲ្យជាក់ច្បាស់នូវអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះតថាគតមានព្រះភាគ ព្រះនាមអត្ថទស្សី ជាព្រះសយម្ភូ ជាលោកនាយក ស្តេចបានចូលទៅទៀបឆ្នេរស្ទឹងវិនតា ។ ខ្ញុំជាអណ្តើកគោចរក្នុងទឹក បានងើបអំពីទឹកមានប្រាថ្នានឹងចម្លងនូវព្រះពុទ្ធជាម្ចាស់ បានចូលទៅជិតព្រះលោកនាយក ហើយពោលថា បពិត្រព្រះមហាមុនី សូមព្រះពុទ្ធជាម្ចាស់ ព្រះនាមអត្ថទស្សី ទ្រង់ឡើងគង់លើខ្នងនៃខ្ញុំព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងចម្លងព្រះអង្គ ព្រោះព្រះអង្គបានធ្វើនូវទីបំផុតនៃទុក្ខ ។ ព្រះអត្ថទស្សីមានយសធំ ជាលោកនាយក ទ្រង់ជ្រាបសេចក្តីត្រិះរិះរបស់ខ្ញុំហើយ ក៏ឡើងគង់លើខ្នងរបស់ខ្ញុំ ។ វេលាណាខ្ញុំព្រួកឃើញនូវខ្លួន វេលាណាខ្ញុំដល់នូវភាពដឹងក្តីហើយ វេលានោះខ្ញុំមិនមានសេចក្តីសុខ បែបនោះសោះឡើយ ដូចជាផ្ទៃនៃបាតជើង ( ដែលត្រូវបន្លា ) មុត ។ ព្រះសម្ពុទ្ធព្រះនាមអត្ថ-ទស្សី មានយសធំ ទ្រង់ឆ្លងដល់ត្រើយហើយ ព្រះអង្គឋិតនៅទៀបឆ្នេរស្ទឹង ហើយទ្រង់ត្រាស់នូវព្រះគាថានេះថា

ចិត្តប្រព្រឹត្តទៅដរាបណា តថាគតឆ្លងនូវក្រសែនៃសេចក្តីសង្ស័យបាន ដរាបនោះ ចំណែកអណ្តើកនេះនឹងបានកើតជា

ស្តេចមានបុណ្យ ព្រោះបានចម្រើននូវតថាគត ។ អណ្តើកនេះនឹងត្រេកអរក្នុងទេវលោកអស់ ១.៨០០ កប្ប ដោយការចម្រើនព្រះពុទ្ធនេះផងដោយមេត្តាចិត្តដែលប្រព្រឹត្តទៅនេះផង ។ លុះច្យុតចាកទេវលោក មកក្នុងលោកនេះ ត្រូវកុសលមូលដាស់តឿនហើយ នឹងអង្គុយនៅលើអាសនៈតែមួយ ហើយទម្លុះនូវក្រសែនៃសេចក្តីសង្ស័យបាន ។

ពូជសូម្បីមានប្រមាណតិចដែលបុគ្គលព្រោះហើយក្នុងស្រែដ៏ល្អ កាលភ្លៀងញុំាងធារទឹកឲ្យធ្លាក់ចុះដោយល្អ ផលរមែងញុំាងអ្នកស្រែឲ្យត្រេកអរបាន ដូចម្តេចមិញ ។ ព្រះពុទ្ធខេត្តនេះ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងហើយ រមែងញុំាងធារគឺផលឲ្យធ្លាក់ចុះដោយប្រពៃ ផលនឹងញុំាងឲ្យខ្ញុំត្រេកអរបានក៏យ៉ាងនោះដែរ ។ ខ្ញុំជាអ្នកមានចិត្តបញ្ជូនទៅកាន់សេចក្តីព្យាយាម ហើយជាអ្នកស្ងប់រម្ងាប់ មិនមានឧបធិក្កិលេស បានកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ១.៨០០ ព្រោះហេតុដែលខ្ញុំធ្វើកុសលកម្ម ក្នុងកាលនោះខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការចម្រើនព្រះសម្ពុទ្ធ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

---

១-ក្នុងអបទានជាព្រះ តរណិយត្ថេរ ។

កាលព្រះមានព្រះភាគនៃយើង ទ្រង់សម្រេចអរហត្ត ហើយគង់នៅក្នុងនគរកបិលពស្តុ ព្រះថេរៈបានទៅកាន់កបិលពស្តុនោះ ថ្វាយបង្គំព្រះសាស្តាជាមួយភិក្ខុទាំងឡាយ កាលភិក្ខុទាំងឡាយសួរដោយបដិសណ្ឋារៈថា អាវុសោលោកនៅក្នុងព្រៃមានផាសុកឬ ក៏ឆ្លើយថា អាវុសោទាំងឡាយ ព្រៃនិងភ្នំគួរជាទីត្រេកអរ កាលពណ៌នាដល់ព្រៃដែលខ្លួននៅហើយ ទើបភាសិតគាថា ដូច្នេះថា

ភ្នំជាវិការៈនៃថ្មទាំងឡាយនោះ មានពណ៌ខៀវដូចពពក ជាភ្នំដ៏រុងរឿង មានទឹកត្រជាក់ ទ្រទ្រង់នូវវត្ថុដ៏បរិសុទ្ធ ដ៏ដេរដាសដោយសត្វអណ្តើកមាសតែងញុំាងយើងឲ្យរីករាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នីលព្ភវណ្ណា** សេចក្តីថា មានពណ៌ដូចវលាហក ( មេឃ ) ដែលខៀវខ្ចី និងមានសណ្ឋានដូចនីលវលាហក ។ បទថា **រុចិរា** សេចក្តីថា មានពន្លឺនិងរស្មីល្អ ។ បទថា **សីតវារី** សេចក្តីថា មានទឹកត្រជាក់ ថ្លាស្អាត ។ បទថា **សុចិន្ធរា** សេចក្តីថា ឈ្មោះថា **សុ-ចិន្ធរា** ព្រោះជាភូមិភាគដែលស្អាតបរិសុទ្ធ និងព្រោះជាទីនៅអាស្រ័យរបស់ព្រះអរិយៈទាំងឡាយដែលមានចិត្តបរិសុទ្ធ ។ ដើម្បីងាយស្រួលដល់ការចងគាថាទើបលោកផ្លាស់និគ្គហិតជា **ធ** ។ បាឋៈថា **សីតវារី សុចិន្ធរា** ដូច្នេះក៏មាន សេចក្តីថា ទ្រទ្រង់នូវទឹកត្រជាក់ស្អាត មានប្រកពទឹកត្រជាក់ ថ្លាស្អាត ។ បទថា **ឥន្ទគោបកសញ្ឆន្នា** សេចក្តីថា ដេរដាសទៅដោយសត្វល្អិតពណ៌ក្រហម មានពណ៌ដូចកែវពពាល ដែលបានឈ្មោះថា មេភ្លៀង

លោកពោលយ៉ាងនេះ ដោយអំណាចនៃពេលដែលមានភ្លៀងធ្លាក់ ចំណែកអាចារ្យពួកខ្លះ ពោលថា បានដល់ សត្វល្អិតពណ៌ក្រហមដែលស៊ីស្នឹកឈើ ឈ្មោះថា **ឥន្ទគោបក** ( សត្វអណ្តើកមាស ) ។ អាចារ្យពួកដទៃពោលថា បានដល់ ដើមកណិការ ។ បទថា **សេលា** បានដល់ ភ្នំដែលសម្រេចដោយថ្ម អធិប្បាយថា មិនមែនភ្នំដី ។ ដោយហេតុនោះ ទើបលោកពោល ( ទុកក្នុងគម្ពីរឧទាន ) ថា ភ្នំជាវិការៈនៃថ្ម ។ បទថា **រមយន្តិ មំ** សេចក្តីថា ញ៉ាំងខ្ញុំឲ្យត្រេកអរ គឺចម្រើននូវការត្រេកអរក្នុងវិវេកដល់ខ្ញុំ ។ ព្រះថេរៈកាលប្រកាសដល់ការត្រេកអរក្នុងព្រៃ ដែលខ្លួនអប់រំមក អស់កាលយូរយ៉ាងនេះ ទើបសម្តែងដល់ការត្រេកអរក្នុងវិវេក ៣ នោះឯង ។ ក្នុងបណ្តាវិវេក ៣ យ៉ាងនោះឧបធិវិវេកព្រះថេរៈសម្តែងដោយការព្យាករអរហត្តផលនោះឯង ។

## អដ្ឋកថា វនវច្ឆត្ថេរគាថា ចប់

## វនវច្ឆស្សថេរស្សសាមណេរគាថា

[ ១៥ ] ឧបជ្ឈាយ៍និយាយនឹងខ្ញុំថា នែសីវកៈ យើងចេញទៅអំពីស្រុកនេះ កាយរបស់យើងនៅក្នុងស្រុក តែចិត្តរបស់យើងទៅកាន់ព្រៃ យើងសូម្បីដេកក៏ឈ្មោះថាដើរ ការជាប់ជំពាក់របស់ជនអ្នកចេះដឹង មិនមានទេ ។

**សាមណេររបស់វនវច្ឆត្ថេរ ។**

## អដ្ឋកថា

## វនវច្ឆស្សថេរស្សសាមណេរគាថា

[ ១៥ ] គាថារបស់វនវច្ឆត្ថេរសាមណេរ មានពាក្យផ្ដើមថា **ឧបជ្ឈាយោ** ដូច្នេះជាដើម ។ រឿងរបស់សាមណេរមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងកប្បទី ៣១ រាប់អំពីកប្បនេះ លោកកើតក្នុងផ្ទះមានត្រកូល ក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមថាវេស្សភូ ថ្ងៃមួយចូលកាន់ព្រៃ ដោយករណីយកិច្ចឯណានីមួយ ឃើញព្រះមានព្រះភាគព្រះនាមថា វេស្សភូ គង់ត្រង់ញកភ្នំ ក្នុងព្រៃនោះ មានចិត្តជ្រះថ្លា ចូលទៅគាល់ថ្វាយបង្គំហើយផ្គងអញ្ជលីហើយឈរ ។ បន្ទាប់មកកុលបុត្តនោះ ឃើញផ្លែចំបក់ គួរជាទីត្រេកអរក្នុងព្រៃនោះ ក៏បេះយកផ្លែចំបក់ទាំងនោះ ចូលទៅថ្វាយព្រះមានព្រះភាគ ។ ព្រះមានព្រះភាគអាស្រ័យសេចក្ដីអនុគ្រោះ ទើបទ្រង់ទទួល ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំង

ឡាយ កាលបុរសជាអ៊ំបួសក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាម ថា កស្សបៈ ក៏បួសមួយអន្ទើនឹងអ៊ំ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ជាច្រើន ក្នុងពុទ្ធុប្បាទនេះ កើតជាក្មួយរបស់ព្រះវនវច្ឆត្ថេរ ។ មានឈ្មោះ ជាសិវកៈ កាលព្រះវនវច្ឆត្ថេរជាបងប្រុសរបស់ខ្លួនបួសក្នុងសាសនា ហើយ ដល់នូវទីបំផុតនៃកិច្ចរបស់បព្វជិតគង់នៅក្នុងព្រៃ នាងជ្រាបដំណឹងនោះហើយ ទើបពោលនឹងកូនថា នែសិវកៈ ចូរអ្នកបួសក្នុងសម្នាក់របស់ព្រះថេរៈហើយ មើលថែលោក ឥឡូវនេះ ព្រះថេរៈចាស់ហើយ ។ ព្រោះពាក្យរបស់មាតា ត្រឹមតែមួយម៉ាត់ប៉ុណ្ណោះ និងព្រោះអធិការដែលខ្លួនធ្លាប់ធ្វើទុកក្នុងកាលមុន ទើបកុលបុត្ត ទៅកាន់សម្នាក់របស់ព្រះថេរៈដែលជាអ៊ំ បួសហើយបម្រើព្រះ ថេរៈ អាស្រ័យនៅក្នុងព្រៃ ។

ថ្ងៃមួយ កាលលោកទៅកាន់ស្រុកជាយដែន ដោយករណីយកិច្ចឯណា នីមួយ អាពាធដ៏ខ្លាំងក្លាបានកើតឡើងដល់លោក ។ ទោះបីមានគេជួយធ្វើថ្នាំ ប្រគេន ក៏អាពាធមិនស្ងប់ ។ កាលសាមណេរយឺតយូរ ព្រះថេរៈគិតថា សាមណេរនេះប្រព្រឹត្តយឺតយូរ នឹងមានអ្វីហ្ន៎ ដូច្នេះហើយ ទើបទៅស្រុកជាយ ដែននោះ ឃើញសាមណេរអាពាធ ទើបធ្វើវត្តដែលគួរធ្វើនោះៗដល់ សាម- ណេរ ញុំាងចំណែកនៃថ្ងៃឲ្យកន្លងទៅហើយ ក្នុងពេលទៀបភ្លឺ ទើបពោលថា នែសិវកៈ តាំងពីខ្ញុំបួសហើយ មិនធ្លាប់នៅក្នុងស្រុក ខ្ញុំនឹងចេញអំពីស្រុកនេះ ទៅកាន់ព្រៃឥឡូវនេះឯង សាមណេរស្តាប់ដូច្នោះហើយទើបពោលថា បពិត្រ លោកម្ចាស់ ឥឡូវនេះ កាយរបស់ខ្ញុំនៅក្នុងស្រុក តែចិត្តនៅក្នុងព្រៃ ព្រោះ

ហេតុនោះ ទោះបីខ្ញុំជេក ខ្ញុំក៏នឹងទៅព្រៃដូចគ្នា ។ ព្រះថេរៈស្តាប់ដូច្នោះហើយ ទើបចាប់ដើមដៃរបស់សាមណេរ នាំទៅកាន់ព្រៃមួយរំពេចនោះឯងហើយឲ្យឱវាទ ។ សាមណេរ តាំងនៅក្នុងឱវាទរបស់ព្រះថេរៈ ចម្រើនវិបស្សនាហើយ សម្រេចអរហត្ត សមដូចពាក្យដែលលោកពោលទុក ក្នុងអបទានថា

ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គប្រាសចាកធូលី គឺរាគៈ ជាច្បងក្នុងលោក ប្រសើរជាងនរៈ ដែលគង់នៅនាចន្លោះភ្នំ ទ្រង់រុងរឿងដូចផ្កាកណិការ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានធ្វើអញ្ជលីលើត្បូង ហើយកាន់ផ្លែកាសុមារិព្រឹក្ស ថ្វាយដល់ព្រះពុទ្ធដ៏ប្រសើរ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ[១] ដូច្នេះ ។

សាមណេរសម្រេចអរហត្តហើយ ប្រៀបធៀបសេចក្តី ដែលឧបជ្ឈាយ៍និងខ្លួនពោលហើយ កាលនឹងប្រកាសសេចក្តីត្រេកអរក្រៃលែង ក្នុងវិវេក

---

១-ក្នុងអបទានជាព្រះ កាសុមារិផលទាយកត្ថេរ ។

*របស់ខ្លួន និងកិច្ចដែលខ្លួនធ្វើស្រេចហើយ ទើបបានភាសិតគាថាថា*

*ឧបជ្ឈាយ៍និយាយនឹងខ្ញុំថា នែសីវកៈ យើងចេញទៅអំពីស្រុក*

*នេះ កាយរបស់យើងនៅក្នុងស្រុក តែចិត្តរបស់យើងទៅកាន់*

*ព្រៃ យើងសូម្បីដេកក៏ឈ្មោះថាដើរ ការជាប់ជំពាក់របស់ជន*

*អ្នកចេះដឹង មិនមានទេ ដូច្នេះ ។*

*បណ្ដាបទទាំងនោះ បទថា* **ឧបជ្ឈាយោ** *សេចក្ដីថា ឈ្មោះថា ឧបជ្ឈាយ៍ ព្រោះចូលទៅសម្លឹងទោសតូចនិងទោសធំ គឺបំណងស្វែងរកប្រយោជន៍ហើយ សម្លឹងដោយញាណចក្ខុ សាមណេរហៅខ្លួនឯងដោយ បទថា* **មំ** *។ បទថា* **អវចាសិ** *ស្មើនិង* **អភាសិ** *ប្រែថា បានពោល ។*

*បទថា* **ឥតោ គច្ឆាមិ សិវក** *ជាពាក្យសម្ដែងអាការដែលប្រាប់ អធិប្បាយថា នែ សិវកៈ យើងទៅអំពីចន្លោះស្រុកនេះ ទៅកាន់ទីដែលជាព្រៃ នោះចុះ ព្រៃប៉ុណ្ណោះសមគួរដែលពួកយើងនៅ ។ សិវកសាមណេរ កាល ឧបជ្ឈាយ៍ពោលយ៉ាងនេះហើយ កើតសេចក្ដីសង្វេគ ដូចសេះអាជានេយ្យដ៏ ប្រសើរដែលត្រូវវាយដោយរំពាត់ ដូច្នោះ កាលប្រកាស ភាពដែលខ្លួនបំណង នឹងនៅព្រៃដូចគ្នា ទើបពោលថា*

*កាយរបស់យើងនៅក្នុងស្រុក តែចិត្តរបស់យើងទៅកាន់ព្រៃ*

*យើងសូម្បីដេក ក៏ឈ្មោះថាដើរ ការជាប់ជំពាក់របស់ជនអ្នក*

*ចេះដឹងមិនមានទេ ដូច្នេះ ។*

*គាថានោះ មានអត្ថដូច្នេះថា ព្រោះឥឡូវនេះ សូម្បីរាងកាយរបស់ខ្ញុំ*

នៅក្នុងស្រុក តែអធ្យាស្រ័យបង្អោនទៅកាន់ព្រៃតែម្យ៉ាង ដូច្នោះសូម្បីខ្ញុំដេក ក៏នឹងទៅ គឺឈ្មោះថា ដេក ព្រោះមិនអាចក្នុងការឈរ អង្គុយ និងដើរ ព្រោះមានជំងឺ ក៏លូន គឺនទៀលទៅដូចពស់ ទាំងអាការដែលដេកនេះ មក ចុះ យើងនឹងទៅកាន់ព្រៃជាមួយគ្នា ព្រោះហេតុអ្វី ព្រោះការប្រឡូកប្រឡំ ដោយពួកគណៈ រមែងមិនមានដល់បុគ្គលដែលដឹងហើយ ព្រោះបុគ្គលដឹង ទោសក្នុងកាម និងក្នុងសង្សារ ដឹងអានិសង្សក្នុងនេក្ខម្ម និងព្រះនិព្វានតាម សេចក្ដីពិតហើយ រមែងមិនជាប់ជំពាក់ក្នុងទីណាមួយ នេះជាសភាវៈធម្មតា ដូច្នោះ ពាក្យរបស់ឧបជ្ឈាយ៍សូម្បីពោលត្រឹមតែម្ដង ក៏កប់ជ្រៅក្នុងចិត្ត ស្មើ គ្នានឹងសាមណេរព្យាករអរហត្តផលដោយការអានពាក្យ ( របស់ឧបជ្ឈាយ៍ ) នោះ ។

## អដ្ឋកថា វនវច្ឆត្ថេរសាមណេរគាថា ចប់

## កុណ្ឌធានត្ថេរគាថា

[ ១៦ ] ភិក្ខុគប្បីកាត់បង់សំយោជនៈខាងក្រោម ៥ គប្បីលះបង់សំយោជនៈខាងលើ ៥ គប្បីចម្រើនឥន្ទ្រិយ ៥ តទៅ ជាអ្នកកន្លងនូវគ្រឿងជាប់ជំពាក់ ៥ ទើបលោកហៅថា ឆ្លងឱឃៈបាន ។

**កុណ្ឌធានត្ថេរ ។**

## អដ្ឋកថា

## កុណ្ឌធានត្ថេរគាថា

[ ១៦ ] គាថារបស់ព្រះកុណ្ឌធានត្ថេរ មានពាក្យផ្ដើមថា **បញ្ច ឆិន្ទេ បញ្ច ជហេ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងកាលរបស់ព្រះមានព្រះភាគ ព្រះនាមថា បទុមុត្តរៈ កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូលនានគរហង្សវតី ចូលទៅគាល់ព្រះមានព្រះភាគ ដោយន័យដូចពោលហើយខាងដើមនោះឯង ស្ដាប់ធម៌ ឃើញភិក្ខុមួយរូបដែលព្រះសាស្ដាទ្រង់ស្ថាបនាក្នុងតំណែងឯតទគ្គៈ ខាងចាប់ស្លាកមុន ក៏ប្រាថ្នាតំណែងនោះ ធ្វើបុណ្យសមគួរដល់តំណែងនោះ រឿយៗទៅ ។ ថ្ងៃមួយកុលបុត្តនោះបានថ្វាយស្និតបេកធំ មានពណ៌លឿងដូចមនោសិលា ដល់ព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ ដែលចេញអំពីនិរោធសមាបត្តិ ហើយគន់ព្រះមានព្រះភាគទ្រង់ទទួលស្និតបេកនោះហើយ ទ្រង់ក៏សោយ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះសោយទិព្វសម្បត្តិក្នុងពួកទេវតា ១១

ដង ជាស្តេចចក្រពត្តិ ២៤ ដង ធ្វើបុណ្យរឿយៗយ៉ាងនេះហើយ អន្ទោល ទៅក្នុងទេវតានិងមនុស្សទាំងឡាយក្នុងកាលរបស់ព្រះពុទ្ធព្រះនាមថាកស្សបៈ កើតជាភុម្មទេវតា ។

ធម្មតាព្រះពុទ្ធដែលមានព្រះជន្មាយុវែងទាំងឡាយ រមែងមិនមានឧបោ-សថរៀងរាល់កន្លះខែឡើយ ពិតហើយ ព្រះមានព្រះភាគព្រះនាមថា វិបស្សី មានឧបោសថ ៦ ឆ្នាំម្តង ព្រះទសពលព្រះនាមកស្សបៈ សូធ្យបាតិមោក្ខ ៦ ខែម្តង ក្នុងវេលាសូធ្យបាតិមោក្ខរបស់ព្រះទសពលនោះ ភិក្ខុដែលជាសម្លាញ់ នឹងគ្នា ២ រូបក្នុងស្រុកជនទៃ ធ្វើដំណើរទៅ ដោយគិតថា យើងនឹងធ្វើឧបោ-សថ ។ ភុម្មទេវតានោះគិតថា ភិក្ខុ ២ រូបនេះស្រឡាញ់គ្នាស្និតពន់ពេក បើ មានអ្នកបំបែកឲ្យបែកគ្នា តើបែកឬហ្ន៎ សម្លឹងរកឱកាសទម្លាយភិក្ខុទាំង ២ អង្គនោះ ដើរទៅមិនឆ្ងាយអំពីភិក្ខុទាំងនោះ ។ កាលនោះ ព្រះថេរៈមួយរូប ឲ្យព្រះថេរៈមួយរូបទៀតកាន់បាត្រនិងចីវរ ដើរទៅកាន់ទីដែលមានទឹករកបាន ដោយស្រួលដើម្បីជម្រះរាងកាយ លាងដៃជើងហើយ ចេញអំពីគុម្ពឈើ ។ ភុម្មទេវតាដើរតាមក្រោយព្រះថេរៈនោះទៅ កាឡាខ្លួនជាស្រីរូបស្អាត ធ្វើជារំ សាយសក់ ហើយចងជាថ្មី ធ្វើជាបោសធូលីត្រង់ខ្នង និងធ្វើជាស្លៀកសំពត់ សាជាថ្មី ដើរតាមស្នាមជើងព្រះថេរៈទៅ ចេញអំពីគុម្ពឈើ ។ ព្រះថេរៈជា សម្លាញ់ ឈរក្នុងចំណែកម្ខាង ឃើញហេតុនោះហើយ កើតទោមនស្ស គិត ថា ឥឡូវនេះ សេចក្តីស្រឡាញ់ដែលជាប់តគ្នាមកអស់កាលយូរជាមួយភិក្ខុ នេះ វិនាសហើយ បើអញដឹងថាភិក្ខុនេះមានកិលេសច្រើនយ៉ាងនេះ នឹងមិន

ធ្វើការស្និទ្ធស្នាល ជាមួយភិក្ខុនេះ អស់កាលប្រមាណប៉ុណ្ណោះឡើយ ដូច្នេះ កាលព្រះថេរៈនោះមកដល់ប៉ុណ្ណោះ ក៏ពោលថា និមន្តទទួលយកបាត្រ ចីវរ របស់លោកទៅចុះ អាវុសោ ខ្ញុំមិនប្រាថ្នារួមដំណើរជាមួយលោក ដែលជាបុគ្គលលាមកឡើយ កាលភិក្ខុលជ្ជីស្តាប់ពាក្យនោះហើយ ហទយៈហាក់បីដូចត្រូវចាក់ដោយលំពែងដ៏មុត ។ លំដាប់នោះ លជ្ជីភិក្ខុនោះ ក៏និយាយនឹងព្រះថេរៈដែលជាសម្លាញ់ថា អាវុសោ លោកនិយាយអ្វី ខ្ញុំមិនដឹងថាត្រូវអាបត្តិសូម្បីទុក្កដ អស់កាលមានប្រមាណប៉ុណ្ណោះ ថ្ងៃនេះ លោកពោលថា ខ្ញុំជាមនុស្សអាក្រក់ លោកឃើញអ្វីឬ ព្រះថេរៈជាសម្លាញ់ពោលថា មិនចាំបាច់ពោលដល់វត្ថុដទៃណាដែលឃើញច្បាស់ លោកនៅទីតែមួយ ជាមួយស្រីដែលប្រដាប់តាក់តែងហើយយ៉ាងនេះ មិនមែនឬ ។ ព្រះថេរៈដែលជាលជ្ជីពោលថា អាវុសោ រឿងនេះមិនមានដល់ខ្ញុំឡើយ ខ្ញុំមិនឃើញមាតុគ្រាមបែបនេះទេ ។ កាលព្រះថេរៈដែលជាលជ្ជីពោលយ៉ាងនេះ អស់វារៈ ៣ ដង ព្រះថេរៈក្រៅអំពីនេះក៏មិនជឿពាក្យ កាន់យកហេតុដែលខ្លួនឃើញហើយនោះឯង ថាជារឿងពិត មិនធ្វើដំណើរជាមួយភិក្ខុនោះ ទៅកាន់សម្នាក់របស់ព្រះសាស្តា ដោយផ្លូវដទៃ ។

បន្ទាប់អំពីនោះមក ដល់ពេលដែលភិក្ខុសង្ឃចូលកាន់រោងឧបោសថភិក្ខុនោះឃើញលជ្ជីភិក្ខុនោះក្នុងរោងឧបោសថ ចាំបានក៏ចេញទៅ ដោយគិតថា ភិក្ខុបែបនេះមានក្នុងរោងឧបោសថនេះអញមិនធ្វើឧបោសថរួមនឹងលោកឡើយ ដូច្នេះហើយ ចេញទៅឈរខាងក្រៅ ។ លំដាប់នោះ កុម្មទេវតាគិតថា អញ

ធ្វើកម្មធ្ងន់ហ្ន៎ ហើយការឡាខ្លួនជាឧបាសកចាស់ ទៅកាន់សម្នាក់របស់ភិក្ខុនោះ ពោលថា បពិត្រលោកម្ចាស់ ហេតុអ្វីលោកម្ចាស់ឈរក្នុងទីនេះ ភិក្ខុនោះឆ្លើយថា នែឧបាសក ភិក្ខុលាមកមួយរូប ចូលទៅក្នុងរោងឧបោសថនេះ អាត្មាមិនធ្វើឧបោសថជាមួយលោកឡើយ អាត្មាគិតដូច្នេះ ទើបមកឈរខាងក្រៅ ។ កុម្មទេវតាក៏ពោលថា បពិត្រលោកម្ចាស់ លោកកុំកាន់យកយ៉ាងនោះឡើយ ភិក្ខុនេះមានសីលបរិសុទ្ធ ឈ្មោះថា មាតុគ្រាមដែលលោកម្ចាស់ឃើញហើយ គឺខ្ញុំនេះឯង ដើម្បីនឹងសាកល្បងមេត្រីភាពរបស់លោកម្ចាស់ទាំង ២ ថា មេត្រីភាពរបស់ព្រះថេរៈទាំង ២ រូបនេះមាំទាំឬមិនមាំទាំហ្ន៎ ដូច្នេះ ខ្ញុំចង់មើលភាពដែលលោកម្ចាស់បែកគ្នា ឬមិនបែកគ្នា ធ្វើកម្មនោះហើយ ។ ភិក្ខុនោះសួរថា នែសប្បុរស អ្នកជានរណា កុម្មទេវតាពោលថា បពិត្រលោកម្ចាស់ ខ្ញុំជាកុម្មទេវតា ។ កាលចន្លលប្រាប់ហេតុ ទេវបុត្តបានរំសាយឫទ្ធិជាទេវតា ក្រាបចុះទៀបបាទដើងរបស់ព្រះថេរៈ អង្វរព្រះថេរៈថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់អត់ទោសដល់ខ្ញុំចុះ ព្រះថេរៈ ( មួយអង្គទៀត ) មិនដឹងទោសនោះទេ សូមលោកម្ចាស់ធ្វើឧបោសថចុះ ដូច្នេះហើយ និមន្តឲ្យព្រះថេរៈចូលកាន់រោងឧបោសថ ។ ព្រះថេរៈនោះ ធ្វើឧបោសថជាមួយគ្នាប៉ុណ្ណោះ តែក៏មិនអង្គុយក្នុងទីជាមួយគ្នានឹងភិក្ខុនោះ ដោយអំណាចនៃការស្និទ្ធស្នាលដូចមិត្ត ក្នុងកាលមុនឡើយ ទាំងមិននិយាយដល់កម្មរបស់ព្រះថេរៈនេះ ។ ឯព្រះថេរៈដែលត្រូវចោទ បំពេញវិបស្សនារឿយៗ សម្រេចអរហត្តហើយ ។

ដោយផលនៃកម្មនោះ កុម្មទេវតា មិនរួចផុតចាកភ័យក្នុងអបាយ អស់មួយពុទ្ធន្តរ ។ បើក្នុងវេលាណាមកកាន់ភាពជាមនុស្ស ទោសដែលអ្នកដទៃណាមួយធ្វើក៏ធ្លាក់មកលើកុលបុត្តនោះឯង ។ ក្នុងកាលនៃព្រះមានព្រះភាគរបស់យើងទាំងឡាយ កុលបុត្តនោះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងនគរសាវត្ថី មនុស្សទាំងឡាយបានដាក់ឈ្មោះថា ធានមាណព ។ ធានមាណពចម្រើនវ័យហើយរៀនត្រៃវេទ ក្នុងពេលចាស់ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា មានសទ្ធាបួសហើយ ចាប់តាំងពីថ្ងៃដែលលោកឧបសម្បទាហើយ ស្ត្រីដែលប្រដាប់តាក់តែងហើយមួយរូប ប្រាកដខ្លួនដើរតាមក្រោយលោក ជានិច្ចយ៉ាងនេះ គឺកាលព្រះថេរៈចូលស្រុក រូបនិមិត្តនោះ ក៏ចូលទៅជាមួយព្រះថេរៈ កាលចេញ ក៏ចេញមកដែរ កាលលោកចូលវិហារក៏ចូលទៅដែរ សូម្បីលោកឈរក៏ឈរដែរ ។

ព្រះថេរៈមិនឃើញស្រីនោះឡើយ តែដោយបុរាណកម្មរបស់លោកនាងក៏ប្រាកដដល់អ្នកដទៃ ស្ត្រីទាំងឡាយ កាលប្រគេនបបរ ឬភិក្ខាក្នុងផ្ទះ នាំគ្នាពោលថា បពិត្រលោកម្ចាស់ បបរមួយវែកនេះសម្រាប់លោក មួយវែកនេះសម្រាប់មិត្តស្រីរបស់ខ្ញុំទាំងឡាយ ដូច្នេះហើយ ធ្វើការសើចចំអក ។ ព្រះថេរៈដល់នូវសេចក្តីលំបាកដ៏ក្រៃលែង ។ សូម្បីតែសាមណេរនិងភិក្ខុកំលោះទាំងឡាយ ក៏នាំគ្នាចោមរោមព្រះថេរៈ ទៅកាន់វិហារ ពោលចំអកថា ព្រះធានជាទន្សេង ( មនុស្សអាក្រក់ ) ។

គ្រានោះ ទើបលោកមានឈ្មោះបន្ថែមទៀតថា កុណ្ឌធានត្ថេរ ដោយ

ហេតុនោះឯង លោកព្យាយាមហើយ ក៏មិនអាចអត់សង្កត់ក្នុងការចំអកបាន ដែលមនុស្សទាំងនោះធ្វើ ក៏កើតការខឹងសម្បាឡើងមក ពោលថា ពួកលោកនោះឯងជាទន្សោង ឧបជ្ឈាយ៍របស់ពួកលោកជាទន្សោង អាចារ្យរបស់ពួកលោកក៏ជាទន្សោង ។ លំដាប់នោះ ភិក្ខុទាំងឡាយទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះកុណ្ឌធានពោលពាក្យគ្រោតគ្រាតយ៉ាងនេះ ជាមួយភិក្ខុកំលោះ និងសាមណេរទាំងឡាយ ព្រះសាស្តាត្រាស់ឲ្យហៅព្រះកុណ្ឌធានមកត្រាស់សួរថា ម្នាលធាន បានឮថា អ្នកពោលពាក្យអាក្រក់ជាមួយភិក្ខុកំលោះនិងសាមណេរទាំងឡាយឬ កាលព្រះថេរៈទូលថា បពិត្រព្រះអង្គដ៏ចម្រើន ជាការពិតព្រះអង្គ ដូច្នេះ ទើបព្រះសាស្តាត្រាស់ថា ហេតុអ្វីទើបអ្នកពោលយ៉ាងនេះ ។ ព្រះកុណ្ឌធានក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គអត់ធន់សេចក្តីលំបាកដែលកើតឡើងជាប្រចាំមិនបាន ទើបពោលយ៉ាងនេះ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ អ្នកមិនអាចញុំាងកម្មដែលអ្នកធ្វើក្នុងកាលមុនឲ្យអស់រហូតដល់ថ្ងៃនេះ អ្នកកុំពោលពាក្យគ្រោតគ្រាតបែបនេះទៀតដូច្នេះ ហើយត្រាស់ ( គាថាធម្មបទ ) ថា

អ្នកកុំនិយាយពាក្យអាក្រក់នឹងអ្នកណាមួយឡើយ ជនទាំងឡាយដែលអ្នកស្តីថាឲ្យហើយ គេគប្បីស្តីថាតបមកអ្នកវិញ ព្រោះថា ការពោលពាក្យប្រណាំងប្រជែង ជាហេតុនាំឲ្យកើតទុក្ខ ការតស៊ូទាំងឡាយ គប្បីប៉ះពាល់នូវអ្នក ។ បើអ្នកធ្វើខ្លួនមិនឲ្យញាប់ញ័រ ដូចរគាំងដែលចៀរមាត់ចេញហើយ ( រមែង

មិនលាន់ឮសូរ) ដូច្នោះ អ្នកទុំះជាបុគ្គលដល់នូវព្រះនិព្វាន ការ
ប្រណាំងប្រជែងមិនមានដល់អ្នក ដូច្នេះ ។

កាលអ្នកស្រុកទាំងឡាយ ក្រាបទូលភាពដែលព្រះថេរៈត្រាច់ទៅជាមួយមាតុគ្រាមដល់ព្រះបាទកោសល ព្រះរាជាទ្រង់បញ្ជូនរាជបុរសទៅ ដោយត្រាស់ថា នែអ្នក ពួកអ្នកចូរទៅ ចូរពិចារណាមើល ដូច្នេះហើយ សូម្បីព្រះរាជាក៏យាងទៅលំនៅរបស់ព្រះថេរៈ ដោយបរិវារតិចតួច ហើយទ្រង់ប្រថាប់ឈរក្នុងចំណែកម្ខាង ក្នុងខណៈនោះ ព្រះថេរៈធ្វើសូចិកម្ម សូម្បីស្រីនោះក៏ប្រាកដដូចឈរក្នុងទីមិនឆ្ងាយ ។ ព្រះរាជាទតឃើញហើយ ទ្រង់ព្រះតម្រិះថា ប្រាកដជាមានហេតុណាមួយ ទើបយាងទៅកាន់ទីដែលស្រីនោះឈរ កាលព្រះរាជាយាងមក ស្រីនោះក៏ធ្វើជាចូលទៅកាន់បណ្ណសាលា ដែលជាលំនៅរបស់ព្រះថេរៈ ។

ព្រះរាជា យាងចូលទៅកាន់បណ្ណសាលានោះឯង មួយអន្លើដោយស្រីនោះ ទ្រង់ត្រួតមើលក៏មិនឃើញ ទើបយល់ថា នេះមិនមែនមាតុគ្រាម គង់ជាកម្មវិបាកណាមួយរបស់ព្រះថេរៈ កាលយាងចូលទៅរកព្រះថេរៈ ក៏មិនថ្វាយបង្គំ ទ្រង់ដឹងថា ហេតុនោះមិនពិត ទើបយាងមកថ្វាយបង្គំព្រះថេរៈហើយប្រថាប់គង់ក្នុងចំណែកម្ខាង ត្រាស់ថា បពិត្រលោកម្ចាស់ លោកម្ចាស់មិនលំបាកដោយអាហារបិណ្ឌបាតទេឬ ព្រះថេរៈទូលថា ល្មមប្រព្រឹត្តទៅបានមហាបពិត្រ ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំយល់ពាក្យពោលរបស់លោកម្ចាស់កាលលោកម្ចាស់ត្រាច់ទៅជាមួយរបស់ដែលសៅហ្មងយ៉ាង

នេះ អ្នកណាគេជ្រះថ្លា ចាប់ពីថ្ងៃនេះទៅ សូមលោកម្ចាស់ កុំចាំបាច់ទៅក្នុងទីណាឡើយ ញោមនឹងទំនុកបម្រុងលោកម្ចាស់ ដោយបច្ច័យ ៤ សូមលោកម្ចាស់កុំប្រមាទក្នុងយោនិសោមនសិការ ដូច្នេះ ហើយក៏ប្រគេនភិក្ខាជាប្រចាំ ព្រះថេរៈបានរាជូបត្ថម្ភ មានចិត្តជាឯកគ្គតា ព្រោះមានភោជនជាទីសប្បាយ ចម្រើនវិបស្សនាហើយ សម្រេចអរហត្ត ចាប់តាំងអំពីនោះ ស្រីនោះក៏អន្តរធានទៅ ។

គ្រានោះ មហាសុភទ្ទាឧបាសិកា នៅក្នុងត្រកូលដែលជាមិច្ឆាទិដ្ឋិ ក្នុងឧគ្គនគរ អធិដ្ឋានឧបោសថ ដោយគិតថា សូមព្រះសាស្តាទ្រង់អនុគ្រោះខ្ញុំ មិនលាបនូវគ្រឿងក្រអូប ឈរលើផ្ទៃប្រាសាទជាន់លើ ធ្វើសច្ចកិរិយាថា ផ្កាទាំងនេះកុំឈប់ត្រង់កណ្តាលផ្លូវ ចូរតាំងជាពិតាន អំពីខាងលើព្រះទសពល ដោយសញ្ញានេះ សូមទ្រង់មកទទួលភិក្ខារបស់ខ្ញុំ មួយអន្លើដោយភិក្ខុ ៥០០ រូប ក្នុងថ្ងៃស្អែក ទើបបាចផ្កាម្ល៉ិះទៅ ៨ ក្តាប់ ។ ផ្កាទាំងឡាយអណ្តែតទៅជាពិតានខាងលើព្រះសាស្តា ក្នុងខណៈដែលទ្រង់សម្តែងព្រះធម៌ទេសនា ព្រះ-សាស្តាទតឃើញពិតានផ្កាម្ល៉ិះនោះហើយ ទ្រង់ទទួលភិក្ខារបស់នាងសុភទ្ទាដោយចិត្ត ។ ក្នុងថ្ងៃស្អែកឡើង កាលអរុណរះហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទថា ម្នាលអានន្ទ ថ្ងៃនេះ ពួកយើងទៅទទួលភិក្ខាក្នុងទីឆ្ងាយ អ្នកកុំឲ្យស្លាកដល់ភិក្ខុដែលជាបុថុជ្ជនឡើយ ចូរឲ្យស្លាកដល់ភិក្ខុដែលជាអរិយៈប៉ុណ្ណោះព្រះថេរៈប្រាប់ដល់ភិក្ខុទាំងឡាយថា អាវុសោទាំងឡាយ ថ្ងៃនេះ ព្រះសាស្តានឹងទទួលភិក្ខាក្នុងទីឆ្ងាយ ភិក្ខុដែលជាបុថុជ្ជន កុំទទួលស្លាក ភិក្ខុដែលជាអរិយៈ

ប៉ុណ្ណោះចូរទទួលស្លាក ដូច្នេះ ។ ព្រះកុណ្ឌធានត្ថេរលាដៃចេញទៅមុននោះឯង ដោយពោលថា អាវុសោ អ្នកចូរនាំស្លាកមក ព្រះអានន្ទពោលថា ព្រះសាស្តាត្រាស់ថា មិនឲ្យស្លាកដល់ភិក្ខុដូចលោក ទ្រង់ឲ្យដល់ភិក្ខុដែលជាអរិយៈ ប៉ុណ្ណោះ ដូច្នេះហើយ កើតបរិវិតក្កក្រាបទូលព្រះសាស្តាហើយ ព្រះសាស្តាត្រាស់ថា ចូរឲ្យស្លាកដល់អ្នកសូម ។

ព្រះថេរៈគិតថា បើស្លាកមិនគួរដល់ព្រះកុណ្ឌធាន កាលបើដូច្នោះ ព្រះសាស្តាគប្បីហាម ក្នុងរឿងនេះប្រហែលជាមានហេតុ ទើបត្រឡប់ទៅដោយគិតថា អញនឹងឲ្យស្លាកដល់ព្រះកុណ្ឌធាន មុនព្រះអានន្ទមកដល់នោះឯង ព្រះកុណ្ឌធានត្ថេរចូលចតុត្ថជ្ឈាន មានអភិញ្ញាជាបាទ ឈរក្នុងអាកាសដោយឫទ្ធិពោលថា អាវុសោអានន្ទ សូមលោកនាំស្លាកមកចុះ ព្រះសាស្តាជីងខ្ញុំ ព្រះសាស្តាទ្រង់មិនហាមភិក្ខុដូចជាខ្ញុំដែលចាប់ស្លាកមុនទេ ដូច្នេះហើយ លាដៃចាប់ស្លាក ។ ព្រះសាស្តាទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ទ្រង់តាំងព្រះថេរៈក្នុងតំណែងនៃភិក្ខុដែលក្រៃលែងជាងភិក្ខុទាំងឡាយ ដែលចាប់ស្លាកបានមុន ។ ព្រោះហេតុដែលព្រះថេរៈនេះ បានព្រះរាជាឧបត្ថម្ភ និងព្រោះបានអាហារជាទីសប្បាយទើបមានចិត្តជាសមាធិ ចម្រើនវិបស្សនា បានជាអ្នកមានអភិញ្ញា ៦ ព្រោះជាអ្នកសម្បូរដោយឧបនិស្ស័យសមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបម្រើព្រះសម្ពុទ្ធដ៏ប្រសើរ ព្រះអង្គជាព្រះសយម្ភូ ជាអគ្គបុគ្គល ទ្រង់គេចចេញចាក

ពួក សម្ងំនៅក្នុងកម្មដ្ឋានអស់ ៧ ថ្ងៃ ។ ខ្ញុំដឹងនូវកាលដែលទ្រង់ចេញអំពីទីសម្ងំ ហើយខ្ញុំកាន់ចេកមួយស្និតធំ នាំចូលទៅថ្វាយព្រះមហាមុនី ព្រះនាមបទុមុត្តរៈ ។ ព្រះមានព្រះភាគជាសព្វញ្ញូជាលោកនាយក ទ្រង់បានទទួល ព្រះមហាមុនីញុំាងចិត្តរបស់ខ្ញុំឲ្យជ្រះថ្លា ទ្រង់សោយ ( ចេកនោះ ) ។ លុះព្រះសម្ពុទ្ធទ្រង់ជាអ្នកដឹកនាំពួក ជាបុគ្គលប្រសើរបំផុត ទ្រង់សោយរួចហើយគង់លើអាសនៈរបស់ព្រះអង្គហើយត្រាស់នូវគាថាទាំងឡាយនេះថា

ពួកយក្សណា ដែលមកជួបជុំ នៅនាភ្នំនេះ និងពួកភូតទាំងពួងដែលនៅអាស្រ័យក្នុងព្រៃនេះ ( ពួកយក្សនិងភូតទាំងនោះ ) ចូរស្តាប់ពាក្យរបស់តថាគតចុះ ។ កុលបុត្តណាបានបម្រើនូវព្រះពុទ្ធ ព្រះអង្គដូចជាកេសររាជសីហ៍ជាស្តេចនៃម្រឹគ តថាគតនឹងសម្តែងសរសើរនូវកុលបុត្តនោះ អ្នកទាំងឡាយចូរស្តាប់តថាគតសម្តែង ។ កុលបុត្តនោះនឹងបានជាស្តេចនៃទេវតាអស់ ១១ ដង នឹងបានជាស្តេចចក្រពត្តិអស់ ៣៤ ដង ។ កន្លងទៅមួយសែនកប្ប នឹងមានព្រះសាស្តាព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល ត្រាស់ដឹងក្នុងលោក ។ កុលបុត្តនោះនឹងបាននូវនាម ( ថាកុណ្ឌធាន ) ដោយវិបាកនៃបាបកម្ម ព្រោះ

ដេរនូវសមណៈទាំងឡាយ ជាអ្នកមានសីល មិនមានអាសវៈ ។ កុលបុត្តដែលឈ្មោះកុណ្ឌធានទោះនឹងបានជាទាយាទក្នុងធម៌របស់ព្រះពុទ្ធព្រះនាមគោតមនោះ នឹងជាព្រះឱរស ជាធម្មនិមិត្ត ទាំងបានជាសាវ័ករបស់ព្រះពុទ្ធអង្គនោះ ។

ខ្ញុំតែងប្រកបរឿយៗ នូវវិវេក ជាអ្នកមានឈាន ត្រេកអរក្នុងឈានញុំាងព្រះសាស្តាឲ្យត្រេកអរ ជាអ្នកមិនមានអាសវៈ ។ ព្រះជិនស្រី មានសាវ័កចោមរោម និងពួកភិក្ខុចោមរោមទ្រង់គង់ក្នុងកណ្តាលភិក្ខុសង្ឃ ហើយញុំាងខ្ញុំឲ្យកាន់យកស្លាក ។ ខ្ញុំធ្វើនូវចីវរឆៀងស្មាម្ខាង ហើយថ្វាយបង្គំព្រះលោកនាយកកាន់យកនូវស្លាកជាដំបូង ក្នុងទីចំពោះ ព្រះភក្ត្រព្រះសម្ពុទ្ធដ៏ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ។ ព្រះមានព្រះភាគញុំាងលោកធាតុមួយម៉ឺនឲ្យញាប់ញ័រ ទ្រង់គង់ក្នុងភិក្ខុសង្ឃ ហើយតាំងខ្ញុំក្នុងទីជាឯតទគ្គៈ ដោយសារអំពើនោះ ។ សេចក្តីព្យាយាមរបស់ខ្ញុំ គួរដើម្បីនាំទៅនូវធុរៈ ជាទីនាំមកនូវធម៌ដ៏ក្សេមចាកយោគៈ ខ្ញុំទ្រទ្រង់នូវរាងកាយជាទីបំផុត ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

ភិក្ខុទាំងឡាយណាដែលជាបុថុជ្ជនមិនដឹងគុណរបស់ព្រះថេរៈ ដែលមានសភាពបែបនេះ ក្នុងការចាប់ស្វាកមុនគេ ក្នុងពេលនោះ នាំគ្នាគិតថា ហេតុអ្វីក៏ដូច្នោះហ្ន៎ ព្រះថេរៈដើម្បីកម្ចាត់សេចក្តីសង្ស័យរបស់ភិក្ខុទាំងនោះទើបហោះទៅកាន់អាកាស ហើយសម្តែងឥទ្ធិប្បាដិហារ្យដើម្បីព្យាករអរហត្តផល ដោយអាងដល់អរហត្តផល ទើបភាសិតគាថានេះថា

ភិក្ខុគប្បីកាត់បង់សំយោជនៈខាងក្រោម ៥ គប្បីលះបង់សំ-យោជនៈខាងលើ ៥ គប្បីចម្រើនឥន្ទ្រិយ ៥ តទៅ ជាអ្នកកន្លងនូវគ្រឿងជាប់ជំពាក់ ៥ ទើបលោកហៅថា ឆ្លងឱឃៈបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បញ្ច ឆិន្ទេ** សេចក្តីថា ភិក្ខុគប្បីកាត់ គឺគប្បីលះសំយោជនៈខាងក្រោម ៥ ដែលញុំាងសត្វឲ្យកើតក្នុងអបាយដោយសស្ត្រា គឺដោយមគ្គទាំង ៣ ខាងក្រោម ដូចបុរសកាត់ខ្សែដែលចងត្រង់ក ចេញទៅដូច្នោះ ។

បទថា **បញ្ច ជហេ** សេចក្តីថា គប្បីលះ ឬគប្បីកាត់សំយោជនៈខាងលើ ៥ ដែលជាហេតុឲ្យចូលដល់ទេវលោកជាន់ខ្ពស់ ដោយអរហត្តមគ្គ ដូចបុរសកាត់ខ្សែដែលចងត្រង់កដូច្នោះ ។

បទថា **បញ្ច ចុត្តរិ ភាវយេ** សេចក្តីថា គប្បីចម្រើនឥន្ទ្រិយ ៥ មានសទ្ធាជាដើម ដើម្បីលះសំយោជនៈដែលប្រព្រឹត្តទៅក្នុងចំណែកខាងលើទាំងនោះឯង ឲ្យក្រៃលែងឡើង គឺឲ្យខ្ពស់ជាងការបានសម្រេចអនាគាមិមគ្គ បាន

ដល់ គប្បីចម្រើនដោយអំណាចនៃការបានសម្រេចមគ្គជាន់ខ្ពស់ ។

បទថា **បញ្ច សង្គាតិគោ** សេចក្តីថា ភិក្ខុដែលមានសភាពបែបនេះ គឺដែលឈានកន្លងនូវធម៌ជាគ្រឿងជាប់ជំពាក់ ៥ ប្រការបានហើយ ដោយការឈានកន្លង គឺលះនូវគ្រឿងជាប់ជំពាក់ គឺរាគៈ ទោសៈ មោហៈ មានៈ និងទិដ្ឋិ ៥ យ៉ាងបាន ។

បទថា **ភិក្ខុ ឱឃតិណ្ណោ វុច្ចតិ** សេចក្តីថា លោកហៅថា ភិក្ខុ ព្រោះទម្លាយកិលេសបានដោយប្រការទាំងពួង និងព្រោះឆ្លង ឱឃៈគឺកាម ឱឃៈគឺភព ឱឃៈគឺទិដ្ឋិ ឱឃៈគឺអវិជ្ជា ហើយតាំងនៅក្នុងព្រះនិព្វានដែលជាត្រើយនៃកិលេសទាំងនោះ ។

អដ្ឋកថា កុណ្ឌធានត្ថេរគាថា ចប់

## ពេលដ្ឋសីសត្ថេរគាថា

[ ១៧ ] អាជានេយ្យដ៏ចម្រើន មានទន្តិ៍លជាទីប្រព្រឹត្តទៅមក ជាសត្វមានបូក តែងទៅបានដោយឥតលំបាក យ៉ាងណាមិញ កាលបើទិវាមិសសុខដែលខ្ញុំបានហើយ វេលាយប់នឹងថ្ងៃទាំងឡាយរបស់ខ្ញុំ តែងប្រព្រឹត្តកន្លងទៅដោយឥតលំបាក ក៏យ៉ាងនោះដែរ ។

ពេលដ្ឋសីសត្ថេរ ។

## អដ្ឋកថា

## ពេលដ្ឋសីសត្ថេរគាថា

[ ១៧ ] គាថារបស់ព្រះពេលដ្ឋសីសត្ថេរ មានពាក្យផ្ដើមថា **យថាបិ ភទ្ទោ អាជញ្ញោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងកាលនៃព្រះមានព្រះភាគ ព្រះនាមថា បទុមុត្តរៈ កុលបុត្តនេះកើតក្នុងផ្ទះដែលមានត្រកូល ចូលទៅគាល់ព្រះមានព្រះភាគ ស្ដាប់ធម៌ហើយ កើតនូវសទ្ធា បួសហើយបំពេញសមណធម៌ មិនអាចញុំាងនូវគុណវិសេសឲ្យកើតបាន ព្រោះមិនមានឧបនិស្សយសម្បត្តិ ។ លោកសន្សំកុសលជាច្រើន ដែលជាឧបនិស្ស័យនៃព្រះនិព្វាន អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ឃើញព្រះមានព្រះភាគ ព្រះនាមថាវេស្សភូ ក្នុងកប្បទី ៣១ អំពីកប្បនេះ ជាអ្នកមានចិត្តជ្រះថ្លា ហើយបានថ្វាយផ្លែក្រូចព្រៃ[១]។

---

១-ក្នុងអបទានជា ក្រូចត្លុង ។

ដោយបុញ្ញកម្មនោះ លោកកើតក្នុងទេវតានិងមនុស្សទាំងឡាយ សន្សំបុណ្យហើយ ចូលដល់សុគតិ ចុតិអំពីសុគតិ អន្ទោលទៅមកក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលព្រាហ្មណ៍ក្នុងនគរសាវត្ថី ។ មុនការត្រាស់ដឹងរបស់ព្រះមានព្រះភាគ បួសជាតាបសបូជាភ្លើងក្នុងសម្នាក់ឧរុវេលកស្សបៈ ក្នុងកាលដែលទ្រង់សម្តែងនូវអាទិត្តបរិយាយសូត្រទូន្មានឧរុវេលកស្សបៈ សម្រេចអរ-ហត្តមួយអន្លើដោយជដិល ១០០០ ។ សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ខ្ញុំបានឃើញនូវព្រះលោកនាយក ទ្រង់រុងរឿងដូចផ្កាកណិការ ឬដូចព្រះចន្ទពេញបូណ៌មី ឬក៏ដូចឈើប្រចាំទ្វីបដ៏រុងរឿង ។ ខ្ញុំមានចិត្តជ្រះថ្លា បានយកផ្លែក្រូចត្លុងទៅថ្វាយព្រះសាស្ដាជា ទក្ខិ-ណេយ្យបុគ្គលទ្រង់មានព្យាយាម ដោយដៃរបស់ខ្លួន ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[1] ។

ព្រះថេរៈនេះសម្រេចអរហត្តយ៉ាងនេះហើយ ជាឧបជ្ឈាយ៍របស់ព្រះធម្មភណ្ឌាគារិក ( ព្រះអានន្ទ ) ។ ថ្ងៃមួយ ចេញអំពីផលសមាបត្តិ ពិចារណាដល់អរហត្ត ដ៏ស្ងប់ ប្រណីត ជានិរាមិសសុខ និងបុព្វកម្មរបស់ខ្លួន ដោយ

១-ក្នុងអបទានជាព្រះ មាតុលុង្គទាយកត្ថេរ ។

អំណាចកម្លាំងនៃបីតិទើបពោលគាថាថា

អាជានេយ្យដ៏ចម្រើន មានទន្ត័លជាទីប្រព្រឹត្តទៅមក ជាសត្វមានបូក តែងទៅបានដោយឥតលំបាក យ៉ាងណាមិញ កាលបើនិរាមិសសុខដែលខ្ញុំបានហើយ វេលាយប់នឹងថ្ងៃទាំងឡាយរបស់ខ្ញុំតែងប្រព្រឹត្តកន្លងទៅដោយឥតលំបាក ក៏យ៉ាងនោះដែរដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យថាបិ** ត្រឹមតែជានិបាត ចុះក្នុងអត្ថអាងដល់ឧបមា ។ បទថា **ភទ្រោ** បានដល់ គោអាជានេយ្យដ៏ស្អាត ដែលសម្បូរដោយថាមពលនិងកម្លាំង ជាសត្វអង់អាច វាងវៃ និងសេចក្ដីព្យាយាម ជាដើម ។ បទថា **អាជញ្ញោ** សេចក្ដីថា ឈ្មោះថា ជាតិអាជានេយ្យ ព្រោះដឹងហេតុ និងវត្ថុដែលមិនមែនជាហេតុ ។ សត្វអាជានេយ្យនោះមាន ៣ ប្រភេទ គឺគោអាជានេយ្យ ១ សេះអាជានេយ្យ ១ ដំរីអាជានេយ្យ ១ ។ ក្នុងអាជានេយ្យ ៣ នោះ គោអាជានេយ្យ លោកបំណងយកក្នុងគាថានេះ គោអាជានេយ្យនោះឯង ប្រកបហើយក្នុងកិច្ចរបស់អ្នកជំនាញក្នុងការភ្ជួរ ដោយហេតុនោះ ទើបលោក ពោលថា **ឧន្គលាវត្តនី** ដូច្នេះ អធិប្បាយថា អូសនង្គ័លទៅ ខាងនោះផង ខាងនេះផង ។ម្យ៉ាងទៀត ឈ្មោះថា **ឧន្គលាវត្តនី** ព្រោះអត្ថថា ជាទីញ៉ាំងនង្គ័លឲ្យវិលទៅ បានដល់ វិលទៅតាមស្នាមនង្គ័លក្នុងស្រែ ។ ក្នុងគាថានេះ លោកពោលជាទីឃៈថា **វត្តនី** ដើម្បីងាយស្រួលក្នុងការចងគាថា ។

បទថា **សិខី** សេចក្តីថា ឈ្មោះថា **សិខា** ព្រោះដូចគ្នានឹងសិរ ព្រោះនៅត្រង់ក្បាល បានដល់ **សិង្គ** គឺស្នែង ដោយកំណាត់យកក្នុងទីបំផុត បានដល់ **សិង្គ** គឺស្នែង ឈ្មោះថា **សិខី** ព្រោះមានស្នែងនោះ ។ អាចារ្យពួកខ្លះពោលថា កំពូល លោក ហៅថា **សិខា** ក្នុងគាថានេះ ។ បទថា **សិខី** នេះប្រាប់ភាពជាប្រធានទាំង ២ ពាក្យ ។ បទថា **អប្បកសិរេន** សេចក្តីថា ដោយលំបាកតិចតួច ។ បទថា **រត្តិន្ទិវា** បានដល់ ទាំងពេលយប់និងពេលថ្ងៃ ។ ប្រកបសេចក្តីថារមែងធ្លងយប់និងថ្ងៃនេះទៅដោយមិនលំបាកដូច្នោះ ។ លោកអធិប្បាយសេចក្តីដូច្នេះថា ប្រៀបដូចគោអាជានេយ្យ ដែលគេទឹមដោយនង្គ័លហើយមិនឃើញដល់ការនឿយហត់ ក្នុងគន្លងនង្គ័លដែលមានឫសស្មៅជាដើម ដើរអូសនង្គ័លទៅខាងនោះខ្លះ ខាងនេះខ្លះ រហូតស្មៅរាបទៅ យ៉ាងណា សូម្បីថ្ងៃនិងយប់ទាំងឡាយរមែងលះបង់ គឺកន្លងខ្ញុំទៅបានដោយមិនលំបាកដូច្នោះ ។ លោកពោលដល់ហេតុក្នុងសេចក្តីនោះថា **សុខេ លទ្ធេ និរាមិសេ** កាលបើនិរាមិសសុខដែលខ្ញុំបានហើយ ដូច្នេះ អធិប្បាយថា ព្រោះហេតុដែលខ្ញុំបានហើយនូវសេចក្តីសុខ គឺផលសមាបត្តិដែលស្ងប់ប្រណីតដែលមិនលាយដោយអាមិសគឺកាម អាមិសគឺលោក និងអាមិសគឺវដ្ដៈ ។ បទនេះជាសត្តមីវិភត្តិ ចុះក្នុងអត្ថនៃបឋមាវិភត្តិ ដូចក្នុងប្រយោគជាដើមថា **វនប្បគុម្ពេ** គឺគុម្ពឈើ **តេន វត រេ វត្តព្វ** គឺរឿងដទៃដែលគប្បីពោលមានទៀតដូច្នេះ ។ ម្យ៉ាងទៀត លោកពោលថា កាលបើនិរាមិសសុខដែលខ្ញុំបានហើយ បន្ទាប់អំពីការពិចារណាថា វេលាយប់នឹងថ្ងៃទាំងឡាយរបស់ខ្ញុំតែងប្រព្រឹត្តកន្លងទៅ

ដោយឥតលំបាក ក៏យ៉ាងនោះដែរ អធិប្បាយថា កាលសុខដែលប្រាសចាក អាមិសដែលខ្ញុំបានហើយមាន ចាប់តាំងពីពេលដែលខ្ញុំបាននិរាមិសសុខនោះ ដូច្នេះ ។

## អដ្ឋកថា ពេលដ្ឋសីសត្ថេរគាថា ចប់

## ទាសកត្ថេរគាថា

[ ១៨ ] បុគ្គលណាមានថីនមិទ្ធៈផង ជាអ្នកបរិភោគច្រើនផង ឈ្លោក ដេកផង ដេកប្រែប្រួលៗផង ដូចជ្រូកស្រុកធំដែលគេចិញ្ចឹមដោយចំណី ក្នុងកាលណា បុគ្គលនោះឈ្មោះថាល្ងង់ខ្លៅ តែងចូលទៅកាន់គភ៌រឿយៗ ក្នុងកាលនោះ ។

ទាសកត្ថេរ ។

## អដ្ឋកថា

## ទាសកត្ថេរគាថា

[ ១៨ ] គាថារបស់ព្រះទាសកត្ថេរ មានពាក្យផ្ដើមថា **មិទ្ធី យទា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងកប្បទី ៩១ អំពីភទ្ទកប្បនេះ កាលព្រះតថាគតមិនទាន់កើតឡើង កុលបុត្តនេះបានប្រគេនផ្លែស្វាយ ដែលគួរជាទីត្រេកអរនៃចិត្តដល់ព្រះបច្ចេកពុទ្ធ ព្រះនាមថា អជិតៈ ដែលចុះអំពីភ្នំគន្ធមាទន៍ មកកាន់ដែនដីមនុស្ស ហើយត្រាច់បិណ្ឌបាតក្នុងស្រុកមួយកន្លែង ដោយបុញ្ញកម្មនោះលោកអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ហើយបួសក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថា កស្សបៈ បានធ្វើបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកជាច្រើន ។

កុលបុត្តនេះខ្វល់ខ្វាយក្នុងកុសលកម្មយ៉ាងនេះ លះសុគតិចូលដល់សុ-

គតិ ក្នុងពុទ្ធុប្បាទនេះកើតក្នុងផ្ទះមានត្រកូលក្នុងនគរសាវត្ថី ។ អនាថបិណ្ឌិក-សេដ្ឋីតែងតាំងក្នុងនាទីជាអ្នកបដិបត្តិវិហារ បដិបត្តិវិហារដោយគោរព មានសទ្ធា បានឃើញព្រះពុទ្ធដោយការស្តាប់ធម៌រឿយៗ បួសហើយ អាចារ្យពួកខ្លះពោលថា ព្រះទាសកៈនេះកើតក្នុងផ្ទះមានត្រកូល ក្នុងកាលព្រះមានព្រះភាគព្រះនាមថា កស្សបៈ ចម្រើនវ័យហើយ ទំនុកបម្រុងព្រះថេរៈដែលជាព្រះខីណាស្រពមួយរូប មានបំណងឲ្យលោកជួយធ្វើកិច្ចទើបប្រើលោកដោយកម្មនោះ កុលបុត្តនោះកើតក្នុងផ្ទៃរបស់ទាសីនៃអនាថបិណ្ឌិកសេដ្ឋី ក្នុងនគរសាវត្ថីក្នុងកាលព្រះមានព្រះភាគនៃយើងទាំងឡាយ ចម្រើនវ័យហើយលោកសេដ្ឋីតែងតាំងទុកក្នុងតំណែងជាអ្នកសំអាតវិហារ ( វត្ត ) បានទូវសទ្ធា ដោយន័យដូចពោលនោះឯង ។ មហាសេដ្ឋី ជ្រាបសីលាចារវត្ត និងអធ្យាស្រ័យរបស់កុលបុត្តនោះហើយ ដោះលែងឲ្យជាអ្នកជា ប្រាប់ថាសូមអ្នកបួសតាមសប្បាយចុះ ភិក្ខុទាំងឡាយឲ្យកុលបុត្តនោះបព្វជ្ជាហើយ ។ ចាប់តាំងពីបួសហើយ កុលបុត្តនោះបែរជាខ្ជិលច្រអូស មិនមានសេចក្តីព្យាយាម មិនធ្វើវត្ត-បដិបត្តិណាមួយ មិនចាំបាច់ពោលដល់ការបំពេញសមណធម៌ឡើយ គិតតែបរិភោគពេញពោះ ច្រើនដោយការដេកតែម្យ៉ាង ។ ក្នុងពេលស្តាប់ធម៌ ចូលទៅត្រង់ជ្រុងខាងចុងបរិស័ទ ដេកលក់ស្រមុកឃូៗសព្វកាល ។ លំដាប់នោះព្រះមានព្រះភាគទ្រង់ប្រមើលមើលបុព្វនិស្ស័យរបស់លោក ដើម្បីឲ្យកើតការសង្វេគ ទើបត្រាស់គាថាថា

បុគ្គលណាមានថីនមិទ្ធៈផង ជាអ្នកបរិភោគច្រើនផង ល្មោក

ដេកផង ដេកប្រែប្រួលៗផង ដូចជ្រូកស្រុកធំដែលគេចិញ្ចឹម
ដោយចំណី ក្នុងកាលណា បុគ្គលនោះឈ្មោះថាល្ងង់ខ្លៅតែង
ចូលទៅកាន់គភ៌រឿយៗ ក្នុងកាលនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មិទ្ធី** សេចក្ដីថា ជាបុគ្គលដែលថីនមិទ្ធៈគ្រប
សង្កត់ហើយ អធិប្បាយថា មិទ្ធៈគ្របសង្កត់បុគ្គលណា ថីនៈក៏រមែងគ្រប
សង្កត់បុគ្គលនោះដូចគ្នា ។ បទថា **យទា** ប្រែថា ក្នុងកាលណា ។

បទថា **មហគ្ឃសោ** សេចក្ដីថា ជាអ្នកបរិភោគច្រើន ដូចអាហរហត្ថ-
ព្រាហ្មណ៍ អលង្សាដកព្រាហ្មណ៍ តត្ថវដ្ដកព្រាហ្មណ៍ កាកមាសកព្រាហ្មណ៍
ភុត្តវមិតកព្រាហ្មណ៍ណាមួយ ។ បទថា **និទ្ទាយិតា** បានដល់ ជាអ្នកដេក
លក់ ។ បទថា **សម្បរិវត្តសាយី** សេចក្ដីថា ដេកបម្រះនឿលទៅមក ។
ដោយបទទាំង ២ ទ្រង់សម្ដែងថា ប្រកបរឿយៗនូវសេចក្ដីសុខក្នុងការដេក
សេចក្ដីសុខក្នុងការទម្រេតខ្នងនិងសុខក្នុងការងងុយដេក ។ បទថា **និវាប-
បុដ្ឋោ** សេចក្ដីថា ដែលគេចិញ្ចឹម គឺទំនុកបម្រុងដោយសូករភត្ត មានកន្ទក់
ជាដើម អធិប្បាយថា ជ្រូកស្រុកដែលគេចិញ្ចឹមតាំងពីនៅតូច លុះមានរាង
កាយធំធាត់ មិនបានចេញក្រៅទ្រុង រមែងដេកនឿលទៅមកក្រោមគ្រែជា-
ដើមនោះឯង ។

លោកអធិប្បាយទុកដូច្នេះថា ក្នុងពេលណា បុរសជាបុគ្គលល្មោភដេក
និងល្មោភក្នុងអាហារ មិនអាចផ្លាស់ប្ដូរឥរិយាបថដទៃបាន ច្រើនដោយការ
ដេកលក់នឿលទៅមក ដូចជ្រូកធំដែលគេផ្គត់ផ្គង់ដោយចំណី ក្នុងកាលនោះ

បុរសនោះមិនអាចមនសិការត្រៃលក្ខណ៍ គឺអនិច្ចំ ទុក្ខំ អនត្តា ព្រោះមិនបាន មនសិការត្រៃលក្ខណ៍ទាំងនោះ ទើបមានបញ្ញាតិច រមែងចូលដល់គតិរឿយៗ ឬមិនផុតចាកទីលំនៅ គឺគតិបានឡើយ ។ ព្រះទាសកត្ថេរស្តាប់ ព្រះគាថានេះហើយ កើតនូវសេចក្តីសង្វេគ ផ្តើមតាំងវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអប-ទានថា

កាលនោះ ព្រះបច្ចេកសម្ពុទ្ធព្រះនាម អជិនៈ ទ្រង់បរិបូណ៌ ដោយចរណៈ ឈ្លាសវៃក្នុងសមាធិ ជាអ្នកប្រាជ្ញគង់នៅក្នុង ព្រៃហិមពាន្ត ។ ខ្ញុំបានយកផ្លែអញ្ជលិព្រឹក្សស្រស់ៗប្រមាណ ប៉ុនក្អម ទាំងយកឆត្រស្លឹកប្រគេនដល់ព្រះសាស្តា ។ ក្នុងកប្ប ទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុង កាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។ បេ ។ ទាំងសាសនា របស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយគិតថា ព្រះមានព្រះភាគទ្រង់ទូន្មានខ្ញុំដោយគាថានេះ ទើបគាថានេះហាក់ដូចជាកង្វេរសម្រាប់ខ្ញុំ ទើបពោលគាថា

---

១-ក្នុងអបទានជា អជ្ជេលផលទាយកត្ថេរ តែក្នុងអដ្ឋកថាមានសេចក្តីខុសប្លែកគ្នាបន្តិចបន្តួច គឺបានប្រគេនផ្លែស្វាយដល់ព្រះបច្ចេកពុទ្ធឈ្មោះ អជិតៈ... ក្នុងកប្បទី ៩១... ក្នុងទីនេះ យើងកាន់យកតាមបិដកខ្មែរ ។

នោះម្តងទៀត ។ ទើបគាថានេះជាការព្យាករអរហត្តផលរបស់លោក ដោយផ្ទាស់មកជាគាថារបស់ព្រះថេរៈ ។

## អដ្ឋកថា ទាសកត្ថេរគាថា ចប់

## សិង្គាលបិតាថេរគាថា

[ ១៩ ] ភិក្ខុជាអ្នកទទួលមត៌កៈរបស់ព្រះពុទ្ធ បានពិចារណានូវផែនដី គឺអត្តភាពនេះដោយសម្គាល់ថាជាពេញដោយឆ្អឹងទាំងអស់ ក្នុងភេសកឡាវ័ន ភិក្ខុនោះតែងលះបង់កាមរាគបានដោយឆាប់រហ័ស ទំនងដូចជាអាត្មាអញ ( នេះ ) ។

**សិង្គាលបិតាថេរ ។**

## អដ្ឋកថា

## សិង្គាលបិតាថេរគាថា

[ ១៩ ] គាថារបស់ព្រះសិង្គាលបិតាថេរ មានពាក្យផ្តើមថា **អហុ ពុទ្ធស្ស ទាយាទោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងកប្បទី ៩៤ រាប់ថយក្រោយអំពីភទ្ទកប្បនេះ កុលបុត្តនេះឃើញព្រះបច្ចេកពុទ្ធព្រះនាមថា សតរង្សី និមន្តបិណ្ឌបាត មានចិត្តជ្រះថ្លាថ្វាយបង្គំហើយ បានប្រគេនផ្លែត្នោតក្នុងដៃរបស់ខ្លួន ដោយបុញ្ញកម្មនោះ កុលបុត្តនោះ កើតក្នុងទេវលោក ធ្វើបុញ្ញកម្មតៗមក អន្ទោលទៅក្នុងសុគតិភពប៉ុណ្ណោះ ក្នុងកាលរបស់ព្រះមានព្រះភាគព្រះនាមថា កស្សបៈ កើតក្នុងកំណើតមនុស្ស បានជាអ្នកមានការជឿមាំក្នុងព្រះសាសនា បួសហើយចម្រើនអដ្ឋិកសញ្ញា ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទះមានត្រកូលក្នុងនគរសាវត្ថី ។ ចម្រើនវ័យហើយ រៀបអាពាហ៍ពិពាហ៍ បានកូនប្រុសម្នាក់ ដាក់ឈ្មោះកូនប្រុសនោះ

ថា សិង្គាល ដោយហេតុនោះ ទើបមនុស្សទាំងឡាយហៅគាត់ថា សិង្គាល-កបិតា ។ ក្នុងកាលតមក លះនូវការជាប់ជំពាក់ក្នុងផ្ទះហើយ បួសក្នុងព្រះសាសនា ព្រះមានព្រះភាគទ្រង់ប្រមើលមើលអជ្ឈាស្រ័យរបស់លោក បានប្រទានអដ្ឋិកសញ្ញាកម្មដ្ឋាន លោកទទួលកម្មដ្ឋាននោះហើយ អាស្រ័យនៅក្នុងព្រៃភេសកឡាវ័នត្រង់សុសុមារគិរនគរ ភគ្គជនបទ ។ លំដាប់នោះ ទេវតាដែលអាស្រ័យនៅក្នុងព្រៃនោះ ដើម្បីញុំាងឧស្សាហ៍ឲ្យកើតដល់លោក កាលប្រកាសសេចក្តីនេះថា លោកនឹងធ្វើផលនៃភាវនា គឺអរហត្តផលឲ្យនៅក្នុងកណ្តាប់ដៃ ក្នុងកាលមិនយូរឡើយដូច្នេះ ដោយអាងដល់អរហត្តផល ទើបពោលថា

ភិក្ខុជាអ្នកទទួលមត៌ក របស់ព្រះពុទ្ធ បានពិចារណានូវផែនដី
គឺអត្តភាពនេះ ដោយសម្គាល់ថាជាពាងឆ្អឹងទាំងអស់ក្នុងភេស-
កឡាវ័ន ភិក្ខុនោះ តែងលះបង់កាមរាគបានដោយឆាប់រហ័ស
ទំនងដូចជាអាត្មាអញ ( នេះ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អហុ** ស្មើគ្នានឹង **ហោតិ** ប្រែថា រមែងមាន ។ បទនេះជាពាក្យពោលដល់អតីតកាល តែប្រើក្នុងអត្ថបច្ចុប្បន្នកាល ។ បទថា **ពុទ្ធស្ស** បានដល់ ព្រះសព្វញ្ញុពុទ្ធ ។

បទថា **ទាយាទោ** សេចក្តីថា ជាធម្មទាយាទ គឺជាអ្នកកាន់យក គឺទទួលនូវទាយាទគឺលោកុត្តរធម៌ ៩ យ៉ាងដោយការបដិបត្តិប្រពៃរបស់ខ្លួន ។

ម្យ៉ាងទៀត បទថា **អហុ** ស្មើគ្នានឹង **អហោសិ** ប្រែថា បានកើតហើយ

អធិប្បាយថា ភិក្ខុរូបខ្លះ នឹងជាអ្នកទាក់ទងក្នុងកាពជាទាយាទរបស់ព្រះពុទ្ធ ដែលមានព្រះនាមយ៉ាងនេះ ក្នុងឥឡូវនេះឯង ។ ដោយហេតុនោះ ទើបទេវតាពោលថា ភិក្ខុនោះតែងលះបង់កាមរាគបាន ដោយឆាប់រហ័ស ដូច្នេះ ។

បទថា **ភេសកឡាវនេ** សេចក្ដីថា ក្នុងព្រៃដែលបានឈ្មោះថា ភេសកឡាវ័ន ព្រោះយក្ខឈ្មោះភេសកៈជាអ្នកហួងហែង គឺគ្រប់គ្រង ឬព្រោះច្រើនទៅដោយសត្វសាហាវ មានដំរីស្មោរជាដើមដែលគួរខ្លាច ។ ទេវតាកាលប្រាប់ហេតុជាទាយាទរបស់ព្រះពុទ្ធ ដល់ភិក្ខុនោះ ទើបពោលថា បានពិចារណានូវផែនដី គឺអត្តភាពនេះ ដោយសម្គាល់ថាជាពងឆ្អឹង ទាំងអស់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កេវលំ** ប្រែថា ទាំងអស់ គឺមិនមានចំណែកសេសសល់ ។ បទថា **អដ្ឋិសញ្ញាយ** បានដល់ ដោយការភាវនាថា ជាឆ្អឹង ។

បទថា **អផរិ** សេចក្ដីថា ផ្សាយទៅហើយ ដោយអំណាចការបង្អោនចិត្តថា ជាឆ្អឹង ។

បទថា **បឋវី** បានដល់ ដី គឺអត្តភាព អធិប្បាយថា អត្តភាព លោកហៅថា **បឋវី** ក្នុងគាថានេះ ដូចប្រយោគ ( ក្នុងធម្មបទ ) ជាដើមថា **កោឥមំ បឋវឹ វិចេស្សតិ** អ្នកណានឹងដឹងច្បាស់នូវផែនដីគឺអត្តភាពនេះ ដូច្នេះ ។ បទថា **មញ្ញេហំ** កាត់បទជា **មញ្ញេ អហំ** បាឋៈថា **មញ្ញាហំ** ដូច្នេះក៏មាន ។

បទថា **សោ** បានដល់ ភិក្ខុនោះ ។ ខ្ញុំយល់ថា លោកនឹងលះបង់ គឺ

លះកាមរាគៈបានដោយឆាប់រួសរាន់ គឺក្នុងកាលមិនយូរឡើយ ព្រោះហេតុអ្វី ព្រោះអដ្ឋិកសញ្ញា ជាបដិបក្ខដោយត្រង់ចំពោះកាមរាគៈ លោកពោលអធិប្បាយទុកដូច្នេះថា ភិក្ខុណាពិចារណាអត្តភាពរបស់ខ្លួន ឬរបស់សត្វទាំងពួងថាជារាងឆ្អឹង ដោយការសម្គាល់ថា ឆ្អឹង ដែលខ្លួនបានហើយក្នុងចំណែកមួយ ភិក្ខុនោះធ្វើឈានមានឆ្អឹងជាអារម្មណ៍នោះឲ្យជាបាទ ពិចារណា នឹងលះនូវកាមរាគៈបាន ដោយអនាគាមិមគ្គ ក្នុងកាលមិនយូរឡើយ ឬនឹងលះតណ្ហាទាំងអស់ដែលបានឈ្មោះថា កាម ព្រោះអត្ថថា ប្រាថ្នា បានឈ្មោះថា រាគៈ ព្រោះអត្ថថា ត្រេកអរ បានដោយមគ្គជាន់ខ្ពស់ ។

ព្រះថេរៈនោះស្តាប់គាថានោះហើយ គិតថា ទេវតានេះពោលយ៉ាងនេះ ដើម្បីញ៉ាំងឧស្សាហៈ ឲ្យកើតឡើងដល់អញ ដូច្នេះហើយ អធិដ្ឋានសេចក្តីព្យាយាមរុលទៅមុខ មិនថយក្រោយ ចម្រើនវិបស្សនា សម្រេចអរហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

> ព្រះមានព្រះភាគទ្រង់ព្រះនាម សតរង្សី ត្រាស់ដឹងដោយព្រះអង្គឯង ទ្រង់ឈ្នះមារ ក្រោកចេញចាកទីស្ងប់ស្ងាត់ ហើយស្តេចទៅដើម្បីគោចរ ។ ខ្ញុំមានដៃកាន់ផ្លែឈើឃើញព្រះនរាសភៈ ក៏ចូលទៅជិត ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយផ្លែត្នោត ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ

។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈសម្រេចអរហត្តហើយ កាន់យកពាក្យដែលទេវតាពោលហើយ បានពោលគាថានោះឯងបន្ទឹជាឧទាន ។ គាថានោះឯងបានជាការព្យាករអរហត្តផលរបស់ព្រះថេរៈនោះ ដូច្នេះ ។

## អដ្ឋកថា សិង្គាលបិតាថេរគាថា ចប់

១-ក្នុងអបទានជាព្រះ តាលផលិយត្ថេរ ។

## កុឡត្ថេរគាថា

[ ២០ ] ពួកជនអ្នកបង្ហូរទឹកតែងបង្ហូរទឹក ពួកអ្នកធ្វើព្រួញរមែងពត់ព្រួញ ពួកជាងចាំងរមែងចាំងឈើ ( យ៉ាងណាមិញ ) ពួកជនអ្នកមានវត្តល្អរមែងទូន្មានខ្លួនឲ្យត្រង់ ( ក៏យ៉ាងនោះដែរ ) ។

កុឡត្ថេរ ។

## អដ្ឋកថា

## កុឡត្ថេរគាថា

[ ២០ ] គាថារបស់ព្រះកុឡត្ថេរ មានពាក្យផ្ដើមថា **ឧទកំ ហិ នយន្តិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះថេរៈនេះ ក្នុងកាលមុន សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានដ៏ច្រើន ដល់ព្រមដោយអធិការ ឃើញព្រះមានព្រះភាគព្រះនាមជាវិបស្សីយាងទៅក្នុងអាកាស មានចិត្តជ្រះថ្លាហើយ ប្រាថ្នានឹងថ្វាយផ្លែដូងទើបឈរ ។

ព្រះបរមសាស្ដា ទ្រង់ជ្រាបវារៈចិត្តរបស់កុលបុត្តនោះហើយ ទ្រង់ចុះមកទទួលហើយ ។ កុលបុត្តនោះ មានចិត្តជ្រះថ្លា បាននូវសទ្ធា ទើបចូលទៅគាល់ព្រះសាស្ដាទូលសូមបព្វជ្ជាហើយ ។ ព្រះសាស្ដាត្រាស់នឹងភិក្ខុណាមួយរូបថា ចូរអ្នកឲ្យកុលបុត្តនេះបួស ។

កុលបុត្តនោះបព្វជ្ជាហើយ បានឧបសម្បទា បំពេញសមណធម៌ ចុតិ

អំពីកពនោះហើយ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយអស់ ៦ ពុទ្ធន្តរ ក្នុងពុទ្ធុប្បាទនេះ កុលបុត្តនេះកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងនគរសាវត្ថី មានឈ្មោះថា កុឡ: ។ កុលបុត្តនោះចម្រើនវ័យហើយ មានសេចក្តីជ្រះថ្លាក្នុងព្រះសាសនា បួសក្នុងសម្នាក់របស់ព្រះមានព្រះភាគ មិនអាចញ៉ាំងគុណវិសេសឲ្យកើតឡើងបាន ព្រោះជាអ្នកច្រើនដោយសេចក្តីរាយមាយ ។ ថ្ងៃមួយ ចូលទៅក្នុងស្រុកដើម្បីបិណ្ឌបាត ឃើញមនុស្សទាំងឡាយកំពុងជីកដីក្នុងរវាងផ្លូវ ធ្វើជាប្រឡាយបង្ហូរទឹកទៅកាន់ទីដែលខ្លួនប្រាថ្នា កំណត់ហេតុនោះទុកចូលកាន់ស្រុក ឃើញជាងព្រួញម្នាក់ ដាក់ព្រួញចូលទៅក្នុងឃ្នាបសម្រាប់ពត់ សម្លឹងដោយកន្ទុយភ្នែក ហើយពត់ឲ្យត្រង់ ទើបកំណត់ហេតុនោះទុក និមន្តទៅទៀត ឃើញជាងចាំងឈើ កំពុងចាំងកង់រថ មានកាំខ្នងកង់និងដុំជាដើម កំណត់ហេតុនោះទុក ចូលទៅកាន់វិហារ ធ្វើកត្តកិច្ចហើយ ទុកបាត្រនិងចីវរ អង្គុយក្នុងទីសម្រាប់សម្រាកក្នុងវេលាថ្ងៃ កាន់យកនិមិត្ត ដែលខ្លួនឃើញហើយជាឧបមា បង្អោនចូលទៅក្នុងការបង្វឹកចិត្តរបស់ខ្លួនហើយគិតថា ពួកមនុស្សនាំយកទឹកដែលមិនមានចិត្តទៅកាន់ទីដែលខ្លួនប្រាថ្នា ជាងព្រួញក៏ដូចគ្នា ពត់ព្រួញដែលប្រាសចាកចិត្ត សូម្បីកោងឲ្យត្រង់បានដោយឧបាយ ជាងឈើក៏ដូចគ្នា រមែងធ្វើឈើដែលកោង មានកំណាត់ឈើជាដើម ដែលមិនមានចេតនា ឲ្យត្រង់ ដោយធ្វើជាកង់ជាដើម កាលបើដូច្នោះ ហេតុអ្វី អាត្មាអញមិនធ្វើចិត្តឲ្យត្រង់ ដូច្នេះហើយ ផ្តើមតាំងវិបស្សនា ព្យាយាមសម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោក

ចងទុកក្នុងអបទានថា

កាលនោះខ្ញុំជាញោមវត្ត ក្នុងនគរពន្ធុមតី បានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលី កំពុងស្តេចទៅឰដ៏អាកាស ។ ខ្ញុំបាន យកផ្លែដូង ទៅថ្វាយដល់ព្រះពុទ្ធដ៏ប្រសើរ ព្រះពុទ្ធទ្រង់មាន យសធំឋិតនៅឰដ៏អាកាសទ្រង់ទទួល ( ផ្លែដូងនោះ ) ។ ខ្ញុំ មានការកើតបីតិជាទីនាំមកនូវសេចក្តីសុខក្នុងបច្ចុប្បន្ន ព្រោះ ថ្វាយនូវផ្លែដូងដល់ព្រះពុទ្ធដោយចិត្តជ្រះថ្លា ។ កាលនោះ ខ្ញុំ បាននូវបីតិ ដ៏ធំទូលាយផង នូវសេចក្តីសុខដ៏ឧត្តមផង រតនៈ តែងកើតឡើងដល់ខ្ញុំ ដែលកើតក្នុងភពនោះៗ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ចក្ខុរបស់ ខ្ញុំដ៏បរិសុទ្ធដូចជាទិព្វ ខ្ញុំជាអ្នកឈ្លាសវៃក្នុងសមាធិ ដល់នូវ អភិញ្ញាបារមី នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏ បានប្រតិបត្តិហើយ ដូច្នេះ[១] ។

លោកធ្វើនិមិត្តពួកណា ឲ្យដូចជាកង្វេរ ចម្រើនវិបស្សនា សម្រេចអរហត្តហើយយ៉ាងនេះ លោកប្រៀបធៀបការទូន្មានចិត្តរបស់ខ្លួននិងនិមិត្តទាំងនោះហើយ កាលនឹងព្យាករអរហត្តផល បានភាសិតគាថានេះថា

---

១-ក្នុងអបទានជាព្រះ នាឡិកេរផលទាយកត្ថេរ ។

ពួកជនអ្នកបង្ហូរទឹក តែងបង្ហូរទឹក ពួកអ្នកធ្វើព្រួញ រមែងពត់
ព្រួញ ពួកជាងចាំង រមែងចាំងឈើ ( យ៉ាងណាមិញ )
ពួកជនអ្នកមានវត្តល្អ រមែងទូន្មានខ្លួនឲ្យត្រង់ ( ក៏យ៉ាងនោះ
ដែរ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ **ហិ** សព្ទ ក្នុងបទថា **ឧទកំ ហិ** ត្រឹមតែជានិបាត ។ បទថា **នយន្តិ** សេចក្ដីថា បុគ្គលណាបង្ហូរទឹកជីកផែនដីក្នុងទីទួលនោះហើយ បំពេញទីទំនាបធ្វើប្រឡាយ ឬដាក់ទរធ្វើអំពីឈើរមែងនាំ ទឹកទៅកាន់ទីដែលខ្លួនប្រាថ្នា ។ ឈ្មោះថា អ្នកបង្ហូរទឹក ព្រោះនាំទឹកទៅ ដោយអាការយ៉ាងនោះ ។

បទថា **តេជនំ** ស្មើគ្នានឹង **កណ្ឌំ** ប្រែថា ព្រួញ លោកពោលអធិប្បាយ ដូច្នេះថា ពួកជនអ្នកបង្ហូរទឹក ក៏បង្ហូរទឹកទៅកាន់ទីដែលខ្លួនប្រាថ្នា តាមគាប់ចិត្តរបស់ខ្លួន សូម្បីពួកជាងព្រួញ ក៏រោលឈើពត់ព្រួញ ធ្វើឲ្យត្រង់ ជាងឈើកាលចាំងឈើដើម្បីប្រយោជន៍ដល់ដុំជាដើម ដោយការចាំង ឈ្មោះថា រមែងចាំងឈើ គឺធ្វើឲ្យត្រង់ ឬធ្វើឲ្យកោងតាមគាប់ចិត្តរបស់ខ្លួន បណ្ឌិតទាំងឡាយដែលជាអ្នកមានវត្តល្អ មានវត្តប្រពៃ ដោយសីលជាដើម តាមដែលសមាទានហើយ ធ្វើហេតុដែលមានប្រមាណប៉ុណ្ណោះ ឲ្យជាអារម្មណ៍ យ៉ាងនេះ កាលញ៉ាំងនូវសោតាបត្តិមគ្គជាដើមឲ្យកើតឡើង ឈ្មោះថា រមែងទូន្មានខ្លួន កាលបានសម្រេចអរហត្តហើយរមែងឈ្មោះថាជាអ្នកទូន្មានខ្លួនបានដ៏កំពូល ដូច្នេះ ។

**អដ្ឋកថា កុឡត្ថេរគាថា ចប់**

## អជិតត្ថេរគាថា

[ ២១ ] ខ្ញុំមិនមានមរណៈភ័យទេ សេចក្តីអាល័យក្នុងជីវិតក៏មិនមាន ខ្ញុំជាអ្នកនឹករឭកជាប់ ដឹងខ្លួនសព្វគ្រប់ នឹងដាក់ចោលរាងកាយបាន ។

**អជិតត្ថេរ ។**

### ឧទាន

និយាយអំពីចូឡវច្ឆត្ថេរ ១ មហាវច្ឆត្ថេរ ១ វនវច្ឆត្ថេរ ១ សីវកសាមណេរ ១ កុណ្ឌធានត្ថេរ ១ ពេលដ្ឋសីសត្ថេរ ១ ទាសកត្ថេរ ១ លំដាប់អំពីនោះទៅមុខទៀត គឺសិង្គាលបិតិកត្ថេរ ១ កុឡត្ថេរ ១ អជិតត្ថេរ ១ រួមជា ១០ ។

**ចប់ ទុតិយវគ្គ ។**

## អដ្ឋកថា

## អជិតត្ថេរគាថា

[ ២១ ] គាថារបស់ព្រះអជិតត្ថេរ មានពាក្យផ្តើមថា **មរណេ មេ ភយំ នត្ថិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងកប្បទី ៩១ កុលបុត្តនេះ ឃើញព្រះមានព្រះភាគព្រះនាមជាវិបស្សី មានចិត្តជ្រះថ្លា បានថ្វាយផ្លែខ្វិត ។ ខាងមុខអំពីនោះ ក៏បានធ្វើបុណ្យនោះៗ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងកប្បនេះ កាលព្រះមានព្រះភាគនៃយើងទាំងឡាយ មិនទាន់កើតឡើង បានកើតជាបុត្ត

របស់អគ្គាសនីយព្រាហ្មណ៍របស់ព្រះមហាកោសល ក្នុងនគរសាវត្ថី កុលបុត្ត នោះមានឈ្មោះថាអជិតៈ ។

ក្នុងសម័យនោះ ពាវរីព្រាហ្មណ៍មានប្រក្រតីនៅក្នុងនគរសាវត្ថី ជាអ្នកប្រកបទៅដោយមហាបុរិសលក្ខណៈ ៣ ប្រការ ចេះចប់ត្រៃវេទ ចេញអំពីនគរសាវត្ថី ហើយបួសជាតាបស អាស្រ័យនៅក្នុងកបិដ្ឋារាម គឺព្រៃខិតត្រង់ច្នេរស្ទឹងគោធាវរី ។

កាលនោះ អជិតមាណព បួសក្នុងសម្នាក់របស់អាចារ្យពាវរីព្រាហ្មណ៍នោះ ។ កាលទេវតាដែលប្រាថ្នាប្រយោជន៍ជាស់តឿនហើយ ត្រូវបញ្ជូនទៅកាន់សម្នាក់របស់ព្រះបរមសាស្ដា ចូលទៅគាល់ព្រះមានព្រះភាគ មួយអន្លើដោយមាណពទាំងឡាយ មានតិស្សមេត្តេយ្យមាណពជាដើម ទូលសួរបញ្ហាទាំងឡាយដោយចិត្តតែម្យ៉ាង កាលបញ្ហានោះដែលព្រះមានព្រះភាគទ្រង់បានវិសជ្ជនាហើយ មានចិត្តជ្រះថ្លា បួសក្នុងសម្នាក់របស់ព្រះបរមសាស្ដា រៀនកម្មដ្ឋានហើយ ចម្រើនវិបស្សនា សម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស គួរទទួល
គ្រឿងបូជា កំពុងស្ដេចទៅតាមច្រក ហើយថ្វាយផ្លែកុិដ្ឋ ។
ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ
ឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផល
ទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំង

សាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

លោកសម្រេចអរហត្តហើយ កាលបន្លឺសីហនាទ ទើបភាសិតគាថាថា

ខ្ញុំមិនមានមរណៈភ័យទេ សេចក្តីអាល័យក្នុងជីវិតក៏មិនមាន
ខ្ញុំជាអ្នកនឹករឭកជាប់ ដឹងខ្លួនសព្វគ្រប់នឹងដាក់ចោលរាងកាយ
បាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មរណេ** បានដល់ មរណនិមិត្ត គឺហេតុនៃសេចក្តីស្លាប់ ។

បទថា **មេ** ប្រែថា ដល់ខ្ញុំ គឺភ័យមិនមានដល់ខ្ញុំ ព្រោះជាបុគ្គលមានជាតិអស់ហើយ ដោយឫសគល់នៃកពខ្ញុំដកបានហើយ អធិប្បាយថា សម្រាប់បុគ្គលដែលមិនទាន់ដកកពនេះបាន គប្បីខ្លាច[illegible]សេចក្តីស្លាប់ព្រោះគិតថា ការកើតរបស់អញដូចម្តេចហ្ន៎ ដូច្នេះ ។

បទថា **និកន្តិ** បានដល់ ការសង្ឃឹម គឺតណ្ហា ការសង្ឃឹមក្នុងជីវិតឈ្មោះថាមិនមានព្រោះចូលទៅប្រាកដដោយល្អក្នុងភាពដែលឧបាទានក្ខន្ធទាំងឡាយជាទុក្ខនិងមិនមានសារៈ ព្រោះភាពដែលសង្ខារត្រូវពិចារណា ញាំញីមកហើយយ៉ាងល្អ ខ្ញុំជាបុគ្គលកើតហើយយ៉ាងនេះ នឹងលះបង់គឺនឹងបោះបង់នូវរាងកាយរបស់ខ្លួន គឺសរីរៈ ឬសរីរៈរបស់ខ្លួនដែលបានឈ្មោះថា ជាភារៈគឺទុក្ខ និងកាលបោះបង់ចោល ក៏គិតថា កិច្ចដែលគប្បីញ៉ាំងប្រយោជន៍ឲ្យសម្រេចដោយរាងកាយនេះ អញឲ្យសម្រេចហើយ ឥឡូវនេះ រាងកាយនោះ

---

១- ក្នុងអបទានជាព្រះ កបិដ្ឋផលទាយកត្ថេរ ។

អញគួរបោះបង់ចោលទៅដោយពិត ឈ្មោះថា **សម្បជានោ** ព្រោះដល់នូវការបរិបូណ៌ដោយបញ្ញា ឈ្មោះថា **បតិស្សតោ** ព្រោះដល់នូវការបរិបូណ៌ដោយសតិនឹងបោះបង់ទៅ ព្រះថេរៈកាលពោលគាថានេះហើយ ចូលឈានបរិនិព្វានហើយក្នុងចន្លោះឯង ដូច្នេះ ។

## អដ្ឋកថា អជិតត្ថេរគាថា ចប់

## វគ្គទី ២ ចប់

# ថេរគាថា ឯកនិបាត

# តតិយវគ្គ

## និគ្រោធត្ថេរគាថា

[ ២២ ] ខ្ញុំមិនខ្លាចមរណៈភ័យទេ ព្រះសាស្តាចារ្យ របស់យើងទាំងឡាយ ទ្រង់ឈ្លាសវៃ ក្នុងព្រះនិព្វាន ឈ្មោះអមតៈ ភ័យមិនឋិតនៅក្នុងព្រះនិព្វានណា ភិក្ខុទាំងឡាយ តែងដល់ ( នូវព្រះនិព្វាននោះ ) ដោយមគ្គនោះ ។

និគ្រោធត្ថេរ ។

# វគ្គទី ៣

## អដ្ឋកថា និគ្រោធត្ថេរគាថា

[ ២២ ] គាថារបស់ព្រះនិគ្រោធត្ថេរ មានពាក្យផ្ដើមថា **នាហំ ភយស្ស ភាយាមិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងកប្បទី ១៨០០ រាប់អំពីភទ្ទកប្បនេះ កុលបុត្តនេះកើតក្នុងត្រកូលព្រាហ្មណមហាសាល ចម្រើនវ័យហើយ ឃើញទោសក្នុងកាមទាំងឡាយនិងអានិសង្សនៃការបួស លះវត្ថុដែលជាប់ជំពាក់ក្នុងផ្ទះ ចូលទៅកាន់ដងព្រៃ ធ្វើបណ្ណសាលា ត្រង់ព្រៃសាលព្រឹក្ស បួសជាតាបស មានមូលផលាផលក្នុងព្រៃជាអាហារ ។

សម័យនោះ ព្រះសម្មាសម្ពុទ្ធព្រះនាមថា បិយទស្សី ទ្រង់កើតឡើងហើយក្នុងលោក ទ្រង់ញ៉ាំងការក្ដៅក្រហាយ គឺកិលេសរបស់សត្វលោក ព្រម

ទាំងទេវលោកឲ្យស្ងប់រម្ងាប់បាន ដោយអំណាចនៃទឹកអម្រឹត គឺព្រះធម៌ ថ្ងៃមួយ ដោយមានពុទ្ធបំណងទ្រង់អនុគ្រោះតាបស ទើបយាងទៅកាន់ព្រៃរាំងនោះ គង់ហើយ ចូលនិរោធសមាបត្តិ តាបសដើរទៅរកមូលផលាផលក្នុងព្រៃ ឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា នាំយកមែករាំង ដែលមានផ្ការីកស្គុះស្គាយ ធ្វើជាបារាំមែកឈើ គ្របបារាំនោះដោយផ្ការាំងសុទ្ធៗ ថ្វាយបង្គំព្រះមានព្រះភាគ មិនចេញទៅរកផ្លែឈើឡើយ ឈរនមស្ការដោយអំណាចនៃបីតិនិងសោមនស្សនោះឯង ព្រះសាស្តាទ្រង់ចេញអំពីនិរោធសមាបត្តិហើយ ដើម្បីអនុគ្រោះតាបសនោះ ទើបទ្រង់ព្រះតម្រិះថា ភិក្ខុសង្ឃចូរមកដោយពុទ្ធបំណងថា តាបសនឹងញុំាងចិត្តឲ្យជ្រះថ្លា ក្នុងភិក្ខុសង្ឃដូច្នេះ ភិក្ខុសង្ឃមកហើយក្នុងរំពេចនោះឯង តាបសឃើញភិក្ខុសង្ឃហើយ មានចិត្តជ្រះថ្លា ថ្វាយបង្គំហើយ ឈរផ្គងអញ្ជលី ។

ព្រះសាស្តា កាលទ្រង់ប្រកាសសម្បត្តិ ដែលជាចំណែកនៃផលបុណ្យរបស់តាបសនោះ ដោយការអាងដល់ការធ្វើការញញឹមឲ្យប្រាកដទ្រង់សម្តែងធម៌ហើយចៀសចេញទៅ មួយអន្លើដោយភិក្ខុសង្ឃ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានដ៏ច្រើនក្នុងពុទ្ធុប្បាទនេះកើតក្នុងត្រកូលព្រាហ្មណ-មហាសាល ក្នុងនគរសាវត្ថីមានឈ្មោះថា និគ្រោធ ។ កុលបុត្តនោះជ្រះថ្លាដោយការឃើញពុទ្ធានុភាព ក្នុងថ្ងៃដែលទ្រង់ទទួលព្រះវិហារជេតពន បួសហើយប្រារព្ធវិបស្សនា ជាអ្នកមានអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ សម

ដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

អាស្រមដ៏ល្អរបស់ខ្ញុំ គេធ្វើលយចូលទៅក្នុងព្រៃពាំងសឹងដេរជាសដោយផ្កាពាំង កាលនោះខ្ញុំនៅក្នុងព្រៃ ។ ព្រះសម្ពុទ្ធមានព្រះភាគព្រះនាមបិយទស្សី ជាព្រះសយម្ភូ ជាអគ្គបុគ្គលទ្រង់ប្រាថ្នាវិវេក បានស្តេចចូលទៅក្នុងព្រៃពាំង ។ ខ្ញុំបានចេញអំពីអាស្រមទៅក្នុងព្រៃ ក្នុងកាលនោះ ខ្ញុំកាលនឹងស្វែងរកនូវមើមឈើនិងផ្លែឈើ បានត្រាច់ទៅក្នុងព្រៃ ។ ខ្ញុំបានឃើញនូវព្រះសម្ពុទ្ធ ព្រះនាមបិយទស្សីមានយសធំ ព្រះអង្គគង់ចូលនិរោធសមាបត្តិដ៏រុងរឿងក្នុងព្រៃធំនោះ ។ ខ្ញុំបានតម្កល់ទុកនូវឈើ ៤ កំណាត់ពីខាងលើនៃព្រះសម្ពុទ្ធ ហើយធ្វើមណ្ឌបយ៉ាងល្អប្រក់ដោយផ្កាពាំងទាំងឡាយ ។ ខ្ញុំបានទ្រទ្រង់នូវមណ្ឌបដែលប្រក់ដោយផ្កាពាំងអស់ ៧ ថ្ងៃ ហើយញុំាងចិត្តឲ្យជ្រះថ្លាក្នុងមណ្ឌបនោះ ទាំងបានថ្វាយបង្គំនូវព្រះពុទ្ធដ៏ប្រសើរ ។ សម័យនោះព្រះមានព្រះភាគ ជាបុរសដ៏ឧត្តម បានចេញអំពីសមាធិហើយគង់សម្លឹងមើលទីអំពីចម្ងាយប្រមាណមួយជួរនឹម ។ សាវ័កឈ្មោះវរុណៈរបស់ព្រះសាស្តាព្រះនាមបិយទស្សី បានចូលទៅគាល់ព្រះលោកនាយក ជាមួយនឹងពួកព្រះអរហន្តមួយសែនអង្គ ជាអ្នកស្ទាត់ជំនាញ ។ ឯព្រះជិនស្រីមានព្រះភាគព្រះនាមបិយទស្សី ជាធំក្នុងលោក ប្រសើរជាងនរៈ គង់ក្នុង

កណ្តាលភិក្ខុសង្ឃហើយទ្រទ្រង់ធ្វើនូវការញញឹមឲ្យប្រាកដ ។ ឧបដ្ឋាកឈ្មោះអនុរុទ្ធៈរបស់ព្រះសាស្តាព្រះនាមបិយទស្សី ធ្វើចីវរឆៀងស្មាម្ខាង ហើយទូលសួរព្រះមហាមុនីថា បពិត្រព្រះមានព្រះភាគ សភាវៈដូចម្តេចហ្ន៎ ជាហេតុនៃព្រះសាស្តាទ្រង់ធ្វើនូវការញញឹម ប្រហែលជាមានហេតុ បានជាព្រះសាស្តាទ្រង់ធ្វើនូវការញញឹម ។

មាណពណាទ្រទ្រង់នូវមណ្ឌបដែលប្រក់ហើយដោយផ្កាកំរង ដល់តថាគតអស់ ៧ ថ្ងៃ តថាគតរឭកឃើញកុសលកម្មរបស់មាណពនោះ ទើបធ្វើនូវការញញឹមឲ្យប្រាកដ ។ បុណ្យណាឲ្យផលក្នុងទេវលោក ឬក្នុងមនុស្សលោក ឬឱកាសណាមិនសមល្មម តថាគតមិនឃើញនូវបុណ្យ ឬឱកាសនោះដែលមិនមានឱកាសឲ្យផលនោះឡើយ ។ កាលបុគ្គលនោះប្រកបដោយបុញ្ញកម្មហើយនៅក្នុងទេវលោកបរិស័ទទាំងប៉ុន្មានរបស់បុគ្គលនោះ សឹងជេរជាសដូចជាផ្កាកំរង ។ បុគ្គលប្រកបដោយបុញ្ញកម្មនោះ នឹងត្រេកត្រអាលដោយពួករបាំ ពួកចម្រៀង ពួកដេញដំប្រគំដ៏ជាទិព្វក្នុងទេវលោកសព្វៗកាល ។ បរិស័ទទាំងប៉ុន្មានរបស់បុគ្គលនោះ សឹងមានក្លិនក្រអូប ទាំងមានភ្លៀងជាវិការៈនៃផ្កាកំរងនឹងធ្លាក់ចុះក្នុងខណៈនោះឯង ។ លុះបុគ្គលនេះច្យុតអំពីទេវលោកនោះ មកកើតជាមនុស្សនឹងមកកាន់ត្រកូល

មនុស្ស មណ្ឌបប្រក់ដោយផ្កាពាំងក្នុងមនុស្សលោកនេះ នឹងទ្រទ្រង់ ( នូវបុគ្គលនេះ ) សព្វៗកាល ។ របាំក្តី ចម្រៀងក្តី គ្រឿងដេញដំប្រគំក្តី នឹងចោមរោមនូវបុគ្គលនេះអស់កាលជានិច្ចក្នុងមនុស្សលោកនេះ នេះជាផលនៃពុទ្ធបូជា ។ មួយទៀត កាលព្រះអាទិត្យរះឡើង ភ្លៀងជាវិការៈនៃផ្កាពាំង នឹងធ្លាក់ចុះមក ឯភ្លៀងជាវិការៈនៃផ្កាពាំងដ៏ប្រកបដោយបុញ្ញកម្ម នឹងធ្លាក់ចុះមកសព្វៗកាល ។ ក្នុងកប្បទី ១.៨០០ ព្រះសាស្តាព្រះនាមគោតម ទ្រង់កើតក្នុងត្រកូលឱក្កាករាជ នឹងត្រាស់ដឹងក្នុងលោក ។ កុលបុត្តនេះនឹងបានជាឱរសដែលព្រះធម៌និម្មិត ជាអ្នកទទួលនូវមត៌កក្នុងធម៌របស់ព្រះគោតមនោះកំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈនឹងបរិនិព្វាន ។ កាលកុលបុត្តនោះត្រាស់ដឹងនូវធម៌ នឹងមានមណ្ឌបប្រក់ដោយផ្កាពាំង កាលគេកំពុងបូជាលើជើងថ្ករ នឹងមានមណ្ឌប ប្រក់ដោយផ្កាពាំងក្នុងទីនោះ ។ លុះព្រះមហាមុនីព្រះនាមបិយទស្សីទ្រង់ប្រកាសនូវវិបាករួចហើយ ទើបសម្តែងនូវព្រះធម៌ ដល់បរិស័ទ ទ្រង់ញុំាងបរិស័ទឲ្យឆ្អែតដោយភ្លៀង គឺព្រះធម៌ ។

ខ្ញុំបានសោយរាជ្យ ជាស្តេចទេវតាក្នុងទេវលោកអស់ ៣០ កប្ប បានជាស្តេចចក្រពត្តិអស់ ៦៧ ដង ។ លុះខ្ញុំច្យុតចាកទេវលោកមកកើតក្នុងមនុស្សលោកនេះ ក៏បាននូវសេចក្តីសុខ

ដ៏ធំទូលាយ មានទាំងមណ្ឌបដែលប្រក់ទៅដោយផ្កាពាំង នេះឯងជាផលនៃមណ្ឌប ។ នេះរាងកាយជាទីបំផុត ភពជាទីបំផុតរបស់ខ្ញុំកំពុងប្រព្រឹត្តទៅ មណ្ឌបប្រក់ដោយផ្កាពាំង តែងមានសព្វៗកាលក្នុងមនុស្សលោកនេះ ។ ខ្ញុំបានញុំាំងព្រះមហាមុនីព្រះនាមគោតម ព្រះអង្គប្រសើរក្នុងពួកសក្យៈ ឲ្យត្រេកអរហើយ បានដល់នូវអចលដ្ឋាន គឺព្រះនិព្វាន ខ្ញុំលះបង់នូវការឈ្នះនិងការចាញ់អស់ហើយ ។ ក្នុងកប្បទី ១.៨០០ ព្រោះហេតុដែលខ្ញុំបានបូជានូវព្រះពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលលោកបានអភិញ្ញា ៦ យ៉ាងនេះហើយ ញុំាំងយប់និងថ្ងៃឲ្យកន្លងទៅដោយផលសុខ ដើម្បីប្រកាសភាពដែលព្រះសាសនា ជានិយ្យានិកធម៌ ដោយជាការព្យាករអរហត្តផល ទើបភាសិតគាថាថា

ខ្ញុំមិនខ្លាចមរណៈភ័យទេ ព្រះសាស្តាចារ្យ របស់យើងទាំងឡាយទ្រង់ឈ្លាសវៃក្នុងព្រះនិព្វាន ឈ្មោះអមតៈ ភ័យមិនបិតនៅក្នុងព្រះនិព្វានណា ភិក្ខុទាំងឡាយតែងដល់ ( នូវព្រះនិព្វាននោះ ) ដោយមគ្គនោះ ដូច្នេះ ។

---

១-ក្នុងអបទានជាព្រះ សាលមណ្ឌបិយត្ថេរ

ក្នុងគាថានោះ ដែលឈ្មោះថា **ភយំ** ព្រោះជាដែននៃសេចក្ដីខ្លាច បាន ដល់ជាតិ និងជរាជាដើម ។ បទថា **ភយស្ស** ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃ បញ្ចមីវិភត្តិ អធិប្បាយថា ខ្ញុំមិនខ្លាចអំពីភ័យមានវត្ថុដែលគប្បីខ្លាចជានិមិត្ត គឺមានជាតិជរានិងមរណៈជាដើមជាហេតុ ។ ព្រះថេរៈពោលដល់ហេតុក្នុងគា ថានោះថា **សត្ថា នោ អមតស្ស កោវិទោ** ប្រែថា ព្រះសាស្ដាចារ្យ របស់យើងទាំងឡាយ ទ្រង់ឈ្លាសវៃក្នុងព្រះនិព្វានឈ្មោះអមតៈ គឺព្រះសា- ស្ដារបស់ពួកយើងទាំងឡាយ ជាអ្នកឈ្លាសក្នុងអមតធម៌ បានដល់ ឈ្លាស ក្នុងការឲ្យធម៌ដែលជាអមតៈដល់វេនេយ្យសត្វទាំងឡាយ ។ បទថា **យត្ថ ភយំ នាវតិដ្ឋតិ** សេចក្ដីថា ភ័យតាមដែលពោលហើយ រមែងមិនតាំងនៅ គឺមិនបានឱកាសក្នុងព្រះនិព្វានណា ។

បទថា **តេន** បានដល់ ដោយព្រះនិព្វាននោះ ។ បទថា **វជន្តិ** សេច- ក្ដីថា រមែងទៅកាន់ទីដែលមិនមានភ័យនោះឯង អធិប្បាយថា ព្រះនិព្វាន ឈ្មោះថា ទីដែលមិនមានភ័យ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះថេរៈពោល ថា **វជន្តិ** ប្រែថា តែងដល់ ឆ្លើយថា ព្រោះថា ភិក្ខុទាំងឡាយ រមែងទៅដោយ ផ្លូវនោះ អធិប្បាយថា ភិក្ខុទាំងឡាយ គឺជាអ្នកឃើញភ័យក្នុងសង្សារដែល ធ្វើតាមឱវាទរបស់ព្រះបរមសាស្ដារមែងទៅតាមផ្លូវអរិយមគ្គមានអង្គ ៨ ។

ម្យ៉ាងទៀត បទថា **យត្ថ** សេចក្ដីថា ភ័យទាំង ២៥ យ៉ាង មានការ ចូលទៅតិះដៀលខ្លួនឯងជាដើម រមែងមិនតាំងចុះ គឺមិនបានជាទីពឹងពំនាក់ ព្រោះការសម្រេចនូវនិមិត្តណា គឺអរិយមគ្គណា ភិក្ខុក្នុងសាសនារបស់ព្រះ

សាស្តា រមែងទៅកាន់ទីដែលមិនមានភ័យដោយអរិយមគ្គនោះ សូម្បីខ្ញុំក៏ទៅផ្លូវនោះ ។ ព្រោះហេតុនោះ ទើបព្រះថេរៈព្យាករអរហត្តថា ខ្ញុំមិនខ្លាចមរណភ័យទេ ដូច្នេះ ។

## អដ្ឋកថា និគ្រោធត្ថេរគាថា ចប់

## ចិត្តកត្ថេរគាថា

[ ២៣ ] ពួកសត្វក្ងោក ជាសត្វមានសម្បុរខៀវ មានកល្អ មានសិរ្ស៍ តែងយំក្នុងព្រៃឈ្មោះការវី ក្ងោកទាំងនោះ លុះត្រូវខ្យល់ត្រជាក់បក់មកតែង ញុំាងបុគ្គលដែលដេកលក់និងបុគ្គលអ្នកមានឈានឲ្យភ្ញាក់ឡើង ។

**ចិត្តកត្ថេរ ។**

---

## អដ្ឋកថា

## ចិត្តកត្ថេរគាថា

[ ២៣ ] គាថារបស់ព្រះចិត្តកត្ថេរ មានពាក្យផ្ដើមថា **នីលា សុគីវា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា លោកសន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ចាប់តាំងពីកាលសាសនារបស់ព្រះមានព្រះភាគព្រះនាមថា បទុមុត្តរៈ ក្នុងកប្បទី ៩១ រាប់អំពីកប្បនេះ កើតក្នុងកំណើតមនុស្ស ដឹងក្ដីហើយ ឃើញព្រះមានព្រះភាគព្រះនាមថាវិបស្សី មានចិត្តជ្រះថ្លាហើយ ធ្វើនូវការបូជាដោយផ្កា ថ្វាយបង្គំហើយ បង្អោនចិត្តជឿក្នុងព្រះបរមសាស្ដានិងក្នុងព្រះនិព្វានថា ឈ្មោះថាធម៌ដែលស្ងប់រម្ងាប់ហើយ គប្បីមានក្នុងព្រះសាសនានេះ ដូច្នេះ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះចុតិអំពីនោះហើយ កើតក្នុងស្ថានតាវត្តិង្ស ខ្ពីឃ្មាតក្នុងបុញ្ញកម្មរឿយៗអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តរបស់ព្រាហ្មណ៍ដែលសម្បូរដោយសម្បត្តិ ក្នុងនគររាជគ្រឹះ

មានឈ្មោះថា ចិត្តកៈ កាលព្រះមានព្រះភាគយាងដល់នគររាជគ្រឹះ គង់នៅក្នុងវេឡុវនវិហារ ចូលទៅគាល់ព្រះមានព្រះភាគ ស្តាប់ធម៌ហើយ បាននូវសទ្ធា បព្វជ្ជាហើយ រៀនកម្មដ្ឋានដែលសមគួរដល់ចរិត ចូលទៅកាន់ព្រៃព្យាយាមចម្រើនភាវនា ធ្វើឈានឲ្យកើត ចម្រើនវិបស្សនាមានឈានជាបាទសម្រេចអរហត្តដោយកាលមិនយូរឡើយសមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំបានឃើញព្រះពុទ្ធព្រះនាម វិបស្សី ទ្រង់មិនមានធូលី ជានាយកក្នុងលោក ព្រះអង្គគង់នៅនាចន្លោះភ្នំ ទ្រង់រុងរឿងដូចជាផ្កាកណិការ ។ ខ្ញុំបានលើកយកនូវផ្កាកណ្តឹង ៣ ទងថ្វាយព្រះសម្ពុទ្ធ លុះបូជាព្រះសម្មាសម្ពុទ្ធហើយ ខ្ញុំមានមុខបែរឆ្ពោះដើរទៅកាន់ទិសខាងត្បូង ។ ដោយអំពើដែលខ្ញុំបានធ្វើហើយដោយល្អនោះផង ដោយចេតនាដែលខ្ញុំបានតម្កល់ទុកនោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតឯឋានតាវត្តិង្ស ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះសម្ពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

---

១-ក្នុងអបទានជាព្រះ តីណិកិំកណិបុប្ផិយត្ថេរ ។

ព្រះថេរៈ កាលសម្រេចអរហត្តហើយ ចូលទៅកាន់នគររាជគ្រឹះ ដើម្បីថ្វាយបង្គំព្រះបរមសាស្តា កាលភិក្ខុទាំងឡាយក្នុងវិហារនោះសួរថា អាវុសោ លោកជាអ្នកមិនប្រមាទនៅក្នុងព្រៃដែរឬ កាលព្យាករអរហត្តផល ដោយប្រកាសដល់ការនៅដោយមិនប្រមាទរបស់ខ្លួន ទើបភាសិតគាថានេះថា

ពួកសត្វក្ងោក ជាសត្វមានសម្បុរខៀវ មានកល្អ មានសិរ្ស៍
តែងយំក្នុងព្រៃឈ្មោះការវី ក្ងោកទាំងនោះ លុះត្រូវខ្យល់ត្រ
ជាក់បក់មក តែងញុំាងបុគ្គលដែលដេកលក់ និងបុគ្គលអ្នក
មានឈានឲ្យភ្ញាក់ឡើង ដូច្នេះ ។

បណ្ដាបទទាំងនោះបទថា **នីលា សុគីវា** ស្មើគ្នានឹង **នីលគីវា** ប្រែថា មានរោមពណ៌ខៀវមានកល្អ ។ តែក្នុងគាថានេះលោកធ្វើជាទីឃៈដើម្បីងាយស្រួលក្នុងការចងគាថា អធិប្បាយថា ប្រកបដោយកល្អ ព្រោះមានរោមវែងដុះជាជួរ ។ ក្ងោកទាំងនោះ ឈ្មោះថា **នីលា** ព្រោះច្រើនដោយពណ៌ខៀវ ។ ឈ្មោះថា **សុគីវា** ព្រោះជាសត្វដែលមានកល្អ ។

បទថា **សិខិនោ** សេចក្តីថា ឈ្មោះថា មានសិរ្សល្អព្រោះមានសិរីល្អត្រង់សិរ្សដែលកើតត្រង់ក្បាល ។ បទថា **មោរា** ស្មើគ្នានឹង **មយុរា** ប្រែថា ក្ងោកទាំងឡាយ ។ បទថា **ការវិយំ** សេចក្តីថា ត្រង់ដើមក្ទាំពាក់ ។ ម្យ៉ាងទៀត ព្រៃនោះមានឈ្មោះថា **ការម្ពិយ** ។ ព្រោះហេតុនោះ ពាក្យថា **ការម្ពិយំ** ទើបបានសេចក្តីថា ក្នុងព្រៃឈ្មោះថា **ការម្ព** ។

បទថា **អភិនទន្តិ** សេចក្តីថា ក្ងោកទាំងនោះស្តាប់សំឡេងផ្គរក្នុងពេល

ភ្លៀងជិតធ្លាក់ នាំគ្នាស្រែកយំក្រលួច ហាក់ដូចសន្តត់សន្ធិនសព្វសត្វ មានហង្ស ជាដើម ដោយសំឡេងផ្សារភ្ជាប់នឹងការដល់ព្រមនៃរដូវកាល ។ បទថា **តេ** បានដល់ ក្ងោកទាំងនោះ ។

បទថា **សីតវាតកីឡិតា** សេចក្ដីថា ក្ងោកទាំងនោះដែលសេចក្ដីរងាគឺភ្លៀងធ្លាក់ចុះមក នាំឲ្យត្រេកអរ ទើបយំល្វេងល្វើយយ៉ាងពីរោះ ។

បទថា **សុត្តំ** បានដល់ ដេកលក់ ដើម្បីបន្ទោបង់នូវការស្រវឹងក្នុងអាហារ ឬដេកលក់ដើម្បីរម្ងាប់នូវការហត់នឿយរបស់រាងកាយ ក្នុងកាលដែលទ្រង់អនុញ្ញាត ។

បទថា **ឈានំ** សេចក្ដីថា ជាអ្នកមានប្រក្រតីសម្ងឹងដោយឈាន គឺសមថៈនិងវិបស្សនា បានដល់ ប្រកបរឿយៗនូវការនា ។

បទថា **និព្ពោធេន្តិ** សេចក្ដីថា ដាស់ឲ្យភ្ញាក់ អធិប្បាយថា ដាស់ឲ្យក្រោកពីដំណេក ដោយការញ៉ាំងសម្បជញ្ញៈឲ្យកើតយ៉ាងនេះថា សូម្បីក្ងោកទាំងនេះក៏មិនដេក ជាសត្វភ្ញាក់រឭក ធ្វើកិច្ចដែលខ្លួនគួរធ្វើ ឯអាត្មាអញប្រយោជន៍អ្វីដោយការដេក ដូច្នេះ ។

អដ្ឋកថា ចិត្តកត្ថេរគាថា ចប់

## គោសាលត្ថេរគាថា

[ ២៤ ] ខ្ញុំបរិភោគមធុបាយាស ជិតគុម្ពប្ញស្សី ហើយពិចារណានូវការកើតឡើងនិងការសូន្យទៅ នៃខន្ធទាំងឡាយ ( ដោយការទទួល ) យកឱ្យាទខាងស្តាំ ខ្ញុំនឹងត្រឡប់ទៅកាន់ប្រកក្នុំ ហើយចម្រើនវិវេកធម៌វិញ ។

គោសាលត្ថេរ ។

---

## អដ្ឋកថា

## គោសាលត្ថេរគាថា

[ ២៤ ] គាថារបស់ព្រះគោសាលត្ថេរ មានពាក្យផ្តើមថា **អហំ ខោ វេឡុគុម្ពស្មឹ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះថេរៈនេះ ជាអ្នកមានបុញ្ញាធិការធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗក្នុងកប្បទី ៩១ អំពីភទ្ទកប្បនេះ ឃើញបង្សុកូលចីវររបស់ព្រះបច្ចេកពុទ្ធ ព្យួរត្រង់គល់ឈើក្បែរភ្នំមួយ មានចិត្តជ្រះថ្លាថា ឱ ! សំពត់បង្សុកូលនេះ ជាទង់ជ័យនៃព្រះអរហន្ត ដូច្នេះហើយ បូជាដោយផ្កា ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតនៅក្នុងស្ថានតាវត្តិង្ស ។ ចាប់តាំងអំពីនោះ ក៏អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះកើតក្នុងត្រកូលស្តុកស្តម្ភមួយក្នុងដែនមគធៈមានឈ្មោះថា គោសាល ។ ព្រោះកុលបុត្តនោះ មានសេចក្តីស្និទ្ធស្នាលជាមួយព្រះសោណកោដិកណ្ណ កាលបានឮថា ព្រះសោណកោដិកណ្ណនោះបួសហើយ

កើតសេចក្ដីសង្វេគថា ឈ្មោះថា សោណកោដិកណ្ណនោះមានសម្បត្តិច្រើន ក៏គង់បួសនឹងពោលទៅថីដល់អាត្មាអញ ដូច្នេះហើយបួសក្នុងសម្នាក់ព្រះមានព្រះភាគ រៀនកម្មដ្ឋានដែលសមគួរដល់ចរិតរបស់ខ្លួន កាលស្វែងរកលំនៅបាននៅត្រង់ភ្នំមួយកន្លែង មិនឆ្ងាយអំពីស្រុកកំណើតរបស់ខ្លួន ។ មាតារបស់លោកប្រគេនភិក្ខារាល់ៗថ្ងៃ ។ ថ្ងៃមួយ មាតាបានប្រគេនបាយាសដែលចម្អិនដោយទឹកឃ្មុំនិងស្ករក្រាមដល់ព្រះថេរៈដែលចូលទៅកាន់ផ្ទះដើម្បីបិណ្ឌបាត ។ ព្រះថេរៈទទួលមធុបាយាសនោះហើយ អង្គុយឆាន់ត្រង់គុម្ពឫស្សីមួយកន្លែងក្រោមស្រមោលនៃភ្នំនោះ លាងដៃនិងបាត្ររួចចម្រើនវិបស្សនា ។ លោកជាអ្នកមានចិត្តតាំងមាំ ព្រោះមានកាយ និងចិត្តសប្បាយដោយបានភោជនជាទីសប្បាយ កាលញាណមានឧទយព្វយញ្ញាណជាដើមចាស់ក្លា ប្រព្រឹត្តទៅខ្វល់ខ្វាយក្នុងវិបស្សនា ញុំាងការនាឲ្យដល់នូវទីបំផុតតាមលំដាប់នៃមគ្គ ធ្វើឲ្យជាក់ច្បាស់នូវអរហត្ត មួយអន្លើដោយបដិសម្ភិទាដោយមិនលំបាក សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

> មានភ្នំមួយឈ្មោះឧទព្វលៈ នៅជិតភ្នំហិមពាន្ត ក្នុងទីនោះ ខ្ញុំបានឃើញសំពត់បង្សុកូល ដែលគេពាក់លើចុងឈើ ។ ក្នុងកាលនោះខ្ញុំមានចិត្តត្រេកអររីករាយ បានបេះផ្កាកណ្ដឹង ៣ ទង ហើយថ្វាយចំពោះសំពត់បង្សុកូលនោះ ។ ដោយអំពើដែលខ្ញុំបានធ្វើហើយដោយល្អនោះផងដោយចេតនាដែលខ្ញុំបានតម្កល់ទុកហើយនោះផង ខ្ញុំលះបង់រាងកាយ ជារបស់មនុស្សហើយ

ទៅកើតឯឋានតាវត្តិង្ស ។ ក្នុងកប្បទី ៩១ អំពីកប្បនេះព្រោះ
ហេតុដែលខ្ញុំធ្វើនូវអំពើល្អ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់
ទុគ្គតិ ព្រោះបានបូជាទង់ជ័យព្រះអរហន្ត ។ កិលេសទាំង
ឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ
ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ មានបំណងនឹងទៅកាន់ភ្នំនោះទៀត ដើម្បីនៅជាសុខក្នុងទិដ្ឋធម៌ កាលប្រកាសបដិបទារបស់ខ្លួន ទើបភាសិតគាថាថា

ខ្ញុំបរិភោគមធុបាយាស ជិតគុម្ពឫស្សី ហើយពិចារណានូវការ
កើតឡើង និងការសូន្យទៅនៃខន្ធទាំងឡាយ ( ដោយការ
ទទួល ) យកឱវាទខាងស្តាំ ខ្ញុំនឹងត្រឡប់ទៅកាន់ប្រកភ្នំហើយ
ចម្រើនវិវេកធម៌វិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វេឡុគុម្ពស្មឹ** សេចក្តីថា ក្បែរគុម្ពឫស្សី គឺត្រង់ម្លប់នៃគុម្ពឫស្សីនោះ ។

បទថា **មធុបាយាសំ** សេចក្តីថា បរិភោគបាយាសដែលចម្អិនដោយទឹកឃ្មុំ ។ បទថា **បទក្ខិណំ** សេចក្តីថា ដោយការទទួលយកខាងស្តាំ អធិប្បាយថា ដោយការទទួលយកឱវាទរបស់ព្រះសាស្តាដោយប្រពៃ ។ បទថា **សម្ម-សន្តោ ខន្ធានំ ឧទយព្វយំ** សេចក្តីថា ពិចារណានូវការកើតឡើង និងការ

---

១-ក្នុងអបទានជាព្រះ បង្សុកូលបូជកត្ថេរ ។

អស់ទៅនៃឧបាទានក្ខន្ធ ៥ អធិប្បាយថា ក្នុងខណៈនោះ ទោះបីធ្វើកិច្ចស្រេច ហើយតែក៏ត្រូវផ្តើមតាំងវិបស្សនាដើម្បីចូលផលសមាបត្តិ ។

បទថា **សាន្តុំ បដិគមិស្សាមិ** សេចក្តីថា ខ្ញុំបំណងនឹងទៅកាន់ភ្នំដែលខ្ញុំធ្លាប់នៅហើយក្នុងកាលមុន ។

បទថា **វិវេកមនុព្រូហយំ** សេចក្តីថា ចម្រើននូវបដិបស្សទ្ធិវិវេក និងកាយវិវេក គឺផលសមាបត្តិ ឬនឹងទៅដោយមានការចម្រើនវិវេកនោះជាហេតុ ព្រះថេរៈកាលពោលយ៉ាងនេះហើយ ទៅកាន់ភ្នំនោះឯង ។ គាថានេះ បានជាការព្យាករអរហត្តផលរបស់ព្រះថេរៈនោះ ។

អដ្ឋកថា គោសាលត្ថេរគាថា ចប់

## សុគន្ធត្ថេរគាថា

[ ២៥ ] អ្នកជាបព្វជិតនៅ ១ វស្សា ចូរពិចារណាភាពនៃធម៌ជាធម៌ល្អ វិជ្ជាទាំង ៣ អ្នកបានសម្រេចហើយ ពុទ្ធសាសនាអ្នកក៏បានធ្វើហើយ ។

**សុគន្ធត្ថេរ ។**

---

## អដ្ឋកថា

## សុគន្ធត្ថេរគាថា

[ ២៥ ] គាថារបស់ព្រះសុគន្ធត្ថេរ មានពាក្យផ្ដើមថា **អនុវស្សិកោ បព្វជិតោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងកប្បទី ៩២ រាប់អំពីកប្បនេះ ក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមថា តិស្សៈ កុលបុត្តនេះកើតក្នុងកំណើតមនុស្ស ដល់នូវភាពជាអ្នកដឹងក្ដីហើយ ចូលទៅកាន់ព្រៃ ដើម្បីបាញ់សត្វ ព្រះបរមសាស្ដាទ្រង់យាងទៅប្រតិស្ឋានស្នាមព្រះបាទឲ្យប្រាកដដើម្បីអនុគ្រោះកុលបុត្តនោះ ។

មាណពឃើញចេតិយ គឺស្នាមព្រះបាទរបស់ព្រះសាស្ដាហើយ ព្រោះមានបុញ្ញាធិការធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ ទើបកើតបីតិ និងសោមនស្សថា ស្នាមជើងទាំងនេះ ជាស្នាមជើងរបស់បុគ្គលដ៏ប្រសើរក្នុងលោកព្រមទាំងទេវលោក ទើបកាន់យកផ្កាសិរមាន់[១] មកធ្វើការបូជា ញុំាងចិត្តឲ្យជ្រះថ្លា ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក ចុតិអំពីទេវ

---

១-សព្ទថា កោរណ្ឌំ ក្នុងអបទានលោកប្រែថា ផ្កាកន្ទុយដំរី ។

លោកនោះហើយខ្នះខ្នែងក្នុងបុណ្យរឿយៗ អន្ទោលទៅក្នុងទេវតានិងមនុស្ស ទាំងឡាយ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាកស្សបៈ កើតជាកុដុម្ពិកៈ បំពេញមហាទានដល់ព្រះបរមសាស្តានិងភិក្ខុសង្ឃ បុកខ្លឹមចន្ទន៍ផ្សំដោយទឹក ដោះគោដែលមានតម្លៃ លាបព្រះគន្ធកុដិ ហើយតាំងសេចក្ដីប្រាថ្នាថា ក្នុងទី ដែលខ្ញុំកើតហើយ សរីរៈរបស់ខ្ញុំ សូមមានក្លិនក្រអូបយ៉ាងនេះ ។ កុលបុត្ត នោះ ធ្វើបុញ្ញកម្មដទៃជាច្រើនក្នុងភពនោះៗ អន្ទោលទៅក្នុងសុគតិភពទាំង ឡាយនោះឯង ក្នុងពុទ្ធុប្បាទនេះកើតក្នុងផ្ទះរបស់ព្រាហ្មណ៍ដែលសម្បូរដោយ សម្បត្តិក្នុងនគរសាវត្ថី ។

ចាប់តាំងពីកាលដែលកុលបុត្តនេះកើតក្នុងផ្ទៃមាតា សរីរៈរបស់មាតាទាំង មូល ក្រអូបផ្សាយទៅពេញផ្ទះ ឯក្នុងថ្ងៃដែលកុលបុត្តកើត ក្លិនក្រអូបក្រៃ លែង ក៏ផ្សាយទៅក្នុងផ្ទះអ្នកជិតខាង ដោយវិសេសនោះឯង ។ មាតាបិតា របស់កុលបុត្តនោះពោលថា កូនរបស់ខ្ញុំ នាំឈ្មោះខ្លួនឯងមកផង ទើបដាក់ ឈ្មោះថា សុគន្ធៈ ដូច្នេះ ។

កុលបុត្តនោះចម្រើនវ័យដោយលំដាប់ ឃើញព្រះមហាសេលត្ថេរ ស្ដាប់ ធម៌ហើយបួសក្នុងសម្នាក់របស់លោក ចម្រើនវិបស្សនាសម្រេចអរហត្តខាង ក្នុង ៧ ថ្ងៃប៉ុណ្ណោះ សមដូចគាថាព័ន្ធដែលពោលទុកក្នុងអបទានថា

ក្នុងភពមុន ខ្ញុំបានកើតជាអ្នកធ្វើការងារក្នុងព្រៃ ចិញ្ចឹមជីវិត
ដោយការសម្លាប់សត្វ តាមលម្អាននៃជីតា កុសលរបស់ខ្ញុំ
មិនមាន ។ ព្រះចក្ខុមសម្ពុទ្ធ ជាព្រះលោកនាយកព្រះនាម

តិស្សៈ ទ្រង់មានព្រះអធ្យាស្រ័យសង្គ្រោះដល់ខ្ញុំ បានសម្ដែងនូវស្នាមព្រះបាទា ៣ អន្លើ ។ ខ្ញុំបានឃើញនូវស្នាមព្រះបាទានៃព្រះសាស្ដាព្រះនាមតិស្សៈដែលទ្រង់ជាន់ទុកមានចិត្តត្រេកអររីករាយ បានញុំាងចិត្តឲ្យជ្រះថ្លាក្នុងស្នាមព្រះបាទា ។ ខ្ញុំបានឃើញនូវដើមកន្ទុយដំរីដុះលើផែនដីមានផ្ការីក ហើយកាច់យកផ្កាកន្ទុយដំរីនោះទាំងចង្កោម ទៅបូជាស្នាមព្រះបាទាដ៏ប្រសើរ ។ ដោយអំពើដែលខ្ញុំបានធ្វើហើយ ដោយល្អនោះផង ដោយចេតនា ដែលខ្ញុំបានតម្កល់ទុកហើយនោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតឯឋានតាវត្តិង្ស ។ ខ្ញុំចូលទៅកាន់កំណើតណាៗ ទោះជាទេវតាឬជាមនុស្សក៏មានពណ៌សម្បុរដូចផ្កាកន្ទុយដំរីមានពន្លឺរស្មីល្អ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំធ្វើ កុសលកម្មក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃការបូជាស្នាមព្រះបាទ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលលោកសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផលបានភាសិតគាថានេះថា

អ្នកជាបព្វជិតនៅខ្ទីរស្សាព្ចូរពិចារណាភាពនៃធម៌ជាធម៌ល្អវិជ្ជា

---

១-ក្នុងអបទានជាព្រះ គោរណ្ឌបុប្ផិយត្ថេរ ។

ទាំង ៣ អ្នកបានសម្រេចហើយ ពុទ្ធសាសនាអ្នកក៏បានធ្វើហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនុវស្សិកោ** សេចក្ដីថា ទៅឯក្រោយ គឺទើបតែចាំវស្សា ទើបឈ្មោះថា **អនុវស្សោ** ធ្វើ **អនុវស្សោ** នោះឯងជា **អនុវស្សិកោ** ។

បទថា **បព្វជិតោ** សេចក្ដីថា ចូលដល់បព្វជ្ជា អធិប្បាយថា ជាអ្នកបួសហើយ តែគប្បីចាំវស្សា គឺមានវស្សា ១ ។ម្យ៉ាងទៀត ដោយអត្ថថា តាមទៅ គឺទៅឯក្រោយ មិនទាន់បានវស្សា ឈ្មោះថា **អនុវស្ស** ។ **អនុវស្ស** នោះ មានដល់ភិក្ខុនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **អនុវស្សិកោ** ។ ភិក្ខុណាដែលបួសហើយ មិនដល់នូវការរាប់វស្សា ព្រោះមានវស្សាមិនទាន់បរិបូណ៌ ទើបភិក្ខុនោះលោកហៅយ៉ាងនេះ ព្រោះហេតុនោះទើបលោកពោលថា **អវស្សិកោ** ប្រែថា មិនទាន់គ្រប់វស្សា ។

បទថា **បស្ស ធម្មសុធម្មតំ** សេចក្ដីថា លោកបួសមិនទាន់បានវស្សាសម្លឹងឃើញធម៌នៃព្រះសាស្ដាជាធម៌ល្អ គឺជាស្វាក្ខាតធម៌ បានដល់ជានិយ្យានិកធម៌ដោយចំណែកមួយ ។ វិជ្ជា ៣ គឺបុព្វេនិវាសញ្ញាណ ទិព្វចក្ខុញ្ញាណ អាសវក្ខយញ្ញាណ ដែលលោកដល់ហើយដោយលំដាប់ គឺធ្វើឲ្យជាក់ច្បាស់ហើយ បន្ទាប់អំពីនោះ សាសនារបស់ព្រះពុទ្ធ គឺពាក្យប្រៀនប្រដៅនៃព្រះសម្មាសម្ពុទ្ធ ដែលខ្ញុំធ្វើស្រេចហើយ បានដល់ អនុសាសនី គឺឱវាទរបស់ព្រះអង្គ ខ្ញុំតាមសិក្សាហើយ ព្រោះហេតុនោះ ព្រះថេរៈកើតបីតិសោមនស្ស

ព្រោះភាពជាអ្នកមានកិច្ចដែលខ្លួនធ្វើសម្រេចហើយ ទើបពោលដល់ខ្លួនដោយសម្មតថាជាអ្នកដទៃ ដូច្នេះឯង ។

## អដ្ឋកថា សុគន្ធត្ថេរគាថា ចប់

## ឆន្និយត្ថេរគាថា

[ ២៦ ] ផលចិត្តដ៏ប្រសើរដែលកើតដោយពន្លឺ ( នៃវិញ្ញាណ ) របស់ខីណាសវភិក្ខុណា អ្នកជាមារមានចិត្តអាក្រក់តែងជ្រែកនូវខីណាសវភិក្ខុនោះ ហើយដល់នូវសេចក្តីទុក្ខរឿយៗ ។

**នន្ទិយត្ថេរ ។**

## អដ្ឋកថា
## ឆន្និយត្ថេរគាថា

[ ២៦ ] គាថារបស់ព្រះនន្ទិយត្ថេរ មានពាក្យផ្តើមថា **ឱភាសជាតំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងកាលរបស់ព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈ កាលព្រះសាស្តាទ្រង់បរិនិព្វានហើយ ឲ្យគេធ្វើវេទិកា[១]បូជាដោយខ្លឹមចន្ទន៍ទុកក្នុងព្រះចេតិយ ញុំាងការបូជាសក្ការៈដ៏ឧឡារឲ្យប្រព្រឹត្តទៅហើយ ចាប់តាំងអំពីនោះ លោកជាអ្នកសម្បូរដោយអធ្យាស្រ័យ សន្សំបុញ្ញកម្ម ដែលជាឧបនិស្ស័យនៃព្រះនិព្វានជាច្រើន ទុកក្នុងភពនោះៗ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងសក្យរាជត្រកូលក្នុងក្រុងកបិលពស្តុ ។

មាតាបិតារបស់កុលបុត្តនោះ កើតនូវការត្រេកអរ ព្រោះហេតុនោះទើប

---

១-សព្ទថា វេទិកំ បិដកខ្មែរអបទាន ប្រែថា ខឿន ។

ដាក់ឈ្មោះថា នន្ទិយ ។ នន្ទិយកុមារចម្រើនវ័យហើយ កាលពួកសក្យៈទាំងឡាយ មានអនុរុទ្ធជាដើម បួសក្នុងសម្នាក់របស់ព្រះបរមសាស្តា ខ្លួនលោកក៏បព្វជ្ជាដែរ ចម្រើនវិបស្សនាសម្រេចអរហត្តក្នុងកាលមិនយូរឡើយ ព្រោះជាអ្នកមានអធិការដែលធ្វើទុកហើយ សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ព្រះជិនស្រីសម្ពុទ្ធព្រះនាមបទុមុត្តរៈ ជាច្បងក្នុងលោកជានរាសភៈ រុងរឿងដូចគំនរភ្លើង ទ្រង់បរិនិព្វានហើយ ។ លុះព្រះមហាវីរៈទ្រង់បរិនិព្វានហើយ ព្រះស្តូបជារបស់ធំសម្បើម ក៏កើតមានឡើង ( ក្នុងកាលនោះ ) ពួកជនតែងនាំគ្នាចូលទៅបម្រើព្រះស្តូប ត្រង់ល្វែងតម្កល់ព្រះធាតុដ៏ប្រសើរឧត្តម ។ កាលនោះ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បានសាងខឿនខ្លឹមចន្ទន៍ បានថ្វាយធូប និងគ្រឿងប្រអប់ដ៏សមគួរដល់ព្រះស្តូប ។ កាលខ្ញុំកើតក្នុងភព ( ណាៗ ) ទោះបីជាទេវតាឬជាមនុស្ស ខ្ញុំមិនបានជួបនូវភាពថោកទាបឡើយ នេះជាផលនៃបុព្វកម្ម ។ ក្នុងកប្បទី ១១៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៨ ជាតិ ព្រះនាមសមត្ថៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១]។

---

១-ក្នុងអបទានជាព្រះ សបរិវារិយត្ថេរ ។

កាលព្រះថេរៈសម្រេចអរហត្តហើយ នៅត្រង់បាចីនវង្សមិគទាយវ័នជាមួយព្រះថេរៈទាំងឡាយ មានព្រះអនុរុទ្ធជាដើម ។ ថ្ងៃមួយ មារមានចិត្តបាបមានបំណងនឹងធ្វើឲ្យខ្លាច ទើបសម្តែងរូបដែលគួរខ្លាចដល់ព្រះថេរៈ ព្រះថេរៈដឹងថា នេះជាមារ កាលសម្តែងថា នៃមារមានចិត្តបាប ព្រះអរិយបុគ្គលពួកណា កន្លងផុតអន្ទាក់នៃមារបានហើយ កិរិយារបស់អ្នកនឹងធ្វើអ្វីក្នុងព្រះអរិយបុគ្គលទាំងនោះបាន ខ្លួនអ្នកនោះឯងនឹងដល់នូវការតានតឹងអន្តរធានព្រោះមានការធ្វើនោះជាហេតុ ទើបភាសិតគាថាថា

ផលចិត្តដ៏ប្រសើរដែលកើតដោយពន្លឺ ( នៃវិញ្ញាណ ) របស់
ទីណាសវភិក្ខុណា អ្នកជាមារមានចិត្តអាក្រក់ តែងជ្រែកនូវទី
ណាសវភិក្ខុនោះ ហើយដល់នូវសេចក្តីទុក្ខរឿយៗ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឱភាសជាតំ** សេចក្តីថា ឈ្មោះថា មានពន្លឺកើតហើយ ដោយពន្លឺគឺញាណ ព្រោះបានសម្រេចមគ្គញាណដ៏ប្រសើរ អធិប្បាយថា ឈ្មោះថា ផូរផង់ពន់ពេក ព្រោះងងឹត គឺកិលេស ត្រូវញាណដ៏ប្រសើរនោះកម្ចាត់អស់ហើយដោយឥតសេសសល់ ។

បទថា **ផលគ្គំ** សេចក្តីថា ដល់ គឺចូលដល់ហើយនូវផល អធិប្បាយថា ប្រកបដោយផលនៃញាណដ៏ប្រសើរ ។

ព្រះថេរៈហៅចិត្តរបស់ព្រះទីណាស្រពថាចិត្ត ដោយពាក្យសាមញ្ញដោយហេតុនោះទើបលោកពោលថា **អភិណ្ហសោ** ។ ចិត្តរបស់ព្រះទីណាស្រពទាំងឡាយជាការគិត ដែលមិនញាប់ញ័រ ព្រោះបង្អោនទៅក្នុងនិរោធ ទើបគួរ

ពោលបានថាជាចិត្តប្រកបដោយផល ព្រោះចូលដល់អរហត្តផលសមាបត្តិ ។ បទថា **តាទិសំ** សេចក្តីថា មានសភាពបែបនោះ បានដល់ ព្រះអរហន្ត ។

បទថា **អាសជ្ជ** បានដល់ សម្ផុតគំរាម ។ ព្រះថេរៈហៅមារថាកណ្ហៈ ព្រោះមានកម្មគ្រោតគ្រាត និងព្រោះមានជាតិថោកថយ ។ បទថា **ទុក្ខំ និគច្ឆសិ** សេចក្តីថា អ្នកនឹងចូលដល់ គឺជួបនូវទុក្ខនិងធ្វើកាយឲ្យលំបាកឥតប្រយោជន៍ ដោយការចូលទៅកាន់ផ្ទៃមាតាជាដើមក្នុងជាតិនេះ និងទុក្ខក្នុងអបាយដែលជាផលតបស្នងក្នុងភពខាងមុខ ។ មារស្តាប់ដូច្នោះហើយ ដឹងថាសមណៈស្គាល់អញ ក៏អន្តរធានទៅក្នុងទីនោះឯង ។

## អដ្ឋកថា នន្ទិយត្ថេរគាថា ចប់

# អភយត្ថេរគាថា

[ ២៧ ] ខ្ញុំបានស្តាប់ព្រះវាចាជាសុភាសិត របស់ព្រះពុទ្ធជាអាទិច្ចពន្ធុ ហើយ បានត្រាស់ដឹងនូវអរិយសច្ចធម៌ដ៏ល្អិត ( ដូចខ្ទាន់ធ្នូជាអ្នកឈ្លាស ) បាញ់ចុងរោមកន្ទុយ ( នៃចៀម ) ដោយព្រួញបាន ។

**អភយត្ថេរ ។**

# អដ្ឋកថា

# អភយត្ថេរគាថា

[ ២៧ ] គាថារបស់ព្រះអភយត្ថេរ មានពាក្យផ្តើមថា **សុត្វា សុភាសិតំ វាចំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុ ដូចម្តេច ។

បានឮថា លោកបួសក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមថា បទុមុត្តរៈ ជាព្រះធម្មកថិក ក្នុងគ្រាសម្តែងធម៌ ពោលសរសើរព្រះមានព្រះភាគ ៤ គាថាសិន ហើយទើបសម្តែងធម៌ក្នុងកាលឯក្រោយ ។ ដោយកម្លាំងនៃបុញ្ញកម្មនោះ ឈ្មោះថា ការបដិសន្ធិក្នុងអបាយ មិនធ្លាប់មានដល់កុលបុត្តនោះ អស់សែននៃកប្ប សមដូចលោកពោលពាក្យជាគាថាថា

ខ្ញុំមានចិត្តជ្រះថ្លា បានសរសើរព្រះសយម្ភូព្រះនាម បទុមុត្តរៈ
ឥតមានបុគ្គលស្មើ ខ្ញុំមិនទៅកាន់អបាយភូមិអស់ ១ សែន
កប្ប ដោយផលនៃកម្មនោះ ដូច្នេះ ។

កុលបុត្តនេះ ជាអ្នកមានផលនៃបុណ្យកុសលប្រមាណមិនបាន ព្រោះ

មានខេត្តសម្បត្តិជាដើម និងព្រោះបុព្វចេតនា បច្ឆិមចេតនានិងសន្និដ្ឋានចេតនា របស់លោកឧឡារពន់ពេក សមដូចលោកពោលទុកថា កាលបុគ្គលជ្រះថ្លាចំពោះគុណជាអចិន្តិយៈ រមែងបានផលជាអចិន្តិយៈ ដូច្នេះ ។ បុណ្យដែលលោកសន្សំទុកក្នុងភពនោះៗ រមែងជាឧបត្ថម្ភកប្បច្ច័យដល់លោក ។ ពិតហើយ លោកបានធ្វើការបូជាព្រះមានព្រះភាគ ព្រះនាមថាវិបស្សីដោយផ្ការំចេក ដោយផលបុណ្យដ៏ពិសេសឧឡារយ៉ាងនេះ លោកអន្ទោលទៅតែក្នុងសុគតិភពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតជាឱរសរបស់ព្រះបាទពិម្ពិសារ មាននាមថា អភ័យ ។ រឿងរបស់កុលបុត្តនេះនឹងជាក់ច្បាស់ខាងមុខ ។

និគណ្ឋនាដបុត្តឲ្យសិក្សាប្រស្នាដែលមានកំណួច ២ ហើយបញ្ជូនទៅដោយពាក្យថា សូមទ្រង់សួរប្រស្នានេះ ហើយលើកវាទៈ សង្កត់សង្កិននូវសមណគោតម ដូច្នេះ ។ កុលបុត្តនោះចូលទៅគាល់ព្រះមានព្រះភាគ រួចទូលសួរប្រស្នានោះ កាលព្រះមានព្រះភាគត្រាស់ដល់បញ្ហានោះជាអនេកព្យាករ បរាជ័យក៏មានដល់ពួកនិគ្រន្ថ តែកុលបុត្តនោះ ក៏ដឹងភាពដែលព្រះសាស្តាជាសម្មាសម្ពុទ្ធ ទើបប្រកាសខ្លួនជាឧបាសក ។ តាំងអំពីនោះ កាលព្រះបាទពិម្ពិសារសោយទិវង្គតហើយ កុលបុត្តនេះកើតសេចក្តីសង្វេគ បួសនៅក្នុងសាសនា បានជាព្រះសោតាបន្ន ដោយតាលច្ឆិគ្គឡូបមសូត្រ ប្រារព្ធវិបស្សនាធ្វើឲ្យជាក់ច្បាស់អរហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះសម្ពុទ្ធជាបុរសខ្ពង់ខ្ពស់ ទ្រង់គង់នៅទៀបច្នេរស្ទឹង វិនតា

ខ្ញុំបានឃើញព្រះពុទ្ធទ្រង់ប្រាសចាកធូលីគឺកិលេស មានព្រះហឫ-
ទ័យមូលក្នុងអារម្មណ៍តែមួយ មានព្រះហឫទ័យតម្កល់មាំ ។
កាលនោះ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជាផ្កាកេត
ដែលមានក្លិនក្រអូបចំពោះព្រះសម្ពុទ្ធដ៏ប្រសើរ ។ ក្នុងកប្បទី
៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាល
នោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេស
ទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ
ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់
ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់ព្រះពុទ្ធរបស់
ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើ
ហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ
ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏
បានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលសម្រេចអរហត្តហើយ កាលព្យាករអរហត្តផល ដោយប្រកាស
ការបដិបត្តិរបស់ខ្លួន ទើបភាសិតគាថាថា

ខ្ញុំបានស្តាប់ព្រះវាចាជាសុភាសិត របស់ព្រះពុទ្ធជាអាទិច្ចពន្ធុ
ហើយ បានត្រាស់ដឹងនូវអរិយសច្ចធម៌ដ៏ល្អិត ( ដូចខ្នាន់ធ្នូ
ជាអ្នកឈ្លាស ) បាញ់ចុងរោមកន្ទុយ ( នៃចៀម ) ដោយ

---

១-ក្នុងអបទានជាព្រះ កេតកបុប្ផិយត្ថេរ ។

ព្រួញបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុត្វា** សេចក្ដីថា ផ្ទៀងនូវសោតៈពិចារណាតាមក្រសែនៃសោតទ្វារ ។

បទថា **សុភាសិតំ** សេចក្ដីថា ត្រាស់ល្អហើយ គឺត្រាស់ហើយដោយប្រពៃនោះឯង បានដល់ ធម្មកថាដែលប្រកាសអរិយសច្ច ៤ ដែលព្រះមានព្រះភាគទ្រង់មិនធ្វើចំណែកណាមួយឲ្យខុសក្លាំងក្លាត់ត្រាស់ហើយ ដោយញ៉ាំងប្រយោជន៍ តាមដែលទ្រង់បំណងឲ្យសម្រេចដោយចំណែកមួយ ព្រោះភាពជាអ្នកត្រាស់ដឹងឯង ដោយប្រពៃ និងព្រោះភាពជាអ្នកមាននូវមហាករុណា អធិប្បាយថា ព្រះធម្មទេសនារបស់ព្រះពុទ្ធដែលផុតចាកសច្ចធម៌ មិនមានឡើយ ។

បទថា **ពុទ្ធស្ស** បានដល់ ព្រះសព្វញ្ញុពុទ្ធ ។ បទថា **អាទិច្ចពន្ធុនោ** សេចក្ដីថា ព្រះមានព្រះភាគទ្រង់ព្រះនាមថា **អាទិច្ចពន្ធុ** ព្រោះអត្ថថា មានព្រះអាទិត្យជាផៅពង្ស ព្រោះប្រសូតក្នុងអាទិច្ចវង្ស ។ របស់ព្រះមានព្រះភាគដែលជាអាទិច្ចពន្ធុនោះ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា អាទិច្ចពន្ធុ ព្រោះអត្ថថា ជាផៅពង្សនៃព្រះអាទិត្យ ព្រោះភាពដែលព្រះមានព្រះភាគ ជាឱរសនៃព្រះអាទិត្យនោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

អ្នកណាមានកម្ដៅ មានពន្លឺភ្លឺផ្លេកៗ ដ៏រុងរឿងក្នុងទីងងឹត មានសណ្ឋានមូល មានតេជៈខ្ពង់ខ្ពស់ ម្នាលរាហុ អ្នកកុំលេបនូវ

អ្នកនោះដែលកំពុងតែចរទៅព្ធដ៏អាកាសឡើយ ម្នាលរាហុអ្នក
ចូរលែងសុរិយទេវបុត្តជាកូនតថាគតចេញ ដូច្នេះ ។

បទថា **បច្ចុញ្ញមឹ** ប្រែថា ចាក់ធ្លុះហើយ ។ ម្យ៉ាងទៀត សព្ទថា **ហិ** ត្រឹមតែជានិបាត ។

បទថា **ឆិបុណាំ** សេចក្តីថា ល្អិតល្អន់ គឺសុខុមក្រៃលែង បានដល់ និរោធសច្ច ឬអរិយសច្ចនោះឯង ។ ម្យ៉ាងទៀត សព្ទថា **ហិ** ត្រឹមតែជា និបាត ចុះក្នុងអត្ថនៃហេតុ សេចក្តីថា ព្រោះចាក់ធ្លុះហើយនូវសច្ចធម៌ទាំង ៤ ដែលល្អិតល្អន់ ហេតុនោះវត្ថុណាដែលត្រូវចាក់ធ្លុះទៀត ក្នុងឥឡូវនេះទើប មិនមាន ។ ដើម្បីនឹងឆ្លើយពាក្យសួរថា ដូចចាក់ធ្លុះនូវអ្វី ទើបព្រះថេរៈពោល ថា ( ដូចខ្មាន់ធ្នូជាអ្នកឈ្លាស ) បាញ់ចុងរោមកន្ទុយនៃទ្រាយដោយព្រួញ បាន ដូច្នោះ ។ ប្រកបសេចក្តីថា ចាក់ធ្លុះអរិយសច្ច ៤ ដោយល្អិតល្អន់ ដូចនាយខ្មាន់ធ្នូអ្នកឈាសសិក្សាល្អហើយ បាញ់ចុងរោមទ្រាយដែលជ្រៀកជា ៧ ចម្រៀកដោយព្រួញ គឺកូនសរមិនឲ្យខុស ដូច្នោះ ។

**អដ្ឋកថា អភយត្ថេរគាថា ចប់**

## លោមសកង្គិយត្ថេរគាថា

[ ២៨ ] កាលខ្ញុំចម្រើនវិវេកធម៌ ក៏កម្ចាត់បង់ស្មៅចិញ្ចៀន ស្បូវ គុម្ព ឈើមានបន្លា ស្បូវរណ្តាស ស្មៅជំណោកទន្សាយ នឹងស្មៅយាប្លង គឺកិលេសគ្រោតគ្រាត កណ្តាល ល្អិត ដោយទ្រូងគឺសេចក្តីព្យាយាមបាន ។

*លោមសកង្គិយត្ថេរ ។*

---

## អដ្ឋកថា

## លោមសកង្គិយត្ថេរគាថា

[ ២៨ ] គាថារបស់ព្រះលោមសកង្គិយត្ថេរ មានពាក្យផ្តើមថា **ទព្ភំ កុសំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងកប្បទី ៩១ អំពីភទ្ទកប្បនេះ កុលបុត្តនេះឃើញព្រះមានព្រះភាគ ព្រះនាមថាវិបស្សី មានចិត្តជ្រះថ្លា បូជាដោយផ្កាផ្សេងៗ ដោយបុញ្ញកម្មនោះកើតក្នុងទេវលោក ធ្វើបុណ្យហើយ អន្ទោលទៅមកក្នុងទេវលោកនោះឯង បួសក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាកស្សបៈ បំពេញសមណធម៌ ។ ដោយសម័យនោះ កាលព្រះបរមសាស្តាត្រាស់ភទ្ទេករត្តប្បដិបទាហើយ ភិក្ខុមួយរូបសន្ទនានឹងកុលបុត្តនោះដោយរឿងភទ្ទេករត្តសូត្រ លោកអធិប្បាយភទ្ទេករត្តសូត្រនោះមិនបាន កាលអធិប្បាយមិនបានទើបតាំងបណិធានថា ក្នុងអនាគត ខ្ញុំគប្បីជាអ្នកអាចដើម្បីនឹងពោលភទ្ទេករត្តសូត្រដល់លោក ភិក្ខុអង្គនោះក៏ពោលថា ខ្ញុំនឹងសួរ ។ ក្នុងបណ្តាភិក្ខុ ២ អង្គនោះ

ភិក្ខុទី ១ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ អស់មួយពុទ្ធន្តរ ហើយកើតក្នុងត្រកូលសក្យរាជ ក្នុងក្រុងកបិលពស្តុ ក្នុងកាលនៃព្រះមានព្រះភាគនៃយើងទាំងឡាយ ។

ដោយភាពជាសុខមាលជាតិ កុលបុត្តនេះក៏មានរោមដុះត្រង់បាតជើងដូចព្រះសោណៈដែរ ដោយហេតុនោះ ទើបគេដាក់ឈ្មោះថា លោមសកង្គិយៈ ។

ភិក្ខុមួយរូបទៀត កើតក្នុងទេវលោក ប្រាកដឈ្មោះថាចន្ទៈ កាលសក្យកុមារទាំងឡាយ មានអនុរុទ្ធជាដើមបួស លោមសកង្គិយកុមារមិនប្រាថ្នានឹងបួសឡើយ ។

លំដាប់នោះ ចន្ទទេវបុត្តចូលទៅរក ហើយសួរដល់ភទ្ទេករត្តប្បដិបទាដើម្បីឲ្យសង្វេគ ។ កុលបុត្តនោះឆ្លើយថា ខ្ញុំមិនដឹង ទេវបុត្តក៏ពោលឡើងថា បើដូច្នោះ ហេតុអ្វីក៏អ្នកសន្យានឹងខ្ញុំថា ខ្ញុំនឹងពោលភទ្ទេករត្តប្បដិបទាដល់លោក តែឥឡូវនេះសូម្បីតែឈ្មោះថា ភទ្ទេករត្ត ក៏ចាំមិនបាន ។

លោមសកង្គិយមាណព ក៏ចូលទៅគាល់ព្រះមានព្រះភាគ មួយអន្លើដោយចន្ទទេវបុត្តនោះ ហើយទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ខ្ញុំព្រះអង្គសន្យាទុកក្នុងភពមុនថា ខ្ញុំនឹងពោលភទ្ទេករត្តប្បដិបទា ដល់ទេវបុត្តនេះពិតមែនឬព្រះអង្គ ព្រះមានព្រះភាគត្រាស់ថា នែកុលបុត្ត ពិតហើយអ្នកធ្វើកតិកាទុកយ៉ាងនេះ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមថាកស្សបៈ ។

រឿងនោះ បណ្ឌិតគប្បីជ្រាបពិស្តារដោយន័យដែលមកហើយ ក្នុងឧបរិបណ្ណាសក: ។ លំដាប់នោះ លោមសកង្គិយមាណពទូលថា បពិត្រព្រះ

អន្តដ៏ចម្រើន បើដូច្នោះ សូមទ្រង់ញ៉ាំងខ្ញុំព្រះអង្គឲ្យបួសចុះ ដូច្នេះ សូម្បីព្រះមានព្រះភាគក៏ឃាត់ថា ព្រះតថាគតទាំងឡាយ មិនញ៉ាំងកុលបុត្តដែលមាតាបិតាមិនទាន់អនុញ្ញាតឲ្យបព្វជ្ជាឡើយ កុលបុត្តនោះចូលទៅកាន់សម្នាក់មាតាហើយពោលថា បពិត្រព្រះមាតា សូមអនុញ្ញាតឲ្យខ្ញុំបួសចុះ កាលមាតាពោលថា នែកូន បាជាសុខមាលជាតិនឹងបួសបានដូចម្តេច ដូច្នេះ ។ កាលនឹងប្រកាសភាពដែលខ្លួនអត់ធន់នឹងអន្តរាយបាន ទើបពោលគាថាថា

កាលខ្ញុំចម្រើនវិវេកធម៌ ក៏កម្ចាត់បង់ស្មៅចិញ្ចៀន ស្បូវ គុម្ព
ឈើមានបន្លា ស្បូវណ្តាស ស្មៅជំណេកទន្សាយ និងស្មៅ
យាប្លង់ គឺកិលេសគ្រោតគ្រាត កណ្តាល ល្អិត ដោយទ្រូង
គឺសេចក្តីព្យាយាមបាន ដូច្នេះ ។

បណ្តាបទទាំងនោះ លោកហៅស្មៅចិញ្ចៀនថា **ឧត្ត** អាចារ្យខ្លះ ហៅថា **សទ្ទុន** ។

បទថា **កុសំ** បានដល់ ស្បូវក្លាំង អាចារ្យខ្លះហៅថា **កាស** ។ បទថា **ឆោដកិលំ** បានដល់ គុម្ពស្មៅដែលមានបន្លានិងមិនមានបន្លា តែក្នុងទីនេះ លោកបំណងយកគុម្ពឈើដែលមានបន្លាប៉ុណ្ណោះ តិណ្ណជាតិមានស្បូវណ្តាសជាដើម ដឹងបានឆាយហើយ ។ ស្មៅទាំងឡាយ មានស្បូវក្លាំងជាដើម ចាត់ជាស្មៅដែលមុត ព្រោះកាលជាន់ដោយជើងទាំង ២ ក៏ញ៉ាំងទុក្ខឲ្យកើត ទាំងធ្វើអន្តរាយក្នុងការដើរទៅ តែខ្ញុំនឹងយកទ្រូងលូនលើស្មៅទាំងនោះ គឺវែកស្មៅទាំងនោះទៅដោយទ្រូង ។ លោកសម្តែងថា កាលត្រូវយកទ្រូងលូនលើស្មៅ

ក៏អត់សង្កត់នូវទុក្ខ ដែលមានស្នេហ៍នោះជាហេតុបានយ៉ាងនេះ ក៏អាចចូលទៅកាន់គុម្ពឈើក្នុងដងព្រៃបំពេញសមណធម៌បាន ។

បទថា **វិវេកមនុព្រូហយំ** សេចក្តីថា ចម្រើននូវកាយវិវេក ចិត្តវិវេក និងឧបធិវិវេក អធិប្បាយថា ចិត្តវិវេករមែងមានដល់បុគ្គលដែលលះនូវការប្រឡូកប្រឡំដោយពួកគណៈ ហើយចម្រើននូវកាយវិវេកតែម្យ៉ាង ញុំាងចិត្តឲ្យតាំងមាំក្នុងអារម្មណ៍ឯណានីមួយ ក្នុងបណ្តាអារម្មណ៍ ៣៨ ប្រការ មិនមានដល់បុគ្គល ដែលត្រេកអរក្នុងការប្រឡូកប្រឡំដោយពួកគណៈ ។ ការសម្រេចឧបធិវិវេកដោយការញុំាងកិលេសឲ្យអស់ទៅ រមែងមានដល់បុគ្គលដែលមានចិត្តជាសមាធិនោះឯងដែលបំពេញវិបស្សនាធ្វើសមថៈនិងវិបស្សនាឲ្យជាគូ មិនមានដល់បុគ្គលដែលមិនមានចិត្តជាសមាធិ ដោយហេតុនោះទើបខ្ញុំពោលថា បទថា **វិវេកមនុព្រូហយំ** បានដល់ ចម្រើននូវកាយវិវេក ចិត្តវិវេកនិងឧបធិវិវេក ។ កាលលោមសកង្គិយមាណពជាបុត្ត ពោលយ៉ាងនេះហើយ មាតាក៏អនុញ្ញាតថា បើដូច្នោះ ចូរបាបួសចុះ ដូច្នេះ ។

កុលបុត្តនោះ ទៅគាល់ព្រះមានព្រះភាគ ទូលសូមបព្វជ្ជា ព្រះសាស្តាឲ្យបួសហើយ ។ ភិក្ខុទាំងឡាយពោលនឹងលោមសកង្គិយៈដែលបួសហើយធ្វើបុព្វកិច្ចស្រេចហើយ រៀននូវកម្មដ្ឋានហើយនឹងចូលទៅកាន់ព្រៃថា អាវុសោ លោកជាស្តេចសុខុមាលជាតិ តើអាចចូលកាន់ព្រៃបានដូចម្តេច ។

លោកពោលគាថានោះឯងដល់ភិក្ខុទាំងនោះ ចូលទៅកាន់ព្រៃ ប្រកបភាវនាបានអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោក

ពោលទុកក្នុងអបទានថា

ខ្ញុំបានបូជាផ្កាខ្ទឹងចំពោះព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស គួរទទួលនូវគ្រឿងបូជា កំពុងស្តេចទៅតាមច្រក ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផលក៏បានពោលគាថានេះដដែលទៀត ដូច្នេះឯង ។

## អដ្ឋកថា លោមសកង្គិយត្ថេរគាថា ចប់

---

១-ក្នុងអបទានជាព្រះ នាគបុប្ផិយត្ថេរ ។

## ជម្ពុគាមិកបុត្តត្ថេរគាថា

[ ២៩ ] អ្នកមិនខ្វល់ខ្វាយចំពោះសំពត់ទេឬ មិនត្រេកអរចំពោះការស្អិតស្អាងទេឬ អ្នកផ្សាយក្លិនសម្រេចអំពីសីលធម៌ឬ ជ្បិតពួកសត្វក្រៅអំពីនេះមិនផ្សាយ ( ក្លិនដូច្នោះទេ ) ។

**ជម្ពុគាមិកបុត្តត្ថេរ ។**

## អដ្ឋកថា

## ជម្ពុគាមិកបុត្តត្ថេរគាថា

[ ២៩ ] គាថារបស់ព្រះជម្ពុគាមិកបុត្តត្ថេរ មានពាក្យផ្ដើមថា **កច្ចិ នោ វត្ថបសុតោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះមានបុញ្ញាធិការធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទព្រះមានព្រះភាគព្រះនាមថាវេស្សភូ ក្នុងកប្បទី ៣១ រាប់អំពីកប្បនេះ ថ្ងៃមួយ ឃើញផ្កាចារទើបបេះផ្កាចារទាំងនោះទៅ រឭកដល់គុណព្រះពុទ្ធ បោះផ្កាទៅក្នុងអាកាសឧទ្ទិសដល់ព្រះមានព្រះភាគបូជាហើយ ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងស្ថានតាវត្តិង្ស ។

បន្ទាប់អំពីនោះ ធ្វើបុណ្យជាច្រើន អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយក្នុងពុទ្ធុប្បាទនេះកើតជាបុត្តរបស់ឧបាសកឈ្មោះ ជម្ពុគាមិក ក្នុងចម្បានគរ ដោយហេតុនោះ ទើបបានឈ្មោះថា ជម្ពុគាមិកបុត្ត ។ កុលបុត្តនោះ

ចម្រើនវ័យហើយ ស្តាប់ធម៌ក្នុងសម្នាក់នៃព្រះមានព្រះភាគកើតសេចក្តីសង្វេគ ធ្វើនូវបុព្វកិច្ច រៀននូវកម្មដ្ឋាន អាស្រ័យនៅក្នុងព្រៃអញ្ជនវ័ន ក្បែរនគរសាកេត ។

លំដាប់នោះ បិតារបស់លោក កាលពិសោធថា កូនប្រុសរបស់អញត្រេកអរក្នុងព្រះសាសនាដែរឬហ្ន៎ ដូច្នេះ ទើបចារអក្ខរាបញ្ជូនទៅដោយសេចក្តីថា លោកម្ចាស់ខ្វល់ខ្វាយក្នុងរឿងសំពត់ដែរឬទេ ដូច្នេះជាដើម ព្រះថេរៈអានសំបុត្រនោះហើយកើតសេចក្តីសង្វេគថា ញោមប្រុសរបស់អញរង្កៀសការនៅដោយសេចក្តីប្រមាទរបស់អញ សូម្បីដល់ថ្ងៃនេះអញក៏មិនទាន់ឈានកន្លងនូវបុថុជ្ជនភូមិទៅបាន ទើបប្រារព្ធព្យាយាម ជាអ្នកមានអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំបានឃើញផ្កាចាររីកហើយ ( បេះផ្កានោះ ) រួចផ្គងអញ្ជលីប្រណម្យឡើង នឹកដល់ព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ហើយបានបូជាបោះផ្កានោះទៅឰដ៏អាកាស ។ ដោយអំពើដែលខ្ញុំបានធ្វើដោយល្អនោះផង ដោយចេតនា ដែលខ្ញុំបានតម្កល់ទុកហើយនោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សទៅក៏បានទៅកើតឯឋានតាវត្តិង្ស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិ

បត្តិហើយ ដូច្នេះ(១) ។

កាលលោកសម្រេចអរហត្តហើយ ទៅកាន់នគរដែលជាលំនៅរបស់ពួកញាតិ កាលប្រកាសភាពដែលសាសនាជានិយ្យានិកធម៌ បានសម្ដែងនូវបាដិហារ្យ ។ ញាតិទាំងឡាយដ៏ច្រើនបានឃើញបាដិហារ្យនោះហើយ មានចិត្តជ្រះថ្លា នាំគ្នាសាងសង្ឃារាម ។ ព្រះថេរៈធ្វើគាថាដែលបិតារបស់ខ្លួនបញ្ជូនទៅឲ្យដែលដូចជាកង្វេរទូន្មានដ៏វិ ប្រារព្ធព្យាយាមធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្ត កាលព្យាករអរហត្តផលដើម្បីបូជាគុណរបស់បិតា បានពោលគាថានោះឯងដោយសេចក្ដីថា

អ្នកមិនខ្វល់ខ្វាយចំពោះសំពត់ទេឬ មិនត្រេកអរចំពោះការ
ស្អិតស្អាងទេឬ អ្នកផ្សាយក្លិនសម្រេចអំពីសីលធម៌ឬ ដ្បិតពួក
សត្វក្រៅអំពីនេះ មិនផ្សាយ ( ក្លិនដូច្នោះទេ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ សព្ទថា **កច្ចិ** ជានិបាត ប្រើក្នុងពាក្យសួរ ។ បទថា **នោ** ប្រើក្នុងការបដិសេធ ។ បទថា **វត្ថុបសុតោ** សេចក្ដីថា ជាអ្នកខ្វល់ខ្វាយក្នុងសំពត់ ហៅថា **វត្ថុបសុត** បានដល់ ត្រេកអរក្នុងការប្រដាប់

---

១-ក្នុងអបទានជាព្រះ កឹសុកបុប្ផិយត្ថេរ ។ ក្នុងទុកនិបាតព្រះថេរៈឈ្មោះ សោមមិត្តត្ថេរ ក៏បានពោលបុព្វកម្មរបស់លោកដោយអបទាននេះដូចគ្នា សេចក្ដីនេះបណ្ឌិតមិនគួរងឿងឆ្ងល់ថា អបទានតែមួយ ហេតុអ្វីទើបមានព្រះថេរៈច្រើនអង្គពោលដូចគ្នាយ៉ាងនេះ ព្រោះក្នុងអតីតកាល កុលបុត្តដែលបេះផ្កាចារជាដើមបូជាព្រះ មានច្រើននាក់ ក្នុងផ្កាឈើនិងផ្លែឈើដទៃក៏មានន័យដូចគ្នានេះ ព្រោះហេតុនោះ ទើបមានព្រះថេរៈច្រើនអង្គពោលអបទានតែមួយ តទៅបើមានព្រះថេរៈដែលពោលអបទានដូចគ្នាយើងមិនបានដាក់លេខយោងទៀតឡើយ ព្រោះនាំឲ្យយឺតយូរ ។

តាក់តែង ( របនា ) ចីវរជាដើម ។ បទថា **វត្ថុបសុតោ** នេះ ត្រឹមតែជាឧបមា ព្រោះលោកបំណាងដល់ការហាមនូវការធ្វើនូវវត្ថុឥតប្រយោជន៍ មានការរចនាបាត្រជាដើមផងដែរ ។ បាឋៈថា **កច្ចិ ន វត្ថុបសុតោ** ដូច្នេះក៏មាន ឯសេចក្តីក៏យ៉ាងនោះដូចគ្នា ។

បទថា **ភូសណារតោ** សេចក្តីថា ត្រេកអរហើយ គឺត្រេកអរក្រៃលែងក្នុងការប្រដាប់តាក់តែងអត្តភាព ដូចភិក្ខុបវខៈ សូម្បីបួសហើយ ក៏គង់ប្រែប្រួល ច្រើនទៅដោយការបម្រើកាយ ខ្វល់ខ្វាយក្នុងការប្រដាប់តាក់តែងបរិក្ខារមានចីវរជាដើម និងសរីរៈរបស់ខ្លួន ។ អត្ថនៃបទទាំង ២ ក្នុងគាថានេះ ក៏មានដូច្នេះថា មិនបានជាបុគ្គលខ្វល់ខ្វាយក្នុងបរិក្ខារ និងមិនត្រេកអរក្នុងការប្រដាប់តាក់តែងទេឬ ។

បទថា **សីលមយំ គន្ធំ** សេចក្តីថា លោកម្ចាស់ញុំាងក្លិនដែលសម្រេចដោយសីលដែលលោកពោល ( ក្នុងធម្មបទ ) ហើយថា ចំណែកក្លិននៃបុគ្គលមានសីលទាំងឡាយណា ក្លិននោះ ទើបក្រអូបលើសលុបផ្សាយទៅក្នុងទេវលោកនិងមនុស្សលោកបាន ដូច្នេះ ឲ្យផ្សាយទៅដោយអំណាចនៃសីល ៤ យ៉ាង ដែលបរិសុទ្ធដោយល្អ មានសីលមិនដាច់ជាដើម ឲ្យកើតឡើងដែរឬទេ អធិប្បាយថា លោកម្ចាស់មានកិត្តិសព្ទដ៏ល្អ ល្បីទៅកាន់ទិសទាំងពួងដោយមូលសីលសម្បត្តិដែរឬទេ ។

បទថា **នេតរា បជា** សេចក្តីថា ពួកជនទ្រុស្តសីលក្រៅអំពីនេះ ញុំាងក្លិនសីលឲ្យផ្សាយទៅមិនបាន គឺឈ្មោះថា ញុំាងក្លិនស្អុយដែលសម្រេចដោយ

ភាពជាអ្នកទ្រុស្តសីលឲ្យផ្សាយទៅ ព្រោះភាពជាអ្នកទ្រុស្តសីលនោះឯង អ-ធិប្បាយថា លោកម្ចាស់ មិនញុំាងក្លិនស្អុយឲ្យផ្សាយទៅយ៉ាងនេះ ហើយញុំាងក្លិនសម្រេចដោយសីលឲ្យផ្សាយទៅដែរឬ ។

ម្យ៉ាងទៀត បទថា **ឆេតវា បជា** នេះ បិតាព្រះថេរៈពង្រីកការផ្សាយទៅនៃក្លិនសីល ក្នុងគន្ធដែលផ្សាយគ្នាថា ពួកជនទ្រុស្តសីលក្រៅអំពីនេះញុំាងក្លិនសីលឲ្យផ្សាយទៅមិនបានឡើយ ព្រោះក្លិនសម្រេចដោយសីល រមែងផ្សាយទៅបាន ។

## អដ្ឋកថា ជម្ពុគាមិកបុត្តត្ថេរគាថា ចប់

## ហារិតត្ថេរគាថា

[ ៣០ ] បុគ្គលកាលពត់ខ្លួន ( ឲ្យត្រង់ ) ដូចជាងអ្នកធ្វើព្រួញពត់ព្រួញ លុះធ្វើចិត្តឲ្យត្រង់ហើយ ទើបទម្លាយ នាំចេញនូវអវិជ្ជាបាន ។

**ហារិតត្ថេរ ។**

## អដ្ឋកថា

## ហារិតត្ថេរគាថា

[ ៣០ ] គាថារបស់ព្រះហារិតត្ថេរ មានពាក្យផ្ដើមថា **សមុន្នមយមត្តានំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះជាអ្នកមានបុញ្ញាធិការធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ចូលទៅសន្សំបុណ្យកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ឃើញព្រះបច្ចេកពុទ្ធព្រះនាមថា សុទស្សនៈ ជាអ្នកមានចិត្តជ្រះថ្លាហើយ ធ្វើការបូជាដោយផ្កាអញ្ចាន់ អន្ទោលទៅក្នុងសុគតិភពតែម្យ៉ាងដោយបុញ្ញកម្មនោះ ។ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលព្រាហ្មណមហាសាលក្នុងនគរសាវត្ថី ។ មានឈ្មោះថា ហារិតៈ ។ កុលបុត្តនោះចម្រើនវ័យហើយ ឪពុកម្ដាយ បាននាំកុមារីរបស់ព្រាហ្មណ៍អ្នកមានត្រកូលស្មើគ្នានិងមានរូបល្អដូចគ្នាជាដើមមកឲ្យ ។ កុលបុត្តនោះសោយភោគទ្រព្យរួមជាមួយកុមារីនោះ សម្លឹងមើលរូបសម្បត្តិរបស់ខ្លួន និងរបស់នាងហើយ ដែលបុណ្យជាស់តឿន បាននូវសេចក្ដីសង្វេគថា ឈ្មោះថា រូប

ល្អដូចអញនិងកុមារីនេះ ក៏គង់ត្រូវជរានិងមច្ចុញាំញីក្នុងកាលមិនយូរឡើយ ។

ក្នុងកាលកន្លងទៅមិនយូរប៉ុន្មាន ពស់វែកចឹកកិរិយា របស់កុលបុត្តនោះស្លាប់ កុលបុត្តនោះកើតសេចក្តីសង្វេគដោយហេតុនោះពន់ប្រមាណ ទៅកាន់សម្នាក់របស់ព្រះសាស្តាហើយ ស្តាប់ធម៌ កាត់បង់នូវការជាប់ជំពាក់ក្នុងផ្ទះបានហើយចេញបួស កាលលោករៀនកម្មដ្ឋានដែលសមគួរដល់ចរិត កម្ម-ដ្ឋានក៏មិនសម្រេច ចិត្តមិនស្មុះត្រង់គន្លង លោកចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ឃើញជាងព្រួញម្នាក់ ដាក់ព្រួញចូលក្នុងឧបករណ៍ ធ្វើនូវការពត់ឲ្យត្រង់ ក៏គិតថា ជាងព្រួញនេះ ពត់ព្រួញដែលមិនមានចេតនាឲ្យត្រង់ ហេតុអ្វីអញក៏មិនធ្វើចិត្តរបស់ខ្លួនឲ្យត្រង់ ដូច្នេះហើយ ត្រឡប់ទៅអំពីនោះឯង អង្គុយចម្រើនវិបស្សនាក្នុងទីសម្រាកពេលថ្ងៃ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់គង់ក្នុងអាកាស កាលនឹងប្រទានឱវាទបានត្រាស់គាថាដោយសេចក្តីថា

> បុគ្គលកាលពត់ខ្លួន ( ឲ្យត្រង់ ) ដូចជាងអ្នកធ្វើព្រួញ ពត់
> ព្រួញ លុះធ្វើចិត្តឲ្យត្រង់ហើយ ទើបទម្លាយនាំចេញនូវអវិជ្ជា
> បាន ដូច្នេះ ។

អាចារ្យពួកខ្លះពោលថា ព្រះថេរៈនេះឯង កាលនឹងទូន្មានខ្លួន ដូចទូន្មានអ្នកដទៃបានពោលគាថានេះ ។

បណ្តាបទទាំងនោះ បទថា **សមុន្នមយំ** សេចក្តីថា លើកខ្លួនឡើងដោយប្រពៃ អធិប្បាយថា លើកខ្លួនចាកការខ្ជិលច្រអូសនោះ មិនឲ្យធ្លាក់ទៅក្នុង

ចំណែកកោសជ្ជៈដោយអំណាចសមាបត្តិ ប្រកបព្យាយាមឲ្យស្មើ ។

បទថា **អត្តានំ** បានដល់ ចិត្ត ។ម្យ៉ាងទៀត បទថា **សមុទ្ធមយំ** សេចក្តីថា លើកខ្លួនឡើងចាកធម៌ដែលជាចំណែកកោសជ្ជៈ ។ ម អក្ខរៈ គ្រាន់តែធ្វើការភ្ជាប់បទ អធិប្បាយថា បើចិត្តរបស់អ្នកដែលមិនប្រព្រឹត្តទៅត្រង់គន្លងកម្មដ្ឋាន ព្រោះភាពជាអ្នកមានសេចក្តីព្យាយាមធូរថយសោត ចូរអ្នកលើកចិត្តនោះឡើងដោយប្រពៃ ដោយអំណាចនៃការប្រារព្ធសេចក្តីព្យាយាម គឺធ្វើមិនឲ្យធូរថយ មិនឲ្យមានកំណួច សេចក្តីថា នៃហារិតៈ កាលអ្នកធ្វើយ៉ាងនេះ ឈ្មោះថា លើកខ្លួនឡើងចាកការខ្ជិលច្រអូស ដូចជាងព្រួញលើកព្រួញឡើងពត់ ដូច្នោះ ចូរអ្នកធ្វើចិត្តឲ្យត្រង់ ហើយទម្លាយនូវអវិជ្ជា ប្រៀបដូចជាងព្រួញ កាលពត់ព្រួញដែលវៀច គឺមិនត្រង់ សូម្បីតែបន្តិចបន្តួច រមែងពត់ឲ្យត្រង់ដើម្បីបាញ់ត្រូវក្តារប៉ាយ យ៉ាងណា អ្នកក៏ដូច្នោះ កាលពត់ចិត្តដែលវួញរា ព្រោះធ្លាក់ទៅក្នុងកោសជ្ជៈ ដោយមិនរក្សាចិត្តដែលវួញរា ព្រោះធ្លាក់ទៅក្នុងឧទ្ធច្ចៈ ដោយមិនបានរក្សា ត្រូវធ្វើចិត្តឲ្យត្រង់ដោយឲ្យដល់អប្បនា ជាអ្នកមានចិត្តតាំងមាំហើយ ខំខ្នែងក្នុងវិបស្សនា ចូរទម្លាយ គឺកម្ចាត់អវិជ្ជាដោយមគ្គញាណដ៏ប្រសើរ ដោយរួសរាន់ ។ ព្រះថេរៈស្តាប់ព្រះគាថានោះហើយ ចម្រើនវិបស្សនា បានជាព្រះអរហន្ត ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ក្នុងទីជិតនៃព្រៃហេមពាន្ត មានភ្នំមួយឈ្មោះ អចលៈ ព្រះ
សម្ពុទ្ធព្រះនាមសុទស្សៈ គង់នៅក្នុងចន្លោះភ្នំនោះ ។ ខ្ញុំបាន

យកផ្កាអំពីព្រៃហិមពាន្ត ហើយទៅកាន់អាកាស បានឃើញ
ព្រះសម្ពុទ្ធទ្រង់ធ្វងឱឃៈ មិនមានអាសវៈក្នុងទីនោះ ។ កាល
នោះខ្ញុំយកផ្កាអញ្ជ័នខៀវមកតម្កល់លើក្បាល ហើយបូជាព្រះ
ពុទ្ធទ្រង់ត្រាស់ដឹងឯង ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ក្នុងកប្បទី
៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ
ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេស
ទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះ
ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផល ក៏បានពោលគាថានោះឯងដដែលទៀត ដូច្នេះ ។

## អដ្ឋកថា ហារិតត្ថេរគាថា ចប់

---

១- ក្នុងអបទានជាព្រះ កុដជបុប្ផិយត្ថេរ ។

## ឧត្តិយត្ថេរគាថា

[ ៣១ ] កាលបើអាពាធ កើតឡើងដល់ខ្ញុំ ស្មារតីកើតឡើងដល់ខ្ញុំថា អាពាធកើតឡើងដល់អញហើយ នេះជាកាលដែលអញមិនគួរប្រមាទ ។

**ឧត្តិយត្ថេរ ។**

**ឧទ្ទាន**

និយាយអំពីនិគ្រោធត្ថេរ ១ ចិត្តកត្ថេរ ១ គោសាលត្ថេរ ១ សុគន្ធត្ថេរ ១ នន្ទិយត្ថេរ ១ អភយត្ថេរ ១ លោមសកង្គិយត្ថេរ ១ ជម្ពុគាមិកបុត្តត្ថេរ ១ ហារិតត្ថេរ ១ ឧត្តិយត្ថេរជាគំរប់ ១ ។

**ចប់ តតិយវគ្គ ។**

## អដ្ឋកថា

## ឧត្តិយត្ថេរគាថា

[ ៣១ ] គាថារបស់ព្រះឧត្តិយត្ថេរ មានពាក្យផ្ដើមថា **អាពាធេ មេ សមុប្បន្នេ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។ បានឮថា កុលបុត្តនេះ មានបុញ្ញាធិការធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ជាច្រើន ។ រាប់អំពីកទ្ធកប្បនេះទៅក្រោយ ៩៤ កប្ប ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថា សិទ្ធត្ថ កុលបុត្តនេះកើតជាក្រពើ មានខ្លួនធំសម្បើម ក្នុងស្ទឹងចន្ទភាគា ។

ក្រពើឃើញព្រះមានព្រះភាគ ត្រង់ឆ្នេរស្ទឹងបំណងនឹងឆ្លងត្រើយ មានចិត្តជ្រះថ្លា បំណងនឹងចម្លងព្រះមានព្រះភាគទើបឡើងទៅដេកក្បែរច្រាំង ព្រះមានព្រះភាគកាលទ្រង់អនុគ្រោះ ទើបទ្រង់ឈរលើខ្នងក្រពើនោះ ។ ក្រពើត្រេកអរដោយសោមនស្ស និងដោយកម្លាំងបីតិ ធ្វើនូវឧស្សាហៈទ្វេគុណ ហែលកាត់ខ្សែទឹក នាំព្រះមានព្រះភាគទៅកាន់ត្រើយនាយ ដោយកម្លាំងដ៏រហ័ស ព្រះសាស្ដាពិចារណាចិត្តជ្រះថ្លារបស់ក្រពើហើយទ្រង់ព្យាករថា ក្រពើនេះចុតិអំពីភពនេះហើយកើតក្នុងទេវលោក ចាប់អំពីនេះទៅ អន្ទោលទៅក្នុងសុគតិភពតែម្យ៉ាងនឹងសម្រេចអមតធម៌ក្នុងកប្បទី ៩៤ អំពីកប្បនេះ ដូច្នេះហើយទ្រង់ក៏យាងទៅ ។ កុលបុត្តនោះអន្ទោលទៅមកតែក្នុងសុគតិភពប៉ុណ្ណោះដោយអាការយ៉ាងនោះ ។ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនព្រាហ្មណ៍ម្នាក់ក្នុង

នគរសាវត្ថី មានឈ្មោះថា ឧត្តិយៈ ។

កុលបុត្តនោះចម្រើនវ័យហើយ គិតថា អញនឹងស្វែងរកអមតធម៌ ក៏បួសជាបរិព្វាជក ។ ថ្ងៃមួយ ចូលទៅគាល់ព្រះមានព្រះភាគ ស្តាប់ធម៌ហើយ បួសក្នុងសាសនា មិនអាចញ៉ាំងគុណវិសេសឲ្យកើតឡើងបាន ព្រោះសីលជាដើមមិនបរិសុទ្ធឃើញភិក្ខុដទៃញ៉ាំងគុណវិសេសឲ្យកើត ហើយព្យាករអរហត្តផល ទើបចូលទៅគាល់ព្រះសាស្តា ទូលសូមឱវាទដោយសង្ខេប ។

ព្រះបរមសាស្តា ទ្រង់ក៏ប្រទានឱវាទដល់ព្រះថេរៈដោយសង្ខេបមានពាក្យជាដើមថា ម្នាលឧត្តិយៈ ព្រោះហេតុនោះ ក្នុងធម្មវិន័យនេះ អ្នកចូរជម្រះសីលឲ្យបរិសុទ្ធ ជាខាងដើមនោះឯង ។ លោកតាំងនៅក្នុងឱវាទរបស់ព្រះសាស្តា ប្រារព្ធវិបស្សនា ។ អាពាធកើតឡើងដល់ព្រះថេរៈ ដែលផ្តើមវិបស្សនាហើយ កាលអាពាធកើតឡើង លោកកើតសេចក្តីសង្វេគ ផ្តើមតាំងសេចក្តីព្យាយាម ចម្រើនកម្មដ្ឋានក្នុងវិបស្សនា ខ្វល់ខ្វាយក្នុងវិបស្សនាហើយសម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកចង់ទុកក្នុងអបទានថា

គ្រានោះ ខ្ញុំកើតជាក្រពើនៅនាឆ្នេរស្ទឹងឈ្មោះ ចន្ទភាគា ខ្ញុំកំពុងខ្វល់ខ្វាយរកចំណីដើម្បីខ្លួន ហើយបានទៅកាន់កំពង់ស្ទឹង ។ សម័យនោះ ព្រះសយម្ភូព្រះនាម សិទ្ធត្ថៈ ជាបុគ្គលប្រសើរ ព្រះអង្គមានប្រាថ្នានឹងឆ្លងស្ទឹង ទ្រង់ស្តេច ចូលទៅកាន់កំពង់នៃស្ទឹងនោះ ។ កាលព្រះសម្ពុទ្ធស្តេចមកដល់ហើយ ខ្ញុំក៏ចូលមកដល់ត្រង់កំពង់នោះដែរ លុះចូលមកដល់ហើយបានពោល

វាចានេះនឹងព្រះសម្ពុទ្ធថា បពិត្រព្រះអង្គមានព្យាយាមធំ សូមព្រះអង្គឡើងកាន់ ( ខ្នងរបស់ខ្ញុំ ) ចុះ ខ្ញុំនឹងចម្លងព្រះអង្គ បពិត្រព្រះមហាមុនី សូមព្រះអង្គអនុគ្រោះនូវវិស័យជារបស់នៃបិតាដល់ខ្ញុំ ឲ្យទាន ។ ព្រះមហាមុនិ ទ្រង់ព្រះសណ្ដាប់នូវសម្រេករបស់ខ្ញុំហើយ ស្ដេចឡើងកាន់ ( ខ្នងរបស់ខ្ញុំ ) ខ្ញុំមានចិត្តរីករាយស្រស់ស្រាយ ចម្លងព្រះលោកនាយក ។ ព្រះលោកនាយកព្រះនាម សិទ្ធត្ថៈ ញ៉ាំងខ្ញុំឲ្យស្រស់ស្រាយពួដ៏ត្រើយខាងនាយនៃស្ទឹងនោះថាអ្នកនឹងដល់នូវព្រះនិព្វានឈ្មោះអមតៈ ។ ខ្ញុំច្យុតចាកកាយនោះ បានទៅកាន់ទេវលោក មានពួកស្រីអប្សរចោមរោម សោយសេចក្ដីសុខដ៏ជាទិព្វ ។ ខ្ញុំបានជាធំជាងទេវតា សោយទេវរាជ្យអស់ ៧ ដង ខ្ញុំបានជាស្ដេចចក្រពត្តិជាធំលើផែនដីអស់ ៧ ដង ។ ខ្ញុំប្រកបរឿយៗនូវវិវេក ជាអ្នកមានប្រាជ្ញាចាស់ សង្រួមល្អ ទ្រទ្រង់នូវរាងកាយជាទីបំផុត ក្នុងពុទ្ធសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុ ដែលខ្ញុំបានចម្លងព្រះនរាសភៈក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការចម្លង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផលដោយ

បំណងប្រកាសអាការៈ ដែលបរិបូណ៌ដោយសម្មាបដិបត្តិរបស់ខ្លួន ជាគោល ទើបបានភាសិតគាថាថា

កាលបើអាពាធ កើតឡើងដល់ខ្ញុំ ស្មារតីកើតឡើងដល់ខ្ញុំថា
អាពាធកើតឡើងដល់អញហើយ នេះជាកាលដែលអញមិន
គួរប្រមាទ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អាពាធេ សមុប្បន្នេ** សេចក្ដីថា កាលរោគ ដែលជាហេតុឲ្យធាតុកម្រើក ព្រោះមានចំណែកមិនស្មើគ្នា ដែលបាននាមថា អាពាធ ព្រោះបៀតបៀនសរីរៈក្រៃលែងកើតឡើងហើយដល់ខ្ញុំ ។

បទថា **សតិ មេ ឧបបជ្ជថ** សេចក្ដីថា អាពាធកើតឡើងហើយដល់ខ្ញុំការ ដែលអាពាធកម្រើកឡើងនេះ មានផ្លូវប្រព្រឹត្តទៅបាន ណ្ហើយចុះ អញនឹង ប្រារព្ធព្យាយាម ដរាបណាអាពាធនេះមិនទាន់ខ្លាំង ដើម្បីដល់នូវធម៌ដែលមិន ទាន់បានដល់ ដើម្បីសម្រេចធម៌ដែលមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ ច្បាស់នូវធម៌ដែលមិនទាន់ធ្វើឲ្យជាក់ច្បាស់ ដូច្នេះ សតិដែលជាទីតាំងនៃការ ប្រារព្ធព្យាយាម ក៏កើតឡើងដល់ខ្ញុំដែលទុក្ខវេទនាកំពុងបៀតបៀន ដោយ អំណាចនៃអាពាធនោះឯង ដោយហេតុនោះ ទើបព្រះថេរៈពោលថា អាពាធ កើតឡើងដល់អញហើយ នេះជាកាលដែលអញមិនគួរប្រមាទ ដូច្នេះ ។

ព្រះថេរៈនេះ ធ្វើសតិដែលកើតឡើងយ៉ាងនេះឲ្យដូចជាកង្វេរ ហើយបាន សម្រេចអរហត្ត ដូច្នេះ ។

អដ្ឋកថា ឧត្តិយត្ថេរគាថា ចប់

វគ្គទី ៣ ចប់

# ថេរគាថា ឯកនិបាត

## ចតុត្ថវគ្គ

### គហុរតីរិយត្ថេរគាថា

[ ៣២ ] បុគ្គលដែលត្រូវរបោមនិងមូសខាំក្នុងព្រៃធំ គប្បីជាអ្នកមានសតិ អត់ធ្មត់ក្នុងព្រៃនោះ ដូចដំរីដែលនៅក្នុងចំណោមនៃសង្គ្រាម ។

**គហុរតីរិយត្ថេរ ។**

## វគ្គទី៤

### អដ្ឋកថា

### គហុរតីរិយត្ថេរគាថា

[ ៣២ ] គាថារបស់ព្រះគហុរតីរិយត្ថេរ មានពាក្យផ្តើមថា **ផុដ្ឋោ ឌំសេហិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះមានបុញ្ញាធិការដែលធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ក្នុងកាលរបស់ព្រះមានព្រះភាគព្រះនាមថាសិខី ក្នុងកប្បទី ៣១ រាប់អំពីភទ្ទកប្បនេះ កុលបុត្តនេះជាព្រានម្រឹគត្រាច់ទៅក្នុងព្រៃ បានឃើញព្រះមានព្រះភាគព្រះនាមថាសិខី ទ្រង់សម្តែងធម៌ដល់ទេវតា នាគ និងយក្ខទាំងឡាយត្រង់គល់ឈើមួយដើម កាលឃើញហើយ ក៏មានចិត្តជ្រះថ្លា បានកាន់យកនិមិត្តក្នុងសំឡេងថា នេះហៅថាធម៌ ដោយចិត្តជ្រះថ្លានោះ កុលបុត្តនោះ

កើតក្នុងទេវលោក អន្ទោលទៅមកក្នុងសុគតិភពប៉ុណ្ណោះ ។ ក្នុងពុទ្ធុប្បាទនេះកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងនគរសាវត្ថី មានឈ្មោះថា អគ្គិទត្ត ចម្រើនវ័យហើយ ឃើញបាដិហារ្យរបស់ព្រះមានព្រះភាគ កើតនូវការជ្រះថ្លា បួសក្នុងព្រះសាសនា រៀនកម្មដ្ឋាន នៅក្នុងដងព្រៃឈ្មោះគហុតីរៈ ដោយហេតុនោះ ទើបលោកបានឈ្មោះថា គហុរតីរិយៈ ។

លោកចម្រើនវិបស្សនាហើយ សម្រេចអរហត្ត ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ក្នុងភពមុន ខ្ញុំកើតជាព្រានម្រឹគនៅក្នុងព្រៃធំ ខ្ញុំបានឃើញព្រះសម្ពុទ្ធទ្រង់ប្រាសចាកធូលីមានពួកទេវតាចោមរោមហើយ កំពុងប្រកាសនូវសច្ចៈ ៤ សម្តែងនូវអមតបទ ។ ខ្ញុំបានស្តាប់ធម៌ដ៏ពីរោះ របស់ព្រះពុទ្ធព្រះនាម សិខី ជាផៅពង្សនៃសត្វលោក ។ ខ្ញុំធ្វើចិត្តឲ្យជ្រះថ្លា ក្នុងឃោសសព្ទរបស់ព្រះសិខីសម្ពុទ្ធដែលរកបុគ្គលប្រៀបស្មើមិនមាន ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះអង្គ ហើយបានឆ្លងនូវភព ដែលសត្វហែលឆ្លងបានដោយកម្រ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បាននូវសញ្ញាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃឃោសសញ្ញា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

---

១ - ក្នុងអបទានជាព្រះ ឃោសសញ្ញកត្ថេរ ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ ថ្វាយបង្គំព្រះមានព្រះភាគ បាន ទៅកាន់នគរសាវត្ថី ញាតិទាំងឡាយបានដំណឹងថា លោកមកហើយ នាំគ្នា ចូលទៅរកបំពេញមហាទានហើយ ។ ព្រះថេរៈស្នាក់នៅពីរបីថ្ងៃ បំណងនឹង ត្រឡប់ទៅកាន់ព្រៃនោះទៀត ញាតិទាំងឡាយ បាននិយាយនឹងព្រះថេរៈថា ឈ្មោះថា ព្រៃមានអន្តរាយច្រើន ដោយអំណាចមូសនិងរបោមជាដើម សូម លោកម្ចាស់នៅក្នុងទីនេះឯង ព្រះថេរៈស្តាប់ដូច្នោះហើយ ពោលថា ព្រៃតែ ម្យ៉ាងប៉ុណ្ណោះជាទីពេញចិត្តរបស់អាត្មា កាលនឹងព្យាករអរហត្តផល ដោយ បំណងប្រកាសសេចក្តីត្រេកអរក្នុងវិវេក ទើបបានភាសិតគាថាថា

បុគ្គលដែលត្រូវរបោម និងមូសខាំក្នុងព្រៃធំ គប្បីជាអ្នកមាន
សតិអត់ធ្មត់ ក្នុងព្រៃនោះ ដូចដំរីដែលនៅក្នុងចំណោមនៃ
សង្គ្រាម ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ផុដ្ឋោ ឌំសេតិ មកសេហិ** សេចក្តីថា អ្នក ដែលត្រូវសត្វល្អិតដែលលាក់ខ្លួនក្នុងទីងងឹតដែលបានឈ្មោះថា របោម ព្រោះ ចូលចិត្តខាំនិងសត្វដែលមានមាត់ដូចម្ជុល ដែលគេស្គាល់ថា មូស ប៉ះពាល់ គឺខាំហើយ ។

បទថា **អរញ្ញស្មឹ** សេចក្តីថា ឈ្មោះថា ព្រៃ ព្រោះប្រកបដោយលក្ខណៈ របស់ព្រៃ ដែលលោកពោលទុកថា ឆ្ងាយអំពីស្រុកប្រមាណ ៥០០ ធ្នូរ ។

បទថា **ព្រហាវនេ** សេចក្តីថា ក្នុងព្រៃឈ្មោះថា **ព្រហា** ព្រោះពោរ ពេញដោយដើមឈើធំនិងគុម្ពឈើធំៗជាដើម ។ បទថា **នាគោ សង្គាមសី-**

**សេវ** *សេចក្តីថា ដូចដំរីដ៏ប្រសើរដែលចូលកាន់សង្គ្រាម អត់ធន់ក្នុងការត្រូវអាវុធរបស់ទាហានដែលជាសត្រូវក្នុងសមរភូមិ ។ បុគ្គលកើតឧស្សាហៈថាឈ្មោះថាការនៅព្រៃ បណ្ឌិតទាំងឡាយមានព្រះពុទ្ធជាដើម សរសើរហើយសរសើរទៀត ដូច្នេះ ។ ឈ្មោះថា* **សតោ** *គឺជាអ្នកមានសតិ ។ បទថា* **តត្រ** *គឺក្នុងព្រៃធំនោះ ។ម្យ៉ាងទៀត កាលសម្ផស្សនៃមូសជាដើមនោះប្រាកដហើយ គប្បីអត់ធន់ គឺសង្កត់ចិត្ត បានដល់ អត់ធ្មត់ អធិប្បាយថាមិនគប្បីលះបង់ការនៅព្រៃដោយគិតថារបោមជាដើមបៀតបៀនអញដូច្នេះ ។*

*អដ្ឋកថា គហុរតីរិយត្ថេរគាថា ចប់*

# សុប្បិយត្ថេរគាថា

[ ៣៣ ] បុគ្គលអ្នកចាស់គ្រាំគ្រា បានដល់ព្រះនិព្វាន ជាគុណជាតមិនចាស់គ្រាំគ្រា អ្នកក្តៅក្រហាយ បានដល់ព្រះនិព្វាន ជាគុណជាតិដ៏ត្រជាក់ ជានិរាមិសសុខ ជាគុណជាតស្ងប់រម្ងាប់ដ៏ក្រៃលែង ជាគុណដ៏ប្រសើរ ជាទីក្សេមចាកយោគៈ ។

## សុប្បិយត្ថេរ ។

# អដ្ឋកថា

# សុប្បិយត្ថេរគាថា

[ ៣៣ ] គាថារបស់ព្រះសុប្បិយត្ថេរ មានពាក្យផ្តើមថា **អជរំ ជីរមានេន** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងកាលរបស់ព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈ កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូល បួសជាតាបសនៅក្នុងដងព្រៃ ឃើញព្រះមានព្រះភាគក្នុងដងព្រៃនោះ មានចិត្តជ្រះថ្លា បានថ្វាយផលាផលដល់ព្រះមានព្រះភាគនិងដល់ភិក្ខុសង្ឃ ។

ដោយបុញ្ញកម្មនោះ លោកអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ហើយកើតក្នុងត្រកូលក្សត្រ ក្នុងកាលរបស់ព្រះសម្មាសម្ពុទ្ធ ព្រះនាមថាកស្សបៈ ។ ដល់នូវការដឹងក្តីដោយលំដាប់ បាននូវសេចក្តីសង្វេគ ដោយអាស្រ័យការគប់រកកល្យាណមិត្ត បួសក្នុងព្រះសាសនា បានជាពហុស្សូត ព្រះ

ថេរៈជាអ្នកលើកខ្លួន សង្កត់សង្កិនអ្នកដទៃ ព្រោះស្រវឹងក្នុងជាតិ និងព្រោះស្រវឹងក្នុងសុតៈនោះឯង ។

ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលអ្នកយាមព្រៃខ្មោច ជាត្រកូលដែលមនុស្សសន្មតថាជាត្រកូលអន់ថយ ក្នុងនគរសាវត្ថី ដោយផលនៃកម្មនោះ ។ លោកមានឈ្មោះថាសុប្បិយៈ ដល់នូវភាពជាអ្នកដឹងក្តីហើយ ចូលទៅរកព្រះសោបាកត្ថេរ ដែលជាសម្លាញ់របស់ខ្លួន ស្តាប់ធម៌ក្នុងសម្នាក់នៃព្រះសោបាកត្ថេរនោះហើយ បាននូវសេចក្តីសង្វេគបួសហើយ បំពេញសម្មាបដិបត្តិ បានភាសិតគាថា ថា

បុគ្គលអ្នកចាស់គ្រាំគ្រា បានដល់ព្រះនិព្វាន ជាគុណជាតមិនចាស់គ្រាំគ្រា អ្នកក្តៅក្រហាយ បានដល់ព្រះនិព្វានជាគុណ-ជាតិដ៏ត្រជាក់ ជានិរាមិសសុខ ជាគុណជាតស្ងប់រម្ងាប់ដ៏ក្រៃលែង ជាគុណដ៏ប្រសើរ ជាទីក្សេមចាកយោគៈ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អជរំ** បានដល់ វៀរចាកជរា លោកពោលសំដៅដល់ព្រះនិព្វាន អធិប្បាយថា ព្រះនិព្វាននោះ ឈ្មោះថា មិនចាស់ ព្រោះព្រះនិព្វាននោះ មិនមានកើត មិនមានចាស់ ឬឈ្មោះថា មិនចាស់ ព្រោះហេតុដែលមិនមានការចាស់ ព្រោះកាលបុគ្គលសម្រេចព្រះនិព្វាននោះហើយ ជរានោះ រមែងមិនមាន ។

បទថា **ជីរមានេន** សេចក្តីថា ចាស់ គឺដល់នូវការចាស់គ្រប់ៗខណៈ ។

បទថា **តប្បមានេន** សេចក្តីថា ដុតកិលេសឲ្យក្តៅ គឺញុំាងភ្លើង ១១

កង មានរាគៈជាដើមឲ្យឆេះខ្ទេចខ្ទី ។

បទថា **និព្វុតិ** បានដល់ ព្រះនិព្វានដែលឈ្មោះថា មានការលត់កិលេស ជាសភាវៈ ព្រោះមិនមានការក្តៅក្រហាយ តាមដែលពោលហើយ ។

បទថា **និមិយំ** សេចក្តីថា គប្បីឲ្យប្រព្រឹត្តទៅ គឺគប្បីនិម្មិតឡើង ។

បទថា **បរមំ សន្តិ** សេចក្តីថា ឈ្មោះថា ស្ងប់យ៉ាងក្រៃលែង ព្រោះចូលទៅស្ងប់សេចក្តីក្រវល់ក្រវាយនៃអភិសង្ខារគឺកិលេសដ៏សេស ជាធម្មតា ។ ឈ្មោះថា **យោគក្ខេមំ** ព្រោះមិនត្រូវចងដោយយោគៈទាំង ៤ ។ ឈ្មោះថា **អនុត្តរំ** ព្រោះមិនមានធម៌ដទៃណាមួយក្រៃលែងជាង ។

ក្នុងគាថានេះ មានសេចក្តីសង្ខេបដូចតទៅនេះ បុគ្គលឈ្មោះថា ចាស់ ព្រោះភាពជាបុគ្គលដែលជរាគ្របសង្កត់គ្រប់ៗខណៈ ម្យ៉ាងទៀត ឈ្មោះថា ដល់នូវការជរា ព្រោះត្រូវភ្លើងគឺរាគៈជាដើមដុត ឈ្មោះថា មានឧបទ្ទវៈ ព្រោះភាពជាបុគ្គលមិនចូលទៅស្ងប់រម្ងាប់ ដោយប្រការទាំងពួង ព្រោះការមិនទៀង ជាទុក្ខនិងមិនមានសារៈយ៉ាងនេះ គប្បីនិម្មិតគឺគប្បីញុំាងព្រះនិព្វានដែលឈ្មោះថា មិនចាស់ ព្រោះភាពជាបដិបក្ខចំពោះជរានោះ ដែលជាដែនចូលទៅស្ងប់រម្ងាប់យ៉ាងក្រៃលែង ដែលរបស់ណាមួយ ចូលទៅប្រទូស្តមិនបាន ជារបស់ប្រសើរឲ្យប្រព្រឹត្តទៅ ដោយគិតថា ជាលាភធំ ជាពន្លឺធំ នៅក្នុងកណ្តាប់ដៃរបស់អញហើយហ្ន៎ ។ ប្រៀបដូចមនុស្សទាំងឡាយ ដោះដូរទំនិញណាមួយ មិនដាក់ចិត្ត មិនសម្លឹង រមែងបាននូវទំនិញច្រើនយ៉ាងណា ព្រះថេរៈនេះក៏យ៉ាងនោះ ជាអ្នកមានចិត្តឯក កាលនឹងប្រកាសភាពដែលខ្លួន

មិនសម្ងំក្នុងកាយ និងជីវិតរបស់ខ្លួន និងភាពដែលខ្លួនមានចិត្តស្ទុះទៅកាន់ព្រះនិព្វាន ទើបពោលថា គប្បីសម្រេចនិព្វានដែលមិនមានអាមិស ជាធម៌ស្ងប់ក្រៃលែង ក្សេមចាកយោគៈ ជាធម៌ដ៏កំពូល ដូច្នេះ ចម្រើននូវបដិបទានោះឯង ខ្នះខ្នែងក្នុងវិបស្សនា សម្រេចអរហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលនោះខ្ញុំកើតជាព្រាហ្មណ៍ឈ្មោះវរុណៈ ជាអ្នកដល់ត្រើយនៃមន្ត្របានលះបង់បុត្ត ១០ នាក់ហើយដើរចូលទៅក្នុងព្រៃ ។ ខ្ញុំបានធ្វើអាស្រមដ៏ល្អ បានធ្វើបណ្ណសាលាជាទីរីករាយនៃចិត្តដែលគេចាត់ចែងថ្នាក់យ៉ាងល្អនៅក្នុងព្រៃធំ ។ កាលនោះព្រះបទុមុត្តរសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក គួរទទួលគ្រឿងបូជា ព្រះអង្គ មានសេចក្តីប្រាថ្នាដើម្បីស្រោចស្រង់ខ្ញុំ បានស្តេចមក កាន់អាស្រមរបស់ខ្ញុំ ។ ពន្លឺដ៏ធំទូលាយក្នុងដងព្រៃទាំងប៉ុន្មានក៏កើតមានឡើង កាលនោះព្រៃធំក៏ភ្លឺប្រវាត់ ដោយអានុភាពរបស់ព្រះពុទ្ធ ។ ខ្ញុំឃើញបាដិហារ្យរបស់ព្រះពុទ្ធដ៏ប្រសើរ ព្រះអង្គមិនញាប់ញ័រដោយលោកធម៌ ខ្ញុំយកស្លឹកខ្ចប់ផ្លែឈើហើយរែកដើរមក ។ ខ្ញុំបានចូលទៅរកព្រះសម្ពុទ្ធហើយថ្វាយផ្លែនោះទាំងអម្រែក ព្រះសម្ពុទ្ធទ្រង់អនុគ្រោះដល់ខ្ញុំ ទ្រង់ត្រាស់ព្រះពុទ្ធដីកានេះថា អ្នកចូររែកនូវអម្រែក តាមក្រោយតថាគតមកកាលបើសង្ឃឆាន់ហើយបុណ្យនឹងមានដល់អ្នក ។

ខ្ញុំយកកញ្ចប់នោះប្រគេនភិក្ខុសង្ឃ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះសង្ឃនោះហើយ ក៏បានទៅកើតឯតុសិត ។ ខ្ញុំប្រកបដោយរបាំទិព្វ ចម្រៀងទិព្វ គ្រឿងប្រគំទិព្វក្នុងឋានសួគ៌នោះ ហើយសោយយសបរិវារដោយបុញ្ញកម្មនោះ ។ ខ្ញុំចូលទៅយកកំណើតណាៗ ទោះជាទេវតា ឬជាមនុស្ស ការខ្វះខាតភោគសម្បត្តិរបស់ខ្ញុំមិនមាន នេះជាផលនៃផលទាន ។ ទ្វីបទាំង ៤ ព្រមទាំងសមុទ្ទ និងភ្នំមានត្រឹមណា ខ្ញុំសោយឥស្សរភាពកំណាត់ត្រឹមនោះ ព្រោះថ្វាយនូវផ្លែឈើចំពោះព្រះពុទ្ធ ។ ពួកបក្សីទាំងប៉ុន្មានណា ហើរក្នុងអាកាស បក្សីទាំងនោះតែងលុះក្នុងអំណាចរបស់ខ្ញុំ នេះជាផលនៃផលទាន ។ ពួកយក្ខក្តី ភូតក្តី អារក្សក្តី កុម្ភណ្ឌក្តី គ្រុឌក្តី ទាំងប៉ុន្មានដែលនៅក្នុងជងព្រៃ តែងមកបម្រើខ្ញុំ ។ ពួកអណ្តើក ឆ្កែ ឃ្មុំ របោម មូស សត្វទាំងពីពួកនេះ តែងលុះក្នុងអំណាចរបស់ខ្ញុំ នេះជាផលនៃផលទាន ។ ពួកសត្វស្វាប ឈ្មោះសុបណ្ណ: ជាបក្សីមានកម្លាំងច្រើន សត្វទាំងនោះតែងយកខ្ញុំជាទីពឹង នេះជាផលនៃផលទាន ។ ពួកនាគណាមានអាយុវែង មានឫទ្ធិ មានយសធំ នាគទាំងនោះឯងតែងលុះក្នុងអំណាចរបស់ខ្ញុំ នេះជាផលនៃផលទាន ។ ពួកសត្វសីហ: ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ឆ្កែស្រុក ឆ្កែព្រៃ សត្វទាំងនោះឯងតែងលុះក្នុងអំណាចរបស់ខ្ញុំ

នេះជាផលនៃផលទាន ។ ពួកទេវតាណាដែលឋិតនៅលើដើមឈើនិងស្មៅក្តី ឋិតនៅឰដ៏អាកាសក្តី ទេវតាទាំងអស់នោះឯងតែងយកខ្ញុំជាទីពឹង នេះជាផលនៃផលទាន ។ ខ្ញុំបានសម្រេចធម៌ដែលគេឃើញបានដោយកម្រជាធម៌ល្អិតជ្រាលជ្រៅដែលព្រះពុទ្ធទ្រង់ប្រកាសល្អហើយ នេះជាផលនៃផលទាន ។ ខ្ញុំបានវិមោក្ខ ៨ ជាអ្នកមិនមានអាសវៈ មានព្យាយាមដុតកម្តៅកិលេស មានប្រាជ្ញាចាស់ នេះជាផលនៃផលទាន ។ ពួកពុទ្ធបុត្តណាដែលឋិតនៅក្នុងផល អស់ទោសៈហើយ មានយសច្រើន បណ្តាពុទ្ធបុត្តទាំងនោះ ខ្ញុំក៏ជាពុទ្ធបុត្តមួយដែរ នេះជាផលនៃផលទាន ។ ខ្ញុំបានសម្រេចអភិញ្ញាបារមី ត្រូវកុសលមូលជាស់តឿនហើយ ក៏បានកំណត់ដឹងនូវអាសវៈទាំងអស់ ជាអ្នកមិនមានអាសវៈ ។ ពុទ្ធបុត្តណា មានវិជ្ជា ៣ សម្រេចនូវឫទ្ធិមានយសច្រើន សម្រេចនូវទិព្វសោត បណ្តាពុទ្ធបុត្តទាំងនោះ ខ្ញុំក៏ជាពុទ្ធបុត្តមួយដែរ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

---

១-ក្នុងអបទានជាព្រះ សព្វផលទាយកត្ថេរ ។

ព្រះថេរៈសម្រេចអរហត្តហើយ ក៏បានពោលគាថានោះឯងដដែលទៀត ដោយកាន់យកជាការព្យាករអរហត្តផល ។

## អដ្ឋកថា សុប្បិយត្ថេរគាថា ចប់

## សោបាកត្ថេរគាថា

[ ៣៤ ] បុគ្គលមានសេចក្តីល្អចំពោះបុត្តតែមួយ ជាទីស្រឡាញ់យ៉ាងណា បុគ្គលត្រូវមានសេចក្តីក្រេមក្សាន្ត មានសោត្ថិភាពចំពោះសព្វសត្វ ក្នុងទិសទាំងពួង ក៏ដូច្នោះដែរ ។

សោបាកត្ថេរ ។

## អដ្ឋកថា

## សោបាកត្ថេរគាថា

[ ៣៤ ] គាថារបស់ព្រះសោបាកត្ថេរ មានពាក្យផ្តើមថា **យថាបិ ឯក-បុត្តស្មឹ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថា កកុសន្ធៈ កុលបុត្តនេះកើតជាកុដុម្ពិកៈ ។ ថ្ងៃមួយឃើញព្រះបរមសាស្តា មានចិត្តជ្រះថ្លា បង្អោនផ្លែក្រូចព្រៃចូលទៅថ្វាយដល់ព្រះសាស្តា ។ ព្រះមានព្រះភាគអាស្រ័យសេចក្តីអនុគ្រោះទ្រង់ក៏ទទួល ។ កុលបុត្តមានសេចក្តីជ្រះថ្លាក្រៃលែងក្នុងភិក្ខុសង្ឃ ផ្តើមតាំងសលាកភត្ត ប្រគេនទីភត្តដល់ភិក្ខុ ៣ រូប ដោយតាំងចិត្តឧទ្ទិសជាសង្ឃទានរហូតដល់អស់ជីវិត ។ ដោយបុញ្ញកម្មទាំងនោះ កុលបុត្តនោះសោយសម្បត្តិអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ សម័យមួយ កើតក្នុង

កំណើតមនុស្ស បានថ្វាយវីរកត្តដល់ព្រះបច្ចេកពុទ្ធមួយអង្គ ។ លោកធ្វើបុណ្យច្រើនក្នុងភពនោះៗយ៉ាងនេះ អន្ទោលទៅមកក្នុងសុគតិភពតែម្យ៉ាង ក្នុងពុទ្ធុប្បាទនេះ បដិសន្ធិក្នុងផ្ទៃស្រីទុគ៌តម្នាក់ ក្នុងនគរសាវត្ថី ដោយផលនៃកម្មដែលមានក្នុងកាលមុន ។ មាតារបស់កុលបុត្តនោះបរិហារគភ៌អស់ ១០ ខែ កាលគភ៌ចាស់ដោយជុំវិញ ក្នុងកាលប្រសូត មិនអាចប្រសូតបានក៏សន្ធប់ដូចបុគ្គលស្លាប់ហើយ អស់កាលយូរ ។ ញាតិទាំងឡាយយកនាងទៅកាន់ព្រៃខ្មោច ដោយសម្គាល់ថាស្លាប់ហើយ លើកឡើងដាក់លើជើងថ្ករចៀសចេញទៅហើយ កាលភ្លៀងតាំងឡើងដោយអំណាចរបស់ទេវតាទើបភ្លើងមិនឆេះ ទារកជាអ្នកមិនមានរោគ កើតចាកផ្ទៃមាតាដោយអានុភាពរបស់ទេវតាព្រោះជាបុគ្គលធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តក្នុងភពចុងក្រោយ ឯមាតាធ្វើកាលកិរិយាហើយ ។ ទេវតាបីទារកទៅដាក់ក្នុងផ្ទះរបស់អ្នកថែរក្សាព្រៃខ្មោចដោយភេទរបស់មនុស្ស ចិញ្ចឹមដោយអាហារសមគួរដល់កាលបន្តិចបន្តួច ។ បន្ទាប់ពីនោះ អ្នករក្សាព្រៃខ្មោចក៏ទទួលទារកនោះឲ្យជាកូនរបស់ខ្លួន ចិញ្ចឹមឲ្យធំធាត់ កុលបុត្តនោះចម្រើនធំធាត់យ៉ាងនោះ រត់លេងជាមួយទារកឈ្មោះសុប្បិយៈដែលជាកូនរបស់អ្នករក្សាព្រៃខ្មោច ព្រោះកុលបុត្តនោះធំចម្រើនដឹងក្តីក្នុងព្រៃខ្មោចទើបបានឈ្មោះថា សោបាកៈ ។

ថ្ងៃមួយ ព្រះមានព្រះភាគទ្រង់ផ្សាយសំណាញ់ញាណទៅក្នុងពេលទៀបភ្លឺ ទ្រង់ប្រមើលមើលផៅពង្សរបស់វេនេយ្យសត្វ ទ្រង់ឃើញកុលបុត្តដែលមានអាយុ ៧ ឆ្នាំ ចូលក្នុងសំណាញ់ញាណ ទើបយាងទៅកាន់ព្រៃខ្មោច ។

ទារកកាលបុព្វហេតុជាស់តឿន ក៏ជាអ្នកមានចិត្តជ្រះថ្លាហើយ ចូលទៅគាល់ព្រះបរមសាស្តាថ្វាយបង្គំហើយឈរ ។ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់កុលបុត្តនោះ កុលបុត្តនោះស្តាប់ធម៌ហើយទូលសូមបព្វជ្ជា កាលព្រះបរមសាស្តាសួរថា បិតារបស់អ្នកអនុញ្ញាតហើយឬ ទើបនាំបិតាទៅកាន់សម្នាក់របស់ព្រះសាស្តា ។ ឪពុករបស់កុលបុត្តនោះ ចូលទៅគាល់ព្រះបរមសាស្តា ថ្វាយបង្គំហើយ អនុញ្ញាតថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ញុំាងទារកនេះឲ្យបួសចុះ ។ ព្រះបរមសាស្តា ឲ្យទារកនោះបួសហើយ ទ្រង់ទូន្មានក្នុងមេត្តាភាវនាកម្មដ្ឋាន ។

លោករៀនកម្មដ្ឋាន មានមេត្តាជាអារម្មណ៍នៅក្នុងព្រៃខ្មោច ញុំាងឈានមានមេត្តាជាអារម្មណ៍ឲ្យកើតហើយ ក្នុងកាលមិនយូរប៉ុន្មានធ្វើឈានឲ្យជាបាទចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវអរហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះសម្ពុទ្ធព្រះនាមកកុសន្ធៈ មានព្យាយាមធំ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គទ្រង់ជៀសចេញចាកពួកហើយស្តេចទៅតាមចន្លោះព្រៃ ។ ខ្ញុំយកផ្លែសម៉ពិភេទក៍ដោតនឹងវល្លិសម័យនោះ ព្រះមានព្រះភាគ ទ្រង់ចម្រើនឈានត្រង់ចន្លោះភ្នំ ខ្ញុំបានឃើញព្រះមានព្រះភាគ ជាទេវតាក្រៃលែងជាងទេវតា ក៏មានចិត្តជ្រះថ្លា ហើយថ្វាយផ្លែសម៉ពិភេទក៍ដល់ព្រះអង្គជាអ្នកប្រាជ្ញ ជាទក្ខិណេយ្យបុគ្គល ។ ក្នុងកប្បនេះឯង ព្រោះ

ហេតុដែលខ្ញុំបានថ្វាយផ្លែសម៉ពិភេទក៏ក្នុងកាលនោះខ្ញុំមិនដែល
ស្គាល់ទុគ្គតិ នេះជាផលនៃផ្លែសម៉ពិភេទក៏ ។ កិលេសទាំង-
ឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ
ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

លោកបានជាព្រះអរហន្តហើយ កាលនឹងសម្តែងវិធីនៃការចម្រើនមេត្តា ដល់ភិក្ខុទាំងឡាយដែលមានប្រក្រតីនៅក្នុងព្រៃខ្មោចពួកជរទៃ បានភាសិតគាថាថា

បុគ្គលមានសេចក្តីល្អចំពោះបុត្តតែមួយ ជាទីស្រឡាញ់យ៉ាង
ណា បុគ្គលត្រូវមានសេចក្តីក្សេមក្សាន្តមានសោត្ថិភាពចំពោះ
សព្វសត្វក្នុងទិសទាំងពួង ក៏ដូច្នោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះបទថា **យថា** ត្រឹមតែជានិបាត ចុះក្នុងអត្ថនៃឧបមា ។ បទថា **ឯកបុត្តស្មឹ** សេចក្តីថា ឈ្មោះថា បុត្ត ដោយអត្ថថា ធ្វើឲ្យបរិសុទ្ធ និងធ្វើវង្សត្រកូលឲ្យតាំងនៅបានដល់បុត្តមានបុត្តដែលកើតអំពីទ្រូងជាដើម ។ បុត្តតែមួយ ឈ្មោះថា **ឯកបុត្តោ** ។ ក្នុងបុត្តតែមួយនោះ ។ បទថា **ឯក-បុត្តស្មឹ** នេះ ជាសត្តមីវិភត្តិ ចុះក្នុងវិស័យ គឺអារម្មណ៍ ។

បទថា **បិយស្មឹ** សេចក្តីថា ឈ្មោះថា **បិយស្មឹ** ព្រោះជាអ្នកប្រព្រឹត្តគួរស្រឡាញ់ ព្រោះជាបុត្តតែមួយ និងព្រោះ រូប សីលនិងអាចារជាដើម ។

បទថា **កុសលី** សេចក្តីថា ក្សេម សួស្តី ដែលលោកហៅថា កុសល

---

១-ក្នុងអបទានជាព្រះ វិភេទកពីជិយត្ថេរ ។

បុគ្គលឈ្មោះថា **កុសលី** ព្រោះជាបុគ្គលមានកុសលគប្បីបាន គឺជាអ្នកស្វែងរកប្រយោជន៍ចំពោះសត្វទាំងឡាយ បានដល់ មានអធ្យាស្រ័យប្រកបដោយមេត្តា ។

បទថា **សព្វេសុ ចាណេសុ** បានដល់ ក្នុងសត្វទូទៅ ។ បទថា **សព្វត្ថ** សេចក្តីថា ក្នុងទិសទាំងពួង គឺក្នុងទីទាំងពួង មានភពជាដើម ឬក្នុងទិសទាំងពួង ដែលមិនបានកំណត់ ។ លោកអធិប្បាយថា មាតាបិតា គប្បីជាអ្នកមានមេត្តា គឺគប្បីស្វែងរកប្រយោជន៍ដោយចំណែកមួយ ក្នុងបុត្តតែមួយជាទីស្រឡាញ់ ជាទីពេញចិត្ត យ៉ាងណា ភិក្ខុក៏ដូច្នោះ គប្បីជាអ្នកមានមេត្តា ដោយប្រាថ្នាប្រយោជន៍ដោយចំណែកមួយក្នុងសត្វទូទៅ ដែលមាននៅក្នុងទិសទាំងពួង មានទិសបូព៌ជាដើម ក្នុងភពទាំងពួង មានកាមភពជាដើម និងក្នុងវ័យទាំងពួងមិនមានកំណត់ មានវ័យកំលោះជាដើម គប្បីផ្សាយមេត្តាដែលមានរសតែមួយ ទៅក្នុងទីទាំងពួងដោយមិនបែងចែកជាន់ថ្នាក់ មិនកំណត់ព្រំដែនថាជាមិត្ត ជាមនុស្សកណ្តាល ឬជាសត្រូវ ។ ព្រះថេរៈកាលពោលគាថានេះហើយ បានឲ្យឱវាទថា អាវុសោទាំងឡាយ បើពួកលោកប្រកបរឿយៗនូវមេត្តាភាវនាយ៉ាងនេះ លោកទាំងឡាយនឹងមានចំណែកនៃអានិសង្សរបស់មេត្តា ១១ ប្រការ ដែលព្រះមានព្រះភាគត្រាស់ហើយ ដោយន័យថា ដេកលក់ជាសុខ ដូច្នេះជាដើម ដោយចំណែកមួយ ។

**អដ្ឋកថា សោបាកត្ថេរ[១]គាថា ចប់**

---

១-ព្រះសោបាកៈមាន ២ អង្គ ព្រះសោបាកៈអង្គនេះម្តាយស្លាប់ ចេញបួសតាមធម្មតាឯមួយអង្គទៀតកើតក្នុងត្រកូលចុងភៅ ម្តាយមិនស្លាប់ ចេញបួសដោយឪពុកចងចោលត្រង់ព្រៃខ្មោច ។

## ចោសិយត្ថេរគាថា

[ ៣៥ ] កាលខ្ញុំដឹងច្បាស់អស់កាលជានិច្ច ស្រីទាំងនុ៎ះ ដែលមិននៅជិតប្រសើរ ខ្ញុំចេញអំពីស្រុកទៅកាន់ព្រៃ ចេញអំពីព្រៃនោះមកកាន់ផ្ទះ ក្រោកចេញចាកផ្ទះនោះហើយចៀសចេញទៅ ម្នាលបោសិយៈ អ្នកកុំហៅរក ( ស្រីទាំងនោះទៀតឡើយ ) ។

បោសិយត្ថេរ ។

## អដ្ឋកថា

## ចោសិយត្ថេរគាថា

[ ៣៥ ] គាថារបស់ព្រះបោសិយត្ថេរ មានពាក្យផ្ដើមថា **អនាសន្នវរា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗជាច្រើន អន្ទោលទៅមកតែក្នុងសុគតិភពប៉ុណ្ណោះ ។ ក្នុងកាលរបស់ព្រះពុទ្ធព្រះនាមថា តិស្សៈ ក្នុងកប្បទី ៩២ រាប់អំពីកប្បនេះ កុលបុត្តនេះកើតជាព្រានម្រឹគនៅក្នុងព្រៃ ។

កាលនោះ ព្រះមានព្រះភាគយាងទៅកាន់ព្រៃ ដើម្បីធ្វើសេចក្ដីអនុគ្រោះបង្ហាញព្រះកាយឲ្យប្រាកដក្នុងគន្លងនៃចក្ខុរបស់ព្រាននោះ ព្រានឃើញព្រះមានព្រះភាគមានចិត្តជ្រះថ្លា ដាក់អាវុធចូលទៅគាល់ឈរផ្គងអញ្ជលីហើយ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងបំណាច់នឹងគង់ ព្រាននោះក៏កាន់យកបាច់ស្មៅមក ក្រាលថ្វាយក្នុងទីដែលរាបស្មើដោយសេចក្តីគោរព ។ ព្រះមានព្រះភាគ ទ្រង់អាស្រ័យសេចក្តីអនុគ្រោះទើបគង់ ។ កាលព្រះមានព្រះភាគគង់ហើយ ព្រានព្រៃសោយបីតិនិងសោមនស្សមិនមែនតិច ថ្វាយបង្គំព្រះមានព្រះភាគ ខ្លួនឯងក៏អង្គុយក្នុងចំណែកម្ខាង ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា ពូជគឺកុសលមានប្រមាណប៉ុណ្ណោះ សមគួរដល់ព្រាននេះ ។ ទ្រង់ក្រោកចាកអាសនៈ យាងទៅហើយ ។ កាលព្រះមានព្រះភាគយាងទៅហើយមិនយូរ រាជសីហ៍មួយបានសម្លាប់ព្រាននោះ ។ គាត់ស្លាប់ទៅកើតក្នុងទេវលោក ។ ព្រះមានព្រះភាគទ្រង់ឃើញហេតុការណ៍ថា បើតថាគតមិនចូលទៅរកព្រាន រាជសីហ៍សម្លាប់បុរសនោះហើយ បុរសនោះនឹងធ្លាក់នរក ដូច្នេះ ទើបយាងទៅរកដើម្បីអនុគ្រោះឲ្យកើតក្នុងសុគតិ និងដើម្បីបណ្តុះពូជ គឺ កុសល ។

កុលបុត្តនោះ ស្ថិតនៅក្នុងទេវលោកដរាបដល់អស់អាយុ ចុតិអំពីទេវលោកនោះហើយ អន្ទោលទៅមកក្នុងសុគតិភពប៉ុណ្ណោះ ។ ក្នុងពុទ្ធុប្បាទកាលនេះ កើតជាកូនរបស់សេដ្ឋីដែលមានសម្បត្តិច្រើនក្នុងក្រុងសាវត្ថី ជាប្អូនប្រុសរបស់ព្រះសង្គាមជិតត្ថេរ ។ កុលបុត្តនោះមានឈ្មោះថា ពោសិយៈ ចម្រើនវ័យហើយ មានភរិយា មានកូនប្រុសមួយ កាលបុណ្យដែលធ្វើទុកជាស់តឿន និងព្រោះជាភពចុងក្រោយ ឲ្យកើតសេចក្តីសង្វេគព្រោះជាតិជាដើម បួសហើយចូលកាន់ព្រៃ ជាអ្នកចេញចាកពួកគណៈ ប្រកបរឿយៗនូវ

កម្មដ្ឋានការនាដែលមានចតុសច្ចៈ ៤ ជាអារម្មណ៍ ខ្វល់ខ្វាយក្នុងវិបស្សនា សម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

នៅជិតភ្នំហិមពាន្ត មានភ្នំមួយឈ្មោះលម្ពកៈ ព្រះតិស្សសម្ពុទ្ធស្តេចចង្រ្កមនាទីវាលក្បែរភ្នំនោះ ។ ក្នុងកាលមុន ខ្ញុំកើតជាព្រានម្រឹគនៅក្នុងព្រៃធំ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ជាទេវតាក្រៃលែងជាងទេវតា ខ្ញុំបានថ្វាយស្មៅមួយក្តាប់ ។ លុះខ្ញុំបានថ្វាយស្មៅដល់ព្រះសម្ពុទ្ធដើម្បីគង់ហើយ ញុំាងចិត្តឲ្យជ្រះថ្លា បានថ្វាយបង្គំព្រះសម្ពុទ្ធរួចបែរមុខទៅកាន់ឧត្តរទិសដើរចេញទៅ ។ ស្រាប់តែមានស្តេចម្រឹគមកបៀតបៀនខ្ញុំ ដែលទើបនឹងដើរទៅភ្លាម ខ្ញុំត្រូវសត្វសីហៈបៀតបៀនហើយ ក៏ធ្វើមរណកាលក្នុងទីនោះ ។ អាសន្នកម្មដែលខ្ញុំធ្វើហើយ ចំពោះព្រះសម្ពុទ្ធដ៏ប្រសើរព្រះអង្គមិនមានអាសវៈ ខ្ញុំក៏បានទៅកើតក្នុងទេវលោកដូចកម្ចាំងកូនសរដែលផុតស្រឡះ ( ចាកបំពង់ព្រួញ ) ។ ប្រាសាទដ៏ល្អដែលបុញ្ញកម្មនិម្មិតហើយក្នុងទេវលោកនោះមានកម្ពស់មួយពាន់សន្ទុះព្រួញ មានជាន់ ៧ បរិបូណ៌ដោយទង់បិទបាំងដោយកែវមណីខៀវ ។ ពន្លឺរបស់ប្រាសាទនោះ តែងផ្សាយចេញដូចព្រះអាទិត្យដែលរះឡើង ប្រាសាទនោះកុះករដោយទេវកញ្ញា ខ្ញុំពេញចិត្តរីករាយក្នុងកាម ។ ខ្ញុំច្យុតចាក

ទេវលោក ត្រូវកុសលមូលជាស់តឿន បានមកកាន់អត្តភាព
ជាមនុស្ស ក៏បានដល់នូវការអស់ទៅនៃអាសវៈ ។ ក្នុងកប្បទី
៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកម្រាលអន្ទិយ
ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃស្មៅមួយ
ក្តាប់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំង
សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ មកកាន់នគរសាវត្ថី ដើម្បីថ្វាយបង្គំព្រះមានព្រះភាគ បានទៅកាន់ផ្ទះនៃញាតិ ដើម្បីអនុគ្រោះញាតិ ។ បណ្តាញាតិទាំងនោះ បុរាណទុតិយិកា ថ្វាយបង្គំហើយ ជំបូងសម្តែងវត្តដូចឧបាសិកា ដោយការឲ្យអាសនៈជាដើម ព្រោះមិនដឹងអធ្យាស្រ័យរបស់ព្រះថេរៈមានបំណងលួងលោម ដោយមាយាស្ត្រីជាដើម ក្នុងកាលខាងក្រោយ ។ ព្រះថេរៈគិតថា ឱ ! ស្រីនេះជាអន្ធពាល បដិបត្តិយ៉ាងនេះជាមួយបុគ្គលដូចអញដូច្នេះហើយ មិនពោលចរចា ក្រោកចាកអាសនៈ មានមុខទៅកាន់ព្រៃនោះឯង ។ ភិក្ខុទាំងឡាយដែលនៅក្នុងព្រៃ សួរលោកថា អាវុសោ ហេតុអ្វីលោកត្រឡប់មកឆាប់ម៉្លេះ មិនជួបញាតិឬ ។ ព្រះថេរៈកាលប្រាប់ការប្រព្រឹត្តទៅក្នុងរឿងនោះ បានភាសិតគាថាថា

កាលខ្ញុំដឹងច្បាស់អស់កាលជានិច្ច ស្រីទាំងនុ៎ះដែលមិននៅជិត
ប្រសើរ ខ្ញុំចេញអំពីស្រុកទៅកាន់ព្រៃ ចេញអំពីព្រៃនោះមក

---

១-ក្នុងអបទានជាព្រះ តិណមុដ្ឋិទាយកត្ថេរ ។

កាន់ផ្ទះ ក្រោកចេញចាកផ្ទះនោះហើយចៀសចេញទៅ ម្នាល
បោសិយៈ អ្នកកុំហៅរក (ស្រីទាំងនោះទៀតឡើយ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនាសន្នវរា** សេចក្ដីថា ស្រីទាំងនេះមិនជិតស្និទ្ធ គឺមិនចូលទៅរក ឬនៅឆ្ងាយជាការល្អ គឺប្រសើរ នាំប្រយោជន៍មកឲ្យបុរស ការមិនចូលទៅរកនោះឯង ត្រូវធ្វើជាប្រចាំ គឺសព្វកាល មិនថាពេលយប់ ឬពេលថ្ងៃ ឬក្នុងទីកំបាំង ។

បទថា **វិជានតា** បានដល់ ដឹងច្បាស់ ។ បាលីថា **អនាសន្នបរា** ដូច្នេះក៏មាន ឯសេចក្ដីក៏ដូចគ្នា ។ ក្នុងគាថានេះ មានអធិប្បាយដូច្នេះថា ដំរីសេះ ក្របីព្រៃ រាជសីហ៍ ខ្លាធំ យក្ខ អារក្ខទឹក និងបិសាចសុទ្ធតែជាសត្វកាច មិនចូលទៅជិតល្អជាង គឺប្រសើរជាង មិននាំសេចក្ដីវិនាសមកឲ្យដល់មនុស្សទាំងឡាយ តែសត្វទាំងនោះ កាលចូលទៅជិត គប្បីធ្វើសេចក្ដីវិនាសឲ្យ ក្នុងបច្ចុប្បន្នតែម្យ៉ាងប៉ុណ្ណោះ ឯស្រីទាំងឡាយ ចូលទៅជិតហើយញុំាងប្រយោជន៍ដែលទាក់ទងហើយក្នុងព្រះនិព្វាន ក្នុងបច្ចុប្បន្ននិងខាងមុខឲ្យវិនាស គឺឲ្យដល់នូវការវិនាសធំកន្លង ព្រោះដូច្នោះ កាលខ្ញុំដឹងច្បាស់អស់កាលជានិច្ច ស្រីទាំងនុ៎ះ ដែលមិននៅជិតប្រសើរ ដូច្នេះ ។ ឥឡូវនេះព្រះថេរៈកាលសម្ដែងសេចក្ដីនោះដោយនាំខ្លួនចូលទៅប្រៀបធៀប ទើបពោលពាក្យជាដើមថា **គាមា អរញ្ញមាគម្ម** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **គាមា** ស្មើគ្នានឹង **គាមំ** ប្រែថា កាន់ស្រុក ។ បទនេះជាបញ្ចមីវិភត្តិ ចុះក្នុងអត្ថទុតិយាវិភត្តិ ។

បទថា **អរញ្ញាមាគម្ម** សេចក្តីថា មកអំពីព្រៃ ។ **ម** អក្ខរៈគ្រាន់តែធ្វើការភ្ជាប់បទ ។ បទនេះជាទុតិយាវិភត្តិ ប្រើក្នុងអត្ថបញ្ចមីវិភត្តិ ។

បទថា **តតោ** សេចក្តីថា ក្រោកចាកគ្រែនោះ ។ បទថា **អនាមន្តេត្វា** សេចក្តីថា មិនលា គឺមិនពោលលា មិននិយាយជាមួយកិរិយាចាស់ ដោយត្រឹមតែពាក្យប៉ុណ្ណេះថា ចូរនាងកុំប្រមាទ ដូច្នេះ ។

ព្រះថេរៈនិយាយនឹងខ្លួនឯងថា បោសិយៈ ដូចនិយាយជាមួយអ្នកដទៃៗ អាចារ្យពួកណាសួរថា **បក្កាមិ** ពាក្យប្រកបរបស់អាចារ្យទាំងនោះ គឺខ្ញុំឈ្មោះថាបោសិយៈចៀសចេញទៅហើយ ។ ឯអាចារ្យពួកណាពោលថា ស្រីនោះឲ្យព្រះថេរៈចូលទៅកាន់ផ្ទះ ឆាន់ហើយ បំណងនឹងលួងលោម ព្រះថេរៈឃើញដូច្នោះ ក៏ចេញចាកផ្ទះ ទៅកាន់វិហាររំពេចនោះឯង អង្គុយលើគ្រែក្នុងលំនៅរបស់ខ្លួន ។ សូម្បីស្រីនោះសោត ក៏ប្រដាប់តាក់តែង ចូលទៅកាន់លំនៅរបស់ព្រះថេរៈក្នុងវិហារខាងក្រោយកត្ត ។ ព្រះថេរៈឃើញស្រីនោះហើយ មិនស្តីចរចា ក្រោកឡើងហើយ មានមុខទៅកាន់ទីសម្រាកក្នុងពេលថ្ងៃ មួយរំពេច ដូច្នេះ អត្ថនៃបាទគាថាថា **គាមា អរញ្ញាមាគម្ម** ប្រែថា ខ្ញុំចេញអំពីស្រុក មកកាន់ព្រៃ ទើបចូលគ្នាបានជាមួយពាក្យដែលអាចារ្យទាំងនោះពោល ។ បទថា **អរញ្ញំ** ក្នុងទីនេះ លោកសំដៅដល់វិហារ ។

## អដ្ឋកថា បោសិយត្ថេរគាថា ចប់

# សាមញ្ញកាមិត្ថេរគាថា

[ ៣៦ ] បុគ្គលអ្នកត្រូវការដោយសេចក្ដីសុខ កាលបើប្រតិបត្តិដើម្បីសេចក្ដីសុខនោះ រមែងបានសេចក្ដីសុខ ( មិនត្រឹមតែប៉ុណ្ណោះ ) បុគ្គលណាចម្រើនអរិយមគ្គ ប្រកបដោយអង្គ ៨ ជាមគ្គដ៏ត្រង់ ដើម្បីដល់ព្រះនិព្វានឈ្មោះ អមតៈ បុគ្គលនោះ រមែងបានកិត្តិគុណផង យសក៏ចម្រើនដល់បុគ្គលនោះផង ។

សាមញ្ញកាមិត្ថេរ ។

# អដ្ឋកថា

## សាមញ្ញកាមិត្ថេរគាថា[១]

[ ៣៦ ] គាថារបស់ព្រះសាមញ្ញកាមិត្ថេរ មានពាក្យផ្ដើមថា **សុខំ សុខត្ថោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះជាអ្នកមានអធិការធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសល ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងកាលរបស់ព្រះមានព្រះភាគព្រះនាមថា វិបស្សី ក្នុងកប្បទី ៩១ រាប់អំពីកទ្ទកប្បនេះ កុលបុត្តនេះកើតក្នុងកំណើតមនុស្ស ។ ឃើញព្រះមានព្រះភាគព្រះនាមវិបស្សីហើយ ជាអ្នកមានចិត្តជ្រះថ្លា បានថ្វាយគ្រែមួយ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទ

---

១-បិដកខ្មែរជា សាមញ្ញកាមិត្ថេរ ។

កាលនេះ កើតជាកូនរបស់បរិព្វាជកម្នាក់ មានឈ្មោះថា សាមញ្ញកាមិ ដឹងក្តី ហើយ ឃើញយមកប្បាដិហារ្យរបស់ព្រះសាស្តា មានចិត្តជ្រះថ្លាហើយ បួស ក្នុងសាសនា រៀនកម្មដ្ឋាន ដែលសមគួរដល់ចរិត ញុំាងឈានឲ្យកើតហើយ ធ្វើឈានឲ្យជាបាទ ចម្រើនវិបស្សនា សម្រេចអរហត្តហើយ សមដូចគាថា ព័ន្ធដែលលោកចងទុកក្នុងអបទានថា

ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយបង្គន់[1]មួយដោយដៃរបស់ខ្លួន ចំពោះ ព្រះមានព្រះភាគ ព្រះនាមវិបស្សី ជាច្បងក្នុងលោក ជាតាទិ បុគ្គល ។ ខ្ញុំបានយានដំរី យានសេះ យានទិព្វ ហើយបានទូវធម៌ ជាទីក្ស័យនៃអាសវៈ ដោយសារការថ្វាយនូវបង្គន់នោះ ។ ក្នុង កប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយបង្គន់ ក្នុង កាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបង្គន់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[2]។

ឯបរិព្វាជក ឈ្មោះ កាតិយានៈ ជាសម្លាញ់កាលពីគ្រហស្ថរបស់ព្រះថេរៈ មិនបានត្រឹមតែរបស់បរិកោគនិងគ្រឿងស្លៀកដណ្តប់ ព្រោះតាំងអំពីព្រះមាន ព្រះភាគកើតឡើង ពួកតិរ្ថិយទាំងឡាយ មានលាភនិងសក្ការៈសាបសូន្យ អស់ ចូលទៅរកព្រះថេរៈទាំងភេទជាអាជីវក សួរថា ពួកលោកម្ចាស់ជា

---

១-បិដកខ្មែរបាលីថា វេច្ចំ ប្រែថា បង្គន់ តែក្នុងអដ្ឋកថា បាលីជា មញ្ចំ ទើបលោកប្រែថា គ្រែ បណ្ឌិតគប្បីសម្តែងសេចក្តីនេះតាមការគួរ ។ ២-ក្នុងអបទានជាព្រះ វេច្ចកទាយកត្ថេរ ។

សក្យបុត្ត ដល់នូវភាពជាអ្នកប្រសើរដោយលាភនិងយសយ៉ាងធំ រមែងរស់នៅដោយសេចក្ដីសុខ ឯពួកខ្ញុំផ្ដាក់ខ្លួនក្រៃក្រ មានជីវិតរស់នៅដោយលំបាក សេចក្ដីសុខ ដែលជាបច្ចុប្បន្ន និងសេចក្ដីសុខ ដែលមានក្នុងសម្បរាយភព សម្រេចដល់អ្នកបដិបត្តិដូចម្ដេចហ្ន៎ ។ សម័យនោះ ព្រះថេរៈ ប្រាប់បរិញ្វាជកថា សេចក្ដីសុខដែលជាលោកុត្តរតែម្យ៉ាងប៉ុណ្ណោះ ឈ្មោះថា សុខដោយត្រង់ សុខនោះ នឹងមានដល់អ្នកបដិបត្តិនូវបដិបទាដែលសមគួរ ដល់លោកុត្តរសុខប៉ុណ្ណោះ ដូច្នេះហើយ កាលនឹងប្រកាសភាពដែលលោក បានសម្រេចលោ-កុត្តរសុខនោះហើយ ទើបភាសិតគាថាថា

បុគ្គលអ្នកត្រូវការដោយសេចក្ដីសុខ កាលបើប្រតិបត្តិ ដើម្បី
សេចក្ដីសុខនោះរមែងបានសេចក្ដីសុខ ( មិនត្រឹមតែប៉ុណ្ណោះ )
បុគ្គលណា ចម្រើនអរិយមគ្គប្រកបដោយអង្គ ៨ ជាមគ្គដ៏
ត្រង់ ដើម្បីដល់ព្រះនិព្វាន ឈ្មោះ អមតៈ បុគ្គលនោះរមែង
បានកិត្តិគុណផង យសក៏ចម្រើនដល់បុគ្គលនោះផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុខំ** ក្នុងគាថានេះ លោកបំណងយកសុខដែលជានិរាមិសសុខ ។ និរាមិសសុខនោះ បានដល់ ផលសមាបត្តិនិងព្រះនិព្វាន សមដូចពាក្យដែលលោកពោល ( ទុកក្នុងទសុត្តរសូត្រ ) ថា សមាធិនេះជាសុខក្នុងបច្ចុប្បន្ន នឹងឲ្យផលជាសុខតទៅមុខ ១ ដូច្នេះ និងក្នុងគាថាធម្មបទថា ព្រះនិព្វានជាសុខយ៉ាងក្រៃលែង ដូច្នេះ ។

បទថា **សុខត្ថោ** សេចក្ដីថា មានសុខជាប្រយោជន៍ គឺមានសេចក្ដីត្រូវ

ការដោយសុខតាមដែលពោលហើយ ។

បទថា **លភតេ** សេចក្តីថា រមែងចូលដល់ ។ សេចក្តីសុខនេះនឹងដល់បុគ្គលដែលត្រូវការប៉ុណ្ណោះ មិនដល់បុគ្គលក្រៅអំពីនេះ លោកពោលថា **ត–ធាចរំ** កាលបើប្រតិបត្តិដើម្បីសេចក្តីសុខនោះ ដូច្នេះ ដើម្បីឆ្លើយនឹងសំណួរថា បុគ្គលណាដែលត្រូវការ អធិប្បាយថា អ្នកបដិបត្តិនូវបដិបទានោះ ដោយបដិបទាឯណា ប្រព្រឹត្តដោយអើពើដើម្បីបដិបទានោះ បុគ្គលនោះនឹងបាននូវសេចក្តីសុខដែលសមគួរដល់បដិបទានោះតែម្យ៉ាងក៏មិនមែន ដោយពិតនឹងជួបនូវកិត្តិយសទៀតផង បានដល់ សម្រេចនូវកេរ្តិ៍ឈ្មោះ គឺភាពជាអ្នកមានយសផ្សាយទៅក្នុងទីកំបាំង ដោយន័យជាដើមថា ជាអ្នកមានសីល មានកាយកម្មវចីកម្មបរិសុទ្ធដោយល្អ មានអាជីវៈបរិសុទ្ធដោយល្អ ជាអ្នកមានការសម្លឹងប្រកបដោយឈាន ដោយប្រការដូច្នេះ ។

បទថា **យសស្ស វឌ្ឍតិ** សេចក្តីថា យស ពោល គឺការលើកតម្កើងសរសើរនូវគុណក្នុងទីចំពោះមុខ និងយស ពោលគឺការដល់ព្រមដោយបរិវាររមែងចម្រើនដល់បុគ្គលនោះ ។ ឥឡូវនេះ ព្រះថេរៈ កាលនឹងសម្តែងនូវប្រយោជន៍ដែលពោលដោយពាក្យថា **តធាចរំ** ថាមានដោយទូទៅ ដោយសរុប ទើបពោលថា បុគ្គលណា ចម្រើនអរិយមគ្គប្រកបដោយអង្គ ៨ ជាមគ្គដ៏ត្រង់ដើម្បីដល់ព្រះនិព្វានឈ្មោះអមតៈ ដូច្នេះ ។

សេចក្តីនៃព្រះគាថានោះ មានដូច្នេះថា បុគ្គលណា រមែងចម្រើន គឺឲ្យកើតនិងចម្រើនឡើងក្នុងសន្តានរបស់ខ្លួននូវបដិបទា ដែលជាហេតុឲ្យដល់នូវ

ការរំលត់ទុក្ខដែលឈ្មោះថា **អរិយ** ព្រោះអត្ថថា បរិសុទ្ធ ព្រោះឆ្ងាយចាក កិលេសទាំងឡាយ និងព្រោះអត្ថថា ធ្វើភាពជាអរិយៈដល់អ្នកបដិបត្តិ ឈ្មោះ ថា **អដ្ឋង្គិក** ព្រោះជាទីប្រជុំនៃមគ្គមានអង្គ ៨ មានសម្មាទិដ្ឋិជាដើម ឈ្មោះ ថា **អញ្ជសំ** ដោយអត្ថថា មិនកោង ព្រោះជាបដិបទាកណ្តាល ដែលវៀរ ចាក អន្តធម៌ ២ យ៉ាង ឈ្មោះថា **ឧជុំ** ព្រោះលះនូវការវៀចនៃកាយបាន ជាដើម ឈ្មោះថា **មគ្គំ** ព្រោះអត្ថថា បុគ្គលត្រូវការព្រះនិព្វាន គប្បីដើរទៅ និងព្រោះអត្ថថា សម្លាប់កិលេសផង ដើរទៅផង ដើម្បីដល់ គឺសម្រេចអមត-ធម៌ គឺអសង្ខតធាតុ បុគ្គលនោះ ពោលដោយត្រង់ លោកហៅថា បុគ្គលអ្នក ត្រូវការដោយសេចក្តីសុខ កាលបើប្រតិបត្តិដើម្បីសេចក្តីសុខនោះ រមែងបាន សេចក្តីសុខ ដូច្នេះ ព្រោះហេតុនោះ រមែងបានសេចក្តីសុខតាមដែលពោល ហើយ ។

បរិព្វាជកស្តាប់គាថានោះហើយ មានចិត្តជ្រះថ្លា ទើបចេញបួស បដិបត្តិ ដោយប្រពៃ ចម្រើនវិបស្សនា ហើយសម្រេចអរហត្តក្នុងកាលមិនយូរឡើយ គាថាព័ន្ធនេះឯងបានជាការព្យាករអរហត្តផលរបស់ព្រះថេរៈ ។

## អដ្ឋកថា សាមញ្ញកាមិត្ថេរគាថា ចប់

## កុមារបុត្តត្ថេរគាថា

[ ៣៧ ] ការស្តាប់ជាការល្អ ការប្រព្រឹត្តជាការល្អ ការនៅដោយឥត អាល័យ ( ក្នុងកាមគុណ ) ជាការល្អគ្រប់កាល ការសួរអំពីប្រយោជន៍ អំពើខាងស្តាំ ( ជាការល្អ ) អំពើទាំងនោះ ឈ្មោះថាជាសាមញ្ញផលរបស់ បុគ្គលអ្នកមិនមានកង្វល់ ។

កុមារបុត្តត្ថេរ ។

## អដ្ឋកថា

## កុមារបុត្តត្ថេរគាថា

[ ៣៧ ] គាថារបស់ព្រះកុមារបុត្តត្ថេរ មានពាក្យផ្ដើមថា **សាធុ សុតំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះជាអ្នកមានបុញ្ញាធិការធ្វើទុកហើយ ក្នុងព្រះពុទ្ធ អង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងកប្បទី ៩១ អំពីភទ្ទកប្បនេះ កុលបុត្តនេះ បួសជាតាបស ស្លៀកសំពត់ ស្បែកខ្លា ជាអ្នកនៅក្នុងព្រះរាជឧទ្យានក្នុងពន្ធុមតីនគរ ឃើញព្រះមានព្រះ ភាគព្រះនាមវិបស្សីជាអ្នកមានចិត្តជ្រះថ្លាហើយបានប្រគេនប្រេងសម្រាប់លាប ព្រះបាទ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក តាំងអំពីនោះមក លោកអន្ទោលទៅក្នុងសុគតិភពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូល

គហបតីក្នុងវេឡុកណ្តកនគរដែនអវន្តី ។ មនុស្សទាំងឡាយ បានឲ្យឈ្មោះគាត់ថា នន្ទៈ ឯមាតារបស់នន្ទកុមារនោះ ឈ្មោះថា កុមា ។ ដោយហេតុនោះ ទើបកុលបុត្តនោះប្រាកដឈ្មោះថា កុមាបុត្ត ។ កុលបុត្តនោះ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសារីបុត្ត បាននូវសទ្ធាហើយបួសធ្វើបុព្វកិច្ចស្រេចហើយ បំពេញសមណធម៌ ត្រង់ចុងភ្នំ មិនអាចញ៉ាំងគុណវិសេសឲ្យកើតឡើងបាន ចូលទៅគាល់ព្រះមានព្រះភាគ ស្តាប់ធម៌ជម្រះកម្មដ្ឋានហើយ នៅក្នុងទីដែលសប្បាយ ញ៉ាំងវិបស្សនាឲ្យចម្រើន ធ្វើឲ្យជាក់ច្បាស់នូវអរហត្តសមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំនៅក្នុងព្រះរាជឧទ្យាន ក្បែរក្រុងពន្ធុមតី កាលនោះខ្ញុំស្លៀកសំពត់ស្បែក ទ្រទ្រង់លំក្អចាន់ ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធទ្រង់ប្រាសចាកធូលីគឺកិលេស ជាព្រះសយម្ភូ ទ្រង់ឈ្នះកិលេស មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានព្រះហឫទ័យបញ្ជូនទៅកាន់ព្រះនិព្វាន ទ្រង់ជាឥសី ទ្រង់មានឈាន ត្រេកអរក្នុងឈាន ។ លុះខ្ញុំឃើញព្រះសម្ពុទ្ធទ្រង់សម្រេចសេចក្តីប្រាថ្នាទាំងពួងផងទ្រង់ឆ្លងនូវអន្លង់ទាំងមិនមានអាសវៈផង ក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយថ្នាំបន្តក់ភ្នែក ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃថ្នាំបន្តក់ភ្នែក ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំង

សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ(១) ។

កាលលោកសម្រេចអរហត្តហើយ ឃើញភិក្ខុទាំងឡាយជាច្រើន មានរាងកាយរឹងមាំនៅក្នុងព្រៃ កាលពោលទូន្មានភិក្ខុទាំងនោះ ប្រកាសភាពដែលសាសនាជាសាសនានាំចេញចាកទុក្ខ ទើបបានភាសិតគាថាថា

ការស្តាប់ជាការល្អ ការប្រព្រឹត្តជាការល្អ ការនៅដោយឥតអាល័យ ( ក្នុងកាមគុណ ) ជាការល្អគ្រប់កាល ការសួរអំពីប្រយោជន៍ អំពើខាងស្តាំ ( ជាការល្អ ) អំពើទាំងនោះឈ្មោះថា ជាសាមញ្ញផល របស់បុគ្គល អ្នកមិនមានកង្វល់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សាធុ** ប្រែថា ជាការល្អ ។ បទថា **សុតំ** ប្រែថា ការស្តាប់ ។ ការស្តាប់កថាវត្ថុ ១០ ដែលបដិសំយុត្តដោយភាពជាអ្នកប្រាថ្នាតិចជាដើម ដែលចូលទៅអាស្រ័យព្រះនិព្វាននោះឯង លោកបំណងយកក្នុងគាថានេះ ។

បទថា **សាធុ ចរិតកំ** សេចក្តីថា ការប្រព្រឹត្ត មានការប្រាថ្នាតិចជាដើមនោះឯង ដែលប្រព្រឹត្តហើយ ជាការល្អ អធិប្បាយថា ការប្រព្រឹត្តល្អនោះឯង លោកហៅថា **ចរិតក** ។ ដោយបទទាំង ២ ព្រះថេរៈសម្តែងពាហុសច្ចៈនិងការបដិបត្តិដ៏សមគួរដល់ពាហុសច្ចៈនោះថាជាការល្អ ។

បទថា **សទា** សេចក្តីថា ក្នុងកាលទាំងពួង គឺក្នុងកាលដែលជាព្រះ-

---

១-ក្នុងអបទានជាព្រះ អព្ពញ្ជនទាយកត្ថេរ ។

នវក មជ្ឈិម និងថេរៈ ឬក្នុងខណៈនៃឥរិយាបថទាំងពួង ។

បទថា **អនិកេតវិហារោ** សេចក្ដីថា កាមគុណ ៥ ឬធម៌គឺអារម្មណ៍ ៦ ដែលជាលោកិយ ឈ្មោះថា **និកេត** ( ការហួងហែង ) ព្រោះអត្ថថា ជាទីតាំង ជាទីនៅអាស្រ័យនៃកិលេសទាំងឡាយ ដូចលោកពោលទុក ( ក្នុងសំយុត្តនិកាយខន្ធវារវគ្គ ) ថា ម្នាលគហបតី បុគ្គលដែលហៅថា មានការអន្ទោលទៅរកកន្លែងស្នាក់ ព្រោះការផ្សាយទៅនិងការជាប់ចំពាក់នៃកិលេសដែលកើតឡើងក្នុងកន្លែងស្នាក់គឺរូបនិមិត្ត ដូច្នេះជាដើម ។ បដិបទាដើម្បីលះនូវការជាប់ជំពាក់ទាំងនោះ ឈ្មោះថា ការនៅដោយឥតអាល័យ ( ក្នុងកាមគុណ ) ។

បទថា **អត្ថបុច្ឆនំ** សេចក្ដីថា ការសួររបស់បុគ្គលដែលចង់ដឹងសេចក្ដីនោះ ចូលទៅរកកល្យាណមិត្ត ហើយសួរដល់ប្រយោជន៍ មានទិដ្ឋធម្មិកត្ថ-ប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍ ឬដោយការសួរដល់ប្រយោជន៍របស់សភាវធម៌ មានកុសលជាដើម ដោយន័យ ( ក្នុងចូឡកម្មវិភង្គសូត្រ ) ថា បពិត្រលោកដ៏ចម្រើន អ្វីជាកុសល អ្វីជាអកុសល អ្វីមានទោស អ្វីឥតទោស ដូច្នេះជាដើម ឈ្មោះថា ការសួរអំពីប្រយោជន៍ ។

បទថា **បទក្ខិណកម្មំ** សេចក្ដីថា កាលសួរដល់វត្ថុជាប្រយោជន៍នោះហើយ តាំងនៅក្នុងឱវាទលោកដោយគោរព ឈ្មោះថា ជាការបដិបត្តិប្រពៃ ។ ត្រង់នេះគប្បីនាំពាក្យថា **សាធុ** មកប្រកបចូលផង ។

បទថា **ឯតំ សាមញ្ញំ** សេចក្ដីថា ការស្ដាប់ណាដែលលោកពោលទុក

ដោយន័យជាដើមថា **សាធុ សុតំ** ដូច្នេះក្តី ការប្រព្រឹត្តប្រាថ្នាតិចណាក្តី ការនៅដោយមិនមានការអាឡោះអាល័យក្តី ការសួរដល់វត្ថុដែលជាប្រយោជន៍ក្តី ការធ្វើតាមឱវាទ ដោយគោរពណាក្តី នេះជាគ្រឿងសម្គាល់របស់សមណៈ គឺប្រារព្ធដល់ភាពជាសមណៈ ។ ព្រោះភាពជាសមណៈ រមែងមានដោយបដិបទានេះប៉ុណ្ណោះ មិនមានដោយបដិបទាដទៃ ដូច្នោះ បទថា **សាមញ្ញំ** ជាឈ្មោះនៃមគ្គនិងផលដោយត្រង់ ។

ម្យ៉ាងទៀត បដិបទានេះ ឈ្មោះថា អបណ្ណកប្បដិបទា គឺបដិបត្តិមិនខុសសម្រាប់ភិក្ខុនោះ ។ គុណគឺគ្រឿងសម្គាល់របស់ភាពជាសមណៈនេះរមែងកើតមានដល់ភិក្ខុណា ដើម្បីសម្តែងភិក្ខុនោះ ទើបលោកពោលថា **អកិញ្ចនស្ស** គឺជាអ្នកមិនមានកង្វល់ ដូច្នេះ អធិប្បាយថា ដល់បុគ្គលមិនចូលទៅប្រកាន់ គឺដល់បុគ្គលដែលវៀរចាកការប្រកាន់ ការហួងហែងនូវសម្បត្តិ មានស្រែ ចម្ការ ប្រាក់ មាស ទាសី និងទាសា ជាដើម ។

អដ្ឋកថា កុមាបុត្តត្ថេរគាថា ចប់

## កុមារបុត្តសហាយត្ថេរគាថា

[ ៣៨ ] ពួកភិក្ខុកាលត្រាច់ចរ ដើរជាសទៅកាន់ជនបទផ្សេងៗ ឈ្មោះថាជាអ្នកមិនសង្រួមផង រមែងញុំាងសមាធិឲ្យភ្លាត់ផង ការត្រាច់ទៅក្នុងដែននឹងធ្វើប្រយោជន៍អ្វីកើត ។ ព្រោះហេតុនោះ បុគ្គលនោះគប្បីបន្ទោបង់នូវសារម្ភកិលេស គប្បីរំពឹង ( ក្នុងកម្មដ្ឋាន ) ធ្វើកុំឲ្យឧបក្កិលេសតាំងនៅជាប្រធានបានឡើយ ។

*ព្រះថេរៈជាសំឡាញ់របស់កុមារបុត្តត្ថេរ ។*

---

## អដ្ឋកថា

## កុមារបុត្តសហាយត្ថេរគាថា

[ ៣៨ ] គាថារបស់ព្រះកុមារបុត្តសហាយត្ថេរ មានពាក្យផ្ដើមថា **ឆាឆាជនបទំ យន្តិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះមានបុញ្ញាធិការធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថា សិទ្ធត្ថ ក្នុងកប្បទី ៩៤ រាប់អំពីភទ្ទកប្បនេះកើតក្នុងផ្ទះមានត្រកូល ចូលដល់ភាពជាអ្នកដឹងក្ដីហើយ ចូលទៅកាន់ព្រៃ កាប់កំណាត់ឈើជាច្រើន ធ្វើឈើប្រចត់ប្រគេនសង្ឃ ។ កុលបុត្តនោះធ្វើបុណ្យតាមសមគួរដល់សម្បត្តិដទៃ ហើយកើតក្នុងពួកទេវតា តាំងអំពីនោះមកក៏អន្ទោល

ទៅមកក្នុងសុគតិតែម្យ៉ាងប៉ុណ្ណោះ ។ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលដែលស្តុកស្តម្ភក្នុងវេឡុកណ្ដកនគរ មានឈ្មោះថា សុទន្ត ។ អាចារ្យពួកខ្លះហៅថា វាសុលៈ ។ កុលបុត្តនេះជាសម្លាញ់ស្និទ្ធស្នាលក្រៃលែងរបស់ព្រះកុមារបុត្តត្ថេរ ធ្លាប់ដើរលេងជាមួយគ្នា ដឹងថាកុមារបុត្តបួសហើយជាអ្នកមានបំណងចង់បួសដែរ ព្រោះធ្លាប់ស្និទ្ធស្នាលនិងធ្លាប់ជាសម្លាញ់ជាមួយព្រះកុមារបុត្ត គិតថា កុមារបុត្តបួសហើយក្នុងព្រះធម្មវិន័យណា ព្រះធម្មវិន័យនោះ មាំទាំដោយពិត ទើបចូលទៅគាល់ព្រះបរមសាស្តា ។ ព្រះមានព្រះភាគទ្រង់សម្តែងធម៌ដល់មាណពនោះ គាត់មានឆន្ទៈក្នុងបព្វជ្ជាពន់ប្រមាណ បួសហើយជាអ្នកខ្វល់ខ្វាយក្នុងភាវនា នៅខាងចុងភ្នំជាមួយកុមារបុត្តត្ថេរនោះឯង ។ ដោយសម័យនោះ ភិក្ខុច្រើនរូបត្រាច់ចារិកទៅកាន់ជនបទផ្សេងៗ ទៅខ្លះ មកខ្លះ ចូលដល់ទីនោះហើយ ដោយហេតុនោះ ទើបកើតកោលាហលត្រង់ចុងភ្នំនោះ ។ ព្រះសុទន្តត្ថេរឃើញដូច្នោះ ក៏កើតសេចក្តីសង្វេគថា ភិក្ខុទាំងនេះបួសក្នុងសាសនាដែលជានិយ្យានិកធម៌ បែរជាទៅត្រេកអរក្នុងជនបទ ធ្វើចិត្តដែលជាសមាធិឲ្យឃ្លៀងឃ្លាត ធ្វើនូវសេចក្តីសង្វេគនោះឯងឲ្យជាកង្វែរ គឺគ្រឿងទូន្មានចិត្តរបស់ខ្លួន បានភាសិតគាថាថា

ពួកភិក្ខុកាលត្រាច់ចរដេរដាស ទៅកាន់ជនបទផ្សេងៗ ឈ្មោះ
ថាជាអ្នកមិនសង្រួមផង រមែងញុំាងសមាធិឲ្យភ្លាត់ផង ការ
ត្រាច់ទៅក្នុងដែន នឹងធ្វើប្រយោជន៍អ្វីកើត ។ ព្រោះហេតុនោះ
បុគ្គលនោះគប្បីបន្ទោបង់នូវសារម្ភកិលេស គប្បីរំពឹង ( ក្នុង

កម្មដ្ឋាន ) ធ្វើកុំឲ្យឧបក្កិលេសតាំងនៅជាប្រធានបានឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **នានាជនបទំ** បានដល់ ជនបទដែលផ្សេងគ្នា មានលក្ខណៈផ្សេងគ្នា អធិប្បាយថា មានច្រើនដែន ដូចជាដែនកាសី និងដែនកោសលជាដើម ។

បទថា **យន្តិ** បានដល់ រមែងទៅ ។ បទថា **វិចរន្តា** សេចក្ដីថា ត្រាច់ចារិកទៅកាន់ជនបទដោយអំណាចនៃវិតក្ក មានជាដើមថា ជនបទនោះរកភិក្ខាបានងាយ រកបិណ្ឌបាតបានងាយ ជនបទនោះ ជាជនបទផុតភ័យ មិនមានរោគ ។

បទថា **អសញ្ញតា** សេចក្ដីថា មានចិត្តមិនសង្រួមហើយ ព្រោះលះមិនបាននូវវិតក្កក្នុងជនបទនោះឯង ។

បទថា **សមាធិញ្ច វិរាធេន្តិ** សេចក្ដីថា បើឈ្មោះថា ញុំាងសមាធិ មានឧបចារសមាធិ និងអប្បនាសមាធិ ដែលជាបាទរបស់ឧត្តរិមនុស្សធម៌ទាំងពួងឲ្យឃ្លៀងឃ្លាត ។ ច សព្ទ ប្រើក្នុងអត្ថនៃសម្ភាវនៈ ( ការសរសើរ ) ។ កាលមិនបានសម្រេចសមាធិដែលមិនទាន់បានសម្រេច ព្រោះមិនមានឱកាសដើម្បីសម្ងំដោយរវល់ត្រាច់ទៅរវាងប្រទេស នឹងធ្វើសមាធិដែលដល់ហើយឲ្យវិនាសទៅ ព្រោះមិនធ្វើឲ្យកើតនូវការជំនាញឈ្មោះថាធ្វើឲ្យឃ្លៀងឃ្លាត ។

បទថា **សុ** ក្នុងបាទគាថាថា **កឹសុ រដ្ឋចរិយា ករិស្សតិ** ត្រឹមតែជានិបាត ។ ព្រះថេរៈកាលតិះដៀលថា កាលត្រាច់ទៅកាន់ដែន គឺត្រាច់ទៅ

តាមជនបទរបស់ភិក្ខុយ៉ាងនេះនឹងធ្វើអ្វីបានគឺនឹងញ៉ាំងប្រយោជន៍អ្វីឲ្យសម្រេច ព្រោះជារបស់ឥតប្រយោជន៍ ។

បទថា **តស្មា** សេចក្តីថា ព្រោះការត្រាច់ទៅកាន់ប្រទេសដទៃបែបនេះ រមែងមិននាំប្រយោជន៍មកឲ្យដល់ភិក្ខុ ថែមទាំងឈ្មោះថា នាំមកនូវការវិនាស ដោយពិត ព្រោះធ្វើឲ្យឃ្លាតចាកសម្បត្តិទាំងឡាយ ។

បទថា **វិនេយ្យ សារម្ភំ** សេចក្តីថា កម្ចាត់ គឺចូលទៅស្ងប់រម្ងាប់នូវការប្រណាំងប្រជែង បានដល់ ការសៅហ្មងនៃចិត្តដែលកើតឡើងដោយអំណាចនៃសេចក្តីត្រេកអរក្នុងលំនៅ ដោយការពិចារណាដ៏សមគួរដល់ការសៅហ្មងនៃចិត្តនោះ ។

បទថា **ឈាយេយ្យ** សេចក្តីថា គប្បីសម្លឹងដោយឈានទាំង ២ យ៉ាង គឺអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ។

បទថា **អបុរក្ខតោ** សេចក្តីថា មិនព្រមឲ្យមិច្ឆាវិតក្ក ឬកិលេស មានតណ្ហាជាដើមគ្របសង្កត់បាន អធិប្បាយថា មិនចូលទៅកាន់អំណាចនៃកិលេសទាំងនោះ គប្បីធ្វើទុកក្នុងចិត្តចំពោះកម្មដ្ឋានតែម្យ៉ាង ។

ព្រះថេរៈកាលពោលយ៉ាងនេះហើយ ធ្វើនូវសេចក្តីសង្វេគនោះឯងឲ្យជាកង្វេរ ចម្រើនវិបស្សនាសម្រេចអរហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលនោះខ្ញុំដើរចូលទៅក្នុងព្រៃធំ បានកាប់ឫស្សីធ្វើជាបង្កាន់ដៃ ប្រគេនដល់ព្រះសង្ឃ ។ ខ្ញុំថ្វាយបង្គំនូវព្រះសង្ឃមានវត្ត

ដោយចិត្តជ្រះថ្លានោះ លុះខ្ញុំប្រគេនកំណាត់ឫស្សីបង្កាន់ដៃរួច ហើយ ក៏បែរមុខឆ្ពោះទៅកាន់ឧត្តរទិស ដើរចេញទៅ ។ ក្នុង កប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយកំណាត់ ឫស្សី ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃ ការឲ្យកំណាត់ឫស្សី ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។ បេ ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ(១) ។

ព្រះថេរៈនេះ ធ្វើអត្ថណាឲ្យជាកង្វេរ គឺគ្រឿងទូន្មាន សម្រេចអរហត្ត ហើយ តាំងចិត្តចំពោះអត្ថនេះប៉ុណ្ណោះ លុះសម្រេចអរហត្តហើយ ក៏បានពោល គាថានេះដដែលទៀតថា **នានាជនបទំ យន្តិ** ដូច្នេះជាដើម ព្រោះដូច្នោះ ការ ពោលនោះឯង ទើបជាការព្យាករអរហត្តរបស់ព្រះថេរៈនោះ ដូច្នេះ ។

## អដ្ឋកថា កុមារបុត្តសហាយត្ថេរគាថា ចប់

១-ក្នុងអបទានជាព្រះ ទណ្ឌទាយកត្ថេរ ។

## គវម្បតិត្ថេរគាថា

[ ៣៩ ] ភិក្ខុណាបង្អិលទន្លេសរភូ ដោយឫទ្ធិបាន ភិក្ខុនោះ គឺគវម្បតិ ជាអ្នកមិនអាស្រ័យ មិនញាប់ញ័រ ( ដោយតណ្ហានឹងទិដ្ឋិ ) ទេវតាទាំងឡាយ តែងនមស្ការនូវព្រះថេរៈនោះ ថាជាមហាមុនី ជាអ្នកកន្លងនូវសង្គធម៌ទាំងពួង ជាអ្នកដល់នូវត្រើយនៃភព ។

**គវម្បតិត្ថេរ ។**

## អដ្ឋកថា

## គវម្បតិត្ថេរគាថា

[ ៣៩ ] គាថារបស់ព្រះគវម្បតិត្ថេរ មានពាក្យផ្ដើមថា **យោ ឥទ្ធិយា សរភុំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ ក្នុងកប្បទី ៣១ រាប់ថយក្រោយអំពីកប្បនេះ កុលបុត្តនេះបានឃើញព្រះពុទ្ធព្រះនាមថាសិខី មានចិត្តជ្រះថ្លា ធ្វើការបូជាដោយផ្កា ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក ធ្វើបុណ្យច្រើនយ៉ាង បានសាងឆត្រនិងវេទិកា ( ខឿន ) បូជាត្រង់ព្រះចេតិយរបស់ព្រះមានព្រះភាគ ព្រះនាមជាកោនាគមនៈ ។ ក្នុងពុទ្ធុប្បាទនៃព្រះមានព្រះភាគព្រះនាមថា កស្សបៈ កុលបុត្តនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ត្រកូលនោះមានហ្វូងគោជាច្រើន ពួកនាយគោបាលក៏រក្សាហ្វូងគោនោះ មាណពនេះ ដើរមើលកិច្ចការដែលពួក

នាយគោបាលខ្វល់ខ្វាយធ្វើហើយ ក្នុងហ្វូងគោនោះ ។ កុលបុត្តនោះឃើញព្រះថេរៈដែលជាខីណាស្រពមួយរូប ត្រាច់បិណ្ឌបាតក្នុងស្រុក ហើយធ្វើភត្តកិច្ចក្រៅស្រុក ក្នុងប្រទេសមួយកន្លែងរាល់ៗថ្ងៃ គិតថា លោកម្ចាស់លំបាកព្រោះត្រូវកម្តៅរបស់ថ្ងៃ ដូច្នេះ ទើបបោះសសរដើមប្រេស ៤ ដើម ហើយយកមែកប្រេស ៤ មែកដាក់លើសសរនោះ ធ្វើជាសាខាមណ្ឌប ( មណ្ឌបមែកឈើ ) ប្រគេនព្រះថេរៈ ។ អាចារ្យពួកខ្លះពោលថា កុលបុត្តនោះដាំដើមប្រេសក្បែរមណ្ឌបនោះ ។ ដើម្បីអនុគ្រោះកុលបុត្តនោះ ព្រះថេរៈក៏អង្គុយក្រោមដើមប្រេសនោះរាល់ៗថ្ងៃ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះចុតិចាកមនុស្សលោកនេះហើយ កើតក្នុងវិមានជាន់ចាតុម្មហារាជិកា ។

ព្រៃប្រេសធំដែលសបញ្ជាក់ដល់កម្មចាស់របស់កុលបុត្តនោះ កើតក្នុងទីជិតទ្វារវិមាន មានផ្កាដទៃដែលសម្បូរដោយពណ៌ និងក្លិនចូលទៅបន្ថែមនូវលម្អគ្រប់រដូវកាល ដោយហេតុនោះ ទើបវិមាននោះ ប្រាកដនាមថា សេរីសកវិមាន ។ ទេវបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ អស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទនេះ កើតជាកុលបុត្តឈ្មោះគវម្បតិ ក្នុងបណ្តាសម្លាញ់ដែលជាគ្រហស្ថទាំង ៤ របស់ព្រះយសត្ថេរ ( យសកុលបុត្ត ) បានឮថាព្រះយសបួសហើយ បានទៅកាន់សម្នាក់របស់ព្រះមានព្រះភាគ មួយអន្លើដោយសម្លាញ់របស់ខ្លួន ព្រះសាស្តាទ្រង់សម្តែងធម៌ដល់កុលបុត្តនោះហើយ ក្នុងកាលចប់ព្រះធម្មទេសនា កុលបុត្តនេះតាំងនៅក្នុងអរហត្តផល មួយអន្លើ

ដោយសម្មាញទាំងឡាយ សមដូចគាថាព័ន្ធដែលលោកចងទុក ក្នុងអបទាន ថា

ក្នុងភពមុន ខ្ញុំកើតជាព្រានម្រឹគ ត្រាច់ទៅក្នុងព្រៃបានឃើញ ព្រះសម្ពុទ្ធទ្រង់ប្រាសចាកធូលីដល់នូវត្រើយនៃធម៌ទាំងពួង ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយចំពោះព្រះសម្ពុទ្ធ ព្រះអង្គប្រកបដោយសេចក្តីករុណា ត្រេកអរចំពោះប្រយោជន៍របស់សព្វសត្វ ហើយបានបូជាផ្កាអញ្ចាញទៀត ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈ កាលសម្រេចអរហត្តហើយ សោយវិមុត្តិសុខក្នុងអញ្ជនវ័ន ក្រុងសាកេត ។ ដោយសម័យនោះ ព្រះមានព្រះភាគ មួយអន្លើដោយភិក្ខុសង្ឃយាងដល់ក្រុងសាកេត ហើយគង់នៅក្នុងអញ្ជនវិហារ សេនាសនៈមិនគ្រប់គ្រាន់ ភិក្ខុជាច្រើនសិងត្រង់ផ្នូកខ្សាច់ ក្បែរមាត់ស្ទឹងសរភូ ជិតព្រះវិហារ គ្រានោះ មានជំនន់ទឹកហូរមកក្នុងកណ្តាលយប់ ពួកសាមណេរជាដើម ក៏ស្រែកខ្ញៀវខ្ញារ ។ ព្រះមានព្រះភាគទ្រង់ជ្រាបហេតុនោះហើយ ទ្រង់ត្រាស់នឹងព្រះគវម្បតិថា ម្នាលគវម្បតិ ចូរអ្នកឃាត់ជំនន់ទឹក ធ្វើឲ្យភិក្ខុទាំងឡាយ

១-ក្នុងអបទានជាព្រះ គិរិនេលកបូជកត្ថេរ ។

មានសេចក្ដីសុខ ព្រះថេរៈទទួលព្រះពុទ្ធតម្រាស់ថា សាធុ ហើយក៏ឃាត់ជំ-នន់ទឹកឲ្យឈប់ដោយកម្លាំងឫទ្ធិ ជំនន់ទឹកបានឈប់ តាំងនៅដូចកំពូលភ្នំអំពីចម្ងាយនោះឯង តាំងអំពីនោះមក អានុភាពរបស់ព្រះថេរៈ ក៏បានប្រាកដក្នុងលោក ។ ថ្ងៃមួយ ព្រះបរមសាស្ដាទតឃើញព្រះថេរៈអង្គុយសម្ដែងធម៌ត្រង់កណ្ដាលទេវបរិស័ទជាច្រើន កាលទ្រង់សរសើរព្រះថេរៈ ដើម្បីប្រកាសគុណរបស់ព្រះថេរៈ ដោយអនុគ្រោះសត្វលោក ទើបទ្រង់ភាសិតគាថាថា

> ភិក្ខុណាបង្ហិលទន្លេសរភូ ដោយឫទ្ធិបាន ភិក្ខុនោះគឺគវម្បតិជា
> អ្នកមិនអាស្រ័យ មិនញាប់ញ័រ ( ដោយតណ្ហា និងទិដ្ឋិ )
> ទេវតាទាំងឡាយ តែងនមស្ការនូវព្រះថេរៈនោះថាជាមហាមុនី
> ជាអ្នកកន្លង នូវសង្គធម៌ទាំងពួង ជាអ្នកដល់នូវត្រើយនៃភព
> ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥទ្ធិយា** បានដល់ ឫទ្ធិដែលសម្រេចដោយអធិដ្ឋាន ។ បទថា **សរភុំ** បានដល់ ស្ទឹងដែលមានឈ្មោះយ៉ាងនេះថា សរភូ តាមដែលសត្វលោកតែងហៅ ។ បទថា **អដ្ឋបេសិ** សេចក្ដីថា ឃាត់មិនឲ្យហូរ គឺឲ្យហូរត្រឡប់ ឲ្យតាំងនៅជាគំនរទឹកធំ ដូចកំពូលភ្នំ ។

បទថា **អសិតោ** កាត់បទជា **ន សិតោ** ប្រែថា មិនជាប់ គឺព្រះថេរៈគវម្បតិនោះ វៀរចាកកិលេសដែលជាទីអាស្រ័យ គឺតណ្ហានិងទិដ្ឋិ ឬមិនជាប់ជំពាក់ដោយកិលេសជាគ្រឿងជាប់ជំពាក់ណាមួយ ព្រោះដកនូវសំយោជនៈពោលគឺ កិលេសជាគ្រឿងជាប់ជំពាក់ទាំងអស់បាន បន្ទាប់អំពីនោះ ក៏ជា

បុគ្គលឈ្មោះថា ជាអ្នកមិនញាប់ញ័រ ព្រោះមិនមានកិលេសដែលជាគ្រឿងញាប់ញ័រទាំងឡាយ ទេវតានិងមនុស្សទាំងពួង ក៏នាំគ្នានមស្ការព្រះគវម្បតិដែលឆ្លងផុតកិលេសជាគ្រឿងជាប់ជំពាក់ទាំងពួងបែបនោះ គឺឈ្មោះថា ជាអ្នកកន្លងនូវសង្គធម៌ទាំងពួង ព្រោះឈានកន្លងនូវធម៌ ដែលជាគ្រឿងជាប់ជំពាក់ គឺរាគៈ ទោសៈ មោហៈ មានះនិងទិដ្ឋិបាន ហើយតាំងនៅ ឈ្មោះថា ជាមហាមុនី ព្រោះជាមុនីដែលជាអសេក្ខៈ បន្ទាប់អំពីនោះ ឈ្មោះថា ជាអ្នកដល់នូវត្រើយនៃភព ព្រោះដល់នូវព្រះនិព្វានដែលជាត្រើយនៃភពទាំងមូល មានកាមភពនិងកម្មភពជាដើម ។ បទថា **ទេវា នមស្សន្តិ** សេចក្តីថា សូម្បីទេវតាទាំងឡាយ គង់នមស្ការ នឹងពោលទៅថ្វីដល់សត្វក្រៅអំពីនេះ ។

ក្នុងកាលចប់គាថា ធម្មាភិសម័យ មានដល់មហាជន ។ ព្រះថេរៈកាលគ្រាព្យាករអរហត្តផល ក៏បានពោលគាថានេះឯង ដោយគិតថា អញនឹងបូជាព្រះសាស្តាដូច្នេះ ។

## អដ្ឋកថា គវម្បតិត្ថេរគាថា ចប់

## តិស្សត្ថេរគាថា

[ ៤០ ] ភិក្ខុអ្នកមានស្មារតី កាលបើក្តៅក្រហាយ ( ដោយភ្លើងទុក្ខ ភ្លើងកិលេស ) ដូចបុគ្គលដែលគេចាក់ដោយលំពែងត្រង់ក្បាល គប្បីវៀរស្រឡះ ដើម្បីលះបង់កាមរាគៈចេញ ។

**តិស្សត្ថេរ ។**

## អដ្ឋកថា

## តិស្សត្ថេរគាថា

[ ៤០ ] គាថារបស់ព្រះតិស្សត្ថេរ មានពាក្យផ្តើមថា **សត្តិយា វិយ ឱមដ្ឋោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះថេរៈនេះ ជាអ្នកមានអធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ នាំចេញនូវស្លឹកឈើចាស់ៗ ត្រង់គល់ឈើដែលជាទីត្រាស់ដឹងរបស់ព្រះមានព្រះភាគព្រះនាមថាតិស្សៈ ហើយធ្វើនូវការសម្អាត ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាឱរសនៃព្រះបិតុច្ឆា របស់ព្រះមានព្រះភាគ ក្នុងនគរកបិលពស្តុមានឈ្មោះជាតិស្សៈ ។

កុលបុត្តនេះបួសតាមព្រះមានព្រះភាគ ឧបសម្បទាហើយ នៅក្នុងព្រៃអាស្រ័យជាតិ មានការប្រកាន់ខ្លួន ច្រើនទៅដោយសេចក្តីក្រោធ ព្រោះការ

បង្អៀតបង្អល់ និងច្រើនទៅដោយការលើកទោសអ្នកដទៃ មិនធ្វើការខ្វល់ខ្វាយក្នុងសមណធម៌ ។

សម័យថ្ងៃមួយ ព្រះសាស្តា ទ្រង់ឃើញព្រះថេរៈដេកលក់ហាមាត់ក្នុងទីសម្រាកពេលថ្ងៃ ដោយទិព្វចក្ខុ ទ្រង់យាងអំពីនគរសាវត្ថីទៅដោយផ្លូវអាកាស ប្រថាប់ឈរក្នុងអាកាស ខាងលើព្រះថេរៈនោះឯង ផ្សាយឱភាសទៅហើយ ញ៉ាំងសតិឲ្យកើតដល់ព្រះថេរៈ ព្រះថេរៈភ្ញាក់ឡើងដោយពន្លឺនោះកាលនឹងប្រទានឱវាទ ទើបត្រាស់ព្រះគាថាថា

> ភិក្ខុអ្នកមានស្មារតីកាលបើក្តៅក្រហាយ ( ដោយភ្លើងទុក្ខភ្លើងកិលេស ) ដូចបុគ្គលដែលគេចាក់ដោយលំពែងត្រង់ក្បាល គប្បីវៀរស្រឡះដើម្បីលះបង់កាមរាគៈចេញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សត្តិយា** នេះ ត្រឹមតែជាមាតិកានៃទេសនា អធិប្បាយថា ដោយសស្ត្រាដែលមានមុខតែម្ខាង ។ បទថា **ឱមដ្ឋោ** បានដល់ ត្រូវប្រហារហើយ អធិប្បាយថា គ្រឿងប្រហារមាន ៤ យ៉ាង គឺ ឱមដ្ឋៈ ១ ឧម្មដ្ឋៈ ១ មដ្ឋៈ ១ វិមដ្ឋៈ ១ ។

បណ្តាគ្រឿងប្រហារ ៤ យ៉ាងនោះ គ្រឿងប្រហារដែលតាំងនៅខាងលើឲ្យមុខផ្កាប់ចុះ ឈ្មោះថា **ឱមដ្ឋ** ។ គ្រឿងប្រហារដែលតាំងនៅខាងក្រោម ឲ្យមុខផ្ងារឡើងលើ ឈ្មោះថា **ឧម្មដ្ឋ** ។ គ្រឿងប្រហារដែលពួយទម្លុះ ដូចជាឈើស្រួចនិងម្ជុល ឈ្មោះថា **មដ្ឋ** ។ គ្រឿងប្រហារដ៏សេសឈ្មោះថា **វិមដ្ឋ** ។

តែក្នុងទីនេះ ទ្រង់សំដៅដល់គ្រឿងប្រហារ ឈ្មោះថា **ឱមដ្ឋ** អធិប្បាយថា គ្រឿងប្រហារឈ្មោះឱមដ្ឋៈនោះ ឃោរឃៅជាងអាវុធគ្រប់យ៉ាង ជាលំពែងដែលដកឡើងបានលំបាក ព្យាបាលបានលំបាក មានពិសខាងក្នុង បណ្តាលឲ្យមានខ្ទុះនិងឈាមនៅខាងក្នុង ខ្ទុះនិងឈាមមិនហូរចេញ បិទនូវមុខរបួសហើយតាំងនៅ បុគ្គលបំណងយកខ្ទុះនិងឈាមចេញ ត្រូវចងក្ជាប់នឹងគ្រែ ឲ្យក្បាលសំយុងចុះ សត្វទាំងឡាយ រមែងដល់នូវការស្លាប់ ឬទុក្ខស្មើរនឹងស្លាប់ ។ បទថា **ឌយ្ហមានេ** បានដល់ ដែលភ្លើងកំពុងដុត ។ បទថា **មត្ថកេ** ប្រែថា ត្រង់ក្បាល ។ លោកអធិប្បាយថា បុរសដែលត្រូវចាក់ដោយលំពែង រមែងប្រារព្ធព្យាយាមដើម្បីដកនូវលំពែងចេញ ធ្វើនូវការរក្សារបួស គឺប្រកបព្យាយាម ដូច្នោះ យ៉ាងណា ឬប្រៀបដូចកាលភ្លើងឆេះលើអំបែងក្បាល បុរសដែលត្រូវភ្លើងឆេះក្បាល រមែងព្យាយាមដើម្បីលត់ភ្លើងនោះ គឺធ្វើនូវសេចក្តីព្យាយាមបែបនោះ យ៉ាងណា ភិក្ខុក៏ដូច្នោះដូចគ្នា គប្បីជាអ្នកមានសតិ គឺមិនប្រមាទ ដើម្បីលះកាមរាគៈ បានដល់ គប្បីជាអ្នកមានឧស្សាហ៍ពន់ពេក ។

ព្រះមានព្រះភាគ កាលទ្រង់ប្រទានឱវាទ ដើម្បីចូលទៅរំលត់ការក្រោធនិងការបង្អៀតបង្អល់ដល់ព្រះថេរៈនោះយ៉ាងនេះហើយ ទ្រង់ញ៉ាំងនូវទេសនាឲ្យចប់ដោយកំពូល គឺការលះកាមរាគៈ ព្រោះតាំងនៅក្នុងឋានៈតែមួយ ។ ព្រះថេរៈស្តាប់គាថានោះហើយ មានចិត្តសង្វេគ ព្យាយាមនៅក្នុងវិបស្សនាហើយ ព្រះសាស្តាទ្រង់ជ្រាបអជ្ឈាស្រ័យរបស់ព្រះថេរៈហើយ ទ្រង់សម្តែង

តិស្សត្ថេរសូត្រ ក្នុងសំយុត្តនិកាយ ក្នុងកាលចប់ទេសនា ព្រះថេរៈតាំងនៅក្នុងអរហត្តផលហើយ ។ សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ខ្ញុំទទួលយសទាំងពីរ ក្នុងទេវលោកផង ក្នុងមនុស្សលោកផង រួចខ្ញុំបានដល់នូវព្រះនិព្វាន ជាសិវដ្ឋានដ៏ប្រសើរ ក្នុងកាលជាទីបំផុត ។ បុរសណាឧទ្ទិសចំពោះព្រះសម្ពុទ្ធ ឬចំពោះដើមពោធិរបស់ព្រះសាស្តានោះ គប្បីទទួលនូវផលបុណ្យ ( ផលទាំងអស់ ) ឈ្មោះថាបុរសនោះបានដោយក្រដូចម្តេចបាន ។ បុគ្គល ( ដែលឋិតនៅ ) ក្នុងមគ្គ ក្នុងផល ក្នុងបរិយត្តិ ក្នុងគុណ គឺឈានទិនិងអភិញ្ញា ជាបុគ្គលប្រសើរក្រៃលែងជាងពួកជនដទៃ ជាអ្នកមិនមានអាសវៈ តែងបរិនិព្វាន ។ ក្នុងកពមុនខ្ញុំមានចិត្តរីករាយ បានយកស្លឹកពោធិទៅចោល ទើបជាអ្នកបរិបូណ៌ដោយអង្គ ២០ នេះសព្វៗកាល ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផល បានពោលគាថានោះឯង ដើម្បីបូជាព្រះសាស្តា ។

**អដ្ឋកថា តិស្សត្ថេរគាថា ចប់**

១-ក្នុងអបទានជាព្រះ ពោធិសម្មជ្ជកត្ថេរ ។

## វឌ្ឍមានត្ថេរគាថា

[ ៤១ ] ភិក្ខុអ្នកមានស្មារតី កាលបើក្តៅក្រហាយ ( ដោយភ្លើងទុក្ខ ភ្លើងកិលេស ) ដូចបុគ្គលដែលគេចាក់ដោយលំពែងត្រង់ក្បាល គប្បីវៀរ ស្រឡះ ដើម្បីលះបង់កវរាគៈចេញ ។

### វឌ្ឍមានត្ថេរ ។

### ឧទ្ទាន

និយាយអំពីគហុរតីរិយត្ថេរ ១ សុប្បិយត្ថេរ ១ សោបាកត្ថេរ ១ បោសិយត្ថេរ ១ សាមញ្ញកាមិត្ថេរ ១ កុមាបុត្តត្ថេរ ១ កុមាបុត្តសហាយកត្ថេរ ១ គវម្បតិត្ថេរ ១ តិស្សត្ថេរ ១ វឌ្ឍមានត្ថេរជាអ្នកមានយសច្រើន ១ ។

### ចប់ ចតុត្ថវគ្គ ។

## អដ្ឋកថា

## វឌ្ឍមានត្ថេរគាថា

[ ៤១ ] គាថារបស់ព្រះវឌ្ឍមានត្ថេរ មានពាក្យផ្តើមថា **សត្តិយា វិយ ឱមដ្ឋោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះថេរៈនេះក៏ជាអ្នកមានបុញ្ញាធិការធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ ក្នុងកប្បទី ៩២ រាប់អំពីភទ្ទកប្បនេះ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាតិស្សៈ កើតក្នុងផ្ទះមានត្រកូល ដឹងក្តីហើយ ឃើញព្រះ

មានព្រះភាគព្រះនាមថាតិស្សៈយាងមកបិណ្ឌបាត មានចិត្តជ្រះថ្លា ហើយថ្វាយផ្លែស្វាយទុំដែលជ្រុះចាកទង ដោយបុញ្ញកម្មនោះ កុលបុត្តនោះ កើតក្នុងទេវលោក សន្សំបុញ្ញកម្មរឿយៗ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលស្តេចលិច្ឆវី ក្នុងនគរវេសាលី មានឈ្មោះថា វឌ្ឍមាន ។

កុលបុត្តនោះចម្រើនវ័យហើយ មានសទ្ធាជ្រះថ្លា ជាទាយក ត្រេកអរក្នុងទាន ជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ជាសង្ឃុបដ្ឋាក កាលព្រះសាស្តាត្រាស់ឲ្យធ្វើការផ្កាប់បាត្រ ព្រោះកំហុសបែបនោះ ហាក់បីដូចជាន់ភ្លើង ញុំាងសង្ឃឲ្យអត់ទោស ញុំាងកម្មឲ្យចូលទៅស្ងប់រម្ងាប់ហើយ ជាអ្នកកើតនូវសេចក្តីសង្វេគ ទើបចេញបួស កាលបួសហើយ ជាអ្នកមានចិត្តត្រូវថីនមិទ្ធៈគ្របសង្កត់ ។ ព្រះសាស្តាកាលធ្វើព្រះថេរៈឲ្យសង្វេគ ទើបត្រាស់ព្រះគាថាថា

ភិក្ខុអ្នកមានស្មារតី កាលបើក្តៅក្រហាយ ( ដោយភ្លើងទុក្ខ
ភ្លើងកិលេស ) ដូចបុគ្គល ដែលគេចាក់ដោយលំពែងត្រង់
ក្បាល គប្បីវៀរស្រឡះ ដើម្បីលះបង់ភវរាគៈចេញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភវរាគប្បហានាយ** សេចក្តីថា ដើម្បីលះនូវភវរាគៈ រូបរាគៈ និងអរូបរាគៈ បើមិនទាន់លះសំយោជនៈខាងក្នុងបាន ការលះសំយោជនៈខាងក្រៅ រមែងមិនមានក៏ពិត តែការលះឱរម្ភាគិយសំយោជនៈ ក៏ឈ្មោះថា ព្រះមានព្រះភាគត្រាស់ទុកហើយ ដោយត្រាស់ដល់ការលះនូវឧទ្ធម្ភាគិយសំយោជនៈ ព្រោះមានក្នុងលំដាប់មកអំពីមុន ។ ម្យ៉ាងទៀត ព្រោះហេតុដែលឧទ្ធម្ភាគិយសំយោជនៈ ដែលព្រះអរិយបុគ្គល ពួកខ្លះ

សូម្បីលះដាច់នូវឱរម្ភាគិយសំយោជនៈបានហើយ ក៏គង់លះបានលំបាកដូច្នោះ ទើបព្រះមានព្រះភាគទ្រង់សម្តែងចំពោះសំយោជនៈដែលលះបានលំបាក ទើបត្រាស់ការលះឧទ្ធម្ភាគិយសំយោជនៈទាំងអស់ ដោយការលះកវរាគៈជាសំខាន់ ព្រោះជារបស់លះបានដោយងាយ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់យ៉ាងនេះ ដោយអំណាចនៃអធ្យាស្រ័យរបស់ព្រះថេរៈនោះឯង ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

អដ្ឋកថា វឌ្ឍមានត្ថេរគាថា ចប់

វគ្គទី ៤ ចប់

# ថេរគាថា ឯកនិបាត

## បញ្ចមវគ្គ

### សិរីវឌ្ឍត្ថេរគាថា

[ ៤២ ] ផ្លេកបន្ទោរ តែងធ្លាក់ចុះត្រង់ទៅកាន់ចន្លោះភ្នំវេភារៈផង ភ្នំបណ្ឌវៈផង ចំណែកខាងភិក្ខុជាបុត្តរបស់ព្រះមានព្រះភាគ ព្រះអង្គជាបុគ្គលនឹងធឹង ឥតមានគូប្រៀប ក៏តែងចូលទៅកាន់ចន្លោះភ្នំ ចម្រើនឈាន ។

*សិរីវឌ្ឍត្ថេរ ។*

## វគ្គទី៥

### អដ្ឋកថា

### សិរីវឌ្ឍត្ថេរគាថា

[ ៤២ ] គាថារបស់ព្រះសិរីវឌ្ឍត្ថេរ មានពាក្យផ្ដើមថា **វិវរមនុបតន្តិ វិជ្ជុតា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះថេរៈអង្គនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាវិបស្សី ក្នុងកប្បទី ៩១ រាប់អំពីភទ្ទកប្បនេះ កើតក្នុងផ្ទះនៃត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ឃើញព្រះមានព្រះភាគព្រះនាមថាវិបស្សីធ្វើការបូជាដោយផ្កាសិរមាន់[១]ដោយបុញ្ញ-

---

១-ក្នុងអបទានជាផ្កាកណ្ដឹង ។

កម្មនោះ កើតក្នុងទេវលោក ធ្វើបុណ្យតៗមក អន្ទោលទៅមកក្នុងសុគតិភព នោះឯង ក្នុងពុទ្ធុប្បាទនេះកើតក្នុងត្រកូលព្រាហ្មណ៍សម្បូរដោយសម្បត្តិក្នុងនគររាជគ្រឹះ មានឈ្មោះថា សិរីវឌ្ឍ ។

សិរីវឌ្ឍកុមារចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះបរមសាស្ដា និងក្នុងព្រះសទ្ធម្ម ក្នុងសមាគមរបស់ព្រះបាទពិម្ពិសារ ទើបចេញបួស ព្រោះបរិបូណ៌ដោយហេតុ ។ កាលលោកបួសហើយ ធ្វើបុព្វកិច្ចស្រេចហើយ ជាអ្នកខ្វល់ខ្វាយក្នុងកម្មដ្ឋាន នៅក្នុងគុហាភ្នំ ទាជនព្រៃមួយកន្លែង មិនឆ្ងាយអំពីភ្នំវេភារៈ ។

ក្នុងសម័យនោះ ភ្លៀងពុំដូចកាលតាំងឡើងយ៉ាងក្រាស់ ផ្ទេកបន្ទោរផ្សាយទូទៅ ដូចធ្លាក់ចូលទៅក្នុងញកភ្នំ កម្ដៅក្នុងរដូវក្ដៅក្នុងកាយរបស់ព្រះថេរៈ ដែលត្រូវកម្ដៅអំពីរដូវគ្របសង្កត់ក៏ស្ងប់ ព្រោះខ្យល់ដែលកើតអំពីភ្លៀងតាំងឡើង ។ ចិត្តរបស់លោកបានឯកគ្គតារម្មណ៍ ព្រោះបានឧតុជាទីសប្បាយ ។ ព្រះថេរៈមានចិត្តតាំងមាំហើយ ខ្វល់ខ្វាយក្នុងវិបស្សនា សម្រេចអរហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះសព្វញ្ញូ លោកនាយក ប្រាកដស្មើដោយគ្រឿងបូជា ជាវិការៈនៃមាស ព្រះលោកនាយក ស្ដេចចុះកាន់ទឹកស្រះហើយ ទ្រង់ស្រង់ ។ ខ្ញុំមានចិត្តត្រេកអរ មានចិត្តរីករាយ កាន់យកនូវផ្កាកណ្ដឹង ទៅបូជាដល់ព្រះវិបស្សី ជាធំជាងសត្វជើងពីរ ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ក្នុងកប្បទី ៩១ អំពី

កប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិព្រះនាមភិមរថៈទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលលោកសម្រេចអរហត្តហើយ កាលនឹងបន្លឺឧទាន ដែលទាក់ទងដោយខ្លួន ដោយអាងដល់អរហត្តផល បានភាសិតគាថាថា

ផ្ទេកបន្ទោរតែងជាលប្រវាត់ ទៅកាន់ចន្លោះភ្នំវេភារៈផង ភ្នំបណ្ឌវៈផង ចំណែកខាងភិក្ខុជាបុត្តរបស់ព្រះមានព្រះភាគ ព្រះអង្គជាបុគ្គលនឹងធឹងឥតមានគូប្រៀប ក៏តែងចូលទៅកាន់ចន្លោះភ្នំ ចម្រើនឈាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិវរំ** បានដល់ ចន្លោះដែលមានក្នុងរវាង គឺត្រង់កណ្តាល ។ បទថា **អនុបតន្តិ** សេចក្តីថា ធ្លាក់ទៅ គឺប្រព្រឹត្តទៅក្នុងលក្ខណៈអនុលោមតាម អធិប្បាយថា ភ្លឺស្វាង ។ ដែលឈ្មោះថា ការប្រព្រឹត្តទៅរបស់ផ្ទេកបន្ទោរ គឺផ្ទេកបន្ទោរជាលប្រវាត់ទៅនោះឯង ។ ព្រោះប្រកប **អនុ** សព្ទចូលទៅក្នុងបទថា **វិវរំ** នេះ ទើបប្រើជាទុតិយាវិភត្តិ ដូចក្នុងប្រយោគថា **រុក្ខមនុវិជ្ជោតន្តិ** ប្រែថា ផ្ទេកបន្ទោរចាំងតាមចន្លោះដើម

---

១-ក្នុងអបទានជាព្រះ កឹកណិកបុប្ផិយត្ថេរ ។

ឈើ ។

បទថា **វិជ្ជុតា** ប្រែថា ផ្លេកបន្ទោរ ។ បទថា **វេភារស្ស ច បណ្ឌវស្ស ច** ប្រកបសេចក្តីថា ចាំងពន្លឺចូលទៅតាមចន្លោះនៃភ្នំវេភារៈ និងភ្នំបណ្ឌវៈ ។ បទថា **នគវិវរគតោ** សេចក្តីថា ចូលទៅកាន់ចន្លោះនៃភ្នំ គឺល្អាងនៃភ្នំ ។ បទថា **ឈាយតិ** សេចក្តីថា សម្លឹងដោយអារម្មណូបនិជ្ឈាន និងលក្ខណូ-បនិជ្ឈាន គឺកាលខ្វល់ខ្វាយក្នុងសមថៈ និងវិបស្សនា ឈ្មោះថារមែងញ៉ាំងឈានឲ្យចម្រើន ។

បទថា **បុត្តោ អប្បដិមស្ស តាទិនោ** សេចក្តីថា ជាបុត្តដែលកើតអំពីទ្រូងរបស់ព្រះមានព្រះភាគឥតមានគូប្រៀបគឺវៀរចាកការប្រៀបធៀប ដោយការដល់ព្រមនៃធម្មកាយ មានគំនរនៃសីលជាដើម និងដោយការដល់ព្រមនៃរូបកាយ ឈ្មោះថា **តាទិនោ** ព្រោះដល់ព្រមដោយលក្ខណៈរបស់អ្នកនឹងធឹងក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ជាដើម ។ គប្បីជ្រាបថា ដោយពាក្យថា **បុត្ត** សព្ទ ក្នុងគាថានោះឯង ឈ្មោះថា ព្រះថេរៈព្យាករអរហត្តផលហើយ ព្រោះសម្តែងដល់ភាពដែលខ្លួនជាបុគ្គលកើតតាមព្រះសាស្តា ។

## អដ្ឋកថា សិរិវឌ្ឍត្ថេរគាថា ចប់

## ខទិរវនិយត្ថេរគាថា

[ ៤៣ ] ម្នាលនាងចាលា ម្នាលនាងឧបចាលា ម្នាលនាងសីសុបចាលា នាងទាំងឡាយ ឈ្មោះចាលា ឈ្មោះឧបចាលា ឈ្មោះសីសុបចាលា ចូរជាអ្នកមានសតិខ្ជាប់ខ្ជួនចុះ ( ដ្បិតព្រះសារីបុត្តជាបង ) របស់នាងទាំងឡាយ បានមកត្រង់ហើយ ដូចអ្នកបាញ់រោមកន្ទុយទ្រាយ ។

**ខទិរវនិយត្ថេរ ។**

## អដ្ឋកថា

## ខទិរវនិយត្ថេរគាថា

[ ៤៣ ] គាថារបស់ព្រះខទិរវនិយត្ថេរ មានពាក្យផ្តើមថា **ចាលេ ឧបចាលេ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ ព្រះថេរៈនេះកើតក្នុងត្រកូលរបស់អ្នកចែវទូក ក្នុងនគរហង្សវតី ធ្វើការចែវទូកត្រង់កំពង់ឈ្មោះបយាគៈនៃស្ទឹងមហាគង្គា ។ ថ្ងៃមួយ ឃើញព្រះមានព្រះភាគមួយអន្លើដោយពួកសាវកយាងទៅកាន់ច្រាំងស្ទឹងគង្គា មានចិត្តជ្រះថ្លា ហើយរៀបចំទូកចម្លង បញ្ជូនព្រះមានព្រះភាគ មួយអន្លើនឹងសាវកទៅដល់ត្រើយនាយ ដោយការបូជាសក្ការៈដ៏ច្រើន ឃើញភិក្ខុមួយរូបដែលព្រះសាស្តាទ្រង់តែងតាំងក្នុងតំណែងនៃឯតទគ្គៈ ជាងបណ្តាភិក្ខុដែលនៅក្នុងព្រៃ តាំងសេចក្តីប្រាថ្នាដើម្បីតំណែងនោះ បំពេញមហាទាន ថ្វាយដល់ព្រះមានព្រះភាគ និង

ភិក្ខុសង្ឃ ។

ព្រះមានព្រះភាគ ទ្រង់ព្យាករសេចក្តីប្រាថ្នារបស់កុលបុត្តនោះថាមិនឥត អំពើឡើយ តាំងអំពីនោះមកកុលបុត្តនោះបំពេញកុសលដែលជាឧបនិស្ស័យ នៃព្រះនិព្វានទុកក្នុងភពនោះៗ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទៃរបស់ព្រាហ្មណីឈ្មោះរូបសារី ក្នុងនាលកគ្រាម ដែនមគធៈ ។ មាតាបិតារបស់កុលបុត្តនេះ បំណងនឹងចងកុលបុត្តនោះដែល ចម្រើនវ័យហើយដោយចំណងគឺផ្ទះ ។ កុលបុត្តនោះស្តាប់ភាពដែលព្រះសារី បុត្តត្រូវជាបងបួសហើយគិតថា លោកម្ចាស់ឧបតិស្សៈជារៀមច្បងរបស់អញ លះបង់សម្បត្តិបែបនេះបួសហើយ អញនឹងបរិភោគទឹកមាត់ដែលលោកម្ចាស់ ឧបតិស្សៈនោះ ស្តោះចោលហើយបានដូចម្តេច ដូច្នេះហើយ កើតសេចក្តី សង្វេគ ដូចម្រឹគដែលកំពុងដើរទៅរកអន្ទាក់ ទើបបញ្ឆោតពួកញាតិ កាល ហេតុសម្បត្តិជាស់តឿន ទៅកាន់សម្នាក់របស់ភិក្ខុទាំងឡាយ ប្រាប់ភាពដែល ខ្លួនជាប្អូនប្រុសរបស់ព្រះធម្មសេនាបតី ប្រាប់នូវការពេញចិត្តក្នុងបព្វជ្ជារបស់ ខ្លួន ។ ភិក្ខុទាំងឡាយឲ្យបព្វជ្ជាហើយ លុះអាយុគ្រប់ ២០ ក៏ឲ្យឧបសម្បទា ទូន្មានកម្មដ្ឋាន ។ លោករៀនកម្មដ្ឋានហើយ ចូលទៅកាន់ព្រៃគគីរ គិតថា អាត្មាអញសម្រេចអរហត្តហើយសឹមចូលទៅគាល់ព្រះមានព្រះភាគ និងជួប ព្រះធម្មសេនាបតី ដូច្នេះហើយ ប្រារព្ធសេចក្តីព្យាយាម ជាអ្នកមានអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយព្រោះមានញាណចាស់ដោយជុំវិញហើយ សមដូច គាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

មានស្ទឹងមួយឈ្មោះភាគីរសីហូរចេញអំពីព្រៃហិមពាន្ត (កាលនោះ) ខ្ញុំកើតជានាយទូកក្នុងកំពង់មិនល្អ ជាកំពង់សម្រាប់ឆ្លងមកកាន់ត្រើយអាយ ។ ព្រះសម្ពុទ្ធជានាយកព្រះនាមបទុមុត្តរៈ ព្រះអង្គប្រសើរជាងសត្វជើងពីរ បម្រុងនឹងឆ្លងខ្សែទឹកក្នុងស្ទឹង ជាមួយនឹងភិក្ខុសង្ឃមួយសែនអង្គ ។ ខ្ញុំបានប្រមូលទូកជាច្រើនមក ហើយធ្វើជំបូលទូកដែលពួកជាងឈើតាក់តែងល្អហើយទៅទទួលព្រះនរាសភៈ ។ ព្រះសម្ពុទ្ធទ្រង់ស្តេចមកឡើងគង់លើទូក ព្រះសាស្តាទ្រង់ឋិតត្រង់កណ្តាលទឹកស្ទឹង ហើយត្រាស់គាថាទាំងនេះថា

បុគ្គលណា បានចម្លងព្រះសម្ពុទ្ធ ព្រមទាំងភិក្ខុសង្ឃ ជាអ្នកមិនមានអាសវៈ បុគ្គលនោះ នឹងត្រេកអរក្នុងទេវលោកដោយចិត្តជ្រះថ្លានោះឯង ។ វិមានមានសណ្ឋានដូចទូកដែលបុញ្ញកម្មធ្វើល្អហើយនឹងកើតដល់អ្នក វិមាននោះនឹងទ្រទ្រង់នូវជំបូល ជាវិការៈនៃផ្កា ឮដ៏អាកាសសព្វៗកាល ។ ក្នុងកប្បទី ៥៨ បុគ្គលនោះនឹងបានជាស្តេចចក្រពត្តិព្រះនាម តារណៈ (ជាឥស្សរៈលើផែនដី) មានសមុទ្ទទាំង ៤ ជាទីបំផុត ទ្រង់ឈ្នះសង្គ្រាម ។ ក្នុងកប្បទី ៥៧ នឹងបានជាស្តេចព្រះនាម ចម្មកៈ មានកម្លាំងច្រើនរុងរឿងដូចព្រះអាទិត្យកំពុងរះ ។ ក្នុងកប្បទីមួយសែនព្រះ

សាស្ដាព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ ស្ដេចចម្លក: ( នោះ ) ច្យុតចាកទេវលោកមកកាន់អត្តភាពជាមនុស្ស នឹងកើតជាព្រាហ្មណ៍ ឈ្មោះរេវត: ។ រេវតកុមារនោះ ត្រូវកុសលមូលជាស់តឿននឹងចេញចាកផ្ទះទៅបួសក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមគោតម ។ រេវតភិក្ខុនោះ លុះបួសរួចហើយក្នុងកាលជាខាងក្រោយ ប្រកបសេចក្ដីព្យាយាម ខំចម្រើនវិបស្សនា កំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

សេចក្ដីព្យាយាមរបស់ខ្ញុំ គួរដើម្បីនាំមកនូវធុរៈ ជាទីនាំមកនូវធម៌ដ៏ក្សេមចាកយោគៈ ខ្ញុំទ្រទ្រង់រាងកាយមានក្នុងទីបំផុតគឺបច្ឆិមជាតិ ក្នុងសាសនានៃព្រះសម្ពុទ្ធ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

ព្រះថេរៈបានអភិញ្ញា ៦ ហើយ ក៏ទុកដាក់សេនាសនៈ កាន់បាត្រនិងចីវរទៅដើម្បីគាល់ព្រះសាស្ដា និងជួបព្រះធម្មសេនាបតី ដល់នគរសាវត្ថីដោយលំដាប់ ចូលទៅកាន់ជេតពនវិហារហើយថ្វាយបង្គំព្រះបរមសាស្ដានិងថ្វាយបង្គំព្រះធម្មសេនាបតី ហើយនៅក្នុងជេតពនមហាវិហារអស់ពីរបីថ្ងៃ ។

លំដាប់នោះ ព្រះសាស្តាគង់នៅក្នុងជំនុំអរិយសង្ឃ ទ្រង់តែងតាំងព្រះថេរៈទុកក្នុងឋានៈជាកំពូលនៃភិក្ខុ ដែលនៅព្រៃទាំងឡាយ ដោយព្រះពុទ្ធតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកនៅក្នុងព្រៃដែលជាសាវ័ករបស់តថាគត ស្រេចនឹងរេវតខទិរវនិយៈប្រសើរជាងគេ ដូច្នេះ ។ ក្នុងកាលតមក លោកត្រឡប់ទៅកាន់មាតុភូមិរបស់ខ្លួន នាំក្មួយប្រុស ៣ នាក់ គឺចាលា ១ ឧបចាលា ១ សីសូបចាលា ១ ដែលជាកូនរបស់បងស្រីទាំង ៣ គឺ នាងចាលា នាងឧបចាលា នាងសីសូបចាលា មកហើយឲ្យបួស ទូន្មានកម្មដ្ឋានដល់ទារកទាំង ៣ ហើយប្រកបរឿយៗនូវកម្មដ្ឋាន ។ ក្នុងសម័យនោះ អាពាធបានកើតដល់ព្រះថេរៈ ព្រះសារីបុត្តបានដំណឹងនោះហើយ ចូលទៅរកព្រះថេរៈដោយគិតថា អញនឹងសួរនូវអាការជំងឺ និងសួរដល់មគ្គផលដែលរេវតៈសម្រេច ។ ព្រះរេវតត្ថេរឃើញព្រះធម្មសេនាបតី ដើរមកអំពីចម្ងាយ កាលពោលទូន្មានសាមណេរទាំងនោះឲ្យកើតសតិ ទើបពោលទូន្មានថា

ម្នាលនាងចាលា ម្នាលនាងឧបចាលា ម្នាលនាងសីសុបចាលា
នាងទាំងឡាយ ឈ្មោះចាលា ឈ្មោះឧបចាលា ឈ្មោះសី
សុបចាលា ចូរជាអ្នកមានសតិខ្ជាប់ខ្ជួនចុះ ( ដ្បិតព្រះសារី
បុត្តជាបង ) របស់នាងទាំងឡាយ បានមកត្រង់ហើយ ដូចអ្នក
បាញ់រោមកន្ទុយទ្រាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចាលេ ឧបចាលេ សីសូបចាលេ** ជាពាក្យ

ហៅសាមណេរទាំងនោះ អធិប្បាយថា ទារកទាំង ៣ នោះ បានឈ្មោះដោយអំណាចនៃភេទស្រីថា ចាលា ឧបចាលា សីសូបចាលា សូម្បីបួសហើយក៏នៅតែហៅយ៉ាងនោះ តែអាចារ្យពួកខ្លះពោលថា សាមណេរទាំង ៣ នោះឈ្មោះថា ចាលី ឧបចាលី និងសីសូបចាលី ។ ព្រះថេរៈកាលដាស់តឿនដោយពាក្យថា នៃសាមណេរចាលា ជាដើម ទើបពោលថា **បតិស្សតិកា នុ ខោ វិហរថ** ដូច្នេះ ហើយសម្តែងហេតុក្នុងការដាស់តឿននោះថា ដ្បិតព្រះសារីបុត្រជាអឹរបស់អ្នកទាំងឡាយ បានមកត្រង់ហើយ ដូចអ្នកបាញ់រោមកន្ទុយទ្រាយ ដូច្នេះ ។

បទថា **បតិស្សតិកា** ប្រែថា មានសតិចំពោះមុខ ។ សព្ទថា **ខោ** ជានិបាត ចុះក្នុងអវធារណៈ ។

បទថា **អាគតោ** ប្រែថា មកហើយ ។ បទថា **វោ** ប្រែថា របស់អ្នកទាំងឡាយ ។

បទថា **វាលំ វិយ វេធិ** សេចក្តីថា ដូចខ្មាន់ធ្នូបាញ់ចុងរោមទ្រាយ ។ ក្នុងបាទនៃគាថានោះ មានសេចក្តីសង្ខេបដូច្នេះ ព្រះថេរៈដែលជាអឹរបស់អ្នកទាំងឡាយ ដែលឈ្មោះថា ដូចនាយខ្មាន់ធ្នូបាញ់ចុងរោមទ្រាយ ព្រោះមានបញ្ញាចាស់ក្លា មានបញ្ញាវាងវៃ មានបញ្ញាចាក់ធ្លុះ ជាបុគ្គលទី ២ បន្ទាប់អំពីព្រះសាស្តា និមន្តមកហើយ ព្រោះដូច្នោះ អ្នកទាំងឡាយចូរតាំងនូវសមណសញ្ញា ជាអ្នកប្រកបទៅដោយសតិសម្បជញ្ញៈចុះ គឺចូរកុំប្រមាទក្នុងវិហារធម៌តាមដែលបានសម្រេច ។

សាមណេរទាំងនោះ ស្តាប់ដូច្នោះហើយ ធ្វើវត្ត មានការក្រោកឡើង ទទួលព្រះធម្មសេនាបតីជាដើម ក្នុងវេលាដែលព្រះថេរៈជាអំ និងពូធ្វើបដិសណ្ឋារៈគ្នា បានអង្គុយចូលសមាធិ ក្នុងទីមិនឆ្ងាយ ។ ព្រះធម្មសេនាបតី ធ្វើបដិសណ្ឋារៈនឹងព្រះរេវតៈហើយ ក្រោកចាកអាសនៈ ចូលទៅរកសាមណេរទាំងនោះ ។ សាមណេរទាំងនោះក្រោកឡើង ថ្វាយបង្គំព្រះថេរៈដែលកំពុងដើរចូលទៅរកនោះឯងឈរហើយ ព្រោះធ្វើការកំណត់ពេលយ៉ាងនោះ ។ ព្រះថេរៈសួរថា ពួកអ្នកនៅដោយវិហារធម៌ណា សាមណេរឆ្លើយថា ដោយវិហារធម៌ ឈ្មោះនេះ ឈ្មោះនេះ ព្រះថេរៈសរសើរប្អូនប្រុសថា ប្អូនប្រុសរបស់អញ ទូន្មានសាមណេរតូចៗនេះបាន ឈ្មោះថាចូលដល់នូវធម៌សមគួរដល់ធម៌ហើយហ្ន៎ ដូច្នេះហើយ ក៏ចៀសចេញទៅ ។

## អដ្ឋកថា ខទិរវនិយត្ថេរគាថា ចប់

## សុមង្គលត្ថេរគាថា

[ ៤៤ ] អញរួចស្រឡះហើយ ផុតស្រឡះហើយដោយប្រពៃ អញរបួតស្រឡះហើយ ចាកអាការគម ៣ យ៉ាង គឺកាលអញកាន់កណ្តៀវ ១ កាលអញកាន់នង្គ័ល ១ កាលអញកាន់ចបតូច ១ ទោះការងារ ( មានកាន់កណ្តៀវជាដើមនោះ ) ក្នុងទីនេះៗក៏ដោយ ឬក៏ការងារ ( មានកាន់កណ្តៀវជាដើម ) ល្មមហើយ គួរហើយ នែសុមង្គល អ្នកចូររំពឹង ( ដល់សមាបត្តិចុះ ) នែសុមង្គល អ្នកចូររំពឹងចុះ នែសុមង្គល អ្នកចូរជាអ្នកកុំប្រមាទ ។

**សុមង្គលត្ថេរ ។**

## អដ្ឋកថា

## សុមង្គលត្ថេរគាថា

[ ៤៤ ] គាថារបស់ព្រះសុមង្គលត្ថេរ មានពាក្យផ្តើមថា **សុមុត្តិកោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះថេរៈនោះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាសិទ្ធត្ថ កើតជារុក្ខទេវតា ។ ថ្ងៃមួយឃើញព្រះសាស្តាស្រង់ទឹកហើយទ្រង់គ្រងចីវរមួយផ្ទាំង ប្រថាប់ឈរ មានចិត្តសោមនស្ស ទើបទះដៃ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំង

ឡាយ ក្នុងពុទ្ធុប្បាទយើងនេះ កើតក្នុងត្រកូលទុគ៌ត ក្នុងស្រុកមួយ មិនឆ្ងាយ អំពីក្រុងសាវត្ថី ដោយផលនៃកម្មដែលឲ្យផលមានសភាពបែបនោះ មាន ឈ្មោះថា សុមង្គល កុលបុត្តនោះចម្រើនវ័យហើយ ជាអ្នកមានកណ្ដៀវ មាន នង្គ័ល មានចប ដែលជាសម្បត្តិរបស់បុគ្គលមានខ្លួនកោង ជាបរិក្ខារចិញ្ចឹម ជីវិតដោយកសិកម្ម ។ ថ្ងៃមួយ កាលព្រះបាទបសេនទិកោសល បំពេញ មហាទាន ថ្វាយព្រះមានព្រះភាគ មួយអន្លើដោយភិក្ខុសង្ឃ គាត់កាន់ផ្ទាំងទឹក ដោះជូរដើរជាមួយមនុស្សទាំងឡាយដែលកាន់យកទេយ្យទានដើរមក ឃើញ សក្ការៈនិងការរាប់អានរបស់ភិក្ខុទាំងឡាយ ហើយគិតថា ពួកសមណៈសក្យ បុត្តទាំងនេះ ស្លៀកសំពត់សាច់ម៉ដ្ឋ បរិភោគភោជនល្អ នៅក្នុងសេនាសនៈ មិនមានខ្យល់ កាលណាហ្ន៎អញគប្បីបួស ដូច្នេះហើយ ចូលទៅរកព្រះថេរៈ មួយរូប ប្រាប់បំណងក្នុងការបួសនៃខ្លួន ព្រះថេរៈមានសេចក្ដីករុណាឲ្យបួស ហើយប្រាប់កម្មដ្ឋាន ។

លោកនៅក្នុងព្រៃ នឿយណាយក្នុងការនៅម្នាក់ឯង ជាអ្នកអផ្សុកបំណង នឹងសឹក ទើបទៅផ្ទះញាតិ ក្នុងរវាងផ្លូវ ឃើញអ្នកស្រែស្លៀកកន្ទប ភ្ជួរស្រែ ជាសំពត់សៅហ្មង រាងកាយពេញដោយធូលី កណ្ដាលថ្ងៃក្ដៅនិងខ្យល់ ក៏ បាននូវសេចក្ដីសង្វេគថា សត្វទាំងនេះ សោយទុក្ខច្រើន ព្រោះហេតុនៃការ ចិញ្ចឹមជីវិត ។ ព្រោះញាណចាស់ក្លា កម្មដ្ឋានដែលលោករៀនមក ក៏ប្រាកដ ឡើង ចូលទៅកាន់គល់ឈើមួយដើម បាននូវការស្ងាត់ មានយោនិសោមន សិការ ចម្រើនវិបស្សនាហើយ សម្រេចអរហត្ត តាមលំដាប់មគ្គ ។ សម

ដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះជិនស្រីដ៏ប្រសើរ ព្រះនាមអត្ថទស្សី ជាច្បងក្នុងលោក ជានរាសភៈ ស្ដេចចេញអំពីវិហារ ចូលសំដៅទៅកាន់ស្រះ ។ លុះព្រះសម្ពុទ្ធ ទ្រង់ស្រង់និងសោយរូបហើយ ទ្រង់មានតែចីវរមួយ ស្ដេចយាងឡើងមក ព្រះមានព្រះភាគ ទ្រង់ឈរក្រឡេកមើលទិសធំទិសតូចក្នុងទីនោះ ។ ខ្ញុំចូលទៅក្នុងលំនៅ បានឃើញព្រះលោកនាយក កាលនោះខ្ញុំជាអ្នករីករាយ ក៏ទះដៃដោយចិត្តរីករាយ ។ ទើបខ្ញុំប្រកបក្នុងការរាំច្រៀង និងប្រគំតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ ( ថ្វាយ ) ចំពោះព្រះសម្ពុទ្ធទ្រង់រុងរឿងដូចព្រះអាទិត្យ ភ្លឺប្រាលដូចមាស ខ្ញុំទៅកើតក្នុងកំណើតណាៗ ទោះបីជាទេវតាឬជាមនុស្ស ខ្ញុំតែងគ្របសង្កត់នូវសត្វទាំងពួងបាន ខ្ញុំរមែងមានយសដ៏ធំ ។ បពិត្រព្រះអង្គជាបុរសអាជានេយ្យខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសដ៏ខ្ពង់ខ្ពស់ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះមុនី ព្រះអង្គទ្រង់ធ្វើព្រះអង្គឲ្យត្រេកអរ ហើយធ្វើអ្នកដទៃឲ្យត្រេកអរផង ។ ខ្ញុំអង្គុយកំណាត់ ធ្វើនូវសេចក្ដីរីករាយ ជាអ្នកមានវត្តល្អ បម្រើនូវព្រះសម្ពុទ្ធ ហើយបានទៅកើតក្នុងតុសិត ។ ក្នុងកប្បទី ១៦០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ១៨ ជាតិ ព្រះនាមឯកចិន្តិតៈ ដូចគ្នា ទ្រង់បរិបូណ៌

ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលបន្លឺឧទាន ដោយអំណាចនៃការប្រកាសសម្បត្តិ និងការផុតទុក្ខរបស់ខ្លួន ទើបពោលគាថាថា

អញរួចស្រឡះហើយ ផុតស្រឡះហើយដោយប្រពៃ អញរបូតស្រឡះហើយ ចាកអាការគម ៣ យ៉ាង គឺកាលអញកាន់កណ្តៀវ ១ កាលអញកាន់នង្គ័ល ១ កាលអញកាន់ចបតូច ១ ទោះការងារ ( មានកាន់កណ្តៀវជាដើមនោះ ) ក្នុងទីនេះៗ ក៏ដោយ ឬក៏ការងារ ( មានកាន់កណ្តៀវជាដើម ) ល្មមហើយ គួរហើយ នៃសុមង្គល អ្នកចូររំពឹង ( ដល់សមាបត្តិចុះ ) នៃសុមង្គល អ្នកចូររំពឹងចុះ នៃសុមង្គល អ្នកចូរជាអ្នកកុំប្រមាទ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុមុត្តិកោ** សេចក្តីថា ឈ្មោះថា **សុមុត្តិ-កោ** ព្រោះរួចផុតល្អ គឺមិនកើតទៀត ព្រោះធ្វើទីបំផុតបានហើយ ព្រះថេរៈកាលទះដៃ ព្រោះការរួចផុតរបស់លោក ដែលគួរសរសើរនិងគួរអស្ចារ្យទើបពោលថា **សុមុត្តិកោ** កាលនឹងសម្តែងភាពដែលការជ្រះថ្លានៃខ្លួន ក្នុងវិមុត្តិនោះឲ្យមាំទាំ ទើបពោលថា **សាហុ សុមុត្តិកោម្හិ** អធិប្បាយថា សាធុ ខ្ញុំផុតល្អហើយហ្ន៎ ដូច្នេះ ។ សួរថា ព្រះថេរៈនេះ ធ្វើឲ្យផុតល្អហើយ ចាកអ្វី

ឆ្លើយថា ទោះបីព្រះថេរៈនេះផុតល្អហើយ ចាកវដ្តទុក្ខទាំងពួងក៏ពិត តែកាលនឹងសម្តែងដល់ទុក្ខដែលប្រាកដមកអំពីមុនរបស់ខ្លួន ដែលជាទុក្ខមិនគួរប្រាថ្នាយ៉ាងក្រៃលែង ទើបពោលពាក្យជាដើមថា **តីហិ ខុជ្ជកេហិ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខុជ្ជកេហិ** សេចក្តីថា ចាកសភាវៈនៃការគម ឬចាកអាការគម ពាក្យថា **ខុជ្ជកេហិ** នោះ ជាបញ្ចមីវិភត្តិ ប្រកបចូលជាមួយសព្ទថា **មុត្តា** ព្រោះថា អ្នកស្រែមិនជាមនុស្សគម ក៏ត្រូវធ្វើខ្លួនឲ្យជាមនុស្សគម ៣ យ៉ាងគឺក្នុងការច្រូត ១ ក្នុងការភ្ជួរ ១ ក្នុងការជីក ១ ។ អ្នកស្រែណាធ្វើការច្រូតជាដើម អាការ មានការច្រូតជាដើមនោះ របស់អ្នកស្រែនោះក៏ឈ្មោះថាគមដោយអាការកោង ព្រោះដូច្នោះ ទើបលោកពោលថា **តីហិ ខុជ្ជកេហិ** ។

ឥឡូវនេះ ព្រះថេរៈកាលសម្តែងនូវទុក្ខទាំងនោះដោយសរុប ទើបពោលថា កាលអញកាន់កណ្តៀវ ១ កាលអញកាន់នង្គ័ល ១ កាលអញកាន់ចបតូច ១ ដូច្នេះ ។

បទថា **អសិតាសុ មយា** ក្នុងគាថានោះ មានន័យថា ខ្ញុំផុតហើយចាកកណ្តៀវទាំងឡាយ ។ បទថា **អសិតាសុ** នេះ ជាសត្តមីវិភត្តិ ចុះក្នុងអត្ថនៃបញ្ចមីវិភត្តិ ។ សូម្បីបទដ៏សេស ក៏មានន័យដូចគ្នា ។ ឯអាចារ្យពួកខ្លះពោលថា **អសិតាសុ មយា** សេចក្តីថា ខ្ញុំដល់ហើយនូវភាពជាបុគ្គលគមព្រោះកណ្តៀវទាំងឡាយ គឺមានកណ្តៀវជាហេតុ ។ តាមមតិរបស់កេចិអាចារ្យទាំងនោះ បទថា **អសិតាសុ** ជាសត្តមីវិភត្តិ ចុះក្នុងអត្ថនៃករណៈ ឬ

ក្នុងហេតុ ។

បទថា **ឆន្នលាសុ** លោកពោលទុកដោយធ្វើជាលិង្គវិបល្លាសអធិប្បាយថា ព្រោះនង្គ័លទាំងឡាយដែលលំបាក លោកពោលថា **ខុទ្ទកុទ្ទាលាសុ** ព្រោះចបដែលខ្លួនប្រើប្រាស់ ជារបស់តូច ( សឹករិល ) ដោយសការៈ ឬដោយការប្រើប្រាស់ ។ បាលីថា **កុណ្ឌកុទ្ទាលាសុ** ដូច្នេះក៏មាន អធិប្បាយថា មានមុខសឹកដោយការប្រើប្រាស់នោះឯង ។

ម អក្ខរៈ ក្នុងបទថា **ឥធមេវ** នេះ ធ្វើការភ្ជាប់បទ ។ **វា** សព្ទ ក្នុងបទថា **អថ វាបិ** ត្រឹមតែជានិបាតប៉ុណ្ណោះ អធិប្បាយថា កណ្តៀវជាដើមនោះ ទោះនៅក្នុងទីនេះឯង គឺនៅក្នុងទីជិតអាត្មាអញនេះឯងក៏ពិត តែក៏មិនសមគួរដល់អាត្មាអញទាំងអស់ ។

បទថា **អលមេវ អលមេវ** នេះ ជាពាក្យពោលត្រួត ដោយអំណាចការប្រញាប់ប្រញាល់ ។

បទថា **ឈាយ** សេចក្តីថា ចូរចម្រើនឈាន ដោយអំណាចនៃឈានដែលសម្បយុត្តដោយផលសមាបត្តិ និងដោយអំណាចនៃទិព្វវិហារជ្ឈានជាដើម ដើម្បីនៅជាសុខក្នុងទិដ្ឋធម៌ ។

ព្រះថេរៈហៅខ្លួនលោកថា សុមង្គល ដើម្បីសម្តែងការអើពើក្នុងឈាន ទើបលោកពោលត្រួតទុក ។

បទថា **អប្បមត្តោ វិហរ** សេចក្តីថា អ្នកត្រូវជាបុគ្គលមិនប្រមាទក្នុងទីទូទៅនោះឯង ដោយការដល់នូវការបរិបូណ៌នៃសតិ និងបញ្ញា នៃសុមង្គល

ឥឡូវនេះ អ្នកចូរនៅជាសុខចុះ ។ អាចារ្យពួកខ្លះពោលថា កាលមិនទាន់សម្រេចអរហត្ត វិបស្សនាប្រព្រឹត្តទៅតាមគន្ធ ព្រះថេរៈរង្កៀសនូវសេចក្ដីទុក្ខរបស់យាវាសដែលជួបមកហើយ ទើបពោលគាថានេះ ដើម្បីឲ្យកើតសេចក្ដីត្រេកអរក្នុងសាសនា ក្រោយមកចម្រើនវិបស្សនាហើយ ក៏សម្រេចអរហត្ត ។ តាមមតិកេចិអាចារ្យទាំងនោះ អត្ថរបស់បទថា **ឈាយ អប្បមត្តោ វិហរ** រមែងត្រឹមត្រូវដោយពិត សូម្បីដោយអំណាចនៃមគ្គ ក្នុងវិបស្សនា ។

## អដ្ឋកថា សុមង្គលត្ថេរគាថា ចប់

## សានុត្ថេរគាថា

[ ៤៥ ] បពិត្រមាតា ពួកញាតិតែងយំរកបុគ្គលដែលស្លាប់ហើយ ឬបុគ្គលដែលរស់នៅតែមិនបានជួបប្រទះ បពិត្រមាតា ពួកញាតិឃើញអាត្មាកំពុងរស់នៅ បពិត្រមាតា ព្រោះហេតុអ្វីទើបអ្នកមាតាយំរកអាត្មា ។

សានុត្ថេរ ។

## អដ្ឋកថា

## សានុត្ថេរគាថា

[ ៤៥ ] គាថារបស់ព្រះសានុត្ថេរ មានពាក្យផ្ដើមថា **មតំ វា អម្ម រោ-ទន្តិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះថេរៈអង្គនោះ ក៏មានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកប្បទី ៩៤ រាប់អំពីកប្បនេះ កុលបុត្តនោះ បានថ្វាយទឹកដើម្បីលាង ព្រះហស្ត ព្រះបាទ និងដើម្បីខ្ពុរព្រះឱស្ឋ ដល់ព្រះមានព្រះភាគព្រះនាមថា សិទ្ធត្ថ ។ ក្នុងវេលាសោយ ព្រះសាស្ដាមានបំណងលាងព្រះហស្តនិងព្រះបាទ ។ កុលបុត្តនោះ កំណត់អាការរបស់ព្រះសាស្ដាហើយ នាំយកទឹកទៅថ្វាយ ។ ព្រះសាស្ដាទ្រង់លាងព្រះហស្តនិងព្រះបាទ ហើយទ្រង់សោយ មានពុទ្ធបំណងនឹងខ្ពុរព្រះឱស្ឋ កុលបុត្តនោះយល់អាការនោះ ទើបបង្អោនទឹកខ្ពុរព្រះឱស្ឋថ្វាយ ព្រះសាស្ដាទ្រង់ខ្ពុរព្រះឱស្ឋហើយ ទ្រង់បញ្ចប់

ការជម្រះព្រះឱស្ឋ ។ ព្រះមានព្រះភាគ ទ្រង់អាស្រ័យសេចក្ដីអនុគ្រោះក្នុងវេយ្យាវច្ចកិច្ច ដែលកុលបុត្តនោះធ្វើដោយអើពើសព្វគ្រប់ដោយអាការៈយ៉ាងនេះ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក ធ្វើបុណ្យរឿយៗ អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ បដិសន្ធិក្នុងផ្ទះឧបាសកម្នាក់ក្នុងនគរសាវត្ថី ។ កាលកុលបុត្តនោះនៅក្នុងផ្ទៃម្ដាយ បិតាក៏ចាកចេញទៅកាន់ទីដទៃ លុះគ្រប់ ១០ ខែ ឧបាសិកាក៏ប្រសូត ហើយដាក់ឈ្មោះថា សានុ ។

កាលសានុកុមារចម្រើនវ័យដោយលំដាប់ ឧបាសិកា ក៏ឲ្យសានុកុមារដែលមានអាយុ ៧ ឆ្នាំប៉ុណ្ណោះបព្វជ្ជាក្នុងសម្នាក់របស់ភិក្ខុទាំងឡាយ ដោយគិតថាសានុកុមារនេះនឹងជាបុគ្គលមិនមានអន្តរាយ ចម្រើនធំធាត់មានសេចក្ដីសុខដោយចំណែកមួយ ដោយឧបាយយ៉ាងនេះ ។ កុលបុត្តនោះមានឈ្មោះប្រាកដថា សានុសាមណេរ ជាអ្នកមានបញ្ញា សម្បូរដោយវត្ត ជាពហូស្សូតជាព្រះធម្មកថិក ជាអ្នកមានអធ្យាស្រ័យប្រកបដោយមេត្តាក្នុងសត្វទាំងឡាយ បានជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ទេវតានិងមនុស្សទាំងឡាយ ដូច្នេះ ។ រឿងទាំងអស់ គប្បីជ្រាបយ៉ាងពិស្ដារ ដោយន័យដូចពោលហើយក្នុងសានុសូត្រ[១]នោះឯង ។

មាតាក្នុងអតីតជាតិរបស់សានុសាមណេរនោះ កើតក្នុងកំណើតយក្ខ ។

---

១-បិ.៣០.ទំ.២១៤ ។

ទើបយក្ខទាំងឡាយគោរពកោតក្រែងច្រើន ព្រោះសម្គាល់ថា នាងជាមាតារបស់សានុត្ថេរ ។ ពេលវេលាកន្លងទៅយ៉ាងនេះ ថ្ងៃមួយព្រះសានុកើតគំនិតចង់សឹក ជាអ្នករាយមាយ ព្រោះមិនមានយោនិសោមនសិការ ដូចប្រកាសឲ្យដឹងនូវទោសនៃភាពជាបុថុជ្ជន ។ យក្ខិនីដែលជាមាតារបស់សានុសាមណេរដឹងហេតុនោះ ទើបប្រាប់ដល់មាតាដែលជាមនុស្សថា សានុសាមណេរជាបុត្ររបស់នាង មានគំនិតកើតឡើងថា អញនឹងសឹក ព្រោះដូច្នោះ ចូរនាងទៅពោលយ៉ាងនេះថា

> នាងគប្បីនិយាយប្រាប់សានុសាមណេរ ដែលភ្ញាក់ឡើងថានេះជាពាក្យរបស់ពួកយក្ស ( ប្រាប់ ) ថា លោកកុំធ្វើអំពើអាក្រក់ក្នុងទីចំពោះមុខឬទីកំបាំងមុខឡើយ បើលោកនឹងធ្វើឬកំពុងធ្វើនូវអំពើលាមក លោកទុកជាហោះរត់ទៅ ក៏មិនរួចអំពីសេចក្តីទុក្ខដែរ ដូច្នេះ ។

កាលពោលយ៉ាងនេះហើយ យក្ខិនីជាមាតាក៏អន្តរធានទៅក្នុងទីនោះឯង ឯមាតាជាមនុស្សស្តាប់ពាក្យនោះហើយ ដល់នូវបរិទេវនាការ និងការសោយសោក ជាអ្នកពេញដោយសេចក្តីទុក្ខ ។

ក្នុងវេលាព្រឹក សានុសាមណេរស្លៀកដណ្តប់ហើយ កាន់បាត្រនិងចីវរចូលទៅកាន់សម្នាក់របស់មាតាទើបមាតាយំ ក៏ពោលថា តើញោមយំព្រោះអាស្រ័យអ្វី មាតាឆ្លើយថា ព្រោះអាស្រ័យកូន ទើបពោលគាថាដល់មាតាថា

បពិត្រមាតា ពួកញាតិតែងយំរកបុគ្គលដែលស្លាប់ហើយ ឬ
បុគ្គលដែលរស់នៅតែមិនបានជួបប្រទះ បពិត្រមាតាពួកញាតិ
ឃើញអាត្មាកំពុងរស់នៅ បពិត្រមាតា ព្រោះហេតុអ្វី ទើប
អ្នកមាតាយំរកអាត្មា ដូច្នេះ ។

គាថានោះមានអត្ថដូច្នោះថា បពិត្រអ្នកម៉ែធម្មតាញាតិនិងមិត្តអ្នកយំរមែងយំប្រារព្ធញាតិឬមិត្តរបស់ខ្លួន ដែលស្លាប់ទៅហើយ ព្រោះការស្លាប់ទៅកាន់បរលោកហើយ ម្យ៉ាងទៀត ញាតិក្តី មិត្តក្តីណាមួយនៅមានជីវិតមិនប្រាកដខ្លួនព្រោះធ្វើដំណើរទៅប្រទេសដទៃ ក៏យំដល់ញាតិឬមិត្តនោះ ដោយហេតុទាំង ២ យ៉ាងនេះ មិនមានក្នុងអាត្មា កាលបើដូច្នោះ ញោមឃើញអាត្មានៅមានជីវិតរស់នៅទ្រទ្រង់សរីរៈ ឈរខាងមុខ ហេតុអ្វីទើបញោមយំ គឺការដែលញោមយំប្រារព្ធអាត្មាមិនមានហេតុសមគួរឡើយ ដូច្នេះ ។

មាតារបស់សានុសាមណេរស្តាប់ពាក្យនោះហើយ កាលនឹងសម្តែងការសឹកបាត់ជាមរណៈក្នុងអរិយវិន័យ ដោយទំនងនៃសុត្តបទថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាពោលលាសិក្ខា ត្រឡប់ទៅកាន់ភេទថោកទាប ភិក្ខុនោះឈ្មោះថាដល់នូវមរណៈនោះ ( ក្នុងវិន័យរបស់ព្រះអរិយៈ ) ដូច្នេះ ទើបពោល ២ គាថាថា

លោកកូន ជនទាំងឡាយតែងយំរកបុគ្គលដែលស្លាប់បាត់ទៅ
ហើយឬបុគ្គលដែលរស់នៅតែគេមិនឃើញ ម្យ៉ាងទៀតបុគ្គល
**ណាលះបង់កាមទាំងឡាយហើយ បែរជាត្រឡប់មករកកាម**

**ក្នុងលោកនេះវិញ** លោកកូន សូម្បីតែបុគ្គលនោះ ក៏ពួកជន យំរកដែរ ព្រោះថា **បុគ្គលនោះរស់នៅមែន** តែទុកដូចជា មនុស្សស្លាប់ហើយ លោកកូន ខ្ញុំបានស្រង់លោកអំពី**ផេះក្តៅ** គឺយាវាសហើយ លោកចង់ធ្លាក់ទៅក្នុងផេះក្តៅវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **លះបង់កាមទាំងឡាយហើយ** សេចក្តីថា លះវត្ថុកាមទាំងឡាយដោយមានអជ្ឈាស្រ័យបង្អោនទៅក្នុងនេក្ខម្មៈ ឯការលះវត្ថុកាមនោះ គប្បីជ្រាបដោយអំណាចនៃការលះកិលេសកាមដោយតទង្គប្បហាន ។ ក្នុងទីនេះបព្វជ្ជាលោកបំណងយកថាជាការលះបង់កាម ។

បទថា **បែរជាត្រឡប់មករកកាម ក្នុងលោកនេះវិញ** សេចក្តីថា ត្រឡប់មកក្នុងផ្ទះនេះទៀតនោះឯង ។ លោកពោលសំដៅដល់ការវិលមកដើម្បីភាពជាបុគ្គលថោកទាប ។ បទថា **បុគ្គលនោះ** សេចក្តីថា បុគ្គលណាបួសហើយសឹក ពួកយើងរមែងយំដល់បុគ្គលនោះឯងដែលដូចជាស្លាប់ហើយ ។ បើមានពាក្យសួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបុគ្គលនោះ ទោះបីមានជីវិតតទៅ ក៏ដូចជាមនុស្សស្លាប់ហើយ គឺបុគ្គលណា ក្រោយអំពីសឹកទៅ ទោះបីមានជីវិតរស់នៅ បុគ្គលនោះឈ្មោះថាស្លាប់ហើយចាកប្រយោជន៍នោះឯង ព្រោះស្លាប់ចាកគុណធម៌ ឥឡូវនេះ ដើម្បីឲ្យសានុសាមណេរនោះកើតនូវសេចក្តីសង្វេគ ទើបមាតាពោលពាក្យជាដើមថា **ផេះក្តៅ** ។

អត្ថនៃគាថានោះដូច្នេះថា ភាវៈរបស់គ្រហស្ថឈ្មោះថា ដូចជាផេះក្តៅ ព្រោះដូចគ្នានឹងនរកឈ្មោះថា **កុក្កុឡ** ដោយអត្ថថាដុត ព្រោះដូចជាអណ្តាត

ភ្លើងដុតហើយទាំងថ្ងៃទាំងយប់ ដែលខ្ញុំជាអ្នកមានសេចក្ដីអនុគ្រោះលើកឡើង ហើយ គឺដកឡើងហើយ នៃបាសានុ លោកនៅប្រាថ្នាធ្លាក់ទៅកាន់រណ្ដៅផេះក្ដៅ គឺបំណងនឹងធ្លាក់ទៅកាន់រណ្ដៅផេះក្ដៅឬ ដូច្នេះ ។

សានុសាមណេរស្ដាប់ពាក្យនោះហើយ កើតសេចក្ដីសង្វេគ ផ្ដើមនូវវិបស្សនាហើយសម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំឃើញ ( នូវព្រះសិទ្ធត្ថសម្ពុទ្ធ ) ជាសមណៈកំពុងឆាន់ បានដងទឹកថ្វាមិនល្អក់ ១ ក្អម ថ្វាយដល់ព្រះសិទ្ធត្ថៈ ។ ក្នុងថ្ងៃនេះខ្ញុំមិនមានមន្ទិល ប្រាសចាកមន្ទិល អស់សេចក្ដីសង្ស័យក្នុងភពដែលខ្ញុំកើតហើយផលរមែងកើតដល់ខ្ញុំ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទឹក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយទឹក ។ ក្នុងកប្បទី ៦១ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ១ អង្គព្រះនាមវិមលៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ គិតថា ការចម្រើនវិបស្សនា និង

---

១-ក្នុងអបទានជាព្រះ ឧទកទាយកត្ថេរ ។

ការសម្រេចអរហត្តកើតដល់អញដោយអំណាចនៃគាថានេះ ដូច្នេះហើយទើបលើកគាថានោះឯងឡើងជាឧទាន ។

### អដ្ឋកថា សានុត្ថេរគាថា ចប់

## រមណីយវិហារិត្ថេរគាថា

[ ៤៦ ] គោអាជានេយ្យដ៏ប្រសើរ ទោះបីភ្លាត់រមែងឈរស៊ប់វិញបានយ៉ាងណា ( អ្នកទាំងឡាយចូរចំណាំខ្ញុំ ) ថាជាសាវករបស់ព្រះសម្មាសម្ពុទ្ធ ដែលបរិបូណ៌ដោយទស្សនសម្បត្តិ ( គ្រប់គ្រាន់ដោយការឃើញ ) ក៏យ៉ាងនោះដែរ ។

### រមណីយវិហារិត្ថេរ ។

## អដ្ឋកថា
## រមណីយវិហារិត្ថេរគាថា

[ ៤៦ ] គាថារបស់ព្រះរមណីយវិហារិត្ថេរ មានពាក្យផ្ដើមថា **យថាបិ ភទ្ទោ អាជញ្ញោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះថេរៈនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះ

ពុទ្ធអន្តរមុនៗ សន្សំបុណ្យទុកជាច្រើនក្នុងភពនោះៗ ក្នុងកប្បទី ៩១ រាប់អំពីភទ្ទកប្បនេះ ឃើញព្រះមានព្រះភាគ ព្រះនាមថា វិបស្សី ហើយមានចិត្តជ្រះថ្លាថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ធ្វើការបូជាដោយផ្កាសិរមាន់ដោយបុញ្ញកម្មនោះ កើតក្នុងទេវលោក ហើយធ្វើបុណ្យ អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តសេដ្ឋីក្នុងក្រុងរាជគ្រឹះ ដល់នូវការវង្វេងក្នុងកាមគុណ ព្រោះការស្រវឹងក្នុងភាពកំលោះ ថ្ងៃមួយកុលបុត្តនោះ ឃើញបុរសម្នាក់ជាសហាយស្មន់ជាមួយប្រពន្ធអ្នកដទៃ ត្រូវទណ្ឌកម្មមានប្រការផ្សេងៗ កើតសេចក្តីសង្វេគ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា ហើយបួស បួសហើយ ព្រោះខ្លួនជាបុគ្គលរាគចរិត ទើបបោសសម្អាតបរិវេណរហូតស្អាត តម្កល់ទឹកឆាន់ ទឹកប្រើប្រាស់យ៉ាងល្អ តាក់តែងគ្រែតាំងយ៉ាងរៀបរយ ។ ព្រោះហេតុនោះ ទើបលោកមាននាមប្រាកដថា រមណីយវិហារី ។

ព្រោះភាពជាអ្នកក្រាស់ដោយរាគៈ ទើបលោកធ្វើកិច្ច ដោយមិនត្រូវឧបាយ ត្រូវអាបត្តិ ព្រោះតាំងចិត្តធ្វើសុក្កៈឲ្យឃ្លាតចាកទី មានវិប្បដិសារៈថា គួរតិះដៀលពិតហ្ន៎ អញជាបុគ្គលយ៉ាងនេះ នៅបរិភោគអាហារដែលគេឲ្យដោយសទ្ធាបានដូចម្តេច ដើរទៅដោយគិតថា អញទឹងសឹក អង្គុយសម្រាកត្រង់គល់ឈើក្នុងរវាងផ្លូវ កាលហ្វូងរទេះធ្វើដំណើរកាត់តាមផ្លូវនោះ គោដែលគេទឹមមួយហត់នឿយធ្លាក់ទៅក្នុងផ្លូវដែលមិនរាបស្មើ ម្ចាស់រទេះ ក៏ដោះគោនោះចេញពីនឹម ឲ្យស៊ោឲ្យទឹក លុះបាត់ហត់នឿយហើយ ក៏ចាប់ទឹមបន្តដំណើរ

ទៅទៀត ព្រះថេរៈឃើញដូច្នោះក៏គិតថា គោនេះភ្ជាត់ខុសផ្លូវម្ដង គង់ក្រោកឡើងនាំភារៈរបស់ខ្លួនទៅបាន យ៉ាងណា អញក៏យ៉ាងនោះ សូម្បីភ្លាំងភ្លាត់ខុះម្ដងម្កាលដោយអំណាចកិលេស ក៏គួរក្រោកឡើងបំពេញសមណធម៌ ដូច្នេះហើយ កើតយោនិសោមនសិការ ត្រឡប់ទៅប្រាប់ការប្រព្រឹត្តទៅរបស់ខ្លួនដល់ព្រះឧបាលិត្ថេរ ចេញចាកអាបត្តិដោយវិធីដែលព្រះឧបាលិប្រាប់ ធ្វើសីលឲ្យបរិសុទ្ធ ចម្រើនវិបស្សនា សម្រេចអរហត្តក្នុងកាលមិនយូរឡើយសមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំឃើញស្នាមព្រះបាទ ដែលទ្រង់ជាន់ទុក ប្រដាប់ដោយគ្រឿងអលង្ការគឺចក្ក ហើយដើរទៅតាមលំដាប់នៃស្នាមព្រះបាទរបស់ព្រះមហេសីព្រះនាមវិបស្សី ។ ខ្ញុំបានឃើញផ្កាស្មៅកន្ទុយដំរីរីកល្អហើយបូជាទាំងឫស ខ្ញុំជាអ្នកមានចិត្តរីករាយ បានថ្វាយបង្គំនូវស្នាមព្រះបាទដ៏ប្រសើរដោយចិត្តរីករាយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៥៧ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ១ អង្គ ព្រះនាមវិតមលៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

១-ក្នុងអបទានជាព្រះ គោរណ្ឌបុប្ផិយត្ថេរ ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ សោយវិមុត្តិសុខ បានពោលនូវគាថាដែលសម្តែងដល់ការសម្រេចអរិយធម៌ មួយអន្លើដោយបដិបទាខាងដើមរបស់ខ្លួនថា

គោអាជានេយ្យដ៏ប្រសើរ ទោះបីភ្លាត់រមែងឈរស៊ប់វិញបាន យ៉ាងណា ( អ្នកទាំងឡាយចូរចំណាំខ្ញុំ ) ថាជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធដែលបរិបូណ៌ដោយទស្សនសម្បត្តិ (គ្រប់គ្រាន់ដោយការឃើញ) ក៏យ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខលិត្វា** បានដល់ ដួលហើយ ។ បទថា **បតិតិដ្ឋតិ** បានដល់ ត្រឡប់ក្រោកឡើងបាន គឺឈរក្នុងទីដើមវិញ ។

បទថា **ឯវំ** សេចក្តីថា គោអាជានេយ្យដ៏ប្រសើរនាំភារៈទៅដល់ទីដែលមានអន្តរាយ ក៏ដួលចុះម្តងម្កាល ព្រោះទីមិនស្មើ មិនរលាស់នឹមចោលព្រោះហេតុនោះ ទោះបីដួលទៅ ក៏ក្រោកឡើងបាន ព្រោះសម្បូរដោយកម្លាំងសម្ពុះនិងសេចក្តីព្យាយាម ឈរបានដោយសភាពនៃខ្លួននោះឯង ហើយនាំភារៈទៅបាន យ៉ាងណា ភិក្ខុដែលជួបនូវការលំបាកព្រោះកិលេស ក៏យ៉ាងនោះ ។ លោកទាំងឡាយ ចូរចាំនូវខ្ញុំដែលសម្បូរដោយទស្សនៈ ព្រោះទោះបីភ្លាំងភ្លាត់ព្រោះភ្លាំងភ្លាត់ចាកការធ្វើ គង់ធ្វើការភ្លាំងភ្លាត់នោះឲ្យបរិសុទ្ធវិញ ព្រោះសម្បូរដោយកម្លាំងនិងសេចក្តីព្យាយាមដោយសម្មាទិដ្ឋិក្នុងមគ្គ ។ បន្ទាប់អំពីនោះទើបឈ្មោះថា ជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ព្រោះកើតហើយដោយអរិយជាតិក្រោយអំពីស្តាប់ធម៌ ឈ្មោះថា ជាបុត្តដែលកើតអំពីទ្រូង ព្រោះភាពជាអភិ-

ជាតបុត្ត ដែលកើតដោយសេចក្តីព្យាយាម ក្នុងព្រះឱរះរបស់ព្រះសម្មាសម្ពុទ្ធ នោះ និងឈ្មោះថា ជាអាជានេយ្យ ព្រោះមានកិច្ចដូចគ្នានឹងគោអាជានេយ្យដ៏ចម្រើន ។

## អដ្ឋកថា រមណីយវិហារិត្ថេរគាថា ចប់

## សមិទ្ធិត្ថេរគាថា

[ ៤៧ ] អាត្មាចេញចាកផ្ទះចូលកាន់ផ្នួស បួសដោយសទ្ធា សតិនិងបញ្ញារបស់ខ្ញុំចម្រើនហើយ ទាំងចិត្តក៏ខ្ញុំតម្កល់ទុកប្រពៃហើយ ( នែមារចិត្តបាប ) អ្នកចូរធ្វើអំពើដ៏គួរតាមប្រាថ្នាចុះ អ្នកនឹងបៀតបៀនអាត្មាមិនបានទេ ។

សមិទ្ធិត្ថេរ ។

## អដ្ឋកថា

## សមិទ្ធិត្ថេរគាថា

[ ៤៧ ] គាថារបស់ព្រះសមិទ្ធិត្ថេរ មានពាក្យផ្ដើមថា **សទ្ធាយាហំ បព្វជិតោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះថេរៈនេះក៏មានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទុកច្រើនក្នុងភពនោះៗ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ឃើញព្រះមានព្រះភាគព្រះនាមថាសិទ្ធត្ថ ជាអ្នកមានចិត្តជ្រះថ្លា កាន់យកផ្កាទាំងទងចងជាបាច់បូជាហើយ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក ធ្វើបុណ្យជាច្រើនអន្ទោលទៅមកក្នុងសុគតិភព ។ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទះមានត្រកូលក្នុងនគររាជគ្រឹះ ។ តាំងអំពីកុលបុត្តនោះកើតហើយ ត្រកូលនោះក៏ចម្រើនស្ដុកស្ដម្ភដោយទ្រព្យ និងស្រូវជាដើម អត្តភាពរបស់កុលបុត្តនោះក៏ស្អាតគួរពិតពិលរមិលមើល ប្រកបដោយគុណសម្បត្តិ ព្រោះដូច្នោះ ទើបមាននាមប្រា-

កដជាសមិទ្ធិព្រោះរុងរឿងដោយទ្រព្យសម្បត្តិនិងបរិបូណ៌ដោយគុណសម្បត្តិ ។

កុលបុត្តនោះ ឃើញពុទ្ធានុភាពក្នុងសមាគមនៃព្រះបាទពិម្ពិសារ មានសទ្ធាបួសហើយ ខ្វល់ខ្វាយក្នុងភាវនា កាលព្រះមានព្រះភាគគង់នៅក្នុងតបោទារាម ថ្ងៃមួយកុលបុត្តនោះគិតយ៉ាងនេះថា ជាលាភហើយហ្ន៎ ព្រះសាស្តារបស់អញជាព្រះសម្មាសម្ពុទ្ធ ឯអញក៏បួសក្នុងធម្មវិន័យ ដែលទ្រង់ត្រាស់ល្អហើយ ទាំងសព្រហ្មចារីរបស់អញក៏ជាអ្នកមានសីលមានកល្យាណធម៌កាលលោកគិតយ៉ាងនេះ ក៏កើតបីតិសោមនស្សដ៏ខ្លាំងក្លា ។ មារមានចិត្តបាបមិនពេញចិត្តទើបបន្លឺសំឡេងខ្លាំងគួរខ្លាច ក្នុងទីមិនឆ្ងាយអំពីព្រះថេរៈ ហាក់បីដូចជាផែនដីស្រុត ។ ព្រះថេរៈក៏ក្រាបទូលសេចក្តីនោះ ដល់ព្រះមានព្រះភាគហើយ ។

ព្រះសាស្តាត្រាស់ថា មារបំណងនឹងបោកបញ្ឆោតអ្នក ម្នាលភិក្ខុអ្នកចូរទៅចុះ អ្នកកុំគិតដល់សេចក្តីនោះ ។ ព្រះថេរៈទៅក្នុងទីនោះ ហើយខ្វល់ខ្វាយក្នុងវិបស្សនា សម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

( ខ្ញុំបានឃើញ ) ព្រះសិទ្ធត្ថសម្ពុទ្ធ ព្រះអង្គជាសារថីទូន្មាន
នូវនរៈ ទ្រង់រុងរឿងដូចផ្កាកណិការ គង់នៅត្រង់ចន្លោះភ្នំ ទ្រង់
ញ៉ាំងទិសទាំងពួងឲ្យភ្លឺស្វាង កាលនោះខ្ញុំសៀតព្រួញធ្វើធ្នូមិន
ឲ្យបែកជាពីរ បានកាច់ផ្កាទាំងទង បូជាព្រះពុទ្ធ ។ ក្នុងកប្បទី
៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែល

ស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្ប ទី ៥១ អំពីនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១ អង្គព្រះនាមជុតិន្ធរៈទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ឯមារមិនដឹងថា ព្រះថេរៈនៅក្នុងទីនោះសម្រេចអរហត្ត ជាព្រះខីណាស្រព ក៏បានបញ្ចេញសំឡេងគួរខ្លាចដោយន័យមុននោះឯង ។ ព្រះថេរៈស្តាប់សំឡេងនោះហើយ មិនតក់ស្លុត មិនភ័យខ្លាច ពោលថា នែមារ បុគ្គលដូចអ្នករយពាន់ ក៏មិនធ្វើសូម្បីតែរោមរបស់យើងឲ្យញាប់ញ័របាន ដូច្នេះហើយ កាលនឹងព្យាករអរហត្តផល ទើបភាសិតគាថាថា

អាត្មាចេញចាកផ្ទះចូលកាន់ផ្នួស បួសដោយសទ្ធា សតិនឹងបញ្ញា របស់ខ្ញុំចម្រើនហើយ ទាំងចិត្តក៏ខ្ញុំតម្កល់ទុកប្រពៃហើយ ( នែមារចិត្តបាប ) អ្នកចូរធ្វើអំពើដ៏គួរតាមប្រាថ្នាចុះ អ្នកនឹងបៀតបៀនអាត្មាមិនបានទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សទ្ធាយ** សេចក្តីថា ដោយការជឿកម្ម និងផលនៃកម្ម និងដោយការជឿក្នុងព្រះរតនត្រ័យ ដែលមានការពេញចិត្តក្នុងធម៌ជាសមុដ្ឋាន ។

---

១-ក្នុងអបទានជាព្រះ សលឡមាលិយត្ថេរ ។

ព្រះថេរៈហៅខ្លួនឯង ដោយបទថា **អហំ** ។ បទថា **បព្វជិតោ** សេចក្តីថា ចូលដល់បព្វជ្ជា ។

បទថា **អគារស្មា** បានដល់ ចាកផ្ទះ ឬចាកការនៅគ្រប់គ្រងផ្ទះ ។ បទថា **អនគារិយំ** បានដល់ បព្វជ្ជា ។ បព្វជ្ជានោះ លោកហៅថា **អនគារិយំ** ព្រោះមិនមានកសិកម្ម ពាណិជ្ជកម្មជាដើមណាមួយដែលឲ្យកើតប្រយោជន៍ចំពោះការគ្រប់គ្រងផ្ទះដែលហៅថា **អគារិយ** ។

ដោយបទថា **សតិ បញ្ញា ច មេ វុឌ្ឍា** នេះ ព្រះថេរៈសម្តែងថា តាំងអំពីខណៈនៃវិបស្សនារហូតដល់អរហត្តតាមលំដាប់មគ្គ ធម៌ទាំងនេះ គឺសតិមានការរឭកបានជាលក្ខណៈ បញ្ញាមានការដឹងទូទៅជាលក្ខណៈ ចម្រើនហើយ គឺស្អាតហើយដល់ខ្ញុំ ឥឡូវនេះ នឹងមិនមានធម៌ដែលត្រូវចម្រើនទៀត សតិបញ្ញារបស់ខ្ញុំដល់នូវភាពបរិបូណ៌ហើយ ដូច្នេះ ។

ដោយបទថា **ចិត្តញ្ច សុសមាហិតំ** នេះ ព្រះថេរៈសម្តែងថា ចិត្តរបស់ខ្ញុំតាំងមាំល្អហើយ ដោយអំណាចនៃសមាបត្តិ ៨ និងដោយអំណាចនៃលោកុត្តរសមាធិ ឥឡូវនេះ មិនមានកិច្ចដែលត្រូវធ្វើចិត្តនោះឲ្យតាំងមាំ ព្រោះសមាធិដល់នូវការបរិបូណ៌ហើយ ។ បទថា **កាមំ ករស្សុ រូបានិ** សេចក្តីថា នៃមារមានចិត្តបាប ព្រោះដូច្នោះ អ្នកធ្វើអាការដែលគួររន្ធត់សណាមួយ ប្រាកបញ្ឆោតយើងតាមគាប់ចិត្ត តែអាការដែលគួររន្ធត់សទាំងនោះ មិនអាចធ្វើឲ្យយើងតក់ស្លុតបានឡើយ គឺមិនអាចធ្វើត្រឹមតែការញាប់ញ័រនៃរាងកាយរបស់យើងបានឡើយ ធ្វើម្តេចនឹងធ្វើចិត្តឲ្យប្រែប្រួលបាន ។ ព្រះថេរៈគំរាមមារថា

ព្រោះហេតុនោះ កិរិយានោះ នឹងមានផលត្រឹមតែធ្វើការបង្អៀតបង្អល់ដល់ចិត្តរបស់អ្នកប៉ុណ្ណោះ ។ មារស្ដាប់ដូច្នោះហើយគិតថា ព្រះថេរៈស្គាល់អញហើយ ក៏អន្តរធានក្នុងទីនោះឯង ។

## អដ្ឋកថា សមិទ្ធិត្ថេរគាថា ចប់

## ឧជ្ជយត្ថេរគាថា

[ ៤៨ ] បពិត្រព្រះពុទ្ធ ជាវីរបុគ្គល ខ្ញុំព្រះអង្គសូមមនស្ការព្រះអង្គ ព្រះអង្គជាអ្នករួចស្រឡះចាកកិលេសទាំងពួង ខ្ញុំព្រះអង្គជាអ្នកមិនមានអាសវៈ តែងប្រព្រឹត្តទៅក្នុងស្មាមឱវាទនៃព្រះអង្គ ។

**ឧជ្ជយត្ថេរ ។**

## អដ្ឋកថា

## ឧជ្ជយត្ថេរគាថា

[ ៤៨ ] គាថារបស់ព្រះឧជ្ជយត្ថេរ មានពាក្យផ្ដើមថា **ឆមោ តេ ពុទ្ធវីរត្ថុ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះថេរៈនេះ ក៏មានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ធ្វើបុណ្យជាច្រើនទុកក្នុងភពនោះៗ ។ ក្នុងកប្បទី ៩២ រាប់អំពីកប្បនេះ កុលបុត្តនេះ ឃើញព្រះមានព្រះភាគព្រះនាមថាតិស្សៈ មានចិត្តជ្រះថ្លា ធ្វើការបូជាដោយផ្កាកណិការ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ កើតក្នុងទេវលោក ធ្វើបុណ្យហើយអន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តរបស់សោត្ថិយព្រាហ្មណ៍ក្នុងក្រុងរាជគ្រឹះ មានឈ្មោះថាឧជ្ជយៈ ។

កុលបុត្តនោះចម្រើនវ័យហើយ ជាអ្នករៀនចប់ត្រៃវេទ មើលមិនឃើញសារៈក្នុងត្រៃវេទនោះ កាលឧបនិស្ស័យសម្បត្តិជាស់តឿន ក៏ទៅកាន់វេឡុ-

វនវិហារ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា មានសទ្ធាបព្វជ្ជាហើយរៀនកម្មដ្ឋានដែលសមគួរដល់ចរិត នៅក្នុងព្រៃ ចម្រើនវិបស្សនាសម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ក្នុងកាលនោះ ខ្ញុំឃើញដើមកណិការមានផ្ការីក ទើបបេះយកទៅបូជាព្រះតិស្សសម្ពុទ្ធ ទ្រង់ធ្វងអន្ទង់ហើយ មិនញាប់ញ័រដោយលោកធម៌ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៣៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣ ជាតិ ព្រះនាមអរុណបាលដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលលោកសម្រេចអរហត្តហើយទៅកាន់សម្នាក់របស់ព្រះសាស្តាថ្វាយបង្គំហើយអង្គុយក្នុងចំណែកម្ខាង កាលនឹងព្យាករអរហត្តផល ដោយអាការសរសើរព្រះមានព្រះភាគ បានពោលគាថាថា

បពិត្រព្រះពុទ្ធជាវីរបុគ្គល ខ្ញុំព្រះអង្គសូមនមស្ការព្រះអង្គ ព្រះអង្គជាអ្នករួចស្រឡះចាកកិលេសទាំងពួង ខ្ញុំព្រះអង្គជាអ្នកមិនមានអាសវៈតែងប្រព្រឹត្តទៅក្នុងស្នាមឱវាទនៃព្រះអង្គ ដូច្នេះ ។

---

១-ក្នុងអបទានជាព្រះ កណិការបុប្ផិយត្ថេរ ។

បណ្ដាបទទាំងនោះ បទថា **នមោ** សំដែងដល់ការនមស្ការ ។ បទថា **តេ** សំដែងដល់ការឱនលំទោនដោយកិរិយានមស្ការ អធិប្បាយថា សូមនមស្ការដល់ព្រះអង្គ ។

បទថា **ពុទ្ធ វីរ** ត្រឹមតែជាពាក្យហៅព្រះមានព្រះភាគ អធិប្បាយថា ព្រះមានព្រះភាគ បណ្ឌិតហៅថា **ពុទ្ធ** ព្រោះត្រាស់ដឹងអត្ថ មានអភិញ្ញាជាដើម ដោយព្រះសយម្ភូញាណ មានញាណដែលគួរដឹងជាដើម យ៉ាងណា សូម្បីបណ្ឌិតហៅថា **វីរ** ក៏យ៉ាងនោះដូចគ្នា ព្រោះទ្រង់ប្រកបទៅដោយសេចក្ដីព្យាយាមធំដែលទ្រង់ផ្ដើមដោយអំណាចនៃការញាំញីមារទាំង ៥ ។

បទថា **អត្ថុ** ស្មើនឹង **ហោតុ** ប្រែថា ចូរមាន ។ បទថា **អត្ថុ** នោះសម្ពន្ធចូលជាមួយបទថា **នមោ** ។

បទថា **វិប្បមុត្តោសិ សព្វធិ** សេចក្ដីថា បានរួចផុតហើយ គឺប្រាសហើយចាកកិលេសទាំងពួង និងក្នុងសង្ខារទាំងពួង គឺមិនមានអ្វីឡើយដែលទ្រង់មិនរួចផុតនោះ ព្រោះហេតុដែលខ្ញុំព្រះអង្គនៅក្នុងឱវាទរបស់ព្រះអង្គទើបជាអ្នកមិនមានអាសវៈនៅជាសុខ អធិប្បាយថា ខ្ញុំព្រះអង្គនៅដោយការប្រព្រឹត្តប្រតិបត្តិ និងក្នុងបញ្ញា គឺក្នុងឱវាទ បានដល់ ក្នុងមគ្គដែលដល់ហើយរបស់ព្រះអង្គ បដិបត្តិតាមសតិ តាមកម្លាំង ឈ្មោះថា **អនាសវោ** ព្រោះលះអាសវៈទាំង ៤ មានកាមាសវៈជាដើម បានអស់ហើយ បពិត្រព្រះវីរៈ ខ្ញុំព្រះអង្គសូមនមស្ការដល់ព្រះមានព្រះភាគអង្គនោះ ។

**អដ្ឋកថា ឧជ្ជយត្ថេរគាថា ចប់**

## សញ្ជយត្ថេរគាថា

[ ៤៩ ] ក្នុងកាលដែលខ្ញុំចេញចាកផ្ទះចូលកាន់ផ្នួស ខ្ញុំមិនធ្លាប់ដឹងនូវសេចក្តីត្រិះរិះ ប្រកបដោយទោសដែលមិនមែនជាអរិយធម៌ទេ ។

សញ្ជយត្ថេរ ។

## អដ្ឋកថា

## សញ្ជយត្ថេរគាថា

[ ៤៩ ] គាថារបស់ព្រះសញ្ជយត្ថេរ មានពាក្យផ្តើមថា **យតោ អហំ** ដូច្នេះ ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាវិបស្សី បានរួបរួមវត្ថុដែលខ្ចាត់ខ្ចាយរាត់រាយក្នុងទីប្រជុំធំ ធ្វើបុណ្យឧទ្ទិសព្រះរតនត្រ័យ ខ្លួនឯងជាបុគ្គលក្រីក្រទើបបានជាអ្នកខ្វល់ខ្វាយបំពេញបុណ្យនៃគណៈជាដើម កុលបុត្តនោះ ចូលទៅគាល់ព្រះមានព្រះភាគតាមកាលវេលា ថ្វាយបង្គំហើយមានចិត្តជ្រះថ្លា បានធ្វើសេចក្តីខ្វល់ខ្វាយ ( បម្រើ ) ចំពោះភិក្ខុទាំងឡាយ ដោយបុញ្ញកម្មនោះកុលបុត្តនោះទៅកើតក្នុងទេវលោក ធ្វើបុណ្យរឿយៗមក អន្ទោលទៅមកក្នុងសុគតិភពប៉ុណ្ណោះ ។ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តរបស់ព្រាហ្មណ៍ ដែលសម្បូរដោយសម្បត្តិក្នុងនគររាជគ្រឹះ ដោយឈ្មោះមានឈ្មោះថាសញ្ជ័យ ។ កុល

បុត្តនោះចម្រើនវ័យហើយ ឃើញព្រាហ្មណ៍ដែលមានឈ្មោះពោះសំឡេងមានព្រហ្មាយុព្រាហ្មណ៍ និងពោក្ខរសាតិព្រាហ្មណ៍ជាដើម មានចិត្តជ្រះថ្លាក្នុងព្រះសាស្តា ក៏កើតនូវការជ្រះថ្លា ចូលទៅគាល់ព្រះសាស្តា ។

ព្រះបរមសាស្តា ទ្រង់សម្តែងធម៌ដល់កុលបុត្តនោះ កុលបុត្តនោះ ស្តាប់ធម៌ហើយ បានជាព្រះសោតាបន្ន ហើយបព្វជ្ជា កាលបព្វជ្ជា គ្រាន់តែចុងកាំបិតដល់សីសៈប៉ុណ្ណោះ ក៏បានអភិញ្ញា ៦ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះមានព្រះភាគព្រះនាមវិបស្សីជាមេគណៈ ខ្ញុំជាអ្នកបម្រើ ជាអ្នកខ្វល់ខ្វាយក្នុងកិច្ចទាំងពួង ។ ឯទេយ្យធម៌របស់ខ្ញុំគ្មាន ខ្ញុំមានចិត្តជ្រះថ្លា ថ្វាយបង្គំព្រះបាទារបស់ព្រះសាស្តា ជាព្រះសុគតស្វែងរកគុណដ៏ធំ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើការខ្វល់ខ្វាយបម្រើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការខ្វល់ខ្វាយបម្រើ ។ ក្នុងកប្បទី ៨ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្រពត្តិព្រះនាមសុ-ចិន្តិយៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិ-បត្តិហើយ ដូច្នេះ[១] ។

---

១-ក្នុងអបទានជាព្រះ វេយ្យាវច្ចកត្ថេរ ។

លោកជាអ្នកបានអភិញ្ញា ៦ កាលព្យាករអរហត្តផល បានពោលគាថាថា

ក្នុងកាលដែលខ្ញុំចេញចាកផ្ទះ ចូលកាន់ផ្នួស ខ្ញុំមិនធ្លាប់ដឹងនូវ
សេចក្ដីត្រិះរិះ ប្រកបដោយទោស ដែលមិនមែនជាអរិយធម៌
ទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យតោ អហំ បព្វជិតោ** សេចក្ដីថា ចាប់តាំងអំពី គឺរាប់អំពីខ្ញុំបានបួសហើយ ។

អធិប្បាយថា ចាប់តាំងអំពីពេលដែលខ្ញុំបួសហើយ ខ្ញុំមិនស្គាល់នូវការត្រិះរិះដែលមិនប្រសើរប្រកបដោយទោសឡើយ ដោយអត្ថ គឺខ្ញុំមិនស្គាល់នូវការត្រិះរិះដែលប្រកបដោយទោស មានរាគៈជាដើម បន្ទាប់អំពីនោះឯង ទើបឈ្មោះថា មិនប្រសើរ គឺអាក្រក់ ។ ម្យ៉ាងទៀត ឈ្មោះថា មិនមែនជារបស់អរិយៈ ព្រោះព្រះអរិយៈទាំងឡាយ មិនប្រព្រឹត្ត និងព្រោះជាបុគ្គលដែលមិនមែនព្រះអរិយៈប្រព្រឹត្ត គឺជារបស់លាមក បានដល់ មិច្ឆាវិតក្ក មានកាមវិតក្កជាដើម ។ ដែលបានឈ្មោះថា សង្កប្ប ព្រោះត្រិះរិះដល់គុណដែលមិនមានពិតជាដើម ក្នុងអារម្មណ៍ដែលខ្លួនឲ្យកើតហើយ ដូច្នោះស្មើគ្នានឹងព្រះថេរៈព្យាករអរហត្តផលថា ខ្ញុំសម្រេចអរហត្តហើយ ក្នុងពេលដែលចុងកាំបិតកោរដល់ក្បាលនោះឯង ។

អដ្ឋកថា សញ្ជយត្ថេរគាថា ចប់

## រាមណេយ្យកត្ថេរគាថា

[ ៥០ ] ចិត្តរបស់ខ្ញុំនោះមិនញាប់ញ័រ ព្រោះសម្រែកនៃសត្វរ៉ៃ ឬព្រោះសត្វព្រៃដែលគួរខ្លាចទេ ព្រោះថា ចិត្តរបស់ខ្ញុំមានអារម្មណ៍មូលតែមួយគ្រេកអរមិនដាច់ ( ក្នុងព្រះនិព្វាន ) ។

រាមណេយ្យកត្ថេរ ។

## អដ្ឋកថា

## រាមណេយ្យកត្ថេរគាថា

[ ៥០ ] គាថានៃព្រះរាមណេយ្យកត្ថេរ មានពាក្យផ្តើមថា **ចិហាចិហា-ភិនទិតេ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទុកក្នុងភពនោះៗជាច្រើន ។ ក្នុងពុទ្ធុប្បាទរបស់ព្រះមានព្រះភាគព្រះនាមថាសិខី កើតក្នុងផ្ទះនៃត្រកូលមួយ លុះដឹងក្តីហើយ ឃើញព្រះមានព្រះភាគ មានចិត្តជ្រះថ្លាហើយ បូជាដោយផ្កាទាំងឡាយ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក ធ្វើបុណ្យតៗមកហើយអន្ទោលទៅមកតែក្នុងសុគតិភពប៉ុណ្ណោះ ។ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលដែលស្តុកស្តម្ភក្នុងនគរសាវត្ថី ចម្រើនវ័យហើយ ជាអ្នកមានសេចក្តីជ្រះថ្លាកើតហើយ ក៏បួសក្នុងកាលដែលព្រះសាស្តាទទួលវិហារឈ្មោះជេតពន រៀនកម្មដ្ឋានដែលសមគួរដល់ចរិត ហើយនៅក្នុងព្រៃ ។ លោកមានឈ្មោះថា

រាមណេយ្យកៈ ព្រោះលោកមានគុណសម្បត្តិសមគួរជាបព្វជិត និងមានបដិបទាដែលគួរជ្រះថ្លា ។ ថ្ងៃមួយ មារបំណងធ្វើឲ្យព្រះថេរៈខ្លាច ទើបស្រែកដោយសំឡេងគួរខ្លាច ។

ព្រះថេរៈស្តាប់សំឡេងនោះហើយ មិនតក់ស្លុតដោយសំឡេងនោះ ព្រោះភាពជាអ្នកធ្ងន់ធ្ងរជាប្រក្រតី ដឹងថានេះជាមារ កាលនឹងសម្តែងការមិនតក់ស្លុតក្នុងសំឡេងនោះ ទើបពោលគាថាដូច្នេះថា

ចិត្តរបស់ខ្ញុំនោះមិនញាប់ញ័រព្រោះសម្រែកនៃសត្វរៃ ឬព្រោះ
សត្វព្រៃដែលគួរខ្លាចទេ ព្រោះថា ចិត្តរបស់ខ្ញុំ មានអារម្មណ៍
មូលតែមួយ ត្រេកអរមិនដាច់ ( ក្នុងព្រះនិព្វាន ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចិហាចិហាភិនទិតេ** សេចក្តីថា ព្រោះហេតុនៃការស្រែករបស់សត្វចាប[១]ដែលបានឈ្មោះថា **ចិហាចិហា** ព្រោះសំឡេងស្រែករឿយៗថា **ចិហាចិហា** អធិប្បាយថា មានសំឡេងយំជាហេតុ ។ បទថា **សិប្បិកាភិរុតេហិ ច** សេចក្តីថា ស្វាដែលមានអាការៈដូចក្មេងស្គមកំព្រឹងមានឈ្មោះដទៃ គឺជាសត្វរពិស លោកហៅថា **សិប្បិក** អាចារ្យពួកខ្លះហៅថា **មហាកលន្ទក** ( កង្ហែនធំ ) ព្រោះសំឡេងស្រែកដូចគ្នានឹងស្វាទាំងឡាយ ។ បទនេះជាតតិយាវិភត្តិចុះក្នុងអត្ថនៃហេតុ អធិប្បាយថា ព្រោះការស្រែករបស់ស្វានោះជាហេតុ ។ បទថា **ន មេ តំ ផន្ទតិ ចិត្តំ** សេចក្តីថា ចិត្តរបស់ខ្ញុំមិនអន្ទះអន្ទែង គឺមិនញាប់ញ័រ ។

---

១-បិដកខ្មែរជា សត្វរៃ ។

លោកអធិប្បាយទុកថា នៃមារមានចិត្តបាប ចិត្តរបស់អាត្មា មិនធ្លាក់ទៅក្រៅកម្មដ្ឋាន ព្រោះហេតុនៃការស្រែកដោយសំឡេងរបស់អ្នកទេ ព្រោះហេតុនៃការស្រែក គឺព្រោះហេតុនៃការបញ្ចេញសំឡេងរបស់ស្វាក្នុងព្រៃនេះ ។ ព្រះថេរៈពោលដល់ហេតុក្នុងការដែលចិត្តមិនធ្លាក់អំពីកម្មដ្ឋានថា **ឯកគ្គំ ឆិរតំ ហិ មេ** ព្រោះថា ចិត្តរបស់ខ្ញុំមានអារម្មណ៍មូលតែមួយ ត្រេកអរមិនដាច់ ( ក្នុងព្រះនិព្វាន ) ដូច្នេះ ។ **ហិ** សព្ទ មានហេតុជាអត្ថ បានដល់ ព្រោះហេតុដែលចិត្តរបស់ខ្ញុំលះបង់នូវការច្រឡូកច្រឡំដោយពួកគណៈ ត្រេកអរហើយ ត្រេកអរក្រៃលែងហើយក្នុងភាពជាបុគ្គលម្នាក់ឯង គឺក្នុងឯកីភាពឬព្រោះហេតុដែលចិត្តរបស់ខ្ញុំលះនូវការរាយមាយខាងក្រៅ ត្រេកអរហើយ ត្រេកអរក្រៃលែងហើយក្នុងឯកីភាព គឺក្នុងឯកគ្គតារម្មណ៍ ឬព្រោះហេតុដែលចិត្តរបស់ខ្ញុំត្រេកអរហើយ ត្រេកអរក្រៃលែងហើយក្នុងព្រះនិព្វានដែលមានភាពតែមួយជាធម៌ឯក ដូច្នោះទើបចិត្តរបស់ខ្ញុំមិនអន្ទះអន្ទែង គឺមិនឃ្លេងឃ្លោងចាកកម្ម-ដ្ឋាន ។ បានឮថា ព្រះថេរៈពោលគាថានេះបណ្តើរ ចម្រើនវិបស្សនាបណ្តើរសម្រេចអរហត្តហើយ ។ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះមានព្រះភាគ ព្រះនាមសិខី ទ្រង់មានវណ្ណៈដូចមាស មានរស្មីច្រើន មានពន្លឺដ៏ប្រសើរ មានមេត្តាចិត្ត មានព្រះស្មារតីស្តេចទៅកាន់ទីចង្ក្រម ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយសរសើរនូវញាណដ៏ឧត្តម ហើយយកនូវផ្កាមិនេលព្រឹក្ស ទៅ

បូជាដល់ព្រះសម្ពុទ្ធ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២៩ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១ អង្គ ព្រះនាមសុមេធយនៈទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

គាថានេះឯង បានជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈ ។

## អដ្ឋកថា រាមណេយ្យកត្ថេរគាថា ចប់

១-ក្នុងអបទានជាព្រះ មិនេលបុប្ផិយត្ថេរ ។

## វិមលត្ថេរគាថា

[ ៥១ ] ផែនដីតែងសើមជ្រាប ( ដោយអាបោធាតុ ) ខ្យល់ក៏រមែងបក់ផ្លុកបន្ទោរ ក៏ជាលប្រវាត់ក្នុងអាកាស ឯវិតក្កៈទាំងឡាយ ( មានកាមវិតក្កៈជាដើម ) របស់ខ្ញុំរមែងរម្ងាប់ ចិត្តរបស់ខ្ញុំ ក៏តម្កល់ទុកល្អហើយ ។

**វិមលត្ថេរ ។**

**ឧទ្ទាន**

និយាយអំពីសិរីវឌ្ឍត្ថេរ ១ ខទិរវនិយរេវតត្ថេរ ១ សុមង្គលត្ថេរ ១ សានុត្ថេរ ១ រមណីយវិហារិត្ថេរ ១ សមិទ្ធិត្ថេរ ១ ឧជ្ជយត្ថេរ ១ សញ្ជយត្ថេរ ១ រាមណេយ្យកត្ថេរ ១ វិមលត្ថេរអ្នកលះបង់កិលេស ១ ។

**ចប់ បញ្ចមវគ្គ ។**

# អដ្ឋកថា

# វិមលត្ថេរគាថា

[ ៥១ ] គាថារបស់ព្រះវិមលត្ថេរ មានពាក្យផ្ដើមថា **ធរណី ច សិញ្ចតិ វា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថា វិបស្សី កើតក្នុងត្រកូលរបស់អ្នកផ្លុំស័ង្ខ ដល់នូវភាពជាអ្នកដឹងក្ដីហើយ សម្រេចការសិក្សាក្នុងសិប្បៈនោះ ។ ថ្ងៃមួយ ជួបព្រះមានព្រះភាគព្រះនាមថាវិបស្សី មានចិត្តជ្រះថ្លា ហើយធ្វើនូវការបូជាដោយការផ្លុំស័ង្ខថ្វាយ តាំងអំពីនោះមក បានធ្វើការបម្រើព្រះសាស្ដាម្ដងម្កាល ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក ធ្វើបុណ្យរឿយៗមក អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាកស្សបៈ កុលបុត្តនោះ យកទឹកក្រអូបស្រោចដើមពោធិដែលជាឈើត្រាស់ដឹង ( របស់ព្រះមានព្រះភាគ ) អធិដ្ឋានថា ក្នុងអនាគតកាលខ្ញុំព្រះអង្គសូមជាអ្នកមានរាងកាយបរិសុទ្ធ ប្រាសចាកមន្ទិល ដូច្នេះហើយលាងអាសនៈត្រង់លានព្រះចេតិយ ត្រង់ខឿនពោធិព្រឹក្ស បោកគក់សមណបរិក្ខារដែលសៅហ្មងរបស់ភិក្ខុទាំងឡាយ ។

កាលចុតិអំពីមនុស្សលោកហើយ ក៏អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលដែលស្តុកស្តម្ភក្នុងនគររាជគ្រឹះ

កាលកុលបុត្តនោះនៅក្នុងផ្ទៃមាតាក្តី ចេញអំពីផ្ទៃមាតាក្តី រាងកាយរបស់កុលបុត្តនោះមិនសៅហ្មងព្រោះស្លេស្មជាដើម មិនប្រឡាក់ ដូចតំណក់ទឹកលើស្លឹកឈូក បានជាបុគ្គលបរិសុទ្ធផូរផង់ ដូចព្រះពោធិសត្វក្នុងភពចុងក្រោយដោយហេតុនោះ ទើបមនុស្សទាំងឡាយឲ្យឈ្មោះថា វិមល ។

វិមលមាណពចម្រើនវ័យហើយ ឃើញពុទ្ធានុភាព ក្នុងកាលដែលទ្រង់ចូលកាន់ក្រុងរាជគ្រឹះ បានចំពោះនូវសទ្ធា បព្វជ្ជាហើយ រៀននូវកម្មដ្ឋាន នៅក្នុងគុហាក្នុង ដែនកោសល ។ ថ្ងៃមួយ មហាមេឃកើតក្នុងទ្វីបទាំង ៤ បានញ៉ាំងភ្លៀងឲ្យធ្លាក់ពេញចក្កវាឡទាំងមូល ។ បានឮថា ភ្លៀងយ៉ាងនេះ រមែងធ្លាក់ក្នុងវិវដ្តដ្ឋាយីកប្ប ក្នុងកាលព្រះពុទ្ធ និងស្តេចចក្រពត្តិ គង់ព្រះជន្មនៅប៉ុណ្ណោះ ។ ចិត្តនៃព្រះថេរៈតាំងមាំមានអារម្មណ៍តែមួយ ព្រោះភ្លៀងស្រោចស្រពធ្វើឲ្យស្ងប់រម្ងាប់កម្តៅក្នុងរដូវប្រាំងនិងព្រោះបានរដូវជាទីសប្បាយលោក មានចិត្តតាំងមាំ ខ្វល់ខ្វាយក្នុងវិបស្សនា បានសម្រេចអរហត្តតាមលំដាប់មគ្គ ក្នុងខណៈនោះឯង សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ខ្ញុំកើតជាអ្នកជុំស័ន្ធ ជាអ្នកប្រកបដោយការបម្រើព្រះមានព្រះភាគព្រះនាមវិបស្សី ជាព្រះសុគត ព្រះអង្គស្វែងរកនូវគុណដ៏ធំជានិច្ច ។ ខ្ញុំតែងជួបផលនៃការបម្រើព្រះលោកនាថទ្រង់ប្រកបដោយតាទិគុណ គឺតូរ្យតន្ត្រី ៦០ ពាន់ តែងចោមរោមខ្ញុំ សព្វៗកាល ។ ក្នុងកប្បទី ៩១ អំពីកប្បនេះព្រោះហេតុដែលខ្ញុំបានបម្រើព្រះពុទ្ធ ជាមហាឥសី ក្នុងកាលនោះ

ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបម្រើ ។ ក្នុងកប្ប
ទី ៩៤ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិ ១៦ ដង ព្រះ
នាមមហានិគ្ឃោសៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិ
ទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់
ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិ
ហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ ជាអ្នកមានចិត្តត្រេកអរ ព្រោះធ្វើកិច្ចស្រេចហើយ កាលនឹងបន្លឺឧទាន បានពោលគាថាថា

ផែនដីតែងសើមជ្រាប ( ដោយអាបោធាតុ ) ខ្យល់ក៏រមែង
បក់ ផ្លេកបន្ទោរក៏ជាលប្រវាត់ក្នុងអាកាស ឯវិតក្កៈទាំងឡាយ
( មានកាមវិតក្កៈជាដើម ) របស់ខ្ញុំរមែងរម្ងាប់ ចិត្តរបស់ខ្ញុំ
ក៏តម្កល់ទុកល្អហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធរណី** ស្មើគ្នានឹង **បថវី** ប្រែថា ផែនដី ។ ផែនដីនោះ លោកហៅថា ធរណី ព្រោះទ្រទ្រង់ទុកនូវវត្ថុដែលល្អខ្លះ មិនល្អខ្លះ ។

បទថា **សិញ្ចតិ** សេចក្តីថា កាលមហាមេឃញុំាងភ្លៀងឲ្យធ្លាក់ពេញលម្ហមេឃដោយជុំវិញ ផែនដីក៏សើមដោយទឹកភ្លៀង ។

បទថា **វាតិ មាលុតោ** សេចក្តីថា ខ្យល់ដែលត្រជាក់ ព្រោះលាយ

---

១-ក្នុងអបទានជាព្រះ ពុទ្ធុបដ្ឋាកត្ថេរ ។

ជាមួយទឹកភ្លៀងក៏បក់មក ។

បទថា **វិទ្ធស្តា ចរតិ ឆភេ** សេចក្តីថា ផ្ទេកបន្ទោរដែលចេញអំពី ពពកក្រាស់ ផ្គរគំរាមក្នុងទីនោះៗ ក៏រាំសទៅក្នុងអាកាសខាងនេះខាងនោះ ដោយទិសជុំវិញ ។

បទថា **ឧបសម្មន្តិ វិតក្កា** សេចក្តីថា មហាវិតក្ក ៩ មានកាមវិតក្កជាដើម ឈ្មោះថាស្ងប់ហើយ ដោយអំណាចនៃតទង្គប្បហានខាងដើមដោយអាការដែលព្រះថេរៈបានសម្រេចសមថៈនិងវិបស្សនាដែលសម្រេចហើយព្រោះមានឧតុជាទីសប្បាយ ឈ្មោះថាចូលទៅស្ងប់ ព្រោះបានសម្រេចអរិយមគ្គ គឺរមែងដាច់សូន្យទៅដោយមិនមានចំណែកសេសសល់ ព្រះថេរៈពោលដល់ខណៈនៃអរិយមគ្គ ធ្វើឲ្យជាបច្ចុប្បន្ន ព្រោះជិតបច្ចុប្បន្ន ។ ម្យ៉ាងទៀត បទនេះ ជាបច្ចុប្បន្នកាល ប្រើក្នុងអត្ថអតីតកាល ។ បទថា **ចិត្តំ សុសមាហិតំ មមំ** សេចក្តីថា ព្រះថេរៈព្យាករអរហត្តផលថា បន្តអំពីនោះមក ចិត្តរបស់ខ្ញុំតាំងមាំដោយល្អដោយលោកុត្តរសមាធិ ឥឡូវនេះ មិនមានកិច្ចអ្វីដែលនឹងត្រូវធ្វើក្នុងការតាំងចិត្តនោះ ដូច្នេះ ។

អដ្ឋកថា វិមលត្ថេរគាថា ចប់

វគ្គទី ៥ ចប់

# ថេរគាថា ឯកនិបាត

## ឆដ្ឋវគ្គ

## គោធិកាទិចតុត្ថេរគាថា

[ ៥២ ] ភ្លៀង ( មានផ្គរ ) ដូចចម្រៀងដ៏ពីរោះ រមែងបង្អុរចុះ ខ្ទម គឺអត្តភាពខ្ញុំ ខ្ញុំបានបិទបាំងហើយ ឥតខ្យល់ចូលបានទេ តែងនាំមកនូវសេចក្តីសុខ ទាំងចិត្តរបស់ខ្ញុំក៏តម្កល់ទុកល្អហើយ ម្នាលភ្លៀង បើអ្នកចង់ ( បង្អុរទឹក ) អ្នកចូរបង្អុរមកចុះ ។

គោធិកត្ថេរ ។

# វគ្គទី៦

## អដ្ឋកថា

## គោធិកាទិចតុត្ថេរគាថា

[ ៥២ ] គាថារបស់ព្រះថេរៈទាំង ៤ អង្គ គឺព្រះគោធិកៈ ១ ព្រះសុពាហុ ១ ព្រះវល្លិយៈ ១ ព្រះឧត្តិយៈ ១ ទាំង ៤ គាថា មានពាក្យផ្តើមថា **វស្សតិ ទេវោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈទាំងនោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះថេរៈទាំងនេះមានបុញ្ញាធិការធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទុកច្រើនក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាសិទ្ធត្ថ ក្នុងកប្បទី ៩៤ រាប់អំពីកប្បនេះ កើតក្នុងផ្ទះមានត្រកូល

ដល់នូវភាពជាអ្នកដឹងក្តីហើយ បានជាសម្លាញ់នឹងគ្នាត្រាច់ទៅ ។

ក្នុងសម្លាញ់ទាំងនោះ សម្លាញ់ម្នាក់ ឃើញព្រះមានព្រះភាគ ព្រះនាមថា សិទ្ធត្ថនិមន្តបិណ្ឌបាត បានថ្វាយអាហារមួយវែក សម្លាញ់ទី ២ មានចិត្តជ្រះថ្លា បានថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយផ្គងអញ្ជលី សម្លាញ់ទី ៣ មានចិត្តជ្រះថ្លា បូជាព្រះមានព្រះភាគដោយផ្កាឧប្បលមួយក្តាប់ សម្លាញ់ទី ៤ ធ្វើការបូជាដោយផ្កាម្លិះ សម្លាញ់ទាំងនោះ កើតក្នុងទេវលោក ដោយបុញ្ញកម្មដែលធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះសាស្តា ខ្វល់ខ្វាយហើយយ៉ាងនេះ ធ្វើបុណ្យតៗមក អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាកស្សបៈ កើតក្នុងផ្ទះមានត្រកូល ជាសម្លាញ់នឹងគ្នា បួសក្នុងព្រះសាសនា បំពេញសមណធម៌ ក្នុងកាលនៃព្រះមានព្រះភាគរបស់យើងទាំងឡាយ មកកើតជាឱរសរបស់ស្តេចមល្លៈទាំង ៤ អង្គ ក្នុងនគរបាវា ។ ពួកស្តេចមល្លៈ បានថ្វាយព្រះនាមរបស់ឱរសទាំងនោះថា គោធិកៈ ១ សុពាហុ ១ វល្លិយៈ ១ ឧត្តិយៈ ១ ព្រះឱរសទាំង ៤ បានជាសម្លាញ់នឹងគ្នា ។ ព្រះឱរសទាំងនោះ នាំគ្នាទៅកាន់នគរកបិលពស្តុដោយករណីយកិច្ចឯណានីមួយ ។ ក្នុងសម័យនោះ ព្រះសាស្តាយាងទៅកាន់ក្រុងកបិលពស្តុ គង់នៅក្នុងនិគ្រោធារាម ទ្រង់សម្តែងយមកបាដិហារ្យ ទ្រង់ទូន្មានស្តេចសក្យៈ មានព្រះបាទសុទ្ធោទនៈជាប្រធាន ។ គ្រានោះ ឱរសនៃស្តេចមល្លៈទាំង ៤ នោះ ឃើញបាដិហារ្យហើយ បានទូវការជ្រះថ្លា បួសហើយ ចម្រើនវិបស្សនាសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាក្នុងកាលមិនយូរឡើយ សមដូច

គាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំបានឃើញព្រះសម្ពុទ្ធមានវណ្ណៈដូចមាស ទ្រង់គួរទទួលគ្រឿងបូជា ទ្រង់ចេញចាកព្រៃធំ គឺតណ្ហា មកកាន់ព្រះនិព្វាន ។ ខ្ញុំទៅតាមស្នាមព្រះបាទា នៃព្រះពុទ្ធ ទ្រង់ញុំាងជនឲ្យរលត់ទុក្ខ ហើយបានថ្វាយភិក្ខាមួយវែក ដល់ព្រះមហេសីព្រះនាមសិទ្ធត្ថៈ ទ្រង់មានប្រាជ្ញា មានព្រះហឫទ័យស្ងប់រម្ងាប់ មានព្យាយាមច្រើន ទ្រង់មិនញាប់ញ័រ ដោយលោកធម៌ សេចក្តីត្រេកអររបស់ខ្ញុំ មានប្រមាណច្រើនចំពោះព្រះពុទ្ធជាអាទិច្ចពន្ធុ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយភិក្ខា ។ ក្នុងកប្បទី ៨៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៧ ជាតិ ព្រះនាមមហារេណុដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១]។

ព្រះសុពាហុត្ថេរពោលគាថានេះថា

( ខ្ញុំបានឃើញ ) នូវព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាសទ្រង់ដូចអាជានេយ្យដ៏ប្រសើរ ឬទ្រង់ដូចដំរីឈ្មោះមាតង្គៈដែលចុះ

---

១-ក្នុងអបទានជា ភិក្ខទាយកត្ថេរ ។

ប្រេង ៣ យ៉ាង ព្រះអង្គស្វែងរកនូវគុណដ៏ធំ ទ្រង់ញុំាងទិស ទាំងពួងឲ្យភ្លឺច្បាស់ ទ្រង់ដូចដើមសាលរាជ មានផ្ការីកហើយ ទ្រង់ជាច្បងក្នុងត្រៃលោក ទ្រង់ឧត្តមជាងនរៈ ទ្រង់ស្តេចនិមន្ត ទៅតាមច្រក បានញុំាងចិត្តខ្ញុំឲ្យជ្រះថ្លាក្នុងញាណ ( របស់ព្រះ អង្គ ) ខ្ញុំបានផ្គងអញ្ជលី មានចិត្តជ្រះថ្លា មានចិត្តរីករាយហើយ ថ្វាយបង្គំព្រះសិទ្ធត្ថ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាល នោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ ទុគ្គតិ នេះជាផលនៃសេចក្តីសម្គាល់ក្នុងញាណ ។ ក្នុងកប្បទី ៧៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១៦ ជាតិ ជា ស្តេចឧត្តមជាងជន ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មាន កម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះវល្លិយត្ថេរពោលគាថានេះថា

ក្នុងកាលនោះ ខ្ញុំកើតជាអ្នកក្រងផ្កានៅអាស្រ័យក្នុងក្រុងឈ្មោះ តិវរា បានឃើញព្រះពុទ្ធព្រះនាមសិទ្ធត្ថៈ មានធូលីគឺរាគៈទៅ ប្រាសហើយ ដែលសត្វលោកបូជាហើយ ។ ខ្ញុំមានចិត្តជ្រះ ថ្លា មានចិត្តរីករាយបានថ្វាយផ្កាមួយក្តាប់ ខ្ញុំទៅកើតកពណាៗ

១-ក្នុងអបទានជាព្រះ ញាណសញ្ញិកត្ថេរ ។

តែងសោយផលជាទីប្រាថ្នា ដែលខ្លួនធ្វើល្អហើយក្នុងកាលមុន ( ក្នុងភពនោះៗ ) ដោយអំណាចអានិសង្សនៃកម្មនោះ ខ្ញុំមានផ្កាម្ទេះព័ទ្ធព័ទ្ធហើយ នេះជាផលនៃសេចក្ដីសម្គាល់ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ អាស្រ័យកប្បគម្រប់ ៩៤ វៀរលែងកប្បបច្ចុប្បន្ននេះចេញ ខ្ញុំបានកើតជាស្ដេច ៥០០ ជាតិ ព្រះនាម នជ្ជុបមៈ ដូចគ្នាក្នុងកប្បនោះ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះឧត្តិយត្ថេរពោលគាថានេះថា

ខ្ញុំបានថ្វាយផ្កាម្ទេះ ដល់ព្រះមានព្រះភាគ ទ្រង់ព្រះនាមសិទ្ធត្ថៈ ខ្ញុំបានរោយរាយផ្កា ៧ ត្រង់ព្រះបាទ ដោយសេចក្ដីរីករាយ ខ្ញុំគ្របសង្កត់ពួកជន និងទេវតាក្នុងថ្ងៃនេះ ដោយកុសលកម្មនោះ ខ្ញុំទ្រទ្រង់រាងកាយជាទីបំផុត ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាផ្កា ។ ក្នុងកប្បគម្រប់ ៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេច

---

១-ក្នុងអបទានជាព្រះ ឧប្បលហត្ថិយត្ថេរ ។

ចក្រពត្តិ ១៣ ជាតិ ព្រះនាមសមន្តគន្ធៈដូចគ្នា ទ្រង់ផ្សាយអាណាចក្រទល់នឹងសមុទ្រទាំង ៤ ជាទីបំផុត ទ្រង់ជាធំជាងគណៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈទាំង ៤ នេះ កាលសម្រេចអរហត្តហើយ ប្រាកដកេរ្តិ៍ឈ្មោះល្បីទៅក្នុងលោក ជាបុគ្គលដែលព្រះរាជានិងមហាមាត្យនៃព្រះរាជាគោរពបូជាហើយ នៅរួមគ្នាក្នុងព្រៃនោះឯង ។ ថ្ងៃមួយ ព្រះបាទពិម្ពិសារចូលទៅរកព្រះថេរៈទាំង ៤ រូបនោះ ដែលចូលទៅកាន់ក្រុងរាជគ្រឹះ ថ្វាយបង្គំហើយនិមន្តឲ្យនៅចាំវស្សាអស់ត្រៃមាស ត្រាស់ឲ្យសាងកុដិថ្វាយព្រះថេរៈទាំងនោះមួយអង្គមួយខ្នង មួយអង្គមួយខ្នង មិនបានប្រក់ដំបូល ព្រោះទ្រង់ភ្លេច ។ ព្រះថេរៈទាំងនោះ ក៏នៅក្នុងកុដិទាំងឡាយដែលមិនបានប្រក់ លុះដល់រដូវវស្សា ភ្លៀងក៏មិនធ្លាក់ ព្រះរាជាទ្រង់ព្រះតម្រិះថា ព្រោះហេតុអ្វីហ្ន៎ ទើបភ្លៀងមិនធ្លាក់ ទ្រង់ជ្រាបហេតុនោះហើយ ត្រាស់ឲ្យប្រក់ដំបូលកុដិទាំងនោះឲ្យបូកលាបដោយដីស្អិត តាក់តែងឲ្យស្អាត ធ្វើនូវការឆ្លងកុដិហើយបានថ្វាយទានដល់មហាភិក្ខុសង្ឃ ។

ដើម្បីអនុគ្រោះព្រះរាជា ព្រះថេរៈទាំងឡាយ ក៏ចូលទៅកាន់កុដិទាំងឡាយ ហើយចូលសមាបត្តិដែលមានមេត្តាជាអារម្មណ៍ ។ លំដាប់នោះម-

---

១-ក្នុងអបទានជាព្រះ បទបូជកត្ថេរ ។

ហាមេឃតាំងឡើងពីទិសឧត្តរ ក្នុងខណៈដែលព្រះថេរៈទាំងឡាយចេញអំពីសមាបត្តិ ភ្លៀងក៏ធ្លាក់មកនោះឯង ក្នុងព្រះថេរៈទាំងនោះ ព្រះគោធិកៈចេញអំពីសមាបត្តិ ព្រមគ្នានឹងមេឃគំរាម ទើបពោលគាថានេះថា

ភ្លៀង ( មានផ្គរ ) ដូចចម្រៀងដ៏ពីរោះ រមែងបង្អុរចុះ ខ្ទម
គឺអត្តភាពខ្ញុំ ខ្ញុំបានបិទបាំងហើយ ឥតខ្យល់ចូលបានទេ តែង
នាំមកនូវសេចក្ដីសុខ ទាំងចិត្តរបស់ខ្ញុំ ក៏តម្កល់ទុកល្អហើយ
ម្នាលភ្លៀងបើអ្នកចង់ ( បង្អុរទឹក ) អ្នកចូរបង្អុរមកចុះ
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វស្សតិ** សេចក្ដីថា ភ្លៀងធ្លាក់ គឺញុំាងតំណក់ភ្លៀងឲ្យស្រក់ចុះមក ។

បទថា **ទេវោ** ស្មើគ្នានឹង **មេឃោ** បានដល់ ភ្លៀង ។ បទថា **យថា សុគីតំ** មានអធិប្បាយថា បញ្ចេញសំឡេងក្រាងក្រអៅ ដូចសំឡេងចម្រៀងដ៏ពីរោះព្រោះក្នុងពេលភ្លៀងធ្លាក់ មិនមែនមានចំពោះតែពពកដែលតាំងឡើងរាប់រយរាប់ពាន់ស្រទាប់ប៉ុណ្ណោះទេ ថែមទាំងឲ្យផ្គរគ្រហឹម ផ្ទេកបន្ទោរជាលប្រវាត់សព្វទិសរមែងល្អ ព្រោះដូច្នោះ ទើបព្រះថេរៈសម្ដែងថា ភ្លៀង ( មានផ្គរ ) ដូចចម្រៀងដ៏ពីរោះធ្លាក់ ដូច្នេះ ។ ដោយហេតុនោះ ទើបព្រះថេរៈពោលដល់ការដែលមិនត្រូវបៀតបៀនអំពីសំឡេង ដោយពាក្យថា ខ្ទម គឺអត្តភាពខ្ញុំ ខ្ញុំបានបិទបាំងហើយ ឥតខ្យល់ចូលបានទេ គឺព្រះថេរៈ ពោលថាកុដិរបស់ខ្ញុំនេះ ប្រក់ដោយស្មៅជាដើមហើយ ដោយភ្លៀងលិចមិនបាន ព្រះថេរៈ

ពោលដល់កុដិដែលទឹកភ្លៀងនោះបៀតបៀនមិនបាន ។ កុដិ ឈ្មោះថា តែង នាំមកនូវសេចក្តីសុខ ព្រោះមានសុខក្នុងការប្រើប្រាស់និងមានឧតុជាទីសប្បាយ មានឧតុជាសុខសព្វយ៉ាង ប្រាសចាកអន្តរាយដែលកើតអំពីខ្យល់ ព្រោះមានទ្វារបិទជិតល្អ ។ ដោយបទពីរនោះ ព្រះថេរៈពោលដល់កុដិ ដែលមិនត្រូវបៀតបៀនថា ជាអាវាសសប្បាយ ។ បទថា **ចិត្តំ សុសមាហិតញ្ច មយ្ហំ** សេចក្តីថា ចិត្តរបស់ខ្ញុំតាំងមាំហើយដោយល្អ ដោយអនុត្តរសមាធិ គឺចុះស៊ប់ល្អហើយក្នុងអារម្មណ៍ គឺព្រះនិព្វាន ។ ដោយបទនេះ ព្រះថេរៈសម្តែងដល់ភាពជាបុគ្គលខ្វល់ខ្វាយតិច ព្រោះមិនមានអន្តរាយខាងក្នុង ។

បទថា **អថ ចេ បត្ថយសិ** សេចក្តីថា ឥឡូវនេះ បើអ្នកប្រាថ្នានឹងធ្លាក់ គឺបើអ្នកចង់ធ្លាក់ ។

បទថា **បវស្ស** សេចក្តីថា ចូរប្រោះព្រំនូវទឹក គឺបង្អុរធ្លាទឹកភ្លៀងចុះមក ព្រះថេរៈហៅមេឃថា **ទេវ** ។

## អដ្ឋកថា គោធិកាទិចតុត្ថេរគាថា ចប់

## សុពាហុត្ថេរគាថា

[ ៥៣ ] *ភ្លៀង ( មានផ្គរ ) ដូចចម្រៀងដ៏ពីរោះ រមែងបង្អុរចុះ ខ្ទម គឺអត្តភាពខ្ញុំ ខ្ញុំបានបិទបាំងហើយ ឥតខ្យល់ចូលបានទេ តែងនាំមកនូវសេចក្តីសុខ ទាំងចិត្តរបស់ខ្ញុំក៏តម្កល់ទុកល្អហើយ ម្នាលភ្លៀង បើអ្នកចង់ ( បង្អុរទឹក ) ចូរបង្អុរមកចុះ ។*

*សុពាហុត្ថេរ ។*

## អដ្ឋកថា

## សុពាហុត្ថេរគាថា

[ ៥៣ ] *ក្នុងគាថាដែលព្រះថេរៈ ៣ អង្គទៀតពោល ប្លែកគ្នាត្រង់បាទទី ៣ ។ ក្នុងគាថាទាំងនោះ គាថាដែលព្រះសុពាហុត្ថេរពោលទុកថា* **ចិត្តំ សុសមាហិតញ្ច កាយេ** *សេចក្តីថា ចិត្តរបស់ខ្ញុំតាំងមាំហើយដោយល្អ គឺចុះស៊ប់ហើយដោយប្រពៃ គឺចុះស៊ប់ហើយក្នុងករជកាយ ដោយអំណាចនៃការចម្រើនកាយគតាសតិ អធិប្បាយថា ព្រះសុពាហុត្ថេរនេះ ធ្វើឈានដែលខ្លួនបានហើយ ដោយអំណាចនៃការចម្រើនកាយគតាសតិ ឲ្យជាបាទចម្រើនវិបស្សនាសម្រេចអរហត្តហើយ ។ ព្រះថេរៈ សំដៅដល់ការចម្រើនកាយគតាសតិនោះ ទើបពោលគាថាថា* **ចិត្តំ សុសមាហិតញ្ច កាយេ** *ដូច្នេះ ។*

*អដ្ឋកថា សុពាហុត្ថេរគាថា ចប់*

## វល្លិយត្ថេរគាថា

[ ៥៤ ] ភ្លៀង ( មានផ្គរ ) ដូចចម្រៀងដ៏ពីរោះ រមែងបង្អុរចុះ ខ្ទមគឺអត្តភាពខ្ញុំ ខ្ញុំបានបិទបាំងហើយ ឥតមានខ្យល់ចូលបានទេតែងនាំមកនូវសេចក្ដីសុខ ខ្ញុំជាអ្នកមិនប្រមាទនៅក្នុងខ្ទមនោះ ម្នាលភ្លៀង បើអ្នកចង់ ( បង្អុរទឹក ) ចូរបង្អុរមកចុះ ។

*វល្លិយត្ថេរ ។*

## អដ្ឋកថា

## វល្លិយត្ថេរគាថា

[ ៥៤ ] ក្នុងវល្លិយត្ថេរគាថា បទថា **តស្សំ វិហរាមិ អប្បមត្តោ** មានអធិប្បាយថា ខ្ញុំឈ្មោះថាជាអ្នកមិនប្រមាទនៅក្នុងខ្ទមនោះ ព្រោះសម្រេចដល់ទីបំផុតនៃបដិបទាដែលឲ្យដល់នូវសេចក្ដីមិនប្រមាទ ឬឥរិយាបថ គឺញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយការបង្អោនចូលទៅក្នុងអរិយវិហារធម៌ និងដោយការប្រកបដោយទិព្វវិហារធម៌ជាដើម នៅក្នុងកុដិនោះ ។

*អដ្ឋកថា វល្លិយត្ថេរគាថា ចប់*

## ឧត្តិយត្ថេរគាថា

[ ៥៥ ] ភ្លៀង ( មានផ្គរ ) ដូចចម្រៀងដ៏ពីរោះ រមែងបង្អុរចុះ ខ្ទម គឺអត្តភាពខ្ញុំ ខ្ញុំបានបិទបាំងហើយ ខ្ញុំឥតមានបុគ្គលគម្រប់ពីរនៅក្នុងខ្ទមនោះទេ ម្នាលភ្លៀង បើអ្នកចង់ ( បង្អុរទឹក ) ចូរបង្អុរមកចុះ ។

**ឧត្តិយត្ថេរ ។**

## អដ្ឋកថា

## ឧត្តិយត្ថេរគាថា

[ ៥៥ ] ក្នុងគាថាដែលព្រះឧត្តិយត្ថេរពោល បទថា **អទុតិយោ** បានដល់ ខ្ញុំជាអ្នកមិនមានសម្លាញ់ គឺវៀរចាកការប្រឡូកប្រឡំដោយកិលេសនិងការប្រឡូកប្រឡំដោយគណៈ ។

អដ្ឋកថា ឧត្តិយត្ថេរគាថា ចប់

អដ្ឋកថាចតុត្ថវគ្គ ចប់

## អញ្ជនវនិយត្ថេរគាថា

[ ៥៦ ] ខ្ញុំបានចូលទៅកាន់ព្រៃអញ្ជន ហើយធ្វើខ្ទមប៉ុនគ្រែអាសន្ទិ ( ហើយអង្គុយ ) ខ្ញុំបានដល់ត្រៃវិជ្ជា ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ។

**អញ្ជនវនិយត្ថេរ ។**

## អដ្ឋកថា

## អញ្ជនវនិយត្ថេរគាថា

[ ៥៦ ] គាថារបស់ព្រះអញ្ជនវនិយត្ថេរ មានពាក្យផ្ដើមថា **អាសន្ទឹ កុដិកំ កត្វា** ដូច្នេះ ។ រឿងរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈ កុលបុត្តនេះ ជាមាលាការឈ្មោះសុទស្សនៈ បូជាព្រះមានព្រះភាគដោយផ្កាម្ជិះធ្វើបុណ្យដទៃៗទៀតជាច្រើន ទុកក្នុងភពនោះៗ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ កុលបុត្តនេះ បួសក្នុងសាសនារបស់ ព្រះមានព្រះភាគព្រះនាមថាកស្សបៈ ហើយបំពេញសមណធម៌ ។ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលវជ្ជី ក្នុងព្រះនគរវេសាលី ក្នុងពេលដែលកុលបុត្តនេះចម្រើនវ័យហើយ ភ័យ ៣ យ៉ាង គឺភ័យកើតអំពីមិនមានភ្លៀង ១ ភ័យកើតអំពីជំងឺ ១ ភ័យកើតអំពីអមនុស្ស ១ កើតឡើងក្នុងដែនវជ្ជី ។ ភ័យទាំងអស់នោះ គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងអដ្ឋកថារតនសូត្រ ។ កាលព្រះមានព្រះភាគយាងដល់ក្រុងវេសាលី កាលភ័យគ្រប់យ៉ាងស្ងប់ហើយ និងកាលធម្មាភិសម័យ

កើតហើយដល់ទេវតានិងមនុស្សទាំងឡាយជាច្រើន ក្នុងការសម្តែងធម៌របស់ព្រះសាស្តា ព្រះរាជកុមារនេះឃើញពុទ្ធានុភាព មានសទ្ធា ទើបចេញបួស ។

ព្រះរាជកុមារនេះ មានប្រវត្តិដូចម្តេច សូម្បីព្រះរាជា ៤ អង្គដទៃទៀតដែលនឹងពោលតទៅ ក៏មានប្រវត្តិយ៉ាងនេះ ។ ព្រះរាជកុមារនៃស្តេចលិច្ឆវីដែលជាសម្លាញ់របស់ព្រះរាជកុមារនេះ ក៏ចេញបួសដោយទំនងនេះឯង ។ ក្នុងសាសនាព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ កុលបុត្តដែលជាសម្លាញ់ទាំងនោះ បួសហើយបំពេញសមណធម៌ រួមជាមួយកុលបុត្តនេះ បានបំពេញបុណ្យបណ្តុះនូវពូជ គឺកុសលជាដើមទៀបបាទមូលនៃព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ។ ក្នុងកុលបុត្តទាំងនោះ ព្រះអញ្ជនវនិយត្ថេរនេះ ធ្វើបុព្វកិច្ចស្រេចហើយ នៅត្រង់ព្រៃខ្មោច ក្នុងអញ្ជនវ័នក្នុងក្រុងសាកេតនោះ លុះដល់ពេលចូលវស្សា បានតាំងចាស់ៗ ដែលមនុស្សទាំងឡាយចោល ហើយដាក់តាំងនៅលើដុំថ្មទាំង ៤ បិទបាំងខាងលើនិងចំហៀងជាដើម រួចប្រកបទ្វារនៅចាំវស្សា លោកព្យាយាម ក៏បានសម្រេចអរហត្ត ក្នុងខែទី ១ ប៉ុណ្ណោះ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

> ក្នុងកាលនោះ ខ្ញុំកើតជាអ្នកក្រងផ្កា ឈ្មោះសុទស្សនៈ បានឃើញព្រះពុទ្ធព្រះអង្គប្រាសចាកធូលីគឺរាគៈ ជាច្បងក្នុងលោកទ្រង់ប្រសើរជាងពួកនរៈ ។ ខ្ញុំកាន់យកផ្កាម្លិះបូជាចំពោះ ព្រះបទុមុត្តរៈ ខ្ញុំមានចក្ខុស្អាត មានចិត្តរីករាយ បានសម្រេចទិព្វចក្ខុ ។ ខ្ញុំមិនដែលទៅកាន់ទុគ្គតិអស់ ១ សែនកប្ប ដោយ

ពុទ្ធបូជានេះផង ដោយការតម្កល់ចិត្តផង ។ ក្នុងកប្បទី ៣៦ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១៦ ជាតិ ព្រះនាមទេវុត្តរដូចគ្នា មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលលោកសម្រេចអរហត្តហើយ សោយវិមុត្តិសុខ ចេញចាកសមាបត្តិហើយ ពិចារណាសម្បត្តិដែលបាន កាលបន្លឺឧទានដោយកម្លាំងបីតិ ទើបពោលគាថាថា

ខ្ញុំបានចូលទៅកាន់ព្រៃអញ្ជន ហើយធ្វើខ្ទម ប៉ុនគ្រែអាសន្ទិ ( ហើយអង្គុយ ) ខ្ញុំបានដល់ត្រៃវិជ្ជា ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាសន្ទឹ កុដិកំ កត្វា** សេចក្តីថា តាំង ៤ ជ្រុង ដើងវែង ហៅថា អាសន្ទិ ។ តាំង ៤ ជ្រុងទ្រវែងល្មមអង្គុយបានតែដេកមិនបាន ក៏មាន ( ក៏ហៅថាអាសន្ទិ ) ។ ព្រះថេរៈធ្វើតាំងនោះឲ្យជាកុដិ ដើម្បីនៅអាស្រ័យតាមដែលពោលមកអំពីមុនគឺធ្វើឲ្យជាកុដិដោយប្រការដែលកាលអង្គុយលើតាំងនោះហើយ អាចបំពេញសមណធម៌ បានដោយស្រួល ព្រោះមិនមានអន្តរាយដែលកើតអំពីរដូវ ព្រះថេរៈសម្តែងដល់ការប្រាថ្នាតិចនិងការសន្តោសដ៏កំពូលរបស់ខ្លួនក្នុងសេនាសនៈ ដោយបទនេះ សម

---

១-ក្នុងអបទានជាព្រះ មុដ្ឋិបុប្ផិយត្ថេរ ។

ដូចគាថាព័ន្ធដែលព្រះធម្មសេនាបតីពោលទុក ( ក្នុងថេរគាថា ) ថា

កាលភិក្ខុអង្គុយដោយភ្នែន ភ្លៀងមិនស្រក់ត្រូវត្រង់ជង្គង់ទាំងពីរ នេះជាការគួរដល់កិរិយានៅជាសុខនៃភិក្ខុអ្នកមានចិត្តស្ងប់ទៅរក ( ព្រះនិព្វាន ) ដូច្នេះ ។ អាចារ្យមួយពួកទៀតអានន្ទវបាឋៈថា **អាសន្ទិកុដិកំ** រួបអធិប្បាយថា ធ្វើកុដិប៉ុនតាំង ។ ឯអាចារ្យដទៃទៀតអធិប្បាយថា កុដិដែលធ្វើលើគ្រែដោយចំពោះសម្រាប់មនុស្សអង្គុយលើអាសនៈ ជាដើម ត្រាច់ទៅ ( គ្រែស្នែង ) ឈ្មោះថា អាសន្ទិ ធ្វើអាសន្ទិនោះឲ្យជាកុដិ ។ បុគ្គលនឹងអង្គុយធ្វើជាអាសនៈជាដើម ឈ្មោះថា អាសន្ទិ ធ្វើអាសន្ទិនោះឲ្យជាកុដិ ។

បទថា **ឱគយ្ហ** សេចក្ដីថា ឈមចុះ គឺចូលទៅរក ។ បទថា **អញ្ជនំ វនំ** បានដល់ ព្រៃដែលមានឈ្មោះយ៉ាងនេះ អធិប្បាយថា វល្លិ លោកហៅថា អញ្ជនៈ ព្រោះមានផ្កាមានពណ៌ដូចផ្កា អញ្ជន ព្រៃនោះបានឈ្មោះថា អញ្ជនវន ព្រោះច្រើនទៅដោយវល្លិនោះ ។ ឯអាចារ្យពួកដទៃ ពោលថា គុម្ពឈើធំ ឈ្មោះថា អញ្ជន ។ ត្រូវនាំពាក្យបន្ថែមថា **វិហារតោ មយា** ( អាស្រ័យនៅ ) មកប្រកបចូលផង បានជាពាក្យថា ខ្ញុំបានចូលទៅកាន់ព្រៃអញ្ជន ហើយធ្វើខ្ទមប៉ុនគ្រែអាសន្ទិ ( ហើយអង្គុយ ) ខ្ញុំបានដល់ត្រៃវិជ្ជា ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ដូច្នេះ ។ ពាក្យជាគាថានេះឯង បានជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈ ។

**អដ្ឋកថា អញ្ជនាវនិយត្ថេរគាថា ចប់**

# កុដិវិហារិត្ថេរគាថា

[ ៥៧ ] ( ខេត្តបាលសួរថា ) នរណា ( អង្គុយនៅ ) ក្នុងខ្ទម ( ព្រះថេរៈតបថា ) ភិក្ខុអ្នកប្រាសចាករាគៈ មានចិត្តតម្កល់ទុកល្អហើយ ( អង្គុយនៅ ) ក្នុងខ្ទម ម្នាលអាវុសោ អ្នកចូរដឹងយ៉ាងនេះថា ខ្ទមដែលអ្នកធ្វើហើយ មិនឥតប្រយោជន៍ទេ ។

កុដិវិហារិត្ថេរ ។

# អដ្ឋកថា
# កុដិវិហារិត្ថេរគាថា

[ ៥៧ ] គាថារបស់ព្រះកុដិវិហារិត្ថេរ មានពាក្យផ្ដើមថា **កោ កុដិកាយំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កាលព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈ ទ្រង់យាងទៅតាមអាកាស កុលបុត្តនេះកាន់ក្អមទឹកត្រជាក់ទៅដោយគិតថា អញនឹងថ្វាយទឹកជាទាន កើតបីតិសោមនស្ស ងើបមុខឡើងលើ បោះក្អមទឹកឡើងទៅលើ ( អាកាស ) ព្រះសាស្ដាទ្រង់ជ្រាបអធ្យាស្រ័យរបស់កុលបុត្តនោះ ទ្រង់ឈរក្នុងអាកាស ទទួលក្អមទឹក ដើម្បីចម្រើនបសាទសទ្ធា ។ ដោយការទទួលទឹកនោះ កុលបុត្តនោះ កើតបីតិនិងសោមនស្សដ៏ខ្លាំងក្លា ។ អត្ថដ៏សេសដូចគ្នាតាមដែលពោលក្នុងរឿងរបស់ព្រះអញ្ជនវនិយត្ថេរទាំងអស់ ។ ឯសេចក្ដីប្លែកគ្នាមានដូច្នេះថា បានឮថា លោកបួសដោយន័យដូចពោលហើយ ធ្វើ

បុព្វកិច្ចស្រេចហើយ ខ្វល់ខ្វាយក្នុងវិបស្សនា ក្នុងវេលាល្ងាច ដើរទៅក្បែរស្រែ កាលភ្លៀងធ្លាក់ឃើញខ្ទមស្បូវតូចរបស់អ្នកយាមស្រែ ទើបចូលទៅហើយអង្គុយលើកម្រាលដែលក្រាលដោយស្មៅក្នុងខ្ទមនោះ ។ គ្រាន់តែលោកអង្គុយក៏បានឧតុជាទីសប្បាយ ខ្វល់ខ្វាយក្នុងវិបស្សនាសម្រេចអរហត្តហើយសមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះសម្ពុទ្ធមានវណ្ណៈដូចមាស ស្តេចនិមន្តទៅឰដ៏អាកាស រុងរឿងដូចភ្លើងឆេះឆ្នាំងខ្លាញ់ ឬដូចភ្លើងកំពុងឆេះភ្លឺរន្ទាល ។ ខ្ញុំកាន់យកទឹកដោយដៃ សាចទៅនាអាកាស ព្រះពុទ្ធមានព្យាយាមធំ ប្រកបដោយសេចក្តីករុណាចំពោះខ្ញុំ ទ្រង់ក៏ទទួល( នូវទឹកនោះ ) ព្រះសាស្តាព្រះនាមបទុមុត្តរៈ ឋិតនៅនាអាកាសទ្រង់ជ្រាបនូវតម្រិះរបស់ខ្ញុំ ហើយទ្រង់សម្តែងគាថាទាំងនេះថាក្នុង ១ សែនកប្ប អ្នកនឹងមិនទៅកាន់ទុគ្គតិ ដោយការថ្វាយទឹកនេះផង ដោយការញុំាងបីតិឲ្យកើតឡើងផង ។ បពិត្រព្រះអង្គជាធំជាងសត្វជើង ២ ជាច្បងក្នុងលោក ទ្រង់ប្រសើរជាងពួកនរៈ ខ្ញុំព្រះអង្គ លះបង់នូវការឈ្នះ និងការចាញ់ហើយ បានដល់នូវអចលដ្ឋាន ដោយកុសលកម្មនោះ ។ ក្នុងកប្បទី ១៦៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣ជាតិ ទ្រង់ព្រះនាមសហស្សរាជដូចគ្នា ទ្រង់ផ្សាយអាណាចក្រទល់នឹងសមុទ្ទទាំង ៤ ទ្រង់ ជាធំជាងពួកជន ។ បដិសម្ភិទា

៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលព្រះថេរៈសម្រេចអរហត្តហើយ អង្គុយក្នុងខ្ទមនោះ អ្នកចាំស្រែត្រឡប់មក សួរថា អ្នកណានៅក្នុងខ្ទម ។ ព្រះថេរៈបានស្តាប់ដូច្នោះ ទើបពោលពាក្យជាដើមថា ភិក្ខុនៅក្នុងខ្ទម ។ ពាក្យរបស់អ្នកចាំស្រែ និងពាក្យរបស់ព្រះថេរៈ លោកចងក្រងទុកជាពួកតែមួយ លើកឡើងកាន់សង្គីតិថា

( ខេត្តបាលសួរថា ) នរណា ( អង្គុយនៅ ) ក្នុងខ្ទម ( ព្រះថេរៈតបថា ) ភិក្ខុអ្នកប្រាសចាករាគៈ មានចិត្តតម្កល់ទុកល្អហើយ ( អង្គុយនៅ ) ក្នុងខ្ទម ម្នាលអាវុសោ អ្នកចូរដឹងយ៉ាងនេះថា ខ្ទមដែលអ្នកធ្វើហើយ មិនឥតប្រយោជន៍ទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កោ កុដិកាយំ** ជាពាក្យសួររបស់អ្នកចាំស្រែថា អ្នកណាអង្គុយក្នុងខ្ទមនេះ ។ បទថា **ភិក្ខុ កុដិកាយំ** ជាពាក្យឆ្លើយរបស់ព្រះថេរៈដល់ខេត្តបាល ។ លំដាប់នោះ ព្រះថេរៈញុំាងអ្នកចាំស្រែឲ្យអនុមោទនាក្នុងការប្រើប្រាស់ខ្ទម ដោយភាពជាខ្ទនជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ ដើម្បីនឹងធ្វើបុណ្យនោះឲ្យតាំងមាំខ្ជាប់ ទើបពោលពាក្យជាដើមថា **វីតរាគោ** ដូច្នេះ ។ គាថានោះ មានអត្ថដូច្នេះ ភិក្ខុដែលទម្លាយកិលេស

---

១-ក្នុងអបទានជាព្រះ ឧទកបូជកត្ថេរ ។

បានហើយមួយរូបអង្គុយក្នុងខ្ទមរបស់អ្នក ព្រោះហេតុនោះឯង ទើបភិក្ខុនោះឈ្មោះថា **វីតរាគោ** ព្រោះមានរាគៈដកឡើងហើយ ដោយប្រការទាំងពួង ដោយមគ្គដ៏ប្រសើរ ឈ្មោះថា **សុសមាហិតចិត្តោ** ព្រោះជា អ្នកមានចិត្តតាំងមាំហើយដោយល្អ ដោយធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ដោយសមាធិដ៏កំពូល នៃអាវុសោខេត្តបាល អាត្មាពោលយ៉ាងណា អ្នកចូរដឹង គឺចូរជឿយ៉ាងនោះ អ្នកចូរផុតទុក្ខ ។

បទថា **អមោឃា តេ កុដិកា កតា** សេចក្តីថា ខ្ទមដែលអ្នកធ្វើទុកមិនឥតប្រយោជន៍ឡើយ គឺខ្ទមដែលអ្នកសាង មិនជាមោឃៈ មិនឥតអំពើមានតែផល មានតែអានិសង្ស ព្រោះព្រះអរហន្តខីណាស្រពបានប្រើប្រាស់ ។ បើអ្នកត្រេកអរក្នុងសេចក្តីនោះនឹងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីចម្រើន និងដើម្បីសេចក្តីសុខដល់អ្នកអស់កាលយូរ ។

អ្នកចាំស្រែស្តាប់ដូច្នោះហើយគិតថា ជាលាភរបស់អញហ្ន៎ ព្រោះក្នុងខ្ទមរបស់អញ មានលោកម្ចាស់ដែលមានសភាពយ៉ាងនេះ ចូលទៅអង្គុយ មានចិត្តជ្រះថ្លា បានឈរអនុមោទនាហើយ ។ ព្រះមានព្រះភាគទ្រង់ស្តាប់ពាក្យសន្ទនារបស់ព្រះថេរៈនិងខេត្តបាលនោះដោយទិព្វសោតធាតុ ទ្រង់ដឹងការអនុមោទនារបស់អ្នកយាមស្រែ កាលទ្រង់ប្រកាសសម្បត្តិអ្នកយាមស្រែដែលនឹងបានទទួល ទើបត្រាស់នឹងអ្នកយាមស្រែដោយគាថាទាំងនេះថា

ដោយផលនៃការដែលភិក្ខុអ្នកមានចិត្តស្ងប់ មិនមានអាសវៈ នៅក្នុងខ្ទមរបស់អ្នកនោះ អ្នកនឹងបានជាស្តេចទេវតា សោយរាជសម្បត្តិក្នុងពួកទេវតា

៣៦ ដង នឹងបានជាស្តេចចក្រពត្តិក្នុងដែន ៣៤ ដង នឹងបានជាព្រះបច្ចេកពុទ្ធដែលប្រាសចាករាគៈនាមថា រតនកុដិ ដូច្នេះ ។

តាំងអំពីនោះមក ព្រះថេរៈក៏កើតសមញ្ញានាមថា កុដិវិហារិត្ថេរនោះឯង ព្រោះលោកបានគុណវិសេសក្នុងខ្ទម ។ គាថានេះឯង បានជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈ ។

## អដ្ឋកថា កុដិវិហារិត្ថេរគាថា ចប់

## ទុតិយកុដិវិហារិត្ថេរគាថា

[ ៥៨ ] ខ្ទមនេះជារបស់ចាស់ កាលបើអ្នកប្រាថ្នាខ្ទមថ្មីឯទៀត អ្នកចូរបណ្តេញនូវសេចក្តីប្រាថ្នាចំពោះខ្ទមចាស់ចេញ ម្នាលភិក្ខុ ខ្ទមថ្មីទៀតតែងនាំមកនូវទុក្ខ ។

កុដិវិហារិត្ថេរ ។

## អដ្ឋកថា

## ទុតិយកុដិវិហារិត្ថេរគាថា

[ ៥៨ ] គាថារបស់ព្រះកុដិវិហារិត្ថេរ មានពាក្យផ្តើមថា **អយមាហុ បុរាណិយា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះថេរៈជាអ្នកមានចិត្តជ្រះថ្លា បានថ្វាយផ្ចិតត្បាញយ៉ាងវិចិត្រដែលធ្វើពីដើមបបុស ដល់ព្រះមានព្រះភាគព្រះនាមជាបទុមុត្តរៈ ក្នុងរដូវក្តៅ ព្រះសាស្តា ទ្រង់ញ៉ាំងកុលបុត្តនោះឲ្យត្រេកអរដោយព្រះគាថាអនុមោទនា ។ សេចក្តីដែលគួរពោលដ៏សេស ក៏ដូចគ្នានឹងរឿងរបស់ព្រះអញ្ជនវនិយត្ថេរដែលពោលហើយនោះឯង ចំណែកសេចក្តីដែលប្លែកគ្នាមានដូច្នេះថា

បានឮថា ព្រះថេរៈនេះបួសហើយ ដោយន័យដូចពោលហើយ នៅក្នុងកុដិចាស់មួយខ្នង មិនគិតបំពេញសមណធម៌ គិតតែកសាងតែម្យ៉ាងថា កុដិរបស់អញចាស់ហើយ គួរធ្វើកុដិថ្មី ។ ទេវតាអ្នកប្រាថ្នាប្រយោជន៍ចំពោះព្រះថេរៈ បានពោលគាថានេះ ដើម្បីឲ្យកើតសេចក្តីសង្វេគ ដោយពាក្យផ្សាយៗ

តែមានអត្ថជ្រៅពន្លឹកថា

ខ្ទមនេះជារបស់ចាស់ កាលបើអ្នកប្រាថ្នាខ្ទមថ្មីឯទៀត អ្នកចូរបណ្តេញនូវសេចក្តីប្រាថ្នាចំពោះខ្ទមចាស់ចេញ ម្នាលភិក្ខុ ខ្ទមថ្មីទៀតតែងនាំមកនូវទុក្ខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អយំ** ជាពាក្យចង្អុលឲ្យឃើញវត្ថុដែលនៅជិត ។ បទថា **អាហុ** សេចក្តីថា មានហើយ ដើម្បីការងាយស្រួលក្នុងការចងគាថា ទើបលោកពោលជាទីឃៈ ។

បទថា **បុរាណិយា** សេចក្តីថា មានមកក្នុងកាលមុន គឺមានមកយូរហើយ ។ បទថា **អញ្ញំ បត្ថយសេ នវំ កុដឹ** សេចក្តីថា លោកប្រាថ្នា គឺបំណង បានដល់ ចង់បាននូវកុដិដែលឈ្មោះថាកុដិថ្មីដទៃអំពីនេះ ព្រោះកុដិនេះទ្រុឌទ្រោមដោយភាពជារបស់ចាស់ ឈ្មោះថា **នវំ** ព្រោះជាកុដិដែលគប្បីកើតក្នុងឥឡូវនេះ សូមលោកលះនូវការសង្ឃឹមក្នុងកុដិទាំងអស់ ដោយអាការៈទាំងពួង គឺចូរប្រាសចាកសេចក្តីប្រាថ្នា គឺការចង់បាន បានដល់ ការសម្ងំក្នុងកុដិថ្មី ដូចក្នុងកុដិចាស់ ជាអ្នកមានចិត្តប្រាសចាកការចង់បានក្នុងកុដិថ្មីនោះ ដោយប្រការទាំងពួង ព្រោះហេតុអ្វី ព្រោះកុដិថ្មីនាំទុក្ខមកឲ្យ អធិប្បាយថា នែភិក្ខុ ព្រោះកុដិដែលឈ្មោះថា ថ្មី គឺដែលគប្បីឲ្យកើតក្នុងឥឡូវនេះឈ្មោះថាជាទុក្ខ ព្រោះនាំទុក្ខមកឲ្យ ដូច្នោះ លោកកុំនាំទុក្ខថ្មីដទៃឲ្យកើត សូមនៅក្នុងកុដិចាស់នោះប៉ុណ្ណោះឯង ធ្វើកិច្ចដែលខ្វនគួរធ្វើ ។

ក្នុងគាថានេះ មានអធិប្បាយដូច្នេះថា នែភិក្ខុ លោកគិតថា កុដិដែល

ប្រក់ដោយស្មៅនេះទ្រុឌទ្រោម ទើបបំណាងនឹងសាងកុដិដែលប្រក់ដោយស្មៅដទៃ មិនបំពេញសមណធម៌ លុះប្រាថ្នាយ៉ាងនេះ ឈ្មោះថា ញុំាងសេចក្ដីប្រាថ្នាកុដិ គឺអត្តភាពតទៅ ព្រោះមិនផុតចាកការកើតក្នុងភពថ្មីដោយមិនបានខ្វល់ខ្វាយក្នុងភាវនា ទើបឈ្មោះថា ញុំាងសេចក្ដីប្រាថ្នាដើម្បីសាងនោះឯង ។ កុដិ គឺអត្តភាពនេះ ប្រៀបដូចកុដិដែលប្រក់ដោយស្មៅថ្មី ឈ្មោះថាជាទុក្ខ ព្រោះទាក់ទងនឹងទុក្ខផ្សេងៗ មាន ជរា មរណៈ សោក និងបរិទេវៈជាដើម ក្រៃលែងជាងទុក្ខក្នុងការសាងកុដិ ព្រោះត្រូវលំបាកក្នុងការធ្វើ ព្រោះដូច្នោះ សូមលោកប្រាសចាកនូវការប្រាថ្នា ប្រាសចាកការសម្ងំក្នុងកុដិ គឺអត្តភាព ដូចប្រាសចាកការប្រាថ្នាក្នុងការសាងកុដិស្មៅ ដូច្នោះ គឺសូមជាបុគ្គលមានចិត្តប្រាសចាកតម្រេកក្នុងអត្តភាពនោះ ដោយប្រការទាំងពួងវដ្ដទុក្ខនឹងមិនមានដល់លោក ដោយអាការយ៉ាងនេះ ។ ព្រះថេរៈស្ដាប់ពាក្យរបស់ទេវតាហើយ កើតនូវសេចក្ដីសង្វេគ ផ្ដើមតាំងវិបស្សនា ព្យាយាម តាំងនៅហើយក្នុងអរហត្តផលក្នុងកាលមិនយូរឡើយ សមដូចលោកពោលទុកក្នុងអបទានថា

ព្រះបទុមុត្តរសម្ពុទ្ធ ជាច្បងក្នុងលោក ជាតាទិបុគ្គល ទ្រង់គង់
លើកម្រាលស្មៅ មានព្រះហឫទ័យស្ងប់រម្ងាប់ ទ្រង់មិនញាប់
ញ័រដោយលោកធម៌ ។ ខ្ញុំកាន់យកផ្កាបបុស ចងធ្វើជាផ្ចិត
បង្អោនថ្វាយព្រះពុទ្ធទ្រង់ជាធំជាងសត្វជើង ២ ព្រះអង្គមិន
ញាប់ញ័រដោយលោកធម៌ ។ ព្រះសព្វញ្ញូជាលោកនាយកទ្រង់

ទទួលផ្ចិតហើយ ទ្រង់ជ្រាបនូវតម្រិះរបស់ខ្ញុំ ទើបទ្រង់សម្តែងគាថានេះថា កាយរបស់តថាគតរលត់ទុក្ខហើយ សេចក្តីក្តៅក្រហាយមិនមានឡើយ យ៉ាងណាមិញ ចិត្តរបស់អ្នក ចូររួចស្រឡះចាកភ្លើងទាំង ៣ ប្រការយ៉ាងនេះដែរ ។ ទេវតាណាមួយ អាស្រ័យដើមឈើ ទេវតាទាំងអស់នោះ មកប្រជុំគ្នា ( ដោយបំណងថា ) ពួកយើងនឹងស្តាប់នូវពុទ្ធវចនៈ ដែលញុំាងទាយកឲ្យរីករាយ ។ ឯព្រះមានព្រះភាគ មានពួកទេវតាចោមរោម ទ្រង់គង់លើកម្រាលនោះ ទ្រង់ញុំាងទាយកឲ្យរីករាយហើយសម្តែងនូវគាថាទាំងនេះថា កុលបុត្តនេះនឹងកើតជាស្តេចចក្រពត្តិ មាននាមថាសុព្វតរាជ ដោយការថ្វាយនូវផ្ចិតនេះផង ដោយការតម្កល់ចិត្តផង កុលបុត្តនោះជាបុគ្គលត្រូវកុសលមូលដាស់តឿនហើយ នឹងបានជាស្តេចចក្រពត្តិទៀត មាននាមថា មាលុតរាជ ដោយសេសផលនៃកម្មនោះ ។ ក្នុង ១ សែនកប្ប កុលបុត្តនេះមិនដែលទៅកាន់ទុគ្គតិ ដោយការថ្វាយផ្ចិតនេះផង ដោយការរាប់អានដ៏ធំទូលាយនេះផង ។ ក្នុង ៣ ហ្មឺនកប្ប នឹងបានជាក្សត្រ ៣៨ ជាតិ ក្សត្រទាំងនោះ ព្រះនាមថាសុព្វតរាជ ក្នុង ២៩០០០ កប្ប បានជាក្សត្រ ៨ ជាតិ ទ្រង់ព្រះនាមមាលុតរាជ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា

របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈតាំងនៅក្នុងអរហត្តផលហើយ បានពោលគាថានោះឯងដដែលទៀតថា គាថានេះជាកន្សែរសម្រាប់ទូន្មានក្នុងការសម្រេចអរហត្តផលរបស់ខ្ញុំ គាថានោះឯង បានជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈ ។ ព្រះថេរៈបាននាមថា កុដិវិហារិត្ថេរ ព្រោះលោកបានគុណវិសេសដោយឱវាទដែលទាក់ទងនឹងកុដិ ដូច្នេះឯង ។

## អដ្ឋកថា ទុតិយកុដិវិហារិត្ថេរគាថា ចប់

---

១-ក្នុងអបទានជាព្រះ នឡមាលិយត្ថេរ ។

## រមណីយកុដិកត្ថេរគាថា

[ ៥៩ ] ខ្ទមរបស់ខ្ញុំដែលគេឲ្យដោយសទ្ធា ជាខ្ទមគួររីករាយ ជាទីត្រេកអរនៃចិត្ត ខ្ញុំមិនមានសេចក្តីត្រូវការដោយកុមារីទាំងឡាយទេ ពួកជនណា មានសេចក្តីត្រូវការ ចូរនារីទាំងឡាយទៅក្នុងទីនោះ ( របស់ពួកជននោះ ) ចុះ ។

រមណីយកុដិកត្ថេរ ។

## អដ្ឋកថា

## រមណីយកុដិកត្ថេរគាថា

[ ៥៩ ] គាថារបស់ព្រះរមណីយកុដិកត្ថេរ មានពាក្យផ្តើមថា **រមណីយា មេ កុដិកា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះថេរៈនេះធ្វើការសាបព្រោះនូវពូជ គឺកុសលទុកក្នុងសាសនា នៃព្រះមានព្រះភាគ ព្រះនាមថា បទុមុត្តរៈ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមថា អត្ថទស្សី ក្នុងទីបំផុតអំពីកប្បនេះ ១៨០០ កប្ប កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ បានថ្វាយពុទ្ធាសនៈដល់ព្រះមានព្រះភាគ បូជាព្រះមានព្រះភាគដោយផ្កាទាំងឡាយ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ធ្វើប្រទក្សិណហើយចៀសចេញទៅ អត្ថដ៏សេស ដូចគ្នាតាមដែលពោលហើយក្នុងរឿង

របស់ព្រះអញ្ញាសិនិយត្ថេរនោះឯង ។ ឯសេចក្តីដែលប្លែកគ្នា មានដូចតទៅនេះថា

បានឮថា ព្រះថេរៈនេះ បួសដោយន័យដូចពោលហើយ ធ្វើបុព្វកិច្ចហើយ នៅក្នុងខ្ទមត្រង់អាវាសមិនឆ្ងាយអំពីស្រុកមួយក្នុងដែនវជ្ជី ។ កុដិនោះ ជាកុដិដែលស្អាត គួរមើល គួរជ្រះថ្លា មានជញ្ជាំងនិងបាត តាក់តែងរៀបរយ សម្បូរដោយទស្សនីយភាព មានចំណែកគួរជាទីត្រេកអរនិងស្រះបោក្ខរណីដែលគួរត្រេកអរជាដើម មានភូមិភាគពេញទៅដោយខ្សាច់នៃកែវមុក្តាជាស្ថានទីគួរត្រេកអរក្រៃលែង ដោយមានបរិវេណ ដែលកៀរស្មើល្អហើយជាដើម ព្រោះព្រះថេរៈជាអ្នកសម្បូរដោយវត្ត ។ ព្រះថេរៈនៅក្នុងកុដិនោះ ផ្តើមតាំងវិបស្សនាហើយសម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំចូលទៅកាន់ព្រៃធំដ៏ស្ងាត់មិនមានសំឡេង មិនរឹករវរ ខ្ញុំថ្វាយសីហាសនៈ ដល់ព្រះសម្ពុទ្ធព្រះនាមអត្ថទស្សី ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ខ្ញុំកាន់យកផ្កាមួយក្តាប់ធ្វើប្រទក្សិណព្រះអង្គ ហើយចូលទៅអង្គុយជិតព្រះសាស្តា រួចដើរចេញទៅបែរមុខឆ្ពោះកាន់ឧត្តរទិស ។ បពិត្រព្រះអង្គ ជាធំជាងសត្វជើង ២ ទ្រង់ជាច្បងក្នុងលោក ទ្រង់ប្រសើរជាងនរៈ ខ្ញុំធ្វើខ្លួនឲ្យរលត់ ឥតមានសេសសល់ ភពទាំងអស់ខ្ញុំគាស់រំលើងហើយ ដោយសារកម្មនោះ ។ ក្នុងកប្បទី ១៨០០ អំពីកប្បនេះ

ក្នុងកាលនោះព្រោះហេតុដែលខ្ញុំបានឲ្យទាន ខ្ញុំមិនដែលស្គាល់
ទុគ្គតិ នេះជាផលនៃ សីហាសនៈ ។ ក្នុងកប្បទី ៧០០ អំពី
កប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិព្រះនាមសន្និព្វាបកៈទ្រង់
បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិ-
សម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យ
ជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិ
ហើយ ដូច្នេះ[១] ។

កាលព្រះថេរៈសម្រេចអរហត្តហើយ គង់នៅត្រង់ខ្ទមនោះ មនុស្សដែលចូលចិត្តមើលវិហារ មកអំពីទីផ្សេងៗ មើលនូវកុដិនោះ ព្រោះកុដិជាទីត្រេកអរ ។

ថ្ងៃមួយ ពួកស្រីដែលមាននិស្ស័យជាអ្នកលេង ២-៣ នាក់ ទៅកាន់ខ្ទមនោះ ឃើញភាពដែលខ្ទមគួរជាទីរីករាយ ទើបពោលថា បពិត្រលោកម្ចាស់ ទីលំនៅរបស់លោកម្ចាស់គួរត្រេកអរ សូម្បីពួកខ្ញុំទាំងឡាយ ក៏មានរូបគួរត្រេកអរ តាំងនៅក្នុងបឋមវ័យ ដូច្នេះ ដោយបំណងថា ព្រះថេរៈនៅក្នុងខ្ទមរូបនេះគប្បីជាអ្នកមានចិត្ត ដែលពួកយើងទាំងឡាយ ទាញមកបានហើយចាប់ផ្ដើមសម្ដែងអាការផ្សេងៗ មានមាយាស្រីជាដើម ព្រះថេរៈកាលប្រកាសភាពដែលខ្លួនជាអ្នកប្រាសចាករាគៈហើយ ទើបពោលគាថាថា

ខ្ទមរបស់ខ្ញុំ ដែលគេឲ្យដោយសទ្ធា ជាខ្ទមគួររីករាយ ជាទី

---

១-ក្នុងអបទានជាព្រះ អាសនុបដ្ឋាយកត្ថេរ ។

គ្រេកអរនៃចិត្ត ខ្ញុំមិនមានសេចក្តីត្រូវការ ដោយកុមារីទាំង-
ឡាយទេ ពួកជនណាមានសេចក្តីត្រូវការ ចូរនារីទាំងឡាយ
ទៅក្នុងទីនោះ ( របស់ពួកជននោះ ) ចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រមណីយា មេ កុដិកា** សេចក្តីថា ពាក្យដែលពួកនាងទាំងឡាយពោលហើយថា បពិត្រលោកម្ចាស់ កុដិរបស់លោកម្ចាស់ គួរជាទីត្រេកអរ ដូច្នេះ ជាសេចក្តីពិត ។ កុដិរបស់អាត្មានេះ គួរជាទីត្រេកអរ គួរជាទីរីករាយ កុដិនោះឯង ជាកុដិដែលទាយកឲ្យដោយសទ្ធា ។ ឈ្មោះថា **សទ្ធាទេយ្យា** ព្រោះជនទាំងនោះ ជឿនូវកម្មនិងផលនៃកម្មថា ផលនេះកើតឡើង ព្រោះធ្វើវត្ថុដែលគួរពេញចិត្តបែបនេះ ហើយប្រគេនដល់បព្វជិត ហើយឲ្យដោយសទ្ធា គឺដោយការពេញចិត្តក្នុងធម៌ មិនបានឲ្យសាងដោយទ្រព្យ ( របស់អាត្មា ) ។ កុដិ ឈ្មោះថា **មនោរមា** ព្រោះធ្វើចិត្តរបស់បុគ្គល ដែលឃើញនូវវត្ថុដែលឲ្យដោយសទ្ធា ដែលឲ្យហើយយ៉ាងនោះ ឲ្យត្រេកអរឯង និងធ្វើចិត្តរបស់អ្នកប្រើប្រាស់ឲ្យត្រេកអរផងដែរ ។

អធិប្បាយថា កុដិ ឈ្មោះថា **មនោរមា** ព្រោះជារបស់ដែលគេឲ្យដោយសទ្ធានោះឯង គឺទាយករៀបចំទេយ្យធម៌ដោយសេចក្តីគោរព ឲ្យដោយសទ្ធាជាដើម ឯសប្បុរសអ្នកប្រើប្រាស់វត្ថុដែលទាយកឲ្យដោយសទ្ធា រមែងជាអ្នកសម្បូរដោយភោគសម្បត្តិ និងអាសយសម្បត្តិ មិនធ្វើឲ្យទាយកខុសបំណង មិនមែនវិបត្តិដោយបយោគសម្បត្តិ និងអាសយសម្បត្តិ ដោយអា-ការដូចអ្នកទាំងឡាយគិត ។

បទថា **ន មេ អត្ថោ កុមារីហិ** សេចក្តីថា ព្រោះហេតុដែលអាត្មាមានចិត្តបែរចេញអំពីកាមទាំងឡាយដោយប្រការទាំងពួង ដូច្នោះ ទើបអាត្មាមិនមានសេចក្តីត្រូវការដោយកុមារីទាំងឡាយ អធិប្បាយថា ឈ្មោះថា ស្រីទាំងឡាយ មិនមានប្រយោជន៍សម្រាប់បុគ្គលដូចអាត្មា សូម្បីមកធ្វើត្រឹមកប្បិយ-ការក នឹងពោលថ្មីដល់ការត្រេកអរដោយរាគៈ ព្រោះហេតុនោះ ទើបអាត្មាមិនត្រូវការដោយកុមារីទាំងឡាយ ។ **កុមារី** សព្ទ ក្នុងគាថានេះ គប្បីឃើញថា ជាការប្រាប់អត្ថន័យ ។ ព្រះថេរៈកាលសម្តែងថា កិរិយាយ៉ាងនេះ គប្បីស្អាតចំពោះមុខរបស់បុគ្គលដែលមានអធ្យាស្រ័យដូចពួកនាង ដែលធ្វើនូវកម្មមិនសមគួរដោយគិតថា ត្រូវបដិបត្តិយ៉ាងនេះក្នុងសម្នាក់របស់មនុស្សដូចអាត្មា រហូតកើតការខុសក្លាំងក្លាត់ ដូច្នេះហើយ ទើបពោលបន្តថា ចូរនារីទាំងឡាយទៅក្នុងទីនោះ ( របស់ពួកជននោះ ) ចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យេសំ** បានដល់ របស់បុគ្គលដែលមិនទាន់ប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ។

បទថា **អត្ថោ** បានដល់ ប្រយោជន៍ ។ បទថា **តហឹ** បានដល់ ក្នុងទីនោះ គឺក្នុងសម្នាក់របស់មនុស្សទាំងនោះ ។ បទថា **ឆារិយោ** ជាអាលបនៈ ។ ស្រីទាំងឡាយស្តាប់ពាក្យជាគាថានោះហើយ ជាអ្នកខ្មាសអៀនមានកន្ទិនចុះ ចៀសចេញទៅដោយផ្លូវដែលមកហើយនោះឯង ពាក្យថា ខ្ញុំមិនមានសេចក្តីត្រូវការដោយកុមារីទាំងឡាយទេ ក្នុងគាថានេះ គប្បីជ្រាបថា ជាពាក្យដែលព្រះថេរៈព្យាករអរហត្តផលហើយ ព្រោះពោលដល់ភាពដែលខ្លួន

មិនត្រូវការដោយកាមទាំងឡាយនោះឯង ។

## អដ្ឋកថា រមណីយកុដិកត្ថេរគាថា ចប់

## កោសល្លវិហារិត្ថេរគាថា

[ ៦០ ] ខ្ញុំបួសដោយសទ្ធា ខ្ញុំមតួចខ្ញុំបានធ្វើទុកក្នុងព្រៃហើយ ខ្ញុំមិនប្រមាទ មានព្យាយាមដ៏តឹងរ៉ឹង មានសតិរក្សាខ្លួន មានការដឹងខ្លួនជាក់លាក់ៗ

កោសល្លវិហារិត្ថេរ ។

## អដ្ឋកថា

## កោសល្លវិហារិត្ថេរគាថា

[ ៦០ ] គាថារបស់ព្រះកោសល្លវិហារិត្ថេរ មានពាក្យផ្តើមថា **សទ្ធាយាហំ បព្វជិតោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះថេរៈនេះក៏សាបព្រោះនូវពូជ គឺកុសលទុកក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈ បានធ្វើបុណ្យនោះៗទុក រឿងដ៏សេស ដូចគ្នានឹងរឿងរបស់ព្រះអញ្ញនវនិយត្ថេរនោះឯង ឯការដែលប្លែកគ្នាដូច្នេះថា

បានឮថា ព្រះថេរៈនោះ បួសដោយន័យដូចពោលហើយ ធ្វើបុព្វកិច្ចស្រេចហើយ នៅក្នុងព្រៃដោយអាស្រ័យត្រកូលរបស់ឧបាសកម្នាក់ក្នុងស្រុកមួយក្នុងដែនកោសល ។ ឧបាសកនោះឃើញព្រះថេរៈត្រង់គល់ឈើ ទើបសាងកុដិប្រគេន ព្រះថេរៈនៅក្នុងកុដិ បានសមាធិ ព្រោះមានអាវាសជាទីសប្បាយខ្វល់ខ្វាយក្នុងវិបស្សនាសម្រេចអរហត្តក្នុងកាលមិនយូរឡើយ សម

ដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ខ្ញុំនៅជិតព្រៃហេមពាន្ត អង្គុយលើកម្រាលស្លឹកឈើ ក្នុងកាលនោះ ខ្ញុំមានសេចក្ដីជាប់ចំពាក់ក្នុងគ្រឿងទទួលទាន ដូចបុរសល្មោភដេក ។ ខ្ញុំកំពុងជីកមើមដំឡូងជ្វានិងដំឡូងវល្លិផង ដំឡូងដៃខ្លានិងដំឡូងជ្រូកផង ខ្ញុំនាំមកនូវផ្លែពុទ្រា ផ្លែក្រខុបនិងផ្លែញ្ញៀដែលខ្ញុំគាក់តែងហើយ ។ ព្រះលោកវិទូ ទ្រង់ព្រះនាមបទុមុត្តរៈ គួរទទួលគ្រឿងបូជា ទ្រង់ជ្រាបនូវតម្រិះរបស់ខ្ញុំទើបនិមន្តមកកាន់សំណាក់ខ្ញុំ ខ្ញុំបានឃើញនូវព្រះមហានាគជាទេវតាប្រសើរជាងទេវតា ជានរាសភៈ ទ្រង់ចូលមកជិត ខ្ញុំក៏យកដំឡូងដៃខ្លាដាក់ចុះក្នុងបាត្រ ។ ក្នុងកាលនោះ ព្រះសម្ពុទ្ធ ជាមហាវីរៈ ទ្រង់ញុំាងខ្ញុំឲ្យត្រេកអរ ហើយទ្រង់សោយ លុះព្រះសព្វញ្ញូសោយរួចហើយទើបសម្ដែងគាថានេះថា អ្នកចូរញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយថ្វាយដំឡូងដៃខ្លា ដល់តថាគត អ្នកនឹងមិនទៅកាន់ទុគ្គតិអស់ ១ សែនកប្ប ។ ភពជាទីបំផុតរបស់ខ្ញុំកំពុងប្រព្រឹត្តទៅ ភពទាំងអស់ខ្ញុំបានគាស់រំលើងហើយ ខ្ញុំទ្រទ្រង់រាងកាយជាទីបំផុតក្នុងសាសនារបស់សម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៥៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិឈ្មោះសុមេខលិរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦

នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ
ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈសម្រេចអរហត្តហើយ កាលនឹងបន្លឺឧទាន ដោយកម្លាំងនៃបីតិដែលកើតឡើងដោយការសោយវិមុត្តិសុខ ទើបពោលគាថាថា

ខ្ញុំបួសដោយសទ្ធា ខ្ញុំមតូចខ្ញុំបានធ្វើទុកក្នុងព្រៃហើយ ខ្ញុំមិន
ប្រមាទ មានព្យាយាមដ៏តឹងរ៉ឹង មានសតិខ្ជាប់ខ្ជួន មានការ
ដឹងខ្លួនជាក់លាក់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សទ្ធាយ** សេចក្តីថា ខ្ញុំឃើញអានុភាពក្នុងការយាងចូលទៅកាន់នគរវេសាលីរបស់ព្រះមានព្រះភាគ ទើបបួស គឺចូលដល់បព្វជ្ជាភេទ ដោយអំណាចនៃសទ្ធាដែលកើតឡើងថា សាសនានេះនាំសត្វចេញចាកទុក្ខដោយចំណែកមួយ ព្រោះដូច្នោះ អាត្មាអញនឹងផុតចាកជរានិងមរណៈបានដោយបដិបទានេះពិត ដូច្នេះ ។

ដោយបទថា **អរញ្ញេ មេ កុដិកា កតា** នេះ ព្រះថេរៈសម្តែងថា ខ្ញុំនៅក្នុងព្រៃ ធ្វើកុដិដោយសមគួរដល់ភេទបព្វជ្ជានោះ គឺខ្ញុំជាអ្នកមានប្រក្រតីនៅព្រៃ ចេញចាកពួក នៅតាមសមគួរដល់បព្វជ្ជាភេទ ដោយហេតុនោះទើបលោកពោលថា ខ្ញុំមិនប្រមាទ មានព្យាយាមដ៏តឹងរ៉ឹង មានសតិខ្ជាប់ខ្ជួន មានការដឹងខ្លួន ជាក់លាក់ ដូច្នេះ ។

ព្រះថេរៈ កាលនឹងខ្វល់ខ្វាយ ក្នុងជាគរិយធម៌ ដោយកាយវិវេកដែល

---

១-ក្នុងអបទានជាព្រះ ពិឡាលិទាយកត្ថេរ ។

បានអំពីការនៅព្រៃ ទើបឈ្មោះថា **អប្បមត្តោ** ដោយការមិននៅប្រាសចាកសតិក្នុងព្រៃនោះ ។ ឈ្មោះថា **អាតាបី** ព្រោះមានសេចក្ដីព្យាយាមដែលប្រារព្ធហើយ ចម្រើនវិបស្សនាដោយធ្វើសតិនិងសម្បជញ្ញៈដែលជាចំណែកខាងដើមឲ្យបរិបូណ៌ ឈ្មោះថា **សម្បជានោ បតិស្សតោ** សេចក្ដីថា ព្រោះនៅដោយចំណែកមួយ និងព្រោះដល់នូវការបរិបូណ៌ ដោយបញ្ញានិងសតិដោយសម្រេចអរហត្តផល ។ គាថានេះឯង បានជាការព្យាករអរហត្តផលរបស់ព្រះថេរៈក្នុងការប្រកាសភាពជាអ្នកមិនប្រមាទជាដើម ព្រោះហេតុដែលលោកនៅក្នុងដែនកោសលមកយូរ ទើបមានសមញ្ញានាមថា កោសល្លវិហារិត្ថេរ ដូច្នេះ ។

អដ្ឋកថា កោសល្លវិហារិត្ថេរគាថា ចប់

## សីវលិត្ថេរគាថា

[ ៦១ ] សង្កប្បធម៌ទាំងនោះ ( មាននេក្ខម្មសង្កប្បៈជាដើម ) សម្រេចហើយដល់ខ្ញុំ ខ្ញុំមានសេចក្តីត្រូវការនឹងចូលទៅកាន់ខ្ទម ដែលជាខ្ទមនាំឲ្យខ្ញុំបានដល់នូវវិជ្ជា និងវិមុត្តិ លះបង់នូវមានានុស័យ ។

**សីវលិត្ថេរ ។**

**ឧទ្ទាន**

និយាយអំពីគោធិកត្ថេរ ១ សុពាហុត្ថេរ ១ វល្លិយត្ថេរ ១ ឧត្តិយត្ថេរជាឥសី ១ អញ្ជនាវនិយត្ថេរ ១ កុដិវិហារិត្ថេរ ២ លើក រមណីយកុដិកត្ថេរ ១ កោសល្លវិហារិត្ថេរ ១ សីវលិត្ថេរ ១ ។

**ចប់ ឆដ្ឋវគ្គ ។**

## អដ្ឋកថា

## សីវលិត្ថេរគាថា

[ ៦១ ] គាថារបស់ព្រះសីវលិត្ថេរ មានពាក្យផ្តើមថា **តេ មេ ឥជ្ឈិំសុ សង្កប្បា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថា បទុមុត្តរៈ កុលបុត្តនោះក៏ទៅកាន់ព្រះវិហារដោយន័យដូចពោលហើយខាងដើម ឈរស្តាប់ធម៌ខាងចុងបរិស័ទ ឃើញព្រះសាស្តាតែងតាំងភិក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈ

ជាឯកភិក្ខុខាងមានលាភទាំងឡាយគិតថា ក្នុងអនាគតកាលអាត្មាអញ ក៏គួរជាបុគ្គលបែបនេះ ដូច្នេះហើយ និមន្តព្រះទសពល ហើយថ្វាយមហាទានដល់ព្រះបរមសាស្តា មួយអន្លើដោយភិក្ខុសង្ឃអស់ ៧ ថ្ងៃ ហើយតាំងសេចក្តីប្រាថ្នាថា បពិត្រព្រះមានព្រះភាគ ដោយបុញ្ញាធិការនេះ ខ្ញុំព្រះអង្គមិនប្រាថ្នាសម្បត្តិដទៃ តែក្នុងអនាគតកាល ខ្ញុំព្រះអង្គគប្បីជា កំពូលជាឯកភិក្ខុទាំងឡាយដែលមានលាភ ដូចភិក្ខុដែលទ្រង់តែងតាំងទុកក្នុងឯតទគ្គៈចុះ ។

ព្រះសាស្តាទ្រង់ឃើញសេចក្តីប្រាថ្នាមិនមានអន្តរាយ ទើបទ្រង់ព្យាករថា សេចក្តីប្រាថ្នារបស់អ្នក នឹងសម្រេចក្នុងសម្នាក់របស់ព្រះពុទ្ធព្រះនាមថា គោតម ដូច្នេះហើយ ទ្រង់ចៀសចេញទៅ ។ កុលបុត្តនោះ ធ្វើកុសលជរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមវិបស្សី បដិសន្ធិក្នុងស្រុកមួយ មិនឆ្ងាយអំពីនគរពន្ធុមតី ។ ក្នុងសម័យនោះ អ្នកក្រុងពន្ធុមតី ប្រណាំងប្រជែងជាមួយព្រះរាជាថ្វាយទានដល់ព្រះទសពល ។ ថ្ងៃមួយ អ្នកនគរទាំងនោះ រួមចិត្តគ្នាថ្វាយទាន និយាយគ្នាថា អ្វីហ្ន៎មិនមានក្នុងទានពិធីរបស់ពួកយើង ហើយមិនឃើញស្ករអំពៅនិងទឹកដោះជូរ ទើបមនុស្សទាំងនោះពោលថា ពួកយើងនឹងរកមកអំពីទីណាមួយ ហើយដាក់បុរសត្រង់ផ្លូវដែលមកអំពីជនបទ ។ គ្រានោះកុលបុត្តនោះ កាន់យកស្ករអំពៅនិងឆ្នាំងទធិ មកអំពីផ្ទះរបស់ខ្លួន គិតថា អញនឹងទៅរករបស់ណាមួយកាន់កំដរដៃទៅផង ទើបដើរចូលក្រុង ហើយគិតថា អញនឹងលុបមុខ លាងដៃជើង ហើយសឹមចូលទៅ សម្លឹងមើលទីផាសុក

ឃើញសម្បកឃ្មុំដែលប្រាសចាកមេប៉ុនយាមទន្តិ៍លគិតថា សម្បកឃ្មុំនេះកើត ដល់អញដោយបុណ្យ ដូច្នេះហើយ ទើបកាន់យកចូលទៅកាន់នគរ បុរស ដែលគេចាត់មកឃើញបុរសនោះហើយទើបសួរថា នែបា អ្នកនាំរបស់នេះទៅ ឲ្យអ្នកណា កុលបុត្តនោះឆ្លើយថា អើអ្នក ខ្ញុំមិននាំមកឲ្យអ្នកណាទេ តែនាំ មកដើម្បីលក់ ។ បុរសនោះក៏ពោលថា នែបា បើដូច្នោះ សូមអ្នកទទួល កហាបណៈនេះទៅ ហើយលក់ទឹកឃ្មុំនិងសម្បកអំពៅនេះឲ្យខ្ញុំ បុរសនោះគិតថា របស់នេះមានតម្លៃមិនច្រើន តែបុរសនេះឲ្យថ្លៃដោយវាយតម្លៃតែម្តងប៉ុណ្ណោះ អញគួរពិសោធមើល ។ លំដាប់នោះ កុលបុត្តនោះនិយាយនឹងបុរសនោះថា ខ្ញុំមិនលក់ដោយតម្លៃមួយកហាបណៈទេ បុរសនោះពោលថា បើដូច្នោះ ចូរ ទទួល ២ កហាបណៈ ហើយលក់ចុះ សូម្បី ២ កហាបណៈក៏មិនលក់ ។ ដោយឧបាយនេះ បុរសនោះក៏តម្លើងថ្លៃដល់ ១០០០ កហាបណៈ ។

បុរសនោះគិតថា របស់នេះមិនគួរមានថ្លៃច្រើន ណ្ហើយចុះ អញនឹងសួរ ដល់កិច្ចការដែលគេត្រូវធ្វើដោយរបស់នេះ ។ គ្រានោះ កុលបុត្តនោះក៏សួរ បុរសនោះថា របស់នេះមានតម្លៃមិនច្រើនតែអ្នកឲ្យថ្លៃណាស់ អ្នកទិញរបស់ នេះទៅធ្វើអ្វី បុរសនោះឆ្លើយថា អើបា អ្នកនគរនេះ ប្រណាំងជាមួយព្រះ រាជា ថ្វាយទានដល់ព្រះទសពល ព្រះនាមថាវិបស្សី មិនឃើញរបស់ ២ យ៉ាងនេះក្នុងទានវិធី ទើបស្វែងរក បើមិនបានរបស់ ២ មុខនេះ អ្នកនគរនឹង ចាញ់ ព្រោះដូច្នោះ ទើបខ្ញុំឲ្យតម្លៃដល់ ១០០០ កហាបណៈ កុលបុត្តនោះ សួរថា ទាននេះគួរដល់អ្នកស្រុកនេះប៉ុណ្ណោះ មិនគួរដល់អ្នកស្រុកដទៃទេឬ

បុរសនោះឆ្លើយថា ទាននេះអ្នកណាៗក៏ថ្វាយបាន មិនមានហាមឃាត់ឡើយ កុលបុត្តនោះសួរថា ក្នុងការថ្វាយទានរបស់អ្នកនគរក្នុងមួយថ្ងៃៗមានមនុស្សឲ្យទ្រព្យ ១០០០ កហាបណៈដែរឬទេ បុរសនោះឆ្លើយថា មិនមានឡើយ កុលបុត្តនោះសួរថា អ្នកដឹងថា របស់ ២ យ៉ាងនេះ មានតម្លៃដល់ ១០០០ កហាបណៈមិនមែនឬ បុរសនោះឆ្លើយថា ពិតហើយខ្ញុំដឹង កុលបុត្តនោះក៏ពោលថា បើដូច្នោះ ចូរអ្នកទៅ ចូរប្រាប់ដល់អ្នកនគរទាំងឡាយថា បុរសម្នាក់មិនព្រមលក់របស់ ២ យ៉ាងនេះ បំណងថ្វាយដោយដៃរបស់ខ្លួនប៉ុណ្ណោះ ពួកអ្នកទឹងអស់កង្វល់ ព្រោះហេតុនៃរបស់ ២ យ៉ាងនេះ ឯអ្នកចូរជាសាក្សីក្នុងការដែលខ្ញុំជាប្រធាន ក្នុងទានវិធីនេះ កុលបុត្តនោះទិញបញ្ចកដុក គឺគ្រឿងហឹរ ៥ យ៉ាង ដោយមាសកដែលដាក់ក្នុងថ្នក់ ដើម្បីជាស្បៀងធ្វើដំណើរ ហើយបុកឲ្យល្អិតដាក់ទធិប្របាច់ទឹកឃ្មុំចូលទៅក្នុងទធិនោះ ផ្សំជាមួយបញ្ចកដុកដែលបុកម៉ដ្ឋដាក់ក្នុងស្លឹកឈូកមួយ រៀបចំផ្ចិតផ្ចង់ស្លឹកឈូកនោះអង្គុយក្នុងទីមិនឆ្ងាយអំពីព្រះទសពល កាលមហាជននាំសក្ការៈមក ក៏រង់ចាំមើលវារៈដែលដល់ខ្លួនក្នុងទីមិនឆ្ងាយ បានឱកាស ក៏ចូលទៅជិតព្រះសាស្ដាក្រាបទូលថា នេះជាទុគ្គតបណ្ណាការដែលមាន សូមទ្រង់អាស្រ័យសេចក្ដីអនុគ្រោះទទួលបណ្ណាការនេះរបស់ខ្ញុំព្រះអង្គផងចុះ ។ ព្រះសាស្ដាទ្រង់អាស្រ័យសេចក្ដីអនុគ្រោះ ទ្រង់ទទួលទេយ្យធម៌នោះដោយបាត្រថ្ម ដែលស្ដេចចតុមហារាជថ្វាយ ហើយទ្រង់អធិដ្ឋានទេយ្យធម៌នោះដែលប្រគេនដល់ភិក្ខុ ៦ លាន ៨ សែនអង្គក៏មិនទាន់អស់ទៅឡើយ ។

កុលបុត្តនោះ ថ្វាយអភិវាទព្រះមានព្រះភាគ ដែលធ្វើកិច្ចស្រេចហើយ ឈរនៅក្នុងចំណែកម្ខាងក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សក្ការៈដែលអ្នកនគរពន្ធុមតី នាំមកថ្វាយព្រះអង្គ ខ្ញុំព្រះអង្គបានឃើញហើយក្នុងថ្ងៃនេះ ដោយផលនៃកម្មនេះ ខ្ញុំព្រះអង្គគប្បីជាបុគ្គលកំពូលជាងអ្នកមានលាភក្នុងភព ដែលកើតហើយ ដូច្នេះ ។ ព្រះសាស្តាត្រាស់ថា ម្នាលកុលបុត្ត សេចក្តីប្រាថ្នារបស់អ្នក ចូរសម្រេចយ៉ាងនោះ ដូច្នេះហើយ ទ្រង់ធ្វើភត្តានុមោទនា ដល់អ្នកនគរ ហើយទ្រង់ចៀសចេញទៅ ។

កុលបុត្តនោះធ្វើកុសលដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ បដិសន្ធិក្នុងគភ៌របស់ព្រះរាជធីតានាមថាសុប្បវាសា ។ រាប់តាំងអំពីថ្ងៃដែលបដិសន្ធិ មានមនុស្សនាំយកបណ្ណាការមកឲ្យនាងសុប្បវាសាមួយថ្ងៃ ១០០ រទេះ ទាំងក្នុងពេលល្ងាចនិងពេលព្រឹក ។ កាលនោះ ដើម្បីនឹងពិសោធបុណ្យនោះ មនុស្សទាំងឡាយ ក៏ឲ្យនាងយកដៃចាប់ល្អីពូជ ។

ពូជមួយគ្រាប់ ក៏ដុះចេញមកជាពូជ ១០០ ដើម ១០០០ ដើម ពូជដែលព្រោះក្នុងស្រែមួយករីស កើតបានជាផ្លែ ៥០ រទេះខ្លះ ៦០ រទេះខ្លះ ក្នុងកាលជញ្ជូនដាក់ជង្រុក មនុស្សទាំងឡាយក៏ឲ្យនាងយកដៃចាប់ទ្វារជង្រុក ។ ដោយបុណ្យរបស់ព្រះរាជធីតា កាលមនុស្សមកទទួលរបស់នោះទៅ ស្រូវដែលមនុស្សយកទៅហើយ ក៏ត្រឡប់ពេញដូចដើម កាលមនុស្សទាំងឡាយពោលថា បុណ្យរបស់ព្រះរាជធីតា ហើយឲ្យដល់បុគ្គលដទៃចាកភាជនៈភត្ត

ដែលពេញ កត្តក៏មិនអស់ទៅ រហូតដល់ឈប់ឲ្យ ។ ទារកនៅក្នុងផ្ទៃនោះឯងដោយកាលវេលាកន្លងទៅ ៧ ឆ្នាំ ។

កាលគភ៌ចាស់ជុំវិញហើយ នាងបានសោយមហាទុក្ខអស់ ៧ ថ្ងៃ ។ នាងហៅស្វាមីមក និយាយថា មុនស្លាប់ទាន់ខ្ញុំនៅមានជីវិតនេះឯង ខ្ញុំសូមឲ្យទានបន្តិច បញ្ជូនប្តីទៅកាន់សម្នាក់ព្រះសាស្តាថា សូមអ្នកទៅ សូមក្រាបទូលការប្រព្រឹត្តទៅនេះដល់ព្រះសាស្តា សូមនិមន្តព្រះសាស្តា បើព្រះសាស្តាត្រាស់ពាក្យណា សូមកំណត់ពាក្យនោះឲ្យល្អ ហើយឆាប់មកប្រាប់ដល់ខ្ញុំ ។ ស្វាមីមកក្រាបទូលដំណឹងរបស់នាងដល់ព្រះមានព្រះភាគហើយ ។

ព្រះសាស្តាត្រាស់ថា សុប្បវាសាធីតារបស់ស្តេចកោលិយៈ ចូរមានសេចក្តីសុខ ប្រាសចាករោគ ចូរប្រសូតឱរសកុំបីមានរោគ ។ ព្រះរាជាស្តាប់ដូច្នោះហើយ ធ្វើអភិវាទព្រះមានព្រះភាគ មានមុខទៅកាន់ព្រះរាជវាំងរបស់ទ្រង់ ។ ទារកប្រសូតចាកគភ៌របស់នាងសុប្បវាសា ដូចចាក់ទឹកចេញអំពីធម្មក្រកមុនព្រះរាជាមកដល់នោះឯង មនុស្សដែលអង្គុយចោមរោមដែលមានមុខជោកដោយទឹកភ្នែក ក៏នាំគ្នាសើចសប្បាយ មហាជននាំគ្នាត្រេកអរបញ្ជូនដំណឹងដល់ព្រះរាជា ។

ព្រះរាជា ទតឃើញការមករបស់មនុស្សទាំងនោះ ទ្រង់ព្រះតម្រិះថា ប្រ-ហែលជាពាក្យរបស់ព្រះទសពលត្រាស់ នឹងជាផលសម្រេច ទ្រង់ប្រញាប់យាងមកប្រាប់ដំណឹងរបស់ព្រះសាស្តាដល់ព្រះរាជធីតា ។ ព្រះរាជធីតាក្រាបទូលថា ជីវិតកត្តដែលទ្រង់និមន្តទុកនោះឯង នឹងជាមង្គលកត្ត សូមទ្រង់ទៅ

និមន្តព្រះទសពលដើម្បីទ្រង់សោយ ៧ ថ្ងៃ ព្រះរាជាទ្រង់ ធ្វើយ៉ាងនោះ ។ មនុស្សទាំងឡាយ នាំគ្នាបំពេញមហាទានដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ទារកប្រសូតមកធ្វើចិត្តដែលក្តៅរបស់ពួកញាតិទាំងពួងឲ្យត្រជាក់បាន ព្រោះដូច្នោះ ទើបមនុស្សទាំងឡាយថ្វាយព្រះនាមទារកថា សីវលីទារក ដូច្នេះ ។ ព្រោះនៅក្នុងផ្ទៃមាតាអស់ ៧ ឆ្នាំ ទើបទារកនោះរឹងប៉ឹងតាំងអំពីពេលកើតមក ។ ព្រះធម្មសេនាបតីសារីបុត្ត បានធ្វើការសន្ទនាប្រាស្រ័យជាមួយសីវលីនោះ ក្នុងថ្ងៃទី ៧ ព្រះបរមសាស្តា ក៏ទ្រង់បានភាសិតព្រះគាថាក្នុងធម្មបទថា

បុគ្គលណា កន្លងផ្លូវវាងគឺរាគៈនិងភក់ដែលគេឆ្លងបានដោយកម្រ គឺកិលេសនិងសង្សារវដ្តនិងមោហៈទាំងនេះបាន ជាអ្នកឆ្លងអន្លង់ទាំង ៤ បានដល់ត្រើយគឺព្រះនិព្វាន ជាអ្នកមានឈានមិនញាប់ញ័រដោយតណ្ហា មិនមានសេចក្តីសង្ស័យ មិនប្រកាន់មាំ ជាអ្នករលត់កិលេសហើយ តថាគតហៅបុគ្គលនោះថា ជាព្រាហ្មណ៍ ដូច្នេះ ។

លំដាប់នោះ ព្រះថេរៈពោលយ៉ាងនេះថា ការដែលអ្នកសោយគំនរទុក្ខយ៉ាងនេះហើយ អ្នកបួសមិនសមគួរឬ ទារកឆ្លើយថា បើបានទទួលអនុញ្ញាតខ្ញុំនឹងបួស ។ ព្រះនាងសុប្បវាសាឃើញទារកនិយាយជាមួយព្រះថេរៈ គិតក្នុងចិត្តថា កូនរបស់អញនិយាយជាមួយព្រះធម្មសេនាបតីដូចម្តេចហ្ន៎ ទើបចូលទៅរកព្រះថេរៈសាកសួរថាកូនរបស់ខ្ញុំនិយាយអ្វីជាមួយលោកម្ចាស់ខ្លះ ។

ព្រះថេរៈឆ្លើយថា កូនរបស់ព្រះនាងពោលដល់ទុក្ខដែលនៅក្នុងគភ៌ ដែលខ្លួនសោយ ហើយពោលថា បើនាងអនុញ្ញាតនឹងបួស ។ នាងឆ្លើយថា បពិត្រលោកម្ចាស់ ប្រពៃពិត សូមលោកម្ចាស់ឲ្យគេបួសចុះ ។ ព្រះថេរៈនាំសីវលីកុមារទៅវិហារ កាលនឹងប្រាប់តចបញ្ចកកម្មដ្ឋាន ឲ្យបួសហើយ ទូន្មានថា នែសីវលី ការឲ្យឱវាទដទៃមិនមានដល់អ្នក ចូរអ្នកពិចារណាដល់ទុក្ខដែលអ្នកសោយអស់ ៧ ឆ្នាំនោះឯង សីវលីសាមណេរពោលថា បពិត្រលោកម្ចាស់ ការៈរបស់លោកម្ចាស់គឺការឲ្យខ្ញុំបួស ឯកិច្ចកម្មឯណាដែលខ្ញុំអាចធ្វើបាន ខ្ញុំនឹងដឹងកិច្ចកម្មនោះឯង ។ សីវលីសាមណេរ ក្នុងខណៈកោរមួយកាំបិតដំបូង តាំងនៅក្នុងសោតាបត្តិផល ក្នុងខណៈកោរកាំបិតទី ២ តាំងនៅក្នុងសកទាគាមិផល ក្នុងខណៈកោរកាំបិតទី ៣ តាំងនៅក្នុងអនាគាមិផល ក្នុងខណៈកោរហើយស្រេច ក៏ធ្វើឲ្យជាក់ច្បាស់នូវអរហត្តព្រមគ្នា ។ ចាប់ពីថ្ងៃដែលសីវលីបានសម្រេចអរហត្ត បច្ច័យ ៤ រមែងកើតឡើងដល់ភិក្ខុសង្ឃគ្រប់គ្រាន់តាមសេចក្តីត្រូវការ ។ ក្នុងសេចក្តីនេះ មានបុព្វប្បវត្តិដូចតទៅនេះថា បានឮថា សម័យមួយ ព្រះមានព្រះភាគ យាងទៅកាន់នគរសាវត្ថី ។ សីវលីថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងសាកល្បងនូវបុណ្យរបស់ខ្ញុំព្រះអង្គ សូមទ្រង់ឲ្យភិក្ខុ ៥០០ ដល់ខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា ម្នាលសីវលី ចូរអ្នកទទួលយកចុះ ។

សីវលីនាំភិក្ខុ ៥០០ បែរមុខទៅកាន់ព្រៃហិមពាន្ត ធ្វើដំណើរកាត់ព្រៃទេវតាដែលអាស្រ័យត្រង់ដើមជ្រៃឃើញលោកគ្រាដំបូង បានថ្វាយទានអស់

៧ ថ្ងៃ ។

លោកឃើញដើមព្រៃជាបឋម ឃើញភ្នំបណ្ឌវៈជាលើកទី ២ ឃើញស្ទឹងអចិរវតីជាលើកទី ៣ ឃើញស្ទឹងវរសាគរជាលើកទី ៤ ឃើញភ្នំហិមពាន្តជាលើកទី ៥ ដល់ព្រៃឆទ្ទន្តជាលើកទី ៦ ដល់ភ្នំគន្ធមាទន៍ជាលើកទី ៧ ជួបភ្នំរេវតៈជាលើកទី ៨ ដូច្នេះ ។

ទេវតានិងមនុស្សទាំងឡាយ បានថ្វាយទាន អស់ ៧ ថ្ងៃ ក្នុងទីគ្រប់កន្លែងដូច្នេះឯង ។

ឯទេវតាដែលជាព្រះរាជាព្រះនាមថា នាគទត្ត ស្ថិតនៅត្រង់ភ្នំគន្ធមាទន៍ បានថ្វាយទានក្នុងថ្ងៃទាំង ៧ គឺថ្វាយខីរបិណ្ឌបាតមួយថ្ងៃ ថ្វាយសប្បិបិណ្ឌបាតមួយថ្ងៃវៀងគ្នាទៅ ។ ភិក្ខុសង្ឃសួរថា មេគោដែលរីតទឹកដោះរបស់រាជទេវតានេះក៏មិនប្រាកដ ការកូរទឹកដោះជូរក៏មិនប្រាកដ នៃ រាជទេវតា របស់នេះកើតឡើងដល់អ្នកដូចម្តេច រាជទេវតាតបថា បពិត្រលោកម្ចាស់ នេះជាផលនៃការថ្វាយសលាកកត្តធ្វើអំពីទឹកដោះ ដល់ព្រះទសពល ព្រះនាមថា កស្សបៈ ។ ក្នុងកាលតមក ព្រះសាស្តាទ្រង់ធ្វើការទទួលព្រះខទិរវនិយ-រេវតត្ថេរ ឲ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់តែងតាំងព្រះសីវលិត្ថេរក្នុងតំណែងឯតទគ្គៈក្នុងបណ្តាភិក្ខុទាំងឡាយ ដែលប្រសើរដោយលាភ និងដោយយសទាំងឡាយក្នុងសាសនារបស់ព្រះអង្គ ។

ឯអាចារ្យពួកខ្លះពោលដល់ការសម្រេចអរហត្តរបស់ព្រះថេរៈ ដែលដល់

នូវភាពជាឯតទគ្គៈដោយលាភ ដោយយសយ៉ាងនេះថា កាលព្រះធម្មសេនាបតីសារីបុត្ត បានឲ្យឱវាទដោយន័យដូចពោលហើយខាងដើម កាលសីវលីកុមារពោលថា ខ្ញុំនឹងដឹងកិច្ចកម្មដែលខ្ញុំអាចធ្វើបាន ដូច្នេះហើយបួសរៀនវិបស្សនាកម្មដ្ឋាន ក្នុងថ្ងៃនោះឯង ឃើញកុដិមួយខ្ទង់ទំនេរ ក៏ចូលទៅកាន់កុដិនោះ រឭកដល់ទុក្ខដែលខ្វះសោយហើយ ក្នុងផ្ទៃរបស់មាតាអស់ ៧ ឆ្នាំ កាលពិចារណាទុក្ខនោះក្នុងអតីត និងអនាគត ដោយទំនងនោះឯង ភពទាំង ៣ ក៏ប្រាកដដូចភ្លើងឆេះទូទៅ ។ សីវលីសាមណេរឈមចុះកាន់ វិបស្សនាវិថី ព្រោះញាណដល់នូវការចាស់ក្លាដោយជុំវិញ ធ្វើអាសវៈទាំងពួងឲ្យអស់ទៅតាមលំដាប់មគ្គ សម្រេចអរហត្តក្នុងខណៈនោះឯង ចាកការឃើញទាំងពីរយ៉ាង មានសេចក្ដីផ្ទុយគ្នាថា ព្រះថេរៈបានសម្រេចព្រះអរហត្ត ដូចគ្នា[១] ព្រះថេរៈជាអ្នកបែកធ្លាយក្នុងបដិសម្ភិទា បាននូវអភិញ្ញា ៦ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

គ្រានោះខ្ញុំកើតជាទេវរាជឈ្មោះវរុណៈ មានយានពលវាហនៈ
បានចូលទៅបម្រើព្រះសម្ពុទ្ធ កាលព្រះអត្ថទស្សី ឧត្តមជាង
សត្វជើងពីរ ជាលោកនាថ ទ្រង់បរិនិព្វានហើយ ខ្ញុំនាំយកតូរ្យ
តន្ត្រីទាំងពួងទៅកាន់ពោធិព្រឹក្សដ៏ប្រសើរ ។ ខ្ញុំប្រមូលគ្រឿង
ដេញដំទាំងអស់ចូលទៅបម្រើដើមពោធិព្រឹក្សដ៏ប្រសើរ ដោយ

---

១-ចាកការឃើញពីរយ៉ាងនោះគឺទី ១ លោកពោលថា សម្រេចអរហត្តតាំងអំពីកោរសក់ហើយ ទី ២ ថា លោកចូលកាន់កុដិទំនេរទើបសម្រេចអរហត្ត ។

ការប្រគំនិងការរាំ ដូចជាបម្រើព្រះសម្ពុទ្ធក្នុងទីចំពោះព្រះភក្រ្ត ។ ខ្ញុំ បម្រើដើមពោធិព្រឹក្សក្នុងទីនោះ ជាឈើដុះលើផែនដី ខ្ញុំអង្គុយផ្គត់ភ្នែនធ្វើកាលកិរិយាក្នុងទីនោះ ។ ខ្ញុំប្រារព្ធនូវអំពើរបស់ខ្លួន មានចិត្តជ្រះថ្លាចំពោះពោធិព្រឹក្សដ៏ប្រសើរក៏បានទៅកើត ក្នុងឋាននិម្មានរតី ដោយចិត្តជ្រះថ្លានោះ ។ តូរ្យតន្ត្រី ៦០០០០ តែងហែហមខ្ញុំសព្វៗកាលដែលកំពុងប្រព្រឹត្តទៅក្នុងពួកមនុស្សនិងទេវតា ក្នុងភពតូចនឹងភពធំ ។ ភ្លើង ៣ ប្រការរបស់ខ្ញុំរលត់ហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំទ្រទ្រង់រាងកាយជាទីបំផុត ក្នុងសាសនា របស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៥០០ អំពីកប្បនេះ ខ្ញុំបានកើតជាក្សត្រ ៣៤ ជាតិ មានព្រះនាមសុពាហុដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ(១) ។

ព្រះសីវលិត្ថេរកាលសម្រេចអរហត្តហើយ កាលបន្លឺឧទានដោយកម្លាំងនៃបីតិ ទើបពោលគាថាថា

សង្កប្បធម៌ទាំងនោះ ( មាននេក្ខម្មសង្កប្បៈជាដើម ) សម្រេចហើយដល់ខ្ញុំ ខ្ញុំមានសេចក្តីត្រូវការនឹងចូលទៅកាន់ខ្ទមដែល

---

១-ក្នុងអបទានជាព្រះ ឯកាសនិយត្ថេរ ។

ជាខ្ញុំមនាំឲ្យខ្ញុំបានដល់នូវវិជ្ជា និងវិមុត្តិ លះបង់នូវមានានុស័យ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តេ មេ ឥជ្ឈិសុ សង្កប្បា យទត្ថោ បាវិសឹ កុដឹ វិជ្ជាវិមុត្តឹ បច្ចេស្សំ** សេចក្ដីថា ការត្រិះរិះក្នុងការចេញចាកកាមជាដើម ដែលធ្វើនូវការដកឡើងនូវការត្រិះរិះក្នុងកាមជាដើម ក្នុងកាលមុនទាំងឡាយណា ដែលខ្ញុំប្រាថ្នាក្រៃលែងថា កាលណាហ្ន៎ អញនឹងចូលទៅស្ងប់ក្នុងតទាយតនៈ គឺព្រះនិព្វាន ដែលព្រះអរិយៈទាំងឡាយចូលដល់ហើយក្នុងបច្ចុប្បន្ន គឺការត្រិះរិះដើម្បីវិមុត្តិ ដែលជាសេចក្ដីប៉ុនប៉ងដើម្បីការរួចផុត បានដល់ មនោរថខ្ញុំមិនប្រមាទរឿយៗ ចូលកាន់កុដិ គឺសុញ្ញាគារដើម្បីរបស់ណា គឺដើម្បីប្រយោជន៍ឯណា គឺដើម្បីញ៉ាំងប្រយោជន៍ណា ឲ្យសម្រេច បានដល់ដើម្បីឃើញច្បាស់ប្រាថ្នាស្វែងរកវិជ្ជា ៣ និងផលវិមុត្តិ ការត្រិះរិះទាំងនោះសម្រេចហើយដល់ខ្ញុំ គឺសេចក្ដីត្រិះរិះទាំងនោះសម្រេចហើយ គឺសមបំណងរបស់ខ្ញុំហើយ គ្រប់ប្រការក្នុងឥឡូវនេះ អធិប្បាយថា ជាអ្នកមានកុសលសង្កប្បសម្រេចហើយ គឺមានមនោរថបរិបូណ៌ហើយ ដើម្បីសម្ដែងដល់សេចក្ដីសម្រេចនៃការត្រិះរិះទាំងនោះ ទើបលោកពោលថា **មានានុសយមុជ្ជហំ** ប្រែថា លះបង់នូវមានានុស័យ ដូច្នេះ ។ ប្រកបសេចក្ដីថា ព្រោះហេតុដែលខ្ញុំដកឡើង គឺលះ បានដល់ កាត់បង់នូវមានានុស័យ ដូច្នោះ ទើបការត្រិះរិះទាំងឡាយនោះរបស់ខ្ញុំសម្រេចហើយ អធិប្បាយថា កាលលះមានានុស័យបានហើយ អនុស័យដែលឈ្មោះថា មិនទាន់លះបានមិនមាន ព្រះអរហត្តក៏

រមែងឈ្មោះថា សម្រេចហើយដែរ ព្រោះដូច្នោះ ទើបការលះមានានុស័យ លោកពោលធ្វើឲ្យជាហេតុនៃការសម្រេចនៃការត្រិះរិះតាមដែលពោលហើយ ។

## អដ្ឋកថា សីវលិត្ថេរគាថា ចប់

## វគ្គទី ៦ ចប់

# ថេរគាថា ឯកនិបាត

## សត្តមវគ្គ

### វប្បត្ថេរគាថា

[ ៦២ ] បណ្ឌិតអ្នកឃើញ រមែងឃើញនូវបណ្ឌិតអ្នកឃើញ ( ផងគ្នា ) ផង ឃើញពាលអ្នកមិនឃើញផង ឯពាលអ្នកមិនឃើញ រមែងមិនឃើញពាលដែលមិនឃើញ ( ផងគ្នា ) ផង នូវបណ្ឌិតអ្នកឃើញផង ។

វប្បត្ថេរ ។

## វគ្គទី ៧

### អដ្ឋកថា វប្បត្ថេរគាថា

[ ៦២ ] គាថារបស់ព្រះវប្បត្ថេរ មានពាក្យផ្តើមថា **បស្សតិ បស្សោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កុលបុត្តនេះ កើតក្នុងផ្ទះមានត្រកូលក្នុងនគរហង្សវតី ដល់នូវភាពជាអ្នកដឹងក្តីហើយ ស្តាប់ពាក្យសរសើរថា ព្រះថេរៈរូបនោះនិងរូបនោះ បានជាអ្នកទទួលនូវធម៌របស់ព្រះសាស្តាជាបឋម ដូច្នេះ ទើបចូលទៅគាល់ព្រះមានព្រះភាគ ហើយតាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងអនាគតកាល សូមឲ្យខ្ញុំព្រះអង្គជាភិក្ខុណាមួយ បណ្តាភិក្ខុដែលទទួលធម៌របស់ព្រះសម្មាសម្ពុទ្ធជាបឋម

ដូច្នេះហើយ ប្រកាសខ្លួនដល់នូវសរណគមន៍ក្នុងសម្នាក់របស់ព្រះសាស្តា ។ កុលបុត្តនោះធ្វើបុណ្យរហូតអស់ជីវិត ចុតិអំពីអត្តភាពនោះហើយ អន្ទោល ទៅមកក្នុងទេវតានិងមនុស្សទាំងឡាយនោះឯង ។ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនព្រាហ្មណ៍វាសេដ្ឋក្នុងក្រុងកបិលពស្តុមានឈ្មោះថាវប្បៈ ។ វប្បព្រាហ្មណ៍ កាលអសិតឥសីព្យាករថា សិទ្ធត្ថកុមារនឹងបានជាសព្វញ្ញូ មួយអន្លើដោយបុត្តព្រាហ្មណ៍ មានកោណ្ឌញ្ញជាប្រធាន លះបង់យកវាសវិស័យ ចេញបួសជាតាបស គិតថា កាលសិទ្ធត្ថកុមារនោះសម្រេចសព្វញ្ញុតញ្ញាណហើយអញនឹងស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះអង្គ ហើយនឹងសម្រេចអមតធម៌ ទើបចូលទៅឧបដ្ឋាកព្រះមហាសត្វ គង់នៅក្នុងឧរុវេលានិគម បំពេញព្យាយាមអស់ ៦ ឆ្នាំ កើតនូវការនឿយណាយដោយព្រះមហាសត្វសោយអាហារមកវិញ ទើបគេចចេញទៅកាន់ព្រៃឥសិបតនៈ ។

កាលព្រះបរមសាស្តាត្រាស់ដឹងហើយ ទ្រង់ញុំាងពេលវេលាឲ្យកន្លងទៅ ៧ សប្តាហ៍ ហើយយាងចូលទៅកាន់ព្រៃឥសិបតនៈសម្តែងនូវធម្មចក្រ វប្បតាបសតាំងនៅក្នុងសោតាបត្តិផល ក្នុងថ្ងៃបាដិបទ ( ថ្ងៃ ១ រោច ) ហើយសម្រេចអរហត្តផលមួយអន្លើដោយអញ្ញាកោណ្ឌញ្ញៈជាដើមក្នុងតិថីទី ៥ នៃបក្ខ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

សង្គ្រាមរបស់ពួកទេវរាជទាំង ២ ព្រះអង្គតាំងផ្តើមឡើងមាន
កងទ័ពតាំងឡើងព្រម សំឡេងគឹកកងខ្លាំងប្រព្រឹត្តទៅ ។ ព្រះ
លោកវិទូព្រះនាម បទុមុត្តរៈ ព្រះអង្គគួរទទួលនូវគ្រឿងបូជា

ជាព្រះសាស្តា ទ្រង់ឋិតនៅនាអាកាស ហើយញុំាងមហាជនឲ្យកើតសង្វេគ ទេវតាទាំងអស់មានចិត្តរីករាយ ក៏ទម្លាក់អាវក្រោះនិងអាវុធចុះ ហើយថ្វាយបង្គំព្រះសម្ពុទ្ធ ជាពួកទេពមានចិត្តមូលតែមួយក្នុងវេលានោះ ។ ព្រះលោកវិទូទ្រង់អនុគ្រោះទ្រង់ជ្រាបនូវតម្រិះរបស់ខ្ញុំ ហើយទ្រង់បន្ទឺឡើងនូវវាចាដ៏អង់អាច ទ្រង់ញុំាងមហាជនឲ្យរលត់ទុក្ខ ( ដោយព្រះពុទ្ធដីកាថា ) មនុស្សមានចិត្តប្រទូស្ត បៀតបៀនតែសត្វមួយ នឹងទៅកើតក្នុងអបាយ ដោយចិត្តប្រទូស្តនោះ ។ អ្នកទាំងឡាយគួរញុំាងចិត្តរបស់ខ្លួនឲ្យរលត់ អ្នកទាំងឡាយ កុំបៀតបៀនសត្វរឿយៗឡើយ ដូចជាដំរីដ៏ប្រសើរ ដែលបៀតបៀនសត្វច្រើនក្នុងប្រធាននៃសង្គ្រាមនោះឡើយ ។ ឯពួកសេនារបស់ស្តេចនៃទេវតាទាំងសងខាងបានស្ងប់ ហើយបានដល់នូវព្រះលោកជេដ្ឋជាតាទិបុគ្គលដ៏ប្រសើរជាទីពឹង ។ ព្រះចក្ខុមសម្ពុទ្ធទ្រង់ធ្វើប្រជុំជនឲ្យយល់ច្បាស់ ទ្រង់ស្រោចស្រង់ប្រជុំជន ហើយទ្រង់ក្រឡេកមើល បែរព្រះភក្ត្រទៅកាន់ឧត្តរទិស ចៀសចេញទៅចាកពួកទេវតា ។ ខ្ញុំបានដល់នូវសរណគមន៍ជាដំបូងចំពោះព្រះពុទ្ធជាធំជាងពួកសត្វជើង ២ ជាតាទិបុគ្គល ខ្ញុំមិនដែលទៅកាន់ទុគ្គតិអស់ ១ សែនកប្ប ។ ក្នុងកប្បទី ៣០០០០ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១៦ ជាតិ ទ្រង់ព្រះនាមមហាចុន្ទកិ

ដូចគ្នា ទ្រង់ប្រសើរក្នុងវេជ ។ បដិសម្ភិទា ៤ វិមោក្ខ ៨
និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា
របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១]។

ព្រះវប្បត្ថេរកាលសម្រេចអរហត្តហើយពិចារណាឃើញថា ព្រះសាស្តាមានព្រះគុណធំក្រៃលែង ដោយពិចារណាដល់សម្បត្តិដែលខ្លួនបានហើយជាសំខាន់ កាលនឹងសម្តែងថា អាត្មាអញចោទព្រះសាស្តា ដែលមានព្រះគុណបែបនេះដោយវាទៈថា ទ្រង់វិលទៅដើម្បីភាពជាអ្នកប្រាជ្ញាច្រើន ឱ ! ឈ្មោះថា បុថុជ្ជនធ្វើបុគ្គលឲ្យខ្វាក់ ធ្វើឲ្យបុគ្គលមិនមានពន្លឺ ភាពជាអរិយៈប៉ុណ្ណោះធ្វើឲ្យកើតនូវកែវភ្នែក គឺធម្មចក្ខុ ដូច្នេះ ទើបពោលគាថាថា

បណ្ឌិតអ្នកឃើញ រមែងឃើញនូវបណ្ឌិតអ្នកឃើញ ( ផងគ្នា )
ផង ឃើញពាលអ្នកមិនឃើញផង ឯពាលអ្នកមិនឃើញ
រមែងមិនឃើញពាលដែលមិនឃើញ ( ផងគ្នា ) ផង នូវ
បណ្ឌិតអ្នកឃើញផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បស្សតិ បស្សោ** សេចក្តីថា បុគ្គលឈ្មោះថា **បស្ស** ព្រោះឃើញ គឺដឹង បានដល់ ត្រាស់ដឹងនូវធម៌ទាំងឡាយដោយមិនភ្លាំងភ្លាត់ដោយសម្មាទិដ្ឋិ សំដៅដល់ព្រះអរិយបុគ្គលដែលបរិបូណ៌ដោយទស្សនៈ ព្រះអរិយបុគ្គលនោះ រមែងឃើញអ្នកឃើញ គឺឃើញមិនខុសថាបុគ្គលនេះឃើញធម៌មិនខុស គឺរមែងដឹងធម៌សមគួរដល់ធម៌ ដោយបញ្ញាចក្ខុ

---

១-ក្នុងអបទានជាព្រះ សរណគមនិយត្ថេរ ។

តាមសេចក្ដីពិត មិនមែនឃើញចំពោះបុគ្គលអ្នកឃើញ តែម៉្យាងប៉ុណ្ណោះទេ ដោយពិតគង់ឃើញបុគ្គលដែលមិនឃើញទៀតផងគឺរមែងឃើញបុថុជ្ជនដែលប្រាសចាកបញ្ញាចក្ខុដែលមិនឃើញធម៌តាមសេចក្ដីពិតទៀតផង ដោយបញ្ញាចក្ខុរបស់ខ្លួនថា បុគ្គលនេះជាបុគ្គលងងឹត ជាបុគ្គលមិនមានភ្នែក ( ឃើញនូវធម៌ ) ដូច្នេះ ។ បទថា **អបស្សន្តោ អបស្សន្តំ បស្សន្តញ្ច ន បស្សតិ** សេចក្ដីថា ឯបុគ្គលអន្ធពាលប្រាសចាកបញ្ញាចក្ខុជាអ្នកមិនឃើញ រមែងមិនឃើញបុគ្គលពាលបែបនោះដែលមិនឃើញថា បុគ្គលនេះមិនឃើញធម៌ និងអធម៌តាមសេចក្ដីពិត គឺមិនដឹង យ៉ាងណា បុគ្គលដែលមិនឃើញ គឺមិនដឹងនូវបណ្ឌិតដែលឃើញធម៌ និងអធម៌ដោយបញ្ញាចក្ខុរបស់ខ្លួនតាមសេចក្ដីពិតថា បុគ្គលនេះយ៉ាងនេះ ក៏យ៉ាងនោះ ព្រោះហេតុនោះ ទើបព្រះថេរៈសម្ដែងបដិបទាដែលមិនខុសរបស់ខ្លួន ក្នុងបុគ្គលដែលគួរសេពគប់ និងមិនគួរសេពគប់ថា សូម្បីអាត្មាអញដែលប្រាសចាកទស្សនៈក្នុងកាលមុន មិនឃើញព្រះមានព្រះភាគដែលទ្រង់ឃើញនូវញេយ្យធម៌សព្វយ៉ាង ដូចឃើញផ្លែកន្ទួតព្រៃក្នុងបាតដៃ ( និងមិនឃើញ ) សាស្ដាទាំង ៦ មានបូរណកស្សបៈជាដើមដែលមិនឃើញ ( ធម៌ ) តាមសេចក្ដីពិត តែឥឡូវនេះ ខ្ញុំចូលដល់ដោយពុទ្ធានុភាព ទើបឃើញបុគ្គលទាំងពីរចំណែកតាមសេចក្ដីពិត ។

*អដ្ឋកថា វប្បត្ថេរគាថា ចប់*

## វជ្ជិបុត្តកត្ថេរគាថា

[ ៦៣ ] យើងម្នាក់ឯងនៅក្នុងព្រៃ ដូចកំណាត់ឈើ ដែលគេចោលក្នុងព្រៃ ពួកកុលបុត្តជាច្រើនរូបរមែងស្រឡាញ់យើង ដូចពួកសត្វនរក ស្រឡាញ់អ្នកដែលទៅកាន់ឋានសួគ៌ ។

វជ្ជិបុត្តកត្ថេរ ។

## អដ្ឋកថា

## វជ្ជិបុត្តកត្ថេរគាថា

[ ៦៣ ] គាថារបស់ព្រះវជ្ជិបុត្តកត្ថេរ មានពាក្យផ្ដើមថា **ឯកកា មយំ អរញ្ញេ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ កើតក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមថាវិបស្សី ក្នុងកប្បទី ៩១ អំពីភទ្ទកប្បនេះកើតក្នុងផ្ទះមានត្រកូលកុលបុត្តនោះដល់នូវភាពជាអ្នកដឹងក្ដីហើយ ថ្ងៃមួយ ឃើញព្រះមានព្រះភាគព្រះនាមថាវិបស្សី ជាអ្នកមានចិត្តជ្រះថ្លាហើយ បានធ្វើនូវការបូជាដោយកេសរផ្កាខ្ទឹង ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ មកកើតក្នុងត្រកូលអាមាត្យ មានឈ្មោះថា វជ្ជិបុត្ត ឃើញពុទ្ធានុភាពរបស់ព្រះមានព្រះភាគ ក្នុងកាលដែលទ្រង់យាងទៅនគរវេសាលី មានសទ្ធាបួសហើយ ធ្វើបុព្វ

កិច្ចស្រេចហើយ រៀនកម្មដ្ឋានចូលទៅកាន់ដងព្រៃមួយកន្លែង មិនឆ្ងាយអំពីនគរវេសាលី ។

សម័យនោះ មានមហោស្រពក្នុងនគរវេសាលី ការរាំ ការច្រៀង ការប្រគំ មានក្នុងទីគ្រប់កន្លែង ។ មហាជននាំគ្នាត្រេកអរ មើលការបរិបូណ៌របស់មហោស្រព កុលបុត្តនោះស្តាប់សំឡេងនោះហើយវង្វេង ព្រោះមិនធ្វើទុកក្នុងចិត្តដោយឧបាយ កាត់បង់នូវវិវេក លះបង់នូវកម្មដ្ឋាន កាលនឹងប្រកាសការមិនត្រេកអររបស់ខ្លួន ទើបពោលគាថា ( ក្នុងសំយុត្តនិកាយសគាថវគ្គ ) ថា

យើងមកនៅក្នុងព្រៃតែម្នាក់ឯង ដូចជាកំណាត់ឈើ ដែលគេបោលក្នុងព្រៃ ក្នុងរាត្រីប្រាកដដូច្នេះ មិនមានអ្នកណាអន់ជាងយើងទៅទៀតទេ ដូច្នេះ ។

ទេវតាដែលអាស្រ័យនៅក្នុងដងព្រៃ ស្តាប់ពាក្យនោះហើយ កាលអនុគ្រោះភិក្ខុនោះ ចង់ឲ្យដឹងយ៉ាងនេះថា នែភិក្ខុ លោកពោលទោសការនៅព្រៃក៏ពិតតែអ្នកប្រាជ្ញប្រាថ្នាវិវេក រមែងរាប់អានលោកដោយច្រើននោះឯង ទើបពោលគាថា ( ក្នុងសំយុត្តនិកាយសគាថវគ្គ ) ថា

លោកនៅក្នុងព្រៃតែម្នាក់ឯងដូចជាកំណាត់ឈើដែលគេបោលនៅក្នុងព្រៃមែន តែមានជនច្រើនគ្នាស្រឡាញ់លោកនោះ ដូចពពួកសត្វ ក្នុងឋាននរក ស្រឡាញ់ពួកទេវតា ក្នុងឋានសួគ៌ ដូច្នេះ ។

ហើយសម្មតព្រះថេរៈឲ្យសង្វេគថា នែភិក្ខុ លោកបួសក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធដែលនាំសត្វចេញចាកទុក្ខ ត្រិះរិះដល់វិតក្កដែលមិននាំសត្វចេញចាកទុក្ខទៅវិញ ។

ភិក្ខុនោះ កាលទេវតានោះឲ្យសង្វេគហើយយ៉ាងនេះ ដូចជាសេះអាជានេយ្យ ត្រូវនាយសារថីវាយហើយដោយរំពាត់ ដូច្នោះ ឈមចុះកាន់គន្លងនៃវិបស្សនាខ្វល់ខ្វាយក្នុងវិបស្សនាសម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះសម្ពុទ្ធមានវណ្ណៈដូចមាសទ្រង់ដូចព្រះអាទិត្យមានរស្មីច្រើន ញុំាងទិសទាំងពួងឲ្យភ្លឺស្វាង ឬដូចព្រះចន្ទ្រពេញវង់ ទ្រង់មានពួកសាវកចោមរោមដូចផែនដីមានសមុទ្រ ( ព័ទ្ធជុំវិញ ) ខ្ញុំយកលម្អងផ្កាខ្ទឹងទាំងឡាយ បូជាចំពោះព្រះវិបស្សី ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុ ដែលខ្ញុំបានបូជាលម្អងផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៤៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ១ អង្គទ្រង់ព្រះនាមរេណុរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

---

១-ក្នុងអបទានជាព្រះ រេណុបូជកត្ថេរ ។

ព្រះវជ្ជិបុត្តកត្ថេរ កាលសម្រេចអរហត្តហើយ គិតថា គាថានេះជាកង្វេរ សម្រាប់សម្រេចអរហត្តរបស់អញ ដូច្នេះហើយ រឭកដល់ន័យដែលទេវតាពោលហើយដល់ខ្លួន ទើបពោលគាថានេះថា

យើងម្នាក់ឯងនៅក្នុងព្រៃ ដូចកំណាត់ឈើ ដែលគេចោលក្នុង

ព្រៃ ពួកកុលបុត្តជាច្រើនរូបរមែងស្រឡាញ់យើង ដូចពួកសត្វ

នរកស្រឡាញ់អ្នកដែលទៅកាន់ឋានសួគ៌ ដូច្នេះ ។

គាថានោះមានអត្ថដូច្នេះថា ខ្ញុំជាអ្នកនៅតែឯង មិនមានសម្លាញ់ក្នុងព្រៃ ឧបមាដូចកំណាត់ឈើដែលគេចោលក្នុងព្រៃ ព្រោះមិនមានមនុស្សមើលថែ តែមនុស្សជាច្រើនតែងត្រេកអរចំពោះខ្ញុំ ដែលនៅយ៉ាងនេះ គឺនៅមានកុល-បុត្តដែលប្រាថ្នានូវប្រយោជន៍ជាច្រើនប្រាថ្នាខ្ញុំក្រៃលែងថា ឱហ្ន៎ ! សូម្បីយើងទាំងឡាយ គប្បីលះនូវគ្រឿងជាប់ជំពាក់ក្នុងផ្ទះហើយ នៅក្នុងព្រៃដូចព្រះវជ្ជិបុត្តកត្ថេរដូច្នោះ ។ សេចក្តីនេះដូចអ្វី ដូចពួកសត្វនរកស្រឡាញ់អ្នកដែលទៅកាន់ឋានសួគ៌ដូច្នោះ អធិប្បាយថា ប្រៀបដូចសត្វនរក គឺ សត្វដែលកើតហើយក្នុងនរកដោយបាបកម្មរបស់ខ្លួន រមែងត្រេកអរចំពោះបុគ្គល ដែលទៅកាន់ឋានសួគ៌ គឺដែលចូលដល់ស្ថានសួគ៌ថា ឱហ្ន៎ ! សូម្បីពួកយើង លះទុក្ខក្នុងនរកហើយ គប្បីសោយសុខក្នុងស្ថានសួគ៌ យ៉ាងណា ឧបមេយ្យនេះ ក៏ដូច្នោះ ។

ក្នុងគាថានេះ ព្រោះលោកបំណងធ្វើប្រយោគឲ្យជាពហុវចនៈ សម្តែងនូវការគោរពក្នុងខ្លួនថា **ឯកកា មយំ វិហរាម** ទើបធ្វើប្រយោគជាឯកវចនៈ

ទៀតថា **តស្ស មេ** ដោយអត្ថនៃបទនោះមានន័យតែមួយដូចគ្នា ។ បើសម្ព័ន្ធដល់បទថា **បិហយន្តិ** ហើយ បទទាំង ២ គឺ **តស្ស មេ** និង **សគ្គគាមិនំ** គប្បីជ្រាបថា ជាចតុត្ថីវិភត្តិ ( ប្រែថា ចំពោះ ) ប្រើក្នុងអត្ថរបស់ទុតិយាវិភត្តិ ( ប្រែថា នូវ ) ។ បទថា **បិហយន្តិ** ខ្ញុំ អធិប្បាយថា ស្មើគ្នានឹង **អភិបត្ថេន្តិ** ( ប្រែថា ប្រាថ្នា ) ព្រោះថា មនុស្សជាច្រើន ឈ្មោះថា រមែងប្រាថ្នានូវគុណមានការនៅព្រៃជាដើម ដូច្នេះ ។

ម្យ៉ាងទៀត បទថា **តស្ស មេ** បានដល់ នូវគុណទាំងឡាយក្នុងខ្លួនរបស់ខ្ញុំនោះ ។

អដ្ឋកថា វជ្ជិបុត្តកត្ថេរគាថា ចប់

## បក្កុលត្ថេរគាថា

[ ៦៤ ] ពួកសត្វ ( ឃាតបាកកុសលធម៌ ) ធ្លាក់ចុះហើយ រមែងធ្លាក់ចុះ ឯពួកសត្វដែលជាប់ចំពាក់ ( ក្នុងកាម ) តែងមកវិញ សោឡសកិច្ចដែលអាត្មាអញធ្វើហើយ ជាតម្រេកដែលគួរត្រេកអរ ព្រះនិព្វានជាសុខដែលមូលមិត្តដោយសេចក្តីសុខ ។

បក្កុលត្ថេរ ។

## អដ្ឋកថា

## បក្កុលត្ថេរគាថា

[ ៦៤ ] គាថារបស់ព្រះបក្កុលត្ថេរ មានពាក្យផ្តើមថា **ចុតា បតន្តិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏មានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ ធ្វើកុសលទុកក្នុងភពនោះៗ ក្នុងកប្បទី ៩១ អំពីកប្បនេះ កើតជាសេនាបតីយក្ខ ឃើញព្រះមានព្រះភាគព្រះនាមថាវិបស្សី មានចិត្តជ្រះថ្លាបានធ្វើការបូជាដោយសំពត់ទិព្វ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលសក្យៈ ក្នុងទេវទហនិគម ក្នុងដែនសក្កៈ មានឈ្មោះថា សម្មោទកុមារ ។

ក្នុងកាលកុលបុត្តនេះនៅក្មេង ជើងដើរមិនកើត ដោយរោគខ្យល់ កុលបុត្តនេះកម្រើកទៅមកដូចមនុស្សខ្វិនអស់មួយរយៈ ដោយហេតុនោះទើបមាន

ឈ្មោះថាថា បក្ខៈ ។ ក្រោយមក ក្នុងពេលដែលរោគជាសះស្បើយ មនុស្ស ទាំងឡាយក៏នៅតែហៅថា បក្ខៈ យ៉ាងនោះដដែល ។ កុលបុត្តនេះ ឃើញ បាដិហារ្យនៃព្រះមានព្រះភាគ ក្នុងសមាគមនៃព្រះញាតិ បានទូវសទ្ធាបួស ហើយ ធ្វើកិច្ចខាងដើមស្រេចហើយ រៀនកម្មដ្ឋានចូលទៅកាន់ព្រៃ ។

ថ្ងៃមួយ លោកចូលស្រុកដើម្បីបិណ្ឌបាត អង្គុយក្រោមដើមឈើមួយដើម ក្នុងវាងផ្លូវ ។ ក្នុងសម័យនោះ ខ្លែងមួយចាបដុំសាច់ហើរទៅកាន់អាកាស ខ្លែងជាច្រើនដេញតាមខ្លែងនោះ ចោមរោមចឹករហូតដុំសាច់ធ្លាក់មក ខ្លែងមួយ ទៀតក៏ពាំដុំសាច់គេចទៅ ខ្លែងដទៃក៏ដេញដណ្តើមដុំសាច់នោះបន្តៗគ្នា ព្រះ ថេរៈឃើញដូច្នោះគិតថា ដុំសាច់នេះមានសភាពយ៉ាងណា កាមទាំងឡាយក៏ យ៉ាងនោះ ជារបស់ទូទៅដល់មនុស្សច្រើនគ្នា មានទុក្ខច្រើន មានការចង្អៀត ចង្អល់ច្រើន ដូច្នេះហើយ ពិចារណាឃើញទោសក្នុងកាមទាំងឡាយ និងអា-និសង្សក្នុងការចេញបួស ផ្តើមតាំងវិបស្សនា មនសិការដោយន័យថា អនិច្ចំ ជាដើម ត្រាច់ទៅបិណ្ឌបាត ធ្វើភត្តកិច្ចហើយ អង្គុយក្នុងទីសម្រាកពេលថ្ងៃ ចម្រើនវិបស្សនាសម្រេចអរហត្តហើយ សមដូចគាថាព័ន្ធដែលលោកចងទុក ក្នុងអបទានថា

ក្នុងកាលនោះ ព្រះមានព្រះភាគព្រះនាមវិបស្សី ជាច្បងក្នុង
លោក ជានរាសភៈ ស្តេចចូលទៅឯក្រុងពន្ធុមៈ ជាមួយនឹង
ពួកភិក្ខុ ៦៨០០០ អង្គ ។ ខ្ញុំចេញទៅអំពីទីក្រុង ដើរសំដៅ
ទៅកាន់ទីចេតិយ បានឃើញព្រះសម្ពុទ្ធ មានធូលី គឺ រាគៈ

ទៅប្រាសហើយ ទ្រង់គួរទទួលនូវគ្រឿងបូជា ។ ពួកយក្ស ៨៤០០០ រូប តែងបម្រើខ្ញុំដោយគោរព ដូចពួកទេវតាបម្រើព្រះឥន្ទ្រ ។ គ្រានោះ ខ្ញុំដើរចេញអំពីលំនៅ កាន់យកសំពត់រួចថ្វាយបង្គំ ដោយសិរសា ហើយថ្វាយសំពត់នោះដល់ព្រះមហេសីសម្ពុទ្ធ ( ដោយសេចក្ដីជ្រះថ្លាថា ) ឱព្រះពុទ្ធទាំងឡាយ ឱព្រះធម៌ទាំងឡាយ ឱសម្បទារបស់ព្រះសាស្ដានៃយើង ផែនដីនេះញាប់ញ័រដោយអានុភាពរបស់ព្រះពុទ្ធ ។ ខ្ញុំឃើញនូវហេតុដ៏អស្ចារ្យ ចំឡែកគួរព្រឺរោមនោះ ក៏ញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធជាធំជាងសត្វជើង ២ ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ លុះខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាហើយ ក៏ថ្វាយសំពត់ដល់ព្រះសាស្ដា ខ្ញុំព្រមទាំងអាមាត្យ និងជនជាបរិស័ទក៏បានដល់នូវព្រះពុទ្ធជាទីពឹង ។ ក្នុងកប្បទី ៩១ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ១៦ ជាតិ ទ្រង់ព្រះនាមវាហនដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

---

១-ក្នុងអបទានជាព្រះ មហាបរិវារត្ថេរ ។

ព្រះថេរៈកាលសម្រេចអរហត្តផលហើយដើម្បីព្យាករអរហត្តផលដោយបំណងយកធម៌ដែលឲ្យកើតសេចក្ដីសង្វេគ ដែលប្រើជាកង្វេរ ហើយចម្រើនវិបស្សនារហូតសម្រេចអរហត្ត ទើបបានពោលគាថាថា

ពួកសត្វ ( ឃ្លាតចាកកុសលធម៌ ) ធ្លាក់ចុះហើយ រមែងធ្លាក់ចុះ ឯពួកសត្វដែលជាប់ចំពាក់ ( ក្នុងកាម ) តែងមកវិញ សោឡសកិច្ចដែលអាត្មាអញធ្វើហើយជាតម្រេកដែលគួរត្រេកអរ ព្រះនិព្វានជាសុខដែលមូលមិត្តដោយសេចក្ដីសុខ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចុតា** បានដល់ របូតហើយ ។ បទថា **បតន្តិ** បានដល់ ធ្លាក់ចុះមក ។ បទថា **បតិតា** សេចក្ដីថា ដុំសាច់ធ្លាក់ចុះត្រង់ផែនដីដោយអំណាចនៃការជ្រុះឬធ្លាក់ចុះ អណ្ដែតនៅក្នុងអាកាស ។ បទថា **គិទ្ធា** បានដល់ ដល់នូវការលោភ ។ បទថា **បុនរាគតា** បានដល់ចូលទៅពាំបន្តទៀត គប្បីប្រកប ៥ សព្ទ ភ្ជាប់ទៅគ្រប់ៗបទ មានពាក្យអធិប្បាយថា ខ្លែងទាំងឡាយក្នុងទីនេះធាបនិងធាបបន្តទៅ ដុំសាច់របូតអំពីមាត់របស់ខ្លែងមួយ ។ ដុំសាច់ដែលរបូតហើយ ក៏ជ្រុះទៅលើផែនដី ។ខ្លែងទាំងអស់ដែលល្មោភ ដល់នូវការល្មោភ ក៏ពាំយកទៅទៀត ។ ខ្លែងទាំងនេះឧបមាយ៉ាងណា ពួកសត្វដែលអន្ទោលទៅក្នុងសង្សារ ក៏យ៉ាងនោះ សត្វពួកណាឃ្លាតចាកធម៌ដែលជាកុសល សត្វទាំងនោះរមែងធ្លាក់ទៅក្នុងអបាយមាននរកជាដើម ឯសត្វដែលធ្លាក់ទៅហើយយ៉ាងនេះដែលតាំងនៅក្នុងសម្បត្តិភព

*កើតនូវសេចក្តីលោភ ព្រោះការពេញចិត្តក្នុងភព ក្នុងកាមភព រូបភព និង អរូបភព ដោយជាប់ជំពាក់ក្នុងកាមសុខល្លិកានុយោគ ក្នុងសម្បត្តិភពនោះៗ ទើបត្រឡប់មកទៀត គឺត្រឡប់មកកាន់ទុក្ខ ដែលសន្មតថាភពនោះៗ ទៀត ដោយកម្មដែលធ្វើឲ្យដល់ភពនោះៗ ព្រោះមិនទាន់រួចផុតចាកភពទៅបាន ។ សត្វទាំងឡាយនេះក៏ដូច្នេះ ។ ឯខ្ញុំធ្វើកិច្ចមានបរិញ្ញាកិច្ចជាដើមហើយ សូម្បីកិច្ចទាំង ១៦ ខ្ញុំក៏ធ្វើស្រេចហើយ ឥឡូវនេះ មិនមានកិច្ចដែលត្រូវធ្វើទៀត ។*

*ព្រះនិព្វានជាដែន ដែលព្រះអរិយៈទាំងឡាយ រលាស់នូវសន្ធតធម៌បាន គួរជាទីត្រេកអរ គួរអភិរម្យ គួររីករាយ ខ្ញុំត្រេកអរហើយ អភិរម្យហើយ រីករាយហើយ ។ ដោយបទថា* **រតំ រម្មំ** *នោះ គប្បីជ្រាបអធិប្បាយថា បាន ដល់សេចក្តីសុខគឺផលសមាបត្តិ ដែលខ្ញុំសម្រេចហើយដោយងាយ គឺព្រះ និព្វានដែលជាសុខដោយចំណែកមួយ ដែលខ្ញុំតាមដល់ គឺចូលដល់ដោយ ងាយ ។ម្យ៉ាងទៀត បានដល់ ផលសុខ និងនិព្វានសុខដែលខ្ញុំតាមដល់ ដោយសុខដែលកើតអំពីវិបស្សនា និងសុខដែលកើតអំពីមគ្គដោយងាយ គឺ ដោយសុខាបដិបទា ។*

### *អដ្ឋកថា បក្ខត្ថេរគាថា ចប់*

## វិមលកោណ្ឌញ្ញត្ថេរគាថា

[ ៦៥ ] វិមលកោណ្ឌញ្ញៈ កើតអំពីស្រីមានដើមឈើជាឈ្មោះ ( អម្ពបាលី ) កើតដោយស្តេចដូចជាទង់ពណ៌ស ( ព្រះបាទពិម្ពិសារ ) លះបង់នូវទង់គឺមានះ កម្ចាត់បង់នូវទង់ធំគឺមានះ ដោយប្រាជ្ញាដូចជាទង់ ។

**វិមលកោណ្ឌញ្ញត្ថេរ ។**

## អដ្ឋកថា

## វិមលកោណ្ឌញ្ញត្ថេរគាថា

[ ៦៥ ] គាថារបស់ព្រះវិមលកោណ្ឌញ្ញត្ថេរ មានពាក្យផ្តើមថា **ទុមវ្ហយាយ ឧប្បន្នោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនោះក៏មានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាវិបស្សី ក្នុងកប្បទី ៩១ អំពីភទ្ទកប្បនេះកើតក្នុងត្រកូលសម្បូរដោយសម្បត្តិ ដល់នូវភាពជាអ្នកដឹងក្តីហើយ ។ ថ្ងៃមួយឃើញព្រះមានព្រះភាគព្រះនាមថាវិបស្សីដែលបរិស័ទធំចោមរោមហើយ ទ្រង់សម្តែងធម៌ មានចិត្តជ្រះថ្លា ហើយបូជាដោយផ្កាមាស ៤ ផ្កា ។ ដើម្បីចម្រើននូវបសាទសទ្ធារបស់កុលបុត្តនេះ ទើបព្រះមានព្រះភាគញុំាងឥទ្ធាភិសង្ខារឲ្យផ្កាបញ្ចេញពន្លឺពណ៌មាសគ្របដណ្តប់ទីនោះទាំងអស់ ។ កុលបុត្តនោះឃើញ

ពុទ្ធាភិសង្ខារនោះហើយ មានចិត្តជ្រះថ្លាពន់ពេក ថ្វាយបង្គំព្រះមានព្រះភាគ ហើយធ្វើពន្លឺនោះឲ្យជានិមិត្ត ហើយចូលកាន់ផ្ទះរបស់ខ្លួនមិនលះបីតិដែលមានព្រះពុទ្ធជាអារម្មណ៍ ធ្វើកាលកិរិយាដោយរោគខ្យល់ កើតក្នុងស្ថានសួគ៌ជាន់តុសិតហើយធ្វើកុសលដទៃទៀត អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយក្នុងពុទ្ធុប្បាទនេះ បដិសន្ធិក្នុងផ្ទៃរបស់នាងអម្ពបាលីអាស្រ័យព្រះបាទពិម្ពិសារ ។

បានឮដំណឹងថា នាងអម្ពបាលីមានរូបស្អាត មានបំណងចង់បាននាងមានមនុស្សពីរបីនាក់ជាប់តាម ក្លែងខ្លួនទៅកាន់នគរវេសាលី សម្រេចការនៅរួមជាមួយនាងមួយរាត្រី កាលនោះកុលបុត្តនោះ បដិសន្ធិក្នុងផ្ទៃរបស់នាង នាងអម្ពបាលីបានក្រាបទូលភាពដែលនាងមានគភ៌ដល់ព្រះបាទពិម្ពិសារ ។

ព្រះរាជាបង្ហាញខ្លួន ព្រះរាជទានទ្រព្យដែលគួរព្រះរាជទាន ហើយគេចចេញទៅ នាងអាស្រ័យការចាស់ជុំវិញនៃគភ៌ ប្រសូតបុត្តហើយ ។ ទារកនោះបានឈ្មោះថា វិមល ក្រោយមកក៏បានប្រាកដឈ្មោះថា វិមលកោណ្ឌញ្ញៈ ។ កុលបុត្តនោះចម្រើនវ័យហើយ ឃើញពុទ្ធានុភាពក្នុងកាលដែលព្រះមានព្រះភាគយាងទៅនគរវេសាលី មានចិត្តជ្រះថ្លា ទើបចេញបួស ធ្វើបុព្វកិច្ចផ្តើមចម្រើនវិបស្សនា សម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះមានព្រះភាគព្រះនាមវិបស្សីជាច្បងក្នុងលោកជានរាសភៈ
ទ្រង់គង់សម្តែងអមតបទដល់ពួកជន ។ ខ្ញុំស្តាប់ធម៌របស់ព្រះ
មានព្រះភាគអង្គនោះ ទ្រង់ជាធំជាងសត្វជើងពីរ ជាតាទិបុគ្គល

ហើយបានថ្វាយផ្កាជាវិការៈនៃមាស ៤ ទងចំពោះព្រះសម្ពុទ្ធ ។ ក្នុងកាលនោះ បរិស័ទមានចំនួនត្រឹមណា ដំបូលជាវិការៈនៃមាស ក៏មានចំនួនត្រឹមនោះ ពន្លឺដ៏ធំទូលាយ ក៏កើតប្រាកដឡើងព្រោះរស្មីព្រះពុទ្ធនិងរស្មីមាស ។ ខ្ញុំមានចិត្តខ្ពស់ឯកមានចិត្តរីករាយ មានសេចក្តីត្រេកអរកើតឡើង ខ្ញុំធ្វើអញ្ជលី ញ៉ាំងបីតិឲ្យកើតឡើងចំពោះពន្លឺទាំងនោះ នាំមកនូវសេចក្តីសុខក្នុងបច្ចុប្បន្ន ទើបថ្វាយបង្គំអារាធនាព្រះសម្ពុទ្ធ ទ្រង់មានវត្តល្អ ញ៉ាំងបាមោជ្ជឲ្យកើតហើយ ចូលទៅកាន់លំនៅរបស់ខ្លួន ។ លុះខ្ញុំចូលទៅកាន់លំនៅហើយ ក៏រឭកនូវព្រះពុទ្ធដ៏ប្រសើរ ខ្ញុំក៏បានទៅកើតក្នុងឋានតុសិត ដោយសេចក្តីជ្រះថ្លានោះឯង ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៤៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេច ១៦ ជាតិ ព្រះនាមនេមិសម្មតៈដូចគ្នា ជាស្តេចចក្រពត្តិមានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផល ដោយ

---

១-ក្នុងអបទានជាព្រះ សុវណ្ណបុប្ផិយត្ថេរ ។

អានដល់អរហត្តផល ទើបពោលគាថាថា

វិមលកោណ្ឌញ្ញៈ កើតអំពីស្រីមានដើមឈើជាឈ្មោះ ( អម្ព-
បាលី ) កើតដោយស្តេចដូចជាទង់ពណ៌ស ( ព្រះបាទពិម្ពិ
សារ ) លះបង់នូវទង់គឺមានះ កម្ចាត់បង់នូវទង់ធំគឺមានះដោយ
ប្រាជ្ញាដូចជាទង់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទុមវ្ហយាយ** បានដល់ ស្រីដែលគេហៅ **ទុម** គឺអម្ពៈ អធិប្បាយថា អំពីស្រីឈ្មោះអម្ពបាលី ។ បទថា **ទុមវ្ហយាយ** នេះ ជាសត្តមីវិភត្តិ ចុះក្នុងអាធារៈ ។ បទថា **ឧប្បន្នោ** សេចក្តីថា កើតហើយ និងចូលដល់ផ្ទៃរបស់នាងអម្ពបាលីនោះ ។

បទថា **ជាតោ បណ្ឌរកេតុនា** បានដល់ កើតព្រោះព្រះបាទពិម្ពិសារ ដែលគេសន្មតថា បណ្ឌរកេតុ ( អ្នកមានឆត្រពណ៌ស ) ជាហេតុ អធិប្បាយថា អាស្រ័យព្រះបាទពិម្ពិសារនោះកើតមក ។

ម្យ៉ាងទៀត បទថា **ឧប្បន្នោ** ជាបទសម្តែងដល់ការកើតឡើងគ្រាដំបូង ។ បន្ទាប់អំពីនោះ មានពាក្យថា **ជាតោ** សម្តែងដល់ការកើត ។ អធិប្បាយថា ចាប់តាំងអំពីប្រសូតហៅថាកើតហើយក្នុងលោក ។ ក្នុងគាថានេះ លោកនាំចេញនូវការលើកតម្កើងខ្លួន ដោយបទថា **ទុមវ្ហយាយ ឧប្បន្នោ** និងសម្តែងថា សូម្បីបុត្តរបស់ស្រីដែលមានប្តីច្រើននាក់ ( ស្រីនគរសោភិនី ) ក៏សម្រេចគុណវិសេសបាន ។ លោកនាំចេញនូវការសន្តត់សន្តិនដោយប្រាប់ថា បិតាជាអ្នកមានកេរ្តិ៍ឈ្មោះដោយពាក្យនេះថា **ជាតោ បណ្ឌរកេតុនា** ។

*បទថា* **កោតុហា** *បានដល់ លះបង់នូវមានះ អធិប្បាយថា មានះ ឈ្មោះថា* **កោតុ** *ដោយអត្ថថា ដូចជាទង់ ព្រោះមានការប្រកាន់ខ្លួន គឺលើកតម្កើងខ្លួនជាលក្ខណៈ ពិតហើយ មានះ លោកពោលថា មានបំណងនឹងលើកខ្លួនឲ្យខ្ពស់ជាអាការៈប្រាកដ ។ បទថា* **កោតុបាយេវ** *បានដល់ ដោយបញ្ញានោះឯង អធិប្បាយថា បញ្ញា ឈ្មោះថាជាទង់របស់ព្រះអរិយៈទាំងឡាយ ព្រោះអត្ថថា ខ្ពស់ក្រៃលែងជាងធម៌ដែលមិនមានទោស និងព្រោះអត្ថថា ជាប្រធានក្នុងការញាំញីសេនាមារ ដោយហេតុនោះទើបបណ្ឌិតពោលថា* **ធម្មោ ហិ ឥសិនំ ធជោ** *សេចក្ដីថា ដ្បិតព្រះធម៌ជាទង់ជ័យនៃពួកឥសី ដូច្នេះ ។ បទថា* **មហាកោតុំ បធំសយិ** *សេចក្ដីថា កិលេសធម៌ទាំងឡាយ ឈ្មោះថា ធំ ព្រោះមានអារម្មណ៍ច្រើន និងឈ្មោះថា មានមានះច្រើនប្រការ មានមានះថា អញប្រសើរជាងគេ និងមានះព្រោះជាតិ ជាដើម និងកិលេសធម៌ទាំងនោះ ឈ្មោះថា* **មហាកោតុ** *ដោយអត្ថថា ដូចជាទង់ ព្រោះអត្ថថា លើកឡើងនូវមានះនោះ បានដល់ មារដ៏លាមក ។ លោកបានគ្របសង្កត់មារនោះធ្វើឲ្យអស់ព្យសន៍ ដោយការកម្ចាត់ពលនៃមារ និងឈានកន្លងវិស័យនៃមារបាន ព្រះថេរៈកាលនឹងសម្ដែងខ្លួនដូចអ្នកដទៃព្យាករអរហត្តផល ដោយការអាងអរហត្តផលថា កម្ចាត់បង់នូវទង់ធំគឺមានះដោយប្រាជ្ញាដូចជាទង់ ដូច្នេះ ។*

*អដ្ឋកថា វិមលកោណ្ឌញ្ញត្ថេរគាថា ចប់*

## ឧក្ខេបកវច្ឆត្ថេរគាថា

[ ៦៦ ] ពុទ្ធវចនៈដែលបុគ្គលរៀនក្នុងសំណាក់នៃឧក្ខេបកវច្ឆត្ថេរ ព្រះថេរៈនោះរមែងសម្ដែងនូវពុទ្ធវចនៈនោះ ដល់គ្រហស្ថទាំងឡាយបាន អស់ឆ្នាំជាច្រើន លោកជាអ្នកមានសេចក្ដីរីករាយដ៏លើសលុប អង្គុយនៅដ៏ស្ងប់ស្ងៀម ។

ឧក្ខេបកវច្ឆត្ថេរ ។

## អដ្ឋកថា

## ឧក្ខេបកវច្ឆត្ថេរគាថា

[ ៦៦ ] គាថារបស់ព្រះឧក្ខេបកវច្ឆត្ថេរ មានពាក្យផ្ដើមថា **ឧក្ខេប-កវច្ឆស្ស** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យ ដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាសិទ្ធត្ថ ក្នុងកប្បទី ៩៤ អំពីភទ្ទកប្បនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ឲ្យសសរដល់ឧបាសកធ្វើសាលាថ្វាយព្រះសាស្ដាដែលខ្វះសសរមួយដើម បានធ្វើកិច្ចរបស់អ្នករួមកិច្ចការ ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក ព្យាយាមធ្វើកុសលរឿយៗ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនរបស់ព្រាហ្មណ៍ម្នាក់ក្នុងនគរសាវត្ថីមាននាមតាមគោត្តថាវច្ឆៈ ។

កុលបុត្តនោះ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា បានចំពោះនូវសទ្ធា បព្វជ្ជាហើយ ក្នុងទីជិតស្រុកដែនកោសល រៀនធម៌ក្នុងសម្នាក់របស់ភិក្ខុទាំងឡាយដែលធ្វើដំណើរច្នេងកាត់ ។ តែលោកកំណត់មិនបានថា នេះជាវិន័យ នេះជាព្រះសូត្រ នេះជាព្រះអភិធម្ម ថ្ងៃមួយ សាកសួរព្រះធម្មសេនាបតីទើបកំណត់ពុទ្ធវចនៈទាំងអស់ តាមវគ្គតាមឃ្លាសូម្បីក្នុងកាលមុននៃការសង្គាយ-នាព្រះធម៌ ទើបកំណត់វត្ថុគ្រប់យ៉ាងតាមដែល ( ព្រះធម្មសេនាបតី ) កំណត់ទុក ការកំណត់ឈ្មោះហៅថា បិដកជាដើម ក៏មានក្នុងបរិយត្តិសទ្ធម្ម មុនការសង្គាយនាព្រះធម៌ព្រោះមានការហៅឈ្មោះភិក្ខុទាំងឡាយថា វិន័យធរជាដើម លោកសាកសួរព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក កំណត់រូបធម៌និងអរូបធម៌ដែលព្រះមានព្រះភាគ ត្រាស់ហើយ ក្នុងព្រះត្រៃបិដកនោះ ផ្តើមចម្រើនវិបស្សនា សម្រេចអរហត្ត ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ពួកគណៈធំរបស់ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ពួកជនទាំងនោះ បានដល់នូវព្រះពុទ្ធជាទីពឹង ហើយជឿព្រះតថាគត ។ ពួកជនទាំងពួងជួបជុំប្រឹក្សាគ្នា ហើយធ្វើរោងថ្វាយព្រះសាស្តា តែនៅខ្វះសសរ ១ ក៏នាំគ្នាជ្រើសរកក្នុងព្រៃធំ ។ កាលនោះ ខ្ញុំឃើញជនទាំងនោះក្នុងព្រៃហើយ ចូលទៅជិតជនទាំងនោះក៏ផ្គងអញ្ជលីសាកសួរពួកនោះ ។ ពួកឧបាសក អ្នកមានសីលទាំងនោះដែលខ្ញុំសួរហើយ ក៏ប្រាប់ថា ពួកយើងប្រាថ្នានឹងធ្វើ

រោងតែនៅខ្វះសសរ ១ ។ ខ្ញុំតបថា អ្នកទាំងឡាយចូរឲ្យសសរ ១ ដែលខ្វះមកខ្ញុំចុះ ខ្ញុំនឹងថ្វាយចំពោះព្រះសាស្តាខ្ញុំនឹងនាំសសរមកសូមពួកឧបាសកទាំងនោះកុំមានសេចក្តីខ្វល់ខ្វាយឡើយ។ ពួកឧបាសកទាំងនោះ មានចិត្តជ្រះថ្លាត្រេកអរ ហើយនាំសសររបស់ខ្ញុំទៅ លុះត្រឡប់អំពីទីនោះវិញ ក៏មកកាន់ផ្ទះរៀងខ្លួន ។ ក្នុងកាលនោះ កាលពួកគណៈ ដែលទើបនឹងទៅមិនទាន់យូរប៉ុន្មាន ខ្ញុំបានថ្វាយសសរ ខ្ញុំមានចិត្តត្រេកអរហើយ បានលើកសសរជាដំបូង ។ ដោយចិត្តជ្រះថ្លានោះ ខ្ញុំចូលទៅកាន់វិមានមានកម្ពស់ ៧ ជាន់ដែលផុសឡើងសម្រាប់ខ្ញុំ ។ ក្នុងកប្បទី ៥៥ ខ្ញុំកើតជាស្តេចឈ្មោះយសោធរៈ កាលបើស្គរដែលគេកំពុងប្រគំ ខ្ញុំក៏ឲ្យគេបម្រើសព្វៗកាល ។ លំនៅរបស់ខ្ញុំក្នុងទីនោះមានកម្ពស់ ៧ ជាន់ ប្រកបដោយផ្ទះមានកំពូលដ៏ប្រសើរ មានសសរតែមួយ ជាទីរីករាយនៃចិត្ត ។ ក្នុងកប្បទី ២១ ខ្ញុំកើតជាក្សត្រិយ៍ឈ្មោះឧទេនៈ លំនៅរបស់ខ្ញុំក្នុងទីនោះមានជាន់ ៧ ដែលគេតាក់តែងល្អហើយ ។ ខ្ញុំកើតក្នុងកំណើតណាៗ ទោះជាទេវតាឬជាមនុស្ស ខ្ញុំតែងទទួលសេចក្តីសុខគ្រប់ប្រការ នេះជាផលនៃសសរមួយ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយសសរក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសសរមួយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨

និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសា-
សនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈ កាលសម្រេចអរហត្តហើយ តាំងមាំក្នុងការមិនខ្ជិលច្រអូស ព្រោះសម្រេចកិច្ចដែលខ្លួនធ្វើហើយ ដើម្បីសេចក្តីអនុគ្រោះគ្រហស្ថ និងបព្វជិតទាំងឡាយដែលចូលទៅកាន់សម្នាក់របស់ខ្លួន ពិចារណាពុទ្ធវចនៈ គឺព្រះត្រៃបិដក ហើយសម្តែងធម៌ ។ ក្នុងថ្ងៃមួយ កំពុងសម្តែងធម៌ គ្រានឹងសម្តែងប្រៀបធៀបខ្លួនដូចគ្នានឹងអ្នកដទៃ បានពោលគាថាថា

ពុទ្ធវចនៈដែលបុគ្គលរៀនក្នុងសំណាក់នៃឧក្ខេបកជវច្ឆត្ថេរ ព្រះ
ថេរៈនោះ រមែងសម្តែងនូវពុទ្ធវចនៈនោះ ដល់គ្រហស្ថទាំង-
ឡាយបាន អស់ឆ្នាំជាច្រើន លោកជាអ្នកមានសេចក្តីរីករាយ
ដ៏លើសលុប អន្តយនៅដ៏ស្ងប់ស្ងៀម ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧក្ខេបកជវច្ឆស្ស** ស្មើគ្នានឹង **កតឧក្ខេ-វច្ឆស្ស** ប្រែថា ព្រះវច្ឆៈជាអ្នកធ្វើនូវគំនរ អធិប្បាយថា ដែលភិក្ខុឈ្មោះវច្ឆៈ កំណត់ទុកជាចំណែកៗ ជាព្រះវិន័យ ជាព្រះសូត្រ ជាព្រះអភិធម្ម តាមពួកព្រះវិន័យ ពួកព្រះសូត្រ ពួកព្រះអភិធម្ម ដែលរៀនមកអំពីសម្នាក់ភិក្ខុ ជាចំណែកៗ ហើយចងក្រងទុកក្នុងពួកនោះៗ តាមដែលទ្រទ្រង់ចាំ ។ បទថា **ឧក្ខេបកជវច្ឆស្ស** នេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ ។

បទថា **សង្កលិតំ ពហូហិ វស្សេហិ** សេចក្តីថា តាំងទុកក្នុងហទយៈ

---

១-ក្នុងអបទានជា ឯកត្ថម្ភិកត្ថេរ ។

ដោយអំណាចនៃការប្រមូលមកជាច្រើនឆ្នាំ ។ បាឋៈថា **សន្ធុលិតំ** ដូច្នេះក៏មាន បានដល់ ទន្ទេញរហូតរត់មាត់ ព្រោះថា ជាប់តជាមួយគ្នាទៅ ធ្វើឲ្យដូចជាស័ន្ធិដែលគេខាត់ហើយ ។ ត្រូវបន្ថែមពាក្យថា **យំ ពុទ្ធវចនំ** ដែលខ្វះចូលមក ។

បទថា **តំ** សេចក្តីថា ពោលដល់ព្រះបរិយត្តិធម៌នោះ ។ លោកពោលបទថា **គហដ្ឋានំ** ព្រោះគ្រហស្ថទាំងនោះមានចំនួនច្រើនជាង ( ភិក្ខុ ) ។ បទថា **សុនិសិន្នោ** សេចក្តីថា អង្គុយស្ងប់មិនកម្រើកក្នុងធម៌នោះ អធិប្បាយថា មិនប្រាថ្នាលាភនិងសក្ការៈជាដើមតាំងនៅក្នុងមាតិកាធម៌ គឺវិមុត្តាយតនៈតែម្យ៉ាងប៉ុណ្ណោះ ហើយសម្តែងធម៌ ។

ដោយហេតុនោះ ទើបលោកពោលថា **ឧឡារចាមោជ្ជោ** ដែលមានសេចក្តីថា ជាអ្នកមានបាមោជ្ជដ៏ឧឡារដែលកើតហើយដោយអំណាចនៃសេចក្តីសុខក្នុងផលសមាបត្តិនិងដោយអំណាចនៃសុខក្នុងធម៌ សមដូចពាក្យដែលលោកពោលទុក ( ក្នុងទសុត្តរសូត្រ ) ថា

> ម្នាលអាវុសោទាំងឡាយ ភិក្ខុបានសូត្រធម៌ដោយពិស្តារតាមដែលបានស្តាប់មក ដែលបានរៀនមកយ៉ាងណាៗ ភិក្ខុនោះជាអ្នកបានដឹងច្បាស់នូវអត្ថផង ដឹងច្បាស់នូវធម៌ផងក្នុងធម៌នោះយ៉ាងនោះៗ កាលលោកបានដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ហើយ សេចក្តីត្រេកអរទន់កើតឡើង ដូច្នេះ ។

**អដ្ឋកថា ឧក្ខេបកដវគ្គោ ចប់**

## មេឃិយត្ថេរគាថា

[ ៦៧ ] ព្រះសម្ពុទ្ធ ជាមហាវីរបុរស ព្រះអង្គដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់ប្រៀនប្រដៅហើយ ខ្ញុំបានស្តាប់ធម៌របស់ព្រះអង្គជាអ្នកត្រេកអរនៅក្នុងសំណាក់ ( ព្រះអង្គ ) ត្រៃវិជ្ជាខ្ញុំបានដល់ហើយ ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ។

មេឃិយត្ថេរ ។

## អដ្ឋកថា

## មេឃិយត្ថេរគាថា

[ ៦៧ ] គាថារបស់ព្រះមេឃិយត្ថេរ មានពាក្យផ្តើមថា **អនុសាសិ មហាវីរោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏មានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សាងព្រោះនូវពូជ គឺកុសលទុកក្នុងភពនោះៗ ។ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាវិបស្សីក្នុងកប្បទី ៩១ រាប់ពីភទ្ទកប្បនេះ កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូលដល់នូវភាពជាអ្នកដឹងក្តីហើយ ។ សម័យនោះ ព្រះមានព្រះភាគព្រះនាមថាវិបស្សី ទ្រង់ដល់នូវទីបំផុតនៃពុទ្ធកិច្ចហើយ ទ្រង់ដាក់នូវអាយុសង្ខារ ផែនដីក៏ញាប់ញ័រជាដើម ព្រោះទ្រង់ដាក់អាយុសង្ខារនោះ មហាជនដល់នូវភាពតក់ស្លុតខ្លាចហើយ ។

លំដាប់នោះ វេស្សវ័ណមហារាជ ទ្រង់ដឹងនូវហេតុការណ៍នោះ យ៉ាង

ប្រាកដប្រជា ទើបទ្រង់ញុំាងមហាជនឲ្យឈប់តក់ស្លុត ។ មហាជនស្ដាប់ហេតុការណ៍នោះ បានដល់នូវសេចក្ដីសង្វេគ ។ កុលបុត្តនេះស្ដាប់ពុទ្ធានុភាពក្នុងទីនោះហើយ កើតនូវសេចក្ដីគោរពរាប់អានយ៉ាងច្រើនក្នុងព្រះសាស្ដាសោយនូវបីតិនិងសោមនស្សដ៏ឧឡារ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលសក្យៈក្នុងនគរកបិលពស្ដុមាននាមថាមេឃិយៈ ។

មេឃិយៈនោះ ចម្រើនវ័យហើយ បួសក្នុងសម្នាក់របស់ព្រះបរមសាស្ដាជាអ្នកឧបដ្ឋាកព្រះសម្ពុទ្ធ កាលព្រះមានព្រះភាគគង់នៅក្នុងជាលិកាវ័ន ឃើញព្រៃស្វាយគួរជាទីរីករាយ ត្រង់ឆ្នេរស្ទឹងកិមិកាលា បំណងនឹងនៅក្នុងព្រៃស្វាយនោះ ត្រូវព្រះមានព្រះភាគទ្រង់ឃាត់អស់វារៈ ២ ដង ហើយទ្រង់ក៏អនុញ្ញាតក្នុងគ្រាទី ៣ ទើបទៅកាន់ព្រៃស្វាយនោះ ត្រូវសត្វល្អិត គឺមិច្ឆាវិតក្កបោមរោមខាំ មិនបានចិត្តជាសមាធិ ទៅកាន់សម្នាក់របស់ព្រះសាស្ដា ក្រាបទូលដំណើរនោះ ។

លំដាប់នោះ ព្រះបរមសាស្ដាទ្រង់បានប្រទានឱវាទ ដល់ព្រះថេរៈដោយន័យ ( ក្នុងអង្គុត្តរនិកាយនវកនិបាត ) ជាដើមថា ម្នាលមេឃិយៈ ធម៌ទាំងឡាយ ៥ យ៉ាងតែងប្រព្រឹត្តទៅដើម្បីចេតោវិមុត្តិដែលពុំទាន់ចាស់ក្លាឲ្យចាស់ក្លាឡើងបាន ដូច្នេះ ។ លោកតាំងនៅក្នុងឱវាទនោះហើយ ចម្រើនវិបស្សនាសម្រេចអរហត្តហើយ សមដូចគាថាព័ន្ធដែលលោកទុកក្នុងអបទានថា

ព្រះវិបស្សីសម្ពុទ្ធ ជាកំពូលក្នុងលោក ទ្រង់ដាក់អាយុសង្ខារ

ក្នុងកាលណា ផែនដីនិងសមុទ្រ ក៏កម្រើកញាប់ញ័រក្នុងកាលនោះ ។ សូម្បីលំនៅរបស់ខ្ញុំដ៏វិចិត្រស្អាតទូលាយប្រាកដដូចធ្លាក់ចុះឃ្លាតចេញ កម្រើកញាប់ញ័រក្នុងកាលជាទីអស់ទៅនៃព្រះជន្មាយុរបស់ព្រះពុទ្ធ ។ កាលដែលលំនៅនៃខ្ញុំញាប់ញ័រហើយ ខ្ញុំក៏មានសេចក្ដីតក់ស្លុតកើតឡើងថា ពន្លឺដ៏ធំបានកើតឡើងហើយដើម្បីអ្វីហ្ន៎ ឬក៏ព្រះបាទវេស្សវ័ណ ស្ដេចមកក្នុងទីនេះ ញុំាងមហាជនឲ្យរលត់ទុក្ខ ឱមែន ភ័យដែលកើតដល់ជីវិតមិនមានទេខ្លួនអ្នកឯងត្រូវតែមានសេចក្ដីគោរព ត្រូវមានចិត្តនឹងតែមួយ ឱព្រះពុទ្ធ ឱព្រះធម៌ ឱសម្បទារបស់ព្រះសាស្ដានៃយើង ព្រោះកាលដែលព្រះអង្គត្រាស់ឡើង ( ក្នុងលោក ) មហាប្រឹថពី ក៏កម្រើកញាប់ញ័រដែរ ។ ខ្ញុំសរសើរនូវពុទ្ធានុភាព ( យ៉ាងនេះ ) ក៏បានរីករាយក្នុងឋានសួគ៌អស់មួយកប្ប ថែមទាំងខ្ញុំធ្វើកុសលកម្ម ក្នុងកប្បដ៏សេសទាំងឡាយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាននូវសេចក្ដីសម្គាល់ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃសេចក្ដីសម្គាល់ក្នុងព្រះពុទ្ធ ។ ក្នុងកប្បទី ១៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិមានព្រះនាម សមិតរាជទ្រង់មានព្យាយាមមានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំង

សាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈសម្រេចអរហត្តហើយ បានទទួលឱកាសចំពោះព្រះភក្ត្រព្រះបរមសាស្ដា កាលនឹងព្យាករអរហត្តផលថា ខ្ញុំសម្រេចអរហត្តហើយ ទើបពោលគាថា ថា

ព្រះសម្ពុទ្ធ ជាមហាវីរបុរស ព្រះអង្គដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់ប្រៀនប្រដៅហើយ ខ្ញុំបានស្ដាប់ធម៌របស់ព្រះអង្គជាអ្នកត្រេកអរនៅក្នុងសំណាក់ ( ព្រះអង្គ ) ត្រៃវិជ្ជាខ្ញុំបានដល់ហើយ ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនុសាសិ** សេចក្ដីថា ព្រះមានព្រះភាគទ្រង់ទូន្មាន គឺបានប្រទានអនុសាសនី ដោយពាក្យជាដើមថា ម្នាលមេឃិយៈ ធម៌ទាំងឡាយ ៥ យ៉ាង តែងប្រព្រឹត្តទៅ ដើម្បីចេតោវិមុត្តិ ដែលពុំទាន់ចាស់ក្លា ឲ្យចាស់ក្លាឡើងបាន ដូច្នេះ ។

បទថា **មហាវីរោ** បានដល់ ជាអ្នកមានសេចក្ដីប្រឹងប្រែងច្រើន អធិប្បាយថា ជាអ្នកមានសេចក្ដីព្យាយាមច្រើនដោយអង្គធម៌ ដែលជាទីតាំងនៃសេចក្ដីព្យាយាមដែលប្រកបដោយអង្គ ៤ ដែលជាគ្រឿងសាងនូវវីរិយបារមីនិងដោយការដល់ព្រមនៃសម្មប្បធាន ៤ យ៉ាងដែលមិនទូទៅដល់សាវកដទៃ ។

បទថា **សព្វធម្មាន បារគូ** សេចក្ដីថា ព្រះមានព្រះភាគ ឈ្មោះថា ជាអ្នកដល់នូវត្រើយនៃធម៌ទាំងពួង ព្រោះទ្រង់ដល់ គឺសម្រេចដល់នូវត្រើយ គឺ

---

១-ក្នុងអបទានជាព្រះ ពុទ្ធសញ្ញកត្ថេរ ។

ទីបំផុតនៃញេយ្យធម៌ទាំងពួងដោយការសម្រេចព្រះញាណ អធិប្បាយថា ជាព្រះសព្វញ្ញូ ។ ម្យ៉ាងទៀត ឈ្មោះថា **សព្វធម្មាន បារគូ** ព្រោះទ្រង់ដល់គឺសម្រេចដល់ព្រះនិព្វានដែលជាត្រើយនៃសង្ខតធម៌ទាំងឡាយទាំងពួងដោយសយម្ភូញាណ ។

បទថា **តស្សាហំ ធម្មំ សុត្វាន** សេចក្តីថា ខ្ញុំស្តាប់សច្ចធម៌ ៤ នោះដែលទ្រង់លើកឡើងសម្តែងឯងរបស់ព្រះមានព្រះភាគដ៏ជាសម្ពុទ្ធអង្គនោះ ។

បទថា **វិហាសឹ សន្តិកេ** សេចក្តីថា ខ្ញុំត្រូវមិច្ឆាវិតក្កបៀតបៀនហើយក្នុងព្រៃស្វាយត្រឡប់ទៅកាន់ចាលិកាវិហារ ស្នាក់នៅក្នុងទីជិតព្រះបរមសាស្តានោះឯង ។ បទថា **សតោ** ប្រែថា មានសតិ អធិប្បាយថា មិនប្រមាទដោយការចម្រើនសមថនិងវិបស្សនា ។

បទថា **អហំ** នេះ គប្បីផ្លាស់ជា **មយា** បន្ថែមចូលក្នុងបទថា **វិជ្ជា-អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ** ប្រែថា ត្រៃវិជ្ជាខ្ញុំបានដល់ហើយ ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ដូច្នេះ ដូចបទថា **មំ** ដែលត្រូវបន្ថែមចូលទៅក្នុងបទថា **អនុសាសិ** ( បានប្រៀនប្រដៅនេះ ) នេះ ។ ព្រះថេរៈ ប្រកាសការសម្រេចវិជ្ជា ៣ តាមដែលពោលហើយ ដោយពាក្យថា ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយដោយសម្តែងថា លោកបដិបត្តិត្រង់តាមឱវាទរបស់ព្រះសាស្តាដោយបរិយាយដទៃ អធិប្បាយថា ការបំពេញឲ្យបរិបូណ៌ក្នុងកងសីលជាដើមនោះឯង ខ្ញុំធ្វើហើយតាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ។

**អដ្ឋកថា មេឃិយត្ថេរគាថា ចប់**

## ឯកធម្មសវនិយត្ថេរគាថា

[ ៦៨ ] កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានដកចោលហើយ ជាតិសង្សារក៏អស់ហើយ ភពថ្មីទៀតមិនមានក្នុងកាលឥឡូវនេះទេ ។

ឯកធម្មសវនិយត្ថេរ ។

## អដ្ឋកថា

## ឯកធម្មសវនិយត្ថេរគាថា

[ ៦៨ ] គាថារបស់ព្រះឯកធម្មសវនិយត្ថេរ មានពាក្យផ្តើមថា **កិលេសា ឈាបិតា មយ្ហំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈ កុលបុត្តនេះកើតជារុក្ខទេវតា ឃើញភិក្ខុ ២-៣ រូប វង្វេងផ្លូវត្រាច់ទៅក្នុងព្រៃធំកាលនឹងអនុគ្រោះ ទើបចុះអំពីកពរបស់ខ្លួន លួងលោមភិក្ខុទាំងនោះឲ្យឆាន់ហើយ នាំទៅកាន់ទីដែលលោកប្រាថ្នា ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ កាលព្រះមានព្រះភាគព្រះនាមថាកស្សបៈកើតឡើងក្នុងលោក បំពេញពុទ្ធកិច្ចស្រេចហើយ បរិនិព្វានកើតជាស្តេចក្រុងពារាណសីព្រះនាមថា កិកិ ក្នុងកាលនោះ ។

កាលព្រះរាជាសោយទិវង្គតហើយ ព្រះរាជឱរសរបស់ព្រះអង្គ ព្រះនាម

ថា បុថុវិន្ទុរាជបានសោយរាជ្យតមក ។ ព្រះរាជឱរសរបស់ព្រះបាទបុថុវិន្ទុរាជ ព្រះនាមថា សុយាម ព្រះរាជឱរសរបស់ព្រះបាទសុយាម ព្រះនាមថា កិកិ-ព្រហ្មទត្ត សោយរាជ្យបន្តគ្នាមក ។ កាលព្រះសាសនាអន្តរធានហើយ មិនបានស្តាប់ព្រះធម្មទេសនា ទើបត្រាស់ឲ្យប្រកាសថា អ្នកណាសម្តែងធម៌បាន យើងនឹងឲ្យទ្រព្យមួយសែនកហាបណៈដល់អ្នកនោះ កាលរកអ្នកសម្តែងធម៌មិនបានសូម្បីត្រឹមតែម្នាក់ ទើបទ្រង់ព្រះតម្រិះថា ក្នុងវេជ្ជសម័យនៃព្រះអយ្យកោជាដើមរបស់អញ ធម៌នៅប្រព្រឹត្តទៅនៅឡើយ អ្នកសម្តែងធម៌ក៏រកបានងាយ តែក្នុងកាលឥឡូវនេះ បុគ្គលដែលពោលគាថាសូម្បីត្រឹម ៤ បាទ ក៏រកបានលំបាក អញនឹងចេញបួសទាន់ធម្មសញ្ញាមិនទាន់សាបសូន្យ ។

សក្កទេវរាជទ្រង់ចុះមកហើយសម្តែងធម៌ដោយគាថាថា **អនិច្ចា វត សង្ខារា** សង្ខារទាំងឡាយមិនទៀង ដូច្នេះហើយ ឲ្យព្រះបាទកិកិព្រហ្មទត្តលះរាជបល្ល័ង្កបែរមុខទៅកាន់ហិមវន្តប្បទេសហើយទ្រង់យានត្រឡប់ ។ ព្រះបាទកិកិព្រហ្មទត្តទ្រង់យានត្រឡប់ហើយទ្រង់បំពេញបុណ្យ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះកើតក្នុងត្រកូលសេដ្ឋី ក្នុងសេតព្យនគរ ចម្រើនវ័យហើយ កាលព្រះមានព្រះភាគគង់នៅក្នុងសីសបាវ័ន ( ព្រៃធ្នង់ ) ក្នុងសេតព្យនគរ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយអង្គុយនាចំណែកម្ខាង ។

ព្រះសាស្តាទ្រង់ប្រមើលមើលអជ្ឈាស្រ័យរបស់កុលបុត្តនោះហើយទ្រង់សម្តែងធម៌ដោយគាថានេះថា **អនិច្ចា វត សង្ខារា** សង្ខារទាំងឡាយមិន

ទៀងហ្ន៎ ដូច្នេះ កាលអនិច្ចសញ្ញាប្រាកដកុលបុត្តនោះក៏បាននូវសេចក្ដីសង្វេគ ព្រោះមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងភពនោះៗ បួសហើយផ្ដើមពិចារណាធម៌ដាក់ចិត្តក្នុងទុក្ខសញ្ញានិងអនត្តសញ្ញា ខ្វល់ខ្វាយវិបស្សនា សម្រេចអរហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ពួកសាវ័ករបស់ព្រះពុទ្ធ ព្រះនាមបទុមុត្តរៈជាអ្នកត្រាច់ទៅក្នុងព្រៃ វង្វេងគ្នាក្នុងព្រៃធំដូចជាមនុស្សខ្វាក់ ។ ពួកសាវ័កទាំងនោះជាបុត្តរបស់ព្រះមុនីនោះវង្វេងគ្នាក្នុងព្រៃធំ ក៏រឭកនូវព្រះសម្ពុទ្ធបទុមុត្តរជានាយក ។ ខ្ញុំក៏ចុះចាកលំនៅ ដើរមកក្នុងសម្នាក់របស់ភិក្ខុហើយប្រាប់ផ្លូវផង ប្រគេនភោជនផង ដល់សាវ័កទាំងនោះ ។ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ទ្រង់ជាច្បងក្នុងលោក ជានរាសភៈ ខ្ញុំមានអាយុ ៧ ឆ្នាំអំពីកំណើត ក៏បានដល់នូវអរហត្ត ដោយកុសលកម្មនោះ ។ ក្នុងកប្បទី ៥០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ១២ ជាតិ ព្រះនាមសចក្ខុរាជដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រោះហេតុដែលព្រះថេរៈសម្រេចកិច្ច ដោយការស្ដាប់ធម៌ តែម្ដងប៉ុណ្ណោះ

---

១-ក្នុងអបទានជាព្រះ មគ្គសញ្ញកត្ថេរ ។

ទើបបាននាមថា ឯកធម្មសវនីយត្ថេរដូច្នេះឯង ។ លោកបានជាព្រះអរហន្ត ហើយ កាលនឹងព្យាករអរហត្តផលបានពោលគាថាថា

កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំបានដក ចោលហើយ ជាតិសង្សារក៏អស់ហើយ ភពថ្មីទៀតមិនមាន ក្នុងកាលឥឡូវនេះទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កិលេសា** សេចក្ដីថា អកុសលធម៌ ឈ្មោះ ថា **កិលេស** ព្រោះកើតហើយក្នុងសន្តានណា រមែងញ៉ាំងសន្តាននោះឲ្យសៅ ហ្មង ឬបៀតបៀនចូលទៅធ្វើឲ្យក្ដៅក្រហាយ បានដល់ កិលេសមានរាគៈ ជាដើម ។

បទថា **ឈាបិតា** សេចក្ដីថា កិលេសទាំងឡាយដែលខ្ញុំដុតហើយទាំង ឫសដោយភ្លើង គឺអរិយមគ្គញាណ ដូចគុម្ពឈើជាដើមត្រូវដុតដោយអសនី- បាត ( រន្ទះ ) ។

បទថា **មយ្ហំ** ស្មើគ្នានឹង **មយា** ( ដែលខ្ញុំ ) ឬក្នុងសន្តានរបស់ខ្ញុំ ។

បទថា **ភវា សព្វេ សមូហតា** សេចក្ដីថា ភពទាំងពួង មានកាមភព និងកម្មភពជាដើម ឈ្មោះថា ដែលខ្ញុំដកឡើងហើយ ព្រោះកិលេសទាំងឡាយ ដែលខ្ញុំដុតហើយ ព្រោះកាលមានកិលេសវដ្ដៈទើបមានកម្មវដ្ដៈ ព្រោះហេតុ ដែលដកកម្មភពបានហើយនោះឯង សូម្បីឧបបត្តិភព ក៏ឈ្មោះថាដកឡើង ហើយដែរ ព្រោះឲ្យដល់នូវការមិនកើតឡើងទៀតជាធម្មតា ។

បទថា **វិក្ខីណោ ជាតិសំសារោ** សេចក្ដីថា សង្សារ មានជាតិជាដើម

ដែលមានលក្ខណៈដែលលោកពោលហើយថា

លំដាប់នៃខន្ធ ធាតុ និងអាយតនៈ នៅប្រព្រឹត្តទៅមិនដាច់ខ្សែ លោក ហៅថា សង្សារ ដូច្នេះ ។

អស់ទៅហើយដោយមិនមានសេសសល់ ព្រោះដូច្នោះ ឥឡូវនេះ ទើប ភពថ្មីមិនមាន ។ គប្បីវិលត្រឡប់មកពោលថា ព្រោះហេតុដែលភពថ្មី មិន មានតទៅ ដូច្នោះ ទើបសង្សារ គឺជាតិអស់ទៅ និងភពថ្មីមិនមាន ព្រោះ ភពទាំងពួងត្រូវដកឡើងហើយ ដូច្នេះ ។ មយ៉ាងទៀត ប្រកបសេចក្តីថាសង្សារ គឺជាតិអស់ទៅហើយ ព្រោះហេតុនោះឯង ក្នុងឥឡូវនេះទើបភពថ្មីមិនមាន ។

**អដ្ឋកថា ឯកធម្មសវនិយត្ថេរគាថា ចប់**

## ឯកុទានិយត្ថេរគាថា

[ ៦៩ ] សេចក្តីសោក រមែងមិនមានដល់អ្នកប្រាជ្ញ មានចិត្តដ៏ខ្ពង់ខ្ពស់ ជាអ្នកមិនប្រមាទ សិក្សាក្នុងធម៌ជាគន្លងនៃការបេះដឹង មានតាទិគុណ ជាអ្នកស្ងប់រម្ងាប់ មានសតិគ្រប់កាល ។

ឯកុទានិយត្ថេរ ។

## អដ្ឋកថា

## ឯកុទានិយត្ថេរគាថា

[ ៦៩ ] គាថារបស់ព្រះឯកុទានិយត្ថេរ មានពាក្យផ្តើមថា **អធិចេតសោ អប្បមជ្ជតោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះបានធ្វើបុញ្ញាធិការទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាអត្ថទស្សី កើតជាយក្ខសេនាបតី កាលព្រះសាស្តាទ្រង់បរិនិព្វានហើយ បានដល់នូវសេចក្តីសោកបរិទេវនាការថា អញមិនមានលាភហ្ន៎ អញរកឱកាសបានដោយលំបាកហ្ន៎ ព្រោះក្នុងកាលដែលព្រះសាស្តាទ្រង់គង់ព្រះជន្មនៅឡើយ អាត្មាអញមិនបានធ្វើបុណ្យមានទានជាដើមឡើយ ។

គ្រានោះ សាវ័ករបស់ព្រះសាស្តា ឈ្មោះថា សាគរ បន្ទោបង់សេចក្តីសោកនោះ ណែនាំឲ្យបូជាព្រះស្តូបរបស់ព្រះសាស្តា ។ យក្ខនោះបូជាព្រះ

ស្តូបអស់ ៥ ឆ្នាំ ចុតិអំពីអត្តភាពនោះហើយ អន្ទោលទៅក្នុងទេវតានិង មនុស្សទាំងឡាយនោះឯង ដោយបុណ្យនោះ ក្នុងកាលនៃព្រះមានព្រះភាគ ទ្រង់ព្រះនាមថាកស្សបៈ កើតក្នុងផ្ទះនៃត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ចូលទៅកាន់សម្នាក់របស់ព្រះសាស្តាម្តងម្កាល ។

ក្នុងសម័យនោះ ព្រះសាស្តាទ្រង់ទូន្មានសាវកទាំងឡាយរឿយៗ ដោយ គាថាថា សេចក្តីសោករមែងមិនមានដល់អ្នកប្រាជ្ញ មានចិត្តដ៏ខ្ពង់ខ្ពស់ ដូច្នេះ ជាដើម ។ កុលបុត្តនោះបានស្តាប់ឱវាទនោះហើយកើតនូវសទ្ធា ទើបចេញបួស កាលបួសហើយ រៀនគាថានោះឯងរឿយៗ ។ លោកបំពេញសមណធម៌ក្នុង សាសនានោះអស់ ២ ម៉ឺនឆ្នាំ មិនអាចញ៉ាំងគុណវិសេសឲ្យកើតឡើងបាន ព្រោះញាណមិនទាន់ចាស់ក្លា ។ លោកចុតិចាកភពនោះហើយ កើតក្នុងទេវ លោក អន្ទោលទៅមកក្នុងសុគតិភពនោះឯង ។ ក្នុងពុទ្ធុប្បាទនេះ កើតជាកូន របស់ព្រាហ្មណ៍ដែលសម្បូរដោយសម្បត្តិក្នុងនគរសាវត្ថី ដល់នូវភាពជាអ្នក ដឹងក្តីហើយ ឃើញពុទ្ធានុភាពក្នុងកាលដែលទ្រង់ទទួលវិហារជេតពន មាន សទ្ធាទើបចេញបួសធ្វើនូវបុព្វកិច្ចស្រេចហើយនៅក្នុងព្រៃ បានទៅកាន់សម្នាក់ របស់ព្រះសាស្តា ក្នុងសម័យនោះព្រះសាស្តាទ្រង់ទតឃើញព្រះសារីបុត្តខ្វល់ ខ្វាយក្នុងអធិចិត្ត ក្នុងទីមិនឆ្ងាយអំពីព្រះអង្គ ទ្រង់បន្លឺឧទានថា សេចក្តីសោក រមែងមិនមានដល់អ្នកប្រាជ្ញ មានចិត្តដ៏ខ្ពង់ខ្ពស់ ដូច្នេះជាដើម ។ ព្រះថេរៈ ស្តាប់ពុទ្ធឧទាននោះហើយ កាលនៅក្នុងព្រៃដើម្បីចម្រើនភាវនាជាប្រចាំក៏បន្លឺ ឧទានគាថានោះឯងម្តងម្កាល ។ ដោយហេតុនោះ ទើបលោកកើតសមញ្ញា-

នាមថា ឯកុទានិយត្ថេរ ។ ថ្ងៃមួយ លោកបាននូវឯកគ្គតារម្មណ៍ ចម្រើនវិបស្សនាហើយ សម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលព្រះសុគតព្រះនាមអត្ថទស្សីទ្រង់បរិនិព្វាន ខ្ញុំបានទៅកើតក្នុងកំណើតយក្សក្នុងលំដាប់ស្មើគ្នា កាលនោះ ខ្ញុំបានដល់នូវយស ។ ខ្ញុំគិតថា អត្តភាពជាមនុស្សអាត្មាអញបានមិនល្អ ភ្លឺស្វាងមិនល្អ តាំងឡើងមិនល្អ ព្រោះថា កាលដែលភោគៈរបស់អាត្មាអញនៅមាន ព្រះសម្ពុទ្ធមានចក្ខុទ្រង់បរិនិព្វាន សាវកឈ្មោះ សាគរៈ ជ្រាបច្បាស់នូវតម្រិះរបស់ខ្ញុំ លោកប្រាថ្នានឹងស្រង់ខ្ញុំ ទើបនិមន្តមកក្នុងសំណាក់ខ្ញុំ ( ហើយពោលថា ) នែ៎ បុរសអ្នកមានប្រាជ្ញាល្អ អ្នកយំសោកពីរឿងអ្វី អ្នកកុំខ្វាចឡើយ ចូរប្រព្រឹត្តធម៌ចុះ ការបរិបូណ៌ដោយពូជ គឺ កុសលរបស់សត្វទាំងអស់ ព្រះពុទ្ធជាម្ចាស់បានប្រគល់ឲ្យហើយ ។ បុគ្គលណាបូជាព្រះសម្ពុទ្ធ ជាលោកនាយក ដែលទ្រង់គង់នៅព្រះជន្មនៅក្តី បូជាព្រះសារីរិកធាតុប្រមាណប៉ុនគ្រាប់ស្ពៃរបស់ព្រះសម្ពុទ្ធដែលបរិនិព្វានហើយក្តី កាលបើចិត្តមានសេចក្តីជ្រះថ្លាស្មើ បុណ្យជាមហគ្គតកុសលស្មើគ្នា ( គង់ចម្រើនដល់បុគ្គលនោះ ) ហេតុនោះ អ្នកចូរធ្វើព្រះស្តូបបញ្ចុះព្រះសារីរិកធាតុរបស់ព្រះជិនស្រីចុះ ។ ខ្ញុំបានស្តាប់វាចាព្រះសាគរត្ថេរ

ហើយ ខ្ញុំកសាងនូវពុទ្ធស្តូប ថែទាំព្រះស្តូបដ៏ប្រសើររបស់ព្រះមុនីអស់ ៥ ឆ្នាំ ។ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជាច្បងក្នុងលោក ជានរាសភៈ ខ្ញុំសោយសម្បត្តិ បានដល់នូវអរហត្តដោយកុសលកម្មនោះ ។ ក្នុងកប្បទី ៧០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៤ ជាតិ ទ្រង់មានប្រាជ្ញាក្រាស់ដូចផែនដីបរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលលោកសម្រេចអរហត្តហើយ សម្ងំដោយវិមុត្តិសុខ ថ្ងៃមួយ ត្រូវព្រះធម្មភណ្ឌាគារិកនិមន្តថា អាវុសោ សូមលោកសម្តែងធម៌ដល់ខ្ញុំ ដូច្នេះ ដើម្បីពិសោធមើលបដិភាណរបស់លោក ព្រោះហេតុដែលលោកបានអប់រំមកអស់កាលយូរ ទើបពោលគាថានេះឯងថា

សេចក្តីសោក រមែងមិនមានដល់អ្នកប្រាជ្ញ មានចិត្តដ៏ខ្ពង់ខ្ពស់ ជាអ្នកមិនប្រមាទ សិក្សាក្នុងធម៌ជាគន្លងនៃការចេះដឹង មានតាទិគុណ ជាអ្នកស្ងប់រម្ងាប់ មានសតិគ្រប់កាល ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អធិចេតសោ** បានដល់ មានចិត្តតាំងមាំ អធិប្បាយថា ប្រកបដោយអរហត្តផលចិត្តដែលក្រៃលែងជាងចិត្តទាំងពួង ។

---

១-ក្នុងអបទានជាព្រះ បច្ចុបដ្ឋានសញ្ញកត្ថេរ ។

បទថា **អប្បមជ្ជតោ** បានដល់ ជាអ្នកមិនប្រមាទ ។ លោកពោលអធិប្បាយទុកថា ប្រកបទៅដោយការធ្វើជាប់តគ្នាក្នុងធម៌ដែលមិនមានទោសទាំងឡាយ ដោយសេចក្តីមិនប្រមាទ ។ បទថា **មុនិនោ** សេចក្តីថា ព្រះខីណាស្រព ឈ្មោះថាជាមុនីព្រោះដឹងនូវលោកទាំង ២ ដូចព្រះតម្រាស់ ( ក្នុងធម្មបទ ) ថា បុគ្គលណា ដឹងប្រយោជន៍ទាំងពីរក្នុងលោក បុគ្គលនោះហៅថា មុនី ដោយហេតុនោះ ដូច្នេះ ។ម្យ៉ាងទៀត ញាណ លោកហៅថា **មោន** ព្រះខីណាស្រពឈ្មោះថា ជាមុនី ព្រោះប្រកបដោយ មោនៈ ពោលគឺបញ្ញាក្នុងព្រះអរហត្តផលនោះ ។ ដល់ភិក្ខុដែលជាមុនីនោះ ។

បទថា **មោនបថេសុ សិក្ខតោ** សេចក្តីថា អ្នកសិក្សាក្នុងគន្លងនៃមោនៈ ពោលគឺញាណក្នុងអរហត្តផល បានដល់ ក្នុងពោធិបក្ខិយធម៌ ៣៧ ប្រការ ដែលជាមាគ៌ានៃឧបាយ ឬសិក្សាក្នុងសិក្ខា ៣ ។ ពាក្យនេះលោកពោលទុកដោយកាន់យកជាបដិបទា ដែលជាចំណែកខាងដើម ។ គប្បីជ្រាបអត្ថក្នុងពាក្យថា **មោនបថេសុ សិក្ខតោ** នេះ យ៉ាងនេះថា ព្រះអរហន្តសម្រេចការសិក្សាហើយ ព្រោះដូច្នោះ ដល់ភិក្ខុអ្នកសិក្សាយ៉ាងនេះ គឺដល់មុនីដែលដល់នូវភាពជាមុនីដោយសិក្ខានេះ ។ ព្រោះហេតុដែលពាក្យនេះ លោកពោលទុកយ៉ាងនេះ ដូច្នោះ បទទាំង ២ នេះ គួរប្រកបសេចក្តីយ៉ាងនេះថា ដល់ភិក្ខុដែលមានចិត្តនឹងធឹង ដោយអំណាចនៃមគ្គចិត្ត និងផលចិត្តខាងក្រោម បុគ្គលមិនប្រមាទដោយអំណាចនៃការមិនប្រមាទ ក្នុងបដិបទាជាគ្រឿងត្រាស់ដឹង គឺអរិយសច្ច ៤ ឈ្មោះថា ជាមុនី ព្រោះប្រកបដោយមគ្គញាណដ៏

ប្រសើរ ។ មួយវិញទៀត គប្បីជ្រាបថា លោកពោលហេតុនៃសេចក្តីព្យាយាម ទុកដោយពាក្យថា **អប្បមជ្ជតោ សិក្ខតោ** នេះ ។ ព្រោះដូច្នោះ ទើបបាន សេចក្តីថា ដល់ភិក្ខុដែលមានចិត្តនឹងធឹងព្រោះហេតុនៃសេចក្តីមិនប្រមាទ និង ព្រោះហេតុនៃការសិក្សា ។ បទថា **សោកា ន ភវន្តិ តាទិនោ** សេចក្តីថា សេចក្តីសោកទាំងឡាយ ដែលមានការព្រាត់ប្រាសចាកវត្ថុដែលប្រាថ្នាហើយ ជាដើមជាវត្ថុ បានដល់ ការក្តៅក្រហាយនៃចិត្តរមែងមិនមានខាងក្នុងរបស់ ភិក្ខុដែលនឹងធឹង គឺរបស់មុនីដែលអស់កិលេស ។ មួយវិញទៀត សេចក្តីសោក ទាំងឡាយរមែងមិនមានដល់ព្រះមុនីដែលជាអសេក្ខៈ ជាអ្នកដល់នូវលក្ខណៈ នៃតាទិបុគ្គល ។ បទថា **ឧបសន្តស្ស** សេចក្តីថា ចូលទៅស្ងប់ហើយដោយ ការចូលទៅស្ងប់កិលេស មានរាគៈជាដើមសព្វកាល ។ បទថា **សទា ស-តីមតោ** សេចក្តីថាដែលមិនវៀរចាកសតិអស់កាលជានិច្ច ព្រោះដល់ហើយ នូវការបរិបូណ៌នៃសតិ ។

ក្នុងគាថានេះ ដោយបទថា **អធិចេតសោ** គប្បីជ្រាបថា បានដល់ អធិ ចិត្តសិក្ខា ។ ដោយបទថា **អប្បមជ្ជតោ** គប្បីជ្រាបថា បានដល់ អធិសីល សិក្ខា ។ ដោយបទថា **មុនិនោ មោនបថេសុ សិក្ខតោ** គប្បីជ្រាបថា បាន ដល់ អធិប្បញ្ញាសិក្ខា ។ មួយវិញទៀត គប្បីជ្រាបថា លោកប្រកាសអធិ-ប្បញ្ញាសិក្ខាដោយបទថា **មុនិនោ** ។ ប្រកាសបដិបទាដែលជាចំណែកខាង ដើមនៃលោកុត្តរសិក្ខាទាំងឡាយនោះដោយបទថា **មោនបថេសុ សិក្ខតោ** ។ ប្រកាសអានិសង្សនៃការធ្វើសិក្ខាឲ្យបរិបូណ៌ដោយបទជាដើមថា **សោកា ន**

**ភវន្តិ** ។ គាថានេះឯង បានជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈ ។

## អដ្ឋកថា ឯកុទានិយត្ថេរគាថា ចប់

## ឆន្នត្ថេរគាថា

[ ៧០ ] ខ្ញុំបានស្តាប់សច្ចធម៌ មានរសដ៏ប្រសើរ របស់ព្រះមានព្រះភាគ ជាបុគ្គលប្រសើរ ដែលព្រះពុទ្ធមានសព្វញ្ញុតញ្ញាណប្រសើរ សម្តែងហើយ ប្រតិបត្តិចំពោះអដ្ឋង្គិកមគ្គ ដើម្បីដល់ព្រះនិព្វានឈ្មោះអមតៈ ព្រះមានព្រះភាគនោះ ព្រះអង្គជាបុគ្គលឈ្លាសវៃក្នុងគន្លងនៃព្រះនិព្វានដ៏ក្សេមចាកយោគៈ ។

ឆន្នត្ថេរ ។

## អដ្ឋកថា

## ឆន្នត្ថេរគាថា

[ ៧០ ] គាថារបស់ព្រះឆន្នត្ថេរ មានពាក្យផ្តើមថា **សុត្វាន ធម្មំ មហាតោ មហារសំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏បានធ្វើបុញ្ញាធិការទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាសិទ្ធត្ថ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ ឃើញព្រះមានព្រះភាគព្រះនាមថាសិទ្ធត្ថ ចូលទៅកាន់គល់ឈើមួយដើម មានចិត្តជ្រះថ្លាបានក្រាលអាសនៈដោយស្លឹកឈើមានសម្ផស្សទន់ថ្វាយព្រះមានព្រះភាគ ហើយរោយផ្កាជុំវិញ ធ្វើនូវការបូជា ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក ធ្វើបុណ្យជាច្រើនដទៃ

ទៀត បានអន្ទោលទៅក្នុងសុគតិភពនោះឯង ។ ក្នុងសាសនាព្រះមានព្រះភាគនៃយើងទាំងឡាយ កើតក្នុងផ្ទៃទាសីក្នុងរាជវាំងរបស់ព្រះបាទសុទ្ធោទនមហារាជ មានឈ្មោះថា ឆន្ន ជាសហជាតនឹងព្រះពោធិសត្វ ។

នាយឆន្នមានសទ្ធា ក្នុងសមាគមនៃព្រះញាតិរបស់ព្រះបរមសាស្តា បួសហើយដោយសេចក្តីស្រឡាញ់ក្នុងព្រះមានព្រះភាគ កើតនូវការប្រកាន់ខ្លួនថា ព្រះពុទ្ធរបស់អញ ព្រះធម៌របស់អញ មិនអាចកាត់សេចក្តីស្នេហាបាន មិនបំពេញសមណធម៌ កាលព្រះសាស្តាបរិនិព្វានហើយ ត្រូវគំរាមដោយព្រហ្មទណ្ឌ ដែលព្រះសាស្តាទ្រង់ធ្វើដោយវិធីផ្តាំផ្ញើ កុលបុត្តនេះដល់នូវសេចក្តីសង្វេគ កាត់សេចក្តីស្នេហាបាន ពិចារណាឃើញច្បាស់ សម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុក ក្នុងអបទានថា

ខ្ញុំបានថ្វាយកម្រាលស្លឹកឈើ ចំពោះព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ទាំងបានរោយរាយផ្កាច្បាជាឧបការៈ ( ដល់កម្រាលស្លឹកឈើ ) ដោយជុំវិញទៀត ។ ( ដោយកុសលកម្មនេះ ) ខ្ញុំបានសោយ ( គ្រប់គ្រង ) ប្រាសាទទាំងឡាយផង គុហាជាទីរីករាយមានថ្លៃច្រើនផង ផ្កាទាំងឡាយមានថ្លៃច្រើន តែងបង្អុរចុះលើសយនៈរបស់ខ្ញុំផង ។ ខ្ញុំដេកនៅលើសយនៈដ៏វិចិត្រក្រាលដោយផ្កាឈើ ទាំងភ្លៀងជាវិការៈនៃផ្កាឈើ ក៏តែងបង្អុរចុះលើសយនៈ ( របស់ខ្ញុំ ) ក្នុងកាលនោះ ។ ក្នុង

កប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយកម្រាលស្លឹកឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃកម្រាលស្លឹកឈើ ។ ក្នុងកប្បទី ៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៧ ដង ព្រះនាមបិតាសន្ថារកៈដូចគ្នា ទ្រង់ជាធំជាងពួកជន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈ កាលសម្រេចអរហត្តហើយ ជាអ្នកឆ្អែតទៅដោយវិមុត្តិសុខ កាលនឹងបន្លឺឧទានដោយកម្លាំងនៃបីតិ បានពោលគាថាថា

ខ្ញុំបានស្តាប់សច្ចធម៌មានរសដ៏ប្រសើរ របស់ព្រះមានព្រះភាគជាបុគ្គលប្រសើរ ដែលព្រះពុទ្ធមានសព្វញ្ញុតញ្ញាណប្រសើរសម្តែងហើយ ប្រតិបត្តិចំពោះអដ្ឋង្គិកមគ្គដើម្បីដល់ព្រះនិព្វានឈ្មោះអមតៈ ព្រះមានព្រះភាគនោះ ព្រះអង្គជាបុគ្គលឈ្លាសវៃក្នុងគន្លងនៃព្រះនិព្វានដ៏ក្សេមចាកយោគៈ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុត្វាន** ប្រែថា ស្តាប់ហើយ បានដល់ផ្ទៀងនូវសោតៈស្តាប់ ហើយពិចារណាតាមក្រសែសោតទ្វារ ។ បទថា **ធម្មំ** បានដល់ អរិយសច្ចធម៌ទាំង ៤ ។ បទថា **មហាតោ** បានដល់ ព្រះមានព្រះភាគ ។ ពិតហើយ ព្រះមានព្រះភាគ សត្វលោកថ្វាយ

---

១-ក្នុងអបទានជាព្រះ សេនាសនទាយកត្ថេរ ។

ព្រះនាមថា **មហា** ព្រោះប្រកបដោយគុណ មានសីលជាដើមដែលធំពន់ពេក គឺឧឡារបំផុត និងព្រោះមនុស្សលោកព្រមទាំងទេវលោកគួរបូជា ជាហេតុឲ្យព្រះមានព្រះភាគអង្គនោះកើតនូវសមញ្ញានាមថា ព្រះមហាសមណៈ ។ បទថា **សុត្វាន ធម្មំ មហតោ** នេះ ជាបញ្ចមីវិភត្តិ ។

បទថា **មហារសំ** សេចក្តីថា ឈ្មោះថា មានរសឧឡារ ព្រោះជាធម៌ដែលឲ្យនូវវិមុត្តិរស ។

បទថា **សព្វញ្ញុតញ្ញាណវរេន ទេសិតំ** សេចក្តីថា ព្រះមានព្រះភាគព្រះនាមថា **សព្វញ្ញូ** ព្រោះទ្រង់ដឹងនូវធម៌ទាំងពួង ការមាននៃសព្វញ្ញូនោះឈ្មោះថា **សព្វញ្ញុតា** ។ ព្រះញាណនោះឯងប្រសើរឬប្រសើរក្នុងព្រះញាណព្រោះហេតុនោះ ទើបឈ្មោះថា **ញាណវរ** ។ ព្រះមានព្រះភាគទ្រង់ព្រះនាមថា **សព្វញ្ញុតញ្ញាណវរ** ព្រោះទ្រង់មានព្រះញាណដ៏ប្រសើរ ប្រកបសេចក្តីថា ស្តាប់ធម៌ដែលព្រះមានព្រះភាគដែលមានព្រះញាណដ៏ប្រសើរ ពោលគឺសព្វញ្ញុតញ្ញាណនោះទ្រង់សម្តែងហើយ គឺត្រាស់ទុកហើយ ឬទ្រង់សម្តែងព្រោះមានហេតុ ពាក្យណាដែលគួរពោលក្នុងទីនេះ ពាក្យនោះគប្បីជ្រាបដោយន័យដូចពោលហើយក្នុងអដ្ឋកថាឥតិវុត្តកៈ ឈ្មោះបរមត្ថទីបនី ។

បទថា **មគ្គំ** បានដល់ អរិយមគ្គប្រកបដោយអង្គ ៨ ។

បទថា **បបជ្ជឹ** បានដល់ ប្រព្រឹត្តទៅហើយ ។ បទថា **អមតស្ស បត្តិយា** ប្រកបសេចក្តីថា ប្រព្រឹត្តទៅកាន់ផ្លូវដែលជាឧបាយនៃការសម្រេចព្រះនិព្វាន ។

បទថា **សោ** ស្មើគ្នានឹង **សោ ភគវា** ប្រែថា ព្រះមានព្រះភាគអង្គនោះ ។

បទថា **យោគក្ខេមស្ស បថស្ស កោវិទោ** សេចក្តីថា ជាអ្នកឈ្លាសក្នុងផ្លូវនៃព្រះនិព្វានដែលយោគៈទាំង ៤ មិនប្រទូស្ត គឺជាអ្នកឈ្លាសដោយល្អក្នុងផ្លូវនៃព្រះនិព្វាននោះ ។ ក្នុងបាទគាថាថា **យោគក្ខេមស្ស បថស្ស កោវិទោ** នេះ មានអធិប្បាយថា ខ្ញុំស្តាប់ការសម្តែងអរិយសច្ច ៤ របស់ព្រះមានព្រះភាគ ហើយប្រព្រឹត្តទៅកាន់ផ្លូវដែលជាឧបាយសម្រេចនូវអមតធម៌ គឺធ្វើគន្លងនៃបដិបទា បានដល់ ខ្ញុំក៏អាស្រ័យឧបាយរបស់ព្រះមានព្រះភាគអង្គនោះឯង ដែលឈ្លាសក្នុងផ្លូវជាដែនក្សេមចាកយោគៈ ដោយប្រការទាំងពួង គឺឈ្លាសក្នុងសន្តានរបស់អ្នកដទៃឬឈ្លាសក្នុងការទូន្មានចិត្ត ដែលអ្នកដទៃដើរទៅដោយត្រង់ផ្លូវ ។ គាថានេះឯងបានជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈ ។

**អដ្ឋកថា ធន្នុត្ថេរគាថា ចប់**

## បុណ្ណត្ថេរគាថា

[ ៧១ ] សីលហ្នឹងឯង ជាកំពូលក្នុងសាសនានេះ ចំណែកបុគ្គលមានប្រាជ្ញា ជាបុគ្គលប្រសើរ ជ័យជំនះក្នុងមនុស្សនិងទេវតាទាំងឡាយរមែងមានព្រោះសីលនិងប្រាជ្ញា ។

បុណ្ណត្ថេរ ។

ឧទ្ទាន

និយាយអំពីវប្បត្ថេរ ១ វជ្ជិបុត្តកត្ថេរ ១ បក្ខត្ថេរ ១ វិមលកោណ្ឌញ្ញត្ថេរ ១ ឧក្ខេបកដវច្ឆត្ថេរ ១ មេឃិយត្ថេរ ១ ឯកធម្មសវនិយត្ថេរ ១ ឯកុទានត្ថេរ ១ ឆន្នត្ថេរ ១ បុណ្ណត្ថេរជាអ្នកមានកម្លាំងច្រើន ១ ។

ចប់ សត្តមវគ្គ ។

# អដ្ឋកថា

## បុណ្ណត្ថេរគាថា

[ ៧១ ] គាថារបស់ព្រះបុណ្ណត្ថេរ មានពាក្យផ្តើមថា **សីលមេវ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះថេរៈនេះក៏មានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងលោកដែលទទេចាកព្រះពុទ្ធក្នុងកប្បទី ៩១ អំពីភទ្ទកប្បនេះ កើតក្នុងត្រកូលព្រាហ្មណ៍ចម្រើនវ័យហើយ សិក្សាសម្រេចនៅក្នុងសិល្បសាស្ត្ររបស់ព្រាហ្មណ៍ ឃើញទោសក្នុងកាមទាំងឡាយ លះឃរាវាសវិស័យ បួសជាតាបស សាងបណ្ណកុដិនៅអាស្រ័យត្រង់ហិមវន្តប្បទេស ។

ត្រង់ញកភ្នំមួយកន្លែង មិនឆ្ងាយអំពីទីដែលតាបសនោះនៅ ព្រះបច្ចេកពុទ្ធមានអាពាធ បរិនិព្វានហើយ ។ ក្នុងសម័យដែលព្រះបច្ចេកពុទ្ធអង្គនោះបរិនិព្វាន មានពន្លឺសន្ធោសន្ធៅឡើង តាបសឃើញពន្លឺនោះហើយ សម្លឹងមើលក្នុងទីផ្សេងៗ ពិចារណាថា ពន្លឺនេះកើតឡើងបានដូចម្តេចហ្ន៎ ឃើញព្រះបច្ចេកពុទ្ធបរិនិព្វានត្រង់ជើងភ្នំ ទើបយកឧសដែលមានក្លិនក្រអូបមកធ្វើឈាបនកិច្ច ហើយប្រោះព្រំដោយទឹកក្រអូប ។ ត្រង់ញកភ្នំនោះ មានទេវបុត្តមួយអង្គឈរក្នុងអាកាស ពោលយ៉ាងនេះថា សាធុ សាធុ សប្បុរស កម្មដែលញ៉ាំងសត្វទៅកាន់សុគតិលោកបានជួបនូវបុណ្យធំបំពេញហើយ ដោយបុណ្យនេះ លោកកើតក្នុងសុគតិភពប៉ុណ្ណោះលោកនឹងមានឈ្មោះថាបុណ្ណៈដូច្នេះ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំង-ឡាយ ក្នុងពុទ្ធុប្បាទនេះកើតក្នុងត្រកូលគហបតីត្រង់កំពង់ឈ្មោះសុប្បារកៈក្នុងសុណាបរន្តជនបទមានឈ្មោះថាបុណ្ណៈ ។ បុណ្ណមាណព ចម្រើនវ័យហើយទៅកាន់នគរសាវត្ថីមួយអន្លើដោយរទេះជាច្រើនដោយធុរកិច្ចក្នុងការជួញដូរ ។

សម័យនោះ ព្រះមានព្រះភាគគង់នៅក្នុងនគរសាវត្ថី លំដាប់នោះ បុណ្ណមាណពទៅកាន់ព្រះវិហារមួយអន្លើដោយពួកឧបាសក ដែលនៅក្នុងនគរសាវត្ថី ស្តាប់ធម៌ក្នុងសម្នាក់នៃព្រះសាស្តាហើយមានសទ្ធា ទើបចេញបួសធ្វើអាចារ្យនិងឧបជ្ឈាយ៍ឲ្យស្រឡាញ់រាប់អានដោយវត្តបដិបត្តិ ។ ថ្ងៃមួយ កុលបុត្តនេះចូលទៅគាល់ព្រះសាស្តាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមឱកាស សូមទ្រង់ប្រទានឱវាទដោយសង្ខេប ដែលជាហេតុឲ្យខ្ញុំព្រះអង្គស្តាប់ហើយទៅនៅក្នុងសុណាបរន្តជនបទបាន ព្រះមានព្រះភាគ ទ្រង់ប្រទានឱវាទដល់ព្រះថេរៈ ដោយន័យជាដើមថា ម្នាលបុណ្ណៈ រូបទាំងឡាយដែលគប្បីដឹងដោយចក្ខុមាន ហើយទ្រង់បន្លឺសីហនាទ បញ្ជូនព្រះថេរៈទៅ ។

ព្រះថេរៈថ្វាយបង្គំព្រះមានព្រះភាគ ហើយទៅកាន់សុណាបរន្តជនបទនៅត្រង់កំពង់ឈ្មោះសុប្បារកៈ ខ្នះខ្នែងក្នុងសមថៈនិងវិបស្សនាធ្វើវិជ្ជា ៣ ឲ្យជាក់ច្បាស់ហើយ ។ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះពុទ្ធជាសយម្ភូ ទ្រង់ឈ្នះមារ គង់នៅក្នុងចន្លោះភ្នំដែលនៅ
អែបចុងញក ព្រះអង្គមានអាពាធក្នុងទីនោះ ។ កាលព្រះពុទ្ធ
ស្តេចបរិនិព្វានហើយ សំឡេងគឹកកងកើតមាន ជុំវិញអាស្រម

របស់ខ្ញុំក្នុងខណៈនោះពន្លឺក៏កើតឡើងក្នុងវេលានោះដែរ ។ ពួកសត្វសាហាវទាំងពួង គឺខ្លាឃ្មុំ ខ្លាព្រៃ ខ្លារខិន និងកេសររាជសីហ៍ ក្នុងដងព្រៃទាំងអម្បាលម៉ាន ក៏បន្លឺសំឡេងឡើងក្នុងខណៈនោះដែរ ។ ខ្ញុំបានឃើញសេចក្តីអស្ចារ្យនោះកើតហើយ ក៏ចូលទៅកាន់ញកភ្នំ បានឃើញព្រះសម្ពុទ្ធទ្រង់ឈ្មោះមារស្តេចបរិនិព្វានហើយត្រង់ញកភ្នំនោះ ។ ( លុះខ្ញុំឃើញ ) នូវព្រះសម្ពុទ្ធទ្រង់ឈ្មោះមារដែលបរិនិព្វានហើយ ទ្រង់ដូចជាសាលរាជព្រឹក្សដែលមានផ្ការីកឬដូចជាព្រះអាទិត្យ ដែលទើបនឹងរះឡើងពុំនោះសោតដូចជារងើកភ្លើងដែលឥតមានអណ្តាត ។ ខ្ញុំបានធ្វើជើងថ្ករបំពេញស្មៅ និងឧសក្នុងទីនោះ លុះខ្ញុំធ្វើជើងថ្ករដ៏វិចិត្ររួចហើយ ក៏បូជាសរីរសព ។ លុះខ្ញុំបូជាសរីរសពរួចហើយ ក៏ស្រោចស្រពនូវទឹកអប់លើព្រះធាតុ ខណៈនោះទេវតាដែលឋិតនៅឰដ៏អាកាស កាន់យកនូវឈ្មោះ ( ខ្ញុំ ) ថា អ្នកបំពេញកិច្ចនោះ ចំពោះព្រះសយម្ភូ ទ្រង់ស្វែងរកនូវគុណដ៏ធំហើយ អ្នកនៅក្នុងសំណាក់នៃព្រះមុនីក្នុងកាលណា អ្នកនឹងបានឈ្មោះថា បុណ្ណកៈ ក្នុងកាលនោះ ។ លុះខ្ញុំច្យុតចាកកាយនោះហើយ ក៏បានទៅកើតក្នុងទេវលោក ក្លិនជាទិព្វបង្អុរចុះពីអាកាសត្រង់កន្លែងដែលខ្ញុំនៅនោះ ។ កាលនោះឈ្មោះរបស់ខ្ញុំថាបុណ្ណកៈក្នុងទីនោះខ្ញុំកើតជាទេវតាឬជាមនុស្សតែងបំពេញ

សេចក្តីបំណងបាន ។ នេះសរីរៈជាទីបំផុតរបស់ខ្ញុំ ភពជាទី
បំផុតកំពុងប្រព្រឹត្តទៅ សូម្បីក្នុងអត្តភាពនេះ គង់អ្នកផងប្រ-
កាសនាម ( របស់ខ្ញុំ ) ថា បុណ្ណកៈ ។ ខ្ញុំបានញុំាងព្រះសម្ពុទ្ធ
ព្រះនាមគោតម ជាសក្យៈដ៏ប្រសើរឲ្យត្រេកអរ ខ្ញុំកំណត់ដឹង
អាសវៈទាំងពួងជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ៩១ អំ-
ពីកប្បនេះក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម
ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃការបូជាសរីរសេពនោះឯង។
កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនា
របស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ ញុំាងមនុស្សទាំងឡាយជាច្រើនឲ្យមានសទ្ធាក្នុងសាសនាដោយបុរស ៥០០ នាក់ ប្រកាសខ្លួនជាឧបាសក និងស្ត្រី ៥០០ នាក់ ប្រកាសខ្លួនជាឧបាសិកា ។ លោកឲ្យគេសាងព្រះគន្ធកុដិឈ្មោះ ចន្ទនមាលា ដោយឈើចន្ទន៍ក្រហមត្រង់សុណាបរន្តជនបទនោះ អារាធនាព្រះមានព្រះភាគដោយទូក គឺផ្កាថា សូមព្រះបរមសាស្តាទ្រង់ទទួលផ្កាមួយអន្លើដោយភិក្ខុទាំងឡាយ ៥០០ ដូច្នេះ ។ ព្រះមានព្រះភាគទ្រង់យាងទៅកាន់ព្រះគន្ធកុដិឈ្មោះចន្ទនមាលានោះ មួយអន្លើដោយភិក្ខុទាំងឡាយប្រមាណប៉ុណ្ណោះដោយអានុភាពនៃឫទ្ធិ ទ្រង់ទទួលព្រះគន្ធកុដិឈ្មោះចន្ទនមាលាកាលអរុណមិនទាន់រះ ទ្រង់ក៏យាងត្រឡប់ ។ ក្នុងកាលតមក ព្រះថេរៈកាលនឹងព្យាករអរហត្តផលក្នុងសម័យបរិនិព្វានបានពោលគាថាថា

សីលហ្នឹងឯង ជាកំពូលក្នុងសាសនានេះ ចំណែកបុគ្គលមាន
ប្រាជ្ញាជាបុគ្គលប្រសើរ ជ័យជំនះក្នុងមនុស្ស និងទេវតាទាំង-
ឡាយរមែងមានព្រោះសីលនិងប្រាជ្ញា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សីលំ** សេចក្ដីថា ឈ្មោះថា សីល ដោយអត្ថថា ប្រក្រតី ឈ្មោះថា សីល ដោយអត្ថថា ជាទីតាំង និងដោយអត្ថថា សមាទាន ។

ពិតណាស់ សីលជាទីតាំងនៃគុណទាំងពួង ដោយហេតុនោះ ទើបលោកពោលថា **សីលេ បតិដ្ឋាយ នរោ សបញ្ញោ** នរជន មានប្រាជ្ញា បានតាំងមាំក្នុងសីលហើយ ដូច្នេះ អធិប្បាយថា បុគ្គលតាំងនៅក្នុងសីល និងធ្វើកាយវាចាឲ្យរៀបរយ ។ សីលប៉ុណ្ណោះ ឈ្មោះថា **ឧត្តមោ** ព្រោះជាបាទ និងជាប្រធាននៃគុណធម៌ ។ សមដូចពុទ្ធតម្រាស់ដែលត្រាស់ទុកថា ម្នាលភិក្ខុ បើដូច្នោះ អ្នកចូរជម្រះក្នុងកុសលធម៌ទាំងឡាយជាខាងដើមបន្តស់សិនចុះ ។ ចុះអ្វីជាខាងដើមនៃកុសលធម៌ទាំងឡាយ ។ គឺសីលដ៏បរិសុទ្ធ ១... ដូច្នេះជាដើម និងពុទ្ធដីកាថា ត្រង់ពាក្យថា បាតិមោក្ខ សេចក្ដីថា ធម្មជាតនេះជាដើម ធម្មជាតនេះជាប្រធាន ធម្មជាតនេះជាមុនដំបូងនៃកុសលធម៌ទាំង-ឡាយ ដូច្នេះ ។

បទថា **ឥធ** ត្រឹមតែជានិបាត ។ បទថា **បញ្ញវា** បានដល់ ដែលដល់ព្រមដោយញាណ ។ ដែលសម្បូរដោយញាណនោះ ជាបុគ្គលប្រសើរ គឺឧត្តមបំផុត បានដល់ បវរ ព្រោះដូច្នោះ ទើបព្រះថេរៈសម្ដែងថា បញ្ញានោះ

ឯងប្រសើរបំផុតដោយគាថាដែលជាបុគ្គលាធិដ្ឋាន ព្រោះថា កុសលធម៌ទាំង-ឡាយ មានបញ្ញាជាកំពូល ។

ឥឡូវនេះ ព្រះថេរៈសម្តែងភាពដែលសីលនិងបញ្ញាជាកំពូលនិងប្រសើរនោះដោយហេតុថា ជ័យជំនះក្នុងមនុស្សនិងទេវតាទាំងឡាយរមែងមានព្រោះសីលនឹងប្រាជ្ញា ដូច្នេះ អធិប្បាយថា នឹងឈ្នះបរបក្ខបាន នឹងឈ្នះកាមកិ-លេសបាន ព្រោះសីលនិងបញ្ញាជាហេតុ ដូច្នេះ ។

**អដ្ឋកថា បុណ្ណកត្ថេរគាថា ចប់**

**វគ្គទី ៧ ចប់**

# ថេរគាថា ឯកនិបាត

## អដ្ឋមវគ្គ

### វច្ឆបាលត្ថេរគាថា

[ ៧២ ] បុគ្គលអ្នកយល់ឃើញប្រយោជន៍ដ៏ល្អិតសុខុមក្រៃលែង ជាអ្នកឈ្លាសវៃដោយប្រាជ្ញា មានកិរិយាប្រព្រឹត្តឱនលំទោន ជាអ្នកសេពល្អ ហើយនូវសីលនៃព្រះពុទ្ធនោះ មិនមែនបានព្រះនិព្វានដោយក្រទេ ។

វច្ឆបាលត្ថេរ ។

## វគ្គទី ៨

### អដ្ឋកថា វច្ឆបាលត្ថេរគាថា

[ ៧២ ] គាថារបស់ព្រះវច្ឆបាលត្ថេរ មានពាក្យផ្ដើមថា **សុសុខុម-និបុណត្ថទស្សិនា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏មានអធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទុកក្នុងភពនោះៗ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយក្នុងកប្បទី ៩១ រាប់អំពីភទ្ទកប្បនេះ កើតក្នុងត្រកូលព្រាហ្មណ៍សម្រេចក្នុងសិប្ប-សាស្ត្ររបស់ព្រាហ្មណ៍ បម្រើភ្លើង ថ្ងៃមួយ យកថាសសរិទ្ធិ ដាក់បាយាសពេញ ស្វែងរកទក្ខិណេយ្យបុគ្គល ឃើញព្រះមានព្រះភាគ ព្រះនាមថាវិបស្សី

ចង្ក្រមក្នុងអាកាស កើតសេចក្តីអស្ចារ្យ ធ្វើនូវអភិវាទចំពោះព្រះមានព្រះភាគ សម្តែងអាការចង់ថ្វាយ ព្រះមានព្រះភាគទ្រង់អាស្រ័យសេចក្តីអនុគ្រោះ ទើបទទួលបាយាសហើយ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ។ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនរបស់ព្រាហ្មណ៍សម្បូរដោយសម្បត្តិក្នុងនគររាជគ្រឹះមានឈ្មោះថាវច្ឆបាល ។ កាលព្រះឧរុវេលកស្សបៈសម្តែងឥទ្ធិប្បាដិហារ្យក្នុងសមាគមនៃព្រះបាទពិម្ពិសារ ហើយសម្តែងការឱនលំទោនដល់ព្រះបរមសាស្តា វច្ឆបាលព្រាហ្មណ៍ឃើញដូច្នោះ កើតនូវសទ្ធាជ្រះថ្លា ទើបចេញបួស ។ លុះបួសបាន ៧ ថ្ងៃប៉ុណ្ណោះ ក៏ចម្រើនវិបស្សនាបានអភិញ្ញា ៦ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះសម្ពុទ្ធមានវណ្ណៈដូចមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ មានកិក្ខុសង្ឃចោមរោម ទ្រង់ចេញអំពីព្រៃធំ ខ្ញុំជួសបាយាសដាក់ក្នុងកាជន៍សំរឹទ្ធិដោយដៃរបស់ខ្លួន ខ្ញុំប្រាថ្នានឹងបូជានូវគ្រឿងបូជា ក៏ដើរសំដៅទៅកាន់ទីបូជា ។ ក្នុងសម័យនោះ ព្រះមានព្រះភាគជាច្បងក្នុងលោកជានរាសភៈទ្រង់ឡើងកាន់ទីចង្ក្រមព្ទដ៏អាកាសជាផ្លូវខ្យល់ ។ ខ្ញុំឃើញហេតុដ៏អស្ចារ្យចំឡែកគួរព្រឺរោមនោះ ក៏ដាក់ចុះនូវកាជន៍សំរឹទ្ធិថ្វាយបង្គំព្រះវិបស្សី ( អារាធនាថា ) បពិត្រព្រះមហាមុនី ព្រះអង្គជាសព្វញ្ញុពុទ្ធ ក្នុងមនុស្សលោកនិងទេវលោក សូមព្រះអង្គអា-

ស្រ័យសេចក្ដីអនុគ្រោះទទួលយក ។ ព្រះមានព្រះភាគ ជាសព្វញ្ញូ លោកនាយក ជាសាស្ដាដ៏ប្រសើរក្នុងលោក ទ្រង់ជ្រាបតម្រិះរបស់ខ្ញុំហើយទ្រង់ទទួលយក ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបាយាស ។ ក្នុងកប្បទី ៤១ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ១ ជាតិ ព្រះនាមពុទ្ធរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយកាលនឹងប្រកាសថា លោកសម្រេចនិព្វានដោយងាយ ទើបពោលគាថានេះថា

បុគ្គលអ្នកយល់ឃើញប្រយោជន៍ដ៏ល្អិតសុខុមក្រៃលែង ជាអ្នកឈ្លាសវៃដោយប្រាជ្ញា មានកិរិយាប្រព្រឹត្តឱនលំទោន ជាអ្នកសេពល្អហើយនូវសីលនៃព្រះពុទ្ធនោះ មិនមែនបានព្រះនិព្វានដោយក្រទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុសុខុមនិបុណត្ថទស្សិនា** សេចក្ដីថា ព្រះយោគាវចរលើកសង្ខារឡើងកាន់ត្រៃលក្ខណ៍ មានភាពជារបស់មិនទៀង ជា

---

១-ក្នុងអបទានជាព្រះ បាយាសទាយកត្ថេរ ។

ដើម ហើយឃើញអត្ថក្នុងធម៌មានអរិយសច្ចនិងបដិច្ចសមុប្បាទជាដើម ដែលឈ្មោះថា **សុខុម** ព្រោះអត្ថថា ឃើញបានលំបាកក្រៃលែង ។ ដែលឈ្មោះថា **និបុណ** ព្រោះអត្ថថា ល្អិតល្អន់ ។ ព្រោះដូច្នោះ ទើបឈ្មោះថា **សុ-សុខុមនិបុណត្ថទស្សិនោ** ដែលព្រះយោគាវចរអ្នកមានប្រក្រតីឃើញអត្ថដ៏សុខុម និងល្អិតនោះ ។

បទថា **មតិកុសលេន** សេចក្តីថា ជាអ្នកមានប្រាជ្ញា គឺបញ្ញាឈ្លាសវៃ បានដល់ ឈ្លាសក្នុងការញុំាងធម្មវិចយសម្ពោជ្ឈង្គប្បញ្ញា ឲ្យកើតឡើងថា បញ្ញារមែងចម្រើនដល់អ្នកប្រព្រឹត្តយ៉ាងនេះ មិនចម្រើនដល់អ្នកប្រព្រឹត្តយ៉ាងនេះឡើយ ដូច្នេះ ។

បទថា **និវាតវុត្តិនោ** សេចក្តីថា មានប្រក្រតីប្រព្រឹត្តឱនលំទោនក្នុងសព្រហ្មចារីទាំងឡាយ និងប្រព្រឹត្តបដិបត្តិដោយសមគួរក្នុងព្រះថេរៈ និងក្នុងនវកភិក្ខុ ។

បទថា **សំសេវិតវុទ្ធសីលិនោ** សេចក្តីថា សីលរបស់ព្រះពុទ្ធដែលព្រះយោគាវចរសេពហើយ គឺប្រព្រឹត្តហើយដោយអើពើ ឈ្មោះថា ជាអ្នកមានសីលរបស់ព្រះពុទ្ធដែលប្រព្រឹត្តហើយដោយអើពើ ដែលព្រះយោគាវចរអ្នកមានសីលរបស់ព្រះពុទ្ធប្រព្រឹត្តហើយដោយអើពើនោះ ។ ម្យ៉ាងទៀត សីលរបស់ព្រះពុទ្ធ ដែលព្រះយោគាវចរនោះសេពហើយ គឺចូលទៅបម្រើហើយ ព្រោះហេតុនោះ ទើបឈ្មោះថា ព្រះយោគាវចរដែលមានសីលរបស់ព្រះពុទ្ធដែលខ្ជួនសេពហើយ ។ នូវព្រះយោគាវចរនោះ ។

**ហិ** សព្វ មានហេតុជាអត្ថ ពង្រីកសេចក្ដីថា ព្រោះព្រះយោគាវចរ មានការប្រព្រឹត្តឱនលំទោន មានសីលរបស់ព្រះពុទ្ធដែលសេពហើយ មានបញ្ញាមុតស្រួច មានប្រក្រតីឃើញអត្ថសុខុមនិងល្អិត ដូច្នោះ ព្រះនិព្វាន ក៏ព្រះយោគាវចរនោះបានដោយមិនលំបាក អធិប្បាយថា បណ្ឌិតទាំងឡាយ រមែងសម្គាល់ក្នុងព្រះយោគាវចរនោះថា គួរជាស់តឿន គួរទូន្មាន ព្រោះជាអ្នកមានប្រក្រតីប្រព្រឹត្តឱនលំទោន ព្រោះជាអ្នកប្រព្រឹត្តបន្ទន់បន្ទាប និងព្រោះជាអ្នកមានសីលរបស់ព្រះពុទ្ធដែលខ្លួនសេពហើយ ព្រះយោគាវចរនេះ ក៏តាំងនៅក្នុងឱវាទរបស់បណ្ឌិតទាំងនោះបំពេញវិបស្សនា រមែងសម្រេចព្រះនិព្វានក្នុងកាលមិនយូរឡើយ ព្រោះជាអ្នកមានបញ្ញាមុតស្រួច និងព្រោះជាអ្នកមានប្រក្រតីឃើញអត្ថដ៏សុខុម និងល្អិត ដូច្នេះ គាថានោះឯងបានជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈ ដូច្នេះ ។

## អដ្ឋកថា វច្ឆបាលត្ថេរគាថា ចប់

# អាតុមត្ថេរគាថា

[ ៧៣ ] ទំពាំងឫស្សីនៅខ្ចី មានចុងលូតលាស់ បែកដៃចេញហើយ បុគ្គលបោចពេចចេញបានដោយក្រ យ៉ាងណាមិញ អាត្មាកាលបើមាតានាំភរិយាមកឲ្យ ក៏យ៉ាងនោះដែរ សូមញោមយល់តាមអាត្មាចុះ ព្រោះឥឡូវនេះអាត្មាបួសហើយ ។

អាតុមត្ថេរ ។

# អដ្ឋកថា

# អាតុមត្ថេរគាថា

[ ៧៣ ] គាថារបស់ព្រះអាតុមត្ថេរ មានពាក្យផ្ដើមថា **យថា កឡីរោ សុសុ វឌ្ឍិតគ្គោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏មានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកប្បទី ៩១ អំពីកប្បនេះ កើតក្នុងផ្ទះមានត្រកូលដល់នូវភាពជាអ្នកដឹងក្ដីហើយ ឃើញព្រះមានព្រះភាគព្រះនាមថាវិបស្សី និមន្តទៅក្នុងវាំងផ្លូវ មានចិត្តជ្រះថ្លា បានធ្វើការបូជាដោយទឹកក្រអូបនិងដោយលម្អិតក្រអូប ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក អន្ទោលទៅមក ក្នុងទេវលោកប៉ុណ្ណោះ បួសក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាកស្សបៈ ហើយ

បំពេញនូវសមណធម៌ តែមិនអាចធ្វើគុណវិសេសឲ្យកើតឡើងបាន ព្រោះញាណនៅមិនទាន់ចាស់ក្លា ។

ក្នុងពុទ្ធុប្បាទនេះ កើតជាសេដ្ឋីបុត្តក្នុងនគរសាវត្ថីមានឈ្មោះថាអាតុម ។ កាលចម្រើនវ័យហើយមាតាប្រឹក្សាជាមួយពួកញាតិថា ពួកយើងនឹងនាំកិរិយាមកឲ្យកូនរបស់យើង កុលបុត្តនោះពិចារណាមើលហេតុនោះហើយ ត្រូវហេតុសម្បត្តិជាស់តឿន ទើបគិតថា ប្រយោជន៍អ្វីដោយការនៅគ្រប់គ្រងផ្ទះដល់អញ អញនឹងបួសក្នុងកាលឥឡូវនេះឯង ដូច្នេះហើយ ទៅកាន់សម្នាក់ភិក្ខុទាំងឡាយបួសហើយ ។ មាតាមានបំណងនឹងញុំាងលោកដែលបួសហើយឲ្យសឹក ទើបលួងលោមដោយន័យផ្សេង ៗ លោកមិនព្រមឲ្យឱកាសដល់មាតា កាលប្រកាសអធ្យាស្រ័យរបស់ខ្លួនទើបពោលគាថានេះថា

ទំពាំងឫស្សីនូវខ្លីមានចុងលូតលាស់ បែកដៃចេញហើយបុគ្គល
បោចរោចចេញបានដោយក្រ យ៉ាងណាមិញ អាត្មាកាលបើ
មាតានាំកិរិយាមកឲ្យ ក៏យ៉ាងនោះដែរ សូមញោមយល់តាម
អាត្មាចុះ ព្រោះឥឡូវនេះអាត្មាបួសហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កឡីរោ** បានដល់ ទំពាំង តែក្នុងគាថានេះសំដៅដល់ទំពាំងនៃដើមឫស្សី ។

បទថា **សុសុ** ប្រែថា មានអាយុតិច ( ខ្លី ) ។ បទថា **វឌ្ឍិតគ្គោ** សេចក្តីថា មានមែកចម្រើនដុះដាល ។ម្យ៉ាងទៀត បទថា **សុសុ វឌ្ឍិតគ្គោ** សេចក្តីថា បែកមែកសាខា លូតលាស់ចេញទៅដោយល្អ គឺមានស្លឹកនិងដៃកើត

ហើយ ។ បទថា **ទុន្និក្ខមោ** សេចក្តីថា មិនអាចកើចកន្ត្រាក់ គឺនាំចេញអំពីគុម្ពឫស្សីបាន ។ បទថា **បសាខជាតោ** សេចក្តីថា មានមែកតូចធំកើតហើយ គឺស្ញូវតែមួយមែក ក៏កើតមែកតូចៗគ្រប់ថ្នាំង ។

បទថា **ឯវំ អហំ ភរិយាយានីតាយ** សេចក្តីថា ដើមឫស្សីដែលមានចុងបែកជាគុម្ព មានមែកតូចធំដែលចាក់ស្រែះគ្នាក្នុងរវាងដើម រមែងជារបស់នាំចេញបានដោយលំបាកអំពីគុម្ពឫស្សី យ៉ាងណា ស្ញូវអាត្មា ក៏យ៉ាងនោះ កាលមាតានាំភរិយាមកឲ្យគប្បីជាអ្នកមានពូជចម្រើនដុះដាល ដោយបុត្តនិងធីតាជាដើម លំបាកនឹងវេីខ្លួនចេញអំពីយកវាសវិស័យបាន ដោយអំណាចនៃតណ្ហា ។

ប្រៀបដូចទំពាំងឫស្សីដែលនៅខ្ចី ដែលមែកសម្រាប់ចាក់ស្រែះមិនទាន់កើត រមែងនាំចេញអំពីគុម្ពឫស្សីបានដោយងាយ យ៉ាងណា ស្ញូវអាត្មា ក៏យ៉ាងនោះ កាលវត្ថុដែលឲ្យជាប់ចំពាក់គឺបុត្តនិងភរិយាជាដើម មិនទាន់កើត រមែងវេីខ្លួនចេញបានងាយ ព្រោះហេតុនោះ កាលមាតាមិនទាន់នាំភរិយាមកប្រគល់ឲ្យ ទើបអាត្មាសូមអនុញ្ញាតគឺសូមឲ្យមាតាអនុញ្ញាតដោយខ្លួនឯង ។

បទថា **បព្វជិតោម្ហិទានិ** សេចក្តីថា ព្រះថេរៈប្រកាសសេចក្តីត្រេកអរក្នុងការចេញបួសរបស់ខ្លួនថា ឥឡូវនេះ អាត្មាបួសហើយ គឺការដែលអាត្មាបួសហើយនោះជាការល្អគឺល្អហើយ ។ម្យ៉ាងទៀត ព្រះថេរៈប្រាប់ដល់មាតាថា សូមមាតាអនុញ្ញាតចុះ ក្នុងឥឡូវនេះ អាត្មាបួសជាបព្វជិតហើយ ។

ក្នុងបាទគាថានេះ មានអធិប្បាយដូច្នេះថា បើមាតាមិនព្រមក្នុងខាងដើម

តែឥឡូវនេះ អាត្មាបានបួសហើយ ព្រោះដូច្នោះ សូមមាតាអនុញ្ញាតឲ្យអាត្មាតាំងនៅក្នុងសមណភាពនោះចុះ មាតាមិនគប្បីឲ្យអាត្មាវិលត្រឡប់ឡើយ ។ កាលព្រះថេរៈពោលយ៉ាងនេះ កំពុងឈរនោះឯង ចម្រើនវិបស្សនា ញុំាងកិលេសឲ្យអស់ទៅតាមលំដាប់នៃមគ្គ បានជាអ្នកមានអភិញ្ញា ៦ ហើយសមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំអង្គុយក្នុងប្រាសាទដ៏ប្រសើរ បានឃើញព្រះជិនស្រីព្រះនាមវិបស្សី ជាសព្វញ្ញូនាយកដ៏ឧត្តម ទ្រង់ល្វាសល្វន់ដូចដើមថ្វាន់ត្រូវខ្យល់ ។ ព្រះលោកនាយក ទ្រង់ធ្វើពុទ្ធដំណើរទៅជិតប្រាសាទ ពន្លឺរបស់ព្រះអង្គផ្សាយចេញ ក្នុងកាលព្រះអាទិត្យអស្ដង្គត ។ ខ្ញុំកាន់យកទឹកអប់មកប្រោះព្រំព្រះសម្ពុទ្ធដ៏ប្រសើរដោយចិត្តជ្រះថ្លានោះ ខ្ញុំក៏ធ្វើកាលកិរិយាក្នុងទីនោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំប្រោះព្រំទឹកអប់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិព្រះនាមគន្ធរាជទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយដូច្នេះ[១] ។

---

១-ក្នុងអបទានជាព្រះ គន្ធោទកិយត្ថេរ ។

ព្រះថេរៈបានអភិញ្ញា ៦ ហើយ លាមាតា កាលមាតាកំពុងសម្លឹងមើលនោះឯង ក៏ទៅតាមអាកាស ។ លុះសម្រេចអរហត្តហើយ លោកក៏បានពោលតែគាថានោះមួយប៉ុណ្ណោះក្នុងចន្លោះៗ ។

បណ្ដាបទទាំងនោះ ដោយការចង្អុលបទនេះថា **បព្វជិតោម្හិ** សូម្បីគាថានេះ ក៏ចាត់ជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈ ព្រោះសម្ដែងដល់ភាពនៃមន្ទិល មានរាគៈជាដើមក្នុងសន្តានរបស់ខ្លួន ដែលព្រះថេរៈវៀរទូទៅហើយ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ទុកក្នុងធម្មបទ ) ថា អ្នកដែលបណ្ដេញមន្ទិលនៃខ្លួន ហេតុនោះ ទើបតថាគតហៅថាបព្វជិតដូច្នេះ ។

## អដ្ឋកថា អាតុមត្ថេរគាថា ចប់

## មាណវត្ថេរគាថា

[ ៧៤ ] ខ្ញុំឃើញមនុស្សចាស់ជរា ឈឺចាប់ ប្រកបដោយទុក្ខ ទាំងឃើញមនុស្សដល់នូវការអស់ទៅនៃអាយុ ស្លាប់ហើយ ហេតុនោះខ្ញុំលះបង់កាមជាទីត្រេកអរនៃចិត្ត ហើយចេញបួស ។

មាណវត្ថេរ ។

## អដ្ឋកថា

## មាណវត្ថេរគាថា

[ ៧៤ ] គាថារបស់ព្រះមាណវត្ថេរ មានពាក្យផ្តើមថា **ជិណ្ណញ្ច ទិស្វា ទុក្ខិតញ្ច ព្យាធិតំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកប្បទី ៩១ អំពីកប្បនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ជាគ្រូមើលនូវលក្ខណៈ ពិចារណាលក្ខណៈនៃអភិជាតិរបស់ព្រះមានព្រះភាគ ព្រះនាមថាវិបស្សី ប្រកាសបុព្វនិមិត្តហើយព្យាករថា បុរសនេះនឹងបានជាព្រះពុទ្ធដោយចំណែកមួយ ដូច្នេះហើយ សរសើរដោយន័យផ្សេងៗ ថ្វាយបង្គំហើយ ធ្វើប្រទក្សិណាចៀសចេញទៅ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងសុគតិតែម្យ៉ាង ក្នុង

ពុទ្ធុប្បាទនេះ កើតក្នុងផ្ទះព្រាហ្មណមហាសាលក្នុងនគរសាវត្ថី ចម្រើនធំធាត់ក្នុងផ្ទះតែម្យ៉ាងរហូត ៧ ឆ្នាំ ក្នុងឆ្នាំទី ៧ ពួកបរិវារនាំទៅលេងឧទ្យានឃើញមនុស្សចាស់ មនុស្សឈឺ និងមនុស្សស្លាប់ក្នុងរវាងផ្លូវ ក៏សួរបរិវារជនទាំងនោះ ព្រោះមិនធ្លាប់ឃើញមនុស្សចាស់ មនុស្សឈឺ និងមនុស្សស្លាប់ ស្តាប់សភាពរបស់ជរា ព្យាធិ និងមរណៈហើយ កើតសេចក្តីសង្វេគ ត្រឡប់អំពីទីនោះទៅកាន់វិហារស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តាឲ្យមាតាបិតាអនុញ្ញាតហើយបួសផ្តើមវិបស្សនាសម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលដែលព្រះវិបស្សីទ្រង់ប្រសូត ខ្ញុំបានទាយនិមិត្តថា ព្រះពុទ្ធនឹងញុំាងប្រជុំជនក្នុងលោកឲ្យរលត់ទុក្ខ ។ កាលព្រះមានព្រះភាគអង្គណាទ្រង់ប្រសូត លោកធាតុ ១ ម៉ឺន តែងញាប់ញ័រ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះជាសាស្តាទ្រង់មានបញ្ញាចក្ខុនឹងសម្តែងធម៌ ។ កាលព្រះមានព្រះភាគអង្គណាទ្រង់ប្រសូត ពន្លឺដ៏ធំក៏កើតប្រាកដ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តាទ្រង់មានបញ្ញាចក្ខុនឹងសម្តែងធម៌ ។ កាលព្រះមានព្រះភាគអង្គណា ទ្រង់ប្រសូត ស្ទឹងទាំងឡាយមិនហូរ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះជាសាស្តា ទ្រង់មានបញ្ញាចក្ខុនឹងសម្តែងធម៌ ។ កាលព្រះមានព្រះភាគអង្គណាទ្រង់ប្រសូត ភ្លើងអវិចីមិនឆេះ ឥឡូវនេះ ព្រះមានព្រះ

ភាគអង្គនោះ ជាសាស្តាទ្រង់មានបញ្ញាចក្ខុ នឹងសម្តែងធម៌ ។ កាលព្រះមានព្រះភាគអង្គណាទ្រង់ប្រសូត ពួកសត្វស្ងាបមិនហើរ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះជាសាស្តាទ្រង់មានបញ្ញាចក្ខុនឹងសម្តែងធម៌ ។ កាលព្រះមានព្រះភាគអង្គណាទ្រង់ប្រសូត គំនរខ្យល់មិនបក់ផាត់ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តាទ្រង់មានបញ្ញាចក្ខុ នឹងសម្តែងធម៌ ។ កាលព្រះមានព្រះភាគអង្គណាទ្រង់ប្រសូត ពួកកែវទាំងពួងក៏រុងរឿង ឥឡូវនេះព្រះមានព្រះភាគអង្គនោះជាសាស្តា ទ្រង់មានបញ្ញាចក្ខុ នឹងសម្តែងធម៌ ។ កាលព្រះមានព្រះភាគអង្គណាទ្រង់ប្រសូតឈានដើរបាន៧ជំហាន ឥឡូវនេះព្រះមានព្រះភាគអង្គនោះ ជាសាស្តា ទ្រង់មានបញ្ញាចក្ខុ នឹងសម្តែងធម៌ ។ ព្រះសម្ពុទ្ធគ្រាន់តែទ្រង់ប្រសូតរួចភ្លាម ទ្រង់រមិលមើលសព្វទិស ទ្រង់បន្លឺនូវវាចាដ៏អង់អាច នេះជាធម្មតា របស់ព្រះពុទ្ធទាំងឡាយ ។ ខ្ញុំញុំាងប្រជុំជនឲ្យកើតសង្វេគ ហើយសរសើរព្រះលោកនាយកថ្វាយបង្គំព្រះសម្ពុទ្ធ ហើយបែរមុខទៅកាន់ទិសខាងកើតដើរចេញទៅ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានសរសើរព្រះសម្ពុទ្ធខ្ញុំមិនដែលស្គាល់ទុគ្គតិនេះ ជាផលនៃការសរសើរ ។ ក្នុងកប្បទី ៩០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិឈ្មោះ សម្មុខាថវិករាជ ទ្រង់បរិ-

បូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិឈ្មោះបឋវីទុន្ទុភិរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៨ អំពីកប្បនេះ ខ្ញុំកើតជាក្សត្រឈ្មោះឱភាសរាជជាស្តេចចក្រពត្តិ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៧ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្រពត្តិ ឈ្មោះសរិតច្ឆេទនរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៦ ខ្ញុំកើតជាស្តេចចក្រពត្តិឈ្មោះអគ្គិនិព្វាបនរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៥ ខ្ញុំកើតជាស្តេចចក្រពត្តិឈ្មោះវាតសមរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៤ ខ្ញុំកើតជាស្តេចចក្រពត្តិឈ្មោះ គតិបច្ឆេទនរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៣ ខ្ញុំកើតជាស្តេចចក្រពត្តិឈ្មោះ រតនបជ្ជលរាជ បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨២ ខ្ញុំកើតជាស្តេចចក្រពត្តិឈ្មោះបទវិក្កមនរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨១ ខ្ញុំកើតជាស្តេចចក្រពត្តិឈ្មោះវិលោកនរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។

ក្នុងកប្បទី ៨០ ខ្ញុំកើតជាស្តេចចក្រពត្តិឈ្មោះ គិរិសារាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈសម្រេចអរហត្តហើយ កាលភិក្ខុទាំងឡាយសួរថា អាវុសោនៅក្មេងណាស់ បួសដោយការសង្វេគក្នុងអ្វី កាលទឹងព្រះអរហតហើយ ដោយអាងដល់និមិត្តដែលចង្អុលបង្ហាញដល់ហេតុ ឲ្យលោកបព្វជ្ជាបានពោលគាថានេះថា

ខ្ញុំឃើញមនុស្សចាស់ជរា ឈឺចាប់ ប្រកបដោយទុក្ខទាំងឃើញមនុស្សដល់នូវការអស់ទៅនៃអាយុស្លាប់ហើយ ហេតុនោះខ្ញុំលះបង់កាមជាទីត្រេកអរនៃចិត្ត ហើយចេញបួស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជិណ្ណំ** សេចក្តីថា ដែលជរាគ្របសង្កត់ គឺដល់ព្រមដោយសភាវៈ មានធ្មេញបាក់ សក់ស្កូវ និងភាពជាអ្នកមានស្បែកជ្រីវជ្រួញជាដើម ។ បទថា **ទុក្ខិតំ** បានដល់ ដល់នូវការលំបាកដែលសន្មតថាជាទុក្ខ ។ ក្នុងបទថា **ព្យាធិតំ** ស្មើគ្នានឹង **គិលានំ** ប្រែថា អ្នកឈឺ ។ ក្នុងទីនេះកាលពោលថា **ព្យាធិតំ** សំដៅដល់ជួបនូវសេចក្តីទុក្ខ ។ បទថា **ទុក្ខិតំ** មានអត្ថប្រាប់ដល់ភាពជាអ្នកមិនឈឺធ្ងន់របស់បុគ្គលដែលដល់នូវទុក្ខ

---

១-ក្នុងអបទានជា សម្មុខាថវិកត្ថេរ ។

នោះ ។ បទថា **មតំ** បានដល់ អ្នកដែលស្លាប់ហើយ ព្រោះធ្វើកាលកិរិយាហើយ រមែងឈ្មោះថាដល់នូវការអស់ទៅ ការសូន្យទៅ ការបែកធ្លាយទៅនៃអាយុ ដូច្នោះ ទើបលោកពោលថា **គតមាយុសង្ខយំ** មនុស្សដល់នូវការអស់ទៅនៃអាយុ ដូច្នេះ ។ ព្រោះហេតុនោះ គឺព្រោះហេតុដែលមនុស្សចាស់ មនុស្សឈឺ និងមនុស្សស្លាប់ លោកបានឃើញហើយ បានដល់ ព្រោះហេតុដែលលោកដល់នូវការសង្វេគថា ឈ្មោះថា ការចាស់ជាដើមនេះ មិនមានចំពោះដល់សត្វទាំងនេះប៉ុណ្ណោះ ដោយពិត មានទូទៅដល់សព្វសត្វ ព្រោះដូច្នោះ សូម្បីខ្ញុំក៏មិនកន្លងនូវការចាស់ជាដើមបានឡើយ ។

បទថា **និក្ខមិត្វាន** បានដល់ ចេញហើយ បាលីក៏យ៉ាងនេះដូចគ្នា ។ សេចក្តីថា ចេញចាកផ្ទះដោយបំណងនឹងបួស ។

បទថា **បព្វជឹ** សេចក្តីថា ចូលដល់បព្វជ្ជាក្នុងសាសនារបស់ព្រះសាស្តា ។

បទថា **បហាយ កាមានិ មនោរមានិ** សេចក្តីថា លះវត្ថុកាមដែលមានឈ្មោះថា **មនោរមា** ព្រោះធ្វើចិត្តរបស់បុគ្គលដែលមិនប្រាសចាករាគៈឲ្យត្រេកអរដោយភាពជាវត្ថុគួរប្រាថ្នា គួរស្រឡាញ់ជាដើម អធិប្បាយថា លះនូវឆន្ទរាគៈដែលទាក់ទងដោយវត្ថុកាមនោះកាត់ផ្តាច់ដោយអរិយមគ្គ គឺដោយការមិនសម្លឹង ។ គាថានេះបានជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈដោយមុខ គឺការចង្អុលបង្ហាញដល់ការលះកាមទាំងឡាយ ។ ព្រះថេរៈអង្គនេះកើតសមញ្ញានាមថា **មាណវ** ព្រោះលោកបួសក្នុងកាលជាមាណព គឺកំលោះ

ដូច្នេះឯង ។

## អដ្ឋកថា មាណវត្ថេរគាថា ចប់

## សុយាមនត្ថេរគាថា

[ ៧៥ ] កាមច្ឆន្ទៈ ព្យាបាទៈ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ វិចិកិច្ឆា រមែង មិនមានដល់ភិក្ខុ ដោយសព្វគ្រប់ ។

*សុយាមនត្ថេរ ។*

## អដ្ឋកថា

## សុយាមនត្ថេរគាថា

[ ៧៥ ] គាថារបស់ព្រះសុយាមនត្ថេរ មានពាក្យផ្ដើមថា **កាមច្ឆន្ទោ ច ព្យាបាទោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

កុលបុត្តនេះក៏មានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យជាច្រើនទុកក្នុងភពនោះៗ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថា វិបស្សី កុលបុត្តនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងធញ្ញវតីនគរ ចម្រើនវ័យហើយសម្រេចការសិក្សាក្នុងសិប្បសាស្ត្ររបស់ពួកព្រាហ្មណ៍ បានជាអាចារ្យបង្រៀនមន្តដល់ពួកព្រាហ្មណ៍ ។ ដោយសម័យនោះ ព្រះមានព្រះភាគព្រះនាមថាវិបស្សីចូលទៅកាន់នគរធញ្ញវតីដើម្បីបិណ្ឌបាតមួយអន្លើដោយមហាភិក្ខុសង្ឃ ។ ព្រាហ្មណ៍ឃើញព្រះមានព្រះភាគមួយអន្លើដោយភិក្ខុទាំងឡាយ មានចិត្តជ្រះថ្លា និមន្តព្រះមានព្រះភាគទៅកាន់ផ្ទះរបស់ខ្លួន តាក់តែងអាសនៈក្រាលអាសនៈ រោយផ្កាលើអាសនៈថ្វាយហើយ ។ កាលព្រះសាស្ដាគង់លើអាសនៈនោះហើយ ក៏អង្គាសព្រះ

សាស្តា និងភិក្ខុសង្ឃឲ្យឆ្អែតស្កប់ស្កល់ដោយបណីតភោជន ហើយបូជាព្រះសាស្តាដែលសោយស្រេចហើយដោយផ្កានិងគ្រឿងក្រអូប ។ ព្រះសាស្តាទ្រង់ធ្វើអនុមោទនា ហើយចៀសចេញទៅ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវលោក ធ្វើបុណ្យទាំងឡាយហើយ អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ។ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនព្រាហ្មណ៍ម្នាក់ក្នុងនគរសាវត្ថី មានឈ្មោះថា សុយាមនៈ ។ សុយាមនព្រាហ្មណ៍ចម្រើនវ័យហើយ ជាអ្នកដល់នូវត្រើយនៃវេទ ជាអ្នកប្រកបទៅដោយការពិចារណាក្រៃលែង វៀសនូវការសេពកាមារម្មណ៍បែបអ្នកស្រុក មានអធ្យាស្រ័យបង្អោនទៅក្នុងឈាន មានសទ្ធាក្នុងកាលដែលព្រះមានព្រះភាគ យាងទៅនគរវេសាលី បួសហើយសម្រេចអរហត្តក្នុងខណៈដាក់កាំបិតកោរដល់សីសៈនោះឯងសមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

> គ្រានោះ ខ្ញុំបានកើតជាព្រាហ្មណ៍នៅក្នុងក្រុងធញ្ញវតី ជាអ្នកឈ្លាសក្នុងគម្ពីរលក្ខណៈសាស្ត្រ ឥតិហាសាស្ត្រ ព្រមទាំងនិឃណ្ឌុសាស្ត្រនិងកេដុភសាស្ត្រ ។ ជាអ្នកឈ្លាសក្នុងបទក្នុងវេយ្យាករណ៍ ក្នុងនិមិត្តបេះចប់ត្រៃវេទ បានបង្ហាញមន្តចំពោះពួកសិស្ស ។ ខ្ញុំតម្កល់ផ្កាឧប្បល ៥ កម្រង លើខ្នង ខ្ញុំមានប្រាថ្នាដើម្បីបូជានូវគ្រឿងបូជា ក្នុងការជួបជុំបិតានិងមាតា ។ វេលានោះ ព្រះមានព្រះភាគព្រះនាមវិបស្សីទ្រង់ជានរាសភៈ

មានភិក្ខុសង្ឃចោមរោម ទ្រង់ញុំាងទិសទាំងពួងឲ្យភ្លឺ ហើយ ស្តេចនិមន្តមក ។ ខ្ញុំបានក្រាលអាសនៈហើយនិមន្តព្រះមហាមុនី បានក្រាលផ្កានោះហើយនាំព្រះអង្គហួសទៅកាន់ផ្ទះរបស់ខ្លួន ។ អាមិសៈណាដែលខ្ញុំបានតម្កល់ទុកមានក្នុងផ្ទះរបស់ខ្ញុំ ខ្ញុំជ្រះថ្លាបានថ្វាយអាមិសៈនោះ ចំពោះព្រះសម្ពុទ្ធ ដោយដៃរបស់ខ្លួន ។ ខ្ញុំដឹងនូវកាលដែលព្រះសម្ពុទ្ធ ទ្រង់សោយរួចហើយ ក៏បានថ្វាយផ្កាមួយក្តាប់ ព្រះសព្វញ្ញុពុទ្ធធ្វើអនុមោទនារួចហើយឈមព្រះភក្ត្រទៅកាន់ទិសឧត្តរ និមន្តចេញទៅ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបុប្ផទាន ។ ក្នុងកប្បជាលំដាប់ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិឈ្មោះ វរទស្សនៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈ កាលសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផលដោយការចង្អុលដល់ការលះនីវរណៈជាប្រធាន ទើបពោលគាថានេះថា

កាមច្ឆន្ទៈ ព្យាបាទៈ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ វិចិកិច្ឆា រមែង

---

១-ក្នុងអបទានជាព្រះ កុសុមាសនិយត្ថេរ ។

មិនមានដល់ភិក្ខុ ដោយសព្វគ្រប់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាមច្ឆន្ទោ** បានដល់ ការពេញចិត្តក្នុងកាមទាំងឡាយ ឈ្មោះថា **កាមច្ឆន្ទ** ព្រោះជាកាមផង ជាការពេញចិត្តផង បានដល់ កាមរាគៈ តម្រេកក្នុងកាម ឯរាគៈទាំងអស់ ឈ្មោះថា **កាមច្ឆន្ទ** ក្នុងគាថានេះ ព្រោះលោកបំណងយករាគៈដែលត្រូវសម្លាប់ដោយមគ្គដ៏ប្រសើរ ដោយហេតុនោះទើបព្រះថេរៈពោលថា រមែងមិនមានដល់ភិក្ខុដោយសព្វគ្រប់ ដូច្នេះ អធិប្បាយថា ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា **កាម** ព្រោះអត្ថថា ជាទីតាំងនៃការប្រាថ្នា រាគៈដែលប្រព្រឹត្តទៅក្នុងកាមនោះ ឈ្មោះថា **កាមច្ឆន្ទ** ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈនិងអវិជ្ជានីវរណៈអាស្រ័យនូវកាមច្ឆន្ទនីវរណៈក្នុងអរូប ( ទើបកើតឡើង ) ដូច្នេះ ។

ដែលឈ្មោះថា **ព្យាបាទ** ព្រោះអត្ថថា ជាហេតុនៃការវិនាស គឺដល់នូវការស្អុយនៃចិត្ត បានដល់ អាឃាតដែលប្រព្រឹត្តទៅហើយ ដោយន័យជាដើមថា **អនត្ថំ មេ អចរិ** ជនឯណោះ បានប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់អាត្មាអញ ដូច្នេះ ។

ដែលឈ្មោះថា **ថីន** គឺភាពដែលចិត្តមិនគួរដល់ការងារ បានដល់ ការរួញរា មិនមានឧស្សាហៈ ។

ដែលឈ្មោះថា **មិទ្ធ** គឺភាពដែលកាយមិនគួរដល់ការងារ បានដល់ ដាច់នូវការត្រេកអរ ។

ថីនៈក្តី មិទ្ធៈក្តី ទាំង ២ យ៉ាង រួមហៅថា ថីនមិទ្ធៈ លោករួមគ្នា ព្រោះជាបដិបក្ខចំពោះការងាររួចគ្នា ។

ភាពដែលចិត្តរាយមាយ ឈ្មោះថា ឧទ្ធច្ចៈ គឺចិត្តត្រូវលើកឡើង គឺមិនស្ងប់ដោយធម៌ណា ធម៌នោះ ចាត់ជាការរាយមាយនៃចិត្ត បានដល់ ឧទ្ធច្ចៈ សូម្បីកុក្កុច្ចៈ គប្បីជ្រាបថា លោកកាន់យកហើយដោយសព្ទថា **ឧទ្ធច្ច** ក្នុងគាថានេះ ព្រោះកុក្កុច្ចៈនោះក៏ជាបដិបក្ខចំពោះការងាររួចគ្នា កុក្កុច្ចៈនោះមានការធ្វើឲ្យក្តៅក្រហាយជាខាងក្រោយជាលក្ខណៈ ព្រោះការក្តៅក្រហាយទាក់ទងដោយអំពើល្អ អំពើអាក្រក់ដែលមិនទាន់បានធ្វើ និងធ្វើហើយក៏វិលមកជាការក្តៅក្រហាយ ។

បទថា **វិចិកិច្ឆា** សេចក្តីថា ឈ្មោះថា វិចិកិច្ឆា ព្រោះជាហេតុឲ្យដល់សេចក្តីសង្ស័យថា យ៉ាងនេះឬហ្ន៎ មិនមែនយ៉ាងនេះឬហ្ន៎ ម្យ៉ាងទៀត ឈ្មោះថា វិចិកិច្ឆា ព្រោះកាលបុគ្គលពិចារណាសភាវធម៌ រមែងជាហេតុឲ្យសាំញ៉ាំ គឺលំបាក បានដល់ ការសង្ស័យដែលទាក់ទងដោយព្រះពុទ្ធជាដើម ។

បទថា **សព្វសោ** បានដល់ ដោយមិនមានចំណែកសេសសល់ ។

បទថា **ន វិជ្ជតិ** បានដល់ មិនមាន គឺព្រះថេរៈព្យាករអរហត្តផលដោយចន្លុលដល់អរហត្តផលថា កាមច្ឆន្ទៈ ព្យាបាទ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ និងវិចិកិច្ឆារមែងមិនមានដោយប្រការទាំងពួង ព្រោះភាពដែលកិលេសទាំងនោះដែលមគ្គដកឡើងបានអស់ហើយ កិច្ចដែលគប្បីធ្វើដទៃមិនមានដល់លោក ឬកិច្ចដែលលោកធ្វើហើយមិនមានផលតបស្នង ដូច្នេះ អធិប្បាយថា កាល

នីវរណៈទាំង ៥ ដែលលោកដកហើយដោយមគ្គ កិលេសទាំងពួង រមែង ឈ្មោះថា លោកដកឡើងបានផងដែរ ព្រោះតាំងនៅក្នុងទីជាមួយគ្នានឹងនីវ-រណៈនោះ ដោយហេតុនោះទើបលោកពោលថា ព្រះមានព្រះភាគទាំងអស់ នោះ បានលះនីវរណធម៌ទាំង ៥ ដែលជាឧបក្កិលេសរបស់ចិត្ត ដូច្នេះ ។

## អដ្ឋកថា សុយាមនត្ថេរគាថា ចប់

## សុសារទត្ថេរគាថា

[ ៧៦ ] ការឃើញនូវព្រះអរិយៈទាំងឡាយ មានអត្ថភាពរៀបចំល្អហើយ ជាការប្រពៃ ( ព្រោះថា ) សេចក្តីសង្ស័យរមែងដាច់ បញ្ញារមែងចម្រើនឡើង ព្រះអរិយៈទាំងនោះ រមែងធ្វើសូម្បីនូវជនពាលឲ្យជាបណ្ឌិតបាន ព្រោះហេតុនោះ ការសមាគមនៃសប្បុរសទាំងឡាយ ជាការប្រពៃ ។

សុសារទត្ថេរ ។

## អដ្ឋកថា

## សុសារទត្ថេរគាថា

[ ៧៦ ] គាថារបស់ព្រះសុសារទត្ថេរ មានពាក្យផ្តើមថា **សាធុ សុវិ-ហិតាន ទស្សនំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈ កុលបុត្តនេះ កើតក្នុងត្រកូលព្រាហ្មណ៍ សិក្សាសម្រេចក្នុងវិជ្ជាទាំងឡាយហើយ ឃើញទោសក្នុងកាមទាំងឡាយ លះយកវាសវិស័យហើយបួសជាតាបស សាងអាស្រមត្រង់ជាយព្រៃក្នុងហិមវន្តប្បទេស ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ព្រះនាមថាបទុមុត្តរៈ កាលទ្រង់អនុគ្រោះ ទើបទ្រង់ចូលទៅក្នុងពេលភិក្ខាចារ ។ កុលបុត្តនោះ ឃើញព្រះមានព្រះភាគអំពីចម្ងាយ មានចិត្តជ្រះថ្លា ក្រោកឡើងទទួល ទទួលបាត្រ ហើយ

ដាក់ផ្លែឈើដែលមានរសផ្អែម បង្អោនចូលទៅថ្វាយ ។ ព្រះមានព្រះភាគទទួលបាត្រនោះហើយ ទ្រង់ធ្វើអនុមោទនា ហើយចៀសចេញទៅ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ។ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ជាញាតិរបស់ព្រះធម្មសេនាបតី មានឈ្មោះថា សុសារទៈ ព្រោះជាអ្នកមានបញ្ញាតិច ។ ក្នុងកាលតមក ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះធម្មសេនាបតី មានសទ្ធា បួសហើយ ចម្រើនវិបស្សនាសម្រេចអរហត្ត ។ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំជាអ្នកស្វាធ្យាយមន្ត្រ ចងចាំមន្ត្រ ចេះចប់ត្រៃវេទនៅក្នុងអាស្រមជិតព្រៃហិមពាន្ត ។ ការបូជាភ្លើង របស់ខ្ញុំតែងមាន ខ្ញុំដាក់ផ្លែឈូកទាំងឡាយក្នុងកញ្ចប់ ហើយព្យួរលើចុងឈើ ។ ព្រះលោកវិទូព្រះនាម បទុមុត្តរៈ ទ្រង់គួរទទួលនូវគ្រឿងបូជា ទ្រង់មានប្រាថ្នានឹងស្រង់ខ្ញុំ ស្តេចនិមន្តទៅដើម្បីភិក្ខា ក៏ចូលមកកាន់សំណាក់នៃខ្ញុំ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បានថ្វាយផ្លែឈូកនោះចំពោះព្រះពុទ្ធ ព្រះសម្ពុទ្ធជាសាស្តាទ្រង់មានវណ្ណៈដូចមាស ទ្រង់ញុំាងបីតិខ្ញុំឲ្យកើត ទ្រង់នាំមកនូវសេចក្តីសុខដល់ខ្ញុំ ក្នុងបច្ចុប្បន្ន គួរទទួលនូវគ្រឿងបូជា ទ្រង់ឋិតនៅនាអាកាស ហើយសម្តែងគាថានេះថា កុលបុត្តនេះនឹងមិនទៅកាន់ទុគ្គតិអស់ ១ សែនកប្ប ដោយផលនៃការថ្វាយផ្លែឈូកនេះផង ដោយផលនៃការតម្កល់ទុកនូវចេតនានេះផង ។

ព្រោះកុសលមូលនោះឯង ខ្ញុំបានសោយសម្បត្តិទាំងឡាយ
ហើយបានដល់នូវព្រះនិព្វានជាឋានមិនញាប់ញ័រ ខ្ញុំលះបោល
ការឈ្នះនិងការចាញ់ ។ ក្នុងកប្បទី ៧០០ អំពីកប្បនេះ ខ្ញុំ
បានកើតជាស្តេចចក្កពត្តិ ឈ្មោះសុមង្គល ទ្រង់បរិបូណ៌ដោយ
កែវទាំង ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤
វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ
ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផលដោយការបង្អុលដល់អានិសង្សក្នុងការសេពគប់សប្បុរស បានពោលគាថានេះថា

ការឃើញនូវព្រះអរិយៈទាំងឡាយ មានអត្តភាពរៀបចំល្អ
ហើយជាការប្រពៃ ( ព្រោះថា ) សេចក្តីសង្ស័យរមែងដាច់
បញ្ញារមែងចម្រើនឡើង ព្រះអរិយៈទាំងនោះរមែងធ្វើសូម្បីនូវ
ជនពាលឲ្យជាបណ្ឌិតបាន ព្រោះហេតុនោះ ការសមាគមនៃ
សប្បុរសទាំងឡាយ ជាការប្រពៃ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សាធុ** បានដល់ ជាសេចក្តីល្អ អធិប្បាយថា ជាសេចក្តីចម្រើន ។ បទថា **សុវិហិតាន ទស្សនំ** សេចក្តីថា ការឃើញសប្បុរសទាំងឡាយដែលមានខ្លួនអប់រំល្អហើយ ដើម្បីងាយស្រួលក្នុងការចងគាថាទើបលោកលុបនិគ្គហិតចេញ ប្រកបសេចក្តីថា ការឃើញព្រះអរិយៈ

---

១-ក្នុងអបទានជាព្រះ ផលទាយកត្ថេរ ។

ទាំងឡាយដែលមានខ្លួនអប់រំល្អហើយដោយគុណ មានសីល ជាដើម ដែលសម្តែងនូវធម៌ ទុកដោយល្អ ដើម្បីអនុគ្រោះដល់អ្នកដទៃជាការល្អ ។ បទថា **ឧបស្សន្នំ** គប្បីជ្រាបថា ជាឧបមា ព្រោះសូម្បីការស្តាប់ជាដើម ក៏រាប់ថាមានឧបការៈច្រើន សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ ( ទុកក្នុងខុទ្ទកនិកាយឥតិវុត្តក ) ថា

ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា បរិបូណ៌ដោយសីល បរិបូណ៌ដោយសមាធិ បរិបូណ៌ដោយបញ្ញា បរិបូណ៌ដោយវិមុត្តិ បរិបូណ៌ដោយវិមុត្តិញាណទស្សនៈ ជាអ្នកទូន្មាន ពន្យល់ឲ្យដឹង សំដែងបញ្ជាក់ឲ្យឃើញងាយ ណែនាំ ធ្វើឲ្យអង់អាច ធ្វើឲ្យរីករាយ ( ក្នុងកុសលធម៌ ) អាចសំដែងនូវព្រះសទ្ធម្មបាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការជួបប្រទះនូវភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការស្តាប់នូវភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការចូលទៅរកភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការចូលទៅអង្គុយជិតភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការរឭកនូវភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការបួសតាមភិក្ខុទាំងនោះថា មាន

ឧបការៈច្រើនផង ដូច្នេះ ។

ម្យ៉ាងទៀត ក្នុងគាថានេះ លោកពោលនូវការឃើញ ( សប្បុរស ) តែម្យ៉ាង ព្រោះគុណសម្បត្តិក្រៅពីនេះ មានការឃើញជាមូល ។ បទថា **កង្ខា ឆិជ្ជតិ** ជាដើម ជាពាក្យប្រាប់ហេតុក្នុងការឃើញនោះ អធិប្បាយថា កាលការឃើញកល្យាណមិត្តបែបនោះមាន កុលបុត្តដែលប្រាថ្នា ការចេះដឹង ប្រាថ្នាប្រយោជន៍ រមែងចូលទៅរក រមែងចូលទៅអង្គុយជិត កល្យាណមិត្តទាំងនោះ រមែងសាកសួរបញ្ហាដោយន័យជាដើមថា បពិត្រលោកដ៏ចម្រើន អ្វីជាកុសល អ្វីជាអកុសល ដូច្នេះ ។ កល្យាណមិត្តទាំងនោះ រមែងបន្ទោបង់នូវសេចក្តីសង្ស័យ ក្នុងឋានៈដែលជាទីតាំងនៃសេចក្តីសង្ស័យមិនមែនតិចដល់បុគ្គលនោះបាន ដោយហេតុនោះ ទើបលោកពោលថា **កង្ខា ឆិជ្ជតិ** សេចក្តីសង្ស័យរមែងដាច់ ដូច្នេះ និងព្រោះហេតុនៃកល្យាណមិត្តទាំងនោះ កាលបន្ទោបង់សេចក្តីសង្ស័យនៃកុលបុត្តទាំងនោះបាន ដោយការសម្តែងធម៌ហើយ រមែងញុំាងនូវការឃើញប្រពៃក្នុងកម្មបថ និងញុំាងការឃើញប្រពៃក្នុងវិបស្សនាឲ្យកើតឡើងក្នុងចំណែកខាងដើម ដូច្នោះ ការដឹងរមែងចម្រើនដល់កុលបុត្តទាំងនោះ ។

ក្នុងកាលណា កុលបុត្តទាំងនោះ ចម្រើនវិបស្សនាហើយ ចាក់ធ្លុះនូវសច្ចៈទាំងឡាយ ក្នុងកាលនោះ វិចិកិច្ឆាមានវត្ថុ ១៦ និងមានវត្ថុ ៨ រមែងត្រូវកាត់ គឺត្រូវដកឡើង បញ្ញា គឺការដឹង រមែងចម្រើនដោយត្រង់ សប្បុរសទាំងឡាយ រមែងធ្វើពាលជនឲ្យជាបណ្ឌិតបាន ដូច្នេះ ។ បទថា **តស្មា** ជា

ដើម ជាពាក្យសរុប អធិប្បាយថា ព្រោះការឃើញសាធុជនទាំងឡាយ ជាហេតុកាត់សេចក្ដីសង្ស័យបាន ធ្វើនូវការដឹងឲ្យចម្រើនដុះដាល សប្បុរសទាំងឡាយរមែងធ្វើពាលជនឲ្យជាបណ្ឌិតបាន ព្រោះដូច្នោះ គឺដោយហេតុនោះ ការសមាគមជាមួយសប្បុរស គឺមនុស្សល្អ បានដល់ ព្រះអរិយៈទាំងឡាយទើបជាការល្អ គឺជាការប្រពៃ ដោយអត្ថថា ការសេពគប់សប្បុរសទាំងនោះ ជាការចម្រើនដោយប្រពៃ ដូច្នេះ ។

អដ្ឋកថា សុសារទត្ថេរគាថា ចប់

## បិយញ្ជហត្ថេរគាថា

[ ៧៧ ] កាលពួកសត្វកំពុងប៉ោងឡើង បណ្ឌិតតែងឱនលំទោន កាលពួកសត្វធ្លាក់ចុះ ( ដោយអំណាចកោសជ្ជៈ ) បណ្ឌិតតែងប្រឹងឡើង កាលពួកសត្វមិនបានអប់រំ ( ព្រហ្មចរិយធម៌ ) បណ្ឌិតតែងអប់រំ កាលពួកសត្វត្រេកអរ ( ក្នុងកាមគុណ ) បណ្ឌិតមិនត្រេកអរទេ ។

**បិយញ្ជហត្ថេរ ។**

## អដ្ឋកថា

## បិយញ្ជហត្ថេរគាថា

[ ៧៧ ] គាថារបស់ព្រះបិយញ្ជហត្ថេរ មានពាក្យផ្ដើមថា **ឧប្បតន្តេសុ និបតេ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនោះក៏មានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាវិបស្សី ក្នុងកប្បទី ៩១ រាប់អំពីភទ្ទកប្បនេះ កើតជារុក្ខទេវតាក្នុងព្រៃហិមពាន្ត ។ ទេវតានោះ អាស្រ័យត្រង់ញកភ្នំ ក្នុងកាលប្រជុំទេវតា ឈរខាងចុងបរិស័ទ ព្រោះជាអ្នកមានអានុភាពតិច ស្ដាប់ធម៌ហើយមានសទ្ធាក្នុងព្រះសាស្ដា ។ ថ្ងៃមួយ ឃើញផ្កាខ្សាប់ក្បែរឆ្នេរស្ទឹងគង្គាមានពណ៌ស្អាតបរិសុទ្ធគួរជាទីត្រេកអរ រឭកដល់គុណរបស់ព្រះសាស្ដាថា គុណរបស់ព្រះសាស្ដាស្អាតបរិសុទ្ធ ក្រៃលែងជាងផ្កាខ្សាប់នេះ ជាព្រះ

គុណមិនមានទីបំផុត មិនមានប្រមាណ ដូច្នេះ ។ ទេវតានោះប្រារព្ធដល់គុណរបស់ព្រះសាស្តាយ៉ាងនេះហើយ មានចិត្តជ្រះថ្លា ដោយបុញ្ញកម្មនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះកើតក្នុងត្រកូលនៃស្តេចលិច្ឆវីក្នុងនគរវេសាលី ចម្រើនវ័យហើយ បានជាអ្នកចម្បាំងមិនធ្លាប់ចាញ់ក្នុងសង្គ្រាមប្រាកដនាមថា បិយញ្ជហ ព្រោះជាទីខ្លាចរអានៃសត្រូវទាំងឡាយ ។

ក្នុងគ្រាដែលព្រះមានព្រះភាគ ទ្រង់យាងទៅកាន់នគរវេសាលី ព្រះរាជកុមារមានសទ្ធាបួសហើយនៅក្នុងព្រៃចម្រើនវិបស្សនា សម្រេចអរហត្តហើយសមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំនៅនាភ្នំហិមពាន្ត ឃើញផ្នូកខ្សាច់ដ៏ល្អក្នុងចន្លោះភ្នំ ខ្ញុំរឭកនូវព្រះសម្ពុទ្ធដ៏ប្រសើរថា ការប្រៀបធៀបក្នុងញាណ ( របស់ព្រះសាស្តា ) មិនមានឡើយ សង្គ្រាមរបស់ព្រះសាស្តា ក៏មិនមានដែរ ព្រះសាស្តាបានជ្រាបនូវធម៌ទាំងពួង ទ្រង់ស៊ប់សួនដោយញាណ ។ បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមថ្វាយបង្គំចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសដ៏ឧត្តមខ្ញុំសូមថ្វាយបង្គំព្រះអង្គ សភាពដទៃស្មើដោយញាណរបស់ព្រះអង្គមិនមានឡើយ មានតែញាណរបស់ព្រះអង្គ ទើបឧត្តមជាកំណត់ ។ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាក្នុងញាណហើយ ក៏បានទៅរីករាយក្នុងឋានសួគ៌អស់ ១ កប្ប ខ្ញុំបានកសាងកុសល ក្នុងកប្បដ៏សេស ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាល

នោះ ព្រោះហេតុដែលខ្ញុំបានទូវសេចក្តីសម្គាល់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្តីសម្គាល់ក្នុងញាណ ។ ក្នុងកប្បទី ៧៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១ ជាតិ ព្រះនាម បុឡិនបុប្ផិយៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផល ដោយការសម្តែងអត្ថថា បដិបទានៃព្រះអរិយៈទាំងឡាយចែកដាច់ពីបដិបទា របស់អន្ធពាលបុថុជ្ជន ទើបពោលគាថាដូច្នេះថា

កាលពួកសត្វកំពុងប៉ោងឡើង បណ្ឌិតតែងឱនលំទោន កាលពួកសត្វធ្លាក់ចុះ ( ដោយអំណាចកោសជ្ជៈ ) បណ្ឌិតតែងប្រឹងឡើង កាលពួកសត្វមិនបានអប់រំ ( ព្រហ្មចរិយធម៌ ) បណ្ឌិតតែងអប់រំ កាលពួកសត្វត្រេកអរ ( ក្នុងកាមគុណ ) បណ្ឌិតមិនត្រេកអរទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧប្បតន្តេសុ** បានដល់ លើកខ្លួនឲ្យខ្ពស់ គឺកាលសត្វទាំងឡាយ ប៉ោងឡើងដោយលើកខ្លួនឡើងដោយកិលេស មាន មានះ ឧទ្ធច្ចៈ ថម្ភៈនិងសារម្ភៈជាដើម ។

---

១-ក្នុងអបទានជាព្រះ ញាណសញ្ញកត្ថេរ ។

បទថា **ឆិបតេ** បានដល់ គប្បីបង្អោនខ្លួន គឺគប្បីជាអ្នកមានការប្រព្រឹត្តឱនលំទោន ដោយវៀរបាបធម៌ទាំងនោះសព្វយ៉ាង ។

បទថា **ឆិបតន្តេសុ** បានដល់ ធ្លាក់ចុះ គឺកាលសត្វទាំងឡាយ សាបសូន្យចាកគុណ ព្រោះមានអធិមុត្តិទាបនិងព្រោះការខ្ជិលច្រអូស ។ បទថា **ឧប្បតេ** បានដល់ គប្បីលើកឡើង គឺគប្បីឧបការៈក្នុងគុណធម៌ ដោយធ្វើឲ្យមានអធិមុត្តិប្រណីតនិងឲ្យប្រារព្ធព្យាយាម ។

ម្យ៉ាងទៀត បទថា **ឧប្បតន្តេសុ** បានដល់ ប៉ោងឡើង គឺកាលកិលេសរំលៀកខ្លួនឡើងមកដើម្បីចោមរោម ។

បទថា **ឆិបតេ** បានដល់ គប្បីឲ្យធ្លាក់ទៅ ដោយការពិចារណាតាមសមគួរ ដោយវិធីដែលកិលេសទាំងនោះមិនកើតឡើង ដោយកម្លាំងនៃការពិចារណា គឺសង្កត់សង្កិនផង ដកឡើងផង ។

បទថា **ឆិបតន្តេសុ** បានដល់ ធ្លាក់ទៅដោយជុំវិញ គឺកាលសេចក្តីព្យាយាម និងការព្យាយាមទន់ខ្សោយ ព្រោះធ្វើទុកក្នុងចិត្តដោយមិនជាឧបាយ ឬកាលធម៌ គឺសមថៈនិងវិបស្សនាតាមដែលប្រារព្ធហើយ វិនាសទៅ ព្រោះមិនដាក់ចិត្តដោយឧបាយ និងព្រោះការប្រកបសេចក្តីព្យាយាមធូរថយ ។

បទថា **ឧប្បតេ** សេចក្តីថា គប្បីរឭកធម៌ទាំងនោះឡើងដោយការដាក់ចិត្តដោយឧបាយ និងដោយបន្ថែមការប្រារព្ធព្យាយាម គឺឲ្យកើតផងឲ្យចម្រើនផង ។

បទថា **វសេ អវសមានេសុ** សេចក្តីថា កាលសត្វទាំងឡាយមិននៅ

ដូចអ្នកប្រព្រឹត្តមគ្គព្រហ្មចរិយៈ និងមិនទៅដូចព្រះអរិយៈ ខ្លួនឯងគប្បីទៅបែបមគ្គព្រហ្មចរិយៈ និងនៅបែបព្រះអរិយៈនោះ ម្យ៉ាងទៀត ដោយអត្ថថា កាលព្រះអរិយៈទាំងឡាយមិនទៅដូចអ្នកមានកិលេស គឺមិនទៅដូចអ្នកមានគូ គឺមានបុត្ត មានភរិយា ខ្លួនឯងគួរនៅដូចព្រះអរិយៈ ។

បទថា **រមមានេសុ នោ រមេ** សេចក្តីថា កាលសត្វទាំងឡាយត្រេកអរដោយការត្រេកអរក្នុងកាមគុណ ដោយការត្រេកអរក្នុងកិលេស ខ្លួនឯងមិនគប្បីត្រេកអរ គឺមិនគប្បីពេញចិត្តយ៉ាងនោះ ម្យ៉ាងទៀត កាលព្រះអរិយៈទាំងឡាយត្រេកអរ ដោយការត្រេកអរក្នុងឈានជាដើមដែលប្រាសចាកអាមិស ខ្លួនឯងក៏គប្បីត្រេកអរយ៉ាងនោះ តែមិនគប្បីត្រេកអរ គឺមិនគប្បីអភិរម្យ ដោយប្រការដទៃចាកការត្រេកអរក្នុងឈានជាដើមនោះសូម្បីម្តងម្កាល ។

## អដ្ឋកថា បិយញ្ជហត្ថេរគាថា ចប់

## ហត្ថារោហបុត្តត្ថេរគាថា

[ ៧៨ ] ចិត្តនេះក្នុងកាលមុន បានត្រាច់ទៅកាន់ចារិក តាមសេចក្តីប្រាថ្នា តាមចំណង់ តាមសេចក្តីស្រួល ថ្ងៃនេះខ្ញុំនឹងផ្ចាញ់ផ្ចាល់ចិត្តនោះដោយឧបាយ ដូចជាហ្មដំរីអ្នកកាន់កង្វេរ សង្កត់សង្កិនដំរីដែលចុះប្រេង ។

*ហត្ថារោហបុត្តត្ថេរ ។*

## អដ្ឋកថា

## ហត្ថារោហបុត្តត្ថេរគាថា

[ ៧៨ ] គាថារបស់ព្រះហត្ថារោហបុត្តត្ថេរ មានពាក្យផ្តើមថា **ឥទំ បុរេ ចិត្តមចារិ ចារិកំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនោះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាវិបស្សី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ ឃើញព្រះសាស្តាចោមរោម ដោយភិក្ខុសង្ឃទាំងឡាយ ទ្រង់ចេញអំពីវិហារ ធ្វើការបូជាដោយផ្កាទាំងឡាយ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ធ្វើប្រទក្សិណហើយ ចៀសចេញទៅ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ។ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលនៃហ្មដំរីក្នុងនគរសាវត្ថី ដល់

នូវភាពជាអ្នកជំនិះក្តីហើយ សម្រេចក្នុងហត្ថិសិប្បសាស្ត្រ ថ្ងៃមួយកាលទូន្មានដំរី ទៅកាន់ផ្ទះស្ទឹង ដោយហេតុសម្បត្តិជាស់តឿនគិតថា ការទូន្មានដំរីនេះមានប្រយោជន៍អ្វីដល់អញ ការទូន្មានខ្លួននោះឯងប្រសើរជាង ដូច្នេះ ទើបចូលទៅគាល់ព្រះមានព្រះភាគ ស្តាប់ធម៌ហើយ មានសទ្ធាបួសហើយ រៀនកម្មដ្ឋានដែលសមគួរដល់ចរិត ចម្រើនវិបស្សនាសង្កត់សង្កិនចិត្ត ដែលស្ទុះទៅខាងក្រៅកម្មដ្ឋានបានដោយកង្វេរ គឺការពិចារណា ព្រោះបានអប់រំមកអស់កាលដ៏យូរ ដូចហត្ថាចារ្យទូន្មានដំរីចុះប្រេងដ៏ប្រសើរ ជាដំរីកាចបាន ដោយកង្វេរ ដូច្នោះ ទើបពោលគាថានេះថា

ចិត្តនេះក្នុងកាលមុនបានត្រាច់ទៅកាន់ចារិក តាមសេចក្តីប្រាថ្នា
តាមចំណង់ តាមសេចក្តីស្រួល ថ្ងៃនេះខ្ញុំនឹងផ្ចញ់ផ្ចាល់ចិត្តនោះ
ដោយឧបាយ ដូចជាហ្មដំរីអ្នកកាន់កង្វេរ សង្កត់សង្កិនដំរីដែល
ចុះប្រេង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥទំ** ព្រះថេរៈពោលទុក ព្រោះចិត្តដែលនឹងពោលតទៅប្រចក្សដល់ខ្លួន ។

បទថា **បុរេ** បានដល់ ក្នុងកាលមុនអំពីការសង្កត់សង្កិនចិត្ត ។ បទថា **អចារិ** បានដល់ អន្ទោលទៅហើយ គឺវិលទៅហើយក្នុងអារម្មណ៍ផ្សេងៗ ព្រោះភាពដែលចិត្តមិនតាំងមាំ ។

បទថា **ចារិកំ** បានដល់ ត្រាច់ទៅតាមប្រាថ្នា ដោយហេតុនោះ ទើបព្រះថេរៈពោលថា ចិត្តនេះក្នុងកាលមុន បានត្រាច់ទៅកាន់ចារិកតាមសេចក្តី

ប្រាថ្នា តាមចំណង់ តាមសេចក្តីស្រួល ដូច្នេះ ។ បទថា **តំ** បានដល់ ចិត្ត នោះ ។ បទថា **អជ្ជ** បានដល់ ក្នុងកាលឥឡូវនេះ ។

បទថា **និគ្គហិស្សាមិ** បានដល់ អាត្មាអញនឹងសង្កត់សង្កិន គឺធ្វើឲ្យអស់ព្យសន៍ ។

បទថា **យោនិសោ** ស្មើគ្នានឹង **ឧបាយេន** ប្រែថា ដោយឧបាយ ។ សួរថា ដូចអ្វី ឆ្លើយថា ដូចហ្មដំរីដែលឈ្លាស សង្កត់សង្កិនដំរីចុះប្រេងដោយកង្វេរដូច្នោះ លោកអធិប្បាយដូច្នេះថា ឈ្មោះថា ចិត្តរបស់អាត្មាអញនេះ មុនអំពីនេះ បានត្រាច់ទៅអស់កាលយូរតាមប្រាថ្នា ដោយប្រការដែលចិត្តនោះប្រាថ្នាដើម្បីត្រេកអរក្នុងអារម្មណ៍មានរូបជាដើម តាមចំណង់ ដោយអំណាចនៃអារម្មណ៍ដែលចិត្តត្រូវការ ឈ្មោះថា តាមសេចក្តីស្រួល ព្រោះអន្ទោលទៅតាមអារម្មណ៍ ដែលឲ្យកើតសេចក្តីសុខ សូម្បីឥឡូវនេះ អញនឹងផ្ចាញ់ផ្ចាលចិត្តនេះ ដោយយោនិសោមនសិការ ដូចហ្មដំរីដែលឈ្លាស ពោលគឺនាយហត្ថាចារ្យសង្កត់សង្កិនដំរីដែលចុះប្រេងដោយកង្វេរ ដូច្នោះ ។ ព្រះថេរៈពោលយ៉ាងនេះរឿយៗ ចម្រើនវិបស្សនាធ្វើឲ្យជាក់ច្បាស់អរហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះមានព្រះភាគ ព្រះនាមវិបស្សី មានវណ្ណៈដូចមាសទ្រង់គួរ
ទទួលនូវទក្ខិណាទាន មានពួកសាវ័កចោមរោម ស្តេចចេញ
អំពីអារាម ។ ខ្ញុំឃើញព្រះពុទ្ធដ៏ប្រសើរ ជាសព្វញ្ញូ មិនមាន
អាសវៈក៏មានចិត្តជ្រះថ្លា មានចិត្តសោមនស្សបានបូជាផ្កាដែល

ស្ដេចនិមន្តទៅ ។ ខ្ញុំជាអ្នករីករាយ មានចិត្តរីករាយចំពោះព្រះសម្ពុទ្ធជាតាទិបុគ្គល ប្រសើរជាងសត្វជើងពីរ ទើបថ្វាយបង្គំព្រះតថាគតម្ដងទៀត ដោយចិត្តជ្រះថ្លានោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៤១ អំពីកប្បនេះ ខ្ញុំកើតជាក្សត្រចក្រពត្តិឈ្មោះ វរុណៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

គាថានោះឯង បានជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈដូច្នេះឯង ។

## អដ្ឋកថា ហត្ថារោហបុត្តត្ថេរគាថា ចប់

---

១-ក្នុងអបទានជាព្រះ គន្ធបុប្ផិយត្ថេរ ។

## មេណ្ឌសិរត្ថេរគាថា

[ ៧៩ ] កាលខ្ញុំមិនទាន់បាន ( ញាណ ) តែងអន្ទោលទៅកាន់សង្សារ អស់ជាតិមិនតែមួយទេ គំនរនៃសេចក្តីទុក្ខរបស់ខ្ញុំ ដែលទទួលរងហើយនោះ ជាគំនរទុក្ខប្រាសចេញទៅហើយ ។

មេណ្ឌសិរត្ថេរ ។

## អដ្ឋកថា

## មេណ្ឌសិរត្ថេរគាថា

[ ៧៩ ] គាថារបស់ព្រះមេណ្ឌសិរត្ថេរ មានពាក្យផ្តើមថា **អនេក-ជាតិសំសារំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏មានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងកប្បទី ៩១ រាប់ថយក្រោយអំពីកប្បនេះ កើតក្នុងត្រកូលព្រាហ្មណ៍ចម្រើនវ័យហើយ លះនូវកាមវិស័យហើយបួសជាតាបសនៅក្នុងព្រៃហិមពាន្ត មួយអន្លើដោយឥសីជាច្រើន ឃើញព្រះបរមសាស្តា មានចិត្តជ្រះថ្លា ឲ្យពួកឥសីនាំផ្កាឈូកមក ធ្វើការបូជាព្រះសាស្តាដោយផ្កា ទូន្មានសាវ័កទាំងឡាយក្នុងអប្បមាទបដិបទា ធ្វើកាលកិរិយាហើយ កើតក្នុងទេវលោក អន្ទោលទៅមកក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលគហបតីនគរសាកេត បានឈ្មោះថាមេណ្ឌ-

សិរ ព្រោះមានក្បាលដូចក្បាលពពែ ។

កាលព្រះមានព្រះភាគគង់នៅក្នុងអញ្ជនវិហារ ក្នុងក្រុងសាកេត ចូលទៅគាល់ព្រះបរមសាស្តា កើតនូវសទ្ធាបព្វជ្ជាហើយចម្រើនសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន បានជាអ្នកមានអភិញ្ញា ៦ ហើយ ។ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

មានភ្នំ ១ ឈ្មោះគោតមៈ នៅព្រៃហិមពាន្ត ដេរដាសដោយឈើផ្សេងៗ ជាទីអាស្រ័យនៅនៃពួកភូតច្រើន ។ ខ្ញុំបានសាងអាស្រមត្រង់កណ្តាលភ្នំនោះ មានពួកសិស្សចោមរោម តែងនៅក្នុងអាស្រម( ខ្ញុំបបួលពួកសិស្សថា ) សូមពួកសិស្សមកកាន់សំណាក់យើង សូមពួកសិស្សនាំផ្កាឈូកមកឲ្យយើងៗ នឹងធ្វើពុទ្ធបូជា ចំពោះព្រះពុទ្ធជាតាទិបុគ្គល ទ្រង់ប្រសើរជាងសត្វជើងពីរ ។ ពួកសិស្សទាំងនោះ ទទួលពាក្យខ្ញុំថា យ៉ាងហ្នឹងហើយៗ បានយកផ្កាឈូកមកឲ្យខ្ញុំ ខ្ញុំធ្វើនិមិត្តតាមទំនងដូច្នោះហើយ បានបង្អោនថ្វាយដល់ព្រះពុទ្ធជាម្ចាស់ ។ ក្នុងកាលនោះ ខ្ញុំបានប្រជុំពួកសិស្ស ហើយប្រៀនប្រដៅដោយប្រពៃថា អ្នកទាំងឡាយ ចូរកុំប្រមាទ សេចក្តីមិនប្រមាទ ជាគុណនាំមកនូវសេចក្តីសុខ ។ ខ្ញុំនោះ បានប្រៀនប្រដៅពួកសិស្សដែលជាអ្នកគួរដល់ពាក្យនេះហើយ ខ្ញុំប្រកបក្នុងអប្បមាទគុណ ក៏បានធ្វើមរណកាលក្នុងពេលនោះ ។ ក្នុងកប្បទី

៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៥១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិព្រះនាមជលុត្តមៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលរឭកដល់ខន្ធបញ្ចកៈ ដែលខ្លួនធ្លាប់អាស្រ័យមកក្នុងកាលមុនរបស់ខ្លួន ទើបពោលគាថានេះថា

កាលខ្ញុំមិនទាន់បាន ( ញាណ ) តែងអន្ទោលទៅកាន់សង្សារអស់ជាតិមិនតែមួយទេ គំនរនៃសេចក្តីទុក្ខរបស់ខ្ញុំដែលទទួលរងហើយនោះ ជាគំនរទុក្ខប្រាសចេញទៅហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនេកជាតិសំសារំ** សេចក្តីថា សង្សារវដ្តនេះរាប់ចំនួនច្រើនសែនជាតិ បទនេះប្រើជាឯកវចនៈទុតិយាវិភត្តិ ព្រោះសំដៅដល់កាលដ៏វែងឆ្ងាយ ។

បទថា **សន្ធាវិស្សំ** បានដល់ ស្ទុះទៅហើយ គឺវិលទៅមកៗ ដោយអំណាចនៃចុតិនិងបដិសន្ធិ ។

បទថា **អនិព្វិសំ** បានដល់ កាលមិនជួប គឺមិនបានទូវញាណជាគ្រឿងបញ្ឈប់វដ្តៈនោះ ។

---

១-ក្នុងអបទានជាព្រះ បទុមបូជកត្ថេរ ។

បទថា **តស្ស មេ** បានដល់ ខ្ញុំដែលអន្ទោលទៅយ៉ាងនេះ ។

បទថា **ទុក្ខជាតស្ស** បានដល់ ទុក្ខដែលកើតដោយអំណាចនៃជាតិជាដើម ម្យ៉ាងទៀត បានដល់ មានទុក្ខជាសភាវៈ ដោយអំណាចនៃជាតិជាទុក្ខ ៣ យ៉ាង ។

បទថា **ទុក្ខក្ខន្ធោ** បានដល់ គំនរនៃទុក្ខ មានកម្មវដ្ត កិលេសវដ្ត និងវិបាកវដ្តជាដើម ។

បទថា **អបរទ្ធោ** សេចក្តីថា តាំងអំពីបានសម្រេចអរហត្តមគ្គ ក៏នឹងមិនវិលទៅ មិនចុតិ មិនកើត ។ ម្យ៉ាងទៀត បាឋៈថា **អបរជ្ឈោ** ដូច្នេះក៏មាន អធិប្បាយថា មិនប្រាសចាកសេចក្តីសម្រេច គឺមិនទៅប្រាសចាកហេតុនៃការដកកិលេស ។ ពាក្យដែលជាគាថានេះឯង ជាការព្យាករណ៍អរហត្តផលរបស់ព្រះថេរៈ ។

## អដ្ឋកថា មេណ្ឌសិរត្ថេរគាថា ចប់

## រក្ខិតត្ថេរគាថា

[ ៨០ ] រាគៈទាំងពួងខ្ញុំលះចោលហើយ ទោសៈទាំងពួងខ្ញុំក៏ដកចោលហើយ មោហៈទាំងពួងរបស់ខ្ញុំក៏ប្រាសចេញហើយ ខ្ញុំជាបុគ្គលត្រជាក់រលត់ទុក្ខហើយ ។

រក្ខិតត្ថេរ ។

## អដ្ឋកថា

## រក្ខិតត្ថេរគាថា

[ ៨០ ] គាថារបស់ព្រះរក្ខិតត្ថេរ មានពាក្យផ្តើមថា **សព្វោ រាគោ បហីនោ មេ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កើតក្នុងផ្ទះនៃត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ ស្តាប់ទេសនារបស់ព្រះសាស្តា មានចិត្តជ្រះថ្លា បានធ្វើនូវការសរសើរ ដោយប្រារព្ធព្រះញាណក្នុងទេសនា ព្រះសាស្តាទ្រង់ប្រមើលមើលការជ្រះថ្លានៃចិត្តរបស់កុលបុត្តនោះហើយ ទ្រង់ព្យាករថា ក្នុងទីបំផុតនៃមួយសែនកប្បអំពីកប្បនេះ អ្នកនឹងបានជាសាវ័កឈ្មោះរក្ខិតៈ របស់ព្រះសម្មាសម្ពុទ្ធព្រះនាមថាគោតម កុលបុត្តនោះស្តាប់ព្យាករនោះហើយមានចិត្តជ្រះថ្លាពន់ប្រមាណ ធ្វើបុណ្យជាច្រើនអន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រ-

កុលសក្យៈក្នុងទេវទហនិគម មាននាមថារក្ខិតៈ ។ កុលបុត្តនេះជាព្រះរាជកុមារមួយអង្គដែលបួសក្នុងចំនួនព្រះរាជកុមារ ៥០០ ដែលពួកសក្យៈ និងកោលិយៈទាំងឡាយថ្វាយដើម្បីជាបរិវាររបស់ព្រះមានព្រះភាគ ។ ព្រះរាជកុមារទាំងនោះ ត្រូវសេចក្តីអផ្សុកគ្របសង្កត់ព្រោះមិនបានបួសដោយសេចក្តីសង្វេគ ក្នុងកាលព្រះសាស្តានាំទៅកាន់ស្រះកុណាល ទ្រង់ប្រកាសទោសក្នុងកាមទាំងឡាយ ដោយទ្រង់ចង្អុលឲ្យឃើញទោសរបស់មាតុគ្រាមក្នុងទេសនាដែលពោលអំពីកុណាលជាតក ហើយទ្រង់ឲ្យប្រកបក្នុងកម្មដ្ឋាន ពេលនោះព្រះរក្ខិតត្ថេរនេះខ្វល់ខ្វាយក្នុងកម្មដ្ឋានចម្រើនវិបស្សនា សម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ជាច្បងក្នុងលោក ទ្រង់ជានាសកៈ ទ្រង់សម្តែងធម៌ជាចំណែកព្រះនិព្វានដល់ពួកជនច្រើន ។ កាលនោះ ខ្ញុំបានស្តាប់នូវព្រះពុទ្ធដីការបស់ព្រះអង្គនោះដែលទ្រង់ពោលដោយវាចាដ៏អង់អាច ខ្ញុំផ្គងអញ្ជលី មានចិត្តនឹងក្នុងអារម្មណ៍តែមួយ ។ សមុទ្រប្រសើរជាងស្ទឹងទាំងឡាយ ភ្នំព្រះសុមេរុប្រសើរជាងភ្នំទាំងឡាយ យ៉ាងណាមិញ ជនណាប្រព្រឹត្តដោយអំណាចចិត្តជននោះមិនដល់មួយចំណិត នៃពុទ្ធញាណឡើយ ក៏យ៉ាងនោះដែរ ។ លុះព្រះសម្ពុទ្ធជាឥសីប្រកបដោយសេចក្តីករុណា ទ្រង់បញ្ឈប់នូវធម្មវិធី គង់ក្នុងកណ្តាលជំនុំភិក្ខុសង្ឃ ហើយសម្តែងនូវគាថាទាំងឡាយនេះថា

ជនណាបានសរសើរ នូវញាណនៃព្រះពុទ្ធ ជាលោកនាយក ជននោះឯង រមែងមិនទៅកាន់ទុគ្គតិ អស់ ១ សែនកប្ប នឹងដុតបំផ្លាញកិលេសទាំងឡាយ មានចិត្តនឹងក្នុងអារម្មណ៍តែមួយ មានចិត្តតម្កល់មាំ នឹងបាននាមថាសោភិតៈ ជាសាវ័កនៃព្រះសាស្តា ។ ខ្ញុំបានដុតបំផ្លាញកងកិលេសហើយ ភពទាំងពួងខ្ញុំបានដកចេញហើយ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។ ក្នុងកប្បទី ៥០០០០ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៧ ជាតិ ព្រះនាមសមុគ្គតៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវទាំង ៧ ប្រការ មានកម្លាំងច្រើន បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលពិចារណាដល់កិលេសដែលខ្លួនលះបានហើយបានពោលគាថាដូច្នេះថា

រាគៈទាំងពួង ខ្ញុំលះចោលហើយ ទោសៈទាំងពួងខ្ញុំក៏ដកចោលហើយ មោហៈទាំងពួងរបស់ខ្ញុំក៏ប្រាសចេញហើយ ខ្ញុំជាបុគ្គលត្រជាក់រលត់ទុក្ខហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សព្វោ រាគោ** បានដល់ រាគៈទាំងអស់

---

១-ក្នុងអបទានជាព្រះ សោភិតត្ថេរ ។

មានកាមរាគៈជាដើម ។ បទថា **បហីនោ** បានដល់ លះហើយដោយអំណាចសមុច្ឆេទប្បហាន ដោយអរិយមគ្គភាវនា ។

បទថា **សព្ពោ ទោសោ** បានដល់ ព្យាបាទទាំងអស់ មានច្រើនប្រភេទដោយភាពជាអាឃាតវត្ថុជាដើម ។

បទថា **សមូហតោ** បានដល់ ដកឡើងហើយដោយមគ្គ ។

បទថា **សព្ពោ មេ វិគតោ មោហោ** បានដល់ មោហៈ ៨ ដែលចែកចេញតាមហេតុកើត មាន **ទុក្ខេ អញ្ញាណំ** ជាដើម គឺមោហៈទាំងអស់ចែកទៅបានមិនមែនតិច តាមហេតុកើតរបស់កិលេស ឈ្មោះថាប្រាសចេញហើយ ព្រោះត្រូវកម្ចាត់ហើយដោយមគ្គ ។

បទថា **សីតិភូតោស្មិ និព្វុតោ** សេចក្តីថា ព្រះថេរៈព្យាករព្រះអរហត្តផលថា ដោយការលះកិលេសដែលជាមូលបានយ៉ាងនេះ ខ្ញុំឈ្មោះថា ដល់ហើយនូវភាពជាបុគ្គលត្រជាក់ ព្រោះមិនមានការក្រវល់ក្រវាយ និងការក្តៅដ៏សេស ព្រោះភាពដែលសន្តិលេសទាំងឡាយ រម្ងាប់ដោយប្រពៃ ព្រោះតាំងនៅក្នុងទីតែមួយ ជាមួយកិលេសដែលជាមូលនោះ ព្រោះហេតុនោះឯងទើបខ្ញុំឈ្មោះថាជាអ្នករំលត់ហើយ ព្រោះរំលត់កិលេសបានដោយប្រការទាំងពួង ។

## អដ្ឋកថា រក្ខិតត្ថេរគាថា ចប់

## ឧគ្គត្ថេរគាថា

[ ៨១ ] អំពើណា ទោះបីតិចឬច្រើន ដែលខ្ញុំធ្វើហើយ អំពើទាំង អស់នុ៎ះ ក៏អស់រលីងហើយ ឥឡូវនេះ កពថ្មីទៀតមិនមានឡើយ ។

**ឧគ្គត្ថេរ ។**

**ឧទ្ទាន**

និយាយអំពីវច្ឆបាលត្ថេរ ១ អាតុមត្ថេរ ១ មាណវត្ថេរជា ឥសី ១ សុយាមនត្ថេរ ១ សុសារទត្ថេរ ១ បិយញ្ជហត្ថេរ ១ ហត្ថារោហបុត្តត្ថេរ ១ មេណ្ឌសិរត្ថេរ ១ រក្ខិតត្ថេរ ១ ព្រះថេរៈឈ្មោះឧគ្គ ១ ។

**ចប់ អដ្ឋមវគ្គ ។**

# អដ្ឋកថា

## ឧគ្គត្ថេរគាថា

[ ៨១ ] គាថារបស់ព្រះឧគ្គត្ថេរ មានពាក្យផ្ដើមថា **យំ មយា បកតំ កម្មំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ ធ្វើបុណ្យជាច្រើនទុកក្នុងភពនោះៗក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាសិខី ក្នុងកប្បទី ៣១ អំពីភទ្ទកប្បនេះ កើតក្នុងផ្ទះមានត្រកូលដល់នូវភាពជាអ្នកដឹងក្ដីហើយ ថ្ងៃមួយ ឃើញព្រះមានព្រះភាគព្រះនាមថាសិខី ជាអ្នកមានចិត្តជ្រះថ្លាហើយបានបូជាដោយផ្កាវំចេក ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក អន្ទោលទៅមកតែក្នុងសុគតិភពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតជាសេដ្ឋីបុត្តក្នុងឧគ្គនិគម ក្នុងដែនកោសល មានឈ្មោះថា ឧគ្គៈ ដូច្នេះ ។ កុលបុត្តនោះចម្រើនវ័យហើយ កាលព្រះមានព្រះភាគគង់នៅត្រង់ភទ្ទារាម ក្នុងនិគមនោះ ទៅវិហារស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា បានជាអ្នកមានសទ្ធាបួសហើយបំពេញវិបស្សនាសម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធ ដែលលោកពោលទុកក្នុងអបទានថា

ពួកឈើមិលក្ខុមានផ្លែ នៅក្បែរឆ្នេរស្ទឹងដ៏ធំ ខ្ញុំកំពុងស្វែងរក
ឈើនោះ បានឃើញព្រះលោកនាយក ។ ក្នុងកាលនោះ ខ្ញុំ
ឃើញដើមកែសមានផ្ការីក ទើបកាច់ផ្កាទាំងទង នាំចូលទៅ

ថ្វាយចំពោះព្រះសម្ពុទ្ធព្រះនាមសិទ្ធិ ជាលោកពន្ធុ ក្រាបទូលថា បពិត្រព្រះសម្ពុទ្ធទ្រង់ប្រសើរ ជាមហាមុនី ព្រះអង្គដល់ហើយនូវអមតបទ ជាទីមិនឃ្លាត ដោយញាណណា ខ្ញុំបូជាចំពោះញាណនោះ ។ លុះខ្ញុំធ្វើការបូជាចំពោះញាណហើយ ទើបបានឃើញនូវឈើមិលក្ខុ ខ្ញុំជាបុគ្គលបាននូវការសម្គាល់នោះ នេះជាផលនៃញាណបូជា ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃញាណបូជា ។ ក្នុងកប្បទី ១៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១២ ជាតិ ព្រះនាមពលុគ្គតៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយដូច្នេះ[១] ។

ព្រះថេរៈ កាលសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផលដោយសម្តែងការចូលទៅកំណត់វដ្តៈរបស់ខ្លួន បានពោលគាថានេះថា

អំពើណានោះបីតិចឬច្រើនដែលខ្ញុំធ្វើហើយ អំពើទាំងអស់នុ៎ះ
ក៏អស់រលីងហើយឥឡូវនេះភពថ្មីទៀតមិនមានឡើយដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យំ មយា បកតំ កម្មំ** សេចក្តីថា កម្ម

---

១-ក្នុងអបទានជាព្រះ សុទស្សនត្ថេរ ។

ណា គឺកម្មដែលជាវិបាកណាដែលខ្ញុំធ្វើហើយ គឺចូលទៅសន្សំហើយ បាន ដល់ ឲ្យកើតហើយក្នុងសង្សារដែលមិនមានទីបំផុតខាងដើម ដោយប្រការមិន មែនតិច គឺដោយជាបាបអកុសលជាដើម និងដោយជាកុសលមានទាន ជា ដើម ដោយកម្មទ្វារ ៣ ដោយឧបបត្តិទ្វារ ៦ ដោយអសំវរទ្វារ ៨ ។

បទថា **អប្បំ វា យទិ វា ពហុំ** សេចក្តីថា កម្មនោះ ឈ្មោះថា **អប្បំ** ព្រោះវត្ថុ ចេតនា បយោគ និងកិលេសជាដើមមានកម្លាំងតិចក្តី ឈ្មោះថា **ពហុំ** ព្រោះវត្ថុ ចេតនា បយោគ និងកិលេសជាដើមនោះមានកម្លាំង និង ព្រោះប្រព្រឹត្តរឿយៗក្តី ។

បទថា **សព្ពមេតំ បរិក្ខីណំ** សេចក្តីថា កម្មទាំងអស់នេះឯង ឈ្មោះ ថា ដល់នូវការអស់ទៅដោយជុំវិញ ព្រោះមគ្គដ៏ប្រសើរ ដែលធ្វើឲ្យកម្មអស់ ទៅ ខ្ញុំសម្រេចហើយ អធិប្បាយថា ព្រោះលះកិលេសវដ្តបាន កម្មវដ្ត រមែង ឈ្មោះថា ខ្ញុំលះបានហើយដែរ ព្រោះវិបាកវដ្តកើតឡើងមិនបាន ។ ដោយ ហេតុនោះ ទើបព្រះថេរៈពោលថា ឥឡូវនេះភពថ្មីទៀតមិនមានឡើយ ដូច្នេះ អធិប្បាយថា ការកើតក្នុងភពថ្មីមិនមានដល់ខ្ញុំទៀតឡើយ ។ បាឋៈថា **សព្ពមេ្ប-តំ** ដូច្នេះក៏មាន ។ បែកបទចេញជា **សព្ពម្បិ ឯតំ** ។

អដ្ឋកថា ឧគ្គត្ថេរគាថា ចប់

វគ្គទី ៨ ចប់

# ថេរគាថា ឯកនិបាត

## នវមវគ្គ

### សមិតិគុត្តត្ថេរគាថា

[ ៨២ ] អំពើលាមកណាដែលខ្ញុំបានធ្វើហើយ ក្នុងជាតិទាំងឡាយដទៃក្នុងភពមុន អំពើលាមកនោះ ខ្ញុំគប្បីទទួលតែក្នុងជាតិនេះទេ វត្ថុដទៃមិនមានឡើយ ។

សមិតិគុត្តត្ថេរ ។

## វគ្គទី៩

### អដ្ឋកថា

### សមិតិគុត្តត្ថេរគាថា

[ ៨២ ] គាថារបស់ព្រះសមិតិគុត្តត្ថេរ មានពាក្យផ្ដើមថា **យំ មយា កតំ បាបំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏មានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធ អង្គមុនៗ សន្សំបុណ្យជាច្រើនទុកក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាវិបស្សី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយជួបព្រះមានព្រះភាគ មានចិត្តជ្រះថ្លា ហើយបានធ្វើការបូជាដោយផ្កាម្លិះ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងភពណាមួយ ក៏បានតាំងនៅ

ក្នុងឋានៈដែលមានកុសលសម្បត្តិ រូបសម្បត្តិ និងបរិវារសម្បត្តិក្រៃលែងជាងសត្វដទៃក្នុងភពនោះៗ ។ ក្នុងអត្តភាពមួយ កុលបុត្តនោះឃើញព្រះបច្ចេកពុទ្ធមួយអង្គត្រាច់បិណ្ឌបាតគិតថា សមណៈត្រងោលនេះ ប្រហែលជាកើតឃ្លង់ ដោយហេតុនោះ ទើបសមណៈរូបនេះចាំបាច់យកសំពត់សណ្តប់ខ្ទប់ដើរទៅ ដូច្នេះហើយ ស្តោះទឹកមាត់ ដើរចេញទៅ ។

ដោយកម្មនោះ កុលបុត្តនោះឆេះនៅក្នុងនរកអស់កាលជាអនេក ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាកស្សបៈ មកកើតជាមនុស្ស បួសជាបរិព្វាជក ឃើញឧបាសកម្នាក់សម្បូរដោយសីលាចារវត្ត អាក់អន់ បានជេរប្រទេចថា ឯងជាមនុស្សឃ្លង់ ដូច្នេះ មិនតែប៉ុណ្ណោះបំផ្លាញលម្អិតសម្រាប់ផ្លូតទឹកដែលមនុស្សទាំងឡាយទុកត្រង់កំពង់ទឹក ហើយចេញទៅ ។

ដោយកម្មនោះ កុលបុត្តនោះកើតក្នុងនរកទៀត សោយទុក្ខអស់ឆ្នាំជាអនេក ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តព្រាហ្មណ៍ម្នាក់ នៅក្នុងនគរសាវត្ថីមានឈ្មោះថាសមិតិគុត្តៈ ។ កុលបុត្តនោះចម្រើនវ័យហើយ ស្តាប់ព្រះធម្មទេសនាក្នុងព្រះបរមសាស្តា ជាអ្នកមានសទ្ធា បួសហើយ មានសីលបរិសុទ្ធដោយផលនៃកម្មចាស់របស់លោក រោគឃ្លង់កើតឡើងហើយ ។ ដោយរោគឃ្លង់នោះ ធ្វើសរីរាវយវៈ របស់ព្រះថេរៈឲ្យបែកជាដំបៅពាសពេញ ហើយមានខ្ទុះហូរចេញ លោកសម្រាកក្នុងសាលាសម្រាប់ភិក្ខុអាពាធ ។

ថ្ងៃមួយ ព្រះធម្មសេនាបតីទៅសួរសុខទុក្ខ សាកសួរភិក្ខុឈឺទាំងឡាយក្នុងទីនោះៗ ឃើញភិក្ខុនោះហើយ ប្រាប់កម្មដ្ឋានដែលមានវេទនាជាអារម្មណ៍

ថា នៃអាវុសោ ជរាបណាខន្ធនៅប្រព្រឹត្តទៅ ក៏ត្រូវសោយទុក្ខទាំងពួង ជរាប នោះ តែកាលខន្ធទាំងឡាយមិនមាននោះឯង ទុក្ខក៏អស់ទៅ ដូច្នេះហើយចៀស ចេញទៅ ។ លោកតាំងនៅក្នុងឱវាទរបស់ព្រះថេរៈ ហើយចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវអភិញ្ញា ៦ ហើយ ។ សមដូចគាថាព័ន្ធដែលលោក ពោលទុកក្នុងអបទានថា

កាលព្រះវិបស្សីទ្រង់ប្រសូត ពន្លឺដ៏ធំក៏កើតឡើង ទាំងផែនដី សមុទ្រនិងភ្នំក៏ញាប់ញ័រ ។ ពួកជនអ្នកទាយនិមិត្ត ( ហោរ ) បានទាយថា ព្រះសម្ពុទ្ធនឹងកើតឡើងក្នុងលោកទ្រង់ជាកំពូល សព្វសត្វនឹងស្រង់ឡើងនូវប្រជុំជន ។ ខ្ញុំបានឮទំនាយពួកហោរ ហើយ ក៏ធ្វើនូវជាតិបូជា ( បូជាក្នុងថ្ងៃប្រសូត ) ជាតិបូជា នេះ ឥតមានបូជាណាប្រហែលឡើយ ។ ខ្ញុំប្រមូលកុសលធ្វើ ចិត្តរបស់ខ្លួនឲ្យជ្រះថ្លា លុះខ្ញុំធ្វើជាតិបូជាហើយក៏ធ្វើកាលកិរិយា ក្នុងទីនោះ ។ ខ្ញុំចូលទៅកើតក្នុងកំណើតណាៗទោះបីជាទេវតា ឬជាមនុស្សតែងកន្លងលើសពួកសត្វទាំងអស់ នេះជាផលនៃ ជាតិបូជា ។ ពួកស្រីមេនំ តែងបម្រើខ្ញុំ ទាំងជនដ៏សេស ក៏លុះ អំណាចចិត្តរបស់ខ្ញុំ ជនទាំងអស់នោះមិនអាចនឹងធ្វើខ្ញុំឲ្យក្រោធ ឡើយ នេះជាផលនៃជាតិបូជា ។ ក្នុងកប្បទី ៩១ អំពីកប្ប នេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើបូជា ខ្ញុំមិនដែល ស្គាល់ទុគ្គតិ នេះជាផលនៃជាតិបូជា ។ ក្នុងកប្បទី ៣ អំពី

កប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣៤ ជាតិ ព្រះនាម សុបារិចរិយៈដូចគ្នា ទ្រង់ជាធំជាងជន មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអភិញ្ញា ៦ ហើយ រឭកដល់បាបកម្មដែលខ្លួនធ្វើហើយក្នុងជាតិមុនៗ ដោយអំណាចនៃរោគដែលខ្លួនកំពុងសោយក្នុងបច្ចុប្បន្ន ដោយសំដៅដល់ការពិចារណាកិលេសដែលលះបានហើយ ឥឡូវនេះ កាលនឹងប្រកាសភាពដែលកិលេសនោះ ខ្លួនលះបានហើយ ដោយប្រការទាំងពួង បានពោលគាថា ដូច្នេះថា

> អំពើលាមកណា ដែលខ្ញុំបានធ្វើហើយក្នុងជាតិទាំងឡាយដទៃ ក្នុងភពមុន អំពើលាមកនោះ ខ្ញុំគប្បីទទួលតែក្នុងជាតិនេះទេ វត្ថុដទៃមិនមានឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធាបំ** បានដល់ អកុសលកម្ម ។ អកុសលកម្មនោះ លោកហៅថា **ធាប** ព្រោះអត្ថថា អាក្រក់ ។ បទថា **បុញ្ញេ** ស្មើនឹង **បុរា** ប្រែថា ក្នុងកាលមុន ។ បទថា **អញ្ញាសុ ជាតិសុ** សេចក្តីថា ក្នុងជាតិដទៃក្រៅអំពីជាតិនេះ បានដល់ ក្នុងអត្តភាពដទៃ ។ ក្នុងគាថានេះមានអត្ថដូច្នេះថា សូម្បីខ្ញុំមិនបានធ្វើបាបកម្ម មានសភាពបែបនោះក្នុងអត្តភាពនេះ

---

១-ក្នុងអបទានជាព្រះ ជាតិបូជកត្ថេរ ។

បាបកម្មនោះកើតមិនបានក្នុងឥឡូវនេះក៏ពិត តែបាបកម្មណាដែលខ្ញុំធ្វើក្នុងជាតិដទៃក្រៅអំពីជាតិនេះនៅមាន បាបកម្មនោះ ខ្ញុំកំពុងសោយក្នុងអត្តភាពនេះឯង អធិប្បាយថា កម្មនោះ គឺផលដែលខ្ញុំកំពុងសោយ គឺជួបក្នុងជាតិនេះឯង គឺក្នុងអត្តភាពនេះឯង ព្រោះហេតុអ្វី ព្រោះរឿងបាបកម្មដទៃមិនមាន ដូច្នោះ ឱកាសដែលនឹងសោយកម្មនោះ គឺការសម្ពន្ធនៃខន្ធដទៃរមែងមិនមានព្រោះខន្ធទាំងនេះមិនមាន បដិសន្ធិរមែងរលត់ទៅដោយការរលត់ នៃចិត្តចុងក្រោយព្រោះលះឧបាទានបានហើយ ដោយប្រការទាំងពួង ដូចអណ្តាតភ្លើងមិនមានកំញមរលត់ទៅ ដូច្នោះ ។ គាថានេះស្មើនឹងព្រះថេរៈបានព្យាករអរហត្តផលហើយ ដោយប្រការដូចពណ៌នាមកនេះ ។

## អដ្ឋកថា សមិតិគុត្តត្ថេរគាថា ចប់

## កស្សបត្ថេរគាថា

[ ៨៣ ] ទីមានភិក្ខាហារដ៏សម្បូណ៌ផង ទីដ៏ក្សេមក្សាន្តមិនមានភ័យផង មានក្នុងទិសណាៗ ម្នាលកូន អ្នកចូលទៅក្នុងទិសនោះៗចុះ សូមកុំឲ្យអ្នកមានសេចក្តីសោកបៀតបៀនបានឡើយ ។

**កស្សបត្ថេរ ។**

## អដ្ឋកថា

## កស្សបត្ថេរគាថា

[ ៨៣ ] គាថារបស់ព្រះកស្សបត្ថេរ មានពាក្យផ្តើមថា **យេន យេន សុភិក្ខានិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថា បទុមុត្តរៈ រៀនចប់ត្រៃវេទនិងសម្រេចការសិក្សាក្នុងសិប្បសាស្ត្ររបស់ព្រាហ្មណ៍ ថ្ងៃមួយឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា ធ្វើនូវការបូជាដោយផ្កាម្ទេះ កាលធ្វើការបូជា ក៏បោះផ្កាទៅលើអាកាសជុំវិញព្រះសាស្តា ។ ដោយពុទ្ធានុភាព ផ្កាទាំងឡាយតាំងនៅក្នុងលក្ខណៈជាដំបូលផ្កាអស់កាល ៧ ថ្ងៃ កុលបុត្តនោះឃើញហេតុអស្ចារ្យនោះហើយមានចិត្តជ្រះថ្លាក្រៃលែង ។ កុលបុត្តនោះធ្វើបុណ្យយ៉ាងច្រើន អន្ទោលទៅមកក្នុងសុគតិភពតែម្យ៉ាងប៉ុណ្ណោះអស់មួយសែនកប្ប ក្នុងពុទ្ធុប្បាទនេះ កើតជាកូនរបស់ឧទិច្ចព្រាហ្មណ៍ក្នុងនគរសាវត្ថីមាននាមថាកស្សបៈ ឪពុកធ្វើកាលកិរិយា

តាំងពីកុលបុត្តនេះនៅក្មេងនៅឡើយ ទើបមាតាចិញ្ចឹមរហូតមក ។

ថ្ងៃមួយ ទៅកាន់វិហារជេតពន ហើយស្តាប់ធម្មទេសនារបស់ព្រះមានព្រះភាគ ក៏បានជាព្រះសោតាបន្នក្នុងអាសនៈនោះឯង ព្រោះភាពដែលកុលបុត្តនោះសម្បូរដោយហេតុ ត្រឡប់ទៅកាន់សម្នាក់មាតា ឲ្យមាតាអនុញ្ញាតហើយបួស ។ កាលព្រះសាស្តាទ្រង់បវារណាក្នុងថ្ងៃចេញវស្សាហើយទ្រង់ចារិកទៅកាន់ជនបទ បំណងនឹងទៅតាមព្រះសាស្តាដោយខ្លួនឯង បានទៅកាន់សម្នាក់មាតាដើម្បីលា ។ មាតាកាលនឹងចន្លុលប្រាប់ ទើបពោលគាថាជាគាថាទូន្មានថា

ទីមានភិក្ខាហារដ៏សម្បូណ៌ផង ទីដ៏ក្សេមក្សាន្តមិនមានភ័យផងមានក្នុងទិសណាៗ ម្នាលកូន អ្នកចូលទៅក្នុងទិសនោះៗចុះ សូមកុំឲ្យអ្នកមានសេចក្តីសោកបៀតបៀនបានឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យេន យេន** បានដល់ ក្នុងទីណាមួយ ។ បទថា **យេន យេន** នេះ ជាតតិយាវិភត្តិចុះក្នុងអត្ថនៃសត្តមីវិភត្តិ ប្រែថា ក្នុងទិសាភាគណាមួយ ។ បទថា **សុភិក្ខានិ** សេចក្តីថា មានអាហាររកបានងាយ អធិប្បាយថា ជាលំនៅរបស់អ្នកស្រុក ។ បទថា **សិវានិ** សេចក្តីថា ផុតភ័យ មិនមានរោគ ។

បទថា **អភយានិ** សេចក្តីថា មិនមានភ័យដែលកើតអំពីចោរភ័យជាដើម ។ ឯរោគភ័យនិងទុព្ភិក្ខភ័យ លោកសង្គ្រោះចូលដោយបទទាំង ២ ថា **សុភិក្ខានិ សិវានិ** នោះឯង ។ បទថា **តេន** ស្មើគ្នានឹង **តត្ថ** អធិប្បាយថា

ក្នុងទិសាភាគនោះៗ ។ មាតាមានសេចក្តីករុណាហៅព្រះថេរៈថាម្នាលកូន ។ សព្ទថា **មា** ជានិបាត ប្រាប់ការបដិសេធ ។ បទថា **សោកាបហតោ** សេចក្តីថា កុំទៅកាន់ដែនដែលប្រាសចាកគុណដូចពោលហើយ កុំបីសោយសោកដែលកើតអំពីទុក្ខភ័យជាដើមបៀតបៀនឡើយ ។

ព្រះថេរៈស្តាប់ឱវាទនោះហើយ កើតសេចក្តីឧស្សាហ៍ថា មាតារបស់អញចង់ឲ្យអញទៅកាន់ទី ដែលប្រាសចាកសេចក្តីសោក ណ្ហើយចុះ អញគួរសម្រេចដល់ស្ថានទី ដែលប្រាសចាកសេចក្តីសោកដោយចំណែកមួយ នោះឯង ហើយផ្តើមចម្រើនវិបស្សនាសម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចពាក្យព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំជាអ្នកស្វាធ្យាយមន្ត អ្នកចងចាំមន្ត អ្នកដល់នូវត្រើយនៃវេទទាំង ៣ កំពុងឈរនៅក្នុងទីវាល បានឃើញព្រះលោកនាយកទ្រង់ស្វែងរកនូវគុណដ៏ធំ ដូចជារាជសីហ៍ត្រាច់ទៅក្នុងព្រៃ ឬដូចស្តេចខ្លាដែលមិនតក់ស្លុត ឬក៏ដូចដំរីឈ្មោះមាតង្គៈដែលកំពុងចុះប្រេង ៣ កន្លែង ។ ខ្ញុំកាន់យកផ្កាសេរមាន់បោះឡើងនាអាកាស ផ្កាទាំងនោះ ក៏ព័ទ្ធព័ន្ធជុំវិញដោយអានុភាពព្រះពុទ្ធ ។ ព្រះសព្វញ្ញូជាលោកនាយក មានព្យាយាមធំទ្រង់អធិដ្ឋានថា ផ្កាទាំងឡាយចូររោយរាយជារបាំងផ្កាជុំវិញតថាគតដ៏ប្រសើរជាងនរៈ ។ លំដាប់នោះ សំណុំផ្កានោះ មានទងចូលក្នុងមានមុខចេញក្រៅធ្វើជារបាំងប្រក់អស់ ៧ ថ្ងៃ តពី

នោះមក ក៏បាត់អស់ទៅ ។ លុះខ្ញុំបានឃើញហេតុជាអស្ចារ្យ ចំឡែកគួរព្រឺរោមនោះ បានញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធ ជាព្រះសុគតលោកនាយក ។ ខ្ញុំត្រូវកុសលមូលជាស់តឿន មិនដែលទៅកើតក្នុងទុគ្គតិអស់ ១ សែនកប្ប ដោយចិត្តជ្រះថ្លានោះ ។ ក្នុងកប្បទី ១៥០២៥ ខ្ញុំបានកើតជាស្តេចចក្រពត្តិច្រើនជាតិព្រះនាមវិលាមាលៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ(១) ។

ព្រះថេរៈកាលសម្រេចអរហត្តហើយគិតថា ពាក្យទូន្មានរបស់មាតានេះឯង ជាកន្ទេរនៃការសម្រេចអរហត្ត ដូច្នេះហើយ បានពោលគាថានោះដដែលទៀត ដូច្នេះ ។

## អដ្ឋកថា កស្សបត្ថេរគាថា ចប់

---

១-ក្នុងអបទានជាព្រះ សេរេយ្យកត្ថេរ ។

## សីហត្ថេរគាថា

[ ៨៤ ] ម្នាលភិក្ខុឈ្មោះសីហៈ ចូរអ្នកកុំប្រមាទ កុំខ្ជិលច្រអូសអស់យប់នឹងថ្ងៃ ចូរអ្នកចម្រើនកុសលធម៌ចុះ ចូរអ្នកលះបង់នូវគ្រោងកាយ គឺអត្តភាពដោយឆាប់ចុះ ។

**សីហត្ថេរ ។**

## អដ្ឋកថា

## សីហត្ថេរគាថា

[ ៨៤ ] គាថារបស់ព្រះសីហត្ថេរ មានពាក្យផ្ដើមថា **សីហាប្បមត្តោ វិហារ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះថេរៈនោះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ។ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាអត្ថទស្សី ក្នុងកប្បទី ១៨០០ រាប់អំពីភទ្ទកប្បនេះ កុលបុត្តនេះកើតជាកិន្នរ ជាអ្នកមានផ្កាជាអាហារ មានផ្កាជាគ្រឿងស្លៀកដណ្ដប់ នៅអាស្រ័យត្រង់ច្នេរស្ទឹងចន្ទភាគា ឃើញព្រះមានព្រះភាគយាងទៅតាមអាកាស មានចិត្តជ្រះថ្លា បំណងនឹងបូជា បានឈរផ្គងអញ្ជលី ។ ព្រះមានព្រះភាគទ្រង់ជ្រាបអធ្យាស្រ័យរបស់កិន្នរនោះ ទើបចុះអំពីអាកាស គង់ពត់ភ្នែនត្រង់គល់ឈើមួយដើម កិន្នរបុកខ្លឹមចន្ទន៍រួចធ្វើការបូជាដោយក្លិនខ្លឹមចន្ទន៍ និងដោយផ្កាទាំងឡាយ ថ្វាយបង្គំធ្វើប្រទក្សិណហើយចៀសចេញទៅ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលស្តេចមល្លៈមាននាមថា សីហៈ ។ សីហកុមារឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លាថ្វាយបង្គំ អង្គុយក្នុងចំណែកម្ខាង ព្រះសាស្តា ទ្រង់ប្រមើលមើលអជ្ឈាស្រ័យរបស់កុលបុត្តនោះ ហើយទ្រង់សំដែងធម៌ កុលបុត្តនោះស្តាប់ធម៌ហើយមានសទ្ធាបួសហើយរៀនកម្មដ្ឋានទៅក្នុងព្រៃ ។ ចិត្តរបស់កុលបុត្តនោះស្ទុះឆ្ពោះទៅក្នុងអារម្មណ៍ផ្សេងៗ មិនមានឯកគ្គតាចិត្តឡើយ មិនអាចញុំាងប្រយោជន៍ខ្លួនឲ្យសម្រេចបាន ព្រះសាស្តាទ្រង់ឃើញដូច្នោះហើយ ទ្រង់ឈរក្នុងអាកាស ទូន្មានដោយគាថាថា

ម្នាលភិក្ខុឈ្មោះសីហៈ ចូរអ្នកកុំប្រមាទ កុំខ្ជិលច្រអូសអស់យប់
នឹងថ្ងៃ ចូរអ្នកចម្រើនកុសលធម៌ចុះ ចូរអ្នកលះបង់នូវគ្រោងកាយ
គឺអត្តភាពដោយឆាប់ចុះ ដូច្នេះ ។

ក្នុងកាលចប់គាថា លោកចម្រើនវិបស្សនា សម្រេចអរហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

គ្រានោះ ខ្ញុំកើតជាកិន្នរ នៅទៀបច្រាំងស្ទឹងចន្ទភាគា ជាអ្នកទទួល
ទាននូវផ្កាឈើ ជាអ្នកស្លៀកនូវផ្កាឈើ ។ កាលនោះ ព្រះ
មានព្រះភាគព្រះនាមអត្ថទស្សី ជាច្បងក្នុងលោកជានរាសភៈ
ស្តេចហោះទៅតាមទីបំផុតនៃព្រៃធំ ដូចស្តេចហង្ស ( ហើរ
ទៅ ) នាអាកាស ( ខ្ញុំសរសើរពុទ្ធគុណថា ) បពិត្រព្រះ
អង្គជាអាជានេយ្យខ្ញុំសូមថ្វាយបង្គំចំពោះព្រះអង្គព្រះហឫទ័យ

របស់ព្រះអង្គស្អាតល្អហើយ ព្រះអង្គមានសម្បុរព្រះភក្ត្រជ្រះថ្លា មានឥន្ទ្រិយ គឺព្រះភក្ត្រស្រស់បស់ ។ លុះព្រះអត្ថទស្សី មានបញ្ញាដូចផែនដី មានបញ្ញាជាគ្រឿងពុះពារ ស្តេចចុះអំពីអាកាសហើយក្រាលសង្ឃាដិទ្រង់ចូលមកទាំងភ្នែន ។ ខ្ញុំបានយកខ្ទឹមចន្ទន៍ដ៏ល្អិតផង់ ហើយដើរចូលមកក្នុងសម្នាក់ព្រះជិនស្រី ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បានបូជាចំពោះព្រះពុទ្ធ ។ ខ្ញុំថ្វាយបង្គំព្រះសម្ពុទ្ធជាច្បងក្នុងលោកជានរាសភៈហើយក៏កើតបាមោជ្ជៈ ឈមមុខទៅកាន់ឧត្តរទិស ដើរចេញទៅ ។ ក្នុងកប្បទី ១១៨ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាខ្ទឹមចន្ទន៍ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១១៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣ ជាតិព្រះនាម រោហិណី ដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយដូច្នេះ[១] ។

បទថា **សីហ** ក្នុងគាថាថា **សីហប្បមត្តោ** ជាដើម ដែលព្រះមានព្រះភាគត្រាស់ហើយ ជាឱវាទជាពាក្យហៅឈ្មោះរបស់ព្រះថេរៈនោះ ។

បទថា **អប្បមត្តោ វិហារ** សេចក្តីថា ចូរអ្នកវៀរចាកសេចក្តីប្រមាទ

---

១-ក្នុងអបទានជាព្រះ ចន្ទនបូជកត្ថេរ ។

ដោយការមិនទៅប្រាសចាកសតិ គឺជាអ្នកប្រកបទៅដោយសតិនិងសម្បជញ្ញៈ គ្រប់ៗឥរិយាបថចុះ ។ ឥឡូវនេះ ដើម្បីសម្ដែងអប្បមាទវិហារធម៌នោះ មួយអន្លើដោយផលដោយសង្ខេប ទើបព្រះមានព្រះភាគត្រាស់ថា **រត្តិន្ទិវំ** ដូច្នេះជាដើម ។ អត្ថនៃបទនោះ មានដូច្នេះថា អ្នកកុំខ្ជិលច្រអូស គឺកុំបណ្ដោយសតិ បានដល់ ចូរជាអ្នកប្រារព្ធព្យាយាមដោយអំណាចនៃសម្មប្បធានមានអង្គ ៤ ដោយន័យ ( ក្នុងសំយុត្តនិកាយសឡាយតនវគ្គ ) ថា ( ភិក្ខុក្នុងសាសនានេះ ) ធ្វើចិត្តឲ្យបរិសុទ្ធចាកអាវរណីយធម៌ដោយការដើរ ដោយការអង្គុយ... ដូច្នេះ ។ ចូរញុំាងធម៌ គឺសមថៈនិងវិបស្សនាដែលជាកុសល និងញុំាងលោកុត្តរធម៌ឲ្យជាក់ច្បាស់ គឺឲ្យកើត បានដល់ ឲ្យចម្រើនទៀតផង កាលឲ្យចម្រើនយ៉ាងនេះហើយ ចូរលះឆន្ទរាគៈក្នុងអត្តភាពដោយរួសរាន់ គឺចូរលះរាងកាយដែលបានដល់អត្តភាពរបស់អ្នក ដោយរួសរាន់ គឺដោយមិនយឺតយូរ ដោយការលះឆន្ទរាគៈ ដែលទាក់ទងហើយក្នុងអត្តភាពនោះជាមុនដូច្នេះ កាលលះយ៉ាងនេះហើយនឹងលះឆន្ទរាគៈបានដោយការរំលត់ឥតសេសសល់នៃចិត្តដួងចុងក្រោយ ដោយមិនមានចំណែកសេសសល់ ក្នុងកាលខាងក្រោយ ។ ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផលបានពោលគាថានេះម្ដងទៀត ដូច្នេះ ។

## អដ្ឋកថា សីហត្ថេរគាថា ចប់

## ឆឹតត្ថេរគាថា

[ ៨៥ ] បុគ្គលដេកលក់រហូតរាត្រីទាំងអស់ ត្រេកអរក្នុងពួកគណៈ ក្នុងវេលាថ្ងៃ ជាអ្នកអប្បបញ្ញា កាលណានឹងធ្វើនូវទីបំផុតនៃទុក្ខបាន ។

**នីតត្ថេរ ។**

## អដ្ឋកថា

## ឆឹតត្ថេរគាថា

[ ៨៥ ] គាថារបស់ព្រះនីតត្ថេរ មានពាក្យផ្តើមថា **សព្វរត្តឹ សុបិត្វាន** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កុលបុត្តនេះជាព្រាហ្មណ៍ឈ្មោះសុនន្ទ ជាអ្នកបង្រៀនមន្តដល់ព្រាហ្មណ៍ទាំងឡាយច្រើនរយនាក់ បូជាយញ្ញឈ្មោះវាជបេយ្យ ។ ព្រះមានព្រះភាគ កាលទ្រង់អនុគ្រោះព្រាហ្មណ៍នោះ ទ្រង់យាងទៅកាន់ទីបូជាយញ្ញ ទ្រង់ចង្ក្រមក្នុងអាកាស ព្រាហ្មណ៍ឃើញព្រះសាស្តា មានចិត្តជ្រះថ្លា ឲ្យកូនសិស្សទាំងឡាយនាំយកផ្កាមក ហើយបោះឡើងទៅលើអាកាស ធ្វើការបូជា ដោយពុទ្ធានុភាពទីស្ថាននោះនិងនគរទាំងមូលហាក់ដូចជាគ្របដណ្តប់ដោយផ្ទាំងសំពត់ គឺផ្កា ។ មហាជនកើតបីតិនិងសោមនស្សដ៏ឧឡារក្នុងព្រះសាស្តា ។

ដោយកុសលកម្មនោះ សុនន្ទព្រាហ្មណ៍អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាព្រាហ្មណបុត្តក្នុងនគរសាវត្ថីមានឈ្មោះ

ថានីត ។ កុលបុត្តនោះដល់នូវភាពជាអ្នកដឹងក្តីហើយគិតថា សមណសក្យបុត្តទាំងនេះ មានសីលងាយៗ មានមារយាទងាយៗ បរិភោគភោជនល្អ នៅក្នុងសេនាសនៈ ដែលមិនមានខ្យល់ អញអាចបួសហើយនៅក្នុងសេនាសនៈនោះបានដោយសប្បាយដូច្នេះ ទើបបួសព្រោះចង់សប្បាយ រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តាហើយមនសិការកម្មដ្ឋានបាន ២-៣ ថ្ងៃប៉ុណ្ណោះ ក៏បោះបង់កម្មដ្ឋាននោះចាន់ពេញពោះតាមត្រូវការរហូតរាងកាយផ្អែតស្អប់ស្អល់ ត្រេកអរក្នុងការប្រឡូកប្រឡំដោយពួកគណៈ ពីព្រឹកទល់ល្ងាច ញុំាងកាលឲ្យកន្លងទៅដោយការសន្ទនាក្នុងតិរច្ឆានកថា ក្នុងវេលាយប់ ក៏ត្រូវថីនមិទ្ធៈគ្របសង្កត់ ដេកលក់ទល់ភ្លឺ ។ ព្រះសាស្តាទ្រង់ប្រមើលមើលការចាស់ក្លានៃហេតុរបស់លោកហើយ កាលទ្រង់ប្រទានឱវាទ ទើបត្រាស់គាថា

> បុគ្គលដេកលក់រហូតរាត្រីទាំងអស់ ត្រេកអរក្នុងពួកគណៈក្នុងវេលាថ្ងៃ ជាអ្នកអប្បបញ្ញា កាលណានឹងធ្វើនូវទីបំផុតនៃទុក្ខបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សព្វរត្តឹ** បានដល់ អស់រាត្រីទាំងមូល ។ បទថា **សុបិត្វាន** បានដល់ ដេកលក់ហើយ អធិប្បាយថា មិនខ្វល់ខ្វាយក្នុងការភ្ញាក់រឭកដែលលោកពោលទុកដោយន័យជាដើមថា ធ្វើចិត្តឲ្យបរិសុទ្ធចាកអាវរណីយធម៌ដោយការដើរ ដោយការអង្គុយ អស់បឋមយាមនៃរាត្រីដូច្នេះ ហើយឈានចុះកាន់ការដេកលក់ក្នុងយាមទាំង ៣ នៃរាត្រីទាំងមូល ។

បទថា **ទិវា** បានដល់ ពេលថ្ងៃ អធិប្បាយថា អស់ចំណែកនៃថ្ងៃទាំង

មូល ។

បទថា **សង្គណិកេ** សេចក្តីថា កាលប្រឡូកប្រឡំនឹងបុគ្គលដែលច្រើន ទៅដោយការធ្វើពង្រកាយឲ្យជាត់ និងដោយការសន្ទនា រឿងឥតប្រយោជន៍ ឈ្មោះថា **សង្គណិកេ** ។ បុគ្គលដែលត្រេកអរ គឺអភិរម្យក្នុងការប្រឡូកប្រឡំនោះ បានដល់ បុគ្គលដែលមិនកាត់ការពេញចិត្តក្នុងការប្រឡូកប្រឡំនោះ ហៅថា **សង្គណិកេ រតោ** ។ បាលីថា **សង្គណិការតោ** ដូច្នេះក៏មាន ។

បទថា **កុទាស្សុ ឆាម** ស្មើគ្នានឹង **កុទា ឆាម** ។ បទថា **អស្សុ** ជានិបាត អធិប្បាយថា ក្នុងកាលណា ។ បទថា **ទុម្មេធោ** បានដល់ បុគ្គលមិនមានបញ្ញា ។ បទថា **ទុក្ខស្ស** បានដល់ ទុក្ខក្នុងវដ្ដៈ ។

បទថា **អន្តំ** ស្មើគ្នានឹង **បរិយោសានំ** ប្រែថា ទីបំផុត អធិប្បាយថា កាលណាធ្វើការចូលទៅប្រកាន់មាំបានដោយចំណែកមួយសោត គឺការធ្វើបំផុតនៃទុក្ខរមែងមិនមានដល់បុគ្គលបែបនេះ ។ បាលីថា **ទុម្មេធ ទុក្ខស្សន្តំ ករិស្សសិ** ដូច្នេះក៏មាន ។ កាលព្រះសាស្តាត្រាស់គាថាយ៉ាងនេះហើយព្រះថេរៈកើតនូវការសង្វេគ ផ្តើមចម្រើនវិបស្សនា សម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

> មានព្រាហ្មណ៍ម្នាក់ឈ្មោះ សុនន្ទៈជាអ្នកចេះចប់មន្ត ស្វាធ្យាយ
> មន្ត គួរគេសូមបាន បានបូងសួងនូវយញ្ញ ឈ្មោះ វាជ-
> បេយ្យៈ ។ កាលនោះ ព្រះលោកវិទូជាអគ្គបុរស ព្រះនាម
> បទុមុត្តរៈ ទ្រង់ប្រកបដោយសេចក្តីករុណា ទ្រង់ស្វែងរកនូវ

គុណ អនុគ្រោះដល់ពួកជន ស្តេចចង្រ្កមនាអាកាស ។ ព្រះសម្ពុទ្ធជាសព្វញ្ញូជាលោកនាយក ទ្រង់ចង្ក្រមរួចហើយក៏ផ្សាយមេត្តាចំពោះពួកសត្វ ( សព្វទិស ) មិនមានប្រមាណ មិនមានឧបធិ ។ ព្រាហ្មណ៍ជាអ្នកចេះចប់មន្ត្រ បានបេះយកផ្កាទាំងទង ប្រជុំពួកសិស្សទាំងអស់ ហើយបោះទៅលើអាកាស ។ ក្នុងកាលនោះនគរ ក៏មានគ្រឿងប្រក់ដោយផ្កាជាកំណាត់ ហេតុតែអានុភាពនៃព្រះពុទ្ធ ផ្កាមិនបានវិនាសអស់ ៧ ថ្ងៃ ។ ដោយកុសលមូលនេះឯង ខ្ញុំបានសោយសម្បត្តិ កំណាត់ដឹងនូវអាសវៈទាំងពួង ឆ្លងនូវតណ្ហាជាគ្រឿងចាក់ស្រែះក្នុងលោក ។ ក្នុងកប្បទី ១១១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣៥ ជាតិ មានព្រះនាមអម្ពរំសៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផល បានពោលគាថានេះម្តងទៀត ដូច្នេះ ។

**អដ្ឋកថា នីតត្ថេរគាថា ចប់**

---

១-ក្នុងអបទានជាព្រះ បុប្ផចទនិយត្ថេរ ។

## សុណាគត្ថេរគាថា

[ ៨៦ ] បុគ្គលឈ្លាសវៃ ក្នុងនិមិត្តរបស់ចិត្ត ដឹងច្បាស់នូវរសនៃវិវេក ដុតកម្តៅកិលេស ជាអ្នកមានប្រាជ្ញារក្សាខ្លួន មានស្មារតីតម្កល់មាំ គប្បីបាននូវនិរាមិសសុខ គឺព្រះនិព្វាន ។

សុនាគត្ថេរ ។

## អដ្ឋកថា

## សុណាគត្ថេរគាថា

[ ៨៦ ] គាថារបស់ព្រះសុនាគត្ថេរ មានពាក្យផ្តើមថា **ចិត្តនិមិត្តស្ស កោវិទោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏មានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាសិខី ក្នុងកប្បទី ៣១ អំពីកប្បនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ចម្រើនវ័យហើយជាអ្នកដល់ត្រើយនៃត្រៃវេទ នៅក្នុងអាស្រមក្បែរមាត់ព្រៃ បង្រៀនមន្តដល់ព្រាហ្មណ៍ ៣០០០ នាក់ ។ ថ្ងៃមួយ ឃើញព្រះសាស្តា ទើបពិនិត្យមើលលក្ខណៈ ហើយរាយមន្តសម្រាប់ទាយលក្ខណៈ កើតសេចក្តីជ្រះថ្លាដ៏ក្រៃលែង ប្រារព្ធព្រះពុទ្ធញ្ញាណថាបុគ្គលប្រកបដោយលក្ខណៈបែបនេះនឹងបានជាព្រះពុទ្ធវិជិតមារ មានព្រះញាណមិនមានទីបំផុត ដូច្នេះ ។

ដោយចិត្តជ្រះថ្លានោះ កុលបុត្តនោះកើតក្នុងទេវលោក អន្ទោលទៅមក ក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តព្រាហ្មណ៍ម្នាក់ ក្នុងនាលកគាមមានឈ្មោះថាសុនាគ ។ កុលបុត្តនោះ ជាសម្លាញ់របស់ព្រះធម្មសេនាបតីកាលនៅជាគ្រហស្ថ ទៅកាន់សម្នាក់របស់ព្រះថេរៈ ស្តាប់ធម៌ហើយ តាំងនៅក្នុងទស្សនភូមិ ( សោតាបន្នបុគ្គល ) ចម្រើនវិបស្សនា សម្រេចអរហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលទុក ក្នុងអបទានថា

មានភ្នំមួយឈ្មោះវសកៈ នៅជិតព្រៃហិមពាន្ត ខ្ញុំសាងអាស្រម នៅនាជើងភ្នំនោះ ។ កាលនោះ ខ្ញុំជាព្រាហ្មណ៍ បានបង្រៀនសិស្ស ៣០០០ នាក់ លុះបង្រៀនសិស្សទាំងនោះរួចហើយ ក៏ចូលទៅកាន់ទីសមគួរ ។ លុះព្រាហ្មណ៍ គឺខ្ញុំនេះឯង ជាអ្នកចេះចប់មន្ត្រ អង្គុយក្នុងទីសមគួរហើយ ស្វែងរកមើលភេទរបស់ព្រះពុទ្ធ ក៏បានញុំាងចិត្តឲ្យជ្រះថ្លាក្នុងញាណ ។ លុះខ្ញុំញុំាងចិត្តឲ្យជ្រះថ្លា ក្នុងញាណនោះរួចហើយ ក៏អង្គុយលើកម្រាលស្លឹកឈើ ពែនភ្នែនធ្វើមរណកាលក្នុងទីនោះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានដល់នូវសេចក្តីសម្គាល់ ( ក្នុងញាណ ) ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃញាណសញ្ញា ។ ក្នុងកប្បទី ២៧ អំពីកប្បនេះខ្ញុំកើតជាស្តេចចក្រពត្តិព្រះនាមសិរីធរៈ ទ្រង់បរិបូណ៌

ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤
វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ
ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈ កាលសម្រេចអរហត្តហើយកាលនឹងព្យាករអរហត្តផលដោយប្រកាសធម្មទេសនាដល់ភិក្ខុទាំងឡាយ បានពោលគាថានេះថា

បុគ្គលឈ្លាសវៃក្នុងនិមិត្តរបស់ចិត្ត ដឹងច្បាស់នូវរសនៃវិវេក
ដុតកម្តៅកិលេសជាអ្នកមានប្រាជ្ញារក្សាខ្លួន មានស្មារតីតម្កល់
មាំ គប្បីបាននូវនិរាមិសសុខ គឺព្រះនិព្វាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចិត្តនិមិត្តស្ស កោវិទោ** សេចក្តីថា បុគ្គលអ្នកឈ្លាស ក្នុងការកាន់យកនិមិត្តនៃភាវនាចិត្ត គឺឈ្លាសក្នុងការកាន់យកនូវចិត្តនិមិត្តដែលគួរដល់ការផ្គងទុកជាដើម យ៉ាងនេះថា គប្បីផ្គងចិត្តក្នុងសម័យនេះ គប្បីឲ្យចិត្តត្រេកអរក្នុងសម័យនេះ គប្បីព្រងើយក្នុងសម័យនេះដូច្នេះ ។ បទថា **បវិវេករសំ វិជានិយ** សេចក្តីថា ដឹងរសនៃចិត្តវិវេកដែលញុំាងកាយវិវេកឲ្យចម្រើន អធិប្បាយថា សោយវិវេកសុខ លោកអធិប្បាយថា បានដល់ ផឹកនូវវិមុត្តិរស ។ បទថា **ឈាយំ** បានដល់ សម្លឹងដោយអារម្មណូបនិជ្ឈាន និងសម្លឹងដោយលក្ខណូបនិជ្ឈានក្នុងកាលខាងក្រោយ ។ បទថា **និបកោ** បានដល់ ឈ្លាសក្នុងការបរិហារកម្មដ្ឋាន ។ បទថា **បតិស្សតោ** បានដល់ ចូលទៅតម្កល់សតិទុក ។ បទថា **អធិគច្ឆេយ្យ សុខំ**

---

១-ក្នុងអបទានជាព្រះ រហោសញ្ញិកត្ថេរ ។

**និរាមិសំ** សេចក្ដីថា តាំងនៅហើយក្នុងសុខដែលកើតអំពីវិវេកដែលគប្បីបាន ដោយភាពជាអ្នកឈ្លាសក្នុងសមថនិមិត្តយ៉ាងនេះជាដើម ជាអ្នកមាននូវសតិ មានសម្បជញ្ញៈ សម្លឹងដោយវិបស្សនាឈាននោះឯង គប្បីសម្រេច គឺគប្បី ចូលទៅដល់ព្រមនូវនិព្វានសុខ និងផលសុខដែលឈ្មោះថា មិនមានអាមិស ព្រោះលាយឡំដោយអាមិស គឺកាម និងអាមិស គឺវដ្ដៈ ។

អដ្ឋកថា សុនាគត្ថេរគាថា ចប់

## នាគិតត្ថេរគាថា

[ ៨៧ ] ព្រះមានព្រះភាគ ជាសាស្ដាចារ្យ កាលសម្ដែងដោយព្រះអង្គឯង ( ដូចផ្លែកន្ទួតព្រៃ ) ក្នុងបាតដៃ តែងប្រៀនប្រដៅសង្ឃយ៉ាងនេះថា ផ្លូវដ៏ប្រសើរនេះជាផ្លូវទៅកាន់ព្រះនិព្វាន មិនមែនដូចផ្លូវរបស់តិរ្ថិយអ្នកពោលផ្សេងៗខាងក្រៅសាសនានេះទេ ។

នាគិតត្ថេរ ។

## អដ្ឋកថា
## នាគិតត្ថេរគាថា

[ ៨៧ ] គាថារបស់ព្រះនាគិតត្ថេរ មានពាក្យផ្ដើមថា **ឥតោ ពហិទ្ធា បុថុអញ្ញវាទិនំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុ ដូចម្ដេច ។

បានឮថា ក្នុងសាសនារបស់ព្រះពុទ្ធព្រះនាម បទុមុត្តរៈ កុលបុត្តនេះជាព្រាហ្មណ៍ឈ្មោះនារទៈ ។ ថ្ងៃមួយ អង្គុយក្នុងរោងមូល ឃើញព្រះមានព្រះភាគដែលភិក្ខុសង្ឃចោមរោមហើយ កំពុងយាងទៅមានចិត្តជ្រះថ្លា សរសើរដោយគាថា ៣ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក ធ្វើបុណ្យហើយអន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះកើតក្នុងត្រកូលនៃស្ដេចសក្យៈក្នុងនគរកបិលពស្ដុមានឈ្មោះថា នាគិត កាលព្រះមាន

ព្រះភាគ គង់នៅក្នុងនគរកបិលពស្តុស្តាប់ មធុបិណ្ឌិកសូត្រ មានសទ្ធាបួសហើយ ចម្រើនវិបស្សនាសម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំអង្គុយនៅក្នុងរោងធំ បានឃើញ ( ព្រះបទុមុត្តរៈ ) ជាលោកនាយកទ្រង់អស់អាសវៈ ទ្រង់ដល់នូវពលធម៌ មានភិក្ខុសង្ឃចោមរោម ។ ( ខ្ញុំសរសើរថា ) ភិក្ខុសង្ឃទាំង ១ សែនអង្គសុទ្ធតែជាអ្នកបានវិជ្ជា ៣ អភិញ្ញា ៦ មានឫទ្ធិច្រើនតែងចោមរោមព្រះសម្ពុទ្ធអ្នកណាឃើញហើយនឹងមិនជ្រះថ្លាបាន ។ ( ក្នុងលោក ) ព្រមទាំងទេវលោកឥតមានញាណណានឹងប្រៀបផ្ទឹមក្នុងញាណព្រះសម្ពុទ្ធបានឡើយ អ្នកណាឃើញព្រះសម្ពុទ្ធ មានញាណរកទីបំផុតគ្មានហើយនឹងមិនជ្រះថ្លាបាន ។ម្យ៉ាងទៀត សាវកទាំងឡាយ សម្ដែងនូវធម្មកាយជាទីកើតនៃរតនៈតែប៉ុណ្ណោះ តែមិនអាចឲ្យព្រះសម្ពុទ្ធកម្រើកបានទេ អ្នកណាឃើញហើយនឹងមិនជ្រះថ្លាបាន ។ នារទបុរសគឺខ្ញុំនោះដើរទៅពីខាងមុខហើយពោលសរសើរនូវព្រះបទុមុត្តរសម្មាសម្ពុទ្ធទ្រង់ឥតមានបុគ្គលផ្ចាលផ្ចាញ់បានដោយគាថាទាំង ៣ នេះ ។ដោយចិត្តជ្រះថ្លានោះផង ដោយការស្និទ្ធស្នាលនឹងព្រះពុទ្ធជាម្ចាស់ផង ខ្ញុំមិនដែលទៅកើតក្នុងទុគ្គតិអស់ ១ សែនកប្ប ។ក្នុងកប្បទី ១៣០ អំពីកប្បនេះ ខ្ញុំបានកើតជាក្សត្រចក្រពត្តិព្រះ

នាមសុមិត្តៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មាន
កម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦
នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ
ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ(១)។

ព្រះថេរៈកាលសម្រេចអរហត្តហើយ អាស្រ័យភាពដែលទេសនារបស់ព្រះសាស្តាជារបស់ពិត និងភាពជានេយ្យានិកធម៌ ទើបកើតបីតិ និងសោមនស្ស កាលបន្លឺឧទានដែលធ្លងទៅដោយកម្លាំងនៃបីតិ បានពោលគាថាថា

ព្រះមានព្រះភាគជាសាស្តាចារ្យ កាលសម្តែងដោយព្រះអង្គ
ឯង ( ដូចផ្លែកន្ទួតព្រៃ ) ក្នុងបាតដៃ តែងប្រៀនប្រដៅសង្ឃ
យ៉ាងនេះថា ផ្លូវដ៏ប្រសើរនេះជាផ្លូវទៅកាន់ព្រះនិព្វានមិនមែន
ដូចផ្លូវរបស់តិរ្ថិយអ្នកពោលផ្សេងៗ ខាងក្រៅសាសនានេះទេ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥតោ ពហិទ្ធា** សេចក្តីថា ក្នុងសាសនាដទៃក្រៅអំពីព្រះពុទ្ធសាសនានេះ ។ ដោយហេតុនោះ ទើបលោកពោលថា **បុថុអញ្ញវាទិនំ** ដូច្នេះ អធិប្បាយថា បានដល់ តិរ្ថិយផ្សេងៗ ។

បទថា **មគ្គោ ន និព្វានគមោ យថា អយំ** សេចក្តីថា ផ្លូវដែលប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ឈ្មោះថា ជាផ្លូវទៅកាន់ព្រះនិព្វាន គឺញុំាងសត្វឲ្យដល់ព្រះនិព្វានព្រោះជាផ្លូវដែលទៅព្រះនិព្វានបានយ៉ាងណា មគ្គ

១-ក្នុងអបទានជាព្រះ អត្ថសន្ទស្សកត្ថេរ ។

*ដែលឲ្យដល់ព្រះនិព្វានមិនមានក្នុងលទ្ធិដទៃឡើយ ព្រោះជាមគ្គដែលមេលទ្ធិដទៃមិនមែនព្រះសម្មាសម្ពុទ្ធប្រកាស ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ទុកក្នុងចូឡសីហនាទសូត្រ ) ថា ម្នាលភិក្ខុទាំងឡាយ សមណៈទី ១ ( គឺ សោតាបន្ន )មានតែក្នុងសាសនានេះ សមណៈទី ២ ( គឺ សកទាគាមី )ក៏មានតែក្នុងសាសនានេះ សមណៈទី ៣ ( គឺ អនាគាមី ) ក៏មានតែក្នុងសាសនានេះ សមណៈទី ៤ ( គឺ អរហន្ត ) ក៏មានតែក្នុងសាសនានេះ វាទៈ ( គឺ ទិដ្ឋិ ៦២ ) របស់សាសនាដទៃសូន្យចាកសមណៈទាំងឡាយ ដូច្នេះ ។*

*បទថា* **ឥតិ** *ប្រែថា ដូច្នេះ ។ បទថា* **អស្សុ** *ត្រឹមតែជានិបាត ។*

*បទថា* **សង្ឃំ** *សំដៅដល់ ភិក្ខុសង្ឃ នេះជាការសម្តែងយ៉ាងឧក្រិដ្ឋ ដូចក្នុងប្រយោគថា* **សត្ថា ទេវមនុស្សានំ** *។ម្យ៉ាងទៀត បទថា* **សង្ឃំ** *ជាសមុហនាម ( ឈ្មោះដែលពោលរួម ) អធិប្បាយថា សំដៅយកជនដែលជាវេនេយ្យសត្វ ។*

*បទថា* **ភគវា** *សេចក្តីថា ឈ្មោះថា* **ភគវា** *ដោយហេតុទាំងឡាយមានភាពជាអ្នកមានជោគជាដើម នេះជាសេចក្តីសង្ខេបក្នុងពាក្យថា* **ភគវា** *នេះ ឯសេចក្តីពិស្តារ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងអដ្ឋកថាឥតិវុត្តកៈ ឈ្មោះបរមត្ថទីបនីឯណោះចុះ ។*

*បទថា* **សត្ថា** *សេចក្តីថា ឈ្មោះថា* **សាស្តា** *ដោយអត្ថថា ទូន្មានប្រៀនប្រដៅក្នុង ទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថ-*

ប្រយោជន៍ តាមសមគួរ ។

បទថា **សយំ** បានដល់ ដោយព្រះអង្គឯង ។ ក្នុងគាថានេះ មានអធិប្បាយថា ព្រះសាស្តា គឺព្រះមានព្រះភាគនៃយើងទាំងឡាយ ទ្រង់បន្លឺសីហនាទថា ឈ្មោះថាអរិយមគ្គរមែងមិនមានក្នុងលទ្ធិខាងក្រៅ ដូចអរិយមគ្គដែលញ៉ាំងសត្វឲ្យទៅកាន់ព្រះនិព្វានដែលមានអង្គ ៨ មានសម្មាទិដ្ឋិជាដើម ដែលសង្គ្រោះដោយខន្ធ ៣ មានសីលក្ខន្ធជាដើម ដែលមាននៅក្នុងសាសនារបស់តថាគត ដូច្នេះ ជាបុគ្គលដឹងដោយសយម្ភូញាណនោះឯង ឬជាបុគ្គលដែលព្រះមហាករុណា ដាស់តឿនហើយនោះឯង ទ្រង់ប្រៀនប្រដៅ គឺប្រៀនប្រដៅភិក្ខុសង្ឃ គឺប្រជុំនៃវេនេយ្យសត្វ ព្រោះព្រះអង្គមានគុណសម្បត្តិក្នុងទេសនាវិលាស ដូចទ្រង់បង្ហាញផ្លែកន្ទួតព្រៃលើបាទព្រះហស្ត ដូច្នោះ ។

## អដ្ឋកថា នាគិតត្ថេរគាថា ចប់

## បរិជួត្ថេរគាថា

[ ៨៨ ] ខន្ធទាំងឡាយ ខ្ញុំឃើញច្បាស់ហើយតាមសេចក្ដីពិត ភពទាំងពួងខ្ញុំទម្លាយហើយ ជាតិសង្សារអស់ហើយ ឥឡូវនេះភពថ្មីមិនមានទេ ។

បរិជួត្ថេរ ។

## អដ្ឋកថា

## បរិជួត្ថេរគាថា

[ ៨៨ ] គាថារបស់ព្រះបរិជួត្ថេរ មានពាក្យផ្ដើមថា **ខន្ធា ទិដ្ឋា យថាភូតំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏មានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ធ្វើបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាអត្ថទស្សី កុលបុត្តនេះបួសជាតាបសឈ្មោះថាកេសវៈ ។ ថ្ងៃមួយ ចូលគាល់ព្រះសាស្ដាស្ដាប់ធម៌ហើយ មានចិត្តជ្រះថ្លាធ្វើអភិវាទផ្គងអញ្ជលីប្រទក្សិណហើយចៀសចេញទៅ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនេះ កើតក្នុងទេវលោក ធ្វើបុណ្យតៗមកអន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ក្នុងមគធរដ្ឋ ដល់នូវភាពជាអ្នកដឹងក្ដីដោយលំដាប់ បួសជាបរិព្វាជក ព្រោះជាអ្នកមានអជ្ឈាស្រ័យបង្អោនទៅក្នុងនេក្ខម្មៈសិក្សាវត្ថុដែលគួរសិក្សាក្នុងលទ្ធិនោះ ស្ដាប់ភាពដែលឧបតិស្សបរិព្វាជក និងកោលិតបរិព្វា

ជកបួសក្នុងព្រះពុទ្ធសាសនាទើបគិតថាជម្មតាជនទាំង ២ នេះ ជាអ្នកមានបញ្ញាច្រើនបួសក្នុងទីណាទីនោះប្រហែលជាប្រសើរដោយពិត ដូច្នេះហើយទៅកាន់សម្នាក់របស់ព្រះសាស្តា ស្តាប់ធម៌ហើយ មានទូវសទ្ធាបួសហើយ ។ ព្រះសាស្តាត្រាស់ប្រាប់វិបស្សនាដល់លោក ព្រះថេរៈប្រារព្ធវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំឈ្មោះនារទៈ តែគេស្គាល់ខ្ញុំថាកេសវៈវិញ ខ្ញុំកំពុងស្វែងរកកុសលអកុសល ក៏បានទៅកាន់សំណាក់ព្រះពុទ្ធជាម្ចាស់ ។ ព្រះអត្ថទស្សីមហាមុនី មានព្រះហឫទ័យ ប្រកបដោយមេត្តាករុណា ព្រះចក្ខុមសម្ពុទ្ធអង្គនោះទ្រង់ញុំាងសត្វឲ្យស្រុះស្រួល ហើយទ្រង់តែងសម្តែងធម៌ ( ចំពោះសត្វ ) ។ ខ្ញុំបានញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយធ្វើអញ្ជលីលើសិរ្បៈ ថ្វាយបង្គំព្រះសាស្តា រួចឈមមុខទៅកាន់បាចីនទិស ចៀសចេញទៅ ។ ក្នុងកប្បទី ១១៧ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ជាម្ចាស់ផែនដី ព្រះនាមអនិមិត្តបនៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលព្យាករអរហត្តផលបានពោល

---

១-ក្នុងអបទានជាព្រះ ឯករំសេនិយត្ថេរ ។

គាថានេះថា

ខន្ធទាំងឡាយ ខ្ញុំឃើញច្បាស់ហើយតាមសេចក្តីពិត ភពទាំងពួងខ្ញុំទម្លាយហើយ ជាតិសង្សារអស់ហើយ ឥឡូវនេះភពថ្មីមិនមានទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខន្ធា** បានដល់ ឧបាទានក្ខន្ធ ៥ អធិប្បាយថា ឧបាទានក្ខន្ធ ៥ នោះ ព្រះយោគាវចរគប្បីឃើញច្បាស់ដោយការចូលទៅកំណត់វិបស្សនានិងដោយអំណាចនៃការអប់រំដោយញាតបរិញ្ញាជាដើម ។

បទថា **ទិដ្ឋា យថាភូតំ** សេចក្តីថា ឃើញហើយដោយមិនខុស ដោយន័យជាដើមថា នេះទុក្ខ ដូច្នេះ ដោយមគ្គប្បញ្ញាដែលប្រកបដោយវិបស្សនាបញ្ញា ។ បទថា **ភវា សព្វេ បទាលិតា** សេចក្តីថា ភពទាំងពួង មានកាមភពជាដើម មួយអន្លើដោយកម្មភពនិងឧបបត្តិភពខ្ញុំទម្លាយបានហើយ គឺកម្ចាត់បានហើយដោយសស្ត្រា គឺមគ្គញាណ អធិប្បាយថា កម្មភព និងឧបបត្តិភព ឈ្មោះថា ខ្ញុំទម្លាយហើយដោយការទម្លាយកិលេសបាននោះឯង ។ ដោយហេតុនោះ ទើបព្រះថេរៈពោលថា ជាតិសង្សារអស់ហើយ ឥឡូវនេះភពថ្មីមិនមានទេ ដូច្នេះ ។ អត្ថនៃគាថានោះខ្ញុំពោលទុកខាងដើមហើយនោះឯង ។

### អដ្ឋកថា បវិដ្ឋត្ថេរគាថា ចប់

## អជ្ជុនត្ថេរគាថា

[ ៨៩ ] ខ្ញុំកាលយល់ច្បាស់នូវសច្ចធម៌ទាំងឡាយ ទើបអាចនឹងរើខ្លួនឡើងចាកទឹក គឺសង្សារឡើងកាន់ទីគោក គឺព្រះនិព្វាន ដូចជាជំនន់ធំកាលបន្សាត់ទៅ ។

អជ្ជុនត្ថេរ ។

## អដ្ឋកថា

## អជ្ជុនត្ថេរគាថា

[ ៨៩ ] គាថារបស់ព្រះអជ្ជុនត្ថេរ មានពាក្យផ្ដើមថា **អសក្ខឹ វត អត្តានំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះសម្ពុទ្ធអង្គមុនៗ សន្សំកុសលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះ ៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាវិបស្សី កើតក្នុងកំណើតរាជសីហ៍ ។ ថ្ងៃមួយ ឃើញព្រះសាស្ដាគង់ត្រង់គល់ឈើមួយដើម ក្នុងព្រៃគិតថា ក្នុងសម័យនេះព្រះសាស្ដាអង្គនេះឯង ជាបុគ្គលឧត្ដមជាងសត្វទាំងពួង ជាបុរសសីហៈ ដូច្នេះហើយ ជាអ្នកមានចិត្តជ្រះថ្លាកាច់មែករាំងដែលមានផ្ការីកស្គុសស្គាយ មកបូជាព្រះសាស្ដា ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលសេដ្ឋី ក្នុងក្រុងសាវត្ថី មានឈ្មោះថា

អដ្ឋុនៈ ។ កុលបុត្តនោះចូលដល់កាពជាអ្នកដឹងក្តីហើយជាអ្នកស្និទ្ធស្នាលនឹងពួកនិគ្រន្ថ បួសក្នុងលទ្ធិនិគ្រន្ថតាំងពីក្មេងនោះឯង ដោយគិតថា អញនឹងសម្រេចអមតធម៌ដោយឧបាយ កាលមិនឃើញសារៈក្នុងលទ្ធិនោះ ឃើញយមកប្បាដិហារ្យ មានសទ្ធាហើយ ទើបបួសក្នុងសាសនា ប្រារព្ធវិបស្សនាបានជាព្រះអរហន្តក្នុងកាលមិនយូរឡើយ ។ សមដូចគាថាព័ន្ធ ដែលលោកពោលទុកក្នុងអបទានថា

គ្រានោះ ខ្ញុំកើតជាកេសរមិគរាជ ជាអភិជាត កំពុងស្វែងរកកុំដែលគេទៅបានដោយកម្រ ក៏បានឃើញព្រះលោកនាយក ( ទើបគិតថា ) ឱហ្ន៎ ព្រះមហាវីរៈនេះហើយ ទ្រង់ញុំាងមហាជនឲ្យរលត់ទុក្ខ បើដូច្នោះ គួរអាត្មាអញចូលទៅអង្គុយជិតព្រះពុទ្ធនេះព្រះអង្គជាទេវតារបស់ទេវតា ជានរាសភៈ ។ ទើបខ្ញុំកាច់យកមែករាំងព្រមទាំងចង្កោមផ្កាចូលទៅគាល់ព្រះសម្ពុទ្ធ ហើយថ្វាយផ្កាដ៏ប្រសើរ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបុប្ផទាន ។ ក្នុងកប្បទី ៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣ ជាតិ ព្រះនាមវិរោចនៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

---

១-ក្នុងអបទានជាព្រះ សាលទាយកត្ថេរ ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលនឹងបន្លឺឧទាន ដោយកម្លាំងនៃបីតិដែលកើតអំពីការសម្រេចសេចក្តីសុខដ៏កំពូល ទើបពោលគាថានេះថា

ខ្ញុំកាលយល់ច្បាស់នូវសច្ចធម៌ទាំងឡាយ ទើបអាចនឹងវង្វេន
ឡើងចាកទឹកគឺសង្សារ ឡើងកាន់ទីគោក គឺព្រះនិព្វានដូចជា
ជំនន់ធំ កាលបន្សាត់ទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសក្ខឹ** ប្រែថា ខ្ញុំអាច ។ សព្ទថា **វត** ត្រឹមតែជានិបាត ប្រើក្នុងការសម្តែងភាពអស្ចារ្យ ព្រោះថា ការចាក់ធ្លុះសច្ចៈនេះជារបស់គួរអស្ចារ្យ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ទុកក្នុងសំយុត្តនិកាយមហាវារវគ្គ ) ថា ម្នាលអានន្ទ អ្នកសម្គាល់ហេតុនោះដូចម្តេច អំពើដូចម្តេចហ្ន៎ដែលបុគ្គលធ្វើបានដោយកម្រក្រៃលែងផង ហេតុកើតឡើងព្រមដោយកម្រផង ។ ជនណា បាញ់សរតាមរន្ធចន្លោងដ៏តូចអំពីចម្ងាយឲ្យចេញទៅតៗគ្នាមិនឲ្យដាច់ ឬក៏ជនណាបាញ់ទម្លុះនូវចុងនៃចុងរោមកន្ទុយដែលច្រៀកជា ៧ ចម្រៀក ដូច្នេះជាដើម ។ បទថា **អត្តានំ** លោកពោលសំដៅដល់ចិត្តដែលប្រព្រឹត្តទៅខាងក្នុងពិតប្រាកដ ព្រោះមិនមានសភាវៈដទៃដែលជាអត្តា ។ បទថា **ឧទ្ធាតុំ** បានដល់ ដើម្បីលើកខ្លួនឡើង ។ បាឋៈទីខ្វះជា **ឧទ្ធដំ** ក៏មាន ។ បទថា **ឧទកា** បានដល់ អំពីទឹក ពោលគឺអន្លង់នៃសង្សារ ។ បទថា **ថលំ** បានដល់ ឡើងកាន់គោក គឺព្រះនិព្វាន ។ បទថា **វុយ្ហមានោ មហោឃេវ** សេចក្តីថា ដូចបុគ្គលអណ្តែតទៅតាមជំនន់ទឹកធំ ។ លោកអធិប្បាយដូច្នេះថា ប្រៀបដូចបុរសដែលត្រូវក្រសែទឹកក្តួច

អណ្តែតទៅយ៉ាងរហ័សក្នុងជំនន់ទឹកធំផង ជ្រៅផង ល្វឹងល្វើយផង មិនមានកោះមិនមានត្រើយបានជួបនូវទូកដ៏មាំទាំ រឹងប៉ឹង សម្បូរដោយចែវនិងថ្នាលបុរសដែលមានបំណងល្អខ្លះនាំទៅឲ្យ គប្បីលើកខ្លួនឡើងអំពីទឹកនោះ គឺដល់នូវត្រើយ ដោយងាយនោះឯង យ៉ាងណា អាត្មាអញ ក៏យ៉ាងនោះដូចគ្នាអណ្តែតទៅដោយកម្លាំងនៃអភិសង្ខារ គឺកិលេស ក្នុងជំនន់ទឹកធំ គឺសង្សារបាននូវទូក គឺអរិយមគ្គ ដែលចូលដល់សមថៈនិងវិបស្សនា ដែលព្រះសាស្តាទ្រង់នាំមកឲ្យ អាចលើកខ្លួនឡើងចាកទឹក គឺកិលេសនោះ គឺដើម្បីដល់ត្រើយគឺព្រះនិព្វានជាវត្ថុគួរអស្ចារ្យ ។ ព្រះថេរៈពោលថា ខ្ញុំកាលយល់ច្បាស់នូវសច្ចធម៌ទាំងឡាយ ដូច្នេះ ដើម្បីសម្តែងដល់សមត្ថភាព តាមដែលខ្លួនបានសម្តែងហើយប្រកបសេចក្តីថា ព្រោះខ្ញុំចាក់ធ្លុះអរិយសច្ច ៤ មានទុក្ខសច្ចជាដើម ដោយការចាក់ធ្លុះ ដោយការកំណត់ដឹង ដោយការលះ ដោយការធ្វើឲ្យជាក់ច្បាស់ និងដោយការចម្រើន គឺបានដឹងហើយដោយអរិយមគ្គញាណដូច្នោះ ទើបខ្ញុំអាចលើកខ្លួនឡើងអំពីទឹក គឺកិលេស ឡើងកាន់គោក គឺព្រះនិព្វាន ។

## អដ្ឋកថា អដ្ឋុនត្ថេរគាថា ចប់

## ទេវសភត្ថេរគាថា

[ ៩០ ] ខ្ញុំចូងឡើងផុតចាកភក់ ចាកល្បាប់ គឺកិលេសហើយ វៀរស្រឡះហើយចាកបាតាល ( ទំនាប ) គឺយោគៈ រួចផុតហើយចាកឱឃៈផង គន្ថៈផង មានះទាំងពួងខ្ញុំកម្ចាត់បង់ហើយ ។

*ទេវសភត្ថេរ ។*

## អដ្ឋកថា

## ទេវសភត្ថេរគាថា

[ ៩០ ] គាថារបស់ព្រះទេវសភត្ថេរ មានពាក្យផ្ដើមថា **ឧត្តិណ្ណា បង្កបលិបា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថា សិខី កើតក្នុងកំណើតនៃព្រានអ្នកសម្លាប់សត្វ ។ ថ្ងៃមួយ ឃើញព្រះសាស្ដាហើយ មានចិត្តជ្រះថ្លា បង្អោនផ្លែទ្រយឹងថ្វាយ ។ ដើម្បីចម្រើននូវបសាទសទ្ធារបស់កុលបុត្តនោះព្រះសាស្ដាទ្រង់សោយផ្លែទ្រយឹងនោះ ។ កុលបុត្តនោះ មានចិត្តជ្រះថ្លាពន់ពេក ដោយឃើញព្រះសាស្ដាសោយផ្លែទ្រយឹងនោះ ចូលទៅគាល់តាមកាលវេលា ធ្វើចិត្តឲ្យជ្រះថ្លាហើយ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក ធ្វើបុណ្យតៗ មក

អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្ត របស់ព្រះរាជាអ្នកគ្រប់គ្រងមណ្ឌលមួយអង្គ តាំងនៅក្នុងរាជសម្បត្តិតាំងអំពី នៅក្មេងនោះឯង សោយនូវសេចក្ដីសុខក្នុងរាជសម្បត្តិ លុះដល់ជរាភាពចូល ទៅគាល់ព្រះមុនីទ្រង់សម្ដែងធម៌ ដល់ព្រះរាជាអង្គនោះ ទ្រង់ស្ដាប់ធម៌ហើយ បាននូវសទ្ធា មានព្រះទ័យសង្វេគលះរាជសម្បត្តិបួសហើយ ចម្រើនវិបស្ស-នាសម្រេចអរហត្តក្នុងកាលមិនយូរឡើយសមដូចគាថាព័ន្ធដែលលោកពោល ទុកក្នុងអបទានថា

គ្រានោះ ខ្ញុំកើតជាសត្វបរោជកៈ ជាសត្វបរោជកៈយ៉ាងតូច បំផុត ទទួលទានដំណោកនៅក្បែរញកភ្នំក្នុងទីជិតសំណាក់ព្រះ សាស្ដាព្រះនាមសិខី ។ ខ្ញុំតែងឃើញព្រះពុទ្ធជាលោកនាយក ទាំងល្ងាចព្រឹក តែខ្ញុំនឹងរកទេយ្យធម៌ថ្វាយព្រះសម្ពុទ្ធមានព្រះ ទ័យនឹងប្រសើរជាងសត្វជើងពីរពុំបាន ។ ខ្ញុំបានយកផ្លែទ្រយឹង ទៅកាន់សំណាក់ព្រះពុទ្ធ ព្រះមានព្រះភាគជាច្បងក្នុងលោកជា នរាសភៈទ្រង់ក៏បានទទួលយក ។ លំដាប់តពីនោះ ខ្ញុំធ្វើមរណ កាលក្នុងទីនោះដោយចិត្តជ្រះថ្លា អាស្រ័យព្រះវិនាយក ដែល ខ្ញុំប្រាថ្នាហើយនោះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះ ហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជា ផលនៃផលទាន ។ ក្នុងកប្បទី ១៥ អំពីកប្បនេះ បានកើត ជាស្ដេចចក្រពត្តិ ៣ ជាតិព្រះនាមនាលកិ ទ្រង់បរិបូណ៌ដោយ

កែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ(១) ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កើតសោមនស្សដោយអំណាចនៃការពិចារណាដល់កិលេសដែលលះហើយ កាលនឹងបន្លឺឧទាន ទើបពោលគាថានេះថា

ខ្ញុំឆ្លងឡើងផុតចាកភក់ ចាកល្បាប់ គឺ កិលេសហើយ វៀរស្រឡះហើយចាកបាតាល ( ទំនាប ) គឺ យោគៈ រួចផុតហើយចាកឱឃៈផង គន្ថៈផង មានះទាំងពួងខ្ញុំកម្ចាត់បង់ហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧត្តិណ្ណា** សេចក្តីថា ឆ្លងផុត គឺឈានកន្លងហើយ ។ បទថា **បង្កបលិបា** បានដល់ ភក់ផង ល្បាប់ផង ។ ភក់ដោយប្រក្រតីលោកហៅថា **បង្ក** ភក់ដែលធំផងជ្រៅផងលោកហៅថា **បលិប** តែក្នុងគាថានេះសំដៅយកសភាវៈឈ្មោះថា **បង្ក** ព្រោះដូចភក់ បានដល់ កាមរាគៈ ព្រោះចិត្តត្រូវប្រឡាក់ដោយភាពមិនស្អាត ។ សភាវៈដែលឈ្មោះថា **បលិប** ព្រោះដូចភក់ បានដល់ ឆន្ទរាគៈដែលក្រាស់មានកូនប្រពន្ធជាដើមជាអារម្មណ៍ព្រោះត្រូវប្រឡាក់ និងព្រោះឆ្លងផុតបានដោយក្រ ដោយន័យដូចពោលហើយឆន្ទរាគៈជាដើមនោះ ខ្ញុំឈានកន្លងហើយ ដោយប្រការទាំងពួង

១-ក្នុងអបទានជាព្រះ ផលទាយកត្ថេរ ។

*ដោយអនាគាមិមគ្គ ព្រោះហេតុនោះ ទើបព្រះថេរៈពោលថា ខ្ញុំធ្វងឡើងផុត ចាកភក់ ចាកល្បាប់ គឺកិលេសហើយ ដូច្នេះ ។*

*បទថា* **ធាតាលា** *សេចក្តីថា ឈ្មោះថា* **ធាតាល** *ព្រោះដូចជានគរ-បាតាល បានដល់ បទេសដែលនៅទាបជាងមហាសមុទ្រ ។ ឯអាចារ្យពួកខ្លះហៅនាគពិភពថា បាតាល ។ តែក្នុងគាថានេះ សភាវៈដែលឈ្មោះថា បា-តាល បានដល់ ទិដ្ឋិ ព្រោះដូចនគរបាតាល ដោយអត្ថថា ពាល់ត្រូវមិនបានស្ងប់បានលំបាក និងធ្វងបានដោយក្រ ។ ទិដ្ឋិទាំងនោះ ខ្ញុំវៀរបានហើយ គឺផ្តាច់ផ្តិលហើយ ដោយប្រការទាំងពួង ព្រោះបានសម្រេចបឋមមគ្គនោះឯង ព្រោះហេតុនោះ ទើបព្រះថេរៈពោលថា វៀរស្រឡះហើយចាកបាតាល ( ទំនាប ) គឺយោគៈ ដូច្នេះ ។*

*បទថា* **មុត្តោ ឱឃា ច គន្ថា ច** *សេចក្តីថា ខ្ញុំផុតហើយ គឺផុតជុំវិញហើយចាកឱឃៈ មានកាមោឃៈជាដើម និងចាកគ្រឿងរួបរឹត មានអភិជ្ឈាកាយគន្ថៈជាដើម ដោយមគ្គនោះៗ អធិប្បាយថា ឈានកន្លងហើយដោយមិនមានកិលេសជាគ្រឿងវិលវល់ និងកិលេសជាគ្រឿងរួបរឹត ។*

*បទថា* **សព្វេ មានា វិសំហតា** *សេចក្តីថា មានះទាំង ៩ យ៉ាង ដល់នូវការសម្លាប់ គឺដល់នូវសេចក្តីវិនាស គឺត្រូវដកឡើងដោយវិសេស ដោយការសម្រេចមគ្គជាន់ខ្ពស់ ( អរហត្ត ) ។ អាចារ្យពួកខ្លះពោលថា* **មានវិធា-ហតា** *ប្រែថា មានះខ្លះត្រូវសម្លាប់ហើយ អធិប្បាយថា មានះចំណែកខ្លះត្រូវទម្លាយ ។ អាចារ្យពួកខ្លះពោលថា* **មានវិសា** *ប្រែថា មានមានះជាពិស*

ដូច្នេះក៏មាន ។ បណ្ឌិតគប្បីយល់អត្ថរបស់អាចារ្យទាំងនោះថា ឈ្មោះថា មានមានះជាពិស ព្រោះមានះដែលជាពិសមានផលជាទុក្ខ ។

## អដ្ឋកថា ទេវសភត្ថេរគាថា ចប់

# សាមិទត្តត្ថេរគាថា

[ ៩១ ] ខន្ធ ៥ ខ្ញុំកំណត់ដឹងហើយ ខន្ធ ៥ មានឫសគល់ដាច់ហើយ ជាតិសង្សារអស់ហើយ ភពថ្មីទៀត ( របស់ខ្ញុំ ) មិនមានក្នុងកាលឥឡូវនេះ ។

## សាមិទត្តត្ថេរ ។

## ឧទ្ទាន

និយាយអំពីសមិតិគុត្តត្ថេរ ១ កស្សបត្ថេរ ១ សីហត្ថេរ ១ នីតត្ថេរ ១ សុនាគត្ថេរ ១ នាគិតត្ថេរ ១ បវិដ្ឋត្ថេរ ១ អជ្ជុនជាឥសី ១ ទេវសភត្ថេរ ១ សាមិទត្តត្ថេរមានកម្លាំងច្រើន ១ ។

## ចប់ នវមវគ្គ ។

# អដ្ឋកថា

# សាមិទត្តត្ថេរគាថា

[ ៩១ ] គាថារបស់ព្រះសាមិទត្តត្ថេរ មានពាក្យផ្ដើមថា **បញ្ចក្ខន្ធា បរិញ្ញាតា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថា អត្ថទស្សី កើតក្នុងផ្ទះនៃត្រកូលដល់នូវភាពជាអ្នកដឹងក្ដីហើយ ។ កាលព្រះសាស្ដាបរិនិព្វានហើយ កុលបុត្តនោះ ធ្វើឆត្របួតដោយផ្កាទាំងឡាយ ធ្វើការបូជាត្រង់ស្តូបរបស់ព្រះសាស្ដា ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក ធ្វើបុណ្យតៗមក អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនរបស់ព្រាហ្មណ៍ម្នាក់ក្នុងក្រុងរាជគ្រឹះមានឈ្មោះថាសាមិទត្ត ។

កុលបុត្តនោះដឹងក្ដីដោយលំដាប់ បានឮអំពីអានុភាពរបស់ព្រះពុទ្ធហើយ ទៅកាន់វិហារមួយអន្លើដោយឧបាសកទាំងឡាយ ឃើញព្រះសាស្ដា កំពុងសម្ដែងធម៌ជាអ្នកមានចិត្តជ្រះថ្លាហើយ អង្គុយក្នុងចំណែកម្ខាង ។

ព្រះសាស្ដាទ្រង់ប្រមើលមើលឧបនិស្ស័យរបស់កុលបុត្តនោះហើយ ទ្រង់សម្ដែងធម៌ អនុលោមតាមអជ្ឈាស្រ័យ ជាហេតុឲ្យកុលបុត្តនោះបាននូវសទ្ធានិងសេចក្ដីសង្វេគក្នុងសង្សារ ។ កុលបុត្តនោះបាននូវសទ្ធាកើតនូវការសង្វេគហើយ ទើបចេញបួស ជាអ្នកខ្ជិលច្រអូសមួយរយៈ ព្រោះញាណមិនទាន់ចាស់ក្លាត្រូវព្រះសាស្ដាទ្រង់សម្ដែងធម៌ជម្រុញឲ្យអាចហ៊ាន ទើបរៀនកម្មដ្ឋាន

ប្រកបសេចក្ដីខ្វល់ខ្វាយក្នុងកម្មដ្ឋាន សម្រេចអរហត្ត ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលព្រះមានព្រះភាគព្រះនាមអត្ថទស្សី ទ្រង់ប្រសើរជាងពួកនរៈទ្រង់បរិនិព្វានហើយ ខ្ញុំបានឲ្យគេធ្វើឆត្របួត ហើយឲ្យលើកឡើងត្រង់ព្រះស្តូប ។ ខ្ញុំបានមកនមស្ការ ព្រះលោកនាយកសព្វៗកាល ហើយធ្វើគ្រឿងប្រក់ដោយផ្កា លើកឡើងតម្កល់ពីខាងលើឆត្រ ។ ក្នុងកប្បទី ១១៧ អំពីកប្បនេះខ្ញុំបានសោយជាទេវរាជ ខ្ញុំមិនដែលទៅកើតជាមនុស្សម្តងឡើយ នេះជាផលនៃថូបបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ក្នុងកាលតមក ព្រះថេរៈត្រូវភិក្ខុទាំងឡាយសួរថា អាវុសោ លោកបានឧត្តរិមនុស្សធម៌ហើយឬ កាលប្រកាសភាពដែលព្រះសាសនាជានិយ្យានិកធម៌ និងការបដិបត្តិធម៌សមគួរដល់ធម៌របស់ខ្លួនដល់ភិក្ខុទាំងនោះ ទើបព្យាករអរហត្តផល ដោយគាថានេះថា

ខន្ធ ៥ ខ្ញុំកំណត់ដឹងហើយ ខន្ធ ៥ មានឫសគល់ដាច់ហើយ ជាតិសង្សារអស់ហើយ ភពថ្មីទៀត ( របស់ខ្ញុំ ) មិនមានក្នុងកាលឥឡូវនេះ ដូច្នេះ ។

---

១-ក្នុងអបទានជាព្រះ អធិចត្តិយត្ថេរ ។

បណ្ដាបទទាំងនោះ បទថា **បញ្ចក្ខន្ធា បរិញ្ញាតា** សេចក្ដីថា ឧបាទានក្ខន្ធ ៥ ខ្ញុំកំណត់ហើយ គឺដឹងហើយ ជាក់ច្បាស់ហើយ បានដល់ ចាក់ធ្លុះហើយដោយបរិញ្ញា ៣ គឺដឹងថា នេះទុក្ខ ទុក្ខមានប្រមាណប៉ុណ្ណេះ មិនមានទុក្ខក្រៃលែងជាងនេះឡើយ ដូច្នេះ ។ បទថា **តិដ្ឋន្តិ ឆិន្នមូលកា** សេចក្ដីថា ឥឡូវនេះ បញ្ចក្ខន្ធទាំងនោះ ឈ្មោះថា មានឫសគល់ខ្ញុំកាត់ផ្ដាច់ហើយតាំងនៅរហូតដល់ការរលត់នៃចិត្តចុងក្រោយ ព្រោះបញ្ចក្ខន្ធទាំងនោះ ខ្ញុំកំណត់ដឹងហើយដោយអាការយ៉ាងនោះឯង និងព្រោះសមុទយៈដែលជាហេតុឲ្យកើតទុក្ខខ្ញុំលះបានហើយដោយប្រការទាំងពួង ។ ឯបញ្ចក្ខន្ធដែលមិនមានបដិសន្ធិរមែងរលត់ទៅដោយការរលត់នៃចិត្តចុងក្រោយដោយហេតុនោះ ទើបព្រះថេរៈពោលថា ជាតិសង្សារអស់ហើយ ភពថ្មីទៀត... ដូច្នេះ ។ អត្ថនៃគាថានោះខ្ញុំបានពោលខាងដើមហើយ ។

**អដ្ឋកថា សាមិទត្តត្ថេរគាថា ចប់**

**វគ្គទី ៩ ចប់**

# ថេរគាថា ឯកនិបាត

## ទសមវគ្គ

### បរិបុណ្ណកត្ថេរគាថា

[ ៩២ ] សុធាភោជនមានរសទាំងរយ អាត្មាអញមិនសរសើរដូចភោជនគឺនិព្វានសុខដែលអាត្មាអញបរិភោគហើយក្នុងថ្ងៃនេះទេ ធម៌ដែលព្រះពុទ្ធគោតម ព្រះអង្គឃើញដោយបញ្ញារាប់មិនបាន ទ្រង់សម្ដែងហើយ ( ទើបជាធម៌មានរសច្រើន ) ។

បរិបុណ្ណកត្ថេរ ។

## វគ្គទី ១០

### អដ្ឋកថា

### បរិបុណ្ណកត្ថេរគាថា

[ ៩២ ] គាថារបស់ព្រះបរិបុណ្ណកត្ថេរ មានពាក្យផ្ដើមថា **ន តថា មតំ សតរសំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាធម្មទស្សី កុលបុត្តនេះ កើតក្នុងផ្ទះមានត្រកូលដល់នូវភាពជាអ្នកដឹងក្ដីហើយ ។ កាលព្រះសាស្ដាបរិនិព្វានហើយ បានធ្វើការបូជាដ៏ឧឡារដោយគ្រឿងសក្ការៈ មានផ្កា

ជាដើម ត្រង់ចេតិយរបស់ព្រះសាស្តា ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងពួកទេវតាទាំងឡាយ ធ្វើបុណ្យហើយ អន្ទោលទៅមកតែក្នុងសុគតិភពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះកើតក្នុងត្រកូលនៃស្តេចសក្យៈក្នុងនគរកបិលពស្តុ ដល់នូវភាពជាអ្នកដឹងក្តីហើយប្រាកដឈ្មោះថា បរិបុណ្ណកៈ ព្រោះជាអ្នកមានសម្បត្តិបរិបូណ៌ ។

កុលបុត្តនោះ បរិភោគអាហារឈ្មោះសតរស អស់កាលដ៏យូរ ព្រោះជាអ្នកសម្បូរដោយសម្បត្តិ ស្តាប់ដំណឹងថាព្រះបរមសាស្តា ទ្រង់សោយព្រះក្រយាហារដែលលាយគ្នា កើតសេចក្តីសង្វេគក្នុងសន្តានថា ព្រះសាស្តាទ្រង់ជាក្សត្រសុខុមាលជាតិ ទ្រង់សម្ពឹងដល់សុខក្នុងព្រះនិព្វាន ទ្រង់ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយអាហារតាមមានតាមបាន ចុះហេតុអ្វី ពួកយើងនាំគ្នាល្មោភក្នុងអាហារ បរិភោគតែអាហារដែលបរិសុទ្ធ សមគួរដែលពួកយើងស្វែងរកសេចក្តីសុខ គឺព្រះនិព្វានតែម្យ៉ាង ដូច្នេះ ។ កុលបុត្តនោះ លះឃរាវាសវិស័យ ហើយបួសក្នុងសម្នាក់របស់ព្រះសាស្តា កាលព្រះសាស្តាទ្រង់ទូន្មានក្នុងកាយគតាសតិកម្មដ្ឋាន តាំងនៅក្នុងកាយគតាសតិកម្មដ្ឋាននោះ ធ្វើឈានដែលបានហើយឲ្យជាបាទធ្វើកម្មក្នុងវិបស្សនា ហើយចម្រើនវិបស្សនាកម្មដ្ឋានសម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលព្រះលោកនាថ ព្រះនាមធម្មទស្សី ជានរាសភៈ ទ្រង់
បរិនិព្វាន ខ្ញុំបានលើកដងទង់ ត្រង់ចេតិយរបស់ព្រះសម្ពុទ្ធដ៏
ប្រសើរ ។ ខ្ញុំបានធ្វើជណ្តើរសម្រាប់ឡើងទៅកាន់ព្រះស្តូបដ៏

ប្រសើរ បានទាំងយកផ្កាជាតិព្រឹកទៅដោតលើព្រះស្តូបដោយតាំងចិត្តថាព្រះពុទ្ធជាបុគ្គលអស្ចារ្យ ព្រះធម៌ជាសភាពអស្ចារ្យ សម្បទារបស់ព្រះសាស្តានៃយើងជារបស់អស្ចារ្យ ។ ដោយសារកុសលកម្មនេះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបូជា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១៦ ជាតិ ព្រះនាម ថូបសិខៈ ដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលបន្លឺឧទានដោយកម្លាំងនៃបីតិដោយមានសេចក្តីគោរពនិងរាប់អានច្រើនក្នុងព្រះធម៌បានពោលគាថានេះថា

សុធាភោជនមានរសទាំងរយអាត្មាអញមិនសរសើរដូចភោជនគឺនិព្វានសុខដែលអាត្មាអញបរិភោគហើយ ក្នុងថ្ងៃនេះទេ ធម៌ដែលព្រះពុទ្ធគោតមព្រះអង្គឃើញដោយបញ្ញារាប់មិនបានទ្រង់សម្តែងហើយ ( ទើបជាធម៌មានរសច្រើន ) ដូច្នេះ ។

បទថា **ន តថាមតំ សតរសំ សុធន្នំ យំ មយជ្ជ បរិភុត្តំ** នោះ ពាក្យថា **តថា** បានដល់ ដោយប្រការនោះ ។ បទថា **មតំ** បានដល់ គួរប្រាថ្នា ។

---

១-ក្នុងអបទានជាព្រះ ថូម្ពារោបកត្ថេរ ។

បទថា **សតរសំ** បានដល់ ភោជនមានរស ១០០ ។ អាចារ្យពួកខ្លះពោលថា ភោជនដែលគេផ្សំដោយសប្បិដែលចម្រាញ់ ១០០ ដងជាដើម ឈ្មោះថា សតរសភោជន គឺភោជនដែលមានរស ១០០ ។ម្យ៉ាងទៀត សព្ទថា **សត** មានអត្ថជាអនេក ដូចក្នុងប្រយោគជាដើមថា **សតសោ សហស្សសោ** ( ជាមួយរយ ជាមួយពាន់ ) ។ ព្រោះហេតុនោះ ភោជនណាមានសូបៈជាអនេក មានព្យញ្ជនៈជាអនេក ភោជននោះ លោកហៅថា **សតរស** ព្រោះមានរសមិនមែនតិច អធិប្បាយថា បានដល់ ភោជនមានរសផ្សេងៗគ្នា ។ បាយដែលស្អាតនោះឯង ហៅថា **សុធន្នំ** ( សុធាភោជន ) ជាអាហាររបស់ទេវតាទាំងឡាយ ។

បទថា **យំ មយជ្ជ បរិភុត្តំ** ក៏គឺ **យំ មយា អជ្ជ អនុភុត្តំ** ។ បទថា **យំ មយា បរិភុត្តំ** នេះ គប្បីប្រកបជាមួយពាក្យថា **សតរសំ សុធន្នំ** នេះផងដែរ ។ លោកអធិប្បាយទុកដូច្នេះថា និព្វានសុខណា ស្ងប់ ប្រណីតដោយចំណែកមួយដែលខ្ញុំសោយក្នុងថ្ងៃនេះ គឺក្នុងឥឡូវនេះ ដោយអំណាចនៃការចូលនិរោធសមាបត្តិ និព្វានសុខនោះ ខ្ញុំត្រេកអរហើយ ប្រាថ្នាហើយ សរសើរហើយដោយប្រការណា ភោជនមានរស ១០០ ដែលខ្ញុំបរិភោគហើយក្នុងពេលសោយរាជ្យក្តី សុធាភោជនដែលខ្ញុំបរិភោគហើយក្នុងអត្តភាពរបស់ទេវតាក្តី មិនគួរត្រេកអរ មិនគួរប្រាថ្នាដោយប្រការនោះ ព្រោះហេតុអ្វី ព្រោះនិព្វានសុខនេះព្រះអរិយៈទាំងឡាយសេពហើយមិនជាទីតាំងនៃកិលេសទាំងឡាយ តែភោជនមានរសរាប់រយនោះដែលបុថុជ្ជនសេពហើយ ប្រព្រឹត្ត

ទៅដោយអាមិស ជាទីតាំងនៃកិលេសទាំងឡាយ ទើបកោជនដែលមានរស ១០០ មិនដល់នូវការរាប់គឺមិនដល់មួយចម្រៀក បានដល់ មិនចូលដល់មួយចំណែកនៃនិញ្វានសុខនោះ ។

ឥឡូវនេះ ព្រះថេរៈកាលសម្តែងធម៌ដែលលោកពោលថា **យំ មយដ្ឋ បរិភុត្តំ** ដូច្នេះជាដើម ទើបពោលថា **អបរិមិតឧស្សិនា គោតមេន ពុទ្ធ-ធនេសិតោ ធម្មោ** ដូច្នេះ ។

គាថានោះ មានពាក្យអធិប្បាយដូច្នេះថា ព្រះមានព្រះភាគទ្រង់ឃើញព្រះនិញ្វានដែលប្រមាណមិនបាន កំណត់មិនបាន ឈ្មោះថាស្ងប់ហើយ ព្រោះមិនមានការកើតឡើងនិងការអស់ទៅ ជាអសង្ខតធាតុ ដោយព្រះសយម្ភូញាណ គឺទ្រង់ឃើញនូវញេយ្យធម៌មិនមានប្រមាណ គឺប្រមាណមិនបាន ព្រោះហេតុនោះ ធម៌ដែលព្រះសម្មាសម្ពុទ្ធគោតម ដែលមានប្រក្រតីឃើញធម៌ប្រមាណមិនបានអង្គនោះទ្រង់សម្តែងហើយដោយល្អដោយន័យជាដើមថា ព្រះធម៌ណាជាទីក្ស័យទៅនៃកិលេស ជាទីប្រាសចាករាគៈ ជាធម៌មិនស្លាប់ ជាធម៌ឧត្តម ដូច្នេះ ឬថា ជាធម៌សម្រាប់បន្ទោបង់នូវសេចក្តីស្រវឹង ជាធម៌កម្ចាត់បង់នូវសេចក្តីស្រេកឃ្លាន ដូច្នេះ ឬថា ការរម្ងាប់សង្ខារទាំងអស់ ដូច្នេះ ព្រះនិញ្វាននោះ ខ្ញុំសោយហើយក្នុងថ្ងៃនេះ ។

អដ្ឋកថា បរិបុណ្ណកត្ថេរគាថា ចប់

## វិជយត្ថេរគាថា

[ ៩៣ ] ភិក្ខុណា មានអាសវៈអស់ហើយ មិនជ្រប់ក្នុងអាហារ ភិក្ខុណាមានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ ( អប្បណិហិតវិមោក្ខ ) ជាអារម្មណ៍ ស្នាមជើងរបស់ភិក្ខុនោះៗ បុគ្គលតាមរកឃើញបានដោយក្រ ដូចស្នាមជើងនៃសត្វស្លាបក្នុងអាកាស ។

**វិជយត្ថេរ ។**

## អដ្ឋកថា

## វិជយត្ថេរគាថា

[ ៩៣ ] គាថារបស់ព្រះវិជយត្ថេរ មានពាក្យផ្តើមថា **យស្សាសវា បរិក្ខីណា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាបិយទស្សី កុលបុត្តនេះ កើតក្នុងត្រកូលដែលសម្បូរដោយសម្បត្តិ ជាអ្នកដឹងក្តីហើយ ។ កាលព្រះសាស្តាទ្រង់បរិនិព្វានហើយ ឲ្យជាងធ្វើវេទិកា គឺទែនដាក់គ្រឿងសក្ការៈរំលេចដោយរតនៈ សម្រាប់ព្រះស្តូបរបស់ព្រះមានព្រះភាគ ព្រះនាមថា បិយទស្សី ហើយធ្វើការឆ្លងវេទិកានោះដ៏ឧឡារ ត្រង់ព្រះស្តូបនោះ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ ត្រាច់ទៅដោយពន្លឺនៃកែវមណីច្រើនរយអត្តភាព កាលកុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ

យ៉ាងនេះ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ក្នុងនគរសាវត្ថី មានឈ្មោះថាវិជយៈ ។ វិជយព្រាហ្មណ៍ចម្រើនវ័យហើយ សម្រេចការសិក្សាក្នុងវិជ្ជារបស់ព្រាហ្មណ៍ទាំងឡាយ បួសជាតាបស ជាអ្នកបានទូវឈានទៅត្រង់ជាយព្រៃ ស្តាប់ការកើតឡើងនៃព្រះពុទ្ធហើយ មានចិត្តជ្រះថ្លា ចូលទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំហើយអង្គុយក្នុងចំណែកម្ខាង ព្រះសាស្តាទ្រង់សម្តែងធម៌ដល់កុលបុត្តនោះហើយ កុលបុត្តនោះស្តាប់ធម៌ហើយបួស ផ្តើមចម្រើនវិបស្សនា សម្រេចអរហត្ត ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

កាលព្រះលោកនាថ ព្រះនាមបិយទស្សី ជានរៈដ៏ឧត្តម ទ្រង់បរិនិព្វានហើយ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បានសាងខឿនចេតិយ សម្រាប់ជាពុទ្ធបូជា ។ ខ្ញុំព័ទ្ធខឿននោះដោយកែវមណីហើយរៀបចំធ្វើបុណ្យឆ្លងខឿនដ៏ប្រសើរហើយក៏ធ្វើមរណកាល ក្នុងកាលនោះ ។ ខ្ញុំទៅកើត ក្នុងកំណើតណាៗ ទោះបីជាទេវតា ឬជាមនុស្ស ទេវតាទាំងឡាយតែងបាំងកែវមណីដ៏អាកាស ( ចំពោះខ្ញុំ ) នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ១១៦ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣២ ជាតិ ព្រះនាមមណិប្បកាសដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបាន

ប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផល បានពោលគាថានេះថា

ភិក្ខុណា មានអាសវៈអស់ហើយ មិនជ្រប់ក្នុងអាហារ ភិក្ខុណាមានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ ( អប្បណិហិតវិមោក្ខ ) ជាអារម្មណ៍ ស្នាមជើងរបស់ភិក្ខុនោះៗ បុគ្គលតាមរកឃើញបានដោយក្រដូចស្នាមជើងនៃសត្វស្លាបក្នុងអាកាស ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យស្សាសវា បរិក្ខីណា** សេចក្ដីថា អាសវៈ ៤ មានកាមាសវៈជាដើម របស់ឧត្តមបុគ្គលណាអស់ហើយដោយប្រការទាំងពួង គឺអស់ទៅហើយដោយអរិយមគ្គ ។

បទថា **អាហារេ ច អនិស្សិតោ** សេចក្ដីថា បុគ្គលណាមិនជាប់ គឺមិនលុះអំណាចនៃចំណង់ បានដល់ មិនដល់នូវការល្មោភក្នុងអាហារ ដោយធម៌ជាគ្រឿងជាប់ជំពាក់ គឺតណ្ហា និងទិដ្ឋិ បទនេះត្រឹមតែជាឧបមា គប្បីជ្រាបថា ក្នុងគាថានេះ លោកកាន់យកបច្ច័យទាំង ៤ ដោយសព្ទដែលជាប្រធាន គឺ **អាហារ** សព្ទ ម្យ៉ាងទៀត គប្បីជ្រាបថា ក្នុងគាថានេះ **អាហារ** សព្ទ គឺបច្ច័យដោយអម ។

ក្នុងបទថា **សុញ្ញតោ អនិមិត្តោ ច** នេះ លោកសំដៅយកអប្បណិហិតវិមោក្ខចូលផងដែរ ។ វិមោក្ខទាំង ៣ នេះ ជាឈ្មោះនៃព្រះនិព្វានទាំង

---

១-ក្នុងអបទានជាព្រះ វេទិការកត្ថេរ ។

អស់ អធិប្បាយថា ព្រះនិព្វាន ឈ្មោះថា ទទេ ព្រោះមិនមានកិលេស មានរាគៈជាដើម លោកហៅថា សុញ្ញតវិមោក្ខ ព្រោះទទេនិងផុតចាកកិលេសមានរាគៈជាដើមនោះ ។ ម្យ៉ាងទៀត ព្រះនិព្វានឈ្មោះថា អនិមិត្តវិមោក្ខ ព្រោះមិនមាននិមិត្តដោយការមិនមាននិមិត្តមានរាគៈជាដើមនិងព្រោះមិនមានសង្ខារនិមិត្តនិងជាវិមុត្តិ ។ ឈ្មោះថា អប្បណិហិតវិមោក្ខ ព្រោះកិលេសទាំងនោះតាំងនៅមិនបានដោយមិនមានទីតាំងនៃកិលេសមានរាគៈជាដើមនិងជាវិមុត្តិ ។ វិមោក្ខ ៣ យ៉ាងនេះ ជាគោចររបស់ភិក្ខុណាដែលធ្វើព្រះនិព្វាននោះឲ្យជាអារម្មណ៍ហើយនៅដោយអំណាចនៃផលសមាបត្តិ ។

បទថា **អាកាសេវ សកុន្តានំ បទំ តស្ស ទុរន្វយំ** សេចក្តីថា ស្នាមជើងរបស់បក្សីទាំងឡាយ ដែលហើរទៅក្នុងអាកាសដែលបុគ្គលមិនអាចដឹងបានថា បក្សីទាំងឡាយប្រើជើងជាន់ក្នុងទីនេះហើយហើរទៅ ប៉ះត្រង់ទីនេះដោយពោះហើយហើរទៅ ប៉ះត្រង់ទីនេះដោយក្បាលហើយហើរទៅ ប៉ះត្រង់ទីនេះដោយស្លាបហើយហើរទៅ ដូចេ្នះ យ៉ាងណា សម្រាប់ភិក្ខុបែបនេះ ក៏យ៉ាងនោះ បុគ្គលមិនអាចដឹងបានថា ទៅហើយក្នុងផ្លូវទាំងឡាយ មានផ្លូវនរកជាដើម ដោយផ្លូវឈ្មោះនេះ ដូចេ្នះ ។

## អដ្ឋកថា វិជយត្ថេរគាថា ចប់

## ឯរកត្ថេរគាថា

[ ៩៤ ] ម្នាលឯរកៈ កាមទាំងឡាយជាទុក្ខ ម្នាលឯរកៈ កាមទាំងឡាយមិនមែនជាសុខទេ ម្នាលឯរកៈ បុគ្គលណាប្រាថ្នាកាម បុគ្គលនោះ ឈ្មោះជាប្រាថ្នាទុក្ខ ម្នាលឯរកៈ បុគ្គលណាមិនប្រាថ្នាកាម បុគ្គលនោះ ឈ្មោះជាមិនប្រាថ្នាទុក្ខទេ ។

ឯរកត្ថេរ ។

## អដ្ឋកថា

## ឯរកត្ថេរគាថា

[ ៩៤ ] គាថារបស់ព្រះឯរកត្ថេរ មានពាក្យផ្ដើមថា **ទុក្ខា កាមា ឯរក** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏មានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទុកក្នុងភពនោះៗជាច្រើន ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមថាសិទ្ធត្ថ កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ។ ថ្ងៃមួយឃើញព្រះសាស្ដា ជាអ្នកមានចិត្តជ្រះថ្លា កាលរករបស់អ្វីមួយដែលគួរថ្វាយព្រះបរមសាស្ដាមិនបាន ទើបគិតថា ណ្ហើយចុះ អញនឹងប្រើកម្លាំងកាយបំពេញបុណ្យដូច្នេះហើយ ក្ការផ្លូវសម្រាប់ព្រះសាស្ដាធ្វើផ្លូវឲ្យរាបស្មើហើយ ។ ព្រះសាស្ដាយាងទៅតាមផ្លូវដែលកុលបុត្តនោះធ្វើហើយយ៉ាងនោះ កុលបុត្តនោះឃើញព្រះមានព្រះភាគយាងទៅតាមផ្លូវនោះជា

អ្នកមានចិត្តជ្រះថ្លា ថ្វាយបង្គំហើយ ផ្គងអញ្ជលី មានព្រះពុទ្ធជាអារម្មណ៍មិនលះបង់បីតិ រហូតដល់ព្រះមានព្រះភាគយាងទៅផុតអំពីទស្សនវិស័យ ( ដាច់កន្ទុយភ្នែក ) ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក ធ្វើបុណ្យរឿយៗ អន្ទោលទៅមកតែក្នុងសុគតិភពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តរបស់កុដុម្ពិកៈក្នុងនគរសាវត្ថី មានឈ្មោះថា ឯរកៈ ជាអ្នកមានរូបល្អ គួរមើល គួរជ្រះថ្លា មានការឈ្លាសវៃក្រៃលែងក្នុងកិច្ចធំតូច ។ មាតាបិតារបស់កុលបុត្តនោះ នាំទារិកាដែលសមគ្នាដោយត្រកូល រូប មារយាទ វ័យ និងការឈ្លាសវៃមករៀបអាពាហ៍ពិពាហ៍ឲ្យ កុលបុត្តនោះ នៅគ្រប់គ្រងផ្ទះ ជាមួយទារិកា ហើយកើតសេចក្ដីសង្វេគក្នុងសង្សារ ដោយអារម្មណ៍ដែលជាទីតាំងនៃសេចក្ដីសង្វេគណាមួយ ព្រោះជាភពចុងក្រោយ ទៅកាន់សម្នាក់របស់ព្រះសាស្ដា ស្ដាប់ធម៌ហើយមានសទ្ធា ទើបចេញបួស ។ ព្រះសាស្ដា ទ្រង់ប្រទានកម្មដ្ឋានដល់ព្រះថេរៈ លោករៀនកម្មដ្ឋានហើយ ត្រូវសេចក្ដីអផ្សុកគ្របសង្កត់ក្នុងកាល ២-៣ ថ្ងៃប៉ុណ្ណោះ ។ គ្រានោះព្រះសាស្ដា ទ្រង់ជ្រាបការប្រព្រឹត្តទៅនៃចិត្តរបស់ព្រះថេរៈ បានត្រាស់ព្រះគាថាជាឱវាទថា **ទុក្ខា កាមា ឯរក** ម្នាលឯរកៈ កាមទាំងឡាយជាទុក្ខ ដូច្នេះជាដើម ។ ព្រះថេរៈស្ដាប់គាថានោះហើយ កើតនូវសេចក្ដីសង្វេគថា ការដែលអាត្មាអញរៀននូវកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្ដាបែបនេះ ហើយលះនូវកម្មដ្ឋាននោះ ជាអ្នកច្រើនទៅដោយមិច្ឆាវិតក្ក ឈ្មោះថាធ្វើនូវកម្មមិនសមគួរឡើយ ដូច្នេះហើយ

ប្រកបវិបស្សនា សម្រេចអរហត្ត ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធ ដែលលោកពោលទុកក្នុងអបទានថា

ព្រះសម្ពុទ្ធមានបញ្ញាចក្ខុព្រះនាមសិទ្ធត្ថៈ ទ្រង់ឆ្លងស្ទឹង ស្តេចពុទ្ធដំណើរទៅកាន់ព្រៃ ខ្ញុំបានឃើញព្រះសម្ពុទ្ធព្រះនាមសិទ្ធត្ថៈនោះ ទ្រង់មានលក្ខណៈដ៏ប្រសើរ ទើបខ្ញុំកាន់យកចបនិងកញ្ជើរធ្វើផ្លូវនោះឲ្យរាបស្មើ ហើយថ្វាយបង្គំព្រះសាស្តា ហើយញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លូវ ។ ក្នុងកប្បទី ៥៧ អំពីកប្បនេះ ខ្ញុំនោះបានកើតជាស្តេច ១ អង្គ ព្រះនាមសុប្បពុទ្ធ ជាធំជាងជន ជានាយក ជាឥស្សរៈលើពួកនរជន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលបានជាព្រះអរហន្តហើយ កាលព្យាករអរហត្តផល បានពោលគាថាដែលព្រះមានព្រះភាគត្រាស់ហើយនោះឯងដដែលទៀតថា

ម្នាលឯរកៈ កាមទាំងឡាយជាទុក្ខ ម្នាលឯរកៈ កាមទាំងឡាយមិនមែនជាសុខទេ ម្នាលឯរកៈ បុគ្គលណាប្រាថ្នាកាម បុគ្គល

---

១-ក្នុងអបទានជាព្រះ មគ្គទាយកត្ថេរ ។

នោះ ឈ្មោះថា ប្រាថ្នាទុក្ខ ម្នាលឯរកៈ បុគ្គលណាមិន ប្រាថ្នាកាម បុគ្គលនោះ ឈ្មោះថា មិនប្រាថ្នាទុក្ខទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទុក្ខា កាមា** សេចក្ដីថា វត្ថុកាមនិងកិ-លេសកាមទាំងនេះ ឈ្មោះថា ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខនិងព្រោះមានវិប-រិណាមទុក្ខនិងសង្ខារទុក្ខជាសភាវៈ គឺញុំាងទុក្ខឲ្យកើតឡើងពិតប្រាកដ សម ដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ( ក្នុងចូឡទុក្ខក្ខន្ធសូត្រ ) ថា កាមទាំងឡាយមានសេចក្ដីសុខតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនោះមានច្រើនពេក ដូច្នេះ ។

ព្រះមានព្រះភាគ ត្រាស់ហៅព្រះថេរៈនោះថា ឯរកៈមុន តែខាងក្រោយ ទើបព្រះថេរៈ ហៅខ្លួនឯងតាមឈ្មោះនោះ ។

បទថា **ន សុខា កាមា** សេចក្ដីថា ឈ្មោះថា កាមនេះមិនជាសេចក្ដីសុខឡើយ សម្រាប់បុគ្គលដែលដឹង តែសម្រាប់បុគ្គលដែលមិនដឹង រមែងប្រាកដថាជាសុខ សមដូចព្រះតម្រាស់ដែលត្រាស់ទុក ( ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ) ថា អ្នកឯណាបានឃើញសុខវេទនា ថាជាទុក្ខវេទនាវិញ បានឃើញទុក្ខវេទនា ថាជាកូនសរ ដូច្នេះជាដើម ។

បទថា **យោ កាមេ កាមយតិ ទុក្ខំ សោ កាមយតិ** សេចក្ដីថា សត្វណាប្រាថ្នាកិលេសកាមនិងវត្ថុកាម ការប្រាថ្នានោះរបស់សត្វនោះ តែងប្រព្រឹត្តទៅដើម្បីការក្តៅក្រហាយក្នុងបច្ចុប្បន្នផង ឈ្មោះថា ជាទុក្ខក្នុងកាលតទៅផង ព្រោះជាហេតុនៃទុក្ខក្នុងអបាយនិងហេតុនៃទុក្ខក្នុងវដ្ដៈ ។ វត្ថុកាម

ឈ្មោះថា ជាទីតាំងនៃទុក្ខ ដោយប្រការដូច្នេះ ។ សត្វនោះ លោកហៅថា ប្រាថ្នាវត្ថុកាម មានទុក្ខជាសភាវៈ មានទុក្ខជានិមិត្ត និងជាទីតាំងនៃសេចក្ដីទុក្ខ ។ ទុក្ខក្រៅអំពីនេះ លោកពោលដើម្បីឲ្យដឹងអត្ថនោះឯង ដោយផ្ទុយគ្នា ព្រោះដូច្នោះ អត្ថនៃទុក្ខនោះ គប្បីជ្រាបដោយបរិយាយ ដូចខ្ញុំពោលហើយ ។

## អដ្ឋកថា ឯរកត្ថេរគាថា ចប់

## មេត្តជិត្ថេរគាថា

[ ៩៥ ] សូមនមស្ការ ព្រះមានព្រះភាគអង្គនោះ ព្រះអង្គជាសក្យបុត្ត មានសិរី ព្រះធម៌ដ៏ប្រសើរនោះ ព្រះពុទ្ធដល់នូវធម៌ដ៏ប្រសើរនោះទ្រង់សម្តែងទុកល្អហើយ ។

មេត្តជិត្ថេរ ។

## អដ្ឋកថា

## មេត្តជិត្ថេរគាថា

[ ៩៥ ] គាថារបស់ព្រះមេត្តជិត្ថេរ មានពាក្យផ្តើមថា **ណមោ ហិ តស្ស ភគវតោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថា អនោមទស្សី កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ជាអ្នកមានចិត្តជ្រះថ្លាក្រៃលែងក្នុងព្រះសាសនា ធ្វើទែនបូជាត្រង់ពោធិព្រឹក្ស ដោយឥដ្ឋទាំងឡាយ ហើយឲ្យបូកលាបដោយបាយអ ព្រះសាស្តាទ្រង់ធ្វើអនុមោទនាដល់កុលបុត្តនោះ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក ធ្វើបុណ្យរឿយៗមក អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនរបស់ព្រាហ្មណ៍ម្នាក់ក្នុងដែនមគធៈមានឈ្មោះថាមេត្តជិ ។

មេត្តជិព្រាហ្មណ៍ចម្រើនវ័យហើយ ឃើញទោសក្នុងកាមទាំងឡាយបួស

ជាតាបសនៅក្នុងព្រៃ បានឮដំណឹងអំពីការកើតឡើងនៃព្រះពុទ្ធហើយ កាល បុព្វហេតុជាស់តឿន ទៅកាន់សម្នាក់របស់ព្រះសាស្តា ទូលសួរបញ្ហា ប្រារព្ធ ការប្រព្រឹត្តទៅ និងការត្រឡប់មក សេចក្តីទុក្ខ និងការរំលត់ទុក្ខ កាលព្រះ សាស្តាទ្រង់វិសជ្ជនាបញ្ហាហើយ បាននូវសទ្ធាបួសហើយ ផ្តើមវិបស្សនា សម្រេចអរហត្តហើយ ។ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំបានធ្វើខឿនពោធិព្រឹក្សនៃព្រះមុនីព្រះនាមអនោមទស្សី បាន ដាក់ដុំបាយអ ហើយធ្វើនូវបាណិកម្ម ( បូក ) ។ ព្រះសាស្តា ព្រះនាម អនោមទស្សី ប្រសើរជាងនរៈ គង់ក្នុងកណ្តាលភិក្ខុ សង្ឃឃើញអំពើដែលខ្ញុំធ្វើល្អនោះហើយ ទើបសម្តែងគាថានេះ ថា កុលបុត្តនេះ បានសោយសម្បត្តិដោយការបូកបាយអនេះ ផង ដោយការតម្កល់ទុកនូវចេតនាផង ហើយនឹងធ្វើនូវព្រះ និព្វានជាទីបំផុតទុក្ខ ។ ខ្ញុំមានសម្បុរមុខថ្លាស្រស់ មានចិត្តនឹង នៅក្នុងអារម្មណ៍តែមួយ មានចិត្តតម្កល់មាំល្អ ខ្ញុំទ្រទ្រង់នូវរាង កាយជាទីបំផុត ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្ប ទី ១០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាម សម្បស្សនៈ ទ្រង់បរិបូណ៌មិនខ្វះខាត ( ដោយសម្បត្តិ ) មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

---

១-ក្នុងអបទានជាព្រះ អនុលោមទាយកត្ថេរ ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលសរសើរព្រះសាស្តា បាន ពោលគាថានេះថា

សូមនមស្ការ ព្រះមានព្រះភាគអង្គនោះ ព្រះអង្គជាសក្យបុត្ត
មានសិរី ព្រះធម៌ដ៏ប្រសើរនោះ ព្រះពុទ្ធដល់នូវធម៌ដ៏ប្រសើរ
នោះទ្រង់សម្តែងទុកល្អហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នមោ** បានដល់ ធ្វើនូវការឱនលំទោន ។ បទថា **ហិ** ត្រឹមតែជានិបាត ។ បទថា **តស្ស** សេចក្តីថា ព្រះមានព្រះភាគ អង្គនោះ ទ្រង់បំពេញបារមី ៣០ ទ្រង់កាច់បំបាក់កិលេសទាំងពួង ហើយ ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ឈ្មោះថា **សក្យបុត្តស្ស** ព្រោះជាបុត្ត នៃស្តេចសក្យៈ ទ្រង់ចម្រើនហើយដោយបុញ្ញសម្បត្តិដែលមិនសាធារណៈដល់ សត្វដទៃ និងឈ្មោះថា **សិរីមតោ** ព្រោះប្រកបដោយសិរី គឺរូបកាយនិងសិរី គឺធម្មកាយដ៏ឧត្តម សូមកិរិយានមស្ការមានដល់ព្រះមានព្រះភាគដែលជាសក្យ បុត្តដ៏មានសិរីអង្គនោះ សេចក្តីថា ខ្ញុំសូមនមស្ការព្រះមានព្រះភាគអង្គនោះ ។

បទថា **តេន** កែជា **តេន ភគវតា** ប្រែថា ដែលព្រះមានព្រះភាគអង្គ នោះ ។ ព្រះថេរៈពោលថា **អយំ** ព្រោះភាពដែលធម៌នោះប្រចក្សដល់ខ្លួន ។ បទថា **អគ្គប្បត្តេន** បានដល់ ប្រសើរ គឺទ្រង់ដឹងនូវធម៌ទាំងពួង ម្យ៉ាងទៀត បានជាអ្នកដល់នូវភាពជាបុគ្គលដ៏ប្រសើរ គឺភាពជាអ្នកប្រសើរ ដោយព្រះ គុណទាំងពួង ។ បទថា **អគ្គធម្មោ** បានដល់ នូវលោកុត្តរធម៌ ៩ ដ៏ ប្រសើរ គឺឧត្តម ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ គឺទ្រង់ប្រកាស

ហើយដោយល្អ មិនខុសក្លាំងក្លាត់ ដូច្នេះ ។

## អដ្ឋកថា មេត្តជិត្ថេរគាថា ចប់

## ចក្ខុបាលត្ថេរគាថា

[ ៩៦ ] ខ្ញុំជាមនុស្សខ្វាក់ មានភ្នែកដែលទោសកម្ចាត់បង់ហើយ ទៅកាន់ផ្លូវឆ្ងាយដាច់ស្រយាល ទោះបីកាលដេក ក៏ខ្ញុំមិនទៅជាមួយនឹងសំឡាញ់ជាបាបមិត្តទេ ។

ចក្ខុបាលត្ថេរ ។

## អដ្ឋកថា

## ចក្ខុបាលត្ថេរគាថា

[ ៩៦ ] គាថារបស់ព្រះចក្ខុបាលត្ថេរ មានពាក្យផ្ដើមថា **អន្ធោហំ ហតនេត្តោស្មិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ធ្វើបុណ្យទុកក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមថាសិទ្ធត្ថ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ។ កាលព្រះមានព្រះភាគបរិនិព្វានហើយ កាលមហាជនកំពុងធ្វើការឆ្លងព្រះស្តូប កាន់យកផ្កាទៅបូជាព្រះស្តូបហើយ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក ធ្វើបុណ្យរឿយៗ អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តរបស់កុដុម្ពិកៈឈ្មោះមហាសុវណ្ណក្នុងនគរសាវត្ថី មានឈ្មោះថា បាលៈ ។

ក្នុងកាលដែលកុលបុត្តនេះ ចេះរត់លេងទៅមកបាន មាតាក៏ប្រសូតបុត្ត

ម្នាក់ទៀតដាក់ឈ្មោះបុត្តនោះថាចូឡបាលហើយហៅបុត្តច្បងថាមហាបាល ។ កាលបុត្តទាំង ២ ចម្រើនវ័យហើយ មាតាបិតាក៏ចងដោយចំណង គឺផ្ទះ ។ ក្នុងសម័យនោះ ព្រះសាស្តាគង់នៅក្នុងវិហារឈ្មោះថាជេតពន ក្នុងក្រុងសាវត្ថី ។ ក្នុងបណ្តាបងប្អូនទាំង ២ នោះ មហាបាលជាបងទៅកាន់វិហារ មួយអន្លើដោយឧបាសកទាំងឡាយដែលទៅកាន់ជេតពនមហាវិហារ ស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តាបាននូវសទ្ធា ហើយប្រគល់សម្បត្តិ ឲ្យជាការៈរបស់ប្អូនប្រុសតែម្នាក់ ខ្លួនឯងចេញបួស ឧបសម្បទាហើយ នៅក្នុងសម្នាក់របស់អាចារ្យនិងឧបជ្ឈាយ៍អស់ ៥ ឆ្នាំ កាលចេញវស្សាបវារណាហើយ រៀននូវកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តា បានភិក្ខុជាសម្លាញ់ ៦០ រូប ស្វែងរកទីលំនៅដែលសមគួរដល់ការចម្រើនភាវនា អាស្រ័យបច្ចន្តគ្រាមមួយកន្លែងនៅក្នុងសាលាស្លឹកដែលពួកឧបាសកធ្វើប្រគេនក្នុងដងព្រៃ បំពេញសមណធម៌ ។

រោគភ្នែកកើតដល់ព្រះថេរៈហើយ គ្រូពេទ្យក៏ធ្វើថ្នាំប្រគេន លោកមិនបដិបត្តិតាមវិធីដែលពេទ្យប្រាប់ ដោយហេតុនោះ រោគរបស់ព្រះថេរៈក៏រាលខ្លាំងឡើង ព្រះថេរៈគិតថា សម្រាប់អាត្មាអញ ការចូលទៅរម្ងាប់រោគ គឺកិលេសប៉ុណ្ណោះប្រសើរជាងការរម្ងាប់រោគភ្នែក ដូច្នេះហើយ មិនដាក់ចិត្តក្នុងការព្យាបាលភ្នែក ជាអ្នកព្យាយាមប្រកបតែក្នុងវិបស្សនា តែម្យ៉ាងប៉ុណ្ណោះ កាលលោកខ្វល់ខ្វាយក្នុងការចម្រើនភាវនា ភ្នែកទាំង ២ ក៏បែក កិលេសទាំងឡាយក៏រលត់ មិនមុនមិនក្រោយ លោកបានសម្រេចជាព្រះអរហន្តសុក្ខវិបស្សកៈហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលព្រះមានព្រះភាគព្រះនាម សិទ្ធត្ថៈ ដែលពួកសត្វលោក
បូជាហើយ គួរទទួលនូវគ្រឿងបូជា ទ្រង់បរិនិព្វានហើយក៏មាន
ការធ្វើព្រះស្តូបដ៏ធំ ។ កាលដែលកំពុងរៀបចំធ្វើព្រះស្តូប ខ្ញុំ
ក៏បានយកផ្កាទៅដោតលើព្រះស្តូប នៃព្រះសិទ្ធត្ថៈមហេសី ។
ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា
ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបុប្ផបូជា ។ ក្នុងកប្បទី
៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៨៥ ជាតិ ព្រះ
នាមសោមទេវដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤
វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ
ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលព្រះថេរៈចូលសម្រាកក្នុងវិហារ ព្រោះរោគក្អែក ពួកឧបាសក ឧបាសិកាឃើញភិក្ខុទាំងឡាយចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ទើបសួរថាព្រោះហេតុអ្វីទើបព្រះថេរៈមិនមក ដឹងដំណឹងនោះហើយ ជាអ្នកមានសេចក្តីសោកគ្របសង្កត់ នាំបិណ្ឌបាតទៅប្រគេនពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំបារម្ភឡើយ ឥឡូវនេះ ពួកខ្ញុំនាំបិណ្ឌបាតមកប្រគេនហើយ នឹងប្រតិបត្តិលោកម្ចាស់ ដូច្នេះហើយ ក៏ធ្វើតាមនោះ ។ ភិក្ខុទាំងឡាយ ៦០ រូប តាំងនៅក្នុងឱវាទរបស់ព្រះថេរៈហើយ សម្រេចអរហត្តក្នុងកាលមិនយូរឡើយ កាលចេញវស្សាបវារណាហើយ ពោលនឹងព្រះថេរៈថា បពិត្រលោកម្ចាស់

---

១-ក្នុងអបទានជាព្រះ ឧម្មាបុប្ផិយត្ថេរ ។

ពួកខ្ញុំនឹងទៅនគរសាវត្ថីដើម្បីថ្វាយបង្គំព្រះសាស្តា ។ ព្រះថេរៈពោលថា ខ្ញុំជាមនុស្សទុព្វលភាពមិនមានភ្នែកផង ផ្លូវក៏មានអន្តរាយផង បើលោកទាំងឡាយទៅជាមួយខ្ញុំនឹងមានអន្តរាយ ចូរលោកទាំងឡាយទៅមុនចុះ លុះដល់ហើយចូរថ្វាយបង្គំព្រះសាស្តា និងថ្វាយបង្គំព្រះមហាថេរៈទាំងឡាយជំនួសខ្ញុំផង ចូរប្រាប់ការប្រព្រឹត្តទៅរបស់ខ្ញុំដល់ចូឡបាលកុដុម្ពិកៈឲ្យបញ្ជូនមនុស្សម្នាក់មក ។ ភិក្ខុទាំងនោះអង្វរយ៉ាងណា ក៏មិនបានឱកាសនាំព្រះថេរៈទៅ ទើបទទួលពាក្យព្រះថេរៈថា សាធុ នាំគ្នាទុកដាក់សេនាសនៈ ហើយលាឧបាសកទៅកាន់ជេតពនមហាវិហារដោយលំដាប់ ថ្វាយបង្គំព្រះសាស្តានិងព្រះមហាថេរៈទាំងឡាយជំនួសព្រះថេរៈតាមបណ្តាំ ក្នុងថ្ងៃទី ២ ទើបទៅបិណ្ឌបាតក្នុងនគរសាវត្ថី ប្រាប់ដំណឹងនោះដល់ចូឡបាលកុដុម្ពិកៈ ចូឡបាលកុដុម្ពិកៈពោលថា បពិត្រលោកម្ចាស់ក្មួយប្រុសរបស់ខ្ញុំមាន គេឈ្មោះថាបាលិត ខ្ញុំនឹងបញ្ជូនក្មួយប្រុសទៅ ទើបពោលថា ផ្លូវមានអន្តរាយ គ្រហស្ថមិនអាចទៅម្នាក់ឯងបាន ព្រោះហេតុនោះគួរឲ្យបួសជាមុន ហើយញ៉ាំងនាយបាលិតឲ្យបួស បញ្ជូនទៅហើយ ។ បាលិតសាមណេរធ្វើដំណើរទៅកាន់សម្នាក់របស់ព្រះថេរៈដោយលំដាប់ ណែនាំខ្លួនដល់ព្រះថេរៈហើយនាំព្រះថេរៈធ្វើដំណើរមក ។ ក្នុងរវាងផ្លូវបានស្តាប់សំឡេងច្រៀង ដែលស្រីរកឧសម្នាក់ច្រៀង ត្រង់ដងព្រៃជិតស្រុកមួយកន្លែង មានចិត្តប្រតិព័ទ្ធ ក៏លែងចុងឈើច្រត់ពោលថា បពិត្រលោកម្ចាស់សូមលោកម្ចាស់បង្អង់មួយស្របក់ទម្រាំខ្ញុំមក ហើយចូលទៅកាន់សម្នាក់របស់នាង ក៏ដល់នូវសីលវិបត្តិក្នុងទីនោះ ។ ព្រះថេរៈគិតថា អញបានឮសំឡេងស្រីច្រៀង

*អម្បាញ់មិញនេះឯង សាមណេរក៏យឺតយូរ ប្រហែលសាមណេរដល់នូវសីលវិបត្តិដោយពិត ។*

*ឯសាមណេរមកហើយពោលថា បពិត្រលោកម្ចាស់ យើងទៅជាមួយគ្នាចុះ ព្រះថេរៈសួរថា អ្នកក្លាយជាបុគ្គលលាមកហើយឬ សាមណេរនៅស្ងៀម ព្រះថេរៈសួររឿយៗ ក៏មិនឆ្លើយ ។ ព្រះថេរៈពោលថា មនុស្សអាក្រក់ដូចអ្នក មិនមានកិច្ចដែលត្រូវកាន់ចុងឈើច្រត់របស់ខ្ញុំ ចូរអ្នកទៅចុះ ដូច្នេះ កាលសាមណេរពោលថា ផ្លូវមានអន្តរាយច្រើនផង លោកម្ចាស់ខ្វាក់ផង នឹងដើរទៅបានដូចម្តេច កាលនឹងសម្តែងសេចក្តីនេះថា នែបុគ្គលពាល ទោះបីខ្ញុំដេកស្លាប់ក្នុងទីនេះក្តី ដេកបម្រះនទៀលទៅមកក្តី ឈ្មោះថា ការដើរទៅជាមួយបុគ្គលដូចអ្នកមិនមាន ដូច្នេះហើយ ទើបពោលគាថានេះថា*

> *ខ្ញុំជាមនុស្សខ្វាក់ មានភ្នែកដែលទោសកម្ចាត់បង់ហើយ ទៅកាន់ផ្លូវឆ្ងាយដាច់ស្រយាល ទោះបីកាលដេក ក៏ខ្ញុំមិនទៅជាមួយនឹងសំឡាញ់ជាបាបមិត្តទេ ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **អន្ធោ** *បានដល់ ជាអ្នកមានភ្នែកពិការ ។ បទថា* **ហតនេត្តោ** *បានដល់ ជាអ្នកមានចក្ខុវិនាសហើយ ។ ដោយបទថា* **ហតនេត្តោ** *នោះ ប្រាប់សេចក្តីចំពោះដល់ការខ្វាក់ដែលពោលទុកថា ខ្ញុំជាមនុស្សខ្វាក់ ព្រោះពិការដោយបយោគវិបត្តិ មិនមែនខ្វាក់អំពីកំណើត ។ ម្យ៉ាងទៀត ដើម្បីសម្តែងថា ពាក្យថា* **អន្ធោ** *នេះ ជាការសម្តែងភាពវិកលវិការរបស់ភ្នែកសាច់ ដូចក្នុងប្រយោគជាដើមថា ( យដិការស្ងួនធ្ងាំង ) តែងចិញ្ចឹម*

មាតាបិតាដែលចាស់ជរាគ្រាំគ្រា ដូច្នេះ មិនមែនសម្ដែងដល់ភាពវិកលវិការ របស់បញ្ញាចក្ខុ ដូចក្នុងប្រយោគជាដើមថា ពួកអន្ធតិរិយ បរិព្វាជកដូចជាមនុស្សខ្វាក់មើលមិនឃើញ ដូច្នេះ និងដូចប្រយោគជាដើមថា គឺបុគ្គលខ្វាក់ ១ បុគ្គលមានភ្នែកម្ខាង ១ បុគ្គលមានភ្នែកទាំងពីរខាង ១ ដូច្នេះ ទើបព្រះថេរៈពោលបទថា **ហតនេត្តោស្មិ** ទុកផងដែរ ព្រោះសម្ដែងដល់ភាពជាអ្នកខ្វាក់ដ៏ក្រៃលែង គឺខ្វាក់មើលមិនឃើញដោយបទថា **ហតនេត្តោស្មិ** នោះ ។

បទថា **កន្តារទ្ធានបក្ខន្ទោ** សេចក្ដីថា ដើរទៅក្នុងផ្លូវឆ្ងាយ ក្នុងព្រៃធំដែលជាកន្ដារ អធិប្បាយថា មិនមែនដើរទៅកាន់ផ្លូវឆ្ងាយ គឺសង្សារ ដែលស្អេកស្កះទៅដោយកន្ដារ មានជាតិកន្ដារជាដើមឡើយ ព្រោះថា ព្រះថេរៈឈានកន្លងផ្លូវឆ្ងាយដែលជាកន្ដារបែបនោះបានហើយ តាំងនៅ ។ បទថា **សយមានោបិ** សេចក្ដីថា សូម្បីដេក គឺកាលជើងទាំង ២ មិនទាំមក ដល់នូវការដេកបម្រះនទៀលទៅមកលើផែនដី ខ្ញុំក៏លូនទៅដោយទ្រូង និងដោយជង្គង់ទាំង ២ ។

បទថា **ន សាហាយេន បាបេន** ប្រកបសេចក្ដីថា នឹងមិនទៅជាមួយបុគ្គលបាបជាសម្លាញ់ដូចអ្នក ។

បាលិតសាមណេរស្ដាប់ពាក្យនោះហើយ កើតសេចក្ដីសង្វេគ គិតថា កម្មដែលអញធ្វើមានទោសដ៏ពន្លឹក ជាកម្មធ្ងន់ហ្ន៎ ផ្គងដើមដៃទាំង ២ ទ្រហោយំរត់ចូលព្រៃហើយ ។ កាលនោះបណ្ឌុកម្ពលសិលាអាសនៈរបស់សក្កទេវរាជសម្ដែងអាការក្ដៅ ដោយតេជៈនៃសីលរបស់ព្រះថេរៈ ដោយហេតុនោះ

សក្កៈដឹងហេតុនោះហើយ យាងទៅកាន់សម្នាក់របស់ព្រះថេរៈ ឲ្យព្រះថេរៈស្គាល់ទ្រង់ជាអ្នកដើរផ្លូវទៅកាន់ក្រុងសាវត្ថី កាន់ចុងឈើច្រត់បង្រួញផ្លូវ នាំព្រះថេរៈទៅកាន់នគរសាវត្ថីក្នុងពេលល្ងាចនោះឯង ហើយនិមន្តឲ្យ ព្រះថេរៈគង់លើបន្ទះក្តារ ក្នុងបណ្ណសាលា ដែលចូឡបាលិតកុដុម្ពិកៈសាងទុកក្បែរវត្តជេតពននោះ ហើយប្រាប់ឲ្យដឹងថា ព្រះថេរៈមកដល់ហើយ ដោយភេទជាសម្លាញ់របស់ចូឡបាលិតនោះ ហើយចៀសចេញទៅ ។ ចូឡបាលិតកុដុម្ពិកៈក៏ឧបដ្ឋាកព្រះថេរៈដោយគោរពដរាបដល់អស់ជីវិត ដូច្នេះឯង ។

## អដ្ឋកថា ចក្ខុបាលត្ថេរគាថា ចប់

## ខណ្ឌសុមនត្ថេរគាថា

[ ៩៧ ] ខ្ញុំបានបូជាផ្កាមួយ រួចក៏បានឲ្យគេបម្រើក្នុងឋានសួគ៌អស់ ៨០ កោដិឆ្នាំ ( រាប់ដោយឆ្នាំមនុស្ស ) ខ្ញុំរលត់ទុក្ខដោយផលនៃកម្មដ៏សេសសល់ ។

ខណ្ឌសុមនត្ថេរ ។

## អដ្ឋកថា

## ខណ្ឌសុមនត្ថេរគាថា

[ ៩៧ ] គាថារបស់ព្រះខណ្ឌសុមនត្ថេរ មានពាក្យផ្ដើមថា **ឯកបុប្ផំ ចជិត្វាន** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងពុទ្ធុប្បាទរបស់ព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ កាលព្រះសាស្ដាបរិនិព្វានហើយ បានសាងវេទិកាធ្វើដោយខ្លឹមចន្ទន៍ជុំវិញព្រះស្ដូបនោះ ហើយបានធ្វើនូវការបូជាធំ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះសោយសម្បត្តិដ៏ឧឡារក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមថាកស្សបៈ កើតក្នុងត្រកូលកុដុម្ពិកៈ ។ កាលព្រះសាស្ដាបរិនិព្វានហើយ ព្រះរាជាទ្រង់ធ្វើការបូជាដោយផ្កា ឧទ្ទិសចំពោះព្រះស្ដូបមាស កុលបុត្តនោះ រកផ្កាមិនបាន

ឃើញផ្កាម្ទិះមួយមែក ទើបទិញផ្កាម្ទិះមួយមែកនោះ ដោយតម្លៃខ្ពស់កាន់យក ទៅបូជាត្រង់ព្រះចេតិយ កើតបីតិសោមនស្សដ៏ឧឡារ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក សោយសុខក្នុងស្ថានសួគ៌ ៨០ កោដិឆ្នាំ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលស្តេចមល្លៈ នានគរបាវា ។ ក្នុងថ្ងៃដែលកុលបុត្តនោះកើត ស្តរអំពៅ ស្តរក្រោម និងផ្កាម្ទិះទាំងឡាយបានកើតក្នុងផ្ទះដោយហេតុនោះ ទើបមនុស្សទាំងឡាយដាក់ឈ្មោះថាខណ្ឌសុមនៈ ។ កុលបុត្តនោះ ដល់នូវភាពជាអ្នកដឹងក្តីហើយ កាលព្រះមានព្រះភាគ គង់នៅក្នុងសួនអម្ពវ័នរបស់នាយចុន្ទក្នុងនគរបាវាចូលទៅគាល់ ហើយស្តាប់ធម៌មានសទ្ធាបួសហើយបំពេញវិបស្សនា បានជាអ្នកមានអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

> ព្រះជិនស្រីសម្ពុទ្ធព្រះនាមបទុមុត្តរៈ ជាច្បងក្នុងលោកជា នរាសភៈ រុងរឿងដូចគំនរភ្លើង ទ្រង់បរិនិព្វានហើយ ។ លុះព្រះមហាវីរៈ ទ្រង់បរិនិព្វានហើយ ព្រះស្តូបជារបស់ធំសម្បើមក៏កើតមានឡើង ( ក្នុងកាលនោះ ) ពួកជនតែងនាំគ្នាចូលទៅបម្រើព្រះស្តូប ត្រង់ល្វែងតម្កល់ព្រះធាតុ ដ៏ប្រសើរឧត្តម ។ កាលនោះខ្ញុំមានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បានសាងខឿនខ្ទឹមចន្ទន៍ បានថ្វាយធូបនិងគ្រឿងប្រអប់ ដ៏សមគួរដល់ព្រះស្តូប ។ កាលខ្ញុំកើតក្នុងភព ( ណាៗ ) ទោះបីជាទេវតា

ឬជាមនុស្ស ខ្ញុំមិនបានជួបនូវភាពថោកទាបឡើយ នេះជាផល
នៃបុព្វកម្ម ។ ក្នុងកប្បទី ១១៥ អំពីកប្បនេះ ខ្ញុំបានកើតជា
ស្តេចចក្រពត្តិ ៨ ជាតិ ព្រះនាមសមត្ថៈដូចគ្នា ទ្រង់មានកម្លាំង
ច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបាន
ធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិ
បត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលរឭកដល់ជាតិមុនរបស់ខ្លួន ឃើញកិរិយាបរិច្ចាគផ្កាម្លិះ ក្នុងជាតិមុននោះជានិមិត្តនៃសគ្គសម្បត្តិនិងជាឧប-និស្ស័យនៃព្រះនិព្វាន កាលប្រកាសសេចក្តីនោះដោយអំណាចនៃឧទាន បានពោលគាថាថា

ខ្ញុំបានបូជាផ្កាមួយ រួចក៏បានឲ្យគេបម្រើក្នុងឋានសួគ៌អស់ ៨០
កោដិឆ្នាំ ( រាប់ដោយឆ្នាំមនុស្ស ) ខ្ញុំរលត់ទុក្ខដោយផលនៃ
កម្មដ៏សេសសល់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯកបុប្ផំ** បានដល់ ផ្កាកោសុម ( ដកគាំ ) មួយ តែបទថា **ឯកបុប្ផំ** នោះ ក្នុងគាថានេះ លោកសំដៅដល់ផ្កាម្លិះ ។ បទថា **ចជិត្វាន** សេចក្តីថា ព្រោះលះបង់ គឺព្រោះហេតុនៃកិរិយា

---

១-ក្នុងអបទានជាព្រះ សបរិវារិយត្ថេរ ព្រះថេរៈអង្គនេះ បានធ្វើបុណ្យទុកដូចព្រះថេរៈឈ្មោះ នន្ទិយត្ថេរ ខាងដើមដែរ ឯកម្មក៏ឲ្យផលដូចគ្នា ព្រោះហេតុនោះ ទើបព្រះថេរៈទាំង ២ អង្គ មានអបទានដូចគ្នា ។

បរិច្ចាគផ្កាមួយដោយធ្វើជាគ្រឿងបូជាព្រះស្តូបរបស់ព្រះសាស្តា ។

បទថា **អសីតិ វស្សកោដិយោ** សេចក្តីថា អស់ ៨០ កោដិឆ្នាំ ដោយរាប់ឆ្នាំមនុស្ស ។ បទថា **អសីតិ វស្សកោដិយោ** នេះ ជាទុតិយាវិភត្តិចុះក្នុងអច្ចន្តសំយោគ ។ បទនេះគប្បីជ្រាបថា លោកពោលដោយអំណាចការកើតហើយកើតទៀត ក្នុងកាមាវចរសួគ៌ជាន់ទី ២ ក្នុងបណ្តាស្ថានសួគ៌ ៦ ជាន់ ។ ព្រោះហេតុនោះ បទថា **សគ្គេសុ** ទើបបានដល់ ក្នុងស្ថានសួគ៌ជាន់តាវត្តិង្ស ។ ក្នុងគាថានេះ បទនេះជាពហុវចនៈព្រោះកើតហើយកើតទៀត ។

បទថា **បរិចារេត្វា** សេចក្តីថា បម្រើឥន្ទ្រិយក្នុងអារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើម ហើយសោយសេចក្តីសុខ ម្យ៉ាងទៀត បានដល់ ឲ្យទេពអប្សរបម្រើខ្លួន ។

ដោយបទថា **សេសកេនម្ហិ និព្វុតោ** នេះ ព្រះថេរៈពោលសំដៅដល់កុសលកម្ម ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងអត្តភាពនោះដោយកម្មដ៏សេស ចាកកម្មដែលជាភវសម្បត្តិអំពីកុសលចេតនា ដែលប្រព្រឹត្តទៅហើយដោយអំណាចនៃការបូជាដោយផ្កា ។ អធិប្បាយថា ព្រោះមានចេតនាច្រើនដែលប្រព្រឹត្តទៅ ដោយអំណាចបុព្វចេតនា និងអបរចេតនា ក្នុងកុសលកម្មនោះ ។

ម្យ៉ាងទៀត បទថា **សេសកេន** សេចក្តីថា កាលកម្មវិបាកនោះ មិនទាន់អស់ទៅ ដោយវិបាកដែលនៅសល់នៃកម្មនោះឯង ខ្ញុំក៏ជាបុគ្គលរំលត់ហើយ គឺខ្ញុំបរិនិព្វានហើយ ដោយកិលេសបរិនិព្វាន ។ ដោយបទថា **សេសកេន**

នេះ ព្រះថេរៈសម្តែងថា អរហត្តដែលខ្លួនតាំងនៅហើយក្នុងអត្តភាពណា ធ្វើឲ្យជាក់ច្បាស់ហើយ អត្តភាពចុងក្រោយនោះ ជាកម្មវិបាករបស់កុសលកម្មនោះ ។

ពាក្យថា ព្រោះវិបាកដែលនៅសេសសល់នៃកម្មនោះឯង ដែលលោកពោលទុកក្នុងទីដទៃ ក៏សំដៅដល់អត្តភាពចុងក្រោយបែបនោះដូចគ្នា ។

## អដ្ឋកថា ខណ្ឌសុមនត្ថេរគាថា ចប់

## តិស្សត្ថេរគាថា

[ ៩៨ ] ខ្ញុំលះភាជន៍សំរឹទ្ធិដែលមានក្បាច់ ១០០ ស្រទាប់ និងភាជន៍មាសមានចំឡាក់ ១០០ ជាន់ ហើយត្រឡប់មកកាន់យកបាត្រដីវិញ ការចូលកាន់ផ្នួសរបស់ខ្ញុំនេះ ឈ្មោះថាជាការអភិសេកទីពីរ ។

**តិស្សត្ថេរ ។**

## អដ្ឋកថា

## តិស្សត្ថេរគាថា

[ ៩៨ ] គាថារបស់ព្រះតិស្សត្ថេរ មានពាក្យផ្តើមថា **ហិត្វា សតបលំ កំសំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាវិបស្សី កើតក្នុងត្រកូលអ្នកធ្វើយាន ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លាធ្វើបន្ទះក្តារដោយដើមចន្ទន៍ ថ្វាយដល់ព្រះមានព្រះភាគ ព្រះមានព្រះភាគទ្រង់ក៏ប្រើប្រាស់បន្ទះក្តារនោះ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក ធ្វើបុណ្យរឿយៗមក អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងរាជត្រកូលក្នុងរោរុវនគរ ។ ព្រះរាជកុមារចម្រើនព្រះជន្មវស្សាហើយ កាលព្រះបិតាសោយទិវង្គត ក៏តាំងនៅក្នុងរាជសម្បត្តិ ជាអទិដ្ឋសម្លាញ់របស់ព្រះ

បាទពិម្ពិសារ បញ្ជូនបណ្ណាការកែវមណី កែវមុក្តានិងសំពត់ជាដើមមកថ្វាយព្រះបាទពិម្ពិសារ ។ ព្រះបាទពិម្ពិសារទ្រង់ស្តាប់ភាពមានបុណ្យរបស់ព្រះបាទនគរភេរុវៈនោះ ទើបទ្រង់បញ្ជូនរាជបណ្ណាការតបទៅ ហើយឲ្យចារឹកពុទ្ធចរិយាក្នុងចិត្តបណ្ណ និងចារឹកបដិច្ចសមុប្បាទ ក្នុងព្រះសុវណ្ណបណ្ណបញ្ជូនទៅថ្វាយ ។ ព្រះបាទភេរុវៈ ទ្រង់ទតព្រះពុទ្ធចរិយាដែលចារឹកលើចិត្តបណ្ណ និងលំដាប់នៃបដិច្ចសមុប្បាទ ដែលចារឹកក្នុងសុវណ្ណបណ្ណ ទ្រង់ពិចារណាឃើញបវត្តិនិងវិវត្តិ ( ការកើតនៃទុក្ខនិងការរលត់នៃទុក្ខ ) ពិចារណាលំដាប់នៃរាជសាសន៍ក្នុងព្រះទ័យហើយ កើតសេចក្តីសង្វេគព្រោះទ្រង់មានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ និងព្រោះភពនេះជាភពចុងក្រោយទើបទ្រង់ព្រះតម្រិះថា អញបានឃើញភេទព្រហ្មចរិយៈនៃព្រះមានព្រះភាគហើយ បានស្គាល់អំពីព្រះរាជសាសន៍មួយផ្លូវទៀត កាមទាំងឡាយមានទុក្ខច្រើន មានការចង្អៀតចង្អល់ច្រើនឥឡូវនេះ ការនៅគ្រប់គ្រងរាជសម្បត្តិមានប្រយោជន៍អ្វី ទើបទ្រង់លះរាជសម្បត្តិកោរសក់និងពុកមាត់ ស្លៀកដណ្តប់កាសាវពស្ត្របួសឧទ្ទិសចំពោះព្រះមានព្រះភាគ កាន់យកបាត្រដែលធ្វើដោយដី ប្រព្រឹត្តដូចអ្នកចាក់សំរាម កាលមហាជនកំពុងបរិទេវនានោះឯង ចេញអំពីព្រះនគរដល់នគររាជគ្រឹះដោយលំដាប់ ចូលទៅគាល់ព្រះមានព្រះភាគ ដែលគង់នៅត្រង់ញកភ្នំឈ្មោះសប្បសោណ្ឌិកជិតនគររាជគ្រឹះនោះថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។

ព្រះសាស្តាទ្រង់សម្តែងធម៌ កុលបុត្តនោះស្តាប់ព្រះធម្មទេសនាកាន់យក

នូវកម្មដ្ឋានក្នុងវិបស្សនា ប្រកបរឿយៗ ខ្វល់ខ្វាយក្នុងវិបស្សនាសម្រេចអរ-ហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

កាលពីដើមខ្ញុំជាអ្នកធ្វើយាន បានសិក្សាស្ទាត់ក្នុងការឈើបាន ធ្វើផែនក្តារដោយខ្លឹមចន្ទន៍ថ្វាយចំពោះព្រះលោកពន្ធុ ។ ( ដោយកុសលកម្មនោះ ) ទើបវិមាននេះដែលបុញ្ញកម្មតាក់តែងដោយមាសតែងភ្លឺរុងរឿង មានទាំងយានដំរី យានសេះ យានទិព្វកើតប្រាកដឡើង ( ដល់ខ្ញុំ ) ។ ទាំងប្រាសាទនិងគ្រែស្នែងក៏កើតឡើង ( ដល់ខ្ញុំដែរ ) កែវជារបស់មិនរំកើប គួរតាមប្រាថ្នា ( ក៏កើតឡើង ) ដល់ខ្ញុំ នេះជាផលនៃផែនក្តារ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផែនក្តារ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផែនក្តារ ។ ក្នុងកប្បទី ៥៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៤ ជាតិ ព្រះនាមករនិម្មិតៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈ សម្រេចអរហត្តហើយ កាលនឹងពោលដល់បដិបទារបស់ខ្លួនដោយអំណាចជាឧទាន ទើបពោលគាថានេះថា

---

១-ក្នុងអបទានជាព្រះ ផលទាយកត្ថេរ ។

ខ្ញុំលះភាជន៍សំរឹទ្ធិដែលមានក្បាច់ ១០០ ស្រទាប់ និងភាជន៍មាសមានចំឡាក់ ១០០ ជាន់ ហើយត្រឡប់មកកាន់យកបាត្រដីវិញ ការចូលកាន់ផ្នួសរបស់ខ្ញុំនេះ ឈ្មោះថាជាការអភិសេកទីពីរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ហិត្វា** បានដល់ លះបង់ហើយ ។ បទថា **សតបលំ** បានដល់ ភាជនៈមាសដែលមានទម្ងន់ ១០០ បលៈ ។ បទថា **កំសំ** បានដល់ សំរឹទ្ធិ ។ បទថា **សោវណ្ណំ** ប្រែថា សម្រេចដោយមាស ។ បទថា **សតរាជិកំ** សេចក្ដីថា ប្រកបដោយក្បាច់ក្បូរមិនមែនតិច ព្រោះភាពជាភាជនៈដែលមានចម្លាក់ដ៏វិចិត្រ និងលម្អដោយក្បាច់ក្បូរជាអនេក ។

បទថា **អគ្គហឹ មត្តិកាបត្តំ** សេចក្ដីថា ព្រះថេរៈក្នុងកាលមុន ធ្លាប់សោយក្នុងភាជនៈដែលមានតម្លៃច្រើនបែបនេះ កាលធ្វើតាមពុទ្ធោវាទ លោកពោលសរសើរការលះរាជសម្បត្តិ និងការចូលដល់បព្វជ្ជាដោយពោលដល់ភាជនៈថា ឥឡូវនេះ ខ្ញុំលះភាជនៈមាស ហើយកាន់យកបាត្រដី ឱ ! ខ្ញុំធ្វើកម្មល្អហើយ ខ្ញុំបានតាំងនៅក្នុងទំនៀមរបស់ព្រះអរិយៈហើយ ។ ដោយហេតុនោះ ទើបព្រះថេរៈពោលថា ឈ្មោះថាជាការអភិសេកទីពីរ ដូច្នេះ អធិប្បាយថា ការចូលដល់បព្វជ្ជាភេទនេះ ជាការអភិសេកលើកទី ២ របស់ខ្ញុំ ដោយកាន់យករាជាភិសេកជាការអភិសេកលើកទី ១ ព្រោះថា ការអភិសេកលើកទី ១ នោះ ជាកម្មដែលសៅហ្មងដោយកិលេស មានរាគៈជាដើមជាការរីករាយប្រកបដោយអនត្ថៈនិងទោសទាក់ទងដោយទុក្ខជាកម្មដែលលាមក ឯការ

អភិសេកលើកទី ២ របស់ខ្ញុំនេះឈ្មោះថាឧត្តមប្រណីត ព្រោះផុយគ្មានឹងការ
អភិសេកលើកទី ១ នោះ ។

## អដ្ឋកថា តិស្សត្ថេរគាថា ចប់

## អភយត្ថេរគាថា

[ ៩៩ ] បុគ្គលកាលឃើញរូបហើយ ធ្វើទុកក្នុងចិត្តនូវនិមិត្តជាទីស្រឡាញ់ សតិរមែងភ្លាំងភ្លាត់ បុគ្គលនោះមានចិត្តត្រេកអរ ទទួលយកលេបយកនូវអារម្មណ៍នោះ អាសវៈទាំងឡាយដែលជាគ្រឿងនាំចូលទៅកាន់ឫសគល់នៃភព រមែងចម្រើនដល់បុគ្គលនោះ ។

អភយត្ថេរ ។

## អដ្ឋកថា

## អភយត្ថេរគាថា

[ ៩៩ ] គាថារបស់ព្រះអភយត្ថេរ មានពាក្យផ្ដើមថា **រូបំ ទិស្វា សតិ មុដ្ឋា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគ ព្រះនាមថាសុមេធ កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ថ្ងៃមួយ ឃើញព្រះមានព្រះភាគព្រះនាមសុមេធ បានធ្វើការបូជាដោយផ្កាស្រល់ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងពួកទេវតា ធ្វើបុណ្យតៗ មកអន្ទោលទៅមកក្នុងសុគតិភពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ក្នុងនគរសាវត្ថី មាននាមថាអភ័យ ដល់នូវភាពជាអ្នកដឹងក្ដីហើយ

កាលហេតុសម្បត្តិជាស់គៀន ថ្ងៃមួយទៅកាន់វិហារ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្ដាហើយ មានសទ្ធា ទើបចេញបួស ធ្វើបុព្វកិច្ចស្រេចហើយ ចម្រើនវិបស្សនា ។

ថ្ងៃមួយ លោកចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ឃើញមាតុគ្រាមតែងខ្លួនយ៉ាងស្អាត ហើយកើតឆន្ទរាគៈ ប្រារព្ធរូបរបស់ស្រីនោះ ដោយអំណាចនៃអយោនិសោមនសិការ ចូលទៅកាន់វិហារ ហើយសង្កត់ចិត្តរបស់ខ្លួនថា កាលអញលះបង់សតិ សម្លឹងមើល កិលេសក្នុងរូបារម្មណ៍កើតឡើងហើយដល់អញ អញធ្វើកម្មមិនសមគួរ ដូច្នេះ ចម្រើនវិបស្សនា សម្រេចអរហត្តក្នុងវេលាពេចនោះឯង សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះសយម្ភូព្រះនាមសុមេធៈ ឥតមានបុគ្គលផ្ចាញ់បាន ទ្រង់ចម្រើនវិវេក ស្ដេចចូលទៅកាន់ព្រៃធំ ។ ខ្ញុំបានឃើញដើមស្រល់មានផ្ការីក ( ទើបកាច់យកមក ) ដោតក្រងធ្វើជាគ្រឿងប្រដាប់ក្បាល បង្អោនថ្វាយព្រះពុទ្ធជាលោកនាយកចំពោះព្រះភក្ត្រ ។ ក្នុងកប្បទី ៣០០០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១១៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ១៦ ជាតិ ព្រះនាមនិម្មិតៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយទាំងសាសនា

របស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលសម្តែងថា សម្រាប់បុគ្គលដែលប្រព្រឹត្តតាមកិលេស មិនមានឱកាសងើបក្បាលឡើងអំពីវដ្តទុក្ខបានទេ ឯខ្លួនខ្ញុំ មិនប្រព្រឹត្តតាមកិលេសទាំងនោះ ដូច្នេះ ដោយការបង្អួលឲ្យឃើញការកើតឡើងនៃកិលេសរបស់ខ្លួន បានពោលគាថាដូច្នេះថា

បុគ្គលកាលឃើញរូបហើយ ធ្វើទុកក្នុងចិត្តនូវនិមិត្តជាទីស្រឡាញ់ សតិរមែងភ្លាំងភ្លាត់ បុគ្គលនោះមានចិត្តត្រេកអរទទួលយកលេបយកនូវអារម្មណ៍នោះ អាសវៈទាំងឡាយ ដែលជាគ្រឿងនាំចូលទៅកាន់ឫសគល់នៃភពរមែងចម្រើនដល់បុគ្គលនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រូបំ** បានដល់ រូបាយតនៈដែលជាទីតាំងនៃតម្រេក រូបាយតនៈក្នុងគាថានេះ លោកសំដៅដល់រូបស្រី ។

បទថា **ទិស្វា** បានដល់ ឃើញដោយចក្ខុ គឺកាន់យករូបនោះ ដោយអំណាចនៃការកំណត់ដោយនិមិត្ត និងដោយអនុព្យញ្ជនៈ ដោយការស្ទុះទៅតាមចក្ខុទ្វារ អធិប្បាយថា ព្រោះការកាន់យករូបនោះថាយ៉ាងនោះជាហេតុ ។

បទថា **សតិ មុដ្ឋា** បានដល់ សតិដែលប្រព្រឹត្តទៅក្នុងកាយ ដែលមានការមិនស្អាតជាសភាវៈ ថាមិនស្អាតនោះឯងប្រាសទៅហើយ ព្រះថេរៈកាលសម្តែងដល់សតិដែលប្រាសទៅ ព្រោះឃើញរូបនោះ ទើបពោលថា

---

១-ក្នុងអបទានជាព្រះ វង្សកិយត្ថេរ ។

ធ្វើទុកក្នុងចិត្តនូវនិមិត្តជាទីស្រឡាញ់ ដូច្នេះ ប្រកបសេចក្ដីថា កាលដាក់ចិត្តក្នុងអារម្មណ៍តាមដែលចូលមកប្រាកដដោយអយោនិសោមនសិការធ្វើបិយារម្មណ៍ឲ្យជានិមិត្តដោយន័យជាដើមថាស្អាត សុខ ដូច្នេះ សតិក៏ប្រាសទៅ ។

បទថា **សារត្តចិត្តោ វេទេតិ** សេចក្ដីថា បន្ទាប់អំពីនោះ ជាអ្នកមានចិត្តត្រេកអរហើយដោយល្អរមែងសោយ គឺត្រេកអរក្នុងរូបារម្មណ៍នោះ កាលកំពុងត្រេកអររូបារម្មណ៍ ក៏គ្របសង្កត់បុគ្គលនោះ គឺអារម្មណ៍គ្របសង្កត់បុគ្គលនោះធ្វើឲ្យលំបាក ធ្វើឲ្យវិលទៅនោះឯង ហើយអាសវៈទាំងឡាយរមែងចម្រើនដល់បុគ្គលនោះដែលកើតហើយយ៉ាងនេះ គឺឈ្មោះថាជាអ្នកចូលដល់មូលនៃភព បានដល់ អាសវៈទាំងឡាយ ៤ មានកាមាសវៈជាដើម មានការចូលដល់នូវភាពជាមូល គឺភាពជាហេតុនៃសង្សារភពជាសភាវៈរមែងចម្រើនដល់បុគ្គលនោះក្រៃលែងនោះឯង គឺមិនវិនាសឡើយ តែអាសវៈទាំង ៤ នោះដែលខ្ញុំតាំងទៅហើយ ក្នុងការពិចារណាចម្រើនវិបស្សនាចាក់ធ្លុះនូវសច្ចៈទាំងឡាយ លះបង់ហើយដោយមិនមានចំណែកសេសសល់តាមលំដាប់នៃមគ្គ គឺអស់ទៅជុំវិញហើយ ។

## អដ្ឋកថា អភយត្ថេរគាថា ចប់

## ឧត្តិយត្ថេរគាថា

[ ១០០ ] បុគ្គលកាលស្តាប់សំឡេង ហើយធ្វើទុកក្នុងចិត្តនូវនិមិត្តជាទីស្រឡាញ់ សតិ រមែងភ្លាំងភ្លាត់ បុគ្គលនោះមានចិត្តត្រេកអរ ទទួលយកលេបយកនូវអារម្មណ៍នោះ អាសវៈទាំងឡាយដែលជាគ្រឿងនាំចូលទៅកាន់សង្សារ រមែងចម្រើនដល់បុគ្គលនោះ ។

ឧត្តិយត្ថេរ ។

## អដ្ឋកថា

## ឧត្តិយត្ថេរគាថា

[ ១០០ ] គាថារបស់ព្រះឧត្តិយត្ថេរ មានពាក្យផ្តើមថា **សទ្ទំ សុត្វា សតិ មុដ្ឋា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាសុមេធ កើតក្នុងផ្ទះមានត្រកូលដល់នូវភាពជាអ្នកដឹងក្តីហើយ ។ ថ្ងៃមួយជួបព្រះសាស្តា ជាអ្នកមានចិត្តជ្រះថ្លាហើយ តាក់តែងបល្ល័ង្កដែលក្រាលដោយសំពត់ធ្វើដោយរោមសត្វ មួយ-អន្លើដោយសំពត់បាំងអំពីខាងលើ សមគួរដល់ព្រះពុទ្ធ ហើយបានថ្វាយទុកក្នុងព្រះគន្ធកុដិ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំង-

ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលស្តេចសក្យនានគរកបិលពស្តុមាន ឈ្មោះថាឧត្តិយៈ កុលបុត្តនោះចម្រើនវ័យហើយឃើញពុទ្ធានុភាពក្នុងសមាគម នៃពួកញាតិរបស់ព្រះសាស្តា ជាអ្នកមានសទ្ធាបួសហើយ បំពេញសមណ ធម៌ ។ ថ្ងៃមួយ ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត បានស្តាប់សំឡេងច្រៀង របស់មាតុគ្រាមក្នុងវាំងផ្លូវកើតឆន្ទរាគៈក្នុងសំឡេងច្រៀងនោះដោយអំណាច នៃអយោនិសោមនសិការ ទើបរម្ងាប់ឆន្ទរាគៈនោះ ដោយកម្លាំងនៃការពិចារ ណា ហើយចូលទៅកាន់វិហារ កើតនូវសេចក្តីសង្វេគ អង្គុយក្នុងទីសម្រាក ពេលថ្ងៃចម្រើនវិបស្សនា សម្រេចអរហត្តក្នុងខណៈនោះឯង សមដូចគាថា ព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំបានថ្វាយបល្ល័ង្ក ( គ្រែ ) ព្រមទាំងពិតាន ចំពោះព្រះមាន ព្រះភាគព្រះនាមសុមេធៈជាច្បងក្នុងលោក ទ្រង់ប្រកបដោយ តាទិគុណ ។ ពេលនោះ បល្ល័ង្កដ៏បរិបូណ៌ដោយកែវ ៧ ប្រ- ការនោះ ( ហាក់ដូចជា ) ដឹងតម្រិះរបស់ខ្ញុំ តែងកើតសម្រាប់ ខ្ញុំសព្វៗកាល ។ ក្នុងកប្បទី ៣០០០០ អំពីកប្បនេះ ក្នុងកាល នោះព្រោះហេតុដែលខ្ញុំបានថ្វាយបល្ល័ង្កខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបល្ល័ង្ក ។ ក្នុងកប្បទី ២០០០០ ខ្ញុំបាន កើតជាស្តេចចក្រពត្តិ ៣ ជាតិ ព្រះនាមសុវណ្ណាភាទ្រង់បរិ- បូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ

ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយកាលនឹងសម្តែងថា កាលបុគ្គលមិនវៀសក្នុងកិលេសទាំងឡាយទេ រមែងមិនមានផ្លូវងើបក្បាលចាកវដ្តទុក្ខបានឡើយ ឯខ្ញុំវៀសក្នុងកិលេសទាំងនោះឯង ដូច្នេះ ដោយបំណងសម្តែងឲ្យឃើញការកើតឡើងនៃកិលេសរបស់ខ្លួន ទើបពោលគាថានេះថា

បុគ្គលកាលស្តាប់សំឡេង ហើយធ្វើទុកក្នុងចិត្តនូវនិមិត្តជាទីស្រឡាញ់ សតិរមែងភ្លាំងភ្លាត់ បុគ្គលនោះមានចិត្តត្រេកអរទទួលយក លេបយកនូវអារម្មណ៍នោះ អាសវៈទាំងឡាយដែលជាគ្រឿងនាំចូលទៅកាន់សង្សារ រមែងចម្រើនដល់បុគ្គលនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សទ្ទំ** បានដល់ សទ្ទារម្មណ៍ដែលជាទីតាំងនៃតម្រេក ។

បទថា **សំសារឧបគាមិនោ** សេចក្តីថា ឈ្មោះថា ជាអ្នកចូលដល់សង្សារ ព្រោះចូលដល់សង្សារដែលជាហេតុនៃវដ្តៈ ដែលលោកពោលទុកយ៉ាងនេះថា លំដាប់នៃខន្ធ ធាតុ អាយតនៈ ដែលប្រព្រឹត្តទៅមិនដាច់លោកហៅថាសង្សារ ដូច្នេះ ។

បាឋៈថា **សំសារូបគាមិនោ** ដូច្នេះក៏មាន ។ ពាក្យដ៏សេសមានន័យដូចពោលហើយក្នុងគាថាដែលអធិប្បាយកន្លងមកហើយនោះ□ង ។

**អដ្ឋកថា ឧត្តិយត្ថេរគាថា ចប់**

---

១-ក្នុងអបទានជាព្រះ បល្លង្កទាយត្ថេរ ។

## ទេវសភត្ថេរគាថា

[ ១០១ ] បុគ្គលប្រកបដោយសម្មប្បធាន មានសតិប្បដ្ឋានជាអារម្មណ៍ ដ៏ដេរដាសដោយផ្កាគឺវិមុត្តិ ជាអ្នកមិនមានអាសវៈនិងបរិនិព្វាន ។

*ទេវសភត្ថេរ ។*

**ឧទ្ទាន**

*និយាយអំពីបរិបុណ្ណត្ថេរ ១ វិជយត្ថេរ ១ ឯរកត្ថេរ ១ មេត្តជិត្ថេរជាអ្នកប្រាជ្ញ ១ ចក្ខុបាលត្ថេរ ១ ខណ្ឌសុមនត្ថេរ ១ តិស្សត្ថេរ ១ អភយត្ថេរ ១ ឧត្តិយត្ថេរមានបញ្ញាច្រើន ១ ទេវសភត្ថេរ ១ ។*

**ចប់ ទសមវគ្គ ។**

# អដ្ឋកថា

## (ទុតិយ)ទេវសភត្ថេរគាថា

[ ១០១ ] គាថារបស់ព្រះទេវសភត្ថេរ មានពាក្យផ្ដើមថា **សម្មប្បធាន សម្បន្នោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាសិខី កើតក្នុងផ្ទះនៃត្រកូលដល់នូវភាពជាអ្នកដឹងក្ដីហើយ ។ ថ្ងៃមួយឃើញព្រះមានព្រះភាគព្រះនាមថាសិខី ជាអ្នកមានចិត្តជ្រះថ្លា ហើយបានធ្វើការបូជាដោយផ្កាច្បា ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះកើតក្នុងសក្យត្រកូលមានឈ្មោះថាទេវសភៈ ។ កុលបុត្តនោះចម្រើនវ័យហើយ ឃើញពុទ្ធានុភាព ក្នុងកាលព្រះបរមសាស្ដាយាងមកដើម្បីរម្ងាប់នូវការទាស់ទែងគ្នា ក្នុងរឿងឆ្នូតក្បាល មានចិត្តជ្រះថ្លាហើយតាំងនៅក្នុងសរណគមន៍ កាលព្រះសាស្ដាគង់នៅក្នុងនិគ្រោធារាម ចូលទៅគាល់ព្រះសាស្ដាទៀត បាននូវសទ្ធាទើបចេញបួស ធ្វើបុព្វកិច្ចស្រេចហើយចម្រើនវិបស្សនា សម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

( ខ្ញុំបានឃើញព្រះពុទ្ធព្រះនាមសិខី ) ទ្រង់បរិសុទ្ធប្រាសចាក

មន្ទិលដូចព្រះចន្ទ្រ មានព្រះហឫទ័យថ្លាស្អាត មិនល្អក់ មាន

នន្ទិរាគៈនិងភពអស់ហើយព្រះអង្គឆ្លងហើយនូវវិសត្តិកាតណ្ហា

ក្នុងលោក ព្រះអង្គញ៉ាំងប្រជុំជនឲ្យរលត់ទុក្ខ ទ្រង់ធ្ងន់ហើយ ជាព្រះមុនីរបស់ពួកជនអ្នកធ្ងន់ កំពុងចម្រើនឈាន មានព្រះហឫទ័យនឹងក្នុងអារម្មណ៍តែមួយ គាំងមាំល្អក្នុងព្រៃ ។ ខ្ញុំពាក់នូវផ្កាច្បាលើខ្សែអំបោះ ហើយថ្វាយចំពោះព្រះពុទ្ធ ព្រះនាមសិខី ជាផៅពង្សនៃលោក ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ គ្រានោះ ព្រោះហេតុដែលខ្ញុំបានធ្វើបុញ្ញកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិព្រះនាមសមន្តចក្ខុ ទ្រង់មានយសច្រើន ជាធំក្នុងមនុស្ស មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ(១) ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ ជាអ្នកមាន បីតិ សោមនស្សកើតហើយ ព្រោះអាស្រ័យវិមុត្តិសុខដែលខ្លួនបានសម្រេចហើយ បានពោលគាថាដោយអំណាចនៃឧទានថា

បុគ្គលប្រកបដោយសម្មប្បធាន មានសតិប្បដ្ឋានជាអារម្មណ៍
ដ៏ដេរដាសដោយផ្កាគឺវិមុត្តិជាអ្នកមិនមានអាសវៈនឹងបរិនិព្វាន
ដូច្នេះ ។

---

១-ក្នុងអបទានជាព្រះ ពន្ធជីវកត្ថេរ ។

បណ្តាបទទាំងនោះ បទថា **សម្មប្បធានសម្បន្នោ** សេចក្តីថា សម្បូរដោយសម្មប្បធាន ៤ យ៉ាង អធិប្បាយថា ញុំាងកិច្ចដែលត្រូវធ្វើដោយសម្មប្បធានទាំងនោះឲ្យដល់ព្រមហើយ តាំងនៅ ។

បទថា **សតិប្បដ្ឋានគោចរោ** សេចក្តីថា ភិក្ខុ ឈ្មោះថា **សតិប្បដ្ឋានគោចរោ** ព្រោះមានសតិប្បដ្ឋាន ៤ មានកាយានុបស្សនាសតិប្បដ្ឋានជាដើមជាអារម្មណ៍ គឺជាទីតាំងនៃការប្រព្រឹត្ត អធិប្បាយថា ជាអ្នកមានចិត្តតាំងមាំហើយក្នុងសតិប្បដ្ឋាន ៤ ។

ផ្កា គឺ វិមុត្តិនោះឯង ឈ្មោះថា ជាផ្កាមានក្លិនក្រអូបឈ្ងុយឈ្ងប់ ព្រោះល្អដោយគុណ ភិក្ខុឈ្មោះថាប្រដាប់តាក់តែងហើយ គឺតាក់តែងហើយ បានដល់ធ្វើឲ្យគ្រប់គ្រាន់ហើយ ដោយវិមុត្តិទាំងនោះ ដោយប្រការទាំងពួង គឺដោយប្រពៃនោះឯង ។

បទថា **បរិនិព្វិស្សត្យនាសវោ** សេចក្តីថា ភិក្ខុកាលបដិបត្តិដោយប្រពៃយ៉ាងនេះ ជាអ្នកមិនមានអាសវៈនឹងបរិនិព្វានដោយសឧបាទិសេសនិព្វានធាតុនិងអនុបាទិសេសនិព្វានធាតុក្នុងកាលមិនយូរឡើយ ។ ពាក្យជាគាថានេះឯងបានជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈ ។

អដ្ឋកថា (ទុតិយ)ទេវសភត្ថេរគាថា ចប់

វគ្គទី ១០ ចប់

# ថេរគាថា ឯកនិបាត

## ឯកាទសមវគ្គ

### ពេលដ្ឋកានិត្ថេរគាថា

[ ១០២ ] បុរសបុគ្គលល្ងង់ខ្លៅ លះបង់សភាពជាគ្រហស្ថ ( ចូលកាន់ផ្នួស ) ជាអ្នកមិនបានអប់រំខ្លួន ជាអ្នកមានមាត់ដូចជានង្គ័ល ខ្ជិលច្រអូស បានតែខាងចិញ្ចឹមពោះ ដូចជ្រូកស្រុកធំដែលគេបំប៉នដោយចំណី តែងចូលទៅកាន់កគ៌រឿយៗ ។

ពេលដ្ឋកានិត្ថេរ ។

## វគ្គទី ១១

### អដ្ឋកថា

### ពេលដ្ឋកានិត្ថេរគាថា

[ ១០២ ] គាថារបស់ព្រះពេលដ្ឋកានិត្ថេរ មានពាក្យផ្ដើមថា **ហិត្វា គហិត្តំ អនវោសិតត្តោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រះមានព្រះភាគ ព្រះនាមថាវេស្សភូ កុលបុត្តនេះកើតក្នុងត្រកូលព្រាហ្មណ៍ ដឹងក្ដីហើយ ដល់នូវការ

សម្រេចក្នុងសិប្បវិជ្ជា របស់ព្រាហ្មណ៍ទាំងឡាយ លះនូវឃរាវាសវិស័យ ហើយបួសជាតាបស មានពួកឥសីចោមរោមគ្រាច់ទៅ ថ្ងៃមួយឃើញព្រះមានព្រះភាគព្រះនាមថាវេស្សភូ កើតនូវបីតិសោមនស្ស អាស្រ័យញាណសម្បត្តិរបស់ព្រះសាស្តាទើបជាអ្នកមានចិត្តជ្រះថ្លាបានធ្វើការបូជាដោយផ្កាទាំងឡាយឧទ្ទិសចំពោះព្រះញាណ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍នាក្រុងសាវត្ថី មានឈ្មោះថា ពេលដ្ឋកានិ ដល់នូវការដឹងក្តីហើយ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាបាននូវសទ្ធាបួសហើយ រៀនកម្មដ្ឋាននៅក្នុងព្រៃត្រង់ដែនកោសលជាអ្នកខិលប្រអូស មានវាងកាយធាត់ មានវាចាគ្រោតគ្រាត មិនញុំាងចិត្តឲ្យកើតឡើងក្នុងសមណធម៌ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ប្រមើលមើលនូវការចាស់ក្លានៃញាណ ហើយញុំាងពេលដ្ឋកានិភិក្ខុឲ្យសង្វេគ ដោយព្រះគាថានេះថា

> បុរសបុគ្គលល្ងង់ខ្លៅ លះបង់សភាពជាគ្រហស្ថ ( ចូលកាន់ផ្នួស ) ជាអ្នកមិនបានអប់រំខ្លួន ជាអ្នកមានមាត់ដូចជានង្គ័ល ខិលប្រអូស បានតែខាងចិញ្ចឹមពោះ ដូចជ្រូកស្រុកធំ ដែលគេបំប៉នដោយចំណី តែងចូលទៅកាន់គភ៌រឿយៗ ដូច្នេះ ។

ព្រះថេរៈឃើញព្រះសាស្តា ដូចគង់ក្នុងទីចំពោះមុខ ស្តាប់គាថានោះហើយ កើតសេចក្តីសង្វេគ ហើយចម្រើនវិបស្សនា សម្រេចអរហត្តក្នុងកាលមិនយូរ

ឡើយព្រោះញាណដល់នូវភាពចាស់ក្លា សមដូចគាថាព័ន្ធដែលលោកពោល ទុកក្នុងអបទានថា

( ព្រះពុទ្ធ ) ទ្រង់រុងរឿងដូចផ្កាកណិការ ទ្រង់គង់នៅនាចន្លោះភ្នំ ញុំាងទិសទាំងពួងឲ្យភ្លឺដូចផ្កាយព្រឹក មាណព ៣ នាក់ជាអ្នកសិក្សាជំនាញក្នុងសិល្បសាស្ត្ររបស់ខ្លួននាំគ្នាវែកអវែ្រក ដើរមកអំពីក្រោយខ្ញុំ ខ្ញុំបានយកផ្កាទាំង ៧ ដែលតាបសដាក់ក្នុងកញ្ចប់នោះ ហើយថ្វាយផ្កាទាំងនោះចំពោះញាណ របស់ព្រះវេស្សភូសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃញាណបូជា ។ ក្នុងកប្បទី ២៩ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្រពត្តិព្រះនាមវិហតាភាសៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលបដិបត្តិតាមឱវាទរបស់ ព្រះសាស្តាក្តី កាលព្យាករអរហត្តផលដោយបំណាំងនឹងពន្រើកសេចក្តីចេញទៅក្តី បានពោលគាថាដដែលនោះឯង ។

បណ្ដាបទទាំងនោះ បទថា **ហិត្វា គិហិត្តំ** សេចក្តីថា លះនូវភាពជា

---

១-ក្នុងអបទានជាព្រះ ចម្បកបុប្ផិយត្ថេរ ។

គ្រហស្ថ អធិប្បាយថា បួសហើយ ។

បទថា **អនធោសិតត្ថោ** សេចក្ដីថា មិនទាន់សម្រេចកិច្ច តាមសមគួរ អធិប្បាយថា ឈ្មោះថា មិនទាន់សម្រេចកិច្ច គឺមានករណីយកិច្ច មិនទាន់សម្រេច ព្រោះមិនទាន់សម្រេចកិច្ចមានបរិញ្ញាជាដើម ដែលសមគួរដល់អ្នកបួសក្នុងសាសនាតាមដែលបំណងទុក ។

ម្យ៉ាងទៀត បទថា **អនធោសិតត្ថោ** សេចក្ដីថា មិនទាន់សម្រេចកិច្ច ដោយលំដាប់ និងមិនទាន់បានធ្វើការនៅចប់ព្រហ្មចរិយៈ តាមលំដាប់នៃមគ្គដែលបរិសុទ្ធទាំងឡាយ អធិប្បាយថា មិនទាន់នៅចប់ក្នុងអរិយវាស ១០ ភិក្ខុឈ្មោះថា **មុខនង្គលី** ព្រោះមាននង្គ័ល ពោលគឺមាត់ អធិប្បាយថា ជីកនូវខ្លួនដោយប្រយោគ គឺពោលពាក្យគ្រោតគ្រាតក្នុងអ្នកដទៃទាំងឡាយ ដូចជីកផែនដីដោយនង្គ័ល ដូច្នោះ ។ បទថា **ឱទរិកោ** សេចក្ដីថា ខ្វល់ខ្វាយតែក្នុងរឿងផ្ទៃ គឺយកការបរិភោគជាធំ ។

បទថា **កុសីតោ** បានដល់ ខ្ជិលច្រអូស គឺមិនព្យាយាមប្រកបការនៃ ។ ព្រះថេរៈ កាលសម្ដែងដល់ការសម្រេចរបស់ភិក្ខុ ដែលមានសភាពយ៉ាងនេះ ក៏ពោលថា **មហាវរាហោវ និវាបបុដ្ឋោ បុនប្បុនំ គព្ភមុបេតិ មន្ទោ** ដូច្នេះ ។

អធិប្បាយនៃគាថានោះ ខ្ញុំពោលខាងដើមហើយនោះឯង ក្នុងគាថានេះ គប្បីយល់ថា ភិក្ខុបួសហើយ ជាបុគ្គលល្ងង់ ឈ្មោះថា រមែងចូលបន្ទប់ ( គភ៌ ) រឿយៗ ព្រោះភាពជាអ្នកមានព្រហ្មចរិយៈនៅមិនទាន់ចប់ជាសភាវៈ យ៉ាងណា ភិក្ខុដូចខ្ញុំជាបណ្ឌិតរមែងមិនដូច្នោះ ។ ព្រះថេរៈព្យាករអរហត្តផល

ដោយបំណាងបរិយាយសេចក្ដីថា បរិនិព្វាន ព្រោះដល់នូវទីបំផុតនៃសមាបត្តិ ដែលមានសភាវៈផ្ទុយគ្នាអំពីការបដិបត្តិដូចពោលហើយ ដូច្នេះឯង ។

## អដ្ឋកថា ពេលដ្ឋកានិត្ថេរគាថា ចប់

## សេតុច្ឆត្ថេរគាថា

[ ១០៣ ] ជនទាំងឡាយដែលត្រូវមានះបញ្ឆោត សៅហ្មងក្នុងសង្ខារ ត្រូវលាភ អលាភ ញាំញីហើយ រមែងមិនបាននូវសមាធិ ។

*សេតុច្ឆត្ថេរ ។*

## អដ្ឋកថា

## សេតុច្ឆត្ថេរគាថា

[ ១០៣ ] គាថារបស់ព្រះសេតុច្ឆត្ថេរ មានពាក្យផ្ដើមថា **មានេន វញ្ចិតាសេ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទរបស់ព្រះសម្មាសម្ពុទ្ធព្រះនាមថា តិស្សៈ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ។ ថ្ងៃមួយឃើញព្រះមានព្រះភាគ ព្រះនាមថាតិស្សៈ មានចិត្តជ្រះថ្លា បានថ្វាយផ្លែខ្នុរដែលមានរសផ្អែម និងរបស់ទំពាគឺផ្លែដូងដែលត្រៀមទុក ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះកើតជាឱរសរបស់ព្រះរាជាដែលសោយរាជក្នុងមណ្ឌលមួយអង្គមាននាមថាសេតុច្ឆៈ ។ កាលព្រះជនកសោយទិវង្គតហើយ កុលបុត្តនេះតាំងនៅក្នុងរាជសម្បត្តិ ធ្វើរាជកិច្ចជូរលុង ព្រោះ

មិនមាននូវឧស្សាហៈនិងមិនមានសមត្ថភាព ធ្វើឲ្យរាជសម្បត្តិធ្លាក់ក្នុងកណ្ដាប់ដៃរបស់សត្រូវ កើតនូវសេចក្ដីសង្វេគ ព្រោះដល់នូវសេចក្ដីទុក្ខ ទតឃើញព្រះមានព្រះភាគ ទ្រង់ចារិកទៅតាមជនបទ ជាអ្នកមានសទ្ធា ទ្រង់ព្រះផ្នួស ហើយធ្វើនូវបរិកម្មសម្រេចអរហត្តក្នុងថ្ងៃនោះឯងសមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ក្នុងកាលពីដើម ខ្ញុំបានថ្វាយផ្លែឈើ បានថ្វាយផ្លែដូងដែលគេសន្មតថាជាបង្អែមចំពោះព្រះមានព្រះភាគ ព្រះនាមតិស្សៈ ។ លុះខ្ញុំថ្វាយផ្លែឈើនោះចំពោះព្រះពុទ្ធព្រះនាមតិស្សៈជាមហេសីហើយ ក៏រីករាយ ខ្ញុំមានសេចក្ដីប្រាថ្នាក្នុងកាម ក៏បានទៅកើតតាមសេចក្ដីប្រាថ្នា ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងគ្រានោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យនូវផ្លែឈើ ។ ក្នុងកប្បទី ១៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ព្រះនាមឥន្ទសមៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលគិះដៀលកិលេសទាំងឡាយ

---

១-ក្នុងអបទានជាព្រះ ខជ្ជទាយកត្ថេរ ។

ទើបពោលគាថាដូច្នេះថា

ជនទាំងឡាយដែលត្រូវមានះបញ្ឆោត សៅហ្មងក្នុងសង្ខារត្រូវលាភ អលាភ ញាំញីហើយរមែងមិនបាននូវសមាធិដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មានេន វញ្ចិតាសេ** សេចក្ដីថា ដែលមានះប្រព្រឹត្តទៅហើយ ដោយន័យជាដើមថា ខ្ញុំជាបុគ្គលប្រសើរបំផុត ដូច្នេះ ធ្វើឲ្យប្រែប្រួលទៅដោយការចូលទៅកាត់នូវកណ្ឌៈ គឺ កុសល ដោយអំណាចនៃកិលេស មានការលើកខ្លួន សង្កត់សង្កិនអ្នកដទៃជាដើម ។

បទថា **សង្ខារេសុ សង្កិលិស្សមានាសេ** សេចក្ដីថា សៅហ្មងក្នុងឥន្ទ្រិយទាំងឡាយ មានចក្ខុជាដើមដែលប្រព្រឹត្តទៅក្នុងខាងក្នុង និងខាងក្រៅ និងក្នុងសង្ខតធម៌ទាំងឡាយ មានរូបជាដើម គឺដល់នូវការសៅហ្មង ដោយការកាន់យកនូវនិមិត្តនោះ ដោយជាតណ្ហាជាដើមថា នុ៎ះរបស់អញ អញជារបស់នោះ នុ៎ះជាខ្លួនរបស់អញ ដូច្នេះ ។

បទថា **លាភាលាភេន មថិតា** សេចក្ដីថា ដែលការបាន និងការមិនបានបរិក្ខារ មានបាត្រ និងចីវរជាដើម និងពស្ដុ មានសំពត់ជាដើម ញាំញីហើយ គឺជាន់ឈ្លីហើយ បានដល់ គ្របសង្កត់ហើយ ព្រោះកើតនូវការអាក់អន់ដោយការបាននិងការមិនបាននោះជាហេតុ ។ បទថា **លាភាលាភេន មថិតា** នេះ ត្រឹមតែជាគំរូ ក្នុងអធិការនេះ បណ្ឌិតគប្បីសង្គ្រោះយកលោកធម៌ ៨ ចូលផងដែរ ។

បទថា **សមាធឹ នាធិគច្ឆន្តិ** សេចក្ដីថា បុគ្គលបែបនេះ ជាអ្នកមិនមាន

ចិត្តជាសមាធិ ដោយអំណាចនៃសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋានក្នុងកាលណាឡើយ រមែងមិនចួប គឺមិនបាន បានដល់ មិនដល់នូវសមាធិ ព្រោះមិនមានធម៌ដែលប្រព្រឹត្តទៅដើម្បីសមាធិ និងព្រោះមានតែអកុសលធម៌ក្រៅអំពីនេះ ក្នុងគាថានេះ ពាក្យថា បុគ្គលមិនមានបដិភាណ ត្រូវកិលេសមានមានះជាដើមគ្របសង្កត់ហើយ ទោះចូលសមាធិនោះឯង ឈ្មោះថា រមែងមិនដល់សមាធិ យ៉ាងណា អ្នកមានប្រីជាទាំងឡាយ មិនដូច្នោះឡើយ អ្នកមានប្រីជាទាំងនោះជាបុគ្គលដូចខ្ញុំ មិនត្រូវកិលេស មានមានះជាដើមគ្របសង្កត់ឡើយ រមែងបាននូវសមាធិដោយចំណែកមួយ ដូច្នេះ គប្បីជ្រាបថា ជាពាក្យព្យាករអរហត្តផលរបស់ព្រះថេរៈ ដោយបំណងពង្រីកសេចក្ដីចេញទៅ ។

អដ្ឋកថា សេតុច្ឆត្តេរគាថា ចប់

## ពន្ធុរត្ថេរគាថា

[ ១០៤ ] ខ្ញុំមិនត្រូវការដោយលាភនុ៎ះទេ ខ្ញុំបានសេចក្តីសុខ ឆ្អែតដោយធម្មរស ក្រេបផឹករសដ៏ប្រសើរថ្លៃថ្លា មិនធ្វើនូវការជាប់ដោយរសទេ ។

ពន្ធុរត្ថេរ ។

## អដ្ឋកថា

## ពន្ធុរត្ថេរគាថា

[ ១០៤ ] គាថារបស់ព្រះពន្ធុរត្ថេរ មានពាក្យផ្តើមថា **ណាហំ ឯតេន អត្ថិកោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ។ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមថាសិទ្ធត្ថ កុលបុត្តនេះជាមហាមាត្យអ្នកគ្រប់គ្រង ក្នុងព្រះរាជវាំងរបស់ព្រះរាជាមួយអង្គ ឃើញព្រះមានព្រះភាគមួយអន្លើដោយបរិស័ទ ចូលកាត់លានព្រះរាជវាំង មានចិត្តជ្រះថ្លា បេះផ្កាច្បាប្បូជាព្រះលោកនាយក មួយអន្លើដោយភិក្ខុសង្ឃ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក អន្ទោលទៅមកក្នុងសុគតិភពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនសេដ្ឋីក្នុងសីលវតីនគរ មានឈ្មោះថាពន្ធុរៈ ។ កុលបុត្តនោះដល់នូវភាពជាអ្នកដឹងក្តីហើយ ទៅកាន់ក្រុងសាវត្ថីដោយករណីយកិច្ច ឯណានីមួយ ហើយទៅកាន់ព្រះវិហារ មួយអន្លើដោយឧបាសកទាំងឡាយ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា មានសទ្ធា

បួសហើយផ្ដើមតាំងវិបស្សនា សម្រេចអរហត្តក្នុងកាលមិនយូរឡើយ ព្រោះជាអ្នកមានញាណចាស់ក្លា សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះមានព្រះភាគ ព្រះនាមសទ្ធត្ថៈ ជាចម្បងក្នុងលោកជានរាសភៈ មានពួកសាវក ចោមរោមហើយ ទ្រង់ស្ដេចមកកាន់ក្រុង ។ ខ្ញុំជាអ្នកគ្រប់គ្រងក្នុងខាងក្នុងបុរី របស់ស្ដេចដែលស្ដេចតែងតាំង ខ្ញុំចូលទៅក្នុងប្រាសាទ បានឃើញព្រះពុទ្ធជាលោកនាយក ។ ខ្ញុំយកផ្កាច្បាពោយរាយចំពោះភិក្ខុសង្ឃពោយរាយចំពោះព្រះពុទ្ធ ធ្វើឲ្យផ្សេងច្រើនក្រៃលែងជាងនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៨៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិឈ្មោះមហិទ្ធិកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបាន ធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ តាំងនៅក្នុងភាពជាអ្នកមានកតញ្ញូ ទៅកាន់នគរវេសាលី ដើម្បីតបគុណព្រះរាជា ដែលមានឧបការៈដល់ខ្លួន គ្រា

---

១-ក្នុងអបទានជាព្រះ កណវេរបុប្ផិយត្ថេរ ។

សម្តែងធម៌ដល់ព្រះរាជា បានប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈព្រះរាជាបានជាព្រះសោតាបន្ន បានសាងវិហារធំ ឈ្មោះសុទស្សនៈ ក្នុងព្រះនគររបស់ព្រះអង្គប្រគេនដល់ព្រះថេរៈ ព្រះថេរៈជាអ្នកមានលាភសក្ការៈដ៏ធំ ។

ព្រះថេរៈប្រគល់វិហារនិងលាភសក្ការៈទាំងអស់ដល់សង្ឃឯខ្លួនឯងត្រាច់បិណ្ឌបាត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយទំនងមុននោះឯងស្នាក់នៅក្នុងសីលវតីនគរនោះអស់ថ្ងៃបន្តិចបន្តួច ជាអ្នកមានបំណងមកកាន់នគរសាវត្ថី ។

ភិក្ខុទាំងឡាយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់នៅក្នុងទីនេះឯង បើខ្វះខាតដោយបច្ច័យទាំងឡាយ ពួកខ្ញុំនឹងញុំាងបច្ច័យនោះឲ្យបរិបូណ៌ ។ ព្រះថេរៈកាលប្រាប់ឲ្យដឹងថា អាវុសោទាំងឡាយ ខ្ញុំមិនមានសេចក្តីត្រូវការដោយបច្ច័យដ៏ឧឡារ ខ្ញុំញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយបច្ច័យតាមមានតាមបាន ខ្ញុំជាអ្នកមានការពេញចិត្តដោយធម្មរសតែម្យ៉ាងប៉ុណ្ណោះ ដូច្នេះហើយ បានពោលគាថាថា

> ខ្ញុំមិនត្រូវការដោយលាភនុ៎ះទេ ខ្ញុំបានសេចក្តីសុខ ឆ្អែតដោយ
> ធម្មរស ក្រេបផឹករសដ៏ប្រសើរថ្លៃថ្លា មិនធ្វើនូវការជាប់ដោយ
> រសទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆាតំ ឃតេន អត្ថិកោ** សេចក្តីថា លោកទាំងឡាយមានបំណងនឹងឲ្យខ្ញុំឆ្អែត ត្រេកអរដោយអាមិសណា ទើបពោលថា ពួកខ្ញុំនឹងធ្វើបច្ច័យឲ្យបរិបូណ៌ ខ្ញុំមិនមានសេចក្តីត្រូវការដោយលាភ គឺអាមិសនេះដែលមានអាមិស គឺបច្ច័យជារស ខ្ញុំពិចារណាថា អាត្មាអញមិន

មានសេចក្តីត្រូវការដោយលាភ គឺអាមិសនេះ ព្រោះការសន្តោស ជាសុខយ៉ាងក្រៃលែង ដូច្នេះ ទើបញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយបច្ច័យតាមមានតាមបាន ។ ឥឡូវនេះ ព្រះថេរៈកាលប្រកាសហេតុដែលជាគោលក្នុងការមិនត្រូវការដោយលាភ គឺអាមិសនោះ ទើបពោលថា ខ្ញុំបានសេចក្តីសុខ ឆ្អែតដោយធម្មរសដូច្នេះ អធិប្បាយថា ខ្ញុំឆ្អែតហើយ គឺត្រេកអរហើយដល់សេចក្តីសុខ បានដល់ មានការពេញចិត្តដោយមានសុខក្រៃលែង ដោយរសនៃពោធិបក្ខិយធម៌ ៣៧ ប្រការ និងដោយរសនៃលោកុត្តរធម៌ ៩ ។

បទថា **បិត្វាន រសគ្គមុត្តមំ** សេចក្តីថា ផឹកនូវរសនៃធម៌ដ៏ឧត្តមជាងរសនៃបច្ច័យនោះៗឯង តាមដែលពោលទុកហើយថា ប្រសើរ គឺប្រសើរបំផុតក្នុងរសទាំងពួងប៉ុណ្ណោះ តាំងនៅហើយ សមដូចព្រះមានព្រះភាគត្រាស់ថា ធម្មរសឈ្នះរសទាំងពួង ដូច្នេះ ។ បទថា **ន ច កាហាមិ វិសេន សន្ថវំ** សេចក្តីថា ខ្ញុំផឹករសព្រះធម៌ដែលជារសដ៏ប្រសើរបែបនេះតាំងនៅហើយ នឹងមិនធ្វើសេចក្តីស្និទ្ធស្នាល គឺប្រឡូកប្រឡំដោយរសដទៃ គឺរសដែលជាពិសដូចគ្នានឹងថ្នាំពិស អធិប្បាយថា មិនមានហេតុឲ្យធ្វើយ៉ាងនោះ ។

## អដ្ឋកថា ពន្ធុរត្ថេរគាថា ចប់

## ខិតកត្ថេរគាថា

[ ១០៥ ] ឱហ្ន៎ កាយរបស់ខ្ញុំស្រាល កាលខ្ញុំត្រូវបីតិនិងសុខដ៏ទូលាយ ពាល់ត្រូវហើយ កាយរបស់ខ្ញុំ រមែងអណ្តែតឡើងបាន ដូចប៉ុយដែលបើង ដោយខ្យល់ ។

**ខិតកត្ថេរ ។**

## អដ្ឋកថា

## ខិតកត្ថេរគាថា

[ ១០៥ ] គាថារបស់ព្រះខិតកត្ថេរ មានពាក្យផ្តើមថា **លហុកោ វត មេ កាយោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះថេរៈនេះ ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទុកក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតជាយក្ខសេនាបតី ថ្ងៃមួយអង្គុយក្នុងសមាគមយក្ខ ឃើញព្រះសាស្តាគង់ត្រង់គល់ឈើមួយកន្លែង ទើបចូលទៅគាល់ ថ្វាយបង្គំព្រះសាស្តាហើយអង្គុយក្នុងចំណែកម្ខាង ។ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់យក្ខនោះ យក្ខស្តាប់ធម៌ហើយ បាននូវបីតិនិងសោមនស្សដ៏ឧឡារ ទះដៃក្រោកឡើង ថ្វាយបង្គំព្រះសាស្តា ធ្វើប្រទក្សិណហើយចៀសចេញទៅ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំង-ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍នាក្រុងសាវត្ថី មានឈ្មោះ

ជាទិតកៈ ដល់នូវភាពជាអ្នកដឹងក្តីហើយ ស្តាប់នូវភាពដែលព្រះមហាមោគ្គ-ល្លានជាអ្នកមានឫទ្ធិច្រើន គិតថាអញនឹងជាបុគ្គលដូចព្រះថេរៈអង្គនេះ កាលបុព្វហេតុជាស់តឿន បួសហើយ រៀនកម្មដ្ឋានក្នុងសម្នាក់នៃព្រះមានព្រះភាគ ធ្វើកម្មក្នុងសមថៈនិងវិបស្សនាទាំងឡាយ បានសម្រេចអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះពុទ្ធព្រះនាមបទុមៈ ព្រះអង្គជាធំជាងសត្វជើងពីរ ជានរា-សភៈ ទ្រង់មានបញ្ញាចក្ខុ ទ្រង់ចេញចាកព្រៃ គឺតណ្ហា តែងសម្តែងនូវធម៌ ។ ពួកយក្សបានប្រជុំគ្នាក្នុងទីជិតព្រះពុទ្ធមហេ-សីដោយកិច្ចដែលពួកយក្សទាំងនោះមកជួបជុំគ្នា ហើយប្រាថ្នាមើល ( នូវព្រះសម្ពុទ្ធ ) ក្នុងខណៈនោះ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តត្រេកអរ ដឹងច្បាស់នូវវាចារបស់ព្រះពុទ្ធ ជាគ្រឿងសម្តែងនូវព្រះនិព្វានឈ្មោះអមតៈទះដៃហើយចូលទៅបម្រើ ។ ខ្ញុំជួបនូវផលនៃការបម្រើ ដែលខ្ញុំសន្សំល្អហើយ ចំពោះព្រះសាស្តា ក្នុងកប្បទីបីម៉ឺន ខ្ញុំមិនដែលទៅកើតក្នុងទុគ្គតិឡើយ ។ ក្នុងកប្បទី ១២៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិព្រះនាម សមលង្កត ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១]។

---

១-ក្នុងអបទានជាព្រះ សុបារិចរិយត្ថេរ ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ តាំងនៅដោយប្រើឥទ្ធិវិធិច្រើនយ៉ាង ធ្វើនូវការសង្គ្រោះពួកសត្វដោយឥទ្ធិប្បាដិហារ និងដោយអនុសាសនីបាដិហារ ព្រោះជាអ្នកជំនាញក្នុងឫទ្ធិទាំងឡាយជាពិសេស ។ កាលភិក្ខុទាំងឡាយសួរថា អាវុសោ លោកប្រើឫទ្ធិបានដូចម្តេច កាលនឹងប្រាប់សេចក្តីនោះបានពោលគាថាថា

ឱហ្ន៎ កាយរបស់ខ្ញុំស្រាល កាលខ្ញុំត្រូវបីតិនឹងសុខដ៏ទូលាយ
ពាល់ត្រូវហើយ កាយរបស់ខ្ញុំរមែងអណ្តែតឡើងបានដូចប៉ុយ
ដែលប៉ើងដោយខ្យល់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **លហុកោ វត មេ កាយោ** មានអធិប្បាយថា រូបកាយរបស់ខ្ញុំ ឈ្មោះថាស្រាលពិតហ្ន៎ ព្រោះការទូន្មានចិត្តមានអាការ ១៤ បានដោយការសង្កត់កិលេសមាននីវរណៈជាដើម និងព្រោះវសីដែលខ្ញុំអប់រំមកល្អហើយដោយការចម្រើនឥទ្ធិបាទ ៤ ដោយវិធីផ្លាស់ប្តូរករជកាយដែលបានឈ្មោះថា មានមហាភូតរូបជាបច្ច័យនេះ ដោយអំណាចចិត្ត ។

បទថា **ផុដ្ឋោ ច បីតិ សុខេន វិបុលេន** ប្រកបសេចក្តីនេះថា រាងកាយរបស់ខ្ញុំដែលសេចក្តីសុខប្រកបដោយបីតិដ៏ឧឡារ ផ្សាយទៅពេញសរីរៈពាល់ត្រូវហើយ ពាក្យនេះ លោកពោលទុក ដើម្បីសម្តែងហេតុដែលធ្វើឲ្យកាយស្រាលបាន អធិប្បាយថា ការឈានចុះកាន់ការដឹងថាកាយស្រាលរមែងមានព្រមនឹងការឈានចុះកាន់ការដឹងថាជាសុខ ក្នុងអធិការនេះ គប្បីជ្រាបការផ្សាយទៅនៃសេចក្តីសុខដោយអំណាចនៃរូប ដែលជាសមុដ្ឋាន នៃការឈាន

ចុះកាន់ការដឹងថាកាយស្រាលនោះ ។

បើមានពាក្យសួរថា បុគ្គលដែលដល់ព្រមដោយចតុត្ថជ្ឈាននិងមានការផ្សាយបីតិ និងសុខទៅបានដូចម្ដេច ព្រោះថា ចតុត្ថជ្ឈាននោះ មានបីតិនិងសុខស្ងប់រម្ងាប់ហើយ ឆ្លើយថា សេចក្ដីនោះជាការពិត តែការផ្សាយទៅនៃបីតិនិងសុខនេះ លោកមិនបានពោលដោយអំណាចនៃលក្ខណៈរបស់ចតុត្ថជ្ឈាន ដោយពិត គឺពោលដោយអំណាចជាបុព្វភាគប៉ុណ្ណោះ ។ បទថា **បីតិសុខេន** បានដល់ សេចក្ដីសុខដែលដូចគ្នានឹងសុខប្រកបដោយបីតិអធិប្បាយថា ក្នុងអធិការនេះ ឧបេក្ខា លោកបំណងយកថាជាសុខ ព្រោះជាសភាវៈដែលស្ងប់រម្ងាប់និងប្រកបទៅដោយញាណវិសេស ។ សមដូចលោកពោល ( ទុកក្នុងបដិសម្ភិទាមគ្គ ) ថា សុខសញ្ញា និងលហុសញ្ញាទៅក្នុងកាយដូច្នេះ ។ ក្នុងបទនោះ មានអធិប្បាយដូច្នេះថា ព្រះអរិយបុគ្គលរមែងឈានចុះ គឺរមែងចូលទៅពាល់ត្រូវ បានដល់ ដល់ព្រមនូវសុខសញ្ញា និងលហុសញ្ញា ដែលកើតព្រមជាមួយឥទ្ធិចិត្ត ដែលមានឈានជាបាទជាអារម្មណ៍ ឬមានរូបកាយជាអារម្មណ៍ សមដូចលោកពោលទុកក្នុងអដ្ឋកថាថា សញ្ញាដែលសម្បយុត្តដោយឧបេក្ខាឈ្មោះថាសុខសញ្ញា ព្រោះថា ឧបេក្ខា លោកពោលថា ជាសុខដ៏ស្ងប់ហើយ សញ្ញានោះឯងគប្បីជ្រាបថា ឈ្មោះថា លហុសញ្ញា ព្រោះផុតហើយចាកនីវរណៈទាំងឡាយ និងចាកធម៌ដែលជាសត្រូវ មានវិតក្កជាដើម ។ សូម្បីករជកាយរបស់ព្រះអរិយបុគ្គល ដែលឈានចុះកាន់សញ្ញានោះ រមែងជាករជកាយស្រាលពិតដូចប៉ុយ ព្រះអរិយបុគ្គលរមែងទៅកាន់

ព្រហ្មលោក ដោយកាយដែលប្រាកដជាស្រាលពិត ដូចប៉ុយដែលរសាត់ទៅតាមកម្លាំងខ្យល់យ៉ាងនេះដោយ ហេតុនោះ ទើបព្រះថេរៈពោលថា កាយរបស់ខ្ញុំរមែងអណ្តែតឡើងបានដូចប៉ុយដែលប៉ើងដោយខ្យល់ ដូច្នោះ ។ គាថានោះ មានអត្ថថា ក្នុងពេលណាខ្ញុំមានបំណងទៅកាន់ព្រហ្មលោក ឬលោកដទៃដោយឫទ្ធិ ក្នុងកាលនោះ កាយរបស់ខ្ញុំ ក៏ស្ទុះទៅកាន់អាកាសមួយរំពេចដូចប៉ុយដ៏វិចិត្រត្រូវខ្យល់ គឺព្យុះបក់ទៅដូច្នោះ ។

## អដ្ឋកថា វិតកត្ថេរគាថា ចប់

## មលិតវម្ភត្ថេរគាថា

[ ១០៦ ] បុគ្គលអ្នកឈ្លាសវៃ ទោះបីអផ្សុក រមែងមិនទៅ ( ក្នុងអាវាសៈដែលមិនសប្បាយ ) ។ សូម្បីកាលត្រេកអរក៏ចៀសចេញ មិនគប្បីនៅគ្រប់គ្រងលំនៅដែលប្រកបដោយអំពើមិនជាប្រយោជន៍ទេ ។

**មលិតវម្ភត្ថេរ ។**

## អដ្ឋកថា

## មលិតវម្ភត្ថេរគាថា

[ ១០៦ ] គាថារបស់ព្រះមលិតវម្ភត្ថេរ មានពាក្យផ្ដើមថា **ឧក្កណ្ឋិតោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ កើតជាបក្សីក្នុងជាតស្រះមួយកន្លែង មិនឆ្ងាយពីព្រៃហិមពាន្ត ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះមានថាបទុមុត្តរៈ ។ ព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កាលទ្រង់អនុគ្រោះបក្សីនោះ ទើបយាងទៅកាន់ស្រះនោះ ហើយទ្រង់ចង្ក្រមត្រង់មាត់ស្រះ ។ បក្សីឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា ពាំយកផ្កាកុមុទក្នុងស្រះទៅបូជាព្រះមានព្រះភាគ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំង-ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តព្រាហ្មណ៍ម្នាក់ក្នុងកុរុកច្ឆនគរ មាននាមថា មលិតវម្ភ ។ កុលបុត្តនោះដឹងក្ដីហើយ ចូលទៅរកព្រះបច្ឆាភូមហាថេរៈ

ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះថេរៈ មានសទ្ធាបួសហើយចម្រើននូវវិបស្សនា ។ ព្រះថេរៈមានសភាពយ៉ាងនេះ គឺក្នុងទីណារកភោជនជាទីសប្បាយបានដោយលំបាក បច្ច័យក្រៅអំពីនេះរកបានងាយ លោកមិនចៀសចេញទៅអំពីទីនោះ តែក្នុងទីណារកភោជនជាទីសប្បាយបានដោយងាយ បច្ច័យក្រៅពីនេះរកបានលំបាក លោកមិននៅក្នុងទីនោះចៀសចេញទៅមួយរំពេច កាលលោកនៅយ៉ាងនេះ ចម្រើនវិបស្សនា សម្រេចអរហត្តហើយ ក្នុងកាលមិនយូរឡើយ ព្រោះភាពដែលលោកជាអ្នកសម្បូរដោយហេតុ និងព្រោះភាពដែលលោកជាអ្នកមានជាតិនៃមហាបុរស សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

មានស្រះកើតឯងដ៏ធំ ក្នុងទីជិតភ្នំហិមពាន្ត ជាស្រះដេរដាសដោយឈូកនិងឧប្បល ព្រោងព្រាតដោយផ្កាឈូកស ។ ក្នុងកាលនោះ ខ្ញុំកើតជាមាន់ ជាសកុណជាតិ នៅជិតស្រះនោះ ជាសត្វមានសីល បរិបូណ៌ដោយវត្តឈ្លាសវៃក្នុងអំពើបុណ្យនិងបាប ។ ព្រះពុទ្ធជាមហាមុនីព្រះនាមបទុមុត្តរៈជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលនូវគ្រឿងបូជា ត្រាច់ទៅក្នុងទីមិនឆ្ងាយអំពីជាតស្រះនោះ ។ ខ្ញុំបានកាច់ផ្កាកុមុទៈ ដែលកើតក្នុងទឹកអន្លោនចូលមកថ្វាយព្រះមហេសី ។ ព្រះពុទ្ធជាមហាមុនីទ្រង់ជ្រាបនូវសេចក្តីត្រិះរិះរបស់ខ្ញុំ ទ្រង់ក៏ទទួលយក ។ ខ្ញុំត្រូវកុសលមូលដាស់តឿន ព្រោះបានឲ្យទាននោះ ខ្ញុំក៏មិនទៅកើត

ក្នុងទុគ្គតិអស់ ១ សែនកប្ប ។ ក្នុងកប្បទី ១១៦ អំពីកប្ប
នេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៨ ជាតិ ព្រះនាមវរុណៈដូច
គ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង
អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា
របស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួន កាល
នឹងបន្លឺឧទានបានពោលគាថាថា

បុគ្គលអ្នកឈ្លាសវៃទោះបីអផ្សុករមែងមិននៅ ( ក្នុងអាវាស
ដែលមិនសប្បាយ ) ។ សូម្បីកាលត្រេកអរក៏ចៀសចេញ
មិនគប្បីនៅគ្រប់គ្រងលំនៅ ដែលប្រកបដោយអំពើមិនជាប្រ-
យោជន៍ទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧក្កណ្ឋិតោបិ ន វសេ** សេចក្តីថា ការអផ្សុក
គឺការមិនត្រេកអរក្នុងកុសលធម៌ទាំងឡាយព្រោះមិនបានភោជនជាទីសប្បាយ
កើតដល់ខ្ញុំដែលនៅក្នុងអាវាសណា ទោះបីខ្ញុំអផ្សុក ក៏នៅក្នុងអាវាសនោះឯង
គឺមិនគេច បានដល់ មិនចៀសចេញទៅ ព្រោះការបានបច្ច័យដទៃ ដែល
សប្បាយ ។

ក្នុងបទថា **ន វសេ** នេះ គប្បីយក **ន** អក្ខរៈ មកភ្ជាប់ជាមួយបទថា
**បក្កមេ** ផងដែរ ។

---

១-ក្នុងអបទានជាព្រះ កុមុទទាយកត្ថេរ ។

បទថា **រមមានោបិ បក្កមេ** សេចក្តីថា ចំណែកការអផ្សុករមែងមិនមានដល់ខ្ញុំក្នុងអាវាសណា ព្រោះមិនមានការខ្វះខាតបច្ច័យ ខ្ញុំត្រេកអរក្រៃលែងក្នុងអាវាសនោះ ដោយពិត ទោះបីខ្ញុំត្រេកអរយ៉ាងនេះ ក៏ត្រូវគេចទៅអំពីអាវាសនោះ គឺមិនគប្បីនៅ ព្រោះមិនបានបច្ច័យដែលជាសប្បាយដ៏សេស ។ កាលខ្ញុំបដិបត្តិយ៉ាងនេះ ក៏បានសម្រេចនូវប្រយោជន៍ខ្លួន ក្នុងកាលមិនយូរឡើយ ។ ក្នុងទីនេះគាថានេះជាការប្រកបសេចក្តី ក្នុងការពិចារណាបដិបទាផ្ទាល់ខ្លួន ។ ចំណែកការឲ្យឱវាទដល់អ្នកដទៃ គប្បីប្រកបសេចក្តីដោយការធ្វើប្រយោគថា ត្រូវនៅគឺមិនចៀសចេញទៅ ។

បទថា **ន ត្វេវានត្ថសំហិតំ វសេ វាសំ វិចក្ខណោ** សេចក្តីថា បុគ្គលមានបញ្ញាឃើញប្រចក្ស គឺជាអ្នកមានជាតិនៃវិញ្ញូជន បំណងនឹងបំពេញនូវប្រយោជន៍ខ្លួនឲ្យបរិបូណ៌ មិនគប្បីនៅក្នុងអាវាសដែលប្រកបដោយវត្ថុមិនជាប្រយោជន៍ក្នុងធម្មវិន័យនេះ មានអធិប្បាយថា ក្នុងអាវាសណាមានបច្ច័យរកបានងាយ សមណធម៌រមែងមិនដល់នូវភាពបរិបូណ៌ ក្នុងអាវាសណាមានបច្ច័យរកបានដោយលំបាក សមណធម៌ក៏មិនដល់នូវភាពបរិបូណ៌ អាវាសបែបនេះឈ្មោះថាប្រកបដោយវត្ថុដែលមិនជាប្រយោជន៍ គឺប្រកបទៅដោយការមិនចម្រើនដុះដាលក្នុងធម្មវិន័យនេះ ។ តែក្នុងទីណា ភិក្ខុបានអាវាសប្រកបដោយអង្គ ៥ បាននូវសប្បាយទាំង ៧ គប្បីនៅក្នុងអាវាសនោះឯង ។

**អដ្ឋកថា មលិតវម្ភត្ថេរគាថា ចប់**

## សុហេមន្តត្ថេរគាថា

[ ១០៧ ] អត្ថមានអាថ៌កំបាំងច្រើន ទ្រទ្រង់លក្ខណៈដ៏ចម្រើន ជនឥតប្រាជ្ញា ឃើញអង្គនៃអត្ថតែមួយ ចំណែកបណ្ឌិតជាអ្នកឃើញអត្ថដ៏ច្រើន ។

សុហេមន្តត្ថេរ ។

## អដ្ឋកថា

## សុហេមន្តត្ថេរគាថា

[ ១០៧ ] គាថារបស់ព្រះសុហេមន្តត្ថេរ មានពាក្យផ្តើមថា **សតលិង្គស្ស អត្ថស្ស** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនៃព្រះមានព្រះភាគព្រះនាមថាតិស្សៈ ក្នុងកប្បទី ៩២ អំពីភទ្ទកប្បនេះ កុលបុត្តនោះកើតជាព្រានព្រៃនៅក្នុងព្រៃ ។ ព្រះមានព្រះភាគយាងចូលកាន់ព្រៃ ដើម្បីអនុគ្រោះកុលបុត្តនោះ ទើបគង់ត្រង់គល់ឈើមួយដើមក្នុងទីមិនឆ្ងាយអំពីព្រានព្រៃនោះ ។ កុលបុត្តនោះ ឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា បេះផ្កាបុស្សនាគដែលមានក្លិនក្រអូបមកបូជាព្រះមានព្រះភាគ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក សន្សំបុណ្យហើយ

អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាព្រាហ្មណបុត្ត ដែលសម្បូរដោយសម្បត្តិ ត្រង់បច្ចន្តជនបទ មានឈ្មោះថាសុហេមន្ត ។ កុលបុត្តនោះដល់នូវភាពជាអ្នកដឹងក្តីហើយ ចូលទៅគាល់ព្រះមានព្រះភាគដែលគង់នៅក្នុងមិគទាយវ័ន ក្នុងសង្កស្សនគរ ស្តាប់ធម៌ហើយបាននូវសទ្ធាបួសហើយ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ផ្តើមតាំងវិបស្សនា បាននូវអភិញ្ញា ៦ ដល់នូវភាពជាអ្នកជំនាញក្នុងបដិសម្ភិទា ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំបានកើតជាព្រានព្រៃ អាស្រ័យនៅក្នុងព្រៃធំ បានឃើញនូវឈើបុន្នាគដែលមានផ្ការីក ក៏នឹកដល់ព្រះសម្ពុទ្ធដ៏ប្រសើរ ។ ខ្ញុំបេះយកផ្កាដែលមានក្លិនក្រអូបឈ្ងុយឈ្ងប់ល្អនោះ ធ្វើជាព្រះស្តូបលើផ្នូកខ្សាច់ ហើយបូជាចំពោះព្រះសម្ពុទ្ធ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៩១ ខ្ញុំបានកើតជាស្តេចចក្រពត្តិមួយព្រះអង្គព្រះនាម តមោនុទៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំក៏បានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ គិតយ៉ាងនេះថា កិច្ចនៃបព្វជិតណា

---

១-ក្នុងអបទានជាព្រះ បុន្នាគបុប្ផិយត្ថេរ ។

*ដែលអញជាសាវកគប្បីសម្រេច កិច្ចនៃបព្វជិតនោះ អញបានសម្រេចហើយដោយលំដាប់ បើដូច្នោះ ក្នុងឥឡូវនេះអញគប្បីធ្វើការអនុគ្រោះភិក្ខុទាំងឡាយ កាលគិតយ៉ាងនេះហើយ ព្រោះភាពដែលលោកជាអ្នកបែកធ្លាយក្នុងបដិសម្ភិទា និងព្រោះភាពដែលលោកជាអ្នកមិនខ្ជិលច្រអូស ទើបឲ្យឱវាទប្រៀនប្រដៅ កាត់សេចក្តីសង្ស័យ សម្តែងធម៌ ប្រាប់កម្មដ្ឋានដល់ភិក្ខុទាំងឡាយដែលចូលទៅកាន់សម្នាក់របស់ខ្លួន ធ្វើឲ្យជាក់ច្បាស់ អស់នូវសេចក្តីសង្ស័យ ក្នុងថ្ងៃមួយ កាលប្រាប់គុណវិសេសដល់ភិក្ខុនិងបុគ្គលដែលជាវិញ្ញូជនដែលចូលទៅកាន់សម្នាក់របស់ខ្លួន ទើបពោលគាថាដូច្នេះថា*

> *អត្ថមានអាចិកំបាំងច្រើន ទ្រទ្រង់លក្ខណៈដ៏ចម្រើន ជនឥតប្រាជ្ញាឃើញអង្គនៃអត្ថតែមួយ ចំណែកបណ្ឌិត ជាអ្នកឃើញអត្ថដ៏ច្រើន ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **សតលិង្គស្ស** *សេចក្តីថា សភាវធម៌ឈ្មោះថា លិង្គៈ ព្រោះដល់នូវអត្ថដែលកំបាំង បានដល់ និមិត្តរបស់សព្ទ ដែលប្រព្រឹត្តទៅក្នុងអត្ថទាំងឡាយ និមិត្តទាំងនោះ ឈ្មោះថា* **សតលិង្គ** *ព្រោះមានអាចិកំបាំងរាប់រយ ។ អធិប្បាយថា* **សត** *សព្ទក្នុងទីនេះជាអនេកត្ថ គឺមានអត្ថច្រើន មិនមែនប្រាប់ការផ្សេងគ្នាក្នុងចំនួនន័យ ដូចក្នុងប្រយោគជាដើមថា* **សតំ** *ប្រែថា ១០០* **សហស្សំ** *ប្រែថា ១០០០ ។ នូវអត្ថដែលកំបាំងរាប់រយនោះ ។*

*បទថា* **អត្ថស្ស** *បានដល់ ញេយ្យធម៌ ។ ញេយ្យធម៌លោកហៅថា*

អត្ថ ព្រោះគប្បីដឹងបានដោយញាណ ។ អត្ថនោះសូម្បីតែមួយ ក៏មានអត្ថមិនមែនតិច ដូចសព្ទថា **សញ្ញា បុរិន្ទទោ មឃវា** និងសព្ទថា **បញ្ញា វិជ្ជា មេធា ញាណំ** ។ **សក្ក** សព្ទជាដើមក្នុងពាក្យថា **សញ្ញា បុរិន្ទទោ មឃវា** នោះ មិនមែនមានអត្ថតាមឥន្ទសព្ទ ដែលប្រែថា ជាធំក្នុងឋានតាវត្តិង្ស ព្រោះមានអត្ថកំបាំង គឺមានអត្ថបង្អួលប្រាប់ ដូចគ្នានឹងពាក្យថា **វិជ្ជា** ជាដើម មិនមែនមានអត្ថដូចពាក្យថា **បញ្ញា** ដែលប្រើក្នុងអត្ថថា ឃើញត្រូវ ។ ដូច្នោះទើបព្រះថេរៈពោលថា **សតលិង្គស្ស អត្ថស្ស** ប្រែថា អត្ថមានអាថ៌កំបាំងច្រើន ដូច្នេះ ។

បទថា **សតលក្ខណធារិនោ** សេចក្ដីថា មានលក្ខណៈមិនមែនតិច ឈ្មោះថា **លក្ខណា** ព្រោះជាគ្រឿងកំណត់ បានដល់ ភាពដែលអត្ថជាតួបច្ច័យ ជាបច្ច័យដែលអាស្រ័យផលរបស់ខ្លួនមានឡើង ព្រោះដោយលក្ខណៈ ( ដែលពោល ) នោះទើបអត្ថកំណត់បានថា អត្ថនេះ ជាហេតុនៃអត្ថនេះ ។ អត្ថតែម្យ៉ាងរមែងមានន័យច្រើនយ៉ាង ដោយហេតុនោះទើបព្រះថេរៈពោលថា **សតលក្ខណធារិនោ** ដូច្នេះ ។ ម្យ៉ាងទៀត ឈ្មោះថា **លក្ខណា** ព្រោះលោកកំណត់ បានដល់ ភាពដែលអត្ថនោះៗ មានពាក្យផ្សេងចេញទៅ ដូចជា សន្ទិតតា ជាដើម ។ តែពាក្យនោះ ដោយអត្ថ គប្បីជ្រាបថា មានន័យមិនផ្សេងគ្នា ។ ឯពាក្យនោះ លោកហៅថា លិង្គ ព្រោះវិគ្គហៈថា ធ្វើឲ្យដឹង គឺឲ្យយល់នូវសាមញ្ញលក្ខណៈ មានការមិនទៀងជាដើម នៃសង្ខតធម៌ទាំងនោះ ។ សេចក្ដីនោះមានអាការដូចពោលមកនេះ ព្រោះហេតុដែលអត្ថសូម្បី

*តែមួយ មានន័យច្រើនយ៉ាង ដោយហេតុនោះ ទើបព្រះថេរៈពោលថា* **សក-លិង្គស្ស អត្ថស្ស សកលក្ខណាធារិណោ** *ដូច្នេះ ។ សមដូចព្រះធម្មសេនាបតីពោលទុកក្នុង ( ខុទ្ទកនិកាយមហានិទ្ទេស ) ថា* **សព្វេ ធម្មា សព្វាកា-រេន ពុទ្ធស្ស ភគវតោ ញាណមុខេ អាបាថំ អាគច្ឆន្តិ** *ធម៌ទាំងអស់រមែងមកកាន់គន្លងចំពោះមុខព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគដោយអា-ការសព្វគ្រប់ ដូច្នេះ ។*

*បទថា* **ឯកង្គទស្សី ទុម្មេធោ** *សេចក្តីថា កាលអត្ថដែលមានអត្ថមិនមែនតិច មានលក្ខណៈជាអនេក ដូច្នេះមាន បុគ្គលណាមានប្រក្រតីឃើញបានដោយចំណែកមួយ ព្រោះមានបញ្ញាមិនទូលាយ គឺឃើញថា មានអត្ថត្រឹមតែមួយ និងមានលក្ខណៈត្រឹមតែមួយ នឹងជឿមាំក្នុងវត្ថុដែលខ្លួនឃើញហើយប៉ុណ្ណោះថា វត្ថុនេះប៉ុណ្ណោះពិត បដិសេធវត្ថុក្រៅអំពីនេះថា វត្ថុដទៃជាមោឃៈ បុគ្គលនោះ ឈ្មោះថា ជាបុគ្គលល្ងង់ខ្លៅ គឺមានបញ្ញាថោកថយកាន់យកត្រឹមតែម្យ៉ាង ព្រោះមិនដឹងពាក្យដែលផ្សេងគ្នា ដែលមានក្នុងអត្ថនោះឯង និងព្រោះជឿមាំក្នុងសភាវខុស ឧបមាដូចមនុស្សក្អែកខ្វាក់ ស្ទាបដំរីដូច្នោះ ។*

*បទថា* **សតទស្សី ច បណ្ឌិតោ** *សេចក្តីថា ឯបណ្ឌិត រមែងឃើញប្រការទាំងឡាយមិនមែនតិច ដែលមានក្នុងអត្ថនោះ ដោយប្រការទាំងពួងដោយបញ្ញាចក្ខុរបស់ខ្លួន ។ ម្យ៉ាងទៀត បុគ្គលណាដឹងនូវអត្ថជាអនេកដែលគប្បីរកបានក្នុងអត្ថនោះដោយបញ្ញាចក្ខុដោយខ្លួនឯងផង សម្តែង និងប្រកាស*

ដល់អ្នកដទៃបានទៀតផង បុគ្គលនោះជាបណ្ឌិត គឺឈ្មោះថា ជាអ្នកមានបញ្ញា ឃើញប្រចក្ស ឈ្លាសក្នុងអត្ថទាំងឡាយ ។

ព្រះថេរៈញុំាងសម្បត្តិ គឺបដិសម្ភិទាញាណដ៏កំពូលរបស់ខ្លួនឲ្យជាក់ច្បាស់ ដល់ភិក្ខុទាំងឡាយដោយប្រការដូច្នេះ ។

## អដ្ឋកថា សុហេមន្តត្ថេរគាថា ចប់

## ធម្មសវរត្ថេរគាថា

[ ១០៨ ] ខ្ញុំរំពឹងឃើញហើយ ទើបចេញចាកផ្ទះ ចូលកាន់ផ្នួស ត្រៃវិជ្ជាខ្ញុំបានហើយ ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ។

**ធម្មសវរត្ថេរ ។**

## អដ្ឋកថា

## ធម្មសវរត្ថេរគាថា

[ ១០៨ ] គាថារបស់ព្រះធម្មសវរត្ថេរ មានពាក្យផ្ដើមថា **បព្វជឹ តុលយិត្វាន** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក្នុងកាលព្រះមានព្រះភាគ ព្រះនាមជាបទុមុត្តរៈ ជាព្រាហ្មណ៍ឈ្មោះថាសុវច្ឆៈ រៀនចប់ត្រៃវេទ ឃើញទោសក្នុងការនៅគ្រប់គ្រងផ្ទះ ទើបបួសជាតាបសសាងអាស្រមក្នុងញកភ្នំ ត្រង់ជាយព្រៃ រួមនឹងតាបសជាច្រើន ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់មានបំណងបណ្ដុះនូវពូជ គឺកុសលដល់កុលបុត្តនោះ ទើបយាងទៅប្រថាប់ឈរលើអាកាស ក្បែរអាស្រម រួចទ្រង់សម្ដែងឥទ្ធិប្បាដិហារ្យ សុវច្ឆតាបសឃើញឥទ្ធិប្បាដិហារ្យនោះ ជាអ្នកមានចិត្តជ្រះថ្លា ប្រាថ្នានឹងបូជា ទើបបេះផ្កាខ្នឹងមកថ្វាយ ។ ព្រះសាស្ដាទ្រង់ព្រះតម្រិះថា សម្រាប់ពូជ គឺកុសលមានប្រមាណប៉ុណ្ណេះ ល្មមសមគួរដល់តាបសនេះ ដូច្នេះហើយ ទ្រង់យាងចៀសចេញទៅ តាបសបេះផ្កាមកពោយ

លើផ្លូវដែលព្រះបរមសាស្តាយាងចូលទៅ ហើយញ៉ាំងចិត្តឲ្យជ្រះថ្លា ឈរផ្គង អញ្ជលីហើយ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ កើតក្នុងទេវលោក អន្ទោលទៅមក ក្នុងសុគតិភពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ដែនមគធៈ មានឈ្មោះថាធម្មសវៈ ដល់នូវភាពជាអ្នកដឹងក្តីហើយ កាលហេតុសម្បត្តិជាស់តឿន ឃើញទោសក្នុងការនៅគ្រប់គ្រងផ្ទះ និងអានិសង្សក្នុងបព្វជ្ជាចូលទៅគាល់ព្រះមានព្រះភាគដែលគង់នៅក្នុងទក្ខិណាគិរីជនបទ ស្តាប់ធម៌ហើយ ជាអ្នកមានសទ្ធា បព្វជ្ជាហើយចម្រើនវិបស្សនាសម្រេច អរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រាហ្មណ៍ឈ្មោះសុវច្ឆៈ ជាអ្នកដល់នូវត្រើយនៃមន្ត មានពួកសិស្សចោមរោមតែងនៅក្នុងចន្លោះភ្នំ ។ ព្រះជិនស្រី ព្រះនាមបទុមុត្តរៈទ្រង់គួរទទួលនូវគ្រឿងបូជា ព្រះអង្គមានប្រាថ្នាដើម្បីស្រោចស្រង់នូវខ្ញុំ ទើបស្តេចមកកាន់សំណាក់ខ្ញុំ ។ ទ្រង់ចង្រ្កមលើអាកាសដូចប្រទីបរុងរឿងទ្រង់ជ្រាបច្បាស់នូវសេចក្តីត្រេកអររបស់ខ្ញុំ ហើយមានព្រះភក្ត្រ បែរទៅទិសខាងកើត ស្តេចចៀសចេញទៅ ។ ចំណែកខាងខ្ញុំ ឃើញហេតុអស្ចារ្យចំឡែកគួរជាទីព្រឺរោមនោះហើយ ក៏កាន់យកនូវផ្កាខ្ទឹងរោយរាយលើផ្លូវដែលព្រះអង្គស្តេចទៅ ។ ក្នុងកប្បទី ១ សែន អំពីកប្បនេះព្រោះហេតុដែលខ្ញុំបានរោយរាយផ្កា ដោយចិត្តជ្រះថ្លានោះ

ខ្ញុំមិនដែលទៅកើតក្នុងទុគ្គតិ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ
ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមមហារថៈ ទ្រង់មានកម្លាំង
ច្រើន បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ
៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំង
សាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[1] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួន ដល់នូវភាពសោមនស្ស បានពោលគាថាដោយអំណាចនៃឧទានថា

ខ្ញុំរំពឹងឃើញហើយ ទើបចេញចាកផ្ទះចូលកាន់ផ្នួស ត្រៃវិជ្ជា
ខ្ញុំបានហើយ ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បច្ចវេក្ខិត្វាន** សេចក្តីថា ពិចារណា គឺត្រិះរិះនូវទោស ក្នុងឃរាវាសដោយន័យជាដើមថា ការនៅគ្រប់គ្រងផ្ទះចង្អៀត ( ពេកណាស់ ) ជាផ្លូវនៃធូលី ដូច្នេះ បានដល់ ពិចារណាទោសក្នុងកាមទាំងឡាយដោយន័យជាដើមថា កាមទាំងឡាយមានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ដូច្នេះ និងអានិសង្សក្នុងការចេញបួសដោយផ្ទុយគ្នានឹងទោសក្នុងកាមនោះដោយបញ្ញាដូចជញ្ជីង ។

ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ឯពាក្យជាគាថានេះបានជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈដូច្នេះឯង ។

**អដ្ឋកថា ធម្មសវរត្ថេរគាថា ចប់**

---

១-ក្នុងអបទានជាព្រះ នាគបុប្ផិយត្ថេរ ។

## ធម្មសវបិតុត្ថេរគាថា

[ ១០៩ ] ខ្ញុំមានអាយុប្រកបដោយឆ្នាំ ១២០ ទើបចេញចាកផ្ទះ ចូលកាន់ផ្នួស ត្រៃវិជ្ជាខ្ញុំបានហើយ ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ។

**ធម្មសវបិតុត្ថេរ ។**

## អដ្ឋកថា

## ធម្មសវបិតុត្ថេរគាថា

[ ១០៩ ] គាថារបស់ព្រះធម្មសវបិតុត្ថេរ មានពាក្យផ្តើមថា **សវីស-វស្សសតិកោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ កាលផែនដីមិនមានព្រះពុទ្ធ កើតឡើងក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ឃើញព្រះបច្ចេកពុទ្ធនៅលើភ្នំឈ្មោះភូតគណៈ មានចិត្តជ្រះថ្លា បានធ្វើការបូជាដោយផ្កាម្ទិះរួត ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក អន្ទោលទៅមកតែក្នុងសុគតិភពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ដែនមគធៈ ដល់នូវភាពជាអ្នកដឹងក្តីហើយ មានក្រុមគ្រួសារ មានកូនឈ្មោះធម្មសវៈ កាលកូនបួសហើយ ខ្លួនឯងក៏ចូលដល់វ័យជរា មានអាយុ ១២០ ឆ្នាំ កើតសេចក្តីសង្វេគថា កូនរបស់អញនៅកំលោះ បួសមុនហើយ បើដូច្នោះ ហេតុ

អ្វីទើបអញមិនបួស ដូច្នេះហើយ ទៅកាន់សម្នាក់ព្រះសាស្តាស្តាប់ធម៌ហើយ បួសផ្តើមវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលពោលទុកក្នុងអបទានថា

ភ្នំឈ្មោះកុក្កុដណៈមានក្នុងទីជិតភ្នំហិមពាន្ត ព្រះជិនស្រីសយម្ភូ
ទ្រង់រលាស់ចេញចាកលោក ទ្រង់គង់មួយអង្គឯងក្នុងទីនោះ ។
ខ្ញុំយកផ្កាម្ទេះរួតទាំងឡាយ បូជាព្រះពុទ្ធ ខ្ញុំមិនដែលទៅកើតជា
វិនិបាតអស់ ៩៩ ពាន់កប្ប ព្រោះកុសលនេះ ។ ក្នុងកប្បទី
១១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១ អង្គ ព្រះ
នាមធរណីរុហៈ ទ្រង់មានកម្លាំងច្រើន ទ្រង់បរិបូណ៌ដោយកែវ
៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ
ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំ
បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួន កើតនូវសោមនស្ស កាលនឹងបន្លឺឧទានបានពោលគាថាដូច្នេះថា

ខ្ញុំមានអាយុប្រកបដោយឆ្នាំ ១២០ ទើបចេញចាកផ្ទះចូលកាន់
ផ្នួសត្រៃវិជ្ជាខ្ញុំបានហើយពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សវីសវស្សសតិកោ** សេចក្តីថា ខ្ញុំមានអាយុ ១២០ គឺខ្ញុំតាំងអំពីកើតមកមានអាយុ ១២០ ឆ្នាំ ។ បទថា **បព្វជី** សេចក្តី

១-ក្នុងអបទានជាព្រះ តិណសូលកត្ថេរ ។

ថា ចូលដល់បព្វជ្ជាភេទ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។ ពាក្យជាគាថានេះឯង បានជាពាក្យព្យាករអរហត្តផលរបស់ព្រះថេរៈ ។

## អដ្ឋកថា ធម្មសវបិតុត្ថេរគាថា ចប់

## សង្ឃរក្ខិតត្ថេរគាថា

[ ១១០ ] ភិក្ខុនេះត្រេកអរក្នុងទីស្ងាត់ហើយ តែក្រែងមិនអើពើនឹងសាសនារបស់ព្រះមានព្រះភាគ ព្រះអង្គជាអ្នកអនុគ្រោះ ដោយប្រយោជន៍ដ៏ក្រៃលែងទេឬ ភិក្ខុនេះជាអ្នកមានឥន្ទ្រិយតាំងនៅជាប្រក្រតី នៅក្នុងទីស្ងាត់ដូច្នោះ ដូចជាម្រឹគញីប្រកបដោយជាតិនៅក្មេងដែលនៅក្នុងព្រៃ ។

**សង្ឃរក្ខិតត្ថេរ ។**

## អដ្ឋកថា

## សង្ឃរក្ខិតត្ថេរគាថា

[ ១១០ ] គាថារបស់ព្រះសង្ឃរក្ខិតត្ថេរ មានពាក្យផ្តើមថា **ន នូនាយំ បរមហិតានុកម្បិនោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំនូវបុណ្យជាច្រើនទុកក្នុងភពនោះៗ ក្នុងកប្បទី ៩៤ អំពីភទ្ទកប្បនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយឃើញព្រះបច្ចេកពុទ្ធ ៧ អង្គនៅត្រង់ជើងភ្នំ មានចិត្តសោមនស្ស បេះយកផ្កាកុម្ភទៅបូជា ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះទៅកើតក្នុងទេវលោក ធ្វើបុណ្យហើយអន្ទោលទៅមកក្នុងសុគតិភពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះកើតក្នុងត្រកូលរបស់

អ្នកមានសក្តកស្តុកក្នុងនគរសាវត្ថី មានឈ្មោះថាសង្ឃរក្ខិតៈ ។ កុលបុត្តនោះដល់នូវភាពជាអ្នកដឹងក្តីហើយ មានសទ្ធាបួសហើយ រៀនកម្មដ្ឋាន សេពគប់ភិក្ខុមួយរូបជាសម្លាញ់នៅក្នុងព្រៃ ។ ក្នុងទីមិនឆ្ងាយអំពីកន្លែងព្រះថេរៈ មានមេម្រឹគកើតកូនត្រង់គុម្ពឈើ មេម្រឹគនោះនៅថែរក្សាកូនតូច ទោះបីត្រូវសេចក្តីឃ្លានគ្របសង្កត់ ក៏មិនទៅរកស៊ីឆ្ងាយ ព្រោះជាប់ជំពាក់ក្នុងកូន ត្រូវលំបាកព្រោះមិនបានទៅរកស្មៅនិងទឹកក្នុងទីឆ្ងាយ ។ ព្រះថេរៈឃើញដូច្នោះ កើតសេចក្តីសង្វេគថា ឱហ្ន៎! សត្វលោកនេះកាលចំណង គឺតណ្ហារួបរឹត រមែងសោយទុក្ខធ្ងន់ មិនអាចកាត់គ្រឿងចង គឺតណ្ហានេះបាន ដូច្នេះហើយ ធ្វើហេតុការណ៍នោះឯងឲ្យជាកង្វេរ ចម្រើនវិបស្សនាសម្រេចអរហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

មានភ្នំខ្ពស់មួយ ឈ្មោះកទម្ពៈ នៅជិតព្រៃហិមពាន្ត មានព្រះបច្ចេកពុទ្ធ ៧ ព្រះអង្គនោះ ទ្រង់គង់នៅខាងភ្នំនោះ ។ ខ្ញុំឃើញផ្កាកុម្ពុ បានផ្គងអញ្ជលីកាន់ផ្កា ៧ ចង្កោម ហើយថ្វាយដោយចិត្តពេញលេញ ។ ខ្ញុំលះបង់រាងកាយរបស់មនុស្សហើយក៏បានទៅកើតឯឋានតាវត្តិង្ស ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានធ្វើអំពើជាកុសល ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំបានដុតបំផ្លាញហើយ ។បេ។ ទាំងសា-

សនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈ កាលសម្រេចអរហត្តហើយ ដឹងថាភិក្ខុជាសម្លាញ់របស់ខ្លួនច្រើនដោយមិច្ឆាវិតក្ក ទើបធ្វើម្រឹគញីនោះឯងឲ្យជាឧបមា ហើយពោលគាថាដូច្នេះថា

ភិក្ខុនេះត្រេកអរក្នុងទីស្ងាត់ហើយ តែក្រែងមិនអើពើនឹង
សាសនារបស់ព្រះមានព្រះភាគ ព្រះអង្គជាអ្នកអនុគ្រោះដោយ
ប្រយោជន៍ដ៏ក្រៃលែងទេឬ ភិក្ខុនេះជាអ្នកមានឥន្ទ្រិយតាំងនៅ
ជាប្រក្រតី នៅក្នុងទីស្ងាត់ដូច្នោះ ដូចជាម្រឹគញីប្រកបដោយ
ជាតិ នៅក្មេងដែលនៅក្នុងព្រៃ ដូច្នេះ ។

បណ្តាបទទាំងនោះ **ន** សព្ទ ក្នុងបទថា **ន ន្វាយំ** នេះ ជានិបាតចុះក្នុងអត្ថថា បដិសេធ ។ បទថា **ន្វ** ជានិបាត ចុះក្នុងអត្ថថា បរិវិតក្ក ។ កាត់បទជា **នុ អយំ** ។ បទថា **បរមហិតានុកម្បិនោ** សេចក្តីថា នៃព្រះមានព្រះភាគ ដែលមានប្រក្រតីអនុគ្រោះសត្វទាំងឡាយដ៏ក្រៃលែង គឺប្រៀបមិនបាន ឬដោយប្រយោជន៍ក្រៃលែង គឺដ៏កំពូល ។ បទថា **រហោគតោ** ស្មើគ្នានឹង **រហសិ គតោ** អធិប្បាយថា នៅក្នុងសុញ្ញាគារ គឺជា អ្នកប្រកបដោយកាយវិវេក ។

បទថា **អនុវិគណេតិ** នេះ ត្រូវនាំយកបទទាំង ២ ថា **ន នុ** មកភ្ជាប់ជាមួយថា **នានុវិគណេតិ នុ** សេចក្តីថា ប្រហែលជាមិនគិត គឺមិន

១-ក្នុងអបទានជាព្រះ សត្តកទម្ពបុប្ផិយត្ថេរ ។

ពិចារណាថា អាត្មាអញត្រូវខ្វះខ្វែង ។ បទថា **សាសនំ** សេចក្តីថា ពាក្យប្រៀនប្រដៅ គឺបដិបទា អធិប្បាយថា ការចម្រើនចតុសច្ចកម្មដ្ឋាន ។ បទថា **តថា ហិ** សេចក្តីថា ព្រោះហេតុនោះឯង បានដល់ ព្រោះមិនខ្វល់ខ្វាយក្នុងពាក្យប្រៀនប្រដៅរបស់ព្រះសាស្តានោះ ។ បទថា **អយំ** សំដៅដល់ **អយំ ភិក្ខុ** ប្រែថា ភិក្ខុនេះ ។

បទថា **ចាកតិន្ទ្រិយោ** សេចក្តីថា ឈ្មោះថា ជាអ្នកមានឥន្ទ្រិយដែលប្រព្រឹត្តទៅតាមសភាវៈ ព្រោះបណ្តែតបណ្តោយឥន្ទ្រិយទាំងឡាយ មានចិត្តជាគម្រប់ ៦ ទៅក្នុងអារម្មណ៍ទាំងឡាយ តាមចិត្តរបស់ខ្លួន អធិប្បាយថា ជាអ្នកមិនសង្រួមចក្ខុទ្វារជាដើម ភិក្ខុនោះឈ្មោះថាជាអ្នកនៅដោយមិនសង្រួមឥន្ទ្រិយ ព្រោះមិនកាត់កិលេសដែលជាគ្រឿងជាប់ជំពាក់ គឺតណ្ហាបាន ព្រះថេរៈ លុះសម្តែងឧបមានៃកិលេសជាគ្រឿងជាប់ជំពាក់ គឺតណ្ហានោះ ទើបពោលថា **មិគី យថា តរុណជាតិកា វនេ** ប្រែថា ដូចមេម្រឹគកូនខ្ចីក្នុងព្រៃដូច្នោះ អធិប្បាយថា មេម្រឹគមានកូននៅតូច រមែងសោយទុក្ខក្នុងព្រៃ ព្រោះកាត់សេចក្តីស្នេហាក្នុងកូនមិនបាន បានដល់ មិនកន្លងផុតសេចក្តីទុក្ខនេះឡើយយ៉ាងណា ភិក្ខុនេះក៏ដូច្នោះ កាលនៅដោយមិនសង្រួមឥន្ទ្រិយ ព្រោះកាត់នូវកិលេសជាគ្រឿងជាប់ជំពាក់មិនបាន ឈ្មោះថា មិនកន្លងផុតទុក្ខក្នុងវដ្តៈ ដូច្នេះ បាឋៈថា **តរុណវិជាតិកា** ក៏មាន ដោយសេចក្តីថា មានកូនខ្ចីដែលត្រូវប្រសូតថ្មម ។ ភិក្ខុនោះស្តាប់ដូច្នោះហើយ កើតសេចក្តីសង្វេគ ចម្រើនវិបស្សនាសម្រេចអរហត្តក្នុងកាលមិនយូរឡើយ ។

**អដ្ឋកថា សង្ឃរក្ខិតត្ថេរគាថា ចប់**

## ឧសភត្ថេរគាថា

[ ១១១ ] ឈើទាំងឡាយលូតលាស់ឡើងព្ធដ៏កំពូលភ្នំ ត្រូវទឹកភ្លៀងបង្អុរចុះថ្មីៗ ស្រោចស្រពហើយរមែងញុំាងចិត្តគួរដល់ការនាកម្មឲ្យកើតឡើង ដោយក្រៃលែងដល់ភិក្ខុឈ្មោះឧសភៈ អ្នកប្រាថ្នាវិវេកធម៌ អ្នកមានសេចក្ដីសម្គាល់ក្នុងព្រៃ ។

### ឧសភត្ថេរ ។

### ឧទ្ទាន

និយាយអំពីពេលដ្ឋកានិត្ថេរ ១ សេតុច្ឆត្ថេរ ១ ពន្ធុរត្ថេរ ១
ខិតកត្ថេរជាឥសី ១ មលិតវម្ភត្ថេរ ១ សុហេមន្តត្ថេរ ១
ធម្មសំវរត្ថេរ ១ ធម្មសជបិតុត្ថេរ ១ សង្ឃរក្ខិតត្ថេរ ១
ឧសភត្ថេរជាមហាមុនី ១ ។

### ចប់ ឯកាទសមវគ្គ ។

# អដ្ឋកថា

## ឧសភត្ថេរគាថា

[ ១១១ ] គាថារបស់ព្រះឧសភត្ថេរ មានពាក្យផ្ដើមថា **នគា នគគ្គេសុ សុសំវិរូឡ្ហា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ធ្វើបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាសិខីក្នុងកប្បទី ៣១ រាប់អំពីភទ្ទកប្បនេះ កុលបុត្តនោះកើតជាទេវបុត្ត ។ ថ្ងៃមួយឃើញព្រះសាស្ដា មានចិត្តជ្រះថ្លា បានធ្វើការបូជាដោយផ្កាទិព្វ ផ្កាដែលបូជានោះ បានតាំងនៅដោយអាការដូចមណ្ឌបផ្កាអស់ ៧ ថ្ងៃ ទេវតានិងមនុស្សទាំងឡាយ មានការប្រជុំគ្នាជាមហាសមាគម ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលអ្នកមានស្តុកស្តម្ភក្នុងដែនកោសលមានឈ្មោះថាឧសភៈ ។ កុលបុត្តនោះដឹងក្ដីហើយ ជាអ្នកមានសទ្ធាក្នុងព្រះសាសនា ក្នុងកាលដែលព្រះសាស្ដាទទួលវិហារឈ្មោះជេតពន បួសហើយធ្វើបុព្វកិច្ចស្រេចហើយនៅត្រង់ជើងភ្នំក្នុងព្រៃ ។ សម័យនោះ កាលមេឃក្នុងរដូវភ្លៀងញុំាងភ្លៀងឲ្យធ្លាក់ចុះ ស្លឹកឈើក៏លូតលាស់យ៉ាងក្រាស់ ព្រោះលើកំពូលភ្នំមានគុម្ពឈើនិងវល្លិ ។ ថ្ងៃមួយព្រះថេរៈចេញអំពីគុហា សម្លឹងមើលព្រៃគួរជាទីត្រេកអរ និងភ្នំគួរជាទីរីករាយនោះឯង គិតដោយយោនិសោមនសិការថា ធម្មជាតិមានដើមឈើឈ្មោះនេះ មិនមានចេតនា ដល់នូវសេចក្ដី

ចម្រើន ព្រោះការសម្បូរដោយឧតុ កាលបើដូច្នោះហេតុអ្វី អញបានឧតុជាទីសប្បាយហើយមិនចម្រើនដោយគុណធម៌ទាំងឡាយ ដូច្នេះហើយ បានពោលគាថាថា

ឈើទាំងឡាយ លូតលាស់ឡើងព្រដ៏កំពូលភ្នំ ត្រូវទឹកភ្លៀងបង្អុរចុះថ្មីៗ ស្រោចស្រពហើយ រមែងញុំាងចិត្តគួរដល់ការនាកម្មឲ្យកើតឡើងដោយក្រៃលែងដល់ភិក្ខុឈ្មោះឧសភៈ អ្នកប្រាថ្នាវិវេកធម៌ អ្នកមានសេចក្តីសម្គាល់ក្នុងព្រៃ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នគា** ប្រែថា ដើមឈើ ។ អាចារ្យពួកខ្លះហៅថា **នាគា** សំដៅដល់ដើមខ្ទឹង ។ បទថា **នគគ្គេសុ** ប្រែថា លើកំពូលភ្នំ ។ បទថា **សុសំវិរូឡ្ហា** សេចក្តីថា ជាដើមឈើមានឫសល្អ គឺផ្សាយទៅដោយជុំវិញ គឺបែកមែកសាខា ទាំងខ្ចី ទាំងចាស់ សម្លឹងមើលទៅល្អដោយជុំវិញ ទាំងខាងក្រោម និងខាងលើ ។

បទថា **ឧទគ្គមេឃេន នវេន សិត្តា** សេចក្តីថា ដែលមេឃធ្វើឲ្យភ្លៀងធ្លាក់ កើតឡើងជាមេធំ ស្រោចស្រព ។

បទថា **វិវេកកាមស្ស** បានដល់ ប្រាថ្នាចិត្តវិវេក ដែលស្ងាត់ហើយចាកកិលេស គឺប្រាថ្នាចិត្តវិវេកនោះថា កាយវិវេកដែលបុគ្គលនៅក្នុងព្រៃបានហើយ ឥឡូវនេះ អញគប្បីបានចិត្តវិវេកដែលជានិស្សយប្បច្ច័យនៃការបានសម្រេចឧបធិវិវេក អធិប្បាយថា បានដល់ សេចក្តីព្យាយាមរឿយៗនូវធម៌ជាគ្រឿងភ្ញាក់រឭក ដោយហេតុនោះ ទើបព្រះថេរៈពោលថា **អរញ្ញសញ្ញិនោ**

ដូច្នេះ អធិប្បាយថា ជាអ្នកមានសេចក្តីសម្គាល់ក្នុងការនៅព្រៃ គឺច្រើនទៅដោយនេក្ខម្មសង្កប្បយ៉ាងនេះថា ឈ្មោះថា ការនៅព្រៃដែលព្រះសាស្តាទ្រង់សរសើរហើយឯការនៅព្រៃនោះ ក៏ត្រឹមតែធ្វើសមថភាវនានិងវិបស្សនាភាវនាឲ្យបរិបូណ៌ ព្រោះដូច្នោះ សមថភាវនានិងវិបស្សនាភាវនានោះ អញគួរធ្វើឲ្យនៅក្នុងកណ្តាប់ដៃ ដូច្នេះ ។

បទថា **ជនេតិ** ស្មើគ្នានឹង **ឧប្បាទេន្តិ** ប្រែថា រមែងឲ្យកើតឡើង ឯបទថា **ជនេតិ** នេះ ជាឯកវចនៈ ប្រើក្នុងអត្ថនៃពហុវចនៈ ។ ឯអាចារ្យពួកខ្លះសូធ្យថា **ជនេន្តិ** ។ បទថា **ភិយ្យោ** បានដល់ ក្រៃលែងឡើងៗ ។

ព្រះថេរៈហៅខ្លួនឯងនោះឯងដោយបទថា **ឧសភស្ស** ដូចហៅអ្នកដទៃ ។

បទថា **កល្យតំ** សេចក្តីថា ភាពដែលចិត្តសមគួរ គឺភាពដែលចិត្តគួរដល់ការងារ បានដល់ ភាពដែលចិត្តគួរដល់ភាវនា ។ សេចក្តីនេះ ខ្ញុំពោលខាងដើមហើយនោះឯង ។ ព្រះថេរៈពោលគាថានេះយ៉ាងនេះ ខ្វល់ខ្វាយនូវវិបស្សនាហើយសម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំជាទេវបុត្ត បានបូជាចំពោះព្រះពុទ្ធ ជានាយកព្រះនាមសិខី
ខ្ញុំបានបូជាចំពោះព្រះពុទ្ធដោយផ្កាមន្ទារវៈ ។ ផ្កាកម្រងទិព្វជា
គ្រឿងប្រក់លើព្រះតថាគតអស់ ៧ ថ្ងៃ ពួកជនទាំងអស់មក
ចួបជុំគ្នាហើយនមស្ការព្រះតថាគត ។ ក្នុងកប្បទី ៣១ អំពី
កប្បនេះ ព្រោះហេតុដែលខ្ញុំ បានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់

ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិព្រះនាម ជុតិន្ធរៈ ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[1] ។

គាថានេះឯង បានជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈ ។

## អដ្ឋកថា ឧសភត្ថេរគាថា ចប់

## វគ្គទី ១១ ចប់

---

១-ក្នុងអបទានជាព្រះ មន្ទារវបុប្ផបូជកត្ថេរ ។

# ថេរគាថា ឯកនិបាត

## ទ្វាទសមវគ្គ

### ជេន្តត្ថេរគាថា

[ ១១២ ] ការបួសជាការក្រពិត គ្រឹះស្ថានបុគ្គលគ្រប់គ្រងបានដោយក្រ ព្រះធម៌ជាសភាពជ្រាលជ្រៅ ភោគៈទាំងឡាយរកបានដោយក្រ ការប្រព្រឹត្ត ( ចិញ្ចឹមជីវិត ) របស់យើងដោយបច្ច័យតាមមានតាមបាន ក៏ជាការក្រ យើងគួរគិតនូវអនិច្ចតាធម៌ឲ្យរឿយៗវិញ ។

ជេន្តត្ថេរ ។

## វគ្គទី ១២

### អដ្ឋកថា

### ជេន្តត្ថេរគាថា

[ ១១២ ] គាថារបស់ព្រះជេន្តត្ថេរ មានពាក្យផ្តើមថា **ទុប្បព្វជ្ជំ វេ ទុរ-ធិវាសា គេហា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានហើយធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ជាអ្នកសន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមថាសិខី កើតជា

ទេវបុត្ត ។ ថ្ងៃមួយឃើញព្រះសាស្តា មានចិត្តជ្រះថ្លា បានធ្វើការបូជាដោយផ្កាល្ពៅទិព្វ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំង-ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាឱរសរបស់ស្តេចគ្រប់គ្រងមណ្ឌលមួយអន្តក្នុងជេន្តគាមដែនមគធៈមានឈ្មោះថាជេន្តៈ ។ កុលបុត្តនេះដល់នូវភាពជាអ្នកដឹងក្តីហើយ កាលហេតុសម្បត្តិជាស់តឿន តាំងពីនៅក្មេង ជាអ្នកមានចិត្តបង្អោនទៅក្នុងបព្វជ្ជា ទ្រង់ព្រះតម្រិះច្រើនដងថា ឈ្មោះថាបព្វជ្ជា ជារបស់ធ្វើបានលំបាក ការនៅគ្រប់គ្រងផ្ទះក៏លំបាក ធម៌ក៏ជារបស់ជ្រាលជ្រៅ ភោគសម្បត្តិ ក៏រកបានដោយលំបាក អញគិតដូចម្តេចហ្ន៎ រាជកុមារជាអ្នកច្រើនទៅដោយការគិតច្រើនយ៉ាងនេះ ថ្ងៃមួយ ចូលទៅកាន់សម្នាក់របស់ព្រះសាស្តាស្តាប់ធម៌ហើយ ក្រោយអំពីបានស្តាប់ធម៌មានចិត្តត្រេកអរក្រៃលែងក្នុងបព្វជ្ជាបួសក្នុងសម្នាក់ព្រះសាស្តារៀនកម្មដ្ឋានហើយ ចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់អរហត្តផលដោយសុខាបដិបទាខិប្បាភិញ្ញា គឺបដិបត្តិងាយ ត្រាស់ដឹងងាយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំជាទេវបុត្ត បានបូជាចំពោះព្រះពុទ្ធ ជានាយកព្រះនាមសិខី
ខ្ញុំកាន់យកផ្កាល្ពៅ បង្អោនថ្វាយព្រះពុទ្ធ ។ ក្នុងកប្បទី ៣១ អំ
ពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់
ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៩ អំពីកប្បនេះ ខ្ញុំ
បានជាស្តេចចក្រពត្តិ៧ជាតិ ទ្រង់មានកម្លាំងច្រើន ទ្រង់ឧត្តម

បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង

អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា

របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ(១) ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួន ក៏កើតនូវសោមនស្សថា អញមិនអាចកាត់វិតក្កដែលកើតឡើងដល់អញជាដំបូងបានហ្ន៎ ដូច្នេះហើយ កាលនឹងសម្តែងអាការដែលវិតក្កកើតឡើង និងភាពដែលកាត់វិតក្កនោះបានដោយប្រពៃហើយ ទើបពោលគាថានេះថា

ការបួសជាការក្រពិត គ្រឹះស្ថានបុគ្គលគ្រប់គ្រងបានដោយក្រ

ព្រះធម៌ជាសភាពជ្រាលជ្រៅ ភោគៈទាំងឡាយរកបានដោយ

ក្រ ការប្រព្រឹត្ត ( ចិញ្ចឹមជីវិត ) របស់យើងដោយបច្ច័យតាម

មានតាមបានក៏ជាការក្រ យើងគួរគិតនូវអនិច្ចតាធម៌ឲ្យរឿយៗ

វិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទុប្បព្វជ្ជំ** សេចក្តីថា ការវៀរអំពើអាក្រក់ ឈ្មោះថា ធ្វើបានដោយក្រ ព្រោះការលះគំនរភោគសម្បត្តិ តិចក្តី ច្រើនក្តី និងការចោមរោម របស់ពួកញាតិ ហើយបួសឧទ្ទិសជីវិត ក្នុងសាសនានេះ ឈ្មោះថាក្រ ព្រោះធ្វើបានដោយក្រ គឺបព្វជ្ជាធ្វើបានដោយក្រ ព្រោះដូច្នោះ ទើបឈ្មោះថា **ទុប្បព្វជ្ជំ** ។

បទថា **វេ** ត្រឹមតែជានិបាត ។ម្យ៉ាងទៀត **វេ** សព្ទ មាន **ឧឡុ** សព្ទ

---

១-ក្នុងអបទានជាព្រះ កក្ការុបូជកត្ថេរ ។

ជាអត្ថថា ការបួសជាការក្រ ដូច្នេះ ទីដែលស្នាក់អាស្រ័យ ឈ្មោះថា គ្រឹះស្ថាន ។ គ្រឹះស្ថាន ឈ្មោះថាគ្រប់គ្រងបានដោយក្រ គឺផ្ទះឈ្មោះថា រស់នៅដោយក្រ បានដល់ គ្រប់គ្រងបានដោយលំបាក អធិប្បាយថា ព្រោះរាជកិច្ចដែលព្រះរាជាទ្រង់បដិបត្តិក្តី ឥស្សរកិច្ចដែលឥស្សរជនត្រូវធ្វើក្តី គហបតិកិច្ចដែលគហបតីត្រូវចាត់ចែងក្តី ទាំងបរិវារជននិងសមណព្រាហ្មណ៍ ក៏អ្នកគ្រប់គ្រងផ្ទះត្រូវសង្គ្រោះ កាលរវល់ធ្វើកិច្ចដែលត្រូវបំពេញនោះៗ ទើបការនៅគ្រប់គ្រងផ្ទះ ធ្វើឲ្យបរិបូណ៌បានដោយក្រ ដូចក្អមទឹកដែលធ្លុះ និងមហាសមុទ្រ ព្រោះដូច្នោះ ទើបផ្ទះឈ្មោះថានៅបានដោយក្រ គ្រប់គ្រងបានដោយក្រ គឺធ្វើបានដោយក្រ ។

បព្វជ្ជាគប្បីកាន់យក ( ព្រោះ ) ធម៌ជារបស់ជ្រាលជ្រៅ បដិវេធធម៌ដែលសម្រេចបានដោយបព្វជ្ជា ដើម្បីឲ្យបានមកនោះជារបស់ជ្រាលជ្រៅ ។ ឈ្មោះថា ឃើញបានដោយក្រ ព្រោះជាអារម្មណ៍នៃញាណ ដ៏ជ្រាលជ្រៅ ឈ្មោះថា ចាក់ធ្លុះបានដោយក្រ ព្រោះចាក់ធ្លុះបានដោយលំបាក ដោយការៈជាធម៌ជ្រាលជ្រៅ ។ ការនៅគ្រប់គ្រងផ្ទះធ្វើបានដោយក្រ ព្រោះភោគៈដែលបុគ្គលនៅគ្រប់គ្រងផ្ទះធ្វើឲ្យអស់ហើយ មិនអាចនៅគ្រប់គ្រងផ្ទះនោះបាន រកបានដោយក្រ ព្រោះបានមកដោយកម្រ ដោយលំបាក ។

កាលបើដូច្នោះ គួរលះឃរាវាសហើយកាន់យកបព្វជ្ជាប៉ុណ្ណោះ ។ កាលបើដូច្នោះ ការប្រព្រឹត្ត ( ចិញ្ចឹមជីវិត ) របស់យើងដោយបច្ច័យ តាមមានតាមបានក៏ជាការក្រ គឺការគ្រប់គ្រងជីវិត បានដល់ការរស់នៅរបស់ពួកយើង

ទាំងឡាយក្នុងទីនេះ គឺក្នុងសាសនានេះដោយបច្ច័យតាមមានតាមបាន គឺតាមដែលបានមកជារបស់ក្រ គឺលំបាក ដ្បិតការចិញ្ចឹមជីវិតរបស់ពួកយើងទាំង-ឡាយដោយបច្ច័យតាមមានតាមបានក្នុងផ្ទះ ឈ្មោះថាក្រ គឺលំបាក ព្រោះការនៅគ្រប់គ្រងផ្ទះធ្វើបានដោយក្រ ឯភោគៈក៏រកបានដោយក្រ ។ សួរថា ក្នុងសេចក្តីនេះ គួរធ្វើដូចម្តេច ឆ្លើយថា យើងគួរគិតនូវអនិច្ចតាធម៌ ឲ្យរឿយៗវិញ គឺធម្មជាតិដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថាជារបស់មិនទៀងអស់ថ្ងៃទាំងមូល គឺទាំងក្នុងពេលយប់និងក្នុងពេលថ្ងៃ ។ បន្ទាប់អំពីនោះ ក៏គួរគិតថា ឈ្មោះថាមិនទៀង ព្រោះកើតឡើងនិងវិនាសទៅ ព្រោះមានខាងដើមនិងទីបំផុត ព្រោះប្រព្រឹត្តទៅមួយជួរខណៈ ព្រោះហេតុនោះ ទើបគួរគិត និងការពិចារណាថា មិនទៀង ។ កាលពិចារណាដោយភាពជារបស់មិនទៀងហើយ ការពិចារណាដោយលក្ខណៈក្រៅអំពីនេះ រមែងសម្រេចដោយងាយនោះឯង ព្រោះហេតុនោះ ក្នុងគាថានេះ ទើបលោកពោលតែអនិច្ចានុបស្សនាតែម្យ៉ាង ព្រោះអនិច្ចលក្ខណៈស៊ីសេចក្តីដល់ទុក្ខលក្ខណៈ និងអនត្តលក្ខណៈនិងព្រោះសាសនិកជនកំណត់កាន់យកបានងាយ សមដូចព្រះតម្រាស់ត្រាស់ថា របស់ណាមិនទៀងរបស់នោះជាទុក្ខ របស់ណាជាទុក្ខរបស់នោះជាអនត្តាឬថា ធម៌ណាមានការកើតឡើងជាធម្មតា ធម៌ទាំងឡាយនោះ មានការរលត់ទៅជាធម្មតា ឬថា សង្ខារទាំងឡាយមានការអស់ទៅសូន្យទៅជាធម្មតា ។ ព្រះថេរៈកាលសង្កត់សង្កិនកិលេសដែលកើតឡើងទៅមកៗ ដោយអំណាចនៃធម៌ដែលជាបដិបក្ខដល់គ្នានឹងគ្នាបានយ៉ាងនេះហើយ ផ្តើមប្រារព្ធវិបស្សនាដោយ

មានអនិច្ចតាជាសំខាន់ ហើយសម្តែងឲ្យដឹងថា ឥឡូវនេះ ជាអ្នកសម្រេចកិច្ចហើយ ដោយបទថា **សតតមចិច្ចតំ** នេះ ។ សមដូចខ្ញុំពោលទុកថា ពិចារណានូវបដិបទារបស់ខ្លួន ដូច្នេះជាដើម ។ ពាក្យជាគាថានេះឯង បានជាការព្យាករអរហត្តផលរបស់ព្រះថេរៈ ។

## អដ្ឋកថា ជេន្តត្ថេរគាថា ចប់

## វច្ឆគោតត្ថេរគាថា

[ ១១៣ ] ខ្ញុំមានវិជ្ជា ៣ មានការដុតកិលេសច្រើន ជាអ្នកឈ្លាសវៃក្នុងចេតោសមថៈ ( ការស្ងប់រម្ងាប់ចិត្ត ) ប្រយោជន៍របស់ខ្លួន ខ្ញុំបានដល់ហើយ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។

វច្ឆគោតត្ថេរ ។

## អដ្ឋកថា

## វច្ឆគោតត្ថេរគាថា

[ ១១៣ ] គាថារបស់ព្រះវច្ឆគោតត្ថេរ មានពាក្យផ្តើមថា **តេវិជ្ជោហំ មហាឈាយី** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ បណ្តុះនូវពូជ គឺកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថា វិបស្សី កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូលក្នុងព្រះនគរពន្ធុមតី កុលបុត្តនោះ ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយធ្វើពុទ្ធបូជារួមជាមួយព្រះរាជា និងអ្នកនគរទាំង-ឡាយបន្ទាប់អំពីនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយក្នុងពុទ្ធុប្បាទនេះ កើតជាកូនរបស់ព្រាហ្មណ៍ដែលសម្បូរដោយសម្បត្តិក្នុងនគររាជគ្រឹះ មានឈ្មោះថាវច្ឆគោត្ត ព្រោះកុលបុត្តនោះជាខ្សែស្រឡាយវច្ឆគោត្ត ។

កុលបុត្តនោះដឹងក្តីហើយ ជួបនូវការសម្រេចក្នុងវិជ្ជារបស់ពួកព្រាហ្មណ៍ មិនឃើញសារៈក្នុងវិជ្ជាទាំងនោះទើបបួសជាបរិព្វាជក ចូលគាល់ព្រះសាស្តា ហើយទូលសួរបញ្ហា កាលព្រះសាស្តាទ្រង់វិសជ្ជនាបញ្ហានោះហើយ ក៏ជាអ្នកមានចិត្តជ្រះថ្លា បួសក្នុងសម្នាក់នៃព្រះសាស្តា ចម្រើនវិបស្សនា សម្រេចអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំបានឃើញព្រះពុទ្ធជានាយកនៃលោក កំពុងស្តេចទៅ ដូចព្រះអាទិត្យមានរស្មីដ៏ច្រើន កាលរះឡើងមានរស្មីពណ៌លឿង ឬដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត ។ ពួកព្រះខីណាស្រពទាំងពួងមានប្រមាណ ៦៨០០០ ហោមរោមព្រះពុទ្ធ ព្រះអង្គជាធំជាងសត្វជើងពីរ ជានរាសភៈ ។ កាលព្រះលោកនាយកកំពុងយាងទៅ ខ្ញុំមានចិត្តជ្រះថ្លា បានបោសថ្នល់នោះ ហើយលើកនូវទង់ជ័យក្នុងទីនោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទង់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយទង់ ។ ក្នុងកប្បទី ៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចព្រះនាមសុធជៈ ទ្រង់មានកម្លាំងច្រើនទ្រង់បរិបូណ៌ដោយអាការទាំងពួង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

---

១-ក្នុងអបទានជាព្រះ វីថិសម្មជ្ជកត្ថេរ ។

ព្រះថេរៈជាអ្នកមានអភិញ្ញា ៦ ពិចារណាបដិបទារបស់ខ្លួនហើយ កើតនូវសោមនស្ស បានពោលគាថាដោយអំណាចនៃឧទានថា

ខ្ញុំមានវិជ្ជា ៣ មានការជុតកិលេសច្រើន ជាអ្នកឈ្លាសវៃក្នុង
ចេតោសមថៈ ( ការស្ងប់រម្ងាប់ចិត្ត ) ប្រយោជន៍របស់ខ្លួន
ខ្ញុំបានដល់ហើយ ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តេវិជ្ជោហំ** សេចក្តីថា បើមនុស្សទាំងឡាយស្គាល់ខ្ញុំថា ជាព្រាហ្មណ៍បានវិជ្ជា ៣ ព្រោះដល់ត្រើយនៃវេទក្នុងកាលមុន តែវិជ្ជាទាំង ៣ នោះ គ្រាន់តែជាឈ្មោះ ព្រោះក្នុងវេទមិនមានកិច្ចដែលទាក់ទងដោយវិជ្ជា ។

តែឥឡូវនេះ ខ្ញុំឈ្មោះថា ជាអ្នកមានវិជ្ជា ៣ ដោយបរមត្ថ ព្រោះបានសម្រេចវិជ្ជា ៣ មានបុព្វេនិវាសញ្ញាណជាដើម ឈ្មោះថា ជាអ្នកមានប្រក្រតីសម្ងំនូវធម៌ដ៏ប្រណីត ព្រោះសម្ងំពួកកិលេសដែលប្រព្រឹត្តទៅក្នុងចំណែកនៃសមុទយៈជាច្រើន គឺមិនមានចំណែកសេសសល់ និងព្រោះសម្ងំ ព្រះនិព្វានដែលជំកន្លង គឺឧឡារ បានដល់ ប្រណីត ។

បទថា **ចេតោសមថកោវិទោ** សេចក្តីថា ជាអ្នកឈ្លាសក្នុងឧបាយជាគ្រឿងធ្វើចិត្តឲ្យស្ងប់ ដោយការចូលទៅស្ងប់សង្កិលេសធម៌ ដែលធ្វើចិត្តឲ្យកម្រើក ។ ព្រះថេរៈពោលដល់ហេតុនៃភាពជាអ្នកមានវិជ្ជា ៣ ដោយបទថា **ចេតោសមថកោវិទោ** នេះ អធិប្បាយថា ភាពជាអ្នកមានវិជ្ជា ៣ នឹងមានដោយការអស់ទៅនៃអាសវៈ ដែលប្រកបដោយភាពជាអ្នកឈ្លាស ក្នុង

សមាធិ មិនមែនដទៃឡើយ ។

បទថា **សទត្ថោ** បានដល់ ប្រយោជន៍របស់ខ្លួន ។ បទនេះលោកធ្វើ ក អក្ខរៈ ឲ្យជា ទ អក្ខរៈ ដូចក្នុងប្រយោគជាដើមថា **អនុប្បត្តសទត្ថោ** ប្រែថា មានប្រយោជន៍ដែលខ្លួនសម្រេចហើយដោយលំដាប់ ។ អរហត្តគប្បី ជ្រាបថា ជាប្រយោជន៍របស់ខ្លួន អធិប្បាយថា អរហត្តនោះ លោកហៅថា ជាប្រយោជន៍របស់ខ្លួន ព្រោះភាពដែលអរហត្តនោះ ជាប្រយោជន៍របស់ខ្លួន ដោយអត្ថថា ទាក់ទងនឹងខ្លួន ដោយអត្ថថា មិនលះបង់នូវខ្លួន ដោយអត្ថថា ជាប្រយោជន៍ដ៏ក្រៃលែងដល់ខ្លួន ។ ប្រយោជន៍របស់ខ្លួននេះ ដែលខ្ញុំ គឺខ្លួន ខ្ញុំបានសម្រេចហើយគឺដល់ហើយ ។ ដោយពាក្យថា **សទត្ថោ** នេះ ព្រះ ថេរៈសម្តែងថា បានធ្វើភាពជាអ្នកសម្បីងធម៌ដែលប្រណីត តាមដែលពោល ហើយឲ្យដល់នូវកំពូលគឺអរហត្តហើយ បទដ៏សេសមានន័យដូចពោលហើយ នោះឯង ។

## អដ្ឋកថា វច្ឆគោត្តត្ថេរគាថា ចប់

## វនវច្ឆត្ថេរគាថា

[ ១១៤ ] ភ្នំថ្មទាំងនោះមានទឹកថ្លា មានថ្មដ៏ក្រាស់ ដែលប្រកបដោយម្រឹគមានកន្ទុយដូចគោ ( ស្វាខ្មៅ ) ដ៏ដេរដាសដោយសារាយក្នុងទឹក តែងញុំាងខ្ញុំឲ្យត្រេកអរ ( សុខចិត្តនៅបាន ) ។

**វនវច្ឆត្ថេរ ។**

## អដ្ឋកថា

## វនវច្ឆត្ថេរគាថា

[ ១១៤ ] គាថារបស់ព្រះវនវច្ឆត្ថេរ មានពាក្យផ្តើមថា **អច្ឆោទិកា បុថុសិលា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ បណ្តុះនូវពូជ គឺកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាវិបស្សី កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ធ្វើការស៊ីឈ្នួលចិញ្ចឹមជីវិត ធ្វើនូវកំហុសចំពោះបុគ្គលណាមួយ ត្រូវការខ្លាចស្លាប់គំរាមហើយគេចទៅ ឃើញពោធិព្រឹក្សក្នុងរវាងផ្លូវ ជាអ្នកមានចិត្តជ្រះថ្លា បោសសម្អាតគល់ពោធិព្រឹក្សនោះ ធ្វើនូវការបូជាដោយសំណុំផ្កាអសោក ថ្វាយបង្គំហើយបែរមុខទៅកាន់ពោធិព្រឹក្ស នមស្ការ អង្គុយពត់ភ្នែន ។ ឃើញសត្រូវដើរមកដើម្បីសម្លាប់ខ្លួន មិនធ្វើចិត្តឲ្យក្រោធក្នុងសត្រូវទាំងនោះ រឭកដល់ពោធិព្រឹក្ស

តែម្យ៉ាង ក៏ធ្លាក់ទៅក្នុងជ្រោះជម្រៅ ១០០ ជួរបុរស ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ កើតក្នុងទេវលោក ធ្វើបុណ្យរឿយៗ មក ហើយអន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តរបស់ព្រាហ្មណ៍សម្បូរដោយសម្បត្តិក្នុងនគររាជគ្រឹះ មានឈ្មោះថា វច្ឆៈ ។ កុលបុត្តនោះចម្រើនវ័យហើយ ជាអ្នកមានសទ្ធា ក្នុងសមាគមរបស់ ព្រះបាទពិម្ពិសារ បួសហើយសម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោក ពោលទុកក្នុងអបទានថា

ខ្ញុំប្រកបក្នុងការងាររបស់ជនដទៃ បានធ្វើនូវកំហុស ជាអ្នក ពេញប្រៀបដោយភ័យ និងពៀរ ហើយក៏ស្ទុះរត់ទៅពួនក្នុងទី ព្រៃ ។ ខ្ញុំឃើញដើមឈើ ដែលមានផ្ការីកស្កុសស្គាយចងជា ចង្កោមដែលធម្មតានិម្មិតល្អហើយ កាន់យកនូវផ្កាក្រហមរោយ រាយចុះទៀបពោធិព្រឹក្ស ។ ខ្ញុំបោសដើមប្រទៀងជាឈើដ៏ឧត្តម ជាពោធិព្រឹក្សនោះ ហើយចូលទៅជិតគល់ពោធិព្រឹក្ស អង្គុយ ផ្គត់ភ្នែន ។ កាលពួកជនស្វែងរកផ្លូវដែលខ្ញុំទៅ ក៏មកកាន់ សំណាក់ខ្ញុំ លុះខ្ញុំឃើញនូវពួកជនទាំងនោះ ក៏នឹកដល់ពោធិ ព្រឹក្សដ៏ឧត្តមក្នុងទីនោះ ។ ខ្ញុំមានចិត្តជ្រះថ្លា ថ្វាយបង្គំដើមពោធិ ព្រឹក្សរួចហើយ ក៏ធ្លាក់ទៅក្នុងជ្រោះភ្នំដែលគួរខ្លាច មានជម្រៅ ច្រើនជួរដើមត្នោត ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុ ដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការ

បូជាពោធិព្រឹក្ស ។ ក្នុងកប្បទី ៣ អំពីកប្បនេះ ខ្ញុំបានកើត
ជាស្តេចចក្រពត្តិព្រះនាមសម្មុសិតៈ ទ្រង់មានកម្លាំងច្រើន បរិ
បូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង
អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា
របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ នៅក្នុងព្រៃនោះឯង ព្រោះត្រេកអរក្នុងវិវេក ទើបកើតសមញ្ញានាមថា វនវច្ឆៈ ។ ក្នុងគ្រាខ្លះ ព្រះថេរៈទៅកាន់នគររាជគ្រឹះម្តងម្កាល ដើម្បីអនុគ្រោះពួកញាតិ កាលញាតិទាំងឡាយ ទំនុកបម្រុងក្នុងនគររាជគ្រឹះនោះ ស្នាក់នៅមិនបានប៉ុន្មានថ្ងៃ ក៏សម្តែងអាការត្រឡប់ទៅកាន់ព្រៃ ពួកញាតិអង្វរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ស្នាក់នៅក្នុងវិហារជិតៗនេះ ដើម្បីអនុគ្រោះពួកខ្ញុំចុះ ពួកខ្ញុំនឹងទំនុកបម្រុងលោកម្ចាស់ ដូច្នេះ ព្រះថេរៈកាលប្រកាសសេចក្តីត្រេកអរក្នុងវិវេក ដោយការចង្អុលឲ្យឃើញគុណនៃភាពជាអ្នកមានភ្នំជាទីត្រេកអរដល់មនុស្សទាំងនោះ ទើបពោលគាថាថា

ភ្នំថ្មទាំងនោះ មានទឹកថ្លា មានថ្មដ៏ក្រាស់ ដែលប្រកបដោយ
ម្រឹគមានកន្ទុយដូចគោ ( ស្វាខ្មៅ ) ដ៏ដេរដាសដោយសា-
រាយក្នុងទឹក តែងញុំាងខ្ញុំឲ្យត្រេកអរ ( សុខចិត្តនៅបាន ) ។

បណ្តាបទទាំងនោះ បទថា **អច្ឆោទិកា** សេចក្តីថា កាលគួរពោលថា

---

១-ក្នុងអបទានជាព្រះ គម្ពបុប្ផិយត្ថេរ ។

**អច្ឆោទកា** ព្រោះជាទីមានទឹកថ្លាមិនល្អក់ និងស្អាត លោកប្រែជាពោលថា **អច្ឆោទិកា** ព្រោះជាលិង្គវិបល្លាស ។ ព្រះថេរៈសម្តែងដល់ភាពសម្បូរនៃទឹកលើភ្នំទាំងនោះ ដោយបទថា **អច្ឆោទិកា** នេះ ។

បទថា **បុថុសិលា** សេចក្តីថា ភ្នំ ឈ្មោះថា **បុថុសិលា** ព្រោះជាភ្នំធំមានសម្លស្សស្របប្បាយ ព្រះថេរៈសម្តែងដល់ភាពសម្បូរដោយទីអង្គុយ ដោយបទថា **បុថុសិលា** នេះ ។ ឈ្មោះថា **គោនង្គុលា** ព្រោះជាសត្វមានកន្ទុយដូចកន្ទុយគោ បានដល់ ស្វាដែលមានពណ៌ខ្មៅ អាចារ្យពួកខ្លះពោលថា បានដល់ ស្វាធម្មតាក៏មាន ។ ឈ្មោះថា **គោនង្គុលមិគាយុតា** ព្រោះដេរដាសទៅដោយស្វានិងប្រើសជាដើមដែលរត់ប្រសេចប្រសាចក្នុងទីនោះៗ ព្រះថេរៈសម្តែងដល់ភាពដែលធម្មជាតិទាំងនោះ ចូលដល់លក្ខណៈរបស់ភាពជាព្រៃ ព្រោះភ្នំទាំងនោះជាឧបចារៈរបស់ពួកអមនុស្ស ដោយបទថា **គោនង្គុលមិ - គាយុតា** នេះ ។

បទថា **អម្ពុសេវាលសញ្ឆន្នា** សេចក្តីថា ឈ្មោះថា ដេរដាសទៅដោយទឹកនិងសារាយក្នុងទីនោះៗ ព្រោះមានទឹកហូរគឺមានទឹកហូរចេញសព្វកាល ។

បទថា **តេ សេលា រមយន្តិ មំ** មានអធិប្បាយថា ខ្ញុំនៅត្រង់ភ្នំណា ភ្នំនោះ ជាភ្នំថ្មី មានសភាពដូច្នេះ ធ្វើឲ្យខ្ញុំត្រេកអរដោយការត្រេកអរក្រៃលែងក្នុងវិវេក ព្រោះហេតុនោះ អាត្មានឹងទៅត្រង់ភ្នំនោះឯង ។ ពាក្យជាគាថានេះ បានជាការព្យាករអរហត្តផលរបស់ព្រះថេរៈ ។

*អដ្ឋកថា វនវច្ឆត្ថេរគាថា ចប់*

# អធិមុត្តត្ថេរគាថា

[ ១១៥ ] កាលបើជីវិតសូន្យថយទៅ សេចក្ដីល្អរបស់សមណៈ នឹងមានមកក្នុងទីណា ដល់បុគ្គលអ្នកជូនក្នុងកាយដ៏អាក្រក់ជាប់ដោយសេចក្ដីសុខក្នុងសរីរៈ ។

**អធិមុត្តត្ថេរ ។**

---

## អដ្ឋកថា

## អធិមុត្តត្ថេរគាថា

[ ១១៥ ] គាថារបស់ព្រះអធិមុត្តត្ថេរ មានពាក្យផ្ដើមថា **កាយទុដ្ឋុល-គរុនោ** ដូច្នេះ ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក្នុងកាលព្រះមានព្រះភាគព្រះនាមថា បទុមុត្តរៈ កើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវការៈជាអ្នកដឹងក្ដីហើយសិក្សាសម្រេចក្នុងវិជ្ជាទាំងឡាយរបស់ព្រាហ្មណ៍ ឃើញទោសក្នុងកាមទាំងឡាយ លះនូវឃរា-វាសវិស័យ ហើយបួសជាតាបសនៅក្នុងព្រៃ ដឹងដំណឹងការកើតឡើង នៃព្រះពុទ្ធ ទើបចូលទៅកាន់ដែនដីមនុស្ស ឃើញព្រះសាស្ដាដែលភិក្ខុសង្ឃចោមរោមយាងទៅ ជាអ្នកមានចិត្តជ្រះថ្លា ក្រាលសំពត់សម្បកឈើរបស់ខ្លួនទៀបបាទមូលរបស់ព្រះសាស្ដា ព្រះសាស្ដា ទ្រង់ជ្រាបអធ្យាស្រ័យរបស់តាបសទើបទ្រង់ឈរលើសំពត់សម្បកឈើនោះ ។ តាបស បូជាព្រះមានព្រះភាគដែលប្រថាប់ឈរលើសំពត់សម្បកឈើនោះ ដោយគ្រឿងក្រអូប ដែលសម

គួរដល់សក្ការៈ ហើយសរសើរដោយគាថា ១០ មានពាក្យថា **សមុទ្ទរសិមំ លោកំ**[១]ដូច្នេះជាដើម ។ ព្រះសាស្តាទ្រង់ព្យាករតាបសថា ក្នុងអនាគតកាល ក្នុងទីបំផុតមួយសែនកប្បអំពីកប្បនេះ តាបសនឹងបួសក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមថាគោតមនឹងបានជាអ្នកមានអភិញ្ញា ៦ ដូច្នេះហើយ ទ្រង់យាងចៀសចេញទៅ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ រហូតដល់ព្រះពុទ្ធអង្គទ្រង់កើតឡើង ។ ក្នុងពុទ្ធុប្បាទនេះ កុលបុត្តនោះកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងនគរសាវត្ថី មានឈ្មោះថា អជិមុត្ត ដល់នូវភាពជាអ្នកដឹងក្តីហើយ សិក្សាសម្រេចក្នុងវិជ្ជាទាំងឡាយរបស់ព្រាហ្មណ៍ មិនឃើញសារៈនៃវិជ្ជាទាំងនោះ ទើបស្វែងរកផ្លូវរំលត់ទុក្ខ ។ ដោយកពនោះជាកពចុងក្រោយ ឃើញពុទ្ធានុភាព ក្នុងថ្ងៃដែលព្រះមានព្រះភាគទទួលព្រះវិហារជេតពន មានសទ្ធា បួសក្នុងសម្នាក់ព្រះសាស្តា ផ្តើមចម្រើនវិបស្សនា ហើយសម្រេចអរហត្ត ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំបានឃើញព្រះលោកនាយក ទ្រង់រុងរឿង ដូចផ្កាកណិការ
ទ្រង់ភ្លឺ ដូចឈើប្រចាំទ្វីប ភ្លឺប្រាលដូចផ្កាយព្រឹក ពុំនោះដូច
ផ្លេកបន្ទោរព្ទដ៏អាកាស ។ ព្រះអង្គមិនខ្លាច មិនតក់ស្លុត ដូច
កេសររាជសីហ៍ជាស្តេចម្រឹគ ទ្រង់ប្រកាសនូវពន្លឺគឺញាណ ទ្រង់

---

១-គាថានេះមានក្នុងអបទានរបស់ព្រះថេរៈខាងមុខ ។

ញ៉ាំញីនូវពួកតិរ្ថិយ ។ ទ្រង់ស្រង់នូវសត្វលោកនេះ ទ្រង់ផ្តាច់បង់នូវសេចក្តីសង្ស័យទាំងអស់មិនខាចដូចស្តេចម្រឹគ ។ ខ្ញុំជាព្រាហ្មណ៍អ្នកទ្រទ្រង់នូវជដានិងស្បែកខ្លា មានចិត្តត្រង់ មានព្យាយាម បានកាន់យកនូវសំពត់សម្បកឈើ ទៅក្រាលទៀបបាទមូល ។ បានយកខ្ទឹមក្លាំពាក់ទៅលាបព្រះតថាគត លុះលាបព្រះសម្ពុទ្ធហើយ បានសរសើរព្រះលោកនាយក ដូច្នេះថា

បពិត្រព្រះមហាមុនី ព្រះអង្គទ្រង់ស្រង់នូវសត្វលោកនេះ ទ្រង់បានឆ្លងនូវឱឃធម៌ ទ្រង់ធ្វើញាណដ៏ប្រសើរឧត្តមឲ្យភ្លឺដោយពន្លឺគឺញាណ ។ ព្រះអង្គញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅក្នុងលោក ទ្រង់ញ៉ាំញីនូវអន្យតិរ្ថិយ ជាបុគ្គលប្រសើរ ទ្រង់ឈ្នះសង្គ្រាម ទ្រង់ញ៉ាំងផែនដីឲ្យកម្រើក ។ ទិដ្ឋិទាំងអស់បែកធ្លាយក្នុងញាណរបស់ព្រះអង្គ ប្រៀបដូចរលកក្នុងមហាសមុទ្រ រមែងបែកធ្លាយ ក្នុងទីបំផុតច្រាំង ។ សំណាញ់នៃព្រានត្រីដ៏ល្អិត ដែលគេបង់ចុះក្នុងស្រះ ពួកសត្វទាំងនោះ ដែលតាំងនៅក្នុងសំណាញ់ ត្រូវគេបៀតបៀនក្នុងខណៈនោះ យ៉ាងណា ។ បពិត្រព្រះអង្គនិរទុក្ខ ពួកអន្យតិរ្ថិយ ក្នុងលោក ជាមនុស្សវង្វេង ប្រាសចាកសច្ចៈ រមែងប្រព្រឹត្តទៅក្នុងខាងក្នុង នៃញាណដ៏ប្រសើររបស់ព្រះអង្គ ក៏យ៉ាងនោះដែរ ។ ព្រះអង្គជាទីពឹងរបស់

ពួកជនដែលឥតផៅពង្ស ដូចជាពួកមនុស្ស ដែលជាទីពំនាក់នៃពួកជនដែលហែលលិចលង់ក្នុងអន្លង់ ព្រះអង្គជាទីរឭករបស់សត្វដែលឋិតនៅក្នុងភ័យ ជាទីប្រព្រឹត្តទៅខាងមុខនៃពួកសត្វដែលត្រូវការក្នុងការរួចចាកកិលេស ។ ព្រះអង្គទ្រង់ត្រាច់ទៅតែមួយអង្គឯង រកបុគ្គលស្មើគ្មានទ្រង់ប្រកបដោយមេត្តានិងករុណា ទ្រង់មានប្រាជ្ញា ទ្រង់ប្រកបក្នុងការលះ ទ្រង់ស្ទាត់ជំនាញ ទ្រង់នឹងធឹង ជាលំនៅនៃគុណ ។ ព្រះអង្គជាអ្នកប្រាជ្ញ ប្រាសចាកការវង្វេង មិនញាប់ញ័រ មិនមានសេចក្តីសង្ស័យ ទ្រង់មានសេចក្តីសន្តោស មានទោសៈខ្ចាក់ចោលហើយ ព្រះអង្គមិនមានមន្ទិល ទ្រង់សម្រួមស្អាតបាត ។ ព្រះអង្គកន្លងនូវកិលេសជាគ្រឿងជាប់ចំពាក់ មានសេចក្តីស្រវឹងកន្លងហើយ ទ្រង់មានវិជ្ជា ៣ ទ្រង់ដល់នូវទីបំផុតនៃភព ទ្រង់កន្លងនូវធម៌ជាដែន មានព្រះទ័យធ្ងន់ក្នុងធម៌ ទ្រង់ផ្សាយសេចក្តីចម្រើនទ្រង់សាបព្រោះប្រយោជន៍ ។ ព្រះអង្គជាអ្នកចម្លងពួកសត្វដូចសំពៅ ទ្រង់ធ្វើនូវសេចក្តីទំនុកបម្រុងដូចកំណាប់ទ្រព្យទ្រង់មិនខ្លាចដូចរាជសីហ៍ ពុំនោះសោតដូចស្តេចដំរីដែលហ្វឹកហ្វឺនហើយ ។

ខ្ញុំលុះសរសើរព្រះមហាមុនី ព្រះនាមបទុមុត្តរៈ ដោយគាថាទាំង

១០ ហើយ ថ្វាយបង្គំព្រះបាទាព្រះសាស្តា រួចឈរនៅស្ងៀម ក្នុងកាលនោះ ។

ព្រះលោកវិទូព្រះនាម បទុមុត្តរៈ ទ្រង់គួរទទួលគ្រឿងបូជា ទ្រង់ជាសាស្តា ឋិតនៅក្នុងពួកភិក្ខុ ទ្រង់បានពោលនូវគាថាទាំង នេះថា កុលបុត្តណាសរសើរនូវសីល បញ្ញា និងធម៌ របស់ តថាគត តថាគតនឹងសរសើរកុលបុត្តនោះ អ្នកទាំងឡាយចូរ ប្រុងស្តាប់នូវភាសិតដែលតថាគតនឹងសម្តែងចុះ ។ បុគ្គលនេះ នឹងរីករាយក្នុងលោក នឹងបានជាធំ គ្របសង្កត់ទេវតាដទៃ នឹងសោយនូវឥស្សរភាពអស់ ៦ ម៉ឺនកប្ប ។ ក្នុងកាលជា ខាងក្រោយមក កុលបុត្តនោះនឹងចេញបួស ត្រូវកុសលមូល ជាស់តឿនហើយនឹងបួសក្នុងសាសនានៃព្រះគោតមមានព្រះ ភាគ ។ លុះបួសហើយ បានវៀរបង់នូវបាបកម្មដោយកាយ កំណត់ដឹងនូវអាសវធម៌ទាំងពួងជាអ្នកមិនមានអាសវៈ នឹងបរិ និព្វាន ។

មេឃកាលកម្មរ ធ្វើផែនដីនេះឲ្យឆ្អែត យ៉ាងណាមិញ បពិត្រព្រះមហាវីរៈ ព្រះអង្គទ្រង់ញុំាងខ្ញុំឲ្យឆ្អែតដោយធម៌ក៏យ៉ាង នោះដែរ ។ ខ្ញុំព្រះអង្គសរសើរនូវសីល បញ្ញា និងធម៌ នៃ ព្រះលោកនាថ ជាអ្នកដល់នូវព្រះនិព្វាន ជាទីស្ងប់ដ៏ក្រៃលែង ជាបទមិនញៀងឃ្លាត ។ ធ្វើម្តេចហ្ន៎ ! ព្រះមានព្រះភាគអង្គ

នោះ ទ្រង់មានចក្ខុ នឹងឋិតនៅអស់កាលយូរ អាត្មាអញនឹង
បានដឹងនូវធម៌ ដែលមិនទាន់ដឹងផង នឹងឃើញនូវអមតបទ
ផង ។ នេះជាបច្ឆិមជាតិរបស់ខ្ញុំ ភពទាំងពួងខ្ញុំដកចោលហើយ
ខ្ញុំកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុង
កប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំសរសើរព្រះពុទ្ធ
ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរ ។ កិលេស
ទាំងឡាយខ្ញុំដុតចោលហើយ ។បេ។ ទាំងសាសនារបស់ព្រះ
ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលនឹងទូន្មានភិក្ខុទាំងឡាយដែល ច្រើនទៅដោយការខ្ជិលច្រអូស ដែលនៅរួមជាមួយលោក ទើបពោលគាថា នេះថា

កាលបើជីវិតសួនរួចថយទៅ សេចក្ដីល្អរបស់សមណៈនឹងមាន
មកក្នុងទីណាដល់បុគ្គលអ្នកជូន់ក្នុងកាយដ៏អាក្រក់ ជាប់ដោយ
សេចក្ដីសុខក្នុងសរីរៈ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាយទុដ្ឋុល្លគរុនោ** សេចក្ដីថា ការប្រកប នៅភាពមិនល្អ ឈ្មោះថា **ទុដ្ឋុល្ល** ការអាក្រក់គ្រោតគ្រាតផ្លូវកាយ ឈ្មោះថា **កាយទុដ្ឋុល្ល** កាយទុដ្ឋុល្លដ៏ធ្ងន់មានដល់ភិក្ខុណា ភិក្ខុនោះឈ្មោះថា **កាយទុដ្ឋុល្លគរុ** អធិប្បាយថា ជាអ្នកមិនគិតដើម្បីចេញចាកទុក្ខ ខ្វល់ខ្វាយតែការ

---

១-ក្នុងអបទានជាព្រះ សព្វកិត្តិកត្ថេរ ។

ទំនុកបម្រុងរាងកាយ គឺធ្វើកាយឲ្យធាត់ ។ ដល់កិច្ចដែលគិតតែទំនុកបម្រុងរាងកាយនោះ ។

បទថា **ហិយ្យមានម្ហិ ជីវិតេ** សេចក្តីថា កាលជីវិតនិងសង្ខារកំពុងអស់ទៅដោយរហ័ស ដូចទឹកក្នុងស្នឹងតូចកំពុងរីងស្ងួតទៅ ដូច្នោះ ។ បទថា **សរីរសុខគិទ្ធស្ស** សេចក្តីថា ដល់នូវការជាប់ជំពាក់ក្នុងសេចក្តីសុខផ្លូវកាយរបស់ខ្លួន មានអាហារប្រណីតជាដើម ។

បទថា **កុតោ សមណសាធុតា** សេចក្តីថា សេចក្តីល្អដោយភាពជាសមណៈ គឺភាពជាសមណៈល្អ គប្បីមានដល់បុគ្គលបែបនេះ ដោយហេតុនោះអំពីណា អធិប្បាយថា ភាពជាសមណៈដែលល្អនឹងមានដល់កិច្ចដែលប្រាសចាកការសម្ងំក្នុងរាងកាយនិងជីវិត ជាអ្នកសន្តោសហើយដោយបច្ចយសន្តោសតាមមានតាមបានប្រារព្ធព្យាយាមហើយដោយចំណែកមួយប៉ុណ្ណោះ។

## អដ្ឋកថា អធិមុត្តត្ថេរគាថា ចប់

## មហានាមត្ថេរគាថា

[ ១១៦ ] អ្នកទុំនឹងសាបសូន្យចាកភ្នំឈ្មោះនេសាទកៈ ( ទីនៅនៃអ្នកនេសាទ ) ជាភ្នំមានយស បិទបាំងដោយដើមក្រែងគង់ នឹងដើមពោនស្វាជាច្រើន ។

**មហានាមត្ថេរ ។**

## អដ្ឋកថា

## មហានាមត្ថេរគាថា

[ ១១៦ ] គាថារបស់ព្រះមហានាមត្ថេរ មានពាក្យផ្ដើមថា **ឯសាវ-ហិយ្យសេ បព្វតេន** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងកាលរបស់ព្រះមានព្រះភាគព្រះនាមថាសុមេធ កើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវការសម្រេចក្នុងវិជ្ជា របស់ព្រាហ្មណ៍ទាំងឡាយ ហើយលះឃរាវាសវិស័យ សាងអាស្រមត្រង់ច្នេរស្ទឹងមួយកន្លែង បង្រៀនមន្តដល់ពួកព្រាហ្មណ៍ជាច្រើន ។ ថ្ងៃមួយ ព្រះមានព្រះភាគយាងទៅកាន់អាស្រមនៃកុលបុត្តនោះ ដើម្បីទ្រង់អនុគ្រោះដល់កុលបុត្តនោះ ។ កុលបុត្តនោះឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លារៀបចំក្រាលអាសនៈថ្វាយ កាលព្រះមានព្រះភាគគង់

ហើយ បង្អោនទឹកឃ្មុំដែលមានរសផ្អែមល្អចូលទៅថ្វាយ ។ ព្រះមានព្រះភាគសោយទឹកឃ្មុំនោះហើយ ទ្រង់ព្យាករអនាគតដោយន័យ ដូចពោលក្នុងរឿងនៃព្រះអធិមុត្តត្ថេរនោះឯង ហើយទ្រង់យាងទៅ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក អន្ទោលទៅមកតែក្នុងសុគតិកពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍នានគរសាវត្ថីមានឈ្មោះថាមហានាម ដល់នូវភាពជាអ្នកដឹងក្តីហើយ ចូលទៅកាន់សម្នាក់របស់ព្រះមានព្រះភាគ ស្តាប់ធម៌ហើយ មានសទ្ធាបួសហើយ រៀនកម្មដ្ឋានត្រង់ភ្នំនេសាទក: មិនអាចសង្កត់នូវការបោមពោមនៃកិលេសបាន គិតថា ជីវិតរបស់អញមានចិត្តសៅហ្មងនេះ នឹងមានប្រយោជន៍អ្វី កាលនឿយណាយក្នុងអត្តភាពក៏ឡើងកាន់កំពូលភ្នំ គិតថា អញនឹងលោតអំពីកំពូលភ្នំនេះសម្លាប់ខ្លួនឲ្យស្លាប់ ទើបពោលគាថាសន្តូតខ្លួនជាអ្នកដទៃថា

អ្នកនុ៎ះនឹងសាបសូន្យចាកភ្នំ ឈ្មោះនេសាទក: ( ទីនៅនៃអ្នកនេសាទ ) ជាភ្នំមានយស បិទបាំងដោយដើមក្រៃងគង់និងដើមពោនស្វាជាច្រើន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯសាវហិយ្យសេ** សេចក្តីថា នៃមហានាមឯងនឹងវិនាស គឺនឹងសាបសូន្យ ។

បទថា **បព្វតេន** សេចក្តីថា ចាកភ្នំនេះ ដែលជាទីនៅអាស្រ័យ ។

បទថា **ពហុកុដជសល្លិកេន** សេចក្តីថា ប្រកបដោយដើមក្រៃងគង់និងដើមពោនស្វា ឬដោយដើមរាជព្រឹក្សនិងដើមពោនស្វាទាំងឡាយ ។

បទថា **នេសាទកេន** បានដល់ ភ្នំមានឈ្មោះយ៉ាងនេះ ។ បទថា **គិរិ-ណា** បានដល់ ភ្នំ អធិប្បាយថា ភ្នំ លោកហៅថា **បព្វត** ព្រោះតាំងនៅដោយថ្នាំង ពោលគឺទីត និងហៅថា **គិរី** ព្រោះជាទីហូរចេញនៃ ធ្នារទឹកជាដើម និងវត្ថុដែលជាសារៈមានឱសថជាដើម ។ តែក្នុងគាថានេះ លោកហៅថា **បព្វត** និងហៅថា **គិរី** ព្រោះមានអត្ថទាំង ២ យ៉ាងរួមគ្នា ។

បទថា **យសស្សិនា** សេចក្ដីថា ប្រាកដ គឺច្បាស់ដោយគុណទាំងពួង ។ បទថា **បរិច្ឆេទេន** បានដល់ ប្រដាប់ដោយដើមឈើ គុម្ពឈើ និងវល្លិជាច្រើនដោយជុំវិញ ឬបានដល់ ជាព្រំដែន ដោយភាពជាលំនៅរបស់អ្នក ។ តែក្នុងគាថានេះ មានអធិប្បាយដូច្នេះថា នៃមហានាម បើអ្នកលះកម្មដ្ឋានជាអ្នកច្រើនដោយវិតក្កសោត អ្នកនឹងសាបសូន្យចាកភ្នំ ឈ្មោះនេសាទកៈដែលជាលំនៅសម្បូរដោយម្ហូបនិងទឹកដែលជាសប្បាយយ៉ាងនេះ ឥឡូវនេះអញនឹងនាំខ្លួនឯងលោតអំពីភ្នំនេះឲ្យស្លាប់ ព្រោះហេតុនោះ ឯងមិនត្រូវធ្លាក់ក្នុងអំណាចនៃវិតក្ក ដូច្នេះ ។

ព្រះថេរៈគំរាមខ្លួនយ៉ាងនេះ ខ្វល់ខ្វាយក្នុងវិបស្សនា សម្រេចអរហត្តហើយសមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

អាស្រមបរមសាលារបស់ខ្ញុំ ជាងបានស្ថាបនាល្អហើយ ទៀប
ឆ្នេរទន្លេឈ្មោះសិន្ធុ ខ្ញុំបានឲ្យពួកសិស្ស រៀនគម្ពីរឥតិហាសៈ
ព្រមទាំងលក្ខណៈ ក្នុងអាស្រមនោះ ។ ពួកសិស្សខ្ញុំ ទាំង
អម្បាលនោះ ជាអ្នកប្រាថ្នានូវធម៌ ជាអ្នកប្រាថ្នាដើម្បីស្ដាប់នូវ

ពាក្យប្រៀនប្រដៅដ៏ល្អ ជាអ្នកដល់នូវបារមីក្នុងធម្មជ្ជធម៌ ខ្ញុំបានទូន្មានហើយ ពួកសិស្សទាំងនោះ នៅក្បែរធ្មេរទន្ទេសិទ្ធ ។ ក្នុងកាលនោះ ពួកសិស្សដែលឈ្លាសក្នុងការកើត និងដំណើរមកផង ក្នុងលក្ខណៈផង ស្វែងរកនូវប្រយោជន៍ដ៏ឧត្តម នៅក្នុងព្រៃធំ ។ កាលនោះឯង ព្រះសម្ពុទ្ធព្រះនាមសុមេធៈ ទ្រង់កើតឡើងក្នុងលោក ទ្រង់ជាអ្នកដឹកនាំពួកសត្វ អនុគ្រោះយើងខ្ញុំបានស្តេចចូលមកជិតខ្ញុំ ។ ខ្ញុំបានឃើញព្រះសុមេធៈ ជាលោកនាយក មានព្យាយាមធំស្តេចចូលមកដល់ហើយ ក៏ធ្វើកម្រាលស្មៅថ្វាយព្រះលោកជេដ្ឋ ខ្ញុំយកទឹកឃ្មុំអំពីព្រៃធំ មកថ្វាយព្រះពុទ្ធដ៏ប្រសើរ ។

ព្រះសម្ពុទ្ធទ្រង់សោយហើយ សម្តែងនូវព្រះពុទ្ធដីកានេះថា កុលបុត្តណា ជ្រះថ្លាបានថ្វាយទឹកឃ្មុំនោះ ដល់តថាគតដោយដៃរបស់ខ្លួនតថាគតនឹងសរសើរនូវកុលបុត្តនោះ អ្នកទាំងឡាយចូរប្រុងស្តាប់ពាក្យតថាគត ដែលនឹងសម្តែងចុះ ។ ដោយអំណោយទឹកឃ្មុំនេះផង ដោយកម្រាលស្មៅនេះផង បុរសនេះនឹងរីករាយក្នុងទេវលោកអស់ ៣ ម៉ឺនកប្ប ។ កន្លងទៅ ៣ ម៉ឺនកប្បទៀត ព្រះសាស្តាព្រះនាមគោតម ទ្រង់សម្ភពក្នុងត្រកូលនៃឱក្កាករាជ នឹងត្រាស់ឡើងក្នុងលោក ។ ឯបុរសនេះ នឹងជាអ្នកទទួលមត៌ក ក្នុងធម៌របស់ព្រះសាស្តាអង្គនោះ ជាឱរស

ដែលធម៌និម្មិតហើយ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ខ្ញុំច្យុតចាកទេវលោក មកចាប់ផ្ទៃនៃមាតា ក្នុងមនុស្សលោកនេះ ភ្លៀងទឹកឃ្មុំបានបង្អុរចុះគ្របនូវផែនដីដោយទឹកឃ្មុំ ។ ក្នុងពេលដែលខ្ញុំប្រសូតចេញមក ភ្លៀងទឹកឃ្មុំ រមែងបង្អុរចុះមកឲ្យខ្ញុំអស់កាលជានិច្ចក្នុងទីនោះ ( ដូចជាគេចាក់ទឹក ) អំពីក្អម ផែនដីគេធ្វងបានដោយក្រ ។ ខ្ញុំបានចេញចាកផ្ទះចូលទៅកាន់ផ្នួស ជាអ្នកបានបាយទឹកជាប្រក្រតី នេះជាផលនៃទានទឹកឃ្មុំ ។ ខ្ញុំកើតក្នុងទេវលោកនិងមនុស្សលោកជាអ្នកបានសម្រេចដូចសេចក្តីប្រាថ្នាគ្រប់ប្រការ ជាអ្នកដល់នូវធម៌ ជាគ្រឿងអស់អាសវៈដោយទានទឹកឃ្មុំនោះឯង ។

កាលភ្លៀងបង្អុរចុះមក កាលស្មៅ ( ដុះ ) កម្ពស់ ៤ ធ្នាប់ កាលដើមឈើលើប្រឹថពីជាទីគួរសោបព្រោះ មានផ្ការីកល្អ ខ្ញុំមិនមានអាសវៈ ដល់នូវសេចក្តីសុខជានិច្ច នៅក្នុងផ្ទះស្ងាត់ទៀបគល់ឈើ ជាមណ្ឌប ។

ខ្ញុំបានកន្ធ្វងបង់នូវភពទាំងឡាយ ដែលជាភពក្នុងបច្ចុប្បន្នរបស់ខ្ញុំ ក្នុងថ្ងៃនេះ អាសវៈរបស់ខ្ញុំអស់ហើយ ឥឡូវនេះភពថ្មីមិនមានទៀតឡើយ ។ ក្នុងកប្បទី ៣ ម៉ឺន អំពីកប្បនេះ ក្នុងកាលនោះព្រោះហេតុដែលខ្ញុំបានឲ្យទាន ខ្ញុំមិនដែលស្គាល់

ទុគ្គតិ នេះជាផលនៃទានទឹកឃ្មុំ ។ កិលេសទាំងឡាយ ខ្ញុំបាន
ដុតចោលហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន
ប្រតិបត្តិហើយ ដូច្នេះ[១] ។

គាថានេះឯង បានជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈដោយប្រការ
ដូច្នេះ ។

## អដ្ឋកថា មហានាមត្ថេរគាថា ចប់

---

១-ក្នុងអបទានជា មធុទាយកត្ថេរ ។

## ចារបរិយត្ថេរគាថា

[ ១១៧ ] បុគ្គលគប់គ្រងទ្វារសង្រួមដោយល្អ ខ្ជាក់ចោលនូវឫសគល់នៃសេចក្តីទុក្ខ ព្រោះលះបង់ផស្សាយតនៈទាំង ៦ ប្រការ ការអស់ទៅនៃអាសវៈខ្ញុំក៏បានដល់ហើយ ។

**ចារបរិយត្ថេរ ។**

## អដ្ឋកថា

## ចារបរិយត្ថេរគាថា

[ ១១៧ ] គាថារបស់ព្រះចារបរិយត្ថេរ មានពាក្យផ្តើមថា **ឆផស្សាយតនេ ហិត្វា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ជាអ្នកសន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមថាបិយទស្សី កើតក្នុងកំណើតព្រានព្រៃ កាលកុលបុត្តនោះដល់នូវភាពជាអ្នកដឹងក្តីហើយ ព្រះមានព្រះភាគបិយទស្សីដើម្បីទ្រង់អនុគ្រោះ ទើបទ្រង់ចូលនិរោធសមាបត្តិ ត្រង់ព្រៃមួយកន្លែង ក្នុងទីដែលកុលបុត្តនោះត្រាច់ទៅ ។

កុលបុត្តនោះកំពុងស្វែងរកម្រឹគ ទៅកាន់ទីនោះ ជួបព្រះសាស្តា មានចិត្តជ្រះថ្លា យកផ្កាបទុមប្រក់មណ្ឌបដែលធ្វើដោយមែកឈើ ធ្វើដូចជាផ្ទះកំពូល

ដោយឲ្យព្រះមានព្រះភាគគង់នៅខាងក្នុង បានទូវបីតិនិងសោមនស្សដ៏លើស លុប ឈរទមស្ការអស់ ៧ ថ្ងៃ ហើយនាំយកផ្កាក្រៀមៗចេញ នាំយកផ្កា ស្រស់ៗមកប្រក់រាល់ថ្ងៃ លុះគ្រប់ ៧ ថ្ងៃ ព្រះសាស្តាចេញអំពីនិរោធសមា បត្តិ ទ្រង់រព្វកដល់ភិក្ខុសង្ឃ ក្នុងវេលានោះឯងភិក្ខុទាំងឡាយប្រមាណ ៨ ម៉ឺន រូប ក៏នាំគ្នាមកចោមរោមព្រះសាស្តា ទេវតាទាំងឡាយមកប្រជុំគ្នា ដោយគិត ថា ពួកយើងនឹងស្តាប់ធម្មកថាដ៏ពីរោះ បានជាមហាសមាគមហើយ ។ ព្រះ សាស្តាទ្រង់ធ្វើអនុមោទនា ទ្រង់ព្យាករថា កុលបុត្តនេះនឹងបានទៅកើតក្នុង ទេវតានិងមនុស្សទាំងឡាយ នឹងបានជាសាវកពោធិញ្ញាណ ក្នុងពុទ្ធុប្បាទនេះ ហើយទ្រង់យាងចៀសចេញទៅ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំង ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ក្នុងក្រុងរាជគ្រឹះមានឈ្មោះ ថា បារាបរិយៈ ព្រោះជាពូជពង្សនៃបរាបរគោត្ត ដល់នូវភាពជាអ្នកដឹងក្តី ហើយ រៀនចប់ត្រៃវេទ បង្រៀនមន្តដល់ព្រាហ្មណ៍ជាច្រើន ឃើញពុទ្ធានុភាព កាលព្រះសាស្តាយាងមកនគររាជគ្រឹះបានទូវសទ្ធាបួសហើយចម្រើនវិបស្ស-នាសម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោល ទុកក្នុងអបទានថា

ព្រះកកុសន្ធសម្ពុទ្ធព្រះនាមបិយទស្សីទ្រង់ត្រាស់ដឹងឯង ទ្រង់
ជានាយកនៃសត្វលោក ទ្រង់ប្រាថ្នានូវសេចក្តីស្ងប់ស្ងាត់ ជា
អ្នកប្រាជ្ញឆ្លៀវឆ្លាសក្នុងសមាធិ ។ ព្រះមហាមុនី ព្រះនាមបិយ

ទស្សី ជាបុរសខ្ពង់ខ្ពស់ ទ្រង់ចូលទៅកាន់ដងព្រៃ ទ្រង់ក្រាលនូវចីវរបំសុកូលហើយ គង់នៅហើយ ។ ក្នុងកាលនោះខ្ញុំបានកើតជាព្រានម្រឹគ ខ្ញុំកំពុងដើរស្វែងរកម្រឹគក្តាន់ ក្នុងព្រៃធំ ។ ខ្ញុំបានឃើញក្នុងព្រៃនោះនូវព្រះសម្ពុទ្ធ ទ្រង់ឆ្លងនូវឱឃៈ មិនមានអាសវៈ ដូចដើមសាលរាជព្រឹក្សមានផ្ការីក ឬដូចព្រះអាទិត្យដែលរះឡើង ។ លុះខ្ញុំឃើញនូវព្រះបិយទស្សីសម្ពុទ្ធ ទ្រង់មានយសច្រើន ជាទេវតាកន្លងទេវតា ក្នុងកាលនោះ ខ្ញុំក៏ចុះកាន់ជាតស្រះ ហើយបេះផ្កាឈូក ។ ខ្ញុំបេះនាំយកផ្កាឈូកជាទីរីករាយនៃចិត្តហើយធ្វើនូវកូដាគារស្តានប្រក់ដោយផ្កាឈូក។ ព្រះមហាមុនី ព្រះនាមបិយទស្សីជិនស្រីសម្មាសម្ពុទ្ធ ទ្រង់មានសេចក្តីអនុគ្រោះ ប្រកបដោយករុណា ទ្រង់គង់ក្នុងកូដាគារស្តានអស់ ៧ យប់ ៧ ថ្ងៃ ។ ខ្ញុំបកផ្កាឈូកចាស់ចោលចេញហើយប្រក់ផ្កាឈូកថ្មីវិញ រួចឈរផ្គងអញ្ជលី ។ ព្រះមហាមុនី ព្រះនាមបិយទស្សីជាលោកនាយក ទ្រង់ចេញអំពីសមាធិហើយ គង់ប្រមើលមើលទិសទាំងឡាយ ។ គ្រានោះព្រះថេរៈឈ្មោះសុទស្សនៈ ជាឧបដ្ឋាកមានឫទ្ធិច្រើន បានជ្រាបព្រះទ័យនៃព្រះបិយទស្សីសម្ពុទ្ធជាសាស្តា ។ ព្រះថេរៈនោះមានភិក្ខុ ៨ ម៉ឺនចោមរោម ហើយចូលទៅគាល់ព្រះលោកនាយកដែលគង់ជាសុខក្នុងទីបំផុតព្រៃ ។ ក្នុងកាលនោះ ទេវតាទាំងឡាយទាំងអស់

ដែលនៅអាស្រ័យក្នុងជងព្រៃ ទាំងប៉ុន្មាន បានដឹងព្រះទ័យនៃព្រះសម្ពុទ្ធ ក៏មកប្រជុំគ្នា ។ កាលពួកយក្ស ពួកកុម្ភណ្ឌ ព្រមទាំងពួកអារក្ស មកប្រជុំគ្នាផង ភិក្ខុសង្ឃក៏បានមកដល់ព្រមផង ទើបព្រះជិនស្រីទ្រង់ត្រាស់ព្រះគាថាទាំងឡាយថា

កុលបុត្តណាបានបូជាតថាគតអស់ ៧ ថ្ងៃ ទាំងបានធ្វើអាវាសដល់តថាគតៗ នឹងសរសើរកុលបុត្តនោះ អ្នកទាំងឡាយចូរប្រុងស្តាប់នូវភាសិតដែលតថាគតនឹងសម្តែងចុះ ។ តថាគតនឹងសម្តែងនូវធម៌ដ៏ល្អិតជ្រាលជ្រៅ ដែលបុគ្គលកម្រយល់ឃើញបានដោយងាយ ដែលតថាគតប្រកាសល្អហើយដោយញាណអ្នកទាំងឡាយចូរប្រុងស្តាប់នូវភាសិតដែលតថាគតនឹងសម្តែងចុះ ។ បុរសនេះ នឹងបានគ្រប់គ្រងទេវរាជ្យអស់ ១៤ កប្ប ផ្ទះកំពូលដ៏ធំទូលាយរបស់ទេវតានោះ ប្រក់ដោយផ្កាឈូក ។ ផ្កាឈូកទាំងឡាយនឹងបាំងពួដ៏អាកាស នេះជាផលនៃបុព្វកម្ម បុរសនោះនឹងអន្ទោលទៅប្រឡូកប្រឡំ ក្នុងកប្បទី ១,៤០០ ។ វិមានជាវិការៈនៃផ្កា នឹងបាំងនៅពួដ៏អាកាសនោះ ទឹកនឹងមិនជាប់ក្នុងស្លឹកឈូកយ៉ាងណា កិលេសទាំងឡាយនឹងមិនជាប់ក្នុងញាណ របស់បុរសនោះយ៉ាងនោះដែរ បុរសនេះនឹងញុំាងនីវរណៈទាំង ៥ ឲ្យឃ្លាតចាកចិត្ត ។ បុរស

នោះនឹងញុំាងចិត្តឲ្យកើតក្នុងនេក្ខម្មៈ ហើយចេញចាកផ្ទះទៅ បួស លំដាប់នោះ វិមានជាវិការៈនៃផ្កាដែលកំពុងបាំងក៏ នឹងចេញទៅតាមដែរ ។ ភិក្ខុនោះមានប្រាជ្ញា មានស្មារតី កាលនៅទៀបគល់ឈើ វិមានជាវិការៈនៃផ្កា នឹងមកបាំង លើព្រះកេសក្នុងទីនោះ ។ ភិក្ខុនោះ នឹងឲ្យបច្ច័យគឺចីវរ បិណ្ឌបាត និងទីដេកទីអង្គុយដល់ភិក្ខុសង្ឃ ជាអ្នកមិនមាន អាសវៈ ហើយនឹងបរិនិព្វាន ។ បុរសនោះចេញទៅកាន់ បព្វជ្ជា ក្នុងដំណើរជាមួយនឹងផ្ទះកំពូល ឯផ្ទះកំពូលក៏ទ្រ- ទ្រង់បាំងភិក្ខុនោះដែល នៅទៀបគល់ឈើ ។

ចេតនារបស់ខ្ញុំមិនមានក្នុងចីវរនិងចង្ហាន់បិណ្ឌបាតទេ ខ្ញុំប្រកប ដោយបុញ្ញកម្ម ទើបបាននូវការសម្រេច ។ ខ្ញុំមានជាតិកំណើត រាប់ដោយកោដិនៃកប្បជាច្រើន ព្រះលោកនាយកទាំងនោះទ្រង់ មានព្រះហឫទ័យផុតស្រឡះ និព្វានកន្លងផុតទៅទទេៗ ។ ក្នុងកប្បទី ១,៨០០ ព្រះលោកនាយកព្រះនាមបិយទស្សី ( ទ្រង់ ត្រាស់ឡើង ) ទើបខ្ញុំបានមកចាប់កំណើតជាព្រានម្រឹគ បាន ចូលទៅគាល់ព្រះអង្គ ។ ឥឡូវនេះខ្ញុំឃើញព្រះគោតមសម្ពុទ្ធ មានបញ្ចចក្ខុ ទ្រង់មិនថោកទាប ខ្ញុំក៏ទៅគាល់ព្រះអង្គ ហើយ ចូលទៅកាន់ផ្នួស ។ ព្រះពុទ្ធជិនស្រី ទ្រង់ធ្វើនូវទីបំផុតនៃទុក្ខ បានសម្តែងនូវព្រះសទ្ធម្ម ខ្ញុំស្តាប់ធម៌របស់ព្រះអង្គ ក៏បានដល់

នូវអចលបទ គឺព្រះនិព្វាន ជាឋានមិនកម្រើក ។ ខ្ញុំបានញ៉ាំង
ព្រះសម្ពុទ្ធព្រះនាមគោតម ជាពូជពង្សនៃសក្យៈ ឲ្យទ្រង់ត្រេក
អរហើយ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអា-
សវៈ ។ ក្នុងកប្បទី ១,៨០០ ព្រោះហេតុដែលខ្ញុំបានបូជានូវ
ព្រះសម្ពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។
កិលេសទាំងឡាយ ខ្ញុំដុតបោលហើយ ។បេ។ ទាំងសាសនា
របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួន កើតនូវសោមនស្សហើយ បានពោលគាថាដោយអំណាចឧទានថា

បុគ្គលគ្រប់គ្រងទ្វារសង្រួមដោយល្អ ខ្ជាក់ចោលនូវឫសគល់
នៃសេចក្តីទុក្ខ ព្រោះលះបង់ផស្សាយតនៈទាំង ៦ ប្រការ ការ
អស់ទៅនៃអាសវៈ ខ្ញុំក៏បានដល់ហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆស្សាយតនេ ហិត្វា** សេចក្តីថា លះនូវអាយតនៈដែលប្រព្រឹត្តទៅខាងក្នុង ៦ មានចក្ខុជាដើមដែលបាននាមថាផស្សាយតនៈ ព្រោះជាទីកើតឡើងនៃផស្សៈទាំងឡាយ ៦ មានចក្ខុសម្ផស្ស ជា-ដើម ដោយអំណាចនៃការលះនូវសេចក្តីសៅហ្មងដែលទាក់ទងដោយអាយ-តនៈ ដែលប្រព្រឹត្តទៅខាងក្នុងនោះ ។

បទថា **គុត្តទ្វារោ សុសំវុតោ** សេចក្តីថា ព្រោះហេតុនោះឯង ទើប

១-ក្នុងអបទានជាព្រះ បទុមកូដាគារិកត្ថេរ ។

ឈ្មោះថា ជាអ្នកមានទ្វារគ្រប់គ្រងហើយ សង្រួមហើយដោយល្អ ព្រោះគ្រប់គ្រងទ្វារទាំងឡាយ មានចក្ខុទ្វារជាដើម និងព្រោះបិទបាំងដោយល្អនូវការធ្វើដែលប្រព្រឹត្តទៅក្នុងចក្ខុទ្វារជាដើមនោះ ដោយទ្វារ គឺសតិដែលហាមបង់នូវការចូលទៅនៃបាបធម៌ទាំងឡាយ មានអភិជ្ឈាជាដើម ។ ម្យ៉ាងទៀត ក្នុងបទថា **គុត្តទ្វារោ សុសំវុតោ** នេះ គប្បីជ្រាបអត្ថយ៉ាងនេះថា ឈ្មោះថា **គុត្តទ្វារោ** ព្រោះរក្សាទ្វារទាំង ៦ ដែលមានចិត្តជាគម្រប់ ៦ ទុកបានដោយន័យដូចពោលហើយ ឈ្មោះថា **សុសំវុតោ** ព្រោះសង្រួមហើយដោយល្អដោយទ្វារទាំងឡាយ មានកាយទ្វារជាដើម ។

បទថា **អឃម្ហូលំ វមេត្វាន** សេចក្តីថា កម្ចាត់បង់បាននូវទោស ពោលគឺអវិជ្ជានិងភវតណ្ហាដែលជាឫសគល់នៃសេចក្តីទុក្ខ គឺវដ្តទុក្ខ ឬខ្ជាក់នូវកិលេសទោសទាំងពួង គឺធ្វើឲ្យចេញទៅក្រៅសន្តាន ដោយទឹកសម្រាប់ខ្ជាក់ ពោលគឺអរិយមគ្គ ឬព្រោះហេតុ គឺធ្វើទុកខាងក្រៅ ។

បទថា **បត្តោ មេ អាសវក្ខយោ** សេចក្តីថា ឈ្មោះថា **អាសវក្ខយោ** ព្រោះជាទីអស់ទៅ នៃអាសវៈទាំងឡាយ មានកាមាសវៈជាដើម ឬព្រោះសម្រេចដោយការអស់ទៅនៃអាសវៈទាំងនោះ បានដល់ ព្រះនិព្វាននិងអរហត្តផល ។ ព្រះថេរៈព្យាករអរហត្តផលដោយអំណាចនៃឧទានថា ខ្ញុំបានសម្រេច គឺដល់នូវការអស់អាសវៈហើយ ដូច្នេះ ។

អដ្ឋកថា បាបបរិយេត្ថេរគាថា ចប់

## យសត្ថេរគាថា

[ ១១៨ ] ខ្ញុំមានខ្លួនប្រោះព្រំល្អ ស្លៀកពាក់ល្អ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង បាននូវវិជ្ជា ៣ ប្រការ ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ។

*យសត្ថេរ ។*

---

## អដ្ឋកថា

## យសត្ថេរគាថា

[ ១១៨ ] គាថារបស់ព្រះយសត្ថេរ មានពាក្យផ្ដើមថា **សុវិលិត្តោ សុវសនោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាសុមេធ កើតជាស្ដេចនាគ មានអានុភាពច្រើន និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន មកកាន់ភពរបស់ខ្លួនហើយ ថ្វាយមហាទាន ឲ្យព្រះមានព្រះភាគទ្រង់គ្រងត្រៃចីវរដែលមានតម្លៃច្រើន និងឲ្យភិក្ខុគ្រប់រូបស្លៀកដណ្ដប់សំពត់ដែលមានតម្លៃច្រើនដូចគ្នា មួយអង្គមួយគូ មួយអង្គមួយគូ មួយអន្ទើដោយសមណបរិក្ខារគ្រប់យ៉ាង ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមថាសិទ្ធត្ថ កើតជាសេដ្ឋីបុត្ត បូជាបរិវេណដើមពោធិ៍ដោយរតនៈ ៧ ។ ក្នុងសាសនាព្រះមានព្រះភាគព្រះ

នាមថាកស្សបៈ បានបួសក្នុងសាសនាបំពេញសមណធម៌ ។ កុលបុត្តនោះអន្ទោលទៅតែក្នុងសុគតិកពប៉ុណ្ណោះ ដោយប្រការដូច្នេះ ។ ក្នុងពុទ្ធុប្បាទនេះកើតជាសេដ្ឋីបុត្តមានសម្បត្តិច្រើនក្នុងក្រុងពារាណសីមានឈ្មោះថា យស ជាសុខុមាលជាតិក្រៃលែង ។ រឿងទាំងអស់មានជាដើមថា យសកុលបុត្តមានប្រាសាទ ៣ គប្បីជ្រាបដោយន័យដែលមកហើយក្នុងខន្ធកៈនោះឯង ។

យសកុលបុត្ត កាលបុព្វហេតុដាស់តឿន ឃើញអាការចម្លែករបស់បរិវារជនដែលដេកលក់ក្នុងវេលារាត្រី កើតនូវសេចក្ដីសង្វេគ ពាក់ទ្រនាប់ជើងមាសចុះអំពីប្រាសាទទៅកាន់ទ្វារនគរ ដែលទេវតាបើកឲ្យ ទៅដល់ក្បែរព្រៃឥសិបតនមិគទាយវ័ន ពោលថា វឹកវរហ្ន៎ លោកដ៏ចម្រើន សាំញ៉ាំហ្ន៎ លោកដ៏ចម្រើន ។ សម័យនោះ ព្រះមានព្រះភាគគង់នៅត្រង់ព្រៃឥសិបតនៈ ទ្រង់ចង្ក្រមក្នុងទីវាល ដើម្បីទ្រង់អនុគ្រោះកុលបុត្តនោះឯង ទើបត្រាស់ថា យស ទីនេះមិនវឹកវរ ទីនេះមិនសាំញ៉ាំទេ ដូច្នេះ កុលបុត្តនោះកើតសោមនស្សថា បានឮថា ទីដែលមិនវឹកវរ ទីដែលមិនសាំញ៉ាំមាន ទើបដោះទ្រនាប់ជើងមាសចូលទៅគាល់ព្រះមានព្រះភាគ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង កាលព្រះសាស្ដាត្រាស់អនុបុព្វីកថា សម្ដែងសច្ចទេសនា លុះចប់សច្ចៈក៏បានជាសោតាបន្ន ។ កាលព្រះមានព្រះភាគសម្ដែងសច្ចទេសនាដល់បិតាដែលតាមរកបានធ្វើឲ្យជាក់ច្បាស់អរហត្តហើយ សមដូចគាថាព័ន្ធ ដែលលោកពោលទុកក្នុងអបទានថា

លំនៅរបស់ខ្ញុំ លយចូលទៅក្នុងមហាសមុទ្រ ដែលបុញ្ញកម្ម

និម្មិតល្អហើយ ស្រះបោក្ខរណីដែលបុញ្ញកម្មនិម្មិតល្អហើយ ជាស្រះមានពួកសត្វចាក្រពាកយាសយំដេរដាសដោយដើមចន្ទុលណីផង ដោយផ្កាឈូកនិងផ្កាឧប្បលផង ស៊ីងតាំងនៅដ៏ល្អជាទីរីករាយនៃចិត្ត តែងហូរចុះក្នុងស្រះបោក្ខរណីនោះ ។ ស្រះនោះ ដេរដាសដោយត្រីនិងអណ្តើក ជាទីប្រជុំនៃម្រឹគផ្សេងៗ គឹកកងដោយសំឡេងនៃក្ងោកនិងក្រៀល មួយអន្ទើដោយសត្វទាំងឡាយ មានសត្វតាវៅជាដើម ដែលមានសំឡេងពីរោះ ។ ពួកសត្វព្រាប ប្រវឹក ចាក្រពាក ក្អែកទឹក ត្រដេវរ៉ិច សាលិកា ចង្កៀលខ្យង ប៉ោលតោក ( មានកុះករ ) ក្នុងស្រះនោះ ។ ពួកសត្វហង្ស ក្រៀល ខ្ទិងស្រោក គ្រលេងគ្រលោងដ៏ច្រើនតែងបន្លឺ សូរសព្ទកងរំពង ស្រះនោះបរិបូណ៌ដោយកែវ ៧ ប្រការ មានដីខ្សាច់ជាវិការៈនៃកែវមណី និងកែវមុក្តា ។ ពួកដើមឈើជាវិការៈនៃមាសទាំងអស់ មានក្លិនផ្សេងៗផ្សាយចេញទៅ ញុំាងលំនៅ ( របស់ខ្ញុំ ) ឲ្យរុងរឿងទាំងថ្ងៃទាំងយប់សព្វៗកាល ។ តូរ្យតន្ត្រី ៦ ម៉ឺន មកប្រគំរាល់វេលាល្ងាចព្រឹក ស្រីៗ ១ ម៉ឺន ៦ ពាន់ តែងមកចោមរោមខ្ញុំសព្វៗកាល ។ ខ្ញុំចេញអំពីលំនៅ មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយបង្គំព្រះសុមេធៈជាលោកនាយក ដ៏មានយសធំអង្គនោះ ។ លុះថ្វាយបង្គំព្រះសម្ពុទ្ធហើយ និមន្តព្រះ

អង្គព្រមទាំងសិស្ស ព្រះសុមេធៈជាលោកនាយកជាអ្នកប្រាជ្ញ អង្គនោះទ្រង់បានទទួលនិមន្តន៍ ។ ព្រះមហាមុនី ទ្រង់ធ្វើធម្ម-កថាដល់ខ្ញុំ ហើយបញ្ជូនខ្ញុំទៅ ខ្ញុំក៏បានថ្វាយបង្គំព្រះសម្ពុទ្ធចូលទៅឯលំនៅរបស់ខ្ញុំ ។ ខ្ញុំបានហៅជនជាបរិស័ទមកថា អ្នកទាំងអស់គ្នាចូរប្រជុំគ្នា ព្រះសម្ពុទ្ធទ្រង់នឹងយាងមកកាន់លំនៅ ( របស់យើង ) ក្នុងបុព្វណ្ហសម័យ យើងឈ្មោះថា មានលាភហើយ អត្តភាពជាមនុស្សឈ្មោះថា យើងបានល្អហើយ ព្រោះយើងនៅរួមគ្នាយ៉ាងនេះ យើងនឹងធ្វើការបូជាដល់ព្រះពុទ្ធដ៏ប្រសើរ ជាសាស្តា ខ្ញុំនឹងតម្កល់បាយនិងទឹក ហើយក្រាបទូលនូវកត្តកាល ។ ព្រះលោកនាយក បាននិមន្តចូលទៅជាមួយនឹងភិក្ខុមួយសែនអង្គ ជាអ្នកស្ងាត់ក្នុងឈាន ។ ខ្ញុំបានធ្វើនូវការក្រោកទទួល ព្រមទាំងមានតូរ្យតន្ត្រីនិងចម្រៀង ប្រគំជាកិត្តិយសផង ព្រះពុទ្ធជាបុរសឧត្តម ទ្រង់គង់លើតាំង ជាវិការៈនៃមាសទាំងអស់ ។ ដំបូលខាងលើ ជាវិការនៃមាសទាំងអស់ ក្នុងកាលនោះ ផ្ចិតទាំងឡាយ ក៏បក់ក្នុងចន្លោះនៃភិក្ខុសង្ឃ ។ ខ្ញុំបានញ៉ាំងភិក្ខុសង្ឃ ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹកដ៏ច្រើន ខ្ញុំបានប្រគេនសំពត់មួយគូៗផ្សេងៗគ្នា ដល់ភិក្ខុសង្ឃៗ ជនទាំងឡាយ ហៅព្រះពុទ្ធអង្គណាថា សុមេធៈ ព្រះពុទ្ធអង្គនោះ ទ្រង់ទទួលការបូជារបស់សត្វលោក ទ្រង់គង់នៅក្នុង

កណ្តាលភិក្ខុសង្ឃ បានពោលគាថាទាំងនេះថា

បុរសណា បានឲ្យតថាគតឆាន់កត្តស្លាប់ស្លាក់ដោយបាយនិង ទឹកទាំងអស់នេះ តថាគតនឹងសរសើរនូវបុរសនោះ អ្នកទាំង ឡាយចូរប្រុងស្តាប់នូវពាក្យរបស់តថាគត ដែលនឹងសម្តែង ចុះ ។ ក្នុងកប្បទី ១,៨០០ បុរសនេះនឹងរីករាយ ក្នុងទេវ លោក នឹងបានជាស្តេចចក្រពត្តិមួយពាន់ជាតិ ។ នឹងកើត ក្នុងកំណើតណា ទោះជាទេវតាឬជាមនុស្ស នឹងមានដំបូល ជាវិការៈនៃមាសទាំងអស់បិទបាំងសព្វៗកាល ។ កន្លងពី នេះទៅ ៣ ម៉ឺនកប្បទៀត ព្រះសាស្តាទ្រង់ព្រះនាមគោតម ទ្រង់សម្ភព ក្នុងត្រកូលនៃឱក្កាករាជ នឹងត្រាស់ឡើងក្នុង លោក ។ បុរសនេះជាអ្នកទទួលមត៌កក្នុងធម៌របស់ព្រះសា-ស្តាអង្គនោះ ជាឱរសដែលធម៌និម្មិតហើយ បានកំណត់ដឹង អាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ បុរសនេះនឹងអង្គុយកណ្តាលភិក្ខុសង្ឃហើយ បន្លឺនូវសីហ-នាទថា ជនទាំងឡាយតែងបាំងឆត្រលើជើងថ្ករ អ្នកទាំង ឡាយ ចូរជុតក្នុងខាងក្រោមនៃឆត្រចុះ ។

សាមញ្ញគុណ ខ្ញុំបានដល់ហើយ កិលេសទាំងឡាយ ខ្ញុំដុត ចោលហើយ ខ្ញុំមិនមានសេចក្តីក្តៅក្រហាយក្នុងមណ្ឌបឬទៀប គល់ឈើឡើយ ។ ក្នុងកប្បទី ៣ ម៉ឺន ក្នុងកាលនោះ ព្រោះ

ហេតុដែលខ្ញុំបានឲ្យទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃ
សព្វទាន ។ កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ។បេ។
ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់លាព្រះហស្តស្តាំចេញហើយ ត្រាស់នឹងកុលបុត្តនោះថា ចូរជាភិក្ខុចុះ ។ ក្នុងរវាងត្រាស់តម្រាស់នោះឯង យសបានជាអ្នកមានសក់និងពុកមាត់ត្រឹមតែ ២ ធ្នាប់ ទ្រទ្រង់នូវបរិក្ខារ ៨ ដូចព្រះថេរៈមានវស្សា ៦០ ។ ព្រះថេរៈពិចារណាបដិបទារបស់ខ្លួន កាលនឹងបន្លឺឧទាន បានពោលគាថាដោយសម្តែងរឿងអំពីដើមរហូតដល់ជាឯហិភិក្ខុថា

ខ្ញុំមានខ្លួនប្រោះព្រំល្អ ស្លៀកពាក់ល្អ ស្អិតស្អាងដោយគ្រឿង
ប្រដាប់គ្រប់យ៉ាង បាននូវវិជ្ជា ៣ ប្រការ ពុទ្ធសាសនាខ្ញុំក៏
បានធ្វើហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុវិលិត្តោ** សេចក្តីថា មានរាងកាយដែលលាបស្រឡាបហើយដោយឫសស្បូវភ្លាំង ចន្ទន៍ក្រហមដ៏ល្អ ។

បទថា **សុវសនោ** សេចក្តីថា ស្លៀកដណ្តប់ដោយសំពត់អ្នកដែនកាសីយ៉ាងល្អដែលមានតម្លៃថ្លៃ ។ បទថា **សព្វាភរណភូសិតោ** សេចក្តីថា ប្រដាប់ដោយអាភរណៈទាំងពួង មានគ្រឿងប្រដាប់ក្បាលជាដើម ។

បទថា **អជ្ឈគមឹ** បានដល់ បានសម្រេចហើយ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

**អដ្ឋកថា យសត្ថេរគាថា ចប់**

---

១-ក្នុងអបទានជាព្រះ សព្វទាយកត្ថេរ ។

## កិម្ពិលត្ថេរគាថា

[ ១១៩ ] វ័យ ( របស់សត្វ ) រមែងធ្លាក់ចុះ ហាក់ដូចជាត្រូវទេវតាបណ្តាញ រូប ( របស់យើង ) កាលមាននៅដោយប្រការដូច្នោះ តែហាក់ដូចជារូបអ្នកដទៃ ខ្លួនខ្ញុំនោះកាលមានពិត តែហាក់ដូចជាមិនមាន ខ្ញុំរឭកឃើញខ្លួន ( របស់ខ្ញុំ ) ហាក់ដូចជារឭកឃើញខ្លួនរបស់អ្នកដទៃដែរ ។

**កិម្ពិលត្ថេរ ។**

## អដ្ឋកថា

## កិម្ពិលត្ថេរគាថា

[ ១១៩ ] គាថារបស់ព្រះកិម្ពិលត្ថេរ មានពាក្យផ្តើមថា **អភិសត្តោវ និបតតិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ធ្វើបុណ្យទាំងឡាយទុកក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះ-មានព្រះភាគព្រះនាមថាកកុសន្ធៈ កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ កាលព្រះមានព្រះភាគបរិនិព្វានហើយបានធ្វើការបូជាដោយកម្រងផ្កាស្រស់ ដោយធ្វើជាមណ្ឌបឧទ្ទិសព្រះធាតុរបស់ព្រះសាស្តា ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ កើតក្នុងឋានតាវត្តិង្ស អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងសក្យ-រាជត្រកូលក្នុងនគរកបិលពស្តុមាននាមថាកិម្ពិលៈ ។ រាជកុមារកិម្ពិលៈចម្រើន

វ័យហើយសម្បូរដោយភោគសម្បត្តិ ។ ព្រះសាស្ដាគង់នៅត្រង់អនុបិយនគរ ទ្រង់ឃើញភាពចាស់ក្លានៃញាណ របស់កុលបុត្តនោះហើយ ដើម្បីឲ្យកើតសេចក្ដីសង្វេគ ទើបទ្រង់និម្មិតរូបស្រីតាំងនៅក្នុងវ័យក្រមុំ ល្អគួរគេយកគន់ ឲ្យប្រាកដចំពោះមុខ តមកធ្វើឲ្យដូចជាត្រូវសេចក្ដីវិនាសអំពីជរា និងរោគគ្របសង្កត់ ដោយលំដាប់ ។ កិម្ពិលកុមារឃើញដូច្នោះ កាលនឹងប្រកាសសេចក្ដីសង្វេគដ៏ខ្លាំងក្លា ទើបពោលគាថាថា

វ័យ ( របស់សត្វ ) រមែងធ្លាក់ចុះ ហាក់ដូចជាត្រូវទេវតា
បណ្ដេញ រូប ( របស់យើង ) កាលមាននៅ ដោយប្រការ
ដូច្នោះ តែហាក់ដូចជារូបអ្នកដទៃ ខ្លួនខ្ញុំនោះ កាលមានពិត
តែហាក់ដូចជាមិនមាន ខ្ញុំរឭកឃើញខ្លួន ( របស់ខ្ញុំ ) ហាក់
ដូចជារឭកឃើញខ្លួនរបស់អ្នកដទៃដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អភិសដ្ឋោវ** សេចក្ដីថា ដូចទេវតាបញ្ជាគឺបង្គាប់ថា ចូរកន្លងទៅដោយរហ័ស កុំបីយឺតយូរឡើយ ។ បាឋៈថា **អភិសដ្ឋោវ** ដូច្នេះក៏មាន អធិប្បាយថា ដូចត្រូវបុគ្គលណាមួយផ្ដាសាថា ចូរកន្លងទៅឲ្យឆាប់ ដូច្នេះ ។

បទថា **និបតតិ** សេចក្ដីថា រមែងរុះរោយ គឺប្រែប្រួលទៅដោយរហ័សមិនតាំងនៅបាន អធិប្បាយថា ដល់នូវការវិនាសទៅគ្រប់ៗខណៈ ។

បទថា **វយោ** បានដល់ ការប្រែប្រួលនៃរាងកាយ មានភាពជាកុមារកំលោះ ក្រមុំជាដើម តែក្នុងបទនេះ លោកពោលសំដៅដល់ភាពជាបុគ្គល

កំលោះក្រមុំនៃរាងកាយនោះ និងព្រោះភាពជាកំលោះក្រមុំ នៃរាងកាយនោះ ពេលស្ថិតស្រពោន ពេលបែកធ្លាយ ជារបស់ប្រាកដច្បាស់ ។

ព្រះថេរៈហៅនូវភាពបរិបូណ៌របស់រូបថា **រូប** សរីរៈឈ្មោះថា រូប ដូចក្នុងប្រយោគ ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ជាដើមថា អាកាសដែលអាស្រ័យឆ្អឹងខ្លះ អាស្រ័យសរសៃខ្លះ អាស្រ័យសាច់ខ្លះ អាស្រ័យស្បែកខ្លះ រួបរួមជាមួយគ្នាហើយ ទើបហៅថារូបបានដូច្នោះឯង ។

បទថា **អញ្ញមិវ តថេវ សន្តំ** បានដល់ រូបតាមដែលមាននេះ អធិប្បាយថា រូបនេះដែលមាន គឺប្រាកដយ៉ាងនោះឯង គឺដោយអាការនោះឯង រមែងប្រាកដដល់ខ្ញុំ ដូចជារបស់ដទៃ អាចារ្យពួកខ្លះពោលថា **តថេវ សន្តំ** ដូច្នេះក៏មាន ។

បទថា **តស្សេវ សតោ** បានដល់ រឭកដល់ខ្លួនរបស់ខ្ញុំនោះឯង ដែលមានមិនដូចអ្នកដទៃ ។

បទថា **អវិប្បវសតោ** សេចក្តីថា មិនទៅប្រាសចាកសតិ អធិប្បាយថា រូបទោះមិនប្រែប្រួលទៅជាដទៃ ព្រោះរស់នៅមកយូរ រមែងប្រាកដដល់ខ្ញុំដែលជាអ្នកមានសតិជារបស់ដទៃ សូម្បីរូបនេះក៏មិនមានក្នុងសរីរៈនេះ ។

បទថា **អញ្ញស្សេវ សរាមិ អត្តានំ** សេចក្តីថា ខ្ញុំរមែងរឭក គឺចូលទូទ្រង់ចាំ បានដល់ ដឹងច្បាស់នូវអត្តភាពរបស់ខ្ញុំនេះ ថាដូចអត្តភាពរបស់សត្វដទៃ ។ ការសង្វេគដ៏ខ្លាំងក្លាកើតឡើងហើយដល់កិម្ពិលកុមារនោះ ដែលដាក់ចិត្តដល់ភាពជារបស់មិនទៀងយ៉ាងនេះ កើតនូវសេចក្តីសង្វេគហើយចូល

គាល់ព្រះសាស្តា ស្តាប់ធម៌ហើយ មានសទ្ធា បួសហើយ ផ្តើមតាំងវិបស្សនា សម្រេចអរហត្តហើយ ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលព្រះកកុសន្ធៈ ទ្រង់បានបន្សាត់បាប បានអប់រំព្រហ្មចរិយធម៌ហើយទ្រង់បរិនិព្វានទៅ ខ្ញុំបានយកកម្រងផ្កាស្រល់មកធ្វើជាមណ្ឌប ។ ខ្ញុំបានទៅកើតក្នុងឋានតាវត្តិង្ស បាននូវវិមានដ៏ឧត្តម គ្របសង្កត់នូវទេវតាដទៃ នេះជាផលនៃបុញ្ញកម្ម ។ ខ្ញុំកាលដើរទៅមកក្តី ឈរក្តី ក្នុងវេលាថ្ងៃឬក្នុងវេលាយប់ ផ្កាស្រល់តែងគ្របបិទបាំងខ្ញុំ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បនេះឯង ព្រោះហេតុដែលខ្ញុំបានបូជានូវព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតចោលហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីកាត់ទន្ទឹង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[1] ។

ព្រះថេរៈសម្រេចអរហត្តហើយ កាលនឹងប្រកាសដល់ការធ្វើទុកក្នុងចិត្ត

---

១-ក្នុងអបទានជាព្រះ សលឡមណ្ឌបិយត្ថេរ ។

នូវអនិច្ចតាដែលកើតឡើងហើយក្នុងកាលមុនរបស់ខ្លួន បានពោលគាថានោះដដែលទៀត ដោយហេតុនោះ ទើបគាថានេះជាការព្យាករអរហត្តផលរបស់ព្រះថេរៈ ។

## អដ្ឋកថា កិម្ពិលត្ថេរគាថា ចប់

## វជ្ជីបុត្តត្ថេរគាថា

[ ១២០ ] អ្នកចូលទៅកាន់គល់ឈើនិងព្រៃញាតស្បាតហើយក្រសោប យកព្រះនិព្វាន ( មកដាក់ ) ក្នុងហឫទ័យបាន នៃគោតម អ្នកចូរពិនិត្យ ចុះកុំមានសេចក្តីប្រមាទឡើយ សេចក្តីរាយមាយចិត្តនឹងធ្វើអ្វីដល់អ្នកកើត ។

វជ្ជីបុត្តត្ថេរ ។

## អដ្ឋកថា

## វជ្ជីបុត្តត្ថេរគាថា

[ ១២០ ] គាថារបស់ព្រះវជ្ជីបុត្តត្ថេរ មានពាក្យផ្តើមថា **រុក្ខមូលគហនំ បសក្កិយ** ដូច្នេះ ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះ ពុទ្ធអង្គមុនៗ ជាអ្នកសន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភព នោះៗ ក្នុងកប្បទី ៩៤ រាប់អំពីភទ្ទកប្បនេះ ឃើញព្រះបច្ចេកពុទ្ធមួយអង្គ និមន្តបិណ្ឌបាត មានចិត្តជ្រះថ្លា ហើយបានប្រគេនផ្លែចេក ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក ធ្វើបុណ្យតៗមក អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះកើតជា រាជឱរសនៃស្តេចលិច្ឆវី ក្នុងក្រុងវេសាលីមាននាមថាវជ្ជីបុត្ត ព្រោះជាឱរស របស់ស្តេចវជ្ជី ។ កុលបុត្តនោះពេញកំលោះ ក្នុងកាលសិក្សាសិប្បៈ មាន សិប្បៈដំរីជាដើម ក៏ជាអ្នកមានអធ្យាស្រ័យបង្អោនទៅក្នុងផ្លូវផុតទុក្ខ ព្រោះជា

អ្នកសម្បូរដោយហេតុ ក្នុងកាលដែលព្រះសាស្តា សម្តែងធម្មទេសនា ចូលកាន់វិហារអន្តរយខាងចុងបរិស័ទស្តាប់ធម៌ហើយ បានទូវសទ្ធាបួសក្នុងសម្នាក់នៃព្រះសាស្តា ចម្រើនវិបស្សនាបានសម្រេចអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ព្រះមានព្រះភាគទ្រង់មានរស្មីច្រើន ត្រាស់ដឹងដោយព្រះអង្គឯង ទ្រង់ឈ្នះមារ ក្រោកចាកទីស្ងប់ស្ងាត់ ស្តេចចេញទៅដើម្បីគោចរ ។ ខ្ញុំមានដៃកាន់ផ្លែឈើ ឃើញព្រះនរាសភៈ ក៏ចូលទៅជិត ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយបានថ្វាយអវដផល ( ផ្លែឈើ ) ដល់ព្រះអង្គ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

---

១-ក្នុងអបទានជាព្រះ អវដផលិយត្ថេរ ។

កាលព្រះថេរៈសម្រេចអភិញ្ញា ៦ ហើយ ក្នុងកាលតមក ក្រោយអំពីព្រះសាស្តាទ្រង់បរិនិព្វានមិនយូរប៉ុន្មាន កាលព្រះថេរៈទាំងឡាយផ្ដើមសង្គាយនាព្រះធម៌ព្រះវិន័យ ស្នាក់នៅក្នុងទីផ្សេងៗ ថ្ងៃមួយឃើញព្រះអានន្ទនៅជាសេក្ខៈនោះឯងមានបរិស័ទធំចោមរោមហើយសម្ដែងធម៌កាលញ៉ាំងឧស្សាហៈឲ្យកើតដល់ព្រះអានន្ទនោះ ដើម្បីឲ្យបានសម្រេចមគ្គជាន់ខ្ពស់ ទើបពោលគាថាដូច្នេះថា

*អ្នកចូលទៅកាន់គល់ឈើនិងព្រៃញាតស្បាត ហើយក្រសោប*
*យកព្រះនិព្វាន ( មកដាក់ ) ក្នុងហឫទ័យបាន នៃគោតម*
*អ្នកចូរពិនិត្យចុះ កុំមានសេចក្តីប្រមាទឡើយ សេចក្ដីរាយ-*
*មាយចិត្តនឹងធ្វើអ្វីដល់អ្នកកើត ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **រុក្ខមូលគហនំ** បានដល់ ព្រៃដែលមានគល់ឈើ ព្រោះមានព្រៃតែមិនមានគល់ឈើក៏មាន មានគល់ឈើ តែមិនមានព្រៃក៏មាន ក្នុង ២ យ៉ាងនោះ ព្រះថេរៈសម្ដែងការមិនមានអន្តរាយអំពីខ្យល់និងកម្ដៅថ្ងៃ ព្រោះជាស្ថានទីមានស្រមោលនិងម្លប់ដោយសព្ទថា **រុក្ខ-មូល** សម្ដែងការមិនមានអន្តរាយអំពីខ្យល់ ព្រោះស្ងាត់ខ្យល់ និងសម្ដែងការមិនមានមហាជនច្រឡូកច្រឡំ ដោយសព្ទថា **គហនំ** ( ព្រៃញាតស្បាត ) និងសម្ដែងដល់ស្ថានទីដែលសមគួរដល់ការចម្រើនភាវនាដោយសព្ទទាំង ២ នោះ ។

បទថា **បសក្កិយ** ស្មើគ្នានឹង **ឧបគន្ត្វា** ប្រែថា ចូលទៅ ។ បទថា

**និព្វានំ ហទយស្មិំ ឱបិយ** សេចក្តីថា តាំងព្រះនិព្វានទុកក្នុងហទយៈ គឺធ្វើទុកក្នុងចិត្តថា បើអញបដិបត្តិយ៉ាងនេះ គប្បីសម្រេចព្រះនិព្វានបាន ។

បទថា **ឈាយ** សេចក្តីថា ចូរសម្ល័ងលក្ខណូបនិជ្ឈាន គឺចូរញ៉ាំងមគ្គភាវនាដែលប្រកបដោយវិបស្សនាភាវនាឲ្យចម្រើន ។ ព្រះថេរៈហៅព្រះអានន្ទដែលជាធម្មកណ្ឌាគារិកដោយគោត្តថា គោតម ។

បទថា **មា ច បមាទោ** សេចក្តីថា កុំដល់នូវការប្រមាទក្នុងអធិកុសលធម៌ទាំងឡាយ ។ ឥឡូវនេះ ព្រះថេរៈកាលសម្តែងការហាមសេចក្តីប្រមាទដែលព្រះអានន្ទត្ថេរមាន ទើបពោលថា **កឹ តេ ពិឡិពិឡិកា ករិស្សតិ** ដូច្នេះ ។

បទថា **ពិឡិពិឡិកា** ក្នុងបាទគាថានោះ បានដល់ កិរិយារាយមាយចិត្ត ។ ព្រះថេរៈបានឲ្យឱវាទថា សំឡេងដែលប្រព្រឹត្តទៅដោយការរាយមាយចិត្តតែងឥតប្រយោជន៍ យ៉ាងណា បញ្ញត្តគឺការសម្តែងចេញរបស់មហាជនដែលដូចជាការរាយមាយចិត្ត ក៏យ៉ាងនោះ នឹងធ្វើប្រយោជន៍អ្វីដល់លោកបាន គឺនឹងញ៉ាំងប្រយោជន៍អ្វីឲ្យសម្រេចដល់លោក ព្រោះហេតុនោះ បុគ្គលខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួន ទើបត្រូវលះបញ្ញត្តរបស់ពួកជនចេញ ។ ព្រះអានន្ទត្ថេរស្តាប់គាថាដែលជាឱវាទនោះហើយ កើតសេចក្តីសង្វេគដោយវាចាដែលព្រះថេរៈពោល ដែលដូចជាខ្យល់បក់យកក្លិនឈ្មុយឈ្ងប់មក ទើបញ៉ាំងពេលវេលាឲ្យកន្លងទៅ ដោយការដើរចង្ក្រម មួយយប់ទល់ភ្លឺ ចម្រើនវិបស្សនា ចូលទៅកាន់សេនាសនៈ គ្រាន់តែទម្រេតកាយលើគ្រែប៉ុណ្ណោះ ក៏

បានសម្រេចអរហត្ត ។

## អដ្ឋកថា វជ្ជីបុត្តត្ថេរគាថា ចប់

## ឥសិទត្តត្ថេរ

[ ១២១ ] ខន្ធទាំង ៥ មានឫសគល់ដាច់ ដែលខ្ញុំកំណត់ដឹងច្បាស់ហើយ ការអស់ទៅនៃទុក្ខខ្ញុំបានដល់ហើយ ការអស់ទៅនៃអាសវៈខ្ញុំក៏បានដល់ហើយដែរ ។

### ឥសិទត្តត្ថេរ ។

### ឧទ្ទាន

និយាយអំពីជេន្តត្ថេរ ១ វច្ឆគោត្តត្ថេរ ១ វនវច្ឆត្ថេរអ្នកមាននាមដ៏ប្រសើរ ១ អធិមុត្តត្ថេរ ១ មហានាមត្ថេរ ១ បារាបរិយត្ថេរ ១ យសត្ថេរ ១ កិម្ពិលត្ថេរ ១ វជ្ជីបុត្តត្ថេរ ១ ឥសិទត្តត្ថេរជាអ្នកមានយសធំ ១ ។

### ចប់ ទ្វាទសមវគ្គ ។

### ឧទ្ទានក្នុងឯកនិបាតនោះគឺ

ព្រះថេរៈ ១២០ អង្គ មានសោឡសកិច្ចធ្វើរួចហើយ ជាអ្នកមិនមានអាសវៈ ដែលព្រះសង្គីតិកាចារ្យអ្នកស្វែងរកនូវគុណធំ បានរួបរួមទុកដោយល្អក្នុងឯកនិបាត ។

### ចប់ ឯកនិបាត ។

# អដ្ឋកថា

## ឥសិទត្តត្ថេរគាថា

[ ១២១ ] គាថារបស់ព្រះឥសិទត្តត្ថេរ មានពាក្យផ្ដើមថា **បញ្ចក្ខន្ធា បរិញ្ញាតា** ដូច្នេះ ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ជាអ្នកសន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមថាវិបស្សី កើតក្នុងផ្ទះមានត្រកូលដល់នូវភាពជាអ្នកដឹងក្ដីហើយ ថ្ងៃមួយឃើញព្រះមានព្រះភាគ យាងតាមវិថី មានចិត្តជ្រះថ្លា បានថ្វាយផ្លែស្វាយមានរសឆ្ងាញ់ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវលោកធ្វើនូវបុណ្យតៗមក ហើយអន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតជាកូននាយរទេះក្នុងវឌ្ឍគាមដែនអវន្ដីមានឈ្មោះថាឥសិទត្ត ។ កុលបុត្តនោះចម្រើនវ័យហើយ បានជាសម្លាញ់កំបាំងមុខរបស់ចិត្តគហបតីក្នុងមច្ឆិកាសណ្ឌជនបទ បានទទួលសំបុត្រ ដែលចិត្តគហបតីសរសេរពណ៌នាពុទ្ធគុណបញ្ជូនទៅឲ្យកើតសេចក្ដីជ្រះថ្លាក្នុងព្រះសាស្ដា ទើបបួសក្នុងសម្នាក់នៃព្រះមហាកច្ចាយនត្ថេរ ប្រារព្ធវិបស្សនាហើយ បានជាអ្នកមានអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំបានឃើញនូវព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស គួរទទួល
នូវគ្រឿងបូជា ដែលទ្រង់កំពុងតែស្ដេចទៅតាមច្រក ហើយ
ប្រគេនផ្លែអមោរព្រឹក្ស ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះ

ហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈព្រោះបានកាត់ចំណងដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលសម្រេចអភិញ្ញា ៦ ហើយ គិតថា នឹងទៅកាន់ទីបម្រើរបស់ព្រះសម្ពុទ្ធ ទើបលាភិក្ខុចាស់ ហើយដើរទៅកាន់មជ្ឈិមប្រទេសដោយលំដាប់ចូលគាល់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង កាលព្រះសាស្តាធ្វើបដិសណ្ឋារៈដោយព្រះតម្រាស់ជាដើមថា ម្នាលភិក្ខុ យន្ត គឺសរីរៈ មានចក្រ ៤ មានទ្វារ ៩ ល្មមអត់ធន់បានដែរឬហ៎ ល្មមប្រព្រឹត្តទៅបានឬហ៎ ដូច្នេះ ។ កាលព្យាករអរហត្តផល ដោយមាតិកា ដែលតបនឹងព្រះតម្រាស់ដោយប្រកាសឲ្យទ្រង់ដឹងថា បពិត្រព្រះអង្គដ៏ចម្រើន ចាប់តាំងអំពីខ្ញុំព្រះអង្គបានទទួលដំណឹងរបស់ព្រះអង្គ ទុក្ខទាំងពួង របស់ខ្ញុំព្រះអង្គក៏ប្រាសទៅ អន្តរាយទាំងពួងក៏ស្ងប់រម្ងាប់ទៅ ដូច្នេះហើយ បានពោលគាថានេះថា

១-ក្នុងអបទានជាព្រះ អមោរផលិយត្ថេរ ។

ខន្ធទាំង ៥ មានឫសគល់ដាច់ ដែលខ្ញុំកំណត់ដឹងច្បាស់ហើយ ការអស់ទៅនៃទុក្ខខ្ញុំបានដល់ហើយ ការអស់ទៅនៃអាសវៈ ខ្ញុំក៏បានដល់ហើយដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បញ្ចក្ខន្ធា បរិញ្ញាតា** សេចក្តីថា ឧបាទានក្ខន្ធទាំង ៥ ខ្ញុំព្រះអង្គក៏កំណត់ដឹងហើយ ដោយប្រការទាំងពួង ដោយមគ្គប្បញ្ញាដែលប្រកបដោយវិបស្សនាបញ្ញាថា នេះទុក្ខ ទុក្ខមានប៉ុណ្ណេះ ទុក្ខក្រៅលែងជាងនេះមិនមានដូច្នេះ អធិប្បាយថា មិនមានទុក្ខណាមួយក្នុងបញ្ចក្ខន្ធទាំងនោះដែលត្រូវកំណត់ដឹង ។

បទថា **តិដ្ឋន្តិ ឆិន្នមូលកា** សេចក្តីថា ទុក្ខទាំងនោះ រមែងតាំងនៅរហូតចិត្តដួងចុងក្រោយរលត់ ព្រោះទុក្ខទាំងនោះ ខ្ញុំព្រះអង្គកំណត់ដឹងហើយដោយប្រការទាំងពួង គឺព្រោះមូលនៃកិលេស មានអវិជ្ជានិងតណ្ហាជាដើម ដែលខ្ញុំព្រះអង្គកាត់ផ្តាច់ហើយ បានដល់ ព្រោះហេតុនៃទុក្ខដែលខ្ញុំព្រះអង្គលះបានហើយ ដោយអរិយមគ្គ ។

បទថា **ទុក្ខក្ខយោ អនុប្បត្តោ** សេចក្តីថា ការអស់ទៅ គឺការអស់ទៅនៃវដ្តទុក្ខ ឈ្មោះថាខ្ញុំព្រះអង្គដល់ហើយដោយលំដាប់ ព្រោះភាពនៃទុក្ខទាំងនោះ មានឫសគល់ដែលខ្ញុំព្រះអង្គផ្តាច់ផ្តិលហើយ បានដល់ ព្រះនិព្វានដែលខ្ញុំព្រះអង្គសម្រេចហើយ ។

បទថា **បត្តោ មេ អាសវក្ខយោ** សេចក្តីថា អរហត្ត ឈ្មោះថា មានឈ្មោះដែលបានហើយថា ការអស់ទៅនៃអាសវៈ ព្រោះជាផលដែលព្រះ-

អរិយបុគ្គលគប្បីបានក្នុងទីបំផុតនៃការអស់ទៅនៃអាសវៈទាំងឡាយ មានកាមាសវៈជាដើម ដែលខ្ញុំព្រះអង្គ សម្រេចហើយ អធិប្បាយថា បានចំពោះហើយ ។ ឯអាចារ្យពួកខ្លះពោលថា **អន្តិមាយំ សមុស្សយោ** ប្រែថា រាងកាយនេះជារាងកាយចុងក្រោយក៏មាន អធិប្បាយថា រាងកាយ គឺអត្តភាពនៃខ្ញុំព្រះអង្គនេះ ឈ្មោះថាមានក្នុងទីបំផុត គឺជាកពចុងក្រោយ របស់កពទាំងពួង ព្រោះភាពដែលព្រះនិព្វានខ្ញុំព្រះអង្គសម្រេចហើយ នោះឯង ។

ពាក្យណាដែលខ្ញុំមិនបានពោលទុកក្នុងបទនោះៗ ពាក្យនោះងាយយល់ទាំងអស់ហើយ ព្រោះមានន័យដូចខ្ញុំពោលហើយខាងដើមនោះឯង ។

***អដ្ឋកថា ឥសីទត្តត្ថេរគាថា ចប់***

***វគ្គទី ១២ ចប់***

***ឯកនិបាតប្រដាប់ដោយគាថា ១២០ ចប់***

# ឯកនិបាត

# ថេរគាថា ឯកនិបាត

## បឋមវគ្គ

### ឧត្តរត្ថេរគាថា

[ ១២២ ] *ភពនីមួយជាសភាពទៀងទាត់មិនមានទេ សូម្បីសង្ខារទាំងឡាយជាសភាពទៀងទាត់ក៏មិនមាន ខន្ធទាំងឡាយនោះរមែងកើតឡើង ច្យុតទៅមកៗ ។ ខ្ញុំបានដឹងច្បាស់នូវទោសនុ៎ះហើយ ជាអ្នកមិនត្រូវការដោយភពទេ បានរលាស់ចាកកាមទាំងពួងហើយ ការអស់ទៅនៃអាសវៈខ្ញុំក៏បានដល់ហើយ ។*

*ឮថា ឧត្តរត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងឡាយ ដោយប្រការដូច្នេះ ។*

# ថេរគាថា ឯកនិបាត

## វគ្គទី ១

### អដ្ឋកថា ឧត្តរត្ថេរគាថា

[ ១២២ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងឯកនិបាតដូច្នេះថា*

*គាថាព្រះឧត្តរត្ថេរ មានពាក្យផ្តើមថា* **នត្ថិ កោចិ ភវោ និច្ចោ** *ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។*

ព្រះថេរៈនោះ ក៏មានអធិការដែលធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគព្រះនាមថា សុមេធៈ កុលបុត្តនោះកើតជាពិទ្យាធរត្រាច់ទៅក្នុងអាកាស ។

សម័យនោះ ព្រះសាស្តាកាលអនុគ្រោះ ទើបបញ្ចេញឆព្វណ្ណរង្សី គង់ក្រោមដើមឈើមួយដើមក្នុងព្រៃ ។ កុលបុត្តនោះ ហោះទៅដោយអាកាស ឃើញព្រះដ៏មានព្រះភាគ មានចិត្តជ្រះថ្លា ចុះអំពីអាកាស បូជាព្រះដ៏មានព្រះភាគដោយផ្កាកណិការដ៏ស្អាតបរិសុទ្ធបរិបូណ៌ ដោយពុទ្ធានុភាព ផ្កាទាំងឡាយតាំងនៅខាងលើព្រះសាស្តា ដោយអាការៈដូចឆត្រ ដោយពុទ្ធានុភាពនោះ ធ្វើឲ្យពិទ្យាធរមានចិត្តជ្រះថ្លាក្រៃលែងពន់ប្រមាណ ។ តមកធ្វើកាលកិរិយាហើយកើតក្នុងឋានតាវត្តិង្ស សោយទិព្វសម្បត្តិដ៏ឧឡារ តាំងនៅក្នុងភពតាវត្តិង្សដរាបដល់អស់អាយុ បន្ទាប់អំពីនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយក្នុងពុទ្ធុប្បាទកាលនេះ កើតជាបុត្តរបស់ព្រាហ្មណមហាសាលក្នុងនគររាជគ្រឹះបាននាមថាឧត្តរៈ ។ កុលបុត្តនោះដល់នូវភាពជាអ្នកដឹងក្តីសិក្សាសម្រេចក្នុងវិជ្ជារបស់ព្រាហ្មណ៍ទាំងឡាយហើយ ជាអ្នកកើតមក ធ្វើលោកឲ្យចម្រើនដោយរូប ដោយវិជ្ជា ដោយវ័យ និងដោយមារយាទ ។ មហាមាត្យ អ្នកដែនមគធៈ ឈ្មោះវស្សការ ឃើញគុណសម្បត្តិរបស់កុលបុត្តនោះហើយជាអ្នកមានបំណងនឹងលើកធីតាឲ្យកុលបុត្តនោះ ប្រាប់បំណងរបស់ខ្លួនហើយ កុលបុត្តនោះ បដិសេធនូវបំណងល្អនោះ ព្រោះភាពជាអ្នកមានអធ្យាស្រ័យ

ក្នុងការរលាស់ចេញចាកកព មាណពនោះ ចូលទៅរកព្រះធម្មសេនាបតីម្តង
ម្កាល ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះថេរៈ តាមកាលវេលាដែលសមគួរបាន
ជាអ្នកមានសទ្ធាបួសហើយ ជាអ្នកបរិបូណ៌ដោយវត្តរង់ចាំបដិបត្តិព្រះថេរៈ ។

សម័យនោះ អាពាធណាមួយកើតដល់ព្រះថេរៈ ដើម្បីនឹងធ្វើថ្នាំប្រគេន
ព្រះថេរៈ ឧត្តរសាមណេរ ទើបកាន់យកបាត្រ ចីវរ ចេញអំពីវិហារទៅអំពី
ព្រលឹមនោះឯង ក្នុងរវាងផ្លូវដាក់បាត្រទុកត្រង់ប្រាំងទន្លេ ដើរទៅរកទឹកដែល
នៅក្នុងទីជិតហើយលុបមុខ ។ លំដាប់នោះ ចោរជីកឧម្មង្គត្រូវក្នាក់ងាររក្សា
នគរដេញតាម គេចអំពីព្រះនគរ តាមទ្វារដែលបើកក្នុងពេលព្រឹកនោះឯង
ហើយយកកញ្ចប់រតនៈដែលខ្ទនលួចមកដាក់ក្នុងបាត្រ របស់សាមណេរហើយ
គេចទៅ ។

សាមណេរដើរចូលទៅក្បែរបាត្រ ពួករាជបុរសដែលដេញតាមចោរមក
ឃើញទ្រព្យក្នុងបាត្ររបស់សាមណេរ ទើបពោលថា សាមណេរនេះជាចោរ
សាមណេរនេះប្រព្រឹត្តជាចោរ ហើយចាប់សាមណេរចងដៃក្រពាត់ស្លាបសេក
បញ្ជូនឲ្យដល់វស្សការព្រាហ្មណ៍ ។ ក្នុងកាលណោះ វស្សការព្រាហ្មណ៍បាន
ទទួលតំណែងជាអ្នកវិនិច្ឆ័យក្តីរបស់ព្រះរាជា អាចដាក់ទោសប្រហារនិងធ្វើទា-
រុណកម្មបាន ។ គាត់មិនវិនិច្ឆ័យក្តីឡើយ ប្រើឲ្យយកឈើស្រួចដោតសាម
ណេរទាំងរស់ ព្រោះចងអាឃាតថា កាលមុនសាមណេរ មិនអើពើនូវពាក្យ
របស់អញ ទៅបួសក្នុងលទ្ធិរបស់បុគ្គលមិច្ឆាទិដ្ឋិសុទ្ធៗ ។ លំដាប់នោះ ព្រះ
ដ៏មានព្រះភាគ ទ្រង់ប្រមើលមើលការចាស់ដោយជុំវិញនៃញាណរបស់ឧត្តរ

សាមណេរហើយយាងទៅទីនោះ ទ្រង់ដាក់ព្រះហស្តដែលមានព្រះអង្គុលីវែង ទន់គ្របដណ្តប់ដោយរស្មីដូចផ្ការមាស ពណ៌ក្រហមតាមធម្មជាតិ ដែលកំពុងហូរព្រោះប្រកបដោយរស្មីពណ៌ស ធៀលច្ចាត់ដោយពន្លឺ នៃកែវមណីត្រង់ម្រាមព្រះហស្ត លើសីសៈរបស់ឧត្តរសាមណេរ ហើយត្រាស់ថា ម្នាលឧត្តរៈ នេះជាផលរបស់កម្មចាស់កើតឡើងហើយដល់អ្នក អ្នកត្រូវធ្វើនូវការអត់ធន់ដោយកម្លាំងនៃការពិចារណាក្នុងផលនៃកម្មនោះ ដូច្នេះហើយ ទ្រង់សម្តែងធម៌ តាមសមគួរដល់អធ្យាស្រ័យ ឧត្តរសាមណេរ បាននូវបីតិនិងបាមោជ្ជៈដ៏ឧឡារ ព្រោះភាពជាអ្នកមានសេចក្តីជ្រះថ្លានិងសោមនស្សដែលកើតអំពីសម្ផស្សនៃព្រះហស្តរបស់ព្រះសាស្តា ដូចគ្នានឹងស្រោចដោយទឹកអម្រឹតឡើងកាន់វិបស្សនាមគ្គតាមដែលសន្សំទុក ញ៉ាំងកិលេសទាំងពួង ឲ្យអស់ទៅហើយ តាមលំដាប់នៃមគ្គ ក្នុងវេលានោះឯងព្រោះញាណចាស់ក្លា និងព្រោះលម្អនៃទេសនារបស់ព្រះសាស្តា ទើបបានសម្រេចអភិញ្ញា ៦ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះសម្ពុទ្ធព្រះនាមសុមេធៈ មានព្រះលក្ខណៈ ៣២ ដ៏ប្រសើរ
មានសេចក្តីប្រាថ្នាក្នុងការស្ងប់ស្ងាត់ទ្រង់ត្រាស់ដឹងដោយប្រពៃ
បានស្តេចចូលទៅក្នុងព្រៃហិមពាន្ត ។ ព្រះមហាមុនី ទ្រង់ជា
ចម្បង ជាបុរសខ្ពង់ខ្ពស់ ប្រកបដោយសេចក្តីករុណា ស្តេច
ចុះកាន់ព្រៃហិមពាន្ត ហើយទ្រង់គង់ផ្គត់ព្រះភ្នែន ។ កាលនោះ
ខ្ញុំកើតជាពិជ្យាធរ ជាអ្នកត្រាច់ទៅក្នុងអាកាស កាន់ច្បូកដែល

ធ្វើល្អហើយ បានហោះទៅឰដ៏អាកាស ក្នុងកាលនោះ ។ ព្រះសម្ពុទ្ធ ព្រះអង្គភ្លឺរុងរឿងក្នុងព្រៃ ដូចភ្លើងលើកំពូលភ្នំ ឬដូចព្រះចន្ទពេញបូណ៌មី ពុំនោះសោត ដូចស្តេចឈើដែលមានផ្ការីកស្គុះស្គាយ ។ ខ្ញុំចេញអំពីព្រៃបានឃើញរស្មីព្រះពុទ្ធដែលផ្សាយចេញ ដូចពណ៌ភ្លើងដែលឆេះបបុស ហើយក៏ញ៉ាំងចិត្តឲ្យជ្រះថ្លា ។ ខ្ញុំកំពុងតែជ្រើសរើសផ្កាក៏បានឃើញផ្កាកណិការមានក្លិនក្រអូបដូចក្លិនទិព្វ ហើយបាននាំយកផ្កា ៣ ទង ទៅបូជាព្រះសម្ពុទ្ធដ៏ប្រសើរ ។ ដោយអានុភាពនៃព្រះពុទ្ធ ផ្កាទាំង ៣ ទង របស់ខ្ញុំក្នុងកាលនោះមានទងឡើងលើ មានត្របកចុះក្រោម ធ្វើជាម្លប់បាំងថ្វាយព្រះសាស្តា ។ ដោយអំពើដែលធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ វិមានដែលកុសលសាងសម្រាប់ខ្ញុំក្នុងទីនោះ មានកម្ពស់ ៦០ យោជន៍ ទទឹង ៣០ យោជន៍ ពួកទេវតាតែង ស្គាល់ថា កណិការវិមាន ។ ប្រាសាទមានកម្ពស់មួយពាន់សន្ទុះព្រួញមានជាន់ ៧ បរិបូណ៌ដោយទង់ជាវិការៈនៃកែវមណី មានពណ៌ខៀវ ផ្ទះកំពូលមួយសែនមានប្រាកដក្នុងវិមានរបស់ខ្ញុំ ។ បល្ល័ង្កជាវិការៈនៃមាសក៏មាន ជាវិការៈកែវមណីក៏មាន ជាវិការៈនៃកែវទទឹមក៏មាន ជាវិការៈនៃកែវផលិកក៏មាន គួរតាម

ប្រាថ្នា គួរតាមបំណង ។ មួយទៀត ទីដេកមានតម្លៃច្រើន ដែលញាត់ដោយគរ ធ្វើដោយរោមសត្វ វិចិត្រដោយរោមសត្វ មានរោមសត្វសីហៈ និងខ្លាធំជាដើម ធ្វើដោយរោមសត្វមានរោមប្រាងឡើងតែម្ខាងជាកម្រាលសមគួរដល់ខ្ញុំយ ។ កាលណាខ្ញុំចេញអំពីលំនៅហើយត្រាច់ទៅកាន់ទេវចរិក ប្រាថ្នានឹងទៅ តែងមានពួកទេវតាចោមរោម ។ ខ្ញុំឋិតនៅខាងក្រោមផ្កាផ្កាប្រក់ខាងលើខ្ញុំ ទីមួយរយយោជន៍ជុំវិញ សុទ្ធសឹងបិទបាំងដោយផ្កាកណិការ ។ តូរ្យតន្ត្រី ៦ ម៉ឺន មកបម្រើខ្ញុំរាល់ល្ងាចព្រឹក ជាអ្នកមិនខ្ជិលច្រអូសទាំងយប់ទាំងថ្ងៃ តែងចោមរោមខ្ញុំជានិច្ច ។ ខ្ញុំត្រេកអរដោយរបាំ ចម្រៀង គ្រឿងដេញដំ និងគ្រឿងប្រគំ ក្នុងវិមាននោះ ខ្ញុំមានសេចក្តីប្រាថ្នាក្នុងកាម តែងរីករាយក្នុងតម្រេកនៃល្បែង ។ ខ្ញុំបរិភោគក្តី ផឹកក្តីក្នុងទីនោះតែងរីករាយក្នុងឋានត្រៃត្រិង្សក្នុងកាលនោះខ្ញុំប្រកបដោយពួកនារី រីករាយក្នុងវិមានដ៏ឧត្តម ។ ខ្ញុំសោយរាជ្យក្នុងឋានទេវលោក អស់ ៥០០ ដង បានជាស្តេចចក្រពត្តិ អស់ ៣០០ ដង ។ សោយប្រទេសរាជ្យដ៏ធំទូលាយ រាប់ជាតិមិនអស់ខ្ញុំកាលអន្ទោលទៅ ក្នុងភពតូចភពធំ តែងបាននូវភោគសម្បត្តិច្រើន ។ ខ្ញុំមិនមានសេចក្តីខ្វះខាតដោយភោគសម្បត្តិ នេះជាផលនៃពុទ្ធបូជា ខ្ញុំតែងអន្ទោលទៅក្នុងភពពីរ គឺទេវតានិង

មនុស្ស ។ ខ្ញុំមិនដែលស្គាល់គតិដទៃទេនេះជាផលនៃពុទ្ធបូជា ខ្ញុំតែងកើតក្នុងត្រកូល ២ គឺត្រកូលក្សត្រ និងត្រកូលព្រាហ្មណ៍ ។ ខ្ញុំមិនកើតក្នុងត្រកូលទាប នេះជាផលនៃពុទ្ធបូជា ខ្ញុំតែងបាននូវយានទាំងអស់នេះ គឺយានដំរី យានសេះ ព្រះសាលៀង រថទ្រង់គ្រឿង នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំតែងបាននូវរបស់ទាំងអស់នេះ គឺ ខ្ញុំស្រី ខ្ញុំប្រុស នារីដែលមានគ្រឿងតាក់តែងសមរម្យ នេះជាផលនៃពុទ្ធបូជា ខ្ញុំតែងបាននូវសំពត់ទាំងអស់នេះ គឺសំពត់កោសេយ្យពស្ត្រ សំពត់កម្ពលសំពត់ខោមពស្ត្រនិងសំពត់កប្បាសិកពស្ត្រ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំតែងបាននូវវត្ថុទាំងអស់នេះ គឺសំពត់ថ្មី ផ្លែឈើថ្មី ភោជនមានរសដ៏ប្រសើរថ្មី នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំតែងបាននូវពាក្យពីរោះ ទាំងអស់នេះថា សូមអ្នកពិសានូវភោជនទាំងនេះ សូមបរិភោគភោជនទាំងនេះ សូមសម្រាន្តលើដំណេកនេះ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំមានគេបូជាក្នុងទីទាំងពួងយស ( កេរ្តិ៍ឈ្មោះ ) របស់ខ្ញុំខ្ពរខ្ពាយទៅក្នុងទិសទាំងពួង ។ ខ្ញុំមានសក្តិធំសព្វកាល មានបរិស័ទមិនបែកបាក់សព្វកាល ខ្ញុំជាបុរសឧត្តមជាងពួកញាតិ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំមិនដែលស្គាល់ត្រជាក់និងក្តៅ ឯសេចក្តីក្តៅក្រហាយ ក៏មិនមានទាំងសេចក្តីទុក្ខព្រួយក្នុងចិត្ត ក៏មិនមានក្នុងហឫទ័យរបស់ខ្ញុំ ។

ខ្ញុំជាអ្នកមានសម្បុរដូចមាស តែងអន្ទោលទៅ ក្នុងភពតូចភពធំខ្ញុំមិនដែលស្គាល់ភាពពណ៌អាក្រក់នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំច្យុតចាកទេវលោក ត្រូវកុសលមូលដាស់តឿន បានមកកើតក្នុងបុរីសាវត្ថី ក្នុងត្រកូលមហាសាល ជាត្រកូលស្តុកស្តម្ភមាំមួន ។ ខ្ញុំលះបង់កាមគុណទាំង ៥ ហើយចូលទៅកាន់ផ្នួស ខ្ញុំមានអាយុ ៧ ឆ្នាំ រាប់អំពីកំណើតមក បានដល់អរហត្ត ។ ព្រះសម្ពុទ្ធទ្រង់មានចក្ខុ ជ្រាបច្បាស់នូវគុណរបស់ខ្ញុំ បានឲ្យឧបសម្បទាដល់ខ្ញុំ ខ្ញុំជាមនុស្សក្រំលោះ គួរដល់ការបូជា នេះជាផលនៃពុទ្ធបូជា ។ ចក្ខុរបស់ខ្ញុំដ៏បរិសុទ្ធដូចជាទិព្វ ខ្ញុំជាអ្នកឈ្លាសវៃក្នុងសមាធិ ដល់នូវត្រើយនៃអភិញ្ញា នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ខ្ញុំបានសម្រេចដោយលំដាប់ ខ្ញុំជាអ្នកឈ្លាសវៃក្នុងឥទ្ធិបាទ បានដល់ត្រើយក្នុងព្រះសទ្ធម្ម នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៣ មុនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះសម្ពុទ្ធក្នុងកាលនោះខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១]។

ឧត្តរសាមណេរជាអ្នកមានអភិញ្ញា ៦ ក្រោកឡើងអំពីឈើអណ្តាត

---

១-ក្នុងអបទានជាព្រះ តីណិកណិការបុប្ផិយត្ថេរ ។

ហើយឈរក្នុងអាកាសសម្តែងបាដិហារ្យ ដោយអនុគ្រោះក្នុងអ្នកដទៃ មហាជនបានកើតអស្ចារ្យក្នុងចិត្ត ។ មុខរបួសរបស់លោកបានជាសះស្បើយក្នុងរំពេចនោះឯង ។ លោកត្រូវភិក្ខុទាំងឡាយសួរថា អាវុសោ លោកសោយទុក្ខដូច្នោះអាចព្យាយាមក្នុងវិបស្សនាបានដូចម្តេច កាលសម្តែងឲ្យជ្រាបថា អាវុសោ នឹងពោលថ្វីដល់ទោសក្នុងសង្សាររបស់ខ្ញុំ ឯអ្នកទាំងឡាយ ឃើញសភាវៈរបស់សង្ខារល្អហើយមិនមែនឬដូច្នោះ ទោះបីខ្ញុំបានទទួលទុក្ខ មានសភាពបែបនោះក៏អាចចម្រើនវិបស្សនា ហើយសម្រេចអរហត្តបាន ទើបពោលគាថាពីរថា

ភពទីមួយ ជាសភាពទៀងទាត់មិនមានទេ សូម្បីសង្ខារទាំង-
ឡាយជាសភាពទៀងទាត់ក៏មិនមាន ខន្ធទាំងឡាយនោះ រមែង
កើតឡើង ច្យុតទៅមកៗ ។ ខ្ញុំបានដឹងច្បាស់នូវទោសនុ៎ះ
ហើយ ជាអ្នកមិនត្រូវការដោយភពទេ បានរលាស់ចាកកាម
ទាំងពួងហើយ ការអស់ទៅនៃអាសវៈ ខ្ញុំក៏បានដល់ហើយ ។

បណ្តាបទទាំងនោះ បទថា **ឧត្តិ កោចិ ភវោ និច្ចោ** សេចក្តីថា ភពទាំងឡាយចែកប្រភេទចេញទៅយ៉ាងនេះ គឺ កម្មភព ឧបបត្តិភព កាមភព រូបភព អរូបភព សញ្ញីភព អសញ្ញីភព នេវសញ្ញីនាសញ្ញីភព ឯកវោការភព ចតុវោការភព បញ្ចវោការភព ។ ក្នុងបណ្តាភពទាំងនោះ ភពណាមួយដែលចែកចេញទៅយ៉ាងនេះថា អាក្រក់ កណ្តាល ឧក្រិដ្ឋ មានអាយុវែង ច្រើនទៅដោយសេចក្តីសុខ មានសុខនិងទុក្ខលាយឡំគ្នាដូច្នេះ នឹងទៀង ឋិតថេរ

មាំទាំ មិនបែកធ្លាយមិនមានឡើយ ព្រោះត្រូវអាស្រ័យហេតុនោះៗ ទើបកើតឡើងបាន ប្រកបសេចក្តីថា ព្រោះហេតុនោះ សភាពបែបនោះឯង សង្ខារទាំងឡាយ ឈ្មោះថា ទៀងមិនមានឡើយ ។

សង្ខារទាំងឡាយនោះឯង ឈ្មោះថាជារបស់កើតហើយ ដោយការកំណត់ចំណាំ សម្មតិថាភព ព្រោះអាស្រ័យបញ្ចក្ខន្ធដែលបាននាមថាសង្ខារ ព្រោះបច្ច័យទាំងឡាយតាក់តែងហើយ រមែងប្រែប្រួលទៅ ព្រោះជរានិងមរណៈ ព្រោះហេតុនោះ ទើបឈ្មោះថាមិនទៀង មានការប្រែប្រួលទៅជាធម្មតា ពិតយ៉ាងនោះ ទើបបរិណាមធម៌ទាំងនោះលោកពោលថាសង្ខារ ដោយហេតុនោះ ទើបព្រះថេរៈពោលថា ខន្ធទាំងឡាយនោះ រមែងកើតឡើងច្យុតទៅមកៗ អធិប្បាយថា បញ្ចក្ខន្ធដែលលោកពោលទុកដោយបរិយាយនៃភព និងដោយបរិយាយនៃសង្ខារទាំងនោះរមែងវិលកើតទៅតាមបច្ច័យ និងកើតហើយ ត្រូវជរាបៀតបៀន គ្របសង្កត់ រមែងឃ្លាត គឺ បែកធ្លាយទៅ ។

ដោយបទថា **ឧបជ្ជន្តិ ច តេ ខណ្ធា ចវន្តិ អបរាបរំ** នេះ ព្រះថេរៈសម្តែងអត្ថថា បញ្ចក្ខន្ធដែលបានឈ្មោះថាភពក្តី សង្ខារក្តី មានការកើតឡើងនិងវិនាសទៅជាសភាវៈ ព្រោះកាលព្រះយោគាវចរ លើកបញ្ចក្ខន្ធឡើងកាន់ត្រៃលក្ខណ៍ ពិចារណាសង្ខារទាំងឡាយ ភពទាំង ៣ រមែងប្រាកដច្បាស់ដូចត្រូវភ្លើងដុតហើយ សង្ខារទាំងឡាយដែលព្រះយោគាវចរដឹងអាទីនវៈ គឺទោសក្នុងបញ្ចក្ខន្ធដែលបច្ច័យតាក់តែង ដោយវិបស្សនាញាណ ទើបឃើញទោសជាអនិច្ចលក្ខណៈ រមែងប្រាកដច្បាស់ភាពជាទុក្ខនិងអនត្តា ជាក់ច្បាស់

ក្រៃលែងឡើង ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ធម៌ណាមិនទៀង ធម៌នោះជាទុក្ខ ធម៌ណាជាទុក្ខ ធម៌នោះជាអនត្តា ។

ព្រោះកាលព្រះយោគាវចរ លើកបញ្ចក្ខន្ធឡើងកាន់ត្រៃលក្ខណ៍ ហើយពិចារណាសង្ខារទាំងឡាយ ភពទាំង ៣ រមែងប្រាកដជាមានភ័យចំពោះមុខដូចផ្ទះដែលត្រូវភ្លើងឆេះដូច្នោះ ទើបព្រះថេរៈពោលថា **ភវេឧម្ហិ អឧត្តិកោ** ដូច្នេះ ។ ប្រកបសេចក្តីថា សូម្បីកលមាយាក្នុងកាមទាំងឡាយ រមែងមិនកើតឡើងដល់បុគ្គលដែលធ្វើខ្លួនឲ្យវិលត្រឡប់ចាកភពទាំងឡាយបាន ដោយប្រការទាំងពួងយ៉ាងនេះ ដោយហេតុនោះ ទើបព្រះថេរៈពោលថា **ឆិស្សដោ សព្វកាមេហិ** បានលះចាកកាមទាំងពួងហើយ ដូច្នេះ អធិប្បាយថា ខ្ញុំជាបុគ្គលមានចិត្តវិលត្រឡប់ចាកកាមទាំងឡាយជាទិព្វដូចជារបស់មនុស្ស ។

បទថា **បត្តោ មេ អាសវក្ខយោ** សេចក្តីថា ព្រោះហេតុដែលខ្ញុំជាបុគ្គលមានសង្ខារដែលកម្ចាត់ល្អហើយ ឃើញទោសក្នុងភពទាំងឡាយ ដោយជាក់ច្បាស់ និងមានចិត្តមិនជាប់ជំពាក់ក្នុងកាមទាំងឡាយដូច្នោះ សូម្បីខ្ញុំអង្គុយលើលំពែង ខ្ញុំក៏បានសម្រេច គឺដល់នូវការអស់ទៅនៃអាសវៈ បានដល់ព្រះនិព្វាន និងអរហត្តផល ។ ព្រះថេរៈបានឲ្យឱវាទដល់ភិក្ខុទាំងឡាយថា សព្រហ្មចារីទាំងឡាយដទៃ ដែលមានចិត្តមិនទាន់ដល់នូវការអស់ទៅនៃអាសវៈ គប្បីធ្វើឧស្សាហៈដើម្បីសម្រេចនូវការអស់ទៅនៃអាសវៈ ។

**អដ្ឋកថា ឧត្តរត្ថេរគាថា ចប់**

## បិណ្ឌោលភារទ្វាជត្ថេរគាថា

[ ១២៣ ] ជីវិត ( របស់ខ្ញុំ ) នេះ រមែងមិនមាន ព្រោះការមិនប្រព្រឹត្តទៅ អាហារមិនមែនធ្វើឲ្យស្ងប់ដល់ហឫទ័យបានទេ គ្រោងកាយតាំងនៅបានដោយអាហារ ខ្ញុំប្រព្រឹត្តនូវការស្វែងរក ព្រោះឃើញដូច្នេះ ។ ការសំពះនិងការបូជាណាដែលមានក្នុងត្រកូលទាំងឡាយ បណ្ឌិតទាំងឡាយបានពោលនូវការសំពះនិងបូជានោះថា ដូចជាភក់ សរ គឺកិលេសដ៏ល្អិត គេដកបានដោយក្រ សក្ការៈក៏បុរសអាក្រក់លះបានដោយក្រ ។

ឮថា បិណ្ឌោលភារៈទ្វាជត្ថេរដ៏មានអាយុ បានសម្ដែងនូវគាថាទាំងឡាយដោយប្រការដូច្នេះ ។

## អដ្ឋកថា

## បិណ្ឌោលភារទ្វាជត្ថេរគាថា

[ ១២៣ ] គាថារបស់ព្រះបិណ្ឌោលភារទ្វាជត្ថេរ មានពាក្យផ្ដើមថា **នយិទំ អនយេន** ដូច្នេះ ។ រឿងរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះថេរៈនេះ ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ព្រះនាមថា បទុមុត្តរៈ កើតក្នុងកំណើតរាជសីហ៍ អាស្រ័យក្នុងគុហាភ្នំ ។ ក្នុងវេលាដែលរាជសីហ៍ចេញទៅរកស៊ី ព្រះដ៏មានព្រះភាគយាងទៅកាន់គុហាដែលជាទីដេករបស់រាជសីហ៍នោះ ដើម្បីអនុគ្រោះ ទ្រង់គង់ចូលនិរោធសមាបត្តិហើយ រាជសីហ៍ពាំដុំសាច់ត្រឡប់មក ឃើញព្រះដ៏មានព្រះភាគត្រង់ទ្វារគុហា ជាអ្នក

មានចិត្តត្រេកអរ ធ្វើការបូជាដោយផ្កាដែលកើតក្នុងទឹក និងផ្កាដែលកើតលើគោក ធ្វើចិត្តឲ្យជ្រះថ្លា បន្លឺសីហនាទ ៣ ដង ដើម្បីឲ្យសត្វសាហាវគេចទៅ ដើម្បីធ្វើការរក្សាព្រះដ៏មានព្រះភាគ បានឈរគាល់ ដោយមានពុទ្ធានុស្សតិជាអារម្មណ៍ បូជាព្រះដ៏មានព្រះភាគអស់ ៧ ថ្ងៃ ដូចបូជាក្នុងថ្ងៃដំបូង ។

លុះកន្លងទៅ ៧ ថ្ងៃ ព្រះដ៏មានព្រះភាគទ្រង់ចេញអំពីនិរោធសមាបត្តិ ទ្រង់ព្រះតម្រិះថា ប៉ុណ្ណេះល្មមជាឧបនិស្ស័យដល់រាជសីហ៍នេះហើយ កាលរាជសីហ៍កំពុងឃើញនោះឯង ក៏ហោះទៅកាន់អាកាស យាងទៅកាន់វិហារ ។ រាជសីហ៍មិនអាចអត់សង្កត់សេចក្តីទុក្ខ ដែលកើតអំពីការព្រាត់ប្រាសចាកព្រះសម្ពុទ្ធ ធ្វើកាលកិរិយាហើយដូចដីវិបាលិលេយ្យកៈ កើតក្នុងត្រកូលគហបតីអ្នកមានភោគៈច្រើនក្នុងនគរហង្សវតី ចម្រើនវ័យហើយ ទៅកាន់ព្រះវិហារមួយអន្លើដោយអ្នកនគរ ស្តាប់ព្រះធម្មទេសនា បំពេញមហាទានអស់ ៧ ថ្ងៃ ហើយធ្វើបុណ្យជរាបដល់អស់ជីវិត អន្ទោលទៅមក ក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងកាលនៃព្រះដ៏មានព្រះភាគ របស់យើងទាំងឡាយ កើតជាបុត្តបុរោហិតរបស់ព្រះបាទឧទេន ក្នុងនគរកោសម្ពីមានឈ្មោះថាភារទ្វាជៈ ។

កុលបុត្តនោះចម្រើនវ័យហើយ រៀនចប់វេទ ៣ បង្រៀនមន្តដល់មាណព ៥០០ ត្រូវមាណពទាំងនោះ បោះបង់ចោល ព្រោះភាពជាអ្នកមានអាចារៈមិនសមគួរ ព្រោះជាអ្នកល្មោភក្នុងការបរិភោគ បានទៅកាន់នគររាជគ្រឹះ ឃើញលាភសក្ការៈរបស់ព្រះដ៏មានព្រះភាគ និងរបស់ភិក្ខុសង្ឃ ទើបបួសក្នុងសា-សនា ជាអ្នកមិនដឹងប្រមាណក្នុងភោជនត្រាច់ទៅ កាលព្រះសាស្តាទ្រង់ធ្វើ

ឲ្យតាំងនៅក្នុងភាពជាអ្នកដឹងប្រមាណដោយឧបាយ ផ្តើមវិបស្សនា បានជាបុគ្គលមានអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ក្នុងភពមុនខ្ញុំកើតជាព្រានម្រឹគ កាលនោះខ្ញុំបានត្រាច់ទៅ ក្នុងព្រៃធំ បានឃើញព្រះសម្ពុទ្ធ ព្រះអង្គមិនមានធូលី គឺកិលេស ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ។ ខ្ញុំមានចិត្តជ្រះថ្លា បានយកផ្លែទ្រយឹងមកថ្វាយព្រះពុទ្ធដ៏ប្រសើរជាបុញ្ញក្ខេត្ត ព្រះអង្គមានព្យាយាម ដោយដៃរបស់ខ្លួន ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែទ្រយឹងក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលបានអភិញ្ញា ៦ ហើយគិតថា មគ្គផលណាដែលពួកសាវ័កទាំងឡាយគប្បីសម្រេចចំពោះព្រះភក្ត្ររបស់ព្រះដ៏មានព្រះភាគ មគ្គផលនោះខ្ញុំក៏បានសម្រេចហើយ បន្លឺសីហនាទក្នុងពួកភិក្ខុថា អ្នកណាមានសេចក្តីសង្ស័យក្នុងមគ្គឬផល បុគ្គលនោះចូរសួរខ្ញុំ ដូច្នេះ ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់តាំងលោកទុកក្នុងតំណែងឯតទគ្គៈដោយព្រះពុទ្ធតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុអ្នកបន្លឺសីហនាទ ស្រេចនឹងបិណ្ឌោលភារទ្វាជប្រសើរ

---

១-ក្នុងអបទានជាព្រះ បិយាលផលទាយកត្ថេរ ។

ជាងគេ ។

ថ្ងៃមួយ កាលអនុគ្រោះព្រាហ្មណ៍ ដែលជាមិច្ឆាទិដ្ឋិមានសេចក្តីកំណាញ់ ដែលធ្លាប់ជាសម្លាញ់នឹងគ្នាក្នុងកាលជាគ្រហស្ថ ដែលចូលទៅរកលោក ទើបលោកពោលកថាពណ៌នាអានិសង្សនៃទានដល់ព្រាហ្មណ៍នោះ ។ កាលព្រាហ្មណ៍ធ្វើនូវការចងចិញ្ចើមដោយគិតថា ព្រះថេរៈនេះបំណងនឹងញ៉ាំងទ្រព្យរបស់អញឲ្យវិនាស ហើយពោលថា ខ្ញុំនឹងប្រគេនកត្តមួយពេលដល់លោក ដូច្នេះ ទើបព្រះថេរៈពោលថា អ្នកចូរប្រគេនកត្តមួយពេលនោះដល់សង្ឃ កុំឲ្យអាត្មាឡើយ ហើយឲ្យព្រាហ្មណ៍នោះបង្អោនកត្តនោះទៅថ្វាយសង្ឃ កាលព្រាហ្មណ៍សម្តែងការមិនពេញចិត្ត ដោយគិតថា ព្រះថេរៈនេះបំណងឲ្យអញថ្វាយទានដល់ភិក្ខុជាច្រើនដូច្នេះ ។ ព្រះថេរៈក៏ឲ្យព្រាហ្មណ៍ជ្រះថ្លាដោយប្រកាសដល់ភាពនៃទក្ខិណាទានដែលថ្វាយក្នុងសង្ឃ ដែលមានព្រះធម្មសេនាបតីនៅក្នុងនោះផងក្នុងថ្ងៃស្អែកឡើងថាមានផលច្រើន ហើយគិតថា ព្រាហ្មណ៍នេះសម្គាល់ថា ព្រះថេរៈនេះដឹកនាំអញឲ្យថ្វាយទាន ដោយចំណង់ក្នុងអាហារ ព្រាហ្មណ៍មិនដឹងការដែលអញកំណត់ដឹងអាហារបាន ហើយដោយប្រការទាំងពួង ណ្ហើយចុះ អញនឹងធ្វើឲ្យព្រាហ្មណ៍ដឹង ដូច្នេះ ទើបពោលគាថា ២ ថា

> ជីវិត ( របស់ខ្ញុំ ) នេះ រមែងមិនមាន ព្រោះការមិនប្រព្រឹត្តទៅ អាហារមិនមែនធ្វើឲ្យស្ងប់ដល់ហឫទ័យបានទេ គ្រោងកាយតាំងនៅបានដោយអាហារខ្ញុំប្រព្រឹត្តនូវការស្វែងរកព្រោះ

ឃើញដូច្នេះ ។ ការសំពះនឹងការបូជាណា ដែលមានក្នុងត្រ-

កូលទាំងឡាយ បណ្ឌិតទាំងឡាយ បានពោលនូវការសំពះ

និងបូជានោះថា ដូចជាភក់ សរគឺកិលេសដ៏ល្អិត គេដកបាន

ដោយក្រ សក្ការៈក៏បុរសអាក្រក់លះបានដោយក្រ ។

បណ្តាបទទាំងនោះ បទថា **នយិទំ អនយេន ជីវិតំ** សេចក្តីថា ជីវិតរបស់ខ្ញុំនេះ ឈ្មោះថារមែងប្រព្រឹត្តទៅដោយមិនសមគួរ គឺដោយការស្វែងរកដែលមិនសមគួរ មានការឲ្យឫស្សី និងការឲ្យផ្កាជាដើម ព្រោះមិនមានការជាប់ជំពាក់ក្នុងជីវិត ។

បទថា **នាហារោ ហទយស្ស សន្តិកោ** សេចក្តីថា អាហារដែលខ្ញុំនាំមក រមែងមិនធ្វើហទយៈ គឺចិត្តឲ្យស្ងប់រម្ងាប់ ដូចមគ្គញាណនិងផលញាណ អធិប្បាយថា ធ្វើត្រឹមតែការរម្ងាប់សេចក្តីឃ្លានក្នុងបច្ចុប្បន្នតែម្យ៉ាងនោះឯង ។

ម្យ៉ាងទៀត បទថា **នាហារោ ហទយស្ស សន្តិកោ** សេចក្តីថា អាហារ គឺវត្ថុដែលជាទីតាំងនៃចំណង់ក្នុងរស មិនបានធ្វើចិត្តរបស់ខ្ញុំឲ្យស្ងប់ គឺមិនធ្វើចិត្តរបស់ខ្ញុំឲ្យជាប់ជំពាក់ ព្រោះមិនមានចំណង់ក្នុងរសនោះឯង អាចារ្យពួកខ្លះពោលថា **សន្តិកេ** ក៏មាន ។

អធិប្បាយថា បុគ្គលដែលមានការបរិភោគច្រើនក្នុងអាហារនោះ រមែងត្រូវខ្វល់ខ្វាយរកលាភសក្ការៈរឿយៗទៅ ទើបអាហារឈ្មោះថា មាននៅក្នុងចិត្តរបស់បុគ្គលនោះ ព្រោះត្រូវដាក់ចិត្តដល់រឿយៗ ចំណែកបុគ្គលណាដឹងនូវអាហារបាន បុគ្គលនោះឈ្មោះថាលះឆន្ទរាគៈ ក្នុងអាហារនោះបានហើយ

អាហារឈ្មោះថាមិនមានក្នុងចិត្តរបស់បុគ្គលនោះ ព្រោះមិនមានការដាក់ចិត្តជាដើមថា ធ្វើម្តេចហ្ន៎ អាត្មាអញគប្បីបានអាហារដូច្នេះ ព្រោះដាក់ចិត្តដល់បញ្ហាដែលមានថា បើអ្នកមិនមានការប្រាថ្នាក្នុងជីវិត និងការចង់បានក្នុងរសអាហារសោត បើដូច្នោះ ហេតុអ្វីទើបអ្នកត្រាច់បិណ្ឌបាត ដូច្នេះ ទើបព្រះថេរៈពោលថា គ្រោងកាយតាំងនៅបានដោយអាហារ ខ្ញុំប្រព្រឹត្តនូវការស្វែងរកព្រោះឃើញដូច្នេះ ។

អាហារ គឺភោជនដែលជាទីតាំង គឺជាបាត បានដល់ ជាបច្ច័យរបស់រាងកាយនោះ ព្រោះហេតុនោះ ទើបរាងកាយឈ្មោះថា អាហារដ្ឋិតិកៈ គឺមាននូវអាហារជាទីតាំង អធិប្បាយថា ខ្ញុំឃើញ គឺ ដឹងយ៉ាងនេះថា ការសន្សំ គឺរាងកាយ មានការប្រព្រឹត្តទៅទាក់ទងដោយអាហារ ទើបត្រាច់ស្វែងរក គឺធ្វើការស្វែងរកអាហារដោយតាំងការសិក្សានេះទុកក្នុងចិត្ត ។

ព្រះថេរៈកាលសម្តែងថា អ្នកមិនគួរគិតក្នុងមនុស្សដូចអាត្មាយ៉ាងនេះថាចូលទៅកាន់ត្រកូល ព្រោះបច្ច័យជាហេតុ និងត្រូវលាភសក្ការៈ គឺការក្រាបថ្វាយបង្គំបូជាក្នុងត្រកូលនោះចងទុកហើយ ទើបពោលគាថាថា **បង្កោ** ដូច្នេះ ។

គាថានោះ មានអធិប្បាយថា ព្រោះហេតុដែលបណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើមបានដឹង គឺដឹងច្បាស់ ឬប្រកាសការសរសើរគុណ និងការបូជាដល់ពួកបព្វជិតដែលចូលទៅកាន់ត្រកូលព្រោះមានបច្ច័យជាហេតុ ដែលប្រព្រឹត្តទៅ ក្នុងត្រកូលទាំងឡាយ គឺក្នុងពួកអ្នកស្រុកនោះថាជាភក់ គឺជាល្បាប់ ព្រោះអត្ថថា ជាហេតុឲ្យបព្វជិតដែលមានខ្លួនមិនបានអប់រំហើយលិច

ចុះនិងព្រោះធ្វើនូវការសៅហ្មងឲ្យដល់បព្វជិតដែលមានខ្លួនមិនបានអប់រំហើយ ដូច្នោះការសរសើរគុណ និងការបូជានោះ ក៏មិនប្រព្រឹត្តទៅដើម្បីចងសប្បុរសទាំងឡាយ នឹងពោលថ្វីដល់ការសង្ឃឹមសក្ការៈនោះ ព្រោះលោកលះបានហើយ តែសម្រាប់អសប្បុរស ការសង្ឃឹមក្នុងសក្ការៈ រមែងឈ្មោះថាសរ គឺកិលេសដ៏ល្អិត គេដកបានដោយក្រ ព្រោះញុំាងឲ្យកើតនូវការបៀតបៀន ដោយជាសភាពដែលដឹងបានដោយលំបាក ព្រោះមិនអាចដកចេញបាន ព្រោះមុតចូលទៅខាងក្នុង ហេតុនោះឯង សក្ការៈ ក៏បុរសអាក្រក់នោះលះបានដោយក្រ គឺទាញចេញបានដោយលំបាក ព្រោះមិនត្រូវតាមបដិបទាដែលជាបដិបទាឲ្យដល់នូវការលះសក្ការៈនោះ ឈ្មោះថាជាបុរសអាក្រក់ ព្រោះមិនលះនូវការប្រាថ្នាក្នុងលាភសក្ការៈ ។ ព្រាហ្មណ៍ស្តាប់ពាក្យជាគាថានោះហើយ បានជាបុគ្គល មានសេចក្តីជ្រះថ្លាក្រៃលែងក្នុងព្រះថេរៈ ។

## អដ្ឋកថា បិណ្ឌោលភារទ្វាជត្ថេរគាថា ចប់

## វល្លិយត្ថេរគាថា

[ ១២៨ ] ស្វាគឺចិត្ត តែងចូលទៅក្នុងខ្ទមគឺអត្តភាព មានទ្វារ ៥ កាលញាប់ញ័រស្ទុះចុះឡើង តែងត្រាច់ទៅតាមទ្វារ ៗ នែស្វា អ្នកចូរឈប់ អ្នកកុំស្ទុះទៅឡើយ ខ្ទមរបស់អ្នកនោះមិនមានដូចក្នុងកាលមុនទៀតទេ អ្នកត្រូវខ្ញុំសង្កត់សង្កិនដោយបញ្ញា អ្នកនឹងទៅកាន់ទីឆ្ងាយមិនបានទេ ។

វល្លិយត្ថេរ ។

## អដ្ឋកថា

## វល្លិយត្ថេរគាថា

[ ១២៨ ] គាថារបស់ព្រះវល្លិយត្ថេរ មានពាក្យផ្តើមថា **មក្កដោ បញ្ច-ទ្វារាយំ** ដូច្នេះ ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះថេរៈនេះ ក៏ជាអ្នកមានបុញ្ញាធិការសន្សំទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យច្រើនទុកក្នុងភពនោះៗ ក្នុងកប្បទី ៣១ រាប់អំពីភទ្ទកប្បនេះកើតក្នុងផ្ទះមានត្រកូល សម្រេចភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយចូលទៅកាន់ព្រៃដោយករណីយកិច្ចឯណានីមួយ ឃើញព្រះបច្ចេកពុទ្ធព្រះនាមថានារទៈ នៅត្រង់គល់ឈើក្នុងព្រៃនោះ មានចិត្តជ្រះថ្លា ធ្វើសាលាដោយដើមបបុសប្រក់ដោយស្មៅប្រគេន និងក្តារផ្ទូវសម្រាប់ចង្រ្កមរបស់ព្រះបច្ចេកពុទ្ធនោះ កៀរខ្សាច់ប្រគេនព្រះបច្ចេកពុទ្ធអង្គនោះ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំង

ឡាយ កើតជាបុត្តរបស់ព្រាហ្មណមហាសាលក្នុងនគរសាវត្ថី ក្នុងពុទ្ធុប្បាទកាលនេះ មានឈ្មោះថាវល្លិយៈ ចម្រើនវ័យហើយ ដល់នូវភាពជាកំលោះតាមលំដាប់ ជាអ្នកធ្លាក់នៅក្រោមអំណាចនៃឥន្ទ្រិយ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ដោយការទូន្មានរបស់កល្យាណមិត្ត ស្តាប់ធម៌ហើយ ជាអ្នកមានសទ្ធាបួសហើយ ផ្តើមតាំងវិបស្សនា សម្រេចអរហត្ត ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ក្នុងទីមិនឆ្ងាយអំពីព្រៃហិមពាន្តមានភ្នំមួយឈ្មោះហារិកៈកាលនោះ ព្រះសយម្ភូសម្ពុទ្ធព្រះនាមនារទៈ គង់នៅទៀបគល់ឈើជិតភ្នំនោះ ។ ខ្ញុំបានធ្វើផ្ទះបបុស បិទបាំងដោយស្មៅ ជម្រះទីចង្ក្រមថ្វាយដល់ព្រះសយម្ភូសម្ពុទ្ធ ។ ដោយអំពើដែលខ្ញុំធ្វើល្អហើយនោះផង ដោយការតម្កល់ចេតនានោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ប្រាសាទរបស់ខ្ញុំ ដែលកុសលកម្មធ្វើល្អហើយ ក្នុងឋានតាវត្តិង្សនោះ គឺ កុសលកម្មនិម្មិត ធ្វើជាខ្ទមបបុសមានកម្ពស់ ៦០ យោជន៍ ទទឹង ៣០ យោជន៍ ។ ខ្ញុំរីករាយក្នុងទេវលោកអស់ ១៤ កប្ប បានសោយរាជ្យក្នុងទេវលោកអស់ ៧១ ដង ។ ខ្ញុំបានជាស្តេចចក្រពត្តិអស់ ៣៤ ដង បានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់ជាតិមិនអស់ ។ ខ្ញុំបានឡើងកាន់ធម្មប្រាសាទ ឧបមាដូចផ្ទះស្ងាត់ដ៏ប្រសើរ ហើយសម្រេច

សម្រាន្តតាមសមគួរក្នុងសាសនានៃព្រះសក្យបុត្ត ។ ក្នុងកប្ប
ទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្មក្នុង
កាលនោះខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃខមបបុស ។
កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។ បេ ។ ទាំង
សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១]។

ព្រះថេរៈកាលសម្រេចអរហត្តហើយ ព្រោះហេតុដែលចិត្តរបស់លោក ក្នុងកាលនៅជាបុថុជ្ជន ប្រព្រឹត្តទៅតាមការប្រាថ្នាក្នុងអារម្មណ៍ទាំងឡាយមាន រូបារម្មណ៍ជាដើម ឥឡូវនេះ កាលនឹងព្យាករអរហត្តផល ដោយប្រកាសថា លោកសង្កត់អារម្មណ៍ មានរូបជាដើមបានហើយដោយអរិយមគ្គ ទើបពោល គាថា ២ ថា

ស្វាគីចិត្ត តែងចូលទៅក្នុងខ្ទមគឺអត្តភាព មានទ្វារ ៥ កាល
ញាប់ញ័រស្ទុះចុះឡើង តែងត្រាច់ទៅតាមទ្វារ ។ នៃស្វា អ្នក
ចូរឈប់អ្នកកុំស្ទុះទៅឡើយ ខ្ទមរបស់អ្នកនោះ មិនមានដូច
ក្នុងកាលមុនទៀតទេ អ្នកត្រូវខ្ញុំសង្កត់សង្កិនដោយបញ្ញា អ្នក
នឹងទៅកាន់ទីឆ្ងាយមិនបានទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យង្គយន្តោ** សេចក្តីថា ព្រះយោគាវចរលះ អារម្មណ៍ឯណានីមួយ ហើយទាញយកអារម្មណ៍មួយទៀត ក្នុងអារម្មណ៍ទាំង ឡាយមានរូបជាដើម ដោយចក្ខុទ្វារជាដើមនោះៗ មិនពេញចិត្តដើម្បីនៅស្ងៀម

---

១-ក្នុងអបទានជាព្រះ នឡកុដិកទាយកត្ថេរ ។

ដោយអំណាចដែលចិត្តសន្តានប្រកាន់មាំ ទើបព្យាយាម គឺ ធ្វើអារម្មណ៍ឲ្យ
ញាប់ញ័ររឿយៗ ទើបញាប់ញ័រទៅតាម គឺ ត្រាច់ទៅតាមការប្រាថ្នា ក្នុង
អារម្មណ៍ មានរូបារម្មណ៍ជាដើមនោះឯង ដូចស្វាចូលទៅរកផ្លែឈើស៊ី ធ្វើ
ដើមឈើក្នុងទីនោះឲ្យកម្រើកទៅមក ព្រោះលះនូវមែកមួយហើយ ទៅទំត្រង់
មែកមួយទៀត ព្រោះការរពិសរបស់ខ្លួន ។ ក្នុងគាថានេះ លោកពោលភាព
ជាបច្ចុប្បន្ន ព្រោះជារឿងដែលជិតនឹងវត្ថុដែលប្រព្រឹត្តទៅ កាលស្វា គឺចិត្ត
ធ្វេធ្វាទៅមកយ៉ាងនេះ ព្រះថេរៈក៏ហាមថា នែស្វា អ្នកចូរឈប់ អ្នកកុំស្ទុះ
ទៅឡើយ សេចក្តីថា នែស្វាគឺចិត្ត ឥឡូវនេះ អ្នកចូរឈប់កុំស្ទុះទៅ គឺចាប់
ពីពេលនេះទៅ អ្នកមិនអាចរត់តទៅបាន ព្រោះផ្ទះ គឺអត្តភាពនោះ អ្នកចូល
ទៅគប់រកមិនបានដូចកាលមុន ព្រោះទ្វារផ្ទះត្រូវបិទហើយ ដូច្នោះ ខ្មុំរបស់
អ្នកនោះមិនមានដូចក្នុងកាលមុនទៀតទេ ព្រោះហេតុអ្វី ព្រោះយើងចាប់ឯង
បានហើយដោយបញ្ញា គឺក្នុងឥឡូវនេះ អ្នកត្រូវសង្កត់សង្កិនទុក រៀបរយ
ហើយ ដោយការកាត់ឧបាទាន ៥ ពោល គឺកិលេសមារនិងអភិសង្ខារមារ
ដោយមគ្គប្បញ្ញា ព្រោះហេតុនោះទើបព្រះថេរៈសម្តែងថា អ្នកនឹងទៅកាន់ទី
ឆ្ងាយមិនបានទេ គឺអ្នកនឹងទៅកាន់អត្តភាពទី ២ ជាដើម ដែលឆ្ងាយជាង
អត្តភាពនេះមិនបាន បានដល់ ការទៅរបស់អ្នកនឹងមានត្រឹមតែចិត្តចុងក្រោយ
ប៉ុណ្ណោះ ។ បាឋៈថា **ឆេតោ ធ្ចរំ** ដូច្នេះក៏មាន ឯសេចក្តីក៏ដូចគ្នា ។

**អដ្ឋកថា វល្លិយត្ថេរគាថា ចប់**

# គង្គាតីរិយត្ថេរគាថា

[ ១២៥ ] ខ្ទមដែលខ្ញុំធ្វើទៀបឆ្នេរទន្លេគង្គារ ដោយស្លឹកត្នោតបីធាង ក៏មាន បាត្ររបស់ខ្ញុំដូចជាឆ្នាំងស្រោចទឹកដោះស្រស់ឲ្យខ្មោច ក៏មាន សំពត់បំសុកូល ក៏មាន ។ ក្នុងរវាងពីរឆ្នាំ ខ្ញុំនិយាយវាចាតែមួយម៉ាត់ ក្នុងរវាងឆ្នាំទីបី គំនរនៃងងឹត ( អវិជ្ជា ) ខ្ញុំក៏បានទំលាយហើយ ។

**គង្គាតីរិយត្ថេរ ។**

# អដ្ឋកថា

# គង្គាតីរិយត្ថេរគាថា

[ ១២៥ ] គាថារបស់ព្រះគង្គាតីរិយត្ថេរ មានពាក្យផ្ដើមថា **តិណ្ណំ មេ តាលបត្តានំ** ដូច្នេះ ។ រឿងរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮមកថា ព្រះថេរៈកើតក្នុងផ្ទះមានត្រកូល ក្នុងកាលរបស់ព្រះដ៏មានព្រះភាគព្រះនាមថា បទុមុត្តរៈ សម្រេចភាពជាបុគ្គលដឹងក្ដីហើយ ជាអ្នកមានសេចក្ដីជ្រះថ្លាក្រៃលែងក្នុងព្រះសាសនា បានថ្វាយទឹកបានដល់ភិក្ខុសង្ឃ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ ទៅកើតក្នុងទេវលោក ធ្វើបុណ្យហើយ អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តរបស់គហបតីម្នាក់ក្នុងនគរសាវត្ថីមានឈ្មោះថា ទត្តៈ ចម្រើនវ័យហើយនៅគ្រប់គ្រងផ្ទះ មិនស្គាល់អគមនីយដ្ឋាន ទើបប្រព្រឹត្តល្មើសក្នុងកិរិយារបស់អ្នកដទៃ ក្នុងកាលតមក ស្គាល់ភាពជាអគមនីយដ្ឋានហើយ កើតសេចក្ដី

សង្វេគបួសហើយ រង្កៀសក្នុងកម្មនោះ តម្កល់ខ្លួនក្នុងលូខប្បដិបទា គឺបដិ-បត្តិយ៉ាងសៅហ្មង ប្រើបំសុកូលចីវរ កាន់យកបាត្រដីមានលក្ខណៈដូចគ្នានឹងថ្នាំងស្រោចទឹកសព ធ្វើកុដិដោយធាងត្នោត ៣ ត្រង់ច្រាំងស្ទឹងគង្គា ដោយហេតុនោះទើបលោកមានសម្មតិនាមថា គង្គាតីរិយៈ ។ លោកអធិដ្ឋានចិត្តថា បើអាត្មាអញមិនបានសម្រេចអរហត្ត នឹងមិននិយាយជាមួយអ្នកណាឡើយ ជាអ្នកស្ងៀមអស់មួយឆ្នាំ នៅដោយមិនពោលចរចា ។ ក្នុងឆ្នាំទី ២ ត្រូវស្រីម្នាក់ក្នុងគោចរគ្រាម បំណងនឹងពិសោធមើលថា តើព្រះថេរៈនេះគដែរឬទេ ទើបកាលនឹងចាក់ទឹកដោះក្នុងបាត្រក៏ក្លែងធ្វើជាដៃពិការហើយចាក់ទៅ លោកភ្លេចខ្លួន ក៏បន្លឺវាចាថា ល្មមហើយប្អូនស្រី ។ តែក្នុងឆ្នាំទី ៣ ព្យាយាមរហូតសម្រេចអរហត្ត ក្នុងវស្សានោះឯង សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តត្រេកអរ បានថ្វាយទឹកមួយក្អម ចំពោះភិក្ខុសង្ឃដ៏ប្រសើរនៃព្រះបទុមុត្តរសម្ពុទ្ធ ។ ( ដោយកុសលកម្មនេះ ) បើខ្ញុំចង់បានទឹកសម្រាប់ផឹកលើកំពូលភ្នំ លើចុងឈើ ក្នុងអាកាស ឬក្នុងផែនដីក្នុងកាលណា ទឹកក៏កើតឡើងយ៉ាងឆាប់ដល់ខ្ញុំក្នុងកាលនោះ ក្នុងកប្បទីមួយសែនអំពីកប្បនេះព្រោះហេតុដែលខ្ញុំបានថ្វាយទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃឧទកទាន ។ កិលេសទាំង-ឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ

ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលបានជាព្រះអរហន្តហើយ កាលនឹងព្យាករណ៍អរហត្តផល ដោយមុខ គឺការបង្អួលបង្ហាញបដិបទាដែលជាចំណែកខាងដើមរបស់ខ្លួន បានពោលគាថា ២ ថា

ខ្ទមដែលខ្ញុំធ្វើទៀបឆ្នេរទន្លេគង្គា ដោយស្លឹកត្នោតបីធាង ក៏មាន បាត្ររបស់ខ្ញុំ ដូចជាឆ្នាំងស្រោចទឹកដោះស្រស់ឲ្យខ្មោច ក៏មាន សំពត់បំសុកូល ក៏មាន ។ ក្នុងរវាងពីរឆ្នាំ ខ្ញុំនិយាយវាចាតែមួយម៉ាត់ ក្នុងរវាងឆ្នាំទីបី គំនរនៃងងឹត ( អវិជ្ជា ) ខ្ញុំក៏បានទំលាយហើយ ។

បណ្ដាបទទាំងនោះ បទថា **តិណ្ណំ មេ តាលបត្តានំ គង្គាតីរេ កុដី កតា** សេចក្ដីថា ខ្ញុំសាងកុដិត្រង់ឆ្នេរស្ទឹងគង្គាដើម្បីការពារភ្លៀងដោយស្លឹកត្នោត ៣ ធាងដែលធ្លាក់អំពីដើមត្នោត ។ ព្រះថេរៈសម្ដែងការសន្ដោសដោយសេនាសនៈរបស់ខ្លួនដោយបទនេះសមដូចពាក្យដែលព្រះធម្មសេនាបតីពោលទុកក្នុង ( ថេរគាថា ) ថា

កាលភិក្ខុអង្គុយដោយភ្នែន ភ្លៀងមិនស្រក់ត្រូវត្រង់ជង្គង់ទាំងពីរ នេះជាការគួរដល់កិរិយានៅជាសុខនៃភិក្ខុអ្នកមានចិត្តស្ងប់ទៅរក ( ព្រះនិព្វាន ) ដូច្នេះ ។

បាឋៈថា **តាលបត្តីនំបិ** ដូច្នេះ ក៏មាន ឯសេចក្ដីក៏ដូចគ្នា ។ បទថា **ឆវសិត្តោ–**

---

១–ក្នុងអបទានជាព្រះ ឧទកទាយកត្ថេរ ។

**វ មេ បត្តោ** សេចក្តីថា បាត្ររបស់ខ្ញុំ ដូចថ្នាំងសម្រាប់ដងទឹកស្រោចខ្មោច អធិប្បាយថា ដូចគ្នានឹងថ្នាំងសម្រាប់ស្រោចទឹកដោះឲ្យអ្នកស្លាប់ ។

បទថា **បំសុកូលញ្ច ចីវរំ** សេចក្តីថា ចីវររបស់ខ្ញុំដូចសំពត់ប្រឡាក់ដី ដែលធ្វើដោយសេសសំពត់ គឺសំពត់ដាច់ដាច ដែលគេបោលក្នុងទីទាំងឡាយ មានបោលត្រង់ផ្លូវនិងត្រង់ព្រៃស្មសានជាដើម ។ ព្រះថេរៈសម្តែងភាពសន្តោស ដោយបរិក្ខារ ដោយបទទាំង ២ ។

បទថា **ទ្វិន្នំ អន្តរវស្សានំ** សេចក្តីថា ក្នុងរវាងវស្សាទាំង ២ គឺក្នុងឆ្នាំ ដែលសម្រេចអរហត្ត រាប់អំពីបួសហើយ ។

បទថា **ឯកា វាចា មេ ភាសិតា** សេចក្តីថា ខ្ញុំនិយាយត្រឹមតែមួយមាត់ គឺពោលហាមការប្រគេនទឹកដោះថា ល្មមហើយប្អូនស្រី ប៉ុណ្ណោះ ការបន្ទឺវាចាដទៃមិនមានឡើយក្នុងវស្សានោះ ព្រះថេរៈសម្តែងការសង្រួមកាយវាចាដ៏ឧក្រិដ្ឋ ដោយបទនោះ ។

បទថា **តតិយេ អន្តរវស្សម្ហិ** សេចក្តីថា ក្នុងរវាងឆ្នាំទី ៣ បានដល់មិនទាន់គ្រប់ ៣ ឆ្នាំល្អនោះឯង ។

បទថា **តមោក្ខន្ធោ បទាលិតោ** សេចក្តីថា គំនរនៃងងឹតដែលខ្ញុំទម្លាយហើយដោយមគ្គដ៏ប្រសើរ អធិប្បាយថា កិលេសយ៉ាងល្អិត ដែលដេកត្រាំរឿយៗក្នុងសន្តាន គឺអវិជ្ជា ដែលខ្ញុំកាត់ផ្តាច់ហើយ ។ ដោយបទថា **តមោក្ខន្ធោ បទាលិតោ** នោះ ព្រះថេរៈពោលដល់ការលះកិលេសទាំងពួងបាន ដោយមិនសេសសល់ ព្រោះមានអត្ថដូចគ្នា ។

**អដ្ឋកថា គង្គាតីរិយត្ថេរគាថា ចប់**

## អជិនត្ថេរគាថា

[ ១២៦ ] បើទុកជាបុគ្គលមានវិជ្ជា ៣ លះបង់មច្ចុបាន មិនមានអាសវៈ ពួកជនពាលអ្នកមិនចេះដឹង រមែងមើលងាយបុគ្គលនោះថា ជាអ្នកមិនមានកេរ្តិ៍ឈ្មោះល្បីល្បាញទៅវិញ ។ បុគ្គលណា ក្នុងលោកនេះ លុះតែជាអ្នកស្វាក់លាក ចំពោះបាយទឹក ទោះបីមានធម៌ដ៏លាមក បុគ្គលនោះទើបពួកជនពាលទាំងនោះ ធ្វើសក្ការៈ ។

**អជិនត្ថេរ ។**

## អដ្ឋកថា

## អជិនត្ថេរគាថា

[ ១២៦ ] គាថារបស់ព្រះអជិនត្ថេរ មានពាក្យផ្តើមថា **អបិ ចេ ហោតិ តេវិជ្ជោ** ដូច្នេះ ។ រឿងរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះថេរៈនេះ ក៏ជាអ្នកមានបុញ្ញាធិការដែលធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទុកក្នុងភពនោះៗ កើតក្នុងផ្ទះមានត្រកូលក្នុងលោកដែលទទេចាកព្រះពុទ្ធគឺសុញ្ញកប្ប ដល់នូវភាពជាអ្នកដឹងក្តីហើយ បានទៅព្រៃដោយករណីយកិច្ចឯណានីមួយ ឃើញព្រះបច្ចេកសម្មាសម្ពុទ្ធ ព្រះនាមថាសុចិន្តិតៈ ត្រូវអាពាធបៀតបៀន អង្គុយក្នុងព្រៃនោះ ទើបចូលទៅរក ថ្វាយបង្គំហើយ ជាអ្នកមានចិត្តជ្រះថ្លា បាននាំយកក្រាមទឹកដោះថ្លាទៅប្រគេនដើម្បីធ្វើជាថ្នាំ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ កើតក្នុងទេវលោក ធ្វើបុណ្យហើយ

វិលវល់ទៅមកក្នុងសុគតិកពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ បដិសន្ធិក្នុងផ្ទះរបស់ព្រាហ្មណ៍ក្រីក្រម្នាក់ក្នុងនគរសាវត្ថី ក្នុងពេលប្រសូត មនុស្សទាំងឡាយទទួលដោយបន្ទះស្បែកខ្លា ដោយហេតុនោះទើបមានឈ្មោះថា អជិនៈ នោះឯង ។

កុលបុត្តនោះ កើតក្នុងត្រកូលទុគ៌ត ព្រោះមិនបានធ្វើកម្ម ដែលជាហេតុញុំាងភោគៈឲ្យប្រព្រឹត្តទៅ សូម្បីវ័យចម្រើនហើយ ក៏ជាបុគ្គលមានបាយនិងទឹកមិនសម្បូរ ត្រាច់ទៅឃើញពុទ្ធានុភាព ក្នុងកាលដែលទ្រង់ទទួលជេតពនមហាវិហារ ជាអ្នកមានសទ្ធាបួសហើយ ធ្វើកម្មក្នុងវិបស្សនា បានជាអ្នកមានអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ខ្ញុំបានឃើញនូវព្រះមានព្រះភាគ ទ្រង់មានព្រះតម្រិះល្អ ព្រះអង្គជាច្បងក្នុងលោក ប្រសើរជាងពួកនរៈ ដែលស្តេចចូលទៅគង់ក្នុងព្រៃធំហើយត្រូវអាពាធកើតអំពីខ្យល់បៀតបៀន ។ លុះខ្ញុំឃើញហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លា បានថ្វាយទឹកដោះថ្លា ព្រោះកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ព្រោះសេចក្តីកោតក្រែងនោះផងទន្លេគង្គាឈ្មោះភាគីរសីនេះនិងមហាសមុទ្រទាំង ៤ ក៏ញុំាងទឹកដោះឲ្យសម្រេចដល់ខ្ញុំ មួយទៀត ផែនដីជាសភាវៈដ៏ធំនេះប្រមាណមិនបានរាប់មិនអស់ ក៏កើតទៅជាទឹកឃ្មុំនិងស្ករក្រោមព្រោះដឹងតម្រិះរបស់ខ្ញុំ ។ ដើមឈើទាំងឡាយនេះ ជាឈើដុះលើផែនដី ដែលឋិតនៅក្នុងទិសទាំងបួន ឈើទាំងនោះក៏កើត

ទៅជាដើមកល្បព្រឹក្ស ព្រោះដឹងគម្រិះរបស់ខ្ញុំ ។ ខ្ញុំបានកើតជាព្រះឥន្ទ សោយរាជ្យជាស្តេចទេវតាអស់ ៥០ ដង ។ បានជាស្តេចចក្រពត្តិ ៥១ ដង បានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់ជាតិមិនអស់ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទឹកដោះថ្លា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១]។

ព្រះថេរៈសម្រេចអរហត្តហើយ ក៏ជាអ្នកមានលាភតិច មិនមានឈ្មោះបោះសំឡេង ព្រោះផលនៃកម្មដែលមានក្នុងកាលមុន សូម្បីឧទ្ទេសកត្ត និងសាលាកកត្តដែលដល់លំដាប់លោក ក៏ថោកថយទាំងអស់ ម្យ៉ាងទៀត ភិក្ខុនិងសាមណេរទាំងឡាយដែលជាបុថុជ្ជន ក៏មើលងាយលោកថា ជាបុគ្គលមិនមានឈ្មោះបោះសំឡេង ព្រោះផលនៃកម្មនោះឯង ព្រះថេរៈកាលញុំាងភិក្ខុទាំងនោះឲ្យសង្វេគ បានពោលគាថា ២ ថា

បើទុកជាបុគ្គលមានវិជ្ជា ៣ លះបង់មច្ចុបាន មិនមានអាសវៈ ពួកជនពាលអ្នកមិនចេះដឹង រមែងមើលងាយបុគ្គលនោះថាជាអ្នកមិនមានកេរ្តិ៍ឈ្មោះល្បីល្បាញទៅវិញ ។ បុគ្គលណា ក្នុងលោកនេះ លុះតែជាអ្នកស្វាក់លាភចំពោះបាយទឹក ទោះបី

---

១-ក្នុងអបទានជាព្រះ យជមណ្ឌទាយកត្ថេរ ។

មានធម៌ដ៏លាមក បុគ្គលនោះទើបពួកជនពាលទាំងនោះ ធ្វើសក្ការៈ ។

សព្ទថា **អបិ** ក្នុងគាថានោះជានិបាត ចុះក្នុងអត្ថថា លើកតម្កើង និងសរសើរ ។ សព្ទថា **ចេ** ប្រើក្នុងអត្ថថា គ្មាន់គ្មេរ ។

បទថា **ហោតិ** ស្មើគ្នានឹង **ភវតិ** ប្រែថា រមែងកើត ។ បុគ្គលឈ្មោះថា **តេវិជ្ជោ** ព្រោះជាអ្នកមានវិជ្ជា ៣ ។

ឈ្មោះថា **មច្ចុហាយី** ព្រោះលះមច្ចុបាន ។ ឈ្មោះថា **អានាសវោ** ព្រោះមិនមានអាសវៈទាំងឡាយ មានកាមាសវៈជាដើម លោកពោលអធិប្បាយទុកថា សូម្បីបុគ្គលជាបុគ្គលឈ្មោះថា **តេវិជ្ជោ** ព្រោះសម្រេចវិជ្ជា ៣ ទាំងនេះ គឺទិព្វចក្ខុញ្ញាណ ១ បុព្វេនិវាសញ្ញាណ ១ អាសវក្ខយញ្ញាណ ១ បន្ទាប់អំពីនោះ ក៏ឈ្មោះថា **អានាសវោ** ព្រោះអាសវៈទាំងឡាយ មានកាមាសវៈជាដើមអស់ទៅហើយដោយប្រការទាំងពួង ឈ្មោះថា **មច្ចុហាយី** ព្រោះមិនមានការស្លាប់ ដោយមិនកាន់យកភពថ្មីទៀត កាលបើដូច្នោះ បុគ្គលពាលទាំងឡាយ រមែងមើលងាយបុគ្គលនោះថា ជាអ្នកមិនមានកេរ្តិ៍ឈ្មោះល្បីល្បាញទៅវិញ អធិប្បាយថា បុគ្គលពាលទាំងឡាយ គឺបុគ្គលដែលមានបញ្ញាថោកថយ រមែងមើលងាយបុរសដ៏ឧត្តមនោះ សូម្បីបានសម្រេចប្រយោជន៍របស់ខ្លួន ដែលកុលបុត្តទាំងឡាយ អ្នកចេញចាកផ្ទះបួសជាបព្វជិតប្រាថ្នាដោយប្រពៃនោះឯងថាជាបុគ្គលមិនមានកេរ្តិ៍ឈ្មោះ មិនមាននាមប្រាកដព្រោះមិនមានលាភដែលកើតឡើង ព្រោះអ្នកពោលទូន្មានរឿងធុតង្គ ជាពហុ-

ស្សូត ជាធម្មកថិក ។ ព្រោះហេតុអ្វី ព្រោះមិនដឹង គឺព្រោះហេតុនៃការមិនដឹង លោកសម្ដែងការមិនដឹងគុណទាំងឡាយនោះថា ជាហេតុក្នុងសេចក្ដីនោះ ។

ព្រះថេរៈកាលនឹងសម្ដែងថា បុគ្គលពាលទាំងឡាយ រមែងមើលងាយបុគ្គលដែលគួរសរសើរ ព្រោះជាបុគ្គលស្វាក់ក្នុងលាភ ព្រោះមិនដឹងគុណទាំងឡាយយ៉ាងណា ក៏រមែងសរសើរបុគ្គលដែលគួរមើលងាយយ៉ាងនេះ ដោយជាបុគ្គលស្វាក់ក្នុងលាភ ព្រោះមិនដឹងគុណទាំងឡាយដូច្នោះ ទើបពោលគាថា ទី ២ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ២ ដូចតទៅនេះថា បទថា **យោ** ជាពាក្យសម្ដែងមិនចំពោះ ។ **ច** សព្ទជានិបាត ប្រើក្នុងព្យតិរេកៈ ( បន្ថែម ) ។ ដោយ **ច** សព្ទនោះ សបញ្ជាក់ឲ្យដឹងនូវការផ្សេងគ្នា ដែលកំពុងពោលដល់បុគ្គលនេះឯងថា ប្លែកអំពីបុគ្គលដែលពោលហើយ ។ សព្ទថា **ខោ** ជានិបាត ចុះក្នុងអវធារណៈ គឺកំណត់សេចក្ដីឲ្យជាក់លាក់ ។

បទថា **អន្នបានស្ស** ត្រឹមតែជាគំរូ ។ បទថា **លាភី** បានដល់ មានលាភ

បទថា **ឥធ** សំដៅដល់ ក្នុងលោកនេះ ។ ឈ្មោះថា **បុគ្គលោ** ព្រោះធ្វើឲ្យសត្តាវាសនោះៗពេញនិងហូរទៅដោយជាតិនិងមរណៈ ។

បទថា **ធាបធម្មោ** បានដល់ ដែលមានធម៌ដ៏លាមក ក្នុងគាថាទី ២ នេះមានអធិប្បាយថា ចំណែកបុគ្គលណា ជាអ្នកមានប្រក្រតីបានត្រឹមតែបច្ច័យមានចីវរជាដើមប៉ុណ្ណោះ មិនបានមគ្គផល មានឈានជាដើម បុគ្គលនោះ

ទោះបីមានធម៌ដ៏អាក្រក់ ដោយភាពជាអ្នកទ្រុស្តសីល ព្រោះមានសេចក្តីប្រាថ្នាលាមក តែក៏គង់បុគ្គលអន្ធពាលទាំងឡាយក្នុងលោកនេះ ធ្វើសក្ការៈគោរព ព្រោះភាពជាអ្នកស្ងាក់ក្នុងលោក ។

## អដ្ឋកថា អជិនត្ថេរគាថា ចប់

## មេឡជិនត្ថេរគាថា

[ ១២៧ ] កាលណា ខ្ញុំបានស្តាប់សច្ចធម៌របស់ព្រះសាស្តា កាលទ្រង់សម្តែង ( កាលនោះ ) ខ្ញុំមិនដឹងនូវសេចក្តីសង្ស័យ ជាបុគ្គលដឹងសព្វចំពោះព្រះសាស្តា ព្រះអង្គជាអ្នកឈ្នះមារ ជាអ្នកដឹកនាំពួក ជាមហាវីរបុរស ជាសារថីដ៏ប្រសើរខ្ពង់ខ្ពស់ ជាងសារថីទាំងឡាយ ឬសេចក្តីសង្ស័យក្នុងអរិយមគ្គនិងបដិបទាក៏មិនមានដល់ខ្ញុំដែរ ។

មេឡជិនត្ថេរ ។

## អដ្ឋកថា
## មេឡជិនត្ថេរគាថា

[ ១២៧ ] គាថារបស់ព្រះមេឡជិនត្ថេរ មានពាក្យផ្តើមថា **យទាហំ ធម្មមស្សោសឹ** ដូច្នេះ ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះថេរៈនេះ ក៏ជាអ្នកមានបុញ្ញាធិការ ដែលធ្វើហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយទុកក្នុងភពនោះៗ ក្នុងកាលរបស់ព្រះមានព្រះភាគព្រះនាមថាសុមេធៈ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយឃើញព្រះដ៏មានព្រះភាគត្រាច់បិណ្ឌបាតមានចិត្តជ្រះថ្លា ថ្វាយផ្លែអាមោទៈ ( ផ្លែម្កាក់ ) មានរសឆ្ងាញ់ ។

ដោយបុញ្ញកម្មនោះ អន្ទោលទៅមក ក្នុងពុទ្ធុប្បាទនេះ កុលបុត្តនោះកើតក្នុងត្រកូលក្សត្រ ក្នុងក្រុងពារាណសីមាននាមថាមេឡជិនៈ ដល់នូវការ

សម្រេចក្នុងសិប្បៈវិជ្ជា ជាអ្នកឈ្លាសវៃ មានឈ្មោះល្បីទៅសព្វទិស ។ កាល ព្រះដ៏មានព្រះភាគគង់នៅក្នុងព្រៃឥសិបតនៈក្រុងពារាណសី កុលបុត្តនោះ ក៏ចូលទៅកាន់វិហារគាល់ព្រះសាស្តា ស្តាប់ធម៌ហើយបានទូវសទ្ធា បួសហើយ ផ្តើមវិបស្សនា សម្រេចអរហត្តក្នុងថ្ងៃនោះឯង សមដូចគាថាព័ន្ធដែលលោក ចងទុកក្នុងអបទានថា

ព្រះសម្ពុទ្ធមានព្រះភាគ ព្រះនាមសតរង្សី ព្រះអង្គត្រាស់ដឹង ឯង ទ្រង់ឈ្នះកិលេសមានប្រាថ្នានូវវិវេក បានចេញទៅដើម្បី គោចរ ។ ខ្ញុំមានផ្លែឈើក្នុងដៃ បានឃើញហើយ ក៏ចូលទៅ រកព្រះមានព្រះភាគដ៏ប្រសើរជាងនរៈ ខ្ញុំក៏មានចិត្តជ្រះថ្លា មាន ចិត្តរីករាយ ហើយបានថ្វាយផ្លែម្នាក់ ។ ក្នុងកប្បទី ៩៤ អំពី កប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុង សំណាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេស ទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះ ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ ក្នុងកាលក្រោយមក កាលភិក្ខុ ទាំងឡាយសួរថា អាវុសោ លោកបានសម្រេចឧត្តរិមនុស្សធម៌ហើយឬ កាល

---

១-ក្នុងអបទានជាព្រះ អម្ពដផលទាយកត្ថេរ ។

បទ្ទឹសីហនាទ បានពោលគាថា ២ ថា

កាលណា ខ្ញុំបានស្តាប់សច្ចធម៌ របស់ព្រះសាស្តាកាលទ្រង់សម្តែង ( កាលនោះ ) ខ្ញុំមិនដឹងនូវសេចក្តីសង្ស័យ ជាបុគ្គលដឹងសព្វចំពោះព្រះសាស្តា ព្រះអង្គជាអ្នកឈ្នះមារ ។ ជាអ្នកដឹកនាំពួក ជាមហាវីរបុរស ជាសារថីដ៏ប្រសើរខ្ពង់ខ្ពស់ជាងសារថីទាំងឡាយ ឬ សេចក្តីសង្ស័យក្នុងអរិយមគ្គ និងបដិបទា ក៏មិនមានដល់ខ្ញុំដែរ ។

បណ្តាបទទាំងនោះ បទថា **យទា** បានដល់ ក្នុងកាលណា ។ ព្រះថេរៈហៅខ្លួនឯងថា **អហំ** ។

បទថា **ធម្មំ** បានដល់ ធម៌ គឺអរិយសច្ចៈ ៤ ។ បទថា **អស្សោសឹ** ប្រែថា ស្តាប់ហើយ ។

បទថា **សត្ថុនោ** សេចក្តីថា ឈ្មោះថាសាស្តា ព្រោះអត្ថថា ទ្រង់ប្រៀនប្រដៅវេនេយ្យសត្វទាំងឡាយ ក្នុងប្រយោជន៍ទាំងឡាយ មានទិដ្ឋធម្មិកត្ថប្រយោជន៍ជាដើម ។

បទថា **កង្ខំ** ប្រែថា សេចក្តីសង្ស័យ ព្រះដ៏មានព្រះភាគ ឈ្មោះថាជា **សព្វញ្ញូ** ព្រោះអត្ថថា ទ្រង់ដឹងនូវសង្ខតធម៌និងអសង្ខតធម៌ដោយមិនមានចំណែកសេសសល់ ។ ឈ្មោះថា **អបរាជិតោ** ព្រោះមិនមានបុគ្គលធ្វើឲ្យចាលចាញ់បាន ទោះក្នុងទីណាក៏ដោយ ឈ្មោះថា **សត្ថវាហោ** ព្រោះអត្ថថា ជញ្ជូនវេនេយ្យសត្វ ចេញចាកសង្សារកន្តារ ទៅកាន់និព្វាន លោកពោលពាក្យ

អធិប្បាយទុកដូច្នេះថា

ចាប់តាំងពីកាលដែលព្រះសាស្ដាទ្រង់សំដែងធម៌ ខ្ញុំបានស្ដាប់ គឺបញ្ជូនចិត្តទៅតាមក្រសែសោតទ្វារ បានដល់ បានទទួលចតុសច្ចធម៌ ខ្ញុំមិនមានសេចក្ដីសង្ស័យ មិនមានការអល់អែក ក្នុងព្រះសម្មាសម្ពុទ្ធ ដែលឈ្មោះថា **សព្វញ្ញូ** គឺទ្រង់ឃើញដោយមិនមានអ្វីរាំង ព្រោះទ្រង់ដឹងនូវសម្មតិធម៌ទាំងដែលជាសង្ខតៈនិងអសង្ខតៈដោយមិនមានចំណែកសេសសល់ ដោយសយម្ភូញាណ ឈ្មោះថា **អបរាជិតោ** ព្រោះ ភាពជាបុគ្គលដែលមារទាំងនោះ ឈ្នះមិនបាន ព្រោះទ្រង់គ្របសង្កត់នូវមារទាំង ៥ ទុកបាន និងព្រោះភាពជាអ្នកមានចក្ក គឺធម៌ដែលបុគ្គលណាមួយ កម្ចាត់មិនបាន ក្នុងលោកព្រមទាំងទេវលោក ឈ្មោះថា **សត្ថវាហោ** ព្រោះទ្រង់នាំវេនេយ្យសត្វឆ្លងកន្ដារ មានលោកកន្ដារជាដើម ឈ្មោះថា **មហាវីរេ** ព្រោះមានភាពក្លាហានច្រើន ឈ្មោះថា **ឧត្តមេ** គឺឧត្តមជាងសារថីទាំងឡាយ ព្រោះទ្រង់ជាទីពឹងរបស់បុគ្គលដែលអាចទូន្មានបាននូវបុគ្គលដទៃ ដែលទូន្មានបានដោយក្រ និងព្រោះទូន្មានដោយវិធីទូន្មានក្រៃលែងជាងនោះដទៃថា ជាព្រះពុទ្ធពិតហ្ន៎ ឬមិនមែនជាព្រះពុទ្ធទេៗ

កង្ខា គឺសេចក្ដីសង្ស័យក្នុងអរិយមគ្គ ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយបែបនោះ និងក្នុងបដិបទាមានសីលជាដើម ដែលជាបដិបទាសមគួរដល់អរិយមគ្គនោះថាជាធម៌នាំសត្វឲ្យផុតទុក្ខបានមែន ឬមិនមែនហ្ន៎ ដូច្នេះមិនមាន គឺមិនមានសេចក្ដីសង្ស័យ ។ ក្នុងបាទគាថានេះ គប្បីជ្រាបថា ដោយ

ការពោលដល់ការមិនមានសេចក្តីសង្ស័យក្នុងអរិយធម៌ ឈ្មោះថា លោកពោលដល់សេចក្តីមិនសង្ស័យក្នុងអរិយសង្ឃទុកហើយនោះឯង ព្រោះកាលតាំងនៅក្នុងមគ្គនោះហើយ រមែងមិនមានសភាពដទៃដូច្នេះឯង ។

## អដ្ឋកថា មេឡជិនត្ថេរគាថា ចប់

## រាធត្ថេរគាថា

[ ១២៨ ] ភ្លៀងរមែងលេចធ្លុះនូវផ្ទះដែលប្រក់មិនល្អ យ៉ាងណាមិញ រាគៈរមែងចាក់ធ្លុះចិត្តដែលមិនបានអប់រំល្អ ក៏យ៉ាងនោះដែរ ។ ភ្លៀងរមែងមិនលេចធ្លុះនូវផ្ទះដែលប្រក់ល្អ យ៉ាងណាមិញ រាគៈរមែងមិនចាក់ធ្លុះចិត្តដែលបានអប់រំល្អ ក៏យ៉ាងនោះដែរ ។

រាធត្ថេរ ។

## អដ្ឋកថា

## រាធត្ថេរគាថា

[ ១២៨ ] គាថារបស់ព្រះរាធត្ថេរ មានពាក្យផ្តើមថា **យថា អគារំ ទុច្ឆន្នំ** ដូច្នេះ ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮមកថាក្នុងពុទ្ធុប្បាទរបស់ព្រះដ៏មានព្រះភាគព្រះនាមថា បទុមុត្តរៈ កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូល ក្នុងនគរហង្សវតី ។ ដល់នូវភាពជាអ្នកដឹងក្តីហើយ ចូលកាន់វិហារគាល់ព្រះសាស្តា ថ្វាយបង្គំហើយអង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ឃើញព្រះសាស្តាទ្រង់តែងតាំងភិក្ខុមួយរូបទុកក្នុងតំណែងនៃភិក្ខុដែលក្រៃលែងជាងភិក្ខុទាំងឡាយខាងបដិភាណៈ ខ្លួនឯងចង់បានតំណែងនោះ ទើបបំពេញមហាទាន និងបានធ្វើការបូជា ដល់ព្រះសាស្តាយ៉ាងឧឡារ តាំងបណិធានទុកយ៉ាងនេះ ចុតិអំពីអត្តភាពនោះហើយ សន្សំបុណ្យទុកក្នុងភពនោះៗ ក្នុងកាលរបស់ព្រះដ៏មានព្រះភាគព្រះនាមថា វិបស្សី កើតក្នុងផ្ទះ

មានត្រកូល សម្រេចភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយឃើញព្រះសាស្តាត្រាច់បិណ្ឌបាត មានចិត្តជ្រះថ្លា បានថ្វាយផ្លែស្វាយមានរសផ្អែម ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ កើតក្នុងទេវលោក ធ្វើបុណ្យហើយអន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងកាលព្រះដ៏មានព្រះភាគនៃយើងទាំងឡាយ កុលបុត្តនេះកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងនគររាជគ្រឹះ មានឈ្មោះថា រាធៈ ។ ចម្រើនវ័យហើយនៅគ្រប់គ្រងផ្ទះ ក្នុងកាលខ្លួនចាស់ត្រូវកូននិងប្រពន្ធរង្កៀស បណ្តេញចេញពីផ្ទះ ទើបទៅកាន់វិហារដោយគិតថាប្រយោជន៍អ្វីដោយការគ្រប់គ្រងផ្ទះរបស់អញ អញនឹងបួស ចូលទៅរកភិក្ខុទាំងឡាយដែលជាថេរៈ សូមបព្វជ្ជា កាលព្រះថេរៈទាំងនោះបដិសេធ ព្រោះយល់ថា ព្រាហ្មណ៍នេះចាស់ហើយ មិនអាចបំពេញវត្តបដិបត្តិបាន ទើបទៅកាន់សម្នាក់របស់ព្រះសាស្តា ក្រាបទូលអធ្យាស្រ័យរបស់ខ្លួន ឲ្យទ្រង់ជ្រាបកាលព្រះសាស្តាទ្រង់ប្រមើលមើលភាពសម្បូរនៃឧបនិស្ស័យ ហើយត្រាស់ឲ្យព្រះធម្មសេនាបតីរៀបចំបំបួស ផ្តើមវិបស្សនាហើយ សម្រេចអរហត្តក្នុងកាលមិនយូរឡើយសមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស គួរទទួលនូវគ្រឿងបូជា កំពុងស្តេចពុទ្ធដំណើរទៅតាមច្រកហើយបានប្រគេនចារផល ( ផ្លែឈើ ) ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ

ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បាន
ប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ នៅក្នុងសម្នាក់របស់ព្រះបរមសាស្តា ជាបុគ្គលក្រៃលែងជាងភិក្ខុទាំងឡាយ ខាងបដិភាណ ដែលជាហេតុឲ្យមានការយល់ក្នុងព្រះធម្មទេសនារបស់ព្រះសាស្តា យ៉ាងជាក់ច្បាស់មែនពិត ព្រះធម្មទេសនាថ្មីៗរបស់ព្រះទសពលជាក់ច្បាស់ឡើង ព្រោះអាស្រ័យការសំដែងនូវទិដ្ឋិរបស់ព្រះថេរៈក៏មាន ។

ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកឈ្លាសវៃក្នុងបដិភាណៈ ស្រេចនឹងរាធៈប្រសើរជាងគេ ។ ថ្ងៃមួយ ព្រះថេរៈកាលសរសើរភាវនាថា សត្វទាំងនេះដែលរាគៈគ្របសង្កត់បាន ព្រោះមិនចម្រើនភាវនា កាលមានការចម្រើនភាវនា រាគៈក៏គ្របសង្កត់មិនបាន ដូច្នេះ ទើបពោលគាថា ២ ថា

ភ្លៀងរមែងលេចធ្លុះនូវផ្ទះដែលប្រក់មិនល្អ យ៉ាងណាមិញរាគៈ
រមែងចាក់ធ្លុះចិត្តដែលមិនបានអប់រំល្អក៏យ៉ាងនោះដែរ ។ ភ្លៀង
រមែងមិនលេចធ្លុះនូវផ្ទះដែលប្រក់ល្អ យ៉ាងណាមិញរាគៈរមែង
មិនចាក់ធ្លុះចិត្តដែលបានអប់រំល្អក៏យ៉ាងនោះដែរ ។

បណ្តាបទទាំងនោះ បទថា **អគារំ** បានដល់ ផ្ទះប្រភេទណានីមួយ ។ បទថា **ទុច្ឆន្នំ** បានដល់ ប្រក់រង្វើលៗ គឺមានប្រហោងតូចធំ ។ បទថា **សម–**

---

១-ក្នុងអបទានជាព្រះ ចារផលិយត្ថេរ ។

**តិវិជ្ឈតិ** សេចក្ដីថា ភ្លៀងដែលធ្លាក់រមែងលេចស្រោចបាន ។

បទថា **អភាវិតំ** សេចក្ដីថា ចិត្តដែលមិនបានអប់រំហើយ ព្រោះវៀរចាកភាវនា ប្រៀបដូចភ្លៀងដែលលេចស្រោចផ្ទះបាន ។

បទថា **រាគោ សមតិវិជ្ឈតិ** សេចក្ដីថា មិនមែនរាគៈ លេចស្រោចបានតែម្យ៉ាងប៉ុណ្ណោះ សូម្បីសព្វកិលេស មានទោសៈ មោហៈ និងមានៈជាដើម ក៏រមែងលេចស្រោចចិត្តបែបនោះបានដូចគ្នា ។

បទថា **សុភាវិតំ** បានដល់ ចិត្តដែលអប់រំល្អហើយដោយសមថភាវនា និងវិបស្សនាភាវនា កិលេសទាំងឡាយ មានរាគៈជាដើម រមែងមិនអាចលេចស្រោចចិត្តបែបនោះបាន ដូចផ្ទះដែលប្រក់ល្អហើយ ភ្លៀងលេចស្រោចមិនបានដូច្នោះ ។

អដ្ឋកថា រាធត្ថេរគាថា ចប់

## សុភូតត្ថេរគាថា

[ ១២៩ ] ជាតិរបស់ខ្ញុំអស់ហើយ សាសនាព្រះជិនស្រី ខ្ញុំបានប្រព្រឹត្ត ចប់ហើយ ឃ្នាប ( បណ្ដាញនៃទិដ្ឋិ ) ខ្ញុំបានលះបង់ហើយ តណ្ហាគ្រឿង នាំទៅកាន់ភព ខ្ញុំក៏ដកចោលហើយ កុលបុត្តចេញចាកផ្ទះចូលកាន់ផ្នួសដើម្បី ប្រយោជន៍ដល់គុណវិសេសណា ប្រយោជន៍ គឺការអស់ទៅនៃសញ្ញោជនៈ ទាំងអស់នោះ ខ្ញុំក៏បានដល់ហើយ ។

សុភូតត្ថេរ ។

## អដ្ឋកថា

## សុភូតត្ថេរគាថា

[ ១២៩ ] គាថារបស់ព្រះសុភូតត្ថេរ មានពាក្យផ្ដើមថា **ខីណា ហិ មយ្ហំ ជាតិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូច ម្ដេច ។

ព្រះថេរៈនេះ ជាអ្នកមានអធិការធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំ បុណ្យទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា សិខី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ថ្ងៃមួយ ឃើញព្រះ សាស្ដាមានចិត្តជ្រះថ្លា បានថ្វាយផ្លែក្រូចព្រៃ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះទៅកើតក្នុងទេវលោក ធ្វើបុណ្យហើយ អន្ទោលទៅមកតែក្នុងសុគតិភពប៉ុណ្ណោះ ។ ក្នុងពុទ្ធុប្បាទនេះកើតជាប្អូនប្រុស

របស់ព្រះរាជគ្រូ ដែលខ្ញុំពោលទុកហើយមុននេះ មានឈ្មោះថា សុរាធៈ កាលព្រះរាជគ្រូជាបងប្រុសបួសហើយ កុលបុត្តនោះក៏ចេញបួស ចម្រើនវិបស្សនា សម្រេចអរហត្តក្នុងកាលមិនយូរឡើយ ។ សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ខ្ញុំបានឃើញនូវព្រះលោកនាយក ទ្រង់រុងរឿងដូចផ្កាកណិការ ឬដូចព្រះចន្ទពេញបូណ៌មី ឬក៏ដូចឈើប្រចាំទ្វីបដ៏រុងរឿង ។ ខ្ញុំមានចិត្តជ្រះថ្លា បានយកផ្លែក្រូចថ្លុងទៅថ្វាយព្រះសាស្តា ជាទក្ខិណេយ្យបុគ្គលទ្រង់មានព្យាយាម ដោយដៃរបស់ខ្លួន ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈ កាលសម្រេចអរហត្តហើយ កាលនឹងព្យាករព្រះអរហត្តផលដើម្បីសម្ដែងថា សាសនា ជានិយ្យានិកធម៌ ទើបពោលគាថា ២ ថា

ជាតិរបស់ខ្ញុំអស់ហើយ សាសនាព្រះជិនស្រី ខ្ញុំបានប្រព្រឹត្តចប់ហើយ ឃ្នាប ( បណ្ដាញនៃទិដ្ឋិ ) ខ្ញុំបានលះបង់ហើយ

---

១-ក្នុងអបទានជាព្រះ មាតុលុង្គផលទាយកត្ថេរ ។ ព្រះថេរៈអង្គនេះ បានថ្វាយផ្លែក្រូចថ្លុងដូចព្រះថេរៈឈ្មោះថា ពេលុវសីសត្ថេរ ក្នុងឯកនិបាតដែរ ហើយអបទានក៏ដូចគ្នាតែមួយ បណ្ឌិតគប្បីជ្រាប ។

តណ្ហាគ្រឿងនាំទៅកាន់ភព ខ្ញុំក៏ដកចោលហើយ ។ កុលបុត្ត
ចេញចាកផ្ទះចូលកាន់ផ្នួស ដើម្បីប្រយោជន៍ដល់គុណវិសេស
ណា ប្រយោជន៍ គឺការអស់ទៅនៃសញ្ញោជនៈទាំងអស់នោះ
ខ្ញុំក៏បានដល់ហើយ ។

បណ្តាបទទាំងនោះ បទថា **វិណា** សេចក្តីថា ដល់ហើយ គឺដល់នូវការអស់ទៅ គឺការអស់យ៉ាងក្រៃលែង ។ បទថា **ជាតិ** បានដល់ ភព ឬការកើតក្នុងភព ។ បទថា **វុសិតំ ជិនសាសនំ** សេចក្តីថា ពាក្យទូន្មានរបស់ព្រះសម្មាសម្ពុទ្ធ ព្រះនាមថា ជិនៈ បានដល់ មគ្គព្រហ្មចរិយៈ ដែលខ្ញុំនៅហើយ គឺនៅចប់ហើយ ។ បទថា **បហីនោ ជាលសង្ខាតោ** សេចក្តីថា ទិដ្ឋិ និងអវិជ្ជា ដែលបាននាមថា បណ្តាញ ព្រោះគ្របសង្កត់សន្តានរបស់សត្វនិងមិនឲ្យឱកាសដើម្បីដក ដែលខ្ញុំលះហើយ គឺដកឡើងដោយមគ្គ ។ បទថា **ភវនេត្តិ សមូហតា** សេចក្តីថា តណ្ហា ដែលយើងតែងដឹងថានាំសត្វទៅកាន់ភពព្រោះនាំសត្វទៅកាន់ភពមានកាមភពជាដើម គឺញ៉ាំងសត្វឲ្យវិលទៅ ដែលខ្ញុំកើចកន្ទ្រាក់ហើយ ។ បទថា **យស្សត្ថាយ បព្វជិតោ** សេចក្តីថា ខ្ញុំចេញបួស គឺចេញចាកផ្ទះបព្វជ្ជា គឺបួសជាបព្វជិតដើម្បីប្រយោជន៍ណា គឺដើម្បីផលឯណា អធិប្បាយថា ប្រយោជន៍គឺប្រយោជន៍យ៉ាងក្រៃលែង ពោលគឺព្រះនិព្វាន និងប្រយោជន៍របស់ខ្លួន ពោលគឺអរហត្តដែលជាគ្រឿងអស់ទៅនៃសំយោជនៈទាំងឡាយមានឱរម្ភាគិយសំយោជនៈនិងឧទ្ធម្ភាគិយសំយោជនៈទាំងពួងដែលជាគ្រឿងចង ក៏ខ្ញុំសម្រេចហើយដោយលំដាប់ គឺដល់ហើយ ។

**អដ្ឋកថា សុរាធត្ថេរគាថា ចប់**

## គោតមត្ថេរគាថា

[ ១៣០ ] ពាក្យសច្ចៈ ចំពោះស្ត្រីណា ដែលគេគប្បីរក្សាគ្រប់កាលទាំងពួង ជាពាក្យដែលគេរកបានដោយក្រក្រៃលែង ពួកជនណាមិនជាប់ចំពាក់ចំពោះស្ត្រីទាំងនោះ ពួកជននោះឈ្មោះថាមុនី រមែងដេកនៅជាសុខ ។

នៃកាម យើងបានប្រព្រឹត្តនូវការសម្លាប់អ្នកហើយ ឥឡូវនេះ យើងមិនជាប់បំណុលនឹងអ្នកទេ យើងនឹងទៅកាន់ព្រះនិព្វានឥឡូវនេះ ដែលជាទីទៅហើយមិនសោយសោក ។

គោតមត្ថេរ ។

## អដ្ឋកថា

## គោតមត្ថេរគាថា

[ ១៣០ ] គាថារបស់ព្រះគោតមត្ថេរ មានពាក្យផ្តើមថា **សុខំ សុបន្តិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះថេរៈនេះ ក៏ជាអ្នកមានបុញ្ញាធិការ ដែលធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ព្រះនាមថាវិបស្សី កើតក្នុងផ្ទះមានត្រកូលដ៏ឥន្ទក្តីហើយ ថ្ងៃមួយឃើញព្រះដ៏មានព្រះភាគ មានចិត្តជ្រះថ្លា បានថ្វាយផ្លែអាមោទៈ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ កើតក្នុងទេវលោក ធ្វើបុណ្យហើយ

អន្ទោលទៅមកតែក្នុងសុគតិភពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ក្រុងរាជគ្រឹះមាននាមថា គោតមៈ ក្នុងពេលមានអាយុ ៧ ខួប ធ្វើពុតជាមនុស្សពិការភ្នែកដើរសូមប្រាក់បានទ្រព្យ ១០០០ រក្សាទុកក្នុងទីដែលផុតភ័យ ហើយបំពេញវត្ត លុះអាយុបាន ១៦-១៧ ឆ្នាំ ត្រូវមិត្តអាក្រក់ដឹកនាំទៅក្នុងកាមារម្មណ៍ ឲ្យទ្រព្យ ១០០០ នោះដល់ស្រីដែលអាស្រ័យរូបចិញ្ចឹមជីវិតម្នាក់ សាបសូន្យព្រហ្មចរិយៈ កាលស្រីនោះ សម្តែងនូវអាការៈនឿយណាយព្រោះឃើញលក្ខណៈជាអ្នកប្រព្រឹត្តព្រហ្មចរិយៈរបស់គាត់ គាត់កើតនូវការនឿយណាយដោយការនៅរួមគ្នាត្រឹមមួយរាត្រី នឹកដល់ការសាបសូន្យព្រហ្មចរិយៈរបស់ខ្លួននិងការវិនាសទ្រព្យ មានវិប្បដិសារៈថា អញធ្វើកម្មមិនសមគួរហ្ន៎ ។ ព្រះសាស្តាទ្រង់ជ្រាបហេតុសម្បត្តិនិងការរាយមាយនៃចិត្តរបស់កុលបុត្តនោះ ទើបបង្ហាញខ្លួនក្នុងទីជិត ។ កុលបុត្តនោះ ឃើញព្រះសាស្តាហើយ មានចិត្តជ្រះថ្លាចូលទៅគាល់ ។ ព្រះដ៏មានព្រះភាគទ្រង់សម្តែងធម៌ដល់កុលបុត្តនោះ កុលបុត្តនោះស្តាប់ធម៌ហើយជាអ្នកមានសទ្ធាចេញបួសបានសម្រេចអរហត្តក្នុងខណៈដែលកោរសក់ស្រេចនោះឯងសមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ខ្ញុំបានឃើញនូវព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស គួរទទួលនូវគ្រឿងបូជា ដែលទ្រង់កំពុងតែស្តេចទៅតាមច្រក ហើយប្រគេនផ្លែអមោរព្រឹក្ស ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់

ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុត
បំផ្លាញហើយ ។ បេ ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន
ប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈ សម្រេចអរហត្តហើយ ញុំាងកាលវេលាឲ្យប្រព្រឹត្តទៅដោយសុខក្នុងឈាន សម្លាញ់ដែលជាគ្រហស្ថម្នាក់ ចូលទៅរកព្រះថេរៈនោះ សួរថា លោកម្ចាស់មុនបួស បានធ្វើដូចម្ដេចក្នុងទ្រព្យដែលបានមកព្រោះសូម ព្រះថេរៈស្ដាប់ដូច្នោះហើយ មិនប្រាប់ថា អាត្មាធ្វើកម្មឈ្មោះនេះ បានប្រកាសទោសក្នុងមាតុគ្រាម ដើម្បីនឹងព្យាករអរហត្តផល ដោយការចង្អុលបង្ហាញដល់ភាពដែលខ្លួនជាអ្នកមានរាគៈទៅប្រាសហើយ ទើបពោលគាថា ២ ថា

ពាក្យសច្ចៈ ចំពោះស្ត្រីណា ដែលគេគប្បីរក្សា គ្រប់កាល
ទាំងពួង ជាពាក្យដែលគេរកបានដោយក្រក្រៃលែង ពួកជន
ណា មិនជាប់ចំពាក់ចំពោះស្ត្រីទាំងនោះ ពួកជននោះឈ្មោះថា
មុនី រមែងដេកនៅជាសុខ ។

នៃកាម យើងបានប្រព្រឹត្តនូវការសម្លាប់អ្នកហើយ ឥឡូវ
នេះយើងមិនជាប់បំណុលនឹងអ្នកទេយើងនឹងទៅកាន់ព្រះនិព្វាន
ឥឡូវនេះ ដែលជាទីទៅហើយមិនសោយសោក ។

បណ្ដាបទទាំងនោះ បទថា **សុខំ សុបន្តិ មុនយោ យេ ឥត្ថីសុ ន ពជ្ឈរេ** សេចក្ដីថា មុនីពួកណា មិនជាប់ជំពាក់ក្នុងស្រីទាំងឡាយ ដែលជាអារម្មណ៍

---

១-ក្នុងអបទានជាព្រះ អមោរផលិយត្ថេរ ។

ឬជាហេតុដោយគ្រឿងចង គឺរាគៈ មុនីទាំងនោះជាអ្នកមានតបៈ មានឥន្ទ្រិយសង្រួមហើយ រមែងដេកលក់ជាសុខ គឺនៅជាសុខ អធិប្បាយថា ទុក្ខរមែងមិនមានដល់មុនីទាំងនោះ ។ បទថា **សុបន្តិ** នេះ ត្រឹមតែជាគំរូ ។

បទថា **សទា វេ រក្ខិតព្វាសុ** សេចក្ដីថា ដែលបុរសរវាំងរក្សាអស់កាលទាំងពួងដោយចំណែកមួយ អធិប្បាយថា ស្រីទាំងឡាយ សូម្បីឲ្យនៅលើប្រាសាទជាន់ទី ៧ ដែលប្រាសចាកបុរស សូម្បីរក្សាទុកខាងក្នុងបន្ទប់ ក៏មិនអាចរក្សាទុកបាន ព្រោះហេតុនោះ ស្រីទាំងនោះ ទើបជាបុគ្គលដែលត្រូវរក្សាសព្វកាល ដូចមេគោស៊ីសម្លូងដូច្នោះ ។ ម្យ៉ាងទៀត ព្រោះស្រីមានចិត្តសាំញ៉ាំ ទើបប្ដីត្រូវរវាំងប្រយ័ត្នសព្វកាល ដោយការឲ្យសំពត់និងគ្រឿងប្រដាប់ជាដើម ដើម្បីមិនឲ្យស្រីផ្លាស់ប្ដូរចិត្តទៅជាដទៃ ឬឈ្មោះថា ត្រូវរវាំងប្រយ័ត្ន ព្រោះស្រីត្រូវរក្សាការស្អាត ដោយការបិទបាំងសភាពនៃរាងកាយដោយផ្កាកម្រងនិងគ្រឿងក្រអូបជាដើម ។

បទថា **យាសុ សច្ចំ សុទុល្លភំ** សេចក្ដីថា ពាក្យសច្ចៈ មិនអាចរកបានក្នុងស្រីពួកណា អធិប្បាយថា ធម្មតាស្រីទាំងឡាយ ទោះចូលទៅកាន់គំនរភ្លើងក៏បាន ផឹកថ្នាំពុលក៏បាន នឹងនាំសស្ត្រាមកក៏បាន ត្រូវចងកស្លាប់ក៏បាន តែមិនអាចតាំងនៅក្នុងសច្ចៈបាន ព្រោះដូច្នោះទើបព្រះថេរៈសម្ដែងថា មុនីទាំងឡាយវៀរស្រីបែបនេះបានហើយទើបនៅជាសុខ ។

ឥឡូវនេះ ព្រះថេរៈកាលនឹងសម្ដែងថា កាមដែលមុនីទាំងឡាយជាប់ជំពាក់ក្នុងស្រីបែបនោះ ព្រោះមិនទាន់លះបាននោះ លោកលះបានដោយល្អ

ហើយ ព្រោះលោកមិនមានការប្រាថ្នាដោយចំណែកមួយ ទើបពោលគាថាទី ២ ទុក ។

បទថា **វធំ ចរិស្ន តេ កាម** សេចក្ដីថា ម្នាលកាមដ៏ចម្រើន ខ្ញុំប្រព្រឹត្ត ព្រហ្មចរិយៈដើម្បីសម្លាប់អ្នក គឺផ្ដាច់ផ្ដិលដោយចំណែកមួយ ដោយអរិយ-មគ្គ ។ បាឋៈថា **ឃរំ ចរិស្នសេ** ដូច្នេះក៏មាន សេចក្ដីថា ខ្ញុំបានប្រព្រឹត្តមគ្គ ព្រហ្មចរិយៈដើម្បីសម្លាប់ គឺដើម្បីប្រហារអ្នក ។

បទថា **អនណាឆានិ តេ មយំ** សេចក្ដីថា ម្នាលកាម ឥឡូវនេះ គឺ ចាប់តាំងពីពេលដែលយើងបានសម្រេចអរហត្ត យើងមិនជាកូនបំណុលរបស់ អ្នក គឺយើងមិនរែកបំណុលរបស់អ្នកតទៅ ព្រោះតណ្ហាដែលធ្វើនូវបំណុល យើងលះបានហើយ អធិប្បាយថា បុគ្គលដែលមិនទាន់ប្រាសចាករាគៈ រមែង ដូចជាអ្នករែកបំណុលរបស់កាម ព្រោះនៅប្រព្រឹត្តទៅក្នុងអំណាចរបស់រាគៈ ចំណែកបុគ្គលដែលប្រាសចាករាគៈ ឈានកន្លងកាមនោះបានហើយ ប្រកបទៅ ដោយភាពជាឥស្សរៈនៃចិត្តដ៏ឧត្ដម ព្រោះមិនបានជាប់បំណុលនោះឯង ទើបខ្ញុំ ឈ្មោះថា ដល់ព្រះនិព្វាន ជាទីដែលបុគ្គលទៅហើយមិនសោក បានដល់ មិនសោយសោក ព្រោះមិនមានហេតុនៃសេចក្ដីសោកដោយប្រការទាំងពួង ដែលមានការសម្រេចព្រះនិព្វានជាហេតុ អធិប្បាយថា ឥឡូវនេះ ខ្ញុំដល់ គឺ ដល់ដោយលំដាប់នូវអនុបាទិសេសនិព្វាននោះឯង ។

**អដ្ឋកថា គោតមត្ថេរគាថា ចប់**

# វសភត្ថេរគាថា

[ ១៣១ ] កុហកបុគ្គលនោះសម្លាប់ខ្លួនឯង ( ដោយការប្រព្រឹត្តិលាមក ) មុន សម្លាប់បុគ្គលដទៃក្រោយ បុគ្គលបំផ្លាញខ្លួនឯង បំផ្លាញបានដោយងាយ ដូចព្រានបក្សីសម្លាប់ ( សត្វស្លាប ) ដោយផ្ទាក់ ។ បុគ្គលមានតែវណ្ណៈខាងក្រៅ មិនឈ្មោះថាព្រាហ្មណ៍ទេ លុះតែមានវណ្ណៈខាងក្នុង ទើបឈ្មោះថាព្រាហ្មណ៍ បពិត្រសុជម្បតិ បាបកម្មមានក្នុងបុគ្គលណា បុគ្គលនោះឈ្មោះថាបុគ្គលខ្មៅ ។

**វសភត្ថេរ ។**

**ឧទ្ទាន**

និយាយអំពីឧត្តរត្ថេរ ១ បិណ្ឌោលភារទ្វាជត្ថេរ ១ វល្លិយត្ថេរ ១ គង្គាតីរិយត្ថេរជាឥសី ១ អជិនត្ថេរ ១ មេឡជិនត្ថេរ ១ រាធត្ថេរ ១ សុរាធត្ថេរ ១ គោតមត្ថេរ ១ វសភត្ថេរ ១ ព្រះថេរៈទាំង ១០ នេះជាអ្នកមានឫទ្ធិច្រើន ។

**ចប់ បឋមវគ្គ ។**

# អដ្ឋកថា

## វសភត្ថេរគាថា

[ ១៣១ ] គាថារបស់ព្រះវសភត្ថេរ មានពាក្យផ្ដើមថា **បុញ្ញេ ហានតិ អត្តានំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះថេរៈនេះ ក៏ជាអ្នកមានបុញ្ញាធិការ ដែលធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយទុកក្នុងភពនោះៗ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងលោកដែលមិនមានព្រះពុទ្ធ ចម្រើនវ័យហើយ ដល់នូវសេចក្ដីសម្រេចក្នុងវិជ្ជានិងសិប្បៈរបស់ព្រាហ្មណ៍ទាំងឡាយ លះការនៅគ្រប់គ្រងផ្ទះបួសជាតាបស ព្រោះជាអ្នកមានអធ្យាស្រ័យបង្អោនទៅក្នុងនេក្ខម្ម មានតាបស ១ ម៉ឺន ៤ ពាន់ រូបជាបរិវារ សាងអាស្រមនៅត្រង់ភ្នំឈ្មោះសមគ្គៈ មិនឆ្ងាយអំពីព្រៃហិមពាន្ត ញុំាងឈាននិងអភិញ្ញាឲ្យកើតហើយ បានឲ្យឱវាទនិងអនុសាសនីដល់តាបសទាំងឡាយ ។ ថ្ងៃមួយ គិតយ៉ាងនេះថា ឥឡូវនេះ អាត្មាអញនេះឯងជាបុគ្គលដែលតាបសទាំងនេះ ធ្វើសក្ការៈ គោរព បូជា តែអាត្មាអញរកបុគ្គលដែលគួរបូជាមិនបាន ការនៅដោយមិនគោរពបុគ្គលណាមួយជាទុក្ខក្នុងលោក ។

កាលគិតយ៉ាងនេះហើយ ព្រោះភាពជាអ្នកមានបុញ្ញាធិការ ដែលធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ ទើបកុលបុត្តនោះ រឭកដល់ការបូជា និងសក្ការៈដែលខ្លួនធ្វើហើយ ក្នុងចេតិយរបស់ព្រះពុទ្ធអង្គមុនៗទាំងឡាយថា កុំដូច្នេះឡើយ អាត្មាអញគប្បីធ្វើចេតិយខ្សាច់ឧទ្ទិសដល់ព្រះពុទ្ធអង្គមុនៗ ហើយធ្វើការបូជាដូច្នេះ ជាបុគ្គលត្រេកអរហើយ និម្មិតព្រះស្តូបខ្សាច់សម្រេចដោយ

មាស ដោយឫទ្ធិ ធ្វើនូវការបូជារាល់ៗថ្ងៃ ដោយផ្កាប្រមាណ ៣ ពាន់ ដែលសម្រេចដោយមាសជាដើម ធ្វើបុណ្យដរាបដល់អស់អាយុ មានឈានមិនសាបសូន្យធ្វើកាលកិរិយាហើយកើតក្នុងព្រហ្មលោក ។

កុលបុត្តនោះ តាំងនៅក្នុងព្រហ្មលោកនោះ ដរាបដល់អស់អាយុហើយ ចុតិចាកព្រហ្មលោកនោះ កើតក្នុងឋានតាវត្តិង្ស អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលលិច្ឆវីក្នុងក្រុងវេសាលី មានឈ្មោះថាវសភៈ ចម្រើនវ័យហើយ ឃើញពុទ្ធានុភាពក្នុងកាលដែលទ្រង់ទៅកាន់នគរវេសាលី ជាអ្នកមានសទ្ធាបួសហើយផ្តើមវិបស្សនាសម្រេចអរហត្តក្នុងកាលមិនយូរឡើយ ។ សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ក្នុងទីជិតនៃព្រៃហិមពាន្ត មានភ្នំមួយឈ្មោះយមកៈ អាស្រមខ្ញុំបានធ្វើហើយ បណ្ណសាលាខ្ញុំក៏បានសាងល្អហើយ ក្បែរជើងភ្នំនោះ ។ ខ្ញុំជាជដិលឈ្មោះនារទៈ ជាអ្នកមានព្យាយាមខ្ពង់ខ្ពស់ សិស្ស ១៤.០០០ តែងបម្រើខ្ញុំសព្វវេលា ។ ខ្ញុំជាអ្នកចូលចិត្តសេចក្តីស្ងប់ស្ងាត់ មានចិត្តស្ងប់រម្ងាប់ ក្នុងកាលនោះខ្ញុំគិតយ៉ាងនេះថា មហាជនតែងបូជាអាត្មាអញ អញមិនបានបូជាអ្នកណាមួយ ។ ជនអ្នកឲ្យឱវាទដល់អាត្មាអញមិនមាន ជនអ្នកស្តីថាណាម្នាក់ក៏មិនមាន អាត្មាអញមិនមានអាចារ្យនិងឧបជ្ឈាយ៍ អាត្មាអញសម្រេចការនៅក្នុងព្រៃ ។ អាត្មាអញ

ចូលទៅបម្រើបុគ្គលណាដែលមានចិត្តធ្ងន់ បុគ្គលនោះជាអាចារ្យរបស់អាត្មាអញមិនមាន ការនៅក្នុងព្រៃឈ្មោះថាឥតប្រយោជន៍ ។ អាត្មាអញ គប្បីស្វែងរកគ្រូដែលគួរបូជានិងគ្រូដែលគួរសរសើរ អាត្មាអញនឹងទៅជាមួយបុគ្គលគួរជាពឹងអាស្រ័យបាននោះ ទើបបុគ្គលណាមួយ នឹងមិនតិះដៀលអាត្មាអញឡើយ ។ ស្ទឹងមាន ច្រាំងរាក់ មានកំពង់ល្អ ជាទីរីករាយនៃចិត្ត ដេរដាសដោយផ្កាខ្យាច់សសុទ្ធ តាំងនៅជិតអាស្រមរបស់ខ្ញុំ ។ កាលនោះ ខ្ញុំបានដើរចូលទៅរកស្ទឹងឈ្មោះអមរិកៈ ហើយប្រមូលយកផ្កាខ្សាច់មកធ្វើជាបុឡិនចេតិយ ( ចេតិយខ្សាច់ ) ។ ព្រះសម្ពុទ្ធទាំងឡាយអង្គណាទ្រង់ធ្វើនូវទីបំផុតនៃភព ជាអ្នកប្រាជ្ញ ព្រះស្តូបនៃព្រះសម្ពុទ្ធទាំងឡាយនោះ ក៏ប្រាកដដូច្នោះ ខ្ញុំធ្វើនូវព្រះស្តូបនោះឲ្យជានិមិត្ត ។ លុះខ្ញុំធ្វើរួចហើយ ខ្ញុំបានសាងនូវព្រះស្តូប ជាវិការៈនៃមាសលើផ្កាខ្សាច់ ខ្ញុំបានបូជានូវផ្កាកណ្តឹងមាសអស់ ៣ ពាន់ ។ ខ្ញុំមានបីតិកើតហើយ ធ្វើនូវអញ្ជលីនមស្ការរាល់ល្ងាចព្រឹក ថ្វាយបង្គំចេតិយផ្កាខ្សាច់ ហាក់ដូចជាថ្វាយបង្គំនូវព្រះសម្ពុទ្ធ ក្នុងទីចំពោះព្រះភក្ត្រ ។ កាលណាកិលេសទាំងឡាយកើតឡើង វិតក្កៈទាំងឡាយដែលអាស្រ័យនូវផ្ទះគឺកាមគុណ ( កើតឡើងក្នុងកាលនោះ ) ខ្ញុំរឭកដល់ព្រះស្តូបដែលខ្ញុំធ្វើល្អហើយ ខ្ញុំពិចារណា

ឃើញច្បាស់ក្នុងខណៈនោះឯង ។ ខ្ញុំបានចូលទៅរកព្រះស្តូប នៃព្រះលោកនាយក ទ្រង់ដឹកនាំសត្វ ដូចពួកឈ្មួញ ហើយទូន្មានខ្លួនថា នែអ្នកនិទ្ទិក្ខុ បើអ្នកហ៊ានបិទបាំងកិលេស ការដែលអ្នកបិទបាំងកិលេសនេះ ជាអំពើមិនគួរ ដល់អ្នកទេ ។ កាលណាខ្ញុំរំពឹងនឹកព្រះស្តូប ឈ្មោះថាខ្ញុំមានសេចក្តីគោរព ក្នុងកាលនោះ ខ្ញុំបានបន្ទោបង់នូវវិតក្កៈអាក្រក់ ដូចដំរីដ៏ប្រសើរដែលត្រូវគេចាក់ដោយកង្វេរ ។ មច្ចុរាជតែងញាំញីខ្ញុំកាលនៅយ៉ាងនេះ លុះខ្ញុំធ្វើមរណកាលក្នុងទីនោះ បានទៅកើតឯព្រហ្មលោក ។ ខ្ញុំនៅក្នុងព្រហ្មលោក ដរាបដល់អស់អាយុ ហើយថយមកកើតក្នុងឋានត្រៃត្រិង្ស បានជាធំ ជាងទេវតាសោយរាជ្យក្នុងទេវលោកអស់ ៨០ ដង ។ ខ្ញុំបានជាស្តេចចក្រពត្តិអស់ ៣០០ ដង បានសោយប្រទេសរាជ្យដ៏ធំទូលាយរាប់ជាតិមិនអស់ ។ ខ្ញុំបានសោយនូវផលនៃផ្កាកណ្តឹងមាសទាំងនោះ ជន ២ ម៉ឺន ២ ពាន់តែងចោមរោមខ្ញុំក្នុងកព ។ ព្រោះខ្ញុំបានសាងព្រះស្តូប លម្អងធូលី មិនប្រឡាក់កាយនៃខ្ញុំ ញើសទាំងឡាយក្នុងខ្លួនមិនហូរចេញ ខ្ញុំមានពន្លឺល្អ ។ ឱ ! ព្រះស្តូបខ្ញុំបានធ្វើល្អហើយ ស្ទឹងឈ្មោះអមរិកៈ ខ្ញុំបានឃើញល្អហើយ ព្រោះខ្ញុំបានធ្វើព្រះស្តូបខ្សាច់ ទើបបានសម្រេចនូវព្រះនិព្វានជាធម្មជាតមិនកម្រើក ។ សត្វមានសេចក្តីប្រាថ្នាធ្វើ

កុសលជាអ្នកប្រកាន់នូវធម៌មានខ្លឹម មិនចាំបាច់មានទីជាស្រែ ឬទីមិនជាស្រែឡើយ ស្រេចហើយត្រឹមតែសេចក្តីប្រតិបត្តិជាគុណមានខ្លឹម ។ បុរសមានកម្លាំងអាចឆ្លងសមុទ្រ ស្ទុះទៅក្នុងមហាសមុទ្របាន ព្រោះកាន់កំណាត់ឈើតូច ។ ខ្ញុំឆ្លងសមុទ្រធំព្រោះអាស្រ័យកំណាត់ឈើនេះ នរជនគប្បីឆ្លងសមុទ្រដោយសេចក្តីព្យាយាមប្រឹងប្រែង មានឧបមាយ៉ាងណា ។ អំពើណាទោះតិចតួចក្តី ថោកទាបក្តីដែលខ្ញុំធ្វើហើយ ខ្ញុំបានឆ្លងសង្សារព្រោះអាស្រ័យអំពើនោះ ក៏មានឧបមេយ្យយ៉ាងនោះឯង ។

លុះដល់បច្ឆិមភព ខ្ញុំត្រូវកុសលមូលដាស់តឿនបានកើតក្នុងត្រកូលមហាសាល ដែលស្តុកស្តម្ភក្នុងក្រុងសាវត្ថី ។ មាតាបិតារបស់ខ្ញុំមានសទ្ធា បានយកព្រះពុទ្ធជាទីពឹង ជនទាំងពីរនាក់នោះ ក៏អនុវត្តតាមពុទ្ធសាសនា ។ ពួកជនបានកាន់យកក្រមរពោធិទៅធ្វើព្រះស្តូប ជាវិការៈនៃមាស តែងនមស្ការចំពោះព្រះភក្ត្រព្រះសក្យបុត្តរាល់ល្ងាចព្រឹក ។ ក្នុងថ្ងៃឧបោសថ ពួកជននាំយកព្រះស្តូបមាស ហើយពោលសរសើរគុណព្រះពុទ្ធ ញុំាងកាលមានយាម ៣ ឲ្យកន្លងទៅ ។ លុះខ្ញុំបានឃើញព្រះស្តូបហើយ ក៏រឭកឃើញនូវចេតិយផ្នូកខ្សាច់ អង្គុយលើអាសនៈមួយ ក៏បានដល់អរហត្ត ។

កាលខ្ញុំស្វែងរកអ្នកប្រាជ្ញ បានជួបព្រះធម្មសេនាបតីនោះ ក៏

ចេញចាកផ្ទះទៅបួស ក្នុងសម្នាក់លោក ។ ខ្ញុំក៏បានសម្រេចអរហត្តក្នុងអាយុ ៧ ឆ្នាំ រាប់អំពីកំណើតមក ព្រះពុទ្ធមានចក្ខុទ្រង់ជ្រាបនូវគុណ បានឲ្យឧបសម្បទាដល់ខ្ញុំ ។ កាលខ្ញុំនៅជាទារកបានសម្រេចកិច្ចហើយ សោឡសកិច្ចក្នុងសាសនានៃព្រះសក្យបុត្ត ខ្ញុំធ្វើរួចហើយក្នុងថ្ងៃនេះ ។ បពិត្រព្រះមហាវីរៈ ខ្ញុំកន្លងពៀរ និងភ័យទាំងពួងហើយ កន្លងកិលេសជាគ្រឿងចំពាក់ទាំងពួងហើយ ជាអ្នកស្វែងរកគុណ ជាសាវ័ករបស់ព្រះអង្គ នេះជាផលនៃព្រះស្តូបមាស ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈលុះសម្រេចអរហត្តហើយ កាលនឹងធ្វើសេចក្តីអនុគ្រោះទាយកទើបមិនហាមបច្ច័យទាំងឡាយ ដែលទាយកទាំងនោះនាំមកប្រគេន បរិភោគបច្ច័យតាមដែលបានមកហើយប៉ុណ្ណោះ ។ បុគ្គលដែលនៅជាបុថុជ្ជនសម្គាល់ថា ព្រះថេរៈនេះជាអ្នកល្មោភដោយការទំនុកបម្រុងរាងកាយ មិនរក្សាចិត្ត ទើបនាំគ្នាមើលងាយ ។

ព្រះថេរៈ មិនគិតដល់ការមើលងាយនោះឡើយ ក្នុងទីមិនឆ្ងាយអំពីកន្លែងព្រះថេរៈ មានភិក្ខុកុហកមួយរូប ជាអ្នកប្រាថ្នាលាភមក សម្តែងខ្លួនដូចជាប្រាថ្នាតិច ដូចជាអ្នកសន្តោស បោកបញ្ឆោតសត្វលោក ត្រាច់ទៅ ។ មហាជន

---

១-ក្នុងអបទានជាព្រះ បុឡិនថូបិយត្ថេរ ។

នាំគ្នាសរសើរភិក្ខុរូបនោះ ដូចព្រះអរហន្ត ។ លំដាប់នោះ សក្កទេវរាជទ្រង់ជ្រាបព្រឹត្តិការណ៍នោះរបស់ព្រះថេរៈហើយ ទើបចូលទៅរកព្រះថេរៈ ហើយសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន ភិក្ខុអ្នកកុហក ធ្វើកម្មឈ្មោះអ្វី ព្រះថេរៈកាលតិះដៀលនូវការប្រាថ្នាលាមក ទើបពោលគាថា ២ ថា

កុហកបុគ្គលនោះ សម្លាប់ខ្លួនឯង ( ដោយការប្រព្រឹត្តលាមក ) មុន សម្លាប់បុគ្គលដទៃក្រោយ បុគ្គលបំផ្លាញខ្លួនឯង បំផ្លាញបានដោយងាយ ដូចព្រានបក្សីសម្លាប់ ( សត្វស្លាប ) ដោយផ្ទាក់ ។ បុគ្គលមានតែវណ្ណៈខាងក្រៅ មិនឈ្មោះថាព្រាហ្មណ៍ទេ លុះតែមានវណ្ណៈខាងក្នុងទើបឈ្មោះថាព្រាហ្មណ៍ បពិត្រសុជម្បតិ បាបកម្មមានក្នុងបុគ្គលណា បុគ្គលនោះឈ្មោះ ថាបុគ្គលខ្មៅ ។

បណ្ដាបទទាំងនោះបទថា **បុព្វេ ហនតិ អត្តានំ** សេចក្ដីថា បុគ្គលកុហក កាលកុហកសត្វលោកដោយការប្រព្រឹត្តបោកបញ្ឆោតរបស់ខ្លួន ឈ្មោះថារមែងសម្លាប់ខ្លួនដោយធម៌ដ៏លាមក មានភាពជាអ្នកប្រាថ្នាលាមកជាដើមមុននោះឯង គឺញ៉ាំងចំណែកនៃសេចក្ដីល្អរបស់ខ្លួនឲ្យវិនាសទៅ ។

បទថា **បច្ឆា ហនតិ សោ បរេ** សេចក្ដីថា បុគ្គលកុហកនោះ សម្លាប់ខ្លួនឯងដោយន័យដូចពោលហើយមុនបន្ទាប់មកទើបសម្លាប់មនុស្សទាំងឡាយដែលសរសើរខ្លួនថា ភិក្ខុនេះជាអ្នកមានសីលជាទីស្រឡាញ់ ជាព្រះអរិយៈដូច្នេះ ហើយធ្វើសក្ការៈ គឺធ្វើសក្ការៈដែលគេប្រគេនខ្លួនមិនឲ្យមានផលច្រើន

ឲ្យវិនាសទៅ ដោយការវិនាសនៃបច្ច័យទេ ។ ព្រះថេរៈ កាលសម្តែងថា មនុស្សក្រុហាក សម្លាប់បានទាំងពីរយ៉ាង តែការសម្លាប់ខ្លួននេះក្រៃលែងជាង ទើបពោលថា **សុហតំ ហន្តិ អត្តានំ** ប្រែថា បុគ្គលបំផ្លាញខ្លួនឯង បំផ្លាញបានដោយងាយ ។

បុគ្គលកុហកនោះ កាលសម្លាប់ខ្លួន រមែងសម្លាប់ គឺធ្វើឲ្យវិនាសបានងាយ សួរថាដូចអ្វី ឆ្លើយថា ដូចព្រានបក្សីដែលរកឧបាយសម្លាប់បក្សីដោយបក្សីធ្លាក់ដូច្នោះ ។ បក្សីធ្លាក់ ឈ្មោះថា **វីតំសោ** ។ ដោយបក្សីធ្លាក់នោះ ។

បទថា **បក្ខិមា** បានដល់ ព្រានបក្សី ។ ប្រៀបដូចព្រានបក្សីបញ្ឆោតបក្សីដទៃយកទៅសម្លាប់ ដោយបក្សីធ្លាក់នោះ ឈ្មោះថារមែងសម្លាប់ខ្លួនក្នុងលោកនេះ ព្រោះជាកម្មដែលអ្នកប្រាជ្ញតិះដៀល និងជាកម្មដែលមានសភាវៈអាក្រក់ជាដើម ចំណែកក្នុងសម្បរាយភព ឈ្មោះថារមែងសម្លាប់ខ្លួនដោយភាពងឹតសៅហ្មងនៃទុគ្គតិនោះឯង តែក្នុងកាលខាងក្រោយ មិនអាចសម្លាប់បក្សីទាំងនោះ បានទៀតយ៉ាងណា បុគ្គលកុហកនោះក៏ដូច្នោះ កន្លងនូវលោកដោយភាពជាអ្នកកុហក ឈ្មោះថា រមែងសម្លាប់ខ្លួនឯងក្នុងលោកនេះ ព្រោះត្រូវក្តៅក្រហាយចិត្ត និងត្រូវតិះដៀលចាកវិញ្ញូជនជាដើមក្នុងបរលោក ឈ្មោះថាសម្លាប់ខ្លួន ព្រោះភាពងឹតសៅហ្មងរបស់ទុគ្គតិ មិនតែប៉ុណ្ណោះ នៅមានឈ្មោះថា ធ្វើទាយកដែលឲ្យបច្ច័យទាំងនោះ ឲ្យដល់ទុក្ខក្នុងអបាយទៀត ។

ប្រការមួយទៀត បុគ្គលកុហក លោកពោលថា រមែងសម្លាប់ទាយក ព្រោះធ្វើទក្ខិណាមិនឲ្យមានផលច្រើនប៉ុណ្ណោះ មិនមែនព្រោះធ្វើទក្ខិណាទានមិន

ឲ្យមានផល សមដូចព្រះតម្រាស់ដែលព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងទក្ខិ-ណាវិភង្គសូត្រថា ទក្ខិណាមានគុណមួយពាន់ ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះបុថុជ្ជនទ្រុស្តសីល ដូច្នេះ ។ ដោយហេតុនោះ ទើបព្រះថេរៈពោលថា បុគ្គលបំផ្លាញខ្លួនឯង បំផ្លាញបានដោយងាយ ។

ព្រះថេរៈកាលសម្តែងថា បុគ្គលតាំងនៅក្នុងអត្តភាព ត្រឹមតែធ្វើឲ្យស្អាតខាងក្រៅយ៉ាងនេះ មិនឈ្មោះថាជាអ្នកបរិសុទ្ធឡើយ តែឈ្មោះថាជាអ្នកបរិសុទ្ធព្រោះការស្អាតខាងក្នុងប៉ុណ្ណោះ ដូច្នេះ ទើបពោលគាថាទី ២ ថា **ន ព្រាហ្មណោ** ជាដើម ។ គាថាទី ២ នោះ មានអធិប្បាយថា បុគ្គលមិនឈ្មោះថាជាព្រាហ្មណ៍ព្រោះហេតុត្រឹមតែសម្បត្តិខាងក្រៅ មានការសម្តែងអាកប្បកិ-រិយាជាដើមនោះឡើយ ឯ **វណ្ណ** សព្ទក្នុងគាថានេះ មានសម្បត្តិជាអត្ថ គឺមានអត្ថថា មាន ។ តែបុគ្គលរមែងឈ្មោះថាជាព្រាហ្មណ៍ព្រោះសម្បត្តិ មានសីលជាដើមក្នុងខាងក្នុង ដោយការធ្វើ អធិប្បាយថា បុគ្គលដែលមានបាបបន្សាត់ហើយ ឈ្មោះថាជាព្រាហ្មណ៍ ដូច្នេះ ។

នៃសុជម្បតិ ជាស្តេចទេវតា ព្រោះដូច្នោះ សូមទ្រង់ជ្រាបចុះថា បាប គឺកម្មដ៏លាមកទាំងឡាយមានក្នុងបុគ្គលណា បុគ្គលនោះឈ្មោះថាជាបុគ្គលខ្មៅ គឺជាបុគ្គលដែលអាក្រក់ដោយចំណែកមួយដូច្នេះ ។ សក្កទេវរាជស្តាប់ដូច្នោះហើយ ទ្រង់គំរាមភិក្ខុដែលកុហក ហើយទូន្មានថា សូមលោកម្ចាស់ប្រព្រឹត្តធម៌ ដូច្នេះហើយ ក៏យាងត្រឡប់ទៅកាន់ឋានរបស់ព្រះអង្គវិញ ។

**អដ្ឋកថា វិសាខត្ថេរគាថា ចប់**

**វគ្គទី ១ ចប់**

# ថេរគាថា ទុកនិបាត

## ទុតិយវគ្គ

### មហាចុន្ទត្ថេរគាថា

[ ១៣២ ] ការស្តាប់ដោយល្អ ជាការចម្រើននៃអ្នកស្តាប់ ការស្តាប់ជាការចម្រើននៃបញ្ញា ( ព្រោះ ) បុគ្គលរមែងយល់សេចក្តីបានដោយសារបញ្ញា សេចក្តីដែលយល់ហើយរមែងនាំសុខមកឲ្យ ។

បុគ្គលគួរសេពសេនាសនៈស្ងាត់ គួរប្រព្រឹត្តធម៌ ដែលជាហេតុរួចស្រឡះចាកសំយោជនៈ បើមិនបានសេចក្តីត្រេកអរក្នុងទីស្ងាត់នោះទេ គប្បីជាអ្នកមានសតិរក្សាខ្លួននៅក្នុងពួកចុះ ។

*មហាចុន្ទត្ថេរ ។*

## វគ្គទី ២

### អដ្ឋកថា មហាចុន្ទត្ថេរគាថា

[ ១៣២ ] គាថារបស់ព្រះមហាចុន្ទត្ថេរ មានពាក្យផ្តើមថា **សុស្សូសា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះថេរៈនេះ ក៏ជាអ្នកមានបុញ្ញាធិការ ដែលធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទុកក្នុងភពនោះៗ ក្នុងកាលព្រះដ៏មានព្រះភាគព្រះនាមថា វិបស្សី កុលបុត្តនេះកើតក្នុងត្រកូលស្មូនឆ្នាំង សម្រេចនិតិកាវ:ហើយ ចិញ្ចឹម

ជីវិតដោយការងាររបស់ស្នូនផ្ទាំង ថ្ងៃមួយឃើញព្រះសាស្តាហើយ មានចិត្តជ្រះថ្លា ធ្វើបាត្រដីមួយរចនាយ៉ាងល្អ ថ្វាយព្រះដ៏មានព្រះភាគ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តរបស់នាងរូបសារីព្រាហ្មណី ជាប្អូនប្រុសរបស់ព្រះថេរៈឈ្មោះសារីបុត្ត ក្នុងនាលកគាមដែនមគធៈមានឈ្មោះថាចុន្ទៈ ។ កុលបុត្តនោះចម្រើនវ័យហើយ បួសតាមព្រះធម្មសេនាបតី អាស្រ័យព្រះធម្មសេនាបតី ផ្តើមតាំងវិបស្សនា ធ្វើសេចក្តីព្យាយាមបានអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ខ្ញុំកើតជាស្នូនផ្ទាំងក្នុងនគរហង្សវតី ខ្ញុំបានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលីគឺកិលេស ទ្រង់ឆ្លងជំនន់គឺកិលេស មិនមានអាសវៈ ។ ខ្ញុំបានថ្វាយបាត្រដីដែលខ្ញុំធ្វើល្អហើយ ដល់ព្រះ-ពុទ្ធដ៏ប្រសើរ ខ្ញុំថ្វាយបាត្រដល់ព្រះមានបុណ្យ មានព្រះហឫទ័យទៀងត្រង់ ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ខ្ញុំកាលកើតក្នុងភព តែងបានថាសមាសផង ថាសមាសក្រឡៃប្រាក់ផង បានជាវិការៈនៃកែវមណីផង ។ ខ្ញុំតែងបរិភោគដោយភាជន៍ នេះជាផលនៃបុញ្ញកម្ម ខ្ញុំជាអ្នកប្រសើរដោយយសបរិ-វារជាងជនទាំងឡាយ ។ ពូជសូម្បីបន្តិចបន្តួចដែលគេសាបព្រោះក្នុងស្រែដ៏ល្អ កាលបើមេឃបង្អុរធារទឹក ដោយប្រពៃផ្លែស្រូវរមែងញុំាងអ្នកស្រែឲ្យត្រេកអរយ៉ាងណាមិញ ។ បត្ត

ទាននេះដែលខ្ញុំសាបព្រោះក្នុងស្រែ គឺព្រះពុទ្ធ ជាទឹក គឺបីតិ បង្អោរចុះមក ផលរមែងធ្វើឲ្យខ្ញុំត្រេកអរ ក៏យ៉ាងនោះដែរ ។ ស្រែទាំងប៉ុន្មានណា គឺព្រះសង្ឃក្តី គណៈក្តី ស្រែទាំងនោះ ស្មើដោយស្រែគឺព្រះពុទ្ធមិនមានឡើយ ព្រោះស្រែ គឺព្រះពុទ្ធ អាចឲ្យសេចក្តីសុខដល់សត្វទាំងពួង ។ បពិត្របុរសអាជា-នេយ្យខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្របុរសដ៏ឧត្តមខ្ញុំសូមថ្វាយបង្គំព្រះអង្គ ខ្ញុំបានថ្វាយបាត្រមួយហើយ បានសម្រេចព្រះនិព្វានជាគុណជាតមិនកម្រើក ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយបាត្រ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃបត្តទាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអភិញ្ញា ៦ ហើយ កាលសរសើរឧបនិស្ស័យរបស់គ្រូ និងការនៅដោយវិវេកដែលជាហេតុឲ្យខ្លួនបានសម្បត្តិ បានពោលនូវគាថា ២ ថា

ការស្តាប់ដោយល្អ ជាការចម្រើននៃអ្នកស្តាប់ ការស្តាប់ជាការចម្រើននៃបញ្ញា ( ព្រោះ ) បុគ្គលរមែងយល់សេចក្តីបានដោយសារបញ្ញា សេចក្តីដែលយល់ហើយរមែង នាំសុខមក

---

១-ក្នុងអបទានជាព្រះ ឯកបត្តទាយកត្ថេរ ។

ឲ្យ ។

បុគ្គលគួរ សេពសេនាសនៈស្ងាត់ គួរប្រព្រឹត្តធម៌ ដែលជាហេតុរួចស្រឡះ ចាកសំយោជនៈ បើមិនបានសេចក្តីត្រេកអរក្នុងទីស្ងាត់នោះទេ គប្បីជាអ្នកមានសតិរក្សាខ្លួននៅក្នុងពួកចុះ ។

បណ្តាបទទាំងនោះ បទថា **សុស្សូសា** បានដល់ ការប្រាថ្នាដើម្បីនឹងស្តាប់នូវសុតៈទាំងពួងដែលគួរដល់ការស្តាប់ សូម្បីការនៅរួមជាមួយគ្រូ ក៏ឈ្មោះថា **សុស្សូសា** អធិប្បាយថា ដែលកុលបុត្តអ្នកប្រាថ្នានឹងស្តាប់នូវភាពដែលមានប្រយោជន៍ មានទិដ្ឋធម្មិកត្ថប្រយោជន៍ជាដើម ចូលទៅរកកល្យាណមិត្ត ចូលទៅអង្គុយជិតដោយការធ្វើវត្ត កាលកល្យាណមិត្តទាំងនោះពេញចិត្តនិងការចូលទៅអង្គុយជិត មានបំណងនឹងឲ្យកុលបុត្តពួកខ្លះចូលដល់ខ្លួន កុលបុត្តនោះ គួរចូលទៅអង្គុយជិត កល្យាណមិត្តទាំងនោះ ហើយផ្ទៀងនូវសោតៈស្តាប់ដោយការត្រូវការស្តាប់ដែលកើតឡើង ព្រោះហេតុនោះ ការនៅរួមជាមួយគ្រូ ទើបលោកហៅថា **សុស្សូសា** ព្រោះជា ដើមហេតុនៃការស្តាប់ដោយល្អ ការស្តាប់ដោយល្អនោះ ឈ្មោះថា **សុតវឌ្ឍនី** ព្រោះជាហេតុឲ្យនូវសុតៈ ដែលបដិសំយុត្តដោយបដិច្ចសមុប្បាទជាដើម ចម្រើន គឺដុះដាលដល់បុគ្គលដែលដល់ព្រមដោយការស្តាប់នោះ អធិប្បាយថា ធ្វើឲ្យជាពហុស្សុត ។

បទថា **សុតំ បញ្ញាយ វឌ្ឍនំ** សេចក្តីថា ពាហុសច្ចៈនោះ ដែលលោក

ពោលទុកដោយន័យជាដើមថា ទ្រទ្រង់នូវពុទ្ធវចនៈ សន្សំនូវពុទ្ធវចនៈក្តីថា ម្នាលភិក្ខុទាំងឡាយ ពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ ... មានច្រើន ដល់បុគ្គលពួកខ្លះក្នុងលោកនេះដូច្នេះក្តី ពាហុសច្ចៈនោះ រមែងញ៉ាំងបញ្ញាដែលជាហេតុឲ្យលះនូវសេចក្តីអាក្រក់ និងឲ្យកើតសេចក្តីល្អ ឲ្យចម្រើន ព្រោះហេតុនោះ ទើបសុតៈឈ្មោះថា ញ៉ាំងបញ្ញាឲ្យចម្រើន សមដូចព្រះដ៏មានព្រះភាគត្រាស់ ( ទុកអង្គុត្តនិកាយសត្តកនិបាត ) ថា

> ម្នាលភិក្ខុទាំងឡាយអរិយសាវក មានការចេះដឹងទុកជាអាវុធ
> រមែងលះបង់នូវអកុសល ចម្រើននូវកុសល លះបង់នូវអំពើ
> មានទោស ចម្រើននូវអំពើមិនមានទោស រមែងរក្សាខ្លួនឲ្យ
> បរិសុទ្ធ ដូច្នេះ ។

បទថា **បញ្ញាយ អត្ថំ ជានាតិ** សេចក្តីថា បុគ្គលជាពហុស្សូត តាំងនៅក្នុងសុតមយញ្ញាណ គឺញាណដែលសម្រេចដោយការស្តាប់ ហើយបដិបត្តិនូវបដិបទានោះ រមែងដឹងតាមសេចក្តីពិត និងសម្រេចនូវប្រយោជន៍ មានលោកិយៈនិងលោកុត្តរ ចែកចេញជាទិដ្ឋធម្មិកត្ថប្រយោជន៍ជាដើម និងចែកដោយអរិយសច្ចៈ មានទុក្ខសច្ចៈជាដើម ដោយការត្រិះរិះតាមដែលស្តាប់មក និងដោយការនៃ គឺការចូលទៅសម្លឹងធម៌ សមដូចព្រះតម្រាស់ដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា បុគ្គលដឹងហេតុដឹងផលនៃសុតៈ តាមដែលបានរៀនមកហើយ រមែងបដិបត្តិធម៌សមគួរដល់ធម៌ ដូច្នេះ និងត្រាស់ទុកក្នុង ( អង្គុត្តនិកាយចតុក្កនិបាត ) ថា បុគ្គលនោះចេះអដ្ឋកថាចេះបាលីនៃពុទ្ធ-

វចនៈ មានប្រមាណច្រើននោះហើយ ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ និងព្រះតម្រាស់ ( ក្នុងមជ្ឈិមនិកាយមជ្ឈិមបណ្ណាសកៈ ) ថា

ទើបពិចារណារកសេចក្តី លុះពិចារណារកសេចក្តីនៃធម៌នោះហើយ ធម៌ទាំងឡាយតែងគួរដល់កិរិយាលៃលកមើល កាលបើមានការលៃលកមើលហើយ ឆន្ទៈក៏កើតឡើង បុគ្គលនោះលុះមានឆន្ទៈកើតហើយ ទើបព្យាយាម លុះព្យាយាមហើយ រមែងស្ទង់មើល លុះស្ទង់មើលហើយ រមែងតម្កល់ទុក មានចិត្តបញ្ជូនទៅ ( កាន់ព្រះនិព្វាន ) ធ្វើឲ្យជាក់ច្បាស់នូវបរមសច្ចៈដោយនាមកាយ ទាំងបានចាក់ធ្លុះ ឃើញច្បាស់នូវបរមសច្ចៈនោះដោយប្រាជ្ញា ដូច្នេះ ។

បទថា **ញាតោ អត្ថោ សុខាវហោ** សេចក្តីថា ប្រយោជន៍ មានទិដ្ឋធម្មិកត្ថប្រយោជន៍ជាដើមក្តី ប្រយោជន៍មានទុក្ខសច្ចៈជាដើមក្តី តាមដែលពោលហើយ ដែលខ្លួនដឹងហើយ គឺសម្រេចហើយតាមសេចក្តីពិត រមែងនាំមក គឺឲ្យសម្រេចសេចក្តីសុខដោយលោកិយសុខនិងលោកុត្តរសុខ ។

សម្រាប់ការនាបញ្ញាដែលតាំងមាំ ប្រយោជន៍រមែងមិនសម្រេច ដោយការស្តាប់ត្រឹមតែម៉្យាងប៉ុណ្ណោះព្រោះហេតុនោះ ព្រះថេរៈកាលសម្តែងដល់វិធីបដិបត្តិនៃការនាបញ្ញានោះ ទើបពោលថា បុគ្គលសេពសេនាសនៈស្ងាត់គួរប្រព្រឹត្តធម៌ជាហេតុរួចស្រឡះចាកសំយោជនៈ គួរប្រព្រឹត្តធម៌ដែលជាហេតុឲ្យចិត្តរួចផុតចាកសំយោជនៈ ។

បណ្ដាបទទាំងនោះ ព្រះថេរៈពោលដល់កាយវិវេកដោយបទថា **សេវេថ បន្តានិ សេនាសនានិ** ។ មួយវិញទៀតព្រោះព្រះថេរៈកំពុងពោលដល់ការលះសំយោជនៈ រមែងមានការនៅយ៉ាងស្ងាត់របស់បុគ្គលដែលគួរដល់វិវេកនោះឯង ព្រោះហេតុនោះ សំវរៈមានសីលសំវរៈជាដើម គប្បីជ្រាបថា សម្រេចហើយដោយមិនចាំបាច់ពោលទុកក្នុងគាថានេះ ។

បទថា **ចរេយ្យ សំយោជនវិប្បមោក្ខំ** សេចក្ដីថា ចិត្តរមែងផុតចាកសំយោជនៈបានដោយប្រការណា ភិក្ខុគប្បីប្រព្រឹត្ត គឺគប្បីបដិបត្តិនូវវិបស្សនាភាវនានិងមគ្គភាវនាដោយប្រការនោះ ។

បទថា **សចេ រតឹ នាធិគច្ឆេយ្យ តត្ថ** អធិប្បាយថា ភិក្ខុមិនទាន់បាននូវការត្រេកអរក្នុងសេនាសនៈដ៏ស្ងាត់ និងក្នុងធម៌ គឺកុសលដែលក្រៃលែងតាមដែលបានហើយទាំងនោះ គឺមិនបាននូវការត្រេកអរក្រៃលែង ព្រោះមិនបានគុណវិសេសជាប់តជាលំដាប់ គប្បីជាអ្នកខ្ជួនរក្សាហើយ គឺមានចិត្តដែលរក្សាហើយ ដោយកំណត់កម្មដ្ឋាន គប្បីជាអ្នកមានសតិ ដោយការចូលទៅតាំងទុកនូវសតិជាគ្រឿងរក្សាក្នុងទ្វារទាំង ៦ ក្នុងសង្ឃ គឺក្នុងពួកនៃភិក្ខុ ។ កាលអ្នកនៅយ៉ាងនេះរមែងឈ្មោះថា ជាអ្នករួចផុតចាកសំយោជនៈដោយពិត ។

**អដ្ឋកថា មហាចុន្ទត្ថេរគាថា ចប់**

## ជោតិទាសត្ថេរគាថា

[ ១៣៣ ] ពួកជនណាបៀតបៀនពួកមនុស្ស ដោយកម្មដែលច្រឡំ ដោយកម្មក្លាខ្លាំងផង ដោយកម្មផ្សេងៗផង ពួកជនទាំងនោះ ឈ្មោះថា មានព្យាយាមអាក្រក់ ជនទាំងនោះតែងត្រូវជន ( ឯទៀត ) ធ្វើ ( ឲ្យដល់នូវសេចក្តីទុក្ខ ) តាមដំណើរដូច្នោះ ព្រោះថាកម្ម ( របស់ជននោះ ) មិនចេះវិនាសទេ ។ ជនធ្វើនូវកម្មណា ទោះបីល្អឬអាក្រក់ ធ្វើនូវកម្មណាៗ រមែងជាទាយាទ ( ទទួលផល ) នៃកម្មនោះៗ ។

**ជោតិទាសត្ថេរ ។**

## អដ្ឋកថា

## ជោតិទាសត្ថេរគាថា

[ ១៣៣ ] គាថារបស់ព្រះជោតិទាសត្ថេរ មានពាក្យផ្តើមថា **យេ ខោ តេ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះថេរៈនេះ ក៏ជាអ្នកមានបុញ្ញាធិការ ដែលធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយទុកក្នុងភពនោះៗ ក្នុងកាលព្រះដ៏មានព្រះភាគព្រះនាមថា សិខី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ។ ថ្ងៃមួយ ឃើញព្រះសាស្តាយាងទៅបិណ្ឌបាត មានចិត្តជ្រះថ្លា បានថ្វាយផ្លែស្វា ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំង

ឡាយក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តរបស់ព្រាហ្មណ៍ដែលសម្បូរដោយសម្បត្តិ ក្នុងបាទិយត្ថជនបទបានឈ្មោះថាជោតិទាសៈ ។ កុលបុត្តនោះដឹងក្តីហើយនៅគ្រប់គ្រងផ្ទះ ថ្ងៃមួយឃើញព្រះមហាកស្សបត្ថេរត្រាច់ទៅបិណ្ឌបាត ក្នុងស្រុករបស់ខ្លួន មានចិត្តជ្រះថ្លា ឲ្យព្រះថេរៈឆាន់ហើយ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះថេរៈ ឲ្យសាងវិហារធំលើភ្នំក្បែរស្រុកខ្លួន និមន្តព្រះថេរៈឲ្យនៅក្នុងវិហារនោះ ទំនុកបម្រុងដោយបច្ច័យ ៤ បានទូវការសង្វេគព្រោះព្រះធម្មទេសនារបស់ព្រះថេរៈ បួសហើយចម្រើនវិបស្សនា ជាអ្នកបានអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ខ្ញុំបានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលី ជាច្បងក្នុងលោក
ប្រសើរជាងនរៈ រុងរឿងដូចផ្កាកណិការ ទ្រង់គង់នៅក្នុងចន្លោះ
ភ្នំ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយធ្វើនូវអញ្ជលីលើក្បាល
បានយកផ្លែស្វាទុំទៅថ្វាយព្រះពុទ្ធដ៏ប្រសើរ ។ ក្នុងកប្បទី ៣១
អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែស្វាក្នុងកាលនោះ
ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេស
ទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះ
ពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈបានអភិញ្ញា ៦ ហើយ រៀនព្រះត្រៃបិដក ដល់នូវភាពជាអ្នកជំនាញក្នុងព្រះវិនយបិដក ជាពិសេសជាអ្នកមានវស្សា ១០ និងជាអ្នកសង្គ្រោះ

---

១-ក្នុងអបទានជាព្រះ កាសុមារិកផលទាយកត្ថេរ ។

បរិស័ទបរិវារ ដើរទៅកាន់នគរសាវត្ថី ដើម្បីថ្វាយបង្គំព្រះដ៏មានព្រះភាគមួយអន្លើដោយភិក្ខុទាំងឡាយដ៏ច្រើន ចូលកាន់អារាមរបស់ពួកតិរ្ថិយ ក្នុងរវាងផ្លូវ ដើម្បីបន្ទោបង់នូវការហត់នឿយក្នុងការដើរផ្លូវ អង្គុយក្នុងចំណែកម្ខាងឃើញព្រាហ្មណ៍ម្នាក់កំពុងដុតតបៈ ៥ ទើបពោលថា ម្នាលព្រាហ្មណ៍ របស់មួយត្រូវដុត របស់មួយទៀតនឹងក្តៅដែរឬ ព្រាហ្មណ៍ស្តាប់ដូច្នោះក៏ក្រោធពោលថា នៃសមណៈត្រងោល របស់ដទៃដែលត្រូវដុតគឺអ្វី ព្រះថេរៈសម្តែងធម៌ទូន្មានព្រាហ្មណ៍ដោយគាថាថា

វត្ថុដែលគួរដុតទាំងនោះគឺ សេចក្តីក្រោធ សេចក្តីប្រណែន
ការបៀតបៀនអ្នកដទៃ ការប្រកាន់ខ្លួន ការប្រណាំងវាសនា ការ
ស្រវឹង ការប្រមាទ តណ្ហា អវិជ្ជា និងការជាប់ជំពាក់ក្នុងភព
មិនមែនរូបក្ខន្ធ ដូច្នេះ ។

ព្រាហ្មណ៍នោះ និងតិរ្ថិយទាំងពួងក្នុងអារាមនៃតិរ្ថិយនោះ ស្តាប់ឱវាទនោះហើយ នាំគ្នាបួសក្នុងសម្នាក់របស់ព្រះថេរៈ ។ ព្រះថេរៈទៅកាន់នគរសាវត្ថី មួយអន្លើដោយភិក្ខុទាំងនោះ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ស្នាក់នៅក្នុងនគរសាវត្ថីអស់ពីរបីថ្ងៃ ហើយត្រឡប់ទៅកាន់ជាតិភូមិរបស់ខ្លួននោះឯង កាលញាតិចូលទៅរក ព្រះថេរៈពោលទូន្មានញាតិដែលមានលទ្ធិផ្សេងដែលប្រកាន់ថា បរិសុទ្ធិព្រោះយញ្ញ បានពោលគាថា ២ ដោយសេចក្តីថា

ពួកជនណាបៀតបៀនពួកមនុស្ស ដោយកម្មដែលច្រឡំដោយ
កម្មក្លាខ្លាំងផង ដោយកម្មផ្សេងៗផង ពួកជនទាំងនោះ ឈ្មោះ

*ថា មានព្យាយាមអាក្រក់ ជនទាំងនោះតែងត្រូវជន ( ឯទៀត ) ធ្វើ ( ឲ្យដល់នូវសេចក្តីទុក្ខ ) តាមដំណើរដូច្នោះ ព្រោះថាកម្ម ( របស់ជននោះ ) មិនចេះវិនាសទេ ។*

*ជនធ្វើនូវកម្មណា ទោះបីល្អឬអាក្រក់ ធ្វើនូវកម្មណាៗ រមែងជាទាយាទ ( ទទួលផល ) នៃកម្មនោះៗ ។*

*បណ្តាបទទាំងនោះ បទថា* **យេ** *ជាពាក្យប្រាប់មិនចំពោះ ។ បទថា* **តេ** *ជាបដិនិទ្ទេសជាមួយពាក្យថា (* **យេ** *) ប្រើក្នុងសេចក្តីមិនចំពោះដូចគ្នា ។ សូម្បីបទទាំង ២ ក៏សម្ពន្ធចូលជាមួយបទថា* **ជនា** *។*

*បទថា* **ខោ** *ត្រឹមតែជានិបាត ។*

*បទថា* **វេឋមិស្សេន** *សេចក្តីថា ដោយការចងត្រង់អវយវៈ មានក្បាលជាដើម ដោយការចងដោយខ្សែស្បែកជាដើម បាលីថា* **វេធមិស្សេន** *ដូច្នេះក៏មាន ឯសេចក្តីក៏ដូចគ្នា ។*

*បទថា* **នានត្តេន ច កម្មុនា** *សេចក្តីថា ដោយកម្ម គឺការចូលទៅបៀតបៀនអ្នកដទៃច្រើនយ៉ាង មានការសម្លាប់ ការប្រហារ ការកាត់អវយវៈ មានដៃនិងជើងជាដើម និងដោយការប្រើដុំគ្រួសជាដើម ។*

*បទថា* **មនុស្សេ** *ត្រឹមតែជាឧបមា ព្រោះដូច្នោះ ទើបមានអធិប្បាយថា បានដល់ ក្នុងសត្វឯណានីមួយ ។ បទថា* **ឧបរុន្ធន្តិ** *ស្មើគ្នានិង* **វិពាធេតិ** *ប្រែថា រមែងបៀតបៀន ។*

*បទថា* **ផរុសូបក្កមា** *បានដល់ សេចក្តីព្យាយាមដែលទារុណ អធិប្បាយ*

ថា ជាការធ្វើរបស់បុគ្គលដែលឃោរឃៅ ។

បទថា **ជនា** បានដល់ សត្វទាំងឡាយ ។ បទថា **តេបិ តត្ថេវ កីរន្តិ** សេចក្តីថា បុគ្គលមានប្រការដូចពោលហើយទាំងនោះ បៀតបៀនអ្នកដទៃដោយហេតុដែលជាកម្មណា រមែងត្រូវធ្វើ គឺតបស្នងឯង ព្រោះហេតុនោះឯង អធិប្បាយថា រមែងសោយទុក្ខបែបនោះដូចគ្នា ។ បាឋៈថា **តថេវ កីរន្តិ** ដូច្នេះក៏មាន ។ សេចក្តីថា ខ្លួនឯងធ្វើទុក្ខឲ្យដល់អ្នកដទៃយ៉ាងណារមែងត្រូវអ្នកដទៃធ្វើគឺឲ្យដល់ទុក្ខយ៉ាងនោះដូចគ្នា ព្រោះហេតុអ្វី ព្រោះថាកម្ម ( របស់ជននោះ ) មិនចេះវិនាសទេ អធិប្បាយថា ព្រោះថា កម្មដែលខ្លួនសាងទុកដោយចំណែកមួយ មិនឲ្យផលនឹងមិនអស់ទៅ គឺឲ្យផល កាលជួបនូវបច្ច័យដែលនៅសល់ ។

ឥឡូវនេះ ព្រះថេរៈ កាលចែកសេចក្តីដែលពោលទុកដោយសង្ខេបថា ព្រោះ ថាកម្ម ( របស់ជននោះ ) មិនចេះវិនាសទេ ដូច្នេះហើយ ដើម្បីនឹងធ្វើឲ្យជាក់ច្បាស់ថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន ទើបពោលគាថាថា **យំ ករោតិ** ជនធ្វើនូវកម្មណា ដូច្នេះជាដើម ។

ពាក្យជាគាថានោះ មានអធិប្បាយថា សត្វធ្វើនូវកម្មណាដែលល្អ គឺជាកុសល ឬថាដែលអាក្រក់គឺជាអកុសលហើយក្នុងកម្ម ២ យ៉ាងនោះ កាលធ្វើកម្មណារមែងឈ្មោះថាធ្វើ គឺសន្សំដោយកម្មនោះ អាចនឹងឲ្យផល ។

បទថា **តស្ស តស្សេវ ទាយាទោ** សេចក្តីថា កាលសត្វកាន់យកផលនៃកម្មនោះៗឯង ឈ្មោះថា រមែងជាបុគ្គលមានចំណែកនៃផលដែលកម្មនោះៗ

គប្បីឲ្យផល ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ទុកក្នុង ( ចូឡកម្មវិភង្គសូត្រ ) ថា ម្នាលមាណពសត្វទាំងឡាយមានកម្មជារបស់ខ្លួន មានកម្មជាទាយាទ ដូច្នេះជាដើម ។ ញាតិទាំងឡាយ របស់ព្រះថេរៈ ស្តាប់គាថាទាំងនេះហើយ តាំងនៅហើយក្នុងសទ្ធាថា សត្វមានកម្មជារបស់ខ្លួនដោយប្រការដូច្នេះ ។

## អដ្ឋកថា ជោតិទាសត្ថេរគាថា ចប់

## ហេរញ្ញកានិត្ថេរគាថា

[ ១៣៤ ] ថ្ងៃនិងយប់ តែងកន្លងទៅ ជីវិតរមែងរលត់ទៅ អាយុរបស់សត្វទាំងឡាយរមែងអស់ទៅ ដូចទឹកស្ទឹងតូច ។ ជនពាលដែលកំពុងធ្វើកម្មដ៏លាមក ក៏មិនភ្ញាក់រឭក ( រហូតដល់ ) ផលដ៏ក្តៅក្រហាយមានដល់គេក្នុងកាលជាខាងក្រោយ ព្រោះថា វិបាករបស់កម្មនោះជាវិបាកដ៏លាមក ។

ហេរញ្ញកានិត្ថេរ ។

## អដ្ឋកថា

## ហេរញ្ញកានិត្ថេរគាថា

[ ១៣៤ ] គាថារបស់ព្រះហេរញ្ញកានិត្ថេរ មានពាក្យផ្តើមថា **អច្ចយន្តិ អហោរត្តា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក្នុងកាលព្រះសម្មាសម្ពុទ្ធព្រះនាមថា បទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរហង្សវតីដឹងក្តីហើយ ស៊ីឈ្នួលអ្នកដទៃចិញ្ចឹមជីវិត ។ ថ្ងៃមួយ បានបរិច្ចាគសំពត់មួយផ្ទាំង ថ្វាយសាវករបស់ព្រះសាស្តានាមថាសុជាត ដែលកំពុងស្វែងរកសំពត់បំសុកូល ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ កើតក្នុងឋានតាវត្តិង្ស អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនរបស់ចោរ-ឃាតសាសកៈ ដែលជាមេស្រុក របស់ព្រះបាទកោសល មានឈ្មោះថា ហេ-

វញ្ញកានិ ។ កុលបុត្តនោះ ចម្រើនវ័យហើយ អំណើះឥតអំពីបិតាទៅ ក៏បាន ទទួលដំណែងជាមេស្រុក ឃើញពុទ្ធានុភាពក្នុងកាលដែលទ្រង់ទទួលវត្តជេត-ពនមហាវិហារ បានជាអ្នកមានសទ្ធា ប្រគល់ដំណែងឲ្យប្អូនប្រុស លាព្រះរាជាចេញបួសហើយ ចម្រើនវិបស្សនាសម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ក្នុងកាលនោះ សាវកនាមសុជាតៈរបស់ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ លោកកំពុងស្វែងរកសំពត់បំសុកូល លើគំនរសំរាមក្បែរច្រក ។ ខ្ញុំជាអ្នកស៊ីឈ្នួលនៃបុគ្គលដទៃ ក្នុងនគរហង្សវតីបានប្រគេនសំពត់ពាក់កណ្តាលហើយថ្វាយបង្គំដោយសិរ្សៈ ។ ដោយអំពើដែលខ្ញុំបានធ្វើល្អនោះផង ដោយចេតនាដែលខ្ញុំបានតម្កល់ទុកហើយនោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សទៅ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ខ្ញុំបានកើតជាព្រះឥន្ទ សោយរាជ្យជាស្តេចនៃទេវតាអស់ ៣៣ ដង ខ្ញុំបានកើតជាស្តេចចក្រពត្តិអស់ ៧៧ ដង ។ ខ្ញុំបានសោយប្រទេសរាជ្យដ៏ធំទូលាយរាប់ជាតិមិនអស់ ខ្ញុំឥតមានភ័យអំពីទីណា តែងត្រេកអរព្រោះកិរិយាឲ្យនូវសំពត់ពាក់កណ្តាល ។ ក្នុងថ្ងៃនេះបើខ្ញុំប្រាថ្នាយកសំពត់ដែលកើតអំពីសម្បកឈើមកប្រក់ព្រៃ និងភ្នំក៏សឹងបាន នេះជាផលនៃការថ្វាយសំពត់ពាក់កណ្តាល ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុ

ដែលខ្ញុំបានឲ្យទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះ
ជាផលនៃសំពត់ពាក់កណ្តាល ។ កិលេសទាំងឡាយខ្ញុំដុតបំ-
ផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិ
បត្តិហើយ ដូច្នេះ[១]។

ព្រះថេរៈនោះ សម្រេចអរហត្តហើយ មានបំណងនឹងឲ្យប្អូនប្រុសរបស់ខ្លួនផ្ចាស់ប្តូរការងារនោះ កាលនឹងជាស់តឿនប្អូនប្រុស ព្រោះឃើញប្អូនប្រុសនៅតែត្រេកអរក្នុងការងារដដែលនោះឯង ទើបពោលគាថា ២ ថា

ថ្ងៃនឹងយប់តែងកន្លងទៅ ជីវិតរមែងរលត់ទៅ អាយុរបស់សត្វ
ទាំងឡាយរមែងអស់ទៅ ដូចទឹកស្ទឹងតូច ។

ជនពាលដែលកំពុងធ្វើកម្មដ៏លាមក ក៏មិនភ្ញាក់រឭក ( រហូត
ដល់ ) ផលដ៏ក្តៅក្រហាយមានដល់គេ ក្នុងកាលជាខាងក្រោយ
ព្រោះថា វិបាករបស់កម្មនោះ ជាវិបាកដ៏លាមក ។

បណ្តាបទទាំងនោះ បទថា **អច្ចយន្តិ** បានដល់ ឈានកន្លង អធិប្បាយថា កំពុងចេញទៅដោយរហ័ស ។

បទថា **អហោរត្តា** បានដល់ ទាំងពេលយប់ និងពេលថ្ងៃ ។ បទថា **ជីវិតំ ឧបរុជ្ឈតិ** សេចក្តីថា ជីវិតិន្ទ្រិយ រមែងរលត់ ដោយអំណាចនៃការ

---

១- ក្នុងអបទានជាព្រះ ឧបឌ្ឍទុស្សទាយកត្ថេរ ។ ព្រះហេរញ្ញកានិត្ថេរនេះមានប្រវត្តិក្នុងអតីតដូចគ្នានឹងព្រះចូឡវច្ឆត្ថេរ ក្នុងឯកនិបាត វគ្គទី ២ ខាងដើមដែរ ឯអបទានលោកក៏ពោលដូចគ្នា បណ្ឌិតគប្បីជ្រាប ។

រលត់ទៅគ្រប់ៗខណៈ សមដូចលោកពោលទុកថា នែភិក្ខុអ្នករមែងចាស់ រមែងឈឺ រមែងស្លាប់ រមែងចុតិ និងបដិសន្ធិគ្រប់ៗខណៈ ដូច្នេះ ។

បទថា **អាយុ ខីយតិ មច្ចានំ** សេចក្តីថា អាយុរបស់សត្វទាំងឡាយនេះ ដែលបានឈ្មោះថា មច្ចៈ ព្រោះមានការស្លាប់ជាសភាវៈ បានដល់ អាយុដែលកំណត់ពេលយ៉ាងខ្ពស់ទុកថា បុគ្គល ( ក្នុងសម័យនេះ ) ដែលរស់នៅយ៉ាងយូរបានត្រឹម ១០០ ឆ្នាំ និងតិចជាង ១០០ ឆ្នាំ ឬច្រើនជាង ១០០ ឆ្នាំក៏មាន ( ដោយតិច ) រមែងអស់ទៅ គឺដល់នូវការអស់ទៅនិងការបែកធ្លាយសេចក្តីនេះឧបមាដូចអ្វី ដូចទឹកក្នុងស្ទឹងតូចដូច្នោះ ជម្មតាទឹកក្នុងស្ទឹងតូច គឺស្ទឹងតូចតាច ដែលហូរអំពីភ្នំ រមែងតាំងនៅមិនបានយូរវែងស្ងួតទៅដោយរហ័ស គឺ គ្រាន់តែហូរមកប៉ុណ្ណោះ ក៏អស់ទៅ យ៉ាងណា អាយុរបស់សត្វទាំងឡាយក៏ដូច្នោះ រមែងអស់ គឺ ដល់នូវការអស់ទៅយ៉ាងឆាប់រហ័ស ។ ក្នុងគាថានេះទឹកនោះឯងលោកហៅថា **ឱទកំ** ដូច ចិត្ត នោះឯង លោកហៅថា **មានសំ** ដូច្នោះ ។

បទថា **អថ ចាចានិ កម្មានិ ករំ ពាលោ ន ពុជ្ឈតិ** សេចក្តីថា កាលសង្ខារជារបស់មិនទៀង មានយ៉ាងនេះ បុគ្គលពាលធ្វើកម្មដ៏លាមក ដោយអំណាចនៃលោភៈ ឬដោយអំណាចនៃសេចក្តីក្រោធ កាលធ្វើក៏មិនដឹងខ្លួន និងកំពុងធ្វើអំពើអាក្រក់ក៏មិនដឹងថាអញធ្វើអាក្រក់ ព្រោះមិនដឹងថាកម្មនេះ មានទុក្ខជាវិបាកបែបនេះ ដូច្នេះ ហេតុនោះទើបពោលថា **ន ពុជ្ឈតិ** ប្រែថា រមែងមិនដឹងខ្លួន ដូច្នេះ ។

បទថា **បច្ចាសស្ស កដុកំ ហោតិ** សេចក្ដីថា បើក្នុងខណៈដែលសន្សំកម្មលាមកនោះ មិនដឹងថា កម្មនេះមានផលយ៉ាងនេះ តែខាងក្រោយអំពីនោះ ទុក្ខដ៏ក្ដៅផ្សាមិនគួរប្រាថ្នានោះឯងនឹងមានដល់បុគ្គលពាលនោះ ដែលកើតក្នុងអបាយភូមិមាននរកជាដើម ។

ព្រោះថា វិបាករបស់កម្មនោះ ជាវិបាកដ៏លាមក គឺព្រោះឈ្មោះថា កម្មដ៏លាមកនោះ មានផលដ៏លាមកអាក្រក់ មិនគួរប្រាថ្នានោះឯង ។ ប្អូនប្រុសរបស់ព្រះថេរៈស្ដាប់ឱវាទនេះហើយ ទូលលាព្រះរាជាបួសហើយ ញ៉ាំងប្រយោជន៍របស់ខ្លួនឲ្យសម្រេចក្នុងកាលមិនយូរឡើយ ។

អដ្ឋកថា ហេរញ្ញកានិត្ថេរគាថា ចប់

## សោមមិត្តត្ថេរគាថា

[ ១៣៥ ] បុគ្គលតោងកំណាត់ឈើតូច រមែងលិចចុះក្នុងជំនន់ធំ យ៉ាងណាមិញ បុគ្គលអាស្រ័យមនុស្សខ្ជិល ទុកជាមានការរស់នៅដោយល្អ ក៏រមែងលិចចុះ ( ក្នុងសង្សារវដ្ត ) យ៉ាងនោះដែរ ។ ព្រោះហេតុនោះ បុគ្គលគប្បីវៀរបុគ្គលខ្ជិល អ្នកមានព្យាយាមថោកទាបនោះចេញ គប្បីនៅរួមជាមួយនឹងពួកអរិយៈ ជាបុគ្គលស្ងប់ស្ងាត់មានឈានមានចិត្តស្ទុង ( ទៅកាន់ព្រះនិព្វាន ) ជាបណ្ឌិតមានព្យាយាមតឹងរ៉ឹងអស់កាលជានិច្ច ។

**សោមមិត្តត្ថេរ ។**

## អដ្ឋកថា

## សោមមិត្តត្ថេរគាថា

[ ១៣៥ ] គាថារបស់ព្រះសោមមិត្តត្ថេរ មានពាក្យផ្តើមថា **បរិត្តំ ទារុំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះថេរៈនេះ ក៏ជាអ្នកមានបុញ្ញាធិការ ដែលធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទុកក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគព្រះនាមថាសិខី កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូល ដឹងក្តីហើយ ស្តាប់ព្រះពុទ្ធគុណមានចិត្តជ្រះថ្លា ថ្ងៃមួយ ឃើញផ្កាចារមានផ្ការីកស្គុសស្គាយ ក៏បេះយកមកហើយ បោះឡើងទៅលើអាកាស តាំងចិត្តបូជាព្រះសាស្តា ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំង

ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងនគរពារាណសី មានឈ្មោះថា សោមមិត្តៈ ជាអ្នកចប់ត្រៃវេទ ជាអ្នកស្និទ្ធស្នាលជាមួយព្រះថេរៈឈ្មោះវិមលៈ ទៅកាន់សម្នាក់របស់ព្រះថេរៈរឿយៗ ស្តាប់ធម៌ហើយ មានសទ្ធាក្នុងសាសនា បួសហើយ បានឧបសម្បទាហើយ បំពេញវត្តបដិបត្តិត្រាប់ទៅ ។

ចំណែកព្រះវិមលត្ថេរ ជាបុគ្គលខ្ជិលច្រអូស ច្រើនទៅដោយការដេកញុំាងយប់និងថ្ងៃឲ្យកន្លងទៅ ព្រះសោមមិត្តៈគិតថា តើមានប្រយោជន៍អ្វី ព្រោះអាស្រ័យព្រះថេរៈខ្ជិលច្រអូសបែបនេះ ដូច្នេះហើយ ទើបលះព្រះវិមលត្ថេរចូលទៅរកព្រះមហាកស្សបត្ថេរ តាំងនៅក្នុងឱវាទរបស់ព្រះមហាកស្សបត្ថេរហើយចម្រើនវិបស្សនា តាំងនៅក្នុងអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកចងទុកក្នុងអបទានថា

ខ្ញុំបានឃើញផ្កាចារិកហើយ ( បេះផ្កានោះ ) រួចផ្គងអញ្ជលីប្រណម្យឡើង នឹកដល់ព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ហើយបានបូជាបោះផ្កានោះទៅឰដ៏អាកាស ។ ដោយអំពើដែលខ្ញុំបានធ្វើដោយល្អនោះផង ដោយចេតនា ដែលខ្ញុំបានតម្កល់ទុកហើយនោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សទៅ ក៏បានទៅកើតឯឋានតាវត្តិង្ស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវកុសលកម្មក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំ-

ផ្កាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ(១) ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលនឹងគំរាមព្រះវិមលត្ថេរដោយឱវាទ បានពោលគាថា ២ ថា

បុគ្គលតោងកំណាត់ឈើតូច រមែងលិចចុះក្នុងជំនន់ធំ យ៉ាងណាមិញ បុគ្គលអាស្រ័យមនុស្សខ្ជិល ទុកជាមានការរស់នៅដោយល្អក៏រមែងលិចចុះ ( ក្នុងសង្សារវដ្ត ) យ៉ាងនោះដែរ ។

ព្រោះហេតុនោះ បុគ្គលគប្បីវៀរបុគ្គលខ្ជិលអ្នកមានព្យាយាមថោកទាបនោះចេញ គប្បីនៅរួមជាមួយនឹងពួកអរិយៈជាបុគ្គលស្ងប់ស្ងាត់ មានឈាន មានចិត្តស្លុង ( ទៅកាន់ព្រះនិព្វាន ) ជាបណ្ឌិតមានព្យាយាមតឹងរ៉ឹងអស់កាលជានិច្ច ។

បណ្តាបទទាំងនោះ បទថា **បរិត្តំ ទារុមារុយ្ហ យថា សីទេ មហណ្ណវេ** សេចក្តីថា កុលបុត្ត សូម្បីមានសីលជាទីស្រឡាញ់ អាស្រ័យមនុស្សខ្ជិលប្រអូស រមែងលិចចុះ គឺធ្លាក់ក្នុងសង្សារ បានដល់ មិនដល់ត្រើយនៃមហណ្ណវៈ គឺព្រះនិព្វាន ព្រោះហេតុយ៉ាងនេះ ដូច្នោះ កុលបុត្តគប្បីវៀរដោយប្រការទាំងពួងនូវបុគ្គលនោះដែល ឈ្មោះថា **កុសីតំ** ព្រោះលិចចុះកាន់សភាវៈថោកទាបងើបក្បាលមិនរួច ដោយអំណាចនៃកុសលធម៌ដ៏ក្រៃលែង ឈ្មោះថា **ហីនវីរិយំ** ព្រោះមិនមានការប្រារព្ធសេចក្តីព្យាយាម អធិប្បាយថា មិនគប្បីកាន់

---

១-ក្នុងអបទានជាព្រះ កីសុកបុប្ផិយត្ថេរ ។

យកនូវទិដ្ឋានុគតិរបស់បុគ្គលនោះ ។ ព្រះថេរៈ កាលសម្តែងទោសនៃការខិលច្រអូសដោយគាថាដែលជាបុគ្គលាធិដ្ឋាន យ៉ាងនេះហើយ ឥឡូវនេះដើម្បីសម្តែងអានិសង្សក្នុងការប្រារព្ធព្យាយាម ទើបពោលគាថាថា **វិវេត្តេហិ** ដូច្នេះជាដើម ។

សេចក្តីនោះ មានអធិប្បាយថា បុគ្គលពួកណា ឈ្មោះថា ជាបុគ្គល **វិវេត្តេហិ** ព្រោះមានកាយវិវេក បន្ទាប់អំពីនោះ ឈ្មោះថា **អរិយេហិ** ព្រោះជាអ្នកឆ្ងាយចាកកិលេសទាំងឡាយ ឈ្មោះថា **បហិតត្តេហិ** ព្រោះភាពជាអ្នកមានចិត្តស្ទុងចំពោះព្រះនិព្វាន ឈ្មោះថា **ឈាយិហិ** ដោយអំណាចនៃអារម្មណូបនិជ្ឈាន និងដោយអំណាចនៃលក្ខណូបនិជ្ឈាន ឈ្មោះថា **អារទ្ធវិរយេហិ** ព្រោះភាពជាអ្នកមានសេចក្តីព្យាយាមដែលផ្គងហើយ សព្វកាលទាំងពួង ឈ្មោះថា **បណ្ឌិតេហិ** ព្រោះប្រកបដោយបញ្ញា មានលោកិយបញ្ញា និងលោកុត្តរបញ្ញាជាដើម កុលបុត្តអ្នកបំណងញ៉ាំងប្រយោជន៍ឲ្យសម្រេច គប្បីនៅជាមួយនឹងបណ្ឌិតទាំងនោះ គឺគប្បីនៅរួមគ្នា ។

ព្រះវិមលត្ថេរស្តាប់ឱវាទនោះហើយ មានចិត្តសង្វេគ ផ្តើមតាំងវិបស្សនា ញ៉ាំងប្រយោជន៍ខ្លួនឲ្យសម្រេចហើយ សេចក្តីនេះនឹងមានតទៅខាងមុខទៀត ។

## អដ្ឋកថា សោមមិត្តត្ថេរគាថា ចប់

## សព្វមិត្តត្ថេរគាថា

[ ១៣៦ ] ជនទាក់ទងនឹងជន ជនអាស្រ័យនូវជន ជនត្រូវជនបៀតបៀនផង ជនបៀតបៀនជនផង ។ ព្រោះថាប្រយោជន៍អ្វី ដោយជនរបស់ជននោះ ឬដោយជនដែលឲ្យកើតហើយ អាត្មាអញគប្បីលះនូវជនដែលបៀតបៀនជនច្រើនហើយទៅ ។

សព្វមិត្តត្ថេរ ។

## អដ្ឋកថា

## សព្វមិត្តត្ថេរគាថា

[ ១៣៦ ] គាថារបស់ព្រះសព្វមិត្តត្ថេរ មានពាក្យផ្ដើមថា **ជនោ ជនម្ហិ សម្ពទ្ធោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យក្នុងភពនោះៗ ។ ក្នុងកប្បទី ៩២ រាប់ថយក្រោយអំពីភទ្ទកប្បនេះ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាតិស្សៈ កុលបុត្តនេះកើតក្នុងត្រកូលព្រានព្រៃ សម្លាប់ម្រឹគក្នុងព្រៃស៊ីសាច់ចិញ្ចឹមជីវិត ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់អនុគ្រោះកុលបុត្តនោះ ទ្រង់ក៏សម្ដែងស្នាមព្រះបាទទុកក្នុងទីក្បែរៗកុលបុត្តនោះចំនួន ៣ ហើយទ្រង់យាងទៅ ។ កុលបុត្តនោះឃើញស្នាមព្រះបាទ មានរូបកង់ចក្រជាគ្រឿងសម្គាល់ ព្រោះមានការសន្សំដែលធ្វើហើយក្នុងព្រះសម្មាសម្ពុទ្ធទាំងឡាយ ក្នុងអតីត-

កាល មានចិត្តជ្រះថ្លាធ្វើការបូជាដោយផ្កាសិរមាន់ ដោយបុញ្ញកម្មនោះ បដិ-សន្ធិក្នុងស្ថានតាវត្តិង្ស អន្ទោលទៅមកក្នុងសុគតិកពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ នាទគរសាវត្ថី មានឈ្មោះថាសព្វមិត្ត កុលបុត្តនោះដឹងក្តីហើយ ឃើញពុទ្ធានុភាពក្នុងកាលដែលព្រះមានព្រះភាគ ទ្រង់ទទួលវិហារឈ្មោះជេតពន បានទូវសទ្ធា បួសហើយ រៀនកម្មដ្ឋានក្នុងព្រៃ ចូលវស្សា លុះចេញវស្សាហើយ ក៏ទៅកាន់នគរសាវត្ថី ដើម្បីថ្វាយបង្គំព្រះមានព្រះភាគ បានឃើញកូនម្រឹគជាប់អន្ទាក់ ដែលព្រានព្រៃដាក់ក្នុងរវាងផ្លូវ ឯមេម្រឹគដែលជាមេរបស់កូនម្រឹគនោះ មិនជាប់អន្ទាក់ តែមិនគេចទៅឆ្ងាយ ព្រោះស្រឡាញ់ក្នុងកូន មិនហ៊ានចូលទៅជិតអន្ទាក់ ព្រោះខ្លាចស្លាប់ ឯកូនម្រឹគកិតភ័យបម្រះនទៀលទៅមក ហៅរកសេចក្តីករុណា ។ ព្រះថេរៈឃើញដូច្នោះហើយគិតថា ឱហ្ន៎ ! ទុក្ខរបស់សត្វទាំងឡាយ មានការស្រឡាញ់ជាហេតុ ដូច្នេះហើយ ធ្វើដំណើរបន្តទៅទៀត ជួបនឹងចោរជាច្រើន ចាប់បុរសម្នាក់ យកចំបើងរុំរាងកាយដុតទាំងរស់ បុរសនោះស្រែកដោយសំឡេងខ្លាំង អាស្រ័យហេតុ ២ យ៉ាងនោះ កើតសេចក្តីសង្វេគ កាលចោរទាំងឡាយកំពុងស្តាប់នោះឯងបានពោល ២ គាថាថា

ជនទាក់ទងនឹងជន ជនអាស្រ័យនូវជន ជនត្រូវជនបៀតបៀនផង ជនបៀតបៀនជនផង ។ ព្រោះថាប្រយោជន៍អ្វីដោយជនរបស់ជននោះ ឬដោយជនដែលឲ្យកើតហើយ អាត្មាអញគប្បីលះនូវជនដែលបៀតបៀនជនច្រើន ហើយទៅ ។

បណ្ដាបទទាំងនោះ បទថា **ជនោ** បានដល់ បុគ្គលអន្ធពាល ។ បទថា **ជនស្មឹ** បានដល់ ជាមួយជនដទៃ ។ បទថា **សម្ពន្ធោ** បានដល់ ជាប់ចំពាក់ដោយគ្រឿងជាប់ជំពាក់គឺតណ្ហា គឺជាប់ជំពាក់ទៅវិញទៅមកដោយន័យជាដើមថា បុគ្គលនេះជាកូនរបស់អញ បុគ្គលនេះជាម្ដាយរបស់អញ ។

ម្យ៉ាងទៀត បាលីក៏យ៉ាងនេះ តែមានអត្ថថា មានចិត្តចងជាប់យ៉ាងនេះថា ជនទាំងនេះចិញ្ចឹមអញមក អញអាស្រ័យជនទាំងនេះចិញ្ចឹមជីវិត ។

បទថា **ជនមេវស្សិតោ ជនោ** សេចក្ដីថា បុគ្គលដទៃត្រេកអរ គឺជាប់ចំពាក់ហើយដោយតណ្ហា បានដល់ កំណត់កាន់យកអ្នកដទៃនោះឯង ដោយន័យជាដើមថា បុគ្គលនេះជាបុត្ររបស់អញ បុគ្គលនេះជាធីតារបស់អញ ។

បទថា **ជនោ ជនេន ហេឋីយតិ ហេឋេតិ ច ជនោ ជនំ** សេចក្ដីថា ជនអាស្រ័យជនដោយអំណាចនៃលោកៈ ខ្វះនូវការពិចារណា ព្រោះការមិនមាននៃកម្មស្សកតាញាណ និងព្រោះការមិនមានការដឹងតាមសេចក្ដីពិតយ៉ាងណា ជនត្រូវជនដទៃបៀតបៀន គឺ ធ្វើឲ្យលំបាកដោយអំណាចទោសក៏ដូច្នោះ ហើយជនកាលមិនដឹងថា កម្មដែលអញធ្វើនេះនឹងជាកម្មធ្លាក់ដល់អញវិញ ព្រោះជាផលទាក់ទងដោយការបៀតបៀនដ៏ខ្លាំងក្លា ទើបបៀតបៀនគ្នា ។ បទថា **កោ ហិ តស្ស ជនេនត្ថោ** សេចក្ដីថា ជនដែលត្រេកអរនឹងគ្នាដោយអំណាចនៃតណ្ហា ឬបៀតបៀនគ្នាដោយអំណាចនៃទោសៈ នឹងកើតប្រយោជន៍អ្វី ។

បទថា **ជនេន ជនិតេន វា** សេចក្ដីថា បុគ្គលដែលជាមាតាបិតា មាន

*កិច្ចញ៉ាំងអ្នកដទៃឲ្យកើតនោះ នឹងមានប្រយោជន៍អ្វី ។ បទថា* **ជនំ ឱហាយ គច្ឆំ តំ ហោថយិត្វា ពហុំ ជនំ** *សេចក្ដីថា ព្រោះបដិបទារបស់បុគ្គលដែលទាក់ទងទៅក្នុងសង្សារ មានលក្ខណៈយ៉ាងនេះដូចគ្នា ដូច្នោះ គួរលះបុគ្គលប្រភេទនោះ គឺជនមានតណ្ហាដែលបៀតបៀនជនក្ដី ជនមានទោសៈដែលបៀតបៀនជនជាច្រើនក្ដី គប្បីលះ គឺលះបង់ជននោះដោយប្រការទាំងពួង ហើយទៅ អធិប្បាយថា គប្បីដល់ គឺទៅកាន់ស្ថានទីដែលជនទាំងនោះ ប្រទូស្តមិនបាន ។*

*ព្រះថេរៈកាលពោលយ៉ាងនោះហើយ ខ្វល់ខ្វាយក្នុងវិបស្សនា សម្រេចអរហត្តហើយ ក្នុងខណៈនោះឯង សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា*

> *ចេតិយរបស់ព្រះមានព្រះភាគព្រះនាម បទុមុត្តរៈ ជាច្បងក្នុងលោក ប្រកបដោយតាទិគុណ តាំងនៅក្នុងព្រៃធំ ជាទីកុះករដោយម្រឹគសាហាវ ។ បុគ្គលណាមួយ មិនអាចនឹងទៅថ្វាយបង្គំចេតិយបានឡើយ ចេតិយនោះត្រូវស្មៅ និងឈើវល្លិរួបរឹតរលើងរលំ ។ កាលនោះ ខ្ញុំជាអ្នកធ្វើការងារក្នុងព្រៃជាមួយបិតា និងជីតា ក៏បានឃើញព្រះស្តូបក្នុងព្រៃធំដែលមានស្មៅវល្លិ រួបរឹតរលើងរលំនោះ ។ លុះខ្ញុំឃើញពុទ្ធស្តូបហើយ ក៏តាំងចិត្តគោរពថា ព្រះស្តូបរបស់ព្រះសម្ពុទ្ធដ៏ប្រសើរនេះ នៅក្នុងព្រៃរលើងរលំខូចខាតអស់ អ្នកស្គាល់គុណ និងទោសនៃ*

ចេតិយនោះ បើមិនបានជម្រះនូវពុទ្ធស្តូបដែលមិនកំបាំង មិនសមគួរត្រឡប់ទៅប្រកបការងារដទៃវិញ ការណ៍នោះមិនសមគួរទេ ។ ទើបខ្ញុំជម្រះស្មៅនិងឈើវល្លិលើព្រះចេតិយ ហើយថ្វាយបង្គំ រួចថយក្រោយអស់ ៨ ជំហាន រួចដើរចេញទៅ ។ លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្លួនសាងល្អនោះផង ដោយការតាំងចេតនានោះផង ។ វិមានរបស់ខ្ញុំ ដែលបុញ្ញកម្មតាក់តែងល្អហើយក្នុងឋានតាវត្តិង្សនោះ មានវណ្ណៈភ្លឺផ្លេកដូចមាស មានកម្ពស់ ៦០ យោជន៍ មានទំហំ ៣០ យោជន៍ ។ ខ្ញុំបានសោយទេវរាជ្យអស់ ៣០០ ដង បានកើតជាស្តេចចក្រពត្តិ ២៥ ដងទៀត ។ ខ្ញុំកាលអន្ទោលទៅក្នុងភពធំភពតូច រមែងបានភោគៈច្រើន ការខ្វះខាតដោយភោគៈរបស់ខ្ញុំមិនមានឡើយ នេះជាផលនៃការជម្រះ ។ កាលខ្ញុំទៅក្នុងព្រៃធំ តែងទៅដោយគ្រែស្នែង ឬជិះលើកដំរី ខ្ញុំទៅកាន់ទិសណាៗព្រៃរមែងសម្រេចជាទីពឹង ( របស់ខ្ញុំក្នុងទិសនោះៗ ) ។ ខ្ញុំប្រកបហើយដោយបុញ្ញកម្ម មិនដែលឃើញដង្កត់ឬបន្លាដោយចក្ខុឡើយ ដង្កត់ជាដើមនោះតែងចៀសចេញទៅឯងៗ ។ ខ្ញុំមិនដែលកើតរោគឃ្លង់ ពក ស្រែង ធ្លួតជ្រូក ឃ្លង់ដែក ដំណួចពិស ឬកមរមាស់ឡើយ នេះជាផលនៃការជម្រះ ។ ខ្ញុំមានសេចក្តីអស្ចារ្យដទៃ

ទៀត គឺព្រោះតែពុទ្ធស្តូបដែលខ្ញុំជម្រះនោះ ខ្ញុំមិនដែលស្គាល់ពកឬផ្លូចកើតក្នុងកាយរបស់ខ្ញុំទេ ។ ខ្ញុំមានសេចក្តីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូបដែលខ្ញុំជម្រះនោះ ខ្ញុំតែងអន្ទោលទៅកើតក្នុងភពពីរ គឺទេវតាឬមនុស្ស ។ ខ្ញុំមានសេចក្តីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូប ដែលខ្ញុំជម្រះនោះ ខ្ញុំមានសម្បុរដូចមាស មានរស្មីរុងរឿងក្នុងទីទាំងពួង ។ ខ្ញុំមានសេចក្តីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូបដែលខ្ញុំជម្រះនោះ សេចក្តីមិនគាប់ចិត្តតែងចៀសវាង សេចក្តីគាប់ចិត្តតែងប្រាកដឡើង ។ ខ្ញុំមានសេចក្តីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូបដែលខ្ញុំជម្រះនោះ ចិត្តរបស់ខ្ញុំស្អាតល្អ ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តខ្ជាប់ខ្ជួន ។ ខ្ញុំមានសេចក្តីអស្ចារ្យដទៃទៀត គឺ ព្រោះតែពុទ្ធស្តូបដែលខ្ញុំជម្រះនោះ ខ្ញុំអង្គុយលើអាសនៈតែមួយ ក៏បានដល់នូវព្រះអរហត្ត ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ កាលនោះព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្មខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការជម្រះ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ចោរទាំងនោះ ស្តាប់ធម៌ក្នុងសម្នាក់ព្រះថេរៈហើយ កើតសេចក្តីសង្វេគ

---

១-ក្នុងអបទានជាព្រះ បកន្ករត្ថេរ ។

បួសហើយ នាំគ្នាបដិបត្តិធម៌សមគួរដល់ធម៌ ដូច្នេះឯង ។

## អដ្ឋកថា សព្វមិត្តត្ថេរគាថា ចប់

## មហាកាឡត្ថេរគាថា

[ ១៣៧ ] ស្រីឈ្មោះនាងកាឡី មានសរីរៈធំ មានរូបខ្មៅដូចក្អែក បំ-បាក់ភ្លៅម្ខាង ហើយបំបាក់ភ្លៅម្ខាងទៀត បំបាក់ដៃម្ខាងហើយ បំបាក់ដៃម្ខាងទៀត ទម្លាយនូវក្បាល ( របស់មនុស្សស្លាប់ធ្វើឲ្យមានខួរហូរចេញ ) ដូចថ្នាំងទធិ ស្រីនុ៎ះអង្គុយរៀបចំ ( សរីរៈសពនោះ ) បុគ្គលណាអ្នកមិនឈ្លាសវៃ តែងធ្វើនូវឧបធិក្កិលេស បុគ្គលនោះជាមនុស្សល្ងង់ រមែងដល់នូវសេចក្តីទុក្ខរឿយៗ ព្រោះហេតុនោះ បុគ្គលកាលដឹង មិនគួរធ្វើឧបធិឡើយ អាត្មាអញ សូមកុំឲ្យមានក្បាលបែកធ្លាយដេក ( ស្តូកស្តឹង ) ទៀតឡើយ ។

**មហាកាឡត្ថេរ ។**

## អដ្ឋកថា

## មហាកាឡត្ថេរគាថា

[ ១៣៧ ] គាថារបស់ព្រះមហាកាឡត្ថេរ មានពាក្យផ្តើមថា **កាឡី ឥត្ថី** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ សន្សំបុណ្យក្នុងភពនោះៗ ក្នុងព្រះពុទ្ធអង្គមុនៗ ។ ក្នុងកប្បទី ៩១ រាប់ថយអំពីភទ្ទកប្បនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ចូលទៅកាន់ព្រៃដោយ ករណីយកិច្ចឯណានីមួយ ឃើញសំពត់បង្សុកូលចីវរដែលព្យួរនៅត្រង់មែកឈើ ក្នុងព្រៃនោះ មានចិត្តជ្រះថ្លាថា សំពត់កាសាវពស្ត្រ

ដែលជាទង់ជ័យនៃព្រះអរិយៈ សំយុងនៅទីនេះ ហើយបេះផ្កាកណ្ដឹង បូជាសំពត់បង្សុកូលចីវរនោះ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលនៃឈ្មួញរទេះ នាសេតព្យនគរ មានឈ្មោះថាមហាកាឡ ដឹងក្តីហើយ នៅគ្រប់គ្រងផ្ទះ ផ្ទុកទំនិញដោយរទេះ ៥០០ ទៅកាន់នគរសាវត្ថីដោយកិច្ច គឺការជួញដូរ ដាក់រទេះក្នុងទីមួយកន្លែង បន្ទោបង់នូវការហត់នឿយក្នុងការដើរផ្លូវ អង្គុយជាមួយបរិស័ទរបស់ខ្លួន ឃើញពួកឧបាសកកាន់យកគ្រឿងក្រអូប និងកម្រងផ្កាជាដើមទៅកាន់វត្តជេតពនមហាវិហារក្នុងវេលាល្ងាច ខ្លួនឯង ក៏ទៅកាន់វិហារជាមួយពួកឧបាសកទាំងនោះ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តាហើយ បាននូវសទ្ធា បួសហើយអធិដ្ឋានសោសានិកង្គធុតង្គ គឺនៅក្នុងព្រៃខ្មោចជាវត្ត ហើយចូលព្រៃស្មសាន ។ ថ្ងៃមួយ មានស្រីម្នាក់ឈ្មោះថា កាឡី ជាអ្នកបូជាសព កាច់ជើងកាច់ដៃរបស់សាកសពដែលស្លាប់ថ្មីៗ ទាំងសងខាង វាយបំបែកក្បាលឲ្យខួរហូរចេញដូចផ្ទាំងទធិ ហើយដាក់អវយវៈគ្រប់ចំណែកឲ្យដូចដើម ដើម្បីឲ្យព្រះថេរៈចម្រើនកម្មដ្ឋាន តម្កល់ទុកឲ្យព្រះថេរៈពិចារណា ក្នុងទីសម្រាប់ប្រកបសេចក្តីព្យាយាម ហើយអង្គុយក្នុងចំណែកម្ខាង ។ ព្រះថេរៈឃើញចំណែកនៃសាកសពហើយ កាលនឹងទូន្មានខ្លួន បានពោលគាថា ២ ថា

ស្រីឈ្មោះនាងកាឡី មានសរីរៈធំ មានរូបខ្មៅដូចក្អែក បំ-
បាក់ភ្លៅម្ខាង ហើយបំបាក់ភ្លៅម្ខាងទៀត បំបាក់ដៃម្ខាង ហើយ

បំបាក់ដៃម្ខាងទៀត ទម្លាយនូវក្បាល ( របស់មនុស្សស្លាប់ធ្វើឲ្យមានខួរហូរចេញ ) ដូចផ្ទាំងទធិ ស្រីនុ៎ះអង្គុយរៀបចំ ( សរីរៈសពនោះ ) បុគ្គលណា អ្នកមិនឈ្លាសវៃ តែងធ្វើនូវឧបធិក្កិលេស បុគ្គលនោះជាមនុស្សល្ងង់ រមែងដល់នូវសេចក្តីទុក្ខរឿយៗ ព្រោះហេតុនោះ បុគ្គលកាលដឹង មិនគួរធ្វើឧបធិឡើយ អាត្មាអញ សូមកុំឲ្យមានក្បាលបែកធ្លាយដេក ( ស្តូកស្តឹង ) ទៀតឡើយ ។

បណ្តាបទទាំងនោះ បទថា **កាឡី** ជាឈ្មោះរបស់ស្រីនោះ ម្យ៉ាងទៀត ឈ្មោះថា កាឡីយ៉ាងនេះ ព្រោះជាស្រីដែលមានរាងកាយខ្មៅ ។

បទថា **ព្រហតី** បានដល់ មានរាងកាយធំ គឺមានរាងកាយធំជំបង ។ បទថា **ធង្ករូបា** សេចក្តីថា ឈ្មោះថា មានរូបដូចក្អែក ព្រោះមានសម្បុរពណ៌ខ្មៅនោះឯង ។

បទថា **សត្ថិញ្ច ភេត្វា** សេចក្តីថា កាច់ជើងរបស់សាកសព ដោយជាន់ដោយជើងហើយកាច់ ។

បទថា **អបរញ្ច សត្ថឹ** សេចក្តីថា កាច់នូវជើងម្ខាងទៀត ។ បទថា **ពាហាញ្ច ភេត្វា** សេចក្តីថា កាច់ដៃត្រង់ចុងដៃនោះឯង ។

បទថា **សីសញ្ច ភេត្វា ទធិថាលកំវ** សេចក្តីថា វាយក្បាលរបស់សាកសពឲ្យមានខួរហូរចេញ ដូចវាយផ្ទាំងទធិដោយដុំដីនិងដំបង ឲ្យទធិហូរចេញ ព្រោះផ្ទាំងបែកហើយនោះឯង ។

បទថា **ឃសា និសិដ្ឋា អភិសន្ធុហិត្វា** សេចក្តីថា ប្រមូលសាកសព ដែលមានអវយវៈត្រូវកាត់ ត្រូវកាច់បំបាក់ខ្ចាត់ខ្ចាយនោះឯងឲ្យជាប់តគ្នាដោយ ដាក់អវយវៈទាំងនោះ ដូចដើមនោះឯង ដូចអង្គុយពង្រាយគំនរសាច់ស្រស់ ត្រង់រានផ្សារដូច្នោះ ។

បទថា **យោ ច អវិទ្វា ឧបធឹ ករោតិ** សេចក្តីថា បុគ្គលណាឃើញ កម្មដ្ឋានដែលប្រាកដដោយសភាវៈនៃសាកសពនេះហើយ មិនដឹងច្បាស់ មិន ឈ្លាស លះបង់នូវកម្មដ្ឋាន ញុំាងឧបធិ គឺកិលេសឲ្យកើត ដោយមិនធ្វើទុក ក្នុងចិត្តដោយឧបាយ បុគ្គលនោះជាបុគ្គលល្ងង់ខ្លៅ គឺមានបញ្ញាទន់ ឈ្មោះថា រមែងចូលដល់ទុក្ខក្នុងអបាយ មាននរកជាដើមរឿយៗ គឺវិលទៅវិលមក ព្រោះ មិនកន្លងផុតសង្សារ ព្រោះហេតុនោះ បុគ្គលកាលដឹងមិនគួរធ្វើឧបធិឡើយ។

បទថា **តស្មា** ប្រែថា ព្រោះហេតុមានសភាពបែបនោះ ។ បទថា **បជានំ ឧបធឹ** សេចក្តីថា បុគ្គលដឹងឧបធិក្កិលេសណា ក្នុងលោកនេះថាជា ហេតុឲ្យកើតទុក្ខ ធ្វើទុកក្នុងចិត្តដោយឧបាយ មិនគប្បីធ្វើ គឺមិនគប្បីញុំាង ឧបធិឲ្យកើត ។ ព្រោះហេតុអ្វី ព្រោះអាត្មាសូមកុំឲ្យមានក្បាលបែកធ្លាយ ដេក ( ស្តូកស្តឹង ) ទៀតឡើយ អធិប្បាយថា សាកសពនេះ ត្រូវគេទម្លាយក្បាល ដេកយ៉ាងណា អញកុំបីជាបុគ្គលដេកក្នុងព្រៃខ្មោច ត្រូវគេវាយក្បាលដោយ ការកើតរឿយៗក្នុងសង្សារដោយការញុំាងនូវឧបធិ គឺកិលេសយ៉ាងនេះឡើយ កាលព្រះថេរៈទូន្មានខ្លួនយ៉ាងនេះឯង ចម្រើនវិបស្សនា សម្រេចអរហត្តហើយ សមដូចគាថាព័ន្ធដែលលោកចងក្នុងអបទានថា

មានភ្នំមួយឈ្មោះភូតគណៈ នៅជិតព្រៃហិមពាន្ត ខ្ញុំបានឃើញសំពត់បង្សុកូលដែលគេព្យួរលើចុងឈើ ក្បែរភ្នំនោះ ។ កាលនោះ ខ្ញុំជាអ្នករើកកាយ មានចិត្តត្រេកអរ បានបេះផ្កាកណ្ដឹង ៣ បូជាចំពោះសំពត់បង្សុកូលនោះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ កាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្កាកណ្ដឹង ៣ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

## អដ្ឋកថា មហាកាឡត្ថេរគាថា ចប់

---

១- ក្នុងអបទានជាព្រះ តីណិកិង្កណិបូជកត្ថេរ ។

## តិស្សត្ថេរគាថា

[ ១៣៨ ] បុគ្គលអ្នកមានក្បាលត្រងោល ដណ្តប់សង្ឃាដិ ជាអ្នកបាន បាយ ទឹក សំពត់និងទីដេក ឈ្មោះថាបានវត្ថុជាសត្រូវច្រើន ។ ភិក្ខុអ្នកមាន សតិ លុះដឹងទោសនុ៎ះ ថាជាភ័យធំក្នុងសក្ការៈទាំងឡាយហើយ គួរជាអ្នក មានលាភតិច មិនឈ្ងក់ដោយលាភ វៀរឲ្យស្រឡះ ។

**តិស្សត្ថេរ ។**

## អដ្ឋកថា

## តិស្សត្ថេរគាថា

[ ១៣៨ ] គាថារបស់ព្រះតិស្សត្ថេរ មានពាក្យផ្តើមថា **ពហូ សបត្តេ លភតិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុ ដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះ ពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងកាលព្រះមានព្រះភាគព្រះនាមថាវិបស្សី កើតក្នុងត្រកូលព្រាហ្មណ៍ ដល់ នូវភាពជាអ្នកដឹងក្តីហើយ ជាអ្នកសម្រេចក្នុងសិប្បៈទាំងឡាយ ឃើញទោស ក្នុងកាមទាំងឡាយ លះឃរាវាសវិស័យ បួសជាតាបស សាងអាស្រមនៅ ត្រង់ជាយព្រៃរាំង ។ ដើម្បីអនុគ្រោះតាបសនោះ ព្រះមានព្រះភាគ ទ្រង់ចូល និរោធសមាបត្តិមិនឆ្ងាយអំពីអាស្រមនោះ តាបសចេញពីអាស្រមទៅរកផលា ផល ឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា បោះបង្គោល ៤ ធ្វើ

បាវាំដោយមែកវាំងដែលមានផ្ការីកស្គុសស្គាយ អំពីខាងលើព្រះមានព្រះភាគ ឈរបូជាព្រះមានព្រះភាគដោយផ្ការាំងថ្មីផង ស្រស់ផង អស់ ៧ ថ្ងៃ មិនលះបីតិ មានពុទ្ធគុណជាអារម្មណ៍ លុះរំលងទៅ ៧ ថ្ងៃ ព្រះសាស្តាចេញអំពីនិរោធ ទ្រង់ត្រិះរិះដល់ភិក្ខុសង្ឃ ព្រះខីណាស្រពប្រមាណមួយសែនមកចោមរោមព្រះសាស្តាក្នុងវេលានោះឯង ។ ព្រះមានព្រះភាគ ទ្រង់ប្រកាសសម្បត្តិដែលកើតមានដល់តាបសហើយ ត្រាស់អនុមោទនាហើយយាងចៀសចេញទៅ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក អន្ទោលទៅមកក្នុងសុគតិភពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលព្រាហ្មណ៍ នាក្រុងរាជគ្រឹះមានឈ្មោះថាតិស្សៈ ចម្រើនវ័យហើយ រៀនចប់ត្រៃវេទ បង្រៀនមន្តដល់មាណព ៥០០ ដល់នូវភាពជាអ្នកប្រសើរដោយលាភ ឃើញពុទ្ធានុភាពក្នុងគ្រាដែលព្រះសាស្តាយាងទៅកាន់នគររាជគ្រឹះ បាននូវសទ្ធា បួសហើយផ្តើមចម្រើនវិបស្សនា សម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

> អាស្រមដ៏ល្អរបស់ខ្ញុំ គេធ្វើលយចូលទៅក្នុងព្រៃរាំង សឹងដេរដាសដោយផ្ការាំង កាលនោះខ្ញុំនៅក្នុងព្រៃ ។ ព្រះសម្ពុទ្ធមានព្រះភាគ ព្រះនាមបិយទស្សីជាព្រះសយម្ភូជាអគ្គបុគ្គល ទ្រង់ប្រាថ្នាវិវេក បានស្តេចចូលទៅក្នុងព្រៃរាំង ។ ខ្ញុំបានចេញអំពីអាស្រម ទៅក្នុងព្រៃ ក្នុងកាលនោះ ខ្ញុំកាលនឹងស្វែងរកនូវ

មើមឈើនិងផ្លែឈើ បានត្រាច់ទៅក្នុងព្រៃ ។ ខ្ញុំបានឃើញនូវព្រះសម្ពុទ្ធព្រះនាមបិយទស្សី មានយសធំ ព្រះអង្គគង់ចូលនិរោធសមាបត្តិដ៏រុងរឿង ក្នុងព្រៃធំនោះ ។ ខ្ញុំបានតម្កល់ទុកនូវឈើ ៤ កំណាត់ ពីខាងលើនៃព្រះសម្ពុទ្ធ ហើយធ្វើមណ្ឌបយ៉ាងល្អ ប្រក់ដោយផ្កាពំងទាំងឡាយ ។ ខ្ញុំបានទ្រទ្រង់នូវមណ្ឌបដែលប្រក់ដោយផ្កាពំង អស់ ៧ ថ្ងៃ ហើយញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងមណ្ឌបនោះទាំងបានថ្វាយបង្គំនូវព្រះពុទ្ធដ៏ប្រសើរ។ សម័យនោះព្រះមានព្រះភាគ ជាបុរសដ៏ឧត្តម បានចេញអំពីសមាធិ ហើយគង់សម្លឹងមើលទី អំពីចម្ងាយប្រមាណមួយជួរនឹម ។ សាវកឈ្មោះវរុណៈ របស់ព្រះសាស្តា ព្រះនាមបិយទស្សី បានចូលទៅគាល់ព្រះលោកនាយក ជាមួយនឹងព្រះអរហន្តមួយសែនអង្គ ជាអ្នកស្ទាត់ជំនាញ ។ ឯព្រះជិនស្រីមានព្រះភាគព្រះនាមបិយទស្សី ជាធំក្នុងលោក ប្រសើរជាងនរៈគង់ក្នុងកណ្តាលភិក្ខុសង្ឃ ហើយទ្រង់ធ្វើនូវការញញឹមឲ្យប្រាកដ ។ ឧបដ្ឋាកឈ្មោះអនុរុទ្ធៈ របស់ព្រះសាស្តា ព្រះនាមបិយទស្សី ធ្វើចីវរឆៀងស្មាម្ខាង ហើយទូលសួរព្រះមហាមុនីថា បពិត្រព្រះមានព្រះភាគ សភាវៈដូចម្តេចហ្ន៎ជាហេតុនៃព្រះសាស្តាទ្រង់ធ្វើនូវការញញឹម ប្រហែលជាមានហេតុបានជាព្រះសាស្តាទ្រង់ធ្វើនូវការញញឹម ។

មាណពណា ទ្រទ្រង់នូវមណ្ឌប ដែលប្រក់ហើយដោយផ្កាកាំងដល់តថាគតអស់ ៧ ថ្ងៃ តថាគតរឭកឃើញកុសលកម្មរបស់មាណពនោះ ទើបធ្វើនូវការញញឹមឲ្យប្រាកដ ។ បុណ្យណាឲ្យផលក្នុងទេវលោក ឬក្នុងមនុស្សលោក ឬឱកាសណាមិនសមល្មម តថាគតមិនឃើញនូវបុណ្យ ឬឱកាសនោះដែលមិនមានឱកាសឲ្យផលនោះឡើយ ។ កាលបុគ្គលនោះប្រកបដោយបុញ្ញកម្ម ហើយនៅក្នុងទេវលោក បរិស័ទទាំងប៉ុន្មានរបស់បុគ្គលនោះ ស៊ឹងជេរជាសដូចជាផ្កាកាំង ។ បុគ្គលប្រកបដោយបុញ្ញកម្មនោះនឹងត្រេកត្រអាលដោយពួករបាំពួកចម្រៀងពួកដេញដំប្រគំដ៏ជាទិព្វក្នុងទេវលោកសព្វៗកាល ។ បរិស័ទទាំងប៉ុន្មាន របស់បុគ្គលនោះ ស៊ឹងមានក្លិនក្រអូប ទាំងមានភ្លៀងជាវិការៈនៃផ្កាកាំង នឹងធ្លាក់ចុះក្នុងខណៈនោះឯង ។ លុះបុគ្គលនេះច្យុតអំពីទេវលោកនេះ មកកើតជាមនុស្ស នឹងមកកាន់ត្រកូលមនុស្ស មណ្ឌបប្រក់ដោយផ្កាកាំងក្នុងមនុស្សលោកនេះ នឹងទ្រទ្រង់ ( នូវបុគ្គលនេះ ) សព្វៗកាល ។ របាំក្តីចម្រៀងក្តី គ្រឿងដេញដំប្រគំក្តី នឹងចោមរោមនូវបុគ្គលនេះអស់កាលជានិច្ច ក្នុងមនុស្សលោកនេះ នេះជាផលនៃពុទ្ធបូជា ។ មួយទៀត កាលព្រះអាទិត្យរះឡើង ភ្លៀងជាវិការៈនៃផ្កាកាំងនឹងធ្លាក់ចុះមក ឯភ្លៀងជាវិការៈនៃផ្កាកាំងដ៏ប្រកបដោយ

បុញ្ញកម្មនឹងធ្លាក់ចុះមកសព្វៗកាល ។ ក្នុងកប្បទី ១.៨០០ ព្រះសាស្តាព្រះនាម គោតម ទ្រង់កើតក្នុងត្រកូលឱក្កាករាជ នឹងត្រាស់ដឹងក្នុងលោក ។ កុលបុត្តនេះនឹងបានជាឱរសដែលព្រះធម៌និម្មិត ជាអ្នកទទួលនូវមត៌ក ក្នុងធម៌របស់ព្រះគោតមនោះ កំណត់ដឹងអាសវៈទាំងពួងជាអ្នកមិនមានអាសវៈនឹងបរិនិព្វាន។ កាលកុលបុត្តនោះត្រាស់ដឹងនូវធម៌ នឹងមានមណ្ឌបប្រក់ដោយផ្កាកំផ្លងកាលគេកំពុងបូជាលើជើងថ្ករនឹងមានមណ្ឌបប្រក់ដោយផ្កាកំផ្លងក្នុងទីនោះ ។ លុះព្រះមហាមុនីព្រះនាមបិយទស្សី ទ្រង់ប្រកាសនូវវិបាករួចហើយ ទើបសម្តែងនូវព្រះធម៌ដល់បរិស័ទ ទ្រង់ញុំាងបរិស័ទឲ្យឆ្អែតដោយភ្លៀង គឺព្រះធម៌ ។

ខ្ញុំបានសោយរាជ្យជាស្តេចទេវតាក្នុងទេវលោកអស់ ៣០ កប្ប បានជាស្តេចចក្រពត្តិអស់ ៦៧ ដង ។ លុះខ្ញុំច្យុតចាកទេវលោក មកកើតក្នុងមនុស្សលោកនេះ ក៏បាននូវសេចក្តីសុខដ៏ធំទូលាយ មានទាំងមណ្ឌបដែលប្រក់ទៅដោយផ្កាកំផ្លង នេះឯងជាផលនៃមណ្ឌប ។ នេះរាងកាយជាទីបំផុត ភពជាទីបំផុតរបស់ខ្ញុំកំពុងប្រព្រឹត្តទៅ មណ្ឌបប្រក់ដោយផ្កាកំផ្លង តែងមានសព្វៗកាល ក្នុងមនុស្សលោកនេះ ។ ខ្ញុំបានញុំាងព្រះមហាមុនីព្រះនាម គោតម ព្រះអង្គប្រសើរក្នុងពួកសក្យៈ ឲ្យត្រេកអរហើយ បានដល់នូវអចលដ្ឋាន គឺ ព្រះនិព្វាន ខ្ញុំលះ

បង់នូវការឈ្នះនិងការចាញ់អស់ហើយ ។ ក្នុងកប្បទី ១.៨០០ ព្រោះហេតុដែលខ្ញុំបានបូជាព្រះពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈ កាលសម្រេចអរហត្តហើយ បានជាអ្នកដល់នូវភាពជាបុគ្គលដ៏ប្រសើរដោយលាភ ប្រសើរដោយយសជាពិសេស ។ ក្នុងបណ្តាភិក្ខុទាំងនោះ ភិក្ខុជាបុថុជ្ជនពួកខ្លះ ឃើញលាភសក្ការៈរបស់ព្រះថេរៈហើយ សម្តែងនូវការមិនពេញចិត្តចេញមក ដោយភាពជាបុគ្គលពាល ។ ព្រះថេរៈដឹងដូច្នោះ កាលនឹងប្រកាសទោសក្នុងលាភសក្ការៈ និងភាពដែលខ្លួនមិនជាប់ជំពាក់ក្នុងលាភសក្ការៈនោះ បានពោលគាថា ២ ថា

> បុគ្គលអ្នកមានក្បាលត្រងោល ដណ្តប់សង្ឃាដិ ជាអ្នកបានបាយ ទឹក សំពត់ និងទីដេក ឈ្មោះថា បានវត្ថុជាសត្រូវច្រើន ។ ភិក្ខុអ្នកមានសតិ លុះដឹងទោសនុ៎ះ ថាជាភ័យធំក្នុងសក្ការៈទាំងឡាយហើយ គួរជាអ្នកមានលាភតិច មិនឈ្លក់ដោយលាភ វៀរឲ្យស្រឡះ ។

---

១-ក្នុងអបទានជាព្រះ សាលមណ្ឌបិយត្ថេរ ។ ព្រះតិស្សត្ថេរនេះបានសាងបុណ្យទុកដូចគ្នានឹងព្រះថេរៈឈ្មោះនិគ្រោធត្ថេរ ក្នុងឯកនិបាតដែរ ព្រោះហេតុនោះទើបអបទានក៏លោកពោលទុកមានន័យដូចគ្នា ។

គាថាទាំង ២ នោះ មានអធិប្បាយថា ឈ្មោះថា **មុណ្ឌោ** ព្រោះ កោរសក់មិនបន្សល់ទុកត្រឹមតែតិចតួច ។ ឈ្មោះថា **សង្ឃាដិបារុតោ** ព្រោះជាអ្នកទ្រទ្រង់ទុកនូវសំពត់កាសាវពស្ត្រ ដែលគេកាត់ហើយយកមកដេរភ្ជាប់គ្នា បព្វជិតចូលដល់ភាពជាបុគ្គលមានភេទប្លែកគ្នាអំពីគ្រហស្ថយ៉ាងនេះ មានការរស់នៅទាក់ទងដោយអ្នកដទៃ បើបានបាយ និងទឹកជាដើមមក បុគ្គលនោះរមែងឈ្មោះថា បាននូវសត្រូវច្រើន ភិក្ខុជាច្រើននឹងនាំគ្នាប្រណែនភិក្ខុនោះ ។

ព្រោះហេតុនោះ ភិក្ខុដឹងអាទីនវៈ គឺទោស ក្នុងលាភសក្ការៈទាំងឡាយថាជាភ័យធំ គឺជាភ័យធំក្រៃលែងនេះ គឺបែបនេះ គប្បីតាំងនូវភាពជាបុគ្គលដែលមានការប្រាថ្នាតិច និងការសន្តោសទុកក្នុងហទយៈ ហើយគប្បីជាអ្នកមានលាភតិច ដោយវៀរលាភ ដែលកើតឡើងសូម្បីជារបស់មិនមានទោស បន្ទាប់អំពីនោះ ក៏ឈ្មោះថា **អនវស្សុតោ** ព្រោះមិនមានការទទឹក គឺការចង់បានក្នុងលាភនោះ ឈ្មោះថាជា **ភិក្ខុ** ព្រោះឃើញភ័យក្នុងសង្សារ ឬព្រោះភាពជាអ្នកមានកិលេស ដែលទម្លាយហើយ ឈ្មោះថា **សតោ** ដោយអំណាចនៃសតិនិងសម្បជញ្ញៈដែលជាទីតាំងនៃសេចក្ដីសន្តោស គប្បីវៀរជុំវិញ គឺត្រាច់ទៅតាមសប្បាយ ភិក្ខុទាំងឡាយនោះស្ដាប់ពាក្យជាគាថាហើយ ញុំាងព្រះថេរៈឲ្យអត់ទោសក្នុងខណៈនោះឯង ។

### អដ្ឋកថា តិស្សត្ថេរគាថា ចប់

## កិម្ពិលត្ថេរគាថា

[ ១៣៩ ] សក្យបុត្តទាំងឡាយ ជាសំឡាញ់នឹងគ្នា បានលះបង់នូវភោគសម្បត្តិជាច្រើន ( ទៅនៅ ) ក្នុងព្រៃឈ្មោះបាចីនវង្សទាយៈ ត្រេកអរចំពោះវត្ថុដែលតាំងនៅក្នុងបាត្រដោយការស្វែងរក មានព្យាយាមខ្ជាប់ខ្ជួន មានចិត្តស្ទុង មានការខ្មីឃ្មាតមាំអស់កាលជានិច្ច លះបង់នូវតម្រេកក្នុងផ្លូវលោក ហើយត្រេកអរដោយតម្រេកក្នុងផ្លូវធម៌ ។

**កិម្ពិលត្ថេរ ។**

## អដ្ឋកថា

## កិម្ពិលត្ថេរគាថា

[ ១៣៩ ] គាថារបស់ព្រះកិម្ពិលត្ថេរ មានពាក្យផ្តើមថា **ចាចីនវំសទាយម្ហិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

ហេតុកើតសេចក្តីសង្វេគ និងបព្វជ្ជាដែលជាបុព្វភាគនៃរឿងរ៉ាវដែលកើតឡើងនោះ ខ្ញុំបានពោលក្នុងអដ្ឋកថានៃគាថា មានពាក្យថា **អភិសត្តោ** ជាដើម ក្នុងឯកនិបាតរួចហើយ ដោយគាថានោះ ព្រះថេរៈសម្តែងហេតុនៃការសម្រេចគុណវិសេស របស់ខ្លួនផងដែរ ។ តែក្នុងគាថានេះ គប្បីជ្រាបថាពោលដល់ពេលដែលលោកសម្រេចគុណវិសេសហើយនៅរួមគ្នាជាមួយព្រះអានុរុទ្ធនិងព្រះនន្ទិយៈ ។ ព្រះថេរៈកាលសម្តែងដល់ការដែលព្រះថេរៈទាំងនោះ នៅរួមគ្នាដោយការព្រមព្រៀងទើបបានពោលគាថា ២ ថា

សក្យបុត្តទាំងឡាយ ជាសំឡាញ់នឹងគ្នា បានលះបង់នូវភោគ
សម្បត្តិជាច្រើន ( ទៅនៅ ) ក្នុងព្រៃឈ្មោះបាចីនវង្សទាយៈ
ត្រេកអរចំពោះវត្ថុដែលតាំងនៅក្នុងបាត្រដោយការស្វែងរក ។
មានព្យាយាមខ្ជាប់ខ្ជួន មានចិត្តស្ងួន មានការខ្មីឃ្មាតមាំ អស់
កាលជានិច្ច លះបង់នូវតម្រេកក្នុងផ្លូវលោក ហើយត្រេកអរ
ដោយតម្រេកក្នុងផ្លូវធម៌ ។

បណ្ដាបទទាំងនោះ បទថា **បាចីនវំសទាយម្ហិ** បានដល់ ក្នុងព្រៃដែលមានបរិវេណរួមគ្នា មានមនុស្សរក្សាគ្រប់គ្រង មានឈ្មោះថា បាចីនវង្សៈ អធិប្បាយថា ព្រៃនោះ លោកហៅថា បាចីនវង្សទាយវន ព្រោះតាំងនៅក្នុងទិសខាងកើតនៃភូមិស្រុក និងព្រោះគ្របដណ្ដប់ទៅដោយគុម្ពឫស្សី ឬហៅថា បាចីនវង្សទាយវន ព្រោះជាព្រៃឫស្សី ។

បទថា **សក្យបុត្តា** បានដល់ ពួករាជកុមាររបស់ស្ដេចសក្យៈ មានព្រះអនុរុទ្ធត្ថេរជាដើម ។

បទថា **សហាយកា** សេចក្ដីថា ឈ្មោះថា ជាសម្លាញ់នឹងគ្នា ព្រោះជាផ្លូវ គឺជាការតាំងនៅរួមគ្នា ដោយកើតសេចក្ដីសង្វេគរួមគ្នា បួសរួមគ្នា ហើយបំពេញសមណធម៌រួមគ្នា ។

បទថា **បហាយានប្បកេ ភោគេ** សេចក្ដីថា បោលនូវគំនរនៃភោគៈធំ ដែលខ្លួនបានដោយបុញ្ញានុភាពដ៏ឱឡារនិងមានមកដោយការបន្តនៃត្រកូល ។ បាលីថា **សហាយានប្បកេ** ដូច្នេះក៏មាន ។

បទថា **ឧញ្ញេ បត្តាគតេ រតា** សេចក្តីថា ឈ្មោះថា ត្រេកអរហើយ គឺត្រេកអរក្រៃលែងហើយ ក្នុងស្បៀងដែលសូមមក ព្រោះបានមកដោយការត្រាច់សូម និងដែលមានក្នុងបាត្រ គឺទាក់ទងក្នុងបាត្រ ព្រោះមកហើយក្នុងបាត្រ បដិសេធអតិរេកលាភ មានសង្ឃភត្តជាដើម ហើយត្រេកអរដោយភត្តដែលលាយឡំគ្នា ដែលខ្ទនបានហើយដោយការត្រាច់បិណ្ឌបាត ដោយអាស្រ័យកម្លាំងស្មងប៉ុណ្ណោះ ។

បទថា **អារទ្ធវីរិយា** សេចក្តីថា តម្កល់សេចក្តីព្យាយាមទុកដើម្បីសម្រេចប្រយោជន៍ដ៏ឧត្តមតាំងអំពីដើម គឺតាំងអំពីដំបូងនោះឯង ។

បទថា **បហិតត្តា** សេចក្តីថា ឈ្មោះថា ជាអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ព្រោះភាពជាអ្នកបង្អោនទៅ ទោរទន់ទៅ ឈមទៅ ( កាន់ព្រះនិព្វាន ) និងព្រោះចូលដល់តាមកាលវេលា ។

បទថា **និច្ចំ ទឡ្ហបរក្កមា** សេចក្តីថា ឈ្មោះថា ជាអ្នកមានសេចក្តីប្រឹងប្រែងមិនធូរថយអស់កាលទាំងពួង ព្រោះព្យាយាម ប្រកបការនៅជាសុខក្នុងទិដ្ឋធម៌ក្នុងវត្តបដិបត្តិទាំងឡាយ ។

បទថា **រមន្តិ ធម្មរតិយា ហិត្វាន លោកិយំ រតឹ** សេចក្តីថា លះនូវការត្រេកអរក្នុងរូបារម្មណ៍ជាដើម ដែលជាលោកិយ ព្រោះដឹងច្បាស់នូវលោក និងព្រោះដល់ទីបំផុតនៃលោក គឺលះបានដោយមគ្គប្បញ្ញា រមែងត្រេកអរ គឺអភិរម្យ ដោយការត្រេកអរក្នុងលោកុត្តរធម៌ និងដោយការត្រេកអរក្នុងព្រះ-និព្វានដែលជាផលដ៏ប្រសើរ ។

**អដ្ឋកថា កិម្ពិលត្ថេរគាថា ចប់**

## ឆន្នត្ថេរគាថា

[ ១៤០ ] ខ្ញុំកាលប្រកបនូវគ្រឿងប្រដាប់ ( កាយ ) ជាបុគ្គលអណ្តែតអណ្តូងឃ្លេងឃ្លោង ត្រូវកាមរាគបៀតបៀន ព្រោះមិនមានយោនិសោមនសិការ: ។ ( ឥឡូវនេះ ) ខ្ញុំដកចិត្តក្នុងភពបានហើយ ព្រោះប្រតិបត្តិដោយយោនិសោមនសិការ: តាមព្រះពុទ្ធជាអាទិច្ចពន្ធុ ព្រះអង្គមានកុសលោបាយ ( ឧបាយល្អ ) ។

នន្ទុត្តេរ ។

## អដ្ឋកថា

## ឆន្នត្ថេរគាថា

[ ១៤០ ] គាថារបស់ព្រះនន្ទុត្តេរ មានពាក្យផ្តើមថា **អយោនិសោមនសិការា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរ:មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរហង្សវតី ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថា បទុមុត្តរ: ដល់នូវភាពជាអ្នកដឹងក្តីហើយ ស្តាប់ធម៌ក្នុងសម្នាក់នៃព្រះមានព្រះភាគ ឃើញព្រះសាស្តាទ្រង់តាំងភិក្ខុមួយរូប ក្នុងតំណែងនៃឯតទគ្គ: ខាងគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយប្រាថ្នានូវតំណែងនោះ ដោយខ្លួនឯង បំពេញមហាទានមានគ្រឿងបូជា និងសក្ការ:ដ៏ធំដល់ព្រះមានព្រះភាគនិងភិក្ខុសង្ឃ តាំងបណិធានថា ក្នុងអនាគតកាល ខ្ញុំព្រះអង្គគប្បីជាសាវ័កដែលមានសភាពបែបនេះរបស់ព្រះពុទ្ធដូចទ្រង់

ដូច្នេះហើយ បន្ទាប់អំពីនោះ ក៏អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទរបស់ព្រះមានព្រះភាគព្រះនាម អត្ថទស្សី កុលបុត្តនេះ កើតជាអណ្ដើកធំក្នុងស្ទឹងឈ្មោះ វិនតា ។ ថ្ងៃមួយ ឃើញព្រះសាស្ដាប្រថាប់ឈរត្រង់ឆ្នេរស្ទឹង ប្រាថ្នានឹងឆ្លងទឹក មានបំណងនឹងញុំាងព្រះមានព្រះភាគឲ្យឆ្លងដោយខ្លួនឯង ទើបក្រាបចុះទៀបព្រះបាទារបស់ព្រះសាស្ដា ព្រះសាស្ដាទ្រង់ទតនូវអធ្យាស្រ័យរបស់អណ្ដើកហើយ ទ្រង់ឡើងគង់លើខ្នង ។ អណ្ដើកត្រេកអរហើយហែលកាត់ខ្សែទឹកទៅដោយរហ័ស ញុំាងព្រះសាស្ដា ឲ្យដល់ត្រើយយ៉ាងរួសរាន់ ។ ព្រះមានព្រះភាគ ទ្រង់អនុមោទនា ត្រាស់ប្រាប់នូវសម្បត្តិដែលកើតដល់អណ្ដើក ហើយយាងចៀសចេញទៅ ។

ដោយបុញ្ញកម្មនោះ អណ្ដើកអន្ទោលទៅ ក្នុងសុគតិភពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងគភ៌របស់ព្រះនាងមហាបជាបតិគោតមី ជាឱរសរបស់ព្រះបាទសុទ្ធោទនមហារាជ ក្នុងនគរកបិលពស្តុ ក្នុងថ្ងៃថ្វាយព្រះនាមព្រះរាជកុមារ ព្រះញាតិបានថ្វាយនាមថានន្ទ ដូច្នេះ ព្រោះទ្រង់ញុំាងពួកញាតិឲ្យត្រេកអរក្នុងពេលប្រសូត ក្នុងកាលដែលនន្ទកុមារចម្រើនព្រះជន្មវស្សាព្រះសាស្ដាទ្រង់ញុំាងធម្មចក្រដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅ ទ្រង់ធ្វើការអនុគ្រោះសត្វលោកយាងទៅនគរកបិលពស្តុទ្រង់ញុំាងភ្លៀងបោក្ខរព័ស្ស ឲ្យជាហេតុក្នុងញាតិសមាគម ត្រាស់វេស្សន្តរជាតក ហើយយាងចូលទៅបិណ្ឌបាត ក្នុងថ្ងៃទី ២ ញុំាងព្រះជនកឲ្យតាំងនៅក្នុងសោតាបត្តិផលដោយព្រះគាថាធម្មបទថា **ឧត្តិដ្ឋេ នប្បមជ្ជេយ្យ** ដូច្នេះហើយ យាងចូលទៅកាន់និវេសន៍ ញុំាងព្រះនាងមហា-

បជាបតីឲ្យតាំងនៅក្នុងសោតាបត្តិផល និងញ៉ាំងព្រះរាជាឲ្យតាំងនៅក្នុងសកទាគាមិផល ដោយព្រះគាថាធម្មបទថា **ធម្មំ សុចរិតំ ចរេ** ជាដើម ក្នុងថ្ងៃទី ៣ កាលពិធីវិវាហមង្គល គឺ ការនាំរាជធីតាចូលទៅកាន់និវេសន៍ ដោយការអភិសេកនន្ទកុមារ កំពុងប្រព្រឹត្តទៅ ទ្រង់ចូលទៅបិណ្ឌបាត ហើយទ្រង់ញ៉ាំងនន្ទកុមារឲ្យកាន់បាត្រ ត្រាស់មង្គលហើយ ទ្រង់មិនទទួលបាត្រអំពីដៃរបស់នន្ទកុមារហើយចូលកាន់ព្រះវិហារ ញ៉ាំងនន្ទកុមារឲ្យកាន់បាត្រ តាមមកកាន់វិហារ ទាំងជាអ្នកមិនប្រាថ្នានោះឯង ឲ្យបព្វជ្ជាហើយ ទ្រង់ជ្រាបភាពដែលនន្ទកុមារត្រូវសេចក្តីមិនត្រេកអរគ្រប់សង្កត់ ព្រោះហេតុដែលឲ្យបព្វជ្ជាដោយវិធីយ៉ាងនេះហើយទ្រង់បន្ទោបង់នូវការមិនត្រេកអរនោះរបស់នន្ទកុមារនោះដោយឧបាយ ។ ព្រះនន្ទពិចារណាដោយយោនិសោមនសិការ ហើយផ្តើមចម្រើនវិបស្សនា សម្រេចអរហត្ត ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះតថាគតមានព្រះភាគ ព្រះនាមអត្ថទស្សី ជាព្រះសយម្ភូ
ជាលោកនាយក ស្តេចបានចូលទៅទៀបឆ្នេរស្ទឹងវិនតា ។ ខ្ញុំ
ជាអណ្តើកគោចរក្នុងទឹកបានងើបអំពីទឹក មានប្រាថ្នានឹងចម្លង
នូវព្រះពុទ្ធជាម្ចាស់ បានចូលទៅជិតព្រះលោកនាយក ហើយ
ពោលថា បពិត្រព្រះមហាមុនី សូមព្រះពុទ្ធជាម្ចាស់ព្រះនាម
អត្ថទស្សី ទ្រង់ឡើងគង់លើខ្នងនៃខ្ញុំព្រះអង្គចុះ ខ្ញុំព្រះអង្គនឹង
ចម្លងព្រះអង្គ ព្រោះព្រះអង្គ បានធ្វើនូវទីបំផុតនៃទុក្ខ ។ ព្រះ

អត្តទស្សីមានយសធំ ជាលោកនាយក ទ្រង់ជ្រាបសេចក្តីត្រិះរិះរបស់ខ្ញុំហើយ ក៏ឡើងគង់លើខ្នងរបស់ខ្ញុំ ។ វេលាណាខ្ញុំរឮកឃើញនូវខ្លួន វេលាណាខ្ញុំដល់នូវការពដឹងក្តីហើយ វេលានោះខ្ញុំមិនមានសេចក្តីសុខបែបនោះសោះឡើយ ដូចជាផ្ទៃនៃបាតជើង ( ដែលត្រូវបន្ទា ) មុត ។ ព្រះសម្ពុទ្ធព្រះនាមអត្តទស្សីមានយសធំ ទ្រង់ឆ្លងដល់ត្រើយហើយ ព្រះអង្គឋិតនៅទៀបឆ្នេរស្ទឹង ហើយទ្រង់ត្រាស់នូវព្រះគាថានេះថា

ចិត្តប្រព្រឹត្តទៅដរាបណា តថាគតឆ្លងនូវក្រសែនៃសេចក្តីសង្ស័យបានដរាបនោះ ចំណែកអណ្តើកនេះ នឹងបានកើតជាស្តេចមានបុណ្យ ព្រោះបានចម្លងនូវតថាគត ។ អណ្តើកនេះនឹងត្រេកអរក្នុងទេវលោកអស់ ១.៨០០ កប្ប ដោយការចម្លងព្រះពុទ្ធនេះផង ដោយមេត្តាចិត្តដែលប្រព្រឹត្តទៅនេះផង ។ លុះច្យុតចាកទេវលោក មកក្នុងលោកនេះ ត្រូវកុសលមូលដាស់តឿនហើយ នឹងអង្គុយនៅលើអាសនៈតែមួយ ហើយឆ្លងនូវក្រសែនៃសេចក្តីសង្ស័យបាន ។

ពូជស្ងួម្បីមានប្រមាណតិច ដែលបុគ្គលព្រោះហើយក្នុងស្រែដ៏ល្អកាលភ្លៀងញុំាំងធារទឹកឲ្យធ្លាក់ចុះដោយល្អផលរមែងញុំាំង អ្នកស្រែឲ្យត្រេកអរបាន ដូចម្តេចមិញ ។ ពុទ្ធខេត្តនេះដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងហើយរមែងញុំាំងធារ គឺ

ផលឲ្យធ្លាក់ចុះដោយប្រពៃ ផលនឹងញ៉ាំងខ្ញុំឲ្យត្រេកអរបានក៏យ៉ាងនោះដែរ ។ ខ្ញុំជាអ្នកមានចិត្តបញ្ជូនទៅកាន់សេចក្តីព្យាយាម ហើយជាអ្នកស្ងប់រម្ងាប់ មិនមានឧបធិក្កិលេស បានកំណាត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ១.៨០០ ព្រោះហេតុ ដែលខ្ញុំធ្វើកុសលកម្មក្នុងកាលនោះខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃការបម្ទង់ព្រះសម្ពុទ្ធ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ សោយវិមុត្តិសុខ ពិចារណាសង្កិលេស ដែលខ្លួនលះបានហើយ និងសេចក្តីសុខដែលខ្លួនបានទទួលថា គួរអស្ចារ្យ ភាពជាអ្នកឈ្លាសក្នុងឧបាយរបស់ព្រះសាស្តាដោយទ្រង់លើកអញចាកភក់គឺភព ហើយឲ្យប្រតិស្ឋានលើគោកគឺព្រះនិព្វាន ដូច្នេះហើយ កើតនូវសោមនស្សបានពោល ២ គាថាដោយអំណាចនៃឧទានថា

ខ្ញុំកាលប្រកបនូវគ្រឿងប្រដាប់ ( កាយ ) ជាបុគ្គលអណ្តែតអណ្តូងឃ្លេងឃ្លោង ត្រូវកាមរាគបៀតបៀន ព្រោះមិនមានយោនិសោមនសិការៈ ។ ( ឥឡូវនេះ ) ខ្ញុំដកចិត្តក្នុងភពបានហើយ ព្រោះប្រតិបត្តិដោយយោនិសោមនសិការៈ តាមព្រះ

---

១-ក្នុងអបទានជាព្រះ តរណិយត្ថេរ ។ ព្រះនន្ទត្ថេរនេះមានបុញ្ញកម្មដែលធ្វើទុក គឺ ធ្លាប់កើតជាសត្វអណ្តើកដូចព្រះ វនវច្ឆត្ថេរ ក្នុងឯកនិបាតដែរ ។

ពុទ្ធជាអាទិច្ចពន្ធុ ព្រះអង្គមានកុសលោបាយ ( ឧបាយល្អ ) ។

បណ្តាបទទាំងនោះ បទថា **អយោនិសោមនសិការា** សេចក្តីថា ព្រោះធ្វើទុកក្នុងចិត្តនូវកាយដែលមិនស្អាត ដោយភាពជារបស់ស្អាត គឺព្រោះហេតុនៃការធ្វើទុកក្នុងចិត្ត ដោយភាពជារបស់ស្អាត ដោយមនសិការមិនប្រពៃដោយឧបាយ អធិប្បាយថា ព្រោះយល់ថា រាងកាយមិនស្អាត ជាស្អាត ។

បទថា **មណ្ឌនំ** សេចក្តីថា នូវគ្រឿងប្រដាប់អត្តភាព ដោយអាភរណៈទាំងឡាយ មានខ្សែដៃជាដើម និងដោយគ្រឿងលម្អស្បែក មានកម្រងផ្កានិងគ្រឿងក្រអូបជាដើម ។

បទថា **អនុយុញ្ជិតំ** សេចក្តីថា ប្រកបហើយ អធិប្បាយថា បានជាបុគ្គលដែលខ្វល់ខ្វាយប្រដាប់តាក់តែងរាងកាយ ។

បទថា **ឧទ្ធតោ** សេចក្តីថា ជាបុគ្គលរាយមាយ ព្រោះការស្រវឹងក្នុងជាតិ គោត្ត រូប និងភាពកំលោះក្រមុំជាដើម គឺជាអ្នកមានចិត្តមិនស្ងប់ ។

បទថា **ចបលោ** សេចក្តីថា ឈ្មោះថា ជាអ្នកឡេះឡោះ ព្រោះភាពជាអ្នកមានចិត្តមិនមាំទាំ ដូចស្វាព្រៃ និងប្រែប្រួល ព្រោះប្រកបក្នុងភាពជាអ្នកមានអារម្មណ៍ញាប់ញ័រក្នុងការប្រដាប់តាក់តែងរាងកាយ និងប្រដាប់ដោយសំពត់ជាដើម ។

បទថា **អាសឹ** ស្មើគ្នានឹង **អហោសឹ** ប្រែថា បានកើតហើយ ។ បទថា **កាមរាគេន** ប្រកបសេចក្តីថា ជាបុគ្គលដែលឆន្ទរាគៈក្នុងវត្ថុកាមទាំងឡាយបៀតបៀន គឺគ្របសង្កត់ បានដល់ ចាក់ដោត ។

បទថា **ឧបាយកុសលេន** សេចក្ដីថា មានព្រះពុទ្ធ គឺព្រះមានព្រះភាគ ដែលជាអ្នកឈ្លាសក្នុងឧបាយជាគ្រឿងទូន្មានវេនេយ្យសត្វជាហេតុ ។ បទថា **ឧបាយកុសេន** នេះ ជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃហេតុ ។ ព្រះថេរៈពោល ថា **ឧបាយកុសកេន** នេះ សំដៅដល់ការនាំកាមរាគៈរបស់ខ្លួនចេញទៅបាន ដោយព្រះតម្រាស់ដែលជាស់តឿនដោយឧបមា ដោយលើកយក ស្វាភ្លើង រោល និងទេពអប្សរមកប្រៀបធៀប អធិប្បាយថា ព្រះមានព្រះភាគ ទ្រង់ ញុំាងព្រះនន្ទត្ថេរឲ្យមានចិត្តប្រាសចាកតម្រេក ក្នុងនាងជនបទកល្យាណីដោយ ប្រៀបធៀបនាងជនបទកល្យាណីថា ស្វានេះយ៉ាងណា នាងជនបទកល្យាណី ប្រៀបនឹងទេពអប្សរ ដែលមានពណ៌ជើងដូចពណ៌ជើងព្រាប ឧបមាដូចជាង ឈើប្រើស្នៀតធំបោះបញ្ចេញនូវស្នៀតតូច និងដូចគ្រូទេព្យ ធ្វើរាងកាយឲ្យ ញាប់ញ័រ ដោយការឲ្យផឹកប្រេងហើយឲ្យក្អួត និងបន្ទោបង់នូវពិសចេញមក ហើយទ្រង់ញុំាងចិត្ត ឲ្យប្រាសចាកតម្រេកក្នុងស្រីទេពអប្សរ ដែលមានពណ៌ ជើងដូចពណ៌ជើងព្រាប ដោយត្រាស់ប្រៀបធៀបម្ដងទៀត ហើយទ្រង់ញុំាង ព្រះថេរៈឲ្យតាំងនៅក្នុងអរិយមគ្គ ដោយការខ្វល់ខ្វាយក្នុងសមថៈនិងវិបស្សនា ដោយប្រពៃនោះឯង សមដូចគាថាដែលព្រះថេរៈពោលទុកថា ខ្ញុំដកចិត្តក្នុង ភពបានហើយព្រោះប្រតិបត្តិដោយយោនិសោមនសិការៈ តាមព្រះពុទ្ធជាអា-ទិច្ចពន្ធុព្រះអង្គមានកុសលោបាយ ( ឧបាយល្អ ) ។

មួយ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់យាងតាមវិសុទ្ធិប្បដិបទាដោយសមថៈ និងវិបស្សនា ដោយប្រពៃនោះឯងដោយឧបាយគឺដោយព្រះបដិភាណ លើក

ចិត្តរបស់ខ្ញុំដែលលិចក្នុងភព បានដល់ភក់គឺសង្សារដោយព្រះហស្ត គឺអរិយ-មគ្គ អធិប្បាយថា ឲ្យឋិតនៅលើគោក គឺព្រះនិព្វាន ។

ព្រះថេរៈបន្លឺឧទាននេះហើយ ក្នុងថ្ងៃស្អែកឡើង ចូលគាល់ព្រះមានព្រះភាគហើយទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់ជាអ្នកធានាដើម្បីឲ្យខ្ញុំព្រះអង្គបានស្រីទេពអប្សរ ៥០០ ដែលមានពណ៌ជើង ដូចពណ៌នៃជើងព្រាបឯណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ សូមដោះទ្រង់ចាកការធានានោះ ។ សូម្បីព្រះមានព្រះភាគក៏ត្រាស់ថា ម្នាលនន្ទ ការធានាណាជាហេតុឲ្យចិត្តរបស់អ្នករួចផុតចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំក្នុងវេលានោះ តថាគត ក៏ផុតចាកការធានានោះហើយ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ជ្រាបភាពដែលព្រះនន្ទជាអ្នកមានការគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយមួយអន្លើនឹងគុណវិសេសរបស់លោក កាលទ្រង់ប្រកាសគុណវិសេសនោះ ទើបទ្រង់តាំងព្រះថេរៈក្នុងតំណែងឯតទគ្គៈដោយភាពជាអ្នកមានទ្វារគ្រប់គ្រងហើយក្នុងឥន្ទ្រិយដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នករក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយស្រេចនឹងនន្ទៈប្រសើរជាងគេ ដូច្នេះ ។ ពិតហើយព្រះថេរៈគិតថា អញដល់នូវប្រការចម្លែកនេះ ព្រោះអាស្រ័យការមិនសង្រួមឥន្ទ្រិយទាំងឡាយ ឯណា អញនឹងសង្កត់នូវការមិនសង្រួមនោះដោយល្អ ដូច្នេះហើយ កើតនូវឧស្សាហៈ ជាអ្នកមានហិរិឱត្តប្បៈដ៏ខ្លាំងក្លាបានដល់នូវការបរិបូណ៌ដ៏ឧក្រិដ្ឋក្នុងឥន្ទ្រិយសំវរៈ ព្រោះជាអ្នកមានអធិការបានធ្វើទុកហើយក្នុងសាសនានៃព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈនោះដូច្នេះ ។

**អដ្ឋកថា នន្ទត្ថេរគាថា ចប់**

## សិរិមត្ថេរគាថា

[ ១៤១ ] បើពួកបរជន ( មនុស្សផ្តេសផ្តាស ) សរសើរនូវបុគ្គលដែលមិនតម្កល់ខ្លួនខ្ជាប់ខ្លួន ពួកបរជនសរសើរនូវបុគ្គលដែលមិនតម្កល់ខ្លួនខ្ជាប់ខ្លួននោះឯង ជាការណ៍ឥតអំពើ ។ បើពួកបរជន តិះដៀលនូវបុគ្គលដែលតម្កល់ខ្លួនខ្ជាប់ខ្លួនល្អ ពួកបរជន តិះដៀលនូវបុគ្គលដែលតម្កល់ខ្លួនខ្ជាប់ខ្លួនល្អនោះឯង ជាការណ៍ឥតអំពើ ។

### សិរិមត្ថេរ ។

### ឧទ្ទាន

និយាយអំពីមហាចុន្ទត្ថេរ ១ ជោតិទាសត្ថេរ ១ ហេរញ្ញកានិត្ថេរ ១ សោមមិត្តត្ថេរ ១ សព្វមិត្តត្ថេរ ១ មហាកាឡត្ថេរ ១ តិស្សត្ថេរ ១ កិម្ពិលត្ថេរ ១ នន្ទត្ថេរ ១ សិរិមត្ថេរ ១ រួមជាថេរៈ ១០ អង្គមានឫទ្ធិច្រើន ។

### ចប់ ទុតិយវគ្គ ។

## អដ្ឋកថា

## សិរិមត្ថេរគាថា

[ ១៤១ ] គាថារបស់ព្រះសិរិមត្ថេរ មានពាក្យផ្តើមថា **បរេ ច នំ បសំសន្តិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយទុកក្នុងភពនោះៗ ។ ក្នុងកាលនៃព្រះ

ពោធិសត្វព្រះនាមថាបទុមុត្តរៈ ទ្រង់បំពេញបារមីហើយ គង់នៅក្នុងស្ថានតុ-សិត ។ កុលបុត្តនោះកើតក្នុងត្រកូលព្រាហ្មណ៍ ដឹងក្ដីហើយ រៀនចប់ត្រៃវេទ ជាអ្នកជំនាញក្នុងបទនិងពាក្យអធិប្បាយនៃសនិឃណ្ឌុសាស្ត្រ កេដុភសាស្ត្រ អក្ខរសាស្ត្រ មានឥតិហាសៈជាគម្រប់ ៥ យល់ក្នុងលោកាយតនសាស្ត្រនិង មហាបុរិសលក្ខណសាស្ត្រមិនខ្វះខាត លះនូវកាមទាំងឡាយ ហើយបួសជា តាបស ព្រោះភាពជាអ្នកមានអធ្យាស្រ័យបង្អោនទៅក្នុងនេក្ខម្មៈ ដែលពួកតា បសប្រមាណ ៨៤០០០ ចោមរោមហើយ ញ៉ាំងឈាននិងអភិញ្ញាឲ្យកើត នៅក្នុងអាស្រម ដែលទេវតានិម្មិតឲ្យ ក្នុងហិវន្តប្បទេស ព្រោះជាអ្នកមាន បុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ និងព្រោះពិចារណាឃើញនូវ ពុទ្ធគុណ តាមលក្ខណៈមន្ត បានធ្វើចេតិយខ្សាច់ត្រង់មាត់ស្ទឹង ដែលមានទឹក វិលមួយកន្លែង ឧទ្ទិសចំពោះព្រះពុទ្ធទាំងឡាយក្នុងអតីត បានជាអ្នកមាន សេចក្ដីត្រេកអរក្រៃលែងក្នុងការបូជានិងសក្ការៈ ។

តាបសទាំងឡាយឃើញដូច្នោះ ក៏សួរថា សក្ការបូជានេះ លោកម្ចាស់ ធ្វើឧទ្ទិសចំពោះអ្នកណា ។ កុលបុត្តនោះ នាំមន្តសម្រាប់មើលលក្ខណៈមក ប្រាប់លក្ខណៈរបស់មហាបុរស តាមដែលមានមកក្នុងគម្ពីរ ហើយប្រាប់ដល់ តាបសទាំងនោះ តាំងនៅក្នុងកម្លាំងញាណរបស់ខ្លួន ប្រកាសគុណរបស់ព្រះ ពុទ្ធ តាមតម្រាមហាបុរិសលក្ខណៈ ។ តាបសទាំងនោះ ស្ដាប់ដូច្នោះ ហើយ ជាអ្នកមានចិត្តជ្រះថ្លា តាំងអំពីនោះមក ក៏នាំគ្នាបូជាព្រះស្តូប ឧទ្ទិសចំពោះព្រះ សម្មាសម្ពុទ្ធ ។

សម័យនោះ ព្រះពោធិសត្វព្រះនាមថាបទុមុត្តរៈ ចុតិអំពីពួកទេវតាជាន់តុសិត ឈានចុះកាន់គភ៌ព្រះមាតា មានពុទ្ធនិមិត្ត ៣២ ប្រការ និងពុទ្ធនិមិត្តទាំងពួងដែលជាអព្ភូតធម៌គួរអស្ចារ្យ ក្នុងកពចុងក្រោយ ។ តាបសសម្តែងពុទ្ធនិមិត្តទាំងនោះដល់អន្តេវាសិកទាំងឡាយ ចម្រើននូវសេចក្តីជ្រះថ្លា ក្នុងព្រះសម្មាសម្ពុទ្ធទាំងឡាយក្រៃលែង ដល់តាបសទាំងនោះ ធ្វើកាលកិរិយាហើយកើតក្នុងព្រហ្មលោក កាលតាបសទាំងនោះ កំពុងធ្វើការបូជាសរីរៈរបស់ខ្លួន ក៏មកប្រាកដខ្លួនហើយពោលថា ខ្ញុំគឺអាចារ្យរបស់លោកទាំងឡាយ ទៅកើតក្នុងព្រហ្មលោក លោកទាំងឡាយកុំប្រមាទ ព្យាយាមប្រកបការបូជាវាលុកចេតិយ ( ចេតិយខ្សាច់ ) និងចូរខ្វល់ខ្វាយក្នុងការចម្រើនភាវនា ដូច្នេះហើយក៏ត្រឡប់ទៅកាន់ព្រហ្មលោក ។

កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយយ៉ាងនេះ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលគហបតីក្នុងនគរសាវត្ថី ព្រោះហេតុដែលកុលបុត្តនោះចម្រើនសិរីសម្បត្តិក្នុងត្រកូលនោះ រាប់ពីថ្ងៃដែលបានកើតមក ទើបមនុស្សទាំងឡាយដាក់ឈ្មោះថាសិរិមា ដូច្នេះ ។ ក្នុងកាលដែលកុលបុត្តនោះចេះដើរ ប្អូនប្រុសក៏កើត មនុស្សទាំងឡាយបានដាក់ឈ្មោះប្អូនប្រុសថាសិរីវឌ្ឍ ដោយពោលថា កុមារនេះកើតមកធ្វើសិរីឲ្យចម្រើន ។ ទារកទាំង ២ នោះ ឃើញពុទ្ធានុភាព ក្នុងកាលដែលព្រះអង្គទទួលព្រះវិហារជេតពន ជាអ្នកបាននូវសទ្ធាបួសហើយ ។ ព្រះថេរៈ ២ រូបនោះ សិរីវឌ្ឍត្ថេរ មិនទាន់បានសម្រេចឧត្តរិមនុស្សធម៌ តែជាអ្នកបានបច្ច័យ ៤ ជាប្រក្រតី ជាបុគ្គល

ដែលគ្រហស្ថនិងបព្វជិតទាំងឡាយ ធ្វើសក្ការគោរពបូជាហើយ ឯព្រះសិរិ-មត្តេរ ចាប់តាំងពីបួសហើយ ជាអ្នកមានលាភតិច ព្រោះមានកម្មចូលមកកាត់ផ្តាច់ តែជាបុគ្គលដែលមហាជនសរសើររាប់អាន ធ្វើកម្មក្នុងសមថៈ និងវិបស្សនាទាំងឡាយ ជាអ្នកមានអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំកើតជាតាបសឈ្មោះទេវលៈ នៅទៀបភ្នំហិមពាន្ត ពួកអ-មនុស្សបានតាក់តែងទីចង្រ្កមឲ្យខ្ញុំ ក្នុងព្រៃហិមពាន្តនោះ ។ ក្នុងកាលនោះឯង ខ្ញុំបានប្រដាប់នូវគ្រឿងប្រដាប់ គឺផ្នួងសក់ ទ្រទ្រង់នូវកុណ្ឌីទឹក កំពុងតែស្វែងរកនូវប្រយោជន៍ដ៏ឧត្តមហើយចេញទៅអំពីព្រៃ ។ ក្នុងកាលនោះ សិស្សទាំងឡាយរបស់ខ្ញុំប្រមាណ ៨៤.០០០ នាក់ បានចូលមកនៅបម្រើខ្ញុំ សិស្សទាំងនោះ មានសេចក្តីខ្វល់ខ្វាយក្នុងកិច្ចជារបស់ខ្លួន ហើយនៅក្នុងព្រៃ ។ ខ្ញុំបានចេញអំពីអាស្រម ហើយធ្វើព្រះចេតិយដ៏ហើយទៅដោយដីខ្សាច់ ខ្ញុំបានប្រមូលផ្កាផ្សេងៗ ហើយបូជានូវព្រះចេតិយនោះ ។ ខ្ញុំបានញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងចេតិយនោះ ហើយបានចូលទៅកាន់អាស្រមវិញ ។

ពួកសិស្សទាំងអស់ នាំគ្នាមកហើយ បានសួរសេចក្តីនេះថា បពិត្រទេវៈ លោកថ្វាយបង្គំនូវព្រះស្តូបណា ព្រះស្តូបនោះដែលលោកធ្វើហើយដោយដីខ្សាច់ ម្យ៉ាងទៀត យើងខ្ញុំទាំង-

ឡាយចង់ដឹង លោកកាលបើយើងខ្ញុំទាំងឡាយសួរហើយសូម មេត្តាប្រាប់ដល់យើងខ្ញុំទាំងឡាយ ។

ព្រះសម្ពុទ្ធទាំងឡាយ ទ្រង់មានចក្ខុ មានយសធំ ( ប្រាកដ ) ក្នុងបទរបស់មន្តនៃអ្នកទាំងឡាយ យើងឃើញហើយតើ ខ្ញុំថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ជាព្រះពុទ្ធដ៏ប្រសើរ មានយសធំ ។

ព្រះសព្វញ្ញូទាំងនោះ ជាលោកនាយក ទ្រង់មានព្យាយាមធំ ប្រាកដដូចម្តេច មានគុណដូចម្តេច មានសីលដូចម្តេច ព្រះសម្ពុទ្ធទាំងនោះ មានយសធំប្រាកដដូចម្តេច ។

ព្រះពុទ្ធទាំងឡាយ មានលក្ខណៈ ៣២ មានព្រះទន្ត ៤០ គត់ មានកំណើតពីរជង ព្រះនេត្រនៃព្រះសម្មាសម្ពុទ្ធទាំងនោះស្រដៀងនឹងភ្នែកកូនគោ ប្រាកដស្មើដោយផ្លែទំពាំងបាយជូរ ។ ព្រះសម្ពុទ្ធទាំងនោះ កាលស្តេចនឹងទៅ ទ្រង់ក្រឡេកមើលនូវទីចម្ងាយមួយជួរនឹមផង ព្រះជានុនៃព្រះសម្មាសម្ពុទ្ធទាំងនោះមិនលាន់ឮសូរផង សំឡេងទីតនៃព្រះជានុរបស់ព្រះសម្មាសម្ពុទ្ធទាំងនោះមិនឮសូរផង ។ ព្រះសម្ពុទ្ធទាំងនោះកាលស្តេចទៅក៏ទ្រង់ទៅដោយល្អ ទៅមិនបានរួសរាន់ ( ទ្រង់ឈាន ) នូវព្រះបាទខាងស្តាំ ជាដំបូង នេះជាធម្មតា នៃព្រះសម្ពុទ្ធទាំងឡាយ ។ មួយទៀត ព្រះពុទ្ធទាំងនោះ ទ្រង់មិនតក់ស្លុតបីដូច

ជាកេសររាជសីហ៍ ជាស្តេចនៃម្រឹគ ព្រះពុទ្ធទាំងឡាយ ទ្រង់មិនលើកតម្កើងព្រះអង្គឯងផងទាំងមិនបន្ទះបន្អាប់ពួកសត្វផង ។ ព្រះពុទ្ធទាំងឡាយទ្រង់ផុតស្រឡះចាកមានះនិងអតិមានះ ទ្រង់មានព្រះហឫទ័យស្មើចំពោះសត្វទាំងពួង ទ្រង់មិនលើកតម្កើងព្រះអង្គឯងនេះជាធម្មតានៃព្រះសម្ពុទ្ធទាំងឡាយ ។ មួយវិញទៀត ព្រះសម្ពុទ្ធទាំងឡាយនោះ កាលកើតឡើងទ្រង់សម្តែងនូវពន្លឺ ទ្រង់ប្រកាសនូវផែនដីទាំងអស់នេះ មានប្រការ ៦ ។ ក្នុងកាលនោះ ព្រះសម្ពុទ្ធទាំងឡាយនុ៎ះ ទ្រង់ទតឃើញនូវនរកនរកតែងរលត់ទៅវិញ មហាមេឃបង្អុរភ្លៀងចុះមក នេះជាធម្មតានៃព្រះពុទ្ធទាំងឡាយ ។ ព្រះតថាគតទាំងនោះ ជាមហានាគប្រាកដដូច្នោះ ព្រះតថាគតទាំងនោះទ្រង់មានយសធំគេមិនអាចថ្លឹងគុណបាន ព្រះតថាគតទាំងឡាយទ្រង់មិនប្រព្រឹត្តកន្លងចាកគុណ មានព្រះគុណ គឺបុគ្គលមិនគប្បីរាប់បាន ។ ពួកសិស្សទាំងអស់ ជាអ្នកប្រកបដោយសេចក្តីគោរព បានអនុមោទនាតាមពាក្យរបស់ខ្ញុំ សិស្សទាំងឡាយនោះ បាននាំគ្នាប្រតិបត្តិគួរតាមសេចក្តីអង់អាច ទាំងគួរតាមកម្លាំងដោយប្រការដូច្នោះ ។ សិស្សទាំងឡាយនោះ ជាអ្នកមិនខ្ជិលច្រអូសក្នុងការងាររបស់ខ្លួន នាំគ្នាបូជានូវព្រះចេតិយខ្សាច់ សិស្សទាំងឡាយនោះ ជាអ្នកជឿតាមពាក្យរបស់ខ្ញុំ ជាអ្នកមានចិត្ត

ដល់នូវភាពជាព្រះពុទ្ធ ។

ក្នុងកាលនោះ មានទេវបុត្តមួយអង្គ មានយសធំ ច្យុត-ចុះមកអំពីឋានតុសិត បានមកកើតក្នុងផ្ទៃមាតា លោកធាតុទាំងមួយម៉ឺន ក៏ញាប់ញ័រ ។ ខ្ញុំឋិតនៅក្នុងទីចង្រ្កម មិនឆ្ងាយអំពីអាស្រម ពួកសិស្សទាំងអស់បានមកប្រជុំគ្នាក្នុងសម្នាក់របស់ខ្ញុំ ហើយសួរខ្ញុំថា ផែនដីបន្ទឺដូចគោឧសភរាជ ស្រែកឡើងដូចស្តេចនៃម្រឹគ រោទ៍ឡើងដូចជាក្រពើ តើជាវិបាកអ្វីហ្ន៎ ។

ខ្ញុំកំពុងសរសើរនូវព្រះសម្ពុទ្ធអង្គណាក្នុងទីជិតនៃព្រះស្តូបដែលធ្វើហើយដោយដីខ្សាច់ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ព្រះអង្គជាគ្រូ បានស្តេចចូលទៅកាន់ផ្ទៃនៃមាតា ។ ខ្ញុំបានធ្វើធម្មកថា ដល់សិស្សទាំងឡាយនោះ ហើយពោលសរសើរនូវព្រះមហាមុនី រួចបញ្ជូនពួកសិស្សឲ្យត្រឡប់ទៅលំនៅជារបស់នៃខ្លួនវិញ ហើយខ្ញុំអង្គុយពែនភ្នែន ។ មួយទៀតខ្ញុំអស់កម្លាំងណាស់ ព្រោះខ្ញុំមានរោគាព្យាធិជាទម្ងន់ ខ្ញុំរឭកនូវព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ហើយក៏ធ្វើមរណកាលក្នុងទីនោះ ។ ក្នុងកាលនោះ ពួកសិស្សទាំងអស់បានមកប្រជុំគ្នា ហើយធ្វើជើងថ្ករួចលើកសពរបស់ខ្ញុំ ដាក់លើជើងថ្ករ ។ សិស្សទាំង-ឡាយនោះបានចោមរោមជើងថ្ករហើយធ្វើនូវអញ្ជលីលើសិរ្បៈ មានសរគឺសេចក្តីសោកគ្របសង្កត់ បានមកប្រជុំគ្នាហើយយំ

កន្ទក់កន្ទេញ ។ កាលសិស្សទាំងឡាយនោះ កំពុងតែយំរៀបរាប់ ខ្ញុំក៏មកកាន់ជើងថ្កូរ ហើយបានពោលថា ម្នាលអ្នកទាំងឡាយមានបញ្ញាល្អ យើងហ្នឹងហើយជាអាចារ្យរបស់អ្នក អ្នកទាំងឡាយ កុំសោកស្តាយឡើយ ។ អ្នកទាំងឡាយ កុំខ្ជិលច្រអូស ចូរនាំគ្នាព្យាយាមក្នុងប្រយោជន៍របស់ខ្លួន ទាំងយប់ទាំងថ្ងៃចុះ អ្នកទាំងឡាយកុំមានសេចក្តីប្រមាទឡើយ ខណៈរបស់អ្នកទាំងឡាយដល់ប្រាកដហើយ ។ លុះខ្ញុំប្រៀនប្រដៅនូវពួកសិស្សរបស់ខ្លួនរួចហើយ ខ្ញុំក៏ត្រឡប់ទៅឯទេវលោកវិញ ខ្ញុំបានកើតក្នុងទេវលោកអស់ ១៨ កប្ប ខ្ញុំបានកើតជាស្តេចចក្រពត្តិអស់ ៥០០ ដង ខ្ញុំបានទទួលសម្បត្តិជាទេវតាអស់ច្រើនរយដង ។ ក្នុងកប្បទាំងឡាយដ៏សេសខ្ញុំបានអន្ទោលទៅកាន់ភពដ៏ប្រឡូកប្រឡំ តែខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃការកសាងព្រះចេតិយខ្សាច់ ។ ឈើទាំងឡាយជាច្រើនតែងរីកផ្កាក្នុងខែជាទីរីកនៃផ្កាកុមុទ យ៉ាងណាមិញ ឯខ្លួនខ្ញុំក៏បានរីកហើយក្នុងលទ្ធិនៃព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គស្វែងរកនូវគុណដ៏ធំដូច្នោះដែរ ។ ខ្ញុំមានព្យាយាមជាទីនាំទៅនូវធុរៈ ដល់ហើយនូវព្រះនិព្វាន ជាទីអស់ទៅនៃយោគៈ ជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែល

ខ្ញុំសរសើរព្រះសម្ពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរព្រះសម្ពុទ្ធ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ដូច្នេះ(១)។

ភិក្ខុ និងសាមណេរទាំងឡាយដែលជាបុថុជ្ជន មិនដឹងថា ព្រះសិរិមត្ថេរ មានអភិញ្ញា ៦ ជាព្រះអរិយៈ ទើបមិនសរសើរ ជជែកគ្នាពេលណា ក៏នាំគ្នាតិះដៀលព្រោះភាពដែលលោកមានលាភតិចដោយសត្វលោកមិនដាក់ចិត្ត ។ តែនាំគ្នាសរសើរព្រះសិរិវឌ្ឍត្ថេរប៉ុណ្ណោះ ព្រោះភាពដែលលោកជាអ្នកដែលសត្វលោក គោរពរាប់អាន ព្រោះភាពដែលលោកសម្បូរបច្ច័យនិងលាភ ។ ព្រះថេរៈគិតថា ធម្មតាបុគ្គលគួរតិះដៀល បែរជាមានអ្នកពោលសរសើរបុគ្គល ដែលគួរសរសើរ បែរជាត្រូវតិះដៀល នេះជាទោសរបស់បុថុជ្ជនកាលតិះដៀល ទើបពោល ២ គាថាដោយសេចក្តីថា

បើពួកបរជន ( មនុស្សផ្តេសផ្តាស ) សរសើរនូវបុគ្គល ដែលមិនតម្កល់ខ្លួនខ្ជាប់ខ្ជួន ពួកបរជនសរសើរនូវបុគ្គលដែល មិនតម្កល់ខ្លួនខ្ជាប់ខ្ជួននោះឯង ជាការណ៍ឥតអំពើ ។ បើពួក បរជនតិះដៀលនូវបុគ្គលដែលតម្កល់ខ្លួនខ្ជាប់ខ្ជួនល្អ ពួកបរ ជនតិះដៀលនូវបុគ្គលដែលតម្កល់ខ្លួនខ្ជាប់ខ្ជួនល្អនោះឯង ជា ការណ៍ឥតអំពើ ។

---

១-ក្នុងអបទានជាព្រះ បុឡិនុប្បាទកត្ថេរ ។

បណ្ដាបទទាំងនោះ បទថា **បរេ** សេចក្ដីថា អ្នកដទៃក្រៅអំពីខ្លួនឈ្មោះថា **បរេ** ក្នុងគាថានេះ លោកសំដៅដល់បុគ្គលពាលទាំងឡាយ ក្រៅអំពីបណ្ឌិតថាជា **បរេ** អធិប្បាយថា ពាក្យសរសើររបស់បុគ្គលពាលទាំងនោះក៏ដូចជាតិះដៀល ព្រោះត្រូវពោលដោយមិនយល់ ទើបមិនត្រូវកាន់យកជាប្រមាណ ។ បទថា **ធំ** ប្រែថា នូវបុគ្គលនោះ ។

បទថា **បសំសន្តិ** សេចក្ដីថា ម្យ៉ាងទៀត បុគ្គលដទៃរមែងសរសើរ គឺសរសើរបុគ្គលដែលមិនមានគុណតាមសេចក្ដីពិតនោះឯង ដោយការសរសើរគុណដែលមិនមានពិតថា ភិក្ខុឈ្មោះនោះជាអ្នកបានឈាន ឬថាជាព្រះអរិយៈព្រោះការមិនដឹង ឬព្រោះវិបរិតទៅ ដោយតណ្ហាវិបត្តិ ។ ឯ ច សព្ទ ដែលមានក្នុងគាថានេះ មានអត្ថបង្អួលលោកខ្លួនឯង ។ ដោយ ច សព្ទនោះលោកសម្ដែងសេចក្ដីនេះថា បុគ្គលដទៃរមែងសរសើរបុគ្គលនោះ ឯការសរសើរនោះ ក៏គ្រាន់តែជាការសរសើររបស់បុគ្គលទាំងនោះ តែក្នុងបុគ្គលដែលមានចិត្តមិនតាំងមាំនោះ មិនមានហេតុក្នុងការសរសើរឡើយ ។

បទថា **អត្តា ច អសមាហិតោ** សេចក្ដីថា បុគ្គលដទៃរមែងសរសើរបុគ្គលណា បើបុគ្គលនោះ គឺបុគ្គលនេះមានចិត្តមិនតាំងមាំ គឺមិនប្រកបដោយមគ្គសមាធិ ផលសមាធិ ឬត្រឹមឧបចារសមាធិនិងអប្បនាសមាធិ អធិប្បាយថា បើខ្លួនមានចិត្តរាយមាយ គឺមានចិត្តវិលទៅខុស ព្រោះលះកិលេសដែលបដិបក្ខចំពោះការតាំងចិត្តមាំមិនបាន ។ ព្រះថេរៈសម្ដែងការមិនមានគុណ គឺសមាធិនិមិត្ត ដោយបទថា **អសមាហិតោ** នេះ ។

បទថា **មោឃំ** ប្រាប់ភាពជានបុំសកលិង្គ ដូចក្នុងប្រយោគជាដើមថា **វិសមំ ចន្ទិមសុរិយា បរិវត្តន្តិ** កាលព្រះចន្ទ និងព្រះអាទិត្យគោចរទៅមិនស្មើ ... ។

បទថា **បរេ បសំសន្តិ** សេចក្តីថា បុគ្គលណារមែងសរសើរបុគ្គលនោះ គឺបុគ្គលដែលមានចិត្តមិនតាំងមាំ បុគ្គលទាំងនោះ រមែងសរសើរជាមោឃៈ គឺសរសើរទទេ បានដល់ សរសើរមិនមានមូល ព្រោះហេតុអ្វី ព្រោះខ្លួនមានចិត្តមិនតាំងមាំ អធិប្បាយថា ព្រោះចិត្តរបស់បុគ្គលនោះមិនតាំងមាំ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ២ ដូចតទៅនេះថា បទថា **គរហន្តិ** សេចក្តីថា រមែងតិះដៀល គឺនិន្ទា បានដល់ពោលទោសព្រះអរិយៈនិងបុគ្គលដែលបានឈាន ព្រោះការមិនដឹងរបស់ខ្លួន ឬព្រោះការប្រទូស្ត ដោយការចង្អុលបង្ហាញដល់ភាពជាអ្នកមិនប្រព្រឹត្តបដិបត្តិ ឬដោយប្រាថ្នាទម្លាយនូវគុណដោយន័យជាដើមថា ភិក្ខុឈ្មោះនោះមិនប្រកបព្យាយាមរឿយៗ ដោយហោចសូម្បីត្រឹមមួយខណៈរីតទឹកដោះគោ ច្រើនទៅដោយការស្អិតស្អាងរាងកាយ ត្រេកអរក្នុងការដេក ត្រេកអរក្នុងការនិយាយពាក្យឥតប្រយោជន៍ ត្រេកអរដោយការប្រឡូកប្រឡំដោយពួកគណៈ ដូច្នេះ ។ ពាក្យដ៏សេសគប្បីជ្រាបដោយបរិយាយដែលខ្ញុំពោលក្នុងគាថាទី ១ ។ កាលព្រះថេរៈប្រកាសភាពដែលខ្លួនជាអ្នកអស់កិលេសនិងភាពដែលព្រះសិរិវឌ្ឍត្ថេរនៅមានកិលេស ដោយគាថាទាំងនេះយ៉ាងនេះហើយ ព្រះសិរិវឌ្ឍត្ថេរស្តាប់ពាក្យជាគាថានេះហើយ កើតសេចក្តីសង្វេគផ្តើមចម្រើនវិបស្សនាញុំាងប្រយោជន៍ខ្លួនឲ្យបរិបូណ៌ហើយ ក្នុង

កាលមិនយូរឡើយ បុគ្គលអ្នកតិះដៀលទាំងឡាយ ក៏សូមឲ្យព្រះថេរៈអត់ទោស ។

## អដ្ឋកថា សិរិមត្តេរគាថា ចប់

## វគ្គទី ២ ចប់

# ថេរគាថា ឯកនិបាត

## តតិយវគ្គ

### ឧត្តរត្ថេរគាថា

[ ១៤២ ] ខន្ធទាំងឡាយ ខ្ញុំកំណត់ដឹងហើយ តណ្ហាខ្ញុំដកចេញស្រឡះហើយ ពោជ្ឈង្គៈខ្ញុំបានចម្រើនហើយ ការក្ស័យទៅនៃអាសវៈ ខ្ញុំក៏បានដល់ហើយ ។ ខ្ញុំនោះ លុះកំណត់ដឹងខន្ធហើយ លុះដកចេញនូវបណ្តាញគឺតណ្ហាហើយ លុះចម្រើនពោជ្ឈង្គហើយ ក៏ទៅជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន។

ឧត្តរត្ថេរ ។

## វគ្គទី ៣

### អដ្ឋកថា

### ឧត្តរត្ថេរគាថា

[ ១៤២ ] គាថារបស់ព្រះឧត្តរត្ថេរ មានពាក្យផ្តើមថា **ខន្ធា មយា បរិញ្ញាតា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ។ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមថាសិទ្ធត្ថ ក្នុងកប្បទី ៩៤ រាប់ថយក្រោយអំពីភទ្ទកប្បនេះ កុលបុត្តនោះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាព

ជាអ្នកដឹងក្តីហើយ ជាអ្នកជ្រះថ្លាក្នុងព្រះសាស្តាប្រកាសខ្លួនជាឧបាសក កាលព្រះសាស្តាព្រះនិព្វានហើយ បានហៅញាតិរបស់ខ្លួនមកប្រជុំគ្នា រួបរួមគ្រឿងសក្ការៈបូជាដ៏ច្រើន ធ្វើការបូជាព្រះធាតុហើយ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំង-ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ក្នុងនគរសាកេតមានឈ្មោះជាឧត្តរៈ ចម្រើនវ័យហើយ ទៅកាន់នគរសាវត្ថីដោយករណីយកិច្ចឯណានីមួយ ឃើញយមកប្បាដិហារ្យដែលព្រះមានព្រះភាគទ្រង់ធ្វើហើយ ត្រង់គល់គណ្ឌម្ពព្រឹក្ស ជ្រះថ្លាហើយ ជាអ្នកមានសទ្ធាចម្រើនក្រៃលែងដោយទេសនាកាលការាមសូត្រ បួសហើយ ទៅកាន់នគររាជគ្រឹះជាមួយព្រះសាស្តា បានឧបសម្បទាហើយ នៅក្នុងនគររាជគ្រឹះនោះឯង ផ្តើមចម្រើនវិបស្សនា បានអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

> កាលព្រះលោកនាថព្រះនាមសិទ្ធត្ថៈ ជាលោកនាយក ស្តេចបរិនិព្វានហើយ ខ្ញុំបានប្រជុំពួកញាតិរបស់ខ្ញុំ ហើយធ្វើនូវការបូជាព្រះធាតុ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះធាតុក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃការបូជាព្រះធាតុ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១]។

---

១-ក្នុងអបទានជាព្រះ ធាតុបូជកត្ថេរ ។

កាលសម្រេចអភិញ្ញា ៦ ហើយ កាលព្រះសាស្តាគង់នៅក្នុងនគរសាវត្ថី ព្រះថេរៈ ចេញអំពីក្រុងរាជគ្រឹះ ទៅកាន់នគរសាវត្ថី ដើម្បីធ្វើពុទ្ធុបដ្ឋាក កាលភិក្ខុទាំងឡាយសួរថា អាវុសោ កិច្ចនៃបព្វជិត លោកឲ្យដល់ទីបំផុតហើយឬ កាលព្យាករអរហត្តផល បានពោលគាថា ២ ថា

ខន្ធទាំងឡាយ ខ្ញុំកំណត់ដឹងហើយ តណ្ហាខ្ញុំដកចេញស្រឡះហើយ ពោជ្ឈង្គៈខ្ញុំបានចម្រើនហើយ ការក្ស័យទៅនៃអាសវៈខ្ញុំក៏បានដល់ហើយ ។ ខ្ញុំនោះលុះកំណត់ដឹងខន្ធហើយ លុះដកចេញនូវបណ្តាញ គឺតណ្ហាហើយ លុះចម្រើនពោជ្ឈង្គហើយ ក៏ទៅជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

បណ្តាបទទាំងនោះ បទថា **ខន្ធា** បានដល់ ឧបាទានក្ខន្ធ ៥ ។ បទថា **បរិញ្ញាតា** សេចក្តីថា កំណត់ដឹង គឺញ៉ាំងទុក្ខសច្ចឲ្យចម្រើនហើយថា នេះទុក្ខ ទុក្ខក្រៅលែងជាងនេះមិនមាន ដូច្នេះ ។ ដោយបទថា **បរិញ្ញាតា** នោះ លោកពោលសំដៅដល់ការត្រាស់ដឹង ដោយការកំណត់ដឹងទុក្ខអរិយសច្ច ។

បទថា **តណ្ហា** សេចក្តីថា កិលេសជាតិ ឈ្មោះថា តណ្ហា ព្រោះអត្ថថា ឲ្យតក់ស្លុត គឺញាប់ញ័រ ។ បទថា **សុសមូហតា** បានដល់ ដែលខ្ញុំដកឡើងហើយ ។ ព្រះថេរៈពោលដល់ការត្រាស់ដឹងដោយការលះសមុទយសច្ច ដោយបទថា **សុសមូហតា** នេះ ។ បទថា **ភាវិតា មម ពោជ្ឈង្គា** សេចក្តីថា ធម៌ ៧ ប្រការ ឈ្មោះថាពោជ្ឈង្គ ព្រោះជាអង្គនៃធម្មសាមគ្គីមានសតិជាដើម ពោលគឺធម៌ជាគ្រឿងត្រាស់ដឹងឬព្រោះជាអង្គនៃព្រះអរិយបុគ្គល

ដែលដល់ព្រមដោយធម្មសាមគ្គីនោះ គឺដែលលោកពោលថា ធម៌ជាគ្រឿងត្រាស់ដឹង ។ ធម៌ទាំងឡាយដែលទាក់ទងហើយក្នុងមគ្គ ពោលគឺ សតិ ធម្មវិចយ វីរិយៈ បីតិ បស្សទ្ធិ សមាធិ និងឧបេក្ខាដែលខ្ញុំចម្រើនហើយ គឺឲ្យកើតហើយ បានដល់ ចម្រើនហើយ ។ ក្នុងគាថានេះ គប្បីជ្រាបថា ធម៌ក្នុងអដ្ឋមគ្គទាំងពួងក្តី ពោធិបក្ខិយធម៌ទាំងអស់ក្តី គប្បីជ្រាបថា លោកកាន់យកហើយដោយសព្ទថា **ពោជ្ឈង្គ** ព្រោះជាប្រភេទធម៌ដែលទៅរួមជាមួយនឹងពោជ្ឈង្គនោះ ។ ព្រះថេរៈសម្តែងការត្រាស់ដឹងដោយការចម្រើនមគ្គសច្ចដោយបទថា **ភាវិតា មម ពោជ្ឈង្គា** នេះដូចគ្នា ។

បទថា **បត្តោ មេ អាសវក្ខយោ** សេចក្តីថា សង្ខតធម៌ឯណា ឈ្មោះថា អាសវក្ខយៈ ព្រោះជាទីអស់ទៅនៃអាសវៈទាំងឡាយ មានកាមាសវៈជាដើម ដែលខ្ញុំដល់ហើយ គឺ សម្រេចហើយ ។ ព្រះថេរៈពោលការត្រាស់ដឹង ដោយការធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ចដោយបទថា **បត្តោ មេ អាសវក្ខយោ** នេះ ។ ព្រះថេរៈសម្តែងសម្បត្តិ ២ គឺសឧបាទិសេសនិព្វាន របស់ខ្លួនដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

ឥឡូវនេះ ព្រះថេរៈកាលសម្តែងសម្បត្តិ គឺអនុបាទិសេសនិព្វាន ទើបពោលគាថាទី ២ ដោយពាក្យជាដើម **សោហំ** ដូច្នេះ ។

គាថាទី ២ នោះ មានអធិប្បាយដូច្នេះថា ខ្ញុំនោះដឹងហើយ គឺកំណត់ដឹងខន្ធទាំងឡាយ ដោយន័យដូចពោលហើយយ៉ាងនេះ កាលកំណត់ដឹងយ៉ាងនេះហើយ ទើបដក គឺលើកឡើងនូវតណ្ហា ដែលបានឈ្មោះថា **ជាលិនី** ព្រោះ

មានសំណាញ់ ពោលគឺ ការកើតរឿយៗ មានការរួបរឹតពួកសត្វក្នុងអត្តភាព របស់ខ្លួន និងអត្តភាពរបស់អ្នកដទៃ ក្នុងអាយតនៈខាងក្នុង និងអាយតនៈ ខាងក្រៅ មានអតីតជាដើម អំពីចិត្តសន្តានរបស់ខ្ញុំ កាលលើកនូវសំណាញ់ គឺតណ្ហានោះបានយ៉ាងនោះ ក៏ញ៉ាំងពោធិបក្ខិយធម៌ មានប្រភេទដូចពោលហើយឲ្យ ចម្រើន គឺ ញ៉ាំងពោធិបក្ខិយធម៌ទាំងនោះ ឲ្យដល់នូវសេចក្តីបរិបូណ៌ ដោយការនា បន្ទាប់អំពីនោះទៅ ទើបជាអ្នកមិនមានអាសវៈ តាំងនៅ ឥឡូវនេះខ្ញុំនឹងបរិ និព្វាន គឺនឹងបរិនិព្វាន ដោយការរលត់នៃចិត្តចុងក្រោយ ដូចអណ្តាតភ្លើងដែល អស់កំញមរលត់ទៅដូច្នោះ ។

## អដ្ឋកថា ឧត្តរត្ថេរគាថា ចប់

## ភទ្ទជិត្ថេរគាថា

[ ១៤៣ ] ប្រាសាទមាស ខាងទទឹង មានសន្ទុះនៃសរ ១៦ ខាងកំពស់ មានសន្ទុះនៃសរ ១០០០ របស់ព្រះរាជាអង្គណា ព្រះរាជាអង្គនោះទ្រង់ព្រះនាមថាបនាទៈ ។ ប្រាសាទនោះមានសន្ទុះនៃសរ ១០០០ មានជាន់ជាច្រើន មានទង់ជ័យជាច្រើន សម្រេចដោយកែវមណីខៀវ អ្នករបាំក៏បានរាំលើប្រាសាទនោះ អ្នករបាំ ៦០០០ នាក់ ( តែងរាំ ) ក្នុងជាន់ទាំង ៧ ។

ភទ្ទជិត្ថេរ ។

## អដ្ឋកថា

## ភទ្ទជិត្ថេរគាថា

[ ១៤៣ ] គាថារបស់ព្រះភទ្ទជិត្ថេរ មានពាក្យផ្ដើមថា **បនាទោ នាម សោ រាជា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថា បទុមុត្តរៈ កើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវភាពជាអ្នកដឹងក្ដីហើយ រៀនចប់សិប្បវិជ្ជានៃព្រាហ្មណ៍ទាំងឡាយ លះកាមហើយបួសជាតាបស សាងអាស្រមត្រង់ជាយព្រៃ ថ្ងៃមួយឃើញព្រះសាស្ដានិមន្ដទៅតាមអាកាស មានចិត្តជ្រះថ្លា ឈរផ្គងអញ្ជលី ។ ព្រះសាស្ដា ទ្រង់ជ្រាបអធ្យាស្រ័យនៃកុលបុត្តនោះ ទ្រង់ចុះអំពីអាកាស ។ តាបសបង្អោនយកទឹកឃ្មុំ ក្រអៅឈូក សប្បិនិងខីរៈ ចូលទៅថ្វាយដល់ព្រះមានព្រះភាគ ព្រះសាស្ដាទ្រង់អាស្រ័យសេច-

ក្តីអនុគ្រោះតាបសទើបទ្រង់ទទួល អនុមោទនាហើយ ចៀសចេញទៅ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងស្ថានតុសិត តាំងនៅក្នុងតុសិតភពនោះ រហូតអស់អាយុ បន្ទាប់អំពីនោះ ក៏អន្ទោលទៅមកនៅតែក្នុងសុគតិភពប៉ុណ្ណោះ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាវិបស្សីកើតជាសេដ្ឋីមានទ្រព្យច្រើន បាននិមន្តភិក្ខុសង្ឃ ៦៨០០០ រូប ឲ្យឆាន់កត្តាហារ និងឲ្យគ្រងត្រៃចីវរ ។

កុលបុត្តនោះ បំពេញកុសលដ៏ច្រើនយ៉ាងនេះហើយ កើតក្នុងទេវលោកដរាបដល់អស់អាយុ ចុតិអំពីទេវលោកនោះហើយ កើតក្នុងមនុស្ស កាលកប្បទទេមិនមានព្រះពុទ្ធ ក៏ទំនុកបម្រុងព្រះបច្ចេកពុទ្ធប្រមាណ ៥០០ អង្គដោយបច្ច័យ ៤ ចុតិអំពីនោះហើយ កើតក្នុងរាជត្រកូល បន្តរាជសម្បត្តិដោយលំដាប់ ទំនុកបម្រុងព្រះឱរសរបស់ព្រះអង្គដែលសម្រេចបច្ចេកពោធិញ្ញាណលុះព្រះបច្ចេកពុទ្ធ បរិនិព្វានហើយ រក្សាព្រះធាតុយកមកកសាងព្រះចេតិយបូជា ។ កុលបុត្តនោះធ្វើបុណ្យនោះៗទុកក្នុងភពនោះៗ យ៉ាងនេះហើយ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តទោលនៃភទ្ទិយសេដ្ឋី ដែលមានសម្បត្តិ ៨០ កោដិក្នុងភទ្ទិយនគរ មានឈ្មោះថាភទ្ទជិ បានឮថា ឥស្សរិយសម្បត្តិ ភោគសម្បត្តិនិងបរិវារសម្បត្តិជាដើម នៃកុលបុត្តនេះ ដូចគ្នានឹងរបស់ព្រះពោធិសត្វក្នុងភពចុងក្រោយ ។

ក្នុងកាលនោះ ព្រះសាស្តាចាំវស្សាក្នុងនគរសាវត្ថី ទ្រង់យាងទៅកាន់ភទ្ទិយនគរ មួយអន្លើដោយមហាភិក្ខុសង្ឃដើម្បីអនុគ្រោះភទ្ទជិកុមារ គង់នៅ

ត្រង់ជាតិយាវែន ទ្រង់វង់ចាំការចាស់ក្លានៃញាណរបស់កទ្ទជិកុមារ ។ កទ្ទជិកុមារអង្គុយលើប្រាសាទខាងលើ បើកបង្អួចសម្លឹងមើល ឃើញមហាជនធ្វើដំណើរទៅស្តាប់ធម៌ ក្នុងសម្នាក់នៃព្រះមានព្រះភាគ ទើបសួរថា មហាជនពពាក់ពពូនទេះ ពួកគេទៅណាហ្ន៎ ដឹងហេតុនោះហើយ ខ្លួនឯងក៏ទៅកាន់សម្នាក់របស់ព្រះសាស្តា ដោយបរិវារច្រើន អង្គុយស្តាប់ធម៌ ញុំាងកិលេសទាំងឡាយឲ្យអស់ទៅ សម្រេចអរហត្តហើយ ទាំងដែលមានខ្លួនប្រដាប់ដោយគ្រឿងអលង្ការទាំងពួង សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលនោះ ខ្ញុំបានចុះក្នុងស្រះបោក្ខរណី ដែលដំរីនានាតែងអាស្រ័យ ខ្ញុំបានដកក្រអៅឈូកក្នុងស្រះនោះ ព្រោះហេតុនៃសេចក្តីស្រេកឃ្លាន ។ សម័យនោះ ព្រះសម្មាសម្ពុទ្ធមានព្រះភាគព្រះនាមបទុមុត្តរៈ ដែលមានព្រះហឫទ័យល្អ ទ្រទ្រង់នូវសំពត់កម្ពលក្រហម ស្តេចទៅតាមផ្លូវអាកាស ។ គ្រានោះខ្ញុំកំពុងរលាស់នូវសំពត់បំសុកូល បានឮសំឡេង ខ្ញុំក្រឡេកមើលទៅខាងលើ ក៏បានឃើញព្រះលោកនាយក ។ ខ្ញុំឈរនៅក្នុងទីនោះឯង ហើយបានអារាធនាព្រះលោកនាយក ទាំងកំពុងកាន់ក្រអៅឈូកមានរសផ្អែម ដោយពាក្យថា វីរៈនិងសប្បិហូរចេញអំពីក្រអៅឈូក ។ សូមព្រះសម្មាសម្ពុទ្ធជាម្ចាស់មានចក្ខុជាសាស្តា មានយសធំ ប្រកបដោយសេចក្តីករុណាស្តេចចុះមកអំពីអាកាសនោះហើយ ទ្រង់ទទួលដោយសេចក្តី

អនុគ្រោះដល់ខ្ញុំ ។ ព្រះសម្មាសម្ពុទ្ធមានចក្ខុ ទ្រង់ទទួលភិក្ខា របស់ខ្ញុំដោយសេចក្តីអនុគ្រោះ លុះទ្រង់ទទួលហើយ ទ្រង់ធ្វើ អនុមោទនា ដល់ខ្ញុំថា ម្នាលអ្នកមានបុណ្យច្រើន អ្នកចូរជា បុគ្គលដល់នូវសេចក្តីសុខចុះ គតិរបស់អ្នកចូរសម្រេចចុះ អ្នក ចូរបាននូវសេចក្តីសុខដ៏ធំទូលាយដោយការឲ្យនូវក្រអៅឈូក នេះចុះ ។ ព្រះសម្មាសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ លុះទ្រង់ត្រាស់ អនុមោទនានេះហើយ ព្រះជិនស្រីសម្មាសម្ពុទ្ធទ្រង់ទទួលភិក្ខា ហើយស្តេចមកតាមផ្លូវអាកាស ។ ខ្ញុំបានកាន់យកក្រអៅឈូក អំពីទីនោះ ហើយមកអាស្រមរបស់ខ្ញុំ ខ្ញុំបានព្យួរក្រអៅឈូក លើមែកឈើ ហើយនឹកនូវទានរបស់ខ្ញុំ ។ គ្រានោះ ខ្យល់ធំ បានតាំងឡើងហើយញាំងព្រៃឲ្យញាប់ញ័រ អាកាសក៏បន្លឺឡើង ដោយសំឡេងរន្ទះបាញ់ ។ ក្នុងកាលនោះ អសនីបាតធ្លាក់ត្រូវ ក្បាលខ្ញុំ ខ្ញុំនោះកំពុងអង្គុយ ក៏ធ្វើមរណកាលក្នុងទីនោះ ។ ខ្ញុំ ប្រកបដោយបុញ្ញកម្ម ហើយបានទៅកើតក្នុងឋានតុសិត សាក សពរបស់ខ្ញុំធ្លាក់ចុះ ខ្ញុំត្រេកអរក្នុងទេវលោក ។ ពួកនារី ៨ ម៉ឺន ៦ ពាន់ តាក់តែងគ្រឿងប្រដាប់ប្រពៃ តែងបម្រើខ្ញុំទាំង ល្ងាចទាំងព្រឹក នេះជាផលនៃការឲ្យក្រអៅឈូក ។ ក្នុងកាល នោះ ខ្ញុំបានមកកាន់កំណើតនៃមនុស្ស ដល់នូវសេចក្តីសុខ សេចក្តីខ្វះខាតភោគរបស់ខ្ញុំមិនមានឡើយ នេះជាផលនៃការ

ថ្វាយក្រអៅឈូក ។ ខ្ញុំជាអ្នកត្រូវព្រះតាទិបុគ្គល ជាទេវតា កន្ទង់ទេវតានោះអនុគ្រោះហើយ ក៏មានអាសវៈទាំងពួងអស់ ឥតសេសសល់ ឥឡូវនេះភពថ្មីរបស់ខ្ញុំមិនមានឡើយ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យភិក្ខា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យក្រអៅឈូក ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលភទ្ទជិកុមារនោះសម្រេចអរហត្តហើយ ព្រះសាស្តាត្រាស់ហៅភទ្ទិយសេដ្ឋីមកត្រាស់ថា កូនរបស់អ្នកស្តាប់ធម៌ហើយតាំងនៅក្នុងអរហត្តទាំងដែលមានគ្រឿងប្រដាប់តាក់តែង ដោយហេតុនោះ ភទ្ទជិកុមារនោះ គួរបួសក្នុងឥឡូវនោះឯង បើមិនបួសនឹងត្រូវបរិនិព្វាន ដូច្នេះ ។ សេដ្ឋីក្រាបទូលថា កូនរបស់ខ្ញុំព្រះអង្គនៅតូចណាស់ មិនគួរបរិនិព្វាន សូមទ្រង់ឲ្យកូនខ្ញុំព្រះអង្គបួសចុះ ព្រះសាស្តាទ្រង់ញ៉ាំងភទ្ទជិកុមារឲ្យបព្វជ្ជា ហើយឲ្យឧបសម្បទា ទ្រង់គង់នៅក្នុងភទ្ទិយនគរនោះអស់ ៧ ថ្ងៃ ហើយយាងដល់កោដិគាម ។ ស្រុកកោដិគាមនោះ តាំងនៅប្រហមាត់ស្ទឹងគង្គា អ្នកកោដិគាមបំពេញមហាទានថ្វាយភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។

ព្រះភទ្ទជិត្ថេរ កាលព្រះសាស្តាទ្រង់ធ្វើអនុមោទនា ក៏ចេញទៅក្រៅស្រុកអង្គុយចូលសមាបត្តិដោយគិតថា អញនិងចេញអំពីសមាបត្តិ ក្នុងកាលដែល

---

១-ក្នុងអបទានជាព្រះ ភិសទាយកត្ថេរ ។

ព្រះសាស្តាយាងមកក្បែរផ្លូវត្រង់ច្រាំងស្ទឹងគង្គា ។ កាលព្រះមហាថេរៈទាំង-ឡាយមកដល់ ក៏មិនទាន់ចេញអំពីសមាបត្តិ ក្នុងកាលដែលព្រះមុនីយាងមកហើយនោះឯង ទើបចេញពីសមាបត្តិ ភិក្ខុជាបុថុជ្ជនទាំងឡាយ នាំគ្នាពោលទោសថា ភទ្ទជិនេះ ទើបតែបួស កាលព្រះមហាថេរៈទាំងឡាយមកដល់ ក៏ជាអ្នករឹងត្អឹងដោយមានះ មិនព្រមចេញពីសមាបត្តិ ។ សម័យនោះពួកអ្នកកោដិគាមរៀបចំទូកជាច្រើនដើម្បីព្រះសាស្តានិងភិក្ខុសង្ឃ ព្រះសាស្តា ទ្រង់ព្រះតម្រិះថា ណ្ហើយចុះតថាគតនឹងប្រកាសអានុភាពរបស់ភទ្ទជិ ដូច្នេះហើយទ្រង់ឈរលើទូក ត្រាស់សួរថា ភទ្ទជិនៅឯណា ព្រះភទ្ទជិត្រេកទូលស្នងព្រះតម្រាស់ថា ខ្ញុំព្រះអង្គភទ្ទជិនៅទីនេះ ហើយចូលទៅគាល់ព្រះសាស្តា ផ្គងអញ្ជលីហើយឈរ ព្រះសាស្តាត្រាស់ថា មកភទ្ទជិចូរអ្នកឡើងទូកជាមួយតថាគត ព្រះភទ្ទជិក៏ហោះទៅឈរក្នុងទូកដែលព្រះសាស្តាទ្រង់ឈរ ក្នុងកាលទូកទៅដល់កណ្តាលស្ទឹងគង្គា ព្រះសាស្តាត្រាស់ថា ម្នាលភទ្ទជិរតនប្រាសាទដែលអ្នកធ្លាប់នៅក្នុងកាលជាព្រះរាជាព្រះនាមថា មហាបនាទៈ នៅឯណា ព្រះភទ្ទជិក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន លិចក្នុងទីនេះ ព្រះសាស្តាត្រាស់ថា ម្នាលភទ្ទជិបើដូច្នោះ ចូរអ្នកកាត់សេចក្តីសង្ស័យរបស់សព្រហ្មចារីទាំង-ឡាយ ។

ខណៈនោះ ព្រះថេរៈថ្វាយបង្គំព្រះសាស្តាហើយ ទៅដោយកម្លាំងឫទ្ធិថ្ងៀបកំពូលប្រាសាទ ដោយមេជើង លើកប្រាសាទដែលមានកម្ពស់ ២៥ យោជន៍ ហោះឡើងទៅលើអាកាស កាលនឹងហោះបានលើកប្រាសាទឡើង

ផុតអំពីទឹក ៥០ យោជន៍ ។ លំដាប់នោះ ញាតិទាំងឡាយក្នុងភពមុនរបស់ព្រះថេរៈកើតជាត្រី អណ្ដើកនិងកង្កែប ដោយជាប់ជំពាក់ក្នុងប្រាសាទ កាលប្រាសាទនោះលើកឡើង ក៏ធ្លាក់ទៅក្នុងទឹក ព្រះសាស្ដា ឃើញសត្វទាំងនោះធ្លាក់ទៅ ទើបត្រាស់ថា ម្នាលភទ្ទជិ ញាតិទាំងឡាយរបស់អ្នកលំបាក ព្រះថេរៈក៏លែងប្រាសាទ តាមព្រះតម្រាស់របស់ព្រះសាស្ដា ប្រាសាទក៏តាំងនៅក្នុងទីដើមនោះឯង ។ ព្រះសាស្ដាយាងដល់ត្រើយ កាលភិក្ខុទាំងឡាយ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ប្រាសាទនេះ ភទ្ទជិត្ថេរធ្លាប់នៅពីកាលណា ទើបព្រះសាស្ដាត្រាស់ មហាបនាទជាតក ញុំាងមហាជនឲ្យផឹកអម្រឹតគឺព្រះធម៌ ។ ព្រះថេរៈកាលសម្ដែងប្រាសាទនោះ ដែលខ្លួនធ្លាប់នៅអាស្រ័យហើយ បានព្យាករអរហត្តផល ដោយពណ៌នា ២ គាថាថា

ប្រាសាទមាស ខាងទទឹង មានសន្ទុះនៃសរ ១៦ ខាងកំពស់
មានសន្ទុះនៃសរ ១០០០ របស់ព្រះរាជាអង្គណា ព្រះរាជា
អង្គនោះ ទ្រង់ព្រះនាមថា បនាទៈ ។

ប្រាសាទនោះមានសន្ទុះនៃសរ ១០០០ មានជាន់ជាច្រើន
មានទង់ជ័យជាច្រើន សម្រេចដោយកែវមណីខៀវ អ្នករបាំក៏
បានរាំលើប្រាសាទនោះ អ្នករបាំ ៦០០០ នាក់ ( តែងរាំ )
ក្នុងជាន់ទាំង ៧ ។

បណ្ដាបទទាំងនោះ បទថា **បនាទោ នាម សោ រាជា** សេចក្ដីថា ព្រះថេរៈ សម្ដែងខ្លួនដូចអ្នកដទៃ ដោយអត្តភាពដែលនៅក្នុងជាតិបន្ទាប់ថា ក្នុង

អតីតកាល មានព្រះរាជាព្រះនាមថា បនាទៈ អធិប្បាយថា ព្រះរាជាអង្គនោះ ប្រាកដនាមថា មហាបនាទៈ ព្រោះមានរាជានុភាពច្រើននិងព្រោះជាអ្នកប្រកបទៅដោយកិត្តិសព្ទដ៏ល្បីល្បាញ ដោយន័យជាដើមថា ចាប់តាំងពីសោយរាជ្យទ្រង់មានសម្បត្តិ គឺព្រះឧស្សាហៈសព្វកាល ដូច្នេះ ។

បទថា **យស្ស យូបោ សុវណ្ណិយោ** សេចក្តីថា ប្រាសាទសម្រេចដោយមាសនេះ របស់ព្រះរាជាណា ។

បទថា **តិរិយំ សោឡសុព្វេធោ** សេចក្តីថា ទទឹងប្រមាណសម្ទុះសរដែលគេបាញ់ធ្លាក់ ១៦ ដង គឺប្រាសាទនោះទទឹងប្រមាណកន្លះយោជន៍ ។

បទថា **ឧច្ចមាហុ សហស្សធា** សេចក្តីថា ខាងលើ គឺកម្ពស់របស់ប្រាសាទនោះ ១០០០ ជាន់ គឺមានកម្ពស់ប្រមាណ ១០០០ សម្ទុះសរ គឺប្រាសាទនោះកម្ពស់ប្រមាណ ២៥ យោជន៍ ។ ក្នុងគាថានេះ អាចារ្យពួកខ្លះអធិប្បាយថា ដើម្បីងាយស្រួលក្នុងការចងគាថា ទើបធ្វើទីឃៈនៃពាក្យថា **អហុ** ឲ្យជា **អាហុ** សម្រេចរូបជា **អាហុ** ។

បទថា **សហស្សកណ្ឌោ** បានដល់ មានជាន់ ១០០០ ។

បទថា **សតភេណ្ឌុ** សេចក្តីថា មានបន្ទប់ច្រើនរយ ។ បទថា **ធជាលុ** បានដល់ សម្បូរដោយទង់ដែលជាប់ត្រង់ចុងបង្គោល និងទង់ផ្កាលាជាដើមដែលគេដោតត្រង់កំពូលជាដើមនោះៗ ។

បទថា **ហរិតាមយោ** សេចក្តីសម្រេចដោយមាសធម្មជាតិ តែអាចារ្យពួកខ្លះ ពោលថា ដូចគ្នានឹងកែវមណីពណ៌ខៀវខ្ចីដែលជាកែវធម្មជាតិ ។

បទថា **គន្ធព្វា** បានដល់ អ្នករបាំ ។ បទថា **ឆ សហស្សានិ សត្តធា** សេចក្ដីថា អ្នករបាំប្រមាណ ៦០០០ ចែកជា ៧ ក្រុម នាំគ្នារាំដើម្បីធ្វើនូវការអភិរម្យដល់ព្រះរាជាក្នុងទី ៧ កន្លែង ។

អ្នករបាំទាំងនោះ ទោះបីរាំយ៉ាងនេះ ក៏មិនអាចធ្វើព្រះរាជា ឲ្យត្រេកអរបានលំដាប់នោះ ទើបសក្កទេវរាជបញ្ជូនស្រីទេពអប្សរ ដែលជំនាញក្នុងការរាំឲ្យសម្ដែងមហោស្រព ក្នុងកាលនោះ ទើបព្រះរាជាទ្រង់សព្វព្រះទ័យ ដូច្នេះ ។

អដ្ឋកថា ភទ្ទជិត្ថេរគាថា ចប់

## សោភិតត្ថេរគាថា

[ ១៨៤ ] ខ្ញុំជាភិក្ខុមានស្មារតី មានបញ្ញា មានកម្លាំងព្យាយាមម៉ឺងម៉ាត់ បានរឭកឃើញអស់ ៥០០ កប្បដូចមួយរាត្រី ។ ខ្ញុំកាលចម្រើនសតិប្បដ្ឋាន ៤ ពោជ្ឈង្គ ៧ និងមគ្គ ៨ បានរឭកឃើញអស់ ៥០០ កប្ប ដូចមួយរាត្រី ។

*សោភិតត្ថេរ ។*

## អដ្ឋកថា
## សោភិតត្ថេរគាថា

[ ១៨៤ ] គាថារបស់ព្រះសោភិតត្ថេរ មានពាក្យផ្តើមថា **សតិមា បញ្ញវា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យក្នុងភពនោះៗ ។ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថា បទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរហង្សវតី ចម្រើនវ័យហើយស្តាប់ធម្មទេសនារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់តាំងភិក្ខុមួយរូប ទុកក្នុងតំណែងជាកំពូលលើសភិក្ខុទាំងឡាយខាងបុព្វេនិវាសញ្ញាណ ធ្វើសេចក្តីប្រាថ្នាតំណែងនោះ ហើយធ្វើនូវបុណ្យទាំងឡាយ អន្ទោលទៅក្នុងសុគតិភពប៉ុណ្ណោះ ។ ក្នុងសាសនានៃព្រះមានព្រះភាគ ព្រះនាមថាសុមេធ កុលបុត្តនេះកើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវភាពជាអ្នកដឹងក្តីហើយ ដល់នូវ

ការសម្រេចក្នុងចំណែកនៃវិជ្ជា និងសិប្បសាស្ត្រ របស់ព្រាហ្មណ៍ទាំងឡាយ មានចិត្តបង្អោនទៅក្នុងនេក្ខម្មៈ លះយកវាសវិស័យ បួសជាតាបស សាង អាស្រមត្រង់ជាយព្រៃ ក្បែរភ្នំហិមពាន្ត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយ មើមឈើនិងផ្លែឈើក្នុងព្រៃ បានដំណឹងនៃការកើតឡើងរបស់ព្រះពុទ្ធ ចូល ទៅគាល់ព្រះសាស្តាត្រង់ កទ្វវតីនគរ ដោយការស្នាក់នៅ ត្រឹមមួយរាត្រី ប៉ុណ្ណោះ ក៏មានចិត្តជ្រះថ្លា សរសើរព្រះសាស្តា ៦ គាថា មានគាថាថា **ត្វំ សត្ថា ច កេតុ ច** ប្រែថា ទ្រង់ជាសាស្តាផងដូចជាទង់ផង ជាដើម ដូច្នេះ ឯព្រះសាស្តាទ្រង់ក៏សរសើរតាបស ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំង-ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងព្រាហ្មណត្រកូល នានគរសាវត្ថី មនុស្ស ទាំងឡាយដាក់ឈ្មោះកុលបុត្តនោះថា សោភិតៈ ។ សម័យតមក កុលបុត្ត នោះ ស្តាប់ធម្មទេសនារបស់ព្រះសាស្តា បានទូវសទ្ធា បួសហើយចម្រើន វិបស្សនាបានសម្រេចអភិញ្ញា ៦ ជាអ្នកមានវសីពិសេស គឺថ្មីកក្នុងបុព្វេ-និវាសញ្ញាណ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

> អាស្រមរបស់ខ្ញុំ គេធ្វើហើយ ក្នុងទិសទក្សិណនៃហិមវន្តប្រ-
> ទេស ក្នុងកាលនោះ ខ្ញុំកំពុងស្វែងរកនូវប្រយោជន៍ដ៏ឧត្តមនៅ
> តែក្នុងព្រៃ ។ ខ្ញុំជាអ្នកសន្តោសដោយលាភនិងអលាភ ជាអ្នក
> ប្រព្រឹត្តមិនចិតសម្បកនៃមើមឈើនិងផ្លែឈើហើយនៅតែម្នាក់
> ឯង ។ ព្រះសម្ពុទ្ធព្រះនាមសុមេធៈ បានកើតក្នុងលោក ទ្រង់

ស្រោចស្រង់នូវមហាជន ហើយប្រកាសនូវសច្ចធម៌ទាំង ៤ ក្នុងខណៈនោះ ។ ខ្ញុំមិនដែលបានស្តាប់នូវព្រះសម្ពុទ្ធ ទាំងឥត មានអ្នកណាមួយប្រៀនប្រដៅខ្ញុំឡើយ លុះកន្លង ៨ ឆ្នាំទៅ ទើបខ្ញុំបានស្តាប់ព្រះលោកនាយក ។ ខ្ញុំបាននាំយកភ្លើង និង ឧសចេញហើយបោសច្រាសអាស្រម រួចបានវែកនូវអម្រែក ចេញទៅអំពីព្រៃធំ ។ ក្នុងកាលនោះ ខ្ញុំនៅក្នុងស្រុក និងនិគម អស់មួយរាត្រីៗ ហើយបានចូលទៅក្នុងក្រុង ឈ្មោះ ចន្ទវតី ដោយលំដាប់ ។ ក្នុងសម័យនោះ ព្រះមានព្រះភាគព្រះនាម សុមេធៈ ជាលោកនាយក ទ្រង់ស្រោចស្រង់នូវពពួកសត្វជា ច្រើនកំពុងសម្តែងនូវអមតបទ ។ ខ្ញុំកន្លងនូវពួកជន ហើយ ថ្វាយបង្គំនូវពាក្យប្រដៅ នៃព្រះជិនស្រី បានធ្វើនូវស្បែកខ្លា ធៀងស្មាម្ខាង ហើយពោលសរសើរគុណនៃព្រះលោកនាយក ថា

ព្រះអង្គជាសាស្តាដូចជាទង់ ដូចជាទង់ជ័យ ឬដូចប្រាសាទ ជាទីពឹងពំនាក់របស់ពួកសត្វ ជាប្រទីប ទ្រង់ឧត្តមជាងសត្វ ជើងពីរ ។ បពិត្រព្រះមុនី ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់មានព្រះ ប្រាជ្ញាដ៏ល្អិតក្នុងទស្សនញ្ញាណ ទ្រង់ញ៉ាំងពួកជនឲ្យឆ្លងនឹងរក បុគ្គលដទៃជាអ្នកចម្លងឲ្យលើសលុបជាងព្រះអង្គ ក្នុងលោក មិនមានឡើយ ។ សមុទ្រសាគរដ៏ឧត្តម បុគ្គលអាចនឹងប្រ-

មាណដោយចុងសក្សួរបាន ឯសព្វញ្ញុតញ្ញាណ របស់ព្រះអង្គ បុគ្គលមិនអាចប្រមាណបានឡើយ ។ ផែនដីបុគ្គលអាចដាក់លើជន្លជញ្ជីងដើម្បីថ្លឹងបាន បពិត្រព្រះអង្គមានចក្ខុ ( វត្ថុដទៃ ) ស្មើដោយបញ្ញារបស់ព្រះអង្គ មិនមានឡើយ ។ អាកាសគេអាចវាស់ដោយខ្សែ ឬដោយអង្គុលីបាន បពិត្រព្រះសព្វញ្ញូ សីលរបស់ព្រះអង្គ បុគ្គលមិនអាចប្រមាណបានឡើយ ។ បពិត្រព្រះអង្គមានចក្ខុ ទឹកក្នុងមហាសមុទ្រក្តី អាកាសក្តី ផែនដីក្តី របស់ទាំងអម្បាលនេះ បុគ្គលអាចប្រមាណបាន ឯព្រះអង្គឥតមានបុគ្គលប្រមាណបានឡើយ ។

គ្រានោះ ខ្ញុំបានសរសើរនូវព្រះសព្វញ្ញូមានយសធំ ដោយព្រះគាថាទាំងឡាយ ៦ ហើយឈរផ្គងនូវអញ្ជលីនៅស្ងៀម ។ ជនទាំងឡាយតែងហៅនូវព្រះមានព្រះភាគអង្គណា ដែលមានព្រះបញ្ញាដូចផែនដី ទ្រង់ទម្លាយបង់នូវកិលេសថា សុមេធៈ ព្រះមានព្រះភាគអង្គនោះ ទ្រង់គង់នៅក្នុងកណ្តាលភិក្ខុសង្ឃ ហើយត្រាស់នូវព្រះគាថាទាំងឡាយនេះថា

បុគ្គលណា បានសរសើរញាណរបស់តថាគត ដោយចិត្តជ្រះថ្លា តថាគតនឹងសរសើរនូវបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់ពាក្យតថាគតសម្តែងចុះ ។ បុគ្គលនោះនឹងត្រេកអរក្នុងទេវលោកអស់ ៧៧ កប្ប នឹងបានជាធំជាងទេវតា សោយ

រាជ្យជាស្តេចនៃទេវតាអស់មួយពាន់ដង ។ នឹងបានជាស្តេចចក្រពត្តិច្រើនរយជាតិ នឹងបានគ្រប់គ្រងប្រទេសរាជ្យ ដ៏ធំទូលាយ នឹងគណនារាប់មិនបាន ។ បើកើតជាទេវតា ឬជាមនុស្សនឹងជាអ្នកប្រកបដោយបុញ្ញកម្ម មានសេចក្តីត្រិះរិះមិនឱនថយទាំងមានប្រាជ្ញាមោះមុត ។ កន្លងទៅ ៣០.០០០ កប្បព្រះសាស្តាព្រះនាម គោតម កើតក្នុងត្រកូលនៃស្តេចឱក្កាកៈត្រាស់ឡើងក្នុងលោក ។ ( កុលបុត្តនេះ ) ជាអ្នកមិនមានកង្វល់ចេញចាកផ្ទះហើយបួស នឹងបានសម្រេច ព្រះអរហត្តក្នុងអាយុ ៧ ឆ្នាំ រាប់អំពីឆ្នាំកំណើតមក ។

ខ្ញុំរឭកឃើញនូវខ្លួនដោយហេតុណា ខ្ញុំបានដល់នូវសាសនាដោយហេតុណា ក្នុងចន្លោះនេះ ខ្ញុំមិនធ្លាប់ដឹងនូវចេតនាដែលមិនជាទីត្រេកអរនៃចិត្តទេ ។ ខ្ញុំអន្ទោលទៅមកក្នុងភពតូចភពធំហើយតែងទទួលនូវសម្បត្តិ ឯសេចក្តីខ្វះខាតភោគៈរបស់ខ្ញុំឥតមានឡើយ នេះជាផលក្នុងការសរសើរនូវព្រះញាណ ។ ភ្លើង ៣ ប្រការរបស់ខ្ញុំរលត់ហើយ ភពទាំងពួង ខ្ញុំបានដកចោលចេញហើយ ខ្ញុំមានអាសវៈទាំងពួងអស់ហើយ ឥឡូវនេះភពថ្មីមិនមានទៀតឡើយ ក្នុងកប្បទី ៣០.០០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានសរសើរនូវព្រះញាណ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលក្នុងការសរសើរនូវ

ព្រះញាណ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។
ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ(១) ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលរឭកដល់បុព្វេនិវាសញ្ញាណរបស់ខ្លួនដោយលំដាប់ បានឃើញដល់អចិត្តកបដិសន្ធិ ក្នុងអសញ្ញភព បន្ទាប់អំពីនោះ ក៏មិនឃើញចិត្តប្បវត្តិអស់ ៥០០ កប្ប ឃើញតែក្នុងជាតិចុងក្រោយប៉ុណ្ណោះ កាលពិចារណាថា ៥០០ កប្បនេះ អាត្មាអញជាអ្វីទើបដឹងដោយអំណាចន័យថា ជាអសញ្ញភព សមដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវតាមានអាយុវែងឈ្មោះអសញ្ញសត្វមាន សោភិតៈ ចុតិអំពីអសញ្ញភពនោះហើយ មកកើតក្នុងភពនេះ លោករមែងដឹងភពនោះសោភិតៈរមែងរឭកបាន ព្រះសាស្ដា ទ្រង់ឃើញភាពឈ្លាស ក្នុងការរឭកជាតិរបស់ព្រះថេរៈដោយអំណាចរបស់ន័យយ៉ាងនេះ ទើបទ្រង់ស្ថាបនាព្រះថេរៈក្នុងតំណែងឯតទគ្គៈរបស់ភិក្ខុដែលរឭកបុព្វេនិវាសញ្ញាណ ។ បន្ទាប់អំពីនោះមក ព្រះសោភិតៈនេះ ពិចារណាបុព្វេនិវាសានុស្សតិញ្ញាណរបស់ខ្លួន មួយអន្លើដោយគុណវិសេស និងបដិបទាដែលជាបច្ច័យ នៃបុព្វេនិវាសានុស្សតិញ្ញាណនោះហើយកើតសោមនស្ស កាលនឹងបន្លឺឧទាន សម្ដែងដល់ហេតុទាំង ២ នោះ បានពោលគាថា ២ ថា

ខ្ញុំជាភិក្ខុមានស្មារតី មានបញ្ញា មានកម្លាំងព្យាយាមមុឹងម៉ាត់
បានរឭកឃើញអស់ ៥០០ កប្បដូចមួយរាត្រី ។ ខ្ញុំកាល

---

១ ក្នុងអបទានជាព្រះ ញាណត្ថវិកត្ថេរ ។

ចម្រើនសតិប្បដ្ឋាន ៤ ពោជ្ឈង្គ ៧ និងមគ្គ ៨ បានរឭក
ឃើញអស់ ៥០០ កប្បដូចមួយរាត្រី ។

បណ្ដាបទទាំងនោះ បទថា **សតិមា** សេចក្ដីថា ឈ្មោះថា ជាអ្នកមាន សតិ ព្រោះបរិបូណ៌ដោយសតិប្បដ្ឋានភាវនា និងព្រោះដល់នូវភាពបរិបូណ៌ នៃសតិ ដែលប្រមូលមក កើតឡើងព្រមគ្នា ។ បទថា **បញ្ញវា** សេចក្ដីថា ឈ្មោះថា **បញ្ញវា** ព្រោះសម្បូរដោយអភិញ្ញា ៦ និងព្រោះដល់នូវភាព បរិបូណ៌ដោយបញ្ញា ។ ឈ្មោះថា **ភិក្ខុ** ព្រោះទម្លាយកិលេសបានហើយ ។ ភិក្ខុឈ្មោះថា **អារទ្ធពលវីរិយោ** ព្រោះមានពល ៥ មានសទ្ធាជាដើម និង មានសេចក្ដីព្យាយាម គឺសម្មប្បធាន ៤ យ៉ាង សម្រេចបរិបូណ៌ហើយ អ- ធិប្បាយថា ក្នុងទីនេះ មានការកាន់យកសទ្ធាជាដើមដោយ **ពល** សព្ទ រមែង កាន់យកធម៌ទាំងឡាយមានសតិជាដើមផងដែរ ព្រោះភាពជាពលៈ ដូចក្នុង ប្រយោគថា **គោពលិពទ្ទា បុញ្ញញាណសម្ភារា** ប្រែថា គោបម្រើ ជាអង្គ នៃបុណ្យនិងបញ្ញាជាដើម ។

បទថា **បញ្ច កប្បសតានាហំ ឯករត្តឹ អនុស្សរឹ** សេចក្ដីថា រឭក ជាតិមុនបាន ៥០០ កប្ប ដូចមួយរាត្រី លោកលុប **វិយ** ចេញ ។ ព្រះ ថេរៈសម្ដែងថាខ្លួនជាអ្នកជំនាញដោយបុព្វេនិវាសញ្ញាណដោយសេចក្ដីនេះ ។

ឥឡូវនេះ ដើម្បីនឹងសម្ដែងបដិបទាដែលជាហេតុនៃភាពជាអ្នកមានសតិ ជាដើមរបស់ខ្លួន និងជាហេតុឲ្យសម្រេចបុព្វេនិវាសញ្ញាណដ៏កំពូលនោះ ទើប ព្រះថេរៈពោលគាថាទី ២ ដោយពាក្យថា **ចត្តារោ** ដូច្នេះជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ២ ដូចតទៅនេះថា បទថា **ចត្តារោ សតិប្បដ្ឋានេ** បានដល់ សតិប្បដ្ឋាន ពោលគឺសតិដែលលាយដោយលោកិយនិងលោកុត្តរមាន ៤ យ៉ាង ដែលផ្សេងគ្នាដោយអារម្មណ៍ មានកាយានុបស្សនាជាដើម ។ បទថា **សត្ត** បានដល់ ពោជ្ឈង្គ ៧ ។ បទថា **អដ្ឋ** បានដល់ មគ្គមានអង្គ ៨ ។

អធិប្បាយថា ពោជ្ឈង្គ ៧ របស់ព្រះអរិយបុគ្គលដែលមានចិត្តតាំងមាំល្អហើយ ក្នុងសតិប្បដ្ឋានទាំងឡាយ រមែងដល់នូវការបរិបូណ៌ដោយការនាពិតប្រាកដ ។ មគ្គដែលប្រកបដោយអង្គ ៨ ដ៏ប្រសើរក៏ដូចគ្នា ។

សមដូចព្រះធម្មសេនាបតីសារីបុត្តពោលថា ក្នុងបណ្តាពោធិបក្ខិយធម៌ ៣៧ ប្រការដែលប្រកបដោយកោដ្ឋាស ៧ កាលកោដ្ឋាស ១ ដល់នូវភាពសម្បូរនៃការនា ឈ្មោះថា កោដ្ឋាសក្រៅអំពីនេះនឹងមិនដល់នូវភាពបរិបូណ៌ដោយការនាមិនមាន ព្រោះព្រះបាលី ( ក្នុងទីឃនិកាយបាដិកវគ្គ ) ថា មានព្រះហឫទ័យតាំងខ្ជាប់ល្អ ក្នុងសតិប្បដ្ឋានទាំង ៤ បានចម្រើននូវសម្ពោជ្ឈង្គទាំង ៧ តាមគួរដល់សេចក្តីពិត ដូច្នេះជាដើម ។ បទថា **ភាវយំ** បានដល់ មានការចម្រើនជាហេតុ ។ បទដ៏សេសមានន័យដូចពោលហើយនោះឯង ។

## អដ្ឋកថា សោភិតត្ថេរគាថា ចប់

# វល្លិយត្ថេរគាថា

[ ១៤៥ ] អំពើណាដែលបុគ្គលគួរធ្វើ ដោយព្យាយាមដ៏មាំ អំពើណាដែលបុគ្គលប្រាថ្នាដើម្បីត្រាស់ដឹង គប្បីធ្វើ ខ្ញុំនឹងធ្វើអំពើនោះៗ មិនទៀយណាយទេ អ្នកចូរមើលសេចក្តីព្យាយាម សេចក្តីប្រឹងប្រែងចុះ អ្នកចូរប្រាប់ផ្លូវដែលជាផ្លូវឈមទៅកាន់ព្រះនិព្វាន ឈ្មោះអមតៈដល់ខ្ញុំ ខ្ញុំនឹងដឹងបានដោយញាណជាគ្រឿងដឹងដូចខ្សែទឹកទន្លេគង្គា ( មិនទៀយណាយ ) នឹងសាគរ ។

វល្លិយត្ថេរ ។

## អដ្ឋកថា

## វល្លិយត្ថេរគាថា

[ ១៤៥ ] គាថារបស់ព្រះវល្លិយត្ថេរ មានពាក្យផ្តើមថា **យំ កិច្ចំ ទឡ្ហវីរិយេន** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយទុកក្នុងភពនោះៗ ។ ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមថាសុមេធ កើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវភាពជាអ្នកដឹងក្តីហើយ សម្រេចក្នុងវិជ្ជានិងសិប្បសាស្ត្រ លះសម្បត្តិ ៨០ កោដិ បួសជាតាបសសាងអាស្រមត្រង់ឆ្នេរស្ទឹងមួយក្នុងព្រៃក្បែរជើងភ្នំ ហើយនៅ ។ ព្រះសាស្តា កាលអនុគ្រោះ ទ្រង់ក៏ចូលទៅ កុលបុត្រនោះ ឃើញព្រះសាស្តាមានចិត្តជ្រះថ្លា លាតកម្រាលស្បែកខ្លាថ្វាយ បូជាព្រះសាស្តា ព្រះមានព្រះភាគ

ទ្រង់គង់លើស្បែកខ្លានោះ ដោយផ្កានិងខ្លឹមចន្ទន៍ ថ្វាយផ្លែស្វាយ ហើយថ្វាយបន្តំដោយបញ្ចង្គប្រតិស្ឋាន ។ ព្រះមានព្រះភាគ កាលទ្រង់ប្រកាសសម្បត្តិដែលគប្បីបាន ព្រោះថ្វាយអាសនៈដែលប្រថាប់គង់ ទ្រង់អនុមោទនាដល់តាបស ហើយចៀសចេញទៅ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ នានគរវេសាលី មានឈ្មោះថា កណ្ហមិត្ត ចម្រើនវ័យហើយ ឃើញពុទ្ធានុភាពក្នុងកាលដែលព្រះសាស្តាយាងទៅកាន់នគរវេសាលី បាននូវសទ្ធា បួសក្នុងសម្នាក់របស់ព្រះមហាកច្ចានត្ថេរ ។ ព្រះថេរៈជាអ្នកមានបញ្ញាទន់ និងធូរថយក្នុងសេចក្តីព្យាយាម អាស្រ័យសព្រហ្មចារីដែលចេះដឹងសព្វកាល អស់កាលយូរ ។

ភិក្ខុទាំងឡាយ ក៏ហៅលោកតាមលក្ខណនិស្ស័យថា វល្លិយៈ នោះឯងព្រោះលោកបើមិនអាស្រ័យភិក្ខុដែលជាបណ្ឌិតណាមួយ មិនអាចចម្រើនលូតលាស់បាន ដូចវល្លិបើមិនអាស្រ័យព្រឹក្សាទាំងឡាយ មានដើមឈើជាដើម ក៏មិនអាចចម្រើនលូតលាស់បាន ដូច្នោះ ។ តែក្នុងកាលតមក លោកចូលទៅរកព្រះវេណុទត្តត្ថេរ តាំងនៅក្នុងឱវាទរបស់ព្រះថេរៈហើយ ជាអ្នកមានសតិសម្បជញ្ញៈ កាលសួរព្រះថេរៈដល់លំដាប់នៃបដិបទាព្រោះញាណចាស់ក្លា ទើបពោលគាថា ២ ថា

អំពើណា ដែលបុគ្គលគួរធ្វើដោយព្យាយាមដ៏មាំ អំពើណា ដែលបុគ្គលប្រាថ្នាដើម្បីត្រាស់ដឹងគប្បីធ្វើ ខ្ញុំនឹងធ្វើអំពើនោះៗ

មិនទៀយណាយទេ អ្នកចូរមើលសេចក្តីព្យាយាមសេចក្តីប្រឹង
ប្រែងចុះ ។ អ្នកចូរប្រាប់ផ្លូវដែលជាផ្លូវឈមទៅកាន់ព្រះនិព្វាន
ឈ្មោះអមតៈដល់ខ្ញុំ ខ្ញុំនឹងដឹងបានដោយញាណ ជាគ្រឿងដឹង
ដូចខ្សែទឹកទន្លេគង្គា ( មិនទៀយណាយ ) នឹងសាគរ ។

បណ្តាបទទាំងនោះ បទថា **យំ កិច្ចំ ទឡ្ហវីរិយេន** សេចក្តីថា វត្តណា ដែលបុគ្គលអ្នកមានសេចក្តីព្យាយាម គឺមានការខ្មីឃ្មាតគប្បីធ្វើ បានដល់ កិច្ចណាដែលបុគ្គលគប្បីធ្វើ គឺគប្បីបដិបត្តិដោយសេចក្តីព្យាយាម ឬដោយការយកចិត្តទុកដាក់ក្នុងធុរៈរបស់បុរស ។

បទថា **យំ កិច្ចំ ពោទ្ធុមិច្ឆតា** សេចក្តីថា កិច្ចណាដែលបុគ្គលអ្នកប្រាថ្នាដើម្បីដឹង គឺប្រាថ្នានឹងចាក់ធ្លុះនូវអរិយសច្ច ៤ ឬព្រះនិព្វាននោះឯង គប្បីធ្វើ ។

បទថា **ករិស្សំ នាវរជ្ឈិស្សំ** សេចក្តីថា ឥឡូវនេះ ខ្ញុំនឹងធ្វើកិច្ចនោះៗ មិនឲ្យខុសភ្លាំងភ្លាត់ គឺនឹងបដិបត្តិតាមពាក្យប្រៀនប្រដៅ ។

បទថា **បស្ស វីរិយំ បរក្កមំ** សេចក្តីថា ព្រះថេរៈសម្តែងភាពជាអ្នកប្រាថ្នាដើម្បីធ្វើរបស់ខ្លួន ដោយពាក្យថា អ្នកចូរមើលសេចក្តីព្យាយាមប្រពៃ ដែលបានឈ្មោះថា **វីរិយ** ព្រោះធ្វើត្រឹមត្រូវតាមវិធីក្នុងធម៌ តាមដែលបដិបត្តិ នឹងបានឈ្មោះថា **បរក្កម** ព្រោះឈានទៅខាងមុខ មិនមែនត្រឹមតែសទ្ធាប៉ុណ្ណោះឡើយ ។

ព្រះថេរៈហៅព្រះវេណុទត្តត្ថេរ អ្នកឲ្យកម្មដ្ឋាន ដែលជាកល្យាណមិត្តថា

**ត្វំ** ដូច្នេះ ។ បទថា **មេ** បានដល់ **មយ្ហំ** ប្រែថា ដល់ខ្ញុំ ។ បទថា **មគ្គ-មក្ខាហិ** បានដល់ សូមលោកប្រាប់អរិយមគ្គ អធិប្បាយថា ចូរប្រាប់កម្មដ្ឋានគឺសច្ចៈ ៤ ដែលញ៉ាំងលោកុត្តរមគ្គឲ្យដល់ព្រម ។

បទថា **អញ្ជសំ** បានដល់ ផ្លូវត្រង់ ព្រោះមិនចូលទៅជិតអន្តធម៌ ២ យ៉ាងដោយជាផ្លូវជាកណ្តាល ។ ឈ្មោះថា **អមតោគធំ** ព្រោះភាពដែលខ្ញុំ តាំងមាំហើយដោយញ៉ាំងចិត្តឲ្យដល់អមតនិព្វាន ។

បទថា **មោនេន** បានដល់ ដោយញាណ គឺមគ្គបញ្ញា ។ បទថា **មោ-និស្សំ** សេចក្តីថា នឹងដឹង គឺនឹងចាក់ធ្លុះ បានដល់ នឹងសម្រេចព្រះនិព្វាន ។

បទថា **គង្គាសោតោវ សាគរំ** សេចក្តីថា ខ្សែនៃស្ទឹងគង្គា មិនឃើយណាយក្នុងការហូរទៅកាន់សាគរ គឺសមុទ្រដោយចំណែកមួយយ៉ាងណា ព្រះវល្លិយត្ថេរក៏យ៉ាងនោះ សូមកម្មដ្ឋានព្រះថេរៈថា ខ្ញុំប្រកបរឿយៗនូវកម្មដ្ឋាននឹងសម្រេចដល់ព្រះនិព្វាន ដោយមគ្គញាណ ព្រោះហេតុនោះ សូមលោកប្រាប់កម្មដ្ឋាននោះដល់ខ្ញុំ ។

ព្រះវេណុទត្តត្ថេរ ស្តាប់ពាក្យនោះហើយ បានឲ្យកម្មដ្ឋានដល់ព្រះវល្លិយត្ថេរ ចំណែកព្រះវល្លិយត្ថេរ ប្រកបព្យាយាមរឿយៗនូវកម្មដ្ឋាន ខ្វល់ខ្វាយនូវវិបស្សនា សម្រេចអរហត្តក្នុងកាលមិនយូរឡើយ ។ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំលះបង់នូវកាមគុណទាំង ៥ ដែលមានសភាពជាទីស្រឡាញ់
ជាទីរីករាយនៃចិត្ត លះបង់នូវសម្បត្តិ ៨០ កោដិ ហើយចូល

ទៅកាន់ផ្ទះ ។ លុះខ្ញុំបួសហើយ បានវៀរនូវបាបកម្មដោយកាយ លះបង់នូវវចីទុច្ចរិត ហើយនៅជិតប្រាំងស្ទឹង ។ ព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ស្តេចបានចូលមករកខ្ញុំ ដែលកំពុងនៅតែម្នាក់ឯង ខ្ញុំក៏មិនស្គាល់ព្រះអង្គថាជាព្រះពុទ្ធទេ តែខ្ញុំបានធ្វើបដិសណ្ឋារៈ ។ លុះខ្ញុំធ្វើបដិសណ្ឋារៈហើយ បានសួរនូវនាមនិងគោត្តថា អ្នកជាទេវតាឬជាគន្ធព្វ ឬមួយអ្នកជាព្រះឥន្ទធ្លាប់ឲ្យទានក្នុងកាលមុន អ្នកជាអ្វី អ្នកជាបុត្តរបស់បុគ្គលណា ឬអ្នកជាមហាព្រហ្ម មកក្នុងទីនេះ បានញុំាំងទិសទាំងពួង ឲ្យភ្លឺប្រាលដូចព្រះអាទិត្យកំពុងរះ ។ ម្នាលអ្នកនិទ្ទុក្ខ ចក្រទាំងឡាយមានកាំមួយពាន់ ប្រាកដក្នុងបាទា ( នៃអ្នក ) អ្នកជាអ្វីអ្នកជាបុត្តរបស់បុគ្គលណាដូចម្តេចហ្ន៎យើងនឹងស្គាល់អ្នក ។ សូមអ្នកប្រាប់នូវនាមនិងគោត្រ ( របស់អ្នក ) ចូរអ្នកនាំនូវសេចក្តីសង្ស័យរបស់ខ្ញុំចេញ ។

តថាគតមិនមែនជាទេវតា មិនមែនជាគន្ធព្វ តថាគតមិនមែនជាព្រះឥន្ទធ្លាប់ឲ្យទានក្នុងកាលមុនទេ ។ មួយទៀត តថាគត មិនមែនជាព្រហ្មទេ តថាគតប្រសើរជាងជនទាំងនោះ បានកន្លងនូវវិស័យរបស់ជនទាំងនោះ ហើយផ្តាច់បង់នូវចំណង គឺកាម ។ តថាគតដុតបង់នូវកិលេសទាំងអស់ហើយ បានដល់នូវសេចក្តីត្រាស់ដឹងដ៏ប្រសើរ ។

ខ្ញុំបានស្តាប់នូវវាចា របស់ព្រះពុទ្ធនោះ ហើយពោលនូវពាក្យនេះថា បពិត្រព្រះមហាមុនី បើព្រះអង្គជាសព្វញ្ញុពុទ្ធជាមហាមុនី សូមព្រះអង្គគង់សិន ខ្ញុំនឹងបូជាព្រះអង្គ ព្រោះព្រះអង្គ ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខបានហើយ ។ ខ្ញុំបានក្រាលនូវស្បែកខ្លាថ្វាយព្រះសាស្តា ព្រះមានព្រះភាគទ្រង់គង់លើស្បែកខ្លានោះ ដូចជាសត្វសីហៈដែលឋិតនៅលើញកនៃភ្នំ ។ ខ្ញុំបានឡើងភ្នំជាប្រញាប់ ហើយបេះយកផ្លែស្វាយ ផ្កាក្លៅនាង និងខ្លឹមចន្ទន៍ដ៏មានតម្លៃច្រើន ខ្ញុំបានលើកផ្គងនូវរបស់ទាំងអស់នុ៎ះជាប្រញាប់ បង្អោនចូលទៅរកព្រះលោកនាយក ខ្ញុំបានថ្វាយផ្លែឈើ បានបូជាផ្កាក្លៅនាង ដល់ព្រះពុទ្ធ ។ ខ្ញុំលាបនូវខ្លឹមចន្ទន៍ ហើយបានថ្វាយបង្គំព្រះសាស្តា ខ្ញុំមានចិត្តជ្រះថ្លា រីករាយដោយបីតិដ៏ធំទូលាយ ។ ក្នុងកាលនោះ ព្រះសុមេធៈជាលោកនាយក ដែលកំពុងគង់លើស្បែកខ្លា ទ្រង់ញុំាងខ្ញុំឲ្យរីករាយ ហើយទ្រង់សម្តែងនូវកុសលកម្មរបស់ខ្ញុំថា

ក្នុងកប្បទី ២.៥០០ បុគ្គលនេះ នឹងត្រេកអរក្នុងទេវលោក ដោយហេតុទាំងពីរយ៉ាង គឺ ដោយការឲ្យនូវផ្លែឈើនេះផង ដោយការឲ្យគ្រឿងក្រអូប និងកម្រងផ្កានេះផង ។ បុគ្គលនេះនឹងមានសេចក្តីត្រិះរិះមិនខុនថយ ប្រព្រឹត្តទៅក្នុងអំណាចនៃខ្លួន ក្នុងកប្បទី ២.៦០០ បុគ្គលនេះនឹងដល់នូវភាពជាមនុស្ស ។

នឹងបានជាស្តេចចក្រពត្តិ មានសមុទ្រទាំង ៤ ជាព្រំប្រទល់ ទាំងមានឫទ្ធិធំ ឯទីក្រុងឈ្មោះវេភារៈ ជាក្រុងដែលវិស្សុកម្ម ទេវបុត្តនិម្មិតថ្វាយ ។ ទីក្រុងឈ្មោះវេភារៈនោះ ជាមាសទាំងអស់ ស្អិតស្អាងដោយរតនៈផ្សេងៗ បុគ្គលនេះនឹងអន្ទោលទៅកាន់កំណើតទាំងឡាយដោយឧបាយនេះឯង ។ បុគ្គលនេះនឹងមានសេចក្តីសុខក្នុងទីទាំងពួង គឺជាក្នុងទេវតា ឬក្នុងមនុស្សលោក លុះដល់បច្ឆិមភពនឹងបានជាព្រហ្មពន្ធុ ( ផៅពង្សនៃបុគ្គលដ៏ប្រសើរ ) ។ បុគ្គលនេះនឹងចេញចាកផ្ទះ ទៅជាអ្នកបួសជាបុគ្គលដល់នូវត្រៃវិជ្ជានៃអភិញ្ញា មិនមានអាសវៈ ហើយបរិនិព្វាន ។

ព្រះសម្ពុទ្ធព្រះនាមសុមេធៈជាលោកនាយក លុះទ្រង់ត្រាស់នូវកម្មរបស់ខ្ញុំនេះហើយ កាលខ្ញុំកំពុងតែសម្លឹងមើល ព្រះអង្គទ្រង់ស្តេចជៀសចេញទៅ តាមផ្លូវអាកាស ។ ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ចូលទៅកើតក្នុងភពតុសិតដោយកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ។ លុះខ្ញុំច្យុតអំពីឋានតុសិត បានមកកើតក្នុងផ្ទៃនៃមាតា ខ្ញុំមិនខ្វះខាតភោគៈ ខ្ញុំនៅក្នុងគភ៌នៃមាតាណា កាលខ្ញុំនៅក្នុងគភ៌មាតានោះបាយក្តី ទឹកក្តី ភោជនក្តី តែងកើតឡើងសម្រាប់មាតា តាមសេចក្តីប្រាថ្នារបស់ខ្ញុំ ។ ខ្ញុំមានអាយុ ៥ ឆ្នាំ រាប់

អំពីឆ្នាំកំណើតមក បានចូលទៅកាន់ផ្នួស កាលដែលគេកំពុង
តែកោរសក់ ខ្ញុំក៏បានសម្រេចព្រះអរហត្ត ។ ខ្ញុំកាលស្វែងរក
នូវបុព្វកម្ម ( របស់ខ្ញុំ ) ក៏មិនបានឃើញបុព្វកម្ម ខាងអាយ
តែបាននឹកឃើញនូវបុព្វកម្មរបស់ខ្ញុំ ក្នុងកប្បទី ៣០.០០០ ។
បពិត្របុរសអាជានេយ្យ ខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្របុរស
ដ៏ឧត្តម ខ្ញុំសូមថ្វាយបង្គំព្រះអង្គ ខ្ញុំបានអាស្រ័យនូវសាសនា
របស់ព្រះអង្គហើយ ទើបដល់នូវអចលបទ គឺព្រះនិព្វាន ។
ក្នុងកប្បទី ៣០.០០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជា
ព្រះសម្ពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល
នៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។
ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលព្យាករអរហត្តផលទើបពោល
បានពោលគាថានេះទុក ដោយប្រការដូច្នេះ ។

## អដ្ឋកថា វល្លិយត្ថេរគាថា ចប់

---

១- ក្នុងអបទានជាព្រះ ចន្ទនមាលិយត្ថេរ ។

# វីតសោកត្ថេរគាថា

[ ១៨៦ ] កាលកប្បកបុរសចូលមក ខ្ញុំនិយាយថា ខ្ញុំនឹងកោរសក់របស់ខ្ញុំ ( លំដាប់នោះ ) ខ្ញុំទាញយកកញ្ចក់អំពីដៃកប្បកបុរសនោះ ហើយឆ្លុះមើលសរីរៈ ។ រាងកាយប្រាកដជារបស់ទទេ ងងឹតក្នុងទីងងឹត គឺ អវិជ្ជាក៏ប្រាសចេញហើយ កិលេសដូចជាកំណាត់សំពត់ទាំងអស់ ខ្ញុំបានផ្តាច់ចោលអស់ហើយ ឥឡូវនេះភពថ្មីមិនមានទេ ។

វីតសោកត្ថេរ ។

## អដ្ឋកថា

## វីតសោកត្ថេរគាថា

[ ១៨៦ ] គាថារបស់ព្រះវីតសោកត្ថេរ មានពាក្យផ្តើមថា **កេសេ មេ ឱលិខិស្សន្តិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យជាច្រើនទុកក្នុងភពនោះៗ ។ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាសិទ្ធត្ថ កុលបុត្តនេះកើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវភាពជាអ្នកសម្រេចក្នុងវិជ្ជា និងសិប្បៈរបស់ព្រាហ្មណ៍ ហើយលះកាមទាំងឡាយ បួសជាឥសីមានពួកឥសីជាច្រើនចោមរោមជាបរិវារនៅក្នុងព្រៃ ស្តាប់ដំណឹងនៃការកើតឡើងរបស់ព្រះពុទ្ធ ត្រេកអរហើយត្រិះរិះថា ព្រះមានព្រះភាគទាំងឡាយ ឃើញបានដោយកម្រ ឧបមាដូចផ្កាល្វា អញគួរចូលគាល់

ក្នុងកាលឥឡូវនេះឯង ដូច្នេះហើយ ធ្វើដំណើរទៅគាល់ព្រះសាស្ដា មួយអន្លើដោយមហាបរិស័ទ កាលនៅសល់ផ្លូវមួយយោជន៍កន្លះទៀតនឹងដល់ ក៏មានជំងឺស្លាប់ ដោយផ្ដោតចិត្តក្នុងព្រះពុទ្ធ ក៏បដិសន្ធិក្នុងទេវលោក ។ កុលបុត្តនោះ អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះកើតជាប្អូនប្រុសរបស់ព្រះបាទធម្មាសោករាជក្នុងទីបំផុតនៃពុទ្ធសករាជ ២១៨ មាននាមថាវីតសោក ។

វីតសោករាជកុមារ ចម្រើនវ័យហើយ ដល់នូវការសម្រេចក្នុងវិជ្ជា និងសិប្បៈទាំងឡាយដែលខត្តិយកុមារគប្បីសិក្សា ជាអ្នកជំនាញក្នុងសុត្តន្តបិដក និងអភិធម្មបិដក ទាំងនៅជាគ្រហស្ថដោយអាស្រ័យព្រះគិរិទត្តត្ថេរ ។ ថ្ងៃមួយក្នុងវេលាដាក់ព្រះមស្សុ ទទួលកញ្ចក់អំពីដៃរបស់ជាងកោរកាត់ សម្លឹងមើលព្រះវរកាយ ឃើញអវយវៈមានស្បែក ជ្រីវជ្រួញនិងសក់ស្កូវជាដើម មានព្រះទ័យសង្វេគ ញុំាងចិត្តឲ្យឈមចុះក្នុងវិបស្សនា ហើយចម្រើនភាវនា បានជាព្រះសោតាបន្ន លើអាសនៈនោះឯង បួសក្នុងសម្នាក់របស់ព្រះគិរិទត្តត្ថេរ ហើយសម្រេចអរហត្ត ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

> ខ្ញុំជាអ្នកស្វាធ្យាយមន្ត ចេះចាំនូវមន្ត ដល់នូវត្រើយនៃត្រៃវេទ
> ក្នុងលក្ខណសាស្ត្រ និងឥតិហាសសាស្ត្រ ព្រមទាំងនិឃណ្ឌុ-
> សាស្ត្រ និងកេដុភសាស្ត្រ ។ ក្នុងកាលនោះ ពួកសិស្សរបស់
> ខ្ញុំមកកាន់ ( សម្នាក់ ) នៃខ្ញុំ ប្រៀបដូចជាខ្សែទឹកស្ទឹង ខ្ញុំក៏

បានបង្ហាញមន្តដល់សិស្សទាំងនោះ ឥតមានខ្ជិលច្រអូសទាំងយប់ទាំងថ្ងៃ ។ លំដាប់នោះឯង ព្រះសម្ពុទ្ធព្រះនាមសិទ្ធត្ថៈបានកើតឡើងហើយក្នុងលោក ទ្រង់ញ៉ាំងសេចក្តីងងឹតដ៏ក្រៃលែងឲ្យវិនាស ហើយញ៉ាំងពន្លឺ គឺញាណឲ្យប្រព្រឹត្តទៅ ។ ក្នុងកាលនោះ មានសិស្សម្នាក់របស់ខ្ញុំ បានប្រាប់ដល់ពួកសិស្សរបស់ខ្ញុំ លុះពួកសិស្សទាំងនោះឮហើយ ទើបប្រាប់សេចក្តីនោះដល់ខ្ញុំ ( ខ្ញុំក៏បានគិតថា ) ព្រះសព្វញ្ញូជាលោកនាយកព្រះអង្គបានកើតឡើងក្នុងលោកហើយ ជនតែងប្រព្រឹត្តតាមនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ឯអាត្មាអញគ្មានលាភនឹងគេសោះ ។ ព្រះពុទ្ធទាំងឡាយ មានចក្ខុ មានយសធំ ព្រះអង្គទ្រង់កើតឡើង ព្រោះអាស្រ័យហេតុ បើដូច្នោះ អាត្មាអញគួរទៅមើលព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ព្រះអង្គជាលោកនាយក ។ ខ្ញុំបានកាន់យកស្បែកខ្លាសំពត់សម្បកឈើនិងកុណ្ឌីទឹករបស់ខ្ញុំចេញអំពីអាស្រម ហើយហៅពួកសិស្សមកប្រាប់ថា ការឃើញនូវព្រះពុទ្ធជាលោកនាយកកម្របុគ្គលបានដោយងាយ ដូចជាផ្កាឧទុម្ពរ ឬដូចជារូបនៃសត្វទន្សាយក្នុងដួងព្រះចន្ទ ឬក៏ដូចជាទឹកដោះនៃសត្វក្អែក ព្រះសម្មាសម្ពុទ្ធ ព្រះអង្គកើតឡើងក្នុងលោក នឹងភាពជាមនុស្ស ទាំងពីរនេះ កម្របុគ្គលបានដោយងាយ កាលបើហេតុទាំងពីរនេះមានហើយការស្តាប់ធម៌ក៏កម្រ

បុគ្គលបានដោយងាយដែរ ។ ព្រះសម្មាសម្ពុទ្ធបានកើតហើយក្នុងលោក ពួកយើងឈ្មោះថាបាននូវចក្ខុ សេចក្តីចម្រើននឹងមានដល់យើង អ្នកទាំងឡាយចូរមកចុះ យើងទាំងអស់នឹងនាំគ្នាទៅកាន់សម្នាក់ព្រះសម្មាសម្ពុទ្ធ ។ កាលនោះ ពួកតាបសទាំងអស់ ទ្រទ្រង់នូវកុណ្ឌីទឹក ស្លៀកពាក់ស្បែកខ្លាទាំងក្រចកតាបសទាំងនោះ ទ្រទ្រង់នូវភារៈគឺផ្នួងសក់ បានចេញទៅអំពីព្រៃ ។ តាបសទាំងនោះជាអ្នកស្វែងរកនូវប្រយោជន៍ដ៏ឧត្តមក្រឡេកមើលមួយជួរទឹមដើរមក ឥតមានសេចក្តីតក់ស្លុត បីដូចជាកូននៃដំរី ឬដូចជាកេសររាជសីហ៍ ឥតមានសេចក្តីតក់ស្លុតឡើយ ។ តាបសទាំងអស់នោះជាអ្នកមិនតក់ស្លុត មិនឡេះឡោះ មានប្រាជ្ញាធ្ងន់ធ្ងរ ជាអ្នកប្រព្រឹត្តរម្យទម តាបសទាំងអស់នោះ កាលត្រាច់រកផលាផល បានចូលទៅគាល់ព្រះពុទ្ធដ៏ប្រសើរ ។ ព្យាធិបានកើតឡើងដល់ខ្ញុំ ដែលនៅក្នុងប្រទេសប្រមាណមួយយោជន៍កន្លះ ( អំពីព្រះពុទ្ធគង់នៅ ) ខ្ញុំបាននឹកដល់ព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ហើយធ្វើមរណកាលក្នុងទីនោះ ។ ក្នុងកប្បទី ៩៤ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបាននូវសេចក្តីសម្គាល់ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃសេចក្តីសម្គាល់នូវព្រះសម្មាសម្ពុទ្ធ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះ

ពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ(១)។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផល បាន ពោលគាថា ២ ថា

កាលកប្បកបុរសចូលមក ខ្ញុំនិយាយថា ខ្ញុំនឹងកោរសក់របស់ ខ្ញុំ ( លំដាប់នោះ ) ខ្ញុំទាញយកកញ្ចក់អំពីដៃកប្បកបុរសនោះ ហើយឆ្ពុះមើលសរីរៈ ។ រាងកាយប្រាកដជារបស់ទទេ ងងឹត ក្នុងទីងងឹតគឺអវិជ្ជាក៏ប្រាសចេញហើយ កិលេសដូចជាកំណាត់ សំពត់ទាំងអស់ខ្ញុំបានផ្តាច់ចោលអស់ហើយ ឥឡូវនេះ កពថ្មី មិនមានទេ ។

បណ្តាបទទាំងនោះ បទថា **កេសេ មេ ឱលិខិស្សន្តិ កប្បកោ ឧបសង្កមិ** សេចក្តីថា កាលខ្ញុំជាគ្រហស្ថ ក្នុងកាលកោរពុកមាត់ ជាងកោរកាត់គិតថា នឹងកាត់ នឹងតាក់តែងសក់របស់ខ្ញុំ ទើបចូលមករកខ្ញុំ ដោយត្រៀមកាត់សក់ ជាដើម ។ បទថា **តតោ** បានដល់ អំពីជាងកោរកាត់នោះ ។ បទថា **សរីរំ បច្ចវេក្ខិស្សំ** សេចក្តីថា ពិចារណារាងកាយដែលជរាគ្របសង្កត់ហើយដោយ ខ្លួនឯងថា រាងកាយរបស់អាត្មាអញត្រូវជរាគ្របសង្កត់ហើយហ្ន៎ ដោយការ សម្លឹងមើលរូប គឺការមើលនិមិត្តលើផ្ទៃមុខ ដែលមានសក់ស្កូវ និងស្បែក ជ្រីវជ្រួញជាដើម ក្នុងកញ្ចក់ដែលមើលឃើញបានពេញរាងកាយ ។ កាលពិ ចារណាយ៉ាងនេះ កាយរបស់ខ្ញុំក៏ប្រាកដជារបស់ទទេ គឺរាងកាយរបស់ខ្ញុំបាន

១-ក្នុងអបទានជាព្រះ ពុទ្ធសញ្ញកត្ថេរ។

ប្រាកដ គឺឃើញច្បាស់ថា ជារបស់ទទេចាកសភាវៈផ្សេងៗមានសភាវៈទៀង ស្ថិតស្ថេរនិងសុខជាដើម ។ ព្រោះហេតុអ្វី ព្រោះងងឹតក្នុងងងឹត គឺអវិជ្ជាក៏ប្រាសចេញហើយ អធិប្បាយថា មនុស្សទាំងឡាយដែលនៅក្នុងអំណាចនៃភាពងងឹតក្នុងកាយរបស់ខ្លួនដោយការ**ង**ងឹត ពោលគឺអយោនិសោមនសិការណា ការមិនឃើញសភាវៈ មានការមិនស្អាតជាដើម ទាំងដែលមានក៏នៅតែកាន់យកអាការថាជារបស់ស្អាតជាដើម ដែលមិនមានការ**ង**ងឹត គឺអវិជ្ជាក្នុងកាយដែលជាមូលនៃការ**ង**ងឹត គឺជាទីតាំងនៃការធ្វើងងឹតនោះ បានប្រាសទៅដោយពន្លឺនៃញាណពោលគឺយោនិសោមនសិការ បន្ទាប់អំពីនោះកិលេសដូចសំពត់ចាស់ទាំងពួង ខ្ញុំបានកាត់ផ្តាច់ហើយ គឺកិលេសទាំងឡាយ ដែលបានឈ្មោះថា **ចោឡា** ព្រោះ ដូចពួកចោរ ដោយការចូលទៅកាត់កណ្ឌៈគឺកុសល ឬដូចជាសំពត់ចាស់ព្រោះភាពជាកំណាត់សំពត់ចាស់ៗដែលគេចោលហើយក្នុងគំនរសំរាមជាដើម ដោយជាសេសសំពត់ដែលត្រូវភ្លើង ឬសំពត់ដែលមនុស្សល្អមិនត្រូវការ ព្រោះជារបស់ដែលឥស្សរជន គឺបុគ្គលចម្រើនខ្ពើមរអើម ខ្ញុំក៏កាត់ផ្តាច់ហើយ ព្រោះកិលេសដូចសំពត់ចាស់ ដាច់ដាចនោះជារបស់ដែលខ្ញុំដកបានហើយ ដោយមគ្គដ៏ប្រសើរនោះឯង ឥឡូវនេះ ភពថ្មីមិនមាន បានដល់ការទៅកើតក្នុងភពថ្មីមិនមានទៀតទេ ។

## អដ្ឋកថា វីតសោកត្ថេរគាថា ចប់

## បុណ្ណមាសត្ថេរគាថា

[ ១៤៧ ] ខ្ញុំលះបង់នីវរណៈទាំង ៥ ដើម្បីដល់ព្រះនិព្វានដ៏ក្សេមចាកយោគៈ កាន់យកកញ្ចក់គឺធម៌ ជាញាណទស្សនៈរបស់ខ្លួន ធ្លុះមើលរាងកាយនេះទាំងអស់ ទាំងខាងក្នុងទាំងខាងក្រៅកាយ ប្រាកដជារបស់ទទេ ទាំងខាងក្នុងទាំងខាងក្រៅ ។

បុណ្ណមាសត្ថេរ ។

## អដ្ឋកថា

## បុណ្ណមាសត្ថេរគាថា

[ ១៤៧ ] គាថារបស់ព្រះបុណ្ណមាសត្ថេរ មានពាក្យផ្ដើមថា **បញ្ចនីវរណេ ហិត្វា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយទុកក្នុងភពនោះៗ ។ ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមថាតិស្សៈ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ថ្ងៃមួយ កាលព្រះសាស្ដាគង់នៅក្នុងព្រៃ ពាក់បង្សុកូលចីវរទុកត្រង់មែកឈើ ហើយយាងចូលទៅកាន់ព្រះគន្ធកុដិ ។ កុលបុត្តនោះ កាន់ធ្នូចូលទៅកាន់ព្រៃ ឃើញសំពត់បង្សុកូលរបស់ព្រះសាស្ដាមានចិត្តជ្រះថ្លាដាក់ធ្នូចុះ វេញកដល់ពុទ្ធគុណាថ្វាយបង្គំសំពត់បង្សុកូលចីវរនោះ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលកុដុម្ពិកៈ ក្នុងនគរសាវត្ថី ។ បានឮថាក្នុងថ្ងៃដែលកុលបុត្តនោះកើត ភាជនៈសព្វយ៉ាងក្នុងផ្ទះនោះពេញទៅដោយសំណែកបាយដែលសម្រេចអំពីមាស និងរតនៈទាំងឡាយ ព្រោះហេតុនោះ ទើបមនុស្សទាំងឡាយដាក់ឈ្មោះកុលបុត្តនោះថា បុណ្ណមាសៈ ។ កុលបុត្តនោះចម្រើនវ័យហើយ គ្រប់គ្រងផ្ទះ មានបុត្តម្នាក់កើតហើយ លះឃរាវាសវិស័យបួសក្នុងអាវាសក្បែរស្រុកព្យាយាមបានអភិញ្ញា ៦ ហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះជិនស្រីមានព្រះភាគព្រះនាមតិស្សៈជាព្រះសយម្ភូជាលោក
នាយកព្រះអង្គបានតម្កល់ទុកនូវសំពត់បង្សុកូល ហើយស្តេច
ចូលទៅក្នុងវិហារ ។ ខ្ញុំបានកាន់យកធ្នូ ដែលខ្លួនរៀបចំស្រេច
ហើយ មានទាំងទឹកបំពង់ កាន់ទាំងដាវដើរចូលទៅក្នុងព្រៃ ។
គ្រានោះ ខ្ញុំបានឃើញសំពត់បង្សុកូល ដែលព្រះអង្គពាក់ទុក
លើចុងឈើ ក្នុងទីនោះខ្ញុំបានដាក់បំពង់ព្រួញចុះក្នុងទីនោះឯង
ហើយបានធ្វើអញ្ជលីលើសិរ្សៈ ។ ខ្ញុំមានចិត្តជ្រះថ្លា រីករាយ
ដោយបីតិដ៏ធំទូលាយ នឹករឭកចំពោះព្រះពុទ្ធដ៏ប្រសើរហើយ
ថ្វាយបង្គំនូវសំពត់បង្សុកូល ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ
ព្រោះហេតុ ដែលខ្ញុំបានថ្វាយបង្គំនូវសំពត់បង្សុកូលក្នុងកាល
នោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបង្គំ ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញអស់ហើយ ។បេ។ ទាំងសា-
សនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលបានអភិញ្ញា ៦ ហើយ ចូលទៅកាន់សាវត្ថីនគរ ថ្វាយបង្គំព្រះសាស្តា ហើយនៅក្នុងព្រៃ កាលលោកទៅមិនបានយូរប៉ុន្មាន កូនប្រុសរបស់លោកក៏ធ្វើកាលកិរិយា មាតារបស់ទារកបានដំណឹងថា ព្រះថេរៈមកហើយ មានបំណងញ៉ាំងព្រះថេរៈឲ្យសឹក ដោយគិតថា ព្រះរាជាកុំបីរឹបអូសយកសម្បត្តិ របស់អ្នកឥតបុត្តនេះឡើយ ចូលទៅកាន់សម្នាក់ព្រះថេរៈដោយបរិវារច្រើន ធ្វើបដិសណ្ឋារៈហើយ ចាប់ផ្តើមលួងលោម ។ ព្រះថេរៈក៏ឈរក្នុងអាកាសដើម្បីឲ្យនាងដឹងថា លោកប្រាសចាករាគៈហើយ កាលនឹងសម្តែងធម៌ដល់នាង ដោយប្រាថ្នានឹងប្រាប់បដិបទារបស់លោក បានពោលគាថា ២ ថា

ខ្ញុំលះបង់នីវរណៈទាំង ៥ ដើម្បីដល់ព្រះនិព្វានដ៏ក្សេមចាក
យោគៈ កាន់យកកញ្ចក់ គឺ ធម៌ ជាញាណទស្សនៈរបស់ខ្លួន
ឆ្លុះមើលរាងកាយនេះទាំងអស់ ទាំងខាងក្នុង ទាំងខាងក្រៅ
កាយប្រាកដជារបស់ទទេ ទាំងខាងក្នុង ទាំងខាងក្រៅ ។

បណ្តាបទទាំងនោះ បទថា **បញ្ច នីវរណេ ហិត្វា** សេចក្តីថា លះគឺកម្ចាត់នូវនីវរណៈ ៥ មានកាមច្ឆន្ទៈជាដើម ដោយការសម្រេចឈាន ។

បទថា **យោគក្ខេមស្ស បត្តិយា** បានដល់ ដើម្បីសម្រេចព្រះនិព្វាន

១-ក្នុងអបទានជា ព្រះបង្សុកូលសញ្ញកត្ថេរ ។

ដែលជាដែនក្បែមចាកយោគៈទាំង ៤ មានកាមយោគៈជាដើម គឺដែលយោគៈទាំងនោះមិនចូលទៅប្រទូស្តហើយ ។

បទថា **ធម្មាធាសំ** បានដល់ កញ្ចក់ដែលជាអង្គធម៌ អធិប្បាយថា កញ្ចក់រមែងឆ្លុះឲ្យឃើញគុណនិងទោសក្នុងរូបកាយរបស់អ្នកមើលយ៉ាងណា កញ្ចក់ធម៌ពោលគឺវិបស្សនាក៏ដូច្នោះ ឈ្មោះថា ជាញាណទស្សនៈ ព្រោះជាហេតុដឹងនូវការផ្សេងគ្នានៃសាមញ្ញលក្ខណៈនៃធម៌ទាំងឡាយ រមែងសឲ្យឃើញដល់គុណក្នុងកាយថា មានការផ្សេងគ្នាដោយឆ្លុះឲ្យឃើញធម៌ ដែលថ្កុំថ្កើង និងធម៌ដែលសៅហ្មង និងដោយឲ្យដឹងថា លះសង្កិលេសធម៌បានឬមិនទាន់បានសម្រាប់បុគ្គលពិចារណាមើល ដោយហេតុនោះ ទើបព្រះថេរៈពោលថា

**ធម្មាធាសំ គហេត្វាន ញាណទស្សនមត្តនោ**
**បច្ចវេក្ខឹ ឥមំ កាយំ សន្តំ អន្តរពាហិរំ ។**

កាន់យកកញ្ចក់គឺធម៌ ជាញាណទស្សនៈរបស់ខ្លួន ឆ្លុះ
មើលរាងកាយនេះទាំងអស់ ទាំងខាងក្នុងទាំងខាងក្រៅកាយ
ប្រាកដជារបស់ទទេ ទាំងខាងក្នុងទាំងខាងក្រៅ ។

សេចក្តីថា កាន់យកនូវកញ្ចក់នៃធម៌ ហើយពិចារណាដោយចំពោះ គឺមើលដោយញាណចក្ខុ នូវរាងកាយនេះ គឺអត្តភាពរបស់យើងនេះដែលជាទីប្រជុំនៃធម៌ ដែលឈ្មោះថា ទាំងក្នុងទាំងខាងក្រៅ ព្រោះភាពជាអាយតនៈដែលប្រព្រឹត្តទៅខាងក្នុងនិងខាងក្រៅទាំងអស់ គឺមិនមានចំណែកសេសសល់ថា មិនទៀងខ្លះ ជាទុក្ខខ្លះ ជាអនត្តាខ្លះ កាលខ្ញុំមើលយ៉ាងនេះ រាងកាយ

បានប្រាកដថា ជារបស់ទទេ ទាំងខាងក្នុងទាំងខាងក្រៅ គឺរាងកាយប្រាកដថាទទេទាំងក្នុងសន្តានរបស់ខ្លួននិងក្នុងសន្តានរបស់អ្នកដទៃ អធិប្បាយថា រាងកាយគឺអត្តភាព ពោលគឺខន្ធ ៥ ដែលវៀរសារៈ មានការទៀងជាដើម ទើបឈ្មោះថា ប្រាកដជារបស់ទទេ ខ្ញុំបានឃើញហើយ តាមសេចក្តីពិត ដោយញាណចក្ខុ ។

ពិតហើយ ខន្ធ ៥ ទាំងមូល លោកហៅថា រាងកាយ ដូចក្នុងប្រយោគ ( ក្នុងសំយុត្តនិកាយនិទានវគ្គ ) ថា

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល ដែលអវិជ្ជាណា បិទបាំងទុកផង ដែលតណ្ហាណាប្រកបទុកផង ទើបកាយនេះកើតឡើង ដូច្នេះជាដើម ។

ព្រះថេរៈកាលសម្តែងឲ្យដឹងថា លោកសម្រេចកិច្ចហើយ ដោយពាក្យថា ខ្ញុំបានឃើញខន្ធ ៥ ដែលបុគ្គលគប្បីឃើញ ក្នុងកាយនេះហើយ ឥឡូវនេះមិនមានចំណែកណាមួយ ក្នុងខន្ធ ៥ នោះ ដែលខ្ញុំត្រូវឃើញទៀត បានព្យាករអរហត្តផលហើយ ដោយបទថា **អធិសិ្សដ្ឋ** ដូច្នេះ ។

ព្រះថេរៈសម្តែងធម៌ ដល់ស្រីដែលជាភរិយាចាស់ ដោយគាថាទាំងនេះយ៉ាងនេះហើយ ញុំាងនាងឲ្យតាំងនៅក្នុងសរណៈនិងសីលហើយបញ្ជូនទៅ ។

## អដ្ឋកថា បុណ្ណមាសត្ថេរគាថា ចប់

## ឆន្នកត្ថេរគាថា

[ ១៤៨ ] គោអាជានេយ្យដ៏ចម្រើន ភ្លាត់ហើយរមែងឈរស៊ប់ឡើងវិញ ទោះបីបាននូវសេចក្តីតក់ស្លុត ក៏ជាសត្វមានចិត្តមិនរួញរា រមែងនាំនូវធុរៈទៅបាន យ៉ាងណាមិញ អ្នកទាំងឡាយសូមជ្រាបនូវខ្ញុំថាជាអាជានេយ្យ បរិបូណ៌ដោយទស្សនៈ ជាសាវករបស់ព្រះសម្មាសម្ពុទ្ធ ជាបុត្ត ជាឱរសរបស់ព្រះពុទ្ធក៏យ៉ាងនោះដែរ ។

ឆន្នកត្ថេរ ។

## អដ្ឋកថា

## ឆន្នកត្ថេរគាថា

[ ១៤៨ ] គាថារបស់ព្រះឆន្នកត្ថេរ មានពាក្យផ្តើមថា **យថាបិ ភទ្ទោ អាជញ្ញោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ ធ្វើបុណ្យទាំងឡាយទុកក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាម សិខី កើតក្នុងបច្ចន្តប្បទេស ដល់នូវភាពជាអ្នកដឹងក្តីហើយ ប្រកបមុខរបរជាព្រានព្រៃ ត្រាច់ទៅ ថ្ងៃមួយឃើញទីចង្ក្រមរបស់ព្រះសាស្តាហើយ មានចិត្តជ្រះថ្លាកោយនូវខ្សាច់ឲ្យស្មើ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលគហបតី ក្នុងចម្បានគរ ញាតិទាំង

ឡាយដាក់ឈ្មោះថានន្ទកៈ ឯបងប្រុសរបស់កុលបុត្តនេះ ឈ្មោះភារតៈ ដែលមានប្រវត្តិជាក់ច្បាស់ទៅខាងមុខ ។ ជនទាំង ២ ដឹងក្តីហើយ បានឮដំណឹងថា ព្រះសោណកោឡិវិសៈបួសហើយ និយាយគ្នាថា អម្បាលព្រះសោណកោឡិវិសៈ ជាសុខុមាលជាតិដល់ម្ល៉ោះ ក៏គង់បួស យើងទាំង ២ នៅរវែកធ្វើអ្វី ដូច្នេះ ទើបចេញបួស ។ បណ្តាព្រះថេរៈ ២ នាក់បងប្អូននោះ ព្រះភារតត្ថេរចម្រើនវិបស្សនាហើយបានជាអ្នកមានអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ ។

ឯព្រះនន្ទកត្ថេរ មិនអាចញុំាងវិបស្សនាឲ្យខ្ពស់ឡើងបាន ព្រោះកិលេសទាំងឡាយមានកម្លាំង តែប្រកបការចម្រើនវិបស្សនាតែម្យ៉ាង លំដាប់នោះ ព្រះភារតត្ថេរដឹងអធ្យាស្រ័យរបស់ព្រះនន្ទកត្ថេរជាប្អូន បំណងនឹងធ្វើជាទីពឹង ក៏ឲ្យព្រះនន្ទកត្ថេរជាបច្ឆាសមណៈ ចេញអំពីវិហារហើយ អង្គុយក្បែរផ្លូវពោលវិបស្សនាកថាហើយ ។

ដោយសម័យនោះ កាលពួកអ្នករទេះធ្វើដំណើរទៅគោដែលគេទឹមដោយរទេះមួយ មិនអាចទាញរទេះក្នុងទីដែលមានភក់បាន ក៏ដួលចុះ ។ លំដាប់នោះ នាយរទេះ ក៏ដោះគោនោះចេញ ឲ្យស៊ោនិងទឹក ឲ្យសម្រាក បាត់នឿយហត់រួចទឹមក្នុងនឹមវិញ ។ លំដាប់នោះ គោនោះសម្រាក បាត់ហត់នឿយហើយលុះមានកម្លាំង ក៏ទាញរទេះនោះចេញអំពីក្នុងភក់ តាំងនៅលើគោកបាន ។

លំដាប់នោះ ព្រះភារតត្ថេរ ក៏បង្ហាញគោនោះជាឧបមា ដល់ព្រះនន្ទកៈថា នែនន្ទកៈ លោកម្ចាស់ឃើញការធ្វើរបស់គោនេះដែរឬទេ កាលព្រះនន្ទកៈ

ឆ្លើយថា ឃើញលោកម្ចាស់ ទើបពោលថា សូមលោកម្ចាស់ ពិចារណាសេចក្ដីនេះឲ្យល្អ ។ ព្រះនន្ទកត្ថេរ ធ្វើគោនោះឯងឲ្យជាអារម្មណ៍ថា គោនេះសម្រាកបាត់នឿយហត់ហើយ អូសរបស់ធ្ងន់អំពីទីដែលជារណ្ដៅ បានយ៉ាងណា សូម្បីអាត្មាអញ ក៏គប្បីលើកខ្លួនចេញអំពីភក់ គឺសង្សារ ក៏យ៉ាងនោះហើយប្រកបការចម្រើនវិបស្សនា បានសម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ក្នុងភពមុន ខ្ញុំកើតជាព្រានម្រឹគនៅក្នុងព្រៃ កំពុងស្វែងរកសត្វឈ្លូស ក៏បានឃើញនូវទីចង្ក្រម ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយចំពោះព្រះសុគតទ្រង់មានសិរី ហើយកើបយកដីខ្សាច់មួយថ្នក់មករោយរាយក្នុងទីចង្ក្រម ។ ក្នុងកប្បទី ៣១ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបានរោយរាយនូវដីខ្សាច់ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃដីខ្សាច់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផល ក្នុងសម្នាក់ព្រះភារតៈដែលជាបងប្រុសរបស់ខ្លួន បានពោលគាថា ២ ថា

គោអាជានេយ្យដ៏ចម្រើនភ្លាត់ហើយ រមែងឈរស៊ប់ឡើងវិញ ទោះបីបាននូវសេចក្ដីតក់ស្លុតក៏ជាសត្វមានចិត្តមិនរួញរា រមែង

---

១-ក្នុងអបទានជាព្រះ បុឡិនចង្កមិយត្ថេរ ។

នាំនូវធុរៈទៅបាន យ៉ាងណាមិញ អ្នកទាំងឡាយសូមជ្រាបនូវ ខ្ញុំថាជាអាជានេយ្យ បរិបូណ៌ដោយទស្សនៈ ជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ជាបុត្ត ជាឱរសរបស់ព្រះពុទ្ធ ក៏យ៉ាងនោះដែរ ។

បណ្តាបទទាំងនោះ បទថា **ភិយ្យោ លទ្ធាន សំវេគំ អធីនោ វហាតេ ធុរំ** សេចក្តីថា បានទូវសេចក្តីសង្វេគថា ការមិននាំការៈដែលមកដល់នេះទៅ ជាវត្ថុមិនសមគួរសម្រាប់បុគ្គលមានកម្លាំង និងសេចក្តីព្យាយាមដោយជាតិឡើយ ដូច្នេះហើយ ជាអ្នកមិនធូរថយ គឺមានចិត្តមិនរួញរា បានដល់ មានចិត្តមិនក្រាញ ។ម្យ៉ាងទៀត បាឋៈថា **អលីនោ** ដូច្នេះក៏មាន ។ ឯអត្ថក៏ដូចគ្នានោះឯង គឺនាំទៅ បានដល់ អូសទៅនូវធុរៈ គឺភារៈរបស់ខ្លួនដោយក្រៃលែង គឺរឿយៗ បានដល់ លើសប្រមាណ ។ បទដ៏សេសមានន័យដូចពោលខាងដើម គឺក្នុងអដ្ឋកថារមណីយវិហារិត្ថេរគាថា[១]ខាងដើមនោះឯង ។

## អដ្ឋកថា នន្ទកត្ថេរគាថា ចប់

១-ក្នុងឯកនិបាត វគ្គទី ៥ ។

## ភារតត្ថេរគាថា

[ ១៨៩ ] ម្នាលនន្ទកៈ អ្នកចូរមក យើងនឹងទៅកាន់សំណាក់នៃព្រះឧបជ្ឈាយ៍ នឹងបន្លឺឡើងនូវសីហនាទ ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះពុទ្ធដ៏ប្រសើរ ។ ព្រះពុទ្ធជាមុនី ទ្រង់បំបួសយើងដោយសេចក្តីអនុគ្រោះយើង ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ យើងបានដល់ហើយ ការអស់ទៅនៃសំយោជនៈទាំងពួង ( យើងក៏បានដល់ហើយ ) ។

ភារតត្ថេរ ។

---

## អដ្ឋកថា

## ភារតត្ថេរគាថា

[ ១៨៩ ] គាថារបស់ព្រះភារតត្ថេរ មានពាក្យផ្តើមថា **ឯហិ នន្ទក គច្ឆាម** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងសាសនារបស់ព្រះមានព្រះភាគ អនោមទស្សី កុលបុត្រនេះកើតក្នុងផ្ទះមានត្រកូល ដឹងក្តីហើយ ថ្ងៃមួយ កាន់យកគូនៃស្បែកជើងដ៏ស្អាត គួរមើល មានសម្ផស្សទន់ នាំឲ្យសប្បាយដល់ការពាក់ ធ្វើដំណើរទៅឃើញព្រះសាស្តាកំពុងចង្ក្រម មានចិត្តជ្រះថ្លា បង្អោនស្បែកជើងថ្វាយ ក្រាបទូលថា សូមទ្រង់ពាក់ស្បែកជើង ដើម្បីប្រព្រឹត្តទៅជាប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ដល់ខ្ញុំព្រះអង្គអស់កាលយូរ ។ ដើម្បីអនុគ្រោះព្រះមានព្រះភាគទ្រង់ក៏ពាក់ស្បែកជើង ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំង-ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលគហបតី ក្នុងចម្បានគរ មានឈ្មោះថាភារតៈ កុលបុត្តនោះដឹងក្តីហើយ ដឹងដំណឹងថា ព្រះសោណកោឡិវិសត្ថេរបួសហើយ កើតសេចក្តីសង្វេគថា អម្បាលព្រះសោណកោឡិវិសត្ថេរ គង់បួស ដូច្នេះហើយចេញបួស ធ្វើបុព្វកិច្ចស្រេចហើយ ធ្វើកម្មក្នុងវិបស្សនា បានជាអ្នកមានអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះមានព្រះភាគព្រះនាម អនោមទស្សី ជាធំក្នុងលោក ប្រ-សើរជាងនរៈមានចក្ខុ ទ្រង់ចេញអំពីរោងសម្រាកក្នុងវេលាថ្ងៃ ស្តេចទៅតាមថ្នល់ ។ ខ្ញុំពាក់ស្បែកជើងដែលខ្ញុំធ្វើល្អហើយដើរទៅកាន់ផ្លូវឆ្ងាយ បានឃើញព្រះសម្ពុទ្ធទ្រង់ស្តេចទៅដោយព្រះបាទាទទេ ព្រះអង្គមានព្រះកាយប្រកបដោយគ្រឿងប្រដាប់ដូចមាស ខ្ញុំញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លាយកស្បែកជើងទៅតម្កល់ទុកជិតព្រះបាទា ហើយពោលនូវពាក្យនេះថា បពិត្រព្រះសុ-គតជាធំ ជានាយក មានព្យាយាមច្រើន សូមព្រះអង្គពាក់នូវស្បែកជើង ខ្ញុំព្រះអង្គនឹងបាននូវផលអំពីស្បែកជើងនេះ សូមឲ្យសម្រេចប្រយោជន៍នោះដល់ខ្ញុំ ។ ព្រះមានព្រះភាគព្រះនាមអនោមទស្សី ជាធំក្នុងលោក ប្រសើរជាងនរៈ ទ្រង់ពាក់នូវស្បែកជើង ហើយត្រាស់ព្រះពុទ្ធដីកានេះថា

បុគ្គលណា មានចិត្តជ្រះថ្លា បានថ្វាយស្បែកជើងដល់តថាគតដោយដៃរបស់ខ្លួន តថាគតនឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់នូវភាសិត ដែលតថាគតនឹងសម្តែងចុះ ។ ទេវតាទាំងអស់ បានដឹងនូវវាចារបស់ព្រះពុទ្ធ ក៏មកប្រជុំគ្នា មានចិត្តខ្ពស់ឡើង មានចិត្តរីករាយ មានសេចក្តីត្រេកអរ ធ្វើនូវអញ្ជលី ។ បុគ្គលនេះនឹងដល់នូវសេចក្តីសុខ ព្រោះការថ្វាយនូវស្បែកជើង នឹងសោយរាជ្យជាស្តេចទេវតាអស់ ៥៥ ដង ។ នឹងបានជាស្តេចចក្រពត្តិ ១០០០ ដង នឹងសោយបទេសរាជ្យដ៏ធំទូលាយរាប់ជាតិមិនអស់ ។ ក្នុងកប្បប្រមាណមិនបានអំពីកប្បនេះ ព្រះសាស្តាមាននាមថា គោតម ទ្រង់កើតក្នុងត្រកូលឱក្កាកៈនឹងបានត្រាស់ក្នុងលោក ។ ( បុរសនេះ ) នឹងបានជាអ្នកទទួលនូវមត៌កក្នុងធម៌របស់ព្រះគោតមនោះ ជាឱរសដែលធម៌និម្មិតហើយ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ ( បុរសនេះឯង ) បើកើតក្នុងទេវលោក ឬក្នុងមនុស្សលោក រមែងជាអ្នកមានប្រាជ្ញានឹងបាននូវយានមានចំណែកប្រៀបដោយយានទេវតា ។

ប្រាសាទ វិមាស ដំរីប្រដាប់ព្រមហើយ រថដែលទឹមដោយសេះអាជានេយ្យ រមែងកើតប្រាកដដល់ខ្ញុំសព្វៗកាល ។ ខ្ញុំទុកជាកាលចេញទៅអំពីលំនៅតែងចេញទៅដោយរថ កាល

សក់ទាំងឡាយ គេកំពុងកោរកាត់ ខ្ញុំក៏បានដល់អរហត្ត ។ ឱ! ជាលាភរបស់ខ្ញុំហើយ អត្តភាពជាមនុស្ស ឈ្មោះថាខ្ញុំបានល្អហើយ ការជួញខ្ញុំប្រកបល្អហើយ ព្រោះខ្ញុំបានថ្វាយស្បែកជើងមួយសម្រាប់ ក៏បានដល់អចលបទ គឺព្រះនិព្វាន ។ ក្នុងកប្បប្រមាណមិនបានអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យស្បែកជើងក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃស្បែកជើង ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈជាអ្នកមានអភិញ្ញា ៦ ហើយ កាលព្រះនន្ទកត្ថេរជាប្អូនរបស់ខ្លួន ធ្វើនូវការព្យាករអរហត្តផល ដោយន័យដូចពោលហើយខាងដើមនោះឯង កាលប្រាប់ដល់បរិវិតក្កដែលកើតឡើងហើយដល់ព្រះនន្ទកត្ថេរថា ឥឡូវនេះ នន្ទកៈក៏បានជាព្រះអរហន្តហើយ ណ្ហើយចុះ យើងទាំង ២ ទៅកាន់សម្នាក់របស់ព្រះសាស្តាដើម្បីទូលភាពដែលយើងទាំង ២ មានព្រហ្មចរិយៈនៅចប់ហើយ ដូច្នេះ បានពោលគាថា ២ ថា

ម្នាលនន្ទកៈ អ្នកចូរមក យើងនឹងទៅកាន់សំណាក់ នៃព្រះឧបជ្ឈាយ៍ នឹងបន្លឺឡើងនូវសីហនាទ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះពុទ្ធដ៏ប្រសើរ ។ ព្រះពុទ្ធជាមុនី ទ្រង់បំបួសយើង ដោយសេចក្តីអនុគ្រោះយើង ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ

---

១- ក្នុងអបទានជា ព្រះបានធិទាយកត្ថេរ ។

យើងបានដល់ហើយ ការអស់ទៅនៃសំយោជនៈទាំងពួង ( យើងក៏បានដល់ហើយ ) ។

បណ្ដាបទទាំងនោះ បទថា **ឆន្នក** ជាអាលបនៈ គឺគ្រាន់តែជាពាក្យហៅ ។ បទថា **ឯហិ** ជាពាក្យហៅព្រះនន្ទកត្ថេរឲ្យមកកាន់សម្នាក់របស់ខ្លួន ។ បទថា **គច្ឆាម** ជាពាក្យប្រាប់កិច្ចដែលព្រះនន្ទកៈនិងលោកគប្បីធ្វើព្រមគ្នា ។

បទថា **ឧបជ្ឈាយស្ស** សំដៅដល់ ព្រះសម្មាសម្ពុទ្ធ អធិប្បាយថា ព្រះសម្មាសម្ពុទ្ធសមគួរថ្វាយព្រះនាមថា ជាឧបជ្ឈាយ៍ដោយពិសេស ព្រោះទ្រង់ចូលទៅសម្លឹងទោសតូចទោសធំ របស់សត្វលោក ព្រមទាំងទេវលោកដោយទ្រង់ប្រមើលមើលអធ្យាស្រ័យ អនុស័យ និងចរិតជាដើម របស់សត្វទាំងឡាយ តាមសេចក្ដីពិត ដោយសមន្តចក្ខុនិងដោយពុទ្ធចក្ខុ ដើម្បីសម្ដែងដល់ប្រយោជន៍នៃការទៅ ទើបព្រះថេរៈពោលថា **សីហនាទំ នទិស្សាម ពុទ្ធសេដ្ឋស្ស សម្មុខា** នឹងបន្លឺឡើងនូវសីហនាទ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះពុទ្ធដ៏ប្រសើរ ដូច្នេះ អធិប្បាយថា ខ្ញុំនឹងបន្លឺអត្តវចនៈដែលឈ្មោះថា សីហនាទព្រោះជាការបន្លឺដោយអង់អាច ដោយការប្រមូល មកនូវគុណវិសេសតាមការពិតចំពោះមុខ គឺចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធ គឺព្រះសម្មាសម្ពុទ្ធដែលទ្រង់ឈ្មោះថា ជាបុគ្គលប្រសើរបំផុត ព្រោះភាពជាបុគ្គលឧត្តមជាងសត្វទាំងពួងនោះឯងឬប្រសើរបំផុតជាងអ្នកប្រាជ្ញទាំងឡាយ មានសាវកពុទ្ធជាដើម ។

ព្រះថេរៈកាលសម្ដែងភាពជាបុគ្គលបំណងនឹងបន្លឺសីហនាទ ទើបពោលពាក្យថា **យាយ** ដូច្នេះជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ២ ដូចតទៅនេះថា បទថា **យាយ** សេចក្តីថា ដើម្បីជាប្រយោជន៍ណា អធិប្បាយថា ដើម្បីបដិបទាដែលសមគួរដល់ប្រយោជន៍ណា ។ បទថា **នោ** ស្មើគ្នានឹង **អម្ហាកំ** ប្រែថា ដល់យើងទាំងឡាយ ។ បទថា **អនុកម្បាយ** សេចក្តីថា ព្រះមានព្រះភាគញុំាំងយើងទាំង ២ ឲ្យបព្វជ្ជា គឺឲ្យបួសដោយសេចក្តីអនុគ្រោះ ។ បទថា **មុនិ** បានដល់ព្រះមានព្រះភាគ ។ បទថា **សោ នោ អត្ថោ អនុប្បត្តោ** អធិប្បាយថា ប្រយោជន៍នោះ បានដល់ អរហត្តផល ដែលជាទីអស់ទៅនៃសំយោជនៈទាំងពួងដែលយើងទាំងឡាយ គឺយើងទាំង ២ ដល់ហើយដោយលំដាប់ គឺសម្រេចហើយ ។

អដ្ឋកថា ភារតត្ថេរគាថា ចប់

## ភារទ្វាជត្ថេរគាថា

[ ១៥០ ] ពួកអ្នកប្រាជ្ញប្រកបដោយប្រាជ្ញា ជាអ្នកឈ្នះសង្គ្រាមគឺកិលេស ឈ្នះមារ ព្រមទាំងវាហនៈរបស់មារ តែងបន្លឺឡើងយ៉ាងនេះ ដូចជាសីហៈបន្លឺលើកំពូលភ្នំ ។ ព្រះសាស្តាខ្ញុំបានគោរពហើយ ព្រះធម៌នឹងព្រះសង្ឃ ខ្ញុំបានបូជាហើយ មួយទៀត ខ្ញុំមានចិត្តត្រេកអររីករាយ ព្រោះឃើញកូន ជាអ្នកមិនមានអាសវៈ ។

ភារទ្វាជត្ថេរ ។

## អដ្ឋកថា

## ភារទ្វាជត្ថេរគាថា

[ ១៥០ ] គាថារបស់ព្រះភារទ្វាជត្ថេរ មានពាក្យផ្តើមថា **នទន្តិ ឯវំ សប្បញ្ញា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទុកក្នុងភពនោះៗ ។ ក្នុងកប្បទី ៣១ រាប់ថយអំពីភទ្ទកប្បនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយឃើញព្រះបច្ចេកពុទ្ធព្រះនាមថា សុមនៈ ត្រាច់បិណ្ឌបាត មានចិត្តជ្រះថ្លាបានប្រគេនផ្លែគុយដែលទុំល្អ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងរាជគ្រឹះ

មានឈ្មោះតាមគោត្តថា ភារទ្វាជៈ ។ ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ បានកូនប្រុសមួយ ដាក់ឈ្មោះថា កណ្ហទិន្ន ក្នុងកាលដែលកណ្ហទិន្នកុមារដឹងក្តីហើយ បញ្ជូនទៅកាន់តក្កសិលានគរ ដោយពាក្យថា នែកូន ចូរឯងទៅសិក្សាវិជ្ជាក្នុងសម្នាក់អាចារ្យឈ្មោះនោះ ហើយចូរត្រឡប់មក ។ កណ្ហទិន្នព្រាហ្មណ៍ ធ្វើដំណើរទៅក្នុងរវាងផ្លូវ បានឃើញព្រះមហាថេរៈមួយរូប ដែលជាសាវ័ករបស់ព្រះសាស្តា ជាកល្យាណមិត្ត ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះមហាថេរៈហើយ បានជាអ្នកមានសទ្ធា បួសហើយ ធ្វើបុព្វកិច្ចស្រេចហើយ ធ្វើកម្មក្នុងវិបស្សនា សម្រេចអរហត្តហើយ ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

គ្រានោះ ព្រះសម្ពុទ្ធព្រះនាមសុមនៈ គង់នៅក្នុងក្រុងឈ្មោះតក្ករា ខ្ញុំបានយកផ្លែគុយទៅថ្វាយព្រះសយម្ភូ ។ ក្នុងកប្បទី ៣១ អំពីកទ្ធកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ(១)។

កាលនោះ ភារទ្វាជព្រាហ្មណ៍ ជាឪពុករបស់ព្រះកណ្ហទិន្នត្ថេរ ចូលទៅគាល់ព្រះមានព្រះភាគដែលគង់នៅក្នុងវិហារវេឡុវ័ន ស្តាប់ធម៌ហើយបួស ធ្វើឲ្យជាក់ច្បាស់នូវអរហត្តក្នុងកាលមិនយូរឡើយ លំដាប់នោះ ព្រះកណ្ហទិន្នត្ថេរ

---

១-ក្នុងអបទានជាព្រះ វល្លិការផលទាយកត្ថេរ ។

ជាកូន មកកាន់នគររាជគ្រឹះដើម្បីថ្វាយបង្គំព្រះសាស្តា ឃើញព្រះភាគវង្គីសៈ ជាលោកឪ អង្គុយក្នុងសម្នាក់របស់ព្រះសាស្តា មានចិត្តត្រេកអរហើយ កាលពិចារណាថា លោកឪរបស់អាត្មាបួសហើយ កិច្ចនៃបព្វជ្ជារបស់លោកដល់ទីបំផុតហើយឬហ្ន៎ ដូច្នេះ ដឹងភាពដែលព្រះថេរៈជាព្រះខីណាស្រពហើយបំណងនឹងឲ្យព្រះថេរៈបន្លឺសីហនាទ ទើបសួរថា ជាការល្អហ្ន៎ដែលលោកម្ចាស់បានបួស តែកិច្ចនៃបព្វជ្ជា លោកម្ចាស់ឲ្យដល់ទីបំផុតហើយឬ ព្រះភាគវង្គីសត្ថេរកាលនឹងសម្តែងការសម្រេចអរហត្តដល់ព្រះថេរៈដែលជាកូន ទើបពោលគាថា ២ ថា

ពួកអ្នកប្រាជ្ញប្រកបដោយប្រាជ្ញា ជាអ្នកឈ្នះសង្គ្រាមគឺកិលេស ឈ្នះមារព្រមទាំងវាហនៈរបស់មារតែងបន្លឺឡើងយ៉ាងនេះ ដូចជាសីហៈបន្លឺលើកំពូលភ្នំ ។ ព្រះសាស្តាខ្ញុំបានគោរពហើយព្រះធម៌នឹងព្រះសង្ឃ ខ្ញុំបានបូជាហើយ មួយទៀត ខ្ញុំមានចិត្តត្រេកអររីករាយ ព្រោះឃើញកូនជាអ្នកមិនមានអាសវៈ ។

បណ្តាបទទាំងនោះ បទថា **ឯវំ នទន្តិ** សេចក្តីថា បន្លឺ គឺបញ្ចេញសំឡេងដោយមិនខ្លាចក្រែង ដោយអំណាចនៃការប្រមូលមកនូវគុណវិសេស តាមសេចក្តីពិត ។

បទថា **ឯវំ** ជាបទសម្តែងអាការដែលគប្បីពោលក្នុងឥឡូវនេះ ។

បទថា **សប្បញ្ញា** សេចក្តីថា ដល់នូវការបរិបូណ៌ដោយបញ្ញាទាំងពួងព្រោះបានសម្រេចបញ្ញាគ្រប់យ៉ាង ដោយបានសម្រេចមគ្គប្បញ្ញាដ៏ប្រសើរ ។

បទថា **វីរា** សេចក្តីថា ឈ្មោះថា មានព្យាយាម ព្រោះសម្បូរដោយព្យាយាម គឺសម្មប្បធាន ៤ យ៉ាង ភ្ជាប់សេចក្តីថា ព្រោះហេតុនោះឯង អ្នកមានបញ្ញា ឈ្នះកិលេសមារ អភិសង្ខារមារ និងទេវបុត្តមារ ព្រមទាំងវាហនៈ ដោយការទម្លាយធម៌ដែលជាចំណែកនៃសង្កិលេសបានដោយមិនសេសសល់ ឈ្មោះថា **វិជិតសង្គាមា** ដោយប្រការទាំងពួង រមែងបន្លឺសីហនាទ ។

ព្រះថេរៈកាលសម្តែងសីហនាទ ដោយការឈ្នះកិលេសដែលគប្បីឈ្នះយ៉ាងនេះហើយឥឡូវនេះដើម្បីសម្តែងសីហនាទនោះដោយការសម្តែងសេចក្តីត្រេកអរដល់វត្ថុដែលគួរត្រេកអរ និងក្នុងការសម្រេចដែលសមតាមបំណងទើបពោលគាថាទី ២ ថា **សត្ថា ច បរិចិណ្ណោ មេ** ព្រះសាស្តា ខ្ញុំបានគោរពហើយ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សត្ថា ច បរិចិណ្ណោ មេ** សេចក្តីថា ព្រះសម្មាសម្ពុទ្ធដែលជាសាស្តារបស់យើង ដែលខ្ញុំប្រតិបត្តិហើយ គឺចូលទៅជិតហើយ ដោយការធ្វើតាមឳវាទានុសាសនី តាមដែលទ្រង់ប្រៀនប្រដៅហើយ អធិប្បាយថា មិនមែនសម្រេចគុណវិសេស ព្រោះហេតុធម្មតា ។

បទថា **ធម្មោ សង្ឃោ ច បូជិតោ** សេចក្តីថា លោកុត្តរធម៌ទាំង ៩ ដែលខ្ញុំបូជាហើយ រាប់អានហើយ ដោយការបដិបត្តិតាមមគ្គដែលសម្រេចបានដោយបដិបត្តិនូវបដិបទា និងព្រះអរិយសង្ឃដែលខ្ញុំបូជាហើយ រាប់អានហើយ ដោយការចូលដល់នូវភាពជាបុគ្គលស្មើដោយសីលនិងទិដ្ឋិ ។

បទថា **អហញ្ច វិត្តោ សុមនោ បុត្តំ ទិស្វា អនាសវំ** សេចក្តីថា ខ្ញុំ

ក៏ត្រេកអរ គឺរីករាយហើយដោយបីតិដែលប្រាសចាកអាមិស ព្រោះឃើញ គឺមានការឃើញជាហេតុថា កូនរបស់ខ្ញុំមិនមានអាសវៈ គឺមានអាសវៈអស់ហើយដោយប្រការទាំងពួង អធិប្បាយថា ព្រោះហេតុនោះ ទើបខ្ញុំត្រេកអរដោយសោមនស្សដែលប្រាសចាកអាមិស ។

## អដ្ឋកថា ភារទ្វាជត្ថេរគាថា ចប់

# កណ្ហទិន្នត្ថេរគាថា

[ ១៥១ ] ពួកសប្បុរស ខ្ញុំបានគប់រកហើយ ធម៌ខ្ញុំក៏បានស្តាប់ហើយរឿយៗ លុះខ្ញុំស្តាប់ហើយ ក៏ដើរតាមផ្លូវធម៌ ដែលឈមទៅកាន់ព្រះនិព្វាន ឈ្មោះ អមតៈ ។ ខ្ញុំត្រូវកវរាគៈបៀតបៀន ( ឥឡូវនេះ ) កវរាគៈមិនមានដល់ខ្ញុំទៀតទេ កវរាគៈ ( ក្នុងអតីតកាល ) មិនមានហើយដល់ខ្ញុំ ( ក្នុងអនាគត ) ក៏នឹងមិនមានទេ ក្នុងបច្ចុប្បន្ននេះទៀតក៏មិនមានដល់ខ្ញុំដែរ ។

**កណ្ហទិន្នត្ថេរ ។**

**ឧទ្ទាន**

និយាយអំពីឧត្តរត្ថេរ ១ ភទ្ទជិត្ថេរ ១ សោភិតត្ថេរ ១ វល្លិយត្ថេរជាឥសី ១ វីតសោកត្ថេរ ១ បុណ្ណមាសត្ថេរ ១ នន្ទកត្ថេរ ១ ភារតត្ថេរ ១ ភារទ្វាជត្ថេរ ១ កណ្ហទិន្នត្ថេរជាមហាមុនី ១ ។

**ចប់ តតិយវគ្គ ។**

# អដ្ឋកថា

# កណ្ហទិន្នត្ថេរគាថា

[ ១៥១ ] គាថារបស់ព្រះកណ្ហទិន្នត្ថេរ មានពាក្យផ្ដើមថា **ឧបាសិតា សប្បុរិសា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយទុកក្នុងភពនោះៗ ។ ក្នុងកប្បទី ៩៤ រាប់ថយអំពីភទ្ទកប្បនេះ កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ។ ថ្ងៃមួយឃើញព្រះបច្ចេកពុទ្ធព្រះនាមសោភិតៈ ធ្វើការបូជាដោយផ្កាបុសនាគ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ក្នុងក្រុងរាជគ្រឹះឈ្មោះកណ្ហទិន្ន ចម្រើនវ័យហើយ កាលឧបនិស្ស័យសម្បត្តិជាស់តឿន ចូលទៅរកព្រះធម្មសេនាបតីស្ដាប់ធម៌ហើយបាននូវសទ្ធា បួសហើយចម្រើនវិបស្សនាសម្រេចអរហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

គ្រានោះព្រះសម្ពុទ្ធ ព្រះនាមសោភិតៈ ទ្រង់គង់លើភ្នំចិត្តកូដ
ខ្ញុំយកផ្កាបុសនាគភ្នំទៅបូជាព្រះសយម្ភូ ។ ក្នុងកប្បទី ៩៤ អំពី
ភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបូជានូវព្រះសម្ពុទ្ធក្នុងកាលនោះ
ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេស
ទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។ បេ ។ ទាំងសាសនារបស់

ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈសម្រេចអរហត្តហើយ កាលព្យាករអរហត្តផល បានពោលគាថា ២ ថា

ពួកសប្បុរស ខ្ញុំបានគប់រកហើយ ធម៌ខ្ញុំក៏បានស្តាប់ហើយ
រឿយៗ លុះខ្ញុំស្តាប់ហើយ ក៏ដើរតាមផ្លូវធម៌ ដែលឈមទៅ
កាន់ព្រះនិព្វានឈ្មោះអមតៈ ។ ខ្ញុំត្រូវភវរាគៈបៀតបៀន ( ឥឡូវ
នេះ ) ភវរាគៈមិនមានដល់ខ្ញុំទៀតទេ ភវរាគៈ ( ក្នុងអតីត
កាល ) មិនមានហើយដល់ខ្ញុំ ( ក្នុងអនាគត ) ក៏នឹងមិន
មានទេ ក្នុងបច្ចុប្បន្ននេះទៀត ក៏មិនមានដល់ខ្ញុំដែរ ។

បណ្តាបទទាំងនោះ បទថា **ឧបាសិតា** សេចក្តីថា សប្បុរសក៏ខ្ញុំបម្រើហើយ គឺចូលទៅអង្គុយជិតដោយការប្រណិប័តន៍ ។

បុរសទាំងឡាយជាអ្នកប្រកបដោយគុណ មានសីលជាដើម ដែលស្ងប់រម្ងាប់ហើយ ឈ្មោះថាសប្បុរស បានដល់ ព្រះអរិយបុគ្គលទាំងឡាយ មានព្រះសារីបុត្តត្ថេរជាដើម ។

បទថា **សប្បុរិសា** នេះ ព្រះថេរៈសម្តែងដល់ការដល់ព្រមដោយចក្រ ២ ដំបូងរបស់ខ្លួន អធិប្បាយថា វៀរចក្ក គឺ ការនៅក្នុងប្រទេសដែលសមគួរ និងការចូលទៅសេពគប់សប្បុរស រមែងកើតមិនបាន ។

បទថា **សុតា ធម្មា** សេចក្តីថា ធម៌ដែលបដិសំយុត្តដោយសច្ចៈ និង

---

១-ក្នុងអបទានជា ព្រះគិរិបុន្នាគិយត្ថេរ ។

បដិច្ចសមុប្បាទជាដើម ដែលខ្ញុំចូលទៅទ្រទ្រង់ហើយ ដោយសោតទ្វារ ។ ព្រះថេរៈកាលសម្តែងភាពជាពហូសូតរបស់ខ្លួន ទើបសម្តែងសម្បត្តិ គឺចក្រ ២ ខាងក្រោយដោយបទថា **សុតា ធម្មា** ដូច្នេះ ។

បទថា **អភិណ្ហសោ** សេចក្តីថា ដោយច្រើន គឺមិនមែនម្តងម្កាល ។

ពាក្យនេះ បណ្ឌិតគប្បីប្រកបចូលក្នុងបទថា **ឧចាសិតា សប្បុរិសា** ផងដែរ ។

បទថា **សុត្វាន បដិបជ្ជិស្សំ អញ្ជសំ អមតោគធំ** សេចក្តីថា ខ្ញុំស្តាប់ធម៌ទាំងនោះហើយ កំណត់រូបធម៌និងអរូបធម៌ តាមដែលត្រាស់ទុកក្នុងទេសនានោះ ដោយលក្ខណៈរបស់ខ្លួនជាដើម ចម្រើនវិបស្សនាដោយលំដាប់ប្រព្រឹត្តទៅ គឺសម្រេចដល់ផ្លូវអដ្ឋង្គិកមគ្គដ៏ត្រង់ ឈមចុះកាន់អមតៈ គឺជាទីតាំងនៃព្រះនិព្វាន បានដល់ ញុំាងព្រះនិព្វានឲ្យដល់ព្រម ។

បទថា **ភវរាគហតស្ស មេ សតោ** សេចក្តីថា កាលខ្ញុំមានសតិបរិបូណ៌ហើយ កម្ចាត់ គឺចូលទៅទម្លាយនូវការត្រេកអរក្នុងភព គឺតណ្ហាក្នុងសង្សារដែលមានខាងដើមនិងទីបំផុត ដែលបុគ្គលតាមចូលទៅកំណត់ដឹងមិនបាន ម្យ៉ាងទៀត បានដល់ មានការត្រេកអរក្នុងភពដែលមគ្គដ៏ប្រសើរកម្ចាត់ហើយ ។

បទថា **ភវរាគោ បុន មេ ន វិជ្ជតិ** សេចក្តីថា ព្រោះហេតុនោះឯងតម្រេកក្នុងភព រមែងមិនមានដល់ខ្ញុំក្នុងបច្ចុប្បន្ននេះទៀតឡើយ ។

បទថា **ន ចាហុ ន មេ ភវិស្សតិ ន ច មេ ឯតរហិ វិជ្ជតិ** សេចក្តីថា

សូម្បីតម្រេកក្នុងភពមានដល់ខ្ញុំ ក្នុងកាលជាបុថុជ្ជន និងក្នុងកាលដែលខ្ញុំនៅជាសេក្ខបុគ្គលក៏ពិត តែចាប់តាំងពីខ្ញុំបានសម្រេចអគ្គមគ្គហើយ តម្រេកក្នុងភពរមែងមិនមាននិងមិនមានហើយ គឺមិនមានដល់ខ្ញុំនិងមិនមានក្នុងបច្ចុប្បន្ន គឺក្នុងកាលឥឡូវនេះ អធិប្បាយថា ខ្ញុំលះភវរាគៈបានហើយ ។ ដោយពាក្យថា **ភវរាគ** នោះឯង ឈ្មោះថាព្រះថេរៈពោលដល់ការមិនមាននៃកិលេសមានមានះជាដើម ព្រោះកិលេស មានមានះជាដើម តាំងនៅក្នុងទីតែមួយជាមួយភវរាគៈនោះ ព្រោះហេតុនោះ ស្មើគ្នានឹងព្រះថេរៈសម្តែងថា លោកអស់សំយោជនៈក្នុងភពហើយ ដោយប្រការទាំងពួង ។

អដ្ឋកថា កណ្ហទិន្នត្ថេរគាថា ចប់

វគ្គទី ៣ ចប់

# ថេរគាថា ឆក្កនិបាត

## ចតុត្ថវគ្គ

### មិគសិរត្ថេរគាថា

[ ១៥២ ] កាលដែលខ្ញុំបួសក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធ ក៏បានរួចស្រឡះ ( ចាកកិលេស ) បានកន្លងកាមធាតុ កាលព្រះពុទ្ធជាបុគ្គលប្រសើរកំពុងពិនិត្យពិចារណា ចិត្តរបស់ខ្ញុំក៏បានរួចផុតចាកកិលេស វិមុត្តិរបស់ខ្ញុំលែងកម្រើក ព្រោះអស់ទៅនៃសំយោជនៈទាំងពួង ។

**មិគសិរត្ថេរ ។**

## វគ្គទី ៤

### អដ្ឋកថា

### មិគសិរត្ថេរគាថា

[ ១៥២ ] គាថារបស់ព្រះមិគសិរត្ថេរ មានពាក្យផ្ដើមថា **យតោ អហំ បព្វជិតោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយទុកក្នុងភពនោះៗ ។ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាកស្សបៈ កើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវភាពជាអ្នកដឹងក្ដីហើយ ថ្ងៃមួយឃើញព្រះសាស្ដា មានចិត្តជ្រះថ្លា បានថ្វាយស្បូវ

៨ ក្តាប់ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ បដិសន្ធិក្នុងត្រកូលព្រាហ្មណ៍ក្នុងកោសលរដ្ឋ មានឈ្មោះថាមិគសិរ ព្រោះកើតក្នុងមិគសិរនក្ខត្តឫក្ស ចម្រើនវ័យហើយ ដល់នូវការសម្រេចក្នុងវិជ្ជានិងសិប្បសាស្រ្តនៃព្រាហ្មណ៍ទាំងឡាយ សិក្សាមន្តឈ្មោះថា ឆវសីសៈ គឺមន្តមើលក្បាលខ្មោច រាយមន្តហើយ យកក្រចកគោះក្បាលរបស់អ្នកស្លាប់ទៅហើយ សូម្បីអស់កាល ៣ ឆ្នាំ ក៏ដឹងបានថា សត្វនេះកើតក្នុងទីឈ្មោះនោះ ។

កុលបុត្តនោះមិនប្រាថ្នាការនៅគ្រប់គ្រងផ្ទះ បួសជាបរិព្វាជក អាស្រ័យវិជ្ជានោះ ជាបុគ្គលដែលសត្វលោកធ្វើសក្ការគោរព មានលាភ ត្រាច់ទៅដល់ក្រុងសាវត្ថី ហើយទៅកាន់សម្នាក់របស់ព្រះសាស្តា កាលប្រកាសអានុភាពរបស់ខ្លួន ទើបក្រាបទូលថា បពិត្រព្រះគោតម ខ្ញុំដឹងទីដែលអ្នកស្លាប់ហើយទៅកើត កាលព្រះមានព្រះភាគត្រាស់សួរថា អ្នកដឹងបានដូចម្តេច ទើបទូលថា ខ្ញុំព្រះអង្គឲ្យគេនាំយកលលាដ៍ក្បាលខ្មោចមក ហើយរាយមន្ត យកក្រចកគោះលលាដ៍ក្បាល រមែងដឹងទីដែលសត្វនោះៗទៅកើត មាននរកជាដើម ។

លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់ឲ្យនាំយកលលាដ៍ក្បាលរបស់ភិក្ខុដែលបរិនិព្វានហើយ មកឲ្យមិគសិរបរិព្វាជក ត្រាស់ថា អ្នកចូរប្រាប់ដល់គតិនៃលលាដ៍ក្បាលនេះថា នេះជាលលាដ៍ក្បាលរបស់អ្នកណា មិគសិរព្រាហ្មណ៍រាយមន្តសម្រាប់មើលលលាដ៍ក្បាលនោះ ហើយគោះដោយក្រចក មិនឃើញ

ទីបំផុត ។ លំដាប់នោះ កាលព្រះសាស្តា ត្រាស់សួរថា អ្នកមិនអាចឬ ទើបទូលថា ខ្ញុំព្រះអង្គសូមសាកល្បងមើលសិន ទោះបីរាយមន្តរឿយៗ ក៏នៅតែមិនដឹងនោះឯង ។ ព្រោះគតិរបស់ព្រះខីណាស្រពដឹងដោយមន្តក្រៅសាសនាបានដូចម្តេច ។ គ្រានោះ ញើសហូរចេញអំពីក្បាលនិងក្លៀករបស់មិគសិរបរិព្វាជក គាត់ខ្មាសហើយឈរស្ងៀម ព្រះសាស្តាត្រាស់ថា អ្នកលំបាកឬបរិព្វាជក ។ បរិព្វាជកទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំលំបាក ខ្ញុំមិនដឹងគតិរបស់លលាដ៍ក្បាលនេះ ចុះព្រះអង្គវិញទ្រង់ដឹងឬ ។ ព្រះសាស្តាត្រាស់ថា តថាគតដឹងគតិរបស់លលាដ៍ក្បាលនេះ សូម្បីក្រៅលែងជាងនេះ ក៏តថាគតដឹង ដូច្នេះហើយត្រាស់ប្រាប់ថាម្ចាស់លលាដ៍នេះដល់នូវព្រះនិព្វានហើយ ។ បរិព្វាជកក្រាបទូលថា សូមទ្រង់ឲ្យវិជ្ជានេះដល់ខ្ញុំ ព្រះមានព្រះភាគត្រាស់ថា បើដូច្នោះ ចូរអ្នកបួសដូច្នេះហើយ ឲ្យបរិព្វាជកនោះបួស ឲ្យប្រកបព្យាយាមក្នុងសមថកម្មដ្ឋាន រួចទ្រង់ទូន្មានវិបស្សនាកម្មដ្ឋានដល់ព្រះថេរៈ ដែលតាំងនៅក្នុងឈាននិងអភិញ្ញាហើយបំពេញវិបស្សនាកម្មដ្ឋាន បានសម្រេចអរហត្តក្នុងកាលមិនយូរឡើយ ។ សមដូចគាថាព័ន្ធ ដែលលោកពោលក្នុងអបទានថា

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយស្បូវ ៨ ក្តាប់
ដល់ព្រះមានព្រះភាគ ព្រះនាមកស្សបៈ ជាខីណាសវព្រាហ្មណ៍
ព្រះអង្គមានព្រហ្មចរិយធម៌នៅរួចហើយ ។ ក្នុងកប្បនេះឯង
ព្រោះហេតុដែលខ្ញុំបានថ្វាយស្បូវ ៨ ក្តាប់ ក្នុងកាលនោះ ខ្ញុំ

មិនដែលស្គាល់ទុគ្គតិ នេះជាផលនៃស្បូវ ៨ ក្តាប់ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយដូច្នេះ[១] ។

ព្រះថេរៈសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផល បានពោលគាថា ២ ថា

កាលដែលខ្ញុំបួសក្នុងសាសានានៃព្រះសម្មាសម្ពុទ្ធ ក៏បានរួចស្រឡះ ( ចាកកិលេស ) បានកន្លងកាមធាតុ កាលព្រះពុទ្ធជាបុគ្គលប្រសើរកំពុងពិនិត្យពិចារណា ចិត្តរបស់ខ្ញុំក៏បានរួចផុតចាកកិលេស វិមុត្តិរបស់ខ្ញុំលែងកម្រើក ព្រោះអស់ទៅនៃសំយោជនៈទាំងពួង ។

បណ្តាបទទាំងនោះ បទថា **យតោ អហំ បព្ពជិតោ សម្មាសម្ពុទ្ធសាសនេ** សេចក្តីថា ខ្ញុំបួសក្នុងព្រះសាសនាក្នុងកាលណា គឺចាប់តាំងពីពេលដែលខ្ញុំបួសហើយ ។

---

១- ក្នុងអបទានជាព្រះ កុសដ្ឋកទាយកត្ថេរ ។

បទថា **វិមុច្ចមានោ ឧគ្គច្ឆិ** សេចក្តីថា កាលខ្ញុំរួចផុតចាកធម៌ដែលជាសង្កិលេស ដោយសមថៈនិងវិបស្សនាជាបឋម ឈ្មោះថា តម្កល់ខ្លួនបានដោយអំណាចនៃធម៌ដ៏ផូរផង់ហើយ កាលតាំងខ្លួនបានយ៉ាងនេះហើយ ឈ្មោះថា បានកន្លងកាមធាតុ គឺឈានកន្លងកាមធាតុបានដោយ អនាគាមិមគ្គដោយចំណែកមួយ ។

បទថា **ព្រហ្មុនោ បេក្ខមានស្ស តតោ ចិត្តំ វិមុច្ចិ មេ** សេចក្តីថា ចិត្តរបស់ខ្ញុំសម្លឹងធម៌របស់ព្រះមានព្រះភាគ ដែលឈ្មោះថា **ព្រហ្មុនោ** ដោយអត្ថថា ប្រសើរបំផុត ព្រោះភាពជាបុគ្គលប្រសើរលើលោក ព្រមទាំងទេវលោក ប្រកបដោយព្រះមហាករុណាថា កុលបុត្តនេះបួសក្នុងសាសនារបស់តថាគតនឹងបដិបត្តិដូចម្តេចហ្ន៎ ដូច្នេះ រួចផុតហើយចាកកិលេសទាំងពួងដោយចំណែកមួយនោះឯង ព្រោះហេតុដែលបានសម្រេចអនាគាមិមគ្គនោះនិងព្រោះសម្រេចអគ្គមគ្គជាក្រោយ ។

បទថា **អកុប្បា មេ វិមុត្តិ** សេចក្តីថា ព្រះថេរៈព្យាករអរហត្តផលថា ព្រោះហេតុដែលចិត្តរបស់ខ្ញុំរួចផុតហើយយ៉ាងនោះឯង គឺព្រោះអស់ទៅ បានដល់ អស់ទៅជុំវិញនៃសំយោជនៈទាំងពួង ទើបវិមុត្តិរបស់ខ្ញុំមិនកម្រើកយ៉ាងនេះដោយប្រការដូច្នេះ ។

អដ្ឋកថា មិគសិរត្ថេរគាថា ចប់

## សិវកត្ថេរគាថា

[ ១៥៣ ] ផ្ទះ គឺអត្តភាពទាំងឡាយ ( ដែលកើត ) រឿយៗ ក្នុងភព នោះៗ ជារបស់មិនទៀង ឥឡូវនេះអាត្មាអញកំពុងតែខំស្វែងរកជាងគឺតណ្ហា អ្នកធ្វើផ្ទះគឺអត្តភាព ការកើតរឿយៗ ជាហេតុនាំមកនូវសេចក្តីទុក្ខ ។ នែជាង ផ្ទះ អ្នកគឺយើងបានឃើញច្បាស់ហើយ អ្នកនឹងធ្វើផ្ទះទៀតមិនបានឡើយ ឆ្អឹង ជំនីរគឺកិលេសទាំងអស់របស់អ្នក យើងបានបំបាក់អស់ហើយ ទាំងហោជាង គឺ អវិជ្ជាទៀតសោត យើងបានរុះរើចោលអស់ហើយ ចិត្តដែលយើងធ្វើឲ្យ វិងស្ងួត ក៏នឹងរលត់ក្នុងភពនេះឯង ។

សិវកត្ថេរ ។

## អដ្ឋកថា

## សិវកត្ថេរគាថា

[ ១៥៣ ] គាថារបស់ព្រះសិវកត្ថេរ មានពាក្យផ្តើមថា **អនិច្ចានិ គហកានិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះ ពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយទុកក្នុងភពនោះៗ ។ ក្នុងសាសនាព្រះ មានព្រះភាគ ព្រះនាមថាវិបស្សី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នក ដឹងក្តីហើយ ។ ថ្ងៃមួយ ឃើញព្រះមានព្រះភាគនិមន្តទៅបិណ្ឌបាត មានចិត្ត ជ្រះថ្លា ទទួលបាត្រហើយ បានថ្វាយនំកុម្មាសរហូតពេញបាត្រ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំង-ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍នាក្រុងរាជគ្រឹះមានឈ្មោះថាសិវកៈ ។ កុលបុត្តនោះចម្រើនវ័យហើយ សម្រេចការសិក្សាក្នុងវិជ្ជា និងសិប្បសាស្ត្រទាំងឡាយ លះបង់កាមទាំងឡាយហើយបួសជាបរិព្វាជកព្រោះភាពជាអ្នកមានអធ្យាស្រ័យបង្អោនទៅក្នុងនេក្ខម្មៈ ត្រាច់ទៅ ចូលគាល់ព្រះសាស្តា ស្តាប់ធម៌ ជាអ្នកបាននូវសទ្ធាបួសហើយ ធ្វើកម្មក្នុងវិបស្សនាហើយ សម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធ ដែលលោកពោលទុកក្នុងអបទានថា

កាលព្រះពុទ្ធព្រះនាមវិបស្សី ទ្រង់ស្វែងរកគុណដ៏ធំ ទ្រង់ស្តេច
ទៅដើម្បីបិណ្ឌបាត ខ្ញុំឃើញបាតទទេហើយ ក៏ដាក់នំឲ្យពេញ
( បាត្រ ) ។ ក្នុងកប្បទី ៩១ អំពីភទ្ទកប្បនេះ ព្រោះហេតុ
ដែលខ្ញុំបានឲ្យនូវកិក្ខាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះ
ជាផលនៃនំ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។
ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផល បានពោល ២ គាថាដោយសេចក្តីថា

ផ្ទះគឺអត្តភាពទាំងឡាយ ( ដែលកើត ) រឿយៗក្នុងភពនោះៗ
ជារបស់មិនទៀង ឥឡូវនេះ អាត្មាអញកំពុងតែខំស្វែងរកជាង

---

១-ក្នុងអបទានជាព្រះ កុម្មាសទាយកត្ថេរ ។

គឺតណ្ហាអ្នកធ្វើផ្ទះគឺអត្តភាព ការកើតរឿយៗជាហេតុនាំមកនូវ
សេចក្តីទុក្ខ ។ នែជាងផ្ទះ អ្នកគឺយើងបានឃើញច្បាស់ហើយ
អ្នកនឹងធ្វើផ្ទះទៀតមិនបានឡើយ ធ្អឹងជំនីរគឺកិលេសទាំងអស់
របស់អ្នក យើងបានបំបាក់អស់ហើយ ទាំងហោជាង គឺអវិជ្ជា
ទៀតសោត យើងបានរុះរើចោលអស់ហើយ ចិត្តដែលយើង
ធ្វើឲ្យវិវដ្តតហើយ ក៏នឹងរលត់ក្នុងភពនេះឯង ។

បណ្តាបទទាំងនោះ បទថា **អនិច្ចានិ គហកានិ តត្ថ តត្ថ បុនប្បុនំ** សេចក្តីថា ផ្ទះទាំងឡាយ បានដល់ ផ្ទះ គឺ អត្តភាពដែលកើតក្នុងភពនោះៗ រឿយៗ ជារបស់មិនទៀង គឺមិនមាំទាំ មិនមាំមួន បានដល់ តាំងនៅក្នុងខណៈតិចតួច ។

បទថា **គហការំ គវេសន្តោ** អធិប្បាយថា កាលខ្ញុំស្វែងរកនាយជាងអ្នកធ្វើផ្ទះ គឺអត្តភាពនេះ បានដល់ មេជាងដែលធ្វើផ្ទះ គឺតណ្ហា បានអន្ទោលទៅអស់កាលមានប្រមាណប៉ុណ្ណោះ ។

បទថា **ទុក្ខា ជាតិ បុនប្បុនំ** នេះ ជាពាក្យសម្តែងហេតុនៃការស្វែងរកមេជាងអ្នកធ្វើផ្ទះ ព្រោះឈ្មោះថាជាតិ នេះជាទុក្ខក្នុងការចូលដល់រឿយៗ ព្រោះលាយទៅដោយជរា ព្យាធិនិងមរណៈ កាលខ្ញុំនៅស្វែងរកជាងផ្ទះនោះ មិនទាន់ជួប ជាតិក៏មិនទាន់អស់ ដូច្នោះ កាលខ្ញុំស្វែងរកជាងអ្នកសាងផ្ទះនោះ ទើបខ្ញុំត្រាច់ទៅ ។

បទថា **គហការក ទិដ្ឋោសិ** សេចក្តីថា នែជាងផ្ទះ ឥឡូវនេះ ខ្ញុំឃើញ

អ្នកហើយដោយក្នុក គឺអរិយមគ្គដែលធ្វើឲ្យឃើញ ។

បទថា **បុនគេហំ** សេចក្ដីថា អ្នកមិនធ្វើ គឺមិនសាងផ្ទះរបស់ខ្ញុំ ពោល គឺអត្តភាពក្នុងសង្សារវដ្ដនេះ តទៅទៀតបានឡើយ ។

បទថា **សព្វា តេ ផាសុកា ភគ្គា** សេចក្ដីថា ឆ្អឹងជំនីរ គឺកិលេសទាំង ពួងរបស់អ្នកខ្ញុំកាច់ហើយ ដោយមិនមានសេសសល់ ។

បទថា **ថូណិកា ច បធាលិតា** សេចក្ដីថា ឥឡូវនេះ ខ្ញុំបំផ្លាញនូវ ហោជាង ពោលគឺអវិជ្ជានៃផ្ទះគឺអត្តភាពដែលអ្នកធ្វើហើយ ។

បទថា **វិមរិយាធិកតំ ចិត្តំ** សេចក្ដីថា ចិត្តរបស់ខ្ញុំ ដែលខ្ញុំធ្វើឲ្យមាន ទីបំផុតទៅប្រាសហើយគឺឲ្យដល់នូវការមិនជាប់តជាធម្មតា អធិប្បាយថាព្រោះ ហេតុនោះឯង ចិត្តរបស់ខ្ញុំនឹងរលត់ក្នុងភពនេះឯង គឺនឹងត្រូវកម្ចាត់ក្នុងភពនេះ ឯង បានដល់ នឹងរលត់ទៅដោយការរលត់នៃចិត្តចុងក្រោយ ។

## អដ្ឋកថា សិវកត្ថេរគាថា ចប់

## ឧបវាណត្ថេរគាថា

[ ១៥៤ ] ព្រះមុនីជាព្រះអរហន្ត មានព្រះដំណើរល្អក្នុងលោក ទ្រង់អាពាធព្រោះខ្យល់ ម្នាលព្រាហ្មណ៍ ប្រសិនបើអ្នកមានទឹកក្តៅ ចូរអ្នកថ្វាយដល់ព្រះមុនី ។ ( ព្រោះថា ) ព្រះពុទ្ធត្រូវពួកបូជនេយ្យបុគ្គល បូជាហើយ ត្រូវពួកសក្ករេយ្យបុគ្គល ( បុគ្គលដែលគេគប្បីធ្វើសក្ការៈ ) ធ្វើសក្ការៈហើយ ត្រូវពួកអបចិនេយ្យបុគ្គល ( បុគ្គលដែលគេគប្បីកោតក្រែង ) កោតក្រែងហើយ អាត្មាប្រាថ្នានឹងនាំទឹកក្តៅទៅថ្វាយព្រះអង្គ ។

**ឧបវាណត្ថេរ ។**

## អដ្ឋកថា

## ឧបវាណត្ថេរគាថា

[ ១៥៤ ] គាថារបស់ព្រះឧបវាណត្ថេរ មានពាក្យផ្តើមថា **អរហំ សុគតោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈ កុលបុត្តនេះកើតក្នុងត្រកូលក្រីក្រ ដល់នូវភាពជាអ្នកដឹងក្តីហើយ ។ កាលព្រះមានព្រះភាគបរិនិព្វានហើយ ពួកមនុស្ស ទេវតា នាគ គ្រុឌ កុម្ភណ្ឌ យក្ខ និងគន្ធព្វទាំងឡាយ រក្សាធាតុរបស់ព្រះអង្គ សាងព្រះស្តូបសម្រេចដោយរតនៈ ៧ ប្រការ កម្ពស់ ៧ យោជន៍ ។ កុលបុត្តនោះ បានយកនូវសំពត់ដណ្តប់របស់ខ្លួនដែលសស្អាតបរិសុទ្ធ ចងត្រង់ចុងឫស្សីធ្វើជាទង់រួចបូជា ។

យក្ខសេនាបតីឈ្មោះថាអភិសម្មតៈ ដែលទេវតាទាំងឡាយ ចាត់ឲ្យមករក្សាទីបូជាព្រះចេតិយ មានកាយមិនប្រាកដ កាន់ទង់នោះ ទ្រទ្រង់ទុកក្នុងអាកាស ធ្វើប្រទក្សិណព្រះចេតិយ ៣ ជុំ កុលបុត្តឃើញដូច្នោះ មានចិត្តជ្រះថ្លាពន់ប្រមាណ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំង-ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ក្នុងនគរសាវត្ថី បានឈ្មោះថាឧបវាណ ដឹងក្តីហើយ ឃើញពុទ្ធានុភាពក្នុងកាលទ្រង់ទទួលវិហារជេតពន ជាអ្នកបាននូវសទ្ធាបួសហើយ ប្រកបការចម្រើនវិបស្សនា សម្រេចអរហត្តហើយ ជាអ្នកមានអភិញ្ញា ៦ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះជិនស្រីសម្ពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង រុងរឿងដូចគំនរភ្លើង ទ្រង់បរិនិព្វានហើយ ។ មហាជនមកជួបជុំគ្នា បូជាព្រះតថាគត ធ្វើជើងថ្ករដ៏វិចិត្រហើយ លើកតម្កល់ព្រះសរីរៈ ។ ពួកមហាជនទាំងនោះ ព្រមទាំងទេវតានិងមនុស្ស លុះធ្វើព្រះសរីរកិច្ចរួចហើយ ប្រមូលព្រះធាតុ ត្រង់កន្លែងជើងថ្ករនោះ មកធ្វើព្រះពុទ្ធស្តូប ។ ជាន់ទី ១ ធ្វើដោយមាស ជាន់ទី ២ ធ្វើដោយកែវមណី ជាន់ទី ៣ ធ្វើដោយប្រាក់ ជាន់ទី ៤ ធ្វើដោយកែវផលិក ។ ជាន់ ទី ៥ នៃព្រះស្តូបនោះ ធ្វើដោយកែវទទឹម ជាន់ទី ៦ ធ្វើដោយកែវមរកត ខាងលើធ្វើ

ដោយរតនៈគ្រប់យ៉ាង ។ ទ្រនាប់ខ្សាច់ ( នៃព្រះស្តូប ) ធ្វើដោយកែវមណី បន្ទាន់ដៃធ្វើដោយកែវ តួព្រះស្តូបធ្វើដោយមាសសុទ្ធទាំងអស់ កម្ពស់ឡើងទៅលើមួយយោជន៍ ។ កាលនោះ ទេវតាមកជួបជុំគ្នាត្រង់កន្លែងនោះ ហើយប្រឹក្សាជាមួយគ្នាថា ពួកយើងនឹងធ្វើព្រះស្តូប ថ្វាយព្រះលោកនាថ ជាតាទិបុគ្គល ។ ព្រះធាតុឥតមានបែកខ្ញែកចេញពីគ្នា ព្រះសរីរធាតុនៅជាដុំមួយ ( បើដូច្នោះ ) ពួកយើងនឹងធ្វើព្រះស្តូប ស្រោបលើព្រះពុទ្ធស្តូបនេះ ។ ពួកទេវតា បានបង្កើនកម្ពស់មួយយោជន៍ដទៃទៀតដោយកែវទាំង ៧ ប្រការ ព្រះស្តូបនោះទៅជាមានកម្ពស់ ២ យោជន៍ តែងកម្ចាត់បង់នូវងងឹតសព្វៗកាល ។ គ្រានោះ ពួកនាគមកជួបជុំគ្នា ត្រង់កន្លែងព្រះស្តូបនោះ ហើយប្រឹក្សាជាមួយគ្នាថា ពួកមនុស្ស និងទេវតា បានធ្វើព្រះស្តូបថ្វាយព្រះពុទ្ធ ។ ពួកយើងកុំប្រហែសឡើយ ព្រោះមនុស្សនិងទេវតាមិនប្រហែស បើដូច្នោះពួកយើងនឹងធ្វើព្រះស្តូបថ្វាយព្រះលោកនាថ ព្រះអង្គជាតាទិបុគ្គល ។ ពួកនាគទាំងនោះប្រមូលកែវឥន្ទនីល កែវមហានីល ទាំងកែវមណីមានរស្មីរុងរឿងក្នុងទីជាមួយគ្នា ហើយស្រោបព្រះពុទ្ធស្តូប ។ ព្រះពុទ្ធចេតិយទាំងមូលប្រដាប់ដោយកែវមណី មានកម្ពស់ ៣ យោជន៍ តែងផ្សាយចេញនូវពន្លឺក្នុងកាលនោះ ។ កាលនោះ ពួកគ្រុឌមកជួបជុំគ្នា

ហើយប្រឹក្សាជាមួយគ្នាថា ពួកមនុស្ស ទេវតា និងនាគទាំងឡាយ បានធ្វើព្រះស្តូបថ្វាយព្រះពុទ្ធ ។ ពួកយើងកុំប្រហែសឡើយ ព្រោះមនុស្ស និងទេវតាទាំងឡាយមិនប្រហែស បើដូច្នោះ ពួកយើងនឹងធ្វើព្រះស្តូបថ្វាយព្រះលោកនាថ ព្រះអង្គជាតាទិបុគ្គល ។ គ្រុឌទាំងនោះបានធ្វើព្រះស្តូបប្រដាប់ដោយកែវមណីសុទ្ធ ឲ្យជាគ្រឿងស្រោប មានទំហំប៉ុនគ្នា ពួកគ្រុឌទាំងនោះ បានធ្វើពុទ្ធចេតិយ ឲ្យមានកម្ពស់កើនមួយយោជន៍ទៀត ។ ព្រះពុទ្ធស្តូប ទៅជាមានកម្ពស់ ៤ យោជន៍ រុងរឿងញុំាងទិសទាំងអស់ឲ្យភ្លឺដូចព្រះអាទិត្យដែលរះឡើង ។ កាលនោះ ពួកកុម្ភណ្ឌមកជួបជុំគ្នា ហើយប្រឹក្សាជាមួយគ្នាថា ពួកមនុស្ស ទេវតា នាគ និងគ្រុឌទាំងឡាយ បាននាំគ្នាធ្វើព្រះស្តូបដ៏ថ្លៃថ្លាថ្វាយព្រះពុទ្ធដ៏ប្រសើរផ្សេងៗ គ្នា ពួកយើងកុំធ្វេសប្រហែសឡើយ ព្រោះមនុស្ស និងទេវតាទាំងឡាយមិនប្រហែស បើដូច្នោះ ពួកយើងនឹងធ្វើព្រះស្តូបថ្វាយព្រះលោកនាថ ព្រះអង្គជាតាទិបុគ្គល ពួកយើងនឹងស្រោបពុទ្ធចេតិយ ដោយកែវទាំងឡាយតទៅទៀត ។ ពួកកុម្ភណ្ឌទាំងនោះ បានធ្វើពុទ្ធចេតិយឲ្យកើនកម្ពស់មួយយោជន៍ទៅទៀត ព្រះស្តូបទៅជាមានកម្ពស់ ៥ យោជន៍ តែងរុងរឿងក្នុងកាលនោះ ។ លំដាប់នោះ ពួកយក្ខមកជួបជុំគ្នាត្រង់កន្លែងព្រះស្តូបនោះ ហើយប្រឹក្សាជាមួយ

គ្នាថា ពួកមនុស្ស ទេវតា នាគ កុម្ភណ្ឌ និងគ្រុឌទាំងឡាយ បានធ្វើព្រះស្តូបដ៏ថ្លៃថ្លា ថ្វាយព្រះពុទ្ធដ៏ប្រសើរផ្សេងៗគ្នា ពួកយើងកុំធ្វេសប្រហែសឡើយ ព្រោះមនុស្សនិងទេវតាទាំងឡាយមិនប្រហែស ពួកយើងនឹងធ្វើព្រះស្តូបថ្វាយព្រះលោកនាថ ព្រះអង្គជាតាទិបុគ្គល ពួកយើងនឹងស្រោបពុទ្ធចេតិយ ដោយកែវផលិកតទៅទៀត ។ ពួកយក្ខទាំងនោះ បានធ្វើពុទ្ធចេតិយ ឲ្យកើនកម្ពស់មួយយោជន៍ទៅទៀត ព្រះស្តូបទៅជាមានកម្ពស់ ៦ យោជន៍តែងរុងរឿងក្នុងកាលនោះ ។ គ្រានោះ ពួកគន្ធព្វប្រជុំប្រឹក្សា ក្នុងទីជាមួយគ្នាថា ពួកមនុស្ស ទេវតា នាគ គ្រុឌ កុម្ភណ្ឌ និងយក្ខទាំងឡាយ ទាំងអស់គ្នាបានធ្វើព្រះស្តូបថ្វាយព្រះពុទ្ធ ឯពួកយើងមិនបានធ្វើព្រះស្តូប ក្នុងទីនោះឡើយ បើដូច្នោះពួកយើងនឹងធ្វើព្រះស្តូបថ្វាយព្រះលោកនាថ ព្រះអង្គជាតាទិបុគ្គល ។ ពួកគន្ធព្វទាំងនោះ បានធ្វើថ្នាក់ ៧ ជាន់ ដរាបតាំងពីទ្រនាប់ខ្សាច់ឡើងទៅ បានធ្វើព្រះស្តូបសុទ្ធតែជាវិការៈនៃមាសទាំងអស់ក្នុងកាលនោះ ។ ព្រះស្តូបទៅជាមានកម្ពស់ ៧ យោជន៍ តែងរុងរឿងក្នុងកាលនោះ គេឥតដឹងថាយប់ថ្ងៃព្រោះពន្លឺមាននៅសព្វៗកាល ។ ព្រះចន្ទព្រះអាទិត្យព្រមទាំងពួកផ្កាយគ្របសង្កត់ពន្លឺព្រះស្តូបនោះមិនបាន ឯប្រទីបរុងរឿងតែក្នុងទីចម្ងាយ ១០០ យោជន៍ជុំវិញ ។ ក្នុងកាលនោះ មនុស្ស

ទាំងឡាយណាមួយ បូជាព្រះស្តូប មនុស្សទាំងនោះ មិនឡើង កាន់ព្រះស្តូប មនុស្សទាំងនោះ តែងហោះទៅឰដ៏អាកាស ។ មានយក្ខមួយឈ្មោះអភិសម្មតៈ ដែលពួកទេវតាតាំងទុកហើយ ចាំទទួលទង់ឬកម្រងផ្កាឰដ៏ខាងលើ ។ មនុស្សទាំងនោះ មិន ឃើញយក្ខនោះទេឃើញតែកម្រងនៃផ្កាអណ្តែតទៅ លុះឃើញ កម្រងផ្កាទាំងនោះហើយ ក៏ដើរទៅ ពួកមនុស្សទាំងអស់នោះ ឯងតែងទៅកាន់សុគតិ ។ ពួកមនុស្ស ទាំងអ្នកខុសក្នុង សាសនា ទាំងអ្នកជ្រះថ្លាក្នុងសាសនាដែលចង់ឃើញបាដិហារ្យ តែងបូជាព្រះស្តូប ។ គ្រានោះ ខ្ញុំកើតជាអ្នកកម្សត់នៅក្នុងក្រុង ហង្សវតី បានឃើញជនរីករាយហើយ ក៏គិតយ៉ាងនេះក្នុងកាល នោះថា ព្រះស្តូបដែលបញ្ចុះព្រះសរីរធាតុប្រាកដដូចនេះ របស់ ព្រះមានព្រះភាគអង្គណា ព្រះមានព្រះភាគអង្គនុ៎ះ មានបុណ្យ ដ៏លើសលុប ពួកជននេះមានចិត្តត្រេកអរហើយ ចំពោះជនអ្នក ធ្វើនូវសក្ការៈរមែងមិនក្តៅក្រហាយ ។ អាត្មាអញនឹងធ្វើសក្ការៈ ថ្វាយព្រះលោកនាថជាតាទិបុគ្គលដែរ នឹងបានជាព្រះទាយាទក្នុង ធម៌របស់ព្រះលោកនាថអង្គនោះ ក្នុងកាលជាអនាគត ។ ខ្ញុំក៏ លើកឡើងនូវសំពត់របស់ជាងជ្រលក់ ដែលបោកគក់ យ៉ាង ស្អាតញ្ញូរទើងចុងឫស្សី ហើយលើកឡើងជាទង់ឰដ៏អាកាស ។ អភិសម្មតយក្ស រីករាយកាន់ទង់របស់ខ្ញុំ ( បិតនៅ ) ឰដ៏

អាកាស ខ្ញុំឃើញទង់ ដែលត្រូវខ្យល់បក់រវិចហើយ ក៏ញុំាង សេចក្តីរីករាយឲ្យកើតដោយក្រៃលែង ។ ខ្ញុំធ្វើចិត្តឲ្យជ្រះថ្លាចំពោះទង់នោះហើយ ក៏ចូលទៅរកព្រះសមណៈ ថ្វាយបង្គំទូលសួរនូវផលទង់នឹងភិក្ខុនោះ ។

ភិក្ខុនោះ សម្តែងនូវកិរិយាកើតឡើងនៃសេចក្តីត្រេកអរនិងបីតិរបស់ខ្ញុំ ប្រាប់ខ្ញុំថា អ្នកនឹងបានទទួលផលរបស់ទង់នោះសព្វៗកាល ។ សេនាមានអង្គ ៤ គឺ ដំរី សេះ រថ ពលថ្មើរជើងនឹងចោមរោមអ្នក អស់កាលជានិច្ច នេះជាផលនៃការថ្វាយទង់ ។ តូរ្យតន្ត្រី ៦០ ពាន់និងស្គរដែលគេតាក់តែងយ៉ាងល្អនឹងចោមរោមអ្នកអស់កាលជានិច្ច នេះជាផលនៃការថ្វាយទង់ ។ ពួកនារី ៨៦ ពាន់ មានខ្លួនតាក់តែងយ៉ាងល្អ មានសំពត់និងគ្រឿងអម្ពរដ៏វិចិត្រ ពាក់កែវមណីនិងកុណ្ឌល ។ ពួកនារីទាំងនោះមានមុខទូលាយ មានមុខស្រស់ស្រាយ មានត្រគាកសាយ មានជង្គង់រៀវល្អនឹងចោមរោមអ្នក អស់កាលជានិច្ច នេះជាផលនៃការថ្វាយទង់ ។ អ្នកនឹងរីករាយ ក្នុងទេវលោកអស់ ៣០ ពាន់កប្ប នឹងបានសោយទេវរាជ្យ ជាធំជាងទេវតាអស់ ៨០ ដង ។ នឹងបានជាស្តេចចក្រពត្តិ អស់មួយពាន់ដងនឹងសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យជាតិ ។ កន្លងទៅមួយសែនកប្ប ព្រះសាស្តាព្រះនាមគោតម

ទ្រង់សម្ភពក្នុងឱក្កាកត្រកូលនឹងត្រាស់ដឹងក្នុងលោក ។ អ្នកនឹងច្យុតចាកទេវលោកមក ត្រូវកុសលមូលដាស់តឿន ប្រកបដោយបុញ្ញកម្មនឹងកើតជាព្រាហ្មណ៍ ។ អ្នកនឹងលះបោលទ្រព្យ ៨០ កោដិ និងទាសកម្មករជាច្រើន ហើយបួសក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមគោតម ។ អ្នកនឹងមានឈ្មោះថាឧបវាណៈ ញុំាងព្រះសម្ពុទ្ធ ព្រះនាមគោតមដ៏ប្រសើរជាងពួកសក្យៈឲ្យប្រោសប្រាណ ហើយនឹងបានជាសាវករបស់ព្រះសាស្តា ។

កុសលកម្មដែលខ្ញុំធ្វើហើយ ក្នុងវាងមួយសែនកប្ប បានឲ្យផលដល់ខ្ញុំក្នុងជាតិនេះ ខ្ញុំផុតស្រឡះហើយ ( ចាកអាសវធម៌ ) ដូចសន្ទុះនៃព្រួញ ( ដែលផុតស្រឡះចាកធ្នូ ) ខ្ញុំដុតបំផ្លាញនូវកិលេសទាំងឡាយរបស់ខ្ញុំហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

កាលនោះ ព្រះឧបវាណបានជាឧបដ្ឋាករបស់ព្រះមានព្រះភាគ ។ គ្រានោះ អាពាធកើតអំពីខ្យល់ កើតដល់ព្រះសាស្តាហើយ ។ ព្រាហ្មណ៍ឈ្មោះថា ទេវហិត ជាសម្លាញ់របស់ព្រះថេរៈកាលនៅជាគ្រហស្ថ អាស្រ័យនៅក្នុងនគរសាវត្ថី បវារណាព្រះថេរៈដោយបច្ច័យ ៤ ។

លំដាប់នោះ ព្រះឧបវាណស្លៀកស្បង់ហើយកាន់បាត្រនិងចីវរ ចូលទៅកាន់លំនៅរបស់ព្រាហ្មណ៍ៗដឹងថា ព្រះថេរៈមកដោយបំណងណាមួយ ទើប

ពោលថា បពិត្រលោកម្ចាស់ លោកបំណាំងរបស់ណា សូមប្រាប់មកចុះ ។ ព្រះថេរៈ កាលប្រាប់បំណាំងដល់ព្រាហ្មណ៍ បានពោល ២ គាថាដោយសេចក្ដីថា

ព្រះមុនីជាព្រះអរហន្ត មានព្រះដំណើរល្អក្នុងលោក ទ្រង់អាពាធព្រោះខ្យល់ ម្នាលព្រាហ្មណ៍ ប្រសិនបើអ្នកមានទឹកក្ដៅ ចូរអ្នកថ្វាយដល់ព្រះមុនី ។ ( ព្រោះថា ) ព្រះពុទ្ធត្រូវពួកបូជនេយ្យបុគ្គលបូជាហើយ ត្រូវពួកសក្ករេយ្យបុគ្គល ( បុគ្គលដែលគេគប្បីធ្វើសក្ការៈ ) ធ្វើសក្ការៈហើយ ត្រូវពួកអបចិនេយ្យបុគ្គល ( បុគ្គលដែលគេគប្បីកោតក្រែង ) កោតក្រែងហើយ អាត្មាប្រាថ្នានឹងនាំទឹកក្ដៅទៅថ្វាយព្រះអង្គ ។

គាថាទាំង ២ នោះ មានអធិប្បាយថា ព្រះមានព្រះភាគអង្គណា ដែលបុគ្គលដែលគេបូជាក្នុងលោកនេះ គឺទេវតាទាំងឡាយ មានសក្កទេវរាជជាដើម ព្រហ្មមានមហាព្រហ្មជាដើម បូជាហើយ ដែលបុគ្គលដែលគេធ្វើសក្ការៈធ្វើសក្ការៈ ដូចជាព្រះបាទពិម្ពិសារនិងព្រះបាទកោសលជាដើម ធ្វើសក្ការៈហើយ ដែលបុគ្គលដែលគេឱនលំទោនទាំងឡាយ បានដល់ព្រះខីណាស្រពទាំងឡាយ អ្នកស្វែងរកគុណជំឱនលំទោនហើយ ព្រះមានព្រះភាគអង្គនោះឈ្មោះថា ជាព្រះអរហន្ត ព្រោះភាពជាអ្នកឆ្ងាយចាកកិលេសជាដើម ឈ្មោះថា ជាព្រះសុគត ព្រោះយាងទៅល្អជាដើម ជាព្រះសព្វញ្ញូ ជាមុនី ជាសាស្ដានៃយើង ជាទេវតាក្រៃលែងជាងទេវតា ជាសក្កៈក្រៃលែងជាង

សក្កៈ ជាព្រហ្មក្រៃលែងជាងព្រហ្មទាំងឡាយ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះទ្រង់ប្រឈួនព្រោះរោគខ្យល់ គឺព្រោះខ្យល់ជាហេតុ បានដល់ហេតុព្រោះខ្យល់កម្រើក នែព្រាហ្មណ៍ បើអ្នកមានទឹកក្តៅ អាត្មាប្រាថ្នានាំទៅថ្វាយ ដើម្បីរម្ងាប់នូវវាតាពាធ គឺដើម្បីបំបាត់រោគខ្យល់ របស់ព្រះមានព្រះភាគអង្គនោះ ។

ព្រាហ្មណ៍ស្តាប់ដូច្នោះហើយ នាំទឹកក្តៅនិងភេសជ្ជៈដែលសមគួរដល់អាការរបស់រោគ និងសមគួរដល់ការរម្ងាប់រោគខ្យល់បង្អោនចូលទៅថ្វាយដល់ព្រះមានព្រះភាគ ។ រោគរបស់ព្រះសាស្តាស្ងប់ហើយ ព្រោះទឹកក្តៅ និងភេសជ្ជៈនោះ ។ ព្រះមានព្រះភាគទ្រង់ធ្វើអនុមោទនាដល់ព្រាហ្មណ៍នោះដូច្នេះឯង ។

## អដ្ឋកថា ឧបវាណត្ថេរគាថា ចប់

## ឥសិទិន្នត្ថេរគាថា

[ ១៥៥ ] ពួកឧបាសក អ្នកទ្រទ្រង់ព្រះបរិយត្តិធម៌ដែលខ្ញុំជួបហើយ បាននិយាយថា កាមទាំងឡាយជារបស់មិនទៀង តែពួកឧបាសកនោះ នៅត្រេកអរក្រៃពេកក្នុងកែវមណីនិងកុណ្ឌលទាំងឡាយផង ជាអ្នកអាឡោះអាល័យក្នុងកូននិងប្រពន្ធផង ។ ពួកឧបាសកទាំងនោះមិនទាន់ដឹងធម៌ពិតទេគ្រាន់តែចេះនិយាយថា កាមទាំងឡាយជារបស់មិនទៀង ឧបាសកទាំងនោះ មិនទាន់មានកម្លាំងញាណដើម្បីកាត់ផ្តាច់នូវរាគទេ ព្រោះហេតុនោះ បានជានៅជាប់ស្អិតចំពោះកូនប្រពន្ធនិងទ្រព្យសម្បត្តិ ។

ឥសិទិន្នត្ថេរ ។

## អដ្ឋកថា

## ឥសិទិន្នត្ថេរគាថា

[ ១៥៥ ] គាថារបស់ព្រះឥសិទិន្នត្ថេរ មានពាក្យផ្តើមថា **ទិដ្ឋា មយា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយទុកក្នុងភពនោះៗ ។ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាវិបស្សី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ កាន់ផ្ទិតបក់បូជាពោធិព្រឹក្ស ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំង

ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលសេដ្ឋីក្នុងសុណាបរន្តជនបទ មានឈ្មោះថា ឥសិទិន្ន ចម្រើនវ័យហើយ ឃើញបាដិហារ្យក្នុងកាលដែលព្រះសាស្ដាទ្រង់ទទួលខ្លឹមចន្ទន៍ និងកម្រងផ្កា មានចិត្តជ្រះថ្លា ចូលទៅគាល់ព្រះសាស្ដា ស្ដាប់ធម៌ហើយ បានជាព្រះសោតាបន្ន ហើយនៅគ្រប់គ្រងផ្ទះ ទេវតាដែលប្រាថ្នាប្រយោជន៍ចំពោះឥសិទិន្នសេដ្ឋី កាលនឹងដាស់តឿន បានពោល ២ គាថាដូច្នេះថា

*ពួកឧបាសកអ្នកទ្រទ្រង់ព្រះបរិយត្តិធម៌ដែលខ្ញុំជួបហើយ បាននិយាយថា កាមទាំងឡាយជារបស់មិនទៀង តែពួកឧបាសកនោះ នៅត្រេកអរក្រៃពេកក្នុងកែវមណីនិងកុណ្ឌលទាំងឡាយផង ជាអ្នកអាឡោះអាល័យក្នុងកូននិងប្រពន្ធផង ។ ពួកឧបាសកទាំងនោះមិនទាន់ដឹងធម៌ពិតទេគ្រាន់តែចេះនិយាយថាកាមទាំងឡាយជារបស់មិនទៀង ឧបាសកទាំងនោះ មិនទាន់មានកម្លាំងញាណដើម្បីកាត់ផ្ដាច់នូវរាគទេ ព្រោះហេតុនោះបានជានៅជាប់ស្អិតចំពោះកូន ប្រពន្ធនឹងទ្រព្យសម្បត្តិ ។*

បណ្ដាបទទាំងនោះ បទថា **ទិដ្ឋា មយា ធម្មធរា ឧបាសកា កាមា អនិច្ចា ឥតិ ភាសមានា** សេចក្ដីថា ឧបាសកទាំងឡាយ ដែលទ្រទ្រង់នូវបរិយត្តិធម៌ពួកខ្លះក្នុងលោកនេះ ខ្ញុំឃើញហើយ គឺព្រោះហេតុដែលឧបាសកនោះ ជាអ្នកទ្រទ្រង់នូវបរិយត្តិធម៌នោះឯង កាលពោលធម៌ដែលបដិសំយុត្តដោយទោសក្នុងកាមទាំងឡាយថា ឈ្មោះថា កាមទាំងនេះមិនទៀង ជាទុក្ខ

មានការប្រែប្រួលទៅជាធម្មតា ដូច្នេះ តែខ្លួនឯងត្រឡប់ជាមានតម្រេកខ្លាំងក្លាក្នុងកែវមណីនិងក្នុងកុណ្ឌលទាំងឡាយ មានការជាប់ជំពាក់ក្នុងបុត្តនិងភរិយាទាំងឡាយ បានដល់ជាអ្នកត្រេកអរហើយ គឺច្រើនទៅដោយតម្រេកក្នុងកែវមណី និងកុណ្ឌលទាំងឡាយ ឬក្នុងកែវមណី និងកុណ្ឌលដែលខ្លួនសន្សំទុកហើយ មានសេចក្ដីស្នេហាជោកជាំក្នុងបុត្តធីតានិងក្នុងភរិយាទាំងឡាយ អធិប្បាយថា ជាបុគ្គលនិយាយផ្សេងធ្វើផ្សេង ខ្ញុំឃើញហើយ ។

បទថា **យតោ** សេចក្ដីថា ព្រោះឧបាសកទាំងនោះនៅមានសេចក្ដីត្រេកអរក្នុងកែវមណីនិងកុណ្ឌលទាំងឡាយ មានការជាប់ជំពាក់ក្នុងបុត្តនិងភរិយាទាំងឡាយ ដូច្នោះ ឧបាសកទាំងនោះ រមែងឈ្មោះថា មិនដឹងពិតនូវធម៌ក្នុងព្រះពុទ្ធសាសនានេះ តាមសេចក្ដីពិត យ៉ាងពិតប្រាកដ គឺដោយចំណែកមួយ អធិប្បាយថា ឧបាសកទាំងឡាយជាអ្នកមានសភាពយ៉ាងនោះ ទោះបីបានពោលថា កាមទាំងឡាយជារបស់មិនទៀង ក៏នៅមានប្រក្រតីជាប់ជំពាក់មានការឃើញថាស្អាត ។

បទថា **រាគញ្ច តេសំ ន ពលត្ថិ ឆេត្តុំ** សេចក្ដីថា ព្រោះកម្លាំងនៃញាណ ដើម្បីកាត់ គឺដើម្បីចូលទៅជកនូវរាគៈនោះ របស់ឧបាសកទាំងនោះមិនមាន ដូច្នោះ គឺដោយហេតុនោះ ទើបឧបាសកទាំងនោះជាប់ គឺជាប់ហើយដោយអំណាចនៃតណ្ហា បានដល់ ជាប់ស្អិតមិនអាចលះកូនប្រពន្ធ និងទ្រព្យសម្បត្តិបាន ព្រោះហេតុនោះ ទើបទេវតាពោលពាក្យនេះដោយអាងអ្នកដទៃតែសំដៅដល់ឧបាសកនោះឯង ។

ឧបាសកនោះស្តាប់ពាក្យនោះហើយ កើតសេចក្តីសង្វេគ បួសហើយបាន សម្រេចអរហត្ត ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោល ទុកនៅក្នុងអបទានថា

ខ្ញុំមានចិត្តរីករាយចំពោះពោធិព្រឹក្សដ៏ឧត្តម របស់ព្រះមានព្រះ ភាគព្រះនាមវិបស្សី ហើយយកផ្កិតទៅបក់ថ្វាយនូវពោធិព្រឹក្ស ដ៏ឧត្តម ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែល ខ្ញុំបានបក់នូវពោធិព្រឹក្សដ៏ឧត្តមក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ ទុគ្គតិ នេះជាផលនៃការបក់ផ្កិត ។ កិលេសទាំងឡាយខ្ញុំដុត បំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិ បត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្តផលក៏បានពោល គាថាទាំងនេះឯង ដូច្នេះ ។

## អដ្ឋកថា ឥសិទិន្នត្ថេរគាថា ចប់

---

១- ក្នុងអបទានជាព្រះ សុមនវីជនិយត្ថេរ ។

## សម្ពុលកច្ឆានត្ថេរគាថា

[ ១៥៦ ] ភ្លៀងបង្អុរចុះផង មេឃគ្រហឹមលាន់ឮលឺៗផង ( ក្នុងពេលនោះ ) អាត្មាអញ នៅតែម្នាក់ឯងក្នុងរូងភ្នំដែលគួរខ្លាច កាលដែលអាត្មាអញនោះ នៅក្នុងរូងភ្នំដែលគួរខ្លាចតែម្នាក់ឯង ភ័យក្តី សេចក្តីតក់ស្លុតក្តី សេចក្តីព្រឺរោមក្តី មិនមានទេ ។ កាលអាត្មាអញនៅម្នាក់ឯង ក្នុងរូងភ្នំដែលគួរខ្លាច ភ័យក្តី សេចក្តីតក់ស្លុតក្តី សេចក្តីព្រឺរោមក្តី មិនមានឡើយ នេះជាធម្មតារបស់អាត្មាអញ ។

សម្ពុលកច្ចានត្ថេរ ។

## អដ្ឋកថា

## សម្ពុលកច្ឆានត្ថេរគាថា

[ ១៥៦ ] គាថារបស់ព្រះសម្ពុលកច្ចានត្ថេរ មានពាក្យផ្តើមថា **ទេវោ ច** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយទុកក្នុងភពនោះៗ ។ ក្នុងទីបំផុតនៃកប្បទី ៩៤ អំពីកប្បនេះ កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូលដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ ឃើញព្រះបច្ចេកពុទ្ធព្រះនាមថាសតរង្សី ចេញអំពីនិរោធ ត្រាច់បិណ្ឌបាត មានចិត្តជ្រះថ្លាហើយ បានប្រគេនផ្លែត្នោត ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និង មនុស្ស

ទាំងឡាយ ក្នុងពុទ្ធុប្បាទនេះកើតក្នុងត្រកូលគហបតី នាដែនមគធៈ ឈ្មោះថា សម្ពុលៈ ព្រោះភាពដែលកុលបុត្តនេះជាកច្ចានគោត្ត ទើបមាននាមប្រាកដថា សម្ពុលកច្ចានៈ ។

លុះកុលបុត្តនោះចម្រើនវ័យហើយ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា បាននូវសទ្ធាបួសហើយ ចម្រើនវិបស្សនានៅក្នុងគុហាភ្នំឈ្មោះភេរវៈជិតព្រៃហិមពាន្ត ។ ថ្ងៃមួយ មហាមេឃតាំងឡើងពុំជួកាល ពពករាប់រយរាប់ពាន់ស្រទាប់ ផ្គរគំរាម ផ្លេកបន្ទោរដាលប្រវាត់ ផ្គរគ្រហឹមគ្អឹលៗ សម្តែងអាកប្បកិរិយានឹងធ្លាក់ភ្លៀង ។ សត្វទាំងឡាយ មានខ្លាឃ្មុំ ចចក ក្របី និងដំរីជាដើម ស្តាប់សំឡេងនោះហើយ ភិតភ័យតក់ស្លុតស្រែកដោយការខ្លាច ។

ឯព្រះថេរៈមិនមានអាល័យក្នុងរាងកាយនិងជីវិត ប្រាសចាកការព្រឺរោមព្រឺស្បែក មិនដាក់ចិត្តក្នុងសំឡេងនោះ ព្រោះប្រារព្ធវិបស្សនា ប្រាថ្នាចម្រើនវិបស្សនាតែម្យ៉ាង ជាអ្នកមានចិត្តតាំងមាំ ព្រោះបានឧតុជាទីសប្បាយ ព្រោះការក្តៅអំពីឧតុក៏ស្ងប់រម្ងាប់ទៅ ខ្វល់ខ្វាយក្នុងវិបស្សនាហើយសម្រេចអរហត្តមួយអន្លើដោយអភិញ្ញា ៦ ក្នុងខណៈនោះឯង សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះសម្ពុទ្ធមានព្រះភាគជាសយម្ភូ ទ្រង់មានរស្មីច្រើន ព្រះអង្គឈ្នះកិលេសមារ ទ្រង់ប្រាថ្នានូវវិវេក ស្តេចចេញទៅដើម្បីគោចរ ។ ខ្ញុំកាន់ផ្លែឈើក្នុងដៃ លុះឃើញព្រះពុទ្ធដ៏ប្រសើរជាងពួកនរៈហើយ ក៏ចូលទៅជិត ខ្ញុំមានចិត្តជ្រះថ្លា មានចិត្ត

រីករាយ បានថ្វាយនូវផ្លែឈើឥតទងនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈសម្រេចអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួនកើតនូវសោមនស្ស កាលព្យាករអរហត្តផលដោយអំណាចនៃឧទាន បានពោល ២ គាថាដូច្នេះថា

ភ្លៀងបង្អុរចុះផង មេឃគ្រហឹមលាន់គ្អឹលៗផង ( ក្នុងពេលនោះ ) អាត្មាអញ នៅតែម្នាក់ឯងក្នុងរូងភ្នំដែលគួរខ្លាចកាលដែលអាត្មាអញនោះនៅក្នុងរូងភ្នំដែលគួរខ្លាចតែម្នាក់ឯង ភ័យក្តី សេចក្តីតក់ស្លុតក្តី សេចក្តីព្រឺរោមក្តី មិនមានទេ ។ កាលអាត្មាអញនៅម្នាក់ឯង ក្នុងរូងភ្នំដែលគួរខ្លាច ភ័យក្តី សេចក្តីតក់ស្លុតក្តី សេចក្តីព្រឺរោមក្តី មិនមានឡើយ នេះជាធម្មតារបស់អាត្មាអញ ។

បណ្តាបទទាំងនោះ បទថា **ទេវោ ច វស្សតិ ទេវោ ចគឡគឡាយតិ** សេចក្តីថា មេឃ គឺភ្លៀងក៏ធ្លាក់ ផ្គរក៏គ្រហឹម ដោយសំឡេងខ្លាំងគ្អឹលៗ បទថា **គឡគឡា** នេះជាសំឡេងផ្គរ ។ បទថា **ឯកកោ ចាហំ ភេរវេ ពិលេ**

---

១ ក្នុងអបទានជាព្រះ អវដផលិយត្ថេរ ។

**វិហរាមិ** សេចក្ដីថា ខ្ញុំតែម្នាក់ឯង មិនមានទូវសម្លាញ់នៅក្នុងរូងភ្នំ ដែលមានភ័យតាំងនៅចំពោះមុខ កាលខ្ញុំនោះមានសភាពយ៉ាងនេះ ការខ្លាច ការតក់ស្លុត ការព្រឺរោមព្រឺស្បែក រមែងមិនមានដល់ខ្ញុំដែលជាអ្នកមានសតិ បានដល់ ការខ្លាចដែលសន្មតថា ការខ្លាចនៃចិត្តក្ដី ការខ្លាចនៃរាងកាយ ដែលមានការខ្លាចនោះជានិមិត្តក្ដី ភាពជាអ្នកមានរោមបះឡើងក្ដី រមែងមិនមានដល់ខ្ញុំ ព្រោះហេតុអ្វី ព្រោះព្រះថេរៈពោលនូវហេតុនោះថា **ធម្មតា មមេសា** នេះជាធម្មតារបស់អាត្មាអញ ។

ពិតហើយ ព្រះថេរៈព្យាករអរហត្តផលថា ភ័យជាដើម គប្បីមានដល់បុគ្គលដែលមិនបានកំណត់ដឹងវត្ថុ ព្រោះមិនទាន់លះឆន្ទរាគៈក្នុងវត្ថុនោះបាន តែភ័យក្នុងវត្ថុនោះ ខ្ញុំកំណត់ដឹងហើយដោយប្រការទាំងពួង ទាំងឆន្ទរាគៈក្នុងវត្ថុនោះ ក៏ខ្ញុំកាត់ផ្ដាច់ហើយ ព្រោះហេតុនោះទើបភ័យជាដើមមិនមាន នេះជាធម្មតារបស់ខ្ញុំ គឺសេចក្ដីនេះ ជាសភាពប្រក្រតីរបស់ខ្ញុំ ។

## អដ្ឋ[illegible]ថា សម្ពុលកច្ចានត្ថេរគាថា ចប់

## វិតកត្ថេរគាថា

[ ១៥៧ ] ចិត្តរបស់ភិក្ខុណាមួយ មានឧបមាដោយភ្នំថ្ម តាំងនៅស៊ប់ រមែងមិនញាប់ញ័រ ( ដោយលោកធម៌ ) ចិត្តដែលប្រាសចាកសេចក្តីត្រេកអរ ក្នុងវត្ថុទាំងឡាយដែលគួរត្រេកអរ រមែងមិនប្រទូស្តក្នុងវត្ថុដែលគួរប្រទូស្ត ។ បុគ្គលណា អប់រំចិត្តបានយ៉ាងនេះ បុគ្គលនោះ នឹងដល់នូវសេចក្តីទុក្ខអំពីណាបាន ។ ចិត្តរបស់អាត្មាអញ មានឧបមាដោយភ្នំថ្ម តាំងនៅស៊ប់ រមែងមិនញាប់ញ័រ ចិត្តអាត្មាអញប្រាសចាកសេចក្តីត្រេកអរក្នុងវត្ថុទាំងឡាយដែលគួរត្រេកអរ រមែងមិនប្រទូស្តក្នុងវត្ថុដែលគួរប្រទូស្ត ។ អាត្មាអញ អប់រំចិត្តបានយ៉ាងនេះ អាត្មាអញនឹងដល់នូវសេចក្តីទុក្ខអំពីណាបាន ។

**វិតកត្ថេរ ។**

## អដ្ឋកថា

## វិតកត្ថេរគាថា

[ ១៥៧ ] គាថារបស់ព្រះវិតកត្ថេរ មានពាក្យផ្តើមថា **កស្ស សេលូបមំ ចិត្តំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយទុកក្នុងភពនោះៗ ។ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថា វិបស្សី ចិញ្ចឹមជីវិតជាឧទ្យានបាល ក្នុងពន្ធុមតីនគរ ។ ថ្ងៃមួយ ឃើញព្រះមានព្រះភាគយាងទៅតាមអាកាស មានចិត្តជ្រះ

ថ្វា មានបំណងនឹងថ្វាយផ្លែដូង ។ ព្រះសាស្តាកាលទ្រង់អនុគ្រោះ ឈរប្រ-ថាប់នៅក្នុងអាកាសនោះឯង ទទួលប្រគេនហើយ ។ កុលបុត្តនោះ ថ្វាយផ្លែដូងនោះហើយ កើតនូវបីតិសោមនស្សដ៏ឧឡារ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍នាដែនកោសលមានឈ្មោះថាខិតកៈ ដល់នូវភាពជាអ្នកដឹងក្តីហើយ ស្តាប់ធម៌ក្នុងសម្នាក់នៃព្រះសាស្តា បាននូវសទ្ធាបួសហើយ រៀនកម្មដ្ឋានក្នុងព្រៃ ព្យាយាមសម្រេចអរហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលនោះខ្ញុំជាញោមវត្ត ក្នុងនគរពន្ធុមតី បានឃើញព្រះពុទ្ធ
ទ្រង់ប្រាសចាកធូលី កំពុងស្តេចទៅឰដ៏អាកាស ។ ខ្ញុំបានយក
ផ្លែដូងទៅថ្វាយដល់ព្រះពុទ្ធដ៏ប្រសើរ ព្រះពុទ្ធទ្រង់មានយសធំ
ឋិតនៅឰដ៏អាកាស ទ្រង់ទទួល ( ផ្លែដូងនោះ ) ។ ខ្ញុំមាន
ការកើតបីតិជាទីនាំមកនូវសេចក្តីសុខក្នុងបច្ចុប្បន្ន ព្រោះថ្វាយ
នូវផ្លែដូងដល់ព្រះពុទ្ធដោយចិត្តជ្រះថ្លា ។ កាលនោះ ខ្ញុំបាននូវ
បីតិដ៏ធំទូលាយផង នូវសេចក្តីសុខដ៏ឧត្តមផង រតនៈតែងកើត
ឡើងដល់ខ្ញុំដែលកើតក្នុងភពនោះៗ ។ ក្នុងកប្បទី ៩១ អំពី
កប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែក្នុងកាលនោះ ខ្ញុំមិន
ដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ចក្ខុរបស់ខ្ញុំដ៏បរិ
សុទ្ធដូចជាទិព្វ ខ្ញុំជាអ្នកឈ្លាសវៃក្នុងសមាធិ ដល់នូវអភិញ្ញា

បារមី នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុត បំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលព្រះថេរៈសម្រេចអរហត្តហើយ សម្ងំដោយសេចក្ដីសុខដែលកើតអំពីផល និងសេចក្ដីសុខក្នុងព្រះនិព្វាន លោកជាអ្នកប្រារព្ធសេចក្ដីព្យាយាមទៅកាន់ដងព្រៃ ដើម្បីសង្គ្រោះភិក្ខុដែលនៅក្នុងដងព្រៃនោះ ទើបពោលគាថា ២ ដូច្នេះថា

ចិត្តរបស់ភិក្ខុណាមួយមានឧបមាដោយភ្នំថ្ម តាំងនៅស៊ប់រមែងមិនញាប់ញ័រ ( ដោយលោកធម៌ ) ចិត្តដែលប្រាសចាកសេចក្ដីត្រេកអរក្នុងវត្ថុទាំងឡាយដែលគួរត្រេកអរ រមែងមិនប្រទូស្តក្នុងវត្ថុដែលគួរប្រទូស្ត ។ បុគ្គលណាអប់រំចិត្តបានយ៉ាងនេះ បុគ្គលនោះនឹងដល់នូវសេចក្ដីទុក្ខអំពីណាបាន[២] ។

បណ្ដាបទទាំងនោះ បទថា **កស្ស សេលូបមំ ចិត្តំ ឋិតំ ឆានុប្បកម្បតិ** សេចក្ដីថា កាលអ្នកទាំងឡាយនៅក្នុងដងព្រៃ ចិត្តរបស់ភិក្ខុណាឈ្មោះថាតាំងមាំ ព្រោះបានសម្រេចអគ្គផល ព្រោះជាអ្នកដល់នូវភាពជាអ្នកមានវសីដោយមិនមានការញាប់ញ័រសព្វយ៉ាងដោយលោកធម៌ទាំងពួង ឧបមា

---

១-ក្នុងអបទានជាព្រះ នាលិកេរផលទាយកត្ថេរ ។ តែក្នុងទីខ្វះ លោកលើកយក ព្រះលពុជផលទាយកត្ថេរមកទុកក្នុងទីនេះ ។ ២-ជាទូទៅក្នុងទុកនិបាតលោកតែងលើកយកគាថាទាំងពីរមក តែក្នុងទីនេះ លោកលើកមកតែមួយគាថាប៉ុណ្ណោះ ។

ដូចក្អំបុកតាន់រមែងមិនញាប់ញ័រ គឺមិនកម្រើក ។

ឥឡូវនេះ ដើម្បីសម្តែងអាការដែលមិនញាប់ញ័រនៃចិត្តនោះ មួយអន្លើ ដោយហេតុនោះ ទើបព្រះថេរៈពោលពាក្យជាដើមថា **វិរត្តំ** ប្រែថា ចិត្តដែលប្រាសចាកតម្រេក ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **វិរត្តំ រជនីយេសុ** សេចក្តីថា មិនត្រេកអរក្នុងអារម្មណ៍ដែលជាទីតាំងនៃតម្រេក គឺក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជាហេតុឲ្យកើតឡើងនៃតម្រេក ដោយអរិយមគ្គ ពោលគឺវិរាគធម៌ អធិប្បាយថា មានការត្រេកអរក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នោះ ដែលលោកដកឡើងហើយដោយប្រការទាំងពួង ។

បទថា **កុប្បនីយេ** សេចក្តីថា ក្នុងអារម្មណ៍ដែលជាទីតាំងនៃការអាក់អន់បានដល់ ក្នុងអារម្មណ៍ជាទីតាំងនៃអាឃាតទាំងពួង។ បទថា **ន កុប្បតិ** សេចក្តីថា មិនប្រទូស្ត គឺមិនកាន់យកអាការដែលខុសប្រក្រតី ។ បទថា **យស្សេវំ ភាវិតំ ចិត្តំ** សេចក្តីថា ចិត្តគឺចិត្តដែលព្រះអរិយបុគ្គលណាអប់រំហើយយ៉ាងនេះ គឺដោយន័យដូចពោលហើយដោយភាពជាតាទិបុគ្គល ។

បទថា **កុតោ តំ ទុក្ខមេស្សតិ** សេចក្តីថា ទុក្ខនឹងចូលដល់បុគ្គលនោះអំពីសត្វ ឬអំពីសង្ខារណា អធិប្បាយថា ទុក្ខរមែងមិនមានដល់បុគ្គលបែបនោះ ។

ព្រះខិតកត្ថេរ កាលនឹងវិសជ្ជនាបញ្ហាត្រឹមតែសួរដោយមិនចំពោះ យ៉ាងនេះ ធ្វើឲ្យបង្អោនចូលទៅក្នុងខ្លួន ទើបព្យាករអរហត្តផលដោយគាថាទី ២ មាន

បទថា **មម សេល្លបមំ ចិត្តំ** ដូច្នេះជាដើម ។ ពាក្យនោះមានអត្ថដូចខ្ញុំពោលទុកហើយ ។

## អដ្ឋកថា ខិតកត្ថេរគាថា ចប់

## សោណពោដិរិយបុត្តត្ថេរគាថា

[ ១៥៨ ] រាត្រី ជារបៀបនៃនក្ខត្តឫក្ស ( មានជរាបណា ) វិញ្ញូជន មិនគួរដេកលក់ដរាបនោះទេ រាត្រីនុ៎ះ វិញ្ញូជនគួរប្រាថ្នាដើម្បីប្រតិបត្តិ ។ ប្រសិនបើ ដំរីជាន់អញ ដែលធ្លាក់ចុះចាកកនៃដំរី សេចក្តីស្លាប់របស់អញក្នុងសង្គ្រាម ( យ៉ាងនេះ ) ប្រសើរជាងអាត្មាអញ ដែលចាញ់ហើយរស់នៅ មិនប្រសើរសោះឡើយ ។

សោណពោដិរិយបុត្តត្ថេរ ។

## អដ្ឋកថា

## សោណពោដិរិយបុត្តត្ថេរគាថា

[ ១៥៨ ] គាថារបស់ព្រះសោណពោដិរិយបុត្តត្ថេរ មានពាក្យផ្តើមថា **នតាវ សុបិតុំ ហោតិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាសិខី កុលបុត្តនេះចិញ្ចឹមជីវិតដោយធ្វើជាព្រានព្រៃ ។ ថ្ងៃមួយ ឃើញព្រះសាស្តា មានចិត្តជ្រះថ្លាបានថ្វាយផ្លែទ្រយឹងដល់ព្រះសាស្តា ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនមេស្រុកឈ្មោះពោដិរិយៈ ក្នុងនគរកបិល

ពស្តុ មានឈ្មោះថា សោណៈ ។ ចម្រើនវ័យហើយ បានជាសេនាបតីរបស់ព្រះរាជាព្រះនាមកទ្ទិយសក្យៈ ។

ក្នុងកាលតមក កាលព្រះបាទកទ្ទិយៈសាងព្រះផ្នួសហើយ ដោយន័យដូចពោលហើយ ខាងដើមនោះឯង ។ សេនាបតីក៏បួសតាម ដោយគិតថា ឈ្មោះថាព្រះរាជាក៏ទ្រង់ចេញបួស ចំណង់បើអញនៅគ្រប់គ្រងផ្ទះ មានប្រយោជន៍អ្វី ។ កាលបួសហើយ បែរជាអ្នកត្រេកអរក្នុងការដេក មិនព្យាយាមប្រកបភាវនា ។ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអនុបិយម្ពវ័នមហាវិហារ ទ្រង់ផ្សាយឱភាសទៅ ញុំាំងសតិឲ្យកើតដល់ព្រះសោណបោដិរិយត្ថេរ ដោយឱភាសនោះ កាលទ្រង់ទូន្មានព្រះថេរៈ ដោយព្រះគាថានេះ បានត្រាស់ ២ គាថាដោយសេចក្ដីថា

> រាត្រីជារបៀបនៃនក្ខត្តឫក្ស ( មានជរាបណា ) វិញ្ញូជន មិនគួរដេកលក់ជរាបនោះទេ រាត្រីនុ៎ះ វិញ្ញូជនគួរប្រាថ្នាដើម្បីប្រតិបត្តិ ។ ប្រសិនបើដំរីជាន់អញដែលធ្លាក់ចុះចាកកនៃដំរី សេចក្ដីស្លាប់ របស់អញក្នុងសង្គ្រាម ( យ៉ាងនេះ ) ប្រសើរជាងអាត្មាអញ ដែលចាញ់ហើយរស់នៅ មិនប្រសើរសោះឡើយ[១] ។

បណ្ដាបទទាំងនោះ បទថា **ន តាវ សុបិតុំ ហោតិ រត្តិ នក្ខត្តមាលិនី** សេចក្ដីថា កាលភិក្ខុដែលមានជាតិនៃវិញ្ញូជន បានហើយនូវខណៈទី ៩ ដែល

១-គាថាទី ២ ព្រះថេរៈជាអ្នកពោល ។

វៀរចាកខណៈ មិនមែនកាល ៨ យ៉ាង តាំងនៅហើយ គង់ធ្វើអរហត្តឲ្យនៅក្នុងកណ្ដាប់ដៃមិនបានដរាបណា ដរាបនោះ រាត្រីដែលប្រកបដោយឫក្សមាលិនី ( រាត្រីដែលមានផ្កាយជារង្វង់ដូចកម្រងផ្កា ) បែបនេះ វិញ្ញូជនមិនគួរដេកលក់ដរាបនោះទេ គឺមិនមែនជាកាលសម្រាប់ដេកលក់ឡើយ ។

មួយប្រការទៀត រាត្រីនុ៎ះវិញ្ញូជនគួរប្រាថ្នាដើម្បីប្រតិបត្តិ ដោយអត្ថ បានដល់ ឈ្មោះថារាត្រីបែបនេះ ជាពេលដែលមានសំឡេងស្ងាត់ជាពិសេសព្រោះជាពេលដែលពួកមនុស្ស ពួកម្រឹគនិងបក្សីទាំងឡាយចូលកាន់និទ្រា ទើបជាពេលដែលវិញ្ញូជនអ្នកដឹងច្បាស់ ប្រាថ្នាដើម្បីយកចិត្តទុកដាក់ ក្នុងបដិបទាខ្លួន គឺដើម្បីខ្វល់ខ្វាយបំពេញព្យាយាម របស់អ្នកមានធម៌ជាគ្រឿងភ្ញាក់រឭក នោះឯង ។

ព្រះសោណត្ថេរស្ដាប់ព្រះឱវាទនោះហើយ ជាអ្នកមានចិត្តសង្វេគ ផ្ដើមតាំងហិរិឱត្តប្បៈ អធិដ្ឋានអព្ភោកាសិកង្គធុតង្គ ធ្វើកម្មក្នុងវិបស្សនា ពោលគាថាទី ២ ថា **ហត្ថិក្ខន្ធាវបតិតំ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **អវបតិតំ** បានដល់ ធ្លាក់ផ្កាប់មុខ គឺមានជើងឡើងលើ មានមុខទៅក្រោម ធ្លាក់ទៅហើយ ។

បទថា **កុញ្ជរោ ចេ អនុក្កមេ** សេចក្ដីថា បើដំរីគប្បីជាន់អញ លោកពោលអធិប្បាយថា បើក្នុងពេលដែលអញឡើងកាន់កដំរី ចូលកាន់សង្គ្រាមធ្លាក់អំពីកដំរី ត្រូវដំរីនោះជាន់ស្លាប់ក្នុងសង្គ្រាម ការស្លាប់នោះរបស់អញ ប្រសើរជាងការបោះបង់កិលេសទាំងឡាយ ហើយមានជីវិតនឹងប្រសើរដូចម្ដេច គឺ

ការរស់នៅនោះមិនប្រសើរឡើយកាលព្រះថេរៈពោលគាថានេះ ខ្វល់ខ្វាយក្នុងវិបស្សនាសម្រេចអរហត្តហើយ សមដូចគាថាព័ន្ធ ដែលលោកពោលទុកក្នុងអបទានថា

ក្នុងភពមុន ខ្ញុំកើតជាព្រានម្រឹគត្រាច់ទៅក្នុងព្រៃធំ បានឃើញព្រះសម្ពុទ្ធទ្រង់ប្រាសចាកធូលីដល់នូវត្រើយនៃធម៌ទាំងពួង ។ ខ្ញុំមានចិត្តជ្រះថ្លា បានកាន់យកផ្លែកុរញ្ជិយព្រឹក្ស ថ្វាយព្រះពុទ្ធដ៏ប្រសើរ ជាបុញ្ញក្ខេត្ត ជាអ្នកប្រាជ្ញដោយដៃរបស់ខ្លួន ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈ កាលសម្រេចអរហត្តហើយ ពោលគាថាទាំង ២ នោះឯងដដែលទៀត គឺគាថាទី ១ ព្រះសាស្តាត្រាស់ហើយ គាថាទី ២ ព្រះថេរៈពោលហើយ ដោយន័យជាដើមថា **ហត្ថិក្ខន្ធាវបតិតំ** ដូច្នេះជាដើម ដោយការពោលម្តងទៀតនូវគាថានោះ ឈ្មោះថា ព្រះថេរៈព្យាករអរហត្តផលហើយនោះឯង ។

**អដ្ឋកថា សោណពោដិរិយបុត្តត្ថេរគាថា ចប់**

---

១- ក្នុងអបទានជាព្រះ កុរញ្ជិយផលទាយកត្ថេរ ។

## និសភត្ថេរគាថា

[ ១៥៩ ] វិញ្ញូជន គប្បីលះបង់កាមគុណទាំង ៥ ដែលមានសភាព គួរស្រឡាញ់ គួររីករាយនៃចិត្ត ហើយចេញអំពីផ្ទះ ( ទៅបួស ) ដោយសទ្ធា ហើយធ្វើនូវទីបំផុតនៃទុក្ខ ។ ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ ខ្ញុំមិនត្រេកអរនឹងការរស់នៅទេ ខ្ញុំ ( គ្រាន់តែ ) ជាអ្នកដឹងខ្លួន មានស្មារតីរង់ចាំតែកាល ( បរិនិព្វាន ) ប៉ុណ្ណោះ ។

និសភត្ថេរ ។

## អដ្ឋកថា

## និសភត្ថេរគាថា

[ ១៥៩ ] គាថារបស់ព្រះនិសភត្ថេរ មានពាក្យផ្តើមថា **បញ្ច កាម-គុណេ ហិត្វា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយទុកក្នុងភពនោះៗ ។ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាវិបស្សី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយឃើញព្រះសាស្តាត្រាច់បិណ្ឌបាត មានចិត្តជ្រះថ្លា បានប្រគេនផ្លែខ្វិត ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងសុគតិភពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទះមានត្រកូលក្នុងកោលិយជនបទ មានឈ្មោះថា

និសភៈ ចម្រើនវ័យហើយឃើញពុទ្ធានុភាពក្នុងសង្គ្រាមរបស់ពួកស្តេចសក្យៈ និងកោលិយៈហើយ បាននូវសទ្ធាបួសហើយ សម្រេចអរហត្តក្នុងថ្ងៃនោះឯង សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស គួរទទួល គ្រឿងបូជា កំពុងស្តេចទៅតាមច្រក ហើយថ្វាយផ្លែខិត ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផល ទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំង សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១]។

ព្រះថេរៈ កាលសម្រេចអរហត្តហើយ ឃើញភិក្ខុទាំងឡាយជាសម្លាញ់ របស់ខ្លួនញ៉ាំងកាលវេលាឲ្យកន្លងទៅនៅដោយសេចក្តីប្រមាទ កាលនឹងទូន្មាន ភិក្ខុទាំងនោះ បានពោលគាថាទី ១ ដោយសេចក្តីថា

វិញ្ញូជន គប្បីលះបង់កាមគុណទាំង ៥ ដែលមានសភាពគួរ ស្រឡាញ់ គួររីករាយនៃចិត្ត ហើយចេញអំពីផ្ទះ ( ទៅបួស ) ដោយសទ្ធា ហើយធ្វើនូវទីបំផុតនៃទុក្ខ ។

គាថាទី ១ នោះ មានអធិប្បាយដូច្នេះថា វិញ្ញូជនលះ គឺលះបង់ បាន ដល់លះកាមគុណ គឺកាមកោដ្ឋាសទាំង ៥ មានរូបជាដើមដែលឈ្មោះថា **បិយរូបេ** ព្រោះមានសភាពដឹកនាំឲ្យពាលជនប្រាថ្នា ឈ្មោះថា **មនោរមេ**

---

១-ក្នុងអបទានជាព្រះ កបិដ្ឋផលទាយកត្ថេរ ។

ព្រោះ មានសភាពជាទីត្រេកអរនៃចិត្តចេញបួស គឺរួចផុតអំពីផ្ទះ គឺចេញអំ-ពីគ្រឿងចងគឺផ្ទះ ចូលកាន់បព្វជ្ជាភេទ ព្រោះជឿផលនៃកម្ម និងជឿក្នុងព្រះរតនត្រ័យតាំងពីបួសហើយ ក៏ព្យាយាម គប្បីជាអ្នកធ្វើនូវទីបំផុតនៃទុក្ខក្នុងវដ្តៈបាន ។

ព្រះថេរៈ ទូន្មានភិក្ខុទាំងឡាយនោះ យ៉ាងនេះហើយ កាលប្រាប់បដិបទារបស់លោកថា លោកទាំងឡាយកុំគិតថា បុគ្គលនេះល្អតែខាងទូន្មានអ្នកដទៃប៉ុណ្ណោះ ឯខ្លួនឯងមិនធ្វើ ទើបព្យាករអរហត្តផលដោយគាថាទី ២ ថា

ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ ខ្ញុំមិនត្រេកអរនឹងការរស់នៅ
ទេ ខ្ញុំ ( គ្រាន់តែ ) ជាអ្នកដឹងខ្លួន មានស្មារតី រង់ចាំតែ
កាល ( បរិនិព្វាន ) ប៉ុណ្ណោះ ។

បណ្តាបទទាំងនោះ បទថា **នាភិនន្ទាមិ មរណំ** សេចក្តីថា ខ្ញុំមិនប្រាថ្នាការស្លាប់ ។

បទថា **នាភិនន្ទាមិ ជីវិតំ** នេះ ជាពាក្យប្រាប់ហេតុនៃបទថា **នាភិនន្ទា-មិ មរណំ** នោះ ខ្ញុំមិនត្រេកអរក្នុងការស្លាប់ក៏ព្រោះខ្ញុំមិនត្រេកអរនឹងការរស់នៅទេ អធិប្បាយថា បុគ្គលណាកសាង គឺចូលទៅសន្សំការតាក់តែងកិលេសដែលហេតុនៃជាតិ ជរា និងមរណៈតទៅ បុគ្គលនោះ កាលត្រេកអរក្នុងការកើតក្នុងភពថ្មី ឈ្មោះថា រមែងត្រេកអរនូវការស្លាប់របស់ខ្លួន ព្រោះជាផលឲ្យកើតក្នុងភពជាប់តគ្នា ព្រោះមិនទាន់លះហេតុបាន ឯព្រះខីណាស្រពលះធម៌ដែលជាហេតុឲ្យដល់នូវការអស់ភពជាតិ តាំងនៅក្នុងធម៌ដែលជាហេតុឲ្យអស់

*ភពជាតិ កំណត់ដឹងទីតាំងដែលកើតបានហើយ ឈ្មោះថា មិនត្រេកអរនូវជីវិតគ្រប់យ៉ាង ឈ្មោះថាមិនត្រេកអរនឹងសេចក្តីស្លាប់ ព្រោះលះហេតុនោះឯងបានហើយដោយល្អ ។ ដោយហេតុនោះទើបព្រះថេរៈពោលថា* **នាភិនន្ទាមិ មរណំ នាភិនន្ទាមិ ជីវិតំ** *ដូច្នេះ ។*

*បើដូច្នោះ ព្រះខីណាស្រពប្រាថ្នាព្រះនិព្វានជាងបរិនិព្វាន លោកតាំងនៅដូចម្តេច ព្រោះហេតុនោះទើបព្រះថេរៈពោលថា ជាអ្នកដឹងខ្លួន មានស្មារតីរង់ចាំតែកាល ( បរិនិព្វាន ) ប៉ុណ្ណោះ ។ អធិប្បាយថា កាលខ្ញុំសម្រេចកិលេសបរិនិព្វានហើយ ខ្ញុំឈ្មោះថា ជាអ្នកដឹងខ្លួន មានស្មារតី ព្រោះដល់នូវការបរិបូណ៌ដោយសតិនិងបញ្ញា រង់ចាំតែកាល ( បរិនិព្វាន ) ប៉ុណ្ណោះ ខ្ញុំរង់ចាំកាលនៃខន្ធបរិនិព្វាន តែខ្ញុំមិនមានសេចក្តីត្រេកអរក្នុងការស្លាប់ ឬក្នុងជីវិតរស់នៅ ព្រោះទាំងការស្លាប់និងការរស់នៅនោះ ខ្ញុំដកឡើងដោយអរហត្តមគ្គហើយនោះឯង ។*

*អដ្ឋកថា និសភត្ថេរគាថា ចប់*

## ឧសភត្ថេរគាថា

[ ១៦០ ] ខ្ញុំធ្វើចីវរ មានពណ៌ដូចជាពណ៌នៃត្រួយស្វាយលើស្មាហើយ ជិះលើកនៃដំរី ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ខ្ញុំចុះពីកដំរី ក៏បាននូវសេចក្តីសង្វេគក្នុងកាលណោះ តែខ្ញុំនោះ ជាមនុស្សកំពុងស្រវឹង ( ដោយជាតិជាដើម ) ហើយខ្ញុំបានដល់នូវធម៌ជាគ្រឿងអស់ទៅនៃអាសវៈ ក្នុងកាលណោះដែរ ។

ឧសភត្ថេរ ។

## អដ្ឋកថា

## ឧសភត្ថេរគាថា

[ ១៦០ ] គាថារបស់ព្រះឧសភត្ថេរ មានពាក្យផ្តើមថា **អម្ពបល្លវ-សង្កាសំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាសិខី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ ឃើញព្រះសាស្តាត្រាច់ទៅបិណ្ឌបាត មានចិត្តជ្រះថ្លា បានប្រគេនផ្លែសង្ឃ័រ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំង-ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលស្តេចសក្យៈក្នុងនគរកបិលពស្តុមាន

នាមថាឧសភៈ ចម្រើនវ័យហើយ ឃើញពុទ្ធានុភាពក្នុងសមាគមព្រះញាតិនៃព្រះសាស្ដា មានសទ្ធាទើបចេញបួស ។

ចាប់តាំងពីបួសហើយ ព្រះឧសភមិនបំពេញសមណធម៌ ត្រេកអរក្នុងការនៅច្រឡូកច្រឡំដោយពួកដោយគណៈក្នុងពេលថ្ងៃ ដេកលក់រហូតអស់ពេលយប់ ញុំាងកាលឲ្យកន្លងទៅ ។ ថ្ងៃមួយ លោកបណ្ដោយសតិដាច់នូវសម្បជញ្ញៈ ដេកលក់ យល់សប្ដិឃើញខ្លួនឯងកោរសក់ និងពុកមាត់ហើយដណ្ដប់ចីវរពណ៌ត្រួយស្វាយខ្ចី អង្គុយលើកដំរី ចូលទៅកាន់នគរដើម្បីបិណ្ឌបាត ឃើញមនុស្សទាំងឡាយមកប្រជុំគ្នាក្នុងទីនោះឯង ទើបចុះពីកដំរីដោយការខ្មាស ភ្ញាក់ឡើងកើតសេចក្ដីសង្វេគថា អាត្មាអញបណ្ដោយសតិ មិនមានសម្បជញ្ញៈដេកលក់យល់សប្ដិឃើញបែបនេះហ្ន៎ផ្ដើមចម្រើនវិបស្សនាសម្រេចអរហត្តក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលនោះ ខ្ញុំបានឃើញព្រះសម្ពុទ្ធទ្រង់មានដំណើរល្វាសល្វន់ ដូចលំពង់ថ្វាន់ត្រូវខ្យល់ ជាទេវតាកន្លងទេវតា ប្រសើរជាងនរៈ កំពុងស្ដេចទៅតាមច្រក ហើយបានថ្វាយផ្លែសង្ឃ័រ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ក្នុងកាលនោះខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១]។

---

១-ក្នុងអបទានជាព្រះ កោសុម្ពផលិយត្ថេរ ។

ក្រោយមក ព្រោះលោកបានសម្រេចអរហត្តផល ដោយប្រើការយល់សប្តិនោះឯងជាកង្វេរ កាលព្យាករអរហត្តផល ទើបពោលគាថា ២ ថា

ខ្ញុំធ្វើចីវរ មានពណ៌ដូចជាពណ៌នៃត្រួយស្វាយលើស្មា ហើយជិះលើកនៃដំរីចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ខ្ញុំចុះពីកដំរីក៏បាននូវសេចក្តីសង្វេគក្នុងកាលណោះ តែខ្ញុំនោះជាមនុស្សកំពុងស្រវឹង ( ដោយជាតិជាដើម ) ហើយខ្ញុំបានដល់នូវធម៌ជាគ្រឿងអស់ទៅនៃអាសវៈក្នុងកាលណោះដែរ ។

បណ្តាបទទាំងនោះ បទថា **អម្ពបល្លវសង្កាសំ អំសេ កត្វាន ចីវរំ** សេចក្តីថា យកចីវរមានពណ៌ដូចកែវប្រវាឡ មានអាការដូចស្លឹកស្វាយខ្ចីពាក់ត្រង់កន្ទៀនស្មា ។

បទថា **គាមំ** សេចក្តីថា អង្គុយលើកដំរី ចូលទៅកាន់រាជធានីរបស់ខ្លួន ដើម្បីបិណ្ឌបាត លុះចូលទៅហើយប៉ុណ្ណោះ ក៏ត្រូវមហាជនចោមរោមមើល ទើបចុះពីកដំរី ហើយឈរ ភ្ញាក់ឡើងហើយ ក៏បាននូវសេចក្តីសង្វេគក្នុងកាលនោះថា ការយល់សប្តិនេះកើតហើយ ព្រោះអញបណ្តោយសតិមិនមានសម្បជញ្ញៈចុះកាន់និទ្រាដូច្នេះ ។

ឯអាចារ្យពួកដទៃពោលថា ព្រះឧសភត្ថេរនៅជាព្រះរាជានោះឯង យល់សប្តិបែបនេះ ក្នុងវេលារាត្រី លុះរាត្រីអស់ហើយ ទើបឡើងកាន់កដំរីត្រាច់ទៅតាមផ្លូវក្នុងព្រះនគរ ទ្រង់រឭកដល់ការយល់សប្តិនោះ ទើបចុះអំពីកដំរីបាននូវសេចក្តីសង្វេគ បួសក្នុងសម្នាក់ព្រះសាស្តា សម្រេចអរហត្តហើយ

កាលទឹងបន្លឺឧទាន ទើបពោលគាថាទាំងនេះ ។

បទថា **ធិត្តោ** ប្រែកបសេចក្ដីថា ក្នុងកាលដែលបានសោយរាជ្យនោះ ខ្ញុំជាអ្នករឹងត្អឹង ដោយការស្រវឹងព្រោះជាតិ និងការស្រវឹងព្រោះភោគៈជាដើម ទើបបាននូវការសង្វេគ ។

## អដ្ឋកថា ឧសភត្ថេរគាថា ចប់

## កប្បដកុរត្ថេរគាថា

[ ១៦១ ] កប្បដកុរៈ ( មានសេចក្ដីត្រិះរិះខុសកើតឡើងយ៉ាងនេះ ) ថា នេះជាកន្ទបរបស់អាត្មាអញ កាលបើក្អមសម្រាប់ដាក់ទឹកអម្រឹត ( របស់តថាគត ) ពេញហើយក្រៃពេក ( តថាគតសម្ដែងធម៌ដើម្បីឲ្យបាននូវទឹកអម្រឹត ) កប្បដកុរភិក្ខុ ក៏ដល់នូវការឃ្លាងអំពីធម៌ ( របស់តថាគត ) នេះជាសាសនារបស់តថាគត ជាផ្លូវការនាផ្សេងៗ ប្រព្រឹត្តទៅ ដើម្បីចម្រើននូវឈានទាំងឡាយ ។ ម្នាលកប្បដកុរៈ អ្នកកុំងោកងក់ តថាគតមិនបានវាយត្រូវអ្នកក្នុងទីជិតត្រចៀកទេ ម្នាលកប្បដកុរៈ ព្រោះថា អ្នកមិនស្គាល់ប្រមាណ បានជាអ្នកចេះតែងោកងក់ក្នុងកណ្ដាលសង្ឃ ។

**កប្បដកុរត្ថេរ ។**

**ឧទ្ទាន**

និយាយអំពីមិគសិរត្ថេរ ១ សិវកត្ថេរ ១ ឧបវាណបណ្ឌិតត្ថេរ ១ ឥសិទិន្នត្ថេរ ១ សម្ពុលកច្ចានត្ថេរ ១ ខិតកត្ថេរមានវសីធំ ១ សោណបោដិរិយបុត្តត្ថេរ ១ និសភត្ថេរ ១ ឧសភត្ថេរ ១ កប្បដកុរត្ថេរ ១ ។

**ចប់ វគ្គទី ៤ ។**

## អដ្ឋកថា

## កប្បដកុរត្ថេរគាថា

[ ១៦១ ] គាថារបស់ព្រះកប្បដកុរត្ថេរ មានពាក្យផ្ដើមថា **អយមិតិ កប្បដោ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាវិបស្សី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ថ្ងៃមួយឃើញព្រះមានព្រះភាគគង់ត្រង់គល់ឈើមួយដើមក្បែរមាត់ស្ទឹងឈ្មោះ វិនតា មានចិត្តជ្រះថ្លា បូជាដោយផ្កាវំពេក ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលក្រីក្រក្នុងក្រុងសាវត្ថី លុះចម្រើនវ័យហើយ ក៏មិនចេះឧបាយរកស៊ីដទៃ ស្លៀកកន្ទបចាស់ៗ កាន់ផ្តិលដើរសុំបាយក្នុងទីនោះៗ ដោយហេតុនោះ ទើបប្រាកដឈ្មោះថាកប្បដកុរៈ ។ លុះចម្រើនវ័យល្អហើយ ប្រកបស្មៅលក់ចិញ្ចឹមជីវិត ថ្ងៃមួយទៅកាន់ព្រៃដើម្បីប្រកបស្មៅ ឃើញព្រះថេរៈជាខីណាស្រពមួយរូបនៅក្នុងព្រៃនោះ ចូលទៅរកព្រះថេរៈ ថ្វាយបង្គំហើយអង្គុយ ព្រះថេរៈក៏សម្ដែងធម៌ដល់កុលបុត្តនោះ ។

កុលបុត្តនោះស្ដាប់ធម៌ហើយ បាននូវសទ្ធា គិតថាការរស់នៅដោយភាពក្រីក្រយ៉ាងនេះ មានប្រយោជន៍អ្វី ទើបចេញបួស ពាក់កន្ទបចាស់ៗទុកក្នុងទីមួយកន្លែង ។ ក្នុងកាលដែលព្រះថេរៈអផ្សុកចង់សឹក កាលទៅសម្លឹងមើល

កន្ទបចាស់ៗនោះ ការអផ្សុកក៏ប្រាសទៅ បានទូវការសង្វេគហើយ ។ ព្រះថេរៈបួសហើយសឹកយ៉ាងនេះអស់ ៧ ដង ។ ភិក្ខុទាំងឡាយ ទូលហេតុនោះដល់ព្រះមានព្រះភាគ ។ ថ្ងៃមួយ កប្បដកុរភិក្ខុ អង្គុយនិទ្រាខាងចុងបរិស័ទក្នុងរោងប្រជុំស្តាប់ធម៌ ព្រះមានព្រះភាគ កាលទ្រង់ជាស់តឿន បានត្រាស់គាថា ២ ថា

កប្បដកុរៈ ( មានសេចក្តីត្រិះរិះខុសកើតឡើងយ៉ាងនេះ ) ថា នេះជាកន្ទប របស់អាត្មាអញ កាលបើក្អមសម្រាប់ដាក់ទឹកអម្រឹត ( របស់តថាគត ) ពេញហើយក្រៃពេក ( តថាគតសម្តែងធម៌ដើម្បីឲ្យបានទូវទឹកអម្រឹត ) កប្បដកុរភិក្ខុ ក៏ដល់នូវការឃ្លាងអំពីធម៌ ( របស់តថាគត ) នេះជាសាសនារបស់តថាគត ជាផ្លូវការនាផ្សេងៗ ប្រព្រឹត្តទៅដើម្បីចម្រើនទូវឈានទាំងឡាយ ។ ម្នាលកប្បដកុរៈ អ្នកកុំងោកងក់ តថាគតមិនបានវាយត្រូវអ្នកក្នុងទីជិតត្រចៀកទេ ម្នាលកប្បដកុរៈ ព្រោះថា អ្នកមិនស្គាល់ប្រមាណ បានជាអ្នកចេះតែងោកងក់ ក្នុងកណ្តាលសង្ឃ ។

បណ្តាបទទាំងនោះ បទថា **អយមិតិ កប្បដោ កប្បដកុរោ** សេចក្តីថា ភិក្ខុឈ្មោះថាកប្បដកុរៈ មានវិតក្កខុសកើតឡើងយ៉ាងនេះថា នេះជាសំពត់ចាស់របស់អញ អញស្លៀកដណ្តប់សំពត់ចាស់ៗនេះ ហើយចិញ្ចឹមជីវិតតាមមានតាមបាន កាលទឹកថ្លាដែលពេញក្នុងក្អមគឺអមតៈ កាលក្អមគឺអមតៈ

របស់តថាគតកំពុងហូរនូវទឹក គឺអមតធម៌ក្នុងទីនោះៗ បានដល់ កាលតថា-គតញ៉ាំងនូវទឹកអម្រឹត គឺធម៌ឲ្យធ្លាក់ចុះ ដោយការប្រកាសពាក្យជាដើមថា តថាគត នឹងប្រៀនប្រដៅនូវអមតធម៌ដែលតថាគតត្រាស់ដឹងហើយ ឥឡូវ តថាគតនឹងសម្តែងធម៌ តថាគតនឹងទូងនូវស្គរ ផ្លូវដែលតថាគតធ្វើទុកដើម្បី សន្សំនូវឈានទាំងឡាយ គឺ ផ្លូវដែលតថាគតធ្វើការដើម្បីចម្រើននូវឈាន ទាំង លោកិយនិងលោកុត្តរ បានដល់ មគ្គភាវនា ដែលចាត់ចែងទុកដើម្បីជាផ្លូវ នេះជាពាក្យប្រៀនប្រដៅរបស់តថាគត តែទោះជាយ៉ាងនោះ កប្បដកុរៈដែល មានចិត្តអផ្សុក មានចិត្តឆ្ងាយចាកសាសនធម៌របស់តថាគត ដែលឈ្មោះថា ក្អមសម្រាប់ដាក់ទឹកអម្រឹត ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលដាស់ តឿនព្រះថេរៈហើយ កាលសម្តែងការនៅ ដោយភាពជាបុគ្គលប្រមាទ ឲ្យ ជ្រាបម្តងទៀត ដូចចាប់ចោរបានទាំងភស្តុតាង ទើបត្រាស់គាថាថា **មា ខោ ត្វំ កប្បដ បចាលេសិ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មា ខោ ត្វំ កប្បដ បចាលេសិ** សេចក្តីថា ម្នាលកប្បដកុរៈ អ្នកកុំស្រវឹង អង្គុយងោកងក់ឡើយ គឺ កុំអង្គុយងក់ បាន ដល់ កុំចូលដល់ការដេកលក់ ដោយគិតថា អញនឹងស្តាប់ធម៌ ។

បទថា **មា ត្វំ ឧបកណ្ណម្ហិ តាឡេស្សំ** សេចក្តីថា តថាគតកុំគប្បីវាយ អ្នកដែលដេកលក់ដោយដៃ គឺទេសនា ក្នុងទីក្បែរត្រចៀក គឺក្បែរត្រចៀក អធិប្បាយថា បន្ទាប់អំពីនេះទៅ ចូរអ្នកបដិបត្តិដោយមិនត្រូវឲ្យតថាគតទូន្មាន ដើម្បីឲ្យលះកិលេសទៀតឡើយ ។

*បទថា* **ន ហិ ត្វំ កប្បដ មត្តមញ្ញាសិ** *សេចក្តីថា ព្រះមានព្រះភាគ ដាស់តឿនថា ម្នាលកប្បដះ អ្នករវល់តែងោកងុយក្នុងកណ្តាលសង្ឃ រមែង មិនស្គាល់ប្រមាណ គឺការល្មម មិនដឹងហេតុត្រឹមប៉ុណ្ណោះថា ខណៈបែបនេះ រកបានដោយកម្រក្រៃលែង ខណៈនោះ កុំបីកន្លងអត្ថាអញឡើយ ដូច្នេះ អ្នកចូរមើលកំហុសរបស់អ្នក ។*

*កាលកប្បដកុរភិក្ខុ ត្រូវព្រះមានព្រះភាគទ្រង់សង្កត់សង្កិន ទ្រង់ដាស់ តឿនយ៉ាងខ្លាំងក្លាដោយគាថា ២ យ៉ាងនេះហើយ កប្បដកុរភិក្ខុកើតនូវសេច-ក្តីសង្វេគ ដូចត្រូវព្រួញមុតដល់ឆ្អឹង ដូចដំរីកាចឆាកមកដើរត្រូវផ្លូវ ដូច្នោះ ផ្តើមចម្រើនវិបស្សនាសម្រេចអរហត្តហើយ ក្នុងកាលមិនយូរឡើយ សមដូច គាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា*

*ព្រះសម្ពុទ្ធជាបុរសខ្ពង់ខ្ពស់ ទ្រង់គង់នៅទៀបច្នេរស្ទឹង វិនតា ខ្ញុំបានឃើញព្រះពុទ្ធទ្រង់ប្រាសចាកធូលី គឺកិលេស មានព្រះ ហឫទ័យមូល ក្នុងអារម្មណ៍តែមួយ មានព្រះហឫទ័យតម្កល់ មាំ ។ កាលនោះ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជា ផ្កាកេត ដែលមានក្លិនក្រអូបចំពោះព្រះសម្ពុទ្ធដ៏ប្រសើរ ។ ក្នុង កប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុង កាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនា របស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។*

---

*១-ក្នុងអបទានជាព្រះ កេតកបុប្ផិយត្ថេរ ។*

កាលព្រះថេរៈសម្រេចអរហត្តហើយ ពោលបញ្ជាក់អះអាងគាថា ទាំង ២ ដែលព្រះសាស្តាត្រាស់ហើយនោះឯង ថាជាកន្សៀវនៃការសម្រេចអរហត្តផលរបស់ខ្លួន គាថាទាំង ២ នេះ រាប់ជាគាថាព្យាករអរហត្តផលរបស់ព្រះកប្បដកុរត្ថេរដូចគ្នា ។

## អដ្ឋកថា កប្បដកុរត្ថេរគាថា ចប់

## វគ្គទី ៤ ចប់

# ថេរគាថា ឧកនិបាត បញ្ចមវគ្គ

## កុមារកស្សបត្ថេរគាថា

[ ១៦២ ] ឱ! ព្រះពុទ្ធ ឱ! ព្រះធម៌ ឱ! សម្បទារបស់ព្រះសាស្តានៃយើងទាំងឡាយ ដែលសាវ័ក នឹងធ្វើឲ្យជាក់ច្បាស់នូវធម៌ប្រាកដដូច្នោះ ។ សក្កាយៈ គឺ បញ្ចុបាទានក្ខន្ធ អាត្មាអញបានហើយក្នុងកប្បទាំងឡាយរាប់មិនបាន រាងកាយនេះជាទីបំផុតរបស់បញ្ចុបាទានក្ខន្ធទាំងនោះ រាងកាយនេះ ជាខាងក្រោយរបស់បញ្ចុបាទានក្ខន្ធទាំងនោះ សង្សារប្រកបដោយជាតិនិងមរណៈ ឥឡូវនេះភពថ្មីមិនមានទេ ។

កុមារកស្សបត្ថេរ ។

## វគ្គទី៥

## កុមារកស្សបត្ថេរគាថា

[ ១៦២ ] គាថារបស់ព្រះកុមារកស្សបត្ថេរ មានពាក្យផ្តើមថា **អហោ ពុទ្ធា អហោ ធម្មា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កើតក្នុងត្រកូលព្រាហ្មណ៍ដល់នូវភាពជាអ្នកដឹងក្តីហើយ តែក្នុងអដ្ឋកថា អង្គុត្តរនិកាយ

លោកពោលថា កើតក្នុងផ្ទះមានត្រកូល ។

កុលបុត្តនោះ ចូលទៅកាន់សម្នាក់របស់ព្រះសាស្តា ហើយស្តាប់ធម៌ ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងនៃភិក្ខុជាឯតទគ្គៈនៃភិក្ខុ ខាងពោលធម៌ដ៏វិចិត្រ ខ្ល□ងប្រាថ្នាតំណែងនោះ ទើបតាំងបណិធានទុក ធ្វើបុណ្យតាមសមគួរដល់បណិធាន ដែលតម្កល់ទុក បំពេញសមណធម៌ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមថាកស្សបៈ អន្ទោលទៅមក ក្នុងសុគតិភពប៉ុណ្ណោះ ។ ក្នុងពុទ្ធុប្បាទនេះ បដិសន្ធិក្នុងគភ៌នៃធីតាសេដ្ឋី ក្នុងក្រុងរាជគ្រឹះ ។

បានឮថា ធីតារបស់សេដ្ឋីនោះ ជាស្រីមានបំណងនឹងបួសក្នុងកាលដែលនៅជាក្រមុំនោះឯង សូមអនុញ្ញាតមាតាបិតា មិនបានទទួលអនុញ្ញាតឲ្យបព្វជ្ជា ក៏ទៅកាន់ត្រកូលប្តី មិនដឹងថាខ្លួនមានគភ៌ ធ្វើប្តីឲ្យប្រោសប្រាណ រហូតប្តីអនុញ្ញាត ទើបបួសក្នុងសម្នាក់ភិក្ខុនីទាំងឡាយ ។ តមក ភិក្ខុនីទាំងឡាយឃើញនាងមានគភ៌ទើបសួរទេវទត្តភិក្ខុៗប្រាប់ថា នាងមិនមែនជាសមណៈ ។ ទើបនាំគ្នាទៅទូលសួរព្រះទសពល ។ ព្រះសាស្តា ឲ្យព្រះឧបាលិត្ថេរជម្រះអធិករណ៍ ។

ព្រះថេរៈឲ្យហៅត្រកូលទាំងឡាយ ដែលនៅក្នុងនគរសាវត្ថី និងឧបាសិកាឈ្មោះវិសាខាមកហើយ វិនិច្ឆ័យក្នុងបរិស័ទ មួយអន្លើដោយព្រះរាជា កាត់សេចក្តីថា ភិក្ខុនីមានទម្ងន់តាំងពីមុនបួស បព្វជ្ជាបរិសុទ្ធ ។ ព្រះសាស្តាទ្រង់ប្រទាននូវសាធុការ ដល់ព្រះថេរៈថា អធិករណ៍ដែលឧបាលិត្ថេរវិនិច្ឆ័យ

ត្រឹមត្រូវល្អហើយ ។

ភិក្ខុនីនោះប្រសូតបុត្តមានរូបដូចមាស ព្រះរាជាព្រះនាមថាបសេនទិកោសលទ្រង់ទទួលចិញ្ចឹមបុត្ររបស់នាង ដាក់ឈ្មោះកុមារនោះថា កស្សបៈ ។ ក្នុងកាលតមក ទ្រង់ប្រដាប់តាក់តែងកុមារហើយនាំទៅកាន់សម្នាក់ព្រះសាស្ដាឲ្យបួសហើយ ព្រោះហេតុដែលកុលបុត្តនោះបួសតាំងពីនៅក្មេង កាលព្រះមានព្រះភាគត្រាស់ថា អ្នកទាំងឡាយចូរហៅកស្សបៈមក ចូរឲ្យផ្លែឈើ ឬរបស់គួរទំពានេះដល់កស្សបៈ ដូច្នេះ ភិក្ខុទាំងឡាយក៏ទូលសួរថា កស្សបៈមួយណា ព្រះសាស្ដាក៏ត្រាស់ថា កុមារកស្សបៈ ។ ព្រះថេរៈ ក៏មានឈ្មោះប្រាកដថា កុមារកស្សបៈនោះឯង សូម្បីមានអាយុច្រើន ព្រោះមានទាមដែលកាន់យកតាមព្រះមានព្រះភាគ ត្រាស់ហៅយ៉ាងនេះ និងព្រោះជាព្រះរាជបុត្តធម៌ ( កូនចិញ្ចឹម ) របស់ព្រះរាជា ។

ចាប់តាំងពីបួសហើយ លោកធ្វើកម្មក្នុងវិបស្សនា និងរៀនព្រះពុទ្ធវចនៈកាលនោះ មហាព្រហ្មជាអនាគាមីដែលធ្លាប់បំពេញសមណធម៌លើកំពូលភ្នំរួមជាមួយនឹងព្រះកុមារកស្សបៈ កើតក្នុងជាន់សុទ្ធាវាសត្រិះរិះថា អញនឹងធ្វើឧបាយដើម្បីសម្រេចមគ្គផលដោយប្រាប់ផ្លូវវិបស្សនា ដូច្នេះហើយ ទើបចងប្រស្នា ១៥ ហើយទៅប្រាប់ដល់ព្រះថេរៈដែលនៅក្នុងព្រៃអន្ធវ័នថា សូមលោកម្ចាស់ទូលសួរបញ្ហានេះនឹងព្រះសាស្ដា ។ ព្រះថេរៈ ទូលសួរបញ្ហាទាំងនោះនឹងព្រះមានព្រះភាគៗ ក៏ទ្រង់ព្យាករបញ្ហាដល់ព្រះថេរៈ ។ ព្រះថេរៈរៀនបញ្ហាទាំងនោះ ដោយទំនងដែលព្រះសាស្ដា ត្រាស់ប្រាប់ហើយនោះឯង

ញ៉ាំងវិបស្សនាឲ្យកាន់យកបទូប់ សម្រេចអរហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រះពុទ្ធព្រះនាម បទុមុត្តរៈ ជាលោកនាយក ទ្រង់ទំនុកបម្រុងសត្វលោកទាំងពួង ជាអ្នកប្រាជ្ញ ទ្រង់កើតឡើង ។ កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ មានឈ្មោះល្បីល្បាញ ជាអ្នកដល់នូវត្រើយនៃត្រៃវេទ កាលដើរទៅដើម្បីសម្រាកក្នុងវេលាថ្ងៃ ក៏បានជួបប្រទះព្រះលោកនាយក ព្រះអង្គជាធម្មកថិកដ៏ត្រកាល កំពុងប្រកាសសម្តែងនូវសច្ចៈ ៤ កំពុងញ៉ាំងមហាជន ព្រមទាំងទេវតា និងសាវកឲ្យត្រាស់ដឹង ។ គ្រានោះ ខ្ញុំមានចិត្តរីករាយ បាននិមន្តព្រះតថាគត រួចតាក់តែងមណ្ឌប ដោយសំពត់មានពណ៌ក្រហមផ្សេងៗ ហើយនិមន្តព្រះពុទ្ធ ព្រមទាំងព្រះសង្ឃ ដែលមានរស្មីប្រាលទ្មោលដូចរតនៈផ្សេងៗឲ្យចាន់ក្នុងមណ្ឌបនោះ លុះចាន់ចង្ហាន់មានរសដ៏ប្រសើរផ្សេងៗគ្រប់ ៧ ថ្ងៃហើយ ទើបខ្ញុំបូជាព្រះតថាគត ព្រមទាំងសាវក ដោយផ្កាដ៏វិចិត្រផ្សេងៗ ហើយក្រាបទៀបព្រះបាទា ប្រាថ្នានូវតំណែងនោះ ។

គ្រានោះ ព្រះមុនីដ៏ប្រសើរ ព្រះអង្គមានករុណាជាលំនៅ ទ្រង់ត្រាស់ថា អ្នកទាំងឡាយចូរមើលព្រាហ្មណ៍ ដ៏ប្រសើរនុ៎ះ ដែលមានមុខ និង ភ្នែកដូចផ្កាឈូក ជាអ្នកច្រើនដោយបីតិ

និងបាមុជ្ជៈ មានរោមឆ្ងឡើង ជាអ្នកនាំមកនូវសេចក្ដីរីករាយ មានភ្នែកស្រឡះ មានសេចក្ដីអាល័យក្នុងសាសនានៃតថាគត មានវត្តប្រតិបត្តិតែមួយ មានចិត្តល្អ បានក្រាបទៀបបាទានៃតថាគត ព្រាហ្មណ៍នុ៎ះ ប្រាថ្នានូវតំណែងនោះ គឺភាពជាអ្នកសម្ដែងធម៌ដ៏វិចិត្រ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ មានមហាបុរស សម្ភពក្នុងត្រកូលស្ដេចឱក្កាកៈនឹងបានជាព្រះសាស្ដាក្នុងលោក ព្រះនាមគោតម ។ ឯព្រាហ្មណ៍នុ៎ះ នឹងបានជាឱរសដែលព្រះធម៌និម្មិត ជាអ្នកទទួលមត៌កក្នុងធម៌របស់ព្រះសាស្ដានោះហើយ នឹងបានជាសាវកនៃព្រះសាស្ដាឈ្មោះថាកុមារកស្សបៈ ។ ដោយអានិសង្សនៃផ្កា និងសំពត់ដ៏វិចិត្រ និងរតនៈទាំងឡាយ កុមារកស្សបៈនោះនឹងបានដល់នូវភាពនៃខ្លួនប្រសើរលើសលុប ជាងធម្មកថិកគ្រកាលទាំងឡាយ ។

ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវសេចក្ដីប្រាថ្នានោះផង ខ្ញុំលុះលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ខ្ញុំវិលចុះវិលឡើងក្នុងភពតូចនិងភពធំ ហាក់ដូចជាអ្នករបាំ ( ដែលរាំវិលចុះឡើង ) ក្នុងកណ្ដាលវេរីណារង្គ ខ្ញុំជាសត្វត្រូវកើតដោយសាខម្រឹគបានចូលទៅចាប់ផ្ទៃក្នុងមេម្រឹគ ។ កាលខ្ញុំកំពុងនៅក្នុងគភ៌ កាលនោះ

វេណាដែលគេសម្លាប់ ក៏មកដល់ ឯមាតារបស់ខ្ញុំត្រូវសាខម្រឹគ លះបង់ចោល គាត់ក៏ទៅយកនិគ្រោធម្រឹគជាទីពឹងវិញ ។ កាលនោះ មាតារបស់ខ្ញុំនោះ ត្រូវស្ដេចម្រឹគនោះជួយដោះអំពីមរណៈ តែមាតាខ្ញុំស៊ូលះជីវិតរបស់ខ្លួន ក៏ទូន្មានខ្ញុំយ៉ាងនេះថា ( ហៃបា បើបាចង់បានសេចក្ដីចម្រើន ) ត្រូវសេពគប់នឹងនិគ្រោធម្រឹគ កុំទៅសេពគប់នឹងសាខម្រឹគឡើយ ការស្លាប់ក្នុងសម្នាក់និគ្រោធម្រឹគទើបប្រសើរ ការរស់ក្នុងសម្នាក់សាខម្រឹគពុំប្រសើរឡើយ ។

ខ្ញុំ មាតា និងម្រឹគដទៃ ត្រូវស្ដេចម្រឹគនោះ ប្រៀនប្រដៅហើយក៏ទទួលធ្វើតាមឱវាទរបស់ស្ដេចម្រឹគនោះហើយ បានទៅកើតក្នុងពិមាននៅឋានតុសិត ជាទីត្រេកអរ ហាក់ដូចជាបុគ្គលទៅកាន់ទីព្រាត់ប្រាសហើយ បានត្រឡប់មកផ្ទះខ្លួនវិញ ។

កាលសាសនានៃព្រះពុទ្ធកស្សបៈ ជាអ្នកប្រាជ្ញសាបសូន្យទៅ ខ្ញុំបានឡើងទៅលើកំពូលភ្នំ ហើយប្រកបតាមសាសនានៃព្រះជិនស្រីទៀត ។ ឥឡូវនេះខ្ញុំទៅចាប់ផ្ទៃក្នុងត្រកូលសេដ្ឋីក្នុងក្រុងរាជគ្រឹះ ឯមាតារបស់ខ្ញុំបានចូលទៅកាន់ផ្នួសទាំងមានគភ៌ ។ ពួកភិក្ខុនីលុះបានដឹងថា មាតាខ្ញុំនោះមានគភ៌ហើយ ក៏នាំគ្នាចូលទៅប្រាប់ទេវទត្ត ទេវទត្តនោះបាននិយាយថា នាងទាំងឡាយចូលញុំាងភិក្ខុនីដ៏លាមកនេះឲ្យវិនាស ។ ឥឡូវនេះ

មាតាជាព្រះជននីរបស់ខ្ញុំ មានសេចក្ដីសុខ ក្នុងសម្នាក់ភិក្ខុនី ដោយសារព្រះមុនិន្ទជិនស្រី ទ្រង់អនុគ្រោះ ។ ព្រះបាទកោ-សលរក្សាផែនដី ទ្រង់ជ្រាបហេតុនោះហើយ ក៏បានចិញ្ចឹមខ្ញុំ ដោយគ្រឿងរក្សាកុមារ ខ្ញុំមានឈ្មោះថាកស្សបៈ ។ ខ្ញុំពឹងពាក់អាស្រ័យនឹងព្រះមហាកស្សបៈ ទើបបានឈ្មោះកុមារកស្សបៈ វិញ ខ្ញុំបានស្ដាប់ធម៌ដែលព្រះពុទ្ធទ្រង់សម្ដែងថា រាងកាយប្រាកដដូចជាដំបូក ។ លំដាប់នោះ ចិត្តរបស់ខ្ញុំក៏រួចស្រឡះចាកអាសវៈ ព្រោះមិនមានការប្រកាន់សព្វគ្រប់ ខ្ញុំទូន្មាននូវខ្លួនឲ្យបានបែបបទហើយ ក៏បានដល់នូវទីជាឯតទគ្គៈ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

ព្រះថេរៈកាលបានសម្រេចអរហត្តហើយ កាលព្រះសាស្ដាទ្រង់តាំងទុកនៅក្នុងតំណែងឯតទគ្គៈ ដោយភាពជាអ្នកពោលធម៌ដ៏វិចិត្រ ពិចារណាបដិ-បទារបស់ខ្លួនហើយ កាលនឹងព្យាករអរហត្តផលដោយមាតិកា គឺប្រកាសនូវគុណរបស់ព្រះរតនត្រ័យ បានពោលគាថា ២ ថា

ឱ! ព្រះពុទ្ធ ឱ! ព្រះធម៌ ឱ! សម្បទារបស់ព្រះសាស្ដានៃ
យើងទាំងឡាយដែលសាវកនឹងធ្វើឲ្យជាក់ច្បាស់នូវធម៌ប្រាកដ
ដូច្នោះ ។ សក្កាយៈ គឺបញ្ចុបាទានក្ខន្ធ អាត្មាអញបានហើយ
ក្នុងកប្បទាំងឡាយរាប់មិនបាន រាងកាយនេះជាទីបំផុតរបស់

បញ្ចុបាទានក្ខន្ធទាំងនោះ រាងកាយនេះ ជាខាងក្រោយរបស់
បញ្ចុបាទានក្ខន្ធទាំងនោះ សង្សារប្រកបដោយជាតិនិងមរណៈ
ឥឡូវនេះ ភពថ្មីមិនមានទេ ។

បណ្តាបទទាំងនោះ បទថា **អហោ** ជានិបាត ចុះក្នុងអត្ថនៃការអស្ចារ្យ បទថា **ពុទ្ធា** បានដល់ សព្វញ្ញុពុទ្ធ ជាពហុវចនៈ ដោយជាពាក្យសម្តែងសេចក្តីគោរព សេចក្តីថា ឱ! ព្រះសម្ពុទ្ធមានគុណគួរអស្ចារ្យ ។

បទថា **ធម្មា** បានដល់ លោកុត្តរធម៌ ៩ និងព្រះបរិយត្តិធម៌ ។

បទថា **អហោ នោ សត្ថុ សម្បទា** សេចក្តីថា គួរអស្ចារ្យសម្បត្តិរបស់ព្រះសាស្តា គឺព្រះទសពលនៃយើងទាំងឡាយ ។

បទថា **យត្ថ** សេចក្តីថា ដោយអំណាចនៃការប្រព្រឹត្តព្រហ្មចរិយៈក្នុងព្រះសាស្តាណា ។

បទថា **ឯតាទិសំ ធម្មំ សាវកោ សច្ឆិកាហិតិ** សេចក្តីថា ឈ្មោះថាសាវក នឹងធ្វើឲ្យជាក់ច្បាស់នូវធម៌ដូច្នេះ គឺបែបនេះ បានដល់ ធម៌ដែលនាំមកនូវការអស់ទៅនូវកិលេសដោយមិនសេសសល់ ដែលជាបរិវារនៃឈាននិងអភិញ្ញា ដែលបរិសុទ្ធវិសេសដោយល្អ ស្ងប់ប្រណីត កំពូល ព្រោះហេតុនោះ ទើបព្រះថេរៈប្រកាសឲ្យដឹង ដល់ការបង្អោនចិត្តទៅក្នុងគុណរបស់ព្រះរតនត្រ័យថា ឱ! ព្រះមានព្រះភាគសម្មាសម្ពុទ្ធទាំងឡាយមានគុណគួរអស្ចារ្យជាហេតុនៃការត្រាស់ដឹងគុណវិសេសយ៉ាងនេះ គុណរបស់ព្រះធម៌គួរអស្ចារ្យ សម្បត្តិរបស់ព្រះសាស្តានៃយើងទាំងឡាយគួរអស្ចារ្យ ការបដិបត្តិរបស់ព្រះ

សង្ឃឈ្មោះថា ព្រះថេរៈប្រកាសហើយ ដោយការប្រកាសនូវសម្បត្តិរបស់ព្រះធម៌នោះឯង ។

ព្រះថេរៈសម្តែងការធ្វើឲ្យជាក់ច្បាស់នូវព្រះធម៌ ដែលខ្លួនសម្តែងហើយ ដោយអំណាចនៃគុណសម្បត្តិទូទៅយ៉ាងនេះ ឥឡូវនេះ បំណងនឹងបង្អោនចូលទៅក្នុងខ្លួន ទើបពោលគាថាជាដើមថា **អសង្ខេយ្យេសុ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសង្ខេយ្យេសុ** បានដល់ ក្នុងមហាកប្បទាំងឡាយដែលកន្លងផុតហួសគន្លងនៃការរាប់ ។

បទថា **សក្កាយា** បានដល់ ឧបាទានក្ខន្ធ ៥ អធិប្បាយថា ឧបាទានក្ខន្ធទាំង ៥ នេះ លោកហៅថា សក្កាយ ព្រោះជាទីប្រជុំនៃធម៌ មានដោយបរមត្ថ ។

បទថា **អហុ** សេចក្តីថា ខន្ធ ៥ នោះ ជារបស់មិនទៅប្រាស ព្រោះមិនជួបនូវឧបាយជាគ្រឿងញ៉ាំងសក្កាយទិដ្ឋិឲ្យវិលត្រឡប់ ។

បទថា **តេសមយំ បច្ឆិមកោ ចរិមោយំ សមុស្សយោ** សេចក្តីថា ព្រោះខន្ធ ៥ នេះជាខន្ធ ៥ ចុងក្រោយនៃខន្ធ ៥ ទាំងពួង ព្រោះហេតុនោះឯង ទើបរាងកាយនេះ រាប់ថាជារាងកាយដែលមានក្នុងទីបំផុតដូច្នោះសង្សារដែលប្រកបដោយជាតិនិងមរណៈដែលបណ្ឌិតតែងដឹងថា ជាលំដាប់នៃខន្ធជាដើម ទើបកពប្ចឹមិនមានក្នុងឥឡូវនេះ ព្រោះមិនមានកពប្ចឹតទៅទៀត អធិប្បាយថា ជាតិនេះជាជាតិចុងក្រោយ ។

អដ្ឋកថា កុមារកស្សបត្ថេរគាថា ចប់

## ធម្មបាលត្ថេរគាថា

[ ១៦៣ ] ភិក្ខុណានៅក្មេង ប្រកបព្យាយាមក្នុងព្រះពុទ្ធសាសនា នាកាលពួកសត្វកំពុងដេកលក់ ភិក្ខុនោះជាអ្នកភ្ញាក់រឭក ជីវិតរបស់ភិក្ខុនោះមិនសោះសូន្យទេ ។ ហេតុនោះ អ្នកមានប្រាជ្ញា កាលរឭកឃើញនូវសាសនានៃព្រះពុទ្ធទាំងឡាយហើយ គួរប្រកបរឿយៗនូវសទ្ធា សីល សេចក្តីជ្រះថ្លា និងការឃើញធម៌ ។

ធម្មបាលត្ថេរ ។

## អដ្ឋកថា

## ធម្មបាលត្ថេរគាថា

[ ១៦៣ ] គាថារបស់ព្រះធម្មបាលត្ថេរ មានពាក្យផ្តើមថា **យោ ហវេ ទហរោ ភិក្ខុ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងសាសនានៃព្រះមានព្រះភាគ ព្រះនាមថាអត្ថទស្សី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាវៈជាអ្នកដឹងក្តីហើយ ចូលទៅកាន់ព្រៃជ្រៅ ដោយករណីយកិច្ចឯណានីមួយ ឃើញព្រះសាស្តាហើយ មានចិត្តជ្រះថ្លាបានថ្វាយផ្លែមិលក្ខុ គឺ ផ្លែជីប្លី ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កាលព្រះសាស្តាបរិនិព្វានហើយ កើតក្នុងត្រកូលព្រាហ្មណ៍ក្នុងដែនអវន្តី ឈ្មោះថាធម្មបាល ចម្រើនវ័យហើយ ចូលទៅកាន់តក្កសិលានគរ រៀនសិល្បសាស្ត្រហើយ កាលធ្វើដំណើរត្រឡប់ បានជួបព្រះថេរៈមួយរូបក្នុងវិហារមួយកន្លែងស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះថេរៈហើយបាននូវសទ្ធាបួសហើយចម្រើនវិបស្សនាបានជាអ្នកមានអភិញ្ញា ៦ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គយល់ឃើញនូវប្រយោជន៍ មានយសធំ ត្រង់ចន្លោះព្រៃ ក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយផ្លែមិលក្ខុព្រឹក្ស ( ដីបី ) ។ ក្នុងកប្បទី ១,៨០០ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈជាអ្នកមានអភិញ្ញា ៦ ហើយ ញុំាងកាលវេលាឲ្យកន្លងទៅដោយសេចក្តីសុខដែលកើតអំពីសមាបត្តិ ថ្ងៃមួយ ឃើញសាមណេរ ២ រូប

---

១-ក្នុងអបទានជាព្រះ មិលក្ខុផលទាយកត្ថេរ ។

ក្នុងវិហារនោះឡើងបេះផ្កាលើដើមឈើ ធ្លាក់មកអំពីមែកឈើដែលបាក់ ទើប ឈរយកដៃទ្រសាមណេរទាំង ២ ដោយអានុភាពនៃឫទ្ធិ ឲ្យសាមណេរទាំង ២ ឈរលើផែនដីដោយសួស្តី កាលនឹងសម្តែងធម៌ដល់សាមណេរទាំងនោះ បានពោលគាថា ២ ថា

ភិក្ខុណានៅក្មេង ប្រកបព្យាយាមក្នុងព្រះពុទ្ធសាសនា នាកាល ពួកសត្វកំពុងដេកលក់ ភិក្ខុនោះជាអ្នកភ្ញាក់រឭក ជីវិតរបស់ ភិក្ខុនោះមិនសោះសូន្យទេ ។ ហេតុនោះ អ្នកមានប្រាជ្ញាកាល រឭកឃើញនូវសាសនានៃព្រះពុទ្ធទាំងឡាយហើយ គួរប្រកប រឿយៗនូវសទ្ធា សីល សេចក្តីជ្រះថ្លា និងការឃើញធម៌ ។

បណ្តាបទទាំងនោះ បទថា **យោ** ជា សព្វនាមមិនចំពោះ ។ បទថា **ហវេ** ត្រឹមតែជានិបាត ចុះក្នុងអត្ថថា មាំទាំ ។

បទថា **ទហរោ** ប្រែថា កំលោះ ។ ឈ្មោះថា **ភិក្ខុ** ព្រោះអត្ថថា រមែង សូម ។ បទថា **យុញ្ជតិ** សេចក្តីថា រមែងព្យាយាម ។

បទថា **ជាគរោ** បានដល់ ប្រកបដោយធម៌ដែលធ្វើឲ្យភ្ញាក់រឭក ។

បទថា **សុត្តេសុ** សេចក្តីថា កាលសត្វទាំងឡាយដេកលក់ លោក អធិប្បាយថា ភិក្ខុណានៅកំលោះ គឺអាយុនៅតិច មិនគិតថា អញនឹងបំពេញ សមណធម៌យ៉ាងនោះ ក្រោយមកក្នុងវេលាចាស់ ព្យាយាមបដិបត្តិដោយការ មិនប្រមាទ ធ្វើនូវសេចក្តីព្យាយាមក្នុងសមថការនានិងវិបស្សនាការនា ក្នុង សាសនារបស់ព្រះពុទ្ធទាំងឡាយ កាលសត្វទាំងឡាយក្រៅអំពីនេះ ដេកលក់

គឺលក់ដោយអវិជ្ជា បានដល់ ប្រមាទហើយ ភិក្ខុនោះ ភ្ញាក់ដោយការប្រកបធម៌របស់អ្នកភ្ញាក់រឭកមានសទ្ធាជាដើម ជីវិតរបស់ភិក្ខុនោះមិនឥតប្រយោជន៍ គឺមិនទទេ ព្រោះបរិបូណ៌ដោយប្រយោជន៍ខ្លួននិងប្រយោជន៍អ្នកដទៃនោះឯង ព្រោះជីវិតនេះ មានសភាពដូច្នេះ ហេតុនោះបុគ្គលមានបញ្ញា គឺភិក្ខុដែលប្រកបដោយបញ្ញា មានឱជាដែលកើតអំពីធម៌ រឭកដល់ពាក្យប្រៀនប្រដៅ គឺឱវាទ បានដល់ អនុសាសនីរបស់ព្រះពុទ្ធទាំងឡាយ មើលឃើញសីសៈរបស់ខ្លួនថា ភ្លើងឆេះទូទៅហើយ គប្បីតាមប្រកបនូវសទ្ធានិងការជឿក្នុងកម្មនិងផលនៃកម្មដែលប្រព្រឹត្តទៅហើយដោយន័យជាដើមថា កម្មមានពិត ផលនៃកម្មមានពិត ដូច្នេះ ។ ( គប្បីតាមប្រកប ) នូវចតុបារិសុទ្ធិសីល ដែលចូលទៅអាស្រ័យសទ្ធានោះ ព្រោះមានការទាក់ទងជាមួយសទ្ធា ដែលជ្រះថ្លាក្នុងព្រះរតនត្រ័យ ប្រព្រឹត្តទៅយ៉ាងនេះថា ព្រះមានព្រះភាគជាអ្នកត្រាស់ដឹងឯងដោយប្រពៃ ធម៌ដែលព្រះមានព្រះភាគត្រាស់ល្អហើយ ព្រះសង្ឃបដិបត្តិល្អ ដូច្នេះ និងនូវការឃើញធម៌ គឺចតុរារិយសច្ចធម៌ ដោយអំណាចនៃការកំណត់ដឹងដោយមគ្គប្បញ្ញាដែលប្រកបដោយវិបស្សនាបញ្ញា អធិប្បាយថា គប្បីធ្វើនូវការខ្វល់ខ្វាយ គឺសេចក្តីព្យាយាមក្នុងធម៌ មានសទ្ធាជាដើមនោះ ។

## អដ្ឋកថា ធម្មបាលត្ថេរគាថា ចប់

## ព្រហ្មាលិត្ថេរគាថា

[ ១៦៤ ] ភិក្ខុណាមួយ បានលះបង់មានះ ជាអ្នកមិនមានអាសវៈ មានឥន្ទ្រិយដល់នូវសេចក្ដីស្ងប់រម្ងាប់ ដូចសេះដែលសារថីបង្ហាត់ល្អហើយ ទុកជាពួកទេវតា ក៏ស្រឡាញ់ភិក្ខុអ្នកមិនញាប់ញ័រនោះ ។ អាត្មាអញបានលះបង់មានះ មិនមានអាសវៈ មានឥន្ទ្រិយដល់នូវសេចក្ដីស្ងប់រម្ងាប់ ដូចសេះដែលនាយសារថីបង្ហាត់ល្អហើយ ទុកជាទេវតាទាំងឡាយ ក៏ស្រឡាញ់អាត្មាអញអ្នកមិនញាប់ញ័រដែរ ។

ព្រហ្មាលិត្ថេរគាថា ។

## អដ្ឋកថា

## ព្រហ្មាលិត្ថេរគាថា

[ ១៦៤ ] គាថារបស់ព្រះព្រហ្មាលិត្ថេរ មានពាក្យផ្ដើមថា **កស្សិន្ទ្រិយានិ សមថំ គតានិ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាវិបស្សី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ថ្ងៃមួយ ឃើញព្រះសាស្ដាត្រាច់ទៅបិណ្ឌបាត មានចិត្តជ្រះថ្លា ថ្វាយបង្គំហើយ បានថ្វាយផ្លែស្វាយ ដែលមានក្លិនក្រអូប ព្រះ

សាស្តាទ្រង់ធ្វើអនុមោទនាហើយយាងទៅ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំង-ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងដែនកោសល មានឈ្មោះថាព្រហ្មាលិ ដល់នូវភាពជាអ្នកដឹងក្តីហើយ កាលហេតុសម្បត្តិជាស់តឿន កើតនូវសេចក្តីសង្វេគក្នុងសង្សារ បួសក្នុងព្រះពុទ្ធសាសនា ដោយអាស្រ័យនូវកល្យាណមិត្ត ដែលជាអ្នកមាំទាំ រៀននូវកម្មដ្ឋាន ដែលសមគួរ ហើយនៅក្នុងព្រៃ ចម្រើនវិបស្សនាបានអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ ព្រោះភាពដែលខ្លួនជាអ្នកមានបញ្ញាចាស់ក្លាហើយ សមដូចគាថាព័ន្ធ ដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស គួរទទួលនូវគ្រឿងបូជា កំពុងស្តេចពុទ្ធដំណើរ ទៅតាមច្រក ហើយបានប្រគេនចារផល ( ផ្លែឈើ ) ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈជាអ្នកមានអភិញ្ញា ៦ ហើយ ញុំាងកាលវេលាឲ្យកន្លងទៅដោយសេចក្តីសុខដែលកើតអំពីមគ្គ និងដោយសេចក្តីសុខដែលកើតអំពីផល ថ្ងៃ

---

១-ក្នុងអបទានជាព្រះ ចារផលិយត្ថេរ ។

មួយ កាលពិនិត្យពិច័យនូវសេចក្តីព្យាយាមដែលព្រះថេរៈកាន់យកក្នុងសេចក្តីព្យាយាម ពោលឧទ្ទិសចំពោះភិក្ខុទាំងឡាយក្នុងដងព្រៃនោះ បានពោល ២ គាថាដោយសេចក្តីថា

ភិក្ខុណាមួយ បានលះបង់មានះ ជាអ្នកមិនមានអាសវៈ មានឥន្ទ្រិយដល់នូវសេចក្តីស្ងប់រម្ងាប់ ដូចសេះដែលសារថីបង្ហាត់ល្អហើយ ទុកជាពួកទេវតា ក៏ស្រឡាញ់ភិក្ខុអ្នកមិនញាប់ញ័រនោះ ។ អាត្មាអញបានលះបង់មានះ មិនមានអាសវៈ មានឥន្ទ្រិយដល់នូវសេចក្តីស្ងប់រម្ងាប់ ដូចសេះដែលនាយសារថីបង្ហាត់ល្អហើយ ទុកជាទេវតាទាំងឡាយក៏ស្រឡាញ់អាត្មាអញអ្នកមិនញាប់ញ័រដែរ ។

គាថាទាំង ២ នោះ មានអធិប្បាយដូចតទៅនេះថា ក្នុងបណ្តាភិក្ខុទាំងឡាយដែលនៅក្នុងដងព្រៃនោះ ឥន្ទ្រិយទាំងឡាយមានចិត្តជាគម្រប់ ៦ របស់ភិក្ខុណា គឺរបស់ភិក្ខុដែលជាថេរៈក្តី នវកក្តី មជ្ឈិមក្តី ដល់នូវការស្ងប់ គឺភាពជាឥន្ទ្រិយដែលទូន្មានហើយ បានដល់ ជាអ្នកមានឥន្ទ្រិយអស់ព្យសហើយ ដូចសេះអស្សតរ ដែលត្រូវនាយសារថីអ្នកឈ្លាសបង្ហឹកហើយ ដូច្នោះ ។ ភិក្ខុណា ឈ្មោះថា **បហីនមានស្ស** ព្រោះលះមានះ ៩ បាន ។ ឈ្មោះថា **អនាសវស្ស** ព្រោះមិនមានអាសវៈទាំង ៤ ។ ឈ្មោះថា **តាទិនោ** ព្រោះដល់នូវលក្ខណៈរបស់តាទិបុគ្គលក្នុងឥដ្ឋារម្មណ៍ជាដើម ទាំងទេវតានិងមនុស្សទាំងឡាយរមែងសរសើរ គឺញញឹមដោយការពេញចិត្តដោយការឃើញបដិ-

បទាប្រពៃជាដើម ។

ដោយកន្ទះបាទដំបូងនៃគាថានោះ ព្រះថេរៈសួរ ( ពោល ) ដល់ការសម្រេចអនាគាមិមគ្គ ព្រោះឥន្ទ្រិយទាំងឡាយរបស់ព្រះអនាគាមីរមែងឈ្មោះថាដល់នូវការស្ងប់ គឺអស់នូវព្យសនហើយ ព្រោះលះនូវកាមរាគៈនិងព្យាបាទបាន ។ ដោយបាទគាថាក្រៅអំពីនេះ សួរដល់ការសម្រេចអរហត្តមគ្គ ព្រោះជាព្រះអរហន្តលោកហៅថា ជាអ្នកលះមានះបានហើយ ជាអ្នកមិនមានអាសវៈ ជាតាទិបុគ្គល ។

កាលនោះព្រះព្រហ្មាលិត្ថេរពោលគាថា បន្ថែមតែពាក្យថា **កស្សិន្ទ្រិយានិ** ដែលព្រះថេរៈ កាន់យកសេចក្តីព្យាយាមពោលទុកហើយនោះ ។ កាលវិសជ្ជនាសេចក្តីនៃគាថានោះ ដោយអំណាចនៃការបង្អោនចូលមកក្នុងខ្លួន ទើបព្យាករអរហត្តផលដោយគាថាទី ២ មានពាក្យថា **មយ្ហិន្ទ្រិយានិ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **មយ្ហិន្ទ្រិយានិ** បានដល់ ឥន្ទ្រិយ មានចក្ខុជាដើមរបស់ខ្ញុំ ។ បទដ៏សេសមានន័យដូចខ្ញុំពោលទុកហើយខាងដើមនោះឯង ។

## អដ្ឋកថា ព្រហ្មាលិត្ថេរគាថា ចប់

## មោឃរាជត្ថេរគាថា

[ ១៦៥ ] ( ព្រះសាស្តាទ្រង់សួរថា ) ម្នាលមោឃរាជ ជាអ្នកមានសម្បុរអាក្រក់ តែមានចិត្តល្អ អ្នកជាភិក្ខុមានចិត្តតម្កល់មាំរឿយៗអស់រាត្រីទាំងឡាយក្នុងកាលត្រជាក់ ប្រកបដោយហេមន្តរដូវ តើអ្នកនឹងធ្វើដោយប្រការដូចម្តេច ។

( មោឃរាជត្ថេរក្រាបទូលថា ) ខ្ញុំព្រះអង្គបានឮដូច្នេះថា ដែនមគធៈទាំងមូល ជាដែនមានសន្ទូងបរិបូណ៌ ពួកភិក្ខុដទៃមានការរស់នៅជាសុខ ( ដោយកម្រាលនិងគ្រឿងស្លៀកដណ្តប់ដ៏ល្អ ) យ៉ាងណា ខ្ញុំព្រះអង្គ ( ក្រាល ) បិទបាំងស្លឹកឈើសម្រេចនូវការដេក ( យ៉ាងនោះដែរ ) ។

**មោឃរាជត្ថេរ ។**

## អដ្ឋកថា

## មោឃរាជត្ថេរគាថា

[ ១៦៥ ] គាថារបស់ព្រះមោឃរាជត្ថេរ មានពាក្យផ្តើមថា **ឆវិបាបកចិត្តភទ្ទក** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ។ ថ្ងៃមួយ ស្តាប់

ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា ឃើញព្រះសាស្ដាតាំងភិក្ខុមួយរូប ទុកក្នុងតំណែងឯតទគ្គៈ ខាងទ្រទ្រង់ចីវរសៅហ្មងទាំងឡាយ ចង់បាននូវតំណែងនោះ បំពេញបុណ្យទុកក្នុងកពនោះៗ ហើយតាំងបណិធានទុក ។ ក្នុងពុទ្ធុប្បាទរបស់ព្រះមានព្រះភាគព្រះនាមថាអត្ថទស្សី កើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវភាពជាអ្នកសម្រេចក្នុងវិជ្ជា និងសិប្បៈរបស់ព្រាហ្មណ៍ទាំងឡាយហើយញុំាងមាណពជាព្រាហ្មណ៍ឲ្យសិក្សានូវវិជ្ជានិងសិប្បសាស្រ្ត ។ ថ្ងៃមួយ ឃើញព្រះមានព្រះភាគអត្ថទស្សីដែលភិក្ខុសង្ឃចោមរោមហើយយាងទៅ មានចិត្តជ្រះថ្លា ទើបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានប្រណម្យអញ្ជលីដាក់លើសិរសាគឺត្បូង ហើយសរសើរព្រះសាស្ដាដោយគាថា ៦ ថា **យាវតា រូបិនោ សត្តា** ពួកសត្វមានរូបក្ដី ដូច្នេះជាដើម ហើយបង្អោនទឹកឃ្មុំពេញកាជនៈថ្វាយព្រះសាស្ដា ។ ព្រះសាស្ដា ទ្រង់ទទួលទឹកឃ្មុំហើយ ទ្រង់ធ្វើអនុមោទនា ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមថាកស្សបៈ បានជាអាមាត្យរបស់ព្រះរាជាព្រះនាមថាកដ្ឋវាហនៈ ជាអ្នកដែលព្រះរាជាបញ្ជូនទៅមួយអន្លើដោយបុរស ១០០០ នាក់ ដើម្បីទូលអារាធនាព្រះសាស្ដា ទៅកាន់សម្នាក់របស់ព្រះសាស្ដាហើយស្ដាប់ធម៌បាននូវសទ្ធាបួសហើយ បំពេញសមណធម៌ ២ ម៉ឺនឆ្នាំ ចុតិអំពីអត្តភាពនោះហើយ អន្ទោលទៅមកក្នុងសុគតិភពប៉ុណ្ណោះអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ មានឈ្មោះថាមោឃរាជ រៀនសិប្បវិជ្ជាក្នុងសម្នាក់នៃពាវរីព្រាហ្មណ៍ កើតនូវសេចក្តីសង្វេគ

បួសជាតាបស មានតាបស ១០០០ ជាបរិវារ ត្រូវពាវរីព្រាហ្មណ៍ បញ្ជូនទៅកាន់សម្នាក់របស់ព្រះសាស្តា មួយអន្លើដោយតាបសទាំងឡាយ មានអជិតតាបសជាដើមទូលសួរបញ្ហាជាមនុស្សទី ១៥ ក្នុងចំនួនតាបសទាំងនោះ លុះចប់ការវិសជ្ជនាបញ្ហា ក៏បានសម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលនោះ ព្រះមានព្រះភាគព្រះនាមអត្ថទស្សី ជាព្រះសយម្ភូឥតមានបុគ្គលផ្ចាញ់បាន មានភិក្ខុសង្ឃចោមរោមស្តេចយាងទៅតាមថ្នល់ ។ ខ្ញុំមានពួកសិស្សហែហមដើរចេញអំពីផ្ទះ លុះចេញទៅ ក៏បានឃើញព្រះលោកនាយកត្រង់ទីនោះ ។ ខ្ញុំធ្វើអញ្ជលីលើសិរសៈ ថ្វាយបង្គំព្រះសម្ពុទ្ធ ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយពោលសរសើរព្រះលោកនាយកថា

ពួកសត្វមានរូបក្តី ឥតរូបក្តី ឥតសញ្ញាក្តី ទាំងប៉ុន្មានពួកសត្វទាំងអស់នោះ តែងប្រជុំចុះខាងក្នុងញាណរបស់ព្រះអង្គ ។ បុគ្គលណា បិទបាំងទឹកដោយសំណាញ់ មានក្រឡាញឹក ពួកសត្វណាមួយនៅក្នុងទឹក ពួកសត្វទាំងនោះរមែងមាននៅខាងក្នុងសំណាញ់ ( របស់បុគ្គលនោះដូចម្តេចមិញ ) ។ សត្វទាំងឡាយណាដែលមានចេតនាទោះបីមានរូបក្តី ឥតរូបក្តី ពួកសត្វទាំងអស់នោះ រមែងប្រជុំចុះខាងក្នុងញាណរបស់ព្រះអង្គ ( ដូច្នោះដែរ ) ។

ព្រះអង្គ ស្រោចស្រង់សត្វលោកនេះ ដែលប្រឡូកប្រឡំ
ដោយងងឹតសត្វទាំងនោះស្តាប់នូវធម៌របស់ព្រះអង្គហើយ
ឆ្លងនូវខ្សែទឹក គឺសេចក្តីសង្ស័យបាន ។ សត្វលោកមាន
អវិជ្ជារួបរឹត មានងងឹតគ្របសង្កត់ហើយ នឹងកម្ចាត់ងងឹត
ទាំងឡាយព្រោះញាណរបស់ព្រះអង្គដែលទ្រោលឡើង ។
ព្រះអង្គមានចក្ខុ បន្ទោបង់នូវងងឹតធំ របស់សត្វទាំងពួង
ជនជាច្រើន លុះស្តាប់ធម៌របស់ព្រះអង្គហើយ នឹងបាន
សម្រេចព្រះនិព្វាន ។

ខ្ញុំញ៉ាំងកោជនឲ្យពេញដោយឃ្មុំផ្អិត ដែលឥតមេ ហើយទ្រ
ដោយដៃទាំងពីរ បង្អោនចូលទៅថ្វាយព្រះមហេសី ។ ព្រះពុទ្ធ
ជាមហាឥសី ព្រះអង្គមានព្យាយាមធំ ទ្រង់ទទួលដោយព្រះ
ហស្តរបស់ព្រះអង្គ ព្រះសព្វញ្ញូទ្រង់សោយនូវឃ្មុំនោះរួចហើយ
ស្តេចហោះឡើងកាន់អាកាសវេហាស៍ ។ ព្រះសាស្តាព្រះនាម
អត្ថទស្សី ជានរាសភៈឋិតនៅឰដ៏អាកាស ទ្រង់ញ៉ាំងចិត្តរបស់
ខ្ញុំឲ្យជ្រះថ្លា ហើយត្រាស់គាថាទាំងឡាយនេះថា

កុលបុត្តណា សរសើរញាណនេះផង សរសើរព្រះពុទ្ធដ៏
ប្រសើរផង កុលបុត្តនោះនឹងមិនទៅកាន់ទុគ្គតិដោយចិត្តដែល
ជ្រះថ្លានោះ ។ កុលបុត្តនោះនឹងបានសោយទេវរាជ្យអស់ ៦៤
ជន នឹងបានសោយប្រទេសរាជ្យ គ្រប់គ្រងផែនដីអស់ ៨០០

ជន នឹងបានជាស្តេចចក្រពត្តិអស់ ៥០០ ជន ។ កុលបុត្ត នោះនឹងបានសោយប្រទេសរាជ្យលើផែនដីអស់មួយអសង្ខេយ្យ ជាអ្នកស្វាធ្យាយមន្តចងចាំមន្តដល់នូវត្រើយនៃវេទទាំង ៣ ។ កុលបុត្តនោះនឹងបួសក្នុងសាសនា របស់ព្រះមានព្រះភាគព្រះនាមគោតម នឹងពិចារណានូវអត្ថដ៏ល្អិតជ្រាលជ្រៅដោយញាណបាន ។ កុលបុត្តនោះ មាននាមថាមោឃរាជ នឹងបានជាសាវ័ករបស់ព្រះសាស្តាអង្គនោះ ជាអ្នកបរិបូណ៌ដោយវិជ្ជា ៣ មានសោឡសកិច្ចធ្វើរួចហើយ ជាអ្នកមិនមានអាសវៈ ។ ព្រះគោ-តមជាអ្នកដឹកនាំពួកដ៏ប្រសើរ នឹងតាំងភិក្ខុនោះក្នុងទីជាឯតទគ្គៈ ។

ខ្ញុំលះបង់នូវយោគធម៌ជារបស់នៃមនុស្ស កាត់ផ្តាច់នូវចំណងក្នុងភពហើយ កំណត់ដឹងនូវអាសវៈទាំងពួង ទាំងជាអ្នកមិនមានអាសវៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

ព្រះថេរៈ សម្រេចអរហត្តហើយ ទ្រទ្រង់នូវសំពត់បង្សុកូលចីវរ ដែលប្រកបដោយសេចក្តីសៅហ្មងទាំង ៣ យ៉ាង គឺសៅហ្មងដោយកាំបិត ១ សៅហ្មងដោយអំបោះ ១ សៅហ្មងដោយទឹកជ្រលក់ ១ ដោយហេតុនោះ ទើបព្រះសាស្តាតាំងព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈ គឺកំពូលជាងភិក្ខុទាំងឡាយខាងទ្រទ្រង់សំពត់ចីវរសៅហ្មង ។ ក្នុងកាលតមក ពោគទាំងឡាយមានពក

និងបូសប្រកបដោយខ្ទុះជាដើម កើតពាសពេញរាងកាយរបស់ព្រះថេរៈ ព្រោះបុរាណកម្មជាបច្ច័យ និងព្រោះមិនធ្វើការព្យាបាល ។ ព្រះថេរៈគិតថា សេនាសនៈជាទោសចំពោះរាងកាយ សូម្បីរដូវរងារ ក៏យកកម្រាលដែលធ្វើដោយចំបើងក្នុងស្រែរបស់អ្នកមគធៈមកក្រាលសិង ។ ថ្ងៃមួយព្រះសាស្តាត្រាស់សួរព្រះថេរៈដែលចូលទៅកាន់ទីបម្រើ ថ្វាយបង្គំហើយអង្គុយក្នុងចំណែកម្ខាងដោយទំនងជាបដិសណ្ឋារៈ ដោយគាថាទី ១ ថា

ម្នាលមោឃរាជជាអ្នកមានសម្បុរអាក្រក់ តែមានចិត្តល្អ អ្នកជាភិក្ខុមានចិត្តតម្កល់មាំរឿយៗអស់រាត្រីទាំងឡាយ ក្នុងកាលត្រជាក់ប្រកបដោយហេមន្តរដូវ តើអ្នកនឹងធ្វើដោយប្រការៈដូចម្តេច ។

បណ្តាបទទាំងនោះ បទថា **ឆវិវណ្ណក** សេចក្តីថា អ្នកឈ្មោះថា មានពណ៌សម្បុរអាក្រក់គឺមានពណ៌សម្បុរមិនផូរផង់ព្រោះជាអ្នកមានពណ៌សម្បុរពាសពេញដោយកមរមាស់និងពងបែកប្រកបដោយខ្ទុះជាដើម ។

បទថា **ចិត្តភទ្ទក** សេចក្តីថា អ្នកមានចិត្តស្អាត គឺមានចិត្តជាសុន្ទរព្រោះលះកិលេសបានដោយឥតសេសសល់ និងព្រោះមានព្រហ្មវិហារធម៌ជាគ្រឿងនៅ ។

បទថា **មោឃរាជ** ជាពាក្យហៅព្រះថេរៈនោះ ។

បទថា **សតតំ សមាហិតោ** សេចក្តីថា ជាអ្នកមានចិត្តប្រកបហើយដោយអរហត្តផលសមាធិអស់កាលជានិច្ច គឺជាប្រចាំ ។

បទថា **ហេមន្តិកសីតកាលរត្តិយោ** សេចក្តីថា អស់រាត្រីកាលដ៏ត្រ-ជាក់ក្នុងហេមន្តសម័យ ។ បទនេះជាទុតិយាវិភត្តិ ប្រើក្នុងអច្ចន្តសំយោគ បាលីថា **ហេមន្តិកាសីតកាលរត្តិយោ** ដូច្នេះក៏មាន ។

បណ្តាបទទាំងនោះ បទថា **ហេមន្តិកា** សេចក្តីថា ឈានចូលកាន់រដូវរងារ គឺទាក់ទងក្នុងហេមន្តរដូវ ។

បទថា **ភិក្ខុ ត្វំសិ** សេចក្តីថា ម្នាលភិក្ខុ អ្នកនឹងធ្វើអ្វី គឺអ្នកមានសភាពយ៉ាងនេះ កាលបុគ្គលដទៃមិនធ្វើសេនាសនៈឲ្យក៏មិនចូលទៅកាន់សេនាសនៈដែលជារបស់សង្ឃ ។

បទថា **កថំ ករិស្សសិ** សេចក្តីថា ព្រះសាស្តាត្រាស់សួរថា អ្នកញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានដូចម្តេចក្នុងរដូវរងារ ដូចដែលពោលហើយ ។ ព្រះថេរៈ កាលព្រះសាស្តាត្រាស់សួរយ៉ាងនេះហើយ កាលក្រាបទូលសេចក្តីនោះ ទើបពោលគាថាដូច្នេះថា

> ខ្ញុំព្រះអង្គបានឮដូច្នេះថា ដែនមគធៈទាំងមូល ជាដែនមានសន្ទូងបរិបូណ៌ ពួកភិក្ខុដទៃមានការរស់នៅជាសុខ ( ដោយកម្រាលនិងគ្រឿងស្លៀកដណ្តប់ដ៏ល្អ ) យ៉ាងណា ខ្ញុំព្រះអង្គ ( ក្រាល ) បិទបាំងស្លឹកឈើសម្រេចនូវការដេក ( យ៉ាងនោះដែរ ) ។

បណ្តាបទទាំងនោះ បទថា **សម្បន្នសស្សា** សេចក្តីថា ប្រូតស្រេចហើយ ព្រះថេរៈហៅដែនមគធៈថា **មគធា** ( ពហុវចនៈ ) ហើយ ។ ព្រះរាជ

*កុមារទាំងឡាយនៅក្នុងជនបទឈ្មោះ* **មគធា** *មគធៈជាជនបទមួយដែលជាលំនៅរបស់អ្នកមគធៈទាំងនោះ ក៏ហៅជាពហុវចនៈថា* **មគធា** *ដូចគ្នាព្រោះជា* **រុឡ្ហី** *សព្ទ ( គឺឯវចនៈប្រើជាពហុវចនៈ ) ។*

*បទថា* **កេវលា** *សេចក្ដីថា មិនមានចំណែកសេសសល់ ។ បទថា* **ឥតិ មេ សុតំ** *សេចក្ដីថា ខ្ញុំព្រះអង្គបានស្ដាប់មកហើយយ៉ាងនេះ ។ បទថា* **សុតំ** *ព្រះថេរៈពោលឲ្យជាប្រទេសដែលលោកមិនធ្លាប់ឃើញ ។ ដ្បិតបទថា* **ឥតិ មេ សុតំ** *នេះ ព្រះថេរៈសម្ដែងអត្ថថា ក្នុងកាលដែលជា រដូវរងាបែបនេះ ខ្ញុំព្រះអង្គអាចនៅក្នុងដែនមគធៈបានគ្រប់ទីកន្លែង ។*

*បទថា* **បលាលច្ឆន្នកោ សេយ្យំ យថញ្ញេ សុខជីវិនោ** *សេចក្ដីថា ព្រះថេរៈប្រកាសយថាលាភសន្តោសរបស់ខ្លួនថា ភិក្ខុទាំងឡាយនៅជាសុខ បានសេនាសនៈដែលជាទីសប្បាយហើយ រមែងដេកដោយមានសេចក្ដីសុខព្រោះកម្រាលនិងសំពត់ដណ្ដប់ដែលល្អយ៉ាងណា ខ្ញុំព្រះអង្គក៏យ៉ាងនោះ ឈ្មោះថាដណ្ដប់កាយដោយចំបើងព្រោះខាងក្រោមក៏ក្រាលដោយចំបើងតែម្យ៉ាង ខាងលើនិងខាងទទឹងក៏ដណ្ដប់រាំងកាយដោយគ្រឿងដណ្ដប់ គឺចំបើងប៉ុណ្ណោះដេកបានយ៉ាងសប្បាយ គឺដេកជាសុខ ។*

## *អដ្ឋកថា មោឃរាជត្ថេរគាថា ចប់*

## វិសាខបញ្ចាលីបុត្តត្ថេរគាថា

[ ១៦៦ ] បុគ្គល មិនគប្បីលើកតម្កើងខ្លួន មិនគប្បីបង្អាប់គេ មិនគប្បីចោលទោសនៃពួកបុគ្គលដទៃ មិនគប្បីបៀតបៀនបុគ្គលអ្នកដល់នូវត្រើយគឺព្រះនិព្វាន មិនគប្បីអួតគុណរបស់ខ្លួនក្នុងកណ្តាលពួកបរិសទ្យ គប្បីជាអ្នកប្រាសចាកឧទ្ធច្ចៈ ជាអ្នកពោលពាក្យល្មមកំណត់ ជាអ្នកមានវត្តល្អប្រពៃ ។ ព្រោះថា បុគ្គលមានប្រាជ្ញាវាងវៃ បានឃើញអត្ថដ៏សុខុមក្រៃលែង បានប្រព្រឹត្តបន្ទាបបន្ទន់ខ្លួន សេពនូវសីលដ៏ចម្រើន មិនមែនបានព្រះនិព្វានដោយក្រឡើយ ។

### វិសាខបញ្ចាលីបុត្តត្ថេរ ។

## អដ្ឋកថា
## វិសាខបញ្ចាលីបុត្តត្ថេរគាថា

[ ១៦៦ ] គាថារបស់ព្រះវិសាខបញ្ចាលីបុត្តត្ថេរ មានពាក្យផ្តើមថា **ន ឧក្ខិបេ នោ ច បរិក្ខិបេ បរេ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកប្បទី ១៤ អំពីកប្បនេះ កើតក្នុងត្រកូលទុគ៌តក្នុងបច្ចន្តគាម ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ ចូលកាន់ព្រៃមួយអន្ទើដោយ

អ្នកបច្ចន្តគាមទាំងឡាយ ដើររកផលាផល ឃើញព្រះបច្ចេកពុទ្ធក្នុងព្រៃនោះ មានចិត្តជ្រះថ្លា បានថ្វាយផ្លែវល្លិ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះកើតក្នុងត្រកូលស្ដេចគ្រប់គ្រងមណ្ឌល នាដែនមគធៈ មានឈ្មោះថាវិសាខ ក្រោយមក ក៏ប្រាកដនាមថា បញ្ចាលបុត្ត ព្រោះភាពជាឱរស ( កូនចិញ្ចឹម ) នៃរាជធីតារបស់ព្រះបាទបញ្ចាល ។ កាលព្រះជនកសោយទិវង្គតហើយកុលបុត្តនោះក៏សោយរាជសម្បត្តិ កាលព្រះសាស្ដាយាងមកកាន់ព្រះរាជវាំងរបស់ទ្រង់ ក៏ទៅកាន់សម្នាក់របស់ព្រះសាស្ដា ស្ដាប់ធម៌ហើយ មានសទ្ធាទើបចេញបួស ទៅកាន់ទេសចារិកជាមួយព្រះសាស្ដា ផ្ដើមចម្រើនវិបស្សនាហើយបានជាអ្នកមានអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ សមដូចគាថាព័ន្ធដែលលោកពោលក្នុងទុកអបទានថា

> ក្នុងកាលនោះ ជនទាំងពួងមកប្រជុំគ្នាក្នុងព្រៃ ជនទាំងឡាយនោះ បាននាំគ្នាស្វែងរកផ្លែឈើ ក៏បាននូវផ្លែឈើ ។ ក្នុងកាលនោះ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ព្រះអង្គត្រាស់ដឹងឯងទ្រង់ឈ្នះកិលេស ក្នុងទីនោះ ខ្ញុំក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយផ្លែវល្លិ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃផលទាន ។ ឱ! ដំណើរដែលខ្ញុំមកក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយ

លំដាប់ ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ
ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បាន
ប្រតិបត្តិហើយ ដូច្នេះ⁽¹⁾។

ព្រះថេរៈជាអ្នកមានអភិញ្ញា ៦ ហើយ ត្រឡប់ទៅកាន់មាតុភូមិដើម្បីអនុគ្រោះពួកញាតិ មនុស្សទាំងឡាយក្នុងទីនោះ ចូលទៅរកព្រះថេរៈ ហើយស្តាប់ធម៌តាមកាល តាមឱកាស ។ ថ្ងៃមួយ សួរព្រះថេរៈដល់លក្ខណៈនៃធម្មកថិកថា បពិត្រលោកម្ចាស់ ភិក្ខុប្រកបដោយគុណ គឺអ្វីប៉ុន្មានហ្ន៎ ទើបហៅថា ធម្មកថិក ព្រះថេរៈកាលនឹងប្រាប់លក្ខណៈនៃធម្មកថិកដល់ជនទាំងនោះ បានពោលគាថា ២ ថា

បុគ្គលមិនគប្បីលើកតម្កើងខ្លួន មិនគប្បីបង្អាប់គេ មិនគប្បី
ថ្កោលទោសនៃពួកបុគ្គលដទៃ មិនគប្បីបៀតបៀនបុគ្គលអ្នក
ដល់នូវត្រើយ គឺព្រះនិព្វាន មិនគប្បីអួតគុណរបស់ខ្លួន ក្នុង
កណ្តាលពួកបរិសទ្យ គប្បីជាអ្នកប្រាសចាកឧទ្ធច្ចៈ ជាអ្នក
ពោលពាក្យល្មមកំណត់ ជាអ្នកមានវត្តល្អចុះ ។ ព្រោះថា
បុគ្គលមានប្រាជ្ញាវាងវៃ បានឃើញអត្ថដ៏សុខុមក្រៃលែង បាន
ប្រព្រឹត្តបន្ទាបបន្ថោនខ្លួន សេពនូវសីលដ៏ចម្រើន មិនមែនបាន
ព្រះនិព្វានដោយក្រឡើយ ។

បណ្តាបទទាំងនោះ បទថា **ន ឧក្កំសេ** សេចក្តីថា មិនគប្បីលើកខ្លួនឡើង

---

១-ក្នុងអបទានជាព្រះ វល្លិផលទាយកត្ថេរ ។

គឺមិនគប្បីលើកតម្កើងខ្លួនដោយត្រកូល មានជាតិជាដើម និងដោយគុណមាន
ភាពជាអ្នកចេះដឹងជាដើម ។

បទថា **នោ ច បរិក្ខិបេ បរេ** សេចក្តីថា មិនគប្បីបង្អាប់អ្នកដទៃ គឺ
បុគ្គលដទៃ ដោយជាតិជាដើមនោះឯង គឺមិនគប្បីសង្កត់អ្នកដទៃ ដោយបិទ
បាំងគុណ ឬមិនគប្បីសង្កត់សង្កិនអ្នកដទៃ ដោយអំណាចនៃការទម្លាយគុណ
គប្បីភ្ជាប់សេចក្តីយ៉ាងនេះថា មិនគប្បីថ្កោលទោសអ្នកដទៃ អធិប្បាយថា មិន
វាយប្រហារបុគ្គលដទៃដោយអំណាចនៃការសម្លឹងទោស បានដល់ មិនគប្បី
សម្លឹងមើលអ្នកដទៃក្នុងផ្លូវគ្រោតគ្រាត អាចារ្យពួកខ្លះពោលថា **ន ឱក្ខិបេ**
ដូច្នេះក៏មាន ឯសេចក្តីក៏ដូចគ្នា ។

បទថា **ឱរគតំ** សេចក្តីថា មិនគប្បីថ្កោលទោស គឺមិនគប្បីហាម មិន
គប្បីជ្រៀតជ្រៀត បានដល់ មិនគប្បីមើលងាយនូវព្រះខីណាស្រព ដែលជា
អ្នកដល់នូវត្រើយនៃវិជ្ជា ជាអ្នកដល់ត្រើយនៃសង្សារ ជាអ្នកមានវិជ្ជា ៣ ឬ
មានអភិញ្ញា ៦ ។

បទថា **ន ចត្តវណ្ណំ បរិសាសុ ព្យាហរេ** សេចក្តីថា ជាអ្នកមិនប្រាថ្នា
លាភសក្ការៈ និងការសរសើរ មិនគប្បីពោលសរសើរគុណរបស់ខ្លួនក្នុង
បរិស័ទ មានខត្តិយបរិស័ទជាដើម ។

បទថា **អនុទ្ធតោ** សេចក្តីថា វៀរចាកនូវការរាយមាយ ព្រោះធម្មក
ថិកទាំងឡាយរមែងមិនត្រេកអរដោយពាក្យរបស់បុគ្គលដែលរាយមាយ ។

បទថា **សម្មិតភាណិ** សេចក្តីថា ពោលដោយពាក្យល្មមប្រមាណដោយ

ប្រពៃនោះឯង អធិប្បាយថា មានប្រក្រតីពោលនូវពាក្យដែលប្រកបទៅដោយប្រយោជន៍ប៉ុណ្ណោះ ជាពាក្យត្រូវកាល មានទីអាង មានទីបំផុត ។ ពាក្យរបស់បុគ្គលដែលពោលលើសអំពីនេះទៅ រមែងមិនជាទីសណ្ដាប់ ។

បទថា **សុព្វតោ** ជាអ្នកមានវត្តល្អ គឺសម្បូរដោយសីល គប្បីនាំបទកិរិយាថា **សិយា** ( គប្បីជា ) មកប្រកបចូលផងដែរ ។

ព្រះថេរៈពោលលក្ខណៈ នៃធម្មកថិកដោយន័យសង្ខេបប៉ុណ្ណោះ យ៉ាងនេះហើយ បង្អោនចិត្តនឹកដល់ភាពជាគុណទាំងនោះ ដែលខ្លួនតម្កល់ទុកក្នុងខ្លួនហើយ ដឹងថាមហាជនមានសេចក្ដីជ្រះថ្លាលើសប្រមាណ កាលនឹងសម្ដែងថា ធម្មកថិកដែលមានលក្ខណៈយ៉ាងនេះ អាស្រ័យវិមុត្តាយតនៈហើយ រមែងបាននូវព្រះនិព្វាន ដោយមិនលំបាកឡើយ គឺបានដោយងាយនោះឯង ទើបពោលគាថាទី ២ ជាដើមថា **សុសុខុមនិបុណត្ថទស្សិនា** ដូច្នេះជាដើម ។

អត្ថនៃគាថាទី ២ នោះ ខ្ញុំបានពោលខាងដើមហើយនោះឯង ។

## អដ្ឋកថា វិសាខបញ្ចាលីបុត្តត្ថេរគាថា ចប់

## ចូឡកត្ថេរគាថា

[ ១៦៧ ] ពួកក្មោក ជាសត្វមានកំប៉ោយល្អ មានសំណុំកន្ទុយល្អ មានករខៀវល្អ មានមុខល្អ មានសម្រែកពីរោះ តែងបន្លឺឡើងផង ទេសភាពធំនេះមានស្មៅខៀវល្អ មានទឹកជ្រួតជ្រាបល្អផង អាកាសមានពពកល្អផង ។ អ្នកជាបុគ្គលមានសភាពគួរសមដោយប្រពៃ ( ចូរចម្រើន ) នូវឈានរបស់ព្រះយោគាវចរ អ្នកមានចិត្តល្អ ចូរមានព្យាយាមល្អក្នុងព្រះពុទ្ធសាសនា ដោយប្រពៃ ចូរបាននូវព្រះនិព្វាន ជាបទដ៏ទៀងឧត្តម ជាធម៌មានពណ៌សល្អក្រៃពេក ជាធម៌ល្អិត ជាធម៌ដែលគេកម្រឃើញដោយងាយ ។

ចូឡកត្ថេរ ។

## អដ្ឋកថា

## ចូឡកត្ថេរគាថា

[ ១៦៧ ] គាថារបស់ព្រះចូឡកត្ថេរ មានពាក្យផ្តើមថា **នទន្តិ មោរា សុសិខា សុបេខុណា** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាសិខី ក្នុងកប្បទី ៣១ អំពីភទ្ទកប្បនេះ កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូលដល់នូវភាពជាអ្នកដឹងក្តីហើយ

ថ្ងៃមួយ ឃើញព្រះសាស្តា មានចិត្តជ្រះថ្លា បានថ្វាយផ្លែចេក ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំង-ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងនគររាជគ្រឹះ មានឈ្មោះថាចូឡកៈ ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្តា ក្នុងកាលដែលទ្រង់ទូន្មានដំរីឈ្មោះ ធនបាល បួសហើយបំពេញសមណធម៌ក្នុងគុហា ឥន្ទសាល ។ ថ្ងៃមួយ លោកអង្គុយត្រង់មាត់ទ្វារគុហា សម្លឹងមើលស្រែអ្នកមគធៈ ។

ក្នុងខណៈនោះ មេឃញុំាងភ្លៀងឲ្យធ្លាក់តាមរដូវកាល បន្លឺសំឡេងដ៏ខ្លាំងពីរោះ មានពពករបរយោរបព៉ាន់ស្រទាប់ ញុំាងភ្លៀងឲ្យធ្លាក់ពេញលម្ហ ល្អដូចកំពូលអញ្ជនៈ ។ ម្យ៉ាងទៀត ហ្វូងក្ងោក ស្តាប់សំឡេងផ្គរ នាំគ្នាត្រេកអរ បន្លឺសំឡេងយំ នាំគ្នាពត់ពែនក្នុងប្រទេសនោះៗ ។ កាលករជកាយស្ងប់រម្ងាប់ហើយ ព្រោះកម្តៅក្នុងរដូវក្តៅកន្លងទៅ ដោយផស្សៈនៃខ្យល់ក្នុងពេលភ្លៀង ធ្វើឲ្យបន្ទប់ដែលជាទីលំនៅរបស់ព្រះថេរៈដល់នូវភាពត្រជាក់ ចិត្តក៏ជាឯកគ្គ-តារម្មណ៍ ព្រោះបាននូវឧតុជាទីសប្បាយ ឈមចុះកាន់គន្លងកម្មដ្ឋាន ។ ព្រះថេរៈដឹងដូច្នោះហើយ កាលញុំាងចិត្តឲ្យមានឧស្សាហៈក្នុងភាវនាដោយបំណងប្រាប់ថា មានការដល់ព្រមនៃកាលវេលាជាដើម បានពោលគាថា ២ ថា

ពួកក្ងោក ជាសត្វមានកំប៉ោយល្អ មានសំណុំកន្ទុយល្អ មាន
កខៀវល្អ មានមុខល្អ មានសម្រែកពីរោះ តែងបន្លឺឡើងផង
ទេសភាពធំនេះ មានស្មៅខៀវល្អ មានទឹកជ្រួតជ្រាបល្អផង

អាកាសមានពពកល្អផង ។ អ្នកជាបុគ្គលមានសភាពគួរសម ដោយប្រពៃ ( ចូរចម្រើន ) នូវឈានរបស់ព្រះយោគាវចរ អ្នកមានចិត្តល្អ ចូរមានព្យាយាមល្អក្នុងព្រះពុទ្ធសាសនាដោយប្រពៃ ចូរបាននូវព្រះនិព្វានជាបទដ៏ទៀងឧត្តមជាធម៌មានពណ៌សល្អក្រៃពេក ជាធម៌ល្អិត ជាធម៌ដែលគេកម្រឃើញដោយងាយ ។

បណ្ដាបទទាំងនោះ បទថា **ឧន្នទ្ធិ មោរា សុសិខា សុបេខុណា សុនីលគីវា សុមុខា សុគជ្ជិនោ** សេចក្ដីថា ក្ងោកទាំងឡាយនេះ ឈ្មោះថា **សុសិខា** ព្រោះប្រកបទៅដោយសិរតាំងនៅក្បាលល្អ ឈ្មោះថា **សុបេខុណា** ព្រោះប្រកបទៅដោយរោមកន្ទុយដ៏ល្អ មានពណ៌ផ្សេងៗ មិនមែនតិច ល្អគួរមើល ឈ្មោះថា **សុនីលគីវា** ព្រោះប្រកបទៅដោយកមានពណ៌ខៀវល្អ ដូចជាមានពណ៌ត្បូងបម្រុះ ។ ឈ្មោះថា **សុមុខា** ព្រោះមាន ចំពុះល្អ ឈ្មោះថា **សុគជ្ជិនោ** ព្រោះមានសំឡេងពីរោះជាប់ចិត្ត ។ ក្ងោកទាំងឡាយមានសិរ យំពីរោះដូចសំឡេងតន្ត្រី បញ្ចេញសព្ទសំនៀងស្រែក ដោយសំឡេងគួរជាទីត្រេកអរ ។

បទថា **សុសទ្ទលា ចាបិ មហាមហី អយំ** សេចក្ដីថា ផែនដីធំនេះមានស្បូវក្លាំងដេរដាស មានតិណ្ណជាតិខៀវស្រងាត់ ។

បទថា **សុព្យាបិតម្ពុ** សេចក្ដីថា មានទឹកផ្អែតទូទៅ គឺមានជលាល័យហូរផ្សាយទៅ ព្រោះមានទឹកហូរច្រើនផ្សាយទៅក្នុងទីនោះៗ ដែលកើតអំពី

ភ្លៀងធ្លាក់ថ្មីៗ ។ បាឋៈថា **សុសុក្កតម្ពុ** ដូច្នេះក៏មាន ដែលមានអធិប្បាយថា មានជលាល័យស្អាតបរិសុទ្ធ ។

បទថា **សុវលាហកំ ឆកំ** សេចក្ដីថា នភាកាសនេះ ឈ្មោះថា **សុវ-លាហកំ** ព្រោះមានវលាហក គឺមេឃល្អ តាំងនៅដូចគ្នានឹងត្របកឧប្បល ខៀវផ្សាយទៅដោយជុំវិញ ។

បទថា **សុកល្លរូបោ សុមនស្ស ឈាយិតំ** សេចក្ដីថា ឥឡូវនេះ អ្នកក៏មានការដល់ព្រមយ៉ាងល្អ គឺមានសភាពដែលគួរដល់ការងារ ព្រោះបាននូវឧតុជាទីសប្បាយ ចូរសម្លឹងនូវឈានដែលព្រះយោគាវចរមានចិត្តល្អ ព្រោះមានចិត្តមិនត្រូវនីវរណៈគ្របសង្កត់ សម្លឹងដោយអំណាចនៃអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ។

បទថា **សុនិក្កមោ ។បេ។ អច្ចុតំ បទំ** សេចក្ដីថា អ្នកសម្លឹងឈានយ៉ាងនេះជាការល្អ គឺជាអ្នកមានព្យាយាមល្អ ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធដែលត្រាស់ដឹងល្អហើយ ចូរសម្រេចគឺចូរធ្វើឲ្យជាក់ច្បាស់ដោយសម្មាបដិបត្តិ ដោយធ្វើឲ្យប្រចក្សដោយខ្លួនឯងនូវព្រះនិព្វាននោះ ដែលឈ្មោះថា **សុសុក្កំ** ព្រោះជាអ្នកមានសីលបរិសុទ្ធល្អហើយ ឈ្មោះថា **សុក្កំ** ព្រោះមិនចូលដល់គោចរនៃសេចក្ដីសៅហ្មងទាំងពួង ឈ្មោះថា **និបុណំ** ព្រោះភាពជាអារម្មណ៍នៃញាណដ៏ល្អិត ឈ្មោះថា **សុទុទ្ទសំ** ព្រោះភាពជាធម៌ជ្រាលជ្រៅក្រៃលែង ឈ្មោះថា **ឧត្តមំ** ព្រោះជារបស់ប្រណីតនិងព្រោះជារបស់ប្រសើរ ឈ្មោះថា **អច្ចុតំ បទំ** ព្រោះភាពជាសភាវៈដែលទៀង ។

ព្រះថេរៈកាលពោលទូន្មានខ្លួនយ៉ាងនេះឯង ជាអ្នកមានចិត្តតាំងមាំហើយ ព្រោះបានឧតុជាទីសប្បាយ ខ្វល់ខ្វាយក្នុងវិបស្សនាសម្រេចអរហត្តផលហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំបានឃើញព្រះលោកនាយក ទ្រង់រុងរឿងដូចផ្កាកណិការ ឬដូចព្រះចន្ទក្នុងថ្ងៃទី ១៥ កើត ឬក៏ដូចទីបរុក្ខ ( ដើមឈើប្រចាំទ្វីប ) ដ៏រុងរឿង ។ ខ្ញុំក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានយកផ្លែចេកថ្វាយព្រះសាស្តា ហើយថ្វាយបង្គំ ដើរចេញទៅ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈសម្រេចអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួន កើតបីតិនិងសោមនស្ស ពោលគាថានោះដដែលទៀត ដោយន័យថា **ឆនន្តិ មោរា** ដូច្នេះជាដើម ។ ដោយហេតុនោះ គាថាទាំង ២ នោះឯងបានជាគាថាព្យាករ អរហត្តផលរបស់ព្រះថេរៈ ។

## អដ្ឋកថា ចូឡកគ្គេរគាថា ចប់

---

១-ក្នុងអបទានជាព្រះ កទលិផលទាយកត្ថេរ ។

## អនូបមត្ថេរគាថា

[ ១៦៨ ] ចិត្តមកកាន់សេចក្ដីត្រេកត្រអាល ដែលកម្មក្កិលេសលើកឡើង ហើយកាន់ដែកស្រួចគឺភព ដែកស្រួចគឺភពនិងកំណាត់ឈើគឺកាមគុណ មាននៅក្នុងទីណា អ្នកតែងទៅក្នុងទីនោះៗ ។ នែចិត្តចង្រៃ អញប្រាប់ឯង នែចិត្តកំណាច អញប្រាប់ឯង ព្រះសាស្ដាដែលគេបានដោយក្រ ( ឥឡូវនេះ ) អ្នកបានហើយ អ្នកកុំដឹកនាំអញទៅក្នុងអំពើឥតប្រយោជន៍ឡើយ ។

**អនូបមត្ថេរ ។**

## អដ្ឋកថា

## អនូបមត្ថេរគាថា

[ ១៦៨ ] គាថារបស់ព្រះអនូបមត្ថេរ មានពាក្យផ្ដើមថា **នន្ទមានាគតំ ចិត្តំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងកប្បទី ៣១ រាប់ថយអំពីភទ្ទកប្បនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ថ្ងៃមួយឃើញព្រះបច្ចេកពុទ្ធព្រះនាមថាបទុមៈ ត្រាច់បិណ្ឌបាតតាមផ្លូវ មានចិត្តជ្រះថ្លា បូជាដោយផ្កាអង្កោល ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលអ្នកមានស្ដុកស្ដម្ភក្នុងដែនកោសល

មានឈ្មោះថាអនូបមៈ ព្រោះជាអ្នកសម្បូរដោយរូបសម្បត្តិ ចម្រើនវ័យហើយ លះកាមទាំងឡាយ បួសហើយ ព្រោះភាពជាអ្នកសម្បូរដោយឧបនិស្ស័យ ប្រកបការចម្រើនវិបស្សនាក្នុងព្រៃ ចិត្តរបស់លោកស្ទុះទៅក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើមខាងក្រៅ កម្មដ្ឋានក៏ប្រែប្រួលទៅ ។ ព្រះថេរៈកាលសង្កត់សង្កិនចិត្តដែលស្ទុះទៅ ទើបពោលដាស់តឿនខ្លួនដោយគាថា ២ ថា

ចិត្តមកកាន់សេចក្ដីត្រេកត្រអាល ដែលកម្មកិលេសលើកឡើង
ហើយកាន់ដែកស្រួច គឺភព ដែកស្រួចគឺភពនិងកំណាត់ឈើ
គឺកាមគុណមាននៅក្នុងទីណា អ្នកតែងទៅក្នុងទីនោះៗ ។ នែ
ចិត្តចង្រៃ អញប្រាប់ឯង នែចិត្តកំណាច អញប្រាប់ឯង ព្រះ
សាស្ដាដែលគេបានដោយក្រ ( ឥឡូវនេះ ) អ្នកបានហើយ
អ្នកកុំដឹកនាំអញទៅក្នុងអំពើឥតប្រយោជន៍ឡើយ ។

បណ្ដាបទទាំងនោះ បទថា **ឆន្ទមាឆាគតំ ចិត្តំ** សេចក្ដីថា ចិត្តមកកាន់ការត្រេកអរ បានដល់ ចិត្តដែលត្រេកអរក្នុងភពនោះៗ នៃតណ្ហាដែលជាតួហេតុនៃការត្រេកអរក្នុងភពនោះៗ មកដល់នូវការត្រេកអររីករាយចាកភពនេះទៅកាន់ភពនោះ ។ បទថា **សូលមារោបមានកំ** សេចក្ដីថា ចិត្តដែលកម្មកិលេសទាំងឡាយ លើកឡើងកាន់ភពនោះៗ ដែលឈ្មោះថា **សូល** ព្រោះដូចគ្នានឹងលំពែងដោយឋានៈជាទីកើតនៃទុក្ខ អស់កាលមានប្រមាណប៉ុណ្ណោះ ។

បទថា **តេន តេនេវ វជសិ យេន សូលំ កលិង្គរំ** សេចក្ដីថា ភពពោលគឺលំពែងនិងកាមគុណពោលគឺកំណាត់ឈើ ដែលបានឈ្មោះថា ជ្រញ់

សម្រាប់សម្រេចទោស ដែលមានក្នុងទីណាមួយ អ្នកមានបាបចិត្តនោះៗរមែង ដើរទៅ គឺចូលដល់ស្ថានទីនោះៗឯង បានដល់ មិនពិចារណាដល់សេចក្តីវិនាសរបស់ខ្លួន ។

បទថា **តាហំ ចិត្តកលឹ ព្រូមិ** សេចក្តីថា ព្រោះហេតុនោះ ទើបខ្ញុំពោលចិត្តនោះថា ជាចិត្តមានទោស គឺជាចិត្តកាឡកណ្ណី ព្រោះមានសេចក្តីប្រមាទ ។ ខ្ញុំពោលគឺ នឹងប្រាប់ថា ធម៌នោះប្រទូស្តចិត្ត គឺ បំផ្លាញនូវចិត្ត ព្រោះនាំមកនូវសេចក្តីវិនាសដល់សន្តានដែលមានឧបការៈច្រើនដល់ខ្លួន ពោលគឺចិត្ត ។ អាចារ្យពួកខ្លះពោលថា **ចិត្តទុព្ភកា** ដូច្នេះក៏មាន សេចក្តីថា សភាពចិត្តដែលមិនមានបុណ្យវាសនា ឬចិត្តដែលមានបុណ្យតិច ។ បើមានអ្នកសួរថា នឹងពោលដូចម្តេច ឆ្លើយថា នឹងប្រាប់ថា ព្រះសាស្តាដែលគេបានដោយក្រ ( ឥឡូវនេះ ) អ្នកបានហើយ អ្នកកុំដឹកនាំអញទៅក្នុងអំពើឥតប្រយោជន៍ឡើយ គឺលោកទទេចាកព្រះពុទ្ធមកច្រើនកប្បរាប់មិនអស់ កាលព្រះសាស្តាកើតឡើងហើយ សម្បត្តិគឺភាពជាមនុស្ស និងការបានចំពោះនូវសទ្ធាជាដើម ក៏គង់ជារបស់រកបានដោយលំបាកពិត កាលបានសម្បត្តិទាំងនោះហើយ សូម្បីព្រះសាស្តាក៏នៅតែរកមិនបាននោះឯង ឥឡូវនេះ ព្រះសាស្តាដែលបុគ្គលរកបានដោយក្រយ៉ាងនេះ អ្នកក៏បានហើយ កាលអ្នកបានសាស្តានោះហើយ អ្នកកុំបបួលអញក្នុងអកុសល ដែលមានតែទោស មិនមានប្រយោជន៍ក្នុងបច្ចុប្បន្ន និងនាំសេចក្តីវិនាស នាំនូវសេចក្តីក្តៅក្រហាយមកឲ្យក្នុងកាលតទៅ ។ ព្រះថេរៈកាលពោលទូន្មានចិត្តរបស់ខ្លួនយ៉ាងនេះឯង ចម្រើនវិបស្សនា សម្រេច

អរហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ក្នុងកាលនោះ ព្រះសម្ពុទ្ធព្រះនាមបទុមៈ គង់នៅលើភ្នំចិត្តកូដ
ខ្ញុំបានឃើញព្រះពុទ្ធជាសយម្ភូអគ្គនោះហើយ ក៏ចូលទៅជិត ។
ក្នុងកាលនោះ ខ្ញុំបានឃើញផ្កាអង្កោលរីក ហើយបេះកាន់ដើរ
ចូលទៅបូជាព្រះជិនស្រីសម្ពុទ្ធព្រះនាមបទុមៈ ។ ក្នុងកប្បទី ៣១
អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសល
កម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា
៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ
ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

អដ្ឋកថា អនូបមត្ថេរគាថា ចប់

---

១-ក្នុងអបទានជាព្រះ អង្កោលបុប្ផិយត្ថេរ ។

## វជ្ជិតត្ថេរគាថា

[ ១៦៩ ] អាត្មាអញ កាលនៅជាបុថុជ្ជន មានងងឹតគឺអវិជ្ជាកើតហើយ មិនបានឃើញអរិយសច្ចៈទាំងឡាយ ក៏អន្ទោលទៅអស់កាលជាអង្វែង តែងវិលទៅក្នុងគតិទាំងឡាយ ។ អាត្មាអញនោះ ជាអ្នកមិនប្រមាទ បានធ្វើសង្សារទាំងឡាយឲ្យវិនាសហើយ បានកាត់ផ្តាច់គតិទាំងពួងអស់ហើយឥឡូវនេះភពថ្មីមិនមានឡើយ ។

វជ្ជិតត្ថេរ ។

---

## អដ្ឋកថា

## វជ្ជិតត្ថេរគាថា

[ ១៦៩ ] គាថារបស់ព្រះវជ្ជិតត្ថេរ មានពាក្យផ្តើមថា **សំសរំ ទីឃ-មទ្ធានំ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងកប្បទី ៦៥ រាប់ថយអំពីកប្បនេះ កើតក្នុងបច្ចន្តគាមមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្តីហើយ ធ្វើជាព្រានព្រៃ ថ្ងៃមួយ ត្រាច់ទៅឃើញព្រះបច្ចេកពុទ្ធនាមថា ឧបសន្តៈ ជាអ្នកនៅក្នុងគុហានៃភ្នំ កុលបុត្តនោះឃើញការស្ងប់រម្ងាប់របស់ព្រះបច្ចេកពុទ្ធហើយ មានចិត្តជ្រះថ្លា បានធ្វើការបូជាដោយផ្កាចម្បា ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំង-ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលស្តុកស្តម្ភ ក្នុងដែនកោសល ចាប់តាំងពីថ្ងៃដែលកុលបុត្តនោះកើត គ្រាន់តែដល់ដៃមាតុគ្រាម ក៏ស្រែកយំ បានឮថា កុលបុត្តនេះ ចុតិអំពីព្រហ្មលោក មកកើតក្នុងមនុស្សលោកនេះ ព្រោះកុលបុត្តនោះអត់ធន់នឹងការប៉ះពាល់របស់មាតុគ្រាមមិនបាន ដូច្នោះ ទើបបានឈ្មោះថាវជ្ជិតៈ ព្រោះវៀរចាកការពាល់ត្រូវរបស់មាតុគ្រាម ។ កុលបុត្តនោះចម្រើនវ័យហើយ ឃើញយមកប្បាដិហារ្យ របស់ព្រះសាស្តា បាននូវសទ្ធាបួសហើយផ្តើមចម្រើនវិបស្សនាបានអភិញ្ញា ៦ ក្នុងថ្ងៃនោះឯង សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះសម្ពុទ្ធមានព្រះហឫទ័យស្ងប់រម្ងាប់ គង់នៅនាចន្លោះភ្នំ ខ្ញុំបានយកផ្កាចម្ប៉ាមួយ ដើរចូលទៅគាល់ព្រះសម្ពុទ្ធដ៏ឧត្តម ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានកាន់ផ្កានោះដោយដៃទាំងពីរហើយបូជាព្រះបច្ចេកមុនីដ៏ឧត្តមដែលទ្រង់ឈ្នះកិលេស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិ-មោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈមានអភិញ្ញា ៦ ហើយ រឭកដល់បុព្វេនិវាសរបស់ខ្លួន ទើប

---

១-ក្នុងអបទានជាព្រះ ឯកចម្បកបុប្ផិយត្ថេរ ។

ពោលគាថា ២ ដោយធម្មសង្វេគថា

អាត្មាអញ កាលនៅជាបុថុជ្ជន មានងងឹតគឺអវិជ្ជាកើត ហើយ មិនបានឃើញអរិយសច្ចៈទាំងឡាយ ក៏អន្ទោលទៅអស់កាលជាអង្វែង តែងវិលទៅក្នុងគតិទាំងឡាយ ។ អាត្មាអញនោះជាអ្នកមិនប្រមាទ បានធ្វើសង្សារទាំងឡាយ ឲ្យវិនាសហើយ បានកាត់ផ្តាច់គតិទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីមិនមានឡើយ ។

បណ្តាបទទាំងនោះ បទថា **សំសរំ** បានដល់ អន្ទោលទៅ បានដល់ ស្ទុះទៅមកក្នុងភពនោះៗ ដោយអំណាចនៃការប្រកាន់និងការលែង ។ បទថា **ទីឃមទ្ធានំ** សេចក្តីថា អន្ទោលទៅក្នុងសង្សារដែលមានខាងដើម និងទីបំផុតមិនប្រាកដ អស់កាលយូរ គឺអស់កាលប្រមាណមិនបាន ។ បទថា **គតីសុ** សេចក្តីថា ក្នុងសុគតិ និងទុគ្គតិទាំងឡាយ ដោយអំណាចនៃកម្មទាំងឡាយដែលខ្លួនធ្វើល្អធ្វើអាក្រក់ ។ បទថា **បរិវត្តិសំ** សេចក្តីថា កាលវិលទៅជុំវិញដូចគ្រឿងបូមទឹក ឈ្មោះថា វិលទៅមកៗ ដោយអំណាចនៃចុតិនិងបដិសន្ធិ ព្រះថេរៈ ពោលហេតុនៃការអន្ទោលនោះថា អាត្មាអញ កាលនៅជាបុថុជ្ជន មានងងឹតគឺអវិជ្ជាកើតហើយ មិនបានឃើញអរិយសច្ចទាំងឡាយ ដូច្នេះ ។

ប្រកបសេចក្តីថា បុគ្គលកាលមិនឃើញអរិយសច្ច ៤ មានទុក្ខសច្ច ជាដើម ដោយញាណចក្ខុ និងមិនបានចាក់ធ្លុះ ឈ្មោះថា **អន្ធភូតោ** ព្រោះងងឹត គឺអវិជ្ជានោះឯង ឈ្មោះថា **បុថុជ្ជនោ** ព្រោះហេតុទាំងឡាយដែលឲ្យ

កើតការក្រាស់នៃកិលេសជាដើម និងអន្ទោលទៅក្នុងគតិទាំងឡាយ ព្រោះភាពដែលខ្លួនជាបុថុជ្ជន សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ( ក្នុងសំយុត្តនិកាយមហាវារវគ្គ ) ថា

ម្នាលភិក្ខុទាំងឡាយ តថាគតក្តីអ្នកទាំងឡាយក្តី ដែលអន្ទោលត្រាច់រង្គាត់ទៅ អស់កាលយូរអង្វែងយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយសច្ច ៤ ដូច្នេះ ។

កាលខ្ញុំនៅជាបុថុជ្ជន នៅក្នុងកាលមុន ដោយន័យដូចពោលហើយនោះឯង ឥឡូវនេះ មិនប្រមាទហើយ ដោយន័យដែលព្រះសាស្តាទ្រង់ប្រទានហើយញ៉ាំងសមថការនានិងវិបស្សនាការនាឲ្យដល់ទីបំផុត ដោយបដិបទា គឺសេចក្តីមិនប្រមាទតាំងនៅ ។

បទថា **សំសារា វិនឡីកតា** សេចក្តីថា កម្មក្កិលេសទាំងឡាយដែលបានឈ្មោះថា សង្សារ ព្រោះជាទីអន្ទោលទៅនៃសត្វទាំងឡាយ ដែលខ្ញុំធ្វើឲ្យអស់ឫសគល់ ព្រោះផ្តាច់ផ្តិលបានហើយ ដោយមគ្គដ៏ប្រសើរ ដូចដើមបបុសដែលមានឫសគល់ទៅប្រាសហើយ ។

បទថា **សព្វា គតី សមុច្ឆិន្នា** សេចក្តីថា គតិទាំងឡាយ មាននរកជាដើម ឈ្មោះថា **សមុច្ឆិន្នា** គឺកម្ចាត់ហើយ ដោយប្រពៃនោះឯង ព្រោះកម្មវដ្តនិងកិលេសវដ្តទាំងឡាយ ខ្ញុំកាត់បានជាសមុច្ឆេទហើយយ៉ាងនេះ ព្រោះហេតុនោះឯង ឥឡូវនេះ ភពថ្មីមិនមានឡើយ ។ គាថាទាំង ២ នេះឯងបានជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈ ដូចពណ៌នាមកនេះឯង ។

**អដ្ឋកថា វជ្ជិតត្ថេរគាថា ចប់**

## សន្និតត្ថេរគាថា

[ ១៧០ ] ខ្ញុំជាបុគ្គលមានសតិតម្កល់ខ្ជាប់ ក៏បាននូវសញ្ញាមួយដែលប្រព្រឹត្តទៅក្នុងពុទ្ធគុណ ជិតដើមអស្សត្ថព្រឹក្ស ជាឈើមានពន្លឺខៀវល្អិតលាស់ត្រសាយត្រសុំល្អ ។ ក្នុងកប្ប ៣១ អំពីកប្បនេះទៅ កាលនោះ ខ្ញុំបាននូវសញ្ញាណា ខ្ញុំបានដល់នូវការអស់ទៅនៃអាសវៈ ព្រោះនាំមកនូវសញ្ញានោះ ។

### សន្និតត្ថេរ ។

### ឧទ្ទាន

និយាយអំពីកុមារកស្សបត្ថេរ ១ ធម្មបាលត្ថេរ ១ ព្រហ្មាលិត្ថេរ ១ មោឃរាជត្ថេរ ១ វិសាខត្ថេរ ១ ចូឡកត្ថេរ ១ អនូបមត្ថេរ ១ វជ្ជិតត្ថេរ ១ សន្និតត្ថេរ កម្ចាត់បង់នូវធូលីគឺកិលេស ១ ។

### ចប់ វគ្គទី ៥ ។

គាថាក្នុងទុកនិបាតមាន ៩៨ ព្រះថេរៈ ៤៩ អង្គ អ្នកឈ្លាសក្នុងន័យបានពោលហើយ ។

### ចប់ ទុកនិបាត ។

# អដ្ឋកថា

# សន្ធិតត្ថេរគាថា

[ ១៧០ ] គាថារបស់ព្រះសន្ធិតត្ថេរ មានពាក្យផ្តើមថា **អស្សត្ថេ ហរិ-តោភាសេ** ដូច្នេះជាដើម ។ រឿងរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមថាសិខី កើតជានាយគោបាលម្នាក់ កាលព្រះសាស្តាបរិនិព្វានហើយ ចូលទៅរកព្រះថេរៈមួយរូប ស្តាប់ធម៌ដែលបដិសំយុត្តដោយពុទ្ធគុណ ក្នុងសម្នាក់នៃព្រះថេរៈ មានចិត្តជ្រះថ្លាសួរថា ព្រះមានព្រះភាគគង់នៅក្នុងទីណា ដឹងថាព្រះមានព្រះភាគបរិនិព្វានហើយ បាននូវអនិច្ចសញ្ញាថា ឱ! សូម្បីព្រះពុទ្ធទាំងឡាយ មានអានុភាពដល់ម៉្លេះក៏ត្រូវយាងទៅកាន់អំណាចនៃភាពជារបស់មិនទៀង ឱ! សង្ខារទាំងឡាយ មិនស្ថិតស្ថេរហ្ន៎ ។ ព្រះថេរៈឲ្យកុលបុត្តនោះកើតឧស្សាហៈ ក្នុងការបូជាពោធិព្រឹក្ស ចូលទៅជិតពោធិព្រឹក្ស តាមកាលដែលសមគួរ ចម្រើនវិ-បស្សនា រឭកដល់ពុទ្ធគុណ ថ្វាយបង្គំដើមពោធិព្រឹក្ស ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំង-ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលដែលស្តុកស្តម្ភក្នុងដែនកោសលមានឈ្មោះថាសន្ធិតៈ ។ ចម្រើនវ័យហើយ ស្តាប់ធម្មកថាដែលបដិសំយុត្តដោយអនិច្ចំ កើតសេចក្តីសង្វេគ បួសហើយផ្តើមចម្រើនវិបស្សនា បានជាអ្នកមានអភិញ្ញា ៦ ក្នុងកាលមិនយូរឡើយ ព្រោះញាណដល់នូវភាពចាស់ក្លា ។

កាលរឭកដល់ជាតិមុនរបស់ខ្លួន រឭកដល់ការថ្វាយបង្គំពោធិព្រឹក្ស ក្នុងសាសនារបស់ព្រះសិខីសម្ពុទ្ធ រឭកដល់ពុទ្ធានុស្សតិនិងការបាននូវអនិច្ចសញ្ញា កាលប្រកាសនូវការសម្រេចគុណវិសេសរបស់ខ្លួន ព្រោះឧបនិស្ស័យនោះ ទើបពោលគាថា ២ ថា

ខ្ញុំជាបុគ្គលមានសតិតម្កល់ខ្ជាប់ ក៏បាននូវសញ្ញាមួយ ដែលប្រព្រឹត្តទៅក្នុងពុទ្ធគុណ ជិតដើមអស្សត្ថព្រឹក្សជាឈើមានពន្លឺខៀវ លូតលាស់ត្រសាយត្រសុំល្អ ។ ក្នុងកប្ប ៣១ អំពីភទ្រកប្បនេះទៅ កាលនោះ ខ្ញុំបាននូវសញ្ញាណា ខ្ញុំបានដល់នូវការអស់ទៅនៃអាសវៈព្រោះនាំមកនូវសញ្ញានោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អស្សត្ថេ** បានដល់ ក្នុងទីជាទីប្រតិស្ឋានដើមអស្សត្ថព្រឹក្ស គឺក្នុងទីរបស់ដើមអស្សត្ថព្រឹក្សដែលជាឈើត្រាស់ដឹងរបស់ព្រះមានព្រះភាគនៃយើងទាំងឡាយ ក្នុងឥឡូវនេះ ។ កាលនោះ មានឈើឈ្មោះបុណ្ឌរិក ជាឈើត្រាស់ដឹងរបស់ព្រះមានព្រះភាគព្រះនាមថាសិខីតាំងនៅ ព្រោះហេតុនោះ ទើបពោធិព្រឹក្សនោះ លោកហៅថា **អស្សត្ថ** ព្រោះជាទីតាំងនៃដើមអស្សត្ថព្រឹក្ស ម្យ៉ាងទៀត បទថា **អស្សត្ថេ** បានដល់ ដើមឈើដែលធ្វើនូវការល្ហែល្ហើយចិត្តឲ្យកើតដល់សត្វទាំងឡាយ ។ តែអាចារ្យពួកខ្លះពោលថា ព្រះថេរៈពោលថា **អស្សត្ថេ** ព្រោះហេតុដែលលោកអង្គុយត្រង់គល់អស្សត្ថព្រឹក្សហើយចម្រើនពុទ្ធានុស្សតិក្នុងកាលនោះ ។

បទថា **ហរិតោភាសេ** សេចក្ដីថា ក្ដីដោយពណ៌កែវផល្លិកដែលមាន

ពណ៌ខៀវស្រស់ ។

បទថា **សំវិរូឡ្ហម្ហិ** សេចក្ដីថា ដុះល្អហើយ គឺប្រតិស្ឋានហើយដោយល្អ ។ ម្យ៉ាងទៀត អាចារ្យពួកខ្លះពោលថា ដុះដាលល្អគ្របដណ្ដប់ទៅដោយស្លឹកខ្ចីនិងស្លឹកចាស់យ៉ាងក្រាស់ ។

បទថា **ទាឍបេ** បានដល់ ដើមឈើ ។

បទថា **ឯកំ ពុទ្ធគតំ សញ្ញំ អលភិត្ថំ បតិស្សតោ** សេចក្ដីថា ខ្ញុំឈ្មោះថាជាអ្នកមានសតិតាំងមាំ ព្រោះមានពុទ្ធគុណជាទីពឹង បានហើយនូវសញ្ញាមានព្រះពុទ្ធជាអារម្មណ៍ដែលឈ្មោះថា **ឯកំ** ព្រោះជាអារម្មណ៍ដែលកើតឡើងតែមួយ ដែលប្រកបដោយពុទ្ធានុស្សតិដែលប្រព្រឹត្តទៅហើយដោយន័យជាដើមថា **ឥតិបិ សោ ភគវា** ដូច្នេះ ។

ឯពុទ្ធានុស្សតិសម្រេចហើយ ដោយសញ្ញាមានប្រមាណប៉ុនណា សញ្ញានោះ ដែលខ្ញុំបានហើយក្នុងកាលនោះ ព្រោះហេតុនោះ ទើបព្រះថេរៈពោលថា **ឯកត្តឹសេ ឥតោ កប្បេ** គឺក្នុងកប្បទី ៣១ រាប់អំពីភទ្ទកប្បនេះ ។

បទថា **យំ សញ្ញំ** បានដល់ បាននូវសញ្ញាដែលសហគតៈដោយពុទ្ធានុស្សតិណា ឬបានអនិច្ចសញ្ញាក្នុងសង្ខារទាំងពួងក្នុងកាលនោះ ដោយការតាមរឭកដល់ពុទ្ធគុណនោះ ព្រោះឃើញភាពជារបស់មិនទៀងនៃព្រះពុទ្ធទាំងឡាយណា ។

បទថា **តស្សា សញ្ញាយ វាហសា** សេចក្ដីថា ធ្វើសញ្ញានោះឲ្យជាឧបនិស្ស័យ ព្រោះភាពដែលសញ្ញាតាមដែលពោលហើយនោះជាហេតុ ។

បទថា **បត្តោ មេ អាសវក្ខយោ** សេចក្ដីថា ការអស់ គឺការរលត់នៃអាសវៈទាំងឡាយដែលខ្ញុំសម្រេចហើយក្នុងឥឡូវនេះ ។ សូម្បីគាថាអបទានរបស់ព្រះថេរៈនេះក៏មាន ២ គាថានេះឯងដែលលោកពោលថា

ខ្ញុំមានស្មារតីបាននូវសញ្ញា ១ ដែលតាំងនៅក្នុងព្រះពុទ្ធត្រង់ដើមអស្សត្ថព្រឹក្សដែលមានរស្មីខៀវដុះឡើងទ្រុបទ្រុល ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះព្រោះហេតុ ដែលខ្ញុំបាននូវសញ្ញា ខ្ញុំដល់នូវការអស់ទៅនៃអាសវៈ ដោយអំណាចនៃសញ្ញានោះ ។ ក្នុងកប្បទី ១៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្រពត្តិព្រះនាមវនិទ្ធៈទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការមានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ ។

អដ្ឋកថា សន្ធិតត្ថេរគាថា ចប់

វគ្គទី ៥ ចប់

ទុកនិបាត ចប់

# ក្បាលទី ៤១

# សុត្តន្តបិដក ចាលីប្រែ -៩៦

## សន្ទឹកចង្អុលប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| និទានកថា | ២ |
| គន្ថារម្ភកថា | ៣ |
| អដ្ឋកថា និទានកថា | ១០ |
| អត្ថរបស់ សីហ សព្ទ | ១០ |


## ឯកនិបាត បឋមវគ្គ


| | |
|---|---|
| សុភូតិត្ថេរគាថា | ៤១ |
| អដ្ឋកថា សុភូតិត្ថេរគាថា | ៤១ |
| អត្ថរបស់ ឆន្ទ សព្ទ | ៥៨ |
| អត្ថរបស់ មេ សព្ទ | ៥៩ |
| អត្ថរបស់ កុដិ សព្ទ | ៦០ |
| អត្ថរបស់ សុខ សព្ទ | ៦១ |
| អត្ថរបស់ ទេវ សព្ទ | ៦៣ |
| អត្ថរបស់ អត្តភាព សព្ទ | ៦៥ |
| មហាកោដ្ឋិកត្ថេរគាថា | ៧២ |
| អដ្ឋកថា មហាកោដ្ឋិកត្ថេរគាថា | ៧២ |
| កង្ខារេវតត្ថេរគាថា | ៨២ |
| អដ្ឋកថា កង្ខារេវតត្ថេរគាថា | ៨២ |
| បុណ្ណមន្តានីបុត្តត្ថេរគាថា | ៩៣ |

អដ្ឋកថា បុណ្ណមន្តានីបុត្តត្ថេរគាថា .......... .......... .......... .......... ........ ៩៣

ទព្វមល្លបុត្តត្ថេរគាថា .......... .......... .......... .......... ..... ១០៣

អដ្ឋកថា ទព្វមល្លបុត្តត្ថេរគាថា .......... .......... .......... .......... .... ១០៣

សីតវនិយត្ថេរគាថា .......... .......... .......... .......... .... ១១៧

អដ្ឋកថា សីតវនិយត្ថេរគាថា .......... .......... .......... .......... .... ១១៧

ភល្លិយត្ថេរគាថា .......... .......... .......... .......... ..... ១២៤

អដ្ឋកថា ភល្លិយត្ថេរគាថា .......... .......... .......... .......... ..... ១២៤

វីរត្ថេរគាថា .......... .......... .......... .......... .... ១៣០

អដ្ឋកថា វីរត្ថេរគាថា .......... .......... .......... .......... .... ១៣០

បិលិន្ទវច្ឆត្ថេរគាថា .......... .......... .......... .......... ... ១៣៤

អដ្ឋកថា បិលិន្ទវច្ឆត្ថេរគាថា .......... .......... .......... .......... ... ១៣៤

បុណ្ណមាសត្ថេរគាថា .......... .......... .......... .......... ... ១៤១

អដ្ឋកថា បុណ្ណមាសត្ថេរគាថា .......... .......... .......... .......... ... ១៤២

## ឯកនិបាត ទុតិយវគ្គ

ចូឡវច្ឆត្ថេរគាថា .......... .......... .......... .......... ..... ១៤៦

អដ្ឋកថា ចូឡវច្ឆត្ថេរគាថា .......... .......... .......... .......... ..... ១៤៦

មហាវច្ឆត្ថេរគាថា .......... .......... .......... .......... ...... ១៥១

អដ្ឋកថា មហាវច្ឆត្ថេរគាថា .......... .......... .......... .......... ...... ១៥១

វនវច្ឆត្ថេរគាថា .......... .......... .......... .......... ..... ១៥៥

អដ្ឋកថា វនវច្ឆត្ថេរគាថា .......... .......... .......... .......... ..... ១៥៥

វនវច្ឆស្សត្ថេរស្សសាមណេរគាថា .......... .......... .......... .......... ...... ១៦១

អដ្ឋកថា វនវច្ឆស្សត្ថេរស្សសាមណេរគាថា ........ ...... ....... ........ ....... ១៦១

កុណ្ឌធានត្ថេរគាថា .......... .......... .......... .......... .............. ១៦៦
អដ្ឋកថា កុណ្ឌធានត្ថេរគាថា .......... .......... .......... .......... .............. ១៦៦
ពេលដ្ឋសីសត្ថេរគាថា .......... .......... .......... .......... .............. ១៧៩
អដ្ឋកថា ពេលដ្ឋសីសត្ថេរគាថា .......... .......... .......... .......... .............. ១៧៩
ទាសកត្ថេរគាថា .......... .......... .......... .......... .............. ១៨៤
អដ្ឋកថា ទាសកត្ថេរគាថា .......... .......... .......... .......... .............. ១៨៤
សិង្គាលបិតាថេរគាថា .......... .......... .......... .......... .............. ១៨៩
អដ្ឋកថា សិង្គាលបិតាថេរគាថា .......... .......... .......... .......... .............. ១៨៩
កុឡត្ថេរគាថា .......... .......... .......... .......... .............. ១៩៤
អដ្ឋកថា កុឡត្ថេរគាថា .......... .......... .......... .......... .............. ១៩៤
អជិតត្ថេរគាថា .......... .......... .......... .......... .............. ១៩៨
អដ្ឋកថា អជិតត្ថេរគាថា .......... .......... .......... .......... .............. ១៩៨

## ឯកនិបាត តតិយវគ្គ

និគ្រោធត្ថេរគាថា .......... .......... .......... .......... .............. ២០២
អដ្ឋកថា និគ្រោធត្ថេរគាថា .......... .......... .......... .......... .............. ២០២
ចិត្តកត្ថេរគាថា .......... .......... .......... .......... .............. ២១០
អដ្ឋកថា ចិត្តកត្ថេរគាថា .......... .......... .......... .......... .............. ២១០
គោសាលត្ថេរគាថា .......... .......... .......... .......... .............. ២១៤
អដ្ឋកថា គោសាលត្ថេរគាថា .......... .......... .......... .......... .............. ២១៤
សុគន្ធត្ថេរគាថា .......... .......... .......... .......... .............. ២១៨
អដ្ឋកថា សុគន្ធត្ថេរគាថា .......... .......... .......... .......... .............. ២១៨
នន្ទិយត្ថេរគាថា .......... .......... .......... .......... .............. ២២៣

អដ្ឋកថា នន្ទិយត្ថេរគាថា .......... .......... .......... .......... ........ ២២៣
អភយត្ថេរគាថា .......... .......... .......... .......... ....... ២២៧
អដ្ឋកថា អភយត្ថេរគាថា .......... .......... .......... .......... ....... ២២៧
លោមសកង្គិយត្ថេរគាថា .......... .......... .......... .......... ........ ២៣២
អដ្ឋកថា លោមសកង្គិយត្ថេរគាថា .......... .......... .......... .......... ........ ២៣២
ជម្ពុគាមិកបុត្តត្ថេរគាថា .......... .......... .......... .......... ........ ២៣៧
អដ្ឋកថា ជម្ពុគាមិកបុត្តត្ថេរគាថា .......... .......... .......... .......... ........ ២៣៧
ហារិតត្ថេរគាថា .......... .......... .......... .......... ....... ២៤២
អដ្ឋកថា ហារិតត្ថេរគាថា .......... .......... .......... .......... ....... ២៤២
ឧត្តិយត្ថេរគាថា .......... .......... .......... .......... ....... ២៤៦
អដ្ឋកថា ឧត្តិយត្ថេរគាថា .......... .......... .......... .......... ....... ២៤៧

# ឯកនិបាត ចតុត្ថវគ្គ

គហុរតីរិយត្ថេរគាថា .......... .......... .......... .......... ....... ២៥១
អដ្ឋកថា គហុរតីរិយត្ថេរគាថា .......... .......... .......... .......... ....... ២៥១
សុប្បិយត្ថេរគាថា .......... .......... .......... .......... ....... ២៥៥
អដ្ឋកថា សុប្បិយត្ថេរគាថា .......... .......... .......... .......... ...... ២៥៥
សោបាកត្ថេរគាថា .......... .......... .......... .......... ........ ២៦២
អដ្ឋកថា សោបាកត្ថេរគាថា .......... .......... .......... .......... ........ ២៦២
បោសិយត្ថេរគាថា .......... .......... .......... .......... ........ ២៦៧
អដ្ឋកថា បោសិយត្ថេរគាថា .......... .......... .......... .......... ........ ២៦៧
សាមញ្ញកាមិត្ថេរគាថា .......... .......... .......... .......... ....... ២៧៣
អដ្ឋកថា សាមញ្ញកាមិត្ថេរគាថា .......... .......... .......... .......... ....... ២៧៣

កុមារបុត្តត្ថេរគាថា .......... .......... .......... .......... ....... ២៧៨
អដ្ឋកថា កុមារបុត្តត្ថេរគាថា .......... .......... .......... .......... ....... ២៧៨
កុមារបុត្តសហាយត្ថេរគាថា .......... .......... .......... .......... ........ ២៨៣
អដ្ឋកថា កុមារបុត្តសហាយត្ថេរគាថា .......... .......... .......... .......... ........ ២៨៣
គវម្បតិត្ថេរគាថា .......... .......... .......... .......... ........ ២៨៨
អដ្ឋកថា គវម្បតិត្ថេរគាថា .......... .......... .......... .......... ........ ២៨៨
តិស្សត្ថេរគាថា .......... .......... .......... .......... ........ ២៩៣
អដ្ឋកថា តិស្សត្ថេរគាថា .......... .......... .......... .......... ........ ២៩៣
វឌ្ឍមានត្ថេរគាថា .......... .......... .......... .......... ....... ២៩៧
អដ្ឋកថា វឌ្ឍមានត្ថេរគាថា .......... .......... .......... .......... ........២៩៧

# ឯកនិបាត បញ្ចមវគ្គ

សិរីវឌ្ឍត្ថេរគាថា .......... .......... .......... .......... ........ ៣០០
អដ្ឋកថា សិរីវឌ្ឍត្ថេរគាថា .......... .......... .......... .......... ........ ៣០០
ខទិរវនិយត្ថេរគាថា .......... .......... .......... .......... ....... ៣០៤
អដ្ឋកថា ខទិរវនិយត្ថេរគាថា .......... .......... .......... .......... ....... ៣០៤
សុមង្គលត្ថេរគាថា .......... .......... .......... .......... ........ ៣១១
អដ្ឋកថា សុមង្គលត្ថេរគាថា .......... .......... .......... .......... ........ ៣១១
សានុត្ថេរគាថា .......... .......... .......... .......... ........ ៣១៨
អដ្ឋកថា សានុត្ថេរគាថា .......... .......... .......... .......... ........ ៣១៨
មរណីយវិហារិត្ថេរគាថា .......... .......... .......... .......... ...... ៣២៤
អដ្ឋកថា មរណីយវិហារិត្ថេរគាថា .......... .......... .......... .......... ...... ៣២៤
សមិទ្ធិត្ថេរគាថា .......... .......... .......... .......... ..... ៣២៩

សទ្ទឹកប្រាប់មាតិកា ៩៧៤

អដ្ឋកថា សមិទ្ធិត្ថេរគាថា .......... .......... .......... .......... ............ ៣២៩
ឧជ្ជយត្ថេរគាថា .......... .......... .......... .......... ............ ៣៣៤
អដ្ឋកថា ឧជ្ជយត្ថេរគាថា .......... .......... .......... .......... ............ ៣៣៤
សញ្ជយត្ថេរគាថា .......... .......... .......... .......... ............ ៣៣៧
អដ្ឋកថា សញ្ជយត្ថេរគាថា .......... .......... .......... .......... ............ ៣៣៧
រាមណេយ្យកត្ថេរគាថា .......... .......... .......... .......... ............. ៣៤០
អដ្ឋកថា រាមណេយ្យកត្ថេរគាថា .......... .......... .......... .......... ............. ៣៤០
វិមលត្ថេរគាថា .......... .......... .......... .......... ............. ៣៤៤
អដ្ឋកថា វិមលត្ថេរគាថា .......... .......... .......... .......... ............. ៣៤៥

# ឯកនិបាត ចតុត្ថវគ្គ

គោធិកាទិចតុត្ថេរគាថា .......... .......... .......... .......... ............ ៣៤៩
អដ្ឋកថា គោធិកាទិចតុត្ថេរគាថា .......... .......... .......... .......... ............ ៣៤៩
សុពាហុត្ថេរគាថា .......... .......... .......... .......... ............ ៣៥៧
អដ្ឋកថា សុពាហុត្ថេរគាថា .......... .......... .......... .......... ............ ៣៥៧
វល្លិយត្ថេរគាថា .......... .......... .......... .......... ............ ៣៥៨
អដ្ឋកថា វល្លិយត្ថេរគាថា .......... .......... .......... .......... ............ ៣៥៨
ឧត្តិយត្ថេរគាថា .......... .......... .......... .......... ............ ៣៥៩
អដ្ឋកថា ឧត្តិយត្ថេរគាថា .......... .......... .......... .......... ............ ៣៥៩
អញ្ជនវនិយត្ថេរគាថា .......... .......... .......... .......... ............. ៣៦០
អដ្ឋកថា អញ្ជនវនិយត្ថេរគាថា .......... .......... .......... .......... ............. ៣៦០
កុដិវិហារិត្ថេរគាថា .......... .......... .......... .......... ............. ៣៦៤
អដ្ឋកថា កុដិវិហារិត្ថេរគាថា .......... .......... .......... .......... ............. ៣៦៤

ទុតិយកុដិវិហារិត្ថេរគាថា .......... .......... .......... .......... ........ ៣៦៩
អដ្ឋកថា ទុតិយកុដិវិហារិត្ថេរគាថា .......... .......... .......... .......... ........ ៣៦៩
រមណីយកុដិកត្ថេរគាថា .......... .......... .......... .......... ....... ៣៧៤
អដ្ឋកថា រមណីយកុដិកត្ថេរគាថា .......... .......... .......... .......... ....... ៣៧៤
កោសល្លវិហារិត្ថេរគាថា .......... .......... .......... .......... ........ ៣៨០
អដ្ឋកថា កោសល្លវិហារិត្ថេរគាថា .......... .......... .......... .......... ........ ៣៨០
សីវលិត្ថេរគាថា .......... .......... .......... .......... ........ ៣៨៤
អដ្ឋកថា សីវលិត្ថេរគាថា .......... .......... .......... .......... ........ ៣៨៤

# ឯកនិបាត សត្តមវគ្គ

វប្បត្ថេរគាថា .......... .......... .......... .......... ........ ៣៩៧
អដ្ឋកថា វប្បត្ថេរគាថា .......... .......... .......... .......... ........ ៣៩៧
វជ្ជិបុត្តកត្ថេរគាថា .......... .......... .......... .......... ........ ៤០២
អដ្ឋកថា វជ្ជិបុត្តកត្ថេរគាថា .......... .......... .......... .......... ........ ៤០២
បក្ខត្ថេរគាថា .......... .......... .......... .......... ........ ៤០៧
អដ្ឋកថា បក្ខត្ថេរគាថា .......... .......... .......... .......... ........ ៤០៧
វិមលកោណ្ឌញ្ញត្ថេរគាថា .......... .......... .......... .......... ........ ៤១២
អដ្ឋកថា វិមលកោណ្ឌញ្ញត្ថេរគាថា .......... .......... .......... .......... ......... ៤១២
ឧក្ខេបកតវច្ឆត្ថេរគាថា .......... .......... .......... .......... ....... ៤១៧
អដ្ឋកថា ឧក្ខេបកតវច្ឆត្ថេរគាថា .......... .......... .......... .......... ....... ៤១៧
មេឃិយត្ថេរគាថា .......... .......... .......... .......... ........ ៤២២
អដ្ឋកថា មេឃិយត្ថេរគាថា .......... .......... .......... .......... ........ ៤២២
ឯកធម្មសវនិយត្ថេរគាថា .......... .......... .......... .......... ........ ៤២៧

អដ្ឋកថា ឯកធម្មសវនិយត្ថេរគាថា .......... .......... .......... .......... .......... ៤២៧

ឯកុទានិយត្ថេរគាថា .......... .......... .......... .......... .......... ៤៣២

អដ្ឋកថា ឯកុទានិយត្ថេរគាថា .......... .......... .......... .......... .......... ៤៣២

ឆន្នត្ថេរគាថា .......... .......... .......... .......... .......... ៤៣៩

អដ្ឋកថា ឆន្នត្ថេរគាថា .......... .......... .......... .......... .......... ៤៣៩

បុណ្ណត្ថេរគាថា .......... .......... .......... .......... .......... ៤៤៤

អដ្ឋកថា បុណ្ណត្ថេរគាថា .......... .......... .......... .......... .......... ៤៤៥


# ឯកនិបាត អដ្ឋមវគ្គ


វច្ឆបាលត្ថេរគាថា .......... .......... .......... .......... .......... ៤៥១

អដ្ឋកថា វច្ឆបាលត្ថេរគាថា .......... .......... .......... .......... .......... ៤៥១

អាតុមត្ថេរគាថា .......... .......... .......... .......... .......... ៤៥៦

អដ្ឋកថា អាតុមត្ថេរគាថា .......... .......... .......... .......... .......... ៤៥៦

មាណវត្ថេរគាថា .......... .......... .......... .......... .......... ៤៦១

អដ្ឋកថា មាណវត្ថេរគាថា .......... .......... .......... .......... .......... ៤៦១

សុយាមនត្ថេរគាថា .......... .......... .......... .......... .......... ៤៦៨

អដ្ឋកថា សុយាមនត្ថេរគាថា .......... .......... .......... .......... .......... ៤៦៨

សុសារទត្ថេរគាថា .......... .......... .......... .......... .......... ៤៧៤

អដ្ឋកថា សុសារទត្ថេរគាថា .......... .......... .......... .......... .......... ៤៧៤

បិយញ្ជហត្ថេរគាថា .......... .......... .......... .......... .......... ៤៨០

អដ្ឋកថា បិយញ្ជហត្ថេរគាថា .......... .......... .......... .......... .......... ៤៨០

ហត្ថារោហបុត្តត្ថេរគាថា .......... .......... .......... .......... .......... ៤៨៥

អដ្ឋកថា ហត្ថារោហបុត្តត្ថេរគាថា .......... .......... .......... .......... .......... ៤៨៥

មេណ្ឌសិរត្ថេរគាថា .......... .......... .......... .......... .......... ........ ៤៨៩
អដ្ឋកថា មេណ្ឌសិរត្ថេរគាថា .......... .......... .......... .......... .......... ........ ៤៨៩
រក្ខិតត្ថេរគាថា .......... .......... .......... .......... .......... ....... ៤៩៣
អដ្ឋកថា រក្ខិតត្ថេរគាថា .......... .......... .......... .......... .......... ........ ៤៩៣
ឧគ្គត្ថេរគាថា .......... .......... .......... .......... .......... ........ ៤៩៧
អដ្ឋកថា ឧគ្គត្ថេរគាថា .......... .......... .......... .......... .......... ........ ៤៩៨

# ឯកនិបាត ឆវគ្គ

សមិតិគុត្តត្ថេរគាថា .......... .......... .......... .......... .......... ...... ៥០១
អដ្ឋកថា សមិតិគុត្តត្ថេរគាថា .......... .......... .......... .......... .......... ..... ៥០១
កស្សបត្ថេរគាថា .......... .......... .......... .......... .......... ....... ៥០៦
អដ្ឋកថា កស្សបត្ថេរគាថា .......... .......... .......... .......... .......... .......... ៥០៦
សីហត្ថេរគាថា .......... .......... .......... .......... .......... ....... ៥១០
អដ្ឋកថា សីហត្ថេរគាថា .......... .......... .......... .......... .......... ....... ៥១០
នីតត្ថេរគាថា .......... .......... .......... .......... .......... ...... ៥១៤
អដ្ឋកថា នីតត្ថេរគាថា .......... .......... .......... .......... .......... ...... ៥១៤
សុនាគត្ថេរគាថា .......... .......... .......... .......... .......... ....... ៥១៨
អដ្ឋកថា សុនាគត្ថេរគាថា .......... .......... .......... .......... .......... ....... ៥១៨
នាគិតត្ថេរគាថា .......... .......... .......... .......... .......... ....... ៥២២
អដ្ឋកថា នាគិតត្ថេរគាថា .......... .......... .......... .......... .......... ...... ៥២២
បវិដ្ឋត្ថេរគាថា .......... .......... .......... .......... .......... ...... ៥២៧
អដ្ឋកថា បវិដ្ឋត្ថេរគាថា .......... .......... .......... .......... .......... ...... ៥២៧
អជ្ជុនត្ថេរគាថា .......... .......... .......... .......... .......... ....... ៥៣០

អដ្ឋកថា អជ្ជុនត្ថេរគាថា .......... .......... .......... .......... .......... ... ៥៣០
ទេវសភត្ថេរគាថា .......... .......... .......... .......... .......... .... ៥៣៤
អដ្ឋកថា ទេវសភត្ថេរគាថា .......... .......... .......... .......... .......... .... ៥៣៤
សាមិទត្តត្ថេរគាថា .......... .......... .......... .......... .......... ... ៥៣៩
អដ្ឋកថា សាមិទត្តត្ថេរគាថា .......... .......... .......... .......... .......... ... ៥៤០

# ឯកនិបាត ឆដ្ឋវគ្គ

បរិបុណ្ណកត្ថេរគាថា .......... .......... .......... .......... .......... .... ៥៤៣
អដ្ឋកថា បរិបុណ្ណកត្ថេរគាថា .......... .......... .......... .......... .......... .... ៥៤៣
វិជយត្ថេរគាថា .......... .......... .......... .......... .......... ... ៥៤៨
អដ្ឋកថា វិជយត្ថេរគាថា .......... .......... .......... .......... .......... ... ៥៤៨
ឯរកត្ថេរគាថា .......... .......... .......... .......... .......... .. ៥៥២
អដ្ឋកថា ឯរកត្ថេរគាថា .......... .......... .......... .......... .......... .. ៥៥២
មេត្តជិត្ថេរគាថា .......... .......... .......... .......... .......... .... ៥៥៧
អដ្ឋកថា មេត្តជិត្ថេរគាថា .......... .......... .......... .......... .......... .... ៥៥៧
ចក្ខុបាលត្ថេរគាថា .......... .......... .......... .......... .......... ... ៥៦១
អដ្ឋកថា ចក្ខុបាលត្ថេរគាថា .......... .......... .......... .......... .......... ... ៥៦១
ខណ្ឌសុមនត្ថេរគាថា .......... .......... .......... .......... .......... .... ៥៦៨
អដ្ឋកថា ខណ្ឌសុមនត្ថេរគាថា .......... .......... .......... .......... .......... .... ៥៦៨
តិស្សត្ថេរគាថា .......... .......... .......... .......... .......... ... ៥៧៣
អដ្ឋកថា តិស្សត្ថេរគាថា .......... .......... .......... .......... .......... ... ៥៧៣
អភយត្ថេរគាថា .......... .......... .......... .......... .......... .... ៥៧៨
អដ្ឋកថា អភយត្ថេរគាថា .......... .......... .......... .......... .......... .... ៥៧៨

ឧត្តិយត្ថេរគាថា .......... .......... .......... .......... .......... .. ៥៨២

អដ្ឋកថា ឧត្តិយត្ថេរគាថា .......... .......... .......... .......... .......... .. ៥៨២

ទេវសភត្ថេរគាថា .......... .......... .......... .......... .............. ៥៨៥

អដ្ឋកថា (ទុតិយ) ទេវសភត្ថេរគាថា .......... .......... .......... .......... ...... ៥៨៦

# ឯកនិបាត ឯកាទសមវគ្គ

ពេលដ្ឋកានិត្ថេរគាថា .......... .......... .......... .......... .............. ៥៨៩

អដ្ឋកថា ពេលដ្ឋកានិត្ថេរគាថា .......... .......... .......... .......... .............. ៥៨៩

សេតុច្ឆត្ថេរគាថា .......... .......... .......... .......... .............. ៥៩៤

អដ្ឋកថា សេតុច្ឆត្ថេរគាថា .......... .......... .......... .......... .............. ៥៩៤

ពន្ធុរត្ថេរគាថា .......... .......... .......... .......... ............ ៥៩៨

អដ្ឋកថា ពន្ធុរត្ថេរគាថា .......... .......... .......... .......... ............ ៥៩៨

ខិតកត្ថេរគាថា .......... .......... .......... .......... ........... ៦០២

អដ្ឋកថា ខិតកត្ថេរគាថា .......... .......... .......... .......... ........... ៦០២

មលិតវម្ភត្ថេរគាថា .......... .......... .......... .......... ............ ៦០៧

អដ្ឋកថា មលិតវម្ភត្ថេរគាថា .......... .......... .......... .......... ............ ៦០៧

សុហេមន្តត្ថេរគាថា .......... .......... .......... .......... ............ ៦១១

អដ្ឋកថា សុហេមន្តត្ថេរគាថា .......... .......... .......... .......... ........... ៦១១

ធម្មសវត្ថេរគាថា .......... .......... .......... .......... .............. ៦១៧

អដ្ឋកថា ធម្មសវត្ថេរគាថា .......... .......... .......... .......... .............. ៦១៧

ធម្មសវបិតុត្ថេរគាថា .......... .......... .......... .......... ............ ៦២០

អដ្ឋកថា ធម្មសវបិតុត្ថេរគាថា .......... .......... .......... .......... .......... ... ៦២០

សង្ឃរក្ខិតត្ថេរគាថា .......... .......... .......... .......... ............. ៦២៣

សន្ទឹកប្រាប់មាតិកា ៩៨០

អដ្ឋកថា សង្ឃរក្ខិតត្ថេរគាថា .......... .......... .......... .......... .......... ...... ៦២៣
ឧសភត្ថេរគាថា .......... .......... .......... .......... .......... ..... ៦២៧
អដ្ឋកថា ឧសភត្ថេរគាថា .......... .......... .......... .......... .......... .... ៦២៨

# ឯកនិបាត ទុតិយវគ្គ

ជេន្តត្ថេរគាថា .......... .......... .......... .......... .......... ..... ៦៣២
អដ្ឋកថា ជេន្តត្ថេរគាថា .......... .......... .......... .......... .......... ..... ៦៣២
វច្ឆគោតត្ថេរគាថា .......... .......... .......... .......... .......... ...... ៦៣៨
អដ្ឋកថា វច្ឆគោតត្ថេរគាថា .......... .......... .......... .......... .......... ...... ៦៣៨
វនវច្ឆត្ថេរគាថា .......... .......... .......... .......... .......... ..... ៦៤២
អដ្ឋកថា វនវច្ឆត្ថេរគាថា .......... .......... .......... .......... .......... ..... ៦៤២
អធិមុត្តត្ថេរគាថា .......... .......... .......... .......... .......... ..... ៦៤៦
អដ្ឋកថា អធិមុត្តត្ថេរគាថា .......... .......... .......... .......... .......... ..... ៦៤៦
មហានាមត្ថេរគាថា .......... .......... .......... .......... .......... .... ៦៥៣
អដ្ឋកថា មហានាមត្ថេរគាថា .......... .......... .......... .......... .......... ...... ៦៥៣
បារាបរិយត្ថេរគាថា .......... .......... .......... .......... .......... ...... ៦៥៩
អដ្ឋកថា បារាបរិយត្ថេរគាថា .......... .......... .......... .......... .......... ...... ៦៥៩
យសត្ថេរគាថា .......... .......... .......... .......... .......... ...... ៦៦៦
អដ្ឋកថា យសត្ថេរគាថា .......... .......... .......... .......... .......... ..... ៦៦៦
កិម្ពិលត្ថេរគាថា .......... .......... .......... .......... .......... .... ៦៧២
អដ្ឋកថា កិម្ពិលត្ថេរគាថា .......... .......... .......... .......... .......... .... ៦៧២
វជ្ជីបុត្តត្ថេរគាថា .......... .......... .......... .......... .......... ...... ៦៧៧
អដ្ឋកថា វជ្ជីបុត្តត្ថេរគាថា .......... .......... .......... .......... .......... ...... ៦៧៧

ឥសិទត្តត្ថេរគាថា .......... ......... .......... .......... ...... ៦៨២

អដ្ឋកថា ឥសិទត្តត្ថេរគាថា .......... ......... .......... .......... ...... ៦៨៣

# ទុកនិបាត បឋមវគ្គ

ឧត្តរត្ថេរគាថា .......... ......... .......... .......... ...... ៦៨៧

អដ្ឋកថា ឧត្តរត្ថេរគាថា .......... ......... .......... .......... ...... ៦៨៧

បិណ្ឌោលភារទ្វាជត្ថេរគាថា .......... ......... .......... .......... ..... ៦៩៨

អដ្ឋកថា បិណ្ឌោលភារទ្វាជត្ថេរគាថា .......... ......... .......... .......... ...... ៦៩៨

វល្លិយត្ថេរគាថា .......... ......... .......... .......... .... ៧០៥

អដ្ឋកថា វល្លិយត្ថេរគាថា .......... ......... .......... .......... ..... ៧០៥

គង្គាតីរិយត្ថេរគាថា .......... ......... .......... .......... ..... ៧០៩

អដ្ឋកថា គង្គាតីរិយត្ថេរគាថា .......... ......... .......... .......... ..... ៧០៩

អជិនត្ថេរគាថា .......... ......... .......... .......... ..... ៧១៣

អដ្ឋកថា អជិនត្ថេរគាថា .......... ......... .......... .......... ..... ៧១៣

មេឡជិនត្ថេរគាថា .......... ......... .......... .......... ..... ៧១៩

អដ្ឋកថា មេឡជិនត្ថេរគាថា .......... ........ .......... ......... ...... ៧១៩

រាធត្ថេរគាថា .......... ......... .......... .......... ..... ៧២៤

អដ្ឋកថា រាធត្ថេរគាថា .......... ......... .......... .......... ..... ៧២៤

សុរាធត្ថេរគាថា .......... ......... .......... .......... ...... ៧២៨

អដ្ឋកថា សុរាធត្ថេរគាថា .......... ......... .......... .......... ...... ៧២៨

គោតមត្ថេរគាថា .......... ......... .......... .......... ..... ៧៣១

អដ្ឋកថា គោតមត្ថេរគាថា .......... ......... .......... .......... ..... ៧៣១

វសភត្ថេរគាថា .......... ......... .......... .......... .... ៧៣៦

សន្ទឹកប្រាប់មាតិកា ៩៨២

អដ្ឋកថា វិសេកត្ថេរគាថា .......... .......... .......... .......... .......... .... ៧៣៧

# ទុតិយវគ្គ

មហាចុន្ទត្ថេរគាថា .......... .......... .......... .......... .......... .... ៧៤៦

អដ្ឋកថា មហាចុន្ទត្ថេរគាថា .......... .......... .......... .......... .......... .... ៧៤៦

ជោតិទាសត្ថេរគាថា .......... .......... .......... .......... .......... .... ៧៥៣

អដ្ឋកថា ជោតិទាសត្ថេរគាថា .......... .......... .......... .......... .......... .... ៧៥៣

ហេរញ្ញកានិត្ថេរគាថា .......... .......... .......... .......... .......... ..... ៧៥៩

អដ្ឋកថា ហេរញ្ញកានិត្ថេរគាថា .......... .......... .......... .......... .......... ..... ៧៥៩

សោមមិត្តត្ថេរគាថា .......... .......... .......... .......... .......... ..... ៧៦៤

អដ្ឋកថា សោមមិត្តត្ថេរគាថា .......... .......... .......... .......... .......... .... ៧៦៤

សព្វមិត្តត្ថេរគាថា .......... .......... .......... .......... .......... ..... ៧៦៨

អដ្ឋកថា សព្វមិត្តត្ថេរគាថា .......... .......... .......... .......... .......... ... ៧៦៨

មហាកាឡត្ថេរគាថា .......... .......... .......... .......... .......... .... ៧៧៥

អដ្ឋកថា មហាកាឡត្ថេរគាថា .......... .......... .......... .......... .......... .... ៧៧៥

តិស្សត្ថេរគាថា .......... .......... .......... .......... .......... .... ៧៨០

អដ្ឋកថា តិស្សត្ថេរគាថា .......... .......... .......... .......... .......... .... ៧៨០

កិម្ពិលត្ថេរគាថា .......... .......... .......... .......... .......... ..... ៧៨៧

អដ្ឋកថា កិម្ពិលត្ថេរគាថា .......... .......... .......... .......... .......... ..... ៧៨៧

នន្ទត្ថេរគាថា .......... .......... .......... .......... .......... ..... ៧៩០

អដ្ឋកថា នន្ទត្ថេរគាថា .......... .......... .......... .......... .......... ..... ៧៩០

សិរិមត្ថេរគាថា .......... .......... .......... .......... .......... .... ៧៩៨

អដ្ឋកថា សិរិមត្ថេរគាថា .......... .......... .......... .......... .......... .... ៧៩៨

# តតិយវគ្គ

ឧត្តរត្ថេរគាថា .......... ......... .......... .......... .......... ...... ៨១០
អដ្ឋកថា ឧត្តរត្ថេរគាថា .......... ......... .......... .......... .......... ...... ៨១០
ភទ្ទជិត្ថេរគាថា .......... ......... .......... .......... .......... ..... ៨១៥
អដ្ឋកថា ភទ្ទជិត្ថេរគាថា .......... ......... .......... .......... .......... .... ៨១៥
សោភិតត្ថេរគាថា .......... ......... .......... .......... .......... ..... ៨២៤
អដ្ឋកថា សោភិតត្ថេរគាថា .......... ......... .......... .......... .......... ..... ៨២៤
វល្លិយត្ថេរគាថា .......... ......... .......... .......... .......... ..... ៨៣២
អដ្ឋកថា វល្លិយត្ថេរគាថា .......... ......... .......... .......... .......... ..... ៨៣២
វីតសោកត្ថេរគាថា .......... ......... .......... .......... .......... ...... ៨៤០
អដ្ឋកថា វីតសោកត្ថេរគាថា .......... ......... .......... .......... .......... ...... ៨៤០
បុណ្ណមាសត្ថេរគាថា .......... ......... .......... .......... .......... ...... ៨៤៦
អដ្ឋកថា បុណ្ណមាសត្ថេរគាថា .......... ......... .......... .......... .......... ...... ៨៤៦
នន្ទកត្ថេរគាថា .......... ......... .......... .......... .......... ..... ៨៥១
អដ្ឋកថា នន្ទកត្ថេរគាថា .......... ......... .......... .......... .......... ..... ៨៥១
ភរតត្ថេរគាថា .......... ......... .......... .......... .......... .... ៨៥៥
អដ្ឋកថា ភរតត្ថេរគាថា .......... ......... .......... .......... .......... .... ៨៥៥
ភារទ្វាជត្ថេរគាថា .......... ......... .......... .......... .......... ... ៨៦១
អដ្ឋកថា ភារទ្វាជត្ថេរគាថា ........ ......... .......... .......... .......... ..... ៨៦១
កណ្ហទិន្នត្ថេរគាថា .......... ......... .......... .......... .......... .... ៨៦៦
អដ្ឋកថា កណ្ហទិន្នត្ថេរគាថា .......... ......... .......... .......... .......... .... ៨៦៧

# ចតុត្ថវគ្គ

មិគសិរត្ថេរគាថា .......... ......... .......... .......... .......... ...... ៨៧១

សន្ទឹកប្រាប់មាតិកា ៩៨៤

អដ្ឋកថា មិគសិរត្ថេរគាថា .......... ......... .......... .......... .... ៨៧១
សិវកត្ថេរគាថា .......... ......... .......... .......... .. ៨៧៦
អដ្ឋកថា សិវកត្ថេរគាថា .......... ......... .......... .......... .... ៨៧៦
ឧបវាណត្ថេរគាថា .......... ......... .......... .......... .... ៨៨០
អដ្ឋកថា ឧបវាណត្ថេរគាថា .......... ......... .......... .......... .... ៨៨០
ឥសិទិន្នត្ថេរគាថា .......... ......... .......... .......... .... ៨៩០
អដ្ឋកថា ឥសិទិន្នត្ថេរគាថា .......... ......... .......... .......... .... ៨៩០
សម្ពុលកច្ចានត្ថេរគាថា .......... ......... .......... .......... .. ៨៩៤
អដ្ឋកថា សម្ពុលកច្ចានត្ថេរគាថា .......... ......... .......... .......... .. ៨៩៤
ខិតកត្ថេរគាថា .......... ......... .......... .......... ... ៨៩៨
អដ្ឋកថា ខិតកត្ថេរគាថា .......... ......... .......... .......... ... ៨៩៨
សោណបោដិរិយបុត្តត្ថេរគាថា .......... ......... .......... .......... ... ៩០៣
អដ្ឋកថា សោណបោដិរិយបុត្តត្ថេរគាថា .......... ......... .......... .......... .... ៩០៣
និសភត្ថេរគាថា .......... ......... .......... .......... ... ៩០៧
អដ្ឋកថា និសភត្ថេរគាថា .......... ......... .......... .......... .... ៩០៧
ឧសភត្ថេរគាថា .......... ......... .......... .......... .... ៩១១
អដ្ឋកថា ឧសភត្ថេរគាថា .......... ......... .......... .......... .... ៩១១
កប្បដកុរត្ថេរគាថា .......... ......... .......... .......... .... ៩១៥
អដ្ឋកថា កប្បដកុរត្ថេរគាថា .......... ......... .......... .......... .... ៩១៦

## បញ្ចមវគ្គ

កុមារកស្សបត្ថេរគាថា .......... ......... .......... .......... ... ៩២១
អដ្ឋកថា កុមារកស្សបត្ថេរគាថា .......... ......... .......... .......... ... ៩២១

ធម្មបាលត្ថេរគាថា .......... ......... .......... .......... ....... ៩៣០
អដ្ឋកថា ធម្មបាលត្ថេរគាថា .......... ......... .......... .......... ....... ៩៣០
ព្រហ្មាលិត្ថេរគាថា .......... ......... .......... .......... ....... ៩៣៤
អដ្ឋកថា ព្រហ្មាលិត្ថេរគាថា .......... ......... .......... .......... ...... ៩៣៤
មោឃរាជត្ថេរគាថា .......... ......... .......... .......... ....... ៩៣៨
អដ្ឋកថា មោឃរាជត្ថេរគាថា .......... ......... .......... .......... ....... ៩៣៨
វិសាខបញ្ចាលីបុត្តត្ថេរគាថា .......... ......... .......... .......... ....... ៩៤៦
អដ្ឋកថា វិសាខបញ្ចាលីបុត្តត្ថេរគាថា .......... ......... .......... .......... ....... ៩៤៦
ចូឡកត្ថេរគាថា .......... ......... .......... .......... ...... ៩៥១
អដ្ឋកថា ចូឡកត្ថេរគាថា .......... ......... .......... .......... ...... ៩៥១
អនូបមត្ថេរគាថា .......... ......... .......... .......... ....... ៩៥៦
អដ្ឋកថា អនូបមត្ថេរគាថា .......... ......... .......... .......... ....... ៩៥៦
វជ្ជិតត្ថេរគាថា .......... ......... .......... .......... ...... ៩៦០
អដ្ឋកថា វជ្ជិតត្ថេរគាថា .......... ......... .......... .......... ...... ៩៦០
សន្ធិតត្ថេរគាថា .......... ......... .......... .......... ...... ៩៦៤
អដ្ឋកថា សន្ធិតត្ថេរគាថា .......... ......... .......... .......... ...... ៩៦៥